# ព្រះ
# ត្រៃបិដក

## ប្រែរួមនឹង
## ព្រះអដ្ឋកថា

## ភាគ៥៧

បាលីប្រែ ៦៩ - ៧០

ពុទ្ធសករាជ ២៥៥៣

ច្បាប់ពិនិត្យ លើកទី២

# ព្រះ

# សុត្តន្តបិដក

## និង

# សទ្ធម្មប្បកាសិនី អដ្ឋកថា

## សេចក្តីប្រែជាភាសាខ្មែរ

# ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ

## បឋមភាគ

# ៥៧

## បាលីប្រែ ៦៩-៧០



*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣*

# ក្បាលទី ៥៧

# សុត្តន្តបិដក

# ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ

# បឋមភាគ

*សូមនមស្ការព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ អង្គនោះ*

*[ ១៤៣ ] បញ្ញាក្នុងការចេញ និងការវិលត្រឡប់ចាកសភាវៈទាំង ២ ឈ្មោះថា មគ្គញ្ញាណ តើដូចម្តេច ។ ក្នុងខណៈនៃសោតាបត្តិមគ្គ សម្មាទិដ្ឋិ ដោយអត្ថថា ឃើញ រមែងចេញចាកមិច្ឆាទិដ្ឋិ រមែងចេញចាកកិលេសដែលប្រព្រឹត្តតាមនូវមិច្ឆាទិដ្ឋិនោះផង ចាកខន្ធទាំងឡាយផង រមែងចេញចាកនិមិត្តទាំងពួងខាងក្រៅផង ហេតុនោះ លោកពោលថា បញ្ញាក្នុងការចេញ និងការវិលត្រឡប់ចាកសភាវៈទាំង ២ ឈ្មោះថា មគ្គញ្ញាណ សម្មាសង្កប្ប ដោយអត្ថថា លើកចិត្តឡើង ( កាន់អារម្មណ៍ ) រមែងចេញចាកមិច្ឆាសង្កប្ប ចេញចាកកិលេសដែលប្រព្រឹត្តតាមនូវមិច្ឆាសង្កប្បនោះផង ចាកខន្ធទាំងឡាយផង ចេញចាកនិមិត្តទាំងពួងខាងក្រៅផង ហេតុនោះ លោកពោលថា បញ្ញាក្នុងការចេញ និងការវិលត្រឡប់ចាកសភាវៈទាំង ២ ឈ្មោះថា មគ្គញ្ញាណ សម្មាវាចា ដោយអត្ថថា រក្សាទុក រមែងចេញចាកមិច្ឆាវាចា ចេញចាកកិលេសដែលប្រព្រឹត្តតាមនូវមិច្ឆាវាចានោះផង ចាកខន្ធទាំងឡាយផង រមែងចេញចាកនិមិត្តទាំងពួងខាងក្រៅផង ហេតុនោះ លោកពោលថា បញ្ញាក្នុងការចេញ និងការវិលត្រឡប់ចាកសភាវៈទាំង ២ ឈ្មោះថា មគ្គញ្ញាណ សម្មាកម្មន្តៈ ដោយអត្ថថា តាំងឡើងរមែង*

ចេញចាកមិច្ឆាកម្មន្តៈ ចេញចាកកិលេសដែលប្រព្រឹត្តតាមនូវមិច្ឆាកម្មន្តៈនោះផង ចាកខន្ធទាំងឡាយផង រមែងចេញចាកនិមិត្តទាំងពួងខាងក្រៅផង ហេតុនោះ លោកពោលថា បញ្ញាក្នុងការចេញ និងការវិលត្រឡប់ ចាកសភាវៈទាំង ២ ឈ្មោះថា មគ្គញ្ញាណ សម្មាអាជីវៈ ដោយអត្ថថា ផូរផង់ រមែងចេញចាកមិច្ឆា-អាជីវៈ ចេញចាកកិលេសដែលប្រព្រឹត្តតាមនូវមិច្ឆាអាជីវៈនោះផង ចាកខន្ធទាំងឡាយផង រមែងចេញចាកនិមិត្តទាំងពួងខាងក្រៅផង ហេតុនោះ លោកពោលថា បញ្ញាក្នុងការចេញ និងការវិលត្រឡប់ចាកសភាវៈទាំង ២ ឈ្មោះថា មគ្គញ្ញាណ សម្មាវាយាមៈ ដោយអត្ថថា ផ្គងឡើង រមែងចេញចាកមិច្ឆាវាយាមៈ ចេញចាកកិលេសដែលប្រព្រឹត្តតាមនូវមិច្ឆាវាយាមៈនោះផង ចាកខន្ធទាំងឡាយផង រមែងចេញចាកនិមិត្តទាំងពួងខាងក្រៅផង ហេតុនោះ លោកពោលថា បញ្ញាក្នុងការចេញ និងការវិលត្រឡប់ ចាកសភាវៈទាំង ២ ឈ្មោះថា មគ្គញ្ញាណ សម្មាសតិ ដោយអត្ថថា ប្រុងប្រយ័ត្ន រមែងចេញចាកមិច្ឆាសតិ ចេញចាកកិលេសដែលប្រព្រឹត្តតាមនូវមិច្ឆាសតិនោះផង ចាកខន្ធទាំងឡាយផង រមែងចេញចាកនិមិត្តទាំងពួងខាងក្រៅផង ហេតុនោះ លោកពោលថា បញ្ញាក្នុងការចេញ និងការវិលត្រឡប់ចាកសភាវៈទាំង ២ ឈ្មោះថា មគ្គញ្ញាណ សម្មាសមាធិ ដោយអត្ថថា មិនរាយមាយ រមែងចេញចាកមិច្ឆាសមាធិ ចេញចាកកិលេសដែលប្រព្រឹត្តតាមនូវមិច្ឆាសមាធិនោះផង ចាកខន្ធទាំងឡាយផង រមែងចេញចាកនិមិត្តទាំងពួងខាងក្រៅផង ហេតុនោះ លោកពោលថា បញ្ញាក្នុងការចេញ និងការវិលត្រឡប់ចាកសភាវៈទាំង ២ ឈ្មោះថា មគ្គញ្ញាណ ។

[ ១៨៤ ] ក្នុងខណៈនៃសកទាគាមិមគ្គ សម្មាទិដ្ឋិ ដោយអត្ថថា ឃើញ ។បេ។ សម្មាសមាធិ ដោយអត្ថថា មិនរាយមាយ រមែងចេញចាកកាមរាគសញ្ញោជនៈ និងបដិឃសញ្ញោជនៈដ៏គ្រោតគ្រាត ចាកកាមរាគានុស័យ និងបដិឃានុស័យដ៏គ្រោតគ្រាត ចេញចាកកិលេសដែលប្រព្រឹត្តតាមសញ្ញោជនៈ និងអនុស័យនោះផង ចាកខន្ធទាំងឡាយផង ចេញចាកនិមិត្តទាំងពួងខាងក្រៅផង ហេតុនោះ លោកពោលថា បញ្ញាក្នុងការចេញ និងការវិលត្រឡប់ចាកសភាវៈទាំង ២ ឈ្មោះថា មគ្គញ្ញាណ ។

[ ១៨៥ ] ក្នុងខណៈនៃអនាគាមិមគ្គ សម្មាទិដ្ឋិ ដោយអត្ថថា ឃើញ ។បេ។ សម្មាសមាធិ ដោយអត្ថថា មិនរាយមាយ រមែងចេញចាកកាមរាគសញ្ញោជនៈ និងបដិឃសញ្ញោជនៈដ៏ល្អិត ចាកកាមរាគានុស័យ និងបដិឃានុស័យដ៏ល្អិត ចេញចាកកិលេសដែលប្រព្រឹត្តតាមសញ្ញោជនៈ និងអនុស័យនោះផង ចាកខន្ធទាំងឡាយផង ចេញចាកនិមិត្តទាំងពួងខាងក្រៅផង ហេតុនោះ លោកពោលថា បញ្ញាក្នុងការចេញ និងការវិលត្រឡប់ចាកសភាវៈទាំង ២ ឈ្មោះថា មគ្គញ្ញាណ ។

[ ១៨៦ ] ក្នុងខណៈនៃអរហត្តមគ្គ សម្មាទិដ្ឋិ ដោយអត្ថថា ឃើញ ។បេ។ សម្មាសមាធិ ដោយអត្ថថា មិនរាយមាយ រមែងចេញចាករូបរាគៈ អរូបរាគៈ មានះ ឧទ្ធច្ចៈ អវិជ្ជា មានានុស័យ ភវរាគានុស័យ និងអវិជ្ជានុស័យ ចេញចាកកិលេស ដែលប្រព្រឹត្តតាមនូវអនុសយក្កិលេសនោះផង ចាកខន្ធទាំងឡាយផង ចេញចាកនិមិត្តទាំងពួងខាងក្រៅផង ហេតុនោះ លោកពោលថា បញ្ញាក្នុង

ការចេញ និងការវិលត្រឡប់ចាកសភាវៈទាំង ២ ឈ្មោះថា មគ្គញ្ញាណ ។

[ ១៤៧ ] យោគី រមែងដុតបំផ្លាញនូវកិលេសដែលមិនទាន់កើតដោយអគ្គឈានដែលកើតហើយ ហេតុនោះ លោកហៅថា ឈាន យោគី រមែងមិនញាប់ញ័រក្នុងទិដ្ឋិផ្សេងៗ ព្រោះភាពជាបុគ្គលឈ្លាសវៃក្នុងឈាន និងវិមោក្ខ ។ បើយោគីតម្កល់ចិត្តហើយពិចារណា រមែងឃើញច្បាស់យ៉ាងណា គប្បីតម្កល់ចិត្តទុកយ៉ាងនោះ វិបស្សនា និងសមថៈ ជាធម៌មានចំណែកស្មើគ្នាជាគូជាប់គ្នា រមែងប្រព្រឹត្តទៅក្នុងកាលណោះ ការឃើញថា សង្ខារទាំងឡាយជាទុក្ខ និរោធជាសុខ បញ្ញាដែលចេញចាកសភាវៈទាំង ២ រមែងពាល់ត្រូវនូវព្រះនិព្វាន ឈ្មោះអមតៈ យោគីអ្នកឈ្លាសវៃក្នុងភាពនៃធម៌ផ្សេងគ្នា និងធម៌ដូចគ្នា រមែងដឹងនូវកិរិយាប្រព្រឹត្តក្នុងវិមោក្ខ រមែងមិនញាប់ញ័រក្នុងទិដ្ឋិផ្សេងៗ ព្រោះភាពជាបុគ្គលឈ្លាសវៃក្នុងញាណទាំងពីរ ។

ដែលឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងការចេញ និងការវិលត្រឡប់ចាកសភាវៈទាំង ២ ឈ្មោះថា មគ្គញ្ញាណ ។

# អដ្ឋកថា

## មគ្គញ្ញាណនិទ្ទេស

[ ១៤៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងមគ្គញ្ញាណនិទ្ទេសដូចតទៅនេះ បទថា **មិច្ឆាទិដ្ឋិយា វុដ្ឋាតិ** បានដល់ ចេញចាកមិច្ឆាទិដ្ឋិ ៦២ ដោយសមុច្ឆេទប្បហាន ដោយការលះបង់ទិដ្ឋានុស័យ ។ បទថា **តទនុវត្តកកិលេសេហិ** បានដល់ ចាកកិលេសច្រើនយ៉ាង ដែលប្រព្រឹត្តទៅតាមមិច្ឆាទិដ្ឋិដែលកើតឡើងដោយអំណាចការប្រកបជាមួយមិច្ឆាទិដ្ឋិ និងដោយឧបនិស្ស័យ ក្នុងមិច្ឆាទិដ្ឋិ ។ ដោយពាក្យនោះ ឈ្មោះថា លោកពោលដល់ការលះកិលេសដែលតាំងនៅក្នុងទីជាមួយគ្នានឹងមិច្ឆាទិដ្ឋិនោះ ។ ពិតហើយ ការតាំងនៅក្នុងទីជាមួយគ្នា មាន ២ យ៉ាង គឺតាំងនៅក្នុងទីជាមួយគ្នាដោយការកើតរួមគ្នា និងតាំងនៅក្នុងទីជាមួយគ្នាដោយការលះ ឈ្មោះថា តាំងនៅក្នុងទីជាមួយគ្នានឹងមិច្ឆាទិដ្ឋិនោះ ព្រោះអត្ថថា តាំងនៅក្នុងចិត្តមួយដួងព្រមជាមួយទិដ្ឋិនោះ ឬបុគ្គលម្នាក់ រហូតដល់ការលះបាន ។ ព្រោះថា កាលលះទិដ្ឋិបាន កិលេសទាំងនេះ គឺលោភៈ មោហៈ ឧទ្ធច្ចៈ អហិរិកៈ អនោត្តប្បៈដែលកើតរួមគ្នាជាមួយទិដ្ឋិនោះ ក្នុងចិត្តដែលជាអសង្ខារិកៈ ២ ដួង ដែលសម្បយុត្តដោយទិដ្ឋិ កិលេសទាំងនេះ គឺលោភៈ មោហៈ ថីនៈ ឧទ្ធច្ចៈ អហិរិកៈ អនោត្តប្បៈដែលកើតរួមគ្នាជាមួយទិដ្ឋិនោះ ក្នុងចិត្តដែលជាសសង្ខារិកៈ ២ ដួង រមែងលះបានដោយការតាំងនៅក្នុងទីជាមួយគ្នា ដោយកើតរួមគ្នា ។

កាលទិដ្ឋិ និងកិលេសត្រូវលះ កិលេសទាំងនេះ គឺលោភៈ ទោសៈ មោហៈ

មានះ វិចិកិច្ឆា ថីនះ ឧទ្ធច្ចះ អហិរិកះ អនោត្តប្បះដែលជាហេតុទៅកាន់អបាយ ដែលតាំងនៅក្នុងបុគ្គលម្នាក់ រមែងត្រូវលះព្រមជាមួយទិដ្ឋិ និងកិលេសនោះ ដោយអំណាចការតាំងនៅក្នុងទីជាមួយគ្នាដោយការលះ ។

បទថា **ខន្ធេហិ** បានដល់ ចាកខន្ធទាំងឡាយដែលប្រព្រឹត្តទៅតាមទិដ្ឋិនោះ គឺចាកអរូបក្ខន្ធ ៤ ដែលតាំងនៅក្នុងទីជាមួយគ្នា ដោយការកើតរួមគ្នា និងតាំងនៅក្នុងទីជាមួយគ្នាដោយការលះដែលប្រព្រឹត្តទៅតាមទិដ្ឋិនោះ ឬចាករូបដែលមានទិដ្ឋិនោះជាសមុដ្ឋាន ម្យ៉ាងទៀត ចាកវិបាកក្ខន្ធដែលគប្បីកើតឡើងក្នុងអនាគត ព្រោះកិលេស មានមិច្ឆាទិដ្ឋិជាដើម ជាបច្ច័យព្រមជាមួយខន្ធ ៥ ។ បទថា **ពហិទ្ធា ច សព្វនិមិត្តេហិ** បានដល់ ចាកសង្ខារនិមិត្តទាំងពួងដែលជាខាងក្រៅពីកងកិលេស តាមដែលពោលហើយ ។ បទថា **មិច្ឆាសង្កប្បា វុដ្ឋាតិ** បានដល់ រមែងចេញចាកមិច្ឆាសង្កប្បក្នុងចិត្ត ៥ ដួង គឺក្នុងចិត្ត ៤ ដួងដែលសម្បយុត្តដោយទិដ្ឋិ និងក្នុងចិត្ត ១ ដួងដែលសហគតះដោយវិចិកិច្ឆា ដែលគប្បីលះបានដោយសោតាបត្តិមគ្គ និងក្នុងអកុសលចិត្តដ៏សេស ដែលជាហេតុទៅកាន់អបាយ ។

បទថា **មិច្ឆាវាចាយ វុដ្ឋាតិ** បានដល់ រមែងចេញពីមុសាវាទ និងបិសុណាវាចា ផរុសវាចា សម្ផប្បលាបះ ដែលជាហេតុទៅកាន់អបាយ ។ បទថា **មិច្ឆាកម្មន្តា វុដ្ឋាតិ** បានដល់ រមែងចេញចាកបាណាតិបាត អទិន្នាទាន និងមិច្ឆាចារ ។ បទថា **មិច្ឆាអាជីវា វុដ្ឋាតិ** បានដល់ រមែងចេញចាកការកុហក ការនិយាយរាក់ទាក់ ការធ្វើនិមិត្ត ប្រើសម្តីជាខ្នាស យកលាភទាក់លាភ

*ម្យ៉ាងទៀត រមែងចេញចាកកាយកម្ម វចីកម្មទាំង ៧ យ៉ាង មានអាជីវៈជាហេតុ ។ គប្បីជ្រាបការចេញចាកមិច្ឆាវាយាមៈ មិច្ឆាសតិ មិច្ឆាសមាធិដោយន័យដូចពោលហើយ ក្នុងការចេញចាកមិច្ឆាសង្កប្ប ។ ម្យ៉ាងទៀត បទថា* **មិច្ឆាសតិ** *បានដល់ សតិដែលកើតឡើងដោយអាការផ្ទុយគ្នាជាមួយសតិ គឺត្រឹមតែអកុសលចិត្តុប្បាទប៉ុណ្ណោះ ។*

*[ ១៨៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងពួក ៣ នៃមគ្គជាន់លើ ដូចតទៅនេះថា អង្គរបស់មគ្គ ៨ មាន* **ឧស្សន្នដ្ឋេន សម្មាទិដ្ឋិ** *ជាដើម រមែងបានដូចដែលបានក្នុងបឋមមគ្គដែលកើតក្នុងបឋមជ្ឈាន ។ ក្នុងបឋមមគ្គ សម្មាទិដ្ឋិ រមែងលះមិច្ឆាទិដ្ឋិ ព្រោះហេតុនោះ ទើបឈ្មោះថា សម្មាទិដ្ឋិ ។ សូម្បីសម្មាសង្កប្បជាដើម ក៏គប្បីជ្រាបដោយអត្ថ គឺការលះមិច្ឆាសង្កប្បជាដើម ។ កាលបើយ៉ាងនោះ ព្រោះលះទិដ្ឋិ ៦២ បានក្នុងបឋមមគ្គនោះឯង ទើបមិនមានទិដ្ឋិដែលគួរលះដោយមគ្គ ៣ ខាងលើ ។*

*ក្នុងអង្គនៃមគ្គទាំងនោះ ឈ្មោះថា សម្មាទិដ្ឋិ តើដូចម្តេច ដូចថ្នាំពិស មាន ឬមិនមាន ថ្នាំកែពិសលោកក៏ហៅថា ថ្នាំកែពិសនោះឯង យ៉ាងណា មិច្ឆាទិដ្ឋិមាន ឬមិនមាន សម្មាទិដ្ឋិនេះក៏ឈ្មោះថាសម្មាទិដ្ឋិ ក៏យ៉ាងនោះដែរ ។ បើយ៉ាងនោះ សម្មាទិដ្ឋិនេះ ក៏ត្រឹមតែជាឈ្មោះប៉ុណ្ណោះ ឯសម្មាទិដ្ឋិមិនមានកិច្ចក្នុងមគ្គខាងលើ ៣ អង្គមគ្គក៏មិនបរិបូណ៌ ព្រោះហេតុនោះ គប្បីធ្វើសម្មាទិដ្ឋិ មួយអន្ទើដោយកិច្ច ទើបអង្គមគ្គបរិបូណ៌ ។ គប្បីសម្តែងសម្មាទិដ្ឋិក្នុងទីនេះ មួយអន្ទើដោយកិច្ច ដោយកំណត់តាមដែលរកបាន ។ មានៈឯណានីមួយ ដែលសម្លាប់*

ដោយមគ្គ ៣ ខាងលើ នៅមានមានះនោះ តាំងនៅក្នុងឋានៈនៃទិដ្ឋិ ទិដ្ឋិនោះ រមែងលះមានះនោះបាន ព្រោះហេតុនោះ ទើបឈ្មោះថា សម្មាទិដ្ឋិ ។ ពិតហើយ សម្មាទិដ្ឋិ រមែងលះមិច្ឆាទិដ្ឋិបានក្នុងសោតាបត្តិមគ្គ ។ តែមានះរបស់ព្រះសោតាបន្ន ដែលត្រូវសម្លាប់ដោយសកទាគាមិមគ្គមាន ទិដ្ឋិនោះ រមែងលះមានះនោះបាន ព្រោះហេតុនោះ ទើបឈ្មោះថា សម្មាទិដ្ឋិ ។ ការត្រិះរិះរបស់ព្រះសោតាបន្ននោះឯង ដែលកើតព្រមជាមួយអកុសលចិត្ត ៧[១] មានការកម្រើកផ្លូវវាចា ការកម្រើកផ្លូវកាយ ការបរិភោគបច្ច័យ ការព្យាយាមដែលកើតរួមគ្នា ភាពជាអ្នកមិនមានស្មារតី ភាពដែលចិត្តមានអារម្មណ៍តែមួយ ដែលកើតរួមគ្នា មានជាមួយចិត្តទាំងនោះឯង ទាំងនេះឈ្មោះថា មិច្ឆាសង្កប្បជាដើម ។ គប្បីជ្រាបថា សម្មាសង្កប្បជាដើម ក្នុងសកទាគាមិមគ្គ ឈ្មោះថា សម្មាសង្កប្ប ព្រោះលះមិច្ឆាសង្កប្បទាំងនោះបាន ។ អង្គ ៨ ព្រមដោយកិច្ច រមែងមានក្នុងសកទាគាមិមគ្គដោយអាការយ៉ាងនេះ ។ មានះរបស់ព្រះសកទាគាមីដែលត្រូវសម្លាប់ដោយអនាគាមិមគ្គមាន មានះនោះ រមែងតាំងនៅក្នុងឋានៈនៃទិដ្ឋិ ។ ការត្រិះរិះជាដើមរបស់ព្រះសកទាគាមីនោះ ដែលកើតរួមគ្នាជាមួយចិត្ត ៧ មាន ។ គប្បីជ្រាបភាពដែលអង្គ ៨ ក្នុងអនាគាមិមគ្គនៅមានកិច្ចដោយការលះចិត្តទាំងនោះ ។ មានះរបស់ព្រះអនាគាមី ដែលត្រូវសម្លាប់ដោយអរហត្តមគ្គមាន មានះនោះ តាំងនៅក្នុងឋានៈនៃទិដ្ឋិ ។ ការត្រិះរិះជាដើម របស់ព្រះអនាគាមីនោះ ដែលកើតរួមជាមួយអកុសលចិត្ត ៥ មាន ។ គប្បីជ្រាប

---

១- លោភមូលចិត្ត ដែលជាទិដ្ឋិវិប្បយុត្ត ៤ ទោសមូលចិត្ត ២ ឧទ្ធច្ចសម្បយុត្តចិត្ត ១ ។

កាពដែលអដ្ឋ ៨ ក្នុងអរហត្តមគ្គ នៅមានកិច្ចដោយការលះអកុសលចិត្ត ទាំងនោះ ។

បទថា **ឱឡារិកា** បានដល់ ជាចំណែកគ្រោតគ្រាត ព្រោះជាបច្ច័យដល់ការឈានកន្លងក្នុងកាយទ្វារ និងវចីទ្វារ ។ បទថា **កាមរាគសញ្ញោជនា** បានដល់ ចាកសំយោជនៈ ពោលគឺការត្រេកអរក្នុងមេថុន ។ ព្រោះកាមរាគៈនោះ រមែងប្រកបសត្វទុកក្នុងកាមភព ព្រោះហេតុនោះ ទើបហៅថា សញ្ញោជនៈ ។ បទថា **បដិឃសញ្ញោជនា** បានដល់ សំយោជនៈ គឺព្យាបាទៈ ព្រោះព្យាបាទនោះ រមែងខ្វាំងខ្ទប់ក្នុងអារម្មណ៍ ព្រោះហេតុនោះ ទើបហៅថា **បដិឃ** ។ សំយោជនៈទាំងនោះ រមែងដេកត្រាំនៅក្នុងសន្តាន ដោយអត្ថថា មានកម្លាំង ព្រោះហេតុនោះ ទើបហៅថា អនុស័យ ។

[ ១៨៥ ] បទថា **អណុសហគតា** បានដល់ ចំណែកល្អិតសុខុម ។ **សហគត** សព្ទ ក្នុងបទនេះ ប្រើក្នុងសេចក្តីយ៉ាងនោះ ។ ពិតហើយ កាមរាគៈ និងព្យាបាទរបស់ព្រះសកទាគាមី ជារបស់ស្រាលស្តើងដោយហេតុ ២ ប្រការ គឺព្រោះកើតឡើង ដោយមិនតាំងចិត្ត និងព្រោះមានកិលេសហោមរោមតិច ។ កិលេសទាំងឡាយរបស់ព្រះសកទាគាមីនោះ រមែងមិនកើតឡើងរឿយៗ ដូចកិលេសរបស់ពាលបុថុជ្ជន រមែងកើតម្តងម្កាល ។ កាលកើតរមែងមិនកើតញាំញីជ្រួតជ្រាបបិទបាំងធ្វើឲ្យងងឹតដូចរបស់បុគ្គលពាល ។ តែកើតឡើងតិចតួចមានអាការស្រាលស្តើង ព្រោះលះបានដោយមគ្គ ២ មិនអាចឲ្យដល់នូវការកន្លងល្មើសទៅបាន ។ កិលេសដែលស្រាលស្តើងយ៉ាងនេះរមែងលះបាន

ដោយអនាគាមិមគ្គ ។

[ ១៤៦ ] បទថា **រូបរាគា** បានដល់ ចាកការពេញចិត្តត្រេកអរក្នុងរូប-ភព ។ បទថា **អរូបរាគា** បានដល់ សេចក្តីពេញចិត្តត្រេកអរក្នុងអរូបភព ។ បទថា **មានា** បានដល់ កិលេសមានលក្ខណៈលើកតម្កើងខ្លួន ។ បទថា **ឧទ្ធច្ចា** បានដល់ កិលេសមានលក្ខណៈមិនស្ងប់ ។ បទថា **អវិជ្ជាយ** បានដល់ កិលេសមានលក្ខណៈធ្វើឲ្យងងឹត ។ បទថា **ភវរាគានុសយា** បានដល់ កិលេសដែលដេកត្រាំ គឺភវរាគៈដែលប្រព្រឹត្តទៅដោយអំណាចរូបរាគៈ និងអរូបរាគៈ ។

[ ១៤៧ ] ឥឡូវនេះ ព្រះសារីបុត្ត កាលនឹងពណ៌នាដល់មគ្គញ្ញាណ ទើបពោលបទថា **អជាតំ ឈាបេតិ** ដូច្នេះជាដើម ។

ក្នុងបទនោះ ប្រែបទថា **អជាតំ ឈាបេតិ ជាតេន ឈានំ តេន បវុច្ចតិ** សេចក្តីថា បុគ្គលដែលប្រកបព្រមដោយអរិយមគ្គនោះ រមែងដុត គឺដុតកម្ទេច កាត់នូវកិលេសនោះៗ ដែលមិនទាន់កើតដោយលោកុត្តរជ្ឈាន នោះៗ ដែលប្រាកដក្នុងសន្តានរបស់ខ្លួន ដោយហេតុនោះ ទើបលោកពោល លោកុត្តរជ្ឈាននោះ ថាជាឈាន ។

បទថា **ឈានវិមោក្ខេ កុសលតា** សេចក្តីថា បុគ្គលដែលប្រកបព្រម ដោយអរិយមគ្គនោះ រមែងមិនញាប់ញ័រក្នុងទិដ្ឋិផ្សេងៗ ដែលលះបានហើយ ដោយបឋមមគ្គនោះឯង ព្រោះភាវៈជាអ្នកឈ្លាសក្នុងឈាន មានវិតក្កជាដើម ដែលសម្បយុត្តដោយអរិយមគ្គនោះ និងក្នុងអរិយមគ្គ ពោលគឺវិមោក្ខ ដោយអំណាចការមិនវង្វេង ។ ឈ្មោះថា ឈានមាន ២ យ៉ាង គឺអារម្មណូបនិជ្ឈាន

១ លក្ខណូបនិជ្ឈាន ១ ។ ឈានមានលោកិយបឋមជ្ឈានជាដើម ឈ្មោះថា ឈាន ព្រោះអត្ថថា ចូលទៅសម្ញឹងអារម្មណ៍ មានកសិណជាដើម វិបស្សនា ឈ្មោះថា ឈាន ព្រោះអត្ថថា ចូលទៅសម្ញឹងសាមញ្ញលក្ខណៈនៃសង្ខារទាំងឡាយតាមសេចក្តីពិត លោកុត្តរ ឈ្មោះថា ឈាន ព្រោះអត្ថថា ចូលទៅសម្ញឹងលក្ខណៈដែលពិតក្នុងនិព្វាន ។ តែក្នុងទីនេះ លោកមិនពាល់ត្រូវឈានដែលមានអត្ថថា ចូលទៅសម្ញឹងលក្ខណៈដែលទូទៅដោយគោត្រភូ ហើយពោលដល់ឈាន ព្រោះអត្ថថា ដុតកិលេសដោយមិនទូទៅ ។ម្យ៉ាងទៀត ក្នុងទីនេះ អត្ថនៃវិមោក្ខ មានអត្ថថា បង្អោនទៅដោយល្អក្នុងអារម្មណ៍ គឺនិព្វាន និងមានអត្ថថា ផុតដោយល្អអំពីកិលេសទាំងឡាយ ។

បទថា **សមាហិតោ យថា ចេ វិបស្សតិ** សេចក្តីថា ព្រះយោគាវចរធ្វើការតាំងចិត្តមាំមុន ដោយសមាធិឯណានីមួយនៃអប្បនាសមាធិ ឧបចារ-សមាធិ និងខណិកសមាធិ ហើយឃើញច្បាស់ក្នុងខាងក្រោយឯណា ។ ចេ សព្ទ ជាសមុច្ចយត្ថៈ ( មានអត្ថថា រួបរួម ) រមែងរួបរួមវិបស្សនា ។

បទថា **វិបស្សមានោ តថា ចេ សមាធយេ** សេចក្តីថា ឈ្មោះថា វិបស្សនានេះ មានសភាពសៅហ្មង មិនមានភាពគួរត្រេកអរ ចំណែកឈ្មោះថា សមថៈ មានសភាពល្អិត មានសភាពគួរត្រេកអរ ព្រោះហេតុនោះ ព្រះយោគាវចរ កាលកំពុងចម្រើនវិបស្សនា គប្បីតាំងមាំដើម្បីធ្វើចិត្តដែលសៅហ្មងដោយវិបស្សនានោះ ឲ្យមានសេចក្តីប្រាថ្នា ( នឹងធ្វើការនៃ ) យ៉ាងនោះ អធិប្បាយថា កាលកំពុងចម្រើនវិបស្សនាចូលសមាធិទៀត ហើយគប្បីធ្វើចិត្ត

*ឲ្យតាំងមាំដូចធ្វើវិបស្សនា ។ ៥ សព្ទ ក្នុងទីនេះ រមែងរួបរួមការតាំងមាំ ។ ក្នុងទីទាំងពីរ ៥ អក្ខរៈ លោកធ្វើដោយការប្រព្រឹត្តទៅតាមគាថាព័ន្ធ តែសេចក្តី ក៏គឺ ច អក្ខរៈនោះឯង ។*

*បទថា* **វិបស្សនា ច សមថោ តទា អហុ** *សេចក្តីថា ព្រោះកាលសមថៈ និងវិបស្សនាជាធម៌គូគ្នា មានសេចក្តីប្រាកដនៃអរិយមគ្គ រមែងមានហេតុនោះ ការប្រកបធម៌ទាំង ២ នោះក្នុងកាលណា រមែងមាន ព្រោះអាចញុំាងអរិយមគ្គឲ្យកើតឡើងក្នុងកាលនោះ វិបស្សនា និងសមថៈមានហើយ គឺសមថៈ និងវិបស្សនា ឈ្មោះថា កើតហើយ ។ ម្យ៉ាងទៀត សមថៈ និងវិបស្សនាទាំងនោះ ជាធម៌មានចំណែកស្មើគ្នា ជាគូជាប់គ្នា រមែងប្រព្រឹត្តទៅក្នុងវេលាឆ្ពោះមុខទៅកាន់អរិយមគ្គ និងក្នុងខណៈនៃមគ្គ ឈ្មោះថា* **សមាន-ភាគា** *ព្រោះអត្ថថា សមថៈ និងវិបស្សនា មានចំណែកស្មើគ្នា ឈ្មោះថា* **យុគនទ្ធា** *ព្រោះអត្ថថា ដូចទឹមជាគូគ្នា អធិប្បាយថា មានធុរៈស្មើគ្នា មានកម្លាំងស្មើគ្នា ដោយអត្ថថា មិនឈានកន្លងគ្នានឹងគ្នា ។ ចំណែកសេចក្តីពិស្តារនៃបទនោះ នឹងមានច្បាស់ក្នុងយុគនទ្ធកថា ។*

*ប្រើនបទថា* **ទុក្ខា សង្ខារា សុខោ និរោធោតិ ទស្សនំ ទុភតោ វុដ្ឋិតា បញ្ញា ផស្សេតិ អមតំ បទំ** *សេចក្តីថា សង្ខារទាំងឡាយជាទុក្ខ និរោធ គឺនិព្វានជាសុខ ព្រោះហេតុនោះ ការឃើញនិព្វានដោយប្រការនោះ របស់អ្នកបដិបត្តិ គឺអរិយមគ្គញ្ញាណ ឈ្មោះថា បញ្ញាចេញចាកធម៌ទាំង ២ ។ បញ្ញានោះ រមែងពាល់ត្រូវ គឺរមែងបានអមតបទ គឺនិព្វាន ដោយពាល់ត្រូវអារម្មណ៍ ។*

និព្វាន ឈ្មោះថា អមតៈ ព្រោះអត្ថថា ដូចគ្នានឹងអមតៈ ដោយអត្ថថា មិនក្តៅក្រហាយ ។ ឈ្មោះថា អមតៈ ព្រោះអត្ថថា និព្វាននោះមិនស្លាប់ គឺមិនមានការស្លាប់ មិនមានការវិនាស លោកពោលថា បទ ព្រោះអត្ថថា ដល់ គឺប្រព្រឹត្តទៅដោយឧស្សាហៈច្រើន ដោយបដិបទាច្រើន តាំងអំពីចំណែកខាងដើម ។

បទថា **វិមោក្ខចរិយំ ជានាតិ** បានដល់ ដឹងការប្រព្រឹត្តទៅនៃវិមោក្ខ ដោយការមិនវង្វេង រមែងដឹងដោយអំណាចការពិចារណា ។ គប្បីជ្រាបវិមោក្ខចរិយាដែលមកហើយ ក្នុងវិមោក្ខកថាខាងមុខថា ទុកតោវុដ្ឋានវិមោក្ខ ១ ទុកតោវុដ្ឋានវិមោក្ខ ៤ ទុកតោវុដ្ឋានានុលោមវិមោក្ខ ៤ ទុកតោវុដ្ឋានប្បដិ-ប្បស្សទ្ធិវិមោក្ខ ៤ ដូច្នេះ ។ សេចក្តីពិស្តារនៃវិមោក្ខទាំងនោះ មកហើយក្នុងវិមោក្ខកថានោះឯង ។

បទថា **នានត្តេកត្តកោវិទោ** បានដល់ ជាអ្នកឈ្លាសក្នុងការផ្សេងគ្នា និងក្នុងការដូចគ្នានៃវិមោក្ខទាំងនោះ ។ គប្បីជ្រាបការដូចគ្នានៃវិមោក្ខទាំងនោះដោយអំណាចនៃទុកតោវុដ្ឋានវិមោក្ខ ការផ្សេងគ្នាដោយអំណាចអរិយមគ្គ ៤ ឬការផ្សេងគ្នាដោយការផ្សេងគ្នា នៃអនុបស្សនា នៃអរិយមគ្គនីមួយៗ ការដូចគ្នាដោយភាពជាអរិយមគ្គ ។

បទថា **ទ្វិន្នំ ញាណានំ កុសលតា** បានដល់ ព្រោះភាពជាអ្នកឈ្លាសក្នុងញាណទាំង ២ នេះ គឺទស្សនៈ និងភាវនា ។ បទថា **ទស្សនំ** បានដល់ សោតាបត្តិមគ្គ ។ សោតាបត្តិមគ្គនោះ លោកហៅថា ទស្សនៈ ព្រោះឃើញ

និព្វានមុន ។ ចំណែកគោត្រភូញាណ រមែងឃើញនិព្វានមុនក៏ពិត តែលោកមិនហៅថា ទស្សនៈ ព្រោះឃើញនិព្វានហើយ មិនមានការលះកិលេសដែលគួរធ្វើ ដូចបុរសដែលមកកាន់សម្នាក់របស់ព្រះរាជា ដោយកិច្ចឯណានីមួយ សូម្បីឃើញព្រះរាជាប្រថាប់នៅលើ-កដំរី យាងមកតាមផ្លូវអំពីចម្ងាយ ត្រូវគេសួរថា លោកឃើញ ( គាល់ ) ព្រះរាជាហើយឬ សូម្បីឃើញហើយក៏ពោលថា ខ្ញុំនៅមិនទាន់បានឃើញ ( គាល់ ) ព្រោះកិច្ចដែលគប្បីធ្វើខ្លួនមិនទាន់បានធ្វើដូច្នោះ ។ ពិតហើយ គោត្រភូញាណនោះ តាំងនៅត្រង់អាវជ្ជនៈ ( គឺការនឹកដល់ ) មគ្គ ។

បទថា **ភាវនា** បានដល់ មគ្គ ៣ ដ៏សេស ។ មគ្គ ៣ ដ៏សេសនោះរមែងកើតឡើងដោយអំណាចភាវនា ក្នុងធម៌ដែលបឋមមគ្គឃើញហើយនោះឯង មិនឃើញអ្វីៗ ដែលបឋមមគ្គមិនធ្លាប់ឃើញ ព្រោះហេតុនោះ ទើបហៅថាភាវនា ។ តែខាងដើម លោកមិនពោលថា **ទ្វិន្នំ ញាណានំ** ( នៃញាណ ២ យ៉ាង ) ព្រោះមគ្គភាវនា នៅមិនទាន់សម្រេចហើយពោលថា **ឈានវិមោក្ខេ កុសលតា** ភាវៈជាអ្នកឈ្លាសក្នុងឈាន និងវិមោក្ខ សំដៅដល់អ្នកបានសោតាបត្តិមគ្គ សកទាគាមិមគ្គ និងអនាគាមិមគ្គ តែគប្បីជ្រាបថា លោកពោលថា **ទ្វិន្នំ ញាណានំ កុសលតា** ភាវៈជាអ្នកឈ្លាសក្នុងញាណ ២ យ៉ាង ព្រោះមគ្គភាវនារបស់អ្នកបានអរហត្តមគ្គ សម្រេចហើយ ។

**អដ្ឋកថាមគ្គញ្ញាណនិទ្ទេស ចប់**

# សុត្តន្តបិដក

[ ១៤៨ ] បញ្ញាសម្រាប់រម្ងាប់នូវព្យាយាម ឈ្មោះថា ផលញ្ញាណ តើដូចម្តេច ។ ក្នុងខណៈនៃសោតាបត្តិមគ្គ សម្មាទិដ្ឋិ ដោយអត្ថថាឃើញរមែងចេញចាកមិច្ឆាទិដ្ឋិ ចេញចាកកិលេសដែលប្រព្រឹត្តទៅតាមនូវមិច្ឆាទិដ្ឋិនោះផង ចាកខន្ធទាំងឡាយផង ចេញចាកនិមិត្តទាំងពួងខាងក្រៅផង សម្មាទិដ្ឋិរមែងកើតឡើង ព្រោះការរម្ងាប់នូវព្យាយាមក្នុងការចេញនោះ នុ៎ះជាផលរបស់មគ្គ សម្មាសង្កប្ប ដោយអត្ថថាលើកចិត្តឡើង ( កាន់អារម្មណ៍ ) រមែងចេញចាកមិច្ឆាសង្កប្ប ចេញចាកកិលេស ដែលប្រព្រឹត្តទៅតាមនូវមិច្ឆាសង្កប្បនោះផង ចាកខន្ធទាំងឡាយផង ចេញចាកនិមិត្តទាំងពួងខាងក្រៅផង សម្មាសង្កប្បរមែងកើតឡើងព្រោះការរម្ងាប់ព្យាយាមក្នុងការចេញនោះ នុ៎ះជាផលរបស់មគ្គ សម្មាវាចា ដោយអត្ថថារក្សាទុករមែងចេញចាកមិច្ឆាវាចា ចេញចាកកិលេសដែលប្រព្រឹត្តទៅតាមនូវមិច្ឆាវាចានោះផង ចាកខន្ធទាំងឡាយផង ចេញចាកនិមិត្តទាំងពួងខាងក្រៅផង សម្មាវាចារមែងកើតឡើង ព្រោះការរម្ងាប់នូវព្យាយាមក្នុងការចេញនោះ នុ៎ះជាផលរបស់មគ្គ សម្មាកម្មន្តៈ ដោយអត្ថថាតាំងឡើង រមែងចេញចាកមិច្ឆាកម្មន្តៈ ចេញចាកកិលេសដែលប្រព្រឹត្តទៅតាមនូវមិច្ឆាកម្មន្តៈនោះផង ចាកខន្ធទាំងឡាយផង ចេញចាកនិមិត្តទាំងពួងខាងក្រៅផង សម្មាកម្មន្តៈរមែងកើតឡើងព្រោះការរម្ងាប់នូវព្យាយាមក្នុងការចេញនោះ នុ៎ះជាផលរបស់មគ្គ សម្មាអាជីវៈ ដោយអត្ថថាផូរផង់ រមែងចេញចាកមិច្ឆាអាជីវៈ ចេញចាកកិលេសដែលប្រព្រឹត្តទៅតាមនូវមិច្ឆាអាជីវៈនោះផង ចាកខន្ធទាំងឡាយផង ចេញចាកនិមិត្តទាំងពួងខាងក្រៅផង សម្មាអាជីវៈ រមែង

កើតឡើងព្រោះការរម្ងាប់នូវព្យាយាម ក្នុងការចេញនោះ ទុំះជាផលរបស់មគ្គ សម្មាវាយាមៈ ដោយអត្ថថាផ្គងឡើងរមែងចេញចាកមិច្ឆាវាយាមៈ ចេញចាកកិលេសដែលប្រព្រឹត្តទៅតាមនូវមិច្ឆាវាយាមៈនោះផង ចាកខន្ធទាំងឡាយផង ចេញចាកនិមិត្តទាំងពួងខាងក្រៅផង សម្មាវាយាមៈ រមែងកើតឡើងព្រោះការរម្ងាប់នូវព្យាយាមក្នុងការចេញនោះ ទុំះជាផលរបស់មគ្គ សម្មាសតិ ដោយអត្ថថាប្រុងប្រយ័ត្ន រមែងចេញចាកមិច្ឆាសតិ ចេញចាកកិលេសដែលប្រព្រឹត្តទៅតាមនូវមិច្ឆាសតិនោះផង ចាកខន្ធទាំងឡាយផង ចេញចាកនិមិត្តទាំងពួងខាងក្រៅផង សម្មាសតិរមែងកើតឡើង ព្រោះការរម្ងាប់នូវព្យាយាមក្នុងការចេញនោះ ទុំះជាផលរបស់មគ្គ សម្មាសមាធិ ដោយអត្ថថាមិនរាយមាយរមែងចេញចាកមិច្ឆាសមាធិ ចេញចាកកិលេសដែលប្រព្រឹត្តទៅតាមនូវមិច្ឆាសមាធិនោះផង ចាកខន្ធទាំងឡាយផង ចេញចាកនិមិត្តទាំងពួងខាងក្រៅផង សម្មាសមាធិ រមែងកើតឡើងព្រោះការរម្ងាប់នូវព្យាយាមក្នុងការចេញនោះ ទុំះជាផលរបស់មគ្គ ។

[ ១៤៩ ] ក្នុងខណៈនៃសកទាគាមិមគ្គ សម្មាទិដ្ឋិដោយអត្ថថាឃើញ ។បេ។ សម្មាសមាធិ ដោយអត្ថថាមិនរាយមាយរមែងចេញចាកកាមរាគសញ្ញោជនៈ និងបដិឃសញ្ញោជនៈដ៏គ្រោតគ្រាត ចាកកាមរាគានុស័យនិងបដិឃានុស័យដ៏គ្រោតគ្រាត ចេញចាកកិលេសដែលប្រព្រឹត្តទៅតាមសញ្ញោជនៈនិងអនុស័យនោះផង ចាកខន្ធទាំងឡាយផង ចេញចាកនិមិត្តទាំងពួងខាងក្រៅផង សម្មាសមាធិរមែងកើតឡើង ព្រោះការរម្ងាប់នូវព្យាយាមក្នុងការចេញនោះ ទុំះជា

ផលរបស់មគ្គ ។

[ ១៥០ ] ក្នុងខណៈនៃអនាគាមិមគ្គ សម្មាទិដ្ឋិ ដោយអត្ថថា ឃើញ ។បេ។ សម្មាសមាធិ ដោយអត្ថថា មិនរាយមាយ រមែងចេញចាកកាមរាគសញ្ញោជនៈ និងបដិឃសញ្ញោជនៈដ៏ល្អិត ចាកកាមរាគានុស័យ និងបដិឃានុស័យដ៏ល្អិត ចេញចាកកិលេស ដែលប្រព្រឹត្តទៅតាមនូវសញ្ញោជនៈ និងអនុស័យនោះផង ចាកខន្ធទាំងឡាយផង ចេញចាកនិមិត្តទាំងពួងខាងក្រៅផង សម្មាសមាធិ រមែងកើតឡើងព្រោះការរម្ងាប់នូវព្យាយាមក្នុងការចេញនោះ ទុំះជាផលរបស់មគ្គ ។

[ ១៥១ ] ក្នុងខណៈនៃអរហត្តមគ្គ សម្មាទិដ្ឋិ ដោយអត្ថថា ឃើញ ។បេ។ សម្មាសមាធិ ដោយអត្ថថា មិនរាយមាយ រមែងចេញចាករូបរាគៈ អរូបរាគៈ មានះ ឧទ្ធច្ចៈ ថីនមិទ្ធៈ អវិជ្ជា ភវរាគានុស័យ មានានុស័យ និងអវិជ្ជានុស័យ ចេញចាកកិលេស ដែលប្រព្រឹត្តទៅតាមនូវសញ្ញោជនៈ និងអនុស័យនោះផង ចាកខន្ធទាំងឡាយផង ចេញចាកនិមិត្តទាំងពួងខាងក្រៅផង សម្មាសមាធិ រមែងកើតឡើងព្រោះការរម្ងាប់នូវព្យាយាមក្នុងការចេញនោះ ទុំះជាផលរបស់មគ្គ ដែលឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញា សម្រាប់រម្ងាប់នូវព្យាយាម ឈ្មោះថា ផលញ្ញាណ ។

# អដ្ឋកថា

# ផលញ្ញាណនិទ្ទេស

[ ១៤៨-១៥១ ] គប្បីជ្រាបវិនិច្ឆ័យ ក្នុងផលញ្ញាណនិទ្ទេស ដូចតទៅនេះ បទថា **តំបយោគប្បដិប្បស្សទ្ធត្តា** បានដល់ ព្រោះភាពដែលបយោគៈដែលចេញទាំងខាងក្នុង និងខាងក្រៅនោះ ជាគុណជាតរម្ងាប់ហើយ ។ ពិតហើយ មគ្គ ឈ្មោះថា រមែងធ្វើបយោគៈដែលចេញចាកទាំងពីរ ទាំងខាងក្នុង និងខាងក្រៅ ដោយការលះកិលេសក្នុងខណៈរបស់ខ្លួន ។ ការរម្ងាប់ដែលជាបយោគៈ ដែលចេញចាកទាំងពីរ ទាំងខាងក្នុង និងខាងក្រៅនៃមគ្គ ឈ្មោះថា ស្ងប់ហើយ ព្រោះលះកិលេសបានក្នុងខណៈនៃផល ។

បទថា **ឧប្បជ្ជតិ** បានដល់ ញាណ រមែងកើតឡើងមួយដង ឬពីរដង ក្នុងលំដាប់នៃមគ្គ ។ តែកើតឡើងច្រើនដងក្នុងកាលនៃផលសមាបត្តិ រមែងកើតដល់អ្នកចេញពីនិរោធ ២ ដង ញាណសូម្បីទាំងអស់រមែងកើតឡើង ព្រោះជាគុណជាតរម្ងាប់បយោគៈដែលចេញនោះ ។

បទថា **មគ្គស្សេតំ ផលំ** បានដល់ លោកសម្ដែងដល់ផលទើបធ្វើ ( បយោគប្បដិប្បស្សទ្ធិ ) ឲ្យជានបុំសកលិង្គ ។ សូម្បីក្នុងខណៈនៃសកទាគាមិមគ្គជាដើម ក៏គប្បីជ្រាបការប្រកបការចេញ ដោយអំណាចអង្គនៃមគ្គនីមួយៗ នោះឯង ៕ ០៚

**អដ្ឋកថាផលញ្ញាណនិទ្ទេស ចប់**

# សុត្តន្តបិដក

[ ១៥២ ] បញ្ញាក្នុងការឃើញនូវកិលេសដែលដាច់ ឈ្មោះថា វិមុត្តិញាណ តើដូចម្តេច ។ ពួកឧបក្កិលេសនៃចិត្តរបស់ខ្លួន គឺសក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសៈ ទិដ្ឋានុស័យ វិចិកិច្ឆានុស័យ លោកផ្តាច់បង់ប្រពៃ ហើយ ដោយសោតាបត្តិមគ្គ ចិត្តរួចស្រឡះ ផុតស្រឡះដោយប្រពៃចាក ឧបក្កិលេស ៥ នេះឯង ព្រមទាំងបរិយុដ្ឋានក្កិលេស ( កិលេសជាគ្រឿង រួបរឹតចិត្ត ) ឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវការរួចស្រឡះចាកឧបក្កិ-លេសនោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់ ហេតុនោះ លោក ពោលថា បញ្ញាក្នុងការឃើញនូវកិលេសដែលដាច់ ឈ្មោះថា វិមុត្តិញាណ ។

[ ១៥៣ ] ពួកឧបក្កិលេសនៃចិត្តរបស់ខ្លួន គឺកាមរាគសញ្ញោជនៈ និង បដិឃសញ្ញោជនៈដ៏គ្រោតគ្រាត កាមរាគានុស័យ និងបដិឃានុស័យដ៏គ្រោត គ្រាត លោកបានផ្តាច់បង់ប្រពៃហើយ ដោយសកទាគាមិមគ្គ ចិត្តរួចស្រឡះ ផុតស្រឡះដោយប្រពៃចាកឧបក្កិលេស ៤ នេះឯង ព្រមទាំងបរិយុដ្ឋានក្កិលេស ឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវការរួចស្រឡះចាកឧបក្កិលេសនោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់ ហេតុនោះ លោកពោលថា បញ្ញាក្នុងការឃើញនូវកិលេសដែលដាច់ ឈ្មោះថា វិមុត្តិញាណ ។

[ ១៥៤ ] ពួកឧបក្កិលេសនៃចិត្តរបស់ខ្លួន គឺកាមរាគសញ្ញោជនៈ បដិ-ឃសញ្ញោជនៈដ៏ល្អិត កាមរាគានុស័យ និងបដិឃានុស័យដ៏ល្អិត លោកបាន ផ្តាច់បង់ប្រពៃហើយដោយអនាគាមិមគ្គ ចិត្តរួចស្រឡះ ផុតស្រឡះដោយប្រពៃ ចាកឧបក្កិលេស ៤ នេះឯង ព្រមទាំងបរិយុដ្ឋានក្កិលេស ឈ្មោះថា ញាណ

ដោយអត្ថថា ដឹងនូវការរួចស្រឡះចាកឧបក្កិលេសនោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់ ហេតុនោះ លោកពោលថា បញ្ញាក្នុងការឃើញនូវកិលេសដែលដាច់ ឈ្មោះថា វិមុត្តិញ្ញាណ ។

[ ១៥៥ ] ពួកឧបក្កិលេសនៃចិត្តរបស់ខ្លួន គឺរូបរាគៈ អរូបរាគៈ មានះ ឧទ្ធច្ចៈ អវិជ្ជា មានានុស័យ ភវរាគានុស័យ អវិជ្ជានុស័យ លោកបានផ្តាច់បង់ប្រពៃហើយដោយអរហត្តមគ្គ ចិត្តរួចស្រឡះ ផុតស្រឡះដោយប្រពៃចាកឧបក្កិលេស ៨ នេះឯង ព្រមទាំងបរិយុដ្ឋានកិលេស ឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវការរួចចាកឧបក្កិលេសនោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់ ហេតុនោះ លោកពោលថា បញ្ញាក្នុងការឃើញនូវកិលេសដែលដាច់ ឈ្មោះថា វិមុត្តិញ្ញាណ ដែលឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងការឃើញនូវកិលេសដែលដាច់ ឈ្មោះថា វិមុត្តិញ្ញាណ ។

# អដ្ឋកថា
# វិមុត្តិញ្ញាណនិទ្ទេស

[ ១៥២-១៥៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវិមុត្តិញ្ញាណនិទ្ទេសដូចតទៅនេះ

បទថា **សក្កាយទិដ្ឋិ** មានវិគ្គហៈថា ឈ្មោះថា សក្កាយទិដ្ឋិ ព្រោះអត្ថថា ការឃើញក្នុងកាយ ពោលគឺខន្ធ ៥ ដែលមាន ដោយអត្ថថា មាន ឬក្នុងកាយនោះដែលមាននោះឯង ។ បទថា **វិចិកិច្ឆា** មានវិគ្គហៈថា ឈ្មោះថា វិចិកិច្ឆា ព្រោះអត្ថថា ប្រាសចាកការប្រោកដប្រជាក្នុងចិត្ត ឬកាលស្វែងរកសភាវធម៌ជាហេតុឲ្យលំបាក ។ បទថា **សីលព្វតបរាមាសោ** មានវិនិច្ឆ័យថា ជាអ្នកប្រកាន់ថា ការបរិសុទ្ធមានដោយសីល មានដោយវត្ត មានដោយសីល និងវត្ត ។ ឈ្មោះថា សីលព្វតបរាមាស ព្រោះអត្ថថា អ្នកប្រកាន់នោះលះសភាវ-ធម៌ បបោសអង្អែលតែវត្ថុដទៃ ។ កាលទិដ្ឋិទាំងពីរយ៉ាងមាន លោកក៏នៅពោលសក្កាយទិដ្ឋិ ដើម្បីសម្តែងដល់ការលះទិដ្ឋិទាំងអស់ ដោយការលះសក្កាយ-ទិដ្ឋិដែលមានវត្ថុ ២០ ជាប្រក្រតី ដោយប្រកាន់សក្កាយទិដ្ឋិតាមប្រក្រតីនោះឯង វៀរតក្កៈ ( ហេតុផល ) និងការអាងអ្នកដទៃ ។ ចំណែកសីលព្វតបរាមាស គប្បីជ្រាបថា លោកពោលដោយឡែក ដើម្បីសម្តែងដល់មិច្ឆាបដិបទារបស់មនុស្សទាំងឡាយ ដែលបដិបត្តិដោយគិតថា អញបដិបត្តិបដិបទាបរិសុទ្ធ ។ លោកពោលដល់ទិដ្ឋានុស័យ វិចិកិច្ឆានុស័យ ដើម្បីសម្តែងដល់ការលះដោយការលះកិលេសទាំង ៣ ដែលដេកត្រាំក្នុងសន្តាននោះឯង មិនបានពោលថាជាកិលេសដោយឡែក ។ បទថា **ឧបក្កិលេសា** មានវិគ្គហៈថា ឈ្មោះថា កិលេស

ព្រោះអត្ថថា ធ្វើឲ្យសៅហ្មង ធ្វើឲ្យក្តៅក្រហាយ ធ្វើឲ្យលំបាក ។ ឈ្មោះថា ឧបក្កិលេស ព្រោះអត្ថថា ជាកិលេសអាក្រក់ ដោយអត្ថថា មានកម្លាំង ។

បទថា **សម្មា សមុច្ឆិន្នា ហោន្តិ** បានដល់ កាត់ផ្តាច់ដោយល្អព្រោះរលត់មិនកើតឡើងទៀតដោយសមុច្ឆេទប្បហាន ។ បទថា **សបរិយុដ្ឋានេហិ** មានវិគ្គហៈថា កិលេសទាំងឡាយ ឈ្មោះថា បរិយុដ្ឋាន ព្រោះអត្ថថា តាំងឡើងកើតឡើង រួបរឹតចិត្ត ។ បទនេះ ជាឈ្មោះរបស់កិលេសទាំងឡាយ ដែលដល់នូវការផ្សាយឡើង ។ ឈ្មោះថា **សបរិយុដ្ឋាន** ព្រោះអត្ថថា ប្រព្រឹត្តទៅព្រមដោយបរិយុដ្ឋានក្កិលេស ។ បទថា **ចិត្តំ វិមុត្តំ ហោតិ** សេចក្តីថា ចិត្តប្រព្រឹត្តទៅដោយអំណាចសន្តតិ ព្រោះកិលេសទាំងនោះ ធ្វើឲ្យកើតក្នុងទីមិនសមគួរ ឈ្មោះថា ជាការរួចផុតហើយចាកសន្តតិនោះ ។ ឈ្មោះថា **សុវិមុត្តំ** ព្រោះផុតហើយដោយល្អយ៉ាងនោះឯង ។ បទថា **តំវិមុត្តិញាណដ្ឋេន** បានដល់ ដោយអត្ថថា ដឹងនូវវិមុត្តិនោះ ។៚

**អដ្ឋកថាវិមុត្តិញ្ញាណនិទ្ទេស ចប់**

# សុត្តន្តបិដក

[ ១៥៦ ] បញ្ញាក្នុងការឃើញនូវធម៌ដែលតាំងឡើងក្នុងកាលនោះ ឈ្មោះថា បច្ចវេក្ខណញ្ញាណ តើដូចម្តេច ។ ក្នុងខណៈនៃសោតាបត្តិមគ្គ សម្មាទិដ្ឋិ ដោយអត្ថថា ឃើញ តាំងឡើងក្នុងកាលណោះ សម្មាសង្កប្ប ដោយអត្ថថា លើកចិត្ត តាំងឡើងក្នុងកាលណោះ សម្មាវាចា ដោយអត្ថថា រក្សាទុក តាំងឡើងក្នុងកាលណោះ សម្មាកម្មន្តៈ ដោយអត្ថថា ផ្តួចផ្តើម តាំងឡើងក្នុងកាលណោះ សម្មាអាជីវៈ ដោយអត្ថថា ផូរផង់ តាំងឡើងក្នុងកាលណោះ សម្មា-វាយាមៈ ដោយអត្ថថា ផ្គងទុក តាំងឡើងក្នុងកាលណោះ សម្មាសតិ ដោយអត្ថថា ប្រុងប្រយ័ត្ន តាំងឡើងក្នុងកាលណោះ សម្មាសមាធិ ដោយអត្ថថា មិនរាយមាយ តាំងឡើងក្នុងកាលណោះ សតិសម្ពោជ្ឈង្គ ដោយអត្ថថា ប្រុងប្រយ័ត្ន តាំងឡើងក្នុងកាលណោះ ធម្មវិចយសម្ពោជ្ឈង្គ ដោយអត្ថថា ឈ្វេចឈ្វៃ តាំងឡើងក្នុងកាលណោះ វីរិយសម្ពោជ្ឈង្គ ដោយអត្ថថា ផ្គងទុក តាំងឡើងក្នុងកាលណោះ បីតិសម្ពោជ្ឈង្គ ដោយអត្ថថា ផ្សាយទៅ តាំងឡើងក្នុងកាលណោះ បស្សទ្ធិសម្ពោជ្ឈង្គ ដោយអត្ថថា ស្ងប់រម្ងាប់ តាំងឡើងក្នុងកាលណោះ សមា-ធិសម្ពោជ្ឈង្គ ដោយអត្ថថា មិនរាយមាយ តាំងឡើងក្នុងកាលណោះ ឧបេក្ខា-សម្ពោជ្ឈង្គ ដោយអត្ថថា ពិចារណា តាំងឡើងក្នុងកាលណោះ សទ្ធាពល ដោយអត្ថថា មិនកម្រើកដោយអស្សទ្ធិយៈ ( ការមិនជឿ ) តាំងឡើងក្នុងកាលណោះ វីរិយពល ដោយអត្ថថា មិនកម្រើកដោយកោសជ្ជៈ ( សេចក្តីខ្ជិលប្រអូស ) តាំងឡើងក្នុងកាលណោះ សតិពល ដោយអត្ថថា មិនកម្រើកដោយបមាទៈ តាំងឡើងក្នុងកាលណោះ សមាធិពល ដោយអត្ថថា មិនកម្រើក

ដោយឧទ្ធច្ចៈ តាំងឡើងក្នុងកាលណោះ បញ្ញាពល ដោយអត្ថថា មិនកម្រើក ដោយអវិជ្ជា តាំងឡើងក្នុងកាលណោះ សទ្ធិន្ទ្រិយ ដោយអត្ថថា ជឿ តាំងឡើងក្នុងកាលណោះ វីរិយិន្ទ្រិយ ដោយអត្ថថា ផ្គងទុក តាំងឡើងក្នុងកាលណោះ សតិន្ទ្រិយ ដោយអត្ថថា ប្រុងប្រយ័ត្ន តាំងឡើងក្នុងកាលណោះ សមាធិន្ទ្រិយ ដោយអត្ថថា មិនរាយមាយ តាំងឡើងក្នុងកាលណោះ បញ្ញិន្ទ្រិយ ដោយអត្ថថា ឃើញ តាំងឡើងក្នុងកាលណោះ ឥន្ទ្រិយ ដោយអត្ថថា ជាធំ តាំងឡើងក្នុង កាលណោះ ពល ដោយអត្ថថា មិនកម្រើក តាំងឡើងក្នុងកាលណោះ សម្ពោជ្ឈង្គ ដោយអត្ថថា ស្រោចស្រង់ តាំងឡើងក្នុងកាលណោះ មគ្គ ដោយអត្ថថា ជាហេតុ តាំងឡើងក្នុងកាលណោះ សតិប្បដ្ឋាន ដោយអត្ថថា ប្រុងប្រយ័ត្ន តាំងឡើងក្នុងកាលណោះ សម្មប្បធាន ដោយអត្ថថា តម្កល់ទុក តាំងឡើងក្នុងកាលណោះ ឥទ្ធិបាទ ដោយអត្ថថា សម្រេច តាំងឡើងក្នុងកាលណោះ សច្ចៈ ដោយអត្ថថា ពិត តាំងឡើងក្នុងកាលណោះ សមថៈ ដោយអត្ថថា មិនរាយមាយ តាំងឡើងក្នុងកាលណោះ វិបស្សនា ដោយអត្ថថា ពិចារណារឿយៗ តាំងឡើងក្នុងកាលណោះ សមថៈ និងវិបស្សនា ដោយអត្ថថា មានរសតែមួយ តាំងឡើងក្នុងកាលណោះ ការជាប់គ្នាជាគូ ដោយអត្ថថា មិនប្រព្រឹត្តកន្លង ( នូវគ្នានិងគ្នា ) តាំងឡើងក្នុងកាលណោះ សីលវិសុទ្ធិ ដោយអត្ថថា សង្រួម តាំង ឡើងក្នុងកាលណោះ ចិត្តវិសុទ្ធិ ដោយអត្ថថា មិនរវើរវាយ តាំងឡើងក្នុងកាលណោះ ទិដ្ឋិវិសុទ្ធិ ដោយអត្ថថា ឃើញ តាំងឡើងក្នុងកាលណោះ វិមោក្ខ ដោយអត្ថថា រួចស្រឡះ តាំងឡើងក្នុង

កាលណោះ វិជ្ជាដោយអត្ថថាត្រាស់ដឹង តាំងឡើងក្នុងកាលណោះ វិមុត្តិ ដោយអត្ថថា លះបង់ស្រឡះ តាំងឡើងក្នុងកាលណោះ ខយញ្ញាណ ( ញាណក្នុងការអស់កិលេស ) ដោយអត្ថថា ផ្តាច់ផ្តិល តាំងឡើងក្នុងកាលណោះ ឆន្ទៈ ដោយអត្ថថា ជាឫសគល់ តាំងឡើងក្នុងកាលណោះ មនសិការ ដោយអត្ថថា ផ្តួចផ្តើម តាំងឡើងក្នុងកាលណោះ ផស្សៈ ដោយអត្ថថា ប្រជុំចុះ តាំងឡើងក្នុងកាលណោះ វេទនា ដោយអត្ថថា ប្រជុំព្រម តាំងឡើងក្នុងកាលណោះ សមាធិ ដោយអត្ថថា ជាប្រធាន តាំងឡើងក្នុងកាលណោះ សតិ ដោយអត្ថថា ជាធំ តាំងឡើងក្នុងកាលណោះ បញ្ញា ដោយអត្ថថា ប្រសើរជាងនោះ តាំងឡើងក្នុងកាលណោះ វិមុត្តិ ដោយអត្ថថា ជាខ្លឹម តាំងឡើងក្នុងកាលណោះ និព្វាន ឈ្មោះអមតៈ ( ជាទីពឹងរបស់សត្វ ) ដោយអត្ថថា ចប់ស្រេច ( នៃកិច្ចក្នុងសាសនា ) តាំងឡើងក្នុងកាលណោះ ព្រះអរិយបុគ្គលលុះចេញ ( ចាកអារម្មណ៍ទាំងឡាយ ) ហើយ រមែងពិចារណា ( នូវអារម្មណ៍ទាំងនោះ ) នេះធម៌ទាំងឡាយ តាំងឡើងក្នុងកាលណោះ ។

[ ១៥៧ ] ក្នុងខណៈនៃសោតាបត្តិផល សម្មាទិដ្ឋិ ដោយអត្ថថា ឃើញ តាំងឡើងក្នុងកាលណោះ សម្មាសង្កប្ប ដោយអត្ថថា លើកចិត្ត ( កាន់អារម្មណ៍ ) តាំងឡើងក្នុងកាលណោះ ។បេ។ ញាណក្នុងការមិនកើតឡើង ដោយអត្ថថា ស្ងប់រម្ងាប់ តាំងឡើងក្នុងកាលណោះ ឆន្ទៈ ដោយអត្ថថា ជាឫសគល់ តាំងឡើងក្នុងកាលណោះ មនសិការ ដោយអត្ថថា ផ្តួចផ្តើម តាំងឡើងក្នុងកាលណោះ ផស្សៈ ដោយអត្ថថា ប្រជុំចុះ តាំងឡើងក្នុងកាលណោះ វេទនា

ដោយអត្ថថា ប្រជុំព្រម តាំងឡើងក្នុងកាលណោះ សមាធិ ដោយអត្ថថា ជាប្រធាន តាំងឡើងក្នុងកាលណោះ សតិ ដោយអត្ថថា ជាធំ តាំងឡើងក្នុងកាលណោះ បញ្ញា ដោយអត្ថថា ប្រសើរជាងនោះ តាំងឡើងក្នុងកាលណោះ វិមុត្តិ ដោយអត្ថថា ជាខ្លឹម តាំងឡើងក្នុងកាលណោះ និព្វាន ឈ្មោះអមតៈ ( ជាទីពឹងរបស់សត្វ ) ដោយអត្ថថា ចប់ស្រេច ( នៃកិច្ចក្នុងសាសនា ) តាំងឡើងក្នុងកាលណោះ ព្រះអរិយបុគ្គល លុះចេញ ( ចាកអារម្មណ៍ទាំងឡាយ ) ហើយ រមែងពិចារណា ( នូវអារម្មណ៍ទាំងនោះ ) នេះធម៌ទាំងឡាយ តាំងឡើងក្នុងកាលណោះ ។

[ ១៥៨ ] ក្នុងខណៈនៃសកទាគាមិមគ្គ ។បេ។ ក្នុងខណៈនៃសកទាគាមិ-ផល ។បេ។ ក្នុងខណៈនៃអនាគាមិមគ្គ ។បេ។ ក្នុងខណៈនៃអនាគាមិផល ។បេ។ ក្នុងខណៈនៃអរហត្តមគ្គ សម្មាទិដ្ឋិ ដោយអត្ថថា ឃើញ តាំងឡើងក្នុងកាលណោះ ។បេ។ ខយញ្ញាណ ដោយអត្ថថា ផ្តាច់ផ្តិល តាំងឡើងក្នុងកាលណោះ ឆន្ទៈ ដោយអត្ថថា ជាឫសគល់ តាំងឡើងក្នុងកាលណោះ ។បេ។ និព្វានឈ្មោះអមតៈ ( ជាទីពឹងរបស់សត្វ ) ដោយអត្ថថា ចប់ស្រេច ( នៃកិច្ចក្នុងសាសនា ) តាំងឡើងក្នុងកាលណោះ ព្រះអរិយបុគ្គល លុះចេញ ( ចាកអារម្មណ៍ទាំងឡាយ ) ហើយ រមែងពិចារណា ( នូវអារម្មណ៍ទាំងនោះ ) នេះធម៌ទាំងឡាយ តាំងឡើងក្នុងកាលណោះ ។

[ ១៥៩ ] ក្នុងខណៈនៃអរហត្តផល សម្មាទិដ្ឋិ ដោយអត្ថថា ឃើញ តាំងឡើងក្នុងកាលណោះ ។បេ។ ញាណក្នុងការមិនកើតឡើង ដោយអត្ថថា ស្ងប់

រម្ងាប់ តាំងឡើងក្នុងកាលណោះ ធន្ទៈ ដោយអត្ថថា ជាឫសគល់ តាំងឡើងក្នុងកាលណោះ ។បេ។ និព្វាន ឈ្មោះអមតៈ ( ជាទីពឹងរបស់សត្វ ) ដោយអត្ថថា ចប់ស្រេច ( នៃកិច្ចក្នុងសាសនា ) តាំងឡើងក្នុងកាលណោះ ព្រះអរិយបុគ្គលលុះចេញ ( ចាកអារម្មណ៍ទាំងឡាយ ) ហើយ រមែងពិចារណា ( នូវអារម្មណ៍ទាំងនោះ ) នេះធម៌ទាំងឡាយ តាំងឡើងក្នុងកាលណោះ ដែលឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងការពិចារណាឃើញនូវពួកធម៌តាំងឡើងក្នុងកាលនោះ ឈ្មោះថា បច្ចវេក្ខណញ្ញាណ ។

# អដ្ឋកថា

## បច្ចវេក្ខណញ្ញាណនិទ្ទេស

[ ១៥៦-១៥៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបច្ចវេក្ខណញ្ញាណនិទ្ទេសដូចតទៅ ព្រះសារីបុត្តត្ថេរ ពោលចែកអង្គនៃមគ្គមុន ព្រោះអត្ថថា ជាហេតុក្នុងខណៈនៃមគ្គនោះឯងហើយ ទើបសម្តែងចែកពោជ្ឈង្គ ដែលជាធម៌ ដែលជាអង្គនៃមគ្គ និងមិនមែនអង្គនៃមគ្គទៀត ដោយភាពជាអង្គនៃអរិយៈ ដែលបានឈ្មោះថា ពោធិ ព្រោះអត្ថថា ត្រាស់ដឹង ។ ពិតហើយ សតិសម្ពោជ្ឈង្គ ធម្មវិចយសម្ពោជ្ឈង្គ វិរិយសម្ពោជ្ឈង្គ សមាធិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គប៉ុណ្ណោះ បីតិសម្ពោជ្ឈង្គ បស្សទ្ធិសម្ពោជ្ឈង្គ ឧបេក្ខាសម្ពោជ្ឈង្គ មិនមែនអង្គនៃមគ្គ ។ បណ្តាធម៌ទាំងឡាយដែលសម្តែងដោយឡែក ដោយអំណាចពល និងដោយអំណាចឥន្ទ្រិយ សទ្ធាប៉ុណ្ណោះ មិនមែនជាអង្គនៃមគ្គ ។ ព្រះសារីបុត្តត្ថេរ កាលសម្តែងធម៌ដែលកើតក្នុងខណៈនៃមគ្គទៀត ដោយអំណាចជាពួក ទើបពោលបទថា **អាធិបតេយ្យដ្ឋេន** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **ឧបដ្ឋានដ្ឋេន សតិបដ្ឋានា** សេចក្តីថា សតិដែលមាននិព្វានជាអារម្មណ៍តែម្យ៉ាងប៉ុណ្ណោះ ឈ្មោះថា សតិប្បដ្ឋាន ៤ ដោយអំណាចឲ្យសម្រេចកិច្ចក្នុងការលះនូវការសម្គាល់ក្នុងកាយថាស្អាត ក្នុងវេទនាថាជាសុខ ក្នុងចិត្តថាទៀង ក្នុងធម៌ថាជាតួខ្លួន វិរិយៈដែលមាននិព្វានជាអារម្មណ៍តែម្យ៉ាងប៉ុណ្ណោះ ឈ្មោះថា សម្មប្បធាន ៤ ដោយអំណាចឲ្យសម្រេចកិច្ច គឺលះអកុសលដែលកើតហើយ និងធ្វើអកុសលដែលមិនទាន់កើត មិនឲ្យ

កើតឡើង ឲ្យសម្រេចកិច្ច គឺធ្វើកុសលដែលមិនទាន់កើតឲ្យកើតឡើង និង រក្សានូវកុសលដែលកើតឡើងហើយ ។

បទថា **តថដ្ឋេន សច្ចា** បានដល់ ឈ្មោះថា អរិយសច្ច ៤ ព្រោះអត្ថថា មិនឃ្លៀងឃ្លាត ក្នុងភាពជាទុក្ខសច្ចជាដើម ។ ម្យ៉ាងទៀត ក្នុងពាក្យនេះ អរិយសច្ច ៤ នោះឯង ឈ្មោះថា ប្រជុំគ្នាក្នុងកាលនោះ ព្រោះអត្ថថា ដឹងច្បាស់ ដោយការចាក់ធ្លុះ ។ ហើយលោកពោលដល់និព្វានដោយឡែកថា **អមតោ-គធំ និព្វានំ** ដូច្នេះ ចំណែកធម៌ដ៏វិសេស ឈ្មោះថា ចូលមកប្រជុំគ្នាក្នុង កាលនោះ ព្រោះអត្ថថា បានទទួលចំពោះ ។ ព្រោះបទថា **តថដ្ឋេន សច្ចា តធា សមុធាគតា** ក្នុងទីនេះ គួរកាត់សម្រេចបានថា ព្រះយោគាវចរ រមែង ពិចារណាសច្ចៈ ៤ ពិតប្រាកដក្នុងទីបំផុតនៃមគ្គផល ។ ឯព្រះបាលី ( ក្នុង ទីឃនិកាយ សីលក្ខន្ធវគ្គ ) ថា សោឡសកិច្ចអាត្មាអញក៏បានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយដូច្នេះ ជាការត្រាស់ដល់ការពិចារណាថា ទុក្ខអាត្មាអញកំណត់ដឹងហើយ សមុទយៈ អាត្មាអញលះហើយ និរោធអាត្មាអញធ្វើឲ្យជាក់ច្បាស់ហើយ មគ្គអាត្មាអញ ចម្រើនហើយ ។ ការពិចារណាយ៉ាងនោះសមគួរ ។ ម្យ៉ាងទៀត ក្នុងបទថា **សមុទយ** នេះ គប្បីជ្រាបដល់កិលេសដែលត្រូវទម្លាយដោយមគ្គនោះៗ ឯង ។ ដោយការពិចារណាសមុទយៈ ដែលពោលក្នុងបទនេះ ក្នុងអដ្ឋកថាលោក ពោលដល់ការពិចារណាកិលេស ២ យ៉ាង ក្នុងទីនេះ លោកពោលដល់ការ ពិចារណាមគ្គ ផល និងនិព្វានថាមកហើយ ដោយសរុបនោះឯង ។ ការ

ពិចារណាទុក្ខតែម្យ៉ាងប៉ុណ្ណោះ លោកមិនបានពោល ។ ទោះបីលោកមិនបានពោលក៏ពិត ការពិតហើយ គួរកាន់យកតាមសភាពក្នុងបាលី និងតាមសភាពសមគួរ ។ ពិតហើយ កាលការដឹងច្បាស់ ការចាក់ធ្លុះសច្ចៈ សម្រេចដល់អ្នកបដិបត្តិ ដើម្បីដឹងច្បាស់នូវការចាក់ធ្លុះសច្ចៈហើយ ការពិចារណាដល់កិច្ចដែលសម្រេចហើយដោយខ្លួនឯង ជាការសមគួរនោះឯង ។

បទ មានបទថា **អវិក្ខេបដ្ឋេន សមថោ** ជាដើម ព្រះសារីបុត្តត្ថេរ ពោលដើម្បីសម្តែងធម៌ គឺសមថៈ និងវិបស្សនាដែលសម្បយុត្តដោយមគ្គនោះឯង ព្រោះអត្ថថា មានកិច្ចតែម្យ៉ាង និងព្រោះអត្ថថា មិនកន្លងនូវគ្នានិងគ្នា ។

បទថា **សំវរដ្ឋេន សីលវិសុទ្ធិ** បានដល់ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈនោះឯង ។ បទថា **អវិក្ខេបដ្ឋេន ចិត្តវិសុទ្ធិ** បានដល់ សម្មាសមាធិនោះឯង ។ បទថា **ទស្សនដ្ឋេន ទិដ្ឋិវិសុទ្ធិ** បានដល់ សម្មាទិដ្ឋិនោះឯង ។ បទថា **វិមុត្តដ្ឋេន** បានដល់ ព្រោះអត្ថថា រួចផុតចាកកិលេសដែលគប្បីទម្លាយដោយមគ្គ ដោយអំណាចសមុច្ឆេទប្បហាន ឬព្រោះអត្ថថា បង្អោនទៅក្នុងអារម្មណ៍ គឺនិព្វាន ។ បទថា **វិមោក្ខោ** បានដល់ ការរួចផុតដោយសមុច្ឆេទ គឺអរិយមគ្គនោះឯង ។ បទថា **បដិវេធនដ្ឋេន វិជ្ជា** បានដល់ ឈ្មោះថា វិជ្ជា ព្រោះអត្ថថា ចាក់ធ្លុះសច្ចៈ គឺសម្មាទិដ្ឋិនោះឯង ។

បទថា **បរិច្ចាគដ្ឋេន វិមុត្តិ** បានដល់ ឈ្មោះថា វិមុត្តិ ព្រោះអត្ថថា លះកិលេសដែលគប្បីទម្លាយដោយមគ្គ ដោយផុតចាកកិលេសនោះ គឺអរិយមគ្គនោះឯង ។ បទថា **សមុច្ឆេទដ្ឋេន ខយេ ញាណំ** បានដល់ ញាណក្នុង

អរិយមគ្គ ដែលធ្វើនូវការអស់ទៅនៃកិលេស ដោយការកាត់កិលេសបានជាសមុច្ឆេទ គឺសម្មាទិដ្ឋិនោះឯង ។

គប្បីជ្រាបឆន្ទៈជាដើមដោយន័យដូចបានពោលហើយ ក្នុងខាងដើមនោះឯង ។ ពិតហើយ ក្នុងទីនេះ ព្រះសារីបុត្តត្ថេរ សម្តែងដោយអាការជាដើមថា កណ្តាល និងខាងចុងនៃមគ្គ ក្នុងខណៈមគ្គនោះឯង ។

ម្យ៉ាងទៀត ក្នុងបទថា **វិមុត្តិ** នេះបានដល់មគ្គវិមុត្តិនោះឯង ។ ម្យ៉ាងទៀត និព្វានសូម្បីលោកកាន់យកក្នុងបទថា **តជ្ជេន សច្ចា** ក៏គប្បីជ្រាបថា លោកពោលទៀតដើម្បីសម្តែងដល់ភាពជាទីបំផុតក្នុងបទនេះ ។ សូម្បីក្នុងខណៈនៃផលក៏មានន័យនេះដូចគ្នា ។ តែក្នុងបទនេះថា **ហេតុជ្ជេន មគ្គោ** គប្បីជ្រាបថា លោកពោលដោយភាពជាហេតុនៃផលនោះឯង ។

បទថា **សម្មប្បធានា** គប្បីជ្រាបថា លោកពោលព្រោះផលដែលជាកិច្ចនៃសេចក្តីព្យាយាម ដែលញុំាងកិច្ច ៤ យ៉ាង ឲ្យសម្រេច ក្នុងខណៈនៃមគ្គសម្រេចហើយក្នុងខណៈកើតព្រោះសម្មប្បធាន រមែងមិនបានក្នុងខណៈផលដោយប្រការដទៃ ។ ព្រះថេរៈដែលលើកពោធិបក្ខិយធម៌ ៣៧ ឡើងសម្តែងក្នុងខណៈនៃមគ្គ ពោលថា ធម៌ ៣៣ ប្រការដ៏សេស វៀរសម្មប្បធាន ៤ រមែងបានក្នុងខណៈនៃផល ។ សច្ចៈជាដើម គប្បីជ្រាបតាមដែលប្រកបបានដោយអំណាចសម្រេចកិច្ច មានកិច្ច គឺការចាក់ធ្លុះជាដើមយ៉ាងនោះដូចគ្នា ។

ម្យ៉ាងទៀត បទថា **វិមោក្ខោ** បានដល់ ផលវិមោក្ខ ។ បទថា **វិមុត្តិ** បានដល់ ផលវិមុត្តិ ។ ឈ្មោះថា **បដិប្បស្សទ្ធជ្ជេន អនុប្បាទេ ញាណំ** មាន

*សេចក្ដីដូចបានពោលហើយនោះឯង ។ បទថា* **វុដ្ឋហិត្វា** *លោកពោលយ៉ាងនេះ ដោយអំណាចនៃផល ព្រោះមិនមានការចេញក្នុងរវាង ។ បទថា* **ឥមេ ធម្មា តទា សមុទាគតា** *គប្បីជ្រាបការភ្ជាប់សេចក្ដីចុះ* **ឥតិ** *សព្ទ ( ថា ... ដូច្នេះ ) ដែលជាពាក្យដ៏សេសចូលមកប្រកបថា ព្រះយោគាវចររមែងពិចារណាថា ធម៌មានប្រការដូចពោលហើយទាំងនេះ ចូលមកប្រជុំគ្នាក្នុងខណៈនៃមគ្គ និងក្នុងខណៈនៃផល ដូច្នេះ ៕*

## អដ្ឋកថាបច្ចវេក្ខណញ្ញាណនិទ្ទេស ចប់

# សុត្តន្តបិដក

[ ១៦០ ] បញ្ញាក្នុងការកំណត់នូវធម៌ខាងក្នុង ឈ្មោះថា វត្ថុនានត្តញ្ញាណ តើដូចម្ដេច ។

បុគ្គលកំណត់នូវធម៌ខាងក្នុង តើដូចម្ដេច ។ បុគ្គលកំណត់នូវចក្ខុខាងក្នុង កំណត់នូវសោតៈខាងក្នុង កំណត់នូវឃានៈខាងក្នុង កំណត់នូវជិវ្ហាខាងក្នុង កំណត់នូវកាយខាងក្នុង កំណត់នូវចិត្តខាងក្នុង ។

[ ១៦១ ] បុគ្គលកំណត់នូវចក្ខុខាងក្នុង តើដូចម្ដេច ។ បុគ្គលកំណត់ថា ចក្ខុកើតហើយព្រោះអវិជ្ជា កំណត់ថា ចក្ខុកើតហើយព្រោះតណ្ហា កំណត់ថា ចក្ខុកើតហើយព្រោះកម្ម កំណត់ថា ចក្ខុកើតហើយ ព្រោះអាហារ កំណត់ថា ចក្ខុអាស្រ័យនូវមហាភូតរូប ៤ កំណត់ថា ចក្ខុកើតឡើងហើយ កំណត់ថា ចក្ខុតាំងឡើងហើយ កំណត់ថា ចក្ខុដែលមិនទាន់មានមានហើយ ដែលមានហើយបែរជានឹងមិនមានវិញ កំណត់នូវចក្ខុថា មានទីបំផុត កំណត់ថា ចក្ខុមិនមាំមួន មិនស្ថិតស្ថេរ មានសេចក្ដីប្រែប្រួលជាធម្មតា កំណត់ថា ចក្ខុមិនទៀង ត្រូវបច្ច័យតាក់តែង កើតឡើងហើយ ព្រោះអាស្រ័យហេតុ មានការអស់ទៅជាធម្មតា មានការសូន្យជាធម្មតា មានការប្រាសនិរាសជាធម្មតា មានការរលត់ជាធម្មតា កំណត់នូវចក្ខុថាមិនទៀង មិនកំណត់ថាទៀង កំណត់ថាជាទុក្ខ មិនកំណត់ថាជាសុខ កំណត់ថាជាអនត្តា មិនកំណត់ថាជាអត្តា រមែងនឿយណាយ មិនត្រេកអរ ធុញទ្រាន់ មិនរីករាយ រម្ងាត់ មិនឲ្យកើតឡើង រលាស់ចោល មិនកាន់យក កាលកំណត់ថាមិនទៀង រមែងលះបង់នូវនិច្ចសញ្ញា កាលកំណត់ថាជាទុក្ខ រមែងលះបង់នូវសុខសញ្ញា កាលកំណត់ថាជាអនត្តា រមែងលះបង់

នូវអត្តសញ្ញា កាលនឿយណាយ រមែងលះបង់នូវសេចក្តីរីករាយ កាលធុញទ្រាន់ រមែងលះបង់នូវរាគៈ កាលរម្ងត់ រមែងលះបង់នូវការកើតឡើង កាលរលាស់ចោល រមែងលះបង់នូវការប្រកាន់មាំ បុគ្គលកំណត់នូវចក្ខុខាងក្នុងដោយប្រការយ៉ាងនេះឯង ។

[ ១៦២ ] បុគ្គលកំណត់នូវសោតៈខាងក្នុង តើដូចម្តេច ។ បុគ្គលកំណត់ថា សោតៈកើតហើយ ព្រោះអវិជ្ជា ។បេ។ បុគ្គលកំណត់នូវសោតៈខាងក្នុងដោយប្រការយ៉ាងនេះឯង ។

បុគ្គលកំណត់នូវឃានៈខាងក្នុង តើដូចម្តេច ។ បុគ្គលកំណត់ថា ឃានៈកើតហើយ ព្រោះអវិជ្ជា ។បេ។ បុគ្គលកំណត់នូវឃានៈខាងក្នុង ដោយប្រការយ៉ាងនេះឯង ។

បុគ្គលកំណត់នូវជិវ្ហាខាងក្នុង តើដូចម្តេច ។ បុគ្គលកំណត់ថា ជិវ្ហាកើតហើយ ព្រោះអវិជ្ជា កំណត់ថា ជិវ្ហាកើតហើយ ព្រោះតណ្ហា កំណត់ថា ជិវ្ហាកើតហើយ ព្រោះកម្ម កំណត់ថា ជិវ្ហាកើតហើយ ព្រោះអាហារ កំណត់ថា ជិវ្ហាអាស្រ័យនូវមហាភូតរូប ៤ កំណត់ថា ជិវ្ហាកើតឡើងហើយ កំណត់ថា ជិវ្ហាតាំងឡើងហើយ កំណត់ថា ជិវ្ហាដែលមិនទាន់មានមានហើយ ដែលមានហើយបែរជានឹងមិនមានវិញ កំណត់នូវជិវ្ហាថា មានទីបំផុត កំណត់ថា ជិវ្ហាមិនមាំមួនមិនស្ថិតស្ថេរ មានសេចក្តីប្រែប្រួលជាធម្មតា កំណត់ថា ជិវ្ហាមិនទៀង ត្រូវបច្ច័យតាក់តែង កើតឡើង ព្រោះអាស្រ័យហេតុ មានការអស់ជាធម្មតា មានការសូន្យជាធម្មតា មានសេចក្តីសាយជាធម្មតា មានការរលត់ជាធម្មតា កំណត់

នូវជិវ្ហាថា មិនទៀង មិនកំណត់ថា ទៀង ។បេ។ រមែងរលាស់ចោល មិនកាន់យក កាលកំណត់ថា មិនទៀង រមែងលះបង់នូវនិច្ចសញ្ញា ។បេ។ កាលរលាស់ចោល រមែងលះបង់នូវសេចក្តីប្រកាន់មាំ បុគ្គលកំណត់នូវជិវ្ហាខាងក្នុង ដោយប្រការយ៉ាងនេះឯង ។

បុគ្គលកំណត់នូវកាយខាងក្នុង តើដូចម្តេច ។ បុគ្គលកំណត់ថា កាយកើតហើយព្រោះអវិជ្ជា កំណត់ថា កាយកើតហើយព្រោះតណ្ហា កំណត់ថា កាយកើតហើយព្រោះកម្ម កំណត់ថា កាយកើតហើយព្រោះអាហារ កំណត់ថា កាយអាស្រ័យនូវមហាភូតរូប ៤ កំណត់ថា កាយកើតឡើងហើយ កំណត់ថា កាយតាំងឡើងហើយ កំណត់ថា កាយដែលមិនទាន់មាន មានហើយ ដែលមានហើយ បែរជានឹងមិនមានវិញ កំណត់នូវកាយថា មានទីបំផុត កំណត់ថា កាយមិនមាំមួន មិនស្ថិតស្ថេរ មានសេចក្តីប្រែប្រួលជាធម្មតា កំណត់ថា កាយមិនទៀង ត្រូវបច្ច័យតាក់តែង កើតឡើងហើយ ព្រោះអាស្រ័យហេតុ មានការអស់ជាធម្មតា មានការសូន្យជាធម្មតា មានការសោយជាធម្មតា មានការរលត់ជាធម្មតា កំណត់នូវកាយថា មិនទៀង មិនកំណត់ថា ទៀង កំណត់ថាជាទុក្ខ មិនកំណត់ថាជាសុខ ។បេ។ រមែងរលាស់ចោល មិនកាន់យក កាលកំណត់ថា មិនទៀង រមែងលះបង់នូវនិច្ចសញ្ញា កាលកំណត់ថាជាទុក្ខ រមែងលះបង់នូវសុខសញ្ញា ។បេ។ កាលរលាស់ចោល រមែងលះបង់នូវសេចក្តីប្រកាន់មាំ បុគ្គលកំណត់នូវកាយខាងក្នុងដោយប្រការយ៉ាងនេះឯង ។

បុគ្គលកំណត់នូវចិត្តខាងក្នុង តើដូចម្តេច ។ បុគ្គលកំណត់ថា ចិត្តកើត

ហើយព្រោះអវិជ្ជា កំណត់ថា ចិត្តកើតហើយព្រោះតណ្ហា កំណត់ថា ចិត្តកើតហើយព្រោះកម្ម កំណត់ថា ចិត្តកើតហើយព្រោះអាហារ កំណត់ថា ចិត្តកើតឡើងហើយ កំណត់ថា ចិត្តតាំងឡើងហើយ កំណត់ថា ចិត្តដែលមិនទាន់មានមានហើយ ដែលមានហើយ បែរជានឹងមិនមានវិញ កំណត់នូវចិត្តថា មានទីបំផុត កំណត់ថា ចិត្តមិនមាំមួន មិនស្ថិតស្ថេរ មានសេចក្តីប្រែប្រួលជាធម្មតា កំណត់ថា ចិត្តមិនទៀង ត្រូវបច្ច័យតាក់តែង កើតឡើងហើយព្រោះអាស្រ័យហេតុ មានការអស់ជាធម្មតា មានការសូន្យជាធម្មតា មានការសោយជាធម្មតា មានការរលត់ជាធម្មតា កំណត់នូវចិត្តថាមិនទៀង មិនកំណត់ថាទៀង កំណត់ថាជាទុក្ខ មិនកំណត់ថាជាសុខ កំណត់ថា ជាអនត្តា មិនកំណត់ថាជាអត្តា រមែងនឿយណាយ មិនត្រេកអរ ធុញទ្រាន់ មិនរីករាយ រម្ងាត់ មិនឲ្យកើតឡើង រលាស់ចោល មិនកាន់យក កាលកំណត់ថា មិនទៀង រមែងលះបង់នូវនិច្ចសញ្ញា កាលកំណត់ថាជាទុក្ខ រមែងលះបង់នូវសុខសញ្ញា កាលកំណត់ថាជាអនត្តា រមែងលះបង់នូវអត្តសញ្ញា កាលនឿយណាយ រមែងលះបង់នូវសេចក្តីរីករាយ កាលធុញទ្រាន់ រមែងលះបង់នូវរាគៈ កាលរម្ងាត់ រមែងលះបង់នូវការកើតឡើង កាលរលាស់ចោល រមែងលះបង់នូវសេចក្តីប្រកាន់មាំ បុគ្គលកំណត់នូវចិត្តខាងក្នុង ដោយប្រការយ៉ាងនេះឯង បុគ្គលកំណត់នូវធម៌ខាងក្នុង ដោយប្រការយ៉ាងនេះឯង ដែលឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងការកំណត់នូវធម៌ខាងក្នុង ឈ្មោះថា វត្ថុនានត្តញ្ញាណ ។

## អដ្ឋកថា

## វត្ថុនានត្តញាណនិទ្ទេស

[ ១៦០-១៦២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវត្ថុនានត្តញាណនិទ្ទេស ដូចតទៅ បទថា **ចក្ខុំ អជ្ឈត្តំ វវត្ថេតិ** បានដល់ ព្រះយោគាវចរ រមែងកំណត់ចក្ខុដែលមានក្នុងខាងក្នុង ។ ព្រះសារីបុត្តត្ថេរ បំណងនឹងពោលដោយអាការដែលព្រះយោគាវចរនោះកំណត់ចក្ខុ ទើបសួរថា បុគ្គលកំណត់ចក្ខុខាងក្នុង តើដូចម្តេច ហើយសម្តែងអាការកំណត់ទៀត ដោយបទថា ចក្ខុកើតហើយព្រោះអវិជ្ជាជាដើម ។

ក្នុងបទទាំងនោះ អវិជ្ជា និងតណ្ហា ដែលជាអតីតជាហេតុឧបត្ថម្ភកម្មដែលជាអតីតជាហេតុឲ្យកើតអាហារ ជាហេតុឧបត្ថម្ភក្នុងបច្ចុប្បន្ន ដោយពាក្យនោះឈ្មោះថា លោកកាន់យកឧតុ និងចិត្តដែលជាគ្រឿងឧបត្ថម្ភចក្ខុដែរនោះឯង ។

បទថា **ចតុន្នំ មហាភូតានំ ឧបាទាយ** ជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថនៃទុតិយាវិភត្តិ អធិប្បាយថា ចក្ខុអាស្រ័យមហាភូតរូប ៤ ហើយប្រព្រឹត្តទៅ ។ ដោយបទនេះ លោកសម្តែងដល់ភាពជាបសាទចក្ខុ បដិសេធភាពជាសសម្ភារ-ចក្ខុ ។ បទថា **ឧប្បន្នំ** បានដល់ កើតឡើងចំពោះមុខដោយអំណាចនៃអទ្ធា ឬដោយអំណាចនៃខណៈដែលជាសន្តតិ ។ បទថា **សមុទាគតំ** បានដល់ តាំងឡើងហើយអំពីហេតុ ។ ដោយហេតុត្រឹមប៉ុណ្ណេះ លោកសម្តែងដល់ការកំណត់ចក្ខុក្នុងចំណែកខាងដើមនៃវិបស្សនា ។

លោកសម្តែងដល់អនិច្ចានុបស្សនា ដោយបទថា **អហុត្វា សម្ភូតំ**

ជាដើម ។ ឈ្មោះថា **អហុត្វា សម្ភូតំ** ព្រោះមិនមានអំពីការកើតក្នុងកាលមុន ។ ឈ្មោះថា **ហុត្វា ន ភវិស្សតិ** ព្រោះមិនមានអំពីការវិនាសខាងមុខ ។ បទថា **អន្តវន្តតោ** មានវិគ្គហៈថា ឈ្មោះថា **អន្តវា** ព្រោះអត្ថថា ចក្ខុនោះមានទីបំផុត ។ ការមានទីបំផុតនោះឯងឈ្មោះថា **អន្តវន្តោ** ដូចបទ ( ក្នុងថេរ-គាថា ) ថា **គតិមន្តោ សតិមន្តោ ធិតិមន្តោ ច យោ ឥសិ** មានញាណគតិ មានស្មារតី មានប្រាជ្ញាជាគ្រឿងទ្រទ្រង់ ជាអ្នកស្វែងរកនូវគុណ ដូច្នេះ ។ ដោយភាពជារបស់មានទីបំផុតនោះ អធិប្បាយថា ដោយមានការបែកធ្លាយទៅ ។

បទថា **អទ្ធុវំ** បានដល់ ឈ្មោះថា មិនមាំទាំព្រោះធ្លាក់ទៅក្នុងការកំណត់ទាំងពួង និងព្រោះមិនមានភាពជារបស់មាំទាំ ។ បទថា **អសស្សតំ** បានដល់ មិនពិតប្រាកដ ។ បទថា **វិបរិណាមធម្មំ** បានដល់ មានការប្រែប្រួលទៅជាប្រក្រតីដោយអាការ ២ យ៉ាង គឺដោយជរា និងដោយមរណៈ ។ បទថា **ចក្ខុំ អនិច្ចំ** ជាដើម និងបទថា **ចក្ខុំ អនិច្ចតោ** ជាដើម មានអត្ថដូចពោលហើយ ។ បទថា **អវិជ្ជាសម្ភូតោ** ជាដើម រមែងសមគួរនោះឯង ព្រោះក្នុងបទថា **មនោ** នេះ លោកបំណងយកចិត្តដែលជាភវង្គ ។ ក្នុងបទនេះថា **អាហារសម្ភូតោ** គប្បីជ្រាបដោយអំណាចផស្សាហារ និងមនោសញ្ចេតនាហារប្រកបគ្នា ។ បទថា **ឧប្បន្នោ** គប្បីជ្រាបដោយអំណាចនៃអទ្ធា និងសន្តតិ ។ល។

**អដ្ឋកថាវត្ថុនានត្តញ្ញាណនិទ្ទេស ចប់**

# សុត្តន្តបិដក

[ ១៦៣ ] បញ្ញាក្នុងការកំណត់នូវធម៌ខាងក្រៅ ឈ្មោះថា គោចរនានត្តញ្ញាណ តើដូចម្តេច ។ បុគ្គលកំណត់នូវធម៌ទាំងឡាយខាងក្រៅ តើដូចម្តេច ។ បុគ្គលកំណត់នូវរូបខាងក្រៅ កំណត់នូវសំឡេងខាងក្រៅ កំណត់នូវក្លិនខាងក្រៅ កំណត់នូវរសខាងក្រៅ កំណត់នូវផ្សព្វខាងក្រៅ កំណត់នូវធម៌ខាងក្រៅ ។

បុគ្គលកំណត់នូវរូបខាងក្រៅ តើដូចម្តេច ។ បុគ្គលកំណត់ថា រូបកើតហើយព្រោះអវិជ្ជា កំណត់ថា រូបកើតហើយព្រោះតណ្ហា កំណត់ថា រូបកើតហើយព្រោះកម្ម កំណត់ថា រូបកើតហើយព្រោះអាហារ កំណត់ថា រូបអាស្រ័យនូវមហាភូតរូប ៤ កំណត់ថារូបកើតឡើងហើយ កំណត់ថា រូបតាំងឡើងហើយ កំណត់ថា រូបដែលមិនទាន់មាន មានហើយ ដែលមានហើយ បែរជានឹងមិនមានវិញ កំណត់នូវរូបថា មានទីបំផុត កំណត់ថា រូបមិនមាំមួន មិនស្ថិតស្ថេរ មានសេចក្តីប្រែប្រួលជាធម្មតា កំណត់ថា រូបមិនទៀង ត្រូវបច្ច័យតាក់តែងកើតឡើងហើយព្រោះអាស្រ័យហេតុ មានការអស់ជាធម្មតា មានការសូន្យជាធម្មតា មានការរសាយជាធម្មតា មានការរលត់ជាធម្មតា កំណត់នូវរូបថា មិនទៀង មិនកំណត់ថាទៀង កំណត់ថា ជាទុក្ខ មិនកំណត់ថា ជាសុខ កំណត់ថា ជាអនត្តា មិនកំណត់ថា ជាអត្តា រមែងនឿយណាយ មិនត្រេកអរ ធុញទ្រាន់ មិនរីករាយ រម្ងត់ មិនឲ្យកើតឡើង រលាស់ចោល មិនកាន់យក កាលកំណត់ថា មិនទៀង រមែងលះបង់នូវនិច្ចសញ្ញា កាលកំណត់ថា ជាទុក្ខ រមែងលះបង់នូវសុខសញ្ញា កាលកំណត់ថា ជាអនត្តា រមែងលះបង់នូវអត្តសញ្ញា កាលនឿយ

ណាយ រមែងលះបង់នូវសេចក្ដីរីករាយ កាលធុញទ្រាន់ រមែងលះបង់នូវរាគៈ កាលរម្ងត់ រមែងលះបង់នូវការកើតឡើង កាលរលាស់ចោល រមែងលះបង់នូវសេចក្ដីប្រកាន់មាំ បុគ្គលកំណត់នូវរូបខាងក្រៅ ដោយប្រការយ៉ាងនេះឯង ។

[ ១៦៤ ] បុគ្គលកំណត់នូវសំឡេងខាងក្រៅ តើដូចម្ដេច ។ បុគ្គលកំណត់ថា សំឡេងកើតហើយព្រោះអវិជ្ជា ។បេ។ កំណត់ថា សំឡេងអាស្រ័យនូវមហាភូតរូប ៤ កំណត់ថា សំឡេងកើតឡើងហើយ កំណត់ថា សំឡេងតាំងឡើងហើយ កំណត់ថា សំឡេងដែលមិនទាន់មាន មានហើយ ដែលមានហើយ បែរជានឹងមិនមានវិញ កំណត់នូវសំឡេងថា មានទីបំផុត កំណត់ថា សំឡេងមិនមាំមួន មិនស្ថិតស្ថេរ មានសេចក្ដីប្រែប្រួលជាធម្មតា កំណត់ថា សំឡេងមិនទៀង ត្រូវបច្ច័យតាក់តែងកើតឡើងហើយ ព្រោះអាស្រ័យហេតុ មានការអស់ជាធម្មតា មានការសូន្យជាធម្មតា មានការរសាយជាធម្មតា មានការរលត់ជាធម្មតា កំណត់នូវសំឡេងថា មិនទៀង ។បេ។ បុគ្គលកំណត់នូវសំឡេងខាងក្រៅ ដោយប្រការយ៉ាងនេះឯង ។

បុគ្គលកំណត់នូវក្លិនខាងក្រៅ តើដូចម្ដេច ។ បុគ្គលកំណត់ថា ក្លិនកើតហើយព្រោះអវិជ្ជា កំណត់ថា ក្លិនកើតហើយព្រោះតណ្ហា ។បេ។ បុគ្គលកំណត់នូវក្លិនខាងក្រៅ ដោយប្រការយ៉ាងនេះឯង ។

បុគ្គលកំណត់នូវរសខាងក្រៅ តើដូចម្ដេច ។ បុគ្គលកំណត់ថា រសកើតហើយព្រោះអវិជ្ជា កំណត់ថា រសកើតហើយព្រោះតណ្ហា ។បេ។ បុគ្គលកំណត់នូវរសខាងក្រៅ ដោយប្រការយ៉ាងនេះឯង ។

បុគ្គលកំណត់នូវផស្សៈខាងក្រៅ តើដូចម្តេច ។ បុគ្គលកំណត់ថា ផស្សៈកើតហើយព្រោះអវិជ្ជា កំណត់ថា ផស្សៈកើតហើយព្រោះតណ្ហា កំណត់ថា ផស្សៈកើតហើយព្រោះកម្ម កំណត់ថា ផស្សៈកើតហើយព្រោះអាហារ កំណត់ថា ផស្សៈកើតឡើងហើយ កំណត់ថា ផស្សៈតាំងឡើងហើយ ។បេ។ បុគ្គលកំណត់នូវផស្សៈខាងក្រៅ ដោយប្រការយ៉ាងនេះឯង ។

បុគ្គលកំណត់នូវធម៌ខាងក្រៅ តើដូចម្តេច ។ បុគ្គលកំណត់ថា ធម៌កើតហើយព្រោះអវិជ្ជា កំណត់ថា ធម៌កើតហើយព្រោះតណ្ហា កំណត់ថា ធម៌កើតហើយព្រោះកម្ម កំណត់ថា ធម៌កើតហើយព្រោះអាហារ កំណត់ថា ធម៌កើតឡើងហើយ កំណត់ថា ធម៌តាំងឡើងហើយ កំណត់ថា ធម៌ដែលមិនទាន់មានមានហើយ ដែលមានហើយ បែរជានឹងមិនមានវិញ កំណត់នូវធម៌ថា មានទីបំផុត កំណត់ថា ធម៌មិនមាំមួន មិនស្ថិតស្ថេរ មានសេចក្តីប្រែប្រួលជាធម្មតា កំណត់ថា ធម៌មិនទៀង ត្រូវបច្ច័យតាក់តែងកើតឡើងហើយ ព្រោះអាស្រ័យហេតុ មានការអស់ជាធម្មតា មានការសូន្យជាធម្មតា មានការសោយជាធម្មតា មានការរលត់ជាធម្មតា កំណត់នូវធម៌ថា មិនទៀង មិនកំណត់ថា ទៀង កំណត់ថា ជាទុក្ខ មិនកំណត់ថា ជាសុខ កំណត់ថា ជាអនត្តា មិនកំណត់ថា ជាអត្តា រមែងនឿយណាយ មិនត្រេកអរ ធុញទ្រាន់ មិនរីករាយ រម្ងាត់ មិនឲ្យកើតឡើង រមែងរលាស់ចោល មិនកាន់យក កាលកំណត់ថា មិនទៀង រមែងលះបង់នូវនិច្ចសញ្ញា កាលកំណត់ថា ជាទុក្ខ រមែងលះបង់នូវសុខសញ្ញា កាលកំណត់ថា ជាអនត្តា រមែងលះបង់នូវអត្តសញ្ញា កាលនឿយណាយ រមែងលះបង់

*នូវសេចក្តីរីករាយ កាលធុញទ្រាន់ រមែងលះបង់នូវរាគៈ កាលរម្ងាត់ រមែងលះបង់នូវការកើតឡើង កាលរលាស់ចោល រមែងលះបង់នូវសេចក្តីប្រកាន់មាំ បុគ្គលកំណត់នូវធម៌ខាងក្រៅ ដោយប្រការយ៉ាងនេះឯង ដែលឈ្មោះថាញាណ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងការកំណត់នូវអារម្មណ៍ខាងក្រៅ ឈ្មោះថា គោចរនានត្តញ្ញាណ ។*

# អដ្ឋកថា

## គោចរនានត្តញ្ញាណនិទ្ទេស

[ ១៦៣-១៦៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងគោចរនានត្តញ្ញាណនិទ្ទេសដូចតទៅ បទថា **រូបេ ពហិទ្ធា វវត្ថេតិ** សេចក្តីថា រមែងកំណត់រូបាយតនធម៌ ដែលជាខាងក្រៅអំពីខាងក្នុង ។ បទថា **អវិជ្ជាសម្ភូតា** ជាដើម លោកពោលហើយព្រោះកម្មជរូបទាក់ទងដោយអត្តភាព ។ ពិតហើយ សូម្បីអាហារ ក៏ជាបច្ច័យឧបត្ថម្ភកម្មជរូប ។ តែព្រោះសំឡេង មានឧតុ និងចិត្តជាសមុដ្ឋាន ទើបលោកមិនពោលដល់ធម៌ពួក ៤ មាន កើតហើយព្រោះអវិជ្ជាជាដើម ។ ព្រោះផោដ្ឋព្វៈជាមហាភូតរូបឯង ទើបលោកមិនពោលថា អាស្រ័យនូវមហាភូតរូប ៤ ។

ម្យ៉ាងទៀត ក្នុងបទថា **ធម្មា** នេះ បានដល់ ខន្ធមិនមានរូប ៣ ដែលប្រកបដោយចិត្តដែលជាភវង្គ សុខុមរូបដែលទាក់ទងក្នុងធម្មាយតនៈដែលមានកម្មជាសមុដ្ឋាន និងរូបជាដើមសូម្បីទាំងអស់ ។ ម្យ៉ាងវិញទៀត រូបណាមួយរមែងកើតឡើងដោយកម្មណាមួយ គប្បីជ្រាបរូបនោះៗ ដោយកម្មនោះៗ ។ ពិតហើយ បើពោលដោយប្រការដទៃក្រៅអំពីនេះ ធម៌ទាំងឡាយ មានរូបជាដើម សូម្បីទាក់ទងក្នុងសន្តានរបស់ខ្លួន ក៏មិនគប្បីសង្គ្រោះចូលទៅទាំងអស់ ។ ព្រោះសូម្បីរូប ដែលទាក់ទងដោយអនិន្ទ្រិយជាដើម ក៏ចូលដល់វិបស្សនាបាន ហេតុនោះគប្បីជ្រាបការសង្គ្រោះធម៌ទាំងនោះដោយបទថា **កម្មសម្ភូតំ** ។ ព្រោះសូម្បីធម៌ទាំងនោះ ក៏មានកម្មប្បច្ច័យ និងឧតុជាសមុដ្ឋាន ទូទៅដល់សព្វសត្វ តែអាចារ្យពួកដទៃពោលថា រូបជាដើម ដែលទាក់ទងដោយអនិន្ទ្រិយ ចូល

ដល់វិបស្សនាមិនបាន តែពាក្យនោះខុសអំពីបាលី ( ធម្មបទ ) ជាដើមថា

**សព្វេ សង្ខារា អនិច្ចាតិ យទា បញ្ញាយ បស្សតិ**

**អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។**

កាលណាបុគ្គលយល់ឃើញដោយប្រាជ្ញាថា សង្ខារទាំងពួង នាំមកនូវសេចក្ដីទុក្ខ ដូច្នេះ កាលណោះ រមែងនឿយណាយ ក្នុងសេចក្ដីទុក្ខ នេះជាផ្លូវនៃសេចក្ដីបរិសុទ្ធ ដូច្នេះ ។

ម្យ៉ាងទៀត ក្នុងវិសុទ្ធមគ្គពោលថា បុគ្គលពួកខ្លះ ក្នុងលោកនេះ ពិចារណាឃើញច្បាស់សង្ខារខាងក្នុងខ្លួន ។ តែព្រោះការចេញទៅអំពីមគ្គ រមែងមិនមាន ដោយត្រឹមតែឃើញខាងក្នុងសុទ្ធៗ ប៉ុណ្ណោះ សូម្បីខាងក្រៅ ក៏គប្បីឃើញផង ហេតុនោះ ព្រះយោគាវចរ រមែងឃើញច្បាស់ សូម្បីខន្ធនៃបុគ្គលដទៃ សូម្បីសង្ខារដែលជាអនុប្បាទិន្នកៈថា មិនទៀង ជាទុក្ខ ជាអនត្តា ព្រោះហេតុនេះ ហេតុនោះ ទើបគួរប្រាថ្នាសូម្បីការកំណត់ចក្ខុជាដើមរបស់បុគ្គលដទៃ សូម្បីការកំណត់រូបដែលទាក់ទងដោយអនិន្ទ្រិយជាដើម ហេតុនោះ សង្ខារដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា ចូលដល់វិបស្សនាមិនបាន រមែងមិនមាន ៕៚

**អដ្ឋកថាគោចរនានត្តញ្ញាណនិទ្ទេស ចប់**

# សុត្តន្តបិដក

[ ១៦៥ ] បញ្ញាក្នុងការកំណត់នូវចរិយា ឈ្មោះថា ចរិយានានត្តញាណ តើដូចម្តេច ។ ពាក្យថា ចរិយា បានដល់ ចរិយា ៣ យ៉ាង គឺវិញ្ញាណចរិយា ១ អញ្ញាណចរិយា ១ ញាណចរិយា ១ ។

វិញ្ញាណចរិយា តើដូចម្តេច ។ អាវជ្ជនកិរិយា ( កិរិយានៃការរំពឹង ) ជាអព្យាក្រឹត ដើម្បីប្រយោជន៍ដល់ការឃើញ ( នូវរូប ) ក្នុងរូបទាំងឡាយ ឈ្មោះថា វិញ្ញាណចរិយា ចក្ខុវិញ្ញាណ មានអត្ថថា សម្រាប់ឃើញ ( នូវរូប ) ក្នុងរូបទាំងឡាយ ឈ្មោះថា វិញ្ញាណចរិយា វិបាកមនោធាតុ សម្រាប់ឡើង ( កាន់អារម្មណ៍ ) ព្រោះភាពនៃអារម្មណ៍ដែលបុគ្គលឃើញក្នុងរូបទាំងឡាយ ឈ្មោះថា វិញ្ញាណចរិយា វិបាកមនោវិញ្ញាណធាតុ ព្រោះភាពនៃវិបាកមនោ-វិញ្ញាណធាតុឡើងកាន់អារម្មណ៍ក្នុងរូបទាំងឡាយ ឈ្មោះថា វិញ្ញាណចរិយា អាវជ្ជនកិរិយា ជាអព្យាក្រឹតដើម្បីប្រយោជន៍ដល់ការស្តាប់ ( នូវសំឡេង ) ក្នុងសំឡេងទាំងឡាយ ឈ្មោះថា វិញ្ញាណចរិយា សោតវិញ្ញាណ មានអត្ថថា សម្រាប់ឮ ( នូវសំឡេង ) ក្នុងសំឡេងទាំងឡាយ ឈ្មោះថា វិញ្ញាណចរិយា វិបាកមនោធាតុសម្រាប់ឡើង ( កាន់អារម្មណ៍ ) ព្រោះភាពនៃអារម្មណ៍ដែលបុគ្គលឮក្នុងសំឡេងទាំងឡាយ ឈ្មោះថា វិញ្ញាណចរិយា វិបាកមនោវិញ្ញាណ-ធាតុ ព្រោះភាពនៃវិបាកមនោវិញ្ញាណធាតុឡើងកាន់អារម្មណ៍ ក្នុងសំឡេងទាំងឡាយ ឈ្មោះថា វិញ្ញាណចរិយា អាវជ្ជនកិរិយាជាអព្យាក្រឹតដើម្បីប្រយោជន៍ដល់ការហិត ( នូវក្លិន ) ក្នុងក្លិនទាំងឡាយ ឈ្មោះថា វិញ្ញាណចរិយា ឃាន-វិញ្ញាណ មានអត្ថថា សម្រាប់ហិតក្លិនក្នុងក្លិនទាំងឡាយ ឈ្មោះថា វិញ្ញាណចរិយា

វិបាកមនោធាតុ សម្រាប់ឡើង ( កាន់អារម្មណ៍ ) ព្រោះភាពនៃអារម្មណ៍ដែលបុគ្គលហិតក្នុងក្លិនទាំងឡាយ ឈ្មោះថា វិញ្ញាណចរិយា វិបាកមនោវិញ្ញាណ-ធាតុ ព្រោះភាពនៃវិបាកមនោវិញ្ញាណធាតុ ឡើងកាន់អារម្មណ៍ក្នុងក្លិនទាំងឡាយ ឈ្មោះថា វិញ្ញាណចរិយា អាវជ្ជនកិរិយាជាអព្យាក្រឹតដើម្បីប្រយោជន៍ដល់ការលិទ្ធភ្លក្ស ( នូវរស ) ក្នុងរសទាំងឡាយ ឈ្មោះថា វិញ្ញាណចរិយា ជិវ្ហា-វិញ្ញាណ មានអត្ថថា សម្រាប់លិទ្ធភ្លក្សនូវរសទាំងឡាយ ឈ្មោះថា វិញ្ញាណ-ចរិយា វិបាកមនោធាតុ សម្រាប់ឡើង ( កាន់អារម្មណ៍ ) ព្រោះភាពនៃអារម្មណ៍ ដែលបុគ្គលលិទ្ធភ្លក្សនូវរសទាំងឡាយ ឈ្មោះថា វិញ្ញាណចរិយា វិបាកមនោវិញ្ញាណធាតុ ព្រោះភាពនៃវិបាកមនោវិញ្ញាណធាតុឡើង ( កាន់អារម្មណ៍ ) ក្នុងរសទាំងឡាយ ឈ្មោះថា វិញ្ញាណចរិយា អាវជ្ជនកិរិយាជាអព្យាក្រឹត ដើម្បីប្រយោជន៍ដល់ការប៉ះពាល់ ក្នុងផ្សព្វទាំងឡាយ ឈ្មោះថា វិញ្ញាណចរិយា កាយវិញ្ញាណ មានអត្ថថា សម្រាប់ពាល់ត្រូវ ( នូវផ្សព្វ ) ក្នុងផ្សព្វទាំងឡាយ ឈ្មោះថា វិញ្ញាណចរិយា វិបាកមនោធាតុ សម្រាប់ឡើង ( កាន់អារម្មណ៍ ) ព្រោះភាពនៃអារម្មណ៍ ដែលបុគ្គលពាល់ត្រូវក្នុងផ្សព្វទាំងឡាយ ឈ្មោះថា វិញ្ញាណចរិយា វិបាកមនោវិញ្ញាណធាតុ ព្រោះភាពនៃវិបាក-មនោវិញ្ញាណធាតុ ឡើងកាន់អារម្មណ៍ក្នុងផ្សព្វទាំងឡាយ ឈ្មោះថា វិញ្ញាណ-ចរិយា អាវជ្ជនកិរិយាជាអព្យាក្រឹត ដើម្បីប្រយោជន៍ដល់ការដឹងច្បាស់ ( នូវធម៌ ) ក្នុងធម៌ទាំងឡាយ ឈ្មោះថា វិញ្ញាណចរិយា មនោវិញ្ញាណធាតុ មានអត្ថថា សម្រាប់ដឹងច្បាស់ក្នុងធម៌ទាំងឡាយ ឈ្មោះថា វិញ្ញាណចរិយា

វិបាកមនោធាតុ សម្រាប់ឡើង ( កាន់អារម្មណ៍ ) ព្រោះភាពនៃអារម្មណ៍ ដែលបុគ្គលដឹងច្បាស់ក្នុងធម៌ទាំងឡាយ ឈ្មោះថា វិញ្ញាណចរិយា វិបាកមនោវិញ្ញាណធាតុ ព្រោះភាពនៃវិបាកមនោវិញ្ញាណធាតុ ឡើងកាន់អារម្មណ៍ក្នុងធម៌ទាំងឡាយ ឈ្មោះថា វិញ្ញាណចរិយា ។

[ ១៦៦ ] សំណួរត្រង់ពាក្យថា វិញ្ញាណចរិយា តើវិញ្ញាណចរិយាដោយអត្ថដូចម្តេច ។ ធម្មជាតណា មិនមានរាគៈ រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា វិញ្ញាណចរិយា ធម្មជាតណា មិនមានទោសៈ រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា វិញ្ញាណចរិយា ធម្មជាតណា មិនមានមោហៈ រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា វិញ្ញាណចរិយា ធម្មជាតណា មិនមានមានះ រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា វិញ្ញាណចរិយា ធម្មជាតណា មិនមានទិដ្ឋិ រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា វិញ្ញាណចរិយា ធម្មជាតណាមិនមានឧទ្ធច្ចៈ រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា វិញ្ញាណចរិយា ធម្មជាតណា មិនមានវិចិកិច្ឆា រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា វិញ្ញាណចរិយា ធម្មជាតណា មិនមានអនុស័យ រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា វិញ្ញាណចរិយា ធម្មជាតណា ប្រាសចាករាគៈ រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា វិញ្ញាណចរិយា ធម្មជាតណា ប្រាសចាកទោសៈ រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា វិញ្ញាណចរិយា ធម្មជាតណា ប្រាសចាកមោហៈ រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា វិញ្ញាណចរិយា ធម្មជាតណា ប្រាសចាកមានះ រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា

វិញ្ញាណចរិយា ធម្មជាតណា ប្រាសចាកទិដ្ឋិ រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា វិញ្ញាណចរិយា ធម្មជាតណា ប្រាសចាកឧទ្ធច្ចៈ រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា វិញ្ញាណចរិយា ធម្មជាតណា ប្រាសចាកវិចិកិច្ឆា រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា វិញ្ញាណចរិយា ធម្មជាតណា ប្រាសចាកអនុស័យ រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា វិញ្ញាណចរិយា ធម្មជាតណា ប្រាសចាកកម្មជាកុសល រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា វិញ្ញាណចរិយា ធម្មជាតណា ប្រាសចាកកម្មជាអកុសល រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា វិញ្ញាណចរិយា ធម្មជាតណា ប្រាសចាកកម្មប្រកបដោយទោស រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា វិញ្ញាណចរិយា ធម្មជាតណា ប្រាសចាកកម្មមិនមានទោស រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា វិញ្ញាណចរិយា ធម្មជាតណា ប្រាសចាកកម្មខ្មៅ រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា វិញ្ញាណចរិយា ធម្មជាតណា ប្រាសចាកកម្ម-ស រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា វិញ្ញាណចរិយា ធម្មជាតណា ប្រាសចាកកម្មដែលចម្រើនដោយសេចក្តីសុខ រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា វិញ្ញាណចរិយា ធម្មជាតណា ប្រាសចាកកម្មដែលចម្រើនដោយសេចក្តីទុក្ខ រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា វិញ្ញាណចរិយា ធម្មជាតណា ប្រាសចាកកម្មមានផលជាសុខ រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា វិញ្ញាណចរិយា ធម្មជាតណា ប្រាសចាកកម្មមានផលជាទុក្ខ រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា វិញ្ញាណចរិយា ធម្មជាតណា រមែងប្រព្រឹត្ត

ទៅក្នុងអារម្មណ៍ដែលខ្ជិនជីន ធម្មជាតនោះ ឈ្មោះថា វិញ្ញាណចរិយា ចរិយា របស់វិញ្ញាណមានសភាពយ៉ាងនេះ ហេតុនោះ ឈ្មោះថា វិញ្ញាណចរិយា ចិត្តនេះ បរិសុទ្ធជាប្រក្រតី ដោយអត្ថថា មិនមានកិលេស ហេតុនោះ ឈ្មោះថា វិញ្ញាណចរិយា នេះវិញ្ញាណចរិយា ។

[ ១៦៧ ] អញ្ញាណចរិយា តើដូចម្តេច ។ អាវជ្ជនកិរិយាជាអព្យាក្រឹត ដើម្បីប្រយោជន៍ដល់ការស្ទុះទៅ ឬលឿនទៅរបស់រាគៈក្នុងរូបទាំងឡាយជាទីពេញចិត្ត ឈ្មោះថា វិញ្ញាណចរិយា ការស្ទុះទៅរបស់រាគៈ ឈ្មោះថា អញ្ញាណចរិយា អាវជ្ជនកិរិយាជាអព្យាក្រឹត ដើម្បីប្រយោជន៍ដល់ការស្ទុះទៅរបស់ទោសៈក្នុងរូបទាំងឡាយមិនជាទីពេញចិត្ត ឈ្មោះថា វិញ្ញាណចរិយា ការស្ទុះទៅរបស់ទោសៈ ឈ្មោះថា អញ្ញាណចរិយា អាវជ្ជនកិរិយាជាអព្យាក្រឹតដើម្បីប្រយោជន៍ដល់ការស្ទុះទៅរបស់មោហៈ ក្នុងវត្ថុមិនគួរក្រឡេកមើល ដោយហេតុទាំងពីរនោះ ឈ្មោះថា វិញ្ញាណចរិយា ការស្ទុះទៅរបស់មោហៈ ឈ្មោះថា អញ្ញាណចរិយា អាវជ្ជនកិរិយាជាអព្យាក្រឹត ដើម្បីប្រយោជន៍ដល់ការស្ទុះទៅរបស់មានះ ជាគ្រឿងចាក់ស្រែះ ឈ្មោះថា វិញ្ញាណចរិយា ការស្ទុះទៅរបស់មានះ ឈ្មោះថា អញ្ញាណចរិយា អាវជ្ជនកិរិយាជាអព្យាក្រឹត ដើម្បីប្រយោជន៍ដល់ការស្ទុះទៅនៃទិដ្ឋិ ជាកិលេសស្ទាបអង្អែល ឈ្មោះថា វិញ្ញាណចរិយា ការស្ទុះទៅរបស់ទិដ្ឋិ ឈ្មោះថា អញ្ញាណចរិយា អាវជ្ជនកិរិយាជាអព្យាក្រឹត ដើម្បីប្រយោជន៍ដល់ការស្ទុះទៅរបស់ឧទ្ធច្ចៈ ដែលរវើរវាយ ឈ្មោះថា វិញ្ញាណចរិយា ការស្ទុះទៅរបស់ឧទ្ធច្ចៈ ឈ្មោះថា

អញ្ញាណចរិយា អាវជ្ជនកិរិយាជាអព្យាក្រឹត ដើម្បីប្រយោជន៍ដល់ការស្ទុះទៅរបស់វិចិកិច្ឆា ដែលដល់នូវសេចក្តីមិនដាច់ស្រេច ឈ្មោះថា វិញ្ញាណចរិយា ការស្ទុះទៅរបស់វិចិកិច្ឆា ឈ្មោះថា អញ្ញាណចរិយា អាវជ្ជនកិរិយាជាអព្យាក្រឹត ដើម្បីប្រយោជន៍ដល់ការស្ទុះទៅរបស់អនុស័យដែលមានកម្លាំង ឈ្មោះថា វិញ្ញាណចរិយា ការស្ទុះទៅរបស់អនុស័យ ឈ្មោះថា អញ្ញាណចរិយា អាវជ្ជនកិរិយាជាអព្យាក្រឹត ដើម្បីប្រយោជន៍ដល់ការស្ទុះទៅរបស់រាគៈ ក្នុងសំឡេងទាំងឡាយជាទីពេញចិត្ត ។បេ។ ក្នុងក្លិនទាំងឡាយជាទីពេញចិត្ត ក្នុងរសទាំងឡាយជាទីពេញចិត្ត ក្នុងផ្សព្វទាំងឡាយជាទីពេញចិត្ត ក្នុងធម្មារម្មណ៍ទាំងឡាយជាទីពេញចិត្ត ឈ្មោះថា វិញ្ញាណចរិយា ការស្ទុះទៅរបស់រាគៈ ឈ្មោះថា អញ្ញាណចរិយា អាវជ្ជនកិរិយាជាអព្យាក្រឹត ដើម្បីប្រយោជន៍ដល់ការស្ទុះទៅរបស់ទោសៈ ក្នុងធម្មារម្មណ៍ទាំងឡាយមិនជាទីពេញចិត្ត ឈ្មោះថា វិញ្ញាណចរិយា ការស្ទុះទៅរបស់ទោសៈ ឈ្មោះថា អញ្ញាណចរិយា អាវជ្ជនកិរិយាជាអព្យាក្រឹត ដើម្បីប្រយោជន៍ដល់ការស្ទុះទៅរបស់មោហៈ ក្នុងវត្ថុមិនគួរក្រឡេកមើលដោយហេតុទាំងពីរនោះ ឈ្មោះថា វិញ្ញាណចរិយា ការស្ទុះទៅរបស់មោហៈ ឈ្មោះថា អញ្ញាណចរិយា អាវជ្ជនកិរិយាជាអព្យាក្រឹត ដើម្បីប្រយោជន៍ដល់ការស្ទុះទៅរបស់ទិដ្ឋិ ជាធម្មជាតស្ទាបអង្អែល ឈ្មោះថា វិញ្ញាណចរិយា ការស្ទុះទៅរបស់ទិដ្ឋិ ឈ្មោះថា អញ្ញាណចរិយា អាវជ្ជនកិរិយាជាអព្យាក្រឹត ដើម្បីប្រយោជន៍ដល់ការស្ទុះទៅរបស់ឧទ្ធច្ចៈ ជាកិលេសរវើរវាយ ឈ្មោះថា វិញ្ញាណចរិយា ការស្ទុះទៅរបស់ឧទ្ធច្ចៈ ឈ្មោះ

ថា អញ្ញាណចរិយា អាវជ្ជនកិរិយាជាអព្យាក្រឹត ដើម្បីប្រយោជន៍ដល់ការស្ទុះទៅរបស់វិចិកិច្ឆាដែលដល់នូវសេចក្តីមិនដាច់ស្រេច ឈ្មោះថា វិញ្ញាណចរិយា ការស្ទុះទៅរបស់វិចិកិច្ឆា ឈ្មោះថា អញ្ញាណចរិយា អាវជ្ជនកិរិយាជាអព្យាក្រឹត ដើម្បីប្រយោជន៍ដល់ការស្ទុះទៅរបស់អនុស័យដែលមានកម្លាំង ឈ្មោះថា វិញ្ញាណចរិយា ការស្ទុះទៅរបស់អនុស័យ ឈ្មោះថា អញ្ញាណចរិយា ។

[ ១៦៨ ] សំណួរត្រង់ពាក្យថា អញ្ញាណចរិយា តើអញ្ញាណចរិយាដោយអត្ថថាដូចម្តេច ។ ធម្មជាតណាប្រកបដោយរាគៈ រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា អញ្ញាណចរិយា ធម្មជាតណា ប្រកបដោយទោសៈ រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា អញ្ញាណចរិយា ធម្មជាតណា ប្រកបដោយមោហៈ រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា អញ្ញាណចរិយា ធម្មជាតណា ប្រកបដោយមានះ រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា អញ្ញាណចរិយា ធម្មជាតណា ប្រកបដោយទិដ្ឋិ រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា អញ្ញាណចរិយា ធម្មជាតណា ប្រកបដោយឧទ្ធច្ចៈ រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា អញ្ញាណចរិយា ធម្មជាតណា ប្រកបដោយវិចិកិច្ឆា រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា អញ្ញាណចរិយា ធម្មជាតណា ប្រកបដោយអនុស័យ រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា អញ្ញាណចរិយា ធម្មជាតណា ប្រកបព្រមដោយរាគៈ រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា អញ្ញាណចរិយា ធម្មជាតណា ប្រកបព្រមដោយទោសៈ រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា អញ្ញាណចរិយា ធម្មជាត

ណា ប្រកបព្រមដោយមោហៈ រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា អញ្ញាណចរិយា ធម្មជាតណា ប្រកបព្រមដោយមានះ រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា អញ្ញាណចរិយា ធម្មជាតណា ប្រកបព្រមដោយទិដ្ឋិ រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា អញ្ញាណចរិយា ធម្មជាតណា ប្រកបព្រមដោយឧទ្ធច្ចៈ រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា អញ្ញាណចរិយា ធម្មជាតណា ប្រកបព្រមដោយវិចិកិច្ឆា រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា អញ្ញាណចរិយា ធម្មជាតណា ប្រកបព្រមដោយអនុស័យ រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា អញ្ញាណចរិយា ធម្មជាតណា ប្រាសចាកកម្មជាកុសល រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា អញ្ញាណចរិយា ធម្មជាតណា ប្រកបព្រមដោយកម្មជាអកុសល រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា អញ្ញាណចរិយា ធម្មជាតណា ប្រកបព្រមដោយកម្មមានទោស រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា អញ្ញាណ-ចរិយា ធម្មជាតណា ប្រាសចាកកម្មមិនមានទោស រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា អញ្ញាណចរិយា ធម្មជាតណា ប្រកបព្រមដោយកម្មខ្មៅ រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា អញ្ញាណចរិយា ធម្មជាតណា ប្រាសចាកកម្ម-ស រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា អញ្ញាណចរិយា ធម្មជាតណា ប្រាសចាកកម្មដែលចម្រើនដោយសេចក្តីសុខ រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា អញ្ញាណចរិយា ធម្មជាតណា ប្រកបព្រមដោយកម្មដែលចម្រើនដោយសេចក្តីទុក្ខ រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា

អញ្ញាណចរិយា ធម្មជាតណា ប្រាសចាកកម្មមានផលជាសុខ រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា អញ្ញាណចរិយា ធម្មជាតណា ប្រកបព្រមដោយកម្មមានផលជាទុក្ខ រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា អញ្ញាណ-ចរិយា ធម្មជាតណា រមែងប្រព្រឹត្តទៅក្នុងហេតុដែលខ្លួនមិនដឹង ធម្មជាតនោះឈ្មោះថា អញ្ញាណចរិយា ចរិយារបស់អញ្ញាណ ( សេចក្តីមិនដឹង ) មានសភាពយ៉ាងនេះ ហេតុនោះ ឈ្មោះថា អញ្ញាណចរិយា នេះឈ្មោះថា អញ្ញាណចរិយា ។

[ ១៦៩ ] ញាណចរិយា តើដូចម្តេច ។ អាវជ្ជនកិរិយា ជាអព្យាក្រឹត ដើម្បីប្រយោជន៍ ដល់អនិច្ចានុបស្សនា ( ការពិចារណាឃើញថាមិនទៀង ) ឈ្មោះថា វិញ្ញាណចរិយា តួអនិច្ចានុបស្សនា ឈ្មោះថា ញាណចរិយា អាវជ្ជនកិរិយាជាអព្យាក្រឹត ដើម្បីប្រយោជន៍ដល់ទុក្ខានុបស្សនា ( ការពិចា-រណាឃើញថាជាទុក្ខ ) ឈ្មោះថា វិញ្ញាណចរិយា តួទុក្ខានុបស្សនា ឈ្មោះថា ញាណចរិយា អាវជ្ជនកិរិយា ជាអព្យាក្រឹត ដើម្បីប្រយោជន៍ដល់អនត្តានុបស្សនា (ការពិចារណាឃើញថាជាអនត្តា ) ឈ្មោះថា វិញ្ញាណចរិយា តួអនត្តានុ-បស្សនា ឈ្មោះថា ញាណចរិយា អាវជ្ជនកិរិយាជាអព្យាក្រឹត ដើម្បីប្រ-យោជន៍ដល់និព្វិទានុបស្សនា ( ការពិចារណាឃើញថាគួរនឿយណាយ ) ។បេ។ ដើម្បីប្រយោជន៍ដល់វិរាគានុបស្សនា ( ការពិចារណាឃើញថាប្រាសចាករាគៈ ) ដើម្បីប្រយោជន៍ដល់និរោធានុបស្សនា ( ការពិចារណាឃើញនូវការរលត់ ) ដើម្បីប្រយោជន៍ដល់បដិនិស្សគ្គានុបស្សនា ( ការពិចារណា

ឃើញថាគួររលាស់ចេញ ) ដើម្បីប្រយោជន៍ដល់ខយានុបស្សនា ( ការពិចារណាឃើញនូវការអស់ ) ដើម្បីប្រយោជន៍ដល់វយានុបស្សនា ( ការពិចារណាឃើញនូវការសូន្យ ) ដើម្បីប្រយោជន៍ដល់វិបរិណាមានុបស្សនា ( ការពិចារណាឃើញនូវការប្រែប្រួល ) ដើម្បីប្រយោជន៍ដល់អនិមិត្តានុបស្សនា ( ការពិចារណាឃើញថាសង្ខារមិនមានកំណត់ ) ដើម្បីប្រយោជន៍ដល់អប្បណិហិតានុបស្សនា ( ការពិចារណាឃើញថាសង្ខារមិនមានទីតម្កល់មាំ ) ដើម្បីប្រយោជន៍ដល់សុញ្ញតានុបស្សនា ( ការពិចារណាឃើញថាសង្ខារសូន្យ ) ដើម្បីប្រយោជន៍ដល់អធិប្បញ្ញាធម្មានុបស្សនា ( ការពិចារណានូវធម៌ដោយបញ្ញាដ៏ក្រៃលែង ) ដើម្បីប្រយោជន៍ដល់យថាភូតញ្ញាណទស្សនៈ ( ការឃើញដោយញាណតាមសេចក្តីពិត ) ដើម្បីប្រយោជន៍ដល់អាទីនវានុបស្សនា ( ការពិចារណាឃើញថាជាទោស ) ដើម្បីប្រយោជន៍ដល់បដិសង្ខានុបស្សនា ( ការពិចារណាឃើញដោយឧបាយបញ្ញា ) ឈ្មោះថា វិញ្ញាណចរិយា តួបដិសង្ខានុបស្សនា ឈ្មោះថា ញាណចរិយា វិវដ្តនានុបស្សនា ឈ្មោះថា ញាណចរិយា សោតាបត្តិមគ្គ ឈ្មោះថា ញាណចរិយា សោតាបត្តិផលសមាបត្តិ ឈ្មោះថា ញាណចរិយា សកទាគាមិមគ្គ ឈ្មោះថា ញាណចរិយា សកទាគាមិផលសមាបត្តិ ឈ្មោះថា ញាណចរិយា អនាគាមិមគ្គ ឈ្មោះថា ញាណចរិយា អនាគាមិផលសមាបត្តិ ឈ្មោះថា ញាណចរិយា អរហត្តមគ្គ ឈ្មោះថា ញាណចរិយា អរហត្តផលសមាបត្តិ ឈ្មោះថា ញាណចរិយា ។

[ ១៧០ ] សំណួរត្រង់ពាក្យថា ញាណចរិយា តើញាណចរិយាដោយអត្ថដូចម្តេច ។ ធម្មជាតណា មិនមានរាគៈ រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា ញាណចរិយា ធម្មជាតណា មិនមានទោសៈ រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា ញាណចរិយា ។បេ។ ធម្មជាតណា មិនមានអនុស័យ រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា ញាណចរិយា ធម្មជាតណា ប្រាសចាករាគៈ រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា ញាណចរិយា ធម្មជាតណា ប្រាសចាកទោសៈ រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា ញាណចរិយា ធម្មជាតណា ប្រាសចាកមោហៈ រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា ញាណចរិយា ធម្មជាតណា ប្រាសចាកមានះ ។បេ។ ធម្មជាតណា ប្រាសចាកទិដ្ឋិ ប្រាសចាកឧទ្ធច្ចៈ ប្រាសចាកវិចិកិច្ឆា ប្រាសចាកអនុស័យ ប្រកបព្រមដោយកម្មជាកុសល ប្រាសចាកកម្មជាអកុសល ប្រាសចាកកម្មមានទោស ប្រកបព្រមដោយកម្មមិនមានទោស ប្រាសចាកកម្មខ្មៅប្រកបព្រមដោយកម្ម-ស ប្រកបព្រមដោយកម្មដែលចម្រើនដោយសេចក្តីសុខ ប្រាសចាកកម្មដែលចម្រើនដោយសេចក្តីទុក្ខ ប្រកបព្រមដោយកម្មមានផលជាសុខ រមែងប្រព្រឹត្តទៅធម្មជាតនោះ ឈ្មោះថា ញាណចរិយា ធម្មជាតណា ប្រាសចាកកម្មមានផលជាទុក្ខ រមែងប្រព្រឹត្តទៅ ធម្មជាតនោះ ឈ្មោះថា ញាណ-ចរិយា ធម្មជាតណា ប្រព្រឹត្តទៅក្នុងញាណ ធម្មជាតនោះ ឈ្មោះថា ញាណ-ចរិយា ចរិយារបស់ញាណមានសភាពយ៉ាងនេះ ហេតុនោះ ឈ្មោះថា ញាណ-ចរិយា នេះឈ្មោះថា ញាណចរិយា ។ វិញ្ញាណចរិយា អញ្ញាណចរិយា

ញ្ញាណចរិយា ( យ៉ាងនេះឯង ) ។ ដែលឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងការកំណត់នូវចរិយា ឈ្មោះថា ចរិយា-នានត្តញ្ញាណ ។

# អដ្ឋកថា

## ចរិយានានត្តញ្ញាណនិទ្ទេស

[ ១៦៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងចរិយានានត្តញ្ញាណនិទ្ទេសដូចតទៅនេះ ក្នុងបទថា **វិញ្ញាណចរិយា** ជាដើម មានវិគ្គហៈដូចតទៅ ឈ្មោះថា **ចរិយា** ព្រោះអត្ថថា ប្រព្រឹត្តទៅក្នុងអារម្មណ៍ ចរិយា គឺវិញ្ញាណ ឈ្មោះថា **វិញ្ញាណចរិយា** ។

ឈ្មោះថា **អញ្ញាណចរិយា** ព្រោះអត្ថថា ប្រព្រឹត្តទៅដោយការមិនដឹង ឬប្រព្រឹត្តទៅ ព្រោះការមិនដឹង ឬប្រព្រឹត្តទៅក្នុងអារម្មណ៍ដែលមិនដឹង ឬការប្រព្រឹត្តទៅនៃភាពមិនដឹង ។ ឈ្មោះថា **ញាណចរិយា** ចរិយា គឺញាណ ឈ្មោះថា ញាណចរិយា ព្រោះអត្ថថា ការប្រព្រឹត្តទៅដោយញាណ ឬរមែងប្រព្រឹត្តទៅព្រោះញាណ ឬរមែងប្រព្រឹត្តទៅក្នុងអារម្មណ៍ដែលដឹងហើយ ឬការប្រព្រឹត្តទៅនៃការដឹង ។

បទថា **ទស្សនត្ថាយ** បានដល់ ប្រព្រឹត្តទៅ ដើម្បីឃើញរូប ។ បទថា **អាវជ្ជនកិរិយាព្យាកតា** មានវិគ្គហៈថា ឈ្មោះថា អាវជ្ជនៈ ព្រោះអត្ថថា នាំចេញទៅចាកសន្តានដែលជាភវង្គហើយរំពឹង គឺបង្អោនទៅកាន់ចិត្តសន្តានក្នុងរូបារម្មណ៍ ។ ឈ្មោះថា **កិរិយា** ព្រោះអត្ថថា ត្រឹមតែការធ្វើ ដ្បិតមិនមានវិបាក ។ ឈ្មោះថា **អព្យាកតា** ព្រោះអត្ថថា ប្រាប់មិនបានថា ជាកុសល ឬអកុសល ។

បទថា **ទស្សនដ្ឋោ** មានវិគ្គហៈថា ឈ្មោះថា **ទស្សនៈ** ព្រោះអត្ថថា ជា

*ហេតុឃើញ ឬឃើញឯង ឬវត្ថុនោះត្រឹមតែការឃើញប៉ុណ្ណោះ ។ ប្រយោជន៍គឺការឃើញ ឈ្មោះថា* **ទស្សនត្ថោ។** *បទថា* **ចក្ខុវិញ្ញាណំ** *បានដល់ កុសលវិបាក ឬអកុសលវិបាក ។ បទថា* **ទិដ្ឋត្តា** *បានដល់ ព្រោះឃើញរូបារម្មណ៍ដោយចក្ខុវិញ្ញាណ ព្រោះមិនមានការទទួលអារម្មណ៍ដែលមិនឃើញ ។*

*បទថា* **អភិនិរោបនា វិបាកមនោធាតុ** *មានវិគ្គហៈថា សម្បដិច្ឆន្នមនោធាតុដែលជាវិបាកទាំង ២ ឈ្មោះថា* **អភិនិរោបនា** *ព្រោះអត្ថថា លើកឡើងកាន់អារម្មណ៍ដែលឃើញហើយនោះឯង ។*

*បទថា* **អភិនិរោបិតត្តា** *បានដល់ ព្រោះមនោធាតុឡើងកាន់រូបារម្មណ៍ ។ បទថា* **វិបាកមនោវិញ្ញាណធាតុ** *បានដល់ សន្តីរណមនោវិញ្ញាណធាតុដែលជាវិបាកទាំងពីរ ។ សូម្បីក្នុងសោតទ្វារជាដើម ក៏មានន័យនេះ សូម្បីលោកមិនពោលដល់វោដ្ឋព្វនៈក្នុងលំដាប់សន្តីរណៈ ក៏គប្បីកាន់យកថាមាន ព្រោះព្រះអដ្ឋកថាចារ្យពោលហើយ ។ បទថា* **វិជាននត្ថាយ** *បានដល់ ដើម្បីដឹងច្បាស់ធម្មារម្មណ៍ និងរូបារម្មណ៍ជាដើម ។ បទថា* **អាវជ្ជនកិរិយាព្យាកតា** *បានដល់ មនោទ្វារាវជ្ជនចិត្ត ។ បទថា* **វិជាននដ្ឋោ** *សេចក្តីថា ការដឹងច្បាស់អារម្មណ៍ដោយអំណាចចិត្តស្ទុះទៅ ក្នុងលំដាប់អាវជ្ជនៈនោះជាអត្ថ មិនមែនដទៃ ។ ព្រោះលោកពោលដល់ជវនចិត្តជាអកុសល និងជវនចិត្តដែលជាវិបស្សនា មគ្គ និងផល ដោយឡែកហើយក្នុងខាងមុខ ក្នុងទីនេះ គួរកាន់យកជវនចិត្តដ៏សេស ។ តែគួរកាន់យកជវនដែលជាហសិតុប្បាទចិត្តនោះឯងដោយពាក្យជាដើមថា ធម្មជាតណា ប្រាសចាកកម្មជាកុសល រមែងប្រព្រឹត្តទៅ*

ធម្មជាតនោះ ឈ្មោះថា វិញ្ញាណចរិយា ។ ព្រោះលោកពោលអហេតុកចិត្ត ប៉ុណ្ណោះក្នុងទ្វារ ៦ គប្បីជ្រាបថា អហេតុកចិត្ត ១៨ នោះឯង គឺអាវជ្ជនចិត្ត ២ ទ្វិបញ្ចវិញ្ញាណចិត្ត ១០ សម្បដិច្ឆន្នចិត្ត ២ សន្តីរណចិត្ត ៣ ហសិតុប្បាទចិត្ត ១ ជាវិញ្ញាណចរិយា ។

[ ១៦៦ ] ឥឡូវនេះ ព្រះសារីបុត្តត្ថេរដើម្បីសម្តែងថា ឈ្មោះថា វិញ្ញាណ-ចរិយា ព្រោះអត្ថថា ត្រឹមតែដឹងច្បាស់អារម្មណ៍ ទើបពោលបទថា **នីរាគា ចរតិ** ដូច្នេះជាដើម ។ ពិតហើយ វិញ្ញាណរមែងដល់នូវការកំណត់ដទៃក្នុងការប្រកបដោយរាគៈជាដើម និងក្នុងការប្រកបដោយសទ្ធាជាដើម កាលមិនមានការប្រកបទាំងនោះ វិញ្ញាណរមែងតាំងនៅក្នុងទីតាំងរបស់ខ្លួននោះឯង ព្រោះហេតុនោះ ទើបព្រះសារីបុត្តត្ថេរ សម្តែងត្រឹមតែកិច្ចរបស់វិញ្ញាណនៃវិញ្ញាណដែលលោកពោលហើយនោះ ដោយពាក្យថា **នីរាគា** ជាដើម ។ ឈ្មោះថា **នីរាគ** ព្រោះអត្ថថា វិញ្ញាណចរិយានេះមិនមានរាគៈ ។ អាចារ្យពួកខ្លះពោលធ្វើជារស្សៈថា **និរាគា** ។

ម្យ៉ាងទៀត សភាវៈនោះ ឈ្មោះថា រាគៈ ដោយអំណាចនៃតម្រេក ។ បណ្តាបទក្រៅអំពីនេះ ឈ្មោះថា ទោសៈ ដោយអំណាចនៃការប្រទូស្ត ។ ឈ្មោះថា មោហៈ ដោយអំណាចការវង្វេង ។ ឈ្មោះថា មានៈ ដោយអំណាចការលើកខ្លួន ។ ឈ្មោះថា ទិដ្ឋិ ដោយអំណាចការយល់ខុស ។ ការរាយមាយ ឬការមិនស្ងប់ ឈ្មោះថា **ឧទ្ធច្ច** ។ វិចិកិច្ឆាមានអត្ថដូចបានពោលហើយ ។ ឈ្មោះថា អនុស័យ ព្រោះអត្ថថា ដេកត្រាំក្នុងសន្តាន ។ កាលគួរពោលថា និរនុសយា

លោកពោលថា **ឆានុសយា** ឯសេចក្ដីដូចគ្នានោះឯង ។ ក្នុងបទនេះគប្បីជ្រាបថា ការមិនមានកិលេសយ៉ាងកណ្ដាល ដែលដល់នូវការគ្របសង្កត់ ។ ពិតហើយ លោកមិនបានពោលដល់វិញ្ញាណចរិយា របស់លោកអ្នកលះអនុស័យបានហើយ ។ ព្រះសារីបុត្តត្ថេរដើម្បីសម្ដែងបរិយាយដទៃថា វិញ្ញាណចរិយាណាមានឈ្មោះថា **នីរាគា** ជាដើម វិញ្ញាណចរិយានោះ ឈ្មោះថា មិនប្រកបដោយរាគៈជាដើម ទើបពោលពាក្យថា **រាគវិប្បយុត្តា** ជាដើម ។ ម្យ៉ាងទៀតដើម្បីសម្ដែងទៀតថា វិញ្ញាណចរិយា មិនប្រកបដោយធម៌ពួកដទៃ ទើបពោលពាក្យថា **កុសលេហិ កម្មេហិ** ជាដើម ។ កុសលនោះឯងជាកម្មមិនមានទោស ព្រោះមិនមានទោស មានរាគៈជាដើម ។ ឈ្មោះថា **សុក្កានិ** ព្រោះប្រកបដោយហិរិឪត្តប្បៈដែលធ្វើភាពជាអ្នកបរិសុទ្ធ ។ ឈ្មោះថា **សុខុទ្រយានិ** ព្រោះអត្ថថា ការកើតឡើង ការឧប្បត្តិកនៃកម្មទាំងនោះជាសុខ ព្រោះមានសុខប្រព្រឹត្តទៅ ។ ម្យ៉ាងទៀត ឈ្មោះថា **សុខុទ្រយានិ** ព្រោះអត្ថថា ការកើតឡើង ការចម្រើននៃកម្មទាំនោះជាសុខ ព្រោះមានសុខជាវិបាក ។ គប្បីប្រកបអកុសល ដោយផ្ទុយគ្នាតាមដែលពោលហើយ ។

បទថា **វិញ្ញាតេ ចរតិ** សេចក្ដីថា អារម្មណ៍ដែលដឹងច្បាស់ដោយវិញ្ញាណឈ្មោះថា ដឹងច្បាស់ហើយ ក្នុងអារម្មណ៍ដែលដឹងច្បាស់ហើយនោះ ។ មានពាក្យអធិប្បាយដូចម្ដេច មានពាក្យអធិប្បាយថា វត្ថុដែលដឹងច្បាស់ហើយព្រោះប្រកបដោយវិញ្ញាណ រមែងបានឈ្មោះថា វិញ្ញាណ ដូចសំពត់មានពណ៌ខៀវ ព្រោះប្រកបដោយពណ៌ខៀវ ទើបហៅថា សំពត់ខៀវ ធម្មជាត

ណា រមែងត្រាច់ទៅក្នុងវិញ្ញាណនោះ ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា វិញ្ញាណចរិយា ។

បទថា **វិញ្ញាណស្ស ឯវរូបា ចរិយា ហោតិ** សេចក្ដីថា វិញ្ញាណមានប្រការដូចពោលហើយ រមែងមានការប្រព្រឹត្ត មានប្រការដូចបានពោលហើយ ។ម្យ៉ាងទៀត លោកពោលដោយវោហារថា ការប្រព្រឹត្តនៃវិញ្ញាណ តែមិនមានការប្រព្រឹត្តដោយឡែកអំពីវិញ្ញាណ ។ បទថា **បកតិបរិសុទ្ធមិទំ ចិត្តំ និក្កិលេសដ្ឋេន** បានដល់ ចិត្តមានប្រការដូចពោលហើយនេះ បរិសុទ្ធដោយប្រក្រតីនោះឯង ព្រោះមិនមានកិលេស មានរាគៈជាដើម ។ ព្រោះហេតុនោះ ទើបលោកពោលថា ឈ្មោះថា វិញ្ញាណចរិយា ព្រោះអត្ថថា ប្រព្រឹត្តត្រឹមតែដឹងប៉ុណ្ណោះ ។ បាឋៈថា **និក្កេសដ្ឋេន** ( ដោយអត្ថថា មិនមានកិលេស ) ក៏មាន ។

[ ១៦៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអញ្ញាណចរិយា ដូចតទៅនេះ បទថា **មនាបិយេសុ** មានវិគ្គហៈថា ឈ្មោះថា ជាទីពេញចិត្ត ព្រោះអត្ថថា ឆ្អែតជ្រះថ្លាក្នុងចិត្ត ឬញុំាងចិត្តឲ្យឆ្អែត ឲ្យចម្រើន ។ ការញុំាងចិត្តឲ្យឆ្អែតនោះឯង ឈ្មោះថា ជាទីពេញចិត្ត ។ ក្នុងរូបដែលជាទីឆ្អែតនោះ ។ ឯរូបទាំងនោះ រូបដែលគួរប្រាថ្នាក្ដី មិនគួរប្រាថ្នាក្ដី ឈ្មោះថា ជាទីពេញចិត្តដោយការកំណត់ ។ ដ្បិតថា រាគៈ រមែងកើតឡើងក្នុងរូបដែលគួរប្រាថ្នាប៉ុណ្ណោះក៏មិនមែន ទោសៈក៏រមែងកើតឡើងក្នុងរូបដែលមិនគួរប្រាថ្នាប៉ុណ្ណោះ ក៏មិនមែន ។

បទថា **រាគស្ស ជវនត្ថាយ** បានដល់ ប្រព្រឹត្តទៅដើម្បីការស្ទុះទៅនៃរាគៈ

ដោយអំណាចការបន្ត ។ បទថា **អាវជ្ជនកិរិយាព្យាកតា** បានដល់ មនោធាតុដែលជាកិរិយាព្យាកតៈដែលនឹករាវរក ដែលមិនមានយោនិសោមនសិការក្នុងចក្ខុទ្វារ ។ បទថា **រាគស្ស ជវនា** បានដល់ រាគៈប្រព្រឹត្តទៅ ៧ ដងដោយច្រើន គឺរាគៈដែលប្រព្រឹត្តទៅរឿយៗ នោះឯង ។ បទថា **អញ្ញាណចរិយា** លោកអធិប្បាយថា ការប្រព្រឹត្តនៃរាគៈដោយការមិនដឹង ព្រោះរាគៈកើតដោយការមិនដឹង ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។

បទថា **តទុភយេន អសមបេក្ខនស្មឹ វត្ថុស្មឹ** បានដល់ ក្នុងវត្ថុ ពោលគឺរូបារម្មណ៍ វៀរចាកការសម្លឹង ដោយអំណាចនៃរាគៈ និងទោសៈ ។ បទថា **មោហស្ស ជវនត្ថាយ** បានដល់ ដើម្បីស្ទុះទៅនៃមោហៈ ដោយអំណាចនៃវិចិកិច្ឆា និងឧទ្ធច្ចៈ ។ បទថា **អញ្ញាណចរិយា** បានដល់ ការប្រព្រឹត្តនៃការមិនដឹងនោះឯង មិនមែនការប្រព្រឹត្តនៃវត្ថុដទៃ ។ បទថា **វិនិពន្ធស្ស** ជាដើម ជាពាក្យពោលដល់សភាពនៃមានះជាដើម ។ បណ្តាបទទាំងនោះ បទថា **វិនិពន្ធស្ស** បានដល់ មានះដែលរួបរឹតហើយ តាំងនៅដោយអំណាចការលើកតម្កើងខ្លួន ។ បទថា **បរាមដ្ឋាយ** បានដល់ ទិដ្ឋិដែលឈានកន្លងភាពដែលរូបជារបស់មិនទៀងជាដើម ហើយប្រកាន់ភាពជារបស់ទៀងជាដើម ដោយចំណែកផ្ទុយ ។ បទថា **វិក្ខេបគតស្ស** បានដល់ ឧទ្ធច្ចៈដែលដល់នូវការរាយមាយទៅក្នុងរូបារម្មណ៍ ។ បទថា **អនិដ្ឋាគតាយ** បានដល់ វិចិកិច្ឆាដែលដល់នូវភាពសម្រេចចិត្តមិនបាន ។ បទថា **ថាមគតស្ស** បានដល់ អនុស័យដែលដល់ភាពជាធម៌មានកម្លាំង ។ បទថា **ធម្មេសុ** បានដល់ រូបជាដើម ឬក្នុងធម៌

ដែលជាធម្មារម្មណ៍ ។

[ ១៦៨ ] ព្រោះរាគៈជាដើម រមែងប្រាកដដោយការមិនដឹង ហេតុនោះ ព្រះសារីបុត្តត្ថេរ កាលធ្វើនូវការមិនដឹងឲ្យប្លែកចេញទៅដោយការប្រកបកិលេស មានរាគៈជាដើម ទើបពោលបទថា **សរាគា ចរតិ** ជាដើម ។ ក្នុងបទទាំងនោះ បទថា **សរាគា ចរតិ** គប្បីជ្រាបដល់ការប្រព្រឹត្តដោយការស្មុះទៅនៃមោហៈ មានះ ទិដ្ឋិ មានានុស័យ ទិដ្ឋានុស័យ អវិជ្ជានុស័យ ។ បទថា **សទោសា ចរតិ** បានដល់ ប្រព្រឹត្តដោយការស្មុះទៅនៃមោហៈ និងអវិជ្ជានុស័យ ។ បទថា **សមោហា ចរតិ** បានដល់ ប្រព្រឹត្តដោយការស្មុះទៅនៃរាគៈ ទោសៈ មានះ ទិដ្ឋិ ឧទ្ធច្ចៈ និងវិចិកិច្ឆានុស័យ ។ បទថា **សមានា ចរតិ** បានដល់ ប្រព្រឹត្តដោយការស្មុះទៅនៃរាគៈ មោហៈ កាមរាគៈ ភវរាគៈ និងអវិជ្ជានុស័យ ។ បទថា **សទិដ្ឋិ ចរតិ** បានដល់ ប្រព្រឹត្តដោយការស្មុះទៅនៃរាគៈ មោហៈ កាមរាគៈ និងអវិជ្ជានុស័យ ។ បទថា **សឧទ្ធច្ចា ចរតិ សវិចិកិច្ឆា ចរតិ** បានដល់ ប្រព្រឹត្តដោយការស្មុះទៅនៃមោហៈ និងអវិជ្ជានុស័យ ។ បទនេះថា **សានុសយា ចរតិ** ក៏គួរប្រកបថា ការប្រព្រឹត្ត មានអនុស័យ ដោយអំណាចអនុស័យដែលសល់ ដែលរកបានក្នុងចិត្តដួងនោះ ដោយធ្វើអនុស័យតែមួយ ឲ្យជាមូលតាមន័យដែលពោលហើយនោះឯង ។ បទថា **រាគសម្បយុត្តា** ជាវេវចនៈរបស់បទថា **សរាគា ចរតិ** ជាដើមនោះឯង ការប្រព្រឹត្តនោះ រមែងប្រព្រឹត្តទៅជាមួយរាគៈជាដើម ដោយអំណាចការប្រកប ព្រោះហេតុនោះ ទើបបានឈ្មោះទាំងឡាយថា **សរាគា** ជាដើម

ការប្រព្រឹត្តប្រកបដោយប្រការទាំងឡាយ មានការកើតរួមគ្នា រលត់រួមគ្នា មានវត្ថុរួមគ្នា និងមានអារម្មណ៍រួមគ្នាជាដើម ស្មើដោយរាគៈជាដើម ព្រោះហេតុនោះ ទើបបានឈ្មោះទាំងឡាយថា **រាគសម្បយុត្តា** ។ ព្រោះការប្រព្រឹត្តនោះឯង មិនប្រកបដោយកុសលកម្មជាដើម ប្រកបដោយអកុសលកម្មជាដើម ហេតុនោះ ព្រះសារីបុត្តត្ថេរ ដើម្បីសម្ដែងថា ជាអញ្ញាណចរិយា ទើបពោលបទថា **កុសលេហិ កម្មេហិ** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **អញ្ញាតេ** បានដល់ ក្នុងអារម្មណ៍ ដែលមិនដឹងតាមសភាវៈដែលពិត ព្រោះមោហៈមានការមិនដឹងជាលក្ខណៈ ។ បទដ៏សេសមានន័យដូចបានពោលហើយ ។

[ ១៦៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងញាណចរិយា ដូចតទៅនេះថា ព្រោះកិរិយាអព្យាកតៈដែលនឹកកាវរក ជាអនន្តរប្បច្ច័យដល់វិវដ្ដនាវិបស្សនាជាដើមមិនមាន ហេតុនោះ ទើបលោកមិនពោលដល់កិរិយាអព្យាកតៈដែលនឹកកាវរកដើម្បីប្រយោជន៍ដល់វិវដ្ដនាវិបស្សនាជាដើមទាំងនោះ តែពោលដល់វិវដ្ដនា-វិបស្សនាជាដើមតែម្ដងនោះឯង ។ ពិតហើយ ការនឹកកាវរក រមែងមានដើម្បីប្រយោជន៍ដល់អនុលោមញ្ញាណប៉ុណ្ណោះ បន្ទាប់អំពីនោះក៏ជាវិវដ្ដនាវិបស្សនា មគ្គ និងផល ។

ម្យ៉ាងទៀត ក្នុងបទថា **ផលសមាបត្តិ** នេះ ផលសមាបត្តិនឹងកើតក្នុងលំដាប់មគ្គក្ដី នឹងកើតក្នុងកាលដទៃក្ដី ។ លោកបំណងយកសូម្បីទាំងពីរយ៉ាង ។

[ ១៧០ ] ក្នុងបទថា **វីរាគា ចរតិ** ជាដើម គប្បីជ្រាបការមិនមានរាគៈជាដើម ដោយការកម្ចាត់រាគៈជាដើម ដោយអត្ថថា ត្រឹមតែការមិនមានរាគៈ

ជាដើមក្នុងវិញ្ញាណចរិយា ។ បទថា **ញាតេ** បានដល់ ក្នុងអារម្មណ៍ដែលដឹងតាមសេចក្តីពិត ។ ព្រះសារីបុត្តត្ថេរសម្តែងដល់ការមិនលាយឡំគ្នានិងគ្នារបស់ចរិយា ៣ ដោយបទថា **អញ្ញា វិញ្ញាណចរិយា** ជាដើម ។ ពិតហើយវិញ្ញាណចរិយា គឺចិត្តុប្បាទដែលជាអហេតុកៈ ដោយអំណាចត្រឹមតែធ្វើកិច្ចដឹងអញ្ញាណចរិយាដោយអំណាចអកុសលចិត្ត ១២ ដែលមានកិច្ចមិនដឹងញាណ-ចរិយាដោយអំណាចវិបស្សនា មគ្គ និងផលដែលធ្វើកិច្ចដឹងដោយពិសេស ។

គប្បីជ្រាបថា ចរិយាទាំងនេះ មិនលាយឡំគ្នានិងគ្នា ចិត្តុប្បាទដែលជាកាមាវចរកិរិយា និងកុសលខាងសហេតុកៈ វៀរវិបស្សនា និងដែលជាកាមាវចរវិបាកខាងសហេតុកៈ និងដែលជារូបាវចរ អរូបាវចរទាំងកុសល និងអព្យាកតៈ ( វិបាក និងកិរិយា ) ផុតចាកចរិយា ៣ ។ គប្បីជ្រាបថា បច្ចវេក្ខណញ្ញាណរបស់ព្រះសេក្ខៈ និងព្រះអសេក្ខៈដែលជាការពិចារណានិព្វាន មគ្គ ផល លោកសង្គ្រោះចូលក្នុងញាណចរិយា ព្រោះវិវដ្តនានុបស្សនាដែលមាននិព្វានជាអារម្មណ៍ លោកសម្តែងហើយថា ជាញាណចរិយា ។ ឯញាណចរិយាទាំងនោះ ធ្វើកិច្ចរបស់ញាណដោយពិសេសនោះឯង ។ល។

**អដ្ឋកថាចរិយានានត្តញ្ញាណនិទ្ទេស ចប់**

# សុត្តន្តបិដក

[ ១៧១ ] បញ្ហាក្នុងការកំណត់នូវធម៌ ៤ ឈ្មោះថា ភូមិនានត្តញាណ តើដូចម្តេច ។ ភូមិមាន ៤ គឺកាមាវចរភូមិ ១ រូបាវចរភូមិ ១ អរូបាវចរភូមិ ១ អបរិយាបន្នភូមិ ១ ។

[ ១៧២ ] កាមាវចរភូមិ តើដូចម្តេច ។ ខាងក្រោមកំណត់ត្រឹមអវីចិ-នរកជាទីបំផុត ខាងលើកំណត់ត្រឹមបរនិម្មិតវសវត្តីទេវតាជាទីបំផុត ខន្ធ ធាតុ អាយតនៈ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណណាមានក្នុងចន្លោះនុ៎ះ រង្គាត់ទៅក្នុងចន្លោះនុ៎ះ រាប់បញ្ចូលក្នុងចន្លោះនុ៎ះ នេះឈ្មោះថា កាមាវចរភូមិ ។

[ ១៧៣ ] រូបាវចរភូមិ តើដូចម្តេច ។ ខាងក្រោម កំណត់ត្រឹមព្រហ្ម-លោកជាទីបំផុត ខាងលើកំណត់ត្រឹមអកនិដ្ឋទេវតាជាទីបំផុត ធម៌ទាំងឡាយ គឺចិត្ត និងចេតសិកណារបស់អ្នកចូលកាន់សមាបត្តិក្តី របស់អ្នកកើតក្នុងព្រហ្ម-លោកក្តី របស់អ្នកមានធម៌ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្នក្តី មានក្នុងចន្លោះនុ៎ះ រង្គាត់ទៅក្នុងចន្លោះនុ៎ះ រាប់បញ្ចូលក្នុងចន្លោះនុ៎ះ នេះឈ្មោះថា រូបាវចរភូមិ ។

[ ១៧៤ ] អរូបាវចរភូមិ តើដូចម្តេច ។ ខាងក្រោមកំណត់ត្រឹមពួកទេវតាអ្នកចូលកាន់អាកាសានញ្ចាយតនភពជាទីបំផុត ខាងលើកំណត់ត្រឹមពួកទេវតាអ្នកចូលកាន់នេវសញ្ញានាសញ្ញាយតនភពជាទីបំផុត ធម៌ទាំងឡាយ គឺចិត្ត និងចេតសិកណារបស់អ្នកចូលកាន់សមាបត្តិក្តី របស់អ្នកចូលទៅកើតក្នុងព្រហ្ម-លោកក្តី របស់អ្នកមានធម៌ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្នក្តី មានក្នុងចន្លោះនុ៎ះ រង្គាត់ទៅក្នុងចន្លោះនុ៎ះ រាប់បញ្ចូលក្នុងចន្លោះនុ៎ះ នេះឈ្មោះថា អរូបា-វចរភូមិ ។

[ ១៧៥ ] អបរិយាបន្នភូមិ តើដូចម្តេច ។ មគ្គ ផល និងអសង្ខតធាតុ ដែលមិនបានរាប់បញ្ចូល ( ក្នុងភូមិនោះ ) នេះឈ្មោះថា អបរិយាបន្នភូមិ នេះភូមិ ៤ ។

[ ១៧៦ ] ភូមិ ៤ ដទៃទៀត គឺសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឈាន ៤ អប្បមញ្ញា ៤ អរូបាវចរសមាបត្តិ ៤ បដិសម្ភិទា ៤ បដិបទា ៤ អារម្មណ៍ ៤ អរិយវង្ស ៤ សង្គហវត្ថុ ៤ ចក្ក ៤ ធម្មបទ ៤ ទាំងនេះឈ្មោះថា ភូមិ ៤ ដែលឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងការកំណត់នូវធម៌ ៤ ឈ្មោះថា ភូមិនានត្តញាណ ។

# អដ្ឋកថា
# ភូមិនានត្តញ្ញាណនិទ្ទេស

[ ១៧១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងភូមិនានត្តញ្ញាណនិទ្ទេសដូចតទៅ បទថា **ភូមិយោ** បានដល់ ចំណែក ឬខេត្តកំណត់ ។

**កាម** ក្នុងបទថា **កាមាវចរ** នេះ មាន ២ យ៉ាង គឺកិលេសកាម ១ វត្ថុកាម ១ ។ ឆន្ទរាគៈជាកិលេសកាម វដ្ដៈដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ជាវត្ថុកាម ។ កិលេសកាម ឈ្មោះថា កាម ព្រោះអត្ថថា ឲ្យប្រាថ្នា វត្ថុកាម ឈ្មោះថា កាម ព្រោះអត្ថថា ដែលបុគ្គលប្រាថ្នា ។ កាម ២ យ៉ាងនោះ ត្រាច់ទៅក្នុងប្រទេសណាដោយការប្រព្រឹត្តទៅ ប្រទេសនោះ ឈ្មោះថា **កាមាវចរ** ព្រោះអត្ថថា ជាទីត្រាច់ទៅនៃកាម ។ ប្រទេសនោះមាន ១១ គឺអបាយ ៤ មនុស្សលោក ១ និងទេវលោក ៦ ។ ដូចជាបុរស ព្រមទាំងឈ្នួញរទេះ ត្រាច់ទៅក្នុងប្រទេសណា ប្រទេសនោះ សូម្បីមានសត្វជើង ២ ជើង ៤ ដទៃត្រាច់ទៅ លោកក៏ហៅថា **សសត្ថាវចរ** ( ជាទីត្រាច់ទៅរបស់ពួកឈ្នួញរទេះ ) ព្រោះកំណត់ឈ្នួញរទេះទាំងនោះ យ៉ាងណា សូម្បីកាលមានរូបាវចរជាដើមពួកដទៃ ត្រាច់ទៅក្នុងប្រទេសនោះ ប្រទេសនោះ លោកក៏ហៅថា កាមាវចរនោះឯង ព្រោះកំណត់កាមទាំងនោះក៏យ៉ាងនោះ ។ កាមាវចរនេះ លោកហៅថា កាមប៉ុណ្ណោះ ព្រោះលុបបទក្រោយ ដូចរូបកព លោកហៅថា រូប ។ ធម៌ឯណានីមួយ ដែលទាក់ទងដោយកាមនោះ ឈ្មោះថា **កាមាវចរ** ព្រោះអត្ថថា ត្រាច់ទៅក្នុងកាម ពោលគឺប្រទេស ១១ នេះ ។ សូម្បីធម៌

ឯណានីមួយក្នុងកាមាវចរនេះ ត្រាច់ទៅក្នុងរូបភព និងអរូបភពក៏ពិត តែធម៌ទាំងនោះ ត្រាច់ទៅក្នុងទីដទៃ ក៏គប្បីជ្រាបថា ជាកាមាវចរដោយពិត ដូចដំរីបានឈ្មោះថាសង្គាមាវចរ ព្រោះត្រាច់ទៅក្នុងសង្គ្រាម សូម្បីត្រាច់ទៅក្នុងនគរ លោកក៏ហៅថា សង្គាមាវចរដូចគ្នា ។ សត្វទាំងឡាយត្រាច់ទៅលើគោក និងក្នុងទឹក សូម្បីនៅក្នុងកន្លែងមិនមែនគោក និងមិនមែនទឹក លោកក៏ហៅថា សត្វគោក សត្វទឹកដូចគ្នា ដូច្នោះ ។

ម្យ៉ាងវិញទៀត ឈ្មោះថា **កាមាវចរ** ព្រោះអត្ថថា កាមត្រាច់ទៅក្នុងធម៌ទាំងឡាយមានប្រការដូចពោលហើយនេះ ដោយការធ្វើជាអារម្មណ៍ ។ ម្យ៉ាងទៀត កាមនោះ សូម្បីត្រាច់ទៅក្នុងរូបាវចរធម៌ និងអរូបាវចរធម៌ក៏ពិត តែគប្បីជ្រាបសេចក្ដីប្រៀបធៀបដូច្នេះថា កាលពោលថា ឈ្មោះថា កូនគោ ( វច្ឆ ) ព្រោះស្រែកយំ ឈ្មោះថា ក្របី ( មហឹស ) ព្រោះដេកលើផែនដី ។ សត្វមានប្រមាណប៉ុណ្ណា ស្រែកយំ ឬដេកលើផែនដី សត្វទាំងពួង នឹងមានឈ្មោះដូច្នោះក៏មិនមែន ។

ក្នុងបទនេះ លោកសម្ដែងដល់ភូមិសត្វ ដែលពោលធ្វើធម៌ទាំងនោះឲ្យជាពួកតែមួយហើយ ទើបធ្វើឲ្យជាឥត្ថីលិង្គថា **កាមាវចរា**។ ក្នុងបទជាដើមថា **រូបាវចរា** រូបភព គឺរូប ឈ្មោះថា រូបាវចរ ព្រោះអត្ថថា ត្រាច់ទៅក្នុងរូបនោះ ។ អរូបភព គឺអរូប ឈ្មោះថា **អរូបាវចរ** ព្រោះអត្ថថា ត្រាច់ទៅក្នុងអរូបនោះ ។ ឈ្មោះថា **បរិយាបន្នា** ព្រោះអត្ថថា ទាក់ទងក្នុងវដ្តៈដែលប្រព្រឹត្តទៅក្នុងភូមិ ៣ គឺឈមចុះខាងក្នុង ឈ្មោះថា **អបរិយាបន្នា** ព្រោះ

អត្ថថា មិនទាក់ទងក្នុងវដ្តៈដែលប្រព្រឹត្តទៅក្នុងភូមិ ៣ នោះ ។

[ ១៧២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃភូមិ មានកាមាវចរភូមិជាដើម ដូចតទៅ

បទថា **ហេដ្ឋតោ** បានដល់ ដោយចំណែកខាងក្រោម ។ បទថា **អវីចិ-និរយំ** មានវិគ្គហៈថា ឈ្មោះថា អវីចិ ព្រោះអត្ថថា រលក គឺរវាងចន្លោះ គឺឱកាសនៃអណ្តាតភ្លើងនៃសត្វ នៃវេទនា មិនមានក្នុងអវីចិនេះ ។ ឈ្មោះថា **និរយ** ព្រោះអត្ថថា ការចម្រើន គឺសេចក្តីសុខមិនមានក្នុងនរកនេះ ។ម្យ៉ាងទៀត ឈ្មោះថា **និរយ** ព្រោះអត្ថថា មិនមានសេចក្តីត្រេកអរ ។

បទថា **បរិយន្តំ ករិត្វា** បានដល់ ធ្វើនរក ពោលគឺអវីចិនោះ ឲ្យជាទីបំផុត ។ បទថា **ឧបរិតោ** បានដល់ ដោយចំណែកខាងលើ ។ បទថា **បរ-និម្មិតវសវត្តី ទេវេ** បានដល់ ទេវតាដែលបានឈ្មោះយ៉ាងនេះ ព្រោះញ៉ាំងអំណាចឲ្យប្រព្រឹត្តទៅក្នុងកាមដែលអ្នកដទៃនិមិត្តឲ្យ ។ បទថា **អន្តោ ករិត្វា** បានដល់ ដាក់ក្នុងខាងក្នុង ។ បទថា **យំ ឯតស្មឹ អន្តរេ** បានដល់ ក្នុងឱកាសនេះ ។ ម្យ៉ាងទៀត បទថា **យំ** ជាលិង្គវិបល្លាស ។

បទថា **ឯត្ថាវចរា** ព្រោះខន្ធជាដើម ពួកដទៃក៏ត្រាច់ទៅក្នុងឱកាសនេះដោយកើតឡើងក្នុងកាលខ្លះ ក្នុងទីខ្លះ ហេតុនោះ ទើបលោកពោលថា **អវចរា** ដើម្បីមិនសង្គ្រោះខន្ធជាដើមទាំងនោះ ។ ដោយហេតុនោះ ខន្ធជាដើមពួកណាឈមចុះក្នុងឱកាសនេះ ត្រាច់ទៅដោយការកើតក្នុងទីគ្រប់អន្លើ និងក្នុងកាលសព្វកាល និងត្រាច់ទៅក្នុងចំណែកខាងក្រោម ដោយការប្រព្រឹត្តទៅរហូតដល់

កើតក្នុងអវីចិនរក រមែងឈ្មោះថាធ្វើការសង្គ្រោះខន្ធជាដើមទាំងនោះ ។ ខន្ធជាដើមទាំងនោះ ឈ្មោះថា **អវចរា** ព្រោះឈមចុះ ត្រាច់ទៅ និងត្រាច់ទៅក្នុងចំណែកខាងក្រោម ។

បទថា **ឯត្ថ បរិយាបន្នា** ព្រោះខន្ធជាដើមទាំងនេះ ត្រាច់ទៅក្នុងឱកាសនេះ រមែងត្រាច់ទៅក្នុងឱកាសដទៃបានខ្លះ តែមិនទាក់ទងក្នុងឱកាសនោះ ហេតុនោះ កាលខន្ធជាដើមទាំងនោះត្រាច់ទៅ សូម្បីក្នុងទីដទៃ រមែងឈ្មោះថា លោកកំណត់យកផងដែរ ។

ឥឡូវនេះ ព្រះសារីបុត្តត្ថេរ កាលសម្ដែងធម៌ដែលទាក់ទង ក្នុងឱកាសនេះ ដោយភាពជាគំនរ ភាពទទេ និងជាបច្ច័យ និងដោយសេចក្ដីពិត ទើបពោលបទថា **ខន្ធធាតុអាយតនា** ជាដើម ។

[ ១៧៣ ] បទថា **ព្រហ្មលោកំ** បានដល់ ស្ថានរបស់ព្រហ្ម ដែលបានដល់ភូមិនៃបឋមជ្ឈាន ។ បទថា **អកនិដ្ឋេ** បានដល់ មិនមែនកនិដ្ឋៈ ព្រោះអត្ថថា ខ្ពង់ខ្ពស់ ។ បទថា **សមាបន្នស្ស** បានដល់ របស់អ្នកចូលសមាបត្តិ ។ ដោយបទនេះ លោកពោលដល់កុសលជ្ឈាន ។ បទថា **ឧប្បន្នស្ស** បានដល់ កើតក្នុងព្រហ្មលោកដោយអំណាចវិបាក ។ ដោយបទនេះ លោកពោលដល់វិបាកជ្ឈាន ។

បទថា **ទិដ្ឋធម្មសុខវិហារិស្ស** មានវិនិច្ឆ័យថា ធម៌ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន គឺក្នុងអត្តភាពដែលប្រចក្ស ឈ្មោះថា ធម៌ជាគ្រឿងនៅជាសុខ ក្នុងបច្ចុប្បន្ន ។ ធម៌ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ននោះ មានដល់បុគ្គលនោះ

ព្រោះហេតុនោះ បុគ្គលនោះ ឈ្មោះថា មានធម៌ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន បានដល់ ព្រះអរហន្ត ។ របស់បុគ្គលដែលមានធម៌ជាគ្រឿងនៅជាសុខ ក្នុងបច្ចុប្បន្ននោះ ។ ដោយពាក្យនោះ លោកពោលដល់កិរិយាញាណ ។ បទថា **ចេតសិកា** បានដល់ ធម៌ដែលកើតក្នុងចិត្ត ឈ្មោះថា ចេតសិក អធិប្បាយថា សម្បយុត្តជាមួយចិត្ត ។

[ ១៧៤ ] បទថា **អាកាសានញ្ចាយតនូបគេ** បានដល់ ទេវតាដែលចូលដល់អាកាសានញ្ចាយតនកព ។ សូម្បីក្នុងបទទីពីរក៏មានន័យនេះដូចគ្នា ។

[ ១៧៥ ] បទថា **មគ្គា** បានដល់ អរិយមគ្គ ៤ ។ បទថា **មគ្គផលានិ** បានដល់ ផលនៃអរិយមគ្គ ៤ ។ បទថា **អសង្ខតា ច ធាតុ** បានដល់ និព្វានធាតុដែលបច្ច័យទាំងឡាយមិនបានតាក់តែង ។

[ ១៧៦ ] បទថា **អបរាបិ ចតស្សោ ភូមិយោ** គប្បីជ្រាបដោយអំណាចចតុក្កៈនីមួយៗ ។ បទថា **ចត្តារោ សតិប្បដ្ឋានា** បានដល់ កាយានុបស្សនាសតិប្បដ្ឋាន វេទនានុបស្សនាសតិប្បដ្ឋាន ចិត្តានុបស្សនាសតិប្បដ្ឋាន ធម្មានុបស្សនាសតិប្បដ្ឋាន ។ មានអធិប្បាយដូច្នេះថា ឈ្មោះថា បដ្ឋាន ព្រោះអត្ថថា តាំងទុក អធិប្បាយថា ចូលទៅតាំងទុក គឺបន្សូរចូលទៅ ។ បដ្ឋាន គឺសតិ ឈ្មោះថា សតិប្បដ្ឋាន ។ ម្យ៉ាងទៀត ឈ្មោះថា សតិ ព្រោះអត្ថថា ការរឭក ។ ឈ្មោះថា បដ្ឋាន ព្រោះអត្ថថា ចូលទៅតាំងទុក ។ សតិនោះផង ជាបដ្ឋានផង ឈ្មោះថា សតិប្បដ្ឋាន ។ ឈ្មោះថា សតិប្បដ្ឋានទាំងឡាយ ព្រោះអត្ថថា សតិទាំងនោះ ច្រើនដោយអំណាចអារម្មណ៍ ។

បទថា **ចត្តារោ សម្មប្បធានា** បានដល់ សេចក្តីព្យាយាមប្រពៃ ដើម្បីមិនឲ្យអកុសលដែលមិនទាន់កើត កើតឡើង ១ សេចក្តីព្យាយាមប្រពៃដើម្បីលះអកុសលដែលកើតឡើងហើយ ១ សេចក្តីព្យាយាមប្រពៃដើម្បីឲ្យកុសលដែលមិនទាន់កើត កើតឡើង ១ សេចក្តីព្យាយាមប្រពៃដើម្បីការតាំងនៅនៃកុសលដែលកើតឡើងហើយ ១ ឈ្មោះថា បធាន ព្រោះអត្ថថា ជាហេតុតាំងទុក គឺព្យាយាម បទនេះ ជាឈ្មោះនៃសេចក្តីព្យាយាម ។

បទថា **សម្មប្បធានំ** បានដល់ សេចក្តីព្យាយាមមិនវិបរិត សេចក្តីព្យាយាមតាមហេតុ សេចក្តីព្យាយាមដោយឧបាយ សេចក្តីព្យាយាម ដោយប្រពៃ ។ សេចក្តីព្យាយាមតែម្យ៉ាងប៉ុណ្ណោះ លោកធ្វើជា ៤ យ៉ាង ដោយអំណាចនៃកិច្ចទើបពោលថា **សម្មប្បធានា** ។ បទថា **ចត្តារោ ឥទ្ធិបាទា** បានដល់ ឆន្ទៈ វីរិយៈ ចិត្តៈ វីមំសា ។ សេចក្តីនៃបទនោះ បានពោលហើយ ។

បទថា **ចត្តារិ ឈានានិ** បានដល់ បឋមជ្ឈាន មានអង្គ ៥ គឺវិតក្កៈ វិចារ បីតិ សុខ ចិត្តេកគ្គតា ទុតិយជ្ឈាន មានអង្គ ៣ គឺបីតិ សុខ ចិត្តេ-កគ្គតា ។ តតិយជ្ឈានមានអង្គ ២ គឺសុខ ចិត្តេកគ្គតា ។ ចតុត្ថជ្ឈាន មានអង្គ ២ គឺឧបេក្ខា ចិត្តេកគ្គតា ។ អង្គទាំងនេះ ហៅថា ឈាន ព្រោះអត្ថថា ចូលទៅសម្ញឹងអារម្មណ៍ ។ បទថា **ចតស្សោ អប្បមញ្ញាយោ** បានដល់ មេត្តា ករុណា មុទិតា ឧបេក្ខា ។ ឈ្មោះថា **អប្បមញ្ញា** ដោយអំណាចការផ្សាយទៅមិនមានប្រមាណ ។ ពិតហើយ អប្បមញ្ញាទាំងនោះ រមែងផ្សាយទៅកាន់សត្វទាំងឡាយប្រមាណមិន បានដោយអំណាចនៃអារម្មណ៍ ឬថា ផ្សាយទៅកាន់

សត្វមួយដោយអំណាចការផ្សាយទៅដោយមិនមានសេសសល់ ( គ្រប់ចំណែករាងកាយ ) ព្រោះហេតុនោះ ទើបលោកពោលថា អប្បមញ្ញា ដោយអំណាចការផ្សាយទៅ មិនមានប្រមាណ ។

បទថា **ចតស្សោ អរូបសមាបត្តិយោ** បានដល់ អាកាសានញ្ចាយតនសមាបត្តិ វិញ្ញាណញ្ចាយតនសមាបត្តិ អាកិញ្ចញ្ញាយតនសមាបត្តិ នេវសញ្ញានាសញ្ញាយតនសមាបត្តិ ។ បទថា **ចតស្សោ បដិសម្ភិទា** មានសេចក្តីដូចបានពោលហើយនោះឯង ។ បទថា **ចតស្សោ បដិបទា** បានដល់ បដិបទា ៤ ដែលព្រះមានព្រះភាគ ត្រាស់ ( ក្នុងទីឃនិកាយ បាដិកវគ្គ ) ថា ទុក្ខាបដិបទាទន្ធាភិញ្ញា ១ ទុក្ខាបដិបទាខិប្បាភិញ្ញា ១ សុខាបដិបទាទន្ធាភិញ្ញា ១ សុខាបដិបទាខិប្បាភិញ្ញា ១ ដូច្នេះ ។

បទថា **ចត្តារិ អារម្មណានិ** បានដល់ អារម្មណ៍ ៤ ដែលព្រះមានព្រះភាគ ត្រាស់ ( ក្នុងធម្មសង្គណិបករណ៍ ) ថា មានប្រមាណតូច មានអារម្មណ៍ដ៏តូច មានប្រមាណតូច តែមានអារម្មណ៍ប្រមាណមិនបាន ប្រមាណមិនបាន តែមានអារម្មណ៍តូច ប្រមាណមិនបាន មានអារម្មណ៍ប្រមាណមិនបាន ដូច្នេះ ។

គប្បីជ្រាបថា លោកពោលដល់ឈាន មានអារម្មណ៍ ដោយអារម្មណ៍ទាំងឡាយ ដោយមិនកំណត់អារម្មណ៍ មានកសិណជាដើម ។

បទថា **ចត្តារោ អរិយវំសា** សេចក្តីថា ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ សាវកនៃព្រះពុទ្ធ ហៅថា ព្រះអរិយៈ ។ វង្ស ខ្សែស្រឡាយ បវេណីរបស់ព្រះអរិយៈ

ទាំងនោះ ឈ្មោះថា វង្សរបស់ព្រះអរិយៈ ។ វង្សរបស់ព្រះអរិយៈទាំងនោះ តើដូចម្តេច ធម៌ទាំង ៤ នេះ គឺសន្តោសដោយចីវរ ១ សន្តោសដោយបិណ្ឌបាត ១ សន្តោសដោយសេនាសនៈ ១ ត្រេកអរក្នុងភាវនា ១ ។ កាលពោលដល់សន្តោសដោយបិណ្ឌបាត ក៏ឈ្មោះថាពោលដល់សន្តោសដោយគិលានប្បច្ច័យផងដែរ ព្រោះភិក្ខុណា សន្តោសក្នុងបិណ្ឌបាត ភិក្ខុនោះ នឹងមិនសន្តោសក្នុងគិលានប្បច្ច័យដូចម្តេចកើត ។

បទថា **ចត្តារិ សង្គហវត្ថូនិ** បានដល់ ហេតុនៃការសង្គ្រោះជន ៤ សង្គហវត្ថុ ៤ នេះ គឺទាន ១ បេយ្យវជ្ជៈ ១ អត្ថចរិយា ១ សមានត្តតា ១ ។ ពាក្យថា ទាន បានដល់ ការឲ្យតាមសមគួរ ។ ពាក្យថា បេយ្យវជ្ជៈ បានដល់ និយាយគួរស្រឡាញ់ តាមសមគួរ ។ ពាក្យថា អត្ថចរិយា បានដល់ការធ្វើសេចក្តីចម្រើនដោយធ្វើកិច្ចដែលគួរធ្វើ ក្នុងទីនោះៗ និងដោយការទូន្មានក្នុងវត្ថុដែលគួរធ្វើ និងមិនគួរធ្វើ ។ ពាក្យថា សមានត្តតា បានដល់ មានការស្មើប្រព្រឹត្តទៅ មួយអន្លើដោយមានះ អធិប្បាយថា មានប្រមាណខ្លួន គិតប្រមាណខ្លួន ។ ឈ្មោះថា សមានត្ត ព្រោះអត្ថថា ជាហេតុឲ្យមានខ្លួនស្មើបុគ្គលដទៃ ភាពជាអ្នកមានខ្លួនស្មើ ឈ្មោះថា សមានត្តតា អធិប្បាយថា ការគិតប្រមាណខ្លួនថា បុគ្គលនេះអន់ជាងអញ បុគ្គលនេះស្មើអញ បុគ្គលនេះល្អជាងអញ ហើយប្រព្រឹត្ត គឺធ្វើតាមសមគួរដល់បុគ្គលនោះ ។ អាចារ្យពួកខ្លះពោលថា ភាពជាអ្នករួមសុខរួមទុក្ខ ឈ្មោះថា សមានត្តតា ។

ក្នុងបទថា **ចត្តារិ ចក្កានិ** នេះ ឈ្មោះថា ចក្ក មាន ៥ យ៉ាង គឺទារុចក្ក

ចក្កធ្វើដោយឈើ ១ ចក្ករតនៈ ១ ធម្មចក្ក ១ ឥរិយាបថចក្ក ១ សម្បត្តិ-ចក្ក ១ ។ បណ្តាចក្កទាំងនោះ ចក្កក្នុងប្រយោគថា **យំ បន តំ ទេវ ចក្កំ ឆហិ មាសេហិ និដ្ឋិតំ ឆារត្តូនេហិ** សូមទ្រង់ព្រះមេត្តាប្រោស ធ្វើអស់ ៦ ខែខ្វះ ៦ រាត្រីនេះឯង ចក្កនេះ ឈ្មោះថា ទារុចក្ក ។ ចក្កក្នុងប្រយោគថា **ចក្កំវត្តយតោ បរិគ្គហេត្វា** ចំពោះព្រះរាជាចក្រពត្តិ ចក្កនេះ ឈ្មោះថា ចក្ក-រ័តន៍ ។ ចក្កក្នុងប្រយោគថា **មយា បវត្តិតំ ចក្កំ** ញុំាងធម្មចក្រ ជាចក្រ ដ៏ប្រសើរ ដែលតថាគតឲ្យប្រព្រឹត្តទៅហើយ ចក្កនេះ ឈ្មោះថា ធម្មចក្ក ។ ចក្កក្នុងប្រយោគថា **ចតុចក្កំ នវទ្វារំ** សរីរៈមានចក្រ ៤ មានទ្វារ ៩ ចក្កនេះ ឈ្មោះថា ឥរិយាបថចក្ក ។ ចក្កក្នុងប្រយោគថា **ចត្តារិមានិ ភិក្ខវេ ចក្កានិ យេហិ សមន្នាគតានំ ទេវមនុស្សានំ ចតុចក្កំ វត្តតិ កតមានិ ចត្តារិ បតិរូបទេសវាសោ សប្បុរិសាវស្សយោ អត្តសម្មាបណិធិ បុព្វេ ច កតបុញ្ញតា** ម្នាលភិក្ខុទាំងឡាយ ចក្កនេះ មាន ៤ ចក្ក ៤ តែងប្រព្រឹត្តទៅ ( ដើម្បីជាប្រយោជន៍ ) ដល់ពួកទេវតា និងមនុស្ស ដែលប្រកបដោយចក្ក ពួកទេវតា និងមនុស្សដែលប្រកបដោយចក្កហើយ មិនយូរប៉ុន្មានក៏បានដល់នូវភាពនៃខ្លួន ជាធំទូលាយក្នុងភោគៈទាំងឡាយ ។ ចក្ក ៤ ដូចម្តេចខ្លះ ។ គឺការនៅក្នុងប្រទេសដ៏សមគួរ ១ ការចូលទៅសេពគប់នឹងពួកសប្បុរស ១ ការតម្កល់ទុកខ្លួនដោយល្អ ១ បុណ្យដែលបានធ្វើទុកហើយក្នុងកាលមុន ១ ចក្កនេះ ឈ្មោះថា សម្បត្តិចក្ក ។ ក្នុងទីនេះបំណងយកសម្បត្តិចក្កនេះឯង ។

ក្នុងបទទាំងនោះ ពាក្យថា ការនៅក្នុងប្រទេសដ៏សមគួរ បានដល់ បរិស័ទ

៤ ប្រាកដក្នុងប្រទេសណា ក្នុងប្រទេសដ៏សមគួរបែបនោះ ។

ពាក្យថា ការចូលទៅសេពគប់នឹងពួកសប្បុរស បានដល់ ចូលទៅអាស្រ័យ សេព គប់រកសប្បុរស មានព្រះពុទ្ធជាដើម ។

ពាក្យថា **ការតម្កល់ទុកខ្លួនដោយល្អ** បានដល់ ការតម្កល់ខ្លួនទុកប្រពៃ ។ បើកាលមុនជាអ្នកមិនមានសទ្ធាជាដើម លះការមិនមានសទ្ធាជាដើមនោះ ហើយតាំងនៅក្នុងសទ្ធាជាដើម ។

ពាក្យថា បុណ្យដែលបានធ្វើទុកហើយក្នុងកាលមុន បានដល់ ភាពជាអ្នកសន្សំកុសលទុកក្នុងកាលមុន ។ សេចក្តីនេះ ជាគោលសំខាន់ក្នុងចក្ក ៤ នេះ ។ កុសលកម្មដែលធ្វើដោយចិត្តសម្បយុត្តដោយញាណណា កុសលកម្មនោះឯង រមែងនាំបុរសនោះចូលទៅក្នុងប្រទេសដ៏សមគួរ ឲ្យសេពគប់សប្បុរស បុគ្គលនោះឯង រមែងតម្កល់ខ្លួនទុកប្រពៃ ។

បទថា **ចត្តារិ ធម្មបទានិ** បានដល់ ចំណែកនៃធម៌ ៤ ។ ធម្មបទ ៤ គឺអ្វីខ្លះ គឺអនភិជ្ឈា ១ អព្យាបាទ ១ សម្មាសតិ ១ សម្មាសមាធិ ១ ។

ការមិនលោភក្តី ឈាន វិបស្សនា មគ្គ ផល និព្វាន ដែលសម្រេចដោយអំណាចនៃអនភិជ្ឈាក្តី ឈ្មោះថា ធម្មបទ គឺអនភិជ្ឈា ។

ការមិនក្រោធក្តី ការសម្រេចឈានជាដើមដែលសម្រេចហើយ ដោយមេត្តាជាគោលក្តី ឈ្មោះថា ធម្មបទ គឺអព្យាបាទ ។

សតិដែលតាំងមាំល្អហើយក្តី ឈានជាដើមដែលសម្រេចហើយដោយសតិជាគោលក្តី ឈ្មោះថា ធម្មបទ គឺសម្មាសតិ ។

សមាបត្តិ ៨ ក្តី ឈានជាដើមដែលសម្រេចហើយដោយសមាបត្តិ ៨ ជាគោលក្តី ឈ្មោះថា ធម្មបទ គឺសម្មាសមាធិ ។

មួយវិញទៀត ឈានជាដើមដែលសម្រេចហើយដោយអំណាចអសុភ ១០ ឈ្មោះថា ធម្មបទ គឺអនភិជ្ឈា ឈានជាដើមដែលសម្រេចហើយដោយអំណាចព្រហ្មវិហារ ៤ ឈ្មោះថា ធម្មបទ គឺអព្យាបាទ ឈានជាដើមដែលសម្រេចហើយដោយអំណាចអនុស្សតិ ១០ និងអាហារេបដិកូលសញ្ញា ឈ្មោះថា ធម្មបទ គឺសម្មាសតិ ឈានជាដើមដែលសម្រេចហើយ ដោយអំណាចកសិណ ១០ និងអានាបានស្សតិ ឈ្មោះថា ធម្មបទ គឺសម្មាសមាធិ ដោយប្រការដូច្នេះ ។

បទថា **ឥមា ចតស្សោ ភូមិយោ** គប្បីប្រកបភូមិនីមួយៗ ដោយអំណាចចតុក្កៈនោះឯង ។ល។

**អដ្ឋកថាភូមិនានត្តញ្ញាណនិទ្ទេស ចប់**

# សុត្តន្តបិដក

[ ១៧៧ ] បញ្ហាក្នុងការកំណត់នូវធម៌ ៩ ឈ្មោះថា ធម្មនានត្តញ្ញាណ តើដូចម្ដេច ។ បុគ្គលកំណត់នូវធម៌ទាំងឡាយ តើដូចម្ដេច ។ បុគ្គលកំណត់នូវពួកកាមាវចរធម៌ថាជាកុសល កំណត់ថាជាអកុសល កំណត់ថាជាអព្យា-ក្រឹត កំណត់នូវពួករូបាវចរធម៌ថាជាកុសល កំណត់ថាជាអព្យាក្រឹត កំណត់នូវពួកអរូបាវចរធម៌ថាជាកុសល កំណត់ថាជាអព្យាក្រឹត កំណត់នូវពួកអបរិយាបន្នធម៌ថាជាកុសល កំណត់ថាជាអព្យាក្រឹត ។

[ ១៧៨ ] បុគ្គលកំណត់នូវពួកកាមាវចរធម៌ថាជាកុសល កំណត់ថាជាអកុសល កំណត់ថាជាកុសល កំណត់ថាជាអព្យាក្រឹត តើដូចម្ដេច ។ បុគ្គលកំណត់នូវកុសលកម្មបថ ១០ ថាជាកុសល កំណត់នូវអកុសលកម្មបថ ១០ ថាជាអកុសល កំណត់នូវរូប វិបាក និងកិរិយាថាជាអព្យាក្រឹត បុគ្គលកំណត់នូវពួកកាមាវចរធម៌ថាជាកុសល កំណត់ថាជាអកុសល កំណត់ថាជាអព្យាក្រឹត យ៉ាងនេះឯង ។

[ ១៧៩ ] បុគ្គលកំណត់នូវពួករូបាវចរធម៌ថាជាកុសល កំណត់ថាជាអព្យាក្រឹត តើដូចម្ដេច ។ បុគ្គលកំណត់នូវឈាន ៤ របស់ជនដែលស្ថិតនៅក្នុងមនុស្សលោកនេះថាជាកុសល កំណត់នូវឈាន ៤ របស់ជនដែលកើតក្នុងព្រហ្មលោកនោះថាជាអព្យាក្រឹត បុគ្គលកំណត់នូវពួករូបាវចរធម៌ថាជាកុសល កំណត់ថាជាអព្យាក្រឹត យ៉ាងនេះឯង ។

[ ១៨០ ] បុគ្គលកំណត់នូវពួកអរូបាវចរធម៌ថាជាកុសល កំណត់ថាជាអព្យាក្រឹត តើដូចម្ដេច ។ បុគ្គលកំណត់នូវអរូបាវចរសមាបត្តិ ៤ របស់ជន

ដែលស្ថិតនៅក្នុងមនុស្សលោកនេះថាជាកុសល កំណត់នូវអរូបាវចរសមាបត្តិ ៤ របស់ជនដែលកើតនៅក្នុងព្រហ្មលោកនោះថាជាអព្យាក្រឹត បុគ្គលកំណត់នូវពួកអរូបាវចរធម៌ថាជាកុសល កំណត់ថាជាអព្យាក្រឹត យ៉ាងនេះឯង ។

[ ១៨១ ] បុគ្គលកំណត់នូវពួកអបរិយាបន្នធម៌ថាជាកុសល កំណត់ថាជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលកំណត់នូវអរិយមគ្គ ៤ ថាជាកុសល កំណត់នូវសាមញ្ញផល ៤ និងព្រះនិព្វានថាជាអព្យាក្រឹត បុគ្គលកំណត់នូវពួកអបរិយាបន្នធម៌ថាជាកុសល កំណត់ថាជាអព្យាក្រឹតយ៉ាងនេះ បុគ្គលកំណត់នូវធម៌ទាំងឡាយ យ៉ាងនេះឯង ។

[ ១៨២ ] ធម៌ ៩ មានបាមុជ្ជ ( សេចក្តីត្រេកអរទន់ ) ជាមូល គឺ កាលបុគ្គលធ្វើទុកក្នុងចិត្តថាមិនទៀង បាមុជ្ជរមែងកើត កាលបុគ្គលមានចិត្តរីករាយហើយ បីតិរមែងកើត កាលបុគ្គលមានចិត្ត ប្រកបដោយបីតិហើយ កាយរមែងស្ងប់ បុគ្គលអ្នកមានកាយស្ងប់ហើយ រមែងទទួលនូវសេចក្តីសុខ កាលបុគ្គលមានសេចក្តីសុខ ចិត្តរមែងតម្កល់មាំ កាលបើចិត្តតម្កល់មាំ បុគ្គលរមែងដឹង រមែងឃើញតាមពិត កាលបុគ្គលដឹង ឃើញតាមពិត រមែងនឿយណាយ កាលបុគ្គលនឿយណាយ រមែងធុញទ្រាន់ បុគ្គលផុតស្រឡះព្រោះតែការធុញទ្រាន់ កាលបុគ្គលធ្វើទុកក្នុងចិត្តថាជាទុក្ខ បាមុជ្ជរមែងកើត ។បេ។ កាលបុគ្គលធ្វើទុកក្នុងចិត្តនូវរូបថាជាអនត្តា បាមុជ្ជរមែងកើត កាលធ្វើទុកក្នុងចិត្តនូវរូបថាមិនទៀង បាមុជ្ជរមែងកើតឡើង កាលធ្វើទុកក្នុងចិត្តនូវរូបថាជាទុក្ខ ។បេ។ នូវរូបថា ជាអនត្តា ។បេ។ កាលធ្វើទុកក្នុងចិត្តនូវវេទនា សញ្ញា

សង្ខារ វិញ្ញាណ ចក្ខុ ។បេ។ នូវជរាមរណៈថាជារបស់មិនទៀង បាមុជ្ជរមែងកើត ។បេ។ កាលធ្វើទុកក្នុងចិត្តនូវជរាមរណៈថាជាទុក្ខ បាមុជ្ជរមែងកើត កាលធ្វើទុកក្នុងចិត្តនូវជរាមរណៈថាជាអនត្តា បាមុជ្ជរមែងកើត កាលបុគ្គលមានចិត្តរីករាយហើយ បីតិរមែងកើត កាលបុគ្គលមានចិត្ត ប្រកបដោយបីតិហើយ កាយរមែងស្ងប់ បុគ្គលអ្នកមានកាយស្ងប់ហើយ រមែងទទួលនូវសេចក្តីសុខ កាលបុគ្គលមានសេចក្តីសុខ ចិត្តរមែងតម្កល់មាំ កាលបើចិត្តតម្កល់មាំ បុគ្គលរមែងដឹង រមែងឃើញតាមពិត កាលដឹង ឃើញតាមពិត រមែងនឿយណាយ កាលនឿយណាយ រមែងធុញទ្រាន់ បុគ្គលផុតស្រឡះ ព្រោះតែការធុញទ្រាន់ នេះធម៌ ៩ ដែលមានបាមុជ្ជជាមូល ។

[ ១៨៣ ] ធម៌ ៩ មានការធ្វើទុកក្នុងចិត្តដោយត្រូវទំនងជាមូល គឺកាលបុគ្គលធ្វើទុកក្នុងចិត្តដោយត្រូវទំនង ថាមិនទៀង បាមុជ្ជរមែងកើត កាលបុគ្គលមានចិត្តរីករាយហើយ បីតិរមែងកើត កាលបុគ្គលមានចិត្តប្រកបដោយបីតិ កាយរមែងស្ងប់ បុគ្គលមានកាយស្ងប់ រមែងទទួលនូវសេចក្តីសុខ កាលបុគ្គលមានសេចក្តីសុខ ចិត្តរមែងតាំងមាំ បុគ្គលដែលមានចិត្តតាំងមាំ រមែងដឹងច្បាស់តាមពិតថា នេះជាទុក្ខ រមែងដឹងច្បាស់តាមពិតថា នេះជាហេតុនាំឲ្យកើតទុក្ខ រមែងដឹងច្បាស់តាមពិតថា នេះជាទីរលត់ទុក្ខ រមែងដឹងច្បាស់តាមពិតថា នេះជាបដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខ កាលបុគ្គលធ្វើទុកក្នុងចិត្តដោយត្រូវទំនងថាជាទុក្ខ បាមុជ្ជរមែងកើត កាលបុគ្គលមានចិត្តរីករាយហើយ បីតិរមែងកើត កាលបុគ្គលមានចិត្តប្រកបដោយបីតិ កាយរមែងស្ងប់ បុគ្គលមានកាយស្ងប់

រមែងទទួលនូវសុខ កាលបុគ្គលមានសេចក្តីសុខ ចិត្តរមែងតម្កល់មាំ បុគ្គលមានចិត្តតម្កល់មាំ រមែងដឹងច្បាស់តាមពិតថានេះជាទុក្ខ រមែងដឹងច្បាស់តាមពិតថានេះជាហេតុនាំឲ្យកើតទុក្ខ រមែងដឹងច្បាស់តាមពិតថានេះជាបដិបទាជាដំណើរទៅកាន់ទីរម្ងត់ទុក្ខ កាលបុគ្គលធ្វើទុកក្នុងចិត្តដោយត្រូវទំនង ថាជាអនត្តា បាមុជ្ជរមែងកើត ។បេ។ កាលបុគ្គលធ្វើទុកក្នុងចិត្តនូវរូប ដោយត្រូវទំនងថាមិនទៀង បាមុជ្ជរមែងកើត កាលបុគ្គលធ្វើទុកក្នុងចិត្តនូវរូបដោយត្រូវទំនងថាជាទុក្ខ បាមុជ្ជរមែងកើត កាលបុគ្គលធ្វើទុកក្នុងចិត្តនូវរូបដោយត្រូវទំនងថាជាអនត្តា បាមុជ្ជរមែងកើត ។បេ។ កាលបុគ្គលធ្វើទុកក្នុងចិត្តនូវវេទនា សញ្ញា សង្ខារ វិញ្ញាណ ចក្ខុ ។បេ។ នូវជរាមរណៈដោយត្រូវទំនងថាជារបស់មិនទៀង បាមុជ្ជរមែងកើត កាលបុគ្គលធ្វើទុកក្នុងចិត្តនូវជរាមរណៈដោយត្រូវទំនង ថាជាទុក្ខ បាមុជ្ជរមែងកើត ។បេ។ កាលបុគ្គលធ្វើទុកក្នុងចិត្តនូវជរាមរណៈដោយត្រូវទំនង ថាជាអនត្តា បាមុជ្ជរមែងកើត កាលបុគ្គលមានចិត្តរីករាយហើយ បីតិរមែងកើត កាលបុគ្គលមានចិត្តប្រកបដោយបីតិ កាយរមែងស្ងប់ បុគ្គលមានកាយស្ងប់ រមែងទទួលនូវសេចក្តីសុខ កាលបុគ្គលមានសេចក្តីសុខ ចិត្តរមែងតម្កល់មាំ បុគ្គលមានចិត្តតម្កល់មាំ រមែងដឹងច្បាស់តាមពិតថា នេះជាហេតុនាំឲ្យកើតទុក្ខ រមែងដឹងច្បាស់តាមពិតថា នេះជាទីរម្ងត់ទុក្ខ រមែងដឹងច្បាស់តាមពិតថា នេះបដិបទាជាដំណើរទៅកាន់ទីរម្ងត់ទុក្ខ នេះធម៌ ៩ ដែលមានការធ្វើទុកក្នុងចិត្តដោយត្រូវទំនងជាមូល ។

[ ១៨៤ ] សេចក្តីផ្សេងៗ មាន ៩ គឺសេចក្តីផ្សេងៗ គឺផស្សៈកើតឡើង

ព្រោះអាស្រ័យសេចក្តីផ្សេងៗ គឺធាតុ សេចក្តីផ្សេងៗ គឺវេទនាកើតឡើង ព្រោះអាស្រ័យសេចក្តីផ្សេងៗ គឺផស្សៈ សេចក្តីផ្សេងៗ គឺសញ្ញាកើតឡើង ព្រោះអាស្រ័យសេចក្តីផ្សេងៗ គឺវេទនា សេចក្តីផ្សេងៗ គឺសង្កប្បកើតឡើង ព្រោះអាស្រ័យសេចក្តីផ្សេងៗ គឺសញ្ញា សេចក្តីផ្សេងៗ គឺឆន្ទៈកើតឡើង ព្រោះអាស្រ័យសេចក្តីផ្សេងៗ គឺសង្កប្ប សេចក្តីផ្សេងៗ គឺបរិឡាហៈ ( ការក្តៅក្រហាយ ) កើតឡើង ព្រោះអាស្រ័យសេចក្តីផ្សេងៗ គឺឆន្ទៈ សេចក្តីផ្សេងៗ គឺបរិយេសនា ( ការស្វែងរក ) កើតឡើង ព្រោះអាស្រ័យសេចក្តីផ្សេងៗ គឺបរិឡាហៈ សេចក្តីផ្សេងៗ គឺលាភកើតឡើង ព្រោះអាស្រ័យសេចក្តីផ្សេងៗ គឺបរិយេសនា នេះសេចក្តីផ្សេងៗ ៩ ដែលឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញា ក្នុងការកំណត់នូវធម៌ ៩ យ៉ាង ឈ្មោះថា ធម្មនានត្តញ្ញាណ ។

# អដ្ឋកថា

# ធម្មនានត្តញ្ញាណនិទ្ទេស

[ ១៧៧-១៧៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងធម្មនានត្តញ្ញាណនិទ្ទេសដូចតទៅ បទថា **កម្មបថេ** ឈ្មោះថា កម្មបថ ព្រោះអត្ថថា កម្មទាំងនោះផង ជាផ្លូវផង ដើម្បីទៅបែកគ្នា បានដល់នូវកម្មបថទាំងនោះ ។

កុសលកម្មបថ ១០ បានដល់ កាយសុចរិត ៣ គឺវៀរចាកការសម្លាប់សត្វ ១ វៀរចាកការលួចទ្រព្យគេ ១ វៀរចាកការប្រព្រឹត្តខុសក្នុងកាម ១ វចីសុចរិត ៤ គឺវៀរចាកការនិយាយកុហក ១ វៀរចាកការនិយាយញុះញង់ ១ វៀរចាកការនិយាយគ្រោតគ្រាត ១ វៀរចាកការនិយាយពាក្យឥតប្រយោជន៍ ១ មនោសុចរិត ៣ គឺមិនសម្លឹងរំពៃចង់បានរបស់គេ ១ មិនព្យាបាទ ១ យល់ត្រូវ ១ ។

អកុសលកម្មបថ ១០ បានដល់ កាយទុច្ចរិត ៣ គឺសម្លាប់សត្វ ១ លួចទ្រព្យគេ ១ ប្រព្រឹត្តខុសក្នុងកាម ១ ។ វចីទុច្ចរិត ៤ គឺនិយាយកុហក ១ និយាយញុះញង់ ១ និយាយសម្ដីគ្រោតគ្រាត ១ និយាយពាក្យឥតប្រយោជន៍ ១ មនោទុច្ចរិត ៣ គឺសម្លឹងរំពៃចង់បានរបស់គេ ១ ព្យាបាទគេ ១ យល់ខុស ១ ។

ម្យ៉ាងទៀត សូម្បីកុសល និងអកុសល លោកក៏ពោលថា កម្មបថ ព្រោះឲ្យកើតបដិសន្ធិនោះឯង សល់អំពីការដែលពោលហើយ លោកមិនពោលថា កម្មបថ ព្រោះមិនមានចំណែកក្នុងការឲ្យកើតបដិសន្ធិ ។ គប្បីជ្រាបថា សូម្បី

កុសល និងអកុសលដ៏សេស លោកក៏កាន់យកដោយសំដៅដល់កុសល និងអកុសលយ៉ាងគ្រោតគ្រាត ។

បទថា **រូបំ** បានដល់ រូប ២៨ ដោយប្រភេទជាភូតរូប និងឧបាទាយរូប ។

បទថា **វិបាកំ** បានដល់ វិបាក ២៣ ដោយអំណាចនៃកាមាវចរកុសល-វិបាក ១៦ និងអកុសលវិបាក ៧ ។

បទថា **កិរិយំ** បានដល់ កាមាវចរកិរិយា ១១ ដោយអំណាចនៃបរិត្ត-កិរិយា ៣ និងមហាកិរិយា ៨ ។ ឈ្មោះថា កិរិយា ព្រោះអត្ថថា ត្រឹមតែការធ្វើ ព្រោះមិនមានវិបាក ។ ដោយហេតុមានប្រមាណប៉ុណ្ណេះ លោកពោលកាមាវចរនោះឯង ដោយអំណាចនៃរូបជាអព្យាក្រឹត វិបាកជាអព្យាក្រឹត និងកិរិយាជាអព្យាក្រឹត ។

[ ១៧៩-១៨០ ] បទថា **ឥធដ្ឋស្ស** បានដល់ របស់បុគ្គលដែលតាំងនៅក្នុងលោកនេះ ។ ដោយច្រើន លោកពោលដោយអំណាចនៃមនុស្សលោក ព្រោះមានឈានភាវនាក្នុងមនុស្សលោក ។ម្យ៉ាងទៀត សូម្បីក្នុងទេវលោកកន្លែងខ្លះ គ្រាខ្លះ ក៏បានឈាន ។ សូម្បីក្នុងព្រហ្មលោកដែលជារូបព្រហ្មទាំងឡាយក៏នៅបានឈានដោយអំណាចអ្នកកើតក្នុងព្រហ្មលោកនោះ ដែលកើតក្នុងជាន់ទាបចុះមក និងដែលកើតក្នុងជាន់ខ្ពស់ឡើងទៅ ។ តែក្នុងជាន់សុទ្ធាវាស និងជាន់អរូបាវចរ មិនមានអ្នកកើតក្នុងជាន់ទាបចុះមក ។ ក្នុងរូបាវចរ និងអរូបាវចរ អ្នកមិនចម្រើនឈាន កាលកើតក្នុងជាន់ទាបចុះមក រមែងកើតក្នុងកាមាវចរសុគតិប៉ុណ្ណោះ មិនកើតក្នុងទុគ្គតិ ។

បទថា **តត្រូបបន្នស្ស** បានដល់ វិបាកជ្ឈាន ៤ ដែលប្រព្រឹត្តទៅដោយអំណាចបដិសន្ធិ ភវង្គ និងចុតិ របស់បុគ្គលអ្នកកើតក្នុងព្រហ្មលោក ដោយអំណាចនៃវិបាក ។ លោកមិនបានពោលដល់កិរិយាដែលជាអព្យាក្រឹត ក្នុងឈានសមាបត្តិដែលជារូបាវចរ និងអរូបាវចរ ។ សូម្បីលោកមិនបានពោលក៏ពិត តែដោយពិតគប្បីជ្រាបថា កាលលោកពោលដល់កុសល ក៏ឈ្មោះថាពោលដល់កិរិយាជាអព្យាក្រឹតផង ព្រោះប្រព្រឹត្តទៅស្មើគ្នា ដោយកុសលដោយពិត ។ គប្បីជ្រាបក្នុងសេចក្ដីនេះ ដូចក្នុងគម្ពីរបដ្ឋាន លោកសង្គ្រោះកិរិយាជវនដោយការកាន់យកកុសលជវននោះឯងថា បើកុសល និងអកុសលរលត់ហើយ ទើបវិបាកកើតឡើង ព្រោះអំពើនោះជាអារម្មណ៍ ដូច្នេះ ។

[ ១៨១ ] បទថា **សាមញ្ញផលានិ** បានដល់ សាមញ្ញផល ៤ ។ ដោយបទនេះ លោកពោលដល់លោកុត្តរវិបាកដែលជាអព្យាក្រឹត ។ បទថា **និព្វានំ** បានដល់ និព្វានដែលជាអព្យាក្រឹត ។

[ ១៨២ ] បទថា **បាមុជ្ជមូលកា** បានដល់ ឈ្មោះថា មានបាមោជ្ជជាមូល ព្រោះអត្ថថា មានបាមុជ្ជជាមូលជាខាងដើម អធិប្បាយថា ផ្ដើមដោយបាមុជ្ជ ដ្បិតថា ប្រកបដោយបាមុជ្ជ ។

ក្នុងបទថា **អនិច្ចតោ មនសិការតោ បាមុជ្ជំ ជាយតិ** នេះ មានសេចក្ដីថា កាលធ្វើទុកក្នុងចិត្តដោយឧបាយ រមែងកើតបាមោជ្ជ ។ កាលមិនធ្វើទុកក្នុងចិត្តដោយឧបាយ រមែងមិនកើតបាមោជ្ជ ។ ពិតហើយ កាលមិនធ្វើទុកក្នុងចិត្តដោយឧបាយ កុសលក៏មិនកើត ចាំបាច់ពោលទៅថ្វីដល់វិបស្សនា ។

បើសួរថា ព្រោះហេតុអ្វី ទើបលោកពោលដោយសរុប ឆ្លើយថា ដើម្បីសម្តែងភាពដែលបាមោជ្ជមានកម្លាំងខ្លាំង ។ ព្រោះកាលមិនមានបាមោជ្ជ ការមិនត្រេកអរក្នុងសេនាសនៈដ៏ស្ងាត់ និងក្នុងធម៌ដែលជាអធិកុសល គឺការអផ្សុកក៏នឹងកើតឡើង កាលបើយ៉ាងនេះ រមែងចៀសចេញចាកភាវនានោះឯង ។ តែបើមានបាមោជ្ជ ភាវនារមែងដល់នូវការពេញ ព្រោះមិនមានការមិនត្រេកអរ ។ម្យ៉ាងទៀត ដើម្បីសម្តែងដល់ភាពដែលការធ្វើទុកក្នុងចិត្ត ដោយឧបាយប្រាជ្ញាមានឧបការៈច្រើនដល់ភាវនា ដោយភាពជាខាងដើម នឹងពោលដល់ពួក ៩ តមក ។

បាមុជ្ជ រមែងកើតដល់បុគ្គលចម្រើនវិបស្សនា ព្រោះមានវិបស្សនាជាបច្ច័យ ដោយបាលី ( ក្នុងធម្មបទ ) ថា

ភិក្ខុពិចារណា ការកើតឡើង និងការវិនាសខន្ធទាំងឡាយ ក្នុងកាលណា ក្នុងកាលនោះ ភិក្ខុនោះ រមែងបានបីតិ និងបាមោជ្ជ បីតិ និងបាមោជ្ជនោះ ឈ្មោះថា ជាអមតធម៌របស់បណ្ឌិតអ្នកដឹងធម៌ទាំងឡាយ ដូច្នេះ ។

តែក្នុងទីនេះ គប្បីកាន់យកបាមោជ្ជ ព្រោះការពិចារណាកលាបៈជាបច្ច័យ ។ ភាពជាអ្នកដល់នូវបាមោជ្ជ ឈ្មោះថា **ចាមុជ្ជំ** គឺបីតិដែលមានកម្លាំងខ្សោយ ។ គប្បីឃើញថា **ម** អក្ខរៈ ចុះក្នុងអត្ថនៃកម្មជាខាងដើម ។

បទថា **បមុទិតស្ស** បានដល់ ដល់នូវបាមោជ្ជ គឺសេចក្តីត្រេកអរដោយបាមោជ្ជនោះ ។ បាឋៈថា **បមោទិតស្ស** ក៏មាន ឯសេចក្តីក៏ដូចគ្នា ។

បទថា **បីតិ** បានដល់ បីតិមានកម្លាំង ។ បទថា **បីតិមនស្ស** បានដល់ ចិត្តប្រកបដោយបីតិ ។ គប្បីឃើញការលុប **យុត្ត** ( សព្ទ ថាប្រកប ) ចេញ ដូចបទថា **អស្សរថោ** រថសេះ គឺរថទឹមដោយសេះ ។ បទថា **កាយោ** បាន ដល់ នាមកាយ ឬរូបកាយ ។ បទថា **បស្សម្ភតិ** បានដល់ ជាអ្នកស្ងប់ សេចក្តីក្រវល់ក្រវាយ ។ បទថា **បស្សទ្ធកាយោ** បានដល់ កាយសប្បាយ ព្រោះប្រកបដោយសេចក្តីស្ងប់ទាំងពីរ ។

បទថា **សុខំ វេទេតិ** បានដល់ រមែងបានសោយចេតសិកសុខ ឬដោយ កាយិកសុខ ។ បទថា **សុខិនោ** បានដល់ ដល់ព្រមដោយសេចក្តីសុខ ។ បទ ថា **ចិត្តំ សមាធិយតិ** បានដល់ ចិត្តរមែងតាំងមាំស្មើ គឺចិត្តមានអារម្មណ៍ តែមួយ ។

បទថា **សមាហិតេ ចិត្តេ** ជាសត្តមីវិភត្ត ចុះក្នុងអត្ថនៃការលក្ខណៈដោយ ជាការៈ ។ ពិតហើយ បុគ្គលរមែងកំណត់ដឹងតាមសេចក្តីពិត ព្រោះការតាំងមាំ នៃចិត្ត ។ បទថា **យថាភូតំ បជានាតិ** បានដល់ រមែងដឹងសង្ខារតាមសេចក្តី ពិតដោយអំណាចនៃឧទយព្វយញ្ញាណជាដើម ។ បទថា **បស្សតិ** បានដល់ រមែងឃើញដោយបញ្ញាចក្ខុ ធ្វើវត្ថុនោះឲ្យពាល់ត្រូវហើយ ដូចឃើញដោយ ភ្នែក ។ បទថា **និព្វិន្ទតិ** បានដល់ រមែងនឿយណាយក្នុងសង្ខារទាំងឡាយ ព្រោះប្រកបដោយវិបស្សនាញាណ ៩ ។ បទថា **និព្វិន្ទំ វិរជ្ជតិ** បានដល់ កាលញ៉ាំងវិបស្សនាឲ្យដល់ថ្នាក់កំពូល រមែងជាការប្រាសចាកតម្រេក ចាក សង្ខារទាំងឡាយ ដោយប្រកបដោយមគ្គញាណ ។ បទថា **វិរាគា វិមុច្ចតិ**

បានដល់ ចិត្តរមែងរួចផុតដោយបង្អោនទៅក្នុងនិព្វាន ដោយផលវិមុត្តិ ព្រោះមគ្គ ពោលគឺវិរាគៈជាហេតុ ។ តែក្នុងវារៈនេះ ក្នុងគម្ពីរខ្លះលោកសរសេរន័យក្នុងសច្ចៈ មានជាដើមថា រមែងដឹងតាមសេចក្តីពិតថា នេះទុក្ខ ដោយចិត្តតាំងមាំ ។ ម្យ៉ាងទៀត ក្នុងគម្ពីរខ្លះ លោកសរសេរន័យរបស់សច្ចៈនោះ ដោយន័យមានជាដើមថា រមែងធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញាថា នេះទុក្ខ ។ សូម្បីក្នុង ២ វារៈនោះ ក៏ផ្សេងគ្នាដោយព្យញ្ជនៈប៉ុណ្ណោះ ដោយអត្ថមិនផ្សេងគ្នាឡើយ ព្រោះពោលដល់មគ្គញ្ញាណថា កាលនៀយណាយ រមែងធុញទ្រាន់ និងកាលមគ្គញ្ញាណសម្រេចហើយ ជាការសម្រេចកិច្ច គឺការត្រាស់ដឹងអរិយសច្ច ៤ ផងដែរ ។ ព្រោះហេតុនោះ សូម្បីវារៈដែលលោកពោលដោយន័យរបស់សច្ចៈ ៤ ក៏មិនបានផ្សេងគ្នាដោយអត្ថ ដោយវារៈនេះ ។

ឥឡូវនេះ ព្រះសារីបុត្តត្ថេរ កាលនឹងឲ្យអារម្មណ៍ផ្សេងគ្នា ព្រោះពោលដល់អារម្មណ៍មិនផ្សេងគ្នាហើយដោយបទ មានជាដើមថា **អនិច្ចតោ** ទើបពោលពាក្យដើមថា **រូបំ អនិច្ចតោ មនសិករោតិ ។**

[ ១៨៣ ] បទថា **យោនិសោមនសិការមូលកា** មានវិគ្គហៈថា យោនិសោមនសិការជាខាងដើម ជាមូលនៃធម៌ទាំងនោះ ព្រោះហេតុនោះ ទើបឈ្មោះថា **យោនិសោមនសិការមូលកា ។** ព្រោះធម៌ ៩ ប្រការ មានបាមោជ្ជជាដើម លះយោនិសោមនសិការចេញហើយ រមែងមានមិនបាន ។

បទថា **សមាហិតេន ចិត្តេន** បានដល់ ដោយចិត្តជាហេតុ ។ បទថា **យថាភូតំ បជានាតិ** បានដល់ រមែងដឹងដោយបញ្ញា ។ កាលពោលថា

រមែងមនសិការដោយឧបាយប្រាជ្ញាថា នេះទុក្ខ លោកសង្គ្រោះសូម្បីការត្រាស់ដឹងសច្ចៈដែលជាចំណែកខាងដើម ដោយអំណាចតាមដែលស្តាប់មក ។ បទថា **យោនិសោមនសិការោ** បានដល់ មនសិការដោយឧបាយ ។

[ ១៨៤ ] បទថា **ធាតុនានត្តំ បដិច្ច ឧប្បជ្ជតិ ផស្សនានត្តំ** សេចក្តីថា ការផ្សេងៗ នៃចក្ខុសម្ផស្សជាដើមអាស្រ័យការផ្សេងៗ នៃចក្ខុធាតុជាដើម កើតឡើង ។ បទថា **ផស្សនានត្តំ បដិច្ច** បានដល់ អាស្រ័យការផ្សេងៗ នៃចក្ខុសម្ផស្សជាដើម ។ បទថា **វេទនានានត្តំ** បានដល់ ការផ្សេងៗ នៃចក្ខុសម្ផស្សជាវេទនាជាដើម ។ បទថា **សញ្ញានានត្តំ** បានដល់ សេចក្តីផ្សេងៗ នៃកាមសញ្ញាជាដើម ។ បទថា **សង្កប្បនានត្តំ** បានដល់ សេចក្តីផ្សេងៗ នៃការត្រិះរិះដល់កាមជាដើម ។ បទថា **ឆន្ទនានត្តំ** បានដល់ ការផ្សេងៗ នៃឆន្ទៈរមែងកើតឡើងយ៉ាងនេះថា ឆន្ទៈក្នុងរូប ឆន្ទៈក្នុងសំឡេងព្រោះការផ្សេងៗ នៃការត្រិះរិះ ។ បទថា **បរិឡាហនានត្តំ** បានដល់ ការផ្សេងៗ នៃការក្តៅក្រហាយ រមែងកើតឡើងយ៉ាងនេះថា ការក្តៅក្រហាយក្នុងរូប ការក្តៅក្រហាយក្នុងសំឡេង ព្រោះការផ្សេងៗ នៃឆន្ទៈ ។ បទថា **បរិយេសនានានត្តំ** បានដល់ ការផ្សេងៗ នៃការស្វែងរករូបជាដើម រមែងកើតឡើងព្រោះការផ្សេងៗ នៃការក្តៅក្រហាយ ។ បទថា **លាភនានត្តំ** បានដល់ ការផ្សេងៗ នៃការបានរូបជាដើម រមែងកើតឡើង ព្រោះការផ្សេងៗ នៃការស្វែងរក ៕

**អដ្ឋកថាធម្មនានត្តញ្ញាណនិទ្ទេស ចប់**

# សុត្តន្តបិដក

[ ១៨៥ ] បញ្ញាដែលជាគ្រឿងដឹងដ៏ប្រសើរ ឈ្មោះថា ញាតដ្ឋញ្ញាណ បញ្ញាសម្រាប់ដឹងជ្រួតជ្រាប ឈ្មោះថា តីរណដ្ឋញ្ញាណ បញ្ញាសម្រាប់លះ ឈ្មោះថា បរិច្ចាគដ្ឋញ្ញាណ បញ្ញាជាគ្រឿងអប់រំ ឈ្មោះថា ឯករសដ្ឋញ្ញាណ បញ្ញាជាគ្រឿងធ្វើឲ្យជាក់ច្បាស់ ឈ្មោះថា ផស្សនដ្ឋញ្ញាណ តើដូចម្តេច ។ ពួកធម៌ណាៗ ដែលបុគ្គលដឹងច្បាស់ហើយ ពួកធម៌នោះៗ ឈ្មោះថា បុគ្គលដឹងហើយ ពួកធម៌ណាៗ ដែលបុគ្គលកំណត់ដឹងហើយ ពួកធម៌នោះៗ ឈ្មោះថា បុគ្គលពិចារណាហើយ ពួកធម៌ណាៗ ដែលបុគ្គលលះបង់ហើយ ពួកធម៌នោះៗ ឈ្មោះថា បុគ្គលលះស្រឡះហើយ ពួកធម៌ណាៗ ដែលបុគ្គលចម្រើនហើយ ពួកធម៌នោះៗ ឈ្មោះថា មានរសតែមួយ ពួកធម៌ណាៗ ដែលបុគ្គលធ្វើឲ្យជាក់ច្បាស់ហើយ ពួកធម៌នោះៗ ឈ្មោះថា បុគ្គលប៉ះពាល់ហើយ ដែលឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាជាគ្រឿងដឹងដ៏ប្រសើរ ឈ្មោះថា ញាតដ្ឋញ្ញាណ បញ្ញា សម្រាប់ដឹងជ្រួតជ្រាប ឈ្មោះថា តីរណដ្ឋញ្ញាណ បញ្ញាសម្រាប់លះ ឈ្មោះថា បរិច្ចាគដ្ឋញ្ញាណ បញ្ញាជាគ្រឿងអប់រំ ឈ្មោះថា ឯករសដ្ឋញ្ញាណ បញ្ញាជាគ្រឿង ធ្វើឲ្យជាក់ច្បាស់ ឈ្មោះថា ផស្សនដ្ឋញ្ញាណ ។

# អដ្ឋកថា

## ញាណបញ្ចកនិទ្ទេស

[ ១៨៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងញាណបញ្ចកនិទ្ទេស ដូចតទៅនេះថា លោកធ្វើបុច្ឆាវិសជ្ជនារួមគ្នាតែមួយប៉ុណ្ណោះ ព្រោះញាណទាំង ៥ នោះ មានការសម្ពន្ធគ្នាជាលំដាប់ ។ បទថា **អភិញ្ញាតា ហោន្តិ** បានដល់ ជាអ្នកដឹងដោយល្អដោយអំណាចដឹងលក្ខណៈនៃសភាវធម៌ ។ បទថា **ញាតា ហោន្តិ** បានដល់ ឈ្មោះថា ជាការដឹងហើយ ព្រោះដឹងតាមសភាវៈ ដោយអំណាចនៃញាតបរិញ្ញា ។ គប្បីជ្រាបការភ្ជាប់សេចក្តីថា ធម៌ទាំងនោះ ដឹងហើយដោយញាណណា ញាណនោះ ឈ្មោះថា ញាណ ព្រោះអត្ថថា ដឹង ឈ្មោះថា បញ្ញា ព្រោះអត្ថថា ដឹងច្បាស់ ។ ដោយន័យនេះ គប្បីប្រកបសូម្បីញាណដ៏សេស ។ បទថា **បរិញ្ញាតា ហោន្តិ** បានដល់ ដឹងដោយជុំវិញដោយអំណាចនៃសាមញ្ញលក្ខណៈ ។ បទថា **តីរិតា ហោន្តិ** បានដល់ ធម៌ដែលចូលទៅពិចារណា ដោយភាពជារបស់មិនទៀងជាដើម ដោយអំណាចតីរណបរិញ្ញា ឈ្មោះថា ដល់ទីបំផុតហើយ ។ បទថា **បហីនា ហោន្តិ** បានដល់ លះនិច្ចសញ្ញាជាដើម ដោយអនិច្ចានុបស្សនាញាណជាដើម តាំងពីភង្គានុបស្សនាញាណ ។ បទថា **បរិច្ចត្តា ហោន្តិ** បានដល់ ដកចោលដោយអំណាចនៃការលះនោះឯង ។ បទថា **ភាវិតា ហោន្តិ** បានដល់ ចម្រើនហើយ និងអប់រំហើយ ។ បទថា **ឯករសា ហោន្តិ** បានដល់ មានកិច្ចដូចគ្នាដោយការឲ្យសម្រេចកិច្ចរបស់ខ្លួន និងដោយការលះធម៌ចំណែកផ្ទុយគ្នា ឬ

មានរសតែមួយ ដូចគ្នាដោយវិមុត្តិរស ដោយអំណាចផុតចាកធម៌ជាចំណែកសត្រូវ ។ បទថា **សច្ឆិកតា ហោន្តិ** បានដល់ ធ្វើឲ្យប្រចក្សហើយ ជាផលធម៌ ដោយអំណាចការបាននិព្វានធម៌ ដោយអំណាចការចាក់ធ្លុះ ។ បទថា **ផស្សិតា ហោន្តិ** បានដល់ ពាល់ត្រូវ គឺបានទទួលផលដោយការពាល់ត្រូវ ដោយការបាន និងដោយការពាល់ត្រូវ ដោយការចាក់ធ្លុះ ។ លោកពោលញាណទាំង ៥ នេះ ដោយអំណាចសុតមយញ្ញាណហើយក្នុងខាងដើម ក្នុងទីនេះ លោកពោលដោយអំណាចការញ៉ាំងកិច្ចរបស់ខ្លួនឲ្យសម្រេច ។ល។

## អដ្ឋកថាញាណបញ្ចកនិទ្ទេស ចប់

# សុត្តន្តបិដក

[ ១៨៦ ] បញ្ញាក្នុងអត្ថផ្សេងៗ ឈ្មោះថា អត្ថប្បដិសម្ភិទាញាណ បញ្ញាក្នុងធម៌ផ្សេងៗ ឈ្មោះថា ធម្មប្បដិសម្ភិទាញាណ បញ្ញាក្នុងនិរុត្តិផ្សេងៗ ឈ្មោះថា និរុត្តិបដិសម្ភិទាញាណ បញ្ញាក្នុងបដិភាណផ្សេងៗ ឈ្មោះថា បដិភាណប្បដិសម្ភិទាញាណ តើដូចម្តេច ។

ធម៌ គឺសទ្ធិន្ទ្រិយ ធម៌ គឺវីរិយិន្ទ្រិយ ធម៌ គឺសតិន្ទ្រិយ ធម៌ គឺសមាធិន្ទ្រិយ ធម៌ គឺបញ្ញិន្ទ្រិយ ធម៌ គឺសទ្ធិន្ទ្រិយផ្សេង ធម៌ គឺវីរិយិន្ទ្រិយផ្សេង ធម៌ គឺសតិន្ទ្រិយផ្សេង ធម៌ គឺសមាធិន្ទ្រិយផ្សេង ធម៌ គឺបញ្ញិន្ទ្រិយផ្សេង ពួកធម៌ផ្សេងៗ នេះ បុគ្គលដឹងហើយដោយញាណណា ពួកធម៌ផ្សេងៗ នេះ បុគ្គលដឹងច្បាស់ហើយ ដោយញាណនោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងធម៌ផ្សេងៗ ឈ្មោះថា ធម្មប្បដិសម្ភិទាញាណ ។

[ ១៨៧ ] អត្ថ គឺសេចក្តីនៃការជឿស៊ប់ អត្ថ គឺសេចក្តីនៃការផ្គងឡើង អត្ថ គឺសេចក្តីនៃការប្រុងប្រយ័ត្ន អត្ថ គឺសេចក្តីនៃការមិនរាយមាយ អត្ថ គឺសេចក្តីនៃការឃើញ អត្ថ គឺសេចក្តីនៃការជឿស៊ប់ផ្សេង អត្ថ គឺសេចក្តីនៃការផ្គងឡើងផ្សេង អត្ថ គឺសេចក្តីនៃការប្រុងប្រយ័ត្នផ្សេង អត្ថ គឺសេចក្តីនៃការមិនរាយមាយផ្សេង អត្ថ គឺសេចក្តីនៃការឃើញផ្សេង អត្ថទាំងឡាយផ្សេងៗ នេះ បុគ្គលដឹងហើយដោយញាណណា អត្ថទាំងឡាយផ្សេងៗ នេះ បុគ្គលដឹងច្បាស់ហើយ ដោយញាណនោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងអត្ថផ្សេងៗ ឈ្មោះថា អត្ថប្បដិសម្ភិទាញាណ ។

[ ១៨៨ ] ការពោលដោយព្យញ្ជនៈ និងនិរុត្តិដើម្បីពន្យល់នូវធម៌ទាំង ៥ ការពោលដោយព្យញ្ជនៈ និងនិរុត្តិ ដើម្បីពន្យល់នូវអត្ថទាំង ៥ ធម្មនិរុត្តិផ្សេង អត្ថនិរុត្តិផ្សេង និរុត្តិទាំងឡាយផ្សេងៗ នេះ បុគ្គលដឹងហើយដោយញាណណា និរុត្តិទាំងឡាយផ្សេងៗ នេះ បុគ្គលដឹងច្បាស់ហើយដោយញាណនោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងនិរុត្តិផ្សេងៗ ឈ្មោះថា និរុត្តិប្បដិសម្ភិទាញាណ ។

[ ១៨៩ ] ពួកញាណក្នុងធម៌ទាំង ៥ ពួកញាណក្នុងអត្ថទាំង ៥ ពួកញាណក្នុងនិរុត្តិទាំង ១០ ពួកញាណក្នុងធម៌ទាំងឡាយផ្សេង ពួកញាណក្នុងអត្ថទាំងឡាយផ្សេង ពួកញាណក្នុងនិរុត្តិទាំងឡាយផ្សេង ពួកញាណផ្សេងៗ នេះ បុគ្គលដឹងហើយដោយញាណណា ពួកញាណផ្សេងៗ នេះ បុគ្គលដឹងច្បាស់ហើយដោយញាណនោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងបដិភាណផ្សេងៗ ឈ្មោះថា បដិភាណប្បដិសម្ភិទាញាណ ។

[ ១៩០ ] ធម៌ គឺសទ្ធាពល ធម៌ គឺវិរិយពល ធម៌ គឺសតិពល ធម៌ គឺសមាធិពល ធម៌ គឺបញ្ញាពល ធម៌ គឺសទ្ធាពលផ្សេង ធម៌ គឺវិរិយពលផ្សេង ធម៌ គឺសតិពលផ្សេង ធម៌ គឺសមាធិពលផ្សេង ធម៌ គឺបញ្ញាពលផ្សេង ពួកធម៌ផ្សេងៗ នេះ បុគ្គលដឹងហើយដោយញាណណា ពួកធម៌ផ្សេងៗ នេះ បុគ្គលដឹងច្បាស់ហើយ ដោយញាណនោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងធម៌ផ្សេងៗ ឈ្មោះថា ធម្មប្បដិសម្ភិទាញាណ ។

[ ១៩១ ] អត្ថ គឺសេចក្តីនៃការមិនញាប់ញ័រ ក្នុងអស្សទ្ធិយៈ ( ការមិនជឿ ) អត្ថ គឺសេចក្តីនៃការមិនញាប់ញ័រក្នុងកោសជ្ជៈ អត្ថ គឺសេចក្តីនៃការមិន

ញាប់ញ័រក្នុងបមាទៈ អត្ថ គឺសេចក្តីនៃការមិនញាប់ញ័រក្នុងឧទ្ធច្ចៈ អត្ថ គឺសេចក្តីនៃការមិនញាប់ញ័រក្នុងអវិជ្ជា អត្ថ គឺសេចក្តីនៃការមិនញាប់ញ័រក្នុងអស្សទ្ធិយៈផ្សេង អត្ថ គឺសេចក្តីនៃការមិនញាប់ញ័រក្នុងកោសជ្ជៈផ្សេង អត្ថ គឺសេចក្តីនៃការមិនញាប់ញ័រក្នុងបមាទៈផ្សេង អត្ថ គឺសេចក្តីនៃការមិនញាប់ញ័រក្នុងឧទ្ធច្ចៈផ្សេង អត្ថ គឺសេចក្តីនៃការមិនញាប់ញ័រក្នុងអវិជ្ជាផ្សេង អត្ថទាំងឡាយផ្សេងៗនេះ បុគ្គលដឹងហើយដោយញាណណា អត្ថទាំងឡាយផ្សេងៗ នេះ បុគ្គលដឹងច្បាស់ហើយ ដោយញាណនោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងអត្ថផ្សេងៗ ឈ្មោះថា អត្ថប្បដិសម្ភិទាញាណ ។

[ ១៩២ ] ការពោលដោយព្យញ្ជនៈ និងនិរុត្តិដើម្បីពន្យល់នូវធម៌ទាំង ៥ ការពោលដោយព្យញ្ជនៈ និងនិរុត្តិដើម្បីពន្យល់នូវអត្ថទាំង ៥ ធម្មនិរុត្តិផ្សេង អត្ថនិរុត្តិផ្សេង និរុត្តិទាំងឡាយផ្សេងៗ នេះ បុគ្គលដឹងហើយដោយញាណណា និរុត្តិទាំងឡាយផ្សេងៗ នេះ បុគ្គលដឹងច្បាស់ហើយដោយញាណនោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងនិរុត្តិផ្សេងៗ ឈ្មោះថា និរុត្តិប្បដិសម្ភិទាញាណ ។

[ ១៩៣ ] ពួកញាណក្នុងធម៌ទាំង ៥ ពួកញាណក្នុងអត្ថទាំង ៥ ពួកញាណក្នុងនិរុត្តិទាំង ១០ ពួកញាណក្នុងធម៌ទាំងឡាយផ្សេង ពួកញាណក្នុងអត្ថទាំងឡាយផ្សេង ពួកញាណក្នុងនិរុត្តិទាំងឡាយផ្សេង ញាណទាំងឡាយផ្សេងៗ នេះ បុគ្គលដឹងហើយដោយញាណណា ញាណទាំងឡាយផ្សេងៗ នេះ បុគ្គលដឹងច្បាស់ហើយដោយញាណនោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងបដិភាណផ្សេងៗ ឈ្មោះថា បដិភាណប្បដិសម្ភិទាញាណ ។

[ ១៩៤ ] ធម៌ គឺសតិសម្ពោជ្ឈង្គ ធម៌ គឺធម្មវិចយសម្ពោជ្ឈង្គ ធម៌ គឺវីរិយ-សម្ពោជ្ឈង្គ ធម៌ គឺបីតិសម្ពោជ្ឈង្គ ធម៌ គឺបស្សទ្ធិសម្ពោជ្ឈង្គ ធម៌ គឺសមាធិ-សម្ពោជ្ឈង្គ ធម៌ គឺឧបេក្ខាសម្ពោជ្ឈង្គ ធម៌ គឺសតិសម្ពោជ្ឈង្គផ្សេង ធម៌ គឺធម្មវិចយសម្ពោជ្ឈង្គផ្សេង ធម៌ គឺវីរិយសម្ពោជ្ឈង្គផ្សេង ធម៌ គឺបីតិសម្ពោជ្ឈង្គផ្សេង ធម៌ គឺបស្សទ្ធិសម្ពោជ្ឈង្គផ្សេង ធម៌ គឺសមាធិសម្ពោជ្ឈង្គផ្សេង ធម៌ គឺឧបេក្ខាសម្ពោជ្ឈង្គផ្សេង ពួកធម៌ផ្សេងៗ នេះ បុគ្គលដឹងហើយដោយញាណណា ពួកធម៌ផ្សេងៗ នេះ បុគ្គលដឹងច្បាស់ហើយដោយញាណនោះ ហេតុនោះលោកពោ ថា បញ្ញាក្នុងធម៌ផ្សេងៗ ឈ្មោះថា ធម្មប្បដិសម្ភិទាញាណ ។

[ ១៩៥ ] អត្ថ គឺសេចក្តីនៃការប្រុងប្រយ័ត្ន អត្ថ គឺសេចក្តីនៃការជ្រើសរើស អត្ថ គឺសេចក្តីនៃការផ្គងឡើង អត្ថ គឺសេចក្តីនៃការផ្សាយ អត្ថ គឺសេចក្តីនៃការស្ងប់ អត្ថ គឺសេចក្តីនៃការមិនរាយមាយ អត្ថ គឺសេចក្តីនៃការពិចារណា អត្ថ គឺសេចក្តីនៃការប្រុងប្រយ័ត្នផ្សេង អត្ថ គឺសេចក្តីនៃការជ្រើសរើសផ្សេង អត្ថ គឺសេចក្តីនៃការផ្គងឡើងផ្សេង អត្ថ គឺសេចក្តីនៃការផ្សាយផ្សេង អត្ថ គឺសេចក្តីនៃការស្ងប់ផ្សេង អត្ថ គឺសេចក្តីនៃការមិនរាយមាយផ្សេង អត្ថ គឺសេចក្តីនៃការពិចារណាផ្សេង អត្ថទាំងឡាយផ្សេងៗ នេះ បុគ្គលដឹងហើយដោយញាណណា អត្ថទាំងឡាយផ្សេងៗ នេះ បុគ្គលដឹងច្បាស់ហើយដោយញាណនោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងអត្ថផ្សេងៗ ឈ្មោះថា អត្ថប្បដិ-សម្ភិទាញាណ ។

[ ១៩៦ ] ការពោលដោយព្យញ្ជនៈ និងនិរុត្តិដើម្បីពន្យល់នូវធម៌ទាំង ៧

ការពោលដោយព្យញ្ជនៈ និងនិរុត្តិ ដើម្បីពន្យល់នូវអត្ថទាំង ៧ ធម្មនិរុត្តិផ្សេង អត្ថនិរុត្តិផ្សេង និរុត្តិទាំងឡាយផ្សេងៗ នេះ បុគ្គលដឹងហើយដោយញាណណា និរុត្តិទាំងឡាយផ្សេងៗ នេះ បុគ្គលដឹងច្បាស់ហើយដោយញាណនោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងនិរុត្តិផ្សេងៗ ឈ្មោះថា និរុត្តិប្បដិសម្ភិទាញាណ ។

[ ១៩៧ ] ពួកញាណក្នុងធម៌ទាំង ៧ ពួកញាណក្នុងអត្ថទាំង ៧ ពួកញាណក្នុងនិរុត្តិទាំង ១៤ ពួកញាណក្នុងធម៌ទាំងឡាយផ្សេង ពួកញាណក្នុងអត្ថទាំងឡាយផ្សេង ពួកញាណក្នុងនិរុត្តិទាំងឡាយផ្សេង ញាណទាំងឡាយផ្សេងៗ នេះ បុគ្គលដឹងហើយដោយញាណណា ញាណទាំងឡាយផ្សេងៗ នេះ បុគ្គលដឹងច្បាស់ហើយ ដោយញាណនោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងបដិភាណផ្សេងៗ ឈ្មោះថា បដិភាណប្បដិសម្ភិទាញាណ ។

[ ១៩៨ ] ធម៌ គឺសម្មាទិដ្ឋិ ធម៌ គឺសម្មាសង្កប្ប ធម៌ គឺសម្មាវាចា ធម៌ គឺសម្មាកម្មន្តៈ ធម៌ គឺសម្មាអាជីវៈ ធម៌ គឺសម្មាវាយាមៈ ធម៌ គឺសម្មាសតិ ធម៌ គឺសម្មាសមាធិ ធម៌ គឺសម្មាទិដ្ឋិផ្សេង ធម៌ គឺសម្មាសង្កប្បផ្សេង ធម៌ គឺសម្មាវាចាផ្សេង ធម៌ គឺសម្មាកម្មន្តៈផ្សេង ធម៌ គឺសម្មាអាជីវៈផ្សេង ធម៌ គឺសម្មាវាយាមៈផ្សេង ធម៌ គឺសម្មាសតិផ្សេង ធម៌ គឺសម្មាសមាធិផ្សេង ធម៌ទាំងឡាយផ្សេងៗ នេះ បុគ្គលដឹងហើយដោយញាណណា ធម៌ទាំងឡាយផ្សេងៗ នេះ បុគ្គលដឹងច្បាស់ហើយដោយញាណនោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងធម៌ផ្សេងៗ ឈ្មោះថា ធម្មប្បដិសម្ភិទាញាណ ។

[ ១៩៩ ] អត្ថ គឺសេចក្តីនៃការឃើញ អត្ថ គឺសេចក្តីនៃការលើកចិត្តឡើង

( កាន់អារម្មណ៍ ) អត្ថ គឺសេចក្តីនៃការរក្សាទុក អត្ថ គឺសេចក្តីនៃការតាំងឡើងព្រម អត្ថ គឺសេចក្តីនៃការផ្សំផ្គុំ អត្ថ គឺសេចក្តីនៃការផ្គងឡើង អត្ថ គឺសេចក្តីនៃការប្រុងប្រយ័ត្ន អត្ថ គឺសេចក្តីនៃការមិនរាយមាយ អត្ថ គឺសេចក្តីនៃការឃើញដទៃ អត្ថ គឺសេចក្តីនៃការលើកចិត្តឡើង ( កាន់អារម្មណ៍ ) ផ្សេង អត្ថ គឺសេចក្តីនៃការរក្សាទុកផ្សេង អត្ថ គឺសេចក្តីនៃការតាំងឡើងព្រមផ្សេង អត្ថ គឺសេចក្តីនៃការផ្សំផ្គុំផ្សេង អត្ថ គឺសេចក្តីនៃការផ្គងឡើងផ្សេង អត្ថ គឺសេចក្តីនៃការប្រុងប្រយ័ត្នផ្សេង អត្ថ គឺសេចក្តីនៃការមិនរាយមាយផ្សេង អត្ថទាំងឡាយផ្សេងៗ នេះ បុគ្គលដឹងហើយដោយញាណណា អត្ថទាំងឡាយផ្សេងៗ នេះ បុគ្គលដឹងច្បាស់ហើយដោយញាណនោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងអត្ថផ្សេងៗ ឈ្មោះថា អត្ថប្បដិសម្ភិទាញាណ ។

[ ២០០ ] ការពោលដោយព្យញ្ជនៈ និងនិរុត្តិដើម្បីពន្យល់នូវធម៌ទាំង ៨ ការពោលដោយព្យញ្ជនៈ និងនិរុត្តិដើម្បីពន្យល់នូវអត្ថទាំង ៨ ធម្មនិរុត្តិផ្សេង អត្ថនិរុត្តិផ្សេង និរុត្តិទាំងឡាយផ្សេងៗ នេះ បុគ្គលដឹងហើយដោយញាណណា និរុត្តិទាំងឡាយផ្សេងៗ នេះ បុគ្គលដឹងច្បាស់ហើយដោយញាណនោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងនិរុត្តិផ្សេងៗ ឈ្មោះថា និរុត្តិប្បដិសម្ភិទាញាណ ។

[ ២០១ ] ពួកញាណក្នុងធម៌ទាំង ៨ ពួកញាណក្នុងអត្ថទាំង ៨ ពួកញាណក្នុងនិរុត្តិទាំង ១៦ ពួកញាណក្នុងធម៌ទាំងឡាយផ្សេង ពួកញាណក្នុងអត្ថទាំងឡាយផ្សេង ពួកញាណក្នុងនិរុត្តិទាំងឡាយផ្សេង ញាណទាំងឡាយផ្សេងៗ នេះ បុគ្គលដឹងហើយដោយញាណណា ញាណទាំងឡាយផ្សេងៗ

នេះ បុគ្គលដឹងច្បាស់ហើយដោយញាណនោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងបដិភាណផ្សេងៗ ឈ្មោះថា បដិភាណប្បដិសម្ភិទាញាណ ដែលឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ព្រោះហេតុនោះ លោកពោលថា បញ្ញាក្នុងអត្ថផ្សេងៗ ឈ្មោះថា អត្ថប្បដិសម្ភិទាញាណ បញ្ញាក្នុងធម៌ផ្សេងៗ ឈ្មោះថា ធម្មប្បដិសម្ភិទាញាណ បញ្ញា ក្នុងនិរុត្តិផ្សេងៗ ឈ្មោះថា និរុត្តិប្បដិសម្ភិទាញាណ បញ្ញាក្នុងបដិភាណ ផ្សេងៗ ឈ្មោះថាបដិភាណប្បដិសម្ភិទាញាណ ។

# អដ្ឋកថា

## បដិសម្ភិទាញាណនិទ្ទេស

[ ១៨៦-២០១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបដិសម្ភិទាញាណនិទ្ទេសដូចតទៅ ព្រោះកាលមិនពោលធម៌ ក៏មិនអាចពោលដល់កិច្ចរបស់ធម៌នោះបាន ហេតុនោះ ទើបខ្ញុំមិនដាក់ចិត្តដល់លំដាប់នៃធម៌ ដែលលោកសម្តែងហើយ តែនឹងសម្តែងធម៌ទាំងឡាយមុន ។ អត្ថនៃធម៌ជាដើម ខ្ញុំបានពោលហើយ ។

ព្រះសារីបុត្តត្ថេរ កាលពោលធម៌ដែលទាក់ទងក្នុង **ធម្ម** សព្ទ ដោយបទថា **សទ្ធិន្ទ្រិយំ ធម្មោ** ជាដើម កាលនឹងសម្តែងអត្ថនៃ **ឆានត្ត** សព្ទ ទើបពោលពាក្យថា **អញ្ញោ សទ្ធិន្ទ្រិយំ ធម្មោ** ជាដើម ។ ពិតហើយ កាលលោកពោលថា **អញ្ញោ ធម្មោ** ឈ្មោះថា លោកសម្តែងដល់ការផ្សេងគ្នានៃធម៌ទាំងឡាយ ។ បទថា **បដិវិទិតា** បានដល់ ឈ្មោះថា ដឹងច្បាស់ គឺប្រាកដដោយភាពជាធម៌ចំពោះមុខ ។ ដោយបទនោះ លោកពោលដល់អត្ថនៃបទថា បដិសម្ភិទា ។

ព្រះសារីបុត្តត្ថេរសម្តែងថា កិច្ច មានការបង្អោនចិត្តជឿជាដើម ជាអត្ថនៃសទ្ធាជាដើមទាំងនោះ ដោយបទថា **អធិមោក្ខដ្ឋោ អត្ថោ** ជាដើម ។ បទថា **សន្ទស្សេតុំ** បានដល់ ដើម្បីសម្តែងដល់បុគ្គលដទៃ របស់បុគ្គលដែលប្រាថ្នានឹងឲ្យបុគ្គលដទៃកំណត់បាន កាលអ្នកដទៃស្តាប់វាចា ក៏រមែងបានដូចគ្នា ។ បទថា **ព្យញ្ជននិរុត្តាភិលាបា** បានដល់ ព្យញ្ជនៈ គឺនាម និរុត្តិ គឺនាម ការពោល គឺនាម ។ នាម ហៅថា ព្យញ្ជនៈ ព្រោះអត្ថថា ធ្វើអត្ថឲ្យប្រាកដ

ហៅថា និរុត្តិ ព្រោះផ្ដោតចំពោះយ៉ាងនេះ ( ក្នុងសំយុត្តនិកាយ ខន្ធវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ សភាវៈទាំងឡាយណា តាក់តែងនូវសង្ខតធម៌ សភាវៈទាំងឡាយនោះ ហៅថា សង្ខារ ដូច្នេះហើយ ពោលធ្វើឲ្យមានហេតុ ហៅថា ការពោល ព្រោះជាហេតុប្រាព្ធដល់អត្ថ ។ ម្យ៉ាងទៀត ឈ្មោះថា **នាម** នេះ មាន ៤ យ៉ាង គឺសាមញ្ញនាម ១ គុណនាម ១ កិត្តិមនាម ១ ឱបបាតិកនាម ១ ។ ក្នុងនាម ៤ យ៉ាងនោះ ក្នុងបឋមកប្ប ព្រះនាមរបស់ព្រះរាជាថា មហាសម្មតិរាជ ព្រោះមហាជនសម្មតិតាំងឡើង ឈ្មោះថា សាមញ្ញនាម ។

លោកពោលសំដៅដល់ពាក្យ ( ក្នុងទីឃនិកាយ បាដិកវគ្គ ) ថា ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ សត្វនោះ មហាជនសន្មតហើយ ព្រោះហេតុនោះឯង ទើបអក្ខរៈជាដំបូងក៏កើតឡើងថា មហាសន្មត ដូច្នេះ ។

ឈ្មោះដែលបានមក ដោយគុណយ៉ាងនេះថា **ធម្មកថិកោ** ព្រះធម្មកថិក **បំសុកូលិកោ** អ្នកទ្រទ្រង់សំពត់បង្សុកូល **វិនយធរោ** អ្នកទ្រទ្រង់វិន័យ **តិបិដកធរោ** អ្នកទ្រទ្រង់បិដក ៣ **សទ្ធោ** អ្នកមានសទ្ធា **សតោ** អ្នកមានសតិ ដូច្នេះ ឈ្មោះថា គុណនាម ។ ឈ្មោះដោយគុណរបស់ព្រះតថាគតច្រើនរយ ឈ្មោះមានឈ្មោះថា **ភគវា អរហំ សម្មាសម្ពុទ្ធោ** ជាដើម ដូចលោកពោលថា

ព្រះនាមរបស់ព្រះតថាគត អ្នកស្វែងរកគុណដ៏ធំក្រៃលែង ព្រម
ដោយគុណមានប្រមាណមិនបាន ។ បណ្ឌិតគួរលើកព្រះនាម
ដោយព្រះគុណឡើងសម្ដែង សូម្បីទាំងពាន់ព្រះនាម ។

*ក្នុងថ្ងៃដាក់ឈ្មោះក្មេងដែលទើបនឹងកើត ពួកញាតិនាំគ្នាធ្វើសក្ការៈ ដល់ទក្ខិណេយ្យបុគ្គលហើយ នៅក្នុងទីជិតៗ កំណត់ដាក់ឈ្មោះថា ទារកនេះឈ្មោះនោះ ដូច្នេះ នេះឈ្មោះថា កិត្តិមនាម ។*

*ម្យ៉ាងទៀត ការបញ្ញត្តិអំពីមុន ក៏ធ្លាក់ដល់ការបញ្ញត្តិបន្ទមក វោហារអំពីមុន ក៏ធ្លាក់ដល់វោហារខាងក្រោយ ។ ដូចក្នុងបុរិមកប្ប ព្រះចន្ទ ក៏ឈ្មោះថាចន្ទ សូម្បីមកដល់ពេលនេះ ក៏នៅឈ្មោះថា ចន្ទនោះឯង ។ ក្នុងអតីត* **សុរិយោ** *ព្រះអាទិត្យ* **សមុទ្ទោ** *សមុទ្ទ* **បថវី** *ដី* **បព្វតោ** *ភ្នំ ក៏ឈ្មោះថា ភ្នំ សូម្បីឥឡូវនេះ ក៏នៅឈ្មោះថាភ្នំនោះឯង នេះឈ្មោះថា ឱបបាតិកនាម ។ ឈ្មោះសូម្បី ៤ យ៉ាងនេះ ក៏ជាឈ្មោះតែមួយនោះឯង ។ ឈ្មោះនោះ ប្រើត្រឹមតែជាការសង្កេតរបស់មនុស្សលោក ពោលដោយបរមត្ថ មិនមាន ។ ឯអាចារ្យពួកដទៃ ពោលថា ឈ្មោះថា នាម ជាសំឡេងបញ្ជាក់ដល់អត្ថ ។*

*គប្បីជ្រាបអត្ថនៃពល ពោជ្ឈង្គ និងអង្គមគ្គដោយទំនងដូចគ្នានឹងន័យដូចពោលហើយនោះឯង ។*

## អដ្ឋកថាបដិសម្ភិទាញាណនិទ្ទេស ចប់

# សុត្តន្តបិដក

[ ២០២ ] បញ្ញាក្នុងវិបស្សនាវិហារផ្សេងៗ ឈ្មោះថា វិហារដ្ឋញ្ញាណ បញ្ញាក្នុងផលសមាបត្តិផ្សេងៗ ឈ្មោះថា សមាបត្តដ្ឋញ្ញាណ បញ្ញាក្នុងវិហារសមាបត្តិផ្សេងៗ ឈ្មោះថា វិហារសមាបត្តដ្ឋញ្ញាណ តើដូចម្ដេច ។

បុគ្គលកាលពិចារណា ឃើញនូវនិមិត្តថាគួរខ្លាច រមែងពាល់ត្រូវរឿយៗ ហើយឃើញនូវកិរិយាសូន្យទៅ ព្រោះចុះចិត្តស៊ប់ក្នុងព្រះនិព្វានដែលមិនមាននិមិត្ត ឈ្មោះថា អនិមិត្តវិហារធម៌ ( សភាវៈជាទីសម្រាកមិនមានកិលេសជានិមិត្ត ) បុគ្គលកាលពិចារណាឃើញនូវបណិធិ ( ធម្មជាតមានកិលេសជាទីតាំង ) ថាគួរខ្លាច រមែងពាល់ត្រូវរឿយៗ ហើយឃើញនូវកិរិយាសូន្យទៅ ព្រោះចុះចិត្តស៊ប់ក្នុងព្រះនិព្វានដែលមិនមានកិលេសជាទីតាំង ឈ្មោះថា អប្បណិហិតវិហារធម៌ ( សភាវៈជាទីសម្រាកមិនមានកិលេសជាទីតាំង ) បុគ្គលកាលពិចារណាឃើញនូវអភិនិវេសៈ ( ការប្រកាន់មាំ ) ថាគួរខ្លាច រមែងពាល់ត្រូវរឿយៗ ហើយឃើញនូវកិរិយាសូន្យទៅ ព្រោះចុះចិត្តស៊ប់ក្នុងព្រះនិព្វានដែលសូន្យចាកកិលេស ឈ្មោះថា សុញ្ញតវិហារធម៌ ( សភាវៈជាទីសម្រាកសូន្យចាកអត្តា ) ។

[ ២០៣ ] បុគ្គលកាលពិចារណាឃើញនូវនិមិត្តថាគួរខ្លាច រមែងព្រងើយកន្តើយក្នុងការប្រព្រឹត្តទៅ ព្រោះចុះចិត្តស៊ប់ក្នុងព្រះនិព្វាន ដែលមិនមាននិមិត្ត ហើយពិចារណានូវធម៌មិនមាននិមិត្ត គឺនិព្វានដែលជាទីរលត់ទុក្ខ ហើយចូល ( កាន់ផលសមាបត្តិ ) ឈ្មោះថា អនិមិត្តសមាបត្តិ ( សមាបត្តិមិនមានកិលេសជានិមិត្ត ) បុគ្គលកាលពិចារណាឃើញនូវបណិធិ ថាគួរខ្លាច រមែងព្រងើយ

កន្ដើយក្នុងការប្រព្រឹត្តទៅ ព្រោះចុះចិត្តស៊ប់ក្នុងព្រះនិព្វានដែលមិនមានបណិធិ ហើយពិចារណានូវធម៌ដែលមិនមានបណិធិ គឺនិព្វានជាទីរលត់ទុក្ខ ហើយចូល ( កាន់ផលសមាបត្តិ ) ឈ្មោះថា អប្បណិហិតសមាបត្តិ ( សមាបត្តិមិនមានកិលេសជាទីតាំង ) បុគ្គលកាលពិចារណាឃើញនូវអភិនិវេសៈថាគួរខ្លាច រមែងព្រងើយកន្ដើយក្នុងការប្រព្រឹត្តទៅ ព្រោះចុះចិត្តស៊ប់ក្នុងព្រះនិព្វានដែលសូន្យចាកអត្តា ហើយពិចារណានូវធម៌ដែលសូន្យចាកអត្តា គឺនិព្វានជាទីរលត់ទុក្ខ ហើយចូល ( កាន់ផលសមាបត្តិ ) ឈ្មោះថា សុញ្ញតសមាបត្តិ ( សមាបត្តិសូន្យចាកអត្តា ) ។

[ ២០៤ ] បុគ្គលកាលពិចារណាឃើញនូវនិមិត្ត ថាគួរខ្លាច រមែងពាល់ត្រូវរឿយៗ ហើយឃើញនូវកិរិយាសូន្យទៅ ព្រោះចុះចិត្តស៊ប់ក្នុងព្រះនិព្វានដែលមិនមាននិមិត្ត រមែងព្រងើយកន្ដើយក្នុងការប្រព្រឹត្តទៅ ហើយពិចារណានូវធម៌ដែលមិនមាននិមិត្ត គឺនិព្វានជាទីរលត់ទុក្ខ ហើយចូល ( កាន់ផល-សមាបត្តិ ) ឈ្មោះថា អនិមិត្តវិហារសមាបត្តិ ( វិហារសមាបត្តិមិនមាននិមិត្ត ) បុគ្គលកាលពិចារណាឃើញនូវបណិធិថាគួរខ្លាច រមែងពាល់ត្រូវរឿយៗ ហើយឃើញនូវកិរិយាសូន្យទៅ ព្រោះចុះចិត្តស៊ប់ក្នុងព្រះនិព្វានមិនមានបណិធិ រមែងព្រងើយកន្ដើយក្នុងការប្រព្រឹត្តទៅ ហើយពិចារណានូវធម៌មិនមានបណិធិ គឺនិព្វានជាទីរលត់ទុក្ខ ហើយចូល ( កាន់ផលសមាបត្តិ ) ឈ្មោះថា អប្បណិ-ហិតវិហារសមាបត្តិ ( វិហារសមាបត្តិមិនមានបណិធិ ) បុគ្គលកាលពិចា-រណាឃើញនូវអភិនិវេសៈ ថាគួរខ្លាច រមែងពាល់ត្រូវរឿយៗ ហើយឃើញនូវ

កិរិយាសូន្យទៅ ព្រោះចុះចិត្តស៊ប់ក្នុងព្រះនិព្វាន ដែលសូន្យចាកអត្តា រមែងព្រងើយកន្តើយ ក្នុងការប្រព្រឹត្តទៅ ហើយពិចារណានូវធម៌ដែលសូន្យចាកអត្តា គឺនិព្វាន ជាទីរលត់ទុក្ខ ហើយចូល ( កាន់ផលសមាបត្តិ ) ឈ្មោះថា សុញ្ញតវិហារសមាបត្តិ ( វិហារសមាបត្តិសូន្យចាកអត្តា ) ។

[ ២០៥ ] បុគ្គលកាលពិចារណាឃើញនូវរូបនិមិត្ត ថាគួរខ្លាច រមែងពាល់ត្រូវរឿយៗ ហើយឃើញនូវកិរិយាសូន្យទៅ ព្រោះចុះចិត្តស៊ប់ក្នុងព្រះនិព្វានមិនមាននិមិត្ត ឈ្មោះថា អនិមិត្តវិហារធម៌ ( សភាវៈជាទីសម្រាកមិនមានកិលេសជានិមិត្ត ) បុគ្គលកាលពិចារណាឃើញនូវរូបបណិធិ ថាគួរខ្លាច រមែងពាល់ត្រូវរឿយៗ ហើយឃើញនូវកិរិយាសូន្យទៅ ព្រោះចុះចិត្តស៊ប់ក្នុងព្រះនិព្វានមិនមានបណិធិ ឈ្មោះថា អប្បណិហិតវិហារធម៌ ( សភាវៈជាទីសម្រាកមិនមានបណិធិ ) បុគ្គលកាលពិចារណាឃើញនូវរូបាភិនិវេសៈ ( ការប្រកាន់មាំនូវរូប ) ថាគួរខ្លាច រមែងពាល់ត្រូវរឿយៗ ហើយឃើញនូវកិរិយាសូន្យទៅ ព្រោះចុះចិត្តស៊ប់ក្នុងព្រះនិព្វានដែលសូន្យចាកអត្តា ឈ្មោះថា សុញ្ញតវិហារធម៌ ( សភាវៈជាទីសម្រាកសូន្យចាកអត្តា ) ។

[ ២០៦ ] បុគ្គលកាលពិចារណាឃើញនូវរូបនិមិត្ត ថាគួរខ្លាច រមែងព្រងើយកន្តើយ ក្នុងការប្រព្រឹត្តទៅ ហើយពិចារណានូវធម៌មិនមាននិមិត្ត គឺព្រះនិព្វានជាទីរលត់ទុក្ខ ហើយចូល ( កាន់ផលសមាបត្តិ ) ព្រោះចុះចិត្តស៊ប់ក្នុងព្រះនិព្វានមិនមាននិមិត្ត ឈ្មោះថា អនិមិត្តសមាបត្តិ បុគ្គលកាលពិចារណាឃើញនូវរូបបណិធិ ថាគួរខ្លាច រមែងព្រងើយកន្តើយក្នុងការប្រព្រឹត្តទៅ ហើយ

ពិចារណានូវធម៌មិនមានបណិធិ គឺព្រះនិព្វានជាទីរលត់ទុក្ខ ហើយចូល ( កាន់ផលសមាបត្តិ ) ព្រោះចុះចិត្តស៊ប់ក្នុងព្រះនិព្វាន មិនមានបណិធិ ឈ្មោះថា អប្បណិហិតសមាបត្តិ បុគ្គលកាលពិចារណាឃើញនូវរូបាភិនិវេសៈ ថាគួរខ្ពើម ព្រងើយកន្តើយក្នុងការប្រព្រឹត្តទៅ ហើយពិចារណានូវធម៌ដ៏សូន្យចាកអត្តា គឺព្រះនិព្វានជាទីរលត់ទុក្ខ ហើយចូល ( កាន់ផលសមាបត្តិ ) ព្រោះចុះចិត្តស៊ប់ក្នុងព្រះនិព្វានដ៏សូន្យចាកអត្តា ឈ្មោះថា សុញ្ញតសមាបត្តិ ។

[ ២០៧ ] បុគ្គលកាលពិចារណាឃើញនូវរូបនិមិត្ត ថាគួរខ្ពើម រមែងពាល់ត្រូវរឿយៗ ហើយឃើញនូវកិរិយាសូន្យទៅ ព្រោះចុះចិត្តស៊ប់ក្នុងព្រះនិព្វានមិនមាននិមិត្ត រមែងព្រងើយកន្តើយក្នុងការប្រព្រឹត្តទៅ ហើយពិចារណានូវធម៌មិនមាននិមិត្ត គឺព្រះនិព្វានជាទីរលត់ទុក្ខ ហើយចូល ( កាន់ផលសមាបត្តិ ) ឈ្មោះថា អនិមិត្តវិហារសមាបត្តិ បុគ្គលកាលពិចារណាឃើញនូវរូបបណិធិ ថាគួរខ្ពើម រមែងពាល់ត្រូវរឿយៗ ហើយឃើញនូវកិរិយាសូន្យទៅ ព្រោះចុះចិត្តស៊ប់ក្នុងព្រះនិព្វានដែលមិនមានបណិធិ រមែងព្រងើយកន្តើយនឹងការប្រព្រឹត្តទៅ ហើយពិចារណានូវធម៌មិនមានបណិធិ គឺព្រះនិព្វានជាទីរលត់ទុក្ខ ហើយចូល ( កាន់ផលសមាបត្តិ ) ឈ្មោះថា អប្បណិហិតវិហារសមាបត្តិ បុគ្គលកាលពិចារណាឃើញនូវរូបាភិនិវេសៈថាគួរខ្ពើម រមែងពាល់ត្រូវរឿយៗ ហើយឃើញនូវកិរិយាសូន្យទៅ ព្រោះចុះចិត្តស៊ប់ក្នុងព្រះនិព្វានដ៏សូន្យចាកអត្តារ មែងព្រងើយកន្តើយក្នុងការប្រព្រឹត្តទៅ ហើយពិចារណានូវធម៌ដ៏សូន្យចាកអត្តា គឺព្រះនិព្វានជាទីរលត់ទុក្ខ ហើយចូល ( កាន់ផលសមាបត្តិ ) ឈ្មោះថា សុញ្ញត-

វិហារសមាបត្តិ ។

[ ២០៨ ] បុគ្គលកាលពិចារណាឃើញនូវវេទនានិមិត្ត ។បេ។ នូវសញ្ញា-និមិត្ត នូវសង្ខារនិមិត្ត នូវវិញ្ញាណនិមិត្ត នូវចក្ខុ ។បេ។ នូវជរាមរណនិមិត្ត ថាគួរខ្លាច រមែងពាល់ត្រូវរឿយៗ ហើយឃើញនូវកិរិយាសូន្យទៅ ព្រោះចុះចិត្តស៊ប់ក្នុងព្រះនិព្វានមិនមាននិមិត្ត ឈ្មោះថា អនិមិត្តវិហារធម៌ បុគ្គលកាលពិចារណាឃើញនូវជរាមរណបណិធិថាគួរខ្លាច រមែងពាល់ត្រូវរឿយៗ ហើយឃើញនូវកិរិយាសូន្យទៅ ព្រោះចុះចិត្តស៊ប់ក្នុងព្រះនិព្វានមិនមានបណិធិ ឈ្មោះថា អប្បណិហិតវិហារធម៌ បុគ្គលកាលពិចារណាឃើញនូវជរាមរណាភិនិវេសៈថាគួរខ្លាច រមែងពាល់ត្រូវរឿយៗ ហើយឃើញនូវកិរិយាសូន្យទៅ ព្រោះចុះចិត្តស៊ប់ក្នុងព្រះនិព្វានដែលសូន្យចាកអត្តា ឈ្មោះថា សុញ្ញតវិហារធម៌ ។

[ ២០៩ ] បុគ្គលកាលពិចារណាឃើញនូវជរាមរណនិមិត្ត ថាគួរខ្លាច រមែងព្រងើយកន្តើយក្នុងការប្រព្រឹត្តទៅ ព្រោះចុះចិត្តស៊ប់ក្នុងព្រះនិព្វានមិនមាននិមិត្ត ហើយពិចារណានូវធម៌មិនមាននិមិត្ត គឺព្រះនិព្វានជាទីរលត់ទុក្ខ ហើយចូលកាន់ ( ផលសមាបត្តិ ) ឈ្មោះថា អនិមិត្តសមាបត្តិ បុគ្គលកាលពិចារណាឃើញនូវជរាមរណបណិធិថាគួរខ្លាច រមែងព្រងើយកន្តើយក្នុងការប្រព្រឹត្តទៅ ព្រោះចុះចិត្តស៊ប់ក្នុងព្រះនិព្វានមិនមានបណិធិ ហើយពិចារណានូវធម៌មិនមានបណិធិ គឺព្រះនិព្វានជាទីរលត់ទុក្ខ ហើយចូលកាន់ ( ផលសមាបត្តិ ) ឈ្មោះថា អប្បណិហិតសមាបត្តិ បុគ្គលកាលពិចារណាឃើញនូវជរាមរណាភិនិវេសៈថាគួរខ្លាច រមែងព្រងើយកន្តើយក្នុងការប្រព្រឹត្តទៅ ព្រោះចុះចិត្តស៊ប់ក្នុងព្រះ

និព្វាន ដែលសូន្យចាកអត្តា ហើយពិចារណានូវធម៌ដ៏សូន្យចាកអត្តា គឺព្រះនិព្វានជាទីរលត់ទុក្ខ ហើយចូលកាន់ ( ផលសមាបត្តិ ) ឈ្មោះថា សុញ្ញតសមាបត្តិ ។

[ ២១០ ] បុគ្គលកាលពិចារណាឃើញនូវជរាមរណនិមិត្ត ថាគួរខ្លាចរមែងពាល់ត្រូវរឿយៗ ហើយឃើញនូវកិរិយាសូន្យទៅ ព្រោះចុះចិត្តស៊ប់ក្នុងព្រះនិព្វានដែលមិនមាននិមិត្ត រមែងព្រងើយកន្តើយក្នុងការប្រព្រឹត្តទៅ ហើយពិចារណានូវធម៌ ដែលមិនមាននិមិត្ត គឺព្រះនិព្វានជាទីរលត់ទុក្ខ ហើយចូល ( កាន់ផលសមាបត្តិ ) ឈ្មោះថា អនិមិត្តវិហារសមាបត្តិ បុគ្គលកាលពិចារណាឃើញនូវជរាមរណបណិធិថាគួរខ្លាច រមែងពាល់ត្រូវរឿយៗ ហើយឃើញនូវកិរិយាសូន្យទៅ ព្រោះចុះចិត្តស៊ប់ក្នុងព្រះនិព្វានមិនមានបណិធិ រមែងព្រងើយកន្តើយក្នុងការប្រព្រឹត្តទៅ ហើយពិចារណានូវធម៌មិនមានបណិធិ គឺព្រះនិព្វានជាទីរលត់ទុក្ខ ឈ្មោះថា អប្បណិហិតវិហារសមាបត្តិ បុគ្គលកាលពិចារណាឃើញនូវជរាមរណាភិនិវេសៈ ថាគួរខ្លាច រមែងពាល់ត្រូវរឿយៗ ហើយឃើញនូវកិរិយាសូន្យទៅ ព្រោះចុះចិត្តស៊ប់ក្នុងព្រះនិព្វាន ដ៏សូន្យចាកអត្តា រមែងព្រងើយកន្តើយក្នុងការប្រព្រឹត្តទៅ ហើយពិចារណានូវធម៌ដ៏សូន្យចាកអត្តា គឺព្រះនិព្វាន ជាទីរលត់ទុក្ខ ឈ្មោះថា សុញ្ញតវិហារសមាបត្តិ អនិមិត្តវិហារធម៌ដោយឡែក អប្បណិហិតវិហារធម៌ដោយឡែក សុញ្ញតវិហារធម៌ដោយឡែក អនិមិត្តសមាបត្តិដោយឡែក អប្បណិហិតសមាបត្តិដោយឡែក សុញ្ញតសមាបត្តិដោយឡែក អនិមិត្តវិហារសមាបត្តិដោយឡែក អប្បណិហិតវិហារ-

សមាបត្តិដោយឡែក សុញ្ញតវិហារសមាបត្តិដោយឡែក ដែលឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងវិបស្សនាវិហារផ្សេងៗ ឈ្មោះថា វិហារដ្ឋញាណ បញ្ញាក្នុងផលសមាបត្តិផ្សេងៗ ឈ្មោះថា សមាបត្តដ្ឋញាណ បញ្ញាក្នុងវិហារសមាបត្តិផ្សេងៗ ឈ្មោះថា វិហារ-សមាបត្តដ្ឋញាណ ។

## អដ្ឋកថា

## ញាណត្តយនិទ្ទេស

[ ២០២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងញាណត្តយនិទ្ទេសដូចតទៅ

បទថា **និមិត្តំ** បានដល់ សង្ខារនិមិត្ត ។ បទថា **អនិមិត្តេ** បានដល់ក្នុងនិព្វាន ដែលបដិបក្ខជាមួយសង្ខារនិមិត្ត ។ បទថា **អធិមុត្តត្តា** បានដល់ព្រោះបណ្តោយចិត្តទៅ ដោយបង្អោនចិត្តទៅក្នុងនិព្វាននោះ ។ បទថា **ផុស្ស ផុស្ស វយំ បស្សតិ** បានដល់ ពាល់ត្រូវហើយ ពាល់ត្រូវហើយនូវសង្ខារនិមិត្តដោយញាណ រមែងឃើញការបែកធ្លាយទៅនៃសង្ខារនិមិត្តនោះ ដោយវិបស្សនាញាណនោះឯង ។ ដោយបទនេះ ជាការសម្រេចដល់កង្គានុបស្សនាញាណ ។ កង្គានុបស្សនានោះ ញុំាងអនិច្ចានុបស្សនាឲ្យសម្រេច ។ អនិច្චានុបស្សនា ញុំាងទុក្ខានុបស្សនាឲ្យសម្រេច ព្រោះវត្ថុដែលមិនទៀង ជាទុក្ខ ទុក្ខានុបស្សនានោះញុំាងអនត្តានុបស្សនាឲ្យសម្រេច ព្រោះវត្ថុដែលជាទុក្ខ ជាអនត្តា ព្រោះហេតុនោះ ឈ្មោះថា លោកពោលដល់អនុបស្សនា ៣ ក្នុងបទនេះ ដោយប្រការដូច្នេះ ។

បទថា **អនិមិត្តោ វិហារោ** បានដល់ វិហារធម៌ដែលជាពួក ៣ នៃវិបស្សនានោះ ឈ្មោះថា អនិមិត្តវិហារ ព្រោះឃើញនិមិត្តដោយភាពជាភ័យ ។ បទថា **បណិធិ** បានដល់ តណ្ហា ។ បទថា **អប្បណិហិតេ** បានដល់ ក្នុងនិព្វានដែលជាបដិបក្ខចំពោះតណ្ហា ។ បទថា **អភិនិវេសំ** បានដល់ ការប្រកាន់មាំក្នុងតួខ្លួន ។ បទថា **សុញ្ញតេ** បានដល់ និព្វានដែលសូន្យចាកតួខ្លួន ។ បទ

ថា **សុញ្ញតោ** បានដល់ សភាពទទេនោះឯង ឈ្មោះថា សុញ្ញត ។

[ ២០៣ ] បទថា **បវត្តំ អជ្ឈុបេក្ខិត្វា** បានដល់ ភាពព្រងើយកន្តើយប្រព្រឹត្តទៅដែលជាវិបាក ដោយការព្រងើយកន្តើយក្នុងសង្ខារ ។ ពិតហើយ សត្វទាំងឡាយ ជាអ្នកពេញចិត្តក្នុងការប្រព្រឹត្តទៅដែលជាវិបាក ពោល គឺសុគតិ តែព្រះយោគាវចរនេះបំណងនឹងចូលផលសមាបត្តិ ឃើញសង្ខារទាំងពួងដែលប្រព្រឹត្តទៅនោះឯងដោយភាពជារបស់មិនទៀង រមែងព្រងើយកន្តើយ ព្រោះថា លុះឃើញយ៉ាងនេះហើយ រមែងចូលផលសមាបត្តិបាន មិនអាចចូលបានដោយប្រការដទៃ ។ បទថា **អាវជ្ជិត្វា** បានដល់ នឹករំពឹងដោយអាវជ្ជនៈ ។ បទថា **សមាបជ្ជតិ** បានដល់ រមែងចូលដល់ផលសមាបត្តិ ។ បទថា **អនិមិត្តា សមាបត្តិ** បានដល់ ឈ្មោះថា សមាបត្តិដែលមិនមាននិមិត្ត ព្រោះឃើញនិមិត្តដោយភាពជាភ័យ ហើយចូលសមាបត្តិ ។

[ ២០៤-២១០ ] បទថា **អនិមិត្តវិហារសមាបត្តិ** បានដល់ ធម៌នេះ ឈ្មោះថា ជាពីរយ៉ាង គឺវិបស្សនាវិហារធម៌ និងផលសមាបត្តិ ។

ឥឡូវនេះ ព្រះសារីបុត្តត្ថេរ កាលចែកសង្ខារនិមិត្តហើយ ទើបពោលបទថា **រូបនិមិត្តំ** ជាដើម ។

ជរា និងមរណសព្ទ ពាក្យដែលគួរពោល ធ្លាប់ពោលហើយនោះឯង ។ កាលពោលដោយពាក្យថា **អញ្ញោ អនិមិត្តវិហារោ** ជាដើម ព្រះសារីបុត្តត្ថេរ សម្តែងសរុប ។ កាលពោលដោយសង្ខេប ញាណក្នុងការផ្សេងនៃវិបស្សនាវិហារធម៌របស់បុគ្គលដែលតាំងនៅក្នុងសង្ខារុបេក្ខាញាណ ដែលជាចំណែក

ខាងដើមនៃផលសមាបត្តិ ឈ្មោះថា វិហារដ្ឋញាណ ។ ញាណក្នុងការផ្សេង នៃផលសមាបត្តិ ឈ្មោះថា សមាបត្តដ្ឋញាណ ។ ញាណក្នុងការផ្សេងនៃ ធម៌ទាំងពីរនោះ ឈ្មោះថា វិហារសមាបត្តដ្ឋញាណ ។

ព្រះយោគាវចរ ដែលបំណងនឹងធ្វើពេលវេលាឲ្យកន្លងទៅដោយវិបស្សនា-វិហារ រមែងញុំាងវិបស្សនាវិហារឲ្យប្រព្រឹត្តទៅ ដែលបំណងនឹងធ្វើពេលវេលាឲ្យកន្លងទៅ ដោយផលសមាបត្តិវិហារ ខ្វល់ខ្វាយទៅតាមលំដាប់របស់វិបស្សនា រមែងញុំាងផលសមាបត្តិឲ្យប្រព្រឹត្តទៅ ដែលបំណងនឹងធ្វើពេលវេលាឲ្យកន្លងទៅដោយធម៌ទាំងពីរនោះ រមែងញុំាងធម៌ទាំងពីរនោះឲ្យប្រព្រឹត្តទៅ ។ ញាណមាន ៣ យ៉ាង ដោយបំណងដល់បុគ្គល ដោយប្រការដូច្នេះ ។ បទដ៏សេសដែលគួរពោលក្នុងទីនេះ ខ្ញុំបានពោលហើយ ក្នុងការពណ៌នាដល់សង្ខារុបេក្ខាញាណនោះឯង ។ល។

## អដ្ឋកថាញាណត្តយនិទ្ទេស ចប់

# សុត្តន្តបិដក

[ ២១១ ] បញ្ញាក្នុងការផ្តាច់បង់នូវអាសវៈ ព្រោះចិត្តបរិសុទ្ធដោយការមិនរាយមាយ ឈ្មោះថា អានន្តរិកសមាធិញ្ញាណ តើដូចម្តេច ។

សេចក្តីមិនរាយមាយ គឺភាពនៃចិត្តមានអារម្មណ៍តែមួយ ដោយអំណាចនៃនេក្ខម្មៈ ឈ្មោះថា សមាធិ ញាណកើតឡើងដោយអំណាចនៃសមាធិនោះ អាសវៈទាំងឡាយ រមែងអស់ទៅដោយញាណនោះ ព្រោះហេតុនោះ សមថៈ ( ការស្ងប់ គឺសមាធិកើត ) មុន ញាណ ( កើត ) ក្រោយការអស់ទៅនៃអាសវៈទាំងឡាយ រមែងកើតមានដោយញាណនោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងការផ្តាច់បង់នូវអាសវៈ ព្រោះចិត្តបរិសុទ្ធដោយការមិនរាយមាយ ឈ្មោះថា អានន្តរិកសមាធិញ្ញាណ ។

[ ២១២ ] សំណួរត្រង់ពាក្យថា អាសវៈទាំងឡាយ តើអាសវៈទាំងឡាយនោះ អ្វីខ្លះ ។ កាមាសវៈ ភវាសវៈ ទិដ្ឋាសវៈ អវិជ្ជាសវៈ ។

អាសវៈទាំងឡាយនុ៎ះ រមែងអស់ក្នុងធម៌ណា ។ ទិដ្ឋាសវៈ រមែងអស់មិនមានសេសសល់ កាមាសវៈ ដែលញុំាងសត្វឲ្យទៅកាន់អបាយ រមែងអស់ ភវាសវៈដែលញុំាងសត្វឲ្យទៅកាន់អបាយ រមែងអស់ អវិជ្ជាសវៈដែលញុំាងសត្វឲ្យទៅកាន់អបាយ រមែងអស់ដោយសោតាបត្តិមគ្គ អាសវៈទាំងឡាយនុ៎ះ រមែងអស់ក្នុងធម៌នុ៎ះឯង កាមាសវៈដ៏គ្រោតគ្រាត រមែងអស់ ភវាសវៈដែលស្ថិតនៅជាមួយនឹងកាមាសវៈនោះរមែងអស់ អវិជ្ជាសវៈដែលស្ថិតនៅជាមួយនឹងភវាសវៈនោះរមែងអស់ដោយសកទាគាមិមគ្គ អាសវៈទាំងឡាយនុ៎ះរមែងអស់ក្នុងធម៌នុ៎ះឯង កាមាសវៈរមែងអស់មិនមានសេសសល់ ភវាសវៈដែល

ស្ថិតនៅជាមួយនឹងកាមាសវៈនោះរមែងអស់ អវិជ្ជាសវៈដែលស្ថិតនៅជាមួយនឹងភវាសវៈនោះ រមែងអស់ដោយអនាគាមិមគ្គ អាសវៈទាំងឡាយនុ៎ះរមែងអស់ក្នុងខណៈនុ៎ះឯង ភវាសវៈរមែងអស់មិនមានសេសសល់ អវិជ្ជាសវៈរមែងអស់មិនមានសេសសល់ដោយអរហត្តមគ្គ អាសវៈទាំងឡាយនុ៎ះ រមែងអស់ក្នុងខណៈនុ៎ះឯង ។

[ ២១៣ ] សេចក្តីមិនរាយមាយ គឺភាពនៃចិត្តមានអារម្មណ៍តែមួយដោយអំណាចការមិនព្យាបាទ ។បេ។ ដោយអំណាចអាលោកសញ្ញា ដោយអំណាចនៃកិរិយាមិនរាយមាយ ដោយអំណាចនៃកិរិយាកំណត់នូវធម៌ ដោយអំណាចញាណ ដោយអំណាចបាមុជ្ជ ( អំណរទន់ ) ដោយអំណាចបឋមជ្ឈាន ដោយអំណាចទុតិយជ្ឈាន ដោយអំណាចតតិយជ្ឈាន ដោយអំណាចចតុត្ថជ្ឈាន ដោយអំណាចអាកាសានញ្ចាយតនសមាបត្តិ ដោយអំណាចវិញ្ញាណញ្ចាយតនសមាបត្តិ ដោយអំណាចអាកិញ្ចញ្ញាយតនសមាបត្តិ ដោយអំណាចនេវសញ្ញានាសញ្ញាយតនសមាបត្តិ ដោយអំណាចបឋវីកសិណ ដោយអំណាចអាបោកសិណ ដោយអំណាចតេជោកសិណ ដោយអំណាចវាយោកសិណ ដោយអំណាចនីលកសិណ ដោយអំណាចបីតកសិណ ដោយអំណាចលោហិតកសិណ ដោយអំណាចឱទាតកសិណ ដោយអំណាចអាកាសកសិណ ដោយអំណាចវិញ្ញាណកសិណ ដោយអំណាចពុទ្ធានុស្សតិ ដោយអំណាចធម្មានុស្សតិ ដោយអំណាចសង្ឃានុស្សតិ ដោយអំណាចសីលានុស្សតិ ដោយអំណាចចាគានុស្សតិ ដោយអំណាចទេវតានុស្សតិ ដោយអំណាចអានាបា-

នស្សតិ ដោយអំណាចមរណស្សតិ ដោយអំណាចកាយគតាសតិ ដោយអំណាច ឧបសមានុស្សតិ ដោយអំណាចឧទ្ធុមាតកសញ្ញា ដោយអំណាចវិនីលកសញ្ញា ដោយអំណាចវិបុព្វកសញ្ញា ដោយអំណាចវិច្ឆិទ្ទកសញ្ញា ដោយអំណាចវិក្ខា-យិតកសញ្ញា ដោយអំណាចវិក្ខិត្តកសញ្ញា ដោយអំណាចហតវិក្ខិត្តកសញ្ញា ដោយអំណាចលោហិតកសញ្ញា ដោយអំណាចបុឡុវកសញ្ញា ដោយអំណាច អដ្ឋិកសញ្ញា ដោយអំណាចការដកដង្ហើមចេញវែង ដោយអំណាចការដក ដង្ហើមចូលវែង ដោយអំណាចការដកដង្ហើមចេញខ្លី ដោយអំណាចការដក ដង្ហើមចូលខ្លី ដោយអំណាចការដឹងច្បាស់នូវកាយ គឺខ្យល់ចេញទាំងពួង ហើយដកដង្ហើមចេញ ដោយអំណាចការដឹងច្បាស់នូវកាយ គឺខ្យល់ចូលទាំង ពួង ហើយដកដង្ហើមចូល ដោយអំណាចការញ៉ាំងកាយសង្ខារឲ្យស្ងប់ ហើយ ដកដង្ហើមចេញ ដោយអំណាចការញ៉ាំងកាយសង្ខារឲ្យស្ងប់ ហើយដកដង្ហើម ចូល ដោយអំណាចការដឹងច្បាស់នូវបីតិ ហើយដកដង្ហើមចេញ ដោយអំណាច ការដឹងច្បាស់នូវបីតិ ហើយដកដង្ហើមចូល ដោយអំណាចការដឹងច្បាស់នូវ សេចក្តីសុខ ហើយដកដង្ហើមចេញ ដោយអំណាចការដឹងច្បាស់នូវសេចក្តីសុខ ហើយដកដង្ហើមចូល ដោយអំណាចការដឹងច្បាស់នូវចិត្តសង្ខារ ហើយដក ដង្ហើមចេញ ដោយអំណាចការដឹងច្បាស់នូវចិត្តសង្ខារ ហើយដកដង្ហើមចូល ដោយអំណាចការញ៉ាំងចិត្តសង្ខារឲ្យស្ងប់ ហើយដកដង្ហើមចេញ ដោយអំណាច ការញ៉ាំងចិត្តសង្ខារឲ្យស្ងប់ ហើយដកដង្ហើមចូល ដោយអំណាចការដឹងច្បាស់ នូវចិត្ត ហើយដកដង្ហើមចេញ ដោយអំណាចការដឹងច្បាស់នូវចិត្ត ហើយដក

ដង្ហើមចូល ដោយអំណាចការញ៉ាំងចិត្តឲ្យរីករាយ ហើយដកដង្ហើមចេញ ដោយអំណាចការញ៉ាំងចិត្តឲ្យរីករាយ ហើយដកដង្ហើមចូល ដោយអំណាចការតាំងចិត្តឲ្យមាំ ។បេ។ ការញ៉ាំងចិត្តឲ្យផុតស្រឡះ ការឃើញរឿយៗ ថា មិនទៀង ការឃើញរឿយៗ នូវវិរាគៈ ការឃើញរឿយៗ នូវនិរោធៈ ការឃើញរឿយៗ នូវបដិនិស្សគ្គៈ ( ធម៌ជាគ្រឿងលះបង់នូវកិលេស ) ហើយដកដង្ហើមចេញ ដោយអំណាចកិរិយា ឃើញនូវបដិនិស្សគ្គៈ ហើយដកដង្ហើមចូល ឈ្មោះថា សមាធិញ្ញាណ រមែងកើតឡើងដោយអំណាចនៃសមាធិនោះ អាសវៈទាំងឡាយ រមែងអស់ដោយញាណនោះ ព្រោះហេតុនោះ សមថៈ ( ការស្ងប់ គឺសមាធិកើត ) មុន ញាណ ( កើត ) ក្រោយ ការអស់នៃអាសវៈទាំងឡាយ រមែងកើតមានដោយញាណនោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងការផ្តាច់បង់នូវអាសវៈ ព្រោះចិត្តបរិសុទ្ធដោយការមិនរាយមាយ ឈ្មោះថា អានន្តរិកសមាធិញ្ញាណ ។

[ ២១៤ ] សំណួរត្រង់ពាក្យថា អាសវៈទាំងឡាយ តើអាសវៈទាំងឡាយនោះ អ្វីខ្លះ ។ កាមាសវៈ ភវាសវៈ ទិដ្ឋាសវៈ អវិជ្ជាសវៈ ។

អាសវៈទាំងឡាយនុ៎ះ អស់ក្នុងធម៌ណា ។ ទិដ្ឋាសវៈ រមែងអស់មិនមានសេសសល់ កាមាសវៈដែលញ៉ាំងសត្វឲ្យទៅកាន់អបាយរមែងអស់ ភវាសវៈដែលញ៉ាំងសត្វឲ្យទៅកាន់អបាយរមែងអស់ អវិជ្ជាសវៈដែលញ៉ាំងសត្វឲ្យទៅកាន់អបាយ រមែងអស់ដោយសោតាបត្តិមគ្គ អាសវៈទាំងឡាយនុ៎ះ រមែងអស់ក្នុងធម៌នុ៎ះឯង ។

កាមាសវៈដ៏គ្រោតគ្រាតរមែងអស់ ភវាសវៈដែលស្ថិតនៅជាមួយនឹងកាមាសវៈនោះរមែងអស់ អវិជ្ជាសវៈដែលស្ថិតនៅជាមួយនឹងភវាសវៈនោះរមែងអស់ដោយសកទាគាមិមគ្គ អាសវៈទាំងឡាយនុ៎ះ រមែងអស់ក្នុងធម៌នុ៎ះឯង ។

កាមាសវៈរមែងអស់មិនមានសេសសល់ ភវាសវៈដែលស្ថិតនៅជាមួយនឹងកាមាសវៈនោះរមែងអស់ អវិជ្ជាសវៈដែលស្ថិតនៅជាមួយនឹងភវាសវៈនោះរមែងអស់ដោយអនាគាមិមគ្គ អាសវៈទាំងឡាយនុ៎ះ រមែងអស់ក្នុងធម៌នុ៎ះឯង ។

ភវាសវៈរមែងអស់មិនមានសេសសល់ អវិជ្ជាសវៈរមែងអស់មិនមានសេសសល់ដោយអរហត្តមគ្គ អាសវៈទាំងឡាយនុ៎ះ រមែងអស់ក្នុងធម៌នុ៎ះឯង ដែលឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងការផ្ដាច់បង់នូវអាសវៈ ព្រោះចិត្តបរិសុទ្ធដោយការមិនរាយមាយ ឈ្មោះថា អានន្តរិកសមាធិញ្ញាណ ។

# អដ្ឋកថា
# អានន្តរិកសមាធិញ្ញាណនិទ្ទេស

[ ២១១ ] គប្បីជ្រាបវិនិច្ឆ័យ ក្នុងអានន្តរិកសមាធិញ្ញាណនិទ្ទេសដូចតទៅ ក្នុងបទថា **នេក្ខម្មវសេន** ជាដើម មានអធិប្បាយដូចតទៅនេះ ធម៌ ៧ ប្រការ គឺនេក្ខម្មៈ អព្យាបាទ អាលោកសញ្ញា ការមិនរាយមាយ ការកំណត់ធម៌ ញាណ និងបាមោជ្ជដែលប្រកបក្នុងឧបចារជ្ឈានរបស់ព្រះសុក្ខវិបស្សកៈ ដែលជាបដិបក្ខចំពោះកិលេសនោះៗ រមែងជាធម៌សម្បយុត្តជាមួយចិត្តមួយដួងប៉ុណ្ណោះ ។

បទថា **ចិត្តស្ស ឯកគ្គតា អវិក្ខេបោ** បានដល់ ភាពជាចិត្តដ៏កំពូលតែមួយ ឈ្មោះថា ឯកគ្គតា ។ ឈ្មោះថា អវិក្ខេប ព្រោះចិត្តមិនរាយមាយទៅក្នុងអារម្មណ៍ផ្សេងៗ ដោយឯកគ្គតានោះ ។ អធិប្បាយថា ភាពមិនរាយមាយ ពោលគឺភាពនៃចិត្តជាឯកគ្គតា ។ បទថា **សមាធិ** បានដល់ ឈ្មោះថា សមាធិ ព្រោះចិត្តតាំងនៅស្មើ ក្នុងអារម្មណ៍តែមួយ ។ បទថា **តស្ស សមាធិស្ស វសេន** បានដល់ ដោយអំណាចនៃសមាធិមានប្រការដូចពោលហើយ ព្រោះដឹងតាមសេចក្តីពិតនៃចិត្តតាំងមាំនោះហើយ ដោយឧបចារសមាធិ ។ បទថា **ឧប្បជ្ជតិ ញាណំ** បានដល់ មគ្គញ្ញាណ រមែងកើតឡើងតាមលំដាប់ ។ បទថា **ខីយន្តិ** បានដល់ រមែងអស់ទៅដោយអំណាចការកាត់ផ្តាច់ ។ បទថា **ឥតិ** ជាបទសរុបអត្ថ មានប្រការដូចពោលហើយ ។ បទថា **បឋមំ សមថោ** បានដល់ សមាធិ រមែងមានក្នុងចំណែកខាងដើម ។ បទថា **បច្ឆា ញាណំ** បានដល់ ញាណ រមែងមានក្នុងចំណែកខាងក្រោយ គឺក្នុងខណៈនៃមគ្គ ។

[ ២១២ ] បទថា **កាមាសវោ** បានដល់ រាគៈប្រកបដោយកាមគុណ ៥ ។ បទថា **ភវាសវោ** បានដល់ ឆន្ទរាគៈក្នុងរូបភព និងអរូបភព សេចក្តីត្រេកអរក្នុងឈាន រាគៈដែលកើតរួមជាមួយសស្សតទិដ្ឋិ សេចក្តីប្រាថ្នាដោយអំណាចនៃភព ។ បទថា **ទិដ្ឋាសវោ** បានដល់ ទិដ្ឋិ ៦២ ។ បទថា **អវិជ្ជាសវោ** បានដល់ ការមិនដឹងក្នុងឋានៈ ៨ មានទុក្ខជាដើម ។ ព្រះសារីបុត្តត្ថេរធ្វើពាក្យសួរដល់ឱកាសដោយសត្តមីវិភត្តិ ហើយសម្តែងការអស់ទៅនៃអាសវៈដោយមគ្គដែលធ្វើនូវការអស់ទៅនៃអាសវៈ ដោយបទថា **សោតាបត្តិមគ្គេន** ជាដើមហើយ ទើបធ្វើពាក្យឆ្លើយតាមឱកាសដោយបទថា **ឯត្ថ** ។ លោកអធិប្បាយថា ក្នុងខណៈនៃមគ្គ ។ បទថា **អនវសេសោ** បានដល់ អនវសេស ព្រោះទិដ្ឋាសវៈនោះមិនមានសេសសល់ ។ បទថា **អបាយគមនីយោ** បានដល់ នរក កំណើតតិរច្ឆាន បិត្តិវិស័យ និងអសុរកាយ ទាំងបួននេះ ឈ្មោះថាអបាយ ព្រោះប្រាសចាកសេចក្តីចម្រើន គឺសេចក្តីសុខ ។ ឈ្មោះថា អបាយគមនីយ ព្រោះអត្ថថា ញុំាងសត្វដែលមានអាសវៈឲ្យទៅកាន់អបាយ ។ លោកពោលអាសវក្ខយកថាហើយ ក្នុងទុកតោវុដ្ឋានកថា ។

[ ២១៣ ] បទថា **អវិក្ខេបវសេន** បានដល់ ដោយអំណាចនៃសមាធិជាឧបនិស្ស័យនៃសមាធិដែលប្រព្រឹត្តទៅហើយ ។ ក្នុងបទថា **បឋវីកសិណវសេន** ជាដើម មានសេចក្តីដូចតទៅនេះថា លោកពោលដល់កសិណ ១០ ដោយអំណាចនៃអប្បនាសមាធិដែលមានកសិណជាអារម្មណ៍ ។ លោកពោលពុទ្ធានុស្សតិជាដើម មរណស្សតិ និងឧបសមានុស្សតិដោយអំណាចនៃឧបចារជ្ឈាន

លោកពោលអានាបានស្សតិ និងកាយគតាសតិ ដោយអំណាចនៃអប្បនាសមាធិ លោកពោលអសុភ ១០ ដោយអំណាចនៃបឋមជ្ឈាន ។

ការរឭកដែលកើតឡើងប្រារព្ធព្រះពុទ្ធ ឈ្មោះថា ពុទ្ធានុស្សតិ ។ ពុទ្ធានុស្សតិនេះ ជាឈ្មោះរបស់សតិ មានព្រះពុទ្ធគុណជាអារម្មណ៍ មាន **ឥតិបិ សោ ភគវា អរហំ** ជាដើម ដោយអំណាចនៃពុទ្ធានុស្សតិនោះ ។

ម្យ៉ាងទៀត ការរឭកដែលកើតឡើងប្រារព្ធព្រះធម៌ ឈ្មោះថា ធម្មានុស្សតិ ។ ធម្មានុស្សតិនេះ ជាឈ្មោះរបស់សតិមានព្រះធម្មគុណជាអារម្មណ៍ មាន **ស្វាក្ខាតោ ភគវតា ធម្មោ** ជាដើម ។

ការរឭកដែលកើតឡើង ប្រារព្ធព្រះសង្ឃ ឈ្មោះថា សង្ឃានុស្សតិ ។ សង្ឃានុស្សតិនេះ ជាឈ្មោះរបស់សតិ មានសង្ឃគុណជាអារម្មណ៍ មាន **សុបដិបន្នោ ភគវតោ សាវកសង្ឃោ** ជាដើម ។

ការរឭកដែលកើតឡើងប្រារព្ធសីល ឈ្មោះថា សីលានុស្សតិ ។ សីលានុស្សតិនេះ ជាឈ្មោះរបស់សតិ ដែលមានគុណរបស់សីល គឺភាពដែលសីលមិនដាច់ជាដើមជាអារម្មណ៍ ។

ការរឭកដែលកើតឡើងប្រារព្ធចាគៈ ឈ្មោះថា ចាគានុស្សតិ ។ ចាគានុស្សតិនេះ ជាឈ្មោះរបស់សតិមានគុណនៃការបរិច្ចាគ គឺភាពដែលខ្លួនលះបង់ជាដើមជាអារម្មណ៍ ។

ការរឭកដែលកើតឡើងប្រារព្ធទេវតាទាំងឡាយ ឈ្មោះថា ទេវតានុស្សតិ ។ ទេវតានុស្សតិនេះ ជាឈ្មោះរបស់សតិដែលមានគុណ គឺសទ្ធាជាដើមរបស់ខ្លួន

ជាអារម្មណ៍ ដោយតាំងទេវតាក្នុងឋានៈជាបន្ទាល់ ។

សតិដែលកើតឡើងប្រារព្ធខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញ ឈ្មោះថា អានាបានស្សតិ ។ អានាបានស្សតិនេះ ជាឈ្មោះរបស់សតិ មានអានាបាន-និមិត្តជាអារម្មណ៍ ។

សតិដែលកើតឡើងប្រារព្ធសេចក្តីស្លាប់ ឈ្មោះថា មរណស្សតិ ។ មរណស្សតិនេះ ជាឈ្មោះរបស់សតិដែលមានមរណៈ ពោល គឺការដាច់ជីវិតិន្ទ្រិយ ដែលទាក់ទងក្នុងភពមួយជាអារម្មណ៍ ។

សតិដែលប្រព្រឹត្តទៅក្នុងសរីរៈ ដែលហៅថាកាយ ព្រោះជាប្រភពកើតនៃវត្ថុបដិកូលទាំងឡាយ មានសក់ជាដើមដែលគួរខ្ពើម ឬទៅកាន់កាយបែបនោះ ឈ្មោះថា កាយគតាសតិ ។ កាលគួរនឹងពោលថា កាយគតសតិ តែលោកពោលថា កាយគតាសតិ ព្រោះមិនធ្វើជារស្សៈ ។ ក្នុងទីនេះ លោកក៏ពោលថា ដោយអំណាចកាយគតាសតិដូចគ្នានោះឯង កាយគតាសតិនេះ ជាឈ្មោះរបស់សតិ មានបដិកូលនិមិត្តក្នុងចំណែករបស់កាយ មានសក់ជាដើមជាអារម្មណ៍ ។

ការរឭកដែលកើតឡើងប្រារព្ធសេចក្តីស្ងប់ ឈ្មោះថា ឧបសមានុស្សតិ ។ ឧបសមានុស្សតិនេះ ជាឈ្មោះរបស់សតិមានការស្ងប់ទុក្ខទាំងពួងជាអារម្មណ៍ ។ អសុភៈ ១០ មានអត្ថដូចបានពោលហើយ ។

ដើម្បីសម្តែងដល់ប្រភេទរបស់អប្បនាសមាធិ និងឧបចារសមាធិ ទើបព្រះសារីបុត្តត្ថេរពោលថា **ទីឃំ អស្សាសវសេន** ជាដើម គឺដោយអំណាចនៃការ

ដកដង្ហើមចូល ដែលហៅថាវែង ដូចលោកពោលថា **ទីឃំ** វែង ។ ដូចព្រះតម្រាស់ ( ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសក ) ថា កាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញវែង ដូច្នេះ ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះ ។

បទថា **សព្វកាយប្បដិសំវេទី** បានដល់ ជាអ្នកដឹងច្បាស់នូវគំនរខ្យល់ដង្ហើមចូល និងគំនរខ្យល់ដង្ហើមចេញទាំងអស់ ។

បទថា **បស្សម្ភយំ កាយសង្ខារំ** បានដល់ រម្ងាប់ គឺចូលទៅស្ងប់កាយ-សង្ខារ ពោល គឺការដកដង្ហើមចូល និងការដកដង្ហើមចេញយ៉ាងគ្រោតគ្រាត ។ លោកពោលអប្បនាសមាធិដោយពួក ៤ នេះ គឺ **ទីឃំ** វែង ១ **រស្សំ** ខ្លី ១ **សព្វកាយប្បដិសំវេទី** ភាពជាអ្នកដឹងច្បាស់កាយទាំងពួង ១ **បស្សម្ភយំ កាយសង្ខារំ** ការរម្ងាប់កាយសង្ខារ ១ ។

បទថា **បីតិបដិសំវេទី** បានដល់ ធ្វើបីតិឲ្យប្រាកដ ។ បទថា **ចិត្ត-សង្ខារបដិសំវេទី** បានដល់ ធ្វើចិត្តសង្ខារ ពោល គឺសញ្ញា និងវេទនាឲ្យប្រាកដ ។ បទថា **អភិប្បមោទយំ ចិត្តំ** បានដល់ ធ្វើចិត្តឲ្យរីករាយ ។ បទថា **សមាទហំ ចិត្តំ** បានដល់ តាំងចិត្តស្មើក្នុងអារម្មណ៍ ។ បទថា **វិមោចយំ ចិត្តំ** បានដល់ ដោះចិត្តចាកនីវរណៈជាដើម ។

លោកពោលពួក ៤ គឺ **បីតិបដិសំវេទី** ដឹងច្បាស់នូវបីតិ ១ **សុខបដិ-សំវេទី** ដឹងច្បាស់នូវសុខ ១ **ចិត្តសង្ខារបដិសំវេទី** ដឹងច្បាស់នូវចិត្តសង្ខារ ១ **បស្សម្ភយំ ចិត្តសង្ខារំ** រម្ងាប់ចិត្តសង្ខារ ១ និងពួក ៤ គឺ **ចិត្តបដិ-**

**សំវេទី** ដឹងច្បាស់នូវចិត្ត ១ **អភិប្បមោទយំ ចិត្តំ** ធ្វើចិត្តឲ្យរីករាយ ១ **សមាទហំ ចិត្តំ** ការតាំងចិត្ត ១ **វិមោចយំ ចិត្តំ** ការដោះចិត្ត ១ ដោយអប្បនាសមាធិ និងដោយអំណាចសមាធិសម្បយុត្តជាមួយនឹងវិបស្សនា ។

បទថា **អនិច្ចានុបស្សី** បានដល់ ដោយអំណាចអនិច្ចានុបស្សនា ។ បទថា **វិរាគានុបស្សី** បានដល់ ដោយអំណាចនិព្វិទានុបស្សនា ។ បទថា **និរោធានុបស្សី** បានដល់ ដោយអំណាចកង្ខានុបស្សនា ។ បទថា **បដិនិស្សគ្គានុបស្សី** បានដល់ ដោយអំណាចវុដ្ឋានគាមិនីវិបស្សនា ( ឃើញច្បាស់ក្នុងការចេញទៅ ) ។

ពិតហើយ ការពិចារណាឃើញការលះបង់នោះ រមែងលះបង់កិលេសជាមួយនឹងខន្ធាភិសង្ខារដោយតទង្គប្បហាន ម្យ៉ាងទៀត រមែងស្ទុះទៅ ព្រោះបង្អោនចិត្តទៅក្នុងនិព្វានដែលផ្ទុយគ្នាជាមួយនឹងកិលេសនោះ ដោយការឃើញទោសក្នុងសង្ខតធម៌ ។ លោកពោលពួក ៤ នេះ ដោយអំណាចនៃសមាធិដែលសម្បយុត្តដោយវិបស្សនា ។

ម្យ៉ាងទៀត ក្នុងបទនេះថា **អស្សាសវសេន បស្សាសវសេន** លោកពោលកាន់យកត្រឹមតែការប្រព្រឹត្តទៅនៃការដកដង្ហើមចូល និងការដកដង្ហើមចេញ មិនមែនពោលដោយអំណាចការធ្វើខ្យល់ដង្ហើមចូល-ចេញ ជាអារម្មណ៍ ។ ចំណែកសេចក្ដីពិស្ដារក្នុងបទនេះ នឹងមានច្បាស់ក្នុងអានាបានកថា ។

**អដ្ឋកថាអានន្តរិកសមាធិញ្ញាណនិទ្ទេស ចប់**

# សុត្តន្តបិដក

[ ២១៥ ] បញ្ញា គឺទស្សនាធិបតេយ្យ ( សេចក្តីឃើញជាធំ ) ផង ការបាននូវវិហារធម៌ដ៏ស្ងប់ និងសេចក្តីចុះចិត្តស៊ប់ក្នុងធម៌ដ៏ឧត្តមផង ឈ្មោះថា អរណាវិហារញ្ញាណ តើដូចម្តេច ។ ពាក្យថា ទស្សនាធិបតេយ្យ គឺការឃើញរឿយៗ ថាមិនទៀង ឈ្មោះថា ទស្សនាធិបតេយ្យ ការឃើញរឿយៗ ថាជាទុក្ខ ឈ្មោះថា ទស្សនាធិបតេយ្យ ការឃើញរឿយៗ ថា មិនមែនខ្លួន ឈ្មោះថា ទស្សនាធិបតេយ្យ ការឃើញរឿយៗ ក្នុងរូប ថាមិនទៀង ឈ្មោះថា ទស្សនាធិបតេយ្យ ការឃើញរឿយៗ ក្នុងរូប ថាជាទុក្ខ ឈ្មោះថា ទស្សនាធិបតេយ្យ ការឃើញរឿយៗ ក្នុងរូប ថាមិនមែនខ្លួន ឈ្មោះថា ទស្សនាធិបតេយ្យ ការឃើញរឿយៗ ក្នុងវេទនា ។បេ។ ក្នុងសញ្ញា ក្នុងសង្ខារ ក្នុងវិញ្ញាណ ក្នុងចក្ខុ ។បេ។ ក្នុងជរាមរណៈ ថាមិនទៀង ឈ្មោះថា ទស្សនាធិបតេយ្យ ការឃើញរឿយៗ ក្នុងជរាមរណៈ ថាជាទុក្ខ ឈ្មោះថា ទស្សនាធិបតេយ្យ ការឃើញរឿយៗ ក្នុងជរាមរណៈ ថាមិនមែនខ្លួន ឈ្មោះថា ទស្សនាធិបតេយ្យ ។

[ ២១៦ ] ពាក្យថា ការបាននូវវិហារធម៌ដ៏ស្ងប់ គឺវិហារធម៌ដ៏សូន្យចាកកិលេស ឈ្មោះថា ការបាននូវវិហារធម៌ដ៏ស្ងប់ វិហារធម៌មិនមាននិមិត្ត ឈ្មោះថា ការបាននូវវិហារធម៌ដ៏ស្ងប់ វិហារធម៌មិនមានបណិធិ ឈ្មោះថា ការបាននូវវិហារធម៌ដ៏ស្ងប់ ។

ពាក្យថា សេចក្តីចុះចិត្តស៊ប់ក្នុងធម៌ដ៏ឧត្តម គឺសេចក្តីចុះចិត្តស៊ប់ក្នុងព្រះនិព្វានដ៏សូន្យចាកកិលេស ឈ្មោះថា សេចក្តីចុះចិត្តស៊ប់ក្នុងធម៌ដ៏ឧត្តម សេចក្តីចុះចិត្តស៊ប់ក្នុងព្រះនិព្វានមិនមាននិមិត្ត ឈ្មោះថា សេចក្តីចុះចិត្តស៊ប់ក្នុងធម៌

ដ៏ឧត្តម សេចក្តីចុះចិត្តស៊ប់ ក្នុងធម៌មិនមានបណិធិ ឈ្មោះថា សេចក្តីចុះចិត្តស៊ប់ ក្នុងធម៌ដ៏ឧត្តម ។

ពាក្យថា អរណវិហារ គឺបឋមជ្ឈាន ឈ្មោះថា អរណវិហារ ទុតិយជ្ឈាន ឈ្មោះថា អរណវិហារ តតិយជ្ឈាន ឈ្មោះថា អរណវិហារ ចតុត្ថជ្ឈាន ឈ្មោះថា អរណវិហារ អាកាសានញ្ចាយតនសមាបត្តិ ឈ្មោះថា អរណ-វិហារ ។បេ។ នេវសញ្ញានាសញ្ញាយតនសមាបត្តិ ឈ្មោះថា អរណវិហារ ។

សំណួរត្រង់ពាក្យថា អរណវិហារ តើអរណវិហារដោយអត្ថថាដូចម្តេច ។ សភាវៈនាំចេញនូវនីវរណធម៌ទាំងឡាយដោយបឋមជ្ឈាន ឈ្មោះថា អរណ-វិហារសភាវៈនាំចេញនូវវិតក្ក និងវិចារ ដោយទុតិយជ្ឈាន ឈ្មោះថា អរណ-វិហារ សភាវៈនាំចេញនូវបីតិដោយតតិយជ្ឈាន ឈ្មោះថា អរណវិហារ សភាវៈនាំចេញនូវសុខ និងទុក្ខដោយចតុត្ថជ្ឈាន ឈ្មោះថា អរណវិហារ សភាវៈនាំចេញនូវរូបសញ្ញាបដិឃសញ្ញា និងនានត្តសញ្ញាដោយអាកាសានញ្ចាយតន-សមាបត្តិ ឈ្មោះថា អរណវិហារ សភាវៈនាំចេញនូវអាកាសានញ្ចាយតន-សញ្ញា ដោយវិញ្ញាណញ្ចាយតនសមាបត្តិ ឈ្មោះថា អរណវិហារ សភាវៈនាំចេញនូវវិញ្ញាណញ្ចាយតនសញ្ញា ដោយអាកិញ្ចញ្ញាយតនសមាបត្តិ ឈ្មោះថា អរណវិហារ សភាវៈនាំចេញនូវអាកិញ្ចញ្ញាយតនសញ្ញា ដោយនេវ-សញ្ញានាសញ្ញាយតនសមាបត្តិ ឈ្មោះថា អរណវិហារ នេះឈ្មោះថា អរណវិហារ ដែលឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា

បញ្ញា គឺទស្សនាធិបតេយ្យផង ការបាននូវវិហារធម៌ដ៏ស្ងប់ និងសេចក្តីចុះចិត្តស៊ប់ ក្នុងធម៌ដ៏ឧត្តមផង ឈ្មោះថា អរណវិហារញ្ញាណ ។

## អដ្ឋកថា

## អរណវិហារញ្ញាណនិទ្ទេស

[ ២១៥-២១៦ ] គប្បីជ្រាបវិនិច្ឆ័យ ក្នុងអរណវិហារញ្ញាណនិទ្ទេសដូចតទៅ ពាក្យថា អនិច្ចានុបស្សនាជាដើម មានន័យដូចបានពោលហើយ ។

បទថា **សុញ្ញតោ វិហារោ** បានដល់ អរហត្តផលសមាបត្តិដែលប្រព្រឹត្តទៅហើយដោយអាការនៃសុញ្ញត គឺភាពសូន្យទទេ របស់អ្នកចេញហើយដោយអនត្តានុបស្សនា ។ បទថា **អនិមិត្តោ វិហារោ** បានដល់ អរហត្តផលសមាបត្តិដែលប្រព្រឹត្តទៅហើយ ដោយអាការនៃអនិមិត្ត គឺមិនមាននិមិត្តរបស់អ្នកចេញហើយដោយអនិច្ចានុបស្សនា ។ បទថា **អប្បណិហិតោ វិហារោ** បានដល់ អរហត្តផលសមាបត្តិ ដែលប្រព្រឹត្តទៅហើយដោយអាការនៃអប្បណិហិត របស់អ្នកចេញហើយ ដោយទុក្ខានុបស្សនា ។ បទថា **សុញ្ញតេ អធិមុត្តតា** បានដល់ ភាពដែលចិត្តជាធម្មជាតបង្អោនទៅក្នុងភាពទទេ ដោយអំណាចនៃបញ្ញាដែលជាចំណែកខាងដើមនៃផលសមាបត្តិ ។ សូម្បីក្នុងពីរបទដ៏សេស ក៏មានន័យនេះដូចគ្នា ។

ដោយបទ មានបទថា **បឋមំ ឈានំ** ជាដើម ព្រះសារីបុត្តពោលដោយឈានសមាបត្តិដែលជាអារម្មណ៍នៃវិបស្សនារបស់អ្នកប្រាថ្នា ដើម្បីចូលអរហត្តផលសមាបត្តិ ។ ពិតហើយ វិបស្សនា ផលសមាបត្តិ ការបង្អោនទៅក្នុងធម៌ដែលប្រណីត និងឈានសមាបត្តិរបស់ព្រះអរហន្តនោះឯង រមែងគួរពោលថា អរណវិហារ ព្រោះលះកិលេសទាំងពួងបានហើយ ។

បទថា **បឋមេន ឈានេន នីវរណេ ហរតីតិ អរណវិហារោ** អធិប្បាយថា បឋមជ្ឈាននោះ ឈ្មោះថា អរណវិហារ ព្រោះបុគ្គលដល់ព្រមដោយបឋមជ្ឈាន រមែងនាំចេញនូវនីវរណៈដោយបឋមជ្ឈាន ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។ ក្នុងការមិនមាននីវរណៈរបស់ព្រះអរហន្តគប្បីជ្រាបថា លោកពោលថា រមែងនាំចេញនូវនីវរណៈ ព្រោះបឋមជ្ឈានជាបដិបក្ខចំពោះនីវរណៈ ។

ប្រសិនបើសួរថា ព្រោះហេតុអ្វី ទើបលោកលើកយកអរណវិហារញ្ញាណឡើងសម្តែង ៣ យ៉ាង ដោយអំណាចនៃវិបស្សនា ផលសមាបត្តិ និងការបង្អោនទៅក្នុងធម៌ដែលប្រណីត ហើយសម្តែងថា ឈានសមាបត្តិនោះឯង ជាអរណវិហារ ឆ្លើយថា ព្រោះធម៌ ៣ យ៉ាងនោះ សម្រេចភាពជាអរណវិហារដោយអំណាចឧទ្ទេសនោះឯង ។ ភាពដែលឈានសមាបត្តិដែលជាភូមិនៃផលសមាបត្តិ និងវិបស្សនា កាលលោកមិនពោល ក៏រមែងមិនដឹងថា ជាអរណវិហារ ព្រោះហេតុនោះ គប្បីជ្រាបថា លោកពោលពាក្យជាដើមថា បឋមជ្ឈានជាអរណវិហារ ដើម្បីធ្វើឈានដែលមិនទាន់ដឹងថា ជាអរណវិហារនោះឯង

ឲ្យដឹងបាន ។

ពិតហើយ ភាពដែលឈានសមាបត្តិទាំងនោះ ជាអរណវិហារ សូម្បីមិនដឹងដោយអំណាចនៃឧទ្ទេសក៏ជាការដឹងបាន ព្រោះលោកពោលហើយ ក្នុងនិទ្ទេស ។ ម្យ៉ាងទៀត ដោយន័យដែលលោកបានប្រកបអរណវិហារហើយ គប្បីប្រកបហើយ កាន់យកដូច្នេះថា អនិច្ចានុបស្សនា ឈ្មោះថា អរណវិហារ ព្រោះនាំចេញនូវនិច្ចសញ្ញា ទុក្ខានុបស្សនា ឈ្មោះថា អរណវិហារ ព្រោះនាំចេញនូវសុខសញ្ញា អនត្តានុបស្សនា ឈ្មោះថា អរណវិហារ ព្រោះនាំចេញនូវអត្តសញ្ញា សុញ្ញតវិហារ ឈ្មោះថា អរណវិហារ ព្រោះនាំចេញនូវភាពមិនសូន្យទទេ អនិមិត្តវិហារ ឈ្មោះថា អរណវិហារ ព្រោះនាំចេញនូវនិមិត្ត អប្បណិហិតវិហារ ឈ្មោះថា អរណវិហារ ព្រោះនាំចេញនូវតណ្ហាជាទីតាំង ភាពដែលចិត្តជាធម្មជាតបង្អោនទៅក្នុងធម៌ដែលទទេ ឈ្មោះថា អរណវិហារ ព្រោះនាំចេញនូវការបង្អោនទៅក្នុងធម៌ដែលមិនសូន្យទទេ ភាពដែលចិត្តជាធម្មជាតបង្អោនទៅក្នុងធម៌ដែលមិនមាននិមិត្ត ឈ្មោះថា អរណវិហារ ព្រោះនាំចេញនូវការបង្អោនទៅក្នុងធម៌ដែលមាននិមិត្ត ភាពដែលចិត្តជាធម្មជាតបង្អោនទៅក្នុងធម៌ដែលមិនមានទីតាំង ឈ្មោះថា អរណវិហារ ព្រោះនាំចេញនូវការបង្អោនទៅក្នុងធម៌ដែលមានទីតាំង ។ ៚

## អដ្ឋកថាអរណវិហារញ្ញាណនិទ្ទេស ចប់

# សុត្តន្តបិដក

[ ២១៧ ] បញ្ញាដែលមានភាពស្អាត់ជំនាញ ព្រោះហេតុប្រកបដោយកម្លាំង ២ ផង ព្រោះការស្ងប់រម្ងាប់នៃសង្ខារ ៣ ផង ព្រោះញាណចរិយាទាំង ១៦ ផង ព្រោះសមាធិចរិយាទាំង ៩ ផង ឈ្មោះថា និរោធសមាបត្តិញ្ញាណ តើដូចម្តេច ។

ពាក្យថា ដោយកម្លាំង ២ គឺកម្លាំង មាន ២ យ៉ាង គឺកម្លាំងសមថៈ ១ កម្លាំងវិបស្សនា ១ ។

[ ២១៨ ] កម្លាំងសមថៈ តើដូចម្តេច ។ ការមិនរាយមាយ គឺភាពនៃចិត្តមានអារម្មណ៍តែមួយដោយអំណាចនៃនេក្ខម្មៈ ឈ្មោះថា កម្លាំងសមថៈ ការមិនរាយមាយ គឺភាពនៃចិត្តមានអារម្មណ៍តែមួយ ដោយអំណាចនៃការមិនព្យាបាទ ឈ្មោះថា កម្លាំងសមថៈ ការមិនរាយមាយ គឺភាពនៃចិត្តមានអារម្មណ៍តែមួយ ដោយអំណាចនៃអាលោកសញ្ញា ឈ្មោះថា កម្លាំងសមថៈ ការមិនរាយមាយ គឺភាពនៃចិត្តមានអារម្មណ៍តែមួយ ដោយអំណាចនៃការមិនរាយមាយ ឈ្មោះថា កម្លាំងសមថៈ ។បេ។ ការមិនរាយមាយ គឺភាពនៃចិត្តមានអារម្មណ៍តែមួយ ដោយអំណាចនៃកិរិយាឃើញរឿយៗ នូវធម៌ជាគ្រឿងលះបង់នូវកិលេស ហើយដកដង្ហើមចេញ ឈ្មោះថា កម្លាំងសមថៈ ការមិនរាយមាយ គឺភាពនៃចិត្តមានអារម្មណ៍តែមួយ ដោយអំណាចនៃកិរិយាឃើញរឿយៗ នូវធម៌ជាគ្រឿងលះបង់នូវកិលេស ហើយដកដង្ហើមចូល ឈ្មោះថា កម្លាំងសមថៈ ។

[ ២១៩ ] សំណួរត្រង់ពាក្យថា កម្លាំងសមថៈ តើកម្លាំងសមថៈដោយអត្ថដូចម្តេច ។ ធម្មជាតមិនកម្រើកក្នុងនីវរណធម៌ដោយបឋមជ្ឈាន ឈ្មោះ

ថា កម្លាំងសមថៈធម្មជាតមិនកម្រើកក្នុងវិតក្ក និងវិចារ ដោយទុតិយជ្ឈាន ឈ្មោះថា កម្លាំងសមថៈ ធម្មជាតមិនកម្រើកក្នុងបីតិ ដោយតតិយជ្ឈាន ឈ្មោះថា កម្លាំងសមថៈ ធម្មជាតមិនកម្រើកក្នុងសុខ និងទុក្ខ ដោយចតុត្ថជ្ឈាន ឈ្មោះថា កម្លាំងសមថៈ ធម្មជាតមិនកម្រើកក្នុងរូបសញ្ញា ក្នុងបដិឃសញ្ញា ក្នុងនានត្តសញ្ញា ដោយអាកាសានញ្ចាយតនសមាបត្តិ ឈ្មោះថា កម្លាំងសមថៈ ធម្មជាតមិនកម្រើកក្នុងអាកាសានញ្ចាយតនសញ្ញា ដោយវិញ្ញាណញ្ចាយតនសមាបត្តិ ឈ្មោះថា កម្លាំងសមថៈ ធម្មជាតមិនកម្រើកក្នុងវិញ្ញាណញ្ចាយតនសញ្ញា ដោយអាកិញ្ចញ្ញាយតនសមាបត្តិ ឈ្មោះថា កម្លាំងសមថៈ ធម្មជាតមិនកម្រើកក្នុងអាកិញ្ចញ្ញាយតនសញ្ញា ដោយនេវសញ្ញានាសញ្ញាយតនសមាបត្តិ ឈ្មោះថា កម្លាំងសមថៈ ធម្មជាតមិនកម្រើក មិនឃ្លេងឃ្លោង មិនញាប់ញ័រក្នុងឧទ្ធច្ចៈផង ក្នុងកិលេសដែលប្រកបដោយឧទ្ធច្ចៈផង ក្នុងខន្ធផង ឈ្មោះថា កម្លាំងសមថៈ នេះកម្លាំងសមថៈ ។

[ ២២០ ] កម្លាំងវិបស្សនា តើដូចម្តេច ។ ការឃើញរឿយៗ ថាមិនទៀង ឈ្មោះថា កម្លាំងវិបស្សនា ការឃើញរឿយៗ ថាជាទុក្ខ ឈ្មោះថា កម្លាំងវិបស្សនា ការឃើញរឿយៗ ថាមិនមែនខ្លួន ឈ្មោះថា កម្លាំងវិបស្សនា ការឃើញរឿយៗ ថាគួរនឿយណាយ ឈ្មោះថា កម្លាំងវិបស្សនា ការឃើញរឿយៗ ថាជាគ្រឿងប្រាសចាកតម្រេក ឈ្មោះថា កម្លាំងវិបស្សនា ការឃើញរឿយៗ ថាជាទីរម្លត់ទុក្ខ ឈ្មោះថា កម្លាំងវិបស្សនា ការឃើញរឿយៗ ថាគួរលះបង់ ឈ្មោះថា កម្លាំងវិបស្សនា ការឃើញរឿយៗ ថាមិនទៀងក្នុងរូប

ឈ្មោះថា កម្លាំងវិបស្សនា ។បេ។ ការឃើញរឿយៗ ថាជាគ្រឿងលះបង់ក្នុងរូប ឈ្មោះថា កម្លាំងវិបស្សនា ការឃើញរឿយៗ ថាមិនទៀងក្នុងវេទនា ។បេ។ ក្នុងសញ្ញា ក្នុងសង្ខារ ក្នុងវិញ្ញាណ ក្នុងចក្ខុ ។បេ។ ក្នុងជរាមរណៈ ឈ្មោះថា កម្លាំងវិបស្សនា ។បេ។ ការឃើញរឿយៗ ថាជាគ្រឿងលះបង់ក្នុងជរាមរណៈ ឈ្មោះថា កម្លាំងវិបស្សនា ។

[ ២២១ ] សំណួរត្រង់ពាក្យថា កម្លាំងវិបស្សនា តើកម្លាំងវិបស្សនាដោយអត្ថដូចម្តេច ។ ធម្មជាតមិនកម្រើកក្នុងនិច្ចសញ្ញា ដោយអនិច្ចានុបស្សនា ឈ្មោះថា កម្លាំងវិបស្សនា ធម្មជាតមិនកម្រើកក្នុងសុខសញ្ញា ដោយទុក្ខានុបស្សនា ឈ្មោះថា កម្លាំងវិបស្សនា ធម្មជាតមិនកម្រើកក្នុងអនត្តសញ្ញា ដោយអនត្តានុបស្សនា ឈ្មោះថា កម្លាំងវិបស្សនា ធម្មជាតមិនកម្រើកក្នុងសេចក្តីត្រេកអរ ដោយនិព្វិទានុបស្សនា ឈ្មោះថា កម្លាំងវិបស្សនា ធម្មជាតមិនកម្រើកក្នុងរាគៈ ដោយវិរាគានុបស្សនា ឈ្មោះថា កម្លាំងវិបស្សនា ធម្មជាតមិនកម្រើកក្នុងកិរិយាកើតឡើងដោយនិរោធានុបស្សនា ឈ្មោះថា កម្លាំងវិបស្សនា ធម្មជាតមិនកម្រើកក្នុងសេចក្តីប្រកាន់មាំដោយបដិនិស្សគ្គានុបស្សនា ឈ្មោះថា កម្លាំងវិបស្សនា ធម្មជាតមិនកម្រើក មិនឃ្លេងឃ្លោង មិនញាប់ញ័រ ក្នុងអវិជ្ជាផង ក្នុងកិលេសដែលប្រកបដោយអវិជ្ជាផង ក្នុងខន្ធផង ឈ្មោះថា កម្លាំងវិបស្សនា នេះកម្លាំងវិបស្សនា ។

[ ២២២ ] សំណួរត្រង់ពាក្យថា ការស្ងប់រម្ងាប់នៃសង្ខារ ៣ តើការស្ងប់រម្ងាប់នៃសង្ខារ ៣ ដូចម្តេច ។ កាលបុគ្គលចូលកាន់ទុតិយជ្ឈាន វចីសង្ខារ

គឺវិតក្កៈ និងវិចារ រមែងស្ងប់រម្ងាប់ កាលបុគ្គលចូលកាន់ចតុត្ថជ្ឈាន កាយ-សង្ខារ គឺអស្សាសៈ និងបស្សាសៈ រមែងស្ងប់រម្ងាប់ កាលបុគ្គលចូលកាន់សញ្ញាវេទយិតនិរោធ ចិត្តសង្ខារ គឺសញ្ញា និងវេទនា រមែងស្ងប់រម្ងាប់ នេះការស្ងប់រម្ងាប់នៃសង្ខារ ៣ ។

[ ២២៣ ] សំណួរត្រង់ពាក្យថា ញាណចរិយា ១៦ តើញាណចរិយា ១៦ ដូចម្តេច ។ ការឃើញរឿយៗ ថាមិនទៀង ឈ្មោះថា ញាណចរិយា ការឃើញរឿយៗ ថាជាទុក្ខ ឈ្មោះថា ញាណចរិយា ការឃើញរឿយៗ ថាមិនមែនខ្លួន ឈ្មោះថា ញាណចរិយា ការឃើញរឿយៗ ថាគួរនឿយណាយ ឈ្មោះថា ញាណចរិយា ការឃើញរឿយៗ ថាជាគ្រឿងប្រាសចាកតម្រេក ឈ្មោះថា ញាណចរិយា ការឃើញរឿយៗ ថាជាគ្រឿងរម្ងត់ទុក្ខ ឈ្មោះថា ញាណចរិយា ការឃើញរឿយៗ ថាជាគ្រឿងលះបង់កិលេស ឈ្មោះថា ញាណចរិយា ការឃើញរឿយៗ ថាជាគ្រឿងប្រាសចាកការវិលវល់ ឈ្មោះថា ញាណចរិយា សោតាបត្តិមគ្គ ឈ្មោះថា ញាណចរិយា សោតាបត្តិផលសមាបត្តិ ឈ្មោះថា ញាណចរិយា សកទាគាមិមគ្គ ឈ្មោះថា ញាណចរិយា សកទាគាមិផលសមា-បត្តិ ឈ្មោះថា ញាណចរិយា អនាគាមិមគ្គ ឈ្មោះថា ញាណចរិយា អនា-គាមិផលសមាបត្តិ ឈ្មោះថា ញាណចរិយា អរហត្តមគ្គ ឈ្មោះថា ញាណ-ចរិយា អរហត្តផលសមាបត្តិ ឈ្មោះថា ញាណចរិយា នេះញាណចរិយា ១៦ ។

[ ២២៤ ] សំណួរត្រង់ពាក្យថា សមាធិចរិយា ៩ តើសមាធិចរិយា ៩ ដូចម្តេច ។ បឋមជ្ឈាន ឈ្មោះថា សមាធិចរិយា ទុតិយជ្ឈាន ឈ្មោះថា

សមាធិចរិយា តតិយជ្ឈាន ឈ្មោះថា សមាធិចរិយា ចតុត្ថជ្ឈាន ឈ្មោះថា សមាធិចរិយា អាកាសានញ្ចាយតនសមាបត្តិ វិញ្ញាណញ្ចាយតនសមាបត្តិ នេវសញ្ញានាសញ្ញាយតនសមាបត្តិ ឈ្មោះថា សមាធិចរិយា វិតក្ក វិចារ បីតិ សុខ និងចិត្តេកគ្គតា ( ប្រព្រឹត្តទៅ ) ដើម្បីប្រយោជន៍ ដល់កិរិយាបាន នូវបឋមជ្ឈាន ។បេ។ វិតក្ក វិចារ បីតិ សុខ និងចិត្តេកគ្គតា ( ប្រព្រឹត្តទៅ ) ដើម្បីប្រយោជន៍ដល់កិរិយា បាននូវនេវសញ្ញានាសញ្ញាយតនសមាបត្តិ នេះ សមាធិចរិយា ៩ ។

[ ២២៥ ] ពាក្យថា សេចក្តីស្ទាត់ អធិប្បាយថា សេចក្តីស្ទាត់មាន ៥ យ៉ាង គឺសេចក្តីស្ទាត់ក្នុងការនឹក ១ សេចក្តីស្ទាត់ក្នុងការចូល ១ សេចក្តីស្ទាត់ក្នុងការអធិដ្ឋាន ១ សេចក្តីស្ទាត់ក្នុងការចេញ ១ សេចក្តីស្ទាត់ក្នុងការពិចារណា ១ ។ បុគ្គលនឹកនូវបឋមជ្ឈានដែលខ្លួនប្រាថ្នាក្នុងទីណា ប្រាថ្នាក្នុងកាលណា ប្រាថ្នាត្រឹមណា សេចក្តីយឺតយូរក្នុងការនឹកមិនមាន ហេតុនោះ ឈ្មោះថា សេចក្តីស្ទាត់ក្នុងការនឹក បុគ្គលចូលកាន់បឋមជ្ឈានដែលខ្លួនប្រាថ្នា ក្នុងទីណា ប្រាថ្នាក្នុងកាលណា ប្រាថ្នាត្រឹមណា សេចក្តីយឺតយូរក្នុងការចូលមិនមាន ហេតុនោះ ឈ្មោះថា សេចក្តីស្ទាត់ក្នុងការចូល បុគ្គលអធិដ្ឋាននូវបឋមជ្ឈាន ដែលខ្លួនប្រាថ្នាក្នុងទីណា ប្រាថ្នាក្នុងកាលណា ប្រាថ្នាត្រឹមណា សេចក្តីយឺតយូរក្នុងការអធិដ្ឋានមិនមាន ហេតុនោះ ឈ្មោះថា សេចក្តីស្ទាត់ក្នុងការអធិដ្ឋាន បុគ្គលចេញអំពីបឋមជ្ឈានដែលខ្លួនប្រាថ្នាក្នុងទីណា ប្រាថ្នាក្នុងកាលណា ប្រាថ្នាត្រឹមណា សេចក្តីយឺតយូរក្នុងការចេញមិនមាន ហេតុនោះ ឈ្មោះថា សេចក្តី

ស្ងាត់ក្នុងការចេញ បុគ្គលពិចារណានូវបឋមជ្ឈានដែលខ្លួនប្រាថ្នា ក្នុងទីណា ប្រាថ្នាក្នុងកាលណា ប្រាថ្នាត្រឹមណា សេចក្ដីយឺតយូរក្នុងការពិចារណាមិនមាន ហេតុនោះ ឈ្មោះថា សេចក្ដីស្ងាត់ក្នុងការពិចារណា បុគ្គលនឹកនូវទុតិយជ្ឈាន ។បេ។ នូវនេវសញ្ញានាសញ្ញាយតនសមាបត្តិដែលខ្លួនប្រាថ្នា ក្នុងទីណា ប្រាថ្នាក្នុងកាលណា ប្រាថ្នាត្រឹមណា សេចក្ដីយឺតយូរ ក្នុងការនឹកមិនមាន ហេតុនោះ ឈ្មោះថា សេចក្ដីស្ងាត់ក្នុងការនឹក បុគ្គលចូលកាន់នេវសញ្ញានាសញ្ញាយតនសមាបត្តិ ដែលខ្លួនប្រាថ្នាក្នុងទីណា ប្រាថ្នាក្នុងកាលណា ប្រាថ្នាត្រឹមណា ។បេ។ បុគ្គលអធិដ្ឋានចេញ ពិចារណាសេចក្ដីយឺតយូរក្នុងការពិចារណាមិនមាន ហេតុនោះ ឈ្មោះថា សេចក្ដីស្ងាត់ក្នុងការពិចារណានេះឯង សេចក្ដីស្ងាត់ ៥ យ៉ាង ឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញា គឺការៈនៃសេចក្ដីស្ងាត់ ព្រោះហេតុប្រកបដោយកម្លាំងទាំង ២ ផង ដោយការស្ងប់រម្ងាប់សង្ខារ ៣ ផង ដោយញាណចរិយា ១៦ ផង ដោយសមាធិចរិយា ៩ ផង ឈ្មោះថា និរោធសមាបត្តិញាណ ។

# អដ្ឋកថា
# និរោធសមាបត្តិញ្ញាណនិទ្ទេស

[ ២១៧-២១៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិរោធសមាបត្តិញ្ញាណនិទ្ទេសដូចតទៅ

បទថា **សមថពលំ** មានវិនិច្ឆ័យថា ឈ្មោះថា **សមថ** ព្រោះអត្ថថា ស្ងប់ធម៌ដែលជាសត្រូវ មានកាមច្ឆន្ទៈជាដើម ។ សមថៈនោះឯង ឈ្មោះថា ជាពល ដោយអត្ថថា មិនញាប់ញ័រ ព្រោះព្រះអនាគាមី និងព្រះអរហន្តនោះឯង ជាអ្នកដល់នូវភាពជាអ្នកធ្វើឲ្យបរិបូរណ៍ក្នុងសមាធិ ដោយការលះកាមច្ឆន្ទៈដែលជាបដិបក្ខចំពោះសមាធិ សមាធិរបស់ព្រះអនាគាមី និងព្រះអរហន្តទាំងនោះឯង ហៅថា **សមថពលំ** ព្រោះដល់នូវការមានកម្លាំងមិនមែនរបស់បុគ្គលដទៃ ។ បាឋៈថា **សមាធិពលំ** ដូច្នេះក៏មាន ។

បទថា **វិបស្សនាពលំ** មានវិនិច្ឆ័យថា ឈ្មោះថា វិបស្សនា ព្រោះអត្ថថា ឃើញធម៌ដោយអាការច្រើនយ៉ាង ដោយភាពជារបស់មិនទៀងជាដើម វិបស្សនានោះឯង ឈ្មោះថា ជាពល ព្រោះអត្ថថា មិនញាប់ញ័រ ។ វិបស្សនាញាណ ដែលដល់នូវការមានកម្លាំង ក៏ជារបស់ព្រះអរិយៈទាំងពីរពួកនោះឯង ។

ក្នុងពល ២ យ៉ាងនោះ សមថពលក៏ដើម្បីស្ងប់ចិត្តសន្តានដោយលំដាប់ និងដើម្បីប្រព្រឹត្តទៅក្នុងនិរោធ ។ ចំណែកវិបស្សនាពល ក៏ដើម្បីឃើញទោសក្នុងវដ្តៈ និងដើម្បីឃើញអានិសង្សក្នុងនិរោធ ។

[ ២១៩ ] បទថា **នីវរណេ** ជាសត្តមីវិភត្តិ ចុះក្នុងអត្ថនៃនិមិត្តសត្តមី ប្រែថា ព្រោះនីវរណៈ អធិប្បាយថា មាននីវរណៈជានិមិត្ត មាននីវរណៈជាបច្ច័យ

ឬជាសត្តមីវិភត្តិ ចុះក្នុងអត្ថនៃតតិយាវិភត្តិ ប្រែថាព្រោះនីវរណៈ ។ បទថា **ន កម្បតិ** បានដល់ បុគ្គលអ្នកមានការដល់ព្រមក្នុងឈាន ។ម៉្យាងវិញទៀត ព្រោះលោកបំណងយកអង្គនៃឈាន ថាជាឈាន ។ សមាធិដែលសម្បយុត្ត ដោយអង្គនៃឈាននោះ រមែងមិនញាប់ញ័រព្រោះនីវរណៈដោយបឋមជ្ឈាន ។ គប្បីកាន់យកការប្រកបនេះឯង ក្នុងនិទ្ទេសនេះ ។

បទថា **ឧទ្ធច្ចេ ច** បានដល់ ព្រោះឧទ្ធច្ចៈដែលជាចិត្តុប្បាទសហគតៈដោយ ឧទ្ធច្ចៈ ។ ម៉្យាងទៀត ពាក្យថា ឧទ្ធច្ចៈ បានដល់ ការរាយមាយ ឧទ្ធច្ចៈនោះ មានការមិនស្ងប់ជាលក្ខណៈ ។ បទថា **ឧទ្ធច្ចសហគតកិលេសេ ច** បានដល់ ព្រោះកិលេស គឺមោហៈ អហិរិកៈ អនោត្តប្បៈ ដែលសហគតៈដោយឧទ្ធច្ចៈ គឺដែលប្រកបដោយឧទ្ធច្ចៈ ដែលដល់នូវភាពជាកិលេសកើតឡើងរួមគ្នាជាដើម ។ បទថា **ខន្ធេ ច** បានដល់ ព្រោះខន្ធ ៤ ដែលសម្បយុត្តដោយឧទ្ធច្ចៈ ។ បទថា **ន កម្បតិ ន ចលតិ ន វេធតិ** ជាវេវចនៈនៃគ្នានិងគ្នា ។ គប្បីប្រកបថា រមែងមិនញាប់ញ័រព្រោះឧទ្ធច្ចៈ មិនឃ្លេងឃ្លោងព្រោះកិលេសសហគតៈដោយ ឧទ្ធច្ចៈ ។ មិនកម្រើកព្រោះខន្ធដែលសហគតៈដោយឧទ្ធច្ចៈ ។ គប្បីជ្រាប វិបស្សនាពលថា ព្រោះលោកពោលដល់អនុបស្សនា ៧ ហើយ ទើប វិបស្សនាពល បរិបូរណ៍ដោយអំណាចនៃអនុបស្សនានោះឯង ។

[ ២២១ ] បទថា **អវិជ្ជាយ ច** បានដល់ ព្រោះអវិជ្ជាក្នុងចិត្តុប្បាទដែល ជាអកុសល ១២ ។ បទថា **អវិជ្ជាសហគតកិលេសេ ច** បានដល់ កិលេស គឺលោភៈ ទោសៈ មានះ ទិដ្ឋិ វិចិកិច្ឆា ថីនៈ ឧទ្ធច្ចៈ អហិរិកៈ អនោត្តប្បៈ

ដែលសម្បយុត្តដោយអវិជ្ជាដែលប្រកបបាន ។

[ ២២២ ] បទថា **វចីសង្ខារា** បានដល់ វិតក្ក និងវិចារ ។ ឈ្មោះថា វចី-សង្ខារ ព្រោះអត្ថថា តាក់តែង គឺញុំាងវាចាឲ្យកើតឡើង ព្រោះបាលី ( មជ្ឈិម-និកាយ មូលបណ្ណាសក ) ថា ម្នាលអាវុសោវិសាខ បុគ្គលត្រិះរិះពិចារណា មុនសិន ទើបបញ្ចេញវាចា ( ក្រោយ ) ព្រោះហេតុនោះ បានជាវិតក្ក និង វិចារ ហៅថា វចីសង្ខារ ដូច្នេះ ។

បទថា **កាយសង្ខារា** បានដល់ ខ្យល់អស្សាសបស្សាសៈ ។ ឈ្មោះថា កាយសង្ខារ ព្រោះអត្ថថា ដែលតាក់តែងកាយ ព្រោះបាលី ( មជ្ឈិមនិកាយ មូលបណ្ណាសក ) ថា ម្នាលអាវុសោវិសាខ ការដកដង្ហើមចេញចូលហ្នឹងឯង ជាធម៌ប្រព្រឹត្តទៅក្នុងកាយ ធម៌ទាំងនុ៎ះជាធម៌ជាប់ទាក់ទងនឹងកាយ ព្រោះហេតុ នោះ បានជាខ្យល់ដកដង្ហើមចេញ-ចូល ហៅថា កាយសង្ខារ ដូច្នេះ ។

បទថា **សញ្ញាវេទយិតនិរោធំ** បានដល់ ការរម្ងត់សញ្ញា និងវេទនា ។ បទថា **ចិត្តសង្ខារា** បានដល់ សញ្ញា និងវេទនា ។ ឈ្មោះថា ចិត្តសង្ខារ ព្រោះ អត្ថថា ការតាក់តែងចិត្ត ព្រោះបាលី ( មជ្ឈិមនិកាយ មូលបណ្ណាសក ) ថា ធម៌ទាំងនុ៎ះ ជាធម៌ជាប់ទាក់ទងនឹងចិត្ត ព្រោះហេតុនោះ បានជាសញ្ញា និង វេទនា ហៅថា ចិត្តសង្ខារ ដូច្នេះ ។

[ ២២៣ ] ក្នុងញាណចរិយាទាំងឡាយ គប្បីជ្រាបថា សូម្បីអនុបស្សនា ដ៏សេស ដែលលោកពោលថាជាញាណចរិយា ក្នុងចរិយាកថាដែលជាខាងដើម នៃវិវដ្ដនានុបស្សនានោះ ឈ្មោះថា កាន់យកហើយដោយអំណាចអនុបស្សនា

ឬដោយសព្ទថា វិវដ្ដនានុបស្សនា ។

បទថា **សោឡសហិ ញាណចរិយាហិ** ជាការកំណត់យ៉ាងឧក្រិដ្ឋ តែសម្រាប់ព្រះអនាគាមី ស្ងប់រម្ងាប់សង្ខារ ៣ ដោយចរិយា ១៤ វៀរអរហត្តមគ្គ និងអរហត្តផល ព្រោះលោកមានកម្លាំងបរិបូរណ៍ ។

[ ២២៤ ] ក្នុងបទថា **នវហិ សមាធិចរិយាហិ** គប្បីជ្រាបសេចក្ដីដូចតទៅនេះថា សមាធិចរិយា ៨ ដោយបឋមជ្ឈានជាដើម សមាធិចរិយា ១ ដោយអំណាចនៃឧបចារជ្ឈាន ក្នុងធម៌ទាំងពួង ដើម្បីបានបឋមជ្ឈានជាដើម រួមជាសមាធិចរិយា ៩ ។ សួរថា ពល និងចរិយា មានអត្ថផ្សេងគ្នាដូចម្ដេច ឆ្លើយថា សូម្បីក្នុងសមថពល លោកក៏ពោលដល់ឧបចារសមាធិ ដោយបរិយាយ ៧ មាន **នេក្ខម្មវសេន** ជាដើម ដោយសេចក្ដីពិស្ដារនៃបេយ្យាលលោកពោលដល់អប្បនាសមាធិ និងឧបចារសមាធិ តាមដែលប្រកបបានដោយវារៈ ៧០[1]មាន **បឋមជ្ឈានវសេន** ជាដើម សូម្បីក្នុងសមាធិចរិយា លោកក៏ពោលដល់អប្បនាសមាធិ ដោយបរិយាយ ៨ មាន **បឋមំ ឈានំ** ជាដើម ។

លោកពោលឧបចារសមាធិដោយបរិយាយ ៨ មាន **បឋមំ ឈានំ បដិលាភត្ថាយ** ជាដើម ព្រោះហេតុនោះ ទើបលោកពោលអប្បនាសមាធិ និងឧបចារសមាធិ ក្នុងទីទាំងពីរ ។ សូម្បីយ៉ាងនោះក៏គប្បីជ្រាបថា ឈ្មោះថា ពល ព្រោះអត្ថថា មិនញាប់ញ័រ ឈ្មោះថា ចរិយា ព្រោះអត្ថថា មានភាព

១- សូមមើលពុទ្ធដីកា ត្រង់លេខឃ្នាប ២១៣ ។

ជំនាញ ។ ម្យ៉ាងទៀត ក្នុងវិបស្សនាពល លោកពោលអនុបស្សនា ៧ ថាជាវិបស្សនាពល ។ និងពោលអនុបស្សនា ៧ ក្នុងញាណចរិយា ទាំងលោកនៅពោលអនុបស្សនា ៩ មានវិវដ្ដានុបស្សនាជាដើម ឲ្យពិសេសឡើង ។ នេះជាសេចក្ដីផ្សេងគ្នានៃអនុបស្សនាទាំងនោះ ។ ចំណែកអនុបស្សនា ៧ គប្បីជ្រាបថា ឈ្មោះថា ពល ព្រោះអត្ថថា មិនញាប់ញ័រ ឈ្មោះថា ចរិយា ព្រោះអត្ថថា មានភាពជំនាញ ។

[ ២២៥ ] ដើម្បីឆ្លើយវសីដែលលោកពោលក្នុងបទនេះថា **វសីភាវតា បញ្ញា** ទើបលោកពោលជាឥត្ថីលិង្គថា **វសីតិ បញ្ច វសិយោ** ដូច្នេះ ។ លោកអធិប្បាយថា ភាពជំនាញនោះឯង ឈ្មោះថា វសី ។

ព្រះសារីបុត្តត្ថេរ កាលដោះស្រាយវសីទាំងនោះដោយសម្ដែងជាបុគ្គលាធិដ្ឋានទៀត ទើបពោលបទថា **អាវជ្ជនាវសី** ជាដើម ។ ការជំនាញក្នុងការនឹកភាវរក ឈ្មោះថា **អាវជ្ជនាវស** ឈ្មោះថា អាវជ្ជនាវសី ព្រោះអត្ថថា ព្រះយោគាវចរនោះ មានភាពជំនាញក្នុងការនឹកភាវរក ។ ក្នុងបទដ៏សេសក៏មានន័យនេះដូចគ្នា ។

បទថា **បឋមំ ឈានំ យត្ថិច្ឆកំ** បានដល់ សមាបត្តិលាភីបុគ្គល នឹកភាវរកដល់បឋមជ្ឈានបានគ្រប់ទីដែលខ្លួនប្រាថ្នា ទោះស្រុកក្ដី ព្រៃក្ដី ។ បទថា **យទិច្ឆកំ** បានដល់ នឹកភាវរកដល់បឋមជ្ឈាន បានគ្រប់កាល ទោះក្នុងពេលត្រជាក់ក្ដី ពេលក្ដៅក្ដី ។ ម្យ៉ាងវិញទៀត នឹកភាវរកដល់បឋមជ្ឈាន បានតាមប្រាថ្នា ទោះមានបឋវីកសិណជាអារម្មណ៍ក្ដី មានអារម្មណ៍កម្មដ្ឋានដ៏សេសជា

អារម្មណ៍ក្តី ។ ការអធិប្បាយបែបមុនល្អជាង ព្រោះលោកពោលដល់ភាពជាអ្នកជំនាញក្នុងឈាន សូម្បីមានកសិណតែមួយជាអារម្មណ៍ហើយ ។

បទថា **យាវតិច្ឆកំ** បានដល់ នឹកកាវរកដល់បឋមជ្ឈានដែលប្រាថ្នាត្រឹមតែមួយផ្ទាត់ម្រាមដៃ ឬ ៧ ថ្ងៃ ។ បទថា **អាវជ្ជនាយ** បានដល់ នឹកកាវរកតាមមនោទ្វារ ។ បទថា **ទន្ធាយិតត្តំ** បានដល់ ការមិនប្រព្រឹត្តទៅក្នុងអំណាចឬការយឺតយូរ ។ បទថា **សមាបជ្ជតិ** បានដល់ រមែងប្រព្រឹត្តទៅ អធិប្បាយថា រមែងចុះស៊ប់ ។ បទថា **អធិដ្ឋាតិ** បានដល់ តម្កល់មាំក្នុងខាងក្នុងសមាបត្តិ ។ ក្នុងវុដ្ឋានវសី បទថា **បឋមំ ឈានំ** ជាទុតិយាវិភត្តិ ចុះក្នុងអត្ថនៃបញ្ចមីវិភត្តិ អធិប្បាយថា ចេញចាកបឋមជ្ឈាន ។ បទថា **បច្ចវេក្ខតិ** បានដល់ ឃើញភ្លាមៗ ដោយការស្ទុះទៅនៃការពិចារណា ។ នេះជាការពណ៌នាបាលីក្នុងបទនេះ ។

តទៅនេះជាការចង្អុលបង្ហាញសេចក្តី កាលព្រះយោគាវចរចេញចាកបឋមជ្ឈាន ហើយនឹកកាវរកដល់វិតក្ក ជវនចិត្ត ៤ ឬ ៥ ដួង មានវិតក្កជាអារម្មណ៍ រមែងស្ទុះទៅក្នុងលំដាប់នៃអាវជ្ជនចិត្តដែលផ្តាច់ភវង្គប្រព្រឹត្តទៅ ។ បន្ទាប់អំពីនោះ ភវង្គចិត្ត ២ ដួងស្ទុះទៅ បន្ទាប់អំពីនោះ អាវជ្ជនចិត្តមានវិចារជាអារម្មណ៍ ស្ទុះទៅដោយន័យដូចពោលហើយទៀត ។ ព្រះយោគាវចរអាចបញ្ជូនចិត្តទៅក្នុងលំដាប់ ក្នុងអង្គឈាន ៥ ដោយប្រការដូច្នេះ ។ គ្រានេះអាវជ្ជនវសីរបស់ព្រះយោគាវចរនោះ ជាការសម្រេច ។

ចំណែកវសីដែលដល់ទីបំផុតនេះ រមែងបានក្នុងយមកប្បាដិហារិយ៍ របស់

ព្រះមានព្រះភាគប៉ុណ្ណោះ ។ ក្រៅអំពីនេះ មិនមានអាវជ្ជនវសីដែលរហ័សជាងនេះ ។ ការរាប់ក្នុងករង្គភារៈក្នុងលំដាប់ៗ មិនមានដល់អ្នកដទៃ ។ ភាពជាអ្នកអាចក្នុងការចូលសមាបត្តិបានរហ័ស ដូចក្នុងការទូន្មាននន្ទោបនន្ទនាគ របស់ព្រះមហាមោគ្គល្លានត្ថេរ ឈ្មោះថា សមាបជ្ជនវសី ។ ភាពជាអ្នកអាចដើម្បីតាំង ( ចូល ) សមាបត្តិ រហូតត្រឹមតែមួយខណៈផ្ទាត់ម្រាមដៃ ឬត្រឹម ១០ ផ្ទាត់ម្រាមដៃ ឈ្មោះថា អធិដ្ឋានវសី ។ ភាពជាអ្នកអាចចេញចាកសមាបត្តិនោះបានរហ័សយ៉ាងនោះឯង ឈ្មោះថា វុដ្ឋានវសី ។ ចំណែកបច្ចវេក្ខណវសីលោកពោលហើយ ក្នុងអាវជ្ជនវសីនោះឯង ។ ព្រោះថា បច្ចវេក្ខណជវនជាលំដាប់នៃអាវជ្ជនៈក្នុងអាវជ្ជនវសីនោះ ។ ហេតុនោះ កាលអាវជ្ជនវសីសម្រេចហើយ បច្ចវេក្ខណវសីក៏សម្រេច កាលអធិដ្ឋានវសីសម្រេចហើយ វុដ្ឋានវសីក៏សម្រេច កាលបើយ៉ាងនេះ ភាពជាអ្នកអាចក្នុងការញុំាងអាវជ្ជនៈឲ្យប្រព្រឹត្តទៅដោយន័យដូចពោលហើយក្នុងកសិណនោះ រហ័សតាមគាប់ចិត្តរបស់បុគ្គលដែលបំណងចូលឈាន មានកសិណនោះៗ ជាអារម្មណ៍ ព្រោះការនិមិត្តរូបផ្សេងៗ ជាដើម សម្រេចបានដោយអំណាចកសិណផ្សេងៗ ព្រោះមិនមានការពិចារណាអង្គឈានក្នុងវេលាសម្ដែងបាដិហារិយ៍ ព្រោះលោកពោលហើយថា វសីដែលដល់ទីបំផុតនេះ រមែងបានក្នុងយមកប្បាដិហារិយ៍របស់ព្រះមានព្រះភាគប៉ុណ្ណោះ ឈ្មោះថា អាវជ្ជនវសី ភាពជាអ្នកអាចក្នុងអប្បនា និងភាពជាអ្នកអាចចូលឈាននោះៗ ក្នុងវិថីនៃអាវជ្ជនៈនោះឯង ឈ្មោះថា សមាបជ្ជនវសី ។ កាលពោលយ៉ាងនេះ ជាការត្រឹមត្រូវនឹងមិនខុស ម្យ៉ាងទៀត លំដាប់នៃវសី

រមែងគួរតាមលំដាប់នោះឯង ។ មួយវិញទៀត ក្នុងការពិចារណាអង្គនៃឈាន ព្រោះលោកពោលថា វសីដែលដល់ទីបំផុតហើយនោះឯង រមែងមានជវនចិត្ត ៥ ដួង កាលជវនចិត្ត ៧ ដួងស្មុះទៅ ដោយន័យដូចពោលហើយ ក៏រមែងមានបច្ចវេក្ខណវសីដូចគ្នា ។

កាលបើយ៉ាងនោះ បើមានអ្នកសង្ស័យថា ពាក្យថា នឹកភាវរកដល់បឋមជ្ឈានរមែងមិនត្រឹមត្រូវ អធិប្បាយបានថា លោកពោលឈាន ប្រព្រឹត្តទៅក្នុងកសិណាថាជាកសិណាដោយសំដៅដល់ហេតុ យ៉ាងណា លោកពោលកសិណដែលជាបច្ច័យដល់ឈានថា ជាឈានដោយសំដៅដល់ផល ( ក៏យ៉ាងនោះ ) ដូចពាក្យ ( ក្នុងធម្មបទ ) ជាដើមថា ការកើតឡើងនៃព្រះពុទ្ធជាសុខ ដូច្នេះ ។ កាលព្រះយោគាវចរតាំងនៅក្នុងកាលតាមដែលកំណត់ ហើយចេញចាកឈាន ហើយចូលឈានទៀត ដូចបុគ្គលភ្ញាក់អំពីដេកលក់ហើយដេកលក់ទៀត ឈ្មោះថា អធិដ្ឋានវសីនោះឯង ចំណែកព្រះយោគាវចរកាលចេញចាកឈាន តាមដែលកំណត់ហើយ អធិដ្ឋានក្នុងការចេញទៀត ក៏ឈ្មោះថា វុដ្ឋានវសី នេះជាការផ្សេងគ្នារបស់វសីទាំងនោះ ដោយប្រការដូច្នេះ ។

ដើម្បីបន្ទុលបង្ហាញនិរោធសមាបត្តិ ទើបមានបញ្ហាកម្មដូចតទៅនេះថា និរោធសមាបត្តិដូចម្តេច នរណាចូលនិរោធសមាបត្តិនោះ នរណាមិនចូល ចូលក្នុងទីណា ព្រោះហេតុអ្វីទើបចូល ការចូលសមាបត្តិនោះដូចម្តេច តាំងនៅដូចម្តេច ចេញដូចម្តេច អ្នកចេញមានចិត្តបង្អោនទៅកាន់អ្វី មនុស្សស្លាប់ និងមនុស្សចូលនិរោធផ្សេងគ្នាដូចម្តេច និរោធសមាបត្តិជាសង្ខត: ឬអសង្ខត: ជា

លោកិយ ឬលោកុត្តរ ជានិប្ផន្នៈ ( សម្រេច ) ឬអនិប្ផន្នៈ ( មិនសម្រេច ) ។

ក្នុងបញ្ហាកម្មទាំងនោះ ពាក្យថា និរោធសមាបត្តិដូចម្តេច អធិប្បាយថា ធម៌ គឺចិត្ត និងចេតសិកមិនប្រព្រឹត្តទៅដោយអំណាចរលត់ទៅ ដោយលំដាប់ ឯណា នេះឈ្មោះថា និរោធសមាបត្តិ ។

ពាក្យថា នរណាចូលនិរោធសមាបត្តិនោះ នរណាមិនចូល អធិប្បាយថា បុថុជ្ជនទាំងអស់ ព្រះសោតាបន្ន ព្រះសកទាគាមី និងលោកអ្នកដែលជា សុក្ខវិបស្សកៈ មួយអន្លើដោយព្រះអនាគាមី និងព្រះអរហន្ត ( ដែលមិន មានសមាបត្តិ ) មិនចូល ។ ចំណែកព្រះអនាគាមី និងព្រះខីណាស្រព អ្នកបានសមាបត្តិ ៨ រមែងចូល ។

ពាក្យថា ចូលក្នុងទីណា អធិប្បាយថា ចូលក្នុងភពដែលមានខន្ធ ៥ ។ ព្រោះហេតុអ្វី ព្រោះមានសមាបត្តិតាមលំដាប់ ។ ចំណែកក្នុងភពដែលមាន ខន្ធ ៤ បឋមជ្ឈានជាដើម មិនមានការកើតឡើយ ព្រោះហេតុនោះ ទើបមិន អាចចូលក្នុងភពនោះបាន ។

ពាក្យថា ព្រោះហេតុអ្វីទើបចូល អធិប្បាយថា ជាអ្នកនឿយណាយក្នុង ការប្រព្រឹត្តទៅរបស់សង្ខារ មិនមានចិត្តក្នុងទិដ្ឋធម៌ ទើបចូល ដោយគិតថា អញដល់និព្វានដែលជាការរម្ងត់ហើយ នឹងនៅជាសុខ ។

ពាក្យថា ការចូលនិរោធសមាបត្តិនោះដូចម្តេច អធិប្បាយថា កាលលោក ខ្នះខ្នែងដោយអំណាចសមថវិបស្សនាហើយ ធ្វើបុព្វកិច្ចស្រេចហើយ ញុំាង នេវសញ្ញានាសញ្ញាយតនៈឲ្យរលត់ ការចូលនិរោធសមាបត្តិមានដោយអាការ

យ៉ាងនេះ ។ បុគ្គលណាខ្នះខ្នែងដោយអំណាចសមថៈប៉ុណ្ណោះ បុគ្គលនោះសម្រេចនេវសញ្ញានាសញ្ញាយតនសមាបត្តិ ហើយតាំងនៅ ។ ចំណែកបុគ្គលណាខ្នះខ្នែងដោយអំណាចវិបស្សនាប៉ុណ្ណោះ បុគ្គលនោះសម្រេចផលសមាបត្តិហើយតាំងនៅ ។ ម្យ៉ាងទៀត បុគ្គលណាខ្នះខ្នែង ដោយអំណាចទាំងពីរយ៉ាងរមែងញ៉ាំងនេវសញ្ញានាសញ្ញាយតនៈឲ្យរលត់ បុគ្គលនោះ ឈ្មោះថា រមែងចូលដល់និរោធសមាបត្តិ នេះជាសេចក្តីសង្ខេបក្នុងបទនេះ ។

ចំណែកសេចក្តីពិស្តារ គប្បីជ្រាបដូចតទៅនេះថា ភិក្ខុក្នុងសាសនានេះ បំណងនឹងចូលនិរោធសមាបត្តិ ឆាន់អាហារស្រេចហើយ លាងដៃ និងជើងអង្គុយពត់ភ្នែនលើអាសនៈ ដែលក្រាលយ៉ាងល្អក្នុងទីស្ងាត់ តាំងកាយឲ្យត្រង់ តម្រង់សតិចំពោះមុខ ។ ភិក្ខុនោះចូលបឋមជ្ឈាន លុះចេញហើយពិចារណាសង្ខារទាំងឡាយក្នុងបឋមជ្ឈាននោះ ដោយភាពជារបស់មិនទៀងជាទុក្ខ ជាអនត្តា ។ វិបស្សនានោះ មាន ៣ យ៉ាង គឺសង្ខារបរិគ្គណ្ហណកវិបស្សនា វិបស្សនាកំណត់សង្ខារ ១ ផលសមាបត្តិវិបស្សនា វិបស្សនាដែលជាផលសមាបត្តិ ១ និរោធសមាបត្តិវិបស្សនា វិបស្សនាដែលជានិរោធសមាបត្តិ ១ ។

ក្នុងវិបស្សនា ៣ យ៉ាងនោះ សង្ខារបរិគ្គណ្ហណកវិបស្សនាទន់ខ្លីក្តី ចាស់ក្លាក្តី រមែងជាបទដ្ឋាននៃមគ្គនោះឯង ។ ផលសមាបត្តិវិបស្សនាចាស់ក្លាដូចគ្នានឹងមគ្គភាវនាទើបគួរ ។ ចំណែកនិរោធសមាបត្តិវិបស្សនាមិនទន់ខ្លីពេក មិនចាស់ក្លាពេកនោះឯងទើបគួរ ។ ព្រោះហេតុនោះ ទើបភិក្ខុនោះពិចារណាឃើញ

ច្បាស់សង្ខារទាំងនោះ ដោយវិបស្សនាដែលមិនទទន់ខ្ជីពេក មិនចាស់ក្លាពេក បន្ទាប់អំពីនោះ ចូលទុតិយជ្ឈាន ចេញចាកទុតិយជ្ឈានហើយ ពិចារណាសង្ខារទាំងឡាយក្នុងទុតិយជ្ឈាននោះ យ៉ាងនោះឯង ។ បន្ទាប់អំពីនោះ ទើបចូលតតិយជ្ឈាន ។បេ។ បន្ទាប់អំពីនោះ ក៏ចូលវិញ្ញាណញ្ចាយតនៈ លុះចេញហើយពិចារណាសង្ខារទាំងឡាយ ក្នុងវិញ្ញាណញ្ចាយតនៈនោះ យ៉ាងនោះឯង ។ លំដាប់នោះ ក៏ចូលអាកិញ្ចញ្ញាយតនៈ កាលចេញហើយក៏ធ្វើកិច្ចខាងដើម ៤ យ៉ាង គឺនានាពទ្ធអវិកោបនៈ មិនឲ្យបរិក្ខារផ្សេងៗ វិនាស ១ សង្ឃបដិមានន សង្ឃត្រូវការ ១ សត្ថុបកោសនៈ ព្រះសាស្តាហៅរក ១ អទ្ធានបរិច្ឆេទ កំណត់កាល ១ ។

ក្នុងកិច្ច ៤ យ៉ាងនោះ ពាក្យថា មិនឲ្យបរិក្ខារផ្សេងៗ វិនាស សេចក្តីថា វត្ថុណាដែលមិនមែនជារបស់ប្រើប្រាស់ជាប់ខ្លួនភិក្ខុនេះ ជារបស់ដាច់អំពីខ្លួនដែលតម្កល់ទុក ដូចជាបាត្រ ចីវរ គ្រែ តាំង ទីនៅអាស្រ័យ ឬសូម្បីបរិក្ខារណាៗ ដទៃ របស់នោះមិនវិនាស គឺមិនវិនាសដោយភ្លើង ទឹក ខ្យល់ ចោរ និងសត្វកណ្តុរជាដើម ដោយប្រការណា គប្បីអធិដ្ឋានដោយប្រការនោះ ។ វិធីអធិដ្ឋានក្នុងសេចក្តីនោះមានដូច្នេះថា ខាងក្នុង ៧ ថ្ងៃនេះ ចូររបស់នេះៗ កុំត្រូវភ្លើងឆេះ កុំត្រូវទឹកបន្សាត់នាំទៅ កុំត្រូវខ្យល់កម្ចាត់ កុំត្រូវចោរលួច កុំត្រូវកណ្តុរកាត់ជាដើម ។ កាលអធិដ្ឋានយ៉ាងនេះ ៧ ថ្ងៃនោះ មិនមានអន្តរាយណាមួយដល់វត្ថុទាំងនោះ បើមិនអធិដ្ឋាននឹងវិនាសដោយភ្លើងជាដើមបាន នេះឈ្មោះថា មិនឲ្យបរិក្ខារផ្សេងៗ វិនាស ។ តែវត្ថុណាដែលប្រើប្រាស់ជាប់នឹងខ្លួន

ដូចជាសំពត់ស្បៀក សំពត់ដណ្តប់ ទីអង្គុយ ក្នុងវត្ថុនោះ មិនមានកិច្ចនឹងអធិដ្ឋានផ្សេងទៀតឡើយ សមាបត្តិនោះឯង រមែងរក្សាវត្ថុទាំងនោះបាន ។

ពាក្យថា សង្ឃត្រូវការ បានដល់ ការរង់ចាំ គឺការទន្ទឹងនៃភិក្ខុសង្ឃ អធិប្បាយថា សង្ឃមិនធ្វើសង្ឃកម្មមុននឹងភិក្ខុនោះមក ។ ម្យ៉ាងទៀត ក្នុងពាក្យនេះ ការរង់ចាំមិនមែនជាបុព្វកិច្ចរបស់ភិក្ខុនេះ ។ តែការនឹកដល់ការរង់ចាំជាបុព្វកិច្ចរបស់ភិក្ខុនេះ ព្រោះហេតុនោះ ភិក្ខុមុនចូលសមាបត្តិ គួរអធិដ្ឋានយ៉ាងនេះថា បើខ្ញុំអង្គុយចូលនិរោធ ៧ ថ្ងៃ សង្ឃបំណងធ្វើកម្មឯណានីមួយ ក្នុងអបលោកនកម្មជាដើម ខ្ញុំនឹងចេញមួយរំពេច មិនចាំបាច់មានភិក្ខុណាមួយមកហៅ ។ ភិក្ខុធ្វើយ៉ាងនេះហើយ ចូលសមាបត្តិ រមែងចេញបានក្នុងសម័យនោះៗឯង ។ តែភិក្ខុណាមិនបានធ្វើយ៉ាងនេះ ទាំងសង្ឃក៏ប្រជុំគ្នាហើយ កាលមិនឃើញភិក្ខុនោះ ទើបសួរថា ភិក្ខុរូបឯណោះទៅណា កាលមានអ្នកប្រាប់ថា កំពុងចូលសមាបត្តិ ទើបបញ្ជូនភិក្ខុមួយរូបទៅថា ចូរលោកទៅហៅភិក្ខុនោះតាមពាក្យសង្ឃ ។ លំដាប់នោះ ត្រឹមពាក្យដែលភិក្ខុនោះឈរនៅក្នុងទីជិតល្មមនឹងបានឮ ពោលថា អាវុសោ សង្ឃរង់ចាំលោកប៉ុណ្ណោះ ដូច្នេះ ភិក្ខុនោះក៏ចេញពីនិរោធ ។ ព្រោះថា ឈ្មោះថា អាណា គឺអំណាចរបស់សង្ឃធ្ងន់យ៉ាងនេះ ។ ព្រោះហេតុនោះ ភិក្ខុដែលចូលនិរោធគួរពិចារណាដល់ការត្រូវការនៃសង្ឃនោះ ហើយចូល នឹងចេញមុននោះឯង ( មិនចាំបាច់ហៅ ) ។

ពាក្យថា ព្រះសាស្តាហៅរក សូម្បីក្នុងបទនេះ ការនឹកដល់ការហៅរករបស់ព្រះសាស្តា ក៏ជាបុព្វកិច្ចរបស់ភិក្ខុនេះ ព្រោះហេតុនោះ គួរនឹកដល់បុព្វកិច្ច

នោះយ៉ាងនេះថា បើអញចូលនិរោធរហូត ៧ ថ្ងៃ ព្រះសាស្ដាទ្រង់បញ្ញត្តិសិក្ខាបទព្រោះរឿងដែលល្មើស ឬទ្រង់សម្ដែងធម៌ ព្រោះហេតុដែលកើតរឿងបែបនោះ អញនឹងចេញដោយមិនចាំបាច់មានភិក្ខុណាមួយមកហៅ ភិក្ខុអង្គុយធ្វើយ៉ាងនេះ រមែងចេញក្នុងសម័យនោះឯង ។ ម្យ៉ាងទៀត ភិក្ខុណាមិនធ្វើយ៉ាងនោះ ទាំងព្រះសាស្ដាកាលបើសង្ឃប្រជុំគ្នា ទ្រង់មិនឃើញភិក្ខុនោះ ត្រាស់សួរថា ភិក្ខុអង្គនោះទៅណា កាលក្រាបទូលថា ចូលនិរោធ ទើបទ្រង់បញ្ជូនភិក្ខុមួយរូបទៅថា ចូរអ្នកទៅហៅភិក្ខុនោះ តាមពាក្យរបស់តថាគត គ្រាន់តែភិក្ខុនោះឈរនៅក្នុងទីជិតល្មមបានឮពោលថា ព្រះសាស្ដាត្រាស់ហៅរកលោកម្ចាស់ ដូច្នេះប៉ុណ្ណោះ ភិក្ខុនោះក៏ចេញចាកនិរោធ ព្រោះថា ការត្រាស់ហៅរករបស់ព្រះសាស្ដា គឺជារឿងដ៏ធ្ងន់យ៉ាងនេះ ។ ព្រោះហេតុនោះ ទើបភិក្ខុដែលចូលនិរោធ គួរអធិដ្ឋានដល់ការត្រាស់ហៅរករបស់ព្រះសាស្ដា ហើយចូលនឹងចេញមុននោះឯង ។

ពាក្យថា កំណត់កាល បានដល់ កំណត់កាលរបស់ជីវិត ។ ពិតហើយភិក្ខុនេះគួរជាអ្នកឈ្លាសក្នុងការកំណត់កាល ។ គួរពិចារណាថា អាយុសង្ខាររបស់ខ្លួននឹងប្រព្រឹត្តទៅបានរហូត ៧ ថ្ងៃ ឬមិនប្រព្រឹត្តទៅបានទេ ហើយសឹមចូលនិរោធ ព្រោះថា បើអាយុសង្ខាររលត់ក្នុងចន្លោះ ៧ ថ្ងៃ ភិក្ខុមិនពិចារណាចូលនិរោធ និរោធសមាបត្តិរបស់ភិក្ខុនោះ មិនអាចហាមសេចក្ដីស្លាប់បាន ។ ភិក្ខុរមែងចេញចាកសមាបត្តិក្នុងចន្លោះបាន ព្រោះថា ខាងក្នុងនិរោធមិនមានការស្លាប់ ព្រោះហេតុនោះ គួរពិចារណាកាលនោះហើយសឹមចូលនិរោធ ។ លោក

ពោលថា សូម្បីមិនពិចារណាក្នុងកាលដ៏សេស ក៏គួរពិចារណាដល់កាលនេះឯង ។ ភិក្ខុនោះចូលអាកិញ្ចញ្ញាយតនៈយ៉ាងនេះហើយ លុះចេញហើយ ក៏ធ្វើបុព្វកិច្ចនេះ រមែងចូលដល់នេវសញ្ញានាសញ្ញាយតនៈបាន លុះកន្លងវារចិត្តមួយ ឬពីរហើយ ជាអ្នកមិនមានចិត្ត រមែងពាល់ត្រូវនិរោធបាន ។ សួរថា ព្រោះហេតុអ្វី ទើបចិត្តលើសពីរជួងឡើងទៅ របស់អ្នកចូលសមាបត្តិនោះប្រព្រឹត្តទៅមិនបាន ឆ្លើយថា ព្រោះជាបយោគនៃនិរោធ ។ ពិតហើយ ការធ្វើសមថៈនិងវិបស្សនាទាំងពីររបស់ភិក្ខុនោះឲ្យជាយុគនទ្ធធម៌ គឺធម៌ដែលជាគូនេះហើយឡើងកាន់សមាបត្តិ ៨ ជាប្រយោគរបស់និរោធតាមលំដាប់ មិនមែនជាបយោគរបស់នេវសញ្ញានាសញ្ញាយតនសមាបត្តិ ព្រោះហេតុនោះ ទើបចិត្តលើសពីរជួងឡើងទៅ មិនប្រព្រឹត្តទៅ ព្រោះជាបយោគនៃនិរោធ ។

ពាក្យថា តាំងនៅដូចម្ដេច អធិប្បាយថា តាំងនៅដោយអំណាចកំណត់កាលនៃសមាបត្តិនោះ ដែលចូលដល់ហើយយ៉ាងនេះ និងដោយមិនមានការអស់អាយុ ការដែលសង្ឃត្រូវការ និងការត្រាស់ហៅរករបស់ព្រះសាស្ដាក្នុងចន្លោះ ។

ពាក្យថា ចេញដូចម្ដេច អធិប្បាយថា ចេញ ២ យ៉ាងនេះ គឺដោយអនាគាមិផលសមាបត្តិរបស់ព្រះអនាគាមី ១ ដោយអរហត្តផលសមាបត្តិ របស់ព្រះអរហន្ត ១ ។

ពាក្យថា អ្នកចេញមានចិត្តបង្អោនទៅកាន់អ្វី អធិប្បាយថា បង្អោនទៅកាន់និព្វាន សមដូចព្រះនាងធម្មទិន្នាថេរីពោល ( ក្នុងមជ្ឈិមនិកាយ មូល-

បណ្ណាសក ) ថា ម្នាលអាវុសោវិសាខ ភិក្ខុដែលចេញអំពីសញ្ញាវេទយិត-និរោធសមាបត្តិ ចិត្តលោកបង្អោនទៅរកវិវេក ទោរទន់ទៅរកវិវេក ឈមទៅរកវិវេក ដូច្នេះ ។

ពាក្យថា អ្នកស្លាប់ និងអ្នកចូលនិរោធ ផ្សេងគ្នាដូចម្ដេច អធិប្បាយថា លោកពោលសេចក្ដីនេះហើយក្នុងព្រះសូត្រ សមដូចព្រះនាងធម្មទិន្នាថេរី ពោល ( ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសក ) ថា ម្នាលអាវុសោ បុគ្គលដែលធ្វើកាលកិរិយាក្ស័យ បុគ្គលនោះ កាយសង្ខារ គឺខ្យល់ដង្ហើមចេញ-ចូល រលត់សូន្យឈឹង វចីសង្ខារ គឺវិតក្ក និងវិចាររលត់សូន្យឈឹង ចិត្តសង្ខារ គឺសញ្ញា និងវេទនារលត់សូន្យឈឹង អាយុក៏អស់ ចំហាយធាតុភ្លើងក៏រលត់សូន្យឈឹង ឥន្ទ្រិយក៏បែកធ្លាយ ឯភិក្ខុដែលចូលកាន់សញ្ញាវេទយិតនិរោធ ភិក្ខុនោះមានកាយសង្ខាររលត់សូន្យឈឹង វចីសង្ខាររលត់សូន្យឈឹង ចិត្តសង្ខាររលត់សូន្យឈឹងដែរ តែអាយុមិនអស់ ចំហាយធាតុភ្លើងមិនរលត់សូន្យទេ ឥន្ទ្រិយនៅថ្លាល្អ ដូច្នេះ ។

ក្នុងពាក្យសួរថា និរោធសមាបត្តិជាសង្ខត: ឬអសង្ខត:**ជាដើម** មានអធិប្បាយដូចតទៅនេះថា មិនគួរពោលថា ជាសង្ខត:ខ្លះ អសង្ខត:ខ្លះ លោកិយខ្លះ លោកុត្តរខ្លះ ។ ព្រោះហេតុអ្វី ព្រោះមិនមានដោយសភាវ: ។ ព្រោះភិក្ខុ ឈ្មោះថា ជាអ្នកចូលដល់ព្រមហើយ ដោយអំណាចនៃការចូលនិរោធ ។ ដូច្នោះ គួរពោលថា ជានិប្ផន្ន: គឺសម្រេចហើយ មិនគួរពោលថា ជាអនិប្ផន្ន: គឺមិនទាន់សម្រេច ។

*សមាបត្តិនេះ ដែលស្ងប់ហើយ ដែលព្រះអរិយៈសេពហើយ ដល់នូវការរាប់ថា ជានិព្វានក្នុងបច្ចុប្បន្ននោះឯង ដោយប្រការដូច្នេះ ។៙*

## អដ្ឋកថានិរោធសមាបត្តិញ្ញាណនិទ្ទេស ចប់

# សុត្តន្តបិដក

[ ២២៦ ] បញ្ញាក្នុងការបង្អស់នូវការប្រព្រឹត្តទៅនៃកិលេស និងខន្ធរបស់បុគ្គលអ្នកដឹងខ្លួន ឈ្មោះថា បរិនិព្វានញ្ញាណ តើដូចម្តេច ។ បុគ្គលដឹងខ្លួនក្នុងលោកនេះ បង្អស់នូវការប្រព្រឹត្តទៅនៃកាមច្ឆន្ទៈ ដោយនេក្ខម្មៈ បង្អស់នូវការប្រព្រឹត្តទៅនៃព្យាបាទ ដោយអព្យាបាទ បង្អស់នូវការប្រព្រឹត្តទៅនៃថីនមិទ្ធៈ ដោយអាលោកសញ្ញា បង្អស់នូវការប្រព្រឹត្តទៅនៃឧទ្ធច្ចៈ ដោយអវិក្ខេបៈ បង្អស់នូវការប្រព្រឹត្តទៅនៃវិចិកិច្ឆា ដោយធម្មវវត្ថានៈ ។បេ។ នៃអវិជ្ជា ដោយញាណ នៃអរតិដោយបាមុជ្ជ នៃនីវរណៈទាំងឡាយដោយបឋមជ្ឈាន ។បេ។ បង្អស់នូវការប្រព្រឹត្តទៅនៃកិលេសទាំងអស់ ដោយអរហត្តមគ្គ ម្យ៉ាងទៀត កាលបុគ្គលអ្នកដឹងខ្លួននិព្វានដោយអនុបាទិសេសនិព្វានធាតុ ការប្រព្រឹត្តទៅនៃចក្ខុនេះ រមែងអស់ទៅ ទាំងការប្រព្រឹត្តដទៃនៃចក្ខុក៏មិនកើតឡើងដែរ ការប្រព្រឹត្តទៅនៃសោតៈនេះ ។បេ។ ការប្រព្រឹត្តទៅនៃឃានៈ ការប្រព្រឹត្តទៅនៃជិវ្ហា ការប្រព្រឹត្តទៅនៃកាយ ការប្រព្រឹត្តទៅនៃចិត្ត រមែងអស់ទៅ ទាំងការប្រព្រឹត្តដទៃនៃចិត្ត ក៏មិនកើតឡើងដែរ នេះឯងបញ្ញាក្នុងការបង្អស់នូវការប្រព្រឹត្តទៅនៃកិលេស និងខន្ធរបស់បុគ្គលអ្នកដឹងខ្លួន ឈ្មោះថា បរិនិព្វានញ្ញាណ ឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងការបង្អស់នូវការប្រព្រឹត្តទៅនៃកិលេស របស់បុគ្គលអ្នកដឹងខ្លួន ឈ្មោះថា បរិនិព្វានញ្ញាណ ។

# អដ្ឋកថា

# បរិនិព្វានញ្ញាណនិទ្ទេស

[ ២២៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបរិនិព្វានញ្ញាណនិទ្ទេសដូចតទៅ បទថា **ឥធ** បានដល់ ក្នុងសាសនានេះ ។ បទថា **សម្បជានោ** សេចក្តីថា បុគ្គលដែលមានសម្បជញ្ញៈ ដោយសម្បជញ្ញៈ ៤ នេះ គឺសាត្ថកសម្បជញ្ញៈ សេចក្តីដឹងខ្លួនក្នុងកិច្ចដែលជាប្រយោជន៍ដល់ខ្លួន ១ សប្បាយសម្បជញ្ញៈ សេចក្តីដឹងខ្លួនក្នុងបច្ច័យដែលសប្បាយ ១ គោចរសម្បជញ្ញៈ សេចក្តីដឹងខ្លួនក្នុងធម៌ដែលជាគោចរ ១ អសម្មោហសម្បជញ្ញៈ សេចក្តីដឹងខ្លួនក្នុងការមិនវង្វេង ១ ។

បទថា **បវត្តំ** បានដល់ ការប្រព្រឹត្តទៅនៃបរិយុដ្ឋានក្កិលេស និងការប្រព្រឹត្តទៅនៃអនុសយក្កិលេស តាមសមគួរក្នុងទីទាំងពួង ។ បទថា **បរិយាទិយតិ** បានដល់ រមែងឲ្យអស់ទៅ គឺធ្វើឲ្យប្រព្រឹត្តទៅមិនបានដោយអំណាចនៃវិក្ខម្ភនប្បហានក្នុងធម៌ទាំងឡាយ ដែលលោកពោលដោយអំណាចនៃឧបចារសមាធិ និងអប្បនាសមាធិ ដោយអំណាចនៃតទង្គប្បហាន ក្នុងធម៌ទាំងឡាយ ដែលលោកពោលដោយអំណាចនៃវិបស្សនា ដោយអំណាចនៃសមុច្ឆេទប្បហាន ក្នុងធម៌ទាំងឡាយដែលលោកពោលដោយអំណាចនៃមគ្គ ។ ពិតហើយ លោកសង្រ្គេបឈានសមាបត្តិ មានទុតិយជ្ឈានជាដើម មហាវិបស្សនា និងមគ្គ ដោយមាតិកាបេយ្យាល ព្រោះញាណដែលប្រព្រឹត្តទៅហើយដល់អ្នកពិចារណាញាណនោះ ឈ្មោះថា បរិនិព្វានញ្ញាណ ហេតុនោះទើបលោកពោលថា បរិនិព្វានដោយការសង្កត់សង្កិន បរិនិព្វានដោយអង្គនៃធម៌នោះ បរិនិព្វានជាសមុច្ឆេទ ។ ដោយបទទាំងនេះ លោកពោលដល់

បច្ចវេក្ខណញ្ញាណ ក្នុងការរម្ងាត់កិលេស ។

ដោយបទថា **អថវា បន** ជាដើម ព្រះសារីបុត្តត្ថេរសម្ដែងដល់បច្ចវេក្ខណញ្ញាណ ក្នុងការរម្ងាត់ខន្ធ ។ បទថា **អនុបាទិសេសាយ និព្វានធាតុយា** បានដល់ និព្វានធាតុមាន ២ យ៉ាង គឺសឧបាទិសេសនិព្វានធាតុ ១ អនុបាទិសេសនិព្វានធាតុ ១ ។ ក្នុងនិព្វានធាតុ ២ យ៉ាងនោះ ឈ្មោះថា **ឧបាទិ** ព្រោះអត្ថថា ដែលបុគ្គលប្រកាន់មាំ គឺប្រកាន់យ៉ាងខ្លាំងក្លាថា អញ របស់អញ បទថា **ឧបាទិ** នេះ ជាឈ្មោះរបស់ខន្ធ ៥ ។ ឈ្មោះថា **ឧបាទិសេស** ព្រោះអត្ថថា ឧបាទិនោះឯង នៅសេសសល់ ។ ឈ្មោះថា **សឧបាទិសេស** ព្រោះអត្ថថា ប្រព្រឹត្តទៅជាមួយនឹងឧបាទិសេស គឺខន្ធ ៥ ដែលសល់ ។ ឈ្មោះថា **អនុបាទិសេស** ព្រោះអត្ថថា មិនមានឧបាទិសេស ក្នុងនិព្វានធាតុនេះ ។ លោកពោលដល់សឧបាទិសេសមុន ចំណែកនិព្វានធាតុនេះជាអនុបាទិសេស ។ ដោយអនុបាទិសេសនិព្វានធាតុនោះ ។ បទថា **ចក្ខុបវត្តំ** បានដល់ ការប្រព្រឹត្តទៅផ្លូវភ្នែក ការប្រោកដផ្លូវភ្នែក ។ បទថា **បរិយាទិយតិ** បានដល់ រម្ងាប់ឲ្យអស់ទៅ គឺត្រូវញាំញី ។ ក្នុងបទដ៏សេសក៏មានន័យនេះ ៗ។

**អដ្ឋកថាបរិនិព្វានញ្ញាណនិទ្ទេស ចប់**

# សុត្តន្តបិដក

[ ២២៧ ] បញ្ញា គឺការមិនប្រាកដ ក្នុងការផ្តិលផ្តាច់ដោយប្រពៃនូវធម៌ទាំងពួងផង ក្នុងការរម្ងាប់ផង ឈ្មោះថា សមសីសដ្ឋញាណ តើដូចម្តេច ។

ពាក្យថា ធម៌ទាំងពួង បានដល់ខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ពួកកុសលធម៌ ពួកអកុសលធម៌ ពួកអព្យាកតធម៌ ពួកកាមាវចរធម៌ ពួករូបាវចរធម៌ ពួកអរូបាវចរធម៌ ពួកអបរិយាបន្នធម៌ ។

[ ២២៨ ] ពាក្យថា ការផ្តិលផ្តាច់ដោយប្រពៃ អធិប្បាយថា បុគ្គលកាត់ផ្តាច់ដោយប្រពៃនូវកាមច្ឆន្ទៈ ដោយនេក្ខម្មៈ កាត់ផ្តាច់ដោយប្រពៃនូវព្យាបាទដោយអព្យាបាទ កាត់ផ្តាច់ដោយប្រពៃនូវថីនមិទ្ធៈដោយអាលោកសញ្ញា កាត់ផ្តាច់ដោយប្រពៃនូវឧទ្ធច្ចៈដោយអវិក្ខេបៈ កាត់ផ្តាច់ដោយប្រពៃនូវវិចិកិច្ឆាដោយធម្មវវត្ថាន កាត់ផ្តាច់ដោយប្រពៃនូវអវិជ្ជាដោយញាណ កាត់ផ្តាច់ដោយប្រពៃនូវអរតិដោយបាមុជ្ជ កាត់ផ្តាច់ដោយប្រពៃនូវពួកនីវរណៈដោយបឋមជ្ឈាន ។បេ។ កាត់ផ្តាច់ដោយប្រពៃនូវកិលេសទាំងពួង ដោយអរហត្តមគ្គ ។

[ ២២៩ ] ពាក្យថា ការរម្ងាប់ គឺបុគ្គលរម្ងាប់នូវកាមច្ឆន្ទៈដោយនេក្ខម្មៈ រម្ងាប់នូវព្យាបាទ ដោយអព្យាបាទ រម្ងាប់នូវថីនមិទ្ធៈ ដោយអាលោកសញ្ញា រម្ងាប់នូវឧទ្ធច្ចៈដោយអវិក្ខេបៈ រម្ងាប់នូវវិចិកិច្ឆាដោយធម្មវវត្ថាន រម្ងាប់នូវអវិជ្ជាដោយញាណ រម្ងាប់នូវអរតិដោយបាមុជ្ជ រម្ងាប់នូវពួកនីវរណៈដោយបឋមជ្ឈាន ។បេ។ រម្ងាប់នូវពួកកិលេសទាំងពួង ដោយអរហត្តមគ្គ ។

[ ២៣០ ] ពាក្យថា មិនប្រាកដ គឺកាលបុគ្គលបានលះបង់នូវនេក្ខម្មៈ កាមច្ឆន្ទៈមិនប្រាកដ កាលបុគ្គលបានលះបង់នូវអព្យាបាទ ព្យាបាទមិនប្រាកដ កាល

បុគ្គលបានស៊ប់នូវអាលោកសញ្ញា ថីនមិទ្ធៈមិនប្រាកដ កាលបុគ្គលបានស៊ប់នូវអវិក្ខេបៈ ឧទ្ធច្ចៈមិនប្រាកដ កាលបុគ្គលបានស៊ប់នូវធម្មវវត្ថាន វិចិកិច្ឆាមិនប្រាកដ កាលបុគ្គលបានស៊ប់នូវញាណ អវិជ្ជាមិនប្រាកដ កាលបុគ្គលបានស៊ប់នូវបាមុជ្ជ អរតិមិនប្រាកដ កាលបុគ្គលបានស៊ប់នូវបឋមជ្ឈាន ពួកនីវរណៈមិនប្រាកដ ។បេ។ កាលបុគ្គលបានស៊ប់នូវអរហត្តមគ្គ ពួកកិលេសទាំងពួងមិនប្រាកដ ។

[ ២៣១ ] ពាក្យថា ស្ងប់រម្ងាប់ សេចក្តីថា នេក្ខម្មៈ ឈ្មោះថា ស្ងប់រម្ងាប់ ព្រោះលះបង់កាមច្ឆន្ទៈ អព្យាបាទ ឈ្មោះថា ស្ងប់រម្ងាប់ ព្រោះលះបង់ព្យាបាទ អាលោកសញ្ញា ឈ្មោះថា ស្ងប់រម្ងាប់ ព្រោះលះបង់ថីនមិទ្ធៈ អវិក្ខេបៈ ឈ្មោះថា ស្ងប់រម្ងាប់ ព្រោះលះបង់ឧទ្ធច្ចៈ ធម្មវវត្ថានឈ្មោះថា ស្ងប់រម្ងាប់ ព្រោះលះបង់វិចិកិច្ឆា ញាណ ឈ្មោះថា ស្ងប់រម្ងាប់ ព្រោះលះបង់អវិជ្ជា បាមុជ្ជ ឈ្មោះថា ស្ងប់រម្ងាប់ ព្រោះលះបង់អរតិ បឋមជ្ឈាន ឈ្មោះថា ស្ងប់រម្ងាប់ ព្រោះលះបង់នីវរណៈ ។បេ។ អរហត្តមគ្គ ឈ្មោះថា ស្ងប់រម្ងាប់ ព្រោះលះបង់កិលេសទាំងពួង ។

[ ២៣២ ] ពាក្យថា ជាប្រធាន សេចក្តីថា ប្រធាន ១៣ យ៉ាង គឺតណ្ហាជាប្រធានក្នុងបលិពោធ ( ការរារាំងផ្លូវនិព្វាន ) ១ មានះជាប្រធានក្នុងការជាប់ជំពាក់ ១ ទិដ្ឋិជាប្រធានក្នុងការស្ទាបអង្អែល ១ ឧទ្ធច្ចៈជាប្រធានក្នុងការរាយមាយ ១ អវិជ្ជាជាប្រធានក្នុងសេចក្តីសៅហ្មង ១ សទ្ធាជាប្រធានក្នុងសេចក្តីជឿស៊ប់ ១ វីរិយៈជាប្រធានក្នុងការផ្គងឡើង ១ សតិជាប្រធានក្នុង

ការប្រុងប្រយ័ត្ន ១ សមាធិជាប្រធានក្នុងការមិនរាយមាយ ១ បញ្ញាជាប្រធានក្នុងការយល់ឃើញ ១ ជីវិតិន្ទ្រិយ ជាប្រធានក្នុងការប្រព្រឹត្ត ១ វិមោក្ខជាប្រធានក្នុងគោចរ ១ និរោធជាប្រធានក្នុងសង្ខារ ១ ឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញា មិនប្រាកដក្នុងការផ្តិលផ្តាច់ដោយប្រពៃនូវធម៌ទាំងពួងផង ក្នុងការរម្ងាត់ផង ឈ្មោះថា សមសីសដ្ឋញាណ ។

# អដ្ឋកថា

## សមសីសញ្ញាណនិទ្ទេស

[ ២២៧-២៣១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសមសីសញ្ញាណនិទ្ទេស ដូចតទៅនេះថា គប្បីជ្រាបការសង្គ្រោះធម៌ទាំងអស់ ដោយពួក ១០ មានខន្ធ ៥ ជាដើម ។ ពិតហើយ លោកមិនបានចាត់ធម៌ទាំងអស់ទុកមួយផ្នែកៗ ដោយពួក ៨ ដ៏សេស វៀរពួកអាយតនៈ និងពួកធាតុដោយអំណាចធម៌ពួកមួយៗ ។ ព្រោះលោកុត្តរធម៌ មិនមែនជាធម៌ដែលត្រូវកាត់ដោយការកាត់ផ្តាច់ហេតុ ហេតុនោះ លោកុត្តរធម៌សូម្បីលោកសង្គ្រោះចូលដោយសព្ទថា **សព្វធម្មា** ក៏មិនគប្បីកាន់យកក្នុងទីនេះ ព្រោះមានពាក្យថា **សមុច្ឆេទ** ធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ចំពោះដែលគួរកាត់ផ្តាច់ដោយការកាត់ហេតុ គួរកាន់យក ។

បទថា **សម្មា សមុច្ឆិន្ទតិ** សេចក្តីថា កាលរម្ងត់បរិយុដ្ឋានកិលេស និងអនុសយកិលេសដោយអំណាចនៃវិក្ខម្ភនប្បហាន តទង្គប្បហាន និងសមុច្ឆេទប្បហានតាមសមគួរ ឈ្មោះថា កាត់ផ្តាច់ដោយប្រពៃ ។ លោកសម្តែងការកាត់ផ្តាច់ដោយប្រពៃ ដោយទេសនាជាបុគ្គលាធិដ្ឋានយ៉ាងនេះ ។

បទថា **និរោធេតិ** បានដល់ រមែងឲ្យរលត់ដោយអនុប្បាទនិរោធ ( រលត់ដោយមិនមានកើតឡើង ) ។ ដោយបទនេះ លោកពោលដល់អត្ថនៃសមុច្ឆេទ ។

បទថា **ន ឧបដ្ឋាតិ** សេចក្តីថា កាលរលត់យ៉ាងនេះហើយ ធម៌នោះៗ ក៏មិនប្រាកដឡើងទៀត គឺមិនកើតឡើង ។ ដោយបទនេះ លោកពោលដល់អត្ថនៃនិរោធ ។ លោកសម្តែងដល់ការមិនប្រាកដដោយអំណាចនៃធម៌ដែលមិនតាំង

ឡើង ដោយប្រការដូច្នេះ ។

បទថា **សមំ** បានដល់ ឈ្មោះថា ស្ងប់ ព្រោះកាមច្ឆន្ទៈជាដើម ស្ងប់ ។ សមធម៌មាន ៣៧ ប្រការ គឺធម៌ ៧ មាននេក្ខម្មៈជាដើម រូបជ្ឈាន អរូបជ្ឈាន ៨ មហាវិបស្សនា ១៨ អរិយមគ្គ ៤ ។

[ ២៣២ ] លោកពោលធម៌ជាប្រធាន គឺសីសៈ ១៣ ប្រការ ដោយអំណាចនៃការសង្គ្រោះធម៌ទាំងអស់ដែលជាសីសៈ តែក្នុងទីនេះ ធម៌ជាប្រធាន ៨ មានសទ្ធាជាដើម រមែងគួរ ព្រោះថា ធម៌ជាប្រធាន ៥ មានតណ្ហាជាដើម មិនមានដល់ព្រះអរហន្ត ។

បទថា **បលិពោធសីសំ** បានដល់ មានគ្រឿងកន្លល់ អធិប្បាយថា ជាគ្រឿងរាំងផ្លូវទៅនិព្វាន ។ បទថា **សីសំ** បានដល់ ជាប្រធាន គឺធម៌ដែលក្រៃលែង ។ បលិពោធនោះឯងជាប្រធាន ឬជាប្រមុខក្នុងបលិពោធទាំងពួងមានការប្រកបដោយធម៌នោះជាដើម ព្រោះហេតុនោះ ទើបឈ្មោះថា **បលិពោ-ធសីសំ** ។ ក្នុងបទដ៏សេសក៏មានន័យនេះឯង ។ តែដោយការផ្សេងគ្នា បទថា **ពន្ធនំ** បានដល់ ការចងក្នុងសង្សារដោយអំណាចការលើកតម្កើងខ្លួន ។ បទថា **បរាមាសោ** បានដល់ សេចក្តីប្រកាន់មាំ ។ បទថា **វិក្ខេបោ** បានដល់ សេចក្តីរាយមាយ ។ បទថា **កិលេសោ** បានដល់ សេចក្តីសៅហ្មង ។ បទថា **អធិមោក្ខោ** បានដល់ បង្អោនចិត្តជឿ ។ បទថា **បគ្គហោ** បានដល់ ការឧស្សាហ៍ ។ បទថា **ឧបដ្ឋានំ** បានដល់ ប្រាកដជិតៗ ។ បទថា **អវិក្ខេបោ** បានដល់ ការមិនរាយមាយ ។ បទថា **ទស្សនំ** បានដល់ ចាក់ធ្លុះ

តាមសេចក្តីពិត ។ បទថា **បវត្តំ** បានដល់ ការប្រព្រឹត្តទៅនៃឧបាទិន្នក្ខន្ធ ។ បទថា **គោចរោ** បានដល់ អារម្មណ៍ ។ ធម៌មានអត្ថជាប្រធាន មានអត្ថជាប្រមុខ បានក្នុងវារៈ ១២ នេះ ។

បទថា **វិមោក្ខោ** បានដល់ និព្វានដែលជានិស្សរណវិមុត្តិ ក្នុងវិមុត្តិ ៥ គឺវិក្ខម្ភនវិមុត្តិ ១ តទង្គវិមុត្តិ ១ សមុច្ឆេទវិមុត្តិ ១ បដិប្បស្សទ្ធិវិមុត្តិ ១ និស្សរណវិមុត្តិ ១ ។

បទថា **សង្ខារសីសំ** បានដល់ ជាប្រធាននៃសង្ខារដែលជាសង្ខតៈទាំងពួង អធិប្បាយថា ជាកំពូល គឺទីបំផុត ។

ដោយបទនេះ លោកពោលដល់អនុបាទិសេសបរិនិព្វាន ឬលោកពោលដល់ខន្ធបរិនិព្វាន ដោយត្រឹមតែមិនមានសង្ខារ ។

បទថា **សមសីសី** ព្រោះអត្ថថា មានសេចក្តីស្ងប់ មាននេក្ខម្មៈជាដើម និងជាប្រធាន មានសទ្ធាជាដើម ឬបុគ្គលនោះមានការស្ងប់ និងធម៌ជាប្រធាន ។

ម្យ៉ាងទៀត ការត្រាស់ដឹងអរិយសច្ច ៤ នេះ គឺបណ្តាធម៌ជាប្រធាន ១៣ ធម៌ជាប្រធាន ៥ មានតណ្ហាជាដើម ជាសមុទយសច្ច ធម៌ជាប្រធាន ៥ មានសទ្ធាជាដើម ជាមគ្គសច្ច ជីវិតិន្ទ្រិយមានការប្រព្រឹត្តទៅជាប្រធាន ជាទុក្ខសច្ច វិមោក្ខមានអារម្មណ៍ជាប្រធាន និងនិរោធ មានសង្ខារជាប្រធាន ជានិរោធសច្ច

ឯការរម្ងាត់កិលេសដែលជាអនុបាទិសេស ក្នុងរោគឯណានីមួយក្តី ក្នុងឥរិយា-បថឯណានីមួយក្តី ក្នុងជីវិតិន្ទ្រិយដែលស្មើគ្នា ( អស់កិលេស និងអស់ជីវិតស្មើគ្នា ) ឯណានីមួយក្តី រមែងមានដល់បុគ្គលណា បុគ្គលនោះ លោកពោលថា សមសីសី ព្រោះមានសេចក្តីស្ងប់ ដូចបានពោលទុកក្នុងកាលមុននិងមានធម៌ជាប្រធានទាំងនេះ ។ល។

## អដ្ឋកថាសមសីសដ្ឋញ្ញាណនិទ្ទេស ចប់

# សុត្តន្តបិដក

[ ២៣៣ ] បញ្ញាក្នុងការរម្ងត់នូវភ្លើងដ៏ក្រាស់ មានភាពផ្សេងៗ និងមានភាពតែមួយ ឈ្មោះថា សល្លេខដ្ឋញ្ញាណ តើដូចម្តេច ។

ពាក្យថា ក្រាស់ សេចក្តីថា ក្រាស់ គឺរាគៈក្រាស់ គឺទោសៈក្រាស់ គឺមោហៈក្រាស់ គឺកោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាថេយ្យៈ ថម្ភៈ សារម្ភៈ មានះ អតិមានះ មទៈ បមាទៈ កិលេសទាំងពួង ទុច្ចរិតទាំងពួង អភិសង្ខារទាំងពួង ភវគាមិកម្មទាំងពួង ។

[ ២៣៤ ] ពាក្យថា ភាពផ្សេងៗ និងភាពតែមួយ គឺកាមច្ឆន្ទៈ ឈ្មោះថា ភាពផ្សេងៗ នេក្ខម្មៈ ឈ្មោះថា ភាពតែមួយ ព្យាបាទ ឈ្មោះថា ភាពផ្សេងៗ អព្យាបាទ ឈ្មោះថា ភាពតែមួយ ថីនមិទ្ធៈ ឈ្មោះថា ភាពផ្សេងៗ អាលោកសញ្ញា ឈ្មោះថា ភាពតែមួយ ឧទ្ធច្ចៈ ឈ្មោះថា ភាពផ្សេងៗ អវិក្ខេបៈ ឈ្មោះថា ភាពតែមួយវិចិកិច្ឆា ឈ្មោះថា ភាពផ្សេងៗ ធម្មវវត្ថានៈ ឈ្មោះថា ភាពតែមួយ អវិជ្ជា ឈ្មោះថា ភាពផ្សេងៗ ញាណ ឈ្មោះថា ភាពតែមួយ អរតិ ឈ្មោះថា ភាពផ្សេងៗ បាមុជ្ជ ឈ្មោះថា ភាពតែមួយ នីវរណៈ ឈ្មោះថា ភាពផ្សេងៗ បឋមជ្ឈាន ឈ្មោះថា ភាពតែមួយ ។បេ។ កិលេសទាំងពួង ឈ្មោះថា ភាពផ្សេងៗ អរហត្តមគ្គ ឈ្មោះថា ភាពតែមួយ ។

[ ២៣៥ ] ពាក្យថា ភ្លើង សេចក្តីថា ភ្លើង ៥ ភ្លើង គឺចរណៈ ( ចរណតេជះ ) ១ ភ្លើង គឺគុណ ( គុណតេជះ ) ១ ភ្លើង គឺប្រាជ្ញា ( បញ្ញាតេជះ ) ១ ភ្លើង គឺបុណ្យ ( បុញ្ញតេជះ ) ១ ភ្លើង គឺធម៌ ( ធម្មតេជះ ) ១ បុគ្គលលត់

ភ្លើង គឺភាពទ្រុស្តសីល ព្រោះដុតកម្តៅដោយភ្លើង គឺចរណៈ លត់ភ្លើង គឺការមិនមានគុណ ព្រោះដុតកម្តៅដោយភ្លើង គឺគុណ លត់ភ្លើង គឺការមិនមានប្រាជ្ញា ព្រោះដុតកម្តៅដោយភ្លើង គឺបញ្ញា លត់ភ្លើង គឺឥតបុណ្យ ព្រោះដុតកម្តៅដោយភ្លើង គឺបុណ្យ លត់ភ្លើង គឺអធម៌ ព្រោះដុតកម្តៅដោយភ្លើង គឺធម៌ ។

[ ២៣៦ ] ពាក្យថា ផូរផង់ សេចក្តីថា កាមច្ឆន្ទៈ ឈ្មោះថា មិនផូរផង់ នេក្ខម្មៈ ឈ្មោះថា ផូរផង់ ព្យាបាទ ឈ្មោះថា មិនផូរផង់ ថីនមិទ្ធៈ ឈ្មោះថា មិនផូរផង់ អាលោកសញ្ញា ឈ្មោះថា ផូរផង់ ឧទ្ធច្ចៈ ឈ្មោះថា មិនផូរផង់ អវិក្ខេបៈ ឈ្មោះថា ផូរផង់ វិចិកិច្ឆា ឈ្មោះថា មិនផូរផង់ ធម្មវវត្ថានៈ ឈ្មោះថា ផូរផង់ អវិជ្ជា ឈ្មោះថា មិនផូរផង់ ញាណ ឈ្មោះថា ផូរផង់ អរតិ ឈ្មោះថា មិនផូរផង់ បាមុជ្ជ ឈ្មោះថា ផូរផង់នីវរណៈ ឈ្មោះថា មិនផូរផង់ បឋមជ្ឈាន ឈ្មោះថា ផូរផង់ ។បេ។ កិលេសទាំងពួង ឈ្មោះថា មិនផូរផង់ អរហត្តមគ្គ ឈ្មោះថា ផូរផង់ ឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងការរម្ងត់ភ្លើងដ៏ក្រាស់ មានភាពផ្សេងៗ និងមានភាពតែមួយ ឈ្មោះថា សល្លេខដ្ឋញាណ ។

# អដ្ឋកថា

## សល្លេខដ្ឋញ្ញាណនិទ្ទេស

[ ២៣៣ ] គប្បីជ្រាបវិនិច្ឆ័យ ក្នុងសល្លេខដ្ឋញ្ញាណនិទ្ទេសដូចតទៅនេះ បទថា **រាគោ បុថុ** បានដល់ រាគៈដាច់ដោយឡែកអំពីលោកុត្តរ អធិប្បាយថា មិនលាយឡំគ្នា ។ ក្នុងបទដ៏សេស ក៏មានន័យនេះ ។ ឈ្មោះថា **រាគោ** ព្រោះអត្ថថា ត្រេកត្រអាល ។ ឈ្មោះថា **ទោសោ** ព្រោះអត្ថថា ប្រទូស្ត ។ ឈ្មោះថា **មោហោ** ព្រោះអត្ថថា វង្វេង ។

ព្រះសារីបុត្ត កាលពោលកិលេសដែលជាប្រធានទាំង ៣ នេះ គឺរាគៈ មានការត្រេកត្រអាលជាលក្ខណៈ ទោសៈ មានការប្រទូស្តជាលក្ខណៈ មោហៈ មានការវង្វេងជាលក្ខណៈហើយ ឥឡូវនេះ កាលនឹងសម្តែងដោយប្រភេទ ទើបពោលបទជាដើមថា **កោធោ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **កោធោ** មានការអាក់អន់ជាលក្ខណៈ នេះលោកបំណងយកសេចក្តីក្រោធដែលមានសត្វជាទីតាំង ។ **ឧបនាហោ** មានការចូលទៅចងទុកជាលក្ខណៈ គឺសេចក្តីក្រោធនោះឯងដែលដល់នូវការមាំទាំ ( មិនរសាយ ) ។ **មក្ខោ** មានការលុបគុណអ្នកដទៃជាលក្ខណៈ អធិប្បាយថា លុបបំបាត់គុណរបស់អ្នកដទៃ ។ **បឡាសោ** មានការវាយឫកស្មើជាលក្ខណៈ អធិប្បាយថា ឃើញគុណអ្នកដទៃដោយអំណាចប្រកាន់ថាស្មើគ្នា ។ **ឥស្សា** មានការធ្វើសម្បត្តិអ្នកដទៃឲ្យអស់ទៅជាលក្ខណៈ អធិប្បាយថា ប្រណែន ។ **មច្ឆរិយំ** មានការលាក់បាំងសម្បត្តិរបស់ខ្លួនជាលក្ខណៈ អធិប្បាយ

ថាសម្បត្តិរបស់អញ កុំបីជារបស់អ្នកដទៃឡើយ ។ **មាយា** មានការបិទបាំងអំពើអាក្រក់ដែលខ្លួនធ្វើជាលក្ខណៈ អធិប្បាយថា ធ្វើជាមាយាដោយការបិទបាំង ។ **សាឋេយ្យំ** មានការប្រកាសគុណដែលមិនមានក្នុងខ្លួនជាលក្ខណៈ អធិប្បាយថា ភាពជាអ្នកអួតអាង ។ **ថម្ភោ** មានការធ្វើចិត្តឲ្យប៉ោងឡើងជាលក្ខណៈ អធិប្បាយថា រឹងត្អឹង ។ **សារម្ភោ** មានការប្រណាំងប្រជែងជាលក្ខណៈ ។ **មានោ** មានការលើកខ្លួនជាលក្ខណៈ ។ **អតិមានោ** មានការមើលងាយអ្នកដទៃជាលក្ខណៈ ។ **មទោ** មានការស្រវឹងជាលក្ខណៈ ។ **បមាទោ** មានការបណ្តោយចិត្តទៅក្នុងកាមគុណ ៥ ជាលក្ខណៈ ។

ព្រះសារីបុត្តត្ថេរ លុះសម្តែងសភាពក្រាស់ ដោយអំណាចកិលេសទុកមួយផ្នែកៗ ហើយ ដើម្បីនឹងសម្តែងដល់កិលេសដែលពោលហើយ និងកិលេសដទៃដែលមិនទាន់បានពោល ដោយសង្គ្រោះចូលជាមួយគ្នាទាំងអស់ ទើបពោលបទជាដើមថា **សព្វេ កិលេសា** ដូច្នេះ ។ ក្នុងបទទាំងនោះ ឈ្មោះថា **កិលេសា** ព្រោះអត្ថថា ញុំាងសត្វឲ្យសៅហ្មង ឲ្យក្តៅក្រហាយ ឲ្យលំបាកក្នុងភពនេះ និងភពខាងមុខ ។ ទាំងដែលសង្គ្រោះចូលក្នុងអកុសលកម្មបថ ទាំងដែលមិនបានសង្គ្រោះចូល ។ ឈ្មោះថា **ទុច្ចរិតា** ព្រោះអត្ថថា ប្រព្រឹត្តដោយអំពើអាក្រក់ ឬប្រព្រឹត្តអាក្រក់ ។ ទុច្ចរិតនោះមាន ៣ ប្រការ គឺ កាយទុច្ចរិត ១ វចីទុច្ចរិត ១ មនោទុច្ចរិត ១ ។

ឈ្មោះថា **អភិសង្ខារា** ព្រោះអត្ថថា តាក់តែងវិបាក ។ អភិសង្ខារនោះក៏មាន ៣ ប្រការ គឺបុញ្ញាភិសង្ខារ អភិសង្ខារ គឺបុណ្យ ១ អបុញ្ញាភិសង្ខារ

អភិសង្ខារ គឺបាប ១ អានេញ្ជាភិសង្ខារ អភិសង្ខារ គឺការមិនញាប់ញ័រ ១ ។ ឈ្មោះថា **ភវគាមី** ព្រោះអត្ថថា សត្វទៅកាន់ភពដោយអំណាចវិបាក ។ កម្ម ដែលជាហេតុឲ្យសត្វទៅកាន់ភព ឈ្មោះថា **ភវគាមិកម្មា** ។ ដោយបទនេះ កាលភាពជាអភិសង្ខារមាន ក៏ឈ្មោះថា ហាមកម្មដែលមិនមានការសោយ ។ នេះជាសេចក្តីផ្សេងគ្នា ដោយប្រការដូច្នេះ ។ បទថា **ឧុច្ចរិតា** និង **កម្មា** លោក ធ្វើជាលិង្គវិបល្លាស ។

[ ២៣៤ ] បទថា **នានត្តេកត្តំ** នេះ ក្នុងឧទ្ទេសសូម្បីមិនមានសព្ទថា **ឯកត្ត** ព្រះសារីបុត្តបំណងនឹងចង្អុលបង្ហាញធម៌ជាសភាវៈមួយ ព្រោះការសម្ព័ន្ធ ដល់គ្នានិងគ្នានៃធម៌ជាសភាពផ្សេងៗ និងធម៌ជាសភាពតែមួយ ទើបធ្វើឧទ្ទេស ថា **នានត្តេកត្តំ** ។ កាលធម៌ជាសភាពតែមួយ ដែលដុសខាត់ធម៌ជាសភាវៈ ផ្សេងៗ រមែងសម្តែងដល់ញាណក្នុងការដុសខាត់បានដោយងាយ ។ បទថា **នានត្តំ** បានដល់ មានសភាពផ្សេងៗ ព្រោះការមិនតាំងមាំ និងព្រោះមានការ អន្ទះអន្ទែង ។ បទថា **ឯកត្តំ** បានដល់ មានសភាពតែមួយ ព្រោះការមាំទាំ និងព្រោះមិនអន្ទះអន្ទែង ។

[ ២៣៥ ] បទថា **ចរណតេជោ** មានវិគ្គហៈថា ឈ្មោះថា **ចរណា** ព្រោះ អត្ថថា ជាហេតុត្រាច់ទៅកាន់ទិសដែលមិនបានទៅ គឺទៅកាន់និព្វាន ។ ចរណៈ នោះគឺអ្វី គឺសីល ។ សីលនោះឯង ឈ្មោះថា តេជះ ព្រោះអត្ថថា ដុតវត្ថុ ដែលជាសត្រូវ ។ បទថា **គុណតេជោ** បានដល់ សមាធិតេជះដែលបានទី តាំងដោយសីល ។ បទថា **បញ្ញាតេជោ** បានដល់ វិបស្សនាតេជះដែលបាន

ទីតាំងដោយសមាធិ ។ បទថា **បុញ្ញតេជោ** បានដល់ អរិយមគ្គកុសលតេជះ ដែលបានទីតាំងដោយវិបស្សនា ។ បទថា **ធម្មតេជោ** បានដល់ ពុទ្ធវចនតេជះ ដែលជាទីតាំងនៃតេជះ ៤ ។ បទថា **ចរណាតេជេន តេជិតត្តា** បានដល់ ព្រោះសីលតេជះ ធ្វើឲ្យក្លៀវក្លា ។ បទថា **ទុស្សីល្យតេជំ** បានដល់ តេជះ ពោល គឺភាពជាអ្នកទ្រុស្តសីល ។ ឈ្មោះថា **តេជោ** ព្រោះដុតសន្តាននោះ ។ បទថា **បរិយាទិយតិ** បានដល់ ឲ្យអស់ទៅ ។ បទថា **អគុណតេជំ** បានដល់ តេជះ គឺសេចក្តីរាយមាយដែលជាបដិបក្ខចំពោះសមាធិ ។ បទថា **ទុប្បញ្ញ-តេជំ** បានដល់ តេជះ គឺមោហៈ ដែលជាបដិបក្ខចំពោះវិបស្សនាញាណ ។ បទថា **អបុញ្ញតេជំ** បានដល់ តេជះ គឺអកុសលកម្ម ដែលជាសម្ភាញរបស់កិលេស ដោយការលះកិលេសដែលសម្លាប់ដោយមគ្គនោះៗ ។ មិនមែនឲ្យអបុញ្ញតេជះវិនាសទៅតែម្យ៉ាងប៉ុណ្ណោះ រមែងញុំាងកុសលកម្ម ឲ្យវិនាសទៅផងដែរ ដោយព្រះបាលី ( ក្នុងអង្គុត្តរនិកាយ ចតុក្កនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ កម្មមិនខ្មៅមិនស មានវិបាកមិនខ្មៅមិនស ប្រព្រឹត្តទៅដើម្បីអស់កម្មក៏មាន ដូច្នេះ ។ លោកពោលតេជះដែលមិនមែនបុណ្យប៉ុណ្ណោះដោយអំណាចជាបដិបក្ខចំពោះបុញ្ញតេជះ ។

បទថា **អធម្មតេជំ** បានដល់ តេជះដែលជាពាក្យពេចន៍សម្តែងលទ្ធិរបស់ពួកតិរ្ថិយផ្សេងៗ ក្នុងអត្ថវិកប្បទីពីរដែលពោល ក្នុងការពណ៌នាឧទ្ទេសនៃញាណនេះ កិលេសក្រាស់ ១៩ យ៉ាង មានរាគៈជាដើមជាតេជះ គឺភាពជាអ្នកទ្រុស្តសីល ។ អបុញ្ញាភិសង្ខារក្នុងពាក្យនេះថា អភិសង្ខារជាកម្មដែលជា

ហេតុឲ្យទៅកាន់ភព និងអកុសលកម្មជាអបុញ្ញាភិសង្ខារ និង កុសលកម្មខាងលោកិយ ឈ្មោះថា រមែងជាបដិបក្ខចំពោះអបុញ្ញតេជះ ព្រោះឲ្យអស់ទៅដោយបុញ្ញតេជះនោះឯង ។ ធម៌ជាសភាវៈផ្សេងៗ ១៥ មានកាមច្ឆន្ទៈជាដើម រមែងជាអគុណតេជះ ធម៌ជាសភាវៈផ្សេងៗ ១៨ មាននិច្ចសញ្ញាជាដើម រមែងជាទុប្បញ្ញាតេជះ ធម៌ជាសភាវៈផ្សេងៗ ៤ ដែលទម្លាយមគ្គ ៤ រមែងជាអបុញ្ញតេជះ គប្បីសង្គ្រោះអធម្មតេជះ ដោយសភាពផ្សេងៗ ដែលទម្លាយសោតាបត្តិមគ្គ ។

[ ២៣៦ ] ព្រះសារីបុត្តត្ថេរបំណងនឹងសម្តែងធម៌ជាគ្រឿងជុសខាត់ដោយធម៌មិនមែនជាគ្រឿងជុសខាត់ដែលជាបដិបក្ខ ដល់ធម៌ជាគ្រឿងជុសខាត់ក្នុងនិទ្ទេស ទើបសម្តែងធម៌ជាគ្រឿងជុសខាត់ ដែលមានធម៌មិនមែនជាគ្រឿងជុសខាត់ជាខាងដើម ។ ធម៌ជាសភាវៈតែមួយ ៣៧ មាននេក្ខម្មៈជាដើម លោកពោលថា ជាធម៌គ្រឿងជុសខាត់ ព្រោះជុសខាត់ធម៌ជាសត្រូវទាំងឡាយ ។ ញាណក្នុងធម៌ជាគ្រឿងជុសខាត់ ៣៧ ប្រភេទ មាននេក្ខម្មៈជាដើមនោះ ឈ្មោះថា សល្លេខដ្ឋញ្ញាណ ។៚

**អដ្ឋកថាសល្លេខដ្ឋញ្ញាណនិទ្ទេស ចប់**

# សុត្តន្តបិដក

[ ២៣៧ ] បញ្ញាក្នុងការផ្គងរបស់បុគ្គលមានចិត្តមិនរួញរា និងបុគ្គលមានខ្លួនបញ្ជូនទៅហើយ ឈ្មោះថា វិរិយារម្ភញ្ញាណ តើដូចម្តេច ។ បញ្ញាក្នុងការផ្គងរបស់បុគ្គលមានចិត្តមិនរួញរា និងបុគ្គលមានខ្លួនបញ្ជូនទៅហើយ ដើម្បីមិនឲ្យកើតនូវអកុសលធម៌ដ៏លាមកដែលមិនទាន់កើត ឈ្មោះថា វិរិយារម្ភញ្ញាណ បញ្ញាក្នុងការផ្គង របស់បុគ្គលមានចិត្តមិនរួញរា និងបុគ្គលមានខ្លួនបញ្ជូនទៅហើយ ដើម្បីលះបង់នូវអកុសលធម៌ដ៏លាមកដែលកើតឡើងហើយ ឈ្មោះថា វិរិយារម្ភញ្ញាណ បញ្ញាក្នុងការផ្គងរបស់បុគ្គលមានចិត្តមិនរួញរា និងបុគ្គលមានខ្លួនបញ្ជូនទៅហើយ ដើម្បីបង្កើតនូវកុសលធម៌ដែលមិនទាន់កើត ឈ្មោះថា វិរិយារម្ភញ្ញាណ បញ្ញាក្នុងការផ្គងរបស់បុគ្គលមានចិត្តមិនរួញរា និងបុគ្គលមានខ្លួនបញ្ជូនទៅហើយ ដើម្បីតាំងនៅមិនឲ្យវិនាស ឲ្យចម្រើនទូលំទូលាយ ឲ្យចម្រើនពេញលេញ នូវកុសលធម៌ដែលកើតឡើងហើយ ឈ្មោះថា វិរិយារម្ភញ្ញាណ ។

[ ២៣៨ ] បញ្ញាក្នុងការផ្គងរបស់បុគ្គលមានចិត្តមិនរួញរា និងបុគ្គលមានខ្លួនបញ្ជូនទៅហើយ ដើម្បីមិនបង្កើតនូវកាមច្ឆន្ទៈដែលមិនទាន់កើត ឈ្មោះថា វិរិយារម្ភញ្ញាណ បញ្ញាក្នុងការផ្គងរបស់បុគ្គលមានចិត្តមិនរួញរា និងបុគ្គលមានខ្លួនបញ្ជូនទៅហើយ ដើម្បីលះបង់កាមច្ឆន្ទៈដែលកើតឡើងហើយ ឈ្មោះថា វិរិយារម្ភញ្ញាណ បញ្ញាក្នុងការផ្គងរបស់បុគ្គលមានចិត្តមិនរួញរា និងបុគ្គលមានខ្លួនបញ្ជូនទៅហើយ ដើម្បីបង្កើតនូវនេក្ខម្មៈដែលមិនទាន់កើត ឈ្មោះថា វិរិយារម្ភញ្ញាណ បញ្ញាក្នុងការផ្គងរបស់បុគ្គលមានចិត្តមិនរួញរា និងបុគ្គលមានខ្លួន

បញ្ជូនទៅហើយ ដើម្បីតាំងនៅមិនឲ្យវិនាសឲ្យចម្រើន ។បេ។ ឲ្យពេញលេញនូវនេក្ខម្មៈដែលកើតឡើងហើយ ឈ្មោះថា វិរិយារម្ភញ្ញាណ ។បេ។ បញ្ញាក្នុងការផ្គងរបស់បុគ្គលមានចិត្តមិនរួញរា និងបុគ្គលមានខ្លួនបញ្ជូនទៅហើយ ដើម្បីមិនបង្កើតនូវកិលេសទាំងពួង ដែលមិនទាន់កើត ឈ្មោះថា វិរិយារម្ភញ្ញាណ បញ្ញាក្នុងការផ្គង របស់បុគ្គលមានចិត្តមិនរួញរា និងបុគ្គលមានខ្លួនបញ្ជូនទៅហើយ ដើម្បីលះបង់នូវកិលេសទាំងពួង ដែលកើតឡើងហើយ ឈ្មោះថា វិរិ-យារម្ភញ្ញាណ ។បេ។ បញ្ញាក្នុងការផ្គងរបស់បុគ្គលមានចិត្តមិនរួញរា និងបុគ្គលមានខ្លួនបញ្ជូនទៅហើយ ដើម្បីបង្កើតនូវអរហត្តមគ្គដែលមិនទាន់កើត ឈ្មោះថា វិរិយារម្ភញ្ញាណ បញ្ញាក្នុងការផ្គងរបស់បុគ្គលមានចិត្តមិនរួញរា និងបុគ្គលមានខ្លួនបញ្ជូនទៅហើយ ដើម្បីតាំងនៅមិនឲ្យវិនាស ឲ្យចម្រើនទូលំទូលាយ ឲ្យចម្រើនពេញលេញនូវអរហត្តមគ្គដែលកើតហើយ ឈ្មោះថា វិរិយារម្ភញ្ញាណ ឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងការផ្គងរបស់បុគ្គលមានចិត្តមិនរួញរា និងបុគ្គលមានខ្លួនបញ្ជូនទៅហើយ ឈ្មោះថា វិរិយារម្ភញ្ញាណ ។

# អដ្ឋកថា

## វីរិយារម្ភញ្ញាណនិទ្ទេស

[ ២៣៧-២៣៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវីរិយារម្ភញ្ញាណនិទ្ទេសដូចតទៅ បទថា **អនុប្បន្នានំ** បានដល់ មិនទាន់កើតក្នុងអត្តភាពមួយ ឬក្នុងអារម្មណ៍មួយ ។ ព្រោះ ឈ្មោះថា អកុសល ដែលមិនទាន់កើតក្នុងសង្សារ ដែលមិនដឹងខាងដើម និងខាងចុង រមែងមិនមាន តែកុសល ( ដែលមិនធ្លាប់កើត ) មាន ។ បទថា **បាបកានំ** បានដល់ អាក្រក់ ។ បទថា **អកុសលានំ ធម្មានំ** បានដល់ ធម៌ដែលកើតអំពីការមិនឈ្លាស ។ បទថា **អនុប្បាទាយ** បានដល់ ដើម្បីមិនឲ្យកើតឡើង ។ បទថា **ឧប្បន្នានំ** បានដល់ ដែលកើតហើយក្នុងអត្តភាពនេះ ។ បទថា **បហានាយ** បានដល់ ដើម្បីលះបង់ ។ បទថា **អនុប្បន្នានំ កុសលានំ ធម្មានំ** បានដល់ ធម៌ដែលកើតអំពីការឈ្លាសដែលមិនធ្លាប់កើតក្នុងអត្តភាពនេះ ។ បទថា **ឧប្បាទាយ** បានដល់ ដើម្បីឲ្យកើតឡើង ។ បទថា **ឧប្បន្នានំ** បានដល់ ដែលកើតហើយ ក្នុងអត្តភាពនេះ ។ បទថា **ឋិតិយា** បានដល់ ដើម្បីតាំងនៅ ។ បទថា **អសម្មោសាយ** បានដល់ ដើម្បីមិនសាបសូន្យ ។ បទថា **ភិយ្យោភាវាយ** បានដល់ ដើម្បីកើតរឿយៗ ។ បទថា **វេបុល្លាយ** បានដល់ ដើម្បីភាពធំទូលាយ ។ បទថា **ភាវនាយ** បានដល់ ដើម្បីសេចក្តីចម្រើន ។ បទថា **បារិបូរិយា** បានដល់ ដើម្បីភាពពេញលេញ ។

ឥឡូវនេះ ព្រះសារីបុត្ត ដើម្បីសម្តែងដល់កាមច្ឆន្ទៈ ក្នុងអកុសល និង

នេក្ខម្មៈក្នុងកុសល ឲ្យវិសេសក្រៃលែងឡើង ទើបពោលបទថា **អនុប្បន្នស្ស កាមច្ឆន្ទស្ស** ជាដើម ។

ក្នុងបទទាំងនោះ បទថា **កាមច្ឆន្ទោ** បានដល់ កាមរាគៈដែលជាបដិបក្ខចំពោះសមាធិ ។ បទថា **នេក្ខម្មំ** បានដល់ បឋមជ្ឈានសមាធិ ឬបឋមជ្ឈាន ឬកុសលធម៌ទាំងអស់នោះឯងជានេក្ខម្មៈ ។

ឥឡូវនេះ ព្រះសារីបុត្ត ដើម្បីសម្ដែងប្រកបដោយអំណាចនៃកិលេសទាំងពួង និងអរហត្តមគ្គដែលជាបដិបក្ខចំពោះកិលេសទាំងពួង ទើបពោលបទថា **អនុប្បន្នានំ សព្វកិលេសានំ** ជាដើម ។

ក្នុងបទទាំងនោះ បទថា **ឧប្បន្នស្ស អរហត្តមគ្គស្ស ឋិតិយា** ជាដើម គប្បីជ្រាបការប្រកបបទជាដើមថា **ឋិតិយា** ដោយអំណាចនៃឋិតិក្ខណៈ និងភង្គក្ខណៈនៃអរហត្តមគ្គដែលកើតឡើងហើយក្នុងឧប្បាទក្ខណៈ ។ សូម្បីក្នុងអដ្ឋកថានៃវិភង្គ លោកក៏ពោលថា ការប្រព្រឹត្តទៅនៃអរហត្តមគ្គ ឈ្មោះថាឋិតិ គឺការតាំងមាំដូចគ្នា ។ តែអាចារ្យពួកខ្លះពោលថា គប្បីឃើញមគ្គដែលជាចំណែកខាងដើមនៃអរហត្តមគ្គ ។៚

**អដ្ឋកថាវិរិយារម្ភញ្ញាណនិទ្ទេស ចប់**

# សុត្តន្តបិដក

[ ២៣៩ ] បញ្ញា គឺការប្រកាសនូវធម៌ផ្សេងៗ ឈ្មោះថា អត្ថសន្ទស្សនញ្ញាណ តើដូចម្ដេច ។ ឈ្មោះថា ធម៌ផ្សេងៗ បានដល់ ខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ពួកកុសលធម៌ ពួកអកុសលធម៌ ពួកអព្យាកតធម៌ ពួកកាមាវចរធម៌ ពួករូបាវចរធម៌ ពួកអរូបាវចរធម៌ ពួកអបរិយាបន្នធម៌ ។

[ ២៤០ ] ពាក្យថា ប្រកាស គឺប្រកាសនូវរូបថាមិនទៀង ប្រកាសនូវរូបថាជាទុក្ខ ប្រកាសនូវរូបថាមិនមែនខ្លួន ប្រកាសនូវវេទនា សញ្ញា សង្ខារ វិញ្ញាណ ចក្ខុ ។បេ។ នូវជរាមរណៈថាមិនទៀង ប្រកាសនូវជរាមរណៈថាជាទុក្ខ ប្រកាសនូវជរាមរណៈថាមិនមែនខ្លួន ។

[ ២៤១ ] ពាក្យថា អត្ថសន្ទស្សនៈ ( ការឃើញច្បាស់នូវអត្ថ ) គឺ បុគ្គលកាលលះបង់កាមច្ឆន្ទៈ រមែងឃើញច្បាស់នូវអត្ថនៃនេក្ខម្មៈ កាលលះបង់ព្យាបាទ រមែងឃើញច្បាស់នូវអត្ថនៃអព្យាបាទ កាលលះបង់ថីនមិទ្ធៈ រមែងឃើញច្បាស់នូវអត្ថនៃអាលោកសញ្ញា កាលលះបង់ឧទ្ធច្ចៈ រមែងឃើញច្បាស់នូវអត្ថនៃអវិក្ខេបៈ កាលលះបង់វិចិកិច្ឆា រមែងឃើញច្បាស់នូវអត្ថនៃធម្មវវត្ថានៈ កាលលះបង់អវិជ្ជា រមែងឃើញច្បាស់នូវអត្ថនៃញាណ កាលលះបង់អរតិ រមែងឃើញច្បាស់នូវអត្ថនៃបាមុជ្ជ កាលលះបង់នីវរណៈ រមែងឃើញច្បាស់នូវអត្ថនៃបឋមជ្ឈាន ។បេ។ កាលលះបង់កិលេសទាំងពួង រមែងឃើញច្បាស់នូវអត្ថនៃអរហត្តមគ្គ ឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញា គឺការប្រកាសនូវធម៌ផ្សេងៗ ឈ្មោះថា អត្ថសន្ទស្សនញ្ញាណ ។

## អដ្ឋកថា

## អត្ថសន្ទស្សនញ្ញាណនិទ្ទេស

[ ២៣៩-២៤១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអត្ថសន្ទស្សនញ្ញាណនិទ្ទេស ដូចតទៅ បទថា **បញ្ចក្ខន្ធា** ជាដើម មានអត្ថដូចបានពោលហើយ ។ បទថា **បកាសេតិ** បានដល់ បញ្ញាធ្វើឲ្យប្រាកដ អធិប្បាយថា ញុំាងការឃើញដោយញាណចក្ខុឲ្យបរិបូរណ៍ដល់អ្នកស្តាប់ ។ បទថា **នានាធម្មា** លោកពោលដល់ធម៌ទាំងពួងដែលជាលោកិយ និងលោកុត្តរ ។ បើសួរថា ព្រោះហេតុអ្វី ទើបលោកពោលធម៌ជាលោកិយប៉ុណ្ណោះ ក្នុងនិទ្ទេសនៃការប្រកាស ឆ្លើយថា លោកមិនពោលដល់ធម៌ជាលោកុត្តរ ព្រោះប្រារព្ធការប្រកាសដោយភាពជារបស់មិនទៀងជាដើម និងព្រោះធម៌ជាលោកុត្តរ មិនរាប់ចូលក្នុងសម្មសនញ្ញាណ តែការប្រកាសដោយអាការដែលគួរប្រកាសធម៌ទាំងនោះ ជាការប្រកាសនោះឯង ព្រោះលោកសង្គ្រោះធម៌ទាំងនោះ ដោយការចង្អុលបង្ហាញធម៌ផ្សេងៗ និងដោយការចង្អុលបង្ហាញនូវការឃើញច្បាស់អត្ថ ។ បទថា **បជហាន្តោ** អធិប្បាយថា ឲ្យអ្នកស្តាប់លះ ។ បទថា **សន្ទស្សេតិ** បានដល់សម្តែងដល់អ្នកស្តាប់ដោយប្រពៃ ។ តែអាចារ្យពួកខ្លះ ពោលដោយន័យជាដើមថា ព្រះយោគាវចររមែងឃើញច្បាស់នូវអត្ថនៃនេក្ខម្មៈ ព្រោះលះកាមច្ឆន្ទៈបានហើយ ។ គប្បីជ្រាបថា លោកពោលន័យនេះដើម្បីសម្តែងថា កាលអ្នកស្តាប់ធម៌ដ៏ត្រង់ទាំងនោះឯង ធ្វើការលះទោស និងបានចំពោះនូវគុណទេសនាញាណ រមែងដល់លំដាប់កំពូល ។៙

**អដ្ឋកថាអត្ថសន្ទស្សនញ្ញាណនិទ្ទេស ចប់**

# សុត្តន្តបិដក

[ ២៨២ ] បញ្ញាក្នុងការត្រាស់ដឹង នូវការសង្គ្រោះធម៌ទាំងពួង ឲ្យមកតែមួយនូវកិលេស មានភាពផ្សេងៗ និងគុណ មានភាពតែមួយ ឈ្មោះថា ទស្សនវិសុទ្ធិញ្ញាណ តើដូចម្តេច ។ ឈ្មោះថា ធម៌ទាំងពួង បានដល់ ខន្ធ ៥ ។បេ។ ពួកអបរិយាបន្នធម៌ ។

ពាក្យថា សង្គ្រោះឲ្យមកតែមួយ គឺធម៌ទាំងពួង លោកប្រមូលមកតែមួយវិញ ដោយអាការ ១២ គឺដោយអត្ថថា ពិត ១ ដោយអត្ថថា មិនមែនខ្លួន ១ ដោយអត្ថថា ទៀង ១ ដោយអត្ថថា ចាក់ធ្លុះ ១ ដោយអត្ថថា ដឹងច្បាស់ ១ ដោយអត្ថថា កំណត់ដឹង ១ ដោយអត្ថថា ទ្រទ្រង់ ១ ដោយអត្ថថា ជាធាតុ ១ ដោយអត្ថថា ដឹង ១ ដោយអត្ថថា ធ្វើឲ្យជាក់ច្បាស់ ១ ដោយអត្ថថា ពាល់ត្រូវ ១ ដោយអត្ថថា ត្រាស់ដឹង ១ នេះធម៌ទាំងពួង លោកប្រមូលមកតែមួយ ដោយអាការ ១២ ។

ពាក្យថា កិលេសមានភាពផ្សេងៗ និងគុណភាពមានតែមួយ គឺកាមច្ឆន្ទៈ ឈ្មោះថា ភាពផ្សេងៗ នេក្ខម្មៈ ឈ្មោះថា ភាពតែមួយ ។បេ។ កិលេសទាំងពួង ឈ្មោះថា ភាពផ្សេងៗ អរហត្តមគ្គ ឈ្មោះថា ភាពតែមួយ ។

ពាក្យថា ការត្រាស់ដឹង គឺត្រាស់ដឹងទុក្ខសច្ច ជាបរិញ្ញាបដិវេធ ត្រាស់ដឹងសមុទយសច្ច ជាបហានប្បដិវេធ ត្រាស់ដឹងនិរោធសច្ច ជាសច្ឆិកិរិយា-បដិវេធ ត្រាស់ដឹងមគ្គសច្ច ជាភាវនាបដិវេធ ។

ពាក្យថា ទស្សនវិសុទ្ធិ គឺទស្សនៈ ( ការឃើញ ) រមែងស្អាតក្នុងខណៈនៃសោតាបត្តិមគ្គ ទស្សនៈស្អាតវិសេសហើយ ក្នុងខណៈនៃសោតាបត្តិផល

ទស្សនៈកំពុងស្អាតក្នុងខណៈនៃសកទាគាមិមគ្គ ទស្សនៈស្អាតវិសេសហើយក្នុងខណៈនៃសកទាគាមិផល ទស្សនៈកំពុងស្អាតក្នុងខណៈនៃអនាគាមិមគ្គ ទស្សនៈស្អាតវិសេសហើយ ក្នុងខណៈនៃអនាគាមិផល ទស្សនៈកំពុងស្អាតក្នុងខណៈនៃអរហត្តមគ្គ ទស្សនៈស្អាតវិសេសហើយក្នុងខណៈនៃអរហត្តផល ឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងការត្រាស់ដឹងនូវការសង្គ្រោះនូវធម៌ទាំងពួងឲ្យមកតែមួយ នូវកិលេសមានភាពផ្សេងៗ និងគុណមានភាពតែមួយ ឈ្មោះថា ទស្សនវិសុទ្ធិញ្ញាណ ។

# អដ្ឋកថា
# ទស្សនវិសុទ្ធិញ្ញាណនិទ្ទេស

[ ២៤២ ] គប្បីជ្រាបវិនិច្ឆ័យ ក្នុងទស្សនវិសុទ្ធិញ្ញាណនិទ្ទេសដូចតទៅ បទថា **សព្វេ ធម្មា ឯកសង្គហិតា** បានដល់ ធម៌ដែលជាសង្ខតៈ និងអសង្ខតៈទាំងអស់ លោកសង្គ្រោះ គឺកំណត់ដោយពួកមួយ ។ បទថា **តថដ្ឋេន** បានដល់ ដោយសភាពដែលពិត អធិប្បាយថា ដោយមាននៅតាមសភាពរៀងៗខ្លួន ។ បទថា **អនត្តដ្ឋេន** បានដល់ ដោយសភាពវៀរចាកតួខ្លួន ពោល គឺអ្នកធ្វើ និងអ្នកទទួល ។ បទថា **សច្ចដ្ឋេន** បានដល់ ដោយសភាពដែលមិនខុសអំពីសេចក្ដីពិត អធិប្បាយថា ដោយភាពមិនជាយ៉ាងដទៃ ចាកសភាពរបស់ខ្លួន ។ បទថា **បដិវេធដ្ឋេន** បានដល់ ដោយសភាពដែលគួរចាក់ធ្លុះដោយញាណតាមសេចក្ដីពិត ។ ក្នុងបទនេះ គប្បីជ្រាបការចាក់ធ្លុះដោយការមិនវង្វេង និងដោយអារម្មណ៍ដោយញាណដែលជាលោកុត្តរ ។ បទថា **អភិជាននដ្ឋេន** បានដល់ ដោយសភាពនៃធម៌នោះៗ ដែលគួរដឹងក្រៃលែងតាមសេចក្ដីពិត ទាំងដោយអារម្មណ៍ ដោយញាណដែលជាលោកិយ ទាំងដោយការមិនវង្វេង និងដោយអារម្មណ៍ដោយញាណដែលជាលោកុត្តរ ។ ដូចព្រះមានព្រះភាគ ទ្រង់ត្រាស់ ( ក្នុងសំយុត្តនិកាយ សឡាយតនវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយរបស់ទាំងអស់ បុគ្គលត្រូវដឹងជាក់ ដូច្នេះ ។ បទថា **បរិជាននដ្ឋេន** បានដល់ ដោយសភាពដែលគួរកំណត់ដឹងធម៌ទាំងឡាយ ដែលដឹងក្រៃលែងហើយ ដោយសភាវៈដោយញាណដែលជាលោកិយ និងលោកុត្តរ ដោយន័យដែលពោលហើយនោះឯង ដោយការមិនទៀងជាដើម និងដោយការចេញទៅជាដើម ដូច

ព្រះតម្រាស់ ( ក្នុងសំយុត្តនិកាយ សឡាយតនវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ របស់ទាំងអស់ បុគ្គលត្រូវកំណត់ដឹង ដូច្នេះ ។ បទថា **ធម្មដ្ឋេន** បានដល់ ដោយសភាវៈដែលជាធម៌ មានការទ្រទ្រង់នូវសភាវៈជាដើម ។ បទថា **ធាតដ្ឋេន** បានដល់ ដោយសភាវៈដែលជាធាតុ មានការមិនមានជីវៈជាដើម ។ បទថា **ញាតដ្ឋេន** បានដល់ ដោយសភាវៈដែលអាចដឹងដោយញាណដែលជាលោកិយ និងលោកុត្តរ ។ សភាវៈដែលអាចដឹងក្នុងពាក្យនេះ គប្បីជ្រាបថា សភាពដែលអាចដឹង ដូចពាក្យដែលលោកពោលថា អារម្មណ៍ដែលឃើញ ដែលបានឮ ដែលបានប៉ះពាល់ ដែលដឹងច្បាស់ ជារូប ដោយអត្ថថា អាចឃើញជាដើម ។ បទថា **សច្ឆិកិរិយដ្ឋេន** បានដល់ ដោយសភាពដែលគួរធ្វើឲ្យប្រចក្សដោយអារម្មណ៍ ។ បទថា **ផុស្សនដ្ឋេន** បានដល់ ដោយសភាពដែលគួរពាល់ត្រូវរឿយៗ ដោយអារម្មណ៍នៃសភាវៈដែលធ្វើឲ្យប្រចក្សហើយ ។ បទថា **អភិសមយដ្ឋេន** បានដល់ ដោយសភាពដែលគួរត្រាស់ដឹងដោយញាណដែលជាលោកិយ ។ សូម្បីលោកពោលញាណនីមួយៗ ថា បញ្ញាក្នុងសភាវៈដែលពិត ជាសច្ចវិវដ្ដញ្ញាណ បញ្ញាដែលគួរដឹងក្រៃលែង ជាញាតដ្ឋញ្ញាណ បញ្ញាដែលធ្វើឲ្យជាក់ច្បាស់ជាផស្សនដ្ឋញ្ញាណ ក្នុងអដ្ឋកថាពោលអភិសមយសព្ទថា មានការចាក់ធ្លុះជាអត្ថ ក្នុងគាថាព័ន្ធថា

អភិសមយសព្ទ រមែងប្រាកដក្នុងអត្ថថា ទីប្រជុំ ខណៈ កាល
ពួក ហេតុ ទិដ្ឋិ ការបានចំពោះ ការលះ និងការចាក់ធ្លុះ ។

ទោះបីយ៉ាងនោះ ក្នុងទីនេះ គប្បីជ្រាបការផ្សេងគ្នានៃធម៌ទាំងនោះ ដោយ

អត្ថតាមដែលពោលហើយ ព្រោះថា ក្នុងអដ្ឋកថានោះឯង លោកពោលដល់ការត្រាស់ដឹងធម៌នោះ ដោយអំណាចញាណដែលជាលោកិយ ។

បទថា **កាមច្ឆន្ទោ នានត្តំ** សេចក្តីថា កាមច្ឆន្ទៈ ជាសភាវៈផ្សេងៗ គ្នា ព្រោះមានការរាយមាយ និងព្រោះមានអារម្មណ៍ផ្សេងៗ ។ គប្បីជ្រាបកិលេសទាំងអស់ ដោយប្រការដូច្នេះ ។

បទថា **នេក្ខម្មំ ឯកត្តំ** សេចក្តីថា នេក្ខម្មៈមានសភាពតែមួយ ដោយមានចិត្តជាឯកគ្គតា និងដោយមិនមានការរាយមាយនៃអារម្មណ៍ផ្សេងៗ ។ គប្បីជ្រាបកុសលទាំងពួង ដោយប្រការដូច្នេះ ។

ក្នុងទីនេះ គប្បីជ្រាបការផ្សេងគ្នានៃអកុសលទាំងឡាយ មានព្យាបាទជាដើម ដែលលោកសង្ខេបដោយបេយ្យាល ដោយអត្ថតាមដែលពោលហើយ ។ ម្យ៉ាងទៀត គប្បីជ្រាបការផ្សេងគ្នានៃធម៌ថ្នាក់ទាប មានវិតក្កវិចារជាដើមដោយសភាពគ្រោតគ្រាតជាងធម៌ថ្នាក់ខ្ពស់ៗ ។ ព្រោះការចាក់ធ្លុះធម៌ដែលសង្គ្រោះជាសភាពតែមួយដែលមានការផ្សេងគ្នា និងដែលមានភាពតែមួយ រមែងសម្រេចដោយការចាក់ធ្លុះសច្ចៈក្នុងខណៈនៃមគ្គ ហេតុនោះ ទើបព្រះសារីបុត្តត្ថេរលើកពាក្យថា **បដិវេធ** ឡើងហើយ សម្តែងដល់ការត្រាស់ដឹងសច្ចៈ ។

បទថា **បរិញ្ញា បដិវេធំ បដិវិជ្ឈតិ** បានដល់ ត្រាស់ដឹងដោយបរិញ្ញាភិសមយ ។ ក្នុងបទដ៏សេស ក៏មានន័យនេះ ។ ពិតហើយ ក្នុងវេលាត្រាស់ដឹងសច្ចៈ មគ្គញាណមានកិច្ច ៤ យ៉ាង ក្នុងខណៈតែមួយ គឺការកំណត់ដឹង ការលះ ការធ្វើឲ្យជាក់ច្បាស់ ការចម្រើន ដូចទូកធ្វើកិច្ច ៤ យ៉ាងក្នុងខណៈតែមួយមិនមុនមិនក្រោយ គឺលះត្រើយអាយ ១ កាត់ក្រសែទឹក ១ នាំទំនិញ

ទៅ ១ ដល់ត្រើយនាយ ១ យ៉ាងណា មគ្គញាណ រមែងត្រាស់ដឹងសច្ចៈ ៤ ក្នុងខណៈតែមួយ មិនមុនមិនក្រោយ គឺត្រាស់ដឹងទុក្ខដោយការកំណត់ដឹង ១ ត្រាស់ដឹងសមុទយៈដោយការលះ ១ ត្រាស់ដឹងមគ្គដោយការចម្រើន ១ ត្រាស់ដឹងនិរោធដោយការធ្វើឲ្យជាក់ច្បាស់ ១ ក៏យ៉ាងនោះ ។ លោកអធិប្បាយដូចម្តេច លោកអធិប្បាយថា មគ្គញាណ ធ្វើនិរោធឲ្យជាអារម្មណ៍ រមែងសម្រេច រមែងឃើញ រមែងចាក់ធ្លុះសច្ចៈទាំង ៤ ដោយអំណាចកិច្ច ដូចទូកលះត្រើយអាយយ៉ាងណា មគ្គញាណ ក៏កំណត់ដឹងទុក្ខយ៉ាងនោះ ។ ទូកកាត់ក្រសែទឹកយ៉ាងណា មគ្គញាណក៏លះសមុទយៈយ៉ាងនោះ ។ ទូកនាំទំនិញទៅយ៉ាងណា មគ្គញាណក៏ចម្រើនមគ្គដោយជាសហជាតបច្ច័យជាដើមក៏យ៉ាងនោះ ។ ទូកដល់ត្រើយនាយ យ៉ាងណា មគ្គញាណ ក៏ធ្វើឲ្យជាក់ច្បាស់នូវនិរោធដែលជាត្រើយនាយ ក៏យ៉ាងនោះ ហេតុនោះ គប្បីជ្រាបឧបមាឧបមេយ្យ ដោយប្រការដូច្នេះ ។

បទថា **ទស្សនំ វិសុជ្ឈតិ** បានដល់ ញាណទស្សនៈរមែងដល់ការបរិសុទ្ធ ដោយការលះផងឌីត គឺកិលេសដែលមគ្គនោះៗ ប្រហារ ។ បទថា **ទស្សនំ វិសុទ្ធំ** បានដល់ ក្នុងខណៈនៃផលនោះៗ កើតឡើង ញាណទស្សនៈ រមែងដល់នូវការបរិសុទ្ធហើយ ដោយដល់នូវការសម្រេចកិច្ចនៃមគ្គញាណនោះៗ ។ លោកពោលមគ្គញាណ និងផលញាណក្នុងទីបំផុត ព្រោះបញ្ញាក្នុងការចាក់ធ្លុះធម៌ទាំងពួង សង្គ្រោះជាពួកតែមួយ ធម៌ទាំងឡាយផ្សេងគ្នា និងធម៌ទាំងឡាយតែមួយ សម្រេចហើយដោយមគ្គញាណ និងផលញាណ ។៤៥៕

**អដ្ឋកថាទស្សនវិសុទ្ធិញាណនិទ្ទេស ចប់**

# សុត្តន្តបិដក

[ ២៨៣ ] បញ្ញាព្រោះការដឹងច្បាស់ ឈ្មោះថា ខន្តិញ្ញាណ តើដូចម្តេច ។ បុគ្គលដឹងច្បាស់រូបថាមិនទៀង ដឹងច្បាស់រូបថាជាទុក្ខ ដឹងច្បាស់រូបថាជាអនត្តា រូបណាៗ ដែលបុគ្គលដឹងច្បាស់ហើយ រូបនោះៗ គួរ ( ជាយ៉ាងនោះមែន ) ហេតុនោះ បញ្ញា ព្រោះការដឹងច្បាស់ ឈ្មោះថា ខន្តិញ្ញាណ បុគ្គលដឹងច្បាស់នូវវេទនា សញ្ញា សង្ខារ វិញ្ញាណ ចក្ខុ ។បេ។ ជរាមរណៈថាមិនទៀង ដឹងច្បាស់ជរាមរណៈថាជាទុក្ខ ដឹងច្បាស់ជរាមរណៈថាជាអនត្តា ជរាមរណៈណាៗ ដែលបុគ្គលដឹងច្បាស់ ជរាមរណៈនោះៗ គួរ ( ជាយ៉ាងនោះមែន ) ហេតុនោះ បញ្ញា ព្រោះការដឹងច្បាស់ ឈ្មោះថា ខន្តិញ្ញាណ ឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាព្រោះការដឹងច្បាស់ ឈ្មោះថា ខន្តិញ្ញាណ ។

[ ២៨៤ ] បញ្ញាព្រោះការពាល់ត្រូវ ឈ្មោះថា បរិយោគាហនញ្ញាណ តើដូចម្តេច ។ បុគ្គលពាល់ត្រូវនូវរូប ថាមិនទៀង ពាល់ត្រូវនូវរូប ថាជាទុក្ខ ពាល់ត្រូវនូវរូប ថាជាអនត្តា ពាល់ត្រូវនូវរូបណាៗ ស្ទង់នូវរូបនោះៗ ( ឃើញថាជាយ៉ាងនោះមែន ) ហេតុនោះ បញ្ញា ព្រោះសេចក្តីពាល់ត្រូវ ឈ្មោះថា បរិយោគាហនញ្ញាណ បុគ្គលពាល់ត្រូវនូវវេទនា សញ្ញា សង្ខារ វិញ្ញាណ

ចក្ខុ ។បេ។ ជរាមរណៈថាមិនទៀង ថាជាទុក្ខ ថាជាអនត្តា ពាល់ត្រូវនូវជរា-មរណៈណាៗ សួង់នូវជរាមរណៈនោះៗ ( ឃើញថាជាយ៉ាងនោះមែន ) ហេតុនោះ បញ្ញា ព្រោះការពាល់ត្រូវ ឈ្មោះថា បរិយោគាហនញ្ញាណ ឈ្មោះថាញាណ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញា ព្រោះការពាល់ត្រូវ ឈ្មោះថា បរិយោគាហនញ្ញាណ ។

# អដ្ឋកថា

## ខន្តិញ្ញាណបរិយោគាហណញ្ញាណនិទ្ទេស

[ ២៤៣-២៤៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងខន្តិញ្ញាណបរិយោគាហណញ្ញាណនិទ្ទេសដូចតទៅនេះ បទថា **រូបំ អនិច្ចតោ វិទិតំ** បានដល់ បញ្ញាដឹងថា រូបជារបស់មិនទៀង ដោយអនិច្ចានុបស្សនា ។ បទថា **រូបំ ទុក្ខតោ វិទិតំ** បានដល់ បញ្ញាដឹងថា រូបជាទុក្ខដោយទុក្ខានុបស្សនា ។ បទថា **រូបំ អនត្តតោ វិទិតំ** បានដល់ បញ្ញាដឹងថា រូបជាអនត្តាដោយអនត្តានុបស្សនា ។ បទថា **យំ យំ វិទិតំ តំ តំ ខមតិ** បានដល់ ដឹងច្បាស់រូបណាៗ ដោយភាពជារបស់មិនទៀងជាដើមរមែងទទួលបាន គឺពេញចិត្តក្នុងរូបនោះៗ ដោយភាពជារបស់មិនទៀងជាដើម ។ លោករចនាក្នុងគម្ពីរខ្លះ ធ្វើជាចំណែកៗ ថា បញ្ញាដឹងច្បាស់រូប ដោយភាពជារបស់មិនទៀង ដឹងច្បាស់រូបណាៗ រមែងទទួលបាននូវរូបនោះៗ ។ គប្បីផ្លាស់លិង្គ និងវចនៈ ហើយប្រកបដោយពាក្យជាដើមថា **វេទនា សញ្ញា សង្ខារា អនិច្ចតោ វិទិតា** បញ្ញាដឹងច្បាស់វេទនា សញ្ញា សង្ខារ ដោយភាពជារបស់មិនទៀង ។

បទថា **ផុសតិ** បានដល់ រមែងពាល់ត្រូវ គឺរមែងផ្សាយទៅដោយការពាល់ត្រូវដោយវិបស្សនាញាណ ។ បទថា **បរិយោគហតិ** បានដល់ រមែងចូលទៅដោយវិបស្សនាញាណ ។ បាឋៈថា **បរិយោគាហតិ** ដូច្នេះក៏មាន ។

**អដ្ឋកថាខន្តិញ្ញាណបរិយោគាហណញ្ញាណនិទ្ទេស ចប់**

# សុត្តន្តបិដក

[ ២៤៥ ] បញ្ញាក្នុងការប្រមូល ឈ្មោះថា បទេសវិហារញ្ញាណ តើដូចម្តេច ។ វេទនាព្រោះមិច្ឆាទិដ្ឋិជាបច្ច័យក៏មាន វេទនាព្រោះការរម្ងាប់នូវមិច្ឆាទិដ្ឋិជាបច្ច័យក៏មាន វេទនាព្រោះសម្មាទិដ្ឋិជាបច្ច័យក៏មាន វេទនាព្រោះការរម្ងាប់នូវសម្មាទិដ្ឋិជាបច្ច័យក៏មាន វេទនាព្រោះមិច្ឆាសង្កប្បជាបច្ច័យក៏មាន វេទនាព្រោះការរម្ងាប់នូវមិច្ឆាសង្កប្បជាបច្ច័យក៏មាន វេទនាព្រោះសម្មាសង្កប្បជាបច្ច័យក៏មាន វេទនាព្រោះការរម្ងាប់នូវសម្មាសង្កប្បជាបច្ច័យក៏មាន ។បេ។ វេទនាព្រោះមិច្ឆាវិមុត្តិជាបច្ច័យក៏មាន វេទនាព្រោះការរម្ងាប់នូវមិច្ឆាវិមុត្តិជាបច្ច័យក៏មាន វេទនាព្រោះសម្មាវិមុត្តិជាបច្ច័យក៏មាន វេទនាព្រោះរម្ងាប់នូវសម្មាវិមុត្តិជាបច្ច័យក៏មាន វេទនាព្រោះឆន្ទៈជាបច្ច័យក៏មាន វេទនាព្រោះការរម្ងាប់នូវឆន្ទៈជាបច្ច័យក៏មាន វេទនាព្រោះវិតក្កជាបច្ច័យក៏មាន វេទនាព្រោះការរម្ងាប់នូវវិតក្កជាបច្ច័យក៏មាន វេទនាព្រោះសញ្ញាជាបច្ច័យក៏មាន វេទនាព្រោះការរម្ងាប់នូវសញ្ញាជាបច្ច័យក៏មាន ឆន្ទៈមិនស្ងប់ វិតក្កមិនស្ងប់ សញ្ញាមិនស្ងប់ វេទនាព្រោះឆន្ទៈជាដើម មិនស្ងប់នោះជាបច្ច័យក៏មាន ឆន្ទៈស្ងប់ តែវិតក្កមិនស្ងប់ សញ្ញាមិនស្ងប់ វេទនាព្រោះវិតក្ក និងសញ្ញាមិនស្ងប់នោះជាបច្ច័យក៏មាន ឆន្ទៈស្ងប់ វិតក្កស្ងប់ តែសញ្ញាមិនស្ងប់ វេទនាព្រោះសញ្ញាមិនស្ងប់នោះជាបច្ច័យក៏មាន ឆន្ទៈស្ងប់ វិតក្កស្ងប់ សញ្ញាស្ងប់ វេទនាមិន

មានព្រោះឆន្ទៈជាដើមស្ងប់នោះជាបច្ច័យក៏មាន សេចក្តីព្យាយាមដើម្បីសម្រេចអរហត្តដែលមិនទាន់សម្រេចនាកាលឋានៈ គឺអរហត្តនោះសម្រេចហើយ វេទនាព្រោះបច្ច័យនៃព្រះអរហត្តនោះក៏មាន ឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ហេតុនោះលោកពោលថា បញ្ញាក្នុងការប្រមូល ឈ្មោះថា បទេសវិហារញ្ញាណ ។

# អដ្ឋកថា
# បទេសវិហារញ្ញាណនិទ្ទេស

[ ២៨៥ ] គប្បីជ្រាបវិនិច្ឆ័យ ក្នុងបទេសវិហារញ្ញាណនិទ្ទេសដូចតទៅនេះថា ព្រះសារីបុត្ត កាលនឹងសម្តែងដល់អាការដែលគួរពិចារណាញាណចំណែកខ្លះ ដែលលើកឡើងក្នុងមាតិកា ទើបពោលបទថា **មិច្ឆាទិដ្ឋិបច្ចយាបិវេទយិតំ** ជាដើម ។

ក្នុងបទទាំងនោះ បទថា **មិច្ឆាទិដ្ឋិប្បច្ចយា** សេចក្តីថា វេទនាសម្បយុត្តដោយទិដ្ឋិក្តី វេទនាជាកុសល អកុសលក្តី វេទនាជាវិបាកក្តី ដែលកើតឡើងធ្វើទិដ្ឋិឲ្យជាឧបនិស្ស័យ រមែងគួរ ។ ក្នុងវេទនាទាំងនោះ វេទនាដែលសម្បយុត្តដោយមិច្ឆាទិដ្ឋិ ជាអកុសលប៉ុណ្ណោះ ។ តែវេទនាជាកុសលក្តី អកុសលក្តី រមែងកើតឡើងព្រោះអាស្រ័យទិដ្ឋិ ។ ពិតហើយ ពួកបុគ្គលមិច្ឆាទិដ្ឋិឲ្យបបរនិងកត្តជាដើម ក្នុងថ្ងៃនៃបក្ខ ព្រោះអាស្រ័យទិដ្ឋិ រមែងតាំងទំនៀមសម្រាប់មនុស្សខ្វាក់ និងមនុស្សមានរោគឃ្លង់ជាដើម រមែងឲ្យសាងសាលាធទាន ក្នុងផ្លូវបែកជា ៤ ឲ្យជីកស្រះបោក្ខរណី ឲ្យដាំសួនផ្កាឈើ សួនផ្លែឈើ សង់ស្ពានក្នុងទីលំបាកព្រោះទឹក ពង្រាបដីដែលមិនស្មើឲ្យស្មើ ។ វេទនាដែលជាកុសលរមែងកើតដល់ពួកបុគ្គលមិច្ឆាទិដ្ឋិទាំងនោះ ដោយប្រការដូច្នេះ ។ តែព្រោះអាស្រ័យមិច្ឆាទិដ្ឋិ រមែងជេរប្រទេចពួកសម្មាទិដ្ឋិ សម្លាប់ និងចងជាដើម សម្លាប់សត្វបួងសួងដល់ទេវតា ។ វេទនាជាអកុសល រមែងកើតដល់ពួកបុគ្គលមិច្ឆាទិដ្ឋិទាំងនោះ ដោយប្រការដូច្នេះ ។ ចំណែកវេទនាជាវិបាក រមែង

មានដល់សត្វដែលទៅក្នុងភពដទៃ ។

ម្យ៉ាងទៀត មិច្ឆាទិដ្ឋិនោះ រមែងជាបច្ច័យដល់វេទនាដែលកើតរួមគ្នា ដោយអំណាចសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ។ មិច្ឆាទិដ្ឋិដែលរលត់ទៅមួយរំពេចនោះ រមែងជាបច្ច័យដល់វេទនា ដែលសម្បយុត្តដោយមិច្ឆាទិដ្ឋិ ក្នុងបច្ចុប្បន្ន ដោយអំណាចអនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ ឧបនិស្សយប្បច្ច័យ អាសេវនប្បច្ច័យ នត្ថិប្បច្ច័យ និងវិគតប្បច្ច័យ មិច្ឆាទិដ្ឋិរមែងជាបច្ច័យដល់វេទនាសហគតៈដោយលោភៈរបស់បុគ្គលដែលធ្វើមិច្ឆាទិដ្ឋិឲ្យធ្ងន់ហើយត្រេកអរ ដោយអារម្មណាធិបតិប្បច្ច័យ និងអារម្មណូបនិស្សយប្បច្ច័យ មិច្ឆាទិដ្ឋិរមែងជាបច្ច័យដល់វេទនាជាអកុសលទាំងពួង របស់បុគ្គលដែលធ្វើមិច្ឆាទិដ្ឋិឲ្យត្រឹមតែជាអារម្មណ៍ដោយអកុសលទាំងពួង និងជាបច្ច័យដល់វេទនាដែលជាកុសល និងអព្យាកតៈ របស់បុគ្គលដែលពិចារណាឃើញច្បាស់មិច្ឆាទិដ្ឋិ ដោយអារម្មណប្បច្ច័យប៉ុណ្ណោះ មិច្ឆាទិដ្ឋិរមែងជាបច្ច័យដល់វេទនាជាកុសល និងអកុសលដែលកើតឡើងដោយមិច្ឆាទិដ្ឋិជាបច្ច័យ និងដល់វេទនាជាវិបាកក្នុងភពដទៃដោយឧបនិស្សយប្បច្ច័យ ។

បទថា **មិច្ឆាទិដ្ឋិវូបសមប្បច្ចយា** សេចក្តីថា សម្មាទិដ្ឋិ ឈ្មោះថា ការស្ងប់មិច្ឆាទិដ្ឋិ ព្រោះហេតុនោះ ការសោយវេទនាណាដែលលោកពោលព្រោះសម្មាទិដ្ឋិជាបច្ច័យ ការសោយវេទនានោះឯង គប្បីជ្រាបថា ព្រោះការស្ងប់មិច្ឆាទិដ្ឋិជាបច្ច័យ ចំណែកអាចារ្យពួកខ្លះពោលថា ឈ្មោះថា ការស្ងប់មិច្ឆាទិដ្ឋិ

រមែងមានក្នុងខណៈនៃវិបស្សនា និងក្នុងខណៈនៃសោតាបត្តិមគ្គ ។

ក្នុងបទថា **សម្មាទិដ្ឋិប្បច្ចយាបិ វេទយិតំ** នេះ មានអធិប្បាយដូចតទៅនេះថា វេទនាសម្បយុត្តដោយសម្មាទិដ្ឋិក្តី វេទនាជាកុសល អកុសលក្តី វេទនាជាវិបាកក្តី កើតឡើងធ្វើសម្មាទិដ្ឋិឲ្យជាឧបនិស្ស័យ រមែងគួរ ។ ក្នុងវេទនាទាំងនោះ វេទនាសម្បយុត្តដោយសម្មាទិដ្ឋិជាកុសលប៉ុណ្ណោះ ។ ម្យ៉ាងទៀត ពួកសម្មាទិដ្ឋិអាស្រ័យសម្មាទិដ្ឋិ ធ្វើបុណ្យយ៉ាងនេះ គឺការបូជាព្រះពុទ្ធ ចាត់ចែងប្រទីប និងផ្កា ស្តាប់ធម៌ក្នុងទីប្រជុំធំ សាងព្រះចេតិយក្នុងទិសដែលមិនទាន់បានសាងជាដើម វេទនាដែលជាកុសល រមែងកើតដល់ជនសម្មាទិដ្ឋិទាំងនោះ ដោយប្រការដូច្នេះ ។ ជនសម្មាទិដ្ឋិទាំងនោះ អាស្រ័យសម្មាទិដ្ឋិនោះឯង រមែងជេរប្រទេចពួកមិច្ឆាទិដ្ឋិ លើកខ្លួនសង្កត់សង្កិនអ្នកដទៃ អកុសលវេទនារមែងកើតដល់ជនសម្មាទិដ្ឋិទាំងនោះ ដោយប្រការដូច្នេះ ។ ចំណែកវិបាក-វេទនា រមែងមានដល់អ្នកដែលទៅក្នុងភពដទៃ ។

ម្យ៉ាងទៀត សម្មាទិដ្ឋិនោះ រមែងជាបច្ច័យដល់វេទនាដែលកើតរួមគ្នាដែលរលត់ទៅភ្លាមៗ នោះ និងដែលជាបច្ចុប្បន្នដោយបច្ច័យដូចពោលហើយក្នុងមិច្ឆា-ទិដ្ឋិនោះឯង លោកិយសម្មាទិដ្ឋិ រមែងជាបច្ច័យដល់វេទនា ដែលសម្បយុត្តដោយបច្ចវេក្ខណៈ ដែលសម្បយុត្តដោយវិបស្សនា និងដែលសម្បយុត្តដោយការពេញចិត្តដោយអារម្មណាប្បច្ច័យ លោកិយសម្មាទិដ្ឋិ រមែងជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ដោយន័យដែលពោលហើយក្នុងមិច្ឆាទិដ្ឋិនោះឯង សម្មាទិដ្ឋិដែលជាមគ្គផល រមែងជាបច្ច័យដល់វេទនា ដែលសម្បយុត្តដោយបច្ចវេក្ខ-

*ណញ្ញាណដោយអារម្មណាធិបតិប្បច្ច័យ និងអារម្មណូបនិស្សយប្បច្ច័យ ។*

*បទថា* **សម្មាទិដ្ឋិវូបសមប្បច្ចយាបិ វេទយិតំ** *សេចក្តីថា មិច្ឆាទិដ្ឋិ ឈ្មោះថា ការស្ងប់សម្មាទិដ្ឋិ ព្រោះហេតុនោះ ការសោយវេទនាណា ដែលលោកពោលព្រោះមិច្ឆាទិដ្ឋិជាបច្ច័យ ការសោយវេទនានោះឯង គប្បីជ្រាបថា ព្រោះការស្ងប់សម្មាទិដ្ឋិជាបច្ច័យ ។ ក្នុងបទថា* **មិច្ឆាសង្កប្បប្បច្ចយា មិច្ឆាសង្កប្ប-វូបសមប្បច្ចយា** *ជាដើម ក៏មានន័យនេះដូចគ្នា ។ ពិតហើយ លោកពោលថា ព្រោះការស្ងប់ធម៌ណាៗ ជាបច្ច័យ លោកបំណងយកវេទនានោះៗ ព្រោះមានធម៌ជាបដិបក្ខចំពោះធម៌នោះៗ ជាបច្ច័យ ។*

*ម្យ៉ាងទៀត គប្បីជ្រាបសេចក្តីក្នុងមិច្ឆាញាណជាដើមដូចតទៅនេះថា ការគិតដើម្បីរកឧបាយក្នុងការធ្វើបាប ឈ្មោះថា មិច្ឆាញាណ ។ ម្យ៉ាងវិញទៀត មិច្ឆាញាណ គឺញាណក្នុងការពិចារណាខុស ។ ញាណដែលជាកុសល និងអព្យាក្រឹតដ៏សេស វៀរវិបស្សនាសម្មាទិដ្ឋិ និងលោកុត្តរសម្មាទិដ្ឋិ ឈ្មោះថា សម្មាញាណ ។ ការបង្អោនទៅក្នុងបាប ឈ្មោះថា មិច្ឆាវិមុត្តិ ។ ម្យ៉ាងទៀត ការផុតដែលមិនពិត ការផុតដែលមិននាំចេញទៅ អ្នកមិនរួចផុតក៏សម្គាល់ថារួចផុត ( ឈ្មោះថា មិច្ឆាវិមុត្តិ ) ។ ការបង្អោនទៅក្នុងកល្យាណធម៌ និងផលវិមុត្តិ ឈ្មោះថា សម្មាវិមុត្តិ ។ សម្មាទិដ្ឋិជាដើម មានអត្ថដូចបានពោលហើយ ក្នុងខាងដើម ។*

*ចំណែកក្នុងបទថា* **ឆន្ទប្បច្ចយាបិ** *ជាដើម គប្បីជ្រាបដូចតទៅនេះថា សេចក្តីលោក ឈ្មោះថា ឆន្ទៈ គប្បីជ្រាបវេទនា ដែលសម្បយុត្តដោយចិត្តដែល*

សហគតៈដោយលោភៈ ៨ ព្រោះមានឆន្ទៈជាបច្ច័យ ។

ព្រោះការស្ងប់ឆន្ទៈជាបច្ច័យ ទើបវេទនាក្នុងបឋមជ្ឈានមាន ។ ព្រោះវិតក្កជាបច្ច័យ ទើបវេទនាក្នុងបឋមជ្ឈានមាន ព្រោះការស្ងប់វិតក្កជាបច្ច័យ ទើបវេទនាក្នុងទុតិយជ្ឈានមាន ព្រោះសញ្ញាជាបច្ច័យ ទើបវេទនាក្នុងសញ្ញា-សមាបត្តិ ៦ ដ៏សេស វៀរបឋមជ្ឈានមាន ។ ព្រោះការស្ងប់សញ្ញាជាបច្ច័យ ទើបវេទនាក្នុងនេវសញ្ញានាសញ្ញាយតនៈមាន ។

ក្នុងបទថា **ឆន្ទោ ច អវូបសន្តោ ហោតិ** ជាដើម សេចក្ដីថា បើឆន្ទៈ វិតក្ក និងសញ្ញាជាធម៌មិនស្ងប់ ។ បទថា **តប្បច្ចយា** បានដល់ ការមិនស្ងប់ ឆន្ទៈ វិតក្ក និងសញ្ញានោះឯង ជាបច្ច័យ ឈ្មោះថា **តប្បច្ចយា** ព្រោះឆន្ទៈ វិតក្ក និងសញ្ញាដែលជាធម៌មិនស្ងប់នោះជាបច្ច័យ ។ អធិប្បាយថា ព្រោះការមិនស្ងប់ឆន្ទៈ វិតក្ក និងសញ្ញាជាបច្ច័យ ទើបវេទនាមាន ។ វេទនានោះជាវេទនាសម្បយុត្តដោយចិត្ត សហគតៈដោយលោភៈ ៨ ។ ប្រសិនបើឆន្ទៈជាធម៌ស្ងប់ វិតក្ក និងសញ្ញាក៏ជាធម៌មិនស្ងប់ ។

បទថា **តប្បច្ចយា** បានដល់ ការស្ងប់ឆន្ទៈនោះ ឯការមិនស្ងប់វិតក្ក និងសញ្ញាជាបច្ច័យ ឈ្មោះថា **តប្បច្ចយោ** ព្រោះឆន្ទៈជាធម៌ស្ងប់ ឯវិតក្ក និងសញ្ញាជាធម៌មិនស្ងប់នោះជាបច្ច័យ ។ វេទនានោះ ជាវេទនាក្នុងបឋមជ្ឈាន ។ ប្រសិនបើឆន្ទៈ និងវិតក្កជាធម៌ស្ងប់ សញ្ញាក៏ជាធម៌មិនស្ងប់ ។

បទថា **តប្បច្ចយា** បានដល់ ការស្ងប់ឆន្ទៈ និងវិតក្កនោះ និងការមិនមានសញ្ញាជាបច្ច័យ ឈ្មោះថា **តប្បច្ចយោ**។ ព្រោះឆន្ទៈ និងវិតក្ក ជាធម៌ស្ងប់

និងសញ្ញាជាធម៌មិនស្ងប់នោះជាបច្ច័យ ។ វេទនានោះជាវេទនាក្នុងទុតិយជ្ឈាន នោះឯង ។ បើឆន្ទៈ វិតក្ក និងសញ្ញាជាធម៌ស្ងប់ ។

បទថា **តប្បច្ចយា** ការស្ងប់ឆន្ទៈ វិតក្ក និងសញ្ញានោះឯងជាបច្ច័យ ឈ្មោះថា **តប្បច្ចយោ** ។ ព្រោះឆន្ទៈ វិតក្ក និងសញ្ញាជាធម៌ស្ងប់នោះជាបច្ច័យ ។ វេទនានោះ ជាវេទនាក្នុងនេវសញ្ញានាសញ្ញាយតនៈនោះឯង តែអាចារ្យពួកខ្លះពណ៌នាយ៉ាងនេះថា ធម្មច្ឆន្ទៈក្នុងជាចំណែកខាងដើម ដោយគិតថា អញនឹងសម្រេចអប្បនាដូច្នេះ ឈ្មោះថា ឆន្ទៈ សេចក្តីពេញចិត្តរបស់អ្នកបានសម្រេចអប្បនាហើយជាសេចក្តីស្ងប់ ។ វិតក្ករមែងមានក្នុងបឋមជ្ឈាន វិតក្ករបស់អ្នកបានសម្រេចទុតិយជ្ឈានហើយក៏ស្ងប់ ។ សញ្ញារមែងមានក្នុងសមាបត្តិ ៧ សញ្ញារបស់អ្នកចូលដល់នេវសញ្ញានាសញ្ញាយតនៈ និងចូលដល់និរោធក៏ស្ងប់ទៅដែរ ដូច្នេះ ។ តែក្នុងទីនេះ និរោធសមាបត្តិ រមែងមិនគួរ ។

បទថា **អប្បត្តស្ស បត្តិយា** បានដល់ ដើម្បីសម្រេចអរហត្តផល ។ បទថា **អត្ថិ អាយវំ** បានដល់ សេចក្តីព្យាយាមមាន ។ បាឋៈថា **អាយាវំ** ដូច្នេះក៏មាន ។ បទថា **តស្មិម្បិ ឋានេ អនុប្បត្តេ** បានដល់ កាលបើនៅមិនទាន់បានសម្រេចអរិយមគ្គ ដែលជាហេតុនៃអរហត្តផលនោះ ដោយអំណាចនៃការប្រារព្ធសេចក្តីព្យាយាមនោះ ។ បទថា **តប្បច្ចយាបិ វេទយិតំ** បាន

*ដល់ ព្រោះឋានៈនៃព្រះអរហត្តជាបច្ច័យ វេទនាក៏មាន ។ ដោយពាក្យនោះ លោកកាន់យកលោកុត្តរវេទនាដែលកើតហើយ ដែលកើតព្រមជាមួយមគ្គ ៤ តែអាចារ្យពួកខ្លះ ពណ៌នាថា បទថា* **អាយវំ** *បានដល់ កិច្ចបដិបត្តិ ។ បទថា* **តស្មិម្បិ ឋានេ អនុប្បត្តេ** *បានដល់ សម្រេចភូមិនោះ ដូច្នេះ ។*

## អដ្ឋកថាបទេសវិហារញ្ញាណនិទ្ទេស ចប់

# សុត្តន្តបិដក

[ ២៤៦ ] បញ្ញាព្រោះភាពជាអធិបតី ឈ្មោះថា សញ្ញាវិវដ្តញ្ញាណ តើដូចម្តេច ។ បញ្ញា ព្រោះមាននេក្ខម្មៈជាអធិបតី រមៀលចេញចាកកាមច្ឆន្ទសញ្ញា ហេតុនោះ បញ្ញា ព្រោះភាពជាអធិបតី ឈ្មោះថា សញ្ញាវិវដ្តញ្ញាណ បញ្ញាព្រោះការមិនមានព្យាបាទជាអធិបតី រមៀលចេញចាកព្យាបាទសញ្ញា ហេតុនោះ បញ្ញា ព្រោះភាពជាអធិបតី ឈ្មោះថា សញ្ញាវិវដ្តញ្ញាណ បញ្ញា ព្រោះមានអាលោកសញ្ញាជាអធិបតី រមៀលចេញចាកថីនមិទ្ធសញ្ញា ហេតុនោះ បញ្ញា ព្រោះភាពជាអធិបតី ឈ្មោះថា សញ្ញាវិវដ្តញ្ញាណ បញ្ញា ព្រោះមានអវិក្ខេបៈជាអធិបតី រមៀលចេញចាកឧទ្ធច្ចសញ្ញា ហេតុនោះ បញ្ញា ព្រោះភាពជាអធិបតី ឈ្មោះថា សញ្ញាវិវដ្តញ្ញាណ បញ្ញា ព្រោះមានធម្មវវត្ថានជាអធិបតី រមៀលចេញចាកវិចិកិច្ឆាសញ្ញា ហេតុនោះ បញ្ញា ព្រោះភាពជាអធិបតី ឈ្មោះថា សញ្ញាវិវដ្តញ្ញាណ បញ្ញា ព្រោះមានញាណជាអធិបតី រមៀលចេញចាកអវិជ្ជាសញ្ញា ហេតុនោះ បញ្ញា ព្រោះភាពជាអធិបតី ឈ្មោះថា សញ្ញាវិវដ្តញ្ញាណ បញ្ញា ព្រោះមានបាមុជ្ជជាអធិបតី រមៀលចេញចាកអរតិសញ្ញា ហេតុនោះ បញ្ញា ព្រោះភាពជាអធិបតី ឈ្មោះថា សញ្ញាវិវដ្តញ្ញាណ បញ្ញា ព្រោះមានបឋមជ្ឈានជាអធិបតី រមៀលចេញចាក នីវរណសញ្ញា ហេតុនោះ បញ្ញា ព្រោះភាពជាអធិបតី ឈ្មោះថា សញ្ញាវិវដ្តញ្ញាណ ។បេ។ បញ្ញាព្រោះមានអរហត្តមគ្គ ជាអធិបតី រមៀលចេញចាកសព្វកិលេស សញ្ញា ហេតុនោះ បញ្ញា ព្រោះភាពជាអធិបតី ឈ្មោះថា សញ្ញាវិវដ្តញ្ញាណ ឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះ

ថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញា ព្រោះភាពជាអធិបតី ឈ្មោះថា សញ្ញាវិវដ្ដញ្ញាណ ។

[ ២៤៧ ] បញ្ញា ក្នុងភាពផ្សេងៗ ឈ្មោះថា ចេតោវិវដ្ដញ្ញាណ តើដូចម្ដេច ។ កាមច្ឆន្ទៈ ឈ្មោះថា ភាពផ្សេងៗ នេក្ខម្មៈ ឈ្មោះថា ភាពតែមួយ កាលបុគ្គលត្រិះរិះនូវនេក្ខម្មៈ ដែលជាភាពតែមួយ ចិត្តរមែងវេៀលចាកកាមច្ឆន្ទៈ ហេតុនោះ បញ្ញាក្នុងភាពផ្សេងៗ ឈ្មោះថា ចេតោវិវដ្ដញ្ញាណ ព្យាបាទ ឈ្មោះថា ភាពផ្សេងៗ អព្យាបាទ ឈ្មោះថា ភាពតែមួយ កាលបុគ្គលត្រិះរិះនូវអព្យាបាទ ដែលជាភាពតែមួយ ចិត្តរមែងវេៀលចាកព្យាបាទ ហេតុនោះ បញ្ញាក្នុងភាពផ្សេងៗ ឈ្មោះថា ចេតោវិវដ្ដញ្ញាណ ថីនមិទ្ធៈ ឈ្មោះថា ភាពផ្សេងៗ អាលោកសញ្ញា ឈ្មោះថា ភាពតែមួយ កាលបុគ្គលត្រិះរិះនូវអាលោកសញ្ញា ដែលជាភាពតែមួយ ចិត្តរមែងវេៀលចេញចាកថីនមិទ្ធៈ ហេតុនោះ បញ្ញា ក្នុងភាពផ្សេងៗ ឈ្មោះថា ចេតោវិវដ្ដញ្ញាណ ។បេ។ កិលេសទាំងពួង ឈ្មោះថា ភាពផ្សេងៗ អរហត្តមគ្គ ឈ្មោះថា ភាពតែមួយ កាលបុគ្គលត្រិះរិះនូវអរហត្តមគ្គ ដែលជាភាពតែមួយ ចិត្តវេៀលចេញចាកកិលេសទាំងពួង ហេតុនោះ បញ្ញាក្នុងភាពផ្សេងៗ ឈ្មោះថា ចេតោវិវដ្ដញ្ញាណ ឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងភាពផ្សេងៗ ឈ្មោះថា ចេតោវិវដ្ដញ្ញាណ ។

[ ២៤៨ ] បញ្ញាក្នុងការអធិដ្ឋាន ឈ្មោះថា ចិត្តវិវដ្ដញ្ញាណ តើដូចម្ដេច ។

បុគ្គលកាលលះនូវកាមច្ឆន្ទៈ តែងអធិដ្ឋានចិត្តដោយអំណាចនេក្ខម្មៈ ហេតុនោះ បញ្ញាក្នុងការអធិដ្ឋាន ឈ្មោះថា ចិត្តវិវដ្តញ្ញាណ បុគ្គលកាលលះនូវព្យាបាទ តែងអធិដ្ឋានចិត្ត ដោយអំណាចអព្យាបាទ ហេតុនោះ បញ្ញាក្នុងការអធិដ្ឋាន ឈ្មោះថា ចិត្តវិវដ្តញ្ញាណ បុគ្គលកាលលះនូវថីនមិទ្ធៈ តែងអធិដ្ឋានចិត្តដោយអំណាចអាលោកសញ្ញា ហេតុនោះ បញ្ញាក្នុងការអធិដ្ឋាន ឈ្មោះថា ចិត្តវិវដ្តញ្ញាណ ។បេ។ បុគ្គលកាលលះនូវកិលេសទាំងអស់ តែងអធិដ្ឋានចិត្តដោយអំណាចអរហត្តមគ្គ ហេតុនោះ បញ្ញាក្នុងការអធិដ្ឋាន ឈ្មោះថា ចិត្តវិវដ្តញ្ញាណ ឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញា ក្នុងការអធិដ្ឋាន ឈ្មោះថា ចិត្តវិវដ្តញ្ញាណ ។

[ ២៤៩ ] បញ្ញាក្នុងសភាវៈសូន្យ ឈ្មោះថា ញាណវិវដ្តញ្ញាណ តើដូចម្តេច ។ កាលបុគ្គលដឹងច្បាស់ ឃើញច្បាស់តាមពិតថា ចក្ខុសូន្យចាកខ្លួន ចាកវត្ថុជារបស់ខ្លួន ចាកការទៀងទាត់ ចាកការស្ថិតស្ថេរ ចាកការប្រាកដ ឬចាករបស់ដែលមិនមានការប្រែប្រួលជាធម្មតា ញាណក៏រមៀលចេញចាកសេចក្តីប្រកាន់ស្អិតនូវកាម ហេតុនោះ បញ្ញាក្នុងសភាវៈសូន្យ ឈ្មោះថា ញាណវិវដ្តញ្ញាណ កាលបុគ្គលដឹងច្បាស់ ឃើញច្បាស់តាមពិតថា ត្រចៀកសូន្យ ។បេ។ ច្រមុះសូន្យ អណ្តាតសូន្យ កាយសូន្យ ចិត្តសូន្យចាកខ្លួន ចាកវត្ថុជារបស់ខ្លួន ចាកការទៀងទាត់ ចាកការស្ថិតស្ថេរ ចាកការប្រាកដ ឬចាករបស់ដែលមិនប្រែប្រួលជាធម្មតា ញាណក៏រមៀលចេញចាកសេចក្តីប្រកាន់

ស្អិតនូវកាម ហេតុនោះ បញ្ញាក្នុងសភាវៈសូន្យ ឈ្មោះថា ញាណវិវដ្ដញ្ញាណ ឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌ នោះហេតុនោះ លោកពោលថា បញ្ញាក្នុងសភាវៈសូន្យ ឈ្មោះថា ញាណវិវដ្ដញ្ញាណ ។

[ ២៥០ ] បញ្ញាក្នុងការលះបង់ ឈ្មោះថា វិមោក្ខវិវដ្ដញ្ញាណ តើដូចម្ដេច ។ បុគ្គលលះបង់កាមច្ឆន្ទៈដោយនេក្ខម្មៈ ហេតុនោះ បញ្ញាក្នុងការលះបង់ ឈ្មោះថា វិមោក្ខវិវដ្ដញ្ញាណ បុគ្គលលះបង់ព្យាបាទដោយអព្យាបាទ ហេតុនោះ បញ្ញាក្នុងការលះបង់ ឈ្មោះថា វិមោក្ខវិវដ្ដញ្ញាណ បុគ្គលលះបង់ថីនមិទ្ធៈដោយអាលោកសញ្ញា ហេតុនោះ បញ្ញាក្នុងការលះបង់ ឈ្មោះថា វិមោក្ខវិវដ្ដញ្ញាណ បុគ្គលលះបង់ឧទ្ធច្ចៈដោយអវិក្ខេបៈ ហេតុនោះ បញ្ញាក្នុងការលះបង់ ឈ្មោះថា វិមោក្ខវិវដ្ដញ្ញាណ បុគ្គលលះបង់វិចិកិច្ឆាដោយធម្មវវត្ថាន ហេតុនោះ បញ្ញាក្នុងការលះបង់ ឈ្មោះថា វិមោក្ខវិវដ្ដញ្ញាណ ។បេ។ បុគ្គលលះបង់កិលេសទាំងអស់ដោយអរហត្តមគ្គ ហេតុនោះ បញ្ញាក្នុងការលះបង់ ឈ្មោះថា វិមោក្ខ-វិវដ្ដញ្ញាណ ឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងការលះបង់ ឈ្មោះថា វិមោក្ខវិវដ្ដញ្ញាណ ។

[ ២៥១ ] បញ្ញាក្នុងអត្ថថាជារបស់ពិត ឈ្មោះថា សច្ចវិវដ្ដញ្ញាណ តើដូចម្ដេច ។ បុគ្គលកាលកំណត់នូវអត្ថថាបៀតបៀន អត្ថថាប្រជុំតាក់តែង អត្ថថាក្ដៅសព្វ អត្ថថាប្រែប្រួលនៃទុក្ខសច្ច រមែងត្រឡប់ ( ចាកកាម ) ហេតុ

នោះ បញ្ញាក្នុងអត្ថថាជារបស់ពិត ឈ្មោះថា សច្ចវិវដ្ដញ្ញាណ បុគ្គលកាលលះបង់នូវអត្ថថាប្រមូលមក អត្ថថានិទាន អត្ថថាប្រកបព្រម អត្ថថាជាប់ជំពាក់នៃសមុទយសច្ច រមែងត្រឡប់ ( ចាកកាម ) ហេតុនោះ បញ្ញាក្នុងអត្ថថាជារបស់ពិត ឈ្មោះថា សច្ចវិវដ្ដញ្ញាណ បុគ្គលកាលធ្វើឲ្យជាក់ច្បាស់នូវអត្ថថាលោសចេញ អត្ថថាស្ងប់ស្ងាត់ អត្ថថាមិនមានបច្ច័យតាក់តែង អត្ថថាអមតៈនៃនិរោធសច្ច រមែងត្រឡប់ ( ចាកកាម ) ហេតុនោះ បញ្ញាក្នុងអត្ថថាជារបស់ពិត ឈ្មោះថា សច្ចវិវដ្ដញ្ញាណ បុគ្គលកាលចម្រើននូវអត្ថថាចេញទៅ អត្ថថាជាហេតុ អត្ថថាឃើញ អត្ថថាភាពជាអធិបតីនៃមគ្គសច្ច រមែងត្រឡប់ ( ចាកកាម ) ហេតុនោះ បញ្ញាក្នុងអត្ថថាជារបស់ពិត ឈ្មោះថា សច្ចវិវដ្ដញ្ញាណ ( វិវដ្ដបុគ្គលមាន ៦ គឺ ) សញ្ញាវិវដ្ដបុគ្គល ១ ចេតោវិវដ្ដបុគ្គល ១ ចិត្តវិវដ្ដបុគ្គល ១ ញាណវិវដ្ដបុគ្គល ១ វិមោក្ខវិវដ្ដបុគ្គល ១ សច្ចវិវដ្ដបុគ្គល ១ ។ បុគ្គលណាកាលដឹងច្បាស់ រមៀលចេញ ( ចាកកិលេសទាំងពួង ) បុគ្គលនោះ ឈ្មោះថា សញ្ញាវិវដ្ដបុគ្គល បុគ្គលណាកាលត្រិះរិះរមៀលចេញ ( ចាកកាមច្ឆន្ទៈ ) បុគ្គលនោះ ឈ្មោះថា ចេតោវិវដ្ដបុគ្គល បុគ្គលណាកាលដឹងវិសេសរមៀល ( ចាកកិលេស ) បុគ្គលនោះ ឈ្មោះថា ចិត្តវិវដ្ដបុគ្គល បុគ្គលណាកាលធ្វើនូវញាណរមៀលចេញ ( ចាកសេចក្ដីប្រកាន់នូវកាម ) បុគ្គលនោះ ឈ្មោះថា ញាណវិវដ្ដបុគ្គល បុគ្គលណាកាលលះបង់រមៀលចេញ ( ចាកកិលេស ) បុគ្គលនោះ ឈ្មោះថា វិមោក្ខវិវដ្ដបុគ្គល បុគ្គលណាតាំងនៅក្នុងសេចក្ដីពិតរមៀលចេញ ( ចាកកាម ) បុគ្គលនោះឈ្មោះថា សច្ចវិវដ្ដ-

បុគ្គល ។

[ ២៥២ ] សញ្ញាវិវដ្ដបុគ្គលមានក្នុងខណៈនៃមគ្គណា ចេតោវិវដ្ដបុគ្គលក៏មានក្នុងខណៈនៃមគ្គនោះដែរ ចេតោវិវដ្ដបុគ្គលមានក្នុងខណៈនៃមគ្គណា សញ្ញាវិវដ្ដបុគ្គលក៏មានក្នុងខណៈនៃមគ្គនោះដែរ សញ្ញាវិវដ្ដបុគ្គល ចេតោវិ-វដ្ដបុគ្គលមានក្នុងខណៈនៃមគ្គណា ចិត្តវិវដ្ដបុគ្គលក៏មានក្នុងខណៈនៃមគ្គនោះដែរ ចិត្តវិវដ្ដបុគ្គលមានក្នុងខណៈនៃមគ្គណា សញ្ញាវិវដ្ដបុគ្គល ចេតោវិវដ្ដ-បុគ្គល ក៏មានក្នុងខណៈនៃមគ្គនោះដែរ សញ្ញាវិវដ្ដបុគ្គល ចេតោវិវដ្ដបុគ្គល ចិត្តវិវដ្ដបុគ្គលមានក្នុងខណៈនៃមគ្គណា ញាណវិវដ្ដបុគ្គលក៏មានក្នុងខណៈនៃមគ្គនោះដែរ ញាណវិវដ្ដបុគ្គលមានក្នុងខណៈនៃមគ្គណា សញ្ញាវិវដ្ដបុគ្គល ចេតោវិវដ្ដបុគ្គល ចិត្តវិវដ្ដបុគ្គលក៏មានក្នុងខណៈនៃមគ្គនោះដែរ សញ្ញាវិវដ្ដ-បុគ្គល ចេតោវិវដ្ដបុគ្គល ចិត្តវិវដ្ដបុគ្គល ញាណវិវដ្ដបុគ្គលមានក្នុងខណៈនៃមគ្គណា វិមោក្ខវិវដ្ដបុគ្គល ក៏មានក្នុងខណៈនៃមគ្គនោះដែរ វិមោក្ខវិវដ្ដបុគ្គលមានក្នុងខណៈនៃមគ្គណា សញ្ញាវិវដ្ដបុគ្គល ចេតោវិវដ្ដបុគ្គល ចិត្តវិវដ្ដបុគ្គល ញាណវិវដ្ដបុគ្គល ក៏មានក្នុងខណៈនៃមគ្គនោះដែរ សញ្ញាវិវដ្ដបុគ្គល ចេតោ-វិវដ្ដបុគ្គល ចិត្តវិវដ្ដបុគ្គល ញាណវិវដ្ដបុគ្គល វិមោក្ខវិវដ្ដបុគ្គលមានក្នុងខណៈនៃមគ្គណា សច្ចវិវដ្ដបុគ្គល ក៏មានក្នុងខណៈនៃមគ្គនោះដែរ សច្ចវិវដ្ដបុគ្គល

មានក្នុងខណៈនៃមគ្គណា សញ្ញាវិវដ្តបុគ្គល ចេតោវិវដ្តបុគ្គល ចិត្តវិវដ្តបុគ្គល ញាណវិវដ្តបុគ្គល វិមោក្ខវិវដ្តបុគ្គល ក៏មានក្នុងខណៈនៃមគ្គនោះដែរ ឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងអត្ថថាជារបស់ពិត ឈ្មោះថា សច្ចវិវដ្តញាណ ។

# អដ្ឋកថា

## វិវដ្ដញ្ញាណាជក្ខនិទ្ទេស

[ ២៤៦ ] គប្បីជ្រាបវិនិច្ឆ័យ ក្នុងវិវដ្ដញាណាធក្កនិទ្ទេសដូចតទៅ បទថា **ឆេក្ខម្មាធិបតត្តា បញ្ញា** បានដល់ បញ្ញាដែលប្រព្រឹត្តទៅដោយសភាព ក្រៃលែងក្នុងនេក្ខម្មៈ ធ្វើនេក្ខម្មៈឲ្យប្រសើរឡើង ។ បទថា **កាមច្ឆន្ទតោ សញ្ញាយ វិវដ្ដតិ** សេចក្ដីថា រមែងចៀសចេញ រមែងវិលត្រឡប់ រមែងថយ ចាកកាមច្ឆន្ទៈ ដោយសញ្ញាដែលសម្បយុត្តដោយបញ្ញាដែលធ្វើនេក្ខម្មៈឲ្យជា ធំ ដែលជាហេតុ ជាអ្នកធ្វើ ។ ក្នុងបទដ៏សេសក៏មានន័យនេះ ។

[ ២៤៧ ] បទថា **កាមច្ឆន្ទោ នានត្តំ** បានដល់ កាមច្ឆន្ទៈ មិនមាន សភាពតែមួយ ព្រោះមិនមានការប្រព្រឹត្តទៅដែលស្ងប់ ។ បទថា **ឆេក្ខម្មំ ឯកត្តំ** បានដល់ នេក្ខម្មៈមានសភាពតែមួយ ព្រោះមានការប្រព្រឹត្តទៅស្ងប់ ។ បទថា **ឆេក្ខម្មេកត្តំ ចេតយតោ** បានដល់ ញុំាងនេក្ខម្មៈឲ្យប្រព្រឹត្តទៅដោយ ការឃើញទោសក្នុងកាមច្ឆន្ទៈ ។ បទថា **កាមច្ឆន្ទតោ ចិត្តំ វិវដ្ដតិ** បានដល់ ចិត្តរមែងគេចចេញចាកកាមច្ឆន្ទៈ ដែលមានទោស ដែលឃើញហើយ ក្នុង ខណៈនៃនេក្ខម្មៈ ។ ក្នុងបទដ៏សេសក៏មានន័យនេះ ។

[ ២៤៨ ] បទថា **កាមច្ឆន្ទំ បជហន្តោ** បានដល់ ការលះកាមច្ឆន្ទៈក្នុង ខណៈដែលនេក្ខម្មៈប្រព្រឹត្តទៅដោយវិក្ខម្ភនប្បហានៈ ។ បទថា **ឆេក្ខម្មវសេន ចិត្តំ អធិដ្ឋាតិ** បានដល់ តាំងចិត្តដែលសម្បយុត្តដោយនេក្ខម្មៈនោះ ដោយ អំណាចនៃនេក្ខម្មៈដែលបានហើយ គឺធ្វើឲ្យតាំងនៅយ៉ាងប្រសើរ អធិប្បាយ

ថា ឲ្យប្រព្រឹត្តទៅ ។ ក្នុងបទដ៏សេសក៏មានន័យនេះ ។

[ ២៤៩ ] បទថា **ចក្ខុំ សុញ្ញំ អត្តេន វា** បានដល់ ចក្ខុសូន្យទទេចាកខ្លួនព្រោះមិនមានខ្លួន ពោល គឺអ្នកធ្វើ និងអ្នកទទួលដែលបុគ្គលពាលកំណត់ ។ ព្រោះចក្ខុណាមិនមានក្នុងទីណា ចក្ខុនោះ ឈ្មោះថា ទទេចាកទីនោះ ។ បទថា **អត្តនិយេន វា** បានដល់ សូន្យចាកការៈជាខ្លួន និងចាករបស់ខ្លួន ព្រោះមិនមានវត្ថុដែលជារបស់ខ្លួន ។ លោកពោលការមិនមានខ្លួន និងការមិនមានវត្ថុដែលទាក់ទងដោយខ្លួន ដើម្បីបដិសេធការប្រកាន់ទាំងពីរយ៉ាង ព្រោះមានការប្រកាន់ដោយអាការទាំងពីររបស់សត្វលោកថា ខ្លួន និងវត្ថុដែលទាក់ទងដោយខ្លួន ។ បទថា **និច្ចេន វា** បានដល់ ឈ្មោះថា សូន្យចាកការទៀង ព្រោះមិនមានបុគ្គលណាមួយដែលកន្លងការបែកធ្លាយ ហើយតាំងនៅបាន ។ បទថា **ធុវេន វា** បានដល់ ឈ្មោះថា ទទេចាកការស្ថិតស្ថេរ ព្រោះមិនមានបុគ្គលណាមួយដែលគង់វង់នៅបានសូម្បីក្នុងខណៈដែលប្រព្រឹត្តទៅ ។ បទថា **សស្សតេន វា** បានដល់ ឈ្មោះថា ទទេចាកការប្រាកដព្រោះមិនមានបុគ្គលណាមួយដែលនៅបានរហូតទៅ ។ បទថា **អវិបរិណាមធម្មេន វា** បានដល់ ឈ្មោះថា ទទេចាកការមិនប្រែប្រួលជាធម្មតា ព្រោះមិនមានបុគ្គលណាមួយដែលជាប្រក្រតីមិនប្រែប្រួលដោយហេតុពីរប្រការ គឺជរា ការចាស់ និងភង្គ ការបែកធ្លាយទៅ ។ម្យ៉ាងទៀត មានអធិប្បាយថា ទទេចាកការទៀង ការស្ថិតស្ថេរ ការគង់វង់ និងការមិនប្រែប្រួលជាធម្មតា ។ **វា** សព្ទ ប្រើក្នុងអត្ថសមុច្ចយៈ គឺការប្រមូលសេចក្តី ។ បទថា **យថាភូតំ ជានតោ បស្សតោ** បានដល់ កាលដឹងសការៈ

តាមសេចក្ដីពិតដោយអនត្តានុបស្សនាញាណ និងឃើញ ដូចឃើញដោយភ្នែក យ៉ាងនេះ ដោយប្រការយ៉ាងនេះ ។ បទថា **ចក្ខាភិនិវេសតោ ញាណំ វិវដ្ដតិ** បានដល់ ញាណរមែងចៀសចេញចាកការប្រកាន់ដែលឃើញហើយ ដែលប្រព្រឹត្តទៅថា ចក្ខុជាតួខ្លួន ឬជាវត្ថុដែលទាក់ទងដោយខ្លួន ដោយអំណាចតទង្គប្បហាន ។ ក្នុងបទដ៏សេសក៏មានន័យនេះ ។

[ ២៥០ ] បទថា **នេក្ខម្មេន កាមច្ឆន្ទំ វោស្សជ្ជតិ** បានដល់ បុគ្គលអ្នកបាននេក្ខម្មៈ រមែងលះបង់កាមច្ឆន្ទៈ ដែលជាបដិបក្ខចំពោះនេក្ខម្មៈនោះដោយនេក្ខម្មៈ ។ បទថា **វោស្សគ្គេ បញ្ញា** បានដល់ បញ្ញាដែលសម្បយុត្តដោយនេក្ខម្មៈនោះ ក្នុងនេក្ខម្មៈដែលជាការលះចេញនៃកាមច្ឆន្ទៈ ។ ក្នុងបទដ៏សេសក៏មានន័យនេះ ។

[ ២៥១ ] បទថា **ចីឡ្ហនដ្ឋំ** ជាដើម មានអត្ថដូចបានពោលហើយ ។ បទថា **បរិជានន្តោ វិវដ្ដតិ** ជាបុគ្គលាធិដ្ឋានទេសនា លោកពោលថា បុគ្គលដែលដល់ព្រមដោយមគ្គ កំណត់ដឹងអត្ថ ៤ យ៉ាងនៃទុក្ខដោយអំណាចនៃកិច្ច រមែងគេចចេញដោយការចេញចាកចំណែកទាំងពីរ ។ បុគ្គលដែលដល់ព្រមដោយញាណ រមែងចៀសចេញសូម្បីក្នុងវិវដ្ដញ្ញាណ ។ បទថា **តថដ្ឋេ បញ្ញា** បានដល់ បញ្ញាជាគ្រឿងចៀសចេញទៅក្នុងសភាវៈដែលពិត របស់បុគ្គលនោះៗឯង ។ ក្នុងបទដ៏សេសក៏មានន័យនេះ ។

ឥឡូវនេះ ព្រះសារីបុត្ត ដើម្បីសម្ដែងវិវដ្ដញ្ញាណ ៦ ដោយការផ្សេងគ្នានៃអាការដោយអំណាចកិច្ចក្នុងខណៈនៃមគ្គនោះឯង ទើបតាំងមាតិកាថា **សញ្ញា-**

**វិវដ្ដោ** ជាដើម ហើយកាលចែកមាតិកានោះដោយអត្ថ ទើបពោលបទថា **សញ្ញាណន្តោ វិវដ្ដតិ** ជាដើម ។

ក្នុងបទទាំងនោះ បទថា **សញ្ញាណន្តោ វិវដ្ដតីតិ សញ្ញាវិវដ្ដោ** សេចក្ដីថា ព្រោះព្រះយោគាវចរកាលដឹងព្រមនេក្ខម្មៈជាដើម ក្នុងចំណែកខាងដើមដោយភាពជាអធិបតីខាងក្រោយ រមែងចៀសទៅចាកកាមច្ឆន្ទៈជាដើមដោយញាណដែលសម្បយុត្តដោយនេក្ខម្មៈ ហេតុនោះ ទើបញាណនោះ ឈ្មោះថា សញ្ញាវិវដ្ដៈ ។ បទថា **ចេតយន្តោ វិវដ្ដតីតិ ចេតោវិវដ្ដោ** សេចក្ដីថា ព្រោះព្រះយោគាវចរ កាលគិតភាពដែលនេក្ខម្មៈតែមួយជាដើម រមែងចៀសចេញទៅចាកកាមច្ឆន្ទៈជាដើម ដោយញាណដែលសម្បយុត្តដោយនេក្ខម្មៈនោះ ហេតុនោះ ទើបញាណនោះ ឈ្មោះថា ចេតោវិវដ្ដៈ ។ បទថា **វិជានន្តោ វិវដ្ដតីតិ ចិត្តវិវដ្ដោ** សេចក្ដីថា ព្រោះព្រះយោគាវចរកាលដឹងច្បាស់ដោយអធិដ្ឋានចិត្តដោយអំណាចនេក្ខម្មៈជាដើម រមែងគេចចេញចាកកាមច្ឆន្ទៈជាដើម ដោយញាណដែលសម្បយុត្តដោយនេក្ខម្មៈនោះ ហេតុនោះ ទើបញាណនោះ ឈ្មោះថា ចិត្តវិវដ្ដៈ ។ បទថា **ញាណំ ករោន្តោ វិវដ្ដតីតិ ញាណវិវដ្ដោ** សេចក្ដីថា ព្រោះព្រះយោគាវចរកាលធ្វើអាយតនៈខាងក្នុង ៦ ឲ្យដឹងច្បាស់ ដោយភាពជារបស់ទទេ ដោយអនត្តានុបស្សនាញាណ រមែងចៀសចេញចាកការប្រកាន់មាំក្នុងអាយតនៈដែលឃើញហើយដោយញាណនោះៗ ឯង ហេតុនោះ ទើបញាណនោះ ឈ្មោះថា ញាណវិវដ្ដៈ ។

បទថា **វោស្សជ្ជន្តោ វិវដ្ដតីតិ វិមោក្ខវិវដ្ដោ** សេចក្ដីថា ព្រោះព្រះយោ-

គាវចរកាលលោសកាមច្ឆន្ទៈជាដើម ដោយនេក្ខម្មៈជាដើម រមែងចៀសចេញ ចាកកាមច្ឆន្ទៈជាដើម ដោយញាណដែលសម្បយុត្តដោយនេក្ខម្មៈជាដើមនោះ ហេតុនោះ ទើបញាណនោះ ឈ្មោះថា វិមោក្ខវិវដ្ដៈ ។

បទថា **តថដ្ឋេ វិវដ្ដតីតិ សច្ចវិវដ្ដោ** សេចក្ដីថា ព្រោះព្រះយោគាវចរ រមែងចៀសចេញ ក្នុងសភាវៈដែលពិត ៤ យ៉ាង ដោយអំណាចការចេញចាក ក្នុងចំណែកទាំង ២ ហេតុនោះ ទើបមគ្គញ្ញាណ ឈ្មោះថា សច្ចវិវដ្ដៈ ។ ម្យ៉ាង ទៀត មគ្គញ្ញាណនោះឯង រមែងចៀសចេញក្នុងសភាពដែលពិត ដោយការ ចេញទៅចាកចំណែកទាំង ២ ព្រោះហេតុនោះ ទើបឈ្មោះថា សច្ចវិវដ្ដៈ ។

[ ២៥២ ] បទថា **យត្ថ សញ្ញាវិវដ្ដោ** ជាដើម គប្បីជ្រាបថា លោក ពោលសំដៅដល់ខណៈនៃសច្ចវិវដ្ដញ្ញាណនោះឯង ព្រោះលោកពោលហើយ ក្នុងសច្ចវិវដ្ដញ្ញាណនិទ្ទេស ។ ពិតហើយ ញាណទាំងអស់ រមែងគួរក្នុងខណៈ នៃមគ្គនោះឯង ។ សួរថា សេចក្ដីនេះដូចម្ដេច ឆ្លើយថា ព្រោះអរិយមគ្គមក ហើយដោយសរុបក្នុងញាណដ៏សេស វៀរញាណក្នុងវិវដ្ដៈ ។ សូម្បីញាណ-វិវដ្ដៈ រមែងគួរក្នុងខណៈនៃមគ្គដោយអំណាចសម្រេចកិច្ចនៃវិបស្សនា ព្រោះ វិបស្សនា សម្រេចកិច្ចដោយមគ្គនោះឯង ។ ម្យ៉ាងទៀត បទថា **ចក្ខុំ សុញ្ញំ** ជាដើម ឈ្មោះថា ចាក់ធ្លុះដោយមគ្គញ្ញាណនោះឯង ដោយអំណាចនៃកិច្ច ព្រោះហេតុនោះ ការពោលដល់ញាណនោះក្នុងខណៈមគ្គ រមែងគួរនោះឯង ។

ម្យ៉ាងទៀត ក្នុងបទនេះ មានការប្រកបសេចក្ដីដូចតទៅនេះថា គួរធ្វើការ ប្រកបក្នុងការប្រៀបធៀបទាំងអស់ ដោយន័យជាដើមថា ក្នុងខណៈនៃមគ្គណា

មានសញ្ញាវិវដ្ដៈ ក្នុងខណៈនៃមគ្គនោះ រមែងមានចេតោវិវដ្ដៈ ។ ក្នុងខណៈនៃមគ្គណាមានចេតោវិវដ្ដៈ ក្នុងខណៈនៃមគ្គនោះ រមែងមានសញ្ញាវិវដ្ដៈ ។ ម្យ៉ាងទៀត សច្ចវិវដ្ដៈមកហើយ ព្រោះអរិយមគ្គ ៤ មកដល់ហើយក្នុងសញ្ញាវិវដ្ដៈ ចេតោវិវដ្ដៈ ចិត្តវិវដ្ដៈ និងវិមោក្ខវិវដ្ដៈ ។

ម្យ៉ាងទៀត ញាណវិវដ្ដៈ ជាការសម្រេចដោយអំណាចនៃកិច្ចដោយសច្ច-វិវដ្ដៈនោះឯង ។ កាលពោលបេយ្យាលឲ្យពិស្ដារក្នុងសញ្ញាវិវដ្ដៈ ចេតោវិវដ្ដៈ ចិត្តវិវដ្ដៈ និងវិមោក្ខវិវដ្ដៈ សូម្បីញាណវិវដ្ដៈ ក៏មកហើយក្នុងញាណទាំងនោះ ព្រោះមានបាលីថា បញ្ញា មានអនត្តានុបស្សនាជាអធិបតី រមែងចៀសចេញចាកការប្រកាន់មាំដោយសញ្ញា ព្រោះហេតុនោះ ទើបបញ្ញាជាអធិបតី ឈ្មោះថា សញ្ញាវិវដ្ដញាណ ការប្រកាន់មាំដោយសភាពផ្សេងៗ អនត្តានុបស្សនាជាសភាពតែមួយ កាលគិតដល់ភាពតែមួយ របស់អនត្តានុបស្សនា ចិត្តរមែងចៀសចេញចាកការប្រកាន់មាំ ព្រោះហេតុនោះ ទើបបញ្ញាក្នុងភាពផ្សេងៗ ជាចេតោវិវដ្ដញាណ កាលលះសេចក្ដីប្រកាន់មាំ ចិត្តរមែងតាំងមាំដោយអំណាចនៃអនត្តានុបស្សនា ព្រោះហេតុនោះ ទើបបញ្ញាក្នុងការអធិដ្ឋាន ឈ្មោះថា ចិត្ត-វិវដ្ដញាណ និងរលាស់ការប្រកាន់មាំ ដោយអនត្តានុបស្សនា ព្រោះហេតុនោះ ទើបបញ្ញាក្នុងការរលាស់ចេញ ឈ្មោះថា វិមោក្ខវិវដ្ដញាណ ។

ម្យ៉ាងទៀត ក្នុងញាណវិវដ្ដៈ រមែងបានសច្ចវិវដ្ដៈផង ព្រោះប្រកបបទថា ចក្ខុទេចាកខ្លួន ឬចាកវត្ថុដែលទាក់ទងដោយខ្លួនជាដើម ដោយអំណាចនៃកិច្ចរបស់អ្នកចេញចាកអនត្តានុបស្សនា ហើយបានអរិយមគ្គ ។ ព្រោះហេតុនោះ ក្នុងវិវដ្ដៈនីមួយៗ រមែងបានវិវដ្ដៈ ៥ ដ៏សេស ។ ព្រោះហេតុនោះ គប្បីជ្រាបថា លោកពោលប្រៀបធៀបទុកថា សញ្ញាវិវដ្ដបុគ្គល មានក្នុងខណៈនៃមគ្គណា ចេតោវិវដ្ដបុគ្គល ក៏មានក្នុងខណៈនៃមគ្គនោះដែរជាដើម ដោយប្រការដូច្នេះ ។l៙

**អដ្ឋកថាវិវដ្ដញ្ញាណចក្កនិទ្ទេស ចប់**

# សុត្តន្តបិដក

[ ២៥៣ ] បញ្ហា ក្នុងអត្ថថា សម្រេចដោយអំណាចនៃការអធិដ្ឋាននូវសុខសញ្ញា និងលហុសញ្ញា ព្រោះការកំណត់នូវកាយ និងចិត្តថាតែមួយ ឈ្មោះថា ឥទ្ធិវិធញ្ញាណ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ចម្រើននូវឥទ្ធិបាទដែលប្រកប ដោយឆន្ទសមាធិ និងបធានសង្ខារ ចម្រើននូវឥទ្ធិបាទដែលប្រកបដោយវិរិយសមាធិ ។បេ។ ចិត្តសមាធិ ។បេ។ វីមំសាសមាធិ និងបធានសង្ខារ ភិក្ខុនោះ អប់រំបង្ហឹកចិត្ត ធ្វើចិត្តឲ្យទន់គួរដល់កម្មក្នុងឥទ្ធិបាទទាំង ៤ នេះ ភិក្ខុនោះ លុះ អប់រំបង្ហឹកចិត្ត ធ្វើចិត្តឲ្យទន់គួរដល់កម្មក្នុងឥទ្ធិបាទទាំង ៤ នេះហើយ ក៏បញ្ចូល កាយក្នុងចិត្តខ្លះ បញ្ចូលចិត្តក្នុងកាយខ្លះ បង្អោនចិត្តដោយអំណាចនៃកាយខ្លះ បង្អោនកាយដោយអំណាចនៃចិត្តខ្លះ អធិដ្ឋានចិត្តដោយអំណាចនៃកាយខ្លះ អធិដ្ឋានកាយដោយអំណាចនៃចិត្តខ្លះ លុះបង្អោនចិត្ត ដោយអំណាចនៃកាយ បង្អោនកាយដោយអំណាចនៃចិត្ត អធិដ្ឋានចិត្តដោយអំណាចនៃកាយ អធិដ្ឋាន កាយដោយអំណាចនៃចិត្តហើយ ក៏បញ្ចូលនូវសុខសញ្ញា និងលហុសញ្ញាទៅ ក្នុងកាយ ភិក្ខុនោះ មានចិត្តអប់រំ បរិសុទ្ធ ផូរផង់ដូច្នោះហើយ ក៏បង្អោនបន្ទន់ ចិត្តទៅក្នុងឥទ្ធិវិធញ្ញាណ ភិក្ខុនោះតែងបានសោយនូវចំណែកនៃឫទ្ធិច្រើនយ៉ាង គឺធ្វើមនុស្សតែមួយរូប ឲ្យទៅជាច្រើនរូបក៏បានខ្លះ ធ្វើមនុស្សច្រើនរូបឲ្យទៅជា មួយរូបក៏បានខ្លះ ធ្វើទីកំបាំងឲ្យទៅជាទីវាលក៏បាន ធ្វើទីវាលឲ្យទៅជាទីកំបាំង ក៏បាន ដើរ ( ទម្លុះ ) ទៅខាងក្រៅជញ្ជាំង ខាងក្រៅកំពែង ខាងក្រៅភ្នំមិន ទើសទាក់ដូចជាដើរទៅក្នុងទីវាលក៏បាន ធ្វើនូវការមុជចុះ និងងើបឡើងក្នុងផែន ដី ដូចជាមុជងើបក្នុងទឹកក៏បាន ដើរទៅលើទឹកមិនបែកធ្លាយដូចជាដើរលើផែន

ដីក៏បាន ទៅទាំងក្អែនព្ទដ៏អាកាសក៏បានដូចជាសត្វស្លាប អាចចាប់ស្ទាបអង្អែល ព្រះចន្ទ និងព្រះអាទិត្យទាំងនេះដែលមានឫទ្ធិច្រើនយ៉ាងនេះ ដែលមានអានុភាព ច្រើនយ៉ាងនេះក៏បាន ញុំាងអំណាចឲ្យប្រព្រឹត្តទៅដោយកាយ រហូតទៅទល់នឹង ព្រហ្មលោកក៏បាន ឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះ ថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញា ក្នុងអត្ថថា សម្រេច ដោយអំណាចនៃការអធិដ្ឋាននូវសុខសញ្ញា និង លហុសញ្ញា ព្រោះការកំណត់នូវកាយ និងចិត្តថាតែមួយ ឈ្មោះថា ឥទ្ធិវិធញ្ញាណ ។

# អដ្ឋកថា

## ឥទ្ធិវិធញ្ញាណនិទ្ទេស

[ ២៥៣ ] គប្បីជ្រាបវិនិច្ឆ័យ ក្នុងឥទ្ធិវិធញ្ញាណនិទ្ទេសដូចតទៅ បទថា **ឥធ ភិក្ខុ** បានដល់ ភិក្ខុក្នុងសាសនានេះ ។ ក្នុងបទនេះថា **ឆន្ទសមាធិប្បធានសង្ខារសមន្នាគតំ** មានពាក្យអធិប្បាយដូចតទៅ សមាធិ មានឆន្ទៈជាហេតុ ឬសមាធិក្រៃលែងដោយឆន្ទៈ ឈ្មោះថា **ឆន្ទសមាធិ** ពាក្យនេះជាឈ្មោះរបស់សមាធិដែលបាន ព្រោះធ្វើកត្តុកម្យតាឆន្ទៈ ( សេចក្តីពេញចិត្តក្នុងការប្រាថ្នានឹងធ្វើ ) ឲ្យជាអធិបតី ។ សង្ខារដែលជាប្រធាន ឈ្មោះថា **បធានសង្ខារ** បទនេះ ជាឈ្មោះរបស់សេចក្តីព្យាយាម គឺសម្មប្បធានដែលឲ្យសម្រេចកិច្ច ៤ យ៉ាង ។ លោកធ្វើជាពហុវចនៈដោយអំណាចធ្វើកិច្ច ៤ យ៉ាង ឲ្យសម្រេច ។

បទថា **សមន្នាគតំ** បានដល់ ចូលដល់ហើយ ដោយឆន្ទសមាធិ និងបធានសង្ខារ ។ បទថា **ឥទ្ធិបាទំ** សេចក្តីថា គំនរនៃចិត្ត និងចេតសិកដ៏សេសដែលជាបាទ ដោយអត្ថថា សម្រេច ដោយបរិយាយនៃការសម្រេច ឬដោយអត្ថថា អធិដ្ឋាននៃឆន្ទសមាធិ និងបធានសង្ខារដែលសម្បយុត្តដោយចិត្តជាកុសល មានឧបចារជ្ឈានជាដើម ដែលបានឈ្មោះថា **ឥទ្ធិ** ដោយបរិយាយនេះថា សត្វទាំងឡាយរមែងសម្រេច គឺសម្រេចហើយ ចម្រើនហើយ ដល់នូវភាពប្រសើរហើយ ដល់ឥទ្ធិនោះ ។ សមដូចព្រះតម្រាស់ដែលបានត្រាស់ក្នុងសុត្តន្តភាជនីយ ក្នុងឥទ្ធិបាទវិភង្គថា ពាក្យថា ឥទ្ធិបាទ គឺវេទនាខន្ធ ។បេ។

វិញ្ញាណក្ខន្ធរបស់បុគ្គលមានសភាពដូច្នេះ ។ ម្យ៉ាងទៀត ទ្រង់ត្រាស់ក្នុងអភិ-ធម្មភាជនីយថា ពាក្យថា ឥទ្ធិបាទ គឺការពាល់ត្រូវ ការសោយអារម្មណ៍[១] ។បេ។ ការផ្គងទុក សេចក្តីមិនរាយមាយរបស់បុគ្គលមានសភាពដូច្នោះ ។

ព្រោះហេតុនោះ ក្នុងពាក្យនេះថា គំនរនៃចិត្ត និងចេតសិកដ៏**សេស** គប្បីជ្រាបថា លោកធ្វើឥទ្ធិនីមួយៗ ក្នុងឆន្ទសមាធិ និងបធានសង្ខារហើយ ធ្វើពាក្យដ៏សេសដោយបទនីមួយៗ ពីរៗ ។

ពិតហើយ លោកសង្គ្រោះខន្ធ ៤ និងធម៌មានផស្សៈជាដើម ទាំងអស់ចូលជាមួយគ្នាយ៉ាងនេះ ។ ក្នុងបទដ៏សេស គប្បីជ្រាបអត្ថដោយន័យនេះ ។ សមាធិដែលបានព្រោះធ្វើឆន្ទៈឲ្យជាអធិបតី លោកពោលថា ឆន្ទសមាធិយ៉ាងណា សមាធិដែលបានព្រោះវីរិយៈ ... ចិត្តៈ ... វីមំសាឲ្យជាអធិបតី លោកក៏ពោលថា វីមំសាសមាធិយ៉ាងនោះ ។

ក្នុងឥទ្ធិបាទនីមួយៗ ធម៌បីៗ គឺមានឆន្ទៈជាដើម[២] មានវីរិយៈជាដើម មានចិត្តជាដើម មានវីមំសាជាដើម លោកពោលថា ឥទ្ធិខ្លះ ឥទ្ធិបាទខ្លះ ដោយប្រការដូច្នេះ ។ ចំណែកខន្ធ ៤ ដែលសម្បយុត្តដ៏សេស ជាឥទ្ធិបាទតែម្យ៉ាង ។ ម្យ៉ាងទៀត ព្រោះធម៌នីមួយ បីៗ នេះ រមែងសម្រេចព្រមគ្នាជាមួយខន្ធ ៤ ដែលសម្បយុត្ត វៀរខន្ធ ៤ នោះចេញ រមែងមិនសម្រេច ហេតុនោះ គប្បីជ្រាបដោយ

---

១- បិដកខ្មែរ មិនមានបាលីថា វេទនា ( ការសោយអារម្មណ៍ ) នេះទេ តែអដ្ឋកថា មាន ទើបយើងរក្សាទុក ។

២- ពាក្យថា មានឆន្ទៈជាដើម ព្រោះមានធម៌ ៣ ទៀត គឺវីរិយៈ ចិត្តៈ វីមំសា កើតរួមជាមួយឆន្ទៈ ដែលជាប្រធាន ទើបហៅថា ឆន្ទសមាធិ ។

បរិយាយនោះថា សូម្បីខន្ធ ៤ ទាំងអស់ ក៏ឈ្មោះថា **ឥទ្ធិ** ព្រោះអត្ថថា ឲ្យសម្រេច ។ ឈ្មោះថា **ឋាន** ព្រោះអត្ថថា ជាទីតាំង ។

ចំណែកក្នុងបទនេះថា **វីរិយសមាធិបធានសង្ខារសមន្នាគតំ** មានសេចក្តីដូចតទៅនេះ បទថា វីរិយៈ និងបធានសង្ខារ មានន័យតែមួយដូចគ្នានោះឯង ។ បើសួរថា ព្រោះហេតុអ្វី ទើបលោកពោលជាពីរយ៉ាង ឆ្លើយថា ក្នុងទីនេះ លោកប្រារព្ធសព្ទថា **វីរិយ** មុន ដោយការសម្តែងវីរិយៈជាអធិបតី ពោលបទថា **បធានសង្ខារ** ដើម្បីសម្តែងភាពដែលវីរិយៈនោះឯង ឲ្យសម្រេចកិច្ច ៤ យ៉ាង ។

ម្យ៉ាងទៀត ព្រោះលោកពោលជាពីរយ៉ាងនោះឯង ក្នុងពាក្យនេះ ទើបលោកពោលថា ធម៌ទីមួយ បីៗ ។ ចំណែកអាចារ្យពួកខ្លះពោលថា ព្រោះត្រាស់ក្នុងវិភង្គថា ពាក្យថា **ឥទ្ធិ** បានដល់ ការសម្រេច ការសម្រេចព្រម អាការសម្រេច អាការសម្រេចព្រម នូវធម៌ទាំងឡាយនោះ ឈ្មោះថា ឥទ្ធិ មិនទាន់សម្រេច ឈ្មោះថា ឥទ្ធិបាទ សម្រេចហើយ ។ តែក្នុងទីនេះ ធ្វើការសម្រេចបានថា ឥទ្ធិក្តី ឥទ្ធិបាទក្តី សម្រេចហើយ កម្មាត់នូវគ្រឿងកំណត់បានហើយ ។ ដោយពាក្យថា ការសម្រេច ការសម្រេចព្រម គប្បីជ្រាបថាត្រាស់ដល់ធម៌ដោយអាការ គឺសេចក្តីសម្រេចនោះឯង ។

បទថា **ភាវេតិ** បានដល់ រមែងសេព ។ សូម្បីក្នុងបទនេះ ការចម្រើនឥទ្ធិបាទជាលោកិយទាំងអស់ ដូចក្នុងសុត្តន្តភាជនីយ ។ ព្រោះហេតុនោះ ព្រះយោគាវចរអ្នកបំណងនឹងញុំាងឥទ្ធិបាទឲ្យបរិបូរណ៍មុន កាលចម្រើនឥទ្ធិបាទ

ដែលជាលោកិយ ជាអ្នកចូលសមាបត្តិ ៨ ដែលដល់នូវការជំនាញ ដែលសម្រេចហើយក្នុងកសិណ ៨ មានបឋវីកសិណជាដើម បង្ហឹកចិត្តដោយអាការ ១៤ គឺដោយអនុលោមកសិណ ១ ដោយបដិលោមកសិណ ១ ដោយអនុ-លោម និងបដិលោមកសិណ ១ ដោយអនុលោមឈាន ១ ដោយបដិលោម-ឈាន ១ ដោយអនុលោម និងបដិលោមឈាន ១ ដោយកន្លងឈាន ១ ដោយកន្លងកសិណ ១ ដោយកន្លងឈាន និងកសិណ ១ ដោយផ្លាស់អង្គ ១ ដោយផ្លាស់អារម្មណ៍ ១ ដោយផ្លាស់អង្គ និងអារម្មណ៍ ១ ដោយកំណត់អង្គ ១ ដោយកំណត់អារម្មណ៍ ១ ហើយទើបចូលឈានរឿយៗ ដោយអំណាចឆន្ទៈ វីរិយៈ ចិត្តៈ វីមំសាជាប្រធាន ។ អាចារ្យពួកខ្លះប្រាថ្នាសូម្បីការកំណត់អង្គ និងអារម្មណ៍ ។ អ្នកដល់ព្រមដោយហេតុខាងដើម សន្សំភាពជំនាញក្នុងហេតុត្រឹមតែឈាន ៤ ពួកក្នុងកសិណទាំងឡាយហើយ ទើបគួរធ្វើ ( សម្តែងឫទ្ធិ ) ព្រោះហេតុនោះ ព្រះយោគាវចរ ចម្រើនឥទ្ធិបាទសមាធិនោះៗ រមែងអធិដ្ឋានវីរិយៈ ៤ ប្រការ មានជាដើមថា ដើម្បីញុំាងពួកអកុសលធម៌ដ៏លាមកដែលមិនទាន់កើតមិនឲ្យកើតឡើង កាលដឹងសេចក្តីវិនាស និងសេចក្តីចម្រើនរបស់សមាធិនោះហើយ រមែងអធិដ្ឋានវីរិយៈស្មើ ។ ព្រះយោគាវចរនោះអប់រំចិត្តក្នុងឥទ្ធិបាទ ៤ យ៉ាងនេះហើយ រមែងញុំាងឥទ្ធិវិធឲ្យសម្រេចបាន ។

បទថា **សោ** ក្នុងបទជាដើមថា **សោ ឥមេសុ ចតូសុ ឥទ្ធិបាទេសុ** បានដល់ ភិក្ខុអ្នកចម្រើនឥទ្ធិបាទ ៤ នោះ ។ បទថា **ចតូសុ ឥទ្ធិបាទេសុ ចិត្តំ បរិភាវេតិ** បានដល់ ភិក្ខុធ្វើឥទ្ធិបាទនីមួយៗ ក្នុងឆន្ទៈជាដើម ឲ្យជាធំរឿយៗ

ហើយ ឈ្មោះថា អប់រំចិត្តក្នុងឥទ្ធិបាទទាំងនោះដោយការចូលឈាន អធិប្បាយថា ឲ្យកាន់យកអាការដោយឆន្ទៈជាដើម ។ បទថា **បរិទមេតិ** បានដល់ ធ្វើចិត្តឲ្យប្រព្រឹត្តទៅខុស ។ ពាក្យមុនជាហេតុនៃពាក្យក្រោយ ។ ព្រោះចិត្តដែលអប់រំហើយ រមែងជាចិត្តដែលគ្របសង្កត់បានហើយ ។ បទថា **មុទុំ ករោតិ** បានដល់ ធ្វើចិត្តដែលសង្កត់បានហើយយ៉ាងនោះ ឲ្យដល់ភាពជំនាញ ។ ចិត្តឲ្យប្រព្រឹត្តទៅក្នុងអំណាច ហៅថា **មុទុ**។ បទថា **កម្មនិយំ** បានដល់ ធ្វើឲ្យសមគួរដល់ការងារ ។ ចិត្តទន់រមែងគួរដល់ការងារ ដូចមាសដែលដេញបរិសុទ្ធហើយ ។ តែក្នុងទីនេះ បានដល់ គួរដល់ការងារ គឺសម្តែងឫទ្ធិបាន ។ បទថា **សោ** បានដល់ ភិក្ខុអ្នកមានចិត្តអប់រំហើយ ។ លោកពោលបទថា **កាយម្បិ ចិត្តេ សមោទហតិ** ជាដើម ដើម្បីសម្តែងវិធីប្រកបដើម្បីសម្រេចនៃការប្រព្រឹត្តទៅនៃចិត្តយ៉ាងងាយស្រួលក្នុងវេលាសម្តែងឫទ្ធិ ។ ក្នុងបទទាំងនោះ បទថា **កាយម្បិ ចិត្តេ សមោទហតិ** សេចក្តីថា រមែងតាំង គឺឲ្យចូលទៅ បានដល់ លើកករជកាយរបស់ខ្លួនទុកក្នុងចិត្តដែលមានឈានជាបាទខ្លះ អធិប្បាយថា ធ្វើកាយឲ្យប្រព្រឹត្តទៅតាមចិត្ត ។ ការធ្វើយ៉ាងនេះ រមែងជាឧបការៈដល់ការទៅដោយកាយ ដែលមិនប្រាកដ ។ បទថា **ចិត្តម្បិ កាយេ សមោទហតិ** សេចក្តីថា រមែងតាំង គឺលើកចិត្តដែលមានឈានជាបាទក្នុងករជកាយរបស់ខ្លួន អធិប្បាយថា ធ្វើចិត្តឲ្យប្រព្រឹត្តទៅតាមកាយខ្លះ ។ ការធ្វើយ៉ាងនេះ រមែងជាឧបការៈដល់ការទៅដោយកាយដែលប្រាកដ ។ បាឋៈថា **សមាទហតិ** ដូច្នេះក៏មាន សេចក្តីថា ឲ្យតាំងទុក ។ បទថា **កាយវសេន**

**ចិត្តំ បរិណាមេតិ** *សេចក្ដីថា កាន់យកចិត្តដែលមានឈានជាបាទលើកឡើងទុកក្នុងករជកាយ ធ្វើឲ្យប្រព្រឹត្តទៅតាមកាយ ។ បទនេះ ជាវេវចនៈនៃការបង្អោនចិត្តទុកក្នុងកាយ ។ បទថា* **ចិត្តវសេន កាយំ បរិណាមេតិ** *សេចក្ដីថា កាន់យកករជកាយហើយ លើកទុកក្នុងចិត្តដែលមានឈានជាបាទ ធ្វើឲ្យប្រព្រឹត្តទៅតាមចិត្ត ។ បទនេះ ជាវេវចនៈនៃការបង្អោនកាយទុកក្នុងចិត្ត ។ បទថា* **អធិដ្ឋាតិ** *បានដល់ អធិដ្ឋានថា សូមឲ្យជាយ៉ាងនេះចុះ ។ លោកពោលដល់ការបង្អោនទៅ ដើម្បីការភ្លឺច្បាស់នៃអត្ថរបស់បទថា* **សមោទហានស្ស** ។ *លោកពោលដល់អធិដ្ឋានដើម្បីការភ្លឺច្បាស់នៃអត្ថរបស់បទថា* **បរិណាមស្ស** ។ *បទថា* **បរិណាមេតិ អធិដ្ឋាតិ** *ជាបទពង្រីកអត្ថ របស់បទថា* **សមោទហាតិ** *នោះ ។ ហេតុនោះ ដោយអំណាចនៃបទទាំងពីរនោះ ទើបលោកពោលថា* **បរិណាមេត្វា អធិដ្ឋហិត្វា** *មិនពោលថា* **សមោទហិត្វា** ។

*បទថា* **សុខសញ្ញញ្ច លហុសញ្ញញ្ច កាយេ ឱក្កមិត្វា វិហរតិ** *សេចក្ដីថា បញ្ចូលសុខសញ្ញា ដែលកើតរួមជាមួយចតុត្ថជ្ឈាន និងលហុសញ្ញាឲ្យចូលទៅក្នុងករជកាយដោយអំណាចការចូលសមាបត្តិ រមែងនៅ ។ ករជកាយរបស់ភិក្ខុនោះ អ្នកមានកាយបង្អោនទៅដោយសញ្ញានោះ ក៏ជាករជកាយស្រាលដូចប៉ុយ-គ ។ បទថា* **សោ** *គឺភិក្ខុ អ្នកធ្វើការប្រកបវិធីនោះ ។ បទថា* **តថាភាវិតេន ចិត្តេន** *ជាតតិយាវិភត្តិ ចុះក្នុងលក្ខណៈនៃឥត្ថម្ភូតៈ ឬចុះក្នុងអត្ថនៃហេតុ សេចក្ដីថា មានចិត្តដែលអប់រំហើយយ៉ាងនោះ គឺជាហេតុ ។ បទថា* **បរិសុទ្ធេន** *បានដល់ ឈ្មោះថា បរិសុទ្ធព្រោះមានសតិ បរិសុទ្ធព្រោះឧបេក្ខា ។*

ឈ្មោះថា **បរិយោទាតេន** ព្រោះការបរិសុទ្ធនោះឯង អធិប្បាយថា ចិត្តត្រចះត្រចង់ ។ បទថា **ឥទ្ធិវិធញ្ញាណាយ** បានដល់ ក្នុងចំណែកនៃឥទ្ធិ ។ ឬដើម្បីញាណ ក្នុងការកំណត់ឥទ្ធិ ។ បទថា **ចិត្តំ អភិនីហរតិ** បានដល់ កាលចិត្តនោះ ជាបាទនៃអភិញ្ញាហើយ ដោយប្រការដូចពោលហើយ ភិក្ខុនោះ រមែងបង្អោនបរិកម្មចិត្តទៅ ដើម្បីសម្រេចឥទ្ធិវិធញ្ញាណ គឺនាំចេញចាកអារម្មណ៍កសិណហើយ ផ្ដោះមុខទៅកាន់ឥទ្ធិវិធ ។ បទថា **អភិនិន្នាមេតិ** បានដល់ ធ្វើការបង្អោនទៅកាន់ឥទ្ធិដែលគួរសម្រេច ឲ្យឈមទៅកាន់ឥទ្ធិ ។ បទថា **សោ** បានដល់ ភិក្ខុអ្នកធ្វើចិត្តឲ្យមានអភិនីហារយ៉ាងនេះ ។ បទថា **អនេកវិហិតំ** បានដល់ ច្រើនយ៉ាង មានប្រការផ្សេងៗ ។ បទថា **ឥទ្ធិវិធំ** បានដល់ ចំណែកនៃឫទ្ធិ ឬកំណត់នៃឫទ្ធិ ។ បទថា **បច្ចនុភោតិ** បានដល់ រមែងសោយផលអធិប្បាយថា រមែងពាល់ត្រូវ គឺធ្វើឲ្យជាក់ច្បាស់ បានដល់ សម្រេច ។ ឥឡូវនេះ ព្រះសារីបុត្តត្ថេរ កាលនឹងសម្ដែងភាពដែលភិក្ខុនោះសម្ដែងឫទ្ធិបានច្រើនយ៉ាង ទើបពោលបទថា **ឯកោបិ ហុត្វា** ជាដើម ។

ក្នុងបទទាំងនោះ បទថា **ឯកោបិ ហុត្វា** បានដល់ ជាបុគ្គលម្នាក់តាមប្រក្រតីមុនសម្ដែងឫទ្ធិ ។ បទថា **ពហុធា ហោតិ** បានដល់ ភិក្ខុបំណងនឹងដើរចង្ក្រមក្ដី បំណងនឹងស្វាធ្យាយក្ដី បំណងនឹងសួរបញ្ហាក្ដី ក្នុងសម្នាក់របស់ភិក្ខុច្រើន ( ទោះនិម្មិតខ្លួន ) ជាមួយរយក៏បាន ជាមួយពាន់ក៏បាន ។ សួរថា ធ្វើយ៉ាងនោះបានដូចម្ដេច ឆ្លើយថា ប្រសិនបើភិក្ខុនោះ ញុំាងធម៌ដែលជាមូលនៃផ្លូវប្រព្រឹត្តទៅកាន់ភូមិរបស់ឫទ្ធិឲ្យបរិបូណ៌ ហើយចូលឈានដែលជា

បាទនៃអភិញ្ញា កាលចេញហើយប្រាថ្នាជាមួយរយ ធ្វើបរិកម្មថា សូមអាត្មាជាមួយរយ សូមអាត្មាជាមួយរយ ហើយចូលឈានដែលជាបាទ កាលចេញហើយក៏អធិដ្ឋាន ។ ព្រមជាមួយនឹងចិត្តដែលអធិដ្ឋាននោះឯង ក៏សម្រេចជាមួយរយបាន ។ សូម្បីក្នុងពាន់នាក់ជាដើម ក៏មានន័យនេះដូចគ្នា ។ ប្រសិនបើមិនសម្រេចយ៉ាងនោះ គួរធ្វើបរិកម្មទៀត ហើយចូលជាលើកទីពីរ កាលចេញហើយ គប្បីអធិដ្ឋាន ។

ក្នុងអដ្ឋកថាសំយុត្តនិកាយពោលថា គួរចូល ១ ដង ឬ ២ ដងក្នុងការចូលនោះ ចិត្តមានឈានជាបាទ មាននិមិត្តជាអារម្មណ៍ ។ បរិកម្មចិត្តមានចំនួនមួយរយ ឬចំនួនមួយពាន់ជាអារម្មណ៍ ។ បរិកម្មចិត្តទាំងនោះមានដោយអំណាចនៃវណ្ណៈ មិនមែនដោយអំណាចនៃបញ្ញត្តិ ។ សូម្បីអធិដ្ឋានចិត្តមានចំនួនមួយរយ ឬចំនួនមួយពាន់ ជាអារម្មណ៍យ៉ាងនោះដូចគ្នា ។ អធិដ្ឋានចិត្តនោះកើតឡើងមួយដងប៉ុណ្ណោះ ក្នុងលំដាប់គោត្រភូ ដូចអប្បនាចិត្តដងដំបូងជាចិត្តក្នុងរូបាវចរចតុត្ថជ្ឈាន ។

ក្នុងបទថា **ពហុធា ហោតិ** នោះ បុគ្គលដែលនិម្មិតបានច្រើន រមែងដូចគ្នាតែមួយជាមួយអ្នកមានឫទ្ធិ ព្រោះនិម្មិតមិនបានកំណត់ ។ រមែងធ្វើវត្ថុដែលអ្នកមានឫទ្ធិធ្វើបានក្នុងការឈរ ការអង្គុយជាដើម ឬក្នុងការនិយាយ ការនៅស្ងៀមជាដើម ។ ប្រសិនបើប្រាថ្នានឹងធ្វើរូបនិមិត្តប្រភេទផ្សេងៗ ធ្វើពួកខ្លះជាបឋមវ័យ ពួកខ្លះជាមជ្ឈិមវ័យ ពួកខ្លះជាបច្ឆិមវ័យ ធ្វើពួកខ្លះឲ្យមានសក់វែង កោរសក់ពាក់កណ្ដាល មានសក់ ២ ពណ៌ មានចីវរពណ៌ក្រហមពាក់កណ្ដាល

មានចីវរពណ៌ស សូត្របទភាណ សម្តែងធម្មកថា សូត្រសរភញ្ញ សួរបញ្ហា ឆ្លើយបញ្ហា ជ្រលក់ចីវរ ស្ងោរចីវរ ដេរ និងគក់ចីវរជាដើមក៏ដូចគ្នា ឬបំណង នឹងធ្វើអាការផ្សេងៗ ដទៃ ភិក្ខុនោះកាលចេញចាកឈាន ដែលជាបាទហើយ ធ្វើបរិកម្មដោយន័យជាដើមថា ភិក្ខុប្រមាណប៉ុណ្ណេះ ចូរជាបឋមវ័យ ហើយ ចូលសមាបត្តិទៀត កាលចេញហើយគប្បីអធិដ្ឋាន ព្រមជាមួយចិត្តអធិដ្ឋាន ភិក្ខុរមែងប្រព្រឹត្តទៅតាមដែលខ្លួនអធិដ្ឋាននោះឯង ។

ក្នុងបទថា **ពហុធាបិ ហុត្វា ឯកោ ហោតិ** ជាដើម ក៏មានន័យនេះ តែ មានសេចក្តីផ្សេងគ្នា ដូចតទៅនេះថា ភិក្ខុនេះកាលនិម្មិតរូបជាច្រើនយ៉ាងនេះ ហើយ ក៏គិតទៀតថា អញម្នាក់ឯងប៉ុណ្ណោះនឹងដើរចង្ក្រម នឹងធ្វើការស្វាធ្យាយ នឹងសួរបញ្ហាក្តី ព្រោះជាអ្នកមានសេចក្តីប្រាថ្នាតិច គិតថា វិហារនេះមានភិក្ខុ តិច បើភិក្ខុពួកខ្លះនិមន្តមកនឹងស្គាល់អញថាភិក្ខុដូចគ្នាតែមួយ មានប្រមាណ ប៉ុណ្ណេះមកអំពីណា នេះជាអានុភាពរបស់ព្រះថេរៈដូច្នេះក្តី ទើបប្រាថ្នាក្នុងរវាង នោះឯងថា សូមអាត្មាអញជាបុគ្គលតែម្នាក់ ចូលឈានជាបាទ កាលចេញចាក ឈានទើបធ្វើបរិកម្មថា សូមអាត្មាអញជាបុគ្គលតែម្នាក់ ហើយចូលឈានម្តង ទៀត ពេលចេញចាកឈានហើយ គប្បីអធិដ្ឋានថា សូមអាត្មាអញជាបុគ្គល តែម្នាក់ចុះ ។ ភិក្ខុនោះនឹងជាបុគ្គលតែម្នាក់ ព្រមជាមួយនឹងចិត្តដែលអធិដ្ឋាន នោះឯង ។ បើមិនធ្វើយ៉ាងនេះរមែងជាបុគ្គលម្នាក់ឯងនោះឯង ដោយអំណាច ពេលវេលាតាមដែលកំណត់ ។

បទថា **អាវិភាវំ** អធិប្បាយថា រមែងធ្វើនូវការប្រាកដ ។ បទថា **តិរោភាវំ**

អធិប្បាយថា រមែងធ្វើនូវការបិទបាំង ( បំបាំងកាយ ) ។ គប្បីភ្ជាប់ដោយបទមុនថា ធ្វើទីកំបាំងឲ្យទៅជាទីវាលក៏បាន ធ្វើទីវាលឲ្យទៅជាទីកំបាំងក៏បាន ។ ក្នុងបទនេះ អ្នកមានឫទ្ធិបំណងនឹងធ្វើឲ្យប្រាកដ រមែងធ្វើទីងងឹតឲ្យភ្លឺក៏បាន ឬធ្វើទីកំបាំងឲ្យឃើញក៏បាន ឬធ្វើទីមិនមែនជាគន្លងនៃភ្នែកឲ្យមកជាគន្លងនៃភ្នែកក៏បាន ។ សួរថា ធ្វើដូចម្ដេច ឆ្លើយថា ភិក្ខុនេះបំណងនឹងបង្ហាញខ្លួន ឬអ្នកដទៃឲ្យប្រាកដដូចបុគ្គលដែលនៅក្នុងទីកំបាំង ឬនៅក្នុងទីឆ្ងាយឲ្យប្រាកដ កាលចេញចាកឈានដែលជាបាទហើយ បង្អោនទឹកថា សូមងងឹតនេះភ្លឺ ឬសូមទីកំបាំងនេះប្រាកដ ឬទីដែលមិនប្រាកដដល់គន្លងចក្ខុនេះចូរប្រាកដដល់គន្លងចក្ខុចុះ ហើយធ្វើបរិកម្មអធិដ្ឋានដោយន័យដូចពោលហើយនោះឯង ព្រមជាមួយនឹងការអធិដ្ឋាន រមែងប្រព្រឹត្តទៅតាមការអធិដ្ឋាននោះឯង ។ អ្នកដទៃសូម្បីឈរនៅក្នុងទីឆ្ងាយក៏ឃើញបាន សូម្បីខ្លួនឯងបំណងនឹងឃើញក៏ឃើញបាន ។ ចំណែកភិក្ខុដែលបំណងនឹងធ្វើឲ្យបាត់ទៅ រមែងធ្វើទីភ្លឺឲ្យងងឹតបាន ឬធ្វើទីដែលមិនកំបាំងឲ្យកំបាំងបាន ឬធ្វើទីដែលជាគន្លងនៃចក្ខុមិនឲ្យជាគន្លងនៃចក្ខុបាន ។ សួរថា ធ្វើដូចម្ដេច ឆ្លើយថា ភិក្ខុនេះបំណងនឹងធ្វើខ្លួន ឬអ្នកដទៃដែលនៅក្នុងទីមិនបិទបាំង ឬដែលឈរក្នុងទីជិតមិនឲ្យប្រាកដ កាលចេញអំពីបាទកជ្ឈានហើយបង្អោនទឹកថា សូមពន្លឺនេះងងឹត ឬសូមទីមិនកំបាំងនេះចូរកំបាំង ឬសូមទីដែលជាគន្លងនៃចក្ខុនេះមិនជាគន្លងនៃចក្ខុ ហើយធ្វើបរិកម្មអធិដ្ឋានដោយន័យដូចពោលហើយនោះឯង ។ ព្រមនឹងការអធិដ្ឋាន រមែងប្រព្រឹត្តទៅតាមការអធិដ្ឋាននោះ ។ អ្នកដទៃសូម្បីឈរនៅទីជិត ក៏មិនឃើញ ។ សូម្បីខ្លួនឯង

បំណងនឹងមិនឃើញក៏មិនឃើញ ។ មួយវិញទៀត បាដិហារ្យដែលប្រាកដ សូម្បីទាំងអស់ ឈ្មោះថា ធ្វើឲ្យប្រាកដ បាដិហារ្យដែលមិនប្រាកដ ឈ្មោះថា ធ្វើឲ្យបាត់ទៅ ។

ក្នុងបាដិហារ្យទាំងនោះ បាដិហារ្យដែលធ្វើឲ្យប្រាកដ ឫទ្ធិក្តី អ្នកមានឫទ្ធិក្តី រមែងប្រាកដ ។ គប្បីសម្តែងបាដិហារ្យដែលប្រាកដនោះ ដោយយមកប្បាដិហារយ៍ ។ ក្នុងបាដិហារ្យដែលមិនប្រាកដ ឫទ្ធិប៉ុណ្ណោះរមែងប្រាកដ អ្នកមានឫទ្ធិមិនប្រាកដ ។ គប្បីសម្តែងបាដិហារ្យដែលមិនប្រាកដនោះដោយមហាកសូត្រ[១] និងដោយព្រហ្មនិមន្តនិកសូត្រ ។

បទថា **តិរោកុឌ្ឌំ** បានដល់ ជញ្ជាំងមួយទៀត អធិប្បាយថា ចំណែកដទៃនៃជញ្ជាំង ។ ខាងក្រៅកំពែង ខាងក្រៅភ្នំ ក៏មានន័យនេះ ។ ពាក្យថា ជញ្ជាំង បានដល់ ជញ្ជាំងផ្ទះ ។ ពាក្យថា កំពែង បានដល់ កំពែងព័ទ្ធផ្ទះ ព័ទ្ធវិហារ ព័ទ្ធភូមិជាដើម ។ បទថា **បព្វតោ** បានដល់ ភ្នំដី ឬភ្នំថ្ម ។ បទថា **អសជ្ជ-មានោ** បានដល់ មិនទើសទាក់ ។ បទថា **សេយ្យថាបិ អាកាសេ** បានដល់ ដូចទៅក្នុងអាកាស ។ បុគ្គលបំណងនឹងទៅយ៉ាងនេះ គប្បីចូលអាកាស-កសិណ លុះចេញហើយនឹកគិតដល់ជញ្ជាំងក្តី កំពែងក្តី ភ្នំក្តី ហើយធ្វើបរិកម្មអធិដ្ឋានថា សូមឲ្យជារបស់ទទេចុះ ។ រមែងជាទីទទេបាននោះឯង ។ រមែងជាប្រយោជន៍ដល់បុគ្គលដែលបំណងនឹងចុះទៅខាងក្រោមក្តី បំណងនឹងឡើងទៅកាន់ខាងលើក្តី ។ រមែងជាប្រយោជន៍ដល់បុគ្គលដែលបំណងនឹងដើរទម្លុះទៅ ។

---

១- ក្នុងទីខ្លះ ហៅថា យមកសូត្រ ។

ភិក្ខុនោះមិនទើសទាក់ក្នុងទីនោះ ។ម្យ៉ាងទៀត បើភិក្ខុនោះអធិដ្ឋាន ហើយកំពុងទៅ ភ្នំក្តី ដើមឈើក្តី ដុះឡើងក្នុងចន្លោះ គប្បីចូលឈានហើយអធិដ្ឋានទៀតឬ ធ្វើយថា មិនមានខូចខាត ព្រោះការចូលឈានហើយអធិដ្ឋានទៀត រមែងដូចជាការកាន់យកនិស្ស័យ ក្នុងសម្នាក់របស់ព្រះឧបជ្ឈាយ៍ ។ ព្រោះភិក្ខុនេះអធិដ្ឋានថា សូមជាទីទទេចុះ ដូច្នេះ រមែងជាទីទទេមួយរំពេច ។ ម្យ៉ាងទៀត ដោយកម្លាំងអធិដ្ឋានដែលធ្វើទុកមុន ការដែលភ្នំដទៃក្តី ដើមឈើដែលដុះឡើងតាមរដូវកាលដទៃក្តី នឹងតាំងឡើងក្នុងចន្លោះដល់ភិក្ខុនោះ នេះមិនមែនជាហេតុ ។ ឯការនិម្មិតមុន រមែងជាសភាវៈមានកម្លាំងជាងការនិម្មិតដែលអ្នកមានឫទ្ធិដទៃនិម្មិត បុគ្គលដែលមានឫទ្ធិក្រៅអំពីនេះ គួរទៅពីខាងលើ ឬខាងក្រោមរបស់ភិក្ខុនោះ ។

ក្នុងបទនេះថា **បថវិយាបិ ឧម្មុជ្ជនិម្មុជ្ជំ** មានសេចក្តីដូចតទៅនេះថា បទថា **ឧម្មុជ្ជំ** បានដល់ ផុសឡើង ។ បទថា **និម្មុជ្ជំ** បានដល់ មុជចុះ ។ ការផុសឡើង និងមុជចុះ ឈ្មោះថា **ឧម្មុជ្ជនិម្មុជ្ជំ** ។ ម្យ៉ាងទៀត ភិក្ខុបំណងនឹងធ្វើយ៉ាងនេះ គប្បីចូលអាបោកសិណ លុះចេញហើយ កំណត់ថា សូមផែនដីក្នុងទីប្រមាណប៉ុណ្ណេះ ចូរជាទឹកចុះ ហើយធ្វើបរិកម្មអធិដ្ឋាន ដោយន័យដូចពោលហើយនោះឯង ។ ជំណាលគ្នានឹងការអធិដ្ឋាន ផែនដីរមែងទៅជាទឹកក្នុងទីតាមដែលបានកំណត់ ។

ភិក្ខុនោះរមែងផុសឡើង មុជចុះក្នុងផែនដីនោះដូចក្នុងទឹក ។ មិនមែនត្រឹមតែការផុសឡើង មុជចុះតែម្យ៉ាងប៉ុណ្ណោះទេ នៅធ្វើវត្ថុដែលប្រាថ្នានឹងធ្វើក៏បាន

ក្នុងកិច្ចទាំងឡាយ មានការងូត ការផឹក ការលុបមុខ និងការដុសលាងរបស់ប្រើប្រាស់ជាដើម ។ ម្យ៉ាងទៀត មិនមែនធ្វើតែទឹកតែម្យ៉ាងប៉ុណ្ណោះទេ កាលភិក្ខុប្រាថ្នាវត្ថុណា មានសប្បិ ប្រេង ទឹកឃ្មុំ និងទឹកអំពៅជាដើម បង្អោនទឹកថា វត្ថុនេះៗ ចូរជាវត្ថុប្រមាណប៉ុណ្ណេះចុះ ហើយធ្វើបរិកម្មអធិដ្ឋាន វត្ថុនោះៗ រមែងប្រព្រឹត្តទៅតាមអធិដ្ឋានបាន ។ កាលលើកឡើងដាក់ភាជនៈ សប្បិក៏ជាសប្បិពិតៗ ប្រេងជាដើមក៏ជាប្រេងពិតៗ ទឹកជាដើមក៏ជាទឹកពិតៗ ។ ភិក្ខុនោះបំណងឲ្យសើមក្នុងផែនដីនោះក៏សើមបាន បំណងមិនឲ្យសើម ក៏មិនសើម ។

ម្យ៉ាងទៀត ផែនដីនោះ ជាទឹកចំពោះតែភិក្ខុនោះប៉ុណ្ណោះ ជាផែនដីដល់ជនដ៏សេស ។ លើផែនដីនោះ មនុស្សក៏គង់ដើរទៅមកបាន យានទាំងឡាយក៏បរបាន សូម្បីកសិកម្មជាដើមក៏ធ្វើបានដូចគ្នា ។ ប្រសិនបើភិក្ខុនេះប្រាថ្នាថា ផែនដីនេះចូរជាទឹកដល់ជនទាំងនោះចុះ ក៏រមែងទៅជាទឹកនោះឯង ។ កាលកន្លងពេលដែលកំណត់ វៀរទឹកក្នុងក្អម និងក្នុងស្រះជាដើមតាមប្រក្រតី ទីដែលកំណត់ទុកដ៏សេស ក៏ក្លាយជាផែនដីវិញ ។

ក្នុងបទនេះថា **ឧទកេបិ អភិជ្ជមានេ គច្ឆតិ** មានអធិប្បាយដូចតទៅនេះថា លោកពោលដល់ទឹកដែលជាន់លើហើយលិចថា **ភិជ្ជមានំ** គឺទឹកបែក ។ ទឹកផុយគ្នា គឺមិនបែក ។ ភិក្ខុបំណងទៅយ៉ាងនេះ គប្បីចូលបឋវីកសិណ លុះចេញហើយ កំណត់ថា ទឹកនេះ ចូរក្លាយទៅជាផែនដីក្នុងទីប្រមាណប៉ុណ្ណេះចុះ ហើយធ្វើបរិកម្មអធិដ្ឋានដោយន័យដូចពោលហើយនោះឯង ។ ដំណាលគ្នានឹងការអធិដ្ឋាន ទឹករមែងក្លាយជាផែនដី ក្នុងទីតាមដែលកំណត់ ។

ភិក្ខុនោះ ដើរលើទឹកនោះដូចដើរលើផែនដី ។ មិនមែនដើរទៅតែម្យ៉ាងនោះទេ គង់ឲ្យសម្រេចឥរិយាបថតាមប្រាថ្នាបាន ។ មិនមែនធ្វើឲ្យទៅជាផែនដីតែម្យ៉ាងប៉ុណ្ណោះ នៅទឹកអធិដ្ឋានវត្ថុណាមួយដែលប្រាថ្នាថា កែវមណី មាស ភ្នំ និងដើមឈើជាដើម ដោយន័យដូចពោលហើយ វត្ថុនោះៗ រមែងប្រព្រឹត្តទៅតាមដែលអធិដ្ឋាននោះឯង ។ ម្យ៉ាងទៀត ទឹកនោះ រមែងក្លាយជាផែនដីដល់ភិក្ខុនោះប៉ុណ្ណោះ ។ រមែងជាទឹកដល់ជនដ៏សេស ។ ត្រី និងអណ្តើក និងក្អែកទឹកជាដើម រមែងត្រាច់ទៅតាមសេចក្តីពេញចិត្ត ។ ប្រសិនបើភិក្ខុនេះប្រាថ្នានឹងធ្វើទឹកនោះឲ្យជាផែនដីដល់មនុស្សទាំងឡាយដទៃ ក៏រមែងធ្វើបាន តែរមែងជាទឹកព្រោះកន្លងកាលដែលបានកំណត់ ។

បទថា **អាកាសេបិ បល្លង្កេន ចង្កមតិ** បានដល់ អង្គុយពត់ភ្នែនទៅដោយជុំវិញក្នុងអាកាសក៏បាន ។ បទថា **បក្ខី សកុណោ** បានដល់ បក្សីមានស្លាប មិនមែនបក្សីដែលមានស្លាបមិនបរិបូរណ៍ ឬបក្សីដែលត្រូវកាត់ស្លាប ព្រោះថា បក្សីនោះ មិនអាចហើរទៅក្នុងអាកាសបាន ។ ភិក្ខុអ្នកបំណងនឹងទៅក្នុងអាកាសយ៉ាងនេះ ចូលបឋវីកសិណ លុះចេញហើយ បើប្រាថ្នានឹងអង្គុយហើយទៅ គួរកំណត់ខ្នាតបល្ល័ង្កធ្វើបរិកម្ម ហើយអធិដ្ឋានដោយន័យដូចពោលហើយ ។ បើបំណងនឹងដេក ហើយទៅ ។ គួរកំណត់ខ្នាតគ្រែ ។ បើបំណងនឹងដើរទៅ គួរកំណត់ខ្នាតផ្លូវ ។ លុះកំណត់ទីតាមសមគួរយ៉ាងនេះ ដោយប្រការដូច្នេះហើយ គួរអធិដ្ឋានថា អាកាសចូរក្លាយជាផែនដី ដោយន័យដូចពោលហើយនោះឯង ។ ដំណាលគ្នានឹងការអធិដ្ឋាននោះឯង អាកាសក៏នឹង

ក្លាយជាផែនដី ។ម្យ៉ាងទៀត ភិក្ខុបំណងនឹងទៅក្នុងអាកាស គួរបានទិព្វចក្ខុផងដែរ ។ ព្រោះហេតុអ្វី ព្រោះក្នុងចន្លោះនោះ រមែងមានភ្នំ និងដើមឈើជាដើម ដែលកើតតាមរដូវកាល ។ ឬនាគ និងគ្រុឌជាដើម ច្រណែននិម្មិតដើម្បីបានឃើញវត្ថុទាំងនោះ ។ ក៏កាលឃើញវត្ថុទាំងនោះហើយ គួរធ្វើដូចម្តេច គួរចូលឈានជាបាទ លុះចេញហើយ ធ្វើបរិកម្មថា វត្ថុទាំងនោះ ចូរជាអាកាសចុះ ហើយអធិដ្ឋាន ។ ម្យ៉ាងទៀត សូម្បីនឹងចុះក្នុងទីទទេ ក៏គួរបានទិព្វចក្ខុ ។ ព្រោះប្រសិនបើភិក្ខុនេះ ចុះត្រង់កំពង់ផ្ទួតទឹក ឬត្រង់ទ្វារស្រុកដែលមិនមែនទីទទេ នឹងប្រាកដដល់មហាជន ។ ព្រោះហេតុនោះ សម្លឹងមើលដោយទិព្វចក្ខុហើយ វៀរទីមិនទទេនោះ ចុះក្នុងទីទទេ ដោយប្រការដូច្នេះ ។

ក្នុងបទនេះថា **ឥមេបិ ចន្ទិមសុរិយេ ឯវំមហិទ្ធិកេ ឯវំមហានុភាវេ** គប្បីជ្រាបសេចក្តីដូចតទៅនេះថា គប្បីជ្រាបការមានឫទ្ធិច្រើនរបស់ព្រះចន្ទ និងព្រះអាទិត្យដោយការគោចរទៅខាងលើរហូត ៤ ម៉ឺន ២ ពាន់យោជន៍ ការមានអានុភាពច្រើនដោយការបញ្ចេញពន្លឺក្នុងខណៈតែមួយក្នុង ៣ ទ្វីប ម្យ៉ាងទៀត មានឫទ្ធិច្រើនដោយការគោចរទៅខាងលើ និងបញ្ចេញពន្លឺ ដោយអាការយ៉ាងនេះ មានអានុភាពច្រើន ដោយការមានឫទ្ធិច្រើននោះៗ ឯង ។

បទថា **បរាមសតិ** បានដល់ ពាល់ត្រូវ ឬប៉ះក្នុងចំណែកមួយ ។ បទថា **បរិមជ្ជតិ** បានដល់ ស្ទាបដូចស្ទាបផ្ទៃកញ្ចក់ដោយជុំវិញ ។ ម្យ៉ាងទៀត ឫទ្ធិនេះរបស់ភិក្ខុនោះ រមែងសម្រេចដោយអំណាចនៃឈាន មានអភិញ្ញាជាបាទ ។ ក្នុងឫទ្ធិនេះ មិនកំណត់កសិណសមាបត្តិ ។ ប្រសិនបើភិក្ខុនេះ ប្រាថ្នានឹងទៅ

*ស្ដាបក៏ទៅស្ដាបបាន ។ បើជាអ្នកអង្គុយ ឬដេកក្នុងទីនោះឯង ប្រាថ្នានឹងស្ដាប ក៏អធិដ្ឋានថា ព្រះចន្ទ ព្រះអាទិត្យ ចូរមានត្រង់ហត្ថបាសចុះ ។ ដោយកម្លាំងអធិដ្ឋាន ភិក្ខុនឹងស្ដាបព្រះចន្ទ ព្រះអាទិត្យដែលមកប្រាកដក្នុងហត្ថបាស ដូចផ្លែត្នោតជ្រុះអំពីទងមកប្រាកដដូច្នោះក៏បាន ឬលូកដៃទៅស្ដាបបាន ។ កាលបើភិក្ខុឈោងដៃទៅ ឧបាទិន្នកៈ ឬអនុបាទិន្នកៈឈោងទៅ អនុបាទិន្នកៈអាស្រ័យឧបាទិន្នកៈឈោងទៅ ។ ភិក្ខុធ្វើយ៉ាងនេះមិនមែនស្ដាបព្រះចន្ទ ព្រះអាទិត្យបានតែប៉ុណ្ណោះទេ ។ បើប្រាថ្នាធ្វើឲ្យជាទីជូតជើង ក៏តាំងទុកត្រង់ជើងបាន ធ្វើតាំងអង្គុយក៏បាន ធ្វើគ្រែដេកក៏បាន ធ្វើខ្នើយកើយក៏បាន ។ សូម្បីភិក្ខុរូបដទៃក៏ធ្វើបាន ដូចភិក្ខុមួយរូបធ្វើ ។ សូម្បីភិក្ខុច្រើនសែនអង្គធ្វើយ៉ាងនេះ វត្ថុមួយនៃវត្ថុទាំងនោះ រមែងសម្រេចដល់ភិក្ខុមួយរូបយ៉ាងនោះ ឯការគោចរ កាលធ្វើពន្លឺរបស់ព្រះចន្ទ ព្រះអាទិត្យរមែងមានជាប្រក្រតី ។ ដូចមណ្ឌលព្រះចន្ទ រមែងប្រាកដត្រង់ថាសទាំងអស់ដែលពេញដោយទឹកទាំង ១ ពាន់ថាស ។ ការគោចរ និងការធ្វើពន្លឺរបស់ព្រះចន្ទ ក៏មានជាប្រក្រតីយ៉ាងណា បាដិហារ្យនេះ ក៏ឧបមាយ៉ាងនោះ ។*

*បទថា* **យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេតិ** *សេចក្ដីថា ភិក្ខុកាលធ្វើអភិញ្ញាច្រើនយ៉ាងក្នុងរវាងនេះ កំណត់ដល់ព្រហ្មលោក រមែងប្រើអំណាចគឺភាពជាធំផ្លូវកាយរបស់ខ្លួនបាន ។ ចំណែកសេចក្ដីពិស្ដារ ក្នុងនិទ្ទេសនេះនឹងមានច្បាស់ក្នុងឥទ្ធិកថានោះឯង ។៚*

**អដ្ឋកថាឥទ្ធិវិធញ្ញាណនិទ្ទេស ចប់**

# សុត្តន្តបិដក

[ ២៥៤ ] បញ្ញាក្នុងការស្ទង់នូវសទ្ទនិមិត្ត មានភាពផ្សេងគ្នា និងមានភាពតែមួយ ដោយអំណាចនៃការផ្សាយទៅនៃវិតក្ក ឈ្មោះថា សោតធាតុ-វិសុទ្ធិញ្ញាណ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ចម្រើននូវឥទ្ធិបាទដែលប្រកបដោយឆន្ទសមាធិ វិរិយសមាធិ ចិត្តសមាធិ វីមំសាសមាធិ និងបធានសង្ខារ ភិក្ខុនោះអប់រំ បង្ហឹកចិត្ត ធ្វើចិត្តឲ្យទន់ គួរដល់កម្មក្នុងឥទ្ធិបាទទាំង ៤ នេះ ភិក្ខុនោះលុះអប់រំ បង្ហឹកចិត្ត ធ្វើចិត្តឲ្យទន់គួរដល់កម្មក្នុងឥទ្ធិបាទទាំង ៤ នេះ ហើយ រមែងធ្វើទុកក្នុងចិត្តនូវសទ្ទនិមិត្តនៃសំឡេងក្នុងទីឆ្ងាយក៏បាន ធ្វើទុកក្នុងចិត្តនូវសទ្ទនិមិត្តនៃសំឡេងក្នុងទីជិតក៏បាន ធ្វើទុកក្នុងចិត្តនូវសទ្ទនិមិត្តនៃសំឡេងដែលគ្រោតគ្រាតក៏បាន ធ្វើទុកក្នុងចិត្តនូវសទ្ទនិមិត្តនៃសំឡេង ដែលល្អិតល្អន់ក៏បាន ធ្វើទុកក្នុងចិត្តនូវសទ្ទនិមិត្តនៃសំឡេងដែលល្អិតក្រៃលែងក៏បាន ធ្វើទុកក្នុងចិត្តនូវសទ្ទនិមិត្តនៃសំឡេងក្នុងទិសខាងកើតក៏បាន ធ្វើទុកក្នុងចិត្តនូវសទ្ទ-និមិត្តនៃសំឡេងក្នុងទិសខាងលិចក៏បាន ធ្វើទុកក្នុងចិត្តនូវសទ្ទនិមិត្តនៃសំឡេងក្នុងទិសខាងជើងក៏បាន ធ្វើទុកក្នុងចិត្តនូវសទ្ទនិមិត្តនៃសំឡេងក្នុងទិសខាងត្បូងក៏បាន ធ្វើទុកក្នុងចិត្តនូវសទ្ទនិមិត្តនៃសំឡេងក្នុងទិសបន្ទាប់ទិសខាងកើតក៏បាន ធ្វើទុកក្នុងចិត្តនូវសទ្ទនិមិត្តនៃសំឡេងក្នុងទិសបន្ទាប់ទិសខាងលិចក៏បាន ធ្វើទុកក្នុងចិត្តនូវសទ្ទនិមិត្តនៃសំឡេង ក្នុងទិសបន្ទាប់ទិសខាងជើងក៏បាន ធ្វើទុកក្នុងចិត្តនូវសទ្ទនិមិត្តនៃសំឡេងក្នុងទិសបន្ទាប់ទិសខាងត្បូងក៏បាន ធ្វើទុកក្នុងចិត្តនូវសទ្ទនិមិត្តនៃសំឡេង ក្នុងទិសខាងក្រោមក៏បាន ធ្វើទុកក្នុងចិត្តនូវសទ្ទនិមិត្តនៃសំឡេងក្នុងទិសខាងលើក៏បាន ភិក្ខុនោះមានចិត្តអប់រំ បរិសុទ្ធ ផូរផង់ ដូច្នោះ

ហើយតែងបង្អោន បន្ទន់ចិត្តទៅក្នុងសោតធាតុវិសុទ្ធិញ្ញាណ ភិក្ខុនោះរមែងស្តាប់ឮនូវសំឡេង ២ យ៉ាង គឺសំឡេងជាទិព្វ ១ សំឡេងជារបស់មនុស្ស ១ ទាំងឆ្ងាយ ទាំងជិត ដោយសោតធាតុដូចជាទិព្វដ៏ស្អាត កន្លងនូវសោតធាតុនៃមនុស្ស ( សាមញ្ញ ) ឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញា ក្នុងការស្ទង់នូវសទ្ទនិមិត្ត មានភាពផ្សេងៗ និងមានភាពតែមួយ ដោយអំណាចនៃការផ្សាយនូវវិតក្ក ឈ្មោះថា សោតធាតុ-វិសុទ្ធិញ្ញាណ ។

## អដ្ឋកថា

## សោតធាតុវិសុទ្ធិញ្ញាណនិទ្ទេស

[ ២៥៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសោតធាតុវិសុទ្ធិញ្ញាណនិទ្ទេសដូចតទៅនេះ លោកពោលបទថា **ទូរេបិ សទ្ទានំ** ជាដើម ដើម្បីចង្អុលបង្ហាញដល់ឧបាយរបស់ភិក្ខុដែលជាអាទិកម្មិក ( អ្នកផ្តើមចម្រើនសមថៈ ) ដែលបំណងនឹងធ្វើទិព្វសោតឲ្យកើត ។

ក្នុងបទទាំងនោះ បទថា **ទូរេបិ សទ្ទានំ សទ្ទនិមិត្តំ** បានដល់ សំឡេងក្នុងរវាងនៃសំឡេងទាំងឡាយក្នុងទីឆ្ងាយ ។ ពិតហើយ សំឡេងនោះឯងជាសទ្ទនិមិត្តដោយអំណាចធ្វើជានិមិត្ត ។ សូម្បីកាលលោកពោលថា **ទូរេ** ក៏បានដល់ក្នុងទីដែលជាគន្លងនៃសំឡេងតាមប្រក្រតីនោះឯង ។ បទថា **ឱឡារិកានំ** បានដល់ សំឡេងគ្រោតគ្រាត ។ បទថា **សុខុមានំ** បានដល់ សំឡេងល្អិត ។ បទថា **សណ្ហសណ្ហានំ** បានដល់ សំឡេងល្អិតដោយសំឡេងដែលល្អិត អធិប្បាយថា សំឡេងល្អិតក្រៃលែង ។ ដោយពាក្យនោះ ឈ្មោះថា លោកពោលដល់សំឡេងដែលល្អិតក្រៃលែង ។ ភិក្ខុដែលបានឈាន ដែលជាអាទិកម្មិក បំណងនឹងញ៉ាំងញាណនេះឲ្យកើត ចូលឈានដែលជាបាទនៃអភិញ្ញាលុះចេញហើយ មានចិត្តក្នុងបរិកម្មសមាធិ មុនដំបូងគួរនឹកកាវរក ដល់សំឡេងគ្រោតគ្រាត មានសំឡេងសីហៈជាដើមក្នុងព្រៃក្នុងទីឆ្ងាយ ជាគន្លងនៃត្រចៀកតាមប្រក្រតី ។ គួរនឹកកាវរកដល់សំឡេងដែលល្អិតៗ តាមលំដាប់តាំងពីសំឡេងគ្រោតគ្រាតទាំងពួងយ៉ាងនេះ គឺសំឡេងរគាំងក្នុងវត្ត សំឡេងស្គរ

សំឡេងសង្ខ សំឡេងស្វាធ្យាយរបស់សាមណេរ និងសំឡេងភិក្ខុកំលោះដែលកំពុងស្វាធ្យាយដោយកម្លាំងទាំងអស់ មានសំឡេងជាដើមថា អ្វីលោកម្ចាស់ អ្វីអាវុសោ របស់ភិក្ខុដែលពោលពាក្យតាមប្រក្រតី សំឡេងបក្សី សំឡេងខ្យល់ សំឡេងស្បូរជើង សំឡេងទឹកពុះ សំឡេងស្លឹកត្នោតងាប់ព្រោះកំដៅថ្ងៃ សំឡេងស្រមោចខ្មៅ ស្រមោចក្រហមដើរជាដើម ។

កាលភិក្ខុធ្វើយ៉ាងនេះ គប្បីមនសិការដល់សទ្ទនិមិត្តក្នុងទិសទាំង ១០ មានទិសខាងកើតជាដើម ទិសនីមួយៗ ដោយលំដាប់តាមន័យដូចបានពោលហើយ ។ ភិក្ខុដែលមនសិការ គួរមនសិការដោយចិត្តប្រព្រឹត្តទៅក្នុងមនោទ្វារដោយការផ្ទៀងត្រចៀកតាមប្រក្រតី ក្នុងសំឡេងដែលត្រចៀកបានឮ តាមប្រក្រតី ។ សំឡេងទាំងនោះរមែងប្រាកដដល់ភិក្ខុដែលមានចិត្តជាប្រក្រតី តែប្រាកដយ៉ាងក្រៃលែង ដល់ភិក្ខុអ្នកមានចិត្តក្នុងបរិកម្មសមាធិ ។ កាលភិក្ខុមនសិការសទ្ទ-និមិត្តយ៉ាងនេះហើយ មនោទ្វារាវជ្ជនៈដែលធ្វើសំឡេងឯណានីមួយក្នុងសំឡេងទាំងនោះឲ្យជាអារម្មណ៍ រមែងកើតឡើងដោយទទួលថា ទិព្វសោតធាតុនឹងកើតក្នុងឥឡូវនេះ កាលមនោទ្វារាវជ្ជនៈនោះរលត់ហើយ ជវនចិត្ត ៤ ឬ ៥ ខណៈរមែងស្ទុះទៅ ។ បណ្ដាចិត្តដែលស្ទុះទៅទាំងនោះ ចិត្ត ៤ ឬ ៥ ខណៈដំបូងរមែងជាកាមាវចរចិត្តដែលមានឈ្មោះថា បរិកម្ម ឧបចារ អនុលោម គោត្រភូ ចិត្តខណៈទី ៤ ឬទី ៥ ជាអប្បនាចិត្តដែលប្រព្រឹត្តទៅក្នុងរូបាវចរចតុត្ថជ្ឈាន ។

បណ្ដាចិត្តទាំងនោះ ញាណដែលកើតឡើងព្រមជាមួយអប្បនាចិត្តនោះឈ្មោះថា ទិព្វសោតធាតុញាណ ។ ភិក្ខុធ្វើញាណនោះឲ្យមានកម្លាំង កំណត់

ត្រឹមតែមួយធ្នាប់ថា អញនឹងស្តាប់សំឡេងក្នុងចន្លោះនេះ ហើយគប្បីចម្រើនបន្ទាប់អំពីនោះ គប្បីចម្រើនដរាបដល់ចក្រវាល ដោយអំណាចជាដើមថា ២ ធ្នាប់ ៤ ធ្នាប់ ៨ ធ្នាប់ មួយចំអាម មួយហត្ថ ខាងក្នុងបន្ទប់ យ៉មុខ បរិវេណ ប្រាសាទ សង្ឃារាម គោចរគាម និងជនបទ ឬបន្ទាប់អំពីនោះ កំណត់ហើយកំណត់ទៀត គប្បីចម្រើនឲ្យក្រៃលែងឡើងទៅ ។ ភិក្ខុនោះសម្រេចអភិញ្ញាយ៉ាងនេះហើយ សូម្បីមិនចូលឈានជាបាទទៀត រមែងបានឮសំឡេង ដែលប្រព្រឹត្តទៅក្នុងខាងក្នុងរបស់ឱកាស ដែលពាល់ត្រូវដោយអារម្មណ៍ដែលមានឈានជាបាទដោយអភិញ្ញាញាណ ។ កាលបានឮយ៉ាងនេះ ប្រសិនបើមានកោលាហលដូចជាសំឡេងស័ង្ខ ស្គរ និងស្គរតូចជាដើមរហូតដល់ព្រហ្មលោក បើជាអ្នកប្រាថ្នាដើម្បីកំណត់ចំពោះតែម្យ៉ាង រមែងអាចកំណត់ថា នេះសំឡេងស័ង្ខ នេះសំឡេងស្គរ ។ កាលបានឮសំឡេងមានប្រយោជន៍ដោយអភិញ្ញាញាណ ភិក្ខុរមែងដឹងអត្ថដោយកាមាវចរចិត្តជាខាងក្រោយ ។ ទិព្វសោតរមែងកើតដល់ភិក្ខុដែលមានត្រចៀកជាប្រក្រតីប៉ុណ្ណោះ មិនបានកើតដល់ភិក្ខុ ដែលមានត្រចៀកថ្លង់ ។ អាចារ្យពួកមួយពោលថា បើត្រចៀកប្រក្រតីវិនាសទៅក្នុងកាលខាងក្រោយ ទិព្វសោតក៏មិនវិនាសដែរ ។

ក្នុងបទនេះថា **សោ ទិព្វាយ សោតធាតុយា** មានអធិប្បាយដូចតទៅ ឈ្មោះថា **ទិព្វ** ព្រោះដូចគ្នានឹងទិព្វ ។ ពិតហើយ បសាទសោតធាតុជាទិព្វដែលអាចទទួលអារម្មណ៍ សូម្បីក្នុងទីឆ្ងាយ ព្រោះផុតចាកឧបក្កិលេស មិនត្រូវបៀតបៀនដោយប្រមាត់ ស្លេស្ម និងឈាមជាដើម ព្រោះទេវតាទាំងឡាយ

កើតដោយកម្មដែលសុចរិត ។ ញាណសោតធាតុនេះក៏ដូចគ្នានោះឯង ព្រោះកើតដោយកម្លាំងនៃការចម្រើនសេចក្ដីព្យាយាមរបស់ភិក្ខុនេះ ព្រោះហេតុនោះទើបឈ្មោះថា **ទិព្វ** ព្រោះដូចគ្នានឹងទិព្វ ។

ម្យ៉ាងវិញទៀត ឈ្មោះថា **ទិព្វ** ព្រោះបានដោយអំណាចនៃទិព្វវិហារធម៌ និងព្រោះខ្លួនអាស្រ័យទិព្វវិហារធម៌ ឈ្មោះថា សោតធាតុ ដោយអត្ថថាស្ដាប់ និងដោយអត្ថថា មិនមានជីវៈ ។ ម្យ៉ាងទៀត ឈ្មោះថា សោតធាតុ ព្រោះអត្ថថាដូចសោតធាតុដោយការធ្វើកិច្ចនៃសោតធាតុ ។ ដោយទិព្វសោតធាតុនោះ ។

បទថា **វិសុទ្ធាយ** បានដល់ បរិសុទ្ធមិនមានឧបក្កិលេស ។ បទថា **អតិក្កន្តមានុសិកាយ** បានដល់ កន្លងឧបចារៈរបស់មនុស្ស កន្លងមំសសោតធាតុរបស់មនុស្ស ដោយការស្ដាប់សំឡេងកន្លងផុតទៅ ហើយតាំងនៅ ។ បទថា **ឧភោ សទ្ទេ សុណាតិ** បានដល់ រមែងបានឮសំឡេងពីរយ៉ាង ។ សំឡេងពីរយ៉ាង គឺអ្វី គឺទាំងសំឡេងជាទិព្វ និងសំឡេងមនុស្ស ។ មានពាក្យអធិប្បាយថា សំឡេងរបស់ទេវតានិងរបស់មនុស្ស ។ ដោយបទនេះ គប្បីជ្រាបការកាន់យកដោយមានព្រំដែន ។

បទថា **យេ ទូរេ សន្តិកេ ច** មានពាក្យអធិប្បាយថា រមែងបានឮសំឡេងក្នុងទីឆ្ងាយសូម្បីក្នុងចក្រវាលដទៃ និងក្នុងទីជិត ដោយហោចសូម្បីសំឡេងសត្វដែលនៅក្នុងកាយរបស់ខ្លួន ។ ដោយពាក្យនេះ គប្បីជ្រាបការកាន់យកដោយមិនមានព្រំដែន ដោយប្រការដូច្នេះ ។៚

**អដ្ឋកថាសោតធាតុវិសុទ្ធិញ្ញាណនិទ្ទេស ចប់**

# សុត្តន្តបិដក

[ ២៥៥ ] បញ្ហាក្នុងការស្ទង់នូវការត្រាច់ទៅ នៃវិញ្ញាណមានភាពផ្សេងៗ និងមានភាពតែមួយ ដោយអំណាចនៃបសាទរបស់ឥន្ទ្រិយទាំងឡាយ ព្រោះផ្សាយទៅនៃចិត្តទាំង ៣ ឈ្មោះថា ចេតោបរិយញ្ញាណ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ចម្រើននូវឥទ្ធិបាទដែលប្រកបដោយឆន្ទសមាធិ និងបធាន-សង្ខារ ចម្រើននូវឥទ្ធិបាទ ដែលប្រកបដោយវីរិយសមាធិ ។បេ។ ចិត្ត-សមាធិ ។បេ។ វីមំសាសមាធិ និងបធានសង្ខារ ភិក្ខុនោះអប់រំ បង្ហឹកចិត្ត ធ្វើចិត្តឲ្យទន់ គួរដល់កម្មក្នុងឥទ្ធិបាទទាំង ៤ នេះ ភិក្ខុនោះលុះអប់រំ បង្ហឹកចិត្ត ធ្វើចិត្តឲ្យទន់គួរដល់កម្មក្នុងឥទ្ធិបាទទាំង ៤ នេះហើយ រមែងដឹងយ៉ាងនេះថា រូបនេះកើតឡើងដោយសោមនស្សិន្ទ្រិយ រូបនេះកើតឡើងដោយទោមនស្សិន្ទ្រិយ រូបនេះកើតឡើងដោយឧបេក្ខិន្ទ្រិយ ភិក្ខុនោះមានចិត្តអប់រំ បរិសុទ្ធផូរផង់ ដូច្នោះហើយក៏បង្អោន បន្ទន់ចិត្តទៅក្នុងចេតោបរិយញ្ញាណ ភិក្ខុនោះរមែងកំណត់ដឹងនូវចិត្តរបស់សត្វដទៃ របស់បុគ្គលដទៃ ដោយចិត្តរបស់ខ្លួន ដឹងនូវចិត្តដែលប្រកបដោយរាគៈ ថាចិត្តប្រកបដោយរាគៈផង ដឹងនូវចិត្តដែលប្រាសចាករាគៈ ថាចិត្តប្រាសចាករាគៈផង ដឹងនូវចិត្តដែលប្រកបដោយទោសៈ ថាចិត្តប្រកបដោយទោសៈផង ដឹងនូវចិត្តដែលប្រាសចាកទោសៈផង ដឹងនូវចិត្តដែលប្រកបដោយមោហៈផង ដឹងនូវចិត្តដែលប្រាសចាកមោហៈផង នូវចិត្តដែលរួញរាផង នូវចិត្តដែលរាយមាយផង នូវចិត្តដែលជាមហគ្គតៈ គឺចិត្តដល់ភាពធំ ( បានដល់រូបាវចរ និងអរូបាវចរ ) ផង នូវចិត្តដែលមិនមែនជាមហគ្គតៈ គឺជាកាមា-វចរផង នូវចិត្តដែលមានចិត្តដទៃក្រៃលែងជាង គឺជាកាមាវចរផង នូវចិត្តដែល

មិនមានចិត្តដទៃក្រៃលែងជាង គឺរូបាវចរ និងអរូបាវចរផង នូវចិត្តដែលតាំងមាំផង នូវចិត្តដែលមិនបានតាំងមាំផង នូវចិត្តដែលរួចស្រឡះផង នូវចិត្តដែលមិនរួចស្រឡះផង នូវចិត្តដែលចុះស៊ប់ផង នូវចិត្តដែលមិនចុះស៊ប់ ថាចិត្តមិនចុះស៊ប់ផង ឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងការស្ទង់នូវការត្រាច់ទៅនៃវិញ្ញាណ មានភាពផ្សេងៗ និងមានភាពតែមួយ ដោយអំណាចនៃបសាទរបស់ឥន្ទ្រិយទាំងឡាយ ព្រោះផ្សាយទៅនៃចិត្តទាំង ៣ ឈ្មោះថា ចេតោបរិយញ្ញាណ ។

# អដ្ឋកថា
# ចេតោបរិយញ្ញាណនិទ្ទេស

[ ២៥៥ ] ក្នុងចេតោបរិយញ្ញាណនិទ្ទេស ព្រះសារីបុត្តត្ថេរលើកវិធីដែលគួរពោលឡើងសម្តែងដោយពាក្យថា **សោ ឯវំ បជានាតិ** ជាដើម ។

បទថា **ឥទំ រូបំ សោមនស្សិន្ទ្រិយសមុដ្ឋិតំ** ជាដើម ជាវិធីដែលភិក្ខុ អ្នកបានឈានដែលជាអាទិកម្មិកគួរបដិបត្តិ ។ សេចក្តីនេះដូចម្តេច ភិក្ខុអ្នកបានឈានបំណងនឹងធ្វើញាណនោះឲ្យកើតឡើង គួរធ្វើទិព្វចក្ខុញាណឲ្យកើតឡើងមុនជាលំដាប់ដំបូង ។ ព្រោះចេតោបរិយញ្ញាណនោះ រមែងសម្រេចដោយអំណាចនៃទិព្វចក្ខុ ទិព្វចក្ខុនោះ ជាបរិកម្មរបស់ចេតោបរិយញ្ញាណ ព្រោះហេតុនោះ ភិក្ខុនោះ ចម្រើនអាលោកកសិណ ឃើញពណ៌របស់លោហិត ដែលប្រព្រឹត្តទៅព្រោះអាស្រ័យហទយរូបរបស់អ្នកដទៃ ដោយទិព្វចក្ខុហើយ គប្បីស្វែងរក ( សម្លឹង ) ចិត្ត ។ ព្រោះលោហិតនោះ ( ឈាមរក្សាបេះដូង ) កាលកសលុ-សោមនស្សប្រព្រឹត្តទៅ រមែងមានពណ៌ក្រហម ដូចពណ៌ផ្លែជ្រៃទុំ ។ បើជាអកុសលសោមនស្សប្រព្រឹត្តទៅ លោហិតនោះរមែងមានពណ៌ល្អក់ ។ បើជាទោមនស្សប្រព្រឹត្តទៅ រមែងមានពណ៌ខ្មៅល្អក់ ដូចពណ៌ផ្លែព្រីងទុំ ។ បើកុសលឧបេក្ខាប្រព្រឹត្តទៅ រមែងមានពណ៌ថ្លា ដូចប្រេងល្ង ។ បើអកុសល-ឧបេក្ខាប្រព្រឹត្តទៅ លោហិតនោះរមែងល្អក់ ។ ព្រោះហេតុនោះ ភិក្ខុនោះឃើញពណ៌លោហិតក្នុងហទយៈរបស់បុគ្គលដទៃថា រូបនេះកើតដោយសោម-នស្សិន្ទ្រិយ រូបនេះកើតឡើងដោយទោមនស្សិន្ទ្រិយ រូបនេះកើតឡើងដោយ

ឧបេក្ខិន្ទ្រិយ ដូច្នេះហើយ ស្វែងរកចិត្ត គប្បីធ្វើចេតោបរិយញ្ញាណឲ្យមានកម្លាំង ។ ព្រោះកាលចេតោបរិយញ្ញាណនោះមានកម្លាំងយ៉ាងនេះ ភិក្ខុរមែងដឹងចិត្តដែលមានប្រភេទជាកាមាវចរជាដើម សូម្បីទាំងអស់ដោយលំដាប់ជាប់តាមអំពីចិត្តទៅកាន់ចិត្ត វៀរការមើលហទយរូប ។ សូម្បីក្នុងអដ្ឋកថាក៏ពោលពាក្យនេះថា សួរថា បុគ្គលបំណងនឹងដឹងចិត្តរបស់អ្នកដទៃក្នុងអរូបភព រមែងឃើញហទយរូបរបស់នរណា រមែងសម្លឹងមើលវិការនៃឥន្ទ្រិយរបស់នរណា ឆ្លើយថា មិនសម្លឹងមើលរបស់នរណាៗ នេះជាវិស័យរបស់អ្នកមានឫទ្ធិ គឺភិក្ខុនឹករាវរកចិត្តក្នុងទីណាៗ រមែងដឹងចិត្ត ១៦ ប្រភេទ ។ នេះជាកថាដោយអំណាចនៃការមិនធ្វើការប្រកាន់មាំ ។

បទថា **បរសត្តានំ** បានដល់ របស់សត្វដ៏សេស វៀរខ្លួនឯង ។ បទថា **បរបុគ្គលានំ** នេះ ក៏មានន័យដូចគ្នានឹងបទថា **បរសត្តានំ** តែលោកពោលការផ្សេងគ្នាដោយព្យញ្ជនៈ ដោយអំណាចវេនេយ្យសត្វ និងដោយការពីរោះនៃទេសនា ។ បទថា **ចេតសា ចេតោ បរិច្ច បជានាតិ** បានដល់ កំណត់ដឹងចិត្តរបស់សត្វទាំងនោះដោយចិត្តរបស់ខ្លួន ហើយដឹងដោយប្រការផ្សេងៗ ដោយអំណាចចិត្តមានរាគៈជាដើម ។ **វា** សព្ទក្នុងបទជាដើមថា **សរាគំ វា** ជាសមុច្ចយត្ថៈ គឺអត្ថថា រួបរួម ។

ក្នុងចិត្តទាំងនោះ ចិត្តដែលសហគតៈដោយលោភៈ ៨ ឈ្មោះថា ចិត្តដែលប្រកបដោយរាគៈ កុសលចិត្ត និងអព្យាកតចិត្តដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ដ៏សេស ឈ្មោះថា ចិត្តដែលប្រាសចាករាគៈ ។ ចំណែកចិត្តទាំង ៤ នេះ គឺចិត្ត

ដែលសហគតៈដោយទោមនស្ស ២ ចិត្តដែលសហគតៈដោយវិចិកិច្ឆា និង ឧទ្ធច្ចៈ ២ មិនសង្គ្រោះចូលក្នុងទុកៈនេះ ។ តែព្រះថេរៈពួកខ្លះ សង្គ្រោះចិត្តសូម្បីទាំងនេះ ដោយបទថា ចិត្តដែលប្រាសចាករាគៈ ។

ចំណែកចិត្តសហគតៈដោយទោមនស្ស ២ ឈ្មោះថា ចិត្តប្រកបដោយទោសៈ ។ កុសលចិត្ត និងអព្យាកតចិត្តដែលប្រព្រឹត្តទៅក្នុងភូមិ ៤ សូម្បីទាំងអស់ ឈ្មោះថា ចិត្តដែលប្រាសចាកទោសៈ ។ អកុសលចិត្ត ១០ ដ៏សេស មិនសង្គ្រោះចូលក្នុងទុកៈនេះ ។ តែព្រះថេរៈពួកខ្លះ សង្គ្រោះអកុសលចិត្តសូម្បីទាំងនោះ ដោយបទថា ចិត្តដែលប្រាសចាកទោសៈ ។

ក្នុងបទនេះថា **សមោហំ វីតមោហំ** ចិត្ត ២ ដែលសហគតៈដោយវិចិកិច្ឆា និងឧទ្ធច្ចៈ ដោយអំណាចមានហេតុមួយ គឺមោហៈ ឈ្មោះថា ចិត្តដែលប្រកបដោយមោហៈ ។ អកុសលចិត្តទាំង ១២ គប្បីជ្រាបថា ឈ្មោះថា ចិត្តដែលប្រកបដោយមោហៈ ព្រោះមោហៈមានក្នុងអកុសលចិត្តទាំងអស់ ។ កុសលចិត្ត និងអព្យាកតចិត្តដ៏សេស ជាចិត្តដែលប្រាសចាកមោហៈ ។ ចំណែកចិត្តដែលមានថីនមិទ្ធៈ ជាចិត្តដែលរួញរា ចិត្តដែលមានឧទ្ធច្ចៈ ជាចិត្តដែលរាយមាយ ។ រូបាវចរចិត្ត និងអរូបាវចរចិត្ត ជាចិត្តដល់ភាពធំ ។ ចិត្តដ៏សេសជាចិត្តដែលមិនមែនជាមហគ្គតៈ ។

ចិត្តប្រព្រឹត្តទៅក្នុងភូមិ ៣ ទាំងអស់ ជាចិត្តដែលមានចិត្តដទៃក្រៃលែងជាង លោកុត្តរចិត្ត ជាចិត្តដែលមិនមានចិត្តដទៃក្រៃលែងជាង ។

ចិត្តដែលដល់ឧបចារៈ និងចិត្តដែលដល់អប្បនា ជាចិត្តដែលតាំងមាំ ។

ចិត្តដែលមិនដល់ទាំងពីរយ៉ាងនោះ ជាចិត្តដែលមិនបានតាំងមាំ ។

ចិត្តដែលដល់តទង្គវិមុត្តិ វិក្ខម្ភនវិមុត្តិ សមុច្ឆេទវិមុត្តិ បដិបស្សទ្ធិវិមុត្តិ និងនិស្សរណវិមុត្តិ ជាចិត្តដែលរួចស្រឡះ ។ ចិត្តដែលមិនដល់វិមុត្តិទាំង ៥ នេះ គប្បីជ្រាបថា ជាចិត្តដែលមិនរួចស្រឡះ ។

ភិក្ខុដែលបានចេតោបរិយញ្ញាណ រមែងដឹងចិត្ត សូម្បីមានប្រភេទ ១៦ យ៉ាង ។ បុថុជ្ជនទាំងឡាយរមែងមិនដឹងមគ្គចិត្ត និងផលចិត្ត របស់ព្រះអរិយៈទាំងឡាយ ។ សូម្បីព្រះអរិយៈថ្នាក់ទាបៗ ក៏មិនដឹងមគ្គចិត្ត និងផលចិត្តរបស់ព្រះអរិយៈថ្នាក់ខ្ពស់ៗ តែព្រះអរិយៈថ្នាក់ខ្ពស់ៗ រមែងដឹងចិត្តរបស់ព្រះអរិយៈថ្នាក់ទាបៗ ដោយប្រការដូច្នេះ ។ល។

## អដ្ឋកថាចេតោបរិយញ្ញាណនិទ្ទេស ចប់

# សុត្តន្តបិដក

[ ២៥៦ ] បញ្ហាក្នុងការសួរនូវធម៌ទាំងឡាយ ដែលប្រព្រឹត្តទៅ ព្រោះបច្ច័យដោយអំណាចនៃការផ្សាយទៅនៃកម្ម ដែលមានកាលផ្សេងៗ និងមានកាលតែមួយ ឈ្មោះថា បុព្វេនិវាសានុស្សតិញ្ញាណ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ( ចម្រើននូវឥទ្ធិបាទ ) ប្រកបដោយឆន្ទសមាធិ ។បេ។ លុះធ្វើចិត្តឲ្យទន់គួរដល់កម្មហើយរមែងដឹងយ៉ាងនេះថា កាលបើធម្មជាតនេះមាន ធម្មជាតនោះក៏មានដែរ ព្រោះតែធម្មជាតនេះកើតឡើង ទើបធម្មជាតនុ៎ះកើតឡើងដែរ គឺសង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណកើតមានព្រោះសង្ខារជាបច្ច័យ នាមរូបកើតមានព្រោះវិញ្ញាណជាបច្ច័យ សឡាយតនៈកើតមានព្រោះនាមរូបជាបច្ច័យ ផស្សៈកើតមានព្រោះសឡាយតនៈជាបច្ច័យ វេទនាកើតមានព្រោះផស្សៈជាបច្ច័យ តណ្ហាកើតមានព្រោះវេទនាជាបច្ច័យ ឧបាទានកើតមានព្រោះតណ្ហាជាបច្ច័យ ភពកើតមានព្រោះឧបាទានជាបច្ច័យ ជាតិកើតមានព្រោះភពជាបច្ច័យ ជរាមរណៈកើតមានព្រោះជាតិជាបច្ច័យ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ លំបាកចិត្ត និងសេចក្តីតានតឹងចិត្តក៏កើតមានព្រម ការកើតឡើងនៃកងទុក្ខ ទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ភិក្ខុនោះមានចិត្តអប់រំ បរិសុទ្ធ ផូរផង់ដូច្នោះហើយ ក៏បង្អោន បង្អោនចិត្តទៅក្នុងបុព្វេនិវាសានុស្សតិញ្ញាណ ភិក្ខុនោះរមែងរឭកឃើញនូវបុព្វេនិវាសច្រើនយ៉ាង គឺរឭកឃើញបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ៣ ជាតិខ្លះ ៤ ជាតិខ្លះ ៥ ជាតិខ្លះ ១០ ជាតិខ្លះ ២០ ជាតិខ្លះ ៣០ ជាតិខ្លះ ៤០ ជាតិខ្លះ ៥០ ជាតិខ្លះ មួយរយជាតិខ្លះ មួយពាន់ជាតិខ្លះ មួយសែនជាតិខ្លះ អស់សំវដ្តកប្បដ៏ច្រើនខ្លះ វិវដ្តកប្បដ៏ច្រើន

ខ្លះ អស់សំវដ្តវិវដ្តកប្បដ៏ច្រើនខ្លះថា អាត្មាអញកើតហើយក្នុងទីឯណោះ មានឈ្មោះយ៉ាងនេះ មានគោត្តយ៉ាងនេះ មានវណ្ណៈយ៉ាងនេះ មានអាហារយ៉ាងនេះ បាននូវសុខ និងទុក្ខយ៉ាងនេះ មានទីបំផុតអាយុយ៉ាងនេះ អាត្មាអញនោះលុះច្យុតចាកទីនោះបានទៅកើតក្នុងទីឯណោះ កាលដែលកើតក្នុងទីនោះ អាត្មាអញមានឈ្មោះយ៉ាងនេះ មានគោត្តយ៉ាងនេះ មានវណ្ណៈយ៉ាងនេះ មានអាហារយ៉ាងនេះ បាននូវសុខ និងទុក្ខយ៉ាងនេះ មានទីបំផុតអាយុយ៉ាងនេះ អាត្មាអញនោះលុះច្យុតចាកទីនោះទើបមកកើតក្នុងទីនេះ ( ភិក្ខុនោះ ) រមែងរឭកឃើញនូវបុព្វេនិវាសច្រើនយ៉ាង ព្រមទាំងអាការ ព្រមទាំងឧទ្ទេសយ៉ាងនេះឯង ឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងការស្ទង់នូវធម៌ទាំងឡាយ ដែលប្រព្រឹត្តទៅព្រោះបច្ច័យ ដោយអំណាចនៃការផ្សាយទៅនៃកម្មមានភាពផ្សេងៗ និងមានភាពតែមួយ ឈ្មោះថា បុព្វេនិវាសានុស្សតិញ្ញាណ ។

# អដ្ឋកថា

## បុព្វេនិវាសានុស្សតិញ្ញាណនិទ្ទេស

[ ២៥៦ ] គប្បីជ្រាបវិនិច្ឆ័យ ក្នុងបុព្វេនិវាសានុស្សតិញ្ញាណនិទ្ទេសដូចតទៅ បទថា **ឯវំ បជានាតិ** ជាដើម ព្រះសារីបុត្តត្ថេរ ពោលដើម្បីសម្តែងវិធីឲ្យកើតបុព្វេនិវាសានុស្សតិញ្ញាណនោះ ដល់បុគ្គលដែលមានចិត្តអប់រំហើយក្នុងឥទ្ធិបាទ ៤ ហើយប្រាថ្នានឹងធ្វើបុព្វេនិវាសានុស្សតិញ្ញាណឲ្យកើត ។ ពិតហើយ ភិក្ខុកាលឃើញបដិច្ចសមុប្បាទដោយលំដាប់ហើយ រមែងឃើញសេចក្តីសង្ខេបនៃផល ដែលជាបច្ចុប្បន្ន ពោល គឺវិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ និងវេទនា រមែងឃើញសង្ខេបនៃហេតុ ពោលគឺកម្ម និងកិលេសក្នុងភពមុន ដែលជាបច្ច័យដល់សេចក្តីសង្ខេបនៃផលនោះ ។ រមែងឃើញសេចក្តីសង្ខេបនៃផលក្នុងភពមុន ដែលជាបច្ច័យដល់សេចក្តីសង្ខេបនៃហេតុនោះ រមែងឃើញសេចក្តីសង្ខេបនៃហេតុក្នុងភពទី ៣ ដែលជាបច្ច័យដល់សេចក្តីសង្ខេបនៃផលនោះ រមែងឃើញការបន្តនៃជាតិ ដោយការឃើញបដិច្ចសមុប្បាទយ៉ាងនេះ ។ ការមនសិការបដិច្ចសមុប្បាទ មានឧបការៈច្រើនដល់បុព្វេនិវាសា-នុស្សតិញ្ញាណ ដោយប្រការដូច្នេះ ។

ក្នុងបទទាំងនោះ បទនេះថា **ឥមស្មឹ សតិ ឥទំ ហោតិ ឥមស្សុប្បាទា ឥទំ ឧប្បជ្ជតិ** ជាពាក្យលើកឡើងពន្រ្យលសេចក្តីរបស់បដិច្ចសមុប្បាទ ។ បើសួរថា ដោយពាក្យណាមួយនៃពាក្យទាំងនោះ អត្ថក៏សម្បូរហើយ ព្រោះហេតុអ្វី ទើបពោលទុកពីរយ៉ាង ឆ្លើយថា ព្រោះមានសេចក្តីផ្សេងគ្នា

ដោយអត្ថ សេចក្ដីនេះដូចម្ដេច សេចក្ដីថា បទថា **ឥមស្មឹ សតិ** បានដល់ កាលបច្ច័យនេះមាន ។ បទនេះ ជាពាក្យពោលទូទៅដល់បច្ច័យទាំងអស់ ។ បទថា **ឥទំ ហោតិ** បានដល់ វត្ថុដែលកើតឡើងព្រោះបច្ច័យនេះរមែងមាន ។ បទនេះ ពោលទូទៅដល់វត្ថុដែលកើតឡើងព្រោះបច្ច័យទាំងអស់ ។ ដោយបទទាំងអស់នេះ ឈ្មោះថា លោកបដិសេធអហេតុកវាទហើយ ព្រោះថា ធម៌ទាំងឡាយណាកើតព្រោះបច្ច័យ មិនមែនកើតព្រោះមិនមានបច្ច័យ ធម៌ទាំងឡាយនោះ មិនឈ្មោះថា អហេតុកៈ ។

បទថា **ឥមស្សុប្បាទា** បានដល់ ព្រោះហេតុ គឺការកើតឡើងនៃបច្ច័យនេះ ។ បទនេះ ជាពាក្យសម្ដែងដល់ភាពដែលបច្ច័យទាំងអស់ មានការកើតឡើង ។ បទថា **ឥទំ ឧប្បជ្ជតិ** បានដល់ វត្ថុនេះ កើតឡើងព្រោះបច្ច័យនេះទើបកើតឡើង ។ បទនេះ ជាពាក្យសម្ដែងដល់វត្ថុ ដែលកើតឡើងអំពីបច្ច័យទាំងអស់ កើតឡើងបន្តអំពីនោះទៅ ។ ដោយពាក្យទាំងអស់នេះ ឈ្មោះថា លោកបដិសេធសស្សតវាទ និងអហេតុកវាទហើយ ព្រោះធម៌ទាំងឡាយណា មានការកើតឡើង ធម៌ទាំងឡាយនោះ មិនទៀង ព្រោះហេតុនោះ ទើបមានពាក្យអធិប្បាយថា កាលមានធម៌ដែលមានហេតុ ធម៌ទាំងនេះ មានហេតុដែលមិនទៀង ទើបមិនជាធម៌ដែលមានហេតុជាដើមថា បុរសដែលប្រក្រតីសន្ទតគ្នាថា ទៀងក្នុងលោក ។

បទថា **យទិទំ** ជាពាក្យចង្អុលបង្ហាញអត្ថដែលគួរចង្អុលបង្ហាញ ។ ក្នុងបទនេះថា **អវិជ្ជាបច្ចយា សង្ខារា** មានអធិប្បាយដូចតទៅនេះថា ផល

**អាស្រ័យវត្ថុណាកើត** វត្ថុនោះជាបច្ច័យ ។ ពាក្យថា **អាស្រ័យ** បានដល់ មិនប្រាស អធិប្បាយថា មិនលះបង់ ។ ពាក្យថា **កើត** អធិប្បាយថា រមែងកើតឡើង និងរមែងប្រព្រឹត្តទៅ ។ម្យ៉ាងទៀត មានអត្ថថាជាឧបការៈ មានអត្ថថា ជាបច្ច័យ ។ អវិជ្ជានោះផង ជាបច្ច័យផង ព្រោះហេតុនោះ ឈ្មោះថាអវិជ្ជាជាបច្ច័យ ។ ព្រោះហេតុនោះ គួរប្រកបសេចក្តីថា ព្រោះអវិជ្ជាជាបច្ច័យ ទើបមានសង្ខារ គប្បីធ្វើការប្រកប **សម្ភវន្តិ** សព្ទ ជាមួយបទដ៏សេសដោយន័យនេះ ។ ម្យ៉ាងទៀត ក្នុងបទថា **សោក** ជាដើមមានសេចក្តីដូចតទៅនេះថា ការក្រៀមក្រំចិត្ត ឈ្មោះថា **សោក** ។ ការយំរៀបរាប់ ឈ្មោះថា **បរិទេវៈ** ។ ឈ្មោះថា **ទុក្ខ** ព្រោះអត្ថថា ឲ្យដល់នូវសេចក្តីលំបាក ។ ម្យ៉ាងទៀត ឈ្មោះថា **ទុក្ខ** ព្រោះអត្ថថា ជីក ( នូវសេចក្តីសុខផ្លូវកាយ និងចិត្ត ) ដោយហេតុ ២ ប្រការ គឺការកើតឡើង និងការតាំងនៅ ។ ការទាស់ចិត្ត ឈ្មោះថា **ទោមនស្ស** ។ ការចង្អៀតចង្អល់ចិត្តយ៉ាងក្រៃលែង ឈ្មោះថា **ឧបាយាស** ។

ក្នុងបទនេះថា **សម្ភវន្តិ** បានដល់ រមែងកើត ។ បទថា **ឯវំ** ជាបទសម្តែងន័យដែលសម្តែងហើយ ។ ដោយបទនោះ ព្រះសារីបុត្តត្ថេរសម្តែងថា ដោយហេតុមានអវិជ្ជាជាដើម មិនមែនដោយលទ្ធិទាំងឡាយ មានព្រះឥសូរជាអ្នកសាងឡើងជាដើមឡើយ ។ បទថា **ឯតស្ស** បានដល់ តាមដែលបានពោលហើយ ។ បទថា **កេវលស្ស** បានដល់ មិនមានសល់ ឬដោយអស់ជើង ។ បទថា **ទុក្ខក្ខន្ធស្ស** បានដល់ កងទុក្ខមិនមែននៃសត្វ មិនមែននៃសុខ និងការ

ស្អាតជាដើមឡើយ ។ បទថា **សមុទយោ** បានដល់ ការកើតឡើង ។ បទថា **ហោតិ** បានដល់ រមែងកើតមាន ។

ក្នុងបទទាំងឡាយនោះ អវិជ្ជា តើដូចម្តេច គឺការមិនដឹងទុក្ខ មិនដឹងទុក្ខសមុទ័យ មិនដឹងទុក្ខនិរោធ មិនដឹងទុក្ខនិរោធគាមិនីបដិបទា មិនដឹងទីបំផុតខាងដើម មិនដឹងទីបំផុតខាងចុង មិនដឹងទីបំផុតខាងដើមផង ខាងចុងផង មិនដឹងធម៌ដែលអាស្រ័យគ្នាកើតឡើង គឺ **ឥទប្បច្ចយតា** ។

សង្ខារ តើដូចម្តេច គឺបុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារ អានេញ្ជាភិសង្ខារ កាយសង្ខារ វចីសង្ខារ ចិត្តសង្ខារ ។ កាមាវចរកុសលចេតនា ៨ រូបាវចរកុសលចេតនា ៥ ឈ្មោះថា បុញ្ញាភិសង្ខារ អកុសលចេតនា ១២ ឈ្មោះថា អបុញ្ញាភិសង្ខារ អរូបាវចរកុសលចេតនា ៤ ឈ្មោះថា អានេញ្ជាភិសង្ខារ ។ កាយសញ្ចេតនា ឈ្មោះថា កាយសង្ខារ វចីសញ្ចេតនា ឈ្មោះថា វចីសង្ខារ មនោសញ្ចេតនា ឈ្មោះថា ចិត្តសង្ខារ ។ ក្នុងសេចក្តីនោះ គប្បីមានពាក្យសួរថា គប្បីដឹងសេចក្តីនោះបានដូចម្តេចថា សង្ខារទាំងនេះ រមែងមានព្រោះអវិជ្ជាជាបច្ច័យ ដឹងបានព្រោះអវិជ្ជានៅមាន ព្រោះថា ការមិនដឹង ពោលគឺអវិជ្ជាក្នុងទុក្ខជាដើម ដែលភិក្ខុណាមិនទាន់លះបាន ភិក្ខុនោះប្រកាន់សង្ខារទុក្ខ ដោយសម្គាល់ថាជាសុខ ព្រោះមិនដឹងក្នុងទុក្ខ និងមិនដឹងទីបំផុតខាងដើមជាដើមមកអំពីមុន ហើយប្រារព្ធសង្ខារ ៣ យ៉ាងដែលជាហេតុនៃទុក្ខនោះ ។ ភិក្ខុសម្គាល់សង្ខារទាំងឡាយដែលជាបរិក្ខាររបស់តណ្ហាដែលជាហេតុនៃទុក្ខ ថាជាហេតុនៃសុខ ព្រោះមិនដឹងសមុទយៈ ទើបប្រារព្ធសង្ខារ ៣ យ៉ាង ។ ចំណែកភិក្ខុដែល

ជាអ្នកមានការសម្គាល់ក្នុងគតិវិសេសដែលមិនជាការរម្ងត់ទុក្ខ ថាជាការរម្ងត់ទុក្ខ ជាអ្នកមានសេចក្តីសម្គាល់ក្នុងយញ្ញ និងតបៈ ដើម្បីការមិនស្លាប់ជាដើម ដែលមិនមែនជាផ្លូវរម្ងត់ទុក្ខ ថាជាផ្លូវរម្ងត់ទុក្ខ ព្រោះមិនដឹងក្នុងនិរោធ និងមគ្គ កាលប្រាថ្នាការរម្ងត់ទុក្ខ ទើបប្រារព្ធសង្ខារ ៣ យ៉ាង ដោយប្រាថ្នាយញ្ញ និងតបៈ ដើម្បីការមិនស្លាប់ជាដើម ។

ម្យ៉ាងវិញទៀត ពោលដោយវិសេស ព្រោះអវិជ្ជាក្នុងសច្ចៈ ៤ នោះ ខ្លួនមិនទាន់លះបាន ភិក្ខុនោះកាលមិនដឹងទុក្ខ ពោលគឺផលបុណ្យសូម្បីលាយឡំដោយទោសមិនតិច មានជាតិ ជរា រោគ មរណៈជាដើម ដោយភាពជាទុក្ខ រមែងប្រារព្ធបុញ្ញាភិសង្ខារ មានកាយសង្ខារ វចីសង្ខារ និងចិត្តសង្ខារ ដើម្បីសម្រេចផលបុណ្យនោះ ដូចបុគ្គលប្រាថ្នាជាទេវតា និងទេពអប្សរ ធ្វើការលោតចូលជ្រោះដែលជាទីស្ថិតនៅនៃទេវតា ដូច្នោះ ។ កាលមិនឃើញផលបុណ្យដែលសន្មតថាជាសុខនោះ ជាទុក្ខព្រោះប្រែប្រួលដែលឲ្យកើតការក្តៅក្រហាយធំក្នុងពេលក្រោយ និងមិនឃើញផលបុណ្យនោះថា ឲ្យនូវការត្រេកអរតិច រមែងប្រារព្ធបុញ្ញាភិសង្ខារ មានប្រការដូចពោលហើយ ដែលមានផលបុណ្យនោះជាបច្ច័យ ដូចសត្វមមាចហើរចូលក្នុងគំនរភ្លើងដូច្នោះ និងដូចបុគ្គលប្រាថ្នាតំណក់ទឹកឃ្មុំប្រារព្ធការលិទ្ធមុខសស្ត្រា ដែលលាបដោយទឹកឃ្មុំដូច្នោះ ។ ម្យ៉ាងទៀត កាលមិនឃើញទោស ក្នុងការសេពកាមជាដើម រមែងប្រារព្ធអបុញ្ញាភិសង្ខារ សូម្បីប្រព្រឹត្តទៅក្នុងទ្វារ ៣ ដោយការសម្គាល់ថាជាសុខ និងដោយភាពជាអ្នកត្រូវកិលេសគ្របសង្កត់ ដូចទារកប្រារព្ធការលេងលាមក និងដូចបុគ្គលចង់ស្លាប់

ប្រព្រឹត្តការបរិភោគថ្នាំពុល ដូច្នោះ ។ កាលមិនដឹងសង្ខារថាជាទុក្ខ ព្រោះការប្រែប្រួលជាទុក្ខក្នុងវិបាកនៃអរូបភព រមែងប្រព្រឹត្តអានេញ្ជាភិសង្ខារ ដែលជាចិត្តសង្ខារដោយការឃើញខុសថាទៀងជាដើម ដូចបុគ្គលវង្វេងទិសប្រព្រឹត្តការដើរផ្លូវបែរមុខទៅកាន់នគរបិសាច ដូច្នោះ ។ ព្រោះអវិជ្ជានៅមាននោះឯង ទើបសង្ខារមាន មិនមែនព្រោះអវិជ្ជាមិនមាន ហេតុនោះ គប្បីជ្រាបសេចក្ដីនេះថា សង្ខារទាំងនេះរមែងមាន ព្រោះអវិជ្ជាជាបច្ច័យ ដោយប្រការដូច្នេះ ។

ក្នុងបទនេះ មានអ្នកសួរថា មុននេះពួកយើងប្រកាន់ថាអវិជ្ជាជាបច្ច័យដល់សង្ខារទាំងឡាយ អវិជ្ជានេះតែម្យ៉ាងប៉ុណ្ណោះ ជាបច្ច័យនៃសង្ខារទាំងឡាយឬ ឬថា បច្ច័យដទៃក៏មានដែរ សួរត្រឡប់ទៅថា អ្នកនិយាយដល់អ្វី សួរបន្តថា បើអវិជ្ជាតែម្យ៉ាងប៉ុណ្ណោះជាបច្ច័យ វាទៈថា មានហេតុតែម្យ៉ាង រមែងត្រឹមត្រូវ បើបច្ច័យដទៃមាន ការសម្ដែងដល់ហេតុតែមួយថា ព្រោះអវិជ្ជាជាបច្ច័យ ទើបមានសង្ខារដូច្នេះ នឹងមិនកើតឡើងបាន ។ មិនកើតក៏មិនមែន ។ ព្រោះហេតុអ្វី

> ព្រោះក្នុងលោកនេះ ផលតែមួយរមែងមានព្រោះហេតុតែមួយ
> ក៏ទេ ផលច្រើនយ៉ាងរមែងមាន ព្រោះហេតុតែមួយក៏ទេ ផល
> តែមួយរមែងមានព្រោះហេតុច្រើនយ៉ាងក៏ទេ តែប្រយោជន៍ក្នុង
> ការសម្ដែងហេតុមួយ និងផលមួយមាន ។

ពិតហើយ ព្រះមានព្រះភាគ ទ្រង់សម្ដែងហេតុ និងផលតែមួយប៉ុណ្ណោះ ដោយសមគួរដល់ទេសនាវិលាស និងដល់វេនេយ្យសត្វ ព្រោះជាប្រធានក្នុងទីខ្លះ ព្រោះប្រាកដច្បាស់ក្នុងទីខ្លះ ព្រោះមិនទូទៅក្នុងទីខ្លះ ព្រោះហេតុនោះ អវិជ្ជានេះ

ក្នុងទីនេះ កាលហេតុនៃសង្ខារទាំងឡាយ មានវត្ថុ អារម្មណ៍ និងសហជាតធម៌ជាដើម ពួកដទៃសូម្បីមាន គប្បីជ្រាបថា លោកសម្តែងដោយភាពជាហេតុនៃសង្ខារទាំងឡាយព្រោះភាពជាប្រធាន គឺជាហេតុនៃហេតុនៃសង្ខារ មានតណ្ហាជាដើមសូម្បីពួកដទៃ ដោយបាលី ( ក្នុងសំយុត្តនិកាយ និទានវគ្គ ) ថា **អស្សាទានុបស្សិនោ វិហរតោ តណ្ហា បវឌ្ឍតិ** កាលភិក្ខុពិចារណាឃើញនូវសេចក្តីត្រេកអរ តណ្ហារមែងចម្រើនឡើង និង ( ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសក ) ថា **អវិជ្ជា សមុទយា អាសវសមុទយោ** សេចក្តីកើតឡើងនៃអាសវៈព្រោះសេចក្តីកើតឡើងនៃអវិជ្ជា ដូច្នេះ ។ ព្រោះប្រាកដច្បាស់ និងព្រោះមិនទូទៅ ដោយព្រះបាលីថា ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនដឹង ត្រូវអវិជ្ជាគ្របសង្កត់ រមែងតាក់តែងបុញ្ញាភិសង្ខារខ្លះ ។ គប្បីជ្រាបប្រយោជន៍ក្នុងការសម្តែងហេតុ និងផលទីមួយៗ ក្នុងទីទាំងពួង ដោយពាក្យអធិប្បាយដែលសម្តែងហេតុ និងផលទីមួយៗ នោះឯង ។ ក្នុងបទនេះមានអ្នកសួរថា កាលបើយ៉ាងនោះ ភាពដែលអវិជ្ជាមានផល មិនគួរប្រាថ្នាដោយចំណែកមួយ និងមានទោសជាបច្ច័យ នៃបុញ្ញាភិសង្ខារ និងអានេញ្ជាភិសង្ខារ តើត្រឹមត្រូវបានដូចម្តេច ព្រោះអំពៅមិនកើតអំពីពូជស្តៅ ឆ្លើយថា មិនត្រឹមត្រូវបានដូចម្តេច ព្រោះក្នុងលោក

បច្ច័យនៃសភាវធម៌ទាំងឡាយ ដែលសម្រេចផល ខុសគ្នាក៏មាន
ដូចគ្នាក៏មាន ម្យ៉ាងទៀត ដូចគ្នា និងមិនដូចគ្នាក៏មាន តែ
សភាវធម៌ទាំងនោះ មិនមែនវិបាក ( នៃបច្ច័យនោះ ) ទេ ។

ដោយប្រការដូច្នេះ គប្បីជ្រាបថា អវិជ្ជានេះ មានផលមិនគួរប្រាថ្នា ដោយ

ចំណែកមួយ ដោយអំណាចវិបាក សូម្បីមានទោសដោយអំណាចសភាវៈ ក៏នៅតែជាបច្ច័យដល់បុញ្ញាភិសង្ខារជាដើមនោះ ដោយអំណាចជាបច្ច័យ ដែលខុសគ្នា និងដូចគ្នាដោយឋានៈ កិច្ច និងសភាវៈ និងដោយអំណាចជាបច្ច័យដូចគ្នា និងមិនដូចគ្នា ។

ម្យ៉ាងវិញទៀត

> បុគ្គលណា វង្វេងក្នុងសង្សារ ដែលមានចុតិ និងឧប្បត្តិក្នុងលក្ខណៈនៃសង្ខារទាំងឡាយ និងក្នុងធម៌ ដែលអាស្រ័យគ្នាកើតឡើងបុគ្គលនោះ រមែងតាក់តែងសង្ខារទាំង ៣ នោះ ព្រោះអវិជ្ជាជាបច្ច័យនៃសង្ខារទាំង ៣ នោះ ដូចបុគ្គលខ្វាក់ភ្នែកពីកំណើតមិនមានអ្នកនាំទៅ ជួនកាលក៏ទៅត្រូវផ្លូវ ជួនកាលក៏ទៅខុសផ្លូវយ៉ាងណា បុគ្គលពាល កាលត្រាច់ទៅក្នុងសង្សារ មិនមានអ្នកដឹកនាំក៏យ៉ាងនោះ ជួនកាលក៏ធ្វើបុណ្យ ជួនកាលក៏ធ្វើបាប កាលបើបុគ្គលនោះដឹងធម៌ហើយ ត្រាស់ដឹងអរិយសច្ច កាលនោះ នឹងត្រាច់ទៅយ៉ាងស្ងប់ ព្រោះអវិជ្ជាស្ងប់ ។

បទថា **សង្ខារប្បច្ចយា វិញ្ញាណំ** សេចក្តីថា កងវិញ្ញាណមាន ៦ គឺចក្ខុវិញ្ញាណ ១ សោតវិញ្ញាណ ១ ឃានវិញ្ញាណ ១ ជិវ្ហាវិញ្ញាណ ១ កាយវិញ្ញាណ ១ មនោវិញ្ញាណ ១ ។ ក្នុងវិញ្ញាណទាំងនោះ ចក្ខុវិញ្ញាណមាន ២ គឺកុសលវិបាក ១ អកុសលវិបាក ១ ។ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណក៏ដូចគ្នា ។ មនោវិញ្ញាណមាន ២២ គឺវិបាកមនោធាតុ

២ អហេតុកមនោវិញ្ញាណធាតុ ៣ សហេតុកវិបាកចិត្ត ៨ រូបាវចរវិបាកចិត្ត ៥ អរូបាវចរវិបាកចិត្ត ៤ ។ វិញ្ញាណទាំងអស់ ជាលោកិយវិបាកវិញ្ញាណ ៣២ ដោយប្រការដូច្នេះ ។

ក្នុងសេចក្តីនោះគប្បីមានពាក្យសួរថា គប្បីដឹងបានយ៉ាងណាថា វិញ្ញាណមានប្រការដូចពោលមកនេះ មានព្រោះសង្ខារជាបច្ច័យ គប្បីឆ្លើយថា ព្រោះកាលមិនមានការសន្សំកម្ម វិបាកក៏មិនមាន ។ វិញ្ញាណនោះជាវិបាក វិបាកនេះរមែងមិនកើតឡើង ព្រោះការមិនមានកម្មដែលសន្សំ ។ បើគប្បីកើតឡើង វិបាកទាំងអស់គប្បីកើតឡើងដល់សត្វគ្រប់ពួក តែវិបាកទាំងអស់ រមែងមិនកើតឡើង ព្រោះហេតុនោះ គប្បីដឹងសេចក្តីនេះថា ព្រោះសង្ខារជាបច្ច័យ ទើបមានវិញ្ញាណ ។ ពិតហើយ វិញ្ញាណទាំងអស់នេះ រមែងប្រព្រឹត្តទៅ ២ ប្រការ គឺបវត្តិកាល និងបដិសន្ធិកាល ។ ក្នុងវិញ្ញាណទាំងនោះ វិញ្ញាណទាំង ១៣ នេះ គឺទ្វិបញ្ចវិញ្ញាណ មនោវិញ្ញាណធាតុ ២ អហេតុកមនោវិញ្ញាណធាតុ ដែលសហគតៈដោយសោមនស្ស ១ រមែងប្រព្រឹត្តទៅក្នុងបវត្តិកាលប៉ុណ្ណោះ ក្នុងបញ្ចវោការភព វិញ្ញាណ ១៩ ដ៏សេស រមែងប្រព្រឹត្តទៅក្នុងបវត្តិកាលខ្លះ ក្នុងបដិសន្ធិកាលខ្លះ តាមសមគួរក្នុងភព ៣ ។

វិញ្ញាណនេះ ត្រឹមតែជាធម៌បានបច្ច័យ ហើយរមែងចូលដល់ភព
ដទៃដោយប្រការដូច្នេះ ការឃ្លាតទៅមកអំពីភព រមែងមិនមាន
ដល់វិញ្ញាណនោះ វិញ្ញាណវៀរហេតុអំពីភពនោះក៏មិនមាន ។

វិញ្ញាណនេះដែលបានបច្ច័យហើយ ដោយប្រការដូច្នេះ ត្រឹមតែជារូបធម៌

និងអរូបធម៌ កាលកើតឡើង លោកហៅថា រមែងចូលដល់ភពដទៃ មិនមែនសត្វ មិនមែនជីវៈ ។ ម្យ៉ាងទៀត ការឃ្លាតចាកភពក្នុងអតីត មកក្នុងភពនេះ របស់វិញ្ញាណនោះ ក៏មិនមានការប្រាកដរបស់វិញ្ញាណក្នុងលោកនេះ វៀរហេតុអំពីភពអតីត ក៏មានមិនបាន ។ ម្យ៉ាងទៀត ក្នុងវិញ្ញាណដែលប្រព្រឹត្តទៅនេះ វិញ្ញាណមុន ហៅថា ចុតិវិញ្ញាណ ព្រោះឃ្លាតទៅ វិញ្ញាណក្រោយ ហៅថា បដិសន្ធិវិញ្ញាណ ព្រោះបន្តក្នុងខាងដើមនៃភពថ្មី ។

ក្នុងពាក្យនេះមានអ្នកសួរថា កាលមានការប្រាកដដោយមិនបានឃ្លាតមកយ៉ាងនេះ ផលនោះគប្បីមានដល់វត្ថុដទៃ និងអំពីវត្ថុដទៃ ព្រោះខន្ធក្នុងអត្តភាពមនុស្សនេះរលត់ទៅ និងព្រោះកម្មដែលជាបច្ច័យនៃផល មិនទៅក្នុងទីដែលកើតនៃផលនោះ មិនមែនឬ ម្យ៉ាងទៀត កាលមិនមានអ្នកសោយផល ផលគប្បីមានដល់អ្នកណា ព្រោះហេតុនោះ ទើបសេចក្តីនេះមិនល្អ ។

ក្នុងសេចក្តីនេះ ខ្ញុំនឹងឆ្លើយដូចតទៅ

ផលណា ក្នុងសន្តាន ផលនេះ មិនមែនមានដល់អ្នកដទៃ
និងមិនមានពីកម្មដទៃ ការតាក់តែងពូជទាំងឡាយ ជាការ
ពិសោធក្នុងសេចក្តីនេះ ។

ការសន្មតថា មានអ្នកទទួល រមែងជាការសម្រេចបានដោយ
ការកើតឡើងនៃផល ក៏ដូចគ្នានឹងការសន្មតថា មានផលដែល
សម្រេចបានដោយការកើតឡើងនៃផលរបស់ដើមឈើដូច្នោះ ។

បុគ្គលណា គប្បីពោលថា កាលបើយ៉ាងនេះ សង្ខារទាំងនេះមាន គប្បីជា

បច្ច័យដល់ផល ឬកាលមិនមាន ក៏គប្បីជាបច្ច័យដល់ផលបាន បើសង្ខារទាំងនោះមាន គប្បីជាបច្ច័យបានសោត វិបាកនៃសង្ខារទាំងនោះ ក៏គប្បីមានក្នុងបវត្តិក្ខណៈនោះឯង បើមិនមានក៏គប្បីជាបច្ច័យបានសោត សង្ខារទាំងឡាយគប្បីនាំផលមកជានិច្ច ទាំងមុន និងក្រោយបវត្តិក្ខណៈ ។ គប្បីឆ្លើយនឹងបុគ្គលនោះយ៉ាងនេះថា

សង្ខារទាំងនេះជាបច្ច័យ ព្រោះធ្វើផលឡើង មិនមែននាំមកនូវផលជានិច្ចឡើយ ក្នុងរឿងនោះ គប្បីជ្រាបរឿងអ្នកជានាជាដើមជាគំរូ ។

ក្នុងពាក្យនេះថា **វិញ្ញាណប្បច្ចយា នាមរូបំ** សេចក្តីថា ខន្ធ គឺវេទនា សញ្ញា សង្ខារជានាម មហាភូតរូប ៤ និងរូបអាស្រ័យមហាភូតរូប ៤ ជារូប ។ ធម៌ទាំង ២៣ នេះ បានដល់ រូប ២០ គឺវត្ថុទសកៈ កាយទសកៈ និងអរូបក្ខន្ធ ៣ ក្នុងខណៈនៃបដិសន្ធិរបស់សត្វដែលកើតក្នុងផ្ទៃដែលមិនមានភាវ-រូប និងសត្វដែលកើតក្នុងស៊ុត គប្បីជ្រាបថា ព្រោះវិញ្ញាណជាបច្ច័យ ទើបមាននាមរូប ។ បន្ថែមភាវទសកៈនៃសត្វដែលមានភាវរូប ទើបជាធម៌ ៣៣ ។ ធម៌ទាំង ៤២ នេះ បានដល់ រូប ៣៩ គឺចក្ខុទសកៈ សោតទសកៈ វត្ថុទសកៈ និងជីវិតិន្ទ្រិយនវកៈ និងអរូបក្ខន្ធ ៣ ក្នុងខណៈនៃបដិសន្ធិ របស់ព្រហ្មកាយិកាជាដើម បណ្តាសត្វដែលជាឱបបាតិកៈទាំងឡាយ គប្បីជ្រាបថា ព្រោះវិញ្ញាណជាបច្ច័យ ទើបមាននាមរូប ។ម្យ៉ាងទៀត ក្នុងកាមភពធម៌ទាំង ៧៣ នេះ បានដល់ រូប ៧០ គឺចក្ខុទសកៈ សោតទសកៈ ឃានទសកៈ ជិវ្ហាទសកៈ កាយ-

ទសកៈ វត្ថុទសកៈ ភាវទសកៈ និងអរូបក្ខន្ធ ៣ ក្នុងខណៈបដិសន្ធិរបស់ឱប-បាតិកៈក្តី សំសេទជៈក្តី ដែលមានភាវៈ និងមានអាយតនៈបរិបូរណ៍ គប្បីជ្រាបថា ព្រោះវិញ្ញាណជាបច្ច័យទើបមាននាមរូប ។ នេះជាការកំណត់យ៉ាងឧក្រិដ្ឋ ។ តែដោយការកំណត់យ៉ាងទាប គប្បីជ្រាបការរាប់នាមរូប ព្រោះវិញ្ញាណជាបច្ច័យក្នុងបដិសន្ធិដោយបន្ថយចំនួនចុះមក ដោយអំណាចនៃភាពមិនប្រក្រតី របស់ទសកៈនោះៗ នៃនាមរូបនោះៗ ។ ចំណែកក្នុងបដិសន្ធិរបស់ពួកអរូបព្រហ្ម មានចំពោះអរូបក្ខន្ធ ៣ ប៉ុណ្ណោះ ក្នុងបដិសន្ធិរបស់ពួកអសញ្ញីសត្វ មានចំពោះជីវិតិន្ទ្រិយនវកៈដោយរូបប៉ុណ្ណោះឯង ។ ន័យក្នុងបដិសន្ធិមានប្រមាណប៉ុណ្ណេះ ។

ក្នុងភាពដែលវិញ្ញាណជាបច្ច័យនៃនាមរូបនោះ គប្បីមានពាក្យសួរថា សេចក្តីនេះថា នាមរូបក្នុងបដិសន្ធិរមែងមានព្រោះវិញ្ញាណជាបច្ច័យ គប្បីដឹងបានដូចម្តេច គប្បីដឹងបានដោយសូត្រ និងដោយភាពត្រឹមត្រូវ ។ ពិតហើយ ក្នុងសូត្រភាពដែលវេទនាជាដើមមានវិញ្ញាណជាបច្ច័យ ជាទីទទួលដោយចំណែកច្រើនតាមន័យ ( ក្នុងអភិធម្ម ធម្មសង្គណិ ) ជាដើមថា ពួកធម៌ប្រព្រឹត្តទៅតាមចិត្ត ដូច្នេះ ។ តែដោយភាពត្រឹមត្រូវ

ពាក្យថា វិញ្ញាណជាបច្ច័យដល់រូប សូម្បីដែលមើលមិនឃើញ
ដូច្នេះ រមែងសម្រេចបានដោយចិត្តជរូប ដែលមើលឃើញបាន
ក្នុងលោកនេះ ។

នាមក្នុងបទថា **នាមរូបប្បច្ចយា សឡាយតនំ** បានពោលហើយ ។ តែរូបក្នុងទីនេះ ដោយនិយមមាន ១១ យ៉ាង គឺមហាភូតរូប ៤ វត្ថុ ៦

ជីវិតិន្ទ្រិយ ១ ។ អាយតនៈ ៦ គឺចក្ខាយតនៈ ១ សោតាយតនៈ ១ ឃានាយតនៈ ១ ជិវ្ហាយតនៈ ១ កាយាយតនៈ ១ មនាយតនៈ ១ ។

ក្នុងបទថា **នាមរូបប្បច្ចយា សឡាយតនំ** នោះ គប្បីមានពាក្យសួរថា សេចក្តីនេះថា នាមរូបជាបច្ច័យដល់សឡាយតនៈ គប្បីដឹងបានដូចម្តេច ឆ្លើយថា ដឹងបានព្រោះកាលនាមរូបមាន ទើបសឡាយតនៈមាន ។ ពិតហើយ អាយតនៈនោះៗ រមែងមានព្រោះនាម និងរូបនោះៗ មាន មិនមែនមាន ដោយប្រការដទៃ ។

បទថា **សឡាយតនប្បច្ចយា ផស្សោ** សេចក្តីថា

ផស្សៈយ៉ាងសង្ខេប មាន ៦ យ៉ាង មានចក្ខុសម្ផស្សជាដើម
ផស្សៈទាំងនោះ ដោយពិស្តារមាន ៣២ យ៉ាងដូចវិញ្ញាណ ។

បទថា **ផស្សប្បច្ចយា វេទនា** សេចក្តីថា

លោកពោលវេទនា មានចក្ខុសម្ផស្សជាវេទនាជាដើម ដោយទ្វារ មាន ៦ ប៉ុណ្ណោះ វេទនាទាំងនោះ ដោយប្រភេទ ក្នុងទីនេះ មាន ៣២ ។

បទថា **វេទនាបច្ចយា តណ្ហា** សេចក្តីថា

ក្នុងទីនេះ លោកសម្តែងតណ្ហា ៦ យ៉ាង ដោយប្រភេទ មានរូបតណ្ហាជាដើម ក្នុងតណ្ហាទាំងនោះ តណ្ហានីមួយៗ មាន ៣ យ៉ាង ដោយអាការដែលប្រព្រឹត្តទៅ ។

អ្នកមានទុក្ខ រមែងប្រាថ្នាសេចក្តីសុខ អ្នកមានសេចក្តីសុខ

រមែងប្រាថ្នាឲ្យមានសេចក្ដីសុខក្រៃលែងឡើង ចំណែកឧបេក្ខា លោកពោលថា ជាសុខនោះឯង ព្រោះស្ងប់ ។

ព្រោះហេតុនោះ ទើបវេទនាទាំង ៣ យ៉ាង ជាបច្ច័យដល់តណ្ហា ទើបព្រះមានព្រះភាគ អ្នកស្វែងរកគុណធំត្រាស់ថា ព្រោះមានវេទនាជាបច្ច័យ ទើបមានតណ្ហា ។

បទថា **តណ្ហាបច្ចយា ឧបាទានំ** សេចក្ដីថា ឧបាទាន ៤ គឺកាមុបាទាន ១ ទិដ្ឋុបាទាន ១ សីលព្វតុបាទាន ១ អត្តវាទុបាទាន ១ ។

បទថា **ឧបាទានប្បច្ចយា ភវោ** ក្នុងទីនេះ លោកបំណងយកកម្មភព ។ តែលោកពោលឧបបត្តិភព ដោយបំណងដល់សត្វ ។

បទថា **ភវប្បច្ចយា ជាតិ** បានដល់ សេចក្ដីប្រាកដនៃបដិសន្ធិក្ខន្ធ មានព្រោះកម្មភពជាបច្ច័យ ។

ក្នុងបទនោះ ប្រសិនបើមានពាក្យសួរថា សេចក្ដីនេះថា ភពជាបច្ច័យដល់ជាតិ គប្បីដឹងបានដូចម្ដេច ឆ្លើយថា ដឹងបានព្រោះប្រាកដភាពផ្សេងគ្នា មានថោកទាប និងប្រណីតជាដើម សូម្បីមានការស្មើគ្នានៃបច្ច័យខាងក្រៅ ។ សត្វទាំងឡាយសូម្បីជាកូនភ្លោះ រមែងប្រាកដភាពផ្សេងគ្នា មានថោកទាប និងប្រណីតជាដើម សូម្បីមានការស្មើគ្នានៃបច្ច័យខាងក្រៅ មានសុក្កៈរបស់បិតា ឈាមរបស់មាតា និងអាហារជាដើម ។ ការផ្សេងគ្នានោះ មិនមែនជាអហេតុកៈ ព្រោះមិនមានក្នុងកាលទាំងពួង និងដល់សត្វទាំងពួង មិនមែនហេតុដទៃ ក្រៅអំពីកម្មភព ព្រោះមិនមានហេតុដទៃក្នុងសន្តានខាងក្នុងរបស់សត្វ ដែលកើត

ក្នុងកម្មភពនោះ ព្រោះហេតុនោះ ទើបឈ្មោះថា មានកម្មភពជាហេតុ ។ ពិតហើយ កម្មជាហេតុនៃការផ្សេងគ្នា មានភាពថោកទាប និងប្រណីតជាដើមរបស់សត្វទាំងឡាយ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ ( ក្នុងមជ្ឈិមនិកាយ ឧបរិបណ្ណាសក ) ថា **កម្មំ សត្តេ វិភជតិ យទិទំ ហីនប្បណីតតាយ** កម្មតែងចែកសត្វទាំងឡាយ ដើម្បីឲ្យថោកទាប និងខ្ពង់ខ្ពស់ ដូច្នេះ ។

ក្នុងបទថា **ជាតិប្បច្ចយា ជរាមរណំ** ជាដើម មានអធិប្បាយដូចតទៅនេះថា ព្រោះកាលមិនមានជាតិ ជរាមរណៈ ឬធម៌ មានសោកជាដើមក៏មិនមាន តែកាលបើមានជាតិ ជរាមរណៈ និងធម៌ទាំងឡាយ មានសោកជាដើម ដែលទាក់ទងជាមួយជរាមរណៈ រមែងមានដល់បុគ្គលពាលដែលត្រូវទុក្ខធម៌ ពាល គឺជរាមរណៈពាល់ត្រូវហើយ ឬដែលមិនទាក់ទងនឹងជរាមរណៈ រមែងមានដល់បុគ្គលពាលដែលត្រូវទុក្ខធម៌នោះៗ ពាល់ត្រូវហើយ ហេតុនោះ គប្បីជ្រាបថា ជាតិជាបច្ច័យដល់ជរាមរណៈ និងដល់ធម៌ទាំងឡាយ មានសោកជាដើម ។

ក្នុងបទថា **សោ តថា ភាវិតេន ចិត្តេន** ជាដើម គប្បីជ្រាបអធិប្បាយដូចតទៅនេះ បទថា **បុព្វេនិវាសានុស្សតិញ្ញាណាយ** លោកអធិប្បាយថា ដើម្បីសម្រេច គឺដល់ញាណនោះ ។ បទថា **អនេកវិហិតំ** បានដល់ ច្រើនយ៉ាង គឺច្រើនប្រការ ឬអធិប្បាយថា ឲ្យប្រព្រឹត្តទៅហើយ ពណ៌នាហើយដោយប្រការមិនតិច ។

បទថា **បុព្វេនិវាសំ** បានដល់ សន្តានដែលនៅក្នុងជាតិនោះៗ ធ្លើកពក្នុងអតីតដែលជិតបំផុតឲ្យជាខាងដើម ។ បទថា **អនុស្សរតិ** បានដល់ រឭកទៅ

ដោយអំណាចលំដាប់ខន្ធ ឬដោយអំណាចចុតិបដិសន្ធិ ។ ពិតហើយ ជនទាំង ៦ គឺតិត្ថិយ ១ សាវកធម្មតា ១ មហាសាវក ១ អគ្គសាវក ១ ព្រះបច្ចេកពុទ្ធ ១ ព្រះសម្ពុទ្ធ ១ រមែងរឭកដល់ជាតិមុនបាន ។

ក្នុងជនទាំងនោះ តិត្ថិយទាំងឡាយ រមែងរឭកបាន ៤០ កប្បប៉ុណ្ណោះ មិនច្រើនជាងនោះ ។ ព្រោះហេតុអ្វី ព្រោះតិត្ថិយមានកម្លាំងបញ្ញាតិច ពិតហើយ បញ្ញារបស់តិត្ថិយទាំងនោះមានកម្លាំងតិច ព្រោះមិនមានការកំណត់នាមរូប ។ សាវកធម្មតារមែងរឭកបាន ១០០ កប្បខ្លះ ១០០០ កប្បខ្លះ ព្រោះមានបញ្ញាក្លៀវក្លា ។ មហាសាវក ៨០ រូប រឭកបាន ១ សែនកប្ប ។ អគ្គសាវកទាំងពីររឭកបាន ១ អសង្ខេយ្យ និង ១ សែនកប្ប ។ ព្រះបច្ចេកពុទ្ធរឭកបាន ២ អសង្ខេយ្យ និង ១ សែនកប្ប ព្រោះអភិនីហាររបស់ព្រះបច្ចេកពុទ្ធទាំងនោះមានប្រមាណត្រឹមនេះ ។ តែព្រះសម្ពុទ្ធទាំងឡាយ រឭកបានមិនមានកំណត់ ។

ម្យ៉ាងទៀត តិត្ថិយទាំងឡាយ រឭកបានតាមលំដាប់ខន្ធប៉ុណ្ណោះ កន្លងលំដាប់ទៅ មិនអាចរឭកដោយអំណាចចុតិ និងបដិសន្ធិបានឡើយ ។ តិត្ថិយទាំងនោះ រឭកបានមិនរំលងលំដាប់ខន្ធ ដូចមនុស្សខ្វាក់ក្អែកដើរទៅ មិនលះបង់ឈើច្រត់ ដូច្នោះ ។

សាវកធម្មតារឭកបានតាមលំដាប់ខន្ធ រមែងឈានទៅដោយអំណាចចុតិ-បដិសន្ធិ ។ មហាសាវក ៨០ រូបក៏យ៉ាងនោះ ។ ចំណែកអគ្គសាវកទាំងពីរមិនមានកិច្ចត្រូវរឭកតាមលំដាប់ខន្ធ រមែងឈានទៅដោយអំណាចចុតិ និងបដិសន្ធិយ៉ាងនេះ គឺឃើញចុតិរបស់អត្តភាពមួយហើយ រមែងឃើញបដិសន្ធិ

ឃើញចុតិរបស់អត្តភាពដទៃ ហើយក៏ឃើញបដិសន្ធិទៀត ព្រះបច្ចេកពុទ្ធក៏ដូចគ្នា ។ ចំណែកព្រះពុទ្ធទាំងឡាយ មិនមានកិច្ចត្រូវព្ចកតាមលំដាប់ខន្ធ មិនមានកិច្ចត្រូវព្ចកឈានទៅដោយអំណាចចុតិ និងបដិសន្ធិ ព្រោះថា ព្រះពុទ្ធទាំងឡាយ ទ្រង់ប្រាថ្នាឋានៈណាៗ ខាងក្រោម គឺអតីតក្តី ខាងលើ គឺអនាគតក្តី ក្នុងកោដិនៃកប្បមិនមែនតិច ឋានៈនោះៗ រមែងប្រាកដបាននោះឯង ព្រោះហេតុនោះ ព្រះពុទ្ធទាំងឡាយទ្រង់សង្ខេបកោដិនៃកប្បមិនមែនតិច ហើយប្រាថ្នាឋានៈណាៗ ទ្រង់ឈានចូលទៅក្នុងឋានៈនោះៗ ដោយអំណាចនៃការឈានទៅដូចជាសីហៈ ។ ញាណរបស់ព្រះពុទ្ធទាំងនោះ ប្រព្រឹត្តទៅហើយយ៉ាងនេះ មិនទើសទាក់ក្នុងជាតិ ក្នុងចន្លោះៗ រមែងកាន់យកឋានៈដែលទ្រង់ប្រាថ្នា ។

កាលជនទាំង ៦ នេះ រព្ចកដល់ជាតិមុនហើយ ការឃើញជាតិមុនរបស់ពួកតិរ្ថិយ រមែងប្រាកដដូចគ្នានឹងពន្លឺអំពិលអំពែក របស់សាវកធម្មតាដូចគ្នានឹងពន្លឺប្រទីប របស់មហាសាវកដូចគ្នានឹងពន្លឺគប់ភ្លើង របស់ព្រះអគ្គសាវកដូចគ្នានឹងរស្មីផ្កាយព្រឹក របស់ព្រះបច្ចេកពុទ្ធដូចគ្នានឹងរស្មីព្រះចន្ទ របស់ព្រះពុទ្ធដូចគ្នានឹងមណ្ឌលព្រះអាទិត្យក្នុងសរទកាល ប្រដាប់ដោយរស្មីមួយពាន់ ។

ការរព្ចកដល់ជាតិមុនរបស់តិរ្ថិយ ដូចមនុស្សខ្វាក់ភ្នែក ដើរទៅដោយចុងឈើច្រត់ ។ របស់សាវកធម្មតា ដូចដើរទៅតាមស្ពានដែលធ្វើដោយឈើ ។ របស់ព្រះមហាសាវកដូចដើរទៅតាមស្ពានដែលមនុស្សដើរ ។ របស់ព្រះអគ្គសាវក ដូចដើរទៅតាមស្ពានរទេះ ។ របស់ព្រះបច្ចេកពុទ្ធ ដូចដើរទៅតាមផ្លូវដើរ ។ របស់ព្រះពុទ្ធ ដូចដើរទៅតាមផ្លូវរទេះធំ ។ ក្នុងអធិការនេះ លោក

បំណាចយកការរឭកដល់ជាតិមុន របស់ព្រះសាវកទាំងឡាយ ។

ព្រោះហេតុនោះ ភិក្ខុដែលជាអាទិកម្មិកបំណាចរឭកយ៉ាងនេះ ត្រឡប់អំពីបិណ្ឌបាត ឆាន់អាហារហើយ ទៅក្នុងទីស្ងាត់ចូលឈាន ៤ តាមលំដាប់ លុះចេញចាកចតុត្ថជ្ឈាន ដែលជាបាទនៃអភិញ្ញាហើយ ពិចារណាបដិច្ចសមុប្បាទដោយន័យដូចពោលហើយ នឹកគិតដល់ការអង្គុយចុងក្រោយ ។ បន្ទាប់អំពីនោះ គប្បីនឹកដល់កិច្ចដែលធ្វើអស់យប់ និងថ្ងៃ ដោយប្រាសលំដាប់យ៉ាងនេះ គឺការក្រាលអាសនៈ ការចូលទៅកាន់សេនាសនៈ ការទុកបាត្រចីវរ ពេលឆាន់ ពេលត្រឡប់មកអំពីស្រុក ពេលត្រាច់ទៅបិណ្ឌបាតក្នុងស្រុក ពេលចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ពេលចេញអំពីវត្ត ពេលថ្វាយបង្គំចេតិយ និងពោធិព្រឹក្ស ពេលលាងបាត្រ ពេលទទួលបាត្រ កិច្ចដែលធ្វើតាំងអំពីទទួលបាត្ររហូតដល់លុបមុខ កិច្ចដែលធ្វើក្នុងពោលទៀបភ្លឺ កិច្ចដែលធ្វើក្នុងមជ្ឈិមយាមក្នុងបឋមយាម ។ កិច្ចប្រមាណប៉ុណ្ណោះរមែងប្រាកដដល់សូម្បីដល់ចិត្តប្រក្រតី ។

ចំណែកចិត្តក្នុងបរិកម្មសមាធិ រមែងប្រាកដក្រៃលែងឡើងទៅ បើមិនមានអ្វីៗ ប្រាកដក្នុងចិត្តនេះ គួរចូលឈានជាបាទទៀត លុះចេញហើយ នឹកគិតម្តងទៀត ដោយហេតុមានប្រមាណប៉ុណ្ណោះ កិច្ចរមែងប្រាកដ ដូចប្រាកដក្នុងប្រទីបដែលមានពន្លឺ ។ គួរនឹកគិតដល់កិច្ចដែលធ្វើហើយ ក្នុងថ្ងៃទី ២ ខ្លះ ក្នុងថ្ងៃទី ៣ ទី ៤ ទី ៥ ទី ១០ ខ្លះ ក្នុងកន្លះខែខ្លះ ក្នុងមួយខែខ្លះ ក្នុងមួយឆ្នាំខ្លះដោយប្រាសលំដាប់យ៉ាងនោះឯង ។ ដោយឧបាយនេះ ភិក្ខុនឹកគិតរហូតដល់បដិសន្ធិរបស់ខ្លួនក្នុងភពនេះ គឺ ១០ ឆ្នាំ ២០ ឆ្នាំ គប្បីនឹកគិតដល់នាមរូបដែលប្រព្រឹត្ត

ទៅក្នុងខណៈចុតិក្នុងភពមុន ។

ពិតហើយ ភិក្ខុដែលឈ្លាស រមែងអាចបើកបដិសន្ធិដោយវារៈដំបូងបាន ហើយធ្វើនាមរូបក្នុងខណៈចុតិឲ្យជាអារម្មណ៍ ព្រោះនាមរូបក្នុងភពមុន រលត់មិនមានសេសសល់ នាមរូបដទៃកើតឡើងក្នុងភពនេះ ហេតុនោះ ទើបឋានៈនោះដូចជាផ្លូវបិទជិត ដែលបុគ្គលមានបញ្ញាថោកថយឃើញបានដោយក្រ ។ ដោយហេតុនោះ មិនគួរបោះបង់ធុរៈថា អញមិនអាចបើកបដិសន្ធិ ហើយធ្វើនាម-រូបក្នុងខណៈចុតិឲ្យជាអារម្មណ៍បាន ។ ភិក្ខុគួរចូលឈានដែលជាបាទនោះឯងរឿយៗ លុះចេញចាកឈាននោះហើយ គប្បីនឹកគិតដល់ឋានៈនោះៗ ។

កាលភិក្ខុធ្វើយ៉ាងនេះហើយ លុះចេញចាកឈានដែលជាបាទ មិននឹកគិតដល់ឋានៈ ដែលនឹកគិតបានហើយក្នុងកាលមុន នឹកគិតដល់បដិសន្ធិប៉ុណ្ណោះ បើកបដិសន្ធិក្នុងកាលមិនយឺតយូរ គប្បីធ្វើនាមរូបក្នុងខណៈចុតិឲ្យជាអារម្មណ៍បានដូចបុរសមានកម្លាំងកាប់ដើមឈើធំ ដើម្បីប្រយោជន៍ដល់ជហ្វាផ្ទះកំពូល សូម្បីមិនអាចកាប់ដើមឈើធំ ដោយប៉ូវថៅដែលរិល ដោយត្រឹមតែកាត់មែកនិងស្លឹកប៉ុណ្ណោះ ក៏មិនដាក់ធុរៈ ទៅកាន់រោងជាងដែកសំលៀងប៉ូវថៅឲ្យមុតហើយត្រឡប់មកកាប់ជាថ្មី បើប៉ូវថៅរិលទៀតគួរឲ្យជាងដែកសំលៀង ហើយគប្បីកាប់យ៉ាងនោះទៀត ។ បុរសនោះកាលកាប់យ៉ាងនេះ ក្នុងកាលមិនយូរដើមឈើធំនោះនឹងដាច់បាន ព្រោះចំណែកដែលកាប់ហើយ មិនមានចំណែកដែលគួរកាប់ទៀត និងព្រោះកាប់ចំណែកដែលមិនទាន់បានកាប់ប៉ុណ្ណោះ ។ ក្នុងសេចក្តីនេះ ញាណដែលធ្វើអារម្មណ៍តាំងអំពីការអង្គុយចុងក្រោយ របូតដល់

បដិសន្ធិឲ្យប្រព្រឹត្តទៅ មិនឈ្មោះថាបុព្វេនិវាសញ្ញាណ តែញាណនោះ ឈ្មោះថា បរិកម្មសមាធិញ្ញាណ ។ អាចារ្យពួកមួយពោលញាណនោះថា ជាអតីតំសញ្ញាណ ។ ពាក្យនោះ សំដៅដល់រូបាវចរ ព្រោះអតីតំសញ្ញាណជារូបាវចរ ទើបមិនត្រូវ ។ តែក្នុងកាលណាមនោទ្វារាវជ្ជនៈឈានកន្លងបដិសន្ធិរបស់ភិក្ខុនោះហើយ ធ្វើនាមរូបដែលប្រព្រឹត្តទៅហើយ ក្នុងចុតិក្ខណៈឲ្យជាអារម្មណ៍កើតឡើងហើយ អប្បនាចិត្តរមែងកើតឡើងដោយន័យដូចពោលហើយ ក្នុងពេលមុន ។ ក្នុងកាលនោះ ញាណដែលសម្បយុត្តដោយចិត្តនោះ របស់ភិក្ខុនោះ ឈ្មោះថា បុព្វេនិវាសានុស្សតិញ្ញាណ ។ ភិក្ខុរមែងរឭកដល់ជាតិមុន ដោយសតិដែលសម្បយុត្តដោយញាណនោះ ។

ក្នុងបទទាំងនោះ បទថា **សេយ្យថីទំ** ជានិបាតក្នុងអត្ថសម្ដែងដល់ប្រភេទដែលប្រារព្ធ ។ ដោយហេតុនោះ ព្រះសារីបុត្ត កាលសម្ដែងចែកប្រភេទនៃបុព្វេនិវាសដែលប្រារព្ធ ទើបពោលបទថា **ឯកម្បិ ជាតឹ** ជាដើម ។ បណ្ដាបទទាំងនោះ បទថា **ឯកម្បិ ជាតឹ** បានដល់ ខន្ធសន្តានឯណានីមួយដែលទាក់ទងក្នុងភពមួយ មានបដិសន្ធិជាមូល មានចុតិជាបរិយោសាន ។ ក្នុងបទថា **ទ្វេបិ ជាតិយោ** ជាដើម ក៏មានន័យនេះ ។ ក្នុងបទថា **អនេកេបិ សំវដ្ដកប្បេ** ជាដើម មានអធិប្បាយដូចតទៅនេះថា កប្បដែលកំពុងវិនាស ឈ្មោះថា សំវដ្ដកប្ប ព្រោះក្នុងគ្រានោះ សត្វទាំងពួងប្រជុំគ្នាក្នុងព្រហ្មលោក ។ កប្បដែលកំពុងចម្រើន ឈ្មោះថា វិវដ្ដកប្ប ព្រោះក្នុងគ្រានោះ សត្វទាំងឡាយចេញចាកព្រហ្មលោក ។ ក្នុងបទទាំងនោះ ឈ្មោះថា លោកកាន់យកសត្វដែលតាំងនៅក្នុង

សំវដ្ដៈដោយសំវដ្ដសត្វ និងសត្វដែលតាំងនៅក្នុងវិវដ្ដៈ ដោយវិវដ្ដសត្វ ព្រោះមានព្រហ្មលោកនោះជាមូល ។ ពិតហើយ កាលបើយ៉ាងនេះ ឈ្មោះថា លោកកំណត់អសង្ខេយ្យ ៤ ដូចព្រះមានព្រះភាគ ត្រាស់ ( ក្នុងអង្គុត្តរនិកាយ ចតុក្កនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ អសង្ខេយ្យ ( កាលដែលយូររាប់មិនបាន ) នៃកប្បនេះ មាន ៤ ។ អសង្ខេយ្យ ៤ គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ កាលកប្បសូន្យទៅ តាំងមានឡើងកម្រនឹងរាប់ ។ ម្នាលភិក្ខុទាំងឡាយ កាលកប្បតាំងនៅក្នុងចន្លោះវិនាសទៅ តាំងមានឡើង ។បេ។ ម្នាលភិក្ខុទាំងឡាយ កាលកប្បត្រឡប់ចម្រើនតាំងមានឡើងវិញ ។បេ។ ម្នាលភិក្ខុទាំងឡាយ កាលកប្បតាំងនៅក្នុងចន្លោះចម្រើនតាំងមានឡើង ក៏កម្រនឹងរាប់ ។

ក្នុងកប្បទាំងនោះ សំវដ្ដកប្បមាន ៣ គឺតេជោសំវដ្ដៈ ១ អាបោសំវដ្ដៈ ១ វាយោសំវដ្ដៈ ១ ។ សំវដ្ដសីមា គឺខេត្តរបស់សំវដ្ដៈ មាន ៣ គឺអាភស្សរា ១ សុភកិណ្ហា ១ វេហប្ផលា ១ ។ កាលណាកប្បវិនាសដោយភ្លើង ត្រូវភ្លើងឆេះដល់ខាងក្រោមនៃអាភស្សរា ។ កាលណាកប្បវិនាសដោយទឹក ត្រូវទឹកជន់លិច រហូតដល់ខាងក្រោមនៃសុភកិណ្ហា ។ កាលណាកប្បវិនាសដោយខ្យល់ ត្រូវខ្យល់បក់ផាត់រហូតដល់ខាងក្រោមនៃវេហប្ផលា ។ ដោយចំណែកទទឹង ពុទ្ធក្ខេត្តមួយ ក៏រមែងវិនាសគ្រប់កប្បដែលវិនាស ។ ពុទ្ធក្ខេត្តមាន ៣ គឺជាតិក្ខេត្ត ១ អាណាខេត្ត ១ វិសយក្ខេត្ត ១ ។

ក្នុងខេត្តទាំង ៣ នោះ ខេត្តដែលកម្រើកញាប់ញ័រក្នុងកាលបដិសន្ធិជាដើមរបស់ព្រះតថាគត មានមួយម៉ឺនចក្រវាលជាទីបំផុត ឈ្មោះថា ជាតិក្ខេត្ត ។

អានុភាពរបស់ព្រះបរិត្តទាំងនេះ គឺរតនបរិត្ត ខន្ធបរិត្ត ធជគ្គបរិត្ត អាដានាដិយបរិត្ត មោរបរិត្ត រមែងប្រព្រឹត្តទៅក្នុងខេត្តដែលមានមួយសែនកោដិចក្កវាលជាទីបំផុត ឈ្មោះថា អាណាខេត្ត ។

ខេត្តដែលមានប្រមាណមិនបាន ដែលព្រះមានព្រះភាគត្រាស់ ( ក្នុងអង្គុត្តរនិកាយ តិកនិបាត ) ថា ឬថា គប្បីប្រាថ្នាដល់ត្រឹមណាក៏បាន ឈ្មោះថា វិសយខេត្ត ។ ព្រះតថាគតរមែងទ្រង់ជ្រាបខេត្តតាមដែលទ្រង់ប្រាថ្នា ។ ក្នុងពុទ្ធក្ខេត្ត ៣ យ៉ាងនេះ អាណាខេត្តមួយរមែងវិនាសទៅ ។ កាលអាណាខេត្តនោះវិនាសទៅ ជាតិក្ខេត្តក៏វិនាសផងដែរ ។ កាលជាតិក្ខេត្តនោះវិនាសទៅ រមែងវិនាសទៅជាមួយគ្នា កាលតាំងនៅរមែងតាំងនៅជាមួយគ្នា ដោយប្រការដូច្នេះ ។

សេចក្ដីវិនាស និងការតាំងនៅរបស់ខេត្តនោះគប្បីជ្រាបយ៉ាងនេះ សម័យណាកប្បវិនាសដោយភ្លើងជំបូង មហាមេឃដែលញ៉ាំងកប្បឲ្យវិនាស តាំងឡើង ញ៉ាំងភ្លៀងមួយមេធំឲ្យធ្លាក់ចុះក្នុងមួយសែនកោដិចក្កវាឡ ។ មនុស្សទាំងឡាយនាំគ្នាត្រេកអរ នាំពូជទាំងពួងយកមកព្រោះ កាលស្រូវដុះឡើងល្មមគោទំពាស៊ីបាន មហាមេឃក៏គ្រហឹម មានសំឡេងដូចលាស្រែក ភ្លៀងសូម្បីមួយតំណក់ ក៏មិនធ្លាក់ ក្នុងកាលនោះ ភ្លៀងឈ្មោះថាមិនមានមួយគ្រាប់នោះឯង ។ សត្វដែលអាស្រ័យភ្លៀងចិញ្ចឹមជីវិត រមែងកើតក្នុងព្រហ្មលោក តាមលំដាប់ ទេវតាដែលអាស្រ័យផ្កា និងផ្លែឈើចិញ្ចឹមជីវិត ក៏ទៅកើតក្នុងព្រហ្មលោកដែរ ។ ពេលវេលាកន្លងទៅយូរយ៉ាងនេះ ទឹកក្នុងទីនោះៗ ក៏រីងទៅសូម្បីត្រី និងអណ្ដើកក៏ស្លាប់ទៅតាមលំដាប់ ហើយកើតក្នុងព្រហ្មលោក សូម្បីសត្វ

នរកក៏ទៅកើតផងដែរ ។ ក្នុងសេចក្តីនេះ អាចារ្យពួកមួយពោលថា សត្វនរករមែងវិនាសទៅក្នុងការប្រាកដឡើងនៃព្រះអាទិត្យជួនទី ៧ ។ សួរថា បុគ្គលវៀចាកឈាន នឹងកើតក្នុងព្រហ្មលោករមែងមិនមាន បណ្តាសត្វទាំងនោះ ពួកខ្លះត្រូវទុព្ភិក្ខភ័យបៀតបៀន ពួកខ្លះមិនគួរដើម្បីបាននូវឈាន សត្វទាំងនោះកើតក្នុងព្រហ្មលោកបានដូចម្តេច ឆ្លើយថា ដោយអំណាចឈានដែលបានក្នុងទេវលោក ។

ពិតហើយ ក្នុងកាលនោះ ដោយកន្លងទៅមួយសែនឆ្នាំកប្បនឹងវិនាស ព្រោះហេតុនោះ កាមាវចរទេវតាទាំងឡាយ ឈ្មោះថា លោកព្យូហ ( ជាសត្វលោក ) មានក្បាលសើម រំសាយសក់ ទ្រហោយំ យកដៃជូតទឹកភ្នែក ដណ្តប់សំពត់ក្រហម មានភេទខុសប្រក្រតី ត្រាច់ទៅក្នុងដែនដីមនុស្ស នាំគ្នាប្រកាសយ៉ាងនេះថា អ្នកនិរទុក្ខទាំងឡាយៗ កន្លងទៅមួយសែនឆ្នាំបន្ទាប់អំពីនេះ កប្បនឹងវិនាស លោកនេះនឹងវិនាស សូម្បីមហាសមុទ្ទក៏នឹងរីងស្ងួត មហាប្រឹថពី និងភ្នំព្រះសិនេរុ នឹងរលំរលាយវិនាសទៅ លោកនឹងវិនាសរហូតដល់ព្រហ្មលោក ។ អ្នកនិរទុក្ខទាំងឡាយ ពួកលោកចូរចម្រើនមេត្តា ករុណា មុទិតា ឧបេក្ខាចុះ ចូរបម្រើមាតាបិតា ចូរជាអ្នកប្រព្រឹត្តឱនលំទោនចំពោះរៀមច្បង ក្នុងត្រកូលដូច្នេះ ។

ពួកមនុស្ស និងភុម្មទេវតាដោយច្រើន លុះស្តាប់ពាក្យរបស់កាមាវចរទេវតាទាំងនោះហើយក៏នាំគ្នាសង្វេគ មានចិត្តទោរទន់បង្អោនរកគ្នានិងគ្នា ធ្វើបុណ្យមានមេត្តាជាដើមហើយ បានទៅកើតក្នុងទេវលោក ។ ក្នុងទេវលោកនោះ ពួក

ទេវតាបរិភោគអាហារទិព្វ ធ្វើបរិកម្មក្នុងវាយោកសិណ ហើយបានឈាន ។ ចំណែកមនុស្សពួកដទៃដែលកើតឡើងក្នុងទេវលោក ដោយអបរាបរិយវេទ-នីយកម្ម ។ សត្វ ឈ្មោះថា គ្រាច់ទៅក្នុងសង្សារ វៀរអបរាបរិយវេទនីយកម្មមិនមាន ។ សូម្បីសត្វទាំងនោះ ក៏រមែងបានឈានយ៉ាងនោះក្នុងភពនោះ ។ សត្វទាំងពួង រមែងកើតឡើងក្នុងព្រហ្មលោក ដោយអំណាចឈានដែលបានហើយ ក្នុងទេវលោកយ៉ាងនេះ ដោយប្រការដូច្នេះ ។

ខាងមុខអំពីភ្លៀងមិនធ្លាក់ទៅ ពេលវេលាកន្លងទៅដ៏យូរលង់ ព្រះអាទិត្យទីពីររមែងប្រាកដ កាលបើព្រះអាទិត្យនោះប្រាកដ ការកំណត់យប់ថ្ងៃមិនប្រាកដ ។ ព្រះអាទិត្យមួយរះឡើង ព្រះអាទិត្យមួយលិចទៅ លោកមិនដាច់កម្តៅអំពីព្រះអាទិត្យឡើយ ក្នុងព្រះអាទិត្យដែលញុំាងកប្បឲ្យវិនាស មិនមានសុរិយទេវបុត្តដូចក្នុងព្រះអាទិត្យប្រក្រតីទេ ក្នុងព្រះអាទិត្យ ២ នោះ កាលព្រះអាទិត្យប្រក្រតីប្រព្រឹត្តទៅ ផ្សែងខ្លះ ភ្លើងខ្លះ រមែងហុយទៅក្នុងអាកាស ។ កាលព្រះអាទិត្យញុំាងកប្បឲ្យវិនាសទៅ លម្ហមេឃប្រាសចាកផ្សែង និងពពកដូចមណ្ឌលកញ្ចក់មិនមានមន្ទិលដូច្នោះ ។ វៀរស្ទឹងធំទាំង ៥ ទឹកក្នុងជ្រោះដ៏សេសក៏រីងស្ងួតទៅ ។

បន្ទាប់អំពីនោះក្នុងកាលដ៏យូរលង់ព្រះអាទិត្យទី ៣ ក៏ប្រាកដ ព្រោះព្រះអាទិត្យទី ៣ នោះប្រាកដ សូម្បីស្ទឹងធំទាំងឡាយក៏រីងស្ងួត ។ បន្ទាប់អំពីនោះក្នុងកាលដ៏យូរលង់ព្រះអាទិត្យទី ៤ ក៏ប្រាកដ ព្រោះព្រះអាទិត្យទី ៤ ប្រាកដស្រះធំទាំង ៧ ដែលជាប្រភពកើតនៃមហានទីទាំងឡាយក្នុងព្រៃហេមពាន្ត គឺ

សីហបបាតនៈ ១ ហំសបាតនៈ ១ កណ្ណមុណ្ឌកៈ ១ រថការទហៈ ១ អនោ-តត្តទហៈ ១ ឆទ្ទន្តទហៈ ១ កុណាលទហៈ ១ រមែងរីងស្ងួតទៅ ។

បន្ទាប់អំពីនោះ ក្នុងកាលកន្លងដ៏យូរលង់ព្រះអាទិត្យទី ៥ ក៏ប្រាកដ ព្រោះព្រះអាទិត្យទី ៥ ប្រាកដ ទឹកសូម្បីត្រឹមតែសើមម្រាមដៃ ក៏មិនមានសេសសល់ ក្នុងមហាសមុទ្រដោយលំដាប់ ។

បន្ទាប់អំពីនោះ ក្នុងកាលដ៏យូរលង់ព្រះអាទិត្យទី ៦ ក៏ប្រាកដ ព្រោះព្រះអាទិត្យទី ៦ ប្រាកដ ចក្កវាឡទាំងមូលមានផ្សែងហុយឡើង ដូចគ្នាតែមួយគ្របដណ្តប់ទៅដោយផ្សែង សូម្បីចក្កវាឡមួយសែនកោដិក៏ដូចគ្នានឹងចក្កវាឡនេះ ។ បន្ទាប់អំពីនោះ ក្នុងកាលដ៏យូរលង់ព្រះអាទិត្យទី ៧ ក៏ប្រាកដ ព្រោះព្រះអាទិត្យទី ៧ ប្រាកដ ចក្កវាឡទាំងមូលមួយអន្លើដោយចក្កវាឡមួយសែនកោដិ មានអណ្តាតភ្លើងរុងរឿង ដូចគ្នាតែមួយ ។ សូម្បីកំពូលភ្នំសិនេរុទាំងឡាយ មានប្រភេទកម្ពស់ប្រមាណ ១០០ យោជន៍ជាដើម ក៏បែកធ្លាយទៅក្នុងអាកាសនោះឯង ។ អណ្តាតភ្លើងនោះ ឆាបឆេះរហូតទល់គ្នានឹងស្ថានសួគ៌ជាន់ចាតុម្មហារាជិកា អណ្តាតភ្លើងឆេះដុតកនកវិមាន រតនវិមាន និងមណីវិមានក្នុងស្ថានសួគ៌នោះ ទៅទល់គ្នានឹងស្ថានតាវត្តិង្ស ។ ដោយឧបាយនេះឯង អណ្តាតភ្លើងបន្តឆេះរហូតដល់បឋមជ្ឈានភូមិ ។ ឆេះព្រហ្មលោកទាំង ៣ ក្នុងបឋម-ជ្ឈានភូមិនោះ ទៅទល់គ្នានឹងអាភស្សរព្រហ្មតាំងនៅ ។ អណ្តាតភ្លើងនោះឆេះមិនរលត់ ដរាបណាសង្ខារត្រឹមតែប៉ុនអណូមួយមាននៅ ។ អណ្តាតភ្លើងដុតសូម្បីផេះក៏មិនឲ្យសេសសល់ ដូចអណ្តាតភ្លើងដែលឆេះសប្បិ និងប្រេង

ហើយ ទើបរលត់ទៅ ព្រោះអស់សង្ខារទាំងពួង ។

តមក ក្នុងកាលដ៏យូរលង់ មហាមេឃតាំងឡើង ញុំាងភ្លៀងគ្រាប់ល្អិតៗ ឲ្យធ្លាក់ចុះជាលើកដំបូង មហាមេឃញុំាងភ្លៀង ដែលមានគ្រាប់ប្រមាណប៉ុនទងឈូក ឈើប្រត់ អង្រែ និងដើមត្នោតជាដើម ឲ្យធ្លាក់ចុះដោយលំដាប់ ធ្វើទីដែលត្រូវភ្លើងឆេះទាំងអស់ ក្នុងសែនកោដិចក្កវាឡឲ្យពេញហើយ ក៏អន្តរធានទៅ ។ ខ្យល់តាំងឡើង បក់ធ្វើទឹកនោះ ទាំងខាងក្រោម និងខាងទទឹងឲ្យទៅជាដុំ រំលែទៅ ដូចគ្នានឹងតំណក់ទឹកលើស្លឹកឈូក ។ សួរថា ធ្វើជំនន់ទឹកធំដល់ម៉្លោះ ឲ្យជាដុំបានដូចម្ដេច ឆ្លើយថា ព្រោះបើកជាចន្លោះ ។ ខ្យល់រមែងធ្វើជាចន្លោះក្នុងទីនោះៗ ដល់ជំនន់ទឹកនោះ ។ ទឹកនោះ ត្រូវខ្យល់បក់ប្រមូលធ្វើឲ្យជាដុំ រលាយទៅ ក៏ហូរចុះទៅខាងក្រោមតាមលំដាប់ ។ កាលទឹកហូរចុះទៅៗ ព្រហ្មលោក រមែងប្រាកដក្នុងទីរបស់ព្រហ្មលោក ម្យ៉ាងទៀត ទេវលោករមែងប្រាកដក្នុងទីនៃកាមាវចរទេវលោក ៤ ជាន់ខាងលើ ។ កាលទឹកហូរចុះដល់ផែនដីដូចមុន ខ្យល់ដ៏មានកម្លាំងរមែងកើតឡើង ។ ខ្យល់ដ៏មានកម្លាំងនោះការពារ ធ្វើឲ្យទឹកមិនហូរចេញ ដូចទឹកដែលដក់នៅក្នុងធម្មក្រកដែលបិទមាត់ ។ កាលទឹកផ្អែមអស់ទៅ ក៏ញុំាងរសផែនដីឲ្យតាំងឡើងខាងលើ ។ រសផែនដីនោះ សម្បូរដោយពណ៌ ក្លិន និងរស ដូចកំណកខាងលើបាយាសដែលមិនមានទឹក ។ ក្នុងកាលនោះ សត្វទាំងឡាយដែលកើតមុន ក្នុងអាកស្សរព្រហ្មលោក ចុតិចាកទីនោះ ព្រោះអស់អាយុក្តី ព្រោះអស់បុណ្យក្តី រមែងកើតក្នុងទីនេះ ។ សត្វទាំងនោះ មានរស្មីដោយខ្លួនឯង ហោះទៅកាន់ពួដ៏

អាកាសបាន ។ សត្វទាំងនោះ កាលភ្លក្សរសផែនដីនោះតាមន័យដូចពោល ហើយ ក្នុងអគ្គញ្ញសូត្រ ត្រូវតណ្ហាគ្របសង្កត់ ព្យាយាមបរិភោគក្រមរផែនដី ដែលធ្វើឲ្យកើតសេចក្តីលោភ ។

គ្រានោះ រស្មីត្រង់ខ្លួនរបស់សត្វទាំងនោះ ក៏វិនាសទៅ ងងឹតក៏ប្រាកដ ។ សត្វទាំងនោះឃើញងងឹតក៏ភ័យខ្លាច បន្ទាប់អំពីនោះ សុរិយមណ្ឌលទំហំ ៥០ យោជន៍ ប្រាកដឡើង ញុំាំងសេចក្តីភ័យខ្លាចរបស់សត្វទាំងនោះឲ្យវិនាសទៅ ឲ្យកើតសេចក្តីក្លៀវក្លា ។ សត្វទាំងនោះ លុះបានឃើញសុរិយមណ្ឌលនោះ ក៏នាំគ្នាត្រេកអរថា យើងបានពន្លឺហើយ ទើបតាំងឈ្មោះសុរិយមណ្ឌលថា សុរិយៈ ព្រោះតាំងឡើងធ្វើឲ្យពួកយើងដែលភ័យខ្លាច បាត់នូវការភ័យខ្លាច ឲ្យកើតសេចក្តីក្លៀវក្លា ព្រោះហេតុនោះ ចូរជាសុរិយៈចុះ ។

កាលបើព្រះសុរិយៈធ្វើពន្លឺអស់ថ្ងៃ ហើយលិចទៅ សត្វទាំងឡាយមាន សេចក្តីភ័យខ្លាចទៀតថា ពន្លឺដែលយើងបាន វិនាសទៅហើយ ។ ទើបសត្វទាំង នោះគិតយ៉ាងនេះថា នឹងជាការល្អ ប្រសិនបើពួកយើងបានពន្លឺដទៃ ។ ចន្ទមណ្ឌលប្រមាណ ៤៩ យោជន៍ប្រាកដឡើងដូចដឹងចិត្តរបស់សត្វទាំងនោះ ។ សត្វទាំងនោះ លុះឃើញចន្ទមណ្ឌលនោះក៏នាំគ្នាត្រេកអរ រីករាយក្រៃលែង ទើបតាំងឈ្មោះចន្ទមណ្ឌលនោះថា ចន្ទ ព្រោះតាំងឡើងប្រៀបដូចបានដឹងនូវ បំណងរបស់ពួកយើង ព្រោះហេតុនោះ ចូរជាចន្ទចុះ ។

កាលព្រះចន្ទ និងព្រះអាទិត្យប្រាកដយ៉ាងនេះ ផ្កាយនក្ខត្តឫក្សទាំងឡាយ ក៏ប្រាកដ ។ ចាប់តាំងអំពីនោះមក យប់ថ្ងៃរមែងប្រាកដ កន្លះខែ មួយខែ រដូវ

ឆ្នាំ ក៏ប្រាកដតាមលំដាប់ ។ ក្នុងថ្ងៃប្រាកដព្រះចន្ទ និងព្រះអាទិត្យនោះឯង ភ្នំសិនេរុ ភ្នំកណ្តាប់ចក្កវាឡ ភ្នំហិមពាន្តក៏ប្រាកដ ។ ទាំងអស់នោះ ប្រាកដក្នុងថ្ងៃពេញបូណ៌មីខែផល្គុនមិនមុនមិនក្រោយ ។ ប្រាកដដូចម្តេច ដូចគ្រាប់ថ្កៅកាលក្តៅក៏ផុះប៉ោងឡើងដោយការកូរត្រឹមតែម្តងប៉ុណ្ណោះ គ្រាប់ថ្កៅត្រង់កន្លែងខ្លះក៏ជាទួលដូចគ្នានឹងស្តូប ត្រង់កន្លែងខ្លះក៏ខូង ត្រង់កន្លែងខ្លះក៏ស្មើយ៉ាងណាក្នុងទីដែលទួលដូចស្តូបក៏ជាភ្នំ ក្នុងទីដែលខូងក៏ជាមហាសមុទ្ទ ក្នុងទីដែលស្មើក៏ជាកោះ ។ កាលសត្វទាំងនោះបរិភោគរសផែនដី ពួកខ្លះក៏សម្បុរស្អាត ពួកខ្លះក៏មានសម្បុរមិនស្អាតតាមលំដាប់ ។ ក្នុងសត្វពីរពួកនោះ ពួកដែលមានសម្បុរស្អាត ក៏មើលងាយដល់ពួកសត្វដែលមានសម្បុរមិនស្អាត ព្រោះការមើលងាយរបស់សត្វទាំងនោះជាបច្ច័យ រសផែនដីក៏វិនាសទៅ ប្រាកដជាក្រមរផែនដី ។ លុះក្រមរផែនដីរបស់សត្វទាំងឡាយនោះ វិនាសទៅដោយន័យនោះ វល្លិបទាលតាក៏ប្រាកដឡើង សូម្បីបទាលតានោះ ក៏វិនាសទៅដោយន័យនោះ ក៏ប្រាកដជាស្រូវសាលី មិនចាំបាច់ប្រើឧសចម្អិន មិនមានកន្ទក់ មិនមានអង្កាម បរិសុទ្ធ មានក្លិនក្រអូប មានផ្លែជាអង្ករ ។ បន្ទាប់អំពីនោះ ភាជនៈរមែងកើតឡើងដល់សត្វទាំងនោះ សត្វទាំងនោះដាក់ស្រូវសាលីលើភាជនៈ ហើយដាក់លើថ្មុំផ្ទង់ថ្ម អណ្តាតភ្លើងកើតឡើងឯង ដុតចម្អិនស្រូវសាលីនោះ ។ ស្រូវដែលឆ្អិននោះ ប្រៀបដូចជាផ្កាម្លិះក្រពុំ ។ មិនចាំបាច់ធ្វើសម្ល ឬម្ហូប ដើម្បីស្រូវសាលីនោះ ប្រាថ្នាបរិភោគរសណាៗ ក៏មានរសនោះៗឲ្យបរិភោគ ។ កាលសត្វទាំងនោះបរិភោគអាហារគ្រោតគ្រាត តាំងអំពីនោះមក

មូត្រ និងករីស: ក៏កើតឡើង ។

កាលនោះ ដើម្បីឲ្យមូត្រនិងករីស:នោះចេញ មុខដំបៅក៏ប្រេះបែកដល់សត្វទាំងនោះ ភាពជាបុរសក៏ប្រាកដដល់បុរស ភាពជាស្ត្រីក៏ប្រាកដដល់ស្ត្រី ។ បានឮថា ក្នុងកាលនោះ ស្រីសម្លឹងប្រុស ឯប្រុសក៏សម្លឹងស្រីហួសកាលវេលា ។ ព្រោះសត្វទាំងនោះ សម្លឹងមើលគ្នាហួសកាលវេលាជាបច្ច័យ ទើបកើតការក្តៅក្រហាយព្រោះកាម ។ បន្ទាប់អំពីនោះ ក៏សេពមេថុនធម៌នឹងគ្នា ។ សត្វទាំងនោះ ត្រូវវិញ្ញូជនតិះដៀល ធ្វើឲ្យលំបាកព្រោះការសេពអសទ្ធម្ម ជាបច្ច័យ ទើបធ្វើផ្ទះដើម្បីបិទបាំងអសទ្ធម្មនោះ ។ សត្វទាំងនោះ កាលគ្រប់គ្រងផ្ទះ ក៏ប្រព្រឹត្តទៅតាមទិដ្ឋានុគតិរបស់សត្វដែលមិនខ្ជិលច្រអូសណាមួយ តាមលំដាប់ ហើយធ្វើការសន្សំ ។ ចាប់តាំងអំពីនោះ កន្ទក់ខ្លះ អង្កាមខ្លះក៏កើតមានដល់ស្រូវសាលី សូម្បីទីដែលច្រូតកាត់ហើយក៏មិនដុះវិញ សត្វទាំងនោះប្រជុំគ្នា ដោយតានតឹងក្នុងចិត្តថា អ្នកដ៏ចម្រើនទាំងឡាយ ធម៌លាមកប្រាកដហើយ ក្នុងសត្វទាំងឡាយ ព្រោះពួកយើងកាលអំពីមុន ជាអ្នកសម្រេចតាមសេចក្តីប្រាថ្នាបានដោយចិត្ត ។ គប្បីឲ្យពិស្តារដោយន័យដូចពោលហើយ ក្នុងអគ្គញ្ញសូត្រនោះឯង ។ តាំងអំពីនោះមក សត្វទាំងឡាយ ក៏បានតែងតាំងរបៀបបដិបត្តិឡើងដូចតទៅនេះថា

ប្រសិនបើមានសត្វណាមួយ កាន់យកចំណែកអ្នកដទៃ ដែលគេមិនបានឲ្យ សត្វទាំងឡាយក៏ស្តីប្រដៅអស់វារៈ ២ ដង ក្នុងលើកទីបីក៏វាយដោយដៃ ដុំដី និងដំបង ។ សត្វទាំងនោះ កាលបើកើតមានការលួចទ្រព្យ និយាយតិះដៀល

និយាយកុហក ក៏ដាក់ទណ្ឌកម្មរាងកាយឡើង ទើបប្រជុំគ្នាគិតថា បើដូច្នោះ ពួកយើងគួរលើកសត្វមួយ ( ឲ្យជាធំ ) យើងនឹងបន្ថែមចំណែកនៃស្រូវសាលីឲ្យដល់បុគ្គលដែលគប្បីកំហែងបុគ្គលដែលគួរកំហែង គប្បីតិះដៀលបុគ្គលដែលគួរតិះដៀល គប្បីបណ្តេញបុគ្គលដែលគួរបណ្តេញ ដោយប្រពៃរបស់ពួកយើង ។ កាលសត្វទាំងឡាយធ្វើសេចក្តីព្រមព្រៀងគ្នាយ៉ាងនេះហើយ ក្នុងកប្បនេះ ព្រះមានព្រះភាគ កាលនៅជាព្រះពោធិសត្វមានរូបស្អាត គួរមើល មានសក្តិធំជាងសត្វទាំងនោះ ក្នុងសម័យនោះ សម្បូរណ៍ដោយបញ្ញា អាចធ្វើនូវការកំហែង និងការសរសើរបាន ។ សត្វទាំងនោះ ក៏នាំគ្នាចូលទៅរកព្រះពោធិសត្វនោះ អង្វរហើយ ក៏លើកតម្កើង ។ ព្រះពោធិសត្វនោះប្រាកដដោយនាម ៣ គឺឈ្មោះថា មហាសម្មត ព្រោះមហាជនសន្មត ១ ឈ្មោះថា ខត្តិយៈ ព្រោះជាអធិបតីនៃស្រែទាំងឡាយ ១ ឈ្មោះថា រាជា ព្រោះឲ្យសត្វទាំងឡាយដទៃត្រេកអរដោយធម៌ស្មើ ១ ។ ព្រះពោធិសត្វ ជាបុរសដំបូង ក្នុងឋានៈជាអច្ឆរិយបុរសក្នុងលោក ។ កាលធ្វើព្រះពោធិសត្វឲ្យជាបុរសដំបូង តាំងនៅក្នុងខត្តិយមណ្ឌលហើយ វណ្ណៈទាំងឡាយ មានវណ្ណៈព្រាហ្មណ៍ជាដើម ក៏តាំងឡើងតាមលំដាប់ ។ ក្នុងកប្បទាំងនោះ តាំងអំពីមហាមេឃញុំាងកប្បឲ្យវិនាសរហូតដល់អណ្តាតភ្លើងរលត់ អសង្ខេយ្យមួយនេះ ហៅថា សំវដ្តកប្ប ។ តាំងអំពីអណ្តាតភ្លើងដែលញុំាងកប្បឲ្យវិនាស លុះរលត់ទៅរហូតដល់មហាមេឃ ( ភ្លៀង ) បរិបូណ៌ ញុំាងសែនកោដិចក្រវាលឲ្យពេញ អសង្ខេយ្យទី ២ នេះហៅថា សំវដ្តដ្ឋាយីកប្ប ។ តាំងអំពីមហាមេឃបរិបូណ៌ រហូតដល់ព្រះចន្ទ

និងព្រះអាទិត្យប្រាកដ អសង្ខេយ្យទី ៣ នេះ ហៅថា វិវដ្តកប្ប ។ តាំងអំពីព្រះចន្ទ និងព្រះអាទិត្យប្រាកដ រហូតដល់មហាមេឃដែលញ៉ាំងកប្បឲ្យវិនាសទៀត អសង្ខេយ្យទី ៤ នេះ ហៅថា វិវដ្តដ្ឋាយីកប្ប ។ អសង្ខេយ្យទាំង ៤ នេះ ជាមហាកប្ប ( អាយុផែនដី ) ១ ។ គប្បីជ្រាបសេចក្តីវិនាស ដោយភ្លើង និងការតាំងនៅ ដោយប្រការដូច្នេះ ។

សម័យណា កប្បវិនាសទៅដោយទឹក ដំបូងមហាមេឃញ៉ាំងកប្បឲ្យវិនាសតាំងឡើង គប្បីឲ្យពិស្តារដោយន័យដូចពោលហើយខាងដើមនោះឯង តែសេចក្តីផ្សេងគ្នាមានដូចតទៅនេះ មហាមេឃមានទឹកក្រុត ញ៉ាំងកប្បឲ្យវិនាសតាំងឡើងក្នុងកប្ប ដែលវិនាសដោយទឹកនេះ ។ ដូចជាព្រះអាទិត្យទីពីរតាំងឡើងក្នុងកប្បដែលវិនាសដោយភ្លើង ដូច្នោះ ។

មហាមេឃនោះ កាលញ៉ាំងភ្លៀងដែលមានគ្រាប់ល្អិតឲ្យធ្លាក់ចុះ រមែងធ្លាក់ចុះពេញសែនកោដិចក្កវាឡដោយតំណក់គ្រាប់ភ្លៀងធំៗ តាមលំដាប់ ។ ផែនដី និងភ្នំជាដើមដែលទឹកក្រុតពាល់ត្រូវហើយ រមែងរលាយ ។ ទឹកត្រូវខ្យល់បក់បោកដោយជុំវិញ ។ ទឹកជន់ឡើងតាំងអំពីផែនដី រហូតដល់ទុតិយជ្ឈានភូមិ ទឹកនោះ ញ៉ាំងព្រហ្មលោក ៣ ឲ្យអន្តរធានទៅក្នុងទីនោះ ទល់គ្នានឹងសុភកណ្ហាតាំងនៅ ។ ទឹកនោះ នៅមិនទាន់ស្ងប់ដរាបណា សង្ខារសូម្បីប៉ុនអណូនៅមាន ។ ម្យ៉ាងទៀត ទឹកនោះគ្របសង្កត់សង្ខារទាំងពួង ដែលទៅតាមទឹកនោះហើយ ក៏ស្ងប់ទៅ អាកាសខាងលើ និងអាកាសខាងក្រោមងងឹតសូន្យសុង ។ ពាក្យទាំងពួងដូចគ្នានឹងពាក្យដែលពោលហើយ ។ តែក្នុងទីនេះ លោកប្រាកដដោយធ្វើ

អាភស្សរព្រហ្មលោកទាំងមូលជាគ្រាដំបូង ។ សត្វទាំងឡាយចុតិចាកសុភ-កិណ្ហាហើយ រមែងកើតក្នុងអាភស្សរព្រហ្មជាដើម ។ ក្នុងកប្បទាំងនោះ តាំងអំពីមហាមេឃញ៉ាំងកប្បឲ្យវិនាស រហូតដល់ទឹកក្រុតដែលញ៉ាំងកប្បឲ្យវិនាសអស់ទៅ អសង្ខេយ្យមួយនេះ ហៅថា សំវដ្តកប្ប តាំងអំពីទឹកក្រុតអស់ទៅ រហូតដល់មហាមេឃបរិបូណ៌ អសង្ខេយ្យទីពីរនេះ ហៅថា សំវដ្តដ្ឋាយីកប្ប តាំងអំពីមហាមេឃបរិបូណ៌ ។បេ។ អសង្ខេយ្យទាំង ៤ នេះជាមហាកប្បមួយ គប្បីជ្រាបការវិនាសដោយទឹក និងការតាំងនៅ ដោយប្រការដូច្នេះ ។

សម័យណា កប្បវិនាសដោយខ្យល់នោះ ដំបូងមហាមេឃ ( ភ្លៀងធំដំបូង ) ញ៉ាំងកប្បឲ្យវិនាសតាំងឡើងហើយ គប្បីឲ្យពិស្តារតាមន័យដូចពោលហើយខាងដើមនោះឯង តែសេចក្តីផ្សេងគ្នាមានដូចតទៅនេះថា ខ្យល់តាំងឡើងដើម្បីញ៉ាំងកប្បឲ្យវិនាស ក្នុងកប្បដែលវិនាសដោយខ្យល់នេះ ដូចព្រះអាទិត្យទីពីរក្នុងកប្បវិនាសដោយភ្លើងដូច្នោះ ។ ខ្យល់នោះញ៉ាំងធូលីគ្រោតគ្រាត ឲ្យហុយឡើងមុន តអំពីនោះ ញ៉ាំងធូលីល្អិត ខ្សាច់ល្អិត ខ្សាច់គ្រោតគ្រាត ដុំក្រួស និងថ្មជាដើមឲ្យតាំងឡើង រហូតដល់ញ៉ាំងដុំថ្មប្រមាណប៉ុនផ្ទះកំពូល និងដើមឈើធំដែលតាំងឡើងក្នុងទីដែលមិនស្មើឲ្យអណ្តែតឡើង ។ វត្ថុទាំងនោះអណ្តែតអំពីផែនដីទៅកាន់អាកាសហើយ រមែងមិនធ្លាក់ត្រឡប់មកវិញ ធូលីទាំងនោះបែកខ្ទេចខ្ទីក្នុងទីនោះឯង ដល់នូវការមិនមាន ។ ខ្យល់ដែលតាំងឡើងខាងក្រោមមហាប្រឹថពីតាមលំដាប់ ហើយបំបើងមហាប្រឹថពីធ្វើបាតឲ្យនៅខាងលើហើយបន្សាត់ទៅក្នុងអាកាស ។ ផែនដីមាន ១០០ យោជន៍ជាប្រមាណ បែកទៅ

ប្រមាណ ២ យោជន៍ ៣ យោជន៍ ៤ យោជន៍ ៥ យោជន៍ ត្រូវកម្លាំងខ្យល់ បក់ទៅបែកខ្ទេចខ្ទីលើអាកាសនោះឯងដល់នូវការមិនមាន ខ្យល់លើកភ្នំកណ្តាប់ចក្កវាឡខ្លះ ភ្នំសិនេរុខ្លះ ហើយបន្សាត់ទៅក្នុងអាកាស ។ ភ្នំទាំងនោះ ទង្គិចគ្នានិងគ្នាហើយបែកខ្ទេចខ្ទីវិនាសទៅ ។ ដោយឧបាយនេះឯង ខ្យល់ញុំាងភុម្មដ្ឋកវិមាន និងអាកាសដ្ឋកវិមានឲ្យវិនាស ញុំាងកាមាវចរទេវលោក ៦ ឲ្យវិនាសហើយ ញុំាងចក្កវាឡសែនកោដិឲ្យវិនាស ។

ក្នុងភ្នំទាំងនោះ ភ្នំកណ្តាប់ចក្កវាឡ និងភ្នំកណ្តាប់ចក្កវាឡ ភ្នំហិមពាន្ត និងភ្នំហិមពាន្ត ភ្នំសិនេរុ និងភ្នំសិនេរុប៉ះទង្គិចគ្នាហើយ បែកខ្ទេចខ្ទីវិនាសទៅ ។ ខ្យល់បក់តាំងអំពីផែនដី រហូតដល់តតិយជ្ឈានភូមិ ។ ខ្យល់ញុំាងព្រហ្មលោក ៣ ជាន់ ក្នុងតតិយជ្ឈានភូមិនោះឲ្យវិនាស រហូតទល់គ្នានឹងវេហប្ផលា ហើយតាំងនៅ ។ កាលញុំាងសង្ខារទាំងពួង ឲ្យវិនាសទៅយ៉ាងនេះ ខ្លួនឯង ( ខ្យល់ប្រល័យកប្ប ) ក៏វិនាសទៅដែរ ។ អាកាសខាងលើ និងអាកាសខាងក្រោម ងងឹតសូន្យសុងដូចគ្នាទាំងអស់ ដូចដែលពោលហើយនោះឯង ។ តែក្នុងទីនេះ លោកប្រាកដដោយធ្វើសុភកិណ្ហព្រហ្មលោកជាដំបូង ។ សត្វទាំងឡាយចុតិអំពីវេហប្ផលាហើយ រមែងកើតក្នុងសុភកិណ្ហព្រហ្មលោកជាដើម ។

ក្នុងកប្បទាំងនោះ តាំងអំពីមហាមេឃញុំាងកប្បឲ្យវិនាសរហូតដល់ខ្យល់ញុំាងកប្បឲ្យវិនាសស្ងប់ អសង្ខេយ្យមួយនេះ ហៅថា សំវដ្តកប្ប តាំងអំពីខ្យល់ស្ងប់ រហូតដល់មហាមេឃបរិបូណ៌ អសង្ខេយ្យទី ២ នេះ ហៅថា សំវដ្តដ្ឋាយីកប្ប ។បេ។ អសង្ខេយ្យទាំង ៤ នេះជាមហាកប្បមួយ ។ គប្បី

ជ្រាបការវិនាសដោយខ្យល់ និងការតាំងទៅ ដោយប្រការដូច្នេះ ។

ព្រោះហេតុអ្វី ទើបលោកវិនាសទៅយ៉ាងនេះ ព្រោះអកុសលមូលជាហេតុ ។ ព្រោះកាលអកុសលមូលក្រាស់ឡើងហើយ លោកក៏វិនាសទៅយ៉ាងនេះ ។ លោកនោះឯងកាលរាគៈក្រាស់ជាងកិលេសដទៃ រមែងវិនាសទៅដោយភ្លើង កាលទោសៈក្រាស់ជាងកិលេសដទៃ រមែងវិនាសទៅដោយទឹក ។ តែអាចារ្យពួកខ្លះពោលថា បើទោសៈក្រាស់ជាង លោកវិនាសទៅដោយភ្លើង កាលរាគៈក្រាស់ជាង លោកវិនាសទៅដោយទឹក ។ កាលមោហៈក្រាស់ជាងកិលេសដទៃ លោកវិនាសទៅដោយខ្យល់ កាលវិនាសទៅយ៉ាងនេះ រមែងវិនាសទៅដោយភ្លើង ៧ ដងជាលំដាប់ លើកទី ៨ វិនាសទៅដោយទឹក ។ វិនាសទៅដោយភ្លើង ៧ ដងទៀត ក្នុងលើកទី ៨ វិនាសទៅដោយទឹក ព្រោះហេតុនោះ កាលវិនាសទៅ ៨ ដងៗ យ៉ាងនេះ វិនាសទៅដោយទឹក ៧ ដង ហើយវិនាសទៅដោយភ្លើងទៀត ៧ ដង ។ ដោយហេតុមានប្រមាណប៉ុណ្ណេះ ៦៣ កប្បឈ្មោះថា កន្លងទៅហើយ ។ ក្នុងរវាងនេះខ្យល់បានឱកាសហាមវារៈ ដែលវិនាសទៅដោយទឹកដល់ព្រមហើយ កម្ចាត់សុភកិណ្ហព្រហ្មលោក ដែលមានអាយុ ៦៤ កប្បបរិបូណ៌ ញុំាងលោកឲ្យវិនាសទៅ ។

ភិក្ខុដែលរឭកដល់កប្ប សូម្បីរឭកដល់ជាតិមុនរមែងរឭកដល់សំវដ្តកប្បជាច្រើនខ្លះ វិវដ្តកប្បជាច្រើនខ្លះ សំវដ្តវិវដ្តកប្បជាច្រើនខ្លះ ក្នុងកប្បទាំងនោះ ។

បទថា **សំវដ្តកប្បេ វិវដ្តកប្បេ** លោកពោលកំណត់ពាក់កណ្តាល របស់កប្បមួយ ។ បទថា **សំវដ្តវិវដ្តកប្បេ** លោកពោលកំណត់យកកប្បទាំងមូល ។

ប្រសិនបើសួរថា រឭកដល់ដូចម្តេច ឆ្លើយថា រឭកដល់ដោយន័យថា **អមុត្រាសឹ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **អមុត្រាសឹ** បានដល់ អញបានកើតហើយ ក្នុងសំវដ្តកប្បនោះ គឺក្នុងភព ក្នុងកំណើត ក្នុងគតិ ក្នុងវិញ្ញាណដ្ឋិតិ ក្នុងសត្តាវាស ឬក្នុងសត្តនិកាយនោះ ។

បទថា **ឯវំនាមោ** បានដល់ មានឈ្មោះយ៉ាងនេះ គឺតិស្សៈ ឬផុស្សៈ ។ បទថា **ឯវំគោត្តោ** បានដល់ មានគោត្តយ៉ាងនេះ គឺកច្ចានគោត្ត ឬកស្សបគោត្ត ។ បទនេះ លោកពោលដោយអំណាចការរឭកដល់ឈ្មោះ និងគោត្តរបស់ខ្លួន ក្នុងអតីតភពរបស់ភិក្ខុនោះ ។

ប្រសិនបើក្នុងកាលនោះ ភិក្ខុនោះបំណងនឹងរឭកដល់វណ្ណសម្បត្តិ ការរស់នៅសៅហ្មង និងប្រណីត ភាពជាអ្នកច្រើនដោយសុខ និងទុក្ខ ឬការមានអាយុតិច អាយុវែងរបស់ខ្លួន ក៏រឭកដល់វត្ថុនោះៗ បាន ។ ដោយហេតុនោះ ទើបព្រះសារីបុត្តត្ថេរពោលថា **ឯវំវណ្ណោ ។បេ។ ឯវមាយុបរិយន្តោ ។**

ក្នុងបទទាំងនោះ បទថា **ឯវំវណ្ណោ** បានដល់ សម្បុរស ឬសម្បុរខ្មៅ ។ បទថា **ឯវមាហារោ** បានដល់ មានស្រូវសាលី សាច់ បាយជាអាហារ ឬមានផ្លែឈើស្រស់ជាអាហារ ។

បទថា **ឯវំសុខទុក្ខប្បដិសំវេទី** បានដល់ សោយសុខ និងទុក្ខដែលប្រព្រឹត្តទៅផ្លូវកាយ ផ្លូវចិត្ត ឬមានប្រភេទជាដើមថា មានអាមិស ឬមិនមានអាមិស ដោយប្រការមិនមែនតិច ។ បទថា **ឯវមាយុបរិយន្តោ** បានដល់ មានអាយុ

កំណត់ ១០០ ឆ្នាំ ឬ ៨ លាន ៤ សែនកប្ប[១] ។

បទថា **សោ តតោ ចុតោ អមុត្រ ឧទបាទឹ** បានដល់ អាត្មាអញកាលចុតិចាកភព កំណើត គតិ វិញ្ញាណដ្ឋិតិ សត្តាវាស ឬសត្តនិកាយនោះហើយ បានមកកើតក្នុងភពកំណើត គតិ វិញ្ញាណដ្ឋិតិ សត្តាវាស ឬសត្តនិកាយឯណោះ ។ បទថា **តត្រាបាសឹ** បានដល់ បានកើតទៀតហើយក្នុងភព កំណើត គតិ វិញ្ញាណដ្ឋិតិ សត្តាវាស ឬសត្តនិកាយនោះ ។ បទថា **ឯវំនាមោ** ជាដើម មានន័យដូចបានពោលហើយ ។ ម្យ៉ាងទៀត ព្រោះបទថា **អមុត្រាសឹ** នេះ ជាការរឭកដល់តាមប្រាថ្នារបស់អ្នកលើកឡើងតាមលំដាប់ ។ បទថា **សោ តតោ ចុតោ** ជាការពិចារណារបស់អ្នកត្រឡប់ ហេតុនោះ គប្បីជ្រាបថា ពាក្យថា **អមុត្រ ឧទបាទឹ** លោកសំដៅដល់ទីកើតរបស់ភិក្ខុនោះ ក្នុងលំដាប់នៃការកើតឡើងនេះ ក្នុងលោកនេះថា ទើបមកកើតក្នុងទីនេះ ។

បទថា **តត្រាបាសឹ** លោកពោលដើម្បីសម្តែងការរឭកដល់ឈ្មោះ និងគោត្តជាដើម ក្នុងទីដែលកើតក្នុងលំដាប់នៃការកើតនេះក្នុងភពនោះ របស់ភិក្ខុនោះ ។ បទថា **សោ តតោ ចុតោ ឥធូបបន្នោ** សេចក្តីថា កាលអាត្មាអញចុតិចាកទីដែលកើតក្នុងលំដាប់នោះហើយ ក៏មកកើតក្នុងត្រកូលក្សត្រិយ៍ ឬក្នុងត្រកូលព្រាហ្មណ៍ឈ្មោះនោះ ក្នុងភពនេះ ។ បទថា **ឥតិ** បានដល់ ដោយប្រការយ៉ាងនេះ ។

---

១- អរូបព្រហ្មជាន់ទី ៤ មានអាយុត្រឹមតែ ៨៤០០០ កប្ប តែបាលីអដ្ឋកថាថា ចតុរាសីតិ-កប្បសតសហស្ស ( ៨៤ សែនកប្ប ) ទើបយើងរក្សាទុក ។

បទថា **សាការំ សឧទ្ទេសំ** បានដល់ ព្រមទាំងឧទ្ទេស ដោយអំណាចឈ្មោះ និងគោត្ត មួយអន្លើដោយអាការ ដោយអំណាចពណ៌សម្បុរជាដើម ។ ពិតហើយ លោកសម្តែងដល់សត្វ ដោយឈ្មោះនិងគោត្តថា តិស្សៈ ផុស្សៈ កស្សបគោត្ត រមែងប្រាកដដោយសេចក្តីផ្សេងគ្នាដោយពណ៌សម្បុរជាដើមថា ខ្មៅ ស ព្រោះហេតុនោះ ឈ្មោះ និងគោត្តជាឧទ្ទេស ។ ក្រៅអំពីនោះជាអាការ ដោយប្រការដូច្នេះ ។៚

**អដ្ឋកថាបុព្វេនិវាសានុស្សតិញ្ញាណនិទ្ទេស ចប់**

# សុត្តន្តបិដក

[ ២៥៧ ] បញ្ហា ក្នុងអត្ថថា ឃើញនូវរូបនិមិត្ត មានភាពផ្សេងៗ និងមានភាពតែមួយដោយអំណាចនៃពន្លឺ ឈ្មោះថា ទិព្វចក្ខុញ្ញាណ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ចម្រើននូវឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិ និងបធានសង្ខារ ចម្រើននូវឥទ្ធិបាទប្រកបដោយវីរិយសមាធិ ។បេ។ ចិត្តសមាធិ ។បេ។ វីមំសាសមាធិ និងបធានសង្ខារ ភិក្ខុនោះរមែងអប់រំ បង្វឹកចិត្ត ធ្វើចិត្តឲ្យទន់ គួរដល់កម្មក្នុងឥទ្ធិបាទទាំង ៤ នេះ ភិក្ខុនោះលុះអប់រំ បង្វឹកចិត្ត ធ្វើចិត្តឲ្យទន់ គួរដល់កម្មក្នុងឥទ្ធិបាទទាំង ៤ នេះហើយ ទើបធ្វើទុកក្នុងចិត្តនូវអាលោកសញ្ញា អធិដ្ឋាននូវទិវាសញ្ញា ( សេចក្តីសម្គាល់ក្នុងពេលថ្ងៃ ) ថា ក្នុងវេលាថ្ងៃយ៉ាងណា ក្នុងវេលាយប់ក៏យ៉ាងនោះ យប់យ៉ាងណា ថ្ងៃក៏យ៉ាងនោះ ( ភិក្ខុនោះ ) មានចិត្តបើកហើយ ឥតមានកិលេសរួបរឹត រមែងចម្រើននូវចិត្តដែលប្រកបដោយពន្លឺបាន ភិក្ខុនោះមានចិត្តអប់រំ បរិសុទ្ធផូរផង់ ដូច្នោះហើយ ក៏បង្អោនបន្ទន់ចិត្តទៅក្នុងសត្តានំចុតូបបាតញ្ញាណ ភិក្ខុនោះមានទិព្វចក្ខុដ៏ស្អាត បរិសុទ្ធកន្លងនូវចក្ខុរបស់មនុស្សសាមញ្ញ រមែងឃើញនូវសត្វទាំងឡាយ កំពុងច្យុតកំពុងកើត ថោកទាប ឧត្តម មានរូបល្អ មានរូបអាក្រក់ ទៅកាន់សុគតិ ទៅកាន់ទុគ្គតិ រមែងដឹងច្បាស់នូវសត្វទាំងឡាយ ដែលអន្ទោលទៅតាមយថាកម្មថា ឱហ្ន៎ ពួកសត្វដ៏ចម្រើននេះប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាអ្នកតិះដៀលនូវពួកព្រះអរិយៈ ជាមិច្ឆាទិដ្ឋិ សមាទាននូវមិច្ឆាទិដ្ឋិ ពួកសត្វនោះ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់

ទៅ ក៏ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ចំណែកខាងពួកសត្វដ៏ចម្រើន នេះ ប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោ-សុចរិត ជាអ្នកមិនតិះដៀលនូវពួកព្រះអរិយៈ ជាសម្មាទិដ្ឋិ សមាទាននូវសម្មា-ទិដ្ឋិ ពួកសត្វនោះ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ ក៏ទៅកើត ក្នុងសុគតិសួគ៌ទេវលោក ភិក្ខុនោះមានទិព្វចក្ខុដ៏បរិសុទ្ធ កន្លងនូវចក្ខុរបស់ មនុស្សសាមញ្ញ រមែងឃើញនូវពួកសត្វដែលកំពុងច្យុត កំពុងកើត ថោកទាប ឧត្តម មានរូបល្អ រូបអាក្រក់ ទៅកាន់សុគតិ ទៅកាន់ទុគ្គតិ រមែងដឹងច្បាស់ នូវពួកសត្វដែលអន្ទោលទៅតាមកម្មយ៉ាងនេះឯង ឈ្មោះថា ញាណ ដោយអត្ថ ថា ដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងអត្ថថា ឃើញនូវរូបនិមិត្ត មានភាព ផ្សេងៗ និងភាពតែមួយដោយអំណាចនៃពន្លឺ ឈ្មោះថា ទិព្វចក្ខុញាណ ។

# អដ្ឋកថា
## ទិព្វចក្ខុញ្ញាណនិទ្ទេស

[ ២៥៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទិព្វចក្ខុញ្ញាណនិទ្ទេសដូចតទៅ

បទថា **អាលោកសញ្ញំ មនសិករោតិ** បានដល់ មនសិការពន្លឺព្រះអាទិត្យ ព្រះចន្ទ និងកែវមណី ទាំងពេលថ្ងៃ ពេលយប់ថា ពន្លឺ ៗ ម្យ៉ាងទៀត កាលបើមនសិការយ៉ាងនេះ លោកពោលថា មនសិការអាលោកសញ្ញា ព្រោះញ៉ាំងសញ្ញាឲ្យប្រព្រឹត្តទៅក្នុងចិត្តថា ពន្លឺ ៗ

បទថា **ទិវាសញ្ញំ អធិដ្ឋាតិ** បានដល់ មនសិការអាលោកសញ្ញា យ៉ាងនេះហើយ តម្កល់សញ្ញាថាជាពេលថ្ងៃ ៗ បទថា **យថា ទិវា តថា រត្តឹ** បានដល់ មនសិការសូម្បីពេលយប់ ដូចជាឃើញពន្លឺក្នុងពេលថ្ងៃ ដូច្នោះ ។ បទថា **យថា រត្តឹ តថា ទិវា** បានដល់ មនសិការពេលថ្ងៃ ដូចឃើញពន្លឺក្នុងពេលយប់ ដូច្នោះ ។ បទថា **ឥតិ វិវដ្ដេន ចេតសា** បានដល់ មានចិត្តមិនបានបិទបាំងយ៉ាងនេះ ។ បទថា **អបរិយោនទ្ធេន** បានដល់ មិនរុំព័ទ្ធដោយជុំវិញ ។ បទថា **សប្បភាសំ ចិត្តំ ភាវេតិ** បានដល់ ចម្រើនចិត្តឲ្យមានពន្លឺ ។ ដោយបទនេះលោកពោលដល់ចិត្ត ដែលមានពន្លឺដោយការបរិកម្មជាអារម្មណ៍របស់ទិព្វចក្ខុ ឬលោកពោលសំដៅដល់ចតុត្ថជ្ឈាន មានអាលោកកសិណជាអារម្មណ៍ ។ កាលភិក្ខុនោះចម្រើនយ៉ាងនេះ ចិត្តមានពន្លឺប្រាសចាកសេចក្ដីងងឹត ដែលបិទបាំង ។ កុលបុត្តដែលជាអាទិកម្មិក ប្រាថ្នាដើម្បីញ៉ាំងទិព្វចក្ខុឲ្យកើត ធ្វើអភិញ្ញាមានឈានជាបាទ មានកសិណជាអារម្មណ៍ដោយទំនងនៃព្រះបាលីនោះឯងឲ្យ

ជាការគួរដល់អភិនីហារ ដោយអាការទាំងពួង ។ ហើយគប្បីធ្វើកសិណយ៉ាង ណាមួយក្នុងកសិណទាំង ៣ យ៉ាងនេះ គឺតេជោកសិណ ១ ឱទាតកសិណ ១ អាលោកកសិណ ១ ឲ្យជិតទុក គប្បីធ្វើឧបចារជ្ឈានឲ្យជាអារម្មណ៍ហើយ ឲ្យចម្រើនហើយបញ្ឈប់ទុក អធិប្បាយថា មិនគួរឲ្យអប្បនាកើតក្នុងអារម្មណ៍ នោះ ។ ប្រសិនបើឲ្យអប្បនាកើត រមែងជានិស្ស័យនៃឈានដែលជាបាទ មិន មែនជានិស្ស័យនៃបរិកម្ម ។ ក្នុងកសិណទាំង ៣ យ៉ាងនេះ អាលោកកសិណ នោះឯងប្រសើរជាង ។ លោកពោលកសិណ ២ យ៉ាងក្រៅអំពីនោះ ដោយ អនុលោមអាលោកកសិណនោះឯង ។ ព្រោះហេតុធ្វើគួរធ្វើអាលោកកសិណ ឬកសិណក្រៅអំពីនេះណាមួយឲ្យជាអារម្មណ៍ ហើយធ្វើឈាន ៤ ឲ្យកើត តាំងនៅក្នុងឧបចារភូមិនោះឯងទៀត ហើយគប្បីចម្រើនកសិណ ។ គប្បីឃើញ រូបខាងក្នុងនៃទីដែលចម្រើនហើយ ។ កាលភិក្ខុនោះឃើញរូប មិនធ្វើការផ្សាយ ទៅនៃពន្លឺដោយចិត្តបរិកម្ម ដោយសេចក្តីខ្វល់ខ្វាយនោះ វារៈនៃបរិកម្មរមែង ផុតទៅ បន្ទាប់អំពីនោះ ពន្លឺក៏បាត់ទៅ កាលពន្លឺបាត់ទៅ រូបក៏មិនប្រាកដ ។ កាលបើយ៉ាងនោះ ភិក្ខុនោះគួរចូលឈានជាបាទរឿយៗ លុះចេញចាកឈាន នោះ គប្បីផ្សាយពន្លឺទៅ ពន្លឺរមែងមានកម្លាំងច្រើនតាមលំដាប់ ដោយប្រការ ដូច្នេះ ។ ពន្លឺនឹងតាំងនៅក្នុងឋានៈ ដែលកំណត់ទុកថា ពន្លឺចូរមានក្នុងទីនេះ ដូច្នេះ ។ ការឃើញរូប រមែងមានដល់ភិក្ខុដែលអង្គុយមើលសូម្បីអស់ថ្ងៃ ។ ក្នុងការឃើញរូបនោះ កាលណារូបនេះ គឺរូបដែលមិនទៅកាន់គន្លងនៃមំសចក្ខុ រូបនៅក្នុងផ្ទៃ រូបអាស្រ័យហទយវត្ថុ រូបអាស្រ័យនៅក្រោមផែនដី រូបនៅ

ខាងក្រៅជញ្ជាំង ភ្នំ និងកំពែង រូបដែលនៅក្នុងចក្កវាឡដទៃរមែងមកកាន់គន្លង នៃញាណចក្ខុរបស់ភិក្ខុនោះ ដូចឃើញដោយមំសចក្ខុ កាលនោះ ទិព្វចក្ខុ រមែងកើតឡើង ។ ទិព្វចក្ខុនោះ អាចឃើញរូបក្នុងទីនេះបាន មិនមែនចិត្ត ដែលជាចំណែកខាងដើម ។

ក្នុងសេចក្ដីនោះ មានលំដាប់នៃការកើតឡើងរបស់ទិព្វចក្ខុ ដូចតទៅនេះ ពាក្យថា កាលមនោទ្វារាវជ្ជនៈ ធ្វើរូបមានប្រការដូចពោលហើយនោះ ឲ្យជា អារម្មណ៍កើតឡើងហើយរលត់ទៅ ជវនចិត្ត ៤ ឬ ៥ ខណៈ ធ្វើរូបនោះឯង ឲ្យជាអារម្មណ៍ ហើយកើតឡើង គប្បីជ្រាបតាមន័យដែលធ្លាប់ពោលហើយ នោះឯង ។ម្យ៉ាងទៀត ញាណនេះ លោកពោលថា ចុតូបបាតញ្ញាណរបស់ សត្វទាំងឡាយខ្លះ ទិព្វចក្ខុញ្ញាណខ្លះ ។ ញាណនេះ រមែងជាអន្តរាយ ដល់ បុថុជ្ជនព្រោះបុថុជ្ជននោះអធិដ្ឋានថា ពន្លឺចូរមានក្នុងទីណាៗ ទីនោះៗ ក៏នឹងមាន ពន្លឺធ្លុះទៅក្នុងផែនដី សមុទ្ទ និងភ្នំដូចគ្នាតែមួយ ។ ពេលនោះ កាលបុថុជ្ជននោះ ឃើញរូប មានយក្ស អារក្សទឹកជាដើមដែលគួរខ្លាចក្នុងទីនោះ ក៏កើតសេចក្ដី ភ័យខ្លាចឡើង ព្រោះហេតុនោះ លោកក៏ដល់នូវការរាយមាយនៃចិត្ត ជា អ្នកសាបសូន្យចាកឈាន ព្រោះហេតុនោះ មិនគួរប្រមាទក្នុងការឃើញរូប ។

បទថា **សត្តានំ ចុតូបបាតញ្ញាណាយ** បានដល់ ដើម្បីញាណដែលដឹង ចុតិ និងបដិសន្ធិរបស់សត្វទាំងឡាយ គឺដើម្បីញាណជាហេតុដឹងចុតិ និង បដិសន្ធិរបស់សត្វទាំងឡាយ អធិប្បាយថា ដើម្បីទិព្វចក្ខុញ្ញាណ ។

បទថា **ទិព្វេន ចក្ខុនា** នេះ មានសេចក្ដីដូចបានពោលហើយ ។ បទថា

**វិសុទ្ធេន** ឈ្មោះថា **វិសុទ្ធេន** ព្រោះជាហេតុនៃទិដ្ឋិវិសុទ្ធិ ដោយការឃើញចុតិនិងបដិសន្ធិ ។ ពិតហើយ បុគ្គលណា ឃើញត្រឹមតែចុតិប៉ុណ្ណោះ មិនឃើញបដិសន្ធិ បុគ្គលនោះរមែងកាន់យកដោយឧច្ឆេទទិដ្ឋិ បុគ្គលណាឃើញបដិសន្ធិប៉ុណ្ណោះ មិនឃើញចុតិ បុគ្គលនោះរមែងកាន់យកដោយទិដ្ឋិ គឺការប្រាកដនៃសត្វថ្មី ។

ចំណែកបុគ្គលណាឃើញទាំងពីរយ៉ាងនោះ បុគ្គលនោះព្រោះកន្លងទិដ្ឋិទាំងពីរនោះបាន ហេតុនោះ ការឃើញរបស់បុគ្គលនោះ ទើបជាហេតុនៃទិដ្ឋិវិសុទ្ធិ ។ ពុទ្ធបុត្តទាំងឡាយរមែងឃើញទាំងពីរយ៉ាងនោះ ។ ដោយហេតុនេះ ទើបលោកពោលថា ឈ្មោះថា បរិសុទ្ធ ព្រោះហេតុនៃទិដ្ឋិវិសុទ្ធិដោយការឃើញចុតិ និងបដិសន្ធិ ។ ឈ្មោះថា **អតិក្កន្តមានុសកំ** ព្រោះឃើញរូបកន្លងឧបចារៈរបស់មនុស្ស ឬឈ្មោះថា **អតិក្កន្តមានុសកំ** ព្រោះកន្លងមំសចក្ខុរបស់មនុស្ស ។ ដោយទិព្វចក្ខុដែលបរិសុទ្ធកន្លងបង់នូវចក្ខុរបស់មនុស្ស ។

បទថា **សត្តេ បស្សតិ** បានដល់ សម្លឹងមើលសត្វទាំងឡាយ ដូចមើលដោយមំសចក្ខុរបស់មនុស្ស ។ ក្នុងបទនេះថា **ចវមានេ ឧបបជ្ជមានេ** មានអធិប្បាយថា បុគ្គលណាមួយមិនអាចឃើញដោយទិព្វចក្ខុក្នុងខណៈចុតិ ឬក្នុងខណៈបដិសន្ធិ ។ សត្វពួកណាជិតចុតិ នឹងចុតិក្នុងឥឡូវនេះ សត្វពួកនោះឈ្មោះថា កំពុងចុតិ ។ ចំណែកសត្វពួកណាបដិសន្ធិហើយ ឬកើតហើយឥឡូវនេះ សត្វពួកនោះលោកបំណងថា កំពុងបដិសន្ធិ ។ លោកសម្តែងថា រមែងឃើញសត្វទាំងនោះបែបនេះ ដែលកំពុងចុតិ និងកំពុងបដិសន្ធិ ។

បទថា **ហីនេ** បានដល់ គួរស្អប់ គួរនឿយណាយ គួរតិះដៀល គួរមើលងាយ ដោយអំណាចនៃជាតិត្រកូល និងភោគៈជាដើម ដែលថោកទាប ព្រោះប្រកបដោយផលរបស់មោហៈ ។ បទថា **បណីតេ** បានដល់ ផ្ទុយគ្នានឹង **ហីនេ** នោះ ព្រោះប្រកបដោយផលរបស់អមោហៈ ។ បទថា **សុវណ្ណេ** បានដល់ ប្រកបដោយពណ៌សម្បុរគួរប្រាថ្នា គួរស្រឡាញ់ គួរពេញចិត្ត ព្រោះប្រកបដោយផលរបស់អទោសៈ ។ បទថា **ទុព្វណ្ណេ** បានដល់ ប្រកបដោយពណ៌សម្បុរមិនគួរប្រាថ្នា មិនគួរស្រឡាញ់ មិនគួរពេញចិត្ត ព្រោះប្រកបដោយផលរបស់ទោសៈ អធិប្បាយថា មិនស្អាត មានរូបខុសប្រក្រតី ។ បទថា **សុគតេ** បានដល់ កើតក្នុងសុគតិភព ឬស្តុកស្តម្ភមានទ្រព្យច្រើន ព្រោះប្រកបដោយផលរបស់អលោភៈ ។ បទថា **ទុគ្គតេ** បានដល់ កើតក្នុងទុគ្គតិភព ឬក្រីក្រ មានបាយ និងទឹកតិច ព្រោះប្រកបដោយផលរបស់លោភៈ ។ បទថា **យថាកម្មូបគេ** បានដល់ ប្រព្រឹត្តទៅតាមកម្មដែលបានសន្សំ លោកពោលដល់កិច្ចរបស់ទិព្វចក្ខុដោយពាក្យដំបូងថា **ចវមានេ** ជាដើម ។ តែដោយបទនេះ លោកពោលដល់កិច្ចនៃយថាកម្មូបគញ្ញាណ គឺញាណកំណត់ដឹងថា សត្វប្រព្រឹត្តទៅតាមកម្ម ។ មួយវិញទៀត លំដាប់នៃការកើតរបស់ញាណនោះ មានដូច្នេះថា ភិក្ខុក្នុងសាសនានេះចម្រើនអាលោកកសិណ មានមុខឆ្ពោះទៅកាន់នរកខាងក្រោម រមែងឃើញសត្វនរកទាំងឡាយ សោយទុក្ខធំក្រៃលែង ការឃើញនោះឯងជាកិច្ចរបស់ទិព្វចក្ខុ ភិក្ខុនោះមនសិការយ៉ាងនេះថា សត្វទាំងនេះ ធ្វើកម្មអ្វីហ្ន៎ ទើបត្រូវសោយទុក្ខនោះ គ្រានោះឯង ញាណមានកម្មនោះៗ ជាអារម្មណ៍ កើត

ដល់ភិក្ខុនោះថា ព្រោះធ្វើកម្មនេះ ។

ម្យ៉ាងទៀត ភិក្ខុចម្រើនអាលោកកសិណ មានមុខឆ្ពោះទៅកាន់ទេវលោកខាងលើ ឃើញសត្វទាំងឡាយសោយមហាសម្បត្តិក្នុងសួននន្ទនវន មិស្សកវន និងបារុសកវនជាដើម ។ ការឃើញនោះក៏ជាកិច្ចរបស់ទិព្វចក្ខុនោះឯង ។ ភិក្ខុនោះមនសិការយ៉ាងនេះថា សត្វទាំងនេះ ធ្វើកម្មអ្វីហ្ន៎ ទើបត្រូវសោយសម្បត្តិនេះ គ្រានោះឯង ញាណមានកម្មនោះជាអារម្មណ៍ កើតដល់ភិក្ខុនោះថា ព្រោះធ្វើកម្មនេះ ឈ្មោះថា យថាកម្មូបគញ្ញាណ ។ ការបរិកម្មញែកចេញទៅដើម្បីញាណនេះ រមែងមិនមាន ។ សូម្បីអនាគតំសញ្ញាណក៏ដូចញាណនេះ ។ ពិតហើយ ញាណទាំងនេះ មានទិព្វចក្ខុញ្ញាណជាបាទ រមែងសម្រេចព្រមជាមួយទិព្វចក្ខុនោះឯង ។

បទថា **ឥមេ** ក្នុងបទជាដើមថា **ឥមេ វត ភោន្តោ** ជាពាក្យសម្តែងឧទាហរណ៍នៃសត្វទាំងឡាយ ដែលឃើញដោយទិព្វចក្ខុ ។ បទថា **វត** ជានិបាតចុះក្នុងអត្ថនៃការរំពឹងដល់ ។ បទថា **ភោន្តោ** បានដល់ អ្នកដ៏ចម្រើនទាំងឡាយ ។ ឈ្មោះថា ទុច្ចរិត ព្រោះប្រព្រឹត្តសេចក្តីអាក្រក់ ឬប្រព្រឹត្តវត្ថុដែលអាក្រក់ ព្រោះស្អុយដោយកិលេស ។ ឈ្មោះថា កាយទុច្ចរិត ព្រោះប្រព្រឹត្តអាក្រក់ផ្លូវកាយ ឬការប្រព្រឹត្តអាក្រក់កើតឡើងតាមផ្លូវកាយ ។ សូម្បីក្នុងបទក្រៅពីនោះ ក៏មានន័យនេះដូចគ្នា ។

បទថា **សមន្នាគតា** បានដល់ ជាអ្នកដល់ព្រមហើយ ។ បទថា **អរិយានំ ឧបវាទកា** បានដល់ ជាអ្នកប្រាថ្នាសេចក្តីវិនាសដល់ព្រះអរិយៈ គឺ

ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះសាវក ដោយហោចសូម្បីដល់គ្រហស្ថដែលជាសោតាបន្ន តិះដៀល អធិប្បាយថា ជេរប្រទេចដោយអន្តិមវត្ថុ ឬដោយការកម្ចាត់គុណ ។ ក្នុងពាក្យតិះដៀលនោះ បុគ្គលពោលថា សមណធម៌របស់លោកទាំងនេះមិនមាន លោកទាំងនេះមិនមែនសមណៈ គប្បីជ្រាបថា ឈ្មោះថាតិះដៀលដោយអន្តិមវត្ថុ បុគ្គលពោលពាក្យជាដើមថា ឈាន វិមោក្ខ មគ្គ ឬផលរបស់លោកទាំងនេះមិនមាន គប្បីជ្រាបថា ឈ្មោះថា តិះដៀលដោយការកម្ចាត់គុណ ។ តែបុគ្គលនោះ ដឹងក្តី មិនដឹងក្តី គប្បីតិះដៀលសូម្បីទាំងពីរយ៉ាងឈ្មោះថា ជាការតិះដៀលព្រះអរិយៈទាំងអស់ ។ ការតិះដៀលព្រះអរិយៈជាកម្មធ្ងន់ ហាមសួគ៌ និងហាមមគ្គដូចគ្នានឹងអនន្តរិយកម្ម តែជាសតេកិច្ឆាគឺល្មមកែខៃបាន ។ ព្រោះហេតុនោះ បុគ្គលណា តិះដៀលព្រះអរិយៈ បុគ្គលនោះ បើខ្លួនចាស់ជាង គួរទៅរក ហើយអង្គុយប្រហោងសូមខមាទោសថា ខ្ញុំបានពោលពាក្យនេះៗ នឹងលោកម្ចាស់ សូមលោកម្ចាស់អត់ទោសឲ្យដល់ខ្ញុំចុះ ។ ប្រសិនបើខ្លួនខ្ចី ( វស្សា ) ជាង គួរថ្វាយបង្គំ ហើយអង្គុយប្រហោងផ្គងអញ្ជលី សូមឲ្យអត់ទោសថា បពិត្រលោកម្ចាស់ ខ្ញុំបានពោលពាក្យនេះៗ នឹងលោកម្ចាស់ សូមលោកម្ចាស់អត់ទោសដល់ខ្ញុំចុះ ។

បើព្រះអរិយៈ ចៀសចេញទៅកាន់ទីដទៃ គួរទៅដោយខ្លួនឯង ឬបញ្ជូនសទ្ធិវិហារិកជាដើមទៅ សូមឲ្យលោកអត់ទោសឲ្យ ។ បើមិនអាចទៅបាន ឬមិនអាចបញ្ជូនទៅបាន គួរទៅរកភិក្ខុទាំងឡាយដែលនៅក្នុងវិហារនោះ ។ បើភិក្ខុទាំងឡាយខ្ចីជាង គួរអង្គុយប្រហោង បើចាស់ជាងគួរបដិបត្តិ ដោយន័យ

ដូចពោលហើយក្នុងព្រះអរិយៈដែលចាស់ជាងនោះឯង ហើយពោលសូមខមាទោសថា បពិត្រលោកម្ចាស់ ខ្ញុំបានពោលពាក្យនេះៗ នឹងលោកម្ចាស់ឈ្មោះនោះ សូមលោកម្ចាស់ឈ្មោះនោះអត់ទោសដល់ខ្ញុំចុះ សូម្បីព្រះអរិយៈមិនអត់ទោសឲ្យចំពោះមុខក៏គួរធ្វើបែបនេះឯង ។ បើព្រះអរិយៈជាអ្នកត្រាច់ទៅតែឯងទីលំនៅមិនប្រាកដ គួរទៅរកភិក្ខុដែលឈ្លាសមួយរូប ហើយពោលថា បពិត្រលោកម្ចាស់ ខ្ញុំបានពោលពាក្យនេះនឹងលោកម្ចាស់ឈ្មោះនោះ កាលខ្ញុំរឭកដល់ពាក្យនោះ រមែងមានសេចក្តីក្តៅក្រហាយចិត្ត តើខ្ញុំធ្វើដូចម្តេចល្អ ភិក្ខុរូបនោះនឹងពោលថា សូមលោកម្ចាស់ កុំគិតថ្វីឡើយ ព្រះថេរៈរមែងអត់ទោសឲ្យលោក សូមលោកស្ងប់ចិត្តចុះ ។

សូម្បីភិក្ខុនោះ ក៏គួរផ្គងអញ្ជលីទៅរកទិសដែលព្រះអរិយៈទៅ ហើយពោលថា សូមលោកម្ចាស់អត់ទោសចុះ ។ ប្រសិនបើព្រះអរិយៈនោះបរិនិព្វានហើយ គួរទៅកាន់គ្រែដែលបរិនិព្វានរហូតដល់ឈាបនដ្ឋាន សូមឲ្យអត់ទោស កាលលោកធ្វើយ៉ាងនេះ ការតិះដៀលព្រះអរិយៈមិនឃាត់សួគ៌ មិនឃាត់មគ្គ ត្រឡប់ជាប្រក្រតីនោះឯង ។

បទថា **មិច្ឆាទិដ្ឋិកា** បានដល់ មានការឃើញវិបរិត ។ បទថា **មិច្ឆាទិដ្ឋិកម្មសមាទានា** បានដល់ អ្នកដែលដឹកនាំអ្នកដទៃ ក្នុងកាយកម្មជាដើមដែលមានមិច្ឆាទិដ្ឋិជាមូល ឈ្មោះថា ជាការប្រកាន់កម្មមានបែបផ្សេងៗ ដោយអំណាចនៃមិច្ឆាទិដ្ឋិ ។ ក្នុងទីនេះ ក្នុងកាលការតិះដៀលព្រះអរិយៈ សង្គ្រោះហើយដោយសព្ទថា វចីទុច្ចរិត និងក្នុងកាលមិច្ឆាទិដ្ឋិ សង្គ្រោះហើយដោយសព្ទ

ថា មានទោទុច្ចរិត ការពោលពាក្យទាំងពីរនេះដដែលទៀត គប្បីជ្រាបថា ដើម្បីសម្តែងដល់ការមានទោសច្រើន ។ ការតិះដៀលព្រះអរិយៈ មានទោសច្រើន ព្រោះដូចគ្នានឹងអនន្តរិយកម្ម សូម្បីព្រះមានព្រះភាគ ក៏បានត្រាស់ ( ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសក ) ថា ម្នាលសារីបុត្ត ភិក្ខុបរិបូណ៌ដោយសីលហើយ បរិបូណ៌ដោយសមាធិហើយ បរិបូណ៌ដោយបញ្ញាហើយ សម្រេចអរហត្តផលក្នុងបច្ចុប្បន្ននេះឯង មានឧបមាយ៉ាងណាមិញ ម្នាលសារីបុត្ត តថាគតពោលនូវហេតុនេះ ជាគ្រឿងផ្តល់នូវពាក្យឧបមេយ្យយ៉ាងនោះដែរ បុគ្គលនោះ បើមិនលះបង់នូវវាចានោះទេ មិនលះបង់នូវចិត្តនោះទេ មិនលះបង់នូវទិដ្ឋិនោះទេ នឹងធ្លាក់ទៅរងទុក្ខក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ដូច្នោះឯង ដូច្នេះ ។

ម្យ៉ាងទៀត ទោសដទៃមានទោសច្រើនជាងមិច្ឆាទិដ្ឋិមិនមាន សមដូចព្រះមានព្រះភាគទ្រង់ត្រាស់ ( ក្នុងអង្គុត្តរនិកាយ ឯកនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងមើលមិនឃើញធម៌ដទៃ សម្បីតែធម៌មួយដែលមានទោសធំយ៉ាងនេះដូចមិច្ឆាទិដ្ឋិនេះឡើយភិក្ខុទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ទោសទាំងឡាយ មានតែមិច្ឆាទិដ្ឋិជាទោសក្រៃលែង ដូច្នេះ ។

បទថា **កាយស្ស ភេទា** បានដល់ ព្រោះលះបង់ខន្ធ ដែលមានចិត្តគ្រប់គ្រង ។ បទថា **បរម្មរណា** បានដល់ ក្នុងការកាន់យកខន្ធដែលកើតក្នុងលំដាប់នោះ ។ ម្យ៉ាងវិញទៀត បទថា **កាយស្ស ភេទា** បានដល់ ព្រោះដាច់ជីវិតិន្ទ្រិយ ។ បទថា **បរម្មរណា** បានដល់ បន្ទាប់អំពីចុតិទៅ ។ បទទាំងឡាយ

មានបទថា **អបាយំ** ជាដើម ជាវេវចនៈរបស់នរកនោះឯង ។ ឈ្មោះថា នរក ព្រោះប្រាសចាកសេចក្ដីចម្រើនដែលសន្មតថាជាបុណ្យ ដែលជាហេតុនៃសួគ៌ និងនិព្វាន ។ ឈ្មោះថា អបាយ ព្រោះមិនមានសេចក្ដីចម្រើននៃសេចក្ដីសុខទាំងឡាយ ។ ឈ្មោះថា ទុគ្គតិ ព្រោះអត្ថថា ជាផ្លូវជាទីអាស្រ័យរបស់ទុក្ខ ។ ម្យ៉ាងវិញទៀត គតិកើតឡើងដោយកម្មអាក្រក់ ព្រោះមានទោសៈច្រើន ឈ្មោះថា ទុគ្គតិ ។ ឈ្មោះថា វិនិបាត ព្រោះអត្ថថា ជាទីធ្លាក់ទៅនៃបុគ្គលអ្នកធ្វើកម្មអាក្រក់ដែលអស់អំណាច ។ ម្យ៉ាងវិញទៀត ឈ្មោះថា វិនិបាត ព្រោះអត្ថថា ជាទីធ្លាក់ទៅនៃសត្វដែលវិនាស គឺអវយវៈតូចធំបែកធ្លាយទៅ ។ ឈ្មោះថា និរយ ព្រោះអត្ថថា ជាទីមិនមានសេចក្ដីចម្រើន ដែលសន្មតថា ជាការត្រេកអរ ។ ម្យ៉ាងវិញទៀត លោកសម្ដែងដល់កំណើតតិរច្ឆានដោយអបាយសព្ទ ។ កំណើតតិរច្ឆាន ឈ្មោះថា អបាយ ព្រោះប្រាសចាកសុគតិ មិនឈ្មោះថាទុគ្គតិ ព្រោះនាគរាជជាដើម ដែលមានសក្ដិធំ ក៏កើត ( ក្នុងកំណើតតិរច្ឆាន ) ។ លោកសម្ដែងបិត្តិវិស័យដោយទុគ្គតិសព្ទ ។ ពិតហើយ បិត្តិវិស័យនោះជាអបាយផង ទុគ្គតិផង ព្រោះប្រាសចាកសុគតិ និងព្រោះជាផ្លូវទៅនៃទុក្ខ តែមិនជាវិនិបាត ព្រោះមិនធ្លាក់ទៅដូចជាអសុរ ។ លោកសម្ដែងអសុរកាយដោយវិនិបាតសព្ទ ។ អសុរកាយនោះ ជាអបាយផង ទុគ្គតិផង ដោយអត្ថតាមដែលពោលហើយ លោកហៅថា វិនិបាត ព្រោះធ្លាក់ទៅចាកការប្រជុំរួមគ្នាទាំងអស់ ។ លោកសម្ដែងនរកនោះឯង មានប្រការមិនមែនតិច មានអវិចីជាដើម ដោយនិរយសព្ទ ។ បទថា **ឧបបន្នា** បានដល់ ចូលដល់ហើយ គឺកើតហើយក្នុងអបាយ

ជាដើមនោះ ។ គប្បីជ្រាបធម៌ចំណែក-ស ដោយផ្ទុយគ្នានឹងការដែលពោល ហើយ ។

ចំណែកសេចក្តីផ្សេងគ្នាមានដូចតទៅនេះថា ក្នុងបទទាំងនោះលោកសង្គ្រោះគតិរបស់មនុស្ស ដោយសុគតិសព្ទ ។ សង្គ្រោះគតិរបស់ទេវតា ដោយសគ្គសព្ទ ។ ក្នុងបទថា **សុគតឹ សគ្គំ លោកំ** នោះ មានវិគ្គហៈដូច្នេះថា ឈ្មោះថា សុគតិ ព្រោះអត្ថថា ទៅល្អ ។ ឈ្មោះថា **សគ្គ** ព្រោះអត្ថថា ល្អវិសេសដោយអារម្មណ៍មានរូបជាដើម ។ សូម្បីទាំងអស់នោះ ឈ្មោះថា **លោក** ព្រោះអត្ថថា បែកធ្លាយ ។ នេះជាការអធិប្បាយពាក្យ ។ បទទាំងអស់មានបទថា **ទិព្វេន ចក្ខុនា** ជាដើម ជាពាក្យសរុបដោយប្រការដូច្នេះ ។ សេចក្តីសង្ខេបក្នុងបទនេះមានដូច្នេះថា រមែងឃើញដោយចក្ខុទិព្វយ៉ាងនេះ ។៙

## អដ្ឋកថាទិព្វចក្ខុញ្ញាណនិទ្ទេស ចប់

## បញ្ញាណាយកិណ្ឌកៈ

ក្នុងញាណ ៥ ទាំងនេះ ឥទ្ធិវិធញ្ញាណ រមែងប្រព្រឹត្តទៅក្នុងអារម្មណ៍ ៧ គឺបរិត្តារម្មណ៍ ១ មហគ្គតារម្មណ៍ ១ អតីតារម្មណ៍ ១ អនាគតារម្មណ៍ ១ បច្ចុប្បន្នារម្មណ៍ ១ អជ្ឈត្តារម្មណ៍ ១ ពហិទ្ធារម្មណ៍ ១ ។

សោតធាតុវិសុទ្ធិញ្ញាណ រមែងប្រព្រឹត្តទៅក្នុងអារម្មណ៍ ៤ គឺបរិត្តារម្មណ៍ ១ បច្ចុប្បន្នារម្មណ៍ ១ អជ្ឈត្តារម្មណ៍ ១ ពហិទ្ធារម្មណ៍ ១ ។

ចេតោបរិយញ្ញាណ រមែងប្រព្រឹត្តទៅក្នុងអារម្មណ៍ ៨ គឺបរិត្តារម្មណ៍ ១ មហគ្គតារម្មណ៍ ១ អប្បមាណារម្មណ៍ ១ មគ្គារម្មណ៍ ១ អតីតារម្មណ៍ ១ អនាគតារម្មណ៍ ១ បច្ចុប្បន្នារម្មណ៍ ១ ពហិទ្ធារម្មណ៍ ១ ។

បុព្វេនិវាសានុស្សតិញ្ញាណ រមែងប្រព្រឹត្តទៅក្នុងអារម្មណ៍ ៨ គឺបរិត្តារម្មណ៍ ១ មហគ្គតារម្មណ៍ ១ អប្បមាណារម្មណ៍ ១ មគ្គារម្មណ៍ ១ អតីតារម្មណ៍ ១ អជ្ឈត្តារម្មណ៍ ១ ពហិទ្ធារម្មណ៍ ១ នវត្តព្វារម្មណ៍ ១ ។

ទិព្វចក្ខុញ្ញាណ រមែងប្រព្រឹត្តទៅក្នុងអារម្មណ៍ ៤ គឺបរិត្តារម្មណ៍ ១ បច្ចុប្បន្នារម្មណ៍ ១ អជ្ឈត្តារម្មណ៍ ១ ពហិទ្ធារម្មណ៍ ១ ។

យថាកម្មូបគញ្ញាណ រមែងប្រព្រឹត្តទៅក្នុងអារម្មណ៍ ៥ គឺបរិត្តារម្មណ៍ ១ មហគ្គតារម្មណ៍ ១ អតីតារម្មណ៍ ១ អជ្ឈត្តារម្មណ៍ ១ ពហិទ្ធារម្មណ៍ ១ ។

អនាគតំសញ្ញាណ រមែងប្រព្រឹត្តទៅក្នុងអារម្មណ៍ ៨ គឺបរិត្តារម្មណ៍ ១ មហគ្គត្តារម្មណ៍ ១ អប្បមាណារម្មណ៍ ១ មគ្គារម្មណ៍ ១ អនាគតារម្មណ៍ ១ អជ្ឈត្តារម្មណ៍ ១ ពហិទ្ធារម្មណ៍ ១ នវត្តព្វារម្មណ៍ ១ ។

**បញ្ញាណាយកិណ្ឌកៈ ចប់**

# សុត្តន្តបិដក

[ ២៥៨ ] បញ្ញាដែលស្ទាត់ជំនាញនៃឥន្ទ្រិយទាំង ៣ ដោយអាការ ៦៤ ឈ្មោះថា អាសវក្ខយញ្ញាណ តើដូចម្តេច ។

ឥន្ទ្រិយ ៣ តើអ្វីខ្លះ ។ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ ១ អញ្ញិន្ទ្រិយ ១ អញ្ញាតាវិន្ទ្រិយ ១ ។

អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ ដល់នូវឋានប៉ុន្មានយ៉ាង អញ្ញិន្ទ្រិយ ដល់នូវឋានប៉ុន្មានយ៉ាង អញ្ញាតាវិន្ទ្រិយ ដល់នូវឋានប៉ុន្មានយ៉ាង ។ អនញ្ញាតញ្ញ-ស្សាមីតិន្ទ្រិយ ដល់នូវឋាន ១ គឺសោតាបត្តិមគ្គ អញ្ញិន្ទ្រិយ ដល់នូវឋាន ៦ គឺសោតាបត្តិផល ១ សកទាគាមិមគ្គ ១ សកទាគាមិផល ១ អនាគាមិមគ្គ ១ អនាគាមិផល ១ អរហត្តមគ្គ ១ អញ្ញាតាវិន្ទ្រិយ ដល់នូវឋាន ១ គឺ អរហត្តផល ។

[ ២៥៩ ] ក្នុងខណៈនៃសោតាបត្តិមគ្គ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ មាន សទ្ធិន្ទ្រិយដែលមានការជឿស៊ប់ជាបរិវារ មានវីរិយិន្ទ្រិយ ដែលមានការផ្គង ឡើងជាបរិវារ មានសតិន្ទ្រិយដែលមានការប្រុងប្រយ័ត្នជាបរិវារ មានសមា-ធិន្ទ្រិយដែលមានការមិនរាយមាយជាបរិវារ មានបញ្ញិន្ទ្រិយ ដែលមានការ ឃើញជាបរិវារ មានមនិន្ទ្រិយដែលមានការដឹងច្បាស់ជាបរិវារ មានសោម-នស្សិន្ទ្រិយដែលមានការសើមជ្រាយជាបរិវារ មានជីវិតិន្ទ្រិយ ដែលមានភាព នៃសន្តតិ កំពុងប្រព្រឹត្តទៅជាអធិបតីជាបរិវារ ធម៌ទាំងឡាយដែលកើតក្នុង ខណៈនៃសោតាបត្តិមគ្គ លើកលែងតែរូបដែលមានចិត្តជាសមុដ្ឋានចេញ សុទ្ធ

តែជាកុសលទាំងអស់ សុទ្ធតែមិនមានអាសវៈទាំងអស់ សុទ្ធតែនាំសត្វចេញចាកវដ្តៈទាំងអស់ សុទ្ធតែដល់នូវការមិនសន្សំនូវកិលេសទាំងអស់ សុទ្ធតែជាលោកុត្តរទាំងអស់ សុទ្ធតែមាននិព្វានជាអារម្មណ៍ទាំងអស់ ក្នុងខណៈនៃសោតាបត្តិមគ្គ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ មានឥន្ទ្រិយទាំង ៨ នេះ ដែលមានសហជាតប្បច្ច័យជាបរិវារ ដែលមានអញ្ញមញ្ញប្បច្ច័យជាបរិវារ ដែលមាននិស្សយប្បច្ច័យជាបរិវារ ដែលមានសម្បយុត្តប្បច្ច័យជាបរិវារ ប្រព្រឹត្តទៅជាមួយគ្នា កើតជាមួយគ្នា លាយឡំជាមួយគ្នា ប្រកបជាមួយគ្នា ធម៌ទាំងនោះជាអាការផង ជាបរិវារផង នៃអនញ្ញាតញ្ញស្សាមីតិន្ទ្រិយនោះ ។

[ ២៦០ ] ក្នុងខណៈនៃសោតាបត្តិផល អញ្ញិន្ទ្រិយ មានសទ្ធិន្ទ្រិយដែលមានការជឿស៊ប់ជាបរិវារ មានវីរិយិន្ទ្រិយដែលមានការផ្គងឡើងជាបរិវារ មានសតិន្ទ្រិយដែលមានការប្រុងប្រយ័ត្នជាបរិវារ មានសមាធិន្ទ្រិយដែលមានការមិនរាយមាយជាបរិវារ មានបញ្ញិន្ទ្រិយដែលមានការឃើញជាបរិវារ មានមនិន្ទ្រិយដែលមានការដឹងច្បាស់ជាបរិវារ មានសោមនស្សិន្ទ្រិយ ដែលមានការសើមជ្រាយជាបរិវារ មានជីវិតិន្ទ្រិយដែលមានភាពនៃសន្តតិកំពុងប្រព្រឹត្តទៅជាអធិបតីជាបរិវារ ធម៌ទាំងឡាយដែលកើតក្នុងខណៈនៃសោតាបត្តិផល លើកលែងតែរូបដែលមានចិត្តជាសមុដ្ឋានចេញ សុទ្ធតែជាអព្យាក្រឹតទាំងអស់ សុទ្ធតែមិនមានអាសវៈទាំងអស់ សុទ្ធតែជាលោកុត្តរទាំងអស់ សុទ្ធតែមាននិព្វានជាអារម្មណ៍ទាំងអស់ ក្នុងខណៈនៃសោតាបត្តិផល អញ្ញិន្ទ្រិយមានឥន្ទ្រិយទាំង ៨ នេះ ដែលមានសហជាតប្បច្ច័យជាបរិវារ ដែលមានអញ្ញមញ្ញ-

ប្បច្ច័យជាបរិវារ ដែលមាននិស្សយប្បច្ច័យជាបរិវារ ដែលមានសម្បយុត្ត-ប្បច្ច័យ ជាបរិវារ ប្រព្រឹត្តទៅជាមួយគ្នា កើតជាមួយគ្នា លាយឡំជាមួយគ្នា ប្រកបជាមួយគ្នា ធម៌ទាំងនោះជាអាការផង ជាបរិវារផងនៃអញ្ញិន្ទ្រិយនោះ ។

[ ២៦១ ] ក្នុងខណៈនៃសកទាគាមិមគ្គ ។បេ។ ក្នុងខណៈនៃសកទាគា-មិផល ។បេ។ ក្នុងខណៈនៃអនាគាមិមគ្គ ។បេ។ ក្នុងខណៈនៃអនាគាមិផល ។បេ។ ក្នុងខណៈនៃអរហត្តមគ្គ អញ្ញិន្ទ្រិយ មានសទ្ធិន្ទ្រិយដែលមានការជឿស៊ប់ជាបរិវារ ។បេ។ មានជីវិតិន្ទ្រិយដែលមានភាពនៃសន្តតិកំពុងប្រព្រឹត្តទៅជាអធិ-បតីជាបរិវារ ធម៌ទាំងឡាយដែលកើតក្នុងខណៈនៃអរហត្តមគ្គ លើកលែងតែរូបដែលមានចិត្តជាសមុដ្ឋានចេញ សុទ្ធតែជាកុសលទាំងអស់ សុទ្ធតែមិនមានអាសវៈទាំងអស់ សុទ្ធតែនាំសត្វឲ្យចេញចាកវដ្តៈទាំងអស់ សុទ្ធតែដល់នូវការមិនសន្សំនូវកិលេសទាំងអស់ សុទ្ធតែជាលោកុត្តរទាំងអស់ សុទ្ធតែមាននិព្វានជាអារម្មណ៍ទាំងអស់ ក្នុងខណៈនៃអរហត្តមគ្គ អញ្ញិន្ទ្រិយ មានឥន្ទ្រិយទាំង ៨ នេះ ដែលមានសហជាតប្បច្ច័យជាបរិវារ ដែលមានអញ្ញមញ្ញប្បច្ច័យជាបរិវារ ដែលមាននិស្សយប្បច្ច័យជាបរិវារ ដែលមានសម្បយុត្តប្បច្ច័យជាបរិវារ ប្រព្រឹត្តទៅជាមួយគ្នា កើតជាមួយគ្នា លាយឡំគ្នា ប្រកបជាមួយគ្នា ធម៌ទាំងនោះ ជាអាការផង ជាបរិវារផង នៃអញ្ញិន្ទ្រិយនោះ ។

[ ២៦២ ] ក្នុងខណៈនៃអរហត្តផល អញ្ញាតាវិន្ទ្រិយ មានសទ្ធិន្ទ្រិយដែលមានការជឿស៊ប់ជាបរិវារ មានវីរិយិន្ទ្រិយដែលមានការផ្គងឡើងជាបរិវារ មានសតិន្ទ្រិយដែលមានការប្រុងប្រយ័ត្នជាបរិវារ មានសមាធិន្ទ្រិយដែលមានការ

មិនរាយមាយជាបរិវារ មានបញ្ញិន្ទ្រិយដែលមានការឃើញជាបរិវារ មានមនិន្ទ្រិយ ដែលមានការដឹងច្បាស់ជាបរិវារ មានសោមនស្សិន្ទ្រិយដែលមានការសើមជ្រាយជាបរិវារ មានជីវិតិន្ទ្រិយដែលមានភាពនៃសន្តតិកំពុងប្រព្រឹត្តទៅជាអធិបតីជាបរិវារ ធម៌ទាំងឡាយដែលកើតក្នុងខណៈនៃអរហត្តផល លើកលែងតែរូបដែលមានចិត្តជាសមុដ្ឋានចេញ សុទ្ធតែជាអព្យាក្រឹតទាំងអស់ សុទ្ធតែមិនមានអាសវៈទាំងអស់ សុទ្ធតែជាលោកុត្តរទាំងអស់ សុទ្ធតែមាននិព្វានជាអារម្មណ៍ទាំងអស់ ក្នុងខណៈនៃអរហត្តផល អញ្ញាតាវិន្ទ្រិយមានឥន្ទ្រិយទាំង ៨ នេះដែលមានសហជាតប្បច្ច័យជាបរិវារ ដែលមានអញ្ញមញ្ញប្បច្ច័យជាបរិវារ ដែលមាននិស្សយប្បច្ច័យជាបរិវារ ដែលមានសម្បយុត្តប្បច្ច័យជាបរិវារ ប្រព្រឹត្តទៅជាមួយគ្នា កើតជាមួយគ្នា លាយឡំគ្នា ប្រកបជាមួយគ្នា ធម៌ទាំងនោះ ជាអាការផង ជាបរិវារផងនៃអញ្ញាតាវិន្ទ្រិយនោះ ឥន្ទ្រិយនោះមានប្រមាណ ៨ ប្រាំបីដងត្រូវជា ៦៤ យ៉ាងនេះឯង ។

[ ២៦៣ ] សំណួរត្រង់ពាក្យថា អាសវៈ តើអាសវៈ ដូចម្តេចខ្លះ ។ កាមាសវៈ ១ ភវាសវៈ ១ ទិដ្ឋាសវៈ ១ អវិជ្ជាសវៈ ១ ។ អាសវៈទាំងនុ៎ះរមែងអស់ក្នុងធម៌ដូចម្តេច ។ ទិដ្ឋាសវៈអស់ ឥតមានសេសសល់ កាមាសវៈដែលញ៉ាំងសត្វឲ្យទៅកាន់អបាយក៏អស់ ភវាសវៈដែលញ៉ាំងសត្វឲ្យទៅកាន់អបាយក៏អស់ អវិជ្ជាសវៈដែលញ៉ាំងសត្វឲ្យទៅកាន់អបាយ ក៏អស់ដោយសោតាបត្តិមគ្គ អាសវៈទាំងនេះ រមែងអស់ក្នុងធម៌នេះឯង កាមាសវៈដ៏គ្រោតគ្រាតរមែងអស់ ភវាសវៈដែលស្ថិតនៅជាមួយនឹងកាមាសវៈនោះក៏អស់

*អវិជ្ជាសវៈដែលស្ថិតនៅជាមួយនឹងភវាសវៈនោះក៏អស់ ដោយសកទាគាមិមគ្គ អាសវៈទាំងនេះ រមែងអស់ក្នុងធម៌នេះឯង កាមាសវៈអស់ឥតមានសេសសល់ ភវាសវៈដែលស្ថិតនៅជាមួយគ្នានឹងកាមាសវៈនោះក៏អស់ អវិជ្ជាសវៈដែលស្ថិតនៅជាមួយនឹងភវាសវៈនោះក៏អស់ ដោយអនាគាមិមគ្គ អាសវៈទាំងនេះ រមែងអស់ក្នុងធម៌នេះឯង ភវាសវៈអស់ឥតមានសេសសល់ អវិជ្ជាសវៈអស់ដោយអរហត្តមគ្គ អាសវៈទាំងនេះ រមែងអស់ក្នុងធម៌នេះឯង ឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាដែលស្ទាត់ជំនាញនៃឥន្ទ្រិយទាំង ៣ ដោយអាការ ៦៤ ឈ្មោះថា អាសវក្ខយញ្ញាណ ។*

# អដ្ឋកថា
# អាសវក្ខយញ្ញាណនិទ្ទេស

[ ២៥៨-២៥៩ ] គប្បីជ្រាបវិនិច្ឆ័យ ក្នុងអាសវក្ខយញ្ញាណនិទ្ទេសដូចតទៅ បទថា **អនញ្ញាតញ្ញស្សាមីតិន្ទ្រិយំ** ជាដើម មានអត្ថដូចបានពោលហើយ ។ បទថា **កតិដ្ឋានានិ គច្ឆតិ** ជាពាក្យសួរដើម្បីកំណត់ឋានៈដែលកើតនៃឥន្ទ្រិយនីមួយៗ ។ បទថា **ឯកំ ឋានំ គច្ឆតិ** លោកអធិប្បាយថា រមែងកើតក្នុងឋានៈ ១ ។ ឋានៈជាឱកាសដែលកើត លោកពោលថា ឋានៈ ព្រោះជាទីតាំង ។ បទថា **ឆ ឋានានិ** បានដល់ ក្នុងខណៈមគ្គ និងផល ៦ ។ ដើម្បីសម្តែងឥន្ទ្រិយទាំងឡាយថា ក្នុងឥន្ទ្រិយ ៣ មានអនញ្ញាតញ្ញស្សាមីតិន្ទ្រិយជាដើម ឥន្ទ្រិយនីមួយៗ ប៉ុណ្ណោះជាធំ ទើបលោកពោលពាក្យជាដើមថា **សទ្ធិន្ទ្រិយំ អធិមោក្ខបរិវារំ ហោតិ។** ក្នុងបទថា **សទ្ធិន្ទ្រិយស្ស អធិមោក្ខដ្ឋោ** អត្ថនៃការជឿស៊ប់របស់សទ្ធិន្ទ្រិយ[១] ជាដើម លោកពោលអធិមោក្ខ ដោយអំណាចកិច្ចនៃសទ្ធិន្ទ្រិយជាដើមយ៉ាងណា សូម្បីក្នុងទីនេះក៏យ៉ាងនោះ លោកពោលថា បទថា **អធិមោក្ខបរិវារំ ហោតិ** បានដល់ សទ្ធិន្ទ្រិយជាបរិវារ ដោយកិច្ចនៃការបង្អោនចិត្តជឿ ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះ ។ បទថា **បរិវារំ** ជាលិង្គវិបល្លាស ។

បទថា **បញ្ញិន្ទ្រិយំ** លោកពោលចែកអនញ្ញាតញ្ញស្សាមីតិន្ទ្រិយនោះឯង ទុកដោយឡែកដើម្បីសម្តែងសភាពដឹង ។ សូម្បីក្នុងអភិធម្ម លោកក៏ចែកបញ្ញា

---

១- បទនេះ មានត្រង់លេខឃ្នាប ៣២ ។

តែម្យ៉ាងប៉ុណ្ណោះក្នុងខណៈមគ្គ និងក្នុងខណៈផល ៨ ចំណែក ដើម្បីសម្តែងសេចក្តីពិសេសនៃកិច្ចដោយបញ្ញា ។ បទថា **អភិសន្ទនបរិវារំ** បានដល់សោមនស្សិន្ទ្រិយជាបរិវារនៃចិត្ត និងចេតសិកដោយកិច្ច គឺសេចក្តីស្នេហាដូចទឹកជាបរិវារនៃលម្អិតដុសខ្ទនក្នុងវេលាងូតទឹក ។ បទនេះ លោកពោលដោយអំណាចមគ្គ ដែលសម្បយុត្តដោយសោមនស្សនោះឯង គប្បីឃើញឧបេក្ខិន្ទ្រិយក្នុងឋានៈនៃសោមនស្សិន្ទ្រិយ ក្នុងមគ្គដែលសម្បយុត្តដោយឧបេក្ខា ។ ម្យ៉ាងទៀត គប្បីកាន់យកឧបេក្ខិន្ទ្រិយនោះថា មានការមិនបន្ថែមឡើង ជាបរិវារនៃសម្បយុត្តធម៌ទាំងឡាយ ។

បទថា **បវត្តសន្តតាធិបតេយ្យបរិវារំ** បានដល់ ការបន្តដែលកំពុងប្រព្រឹត្តទៅ ឈ្មោះថា បវត្តសន្តតិ អធិប្បាយថា សន្តានដែលកំពុងប្រព្រឹត្តទៅ ។ ភាពជាអធិបតី ឈ្មោះថា អធិតេយ្យ អធិតេយ្យក្នុងការបន្ត ដែលកំពុងប្រព្រឹត្តទៅ ឈ្មោះថា **បវត្តសន្តតាធិបតេយ្យ**។ ជីវិតិន្ទ្រិយជាបរិវារនៃអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ ព្រោះជាបច្ច័យដល់ជីវិតិន្ទ្រិយ ដែលកំពុងប្រព្រឹត្តទៅ និងដល់ការប្រព្រឹត្តទៅខាងមុខ ដោយភាពជាអធិបតីនៃការបន្ត ដែលប្រព្រឹត្តទៅដោយអំណាចនៃខាងដើម និងខាងចុង ។ បទថា **សោតាបត្តិមគ្គក្ខណេ ជាតា ធម្មា** ជាដើម លោកពោលដើម្បីសម្តែងដល់គុណនៃធម៌ដែលសម្បយុត្តដោយមគ្គទាំងពួង ។ ក្នុងបទទាំងនោះ បទថា **មគ្គក្ខណេ ជាតា** បានដល់ ធម៌ដែលតាំងឡើងក្នុងមគ្គប៉ុណ្ណោះ មិនមែនធម៌ដទៃ ។ ព្រោះរូបសូម្បីតាំងឡើងក្នុងខណៈមគ្គ ក៏មិនបាន ឈ្មោះថា កុសលជាដើម ។ ហេតុនោះ

ព្រះសារីបុត្តត្ថេរ កាលនាំរូបនោះចេញទៅ ទើបពោលថា **ឋបេត្វា ចិត្តសមុដ្ឋានំ រូបំ** ដូច្នេះ ។ ធម៌ទាំងឡាយទាំងពួងនោះជាកុសល ដោយអត្ថថា មានការទម្លាយវត្ថុគួរខ្ពើមជាដើម ។ ធម៌ទាំងនោះ ធ្វើនិព្វានឲ្យជាអារម្មណ៍ ហើយប្រព្រឹត្តទៅ ។ ឈ្មោះថា **អនាសវា** ព្រោះអត្ថថា ធម៌ទាំងនោះ មិនមានអាសវៈ ។ ធម៌ទាំងឡាយ កាត់មូលនៃវដ្ដៈ ធ្វើនិព្វានឲ្យជាអារម្មណ៍ ឈ្មោះថា **និយ្យានិកា** ព្រោះអត្ថថា នាំចេញចាកវដ្ដៈ ។ ធម៌ទាំងឡាយ ឈ្មោះថា **អបចយគាមិនោ** ព្រោះអត្ថថា ដល់នូវការមិនសន្សំ ព្រោះប្រាសចាកការសន្សំ ពោលគឺកុសល និងអកុសល ព្រោះធ្វើនិព្វាន ពោលគឺការមិនសន្សំឲ្យជាអារម្មណ៍ប្រព្រឹត្តទៅ ឈ្មោះថា **អបចយគាមិនោ** ព្រោះអត្ថថា មិនសន្សំ គឺកម្ចាត់វត្ថុដែលប្រព្រឹត្តទៅ ។ ឈ្មោះថា **លោកុត្តរា** ព្រោះអត្ថថា ឆ្លងឡើង គឺផុតចាកលោកដោយការមិនទាក់ទងក្នុងលោក ។ ឈ្មោះថា **និព្វានារម្មណា** ព្រោះអត្ថថា ធម៌ទាំងនោះ មាននិព្វានជាអារម្មណ៍ ។

បទថា **ឥមានិ អដ្ឋិន្ទ្រិយានិ** ជាដើម លោកពោលដើម្បីសម្ដែងភាពជាបរិវារ ដូចបានពោលហើយក្នុងកាលមុន ភាពជាធម៌ដែលសហគតៈដោយឥន្ទ្រិយនោះជាដើម និងអាការដូចបានពោលហើយក្នុងខាងដើម ។ ក្នុងបទទាំងនោះ បទថា **អដ្ឋិន្ទ្រិយានិ** បានដល់ ឥន្ទ្រិយ ៨ មួយអន្លើដោយបញ្ញិន្ទ្រិយ ដោយន័យដូចពោលហើយខាងដើម ។

បទថា **សហជាតបរិវារា** បានដល់ ឥន្ទ្រិយ ៧ ក្រៅអំពីនេះ មួយអន្លើដោយឥន្ទ្រិយនីមួយៗ ក្នុងឥន្ទ្រិយ ៨ ជាសហជាតធម៌ ទើបឈ្មោះថាជា

សហជាតធម៌ ដែលជាបរិវារនៃអនញ្ញាតញ្ញស្សាមីតិន្ទ្រិយនោះ ។ ដូចគ្នានោះឯង ធម៌ដទៃជាបរិវាររបស់ធម៌ដទៃ ធម៌ដទៃក៏ជាបរិវាររបស់ធម៌ដទៃ ព្រោះហេតុនោះ មានអញ្ញមញ្ញប្បច្ច័យជាបរិវារ មាននិស្សយប្បច្ច័យជាបរិវារ មានសម្បយុត្តប្បច្ច័យជាបរិវារ ដូចគ្នានោះឯង ។

បទថា **សហគតា** បានដល់ ដល់នូវភាពជាធម៌ដែលកើតរួមគ្នាជាដើមជាមួយនឹងអនញ្ញាតញ្ញស្សាមីតិន្ទ្រិយនោះ ។ បទថា **សហជាតា** បានដល់ កើតព្រមគ្នាជាមួយអនញ្ញាតញ្ញស្សាមីតិន្ទ្រិយនោះ ។ បទថា **សំសដ្ឋា** បានដល់ លាយឡំជាមួយអនញ្ញាតញ្ញស្សាមីតិន្ទ្រិយនោះ ។ បទថា **សម្បយុត្តា** បានដល់ ប្រកបដោយប្រការមានការកើតរួមគ្នាជាដើម ស្មើគ្នាដោយអនញ្ញ-តញ្ញស្សាមីតិន្ទ្រិយនោះ ។ បទថា **តេ** បានដល់ ធម៌ គឺឥន្ទ្រិយទាំង ៨ នោះឯង ។ បទថា **តស្ស** បានដល់ របស់អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ ។ បទថា **អាការា** បានដល់ ចំណែកដែលជាបរិវារ ។

[ ២៦០ ] បទថា **ផលក្ខណេ ជាតា ធម្មា សព្វេវ អព្យាកតា ហោន្តិ** បានដល់ លោកពោលធម៌ទាំងឡាយ មួយអន្លើដោយរូបដែលមានចិត្តជាសមុដ្ឋាន ព្រោះសូម្បីរូបក៏ជាអព្យាកតៈ ។ ក្នុងខណៈនៃផល លោកមិនពោលថា ជាកុសល ជានិយ្យានិកៈ និងជាអបចយគាមី ព្រោះមគ្គប៉ុណ្ណោះជាកុសល ជានិយ្យានិកៈ ( ធម៌ជាគ្រឿងនាំចេញ ) និងជាអបចយគាមី ( ធម៌ជាគ្រឿងឲ្យដល់នូវការមិនសន្សំ ) ។

[ ២៦២ ] បទថា **ឥតិ** ជាដើម ជាបទសរុបមានប្រការដូចពោលហើយ ។

ក្នុងបទទាំងនោះ បទថា **អដ្ឋដ្ឋកានិ** បានដល់ ពួក ៨ នៃឥន្ទ្រិយ ៨ ពួក ដោយអំណាចពួក ៨ មួយពួកៗ ក្នុងមគ្គ និងផល ៨ ។ បទថា **ចតុសដ្ឋិ ហោន្តិ** បានដល់ រួមជាអាការ ៦៤ ។

[ ២៦៣ ] បទថា **អាសវា** ជាដើម មានសេចក្តីដូចពោលហើយ ក្នុងខាងដើមនោះឯង ។ ក្នុងទីនេះ គប្បីជ្រាបថា លោកមិនបានពោលដល់អាសវៈ ដែលគប្បីលះដោយអរហត្តមគ្គ តែពោលដល់អាសវៈដែលគប្បីលះដោយមគ្គ ៣ ដ៏សេស ដែលលោកពោលហើយដោយត្រឹមតែជាពាក្យពោលទូទៅ ដល់ការអស់អាសវៈ ។ ពិតហើយ លោកពោលដល់អរហត្តមគ្គញ្ញាណប៉ុណ្ណោះ ថា ខយញ្ញាណ ព្រោះអាសវៈទាំងឡាយអស់ទៅ ដោយមិនមានអាសវៈណាមួយសេសសល់ឡើយ ។ ព្រោះហេតុនោះ ទើបលោកពោលថា ព្រះអរហន្តប៉ុណ្ណោះ ជាអ្នកមានអាសវៈអស់ហើយ ។

## អដ្ឋកថាអាសវក្ខយញ្ញាណនិទ្ទេស ចប់

# សុត្តន្តបិដក

[ ២៦៤ ] បញ្ញា ក្នុងអត្ថថា កំណត់ដឹង ឈ្មោះថា ទុក្ខញ្ញាណ បញ្ញា ក្នុងអត្ថថា លះ ឈ្មោះថា សមុទយញ្ញាណ បញ្ញា ក្នុងអត្ថថា ធ្វើឲ្យជាក់ច្បាស់ ឈ្មោះថា និរោធញ្ញាណ បញ្ញា ក្នុងអត្ថថា ចម្រើន ឈ្មោះថា មគ្គញ្ញាណ តើដូចម្តេច ។ ទុក្ខសច្ច មានអត្ថថា បៀតបៀន មានអត្ថថា ក្តៅក្រហាយ មានអត្ថថា បច្ច័យតាក់តែង មានអត្ថថា ប្រែប្រួល មានអត្ថថា គួរកំណត់ដឹង សមុទយសច្ច មានអត្ថថា ប្រមូលមក មានអត្ថថា ជាហេតុ មានអត្ថថា ប្រកបព្រម មានអត្ថថា កង្វល់ មានអត្ថថា លះបង់ និរោធសច្ច មានអត្ថថា រលាស់ចេញ មានអត្ថថា ស្ងាត់ មានអត្ថថា មិនមានបច្ច័យប្រជុំតាក់តែង មានអត្ថថា មិនស្លាប់ មានអត្ថថា ធ្វើឲ្យជាក់ច្បាស់ មគ្គសច្ច មានអត្ថថា ស្រោចស្រង់ មានអត្ថថា ជាហេតុ មានអត្ថថា ឃើញ មានអត្ថថា ជាអធិបតី មានអត្ថថា គួរចម្រើន ឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវធម៌ ឈ្មោះថា បញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញា ក្នុងអត្ថថា កំណត់ដឹង ឈ្មោះថា ទុក្ខញ្ញាណ បញ្ញា ក្នុងអត្ថថា លះ ឈ្មោះថា សមុទយញ្ញាណ បញ្ញា ក្នុងអត្ថថា ធ្វើឲ្យជាក់ច្បាស់ ឈ្មោះថា និរោធញ្ញាណ បញ្ញាក្នុងអត្ថថា ចម្រើន ឈ្មោះថា មគ្គញ្ញាណ ។

[ ២៦៥ ] ទុក្ខញ្ញាណ ទុក្ខសមុទយញ្ញាណ ទុក្ខនិរោធញ្ញាណ ទុក្ខនិរោធគាមិនីបដិបទាញ្ញាណ តើដូចម្តេច ។ ញាណរបស់បុគ្គលដែលប្រកបព្រមដោយមគ្គ ឈ្មោះថា ទុក្ខញ្ញាណផង ឈ្មោះថា ទុក្ខសមុទយញ្ញាណផង ឈ្មោះថា ទុក្ខនិរោធញ្ញាណផង ឈ្មោះថា ទុក្ខនិរោធគាមិនីបដិបទាញ្ញាណផង ។

[ ២៦៦ ] បណ្ដាញាណទាំងនោះ ទុក្ខញាណ តើដូចម្ដេច ។ បញ្ញា ការដឹងច្បាស់ សេចក្ដីពិចារណាធម៌ សេចក្ដីជ្រើសរើស សេចក្ដីពិចារណា ការកំណត់ ការកត់សម្គាល់ ការកត់ត្រា ភាពជាបណ្ឌិត ភាពជាអ្នកឈ្លាសវៃ ភាពជាបុគ្គលមានសេចក្ដីជ្រះស្អាត ភាពជាបុគ្គលមានសេចក្ដីភ្លឺច្បាស់ ការគិតសេចក្ដីយល់ ធម្មជាតដូចជាផែនដី ធម្មជាតកម្ចាត់កិលេស ធម្មជាតណែនាំ ធម្មជាតឃើញច្បាស់ សេចក្ដីដឹងល្អ សភាពដូចជាជន្ទួញ បញ្ញា បញ្ញិន្ទ្រិយ បញ្ញាពល គ្រឿងសស្ត្រា គឺបញ្ញា ប្រាសាទ គឺបញ្ញា ពន្លឺ គឺបញ្ញា ឱភាស គឺបញ្ញា គ្រឿងធ្នុះ គឺបញ្ញា រតនៈ គឺបញ្ញា សេចក្ដីមិនវង្វេង ធម្មវិចយ សម្មាទិដ្ឋិឯណា ប្រារព្ធនូវសេចក្ដីទុក្ខ ហើយកើតឡើង នេះលោកហៅថា ទុក្ខញាណ ។

[ ២៦៧ ] បញ្ញា ការដឹងច្បាស់ ។បេ។ សេចក្ដីមិនវង្វេង ធម្មវិចយ សម្មាទិដ្ឋិណា ប្រារព្ធនូវទុក្ខសមុទ័យ ។បេ។ ប្រារព្ធនូវទុក្ខនិរោធ ។បេ។ ប្រារព្ធនូវទុក្ខនិរោធគាមិនីបដិបទា ហើយកើតឡើង នេះលោកហៅថា ទុក្ខនិរោធគាមិនីបដិបទាញាណ ឈ្មោះថា ញាណ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថា ប្រាជ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា ទុក្ខញាណ ទុក្ខសមុទយញាណ ទុក្ខនិរោធញាណ ទុក្ខនិរោធគាមិនីបដិបទាញាណ ។

# អដ្ឋកថា

# សច្ចញាណចតុក្កទ្វយនិទ្ទេស

[ ២៦៤-២៦៧ ] គប្បីជ្រាបវិនិច្ឆ័យ ក្នុងសច្ចញាណចតុក្កទ្វយនិទ្ទេសដូចតទៅ បទថា **ទុក្ខស្ស បីឡនដ្ឋោ** ជាដើម មានអត្ថដូចបានពោលហើយ ។ បទថា **មគ្គសមង្គិស្ស ញាណំ ទុក្ខេបេតំ ញាណំ** លោកពោលដោយអំណាចការត្រាស់ដឹងក្នុងលើកទីមួយ ហាក់បីដូចត្រាស់ដឹងក្នុងពួក ៤ ដោយមិនមានចន្លោះ ។ ពិតហើយ សច្ចញាណមាន ២ យ៉ាង គឺលោកិយ ១ លោកុត្តរ ១ ។ លោកិយមាន ២ គឺអនុពោធិញាណ ១ បច្ចវេក្ខ-ណញ្ញាណ ១ ។

អនុពោធិញាណ រមែងប្រព្រឹត្តទៅក្នុងនិរោធ និងមគ្គ ដោយអំណាចការបានស្តាប់មកជាដើម របស់បុគ្គលដែលផ្តើមបំពេញព្យាយាម រមែងប្រព្រឹត្តទៅ ក្នុងទុក្ខ និងសមុទយៈ ដោយអំណាចធ្វើឲ្យជាអារម្មណ៍ ។

បច្ចវេក្ខណញ្ញាណ រមែងប្រព្រឹត្តទៅក្នុងសច្ចៈ ៤ របស់ភិក្ខុអ្នកចាក់ធ្លុះសច្ចៈហើយដោយអំណាចធ្វើឲ្យជាអារម្មណ៍ ។ លោកុត្តរ ក៏គឺបដិវេធញ្ញាណធ្វើនិរោធឲ្យជាអារម្មណ៍ហើយ រមែងចាក់ធ្លុះសច្ចៈ ៤ ដោយកិច្ច ។ ដូចព្រះមានព្រះភាគ ត្រាស់ ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលណាឃើញទុក្ខ បុគ្គលនោះឈ្មោះថា ឃើញទុក្ខសមុទ័យផង ឃើញទុក្ខនិរោធផង ឃើញទុក្ខនិរោធគាមិនីបដិបទាផង ដូច្នេះ ។ គប្បីពោលដល់ន័យទាំងអស់ ។ ក្នុងទីនេះ ក៏ត្រាស់ដល់បដិវេធញ្ញាណនេះឯង

ដោយវារៈនេះ ។ តែញាណនោះ ក៏ត្រាស់ដើម្បីសម្តែងថា សូម្បីលោកុត្តរៈ រមែងបាននូវឈ្មោះទាំងឡាយថា **ទុក្ខេ ញាណំ** ជាដើម ។ តែក្នុងទីនេះ លោកបំណងយកលោកិយញ្ញាណប៉ុណ្ណោះ ។ ព្រោះហេតុនោះ ទើបព្រះសារីបុត្តត្រូវពោលថា **តត្ថ កតមំ ទុក្ខេ ញាណំ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ទុក្ខំ អារព្ភ** បានដល់ ទាញយកទុក្ខសច្ច គឺធ្វើឲ្យជាអារម្មណ៍ ។ ក្នុងបទថា **បញ្ញា** ជាដើម គប្បីជ្រាបអធិប្បាយដូចតទៅ ឈ្មោះថា បញ្ញា ព្រោះអត្ថថា ឲ្យដឹង ពោលគឺធ្វើអត្ថនោះៗ ឲ្យប្រាកដ ។ម្យ៉ាងវិញទៀត ឈ្មោះថា បញ្ញា ព្រោះអត្ថថា ដឹងធម៌ទាំងឡាយដោយប្រការនោះៗ មានការមិនទៀងជាដើម ។ បទនេះ ជាបទសម្តែងសភាវៈរបស់បញ្ញានោះ ។ អាការដឹងច្បាស់ ឈ្មោះថា **បជានានា** ។ ឈ្មោះថា **វិចយោ** ព្រោះអត្ថថា ញែកចេញនូវការមិនទៀងជាដើម ។ បទថា **បវិចយោ** លោកបន្ថែមពាក្យឧបសគ្គ ( ចុះ ប ឧបសគ្គ ) អធិប្បាយថា ញែកចេញដោយទូទៅ ។ ឈ្មោះថា **ធម្មវិចយោ** ព្រោះអត្ថថា ជ្រើសរើសនូវសច្ចធម៌ ៤ ។ ឈ្មោះថា **សល្លក្ខណា** ដោយអំណាចការកំណត់ការមិនទៀងជាដើម ដោយប្រពៃ ។ សល្លក្ខណានោះឯង លោកពោលថា ឧបលក្ខណា និងបច្ចុបលក្ខណា ដោយផ្សេងគ្នាត្រង់ឧបសគ្គ អធិប្បាយថា ការកំណត់សម្គាល់យ៉ាងខ្ពស់ ឈ្មោះថា ការចូលទៅកំណត់សម្គាល់ដែលអាស្រ័យធម៌ មានការមិនទៀងជាដើមនោះៗ ។ភាពជាបណ្ឌិតឈ្មោះថា **បណ្ឌិច្ចំ** ។ ភាពជាអ្នកឈ្លាស ឈ្មោះថា **កោសល្លំ** ។ ភាពជាបុគ្គលល្អិតល្អន់ ឈ្មោះថា **នេបុញ្ញំ** ។ ឈ្មោះថា **វេភព្យា** ដោយអំណាច

ការដឹងច្បាស់នូវការមិនទៀងជាដើម ។ ឈ្មោះថា **ចិន្តា** ដោយអំណាចគិតដល់ការមិនទៀងជាដើម ។ ម្យ៉ាងទៀត ឈ្មោះថា **ចិន្តា** ព្រោះញុំាងបុគ្គលដែលកើតនូវការគិតឲ្យគិតដល់ការមិនទៀងជាដើម ។ ឈ្មោះថា **ឧបបរិក្ខា** ព្រោះពិចារណាដល់ការមិនទៀងជាដើម ។ ផែនដី ឈ្មោះថា **ភូរិ** បញ្ញានេះ ឈ្មោះថា **ភូរិ** ព្រោះអត្ថថា ដូចផែនដី ដោយអត្ថថា ល្អិត និងដោយអត្ថថា ទូលំទូលាយ ។ ម្យ៉ាងវិញទៀត បញ្ញានោះឯង លោកពោលថា **ភូរិ** ព្រោះអត្ថថា ត្រេកអរក្នុងអត្ថដែលពិត ។ ឈ្មោះថា **មេធា** ព្រោះអត្ថថា ទម្លាយ គឺប្រហារកិលេសទាំងឡាយ ដូចរន្ទះទម្លាយភ្នំថ្ម ដូច្នោះ ។ ម្យ៉ាងវិញទៀត ឈ្មោះថា **មេធា** ព្រោះអត្ថថា កាន់យក និងទ្រទ្រង់បានរហ័ស ។ ឈ្មោះថា **បរិណាយិកា** ព្រោះអត្ថថា រមែងនាំបុគ្គលដែលកើតបញ្ញាទៅក្នុងបដិបទាដើម្បីប្រយោជន៍ដល់ខ្លួន និងក្នុងការចាក់ធ្លុះសម្បយុត្តធម៌ តាមលក្ខណៈដែលពិត ។ ឈ្មោះថា **វិបស្សនា** ព្រោះអត្ថថា ឃើញធម៌ទាំងឡាយជាក់ច្បាស់ ដោយអំណាចការមិនទៀងជាដើម ។ ឈ្មោះថា **សម្បជានោ** ព្រោះដឹងការមិនទៀងជាដើមដោយប្រពៃដោយទូទៅ ។ ភាពនៃសម្បជានៈនោះ ឈ្មោះថា **សម្បជញ្ញំ** ។ បញ្ញាដូចជន្លួញ ឈ្មោះថា **បតោទោ** ព្រោះអត្ថថា ចាក់នូវចិត្តវៀចវេរដែលស្ទុះទៅក្រៅផ្លូវ ដើម្បីឲ្យចូលផ្លូវដូចជន្លួញចាក់សេះសន្ធពដែលរត់ទៅក្រៅផ្លូវ ដើម្បីឲ្យឡើងកាន់ផ្លូវដូច្នោះ ។ ឈ្មោះថា **ឥន្ទ្រិយំ** ព្រោះអត្ថថា ធ្វើភាពជាធំក្នុងលក្ខណៈឃើញ ។ ភាពជាធំ គឺបញ្ញា ឈ្មោះថា **បញ្ញិន្ទ្រិយំ** ។ លោកអធិប្បាយដូចម្ដេច ។ លោកមិនពោលពាក្យនេះថា ឥន្ទ្រិយនៃបញ្ញា

ឈ្មោះថា បញ្ញិន្ទ្រិយ ដូចពាក្យជាដើមថា ឥន្ទ្រិយរបស់បុរស ឈ្មោះថា បុរិ-សិន្ទ្រិយ ដោយពិត ឥន្ទ្រិយ គឺបញ្ញា ឈ្មោះថា បញ្ញិន្ទ្រិយ ។ ឈ្មោះថា **បញ្ញាពលំ** ព្រោះអត្ថថា មិនញាប់ញ័រទៅដោយអវិជ្ជា ។ បញ្ញាដូចជាសស្ត្រា ព្រោះអត្ថថា កាត់កិលេស ទើបឈ្មោះថា **បញ្ញាសត្ថំ** ។ បញ្ញាដូចជាប្រាសាទ ដោយអត្ថថា ឡើងទៅខ្ពស់ ទើបឈ្មោះថា **បញ្ញាបាសាទោ** ។ បញ្ញាដូចជាពន្លឺ ដោយអត្ថថា ធ្វើឲ្យភ្លឺស្វាង ទើបឈ្មោះថា **បញ្ញាអាលោកោ** ។ បញ្ញាដូចជារស្មី ដោយអត្ថថា ធ្វើឲ្យភ្លឺ ទើបឈ្មោះថា **បញ្ញាឱភាសោ** ។ បញ្ញាដូចប្រទីប ដោយអត្ថថា ធ្វើឲ្យភ្លឺ ទើបឈ្មោះថា **បញ្ញាបជ្ជោតោ** ។ ពិតហើយ លោកធាតុមួយម៉ឺនមានពន្លឺតែមួយ មានឱកាសតែមួយ មានគ្រឿងធ្លុះតែមួយរមែងប្រាកដដល់អ្នកមានបញ្ញាដែលអង្គុយដោយភ្នែនតែមួយ ដោយហេតុនោះ ទើបលោកពោលបទទាំង ៣ នោះ ។ មួយវិញទៀត ក្នុង ៣ បទនេះ សូម្បីដោយបទមួយក៏សម្រេចសេចក្តីដូចគ្នា ព្រះមានព្រះភាគ ទ្រង់សម្តែងសូត្រពួកណា ដោយអធ្យាស្រ័យរបស់សត្វទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ សេចក្តីរុងរឿងនេះ មាន ៤ យ៉ាង ។ សេចក្តីរុងរឿង ៤ យ៉ាង តើដូចម្តេចខ្លះ ។ គឺសេចក្តីរុងរឿងនៃព្រះចន្ទ ១ សេចក្តីរុងរឿងនៃព្រះអាទិត្យ ១ សេចក្តីរុងរឿងនៃភ្លើង ១ សេចក្តីរុងរឿងនៃប្រាជ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីរុងរឿង ៤ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាសេចក្តីរុងរឿងទាំង ៤ នេះ សេចក្តីរុងរឿងដែលប្រសើរនុ៎ះ គឺសេចក្តីរុងរឿងនៃប្រាជ្ញា ។ យ៉ាងនោះឯង ម្នាលភិក្ខុទាំងឡាយ រស្មីរុងរឿងនេះមាន ៤ យ៉ាង ។ ម្នាលភិក្ខុទាំង

ឡាយ ពន្លឺរស្មីនេះមាន ៤ យ៉ាង[១] ដូច្នេះ ។ ក្នុងទីនេះព្រះថេរៈ ក៏សម្ដែងដោយសមគួរដល់សូត្រនោះ ព្រោះថា អត្ថដែលចែកដោយអាការមិនមែនតិច ក៏ជាការចែកល្អហើយ អត្ថដទៃរមែងដឹងបានដោយប្រការដទៃ អត្ថដទៃក៏រមែងដឹងបានដោយប្រការដទៃទៀត ។ បញ្ញាដូចរតនៈ ដោយអត្ថថា ធ្វើសេចក្ដីត្រេកអរ ឲ្យនូវការត្រេកអរ ញ៉ាំងការត្រេកអរឲ្យកើត ធ្វើឲ្យវិចិត្រ ប្រាកដឡើងបានដោយលំបាក ប្រឹងមិនបាន ជាគ្រឿងប្រើប្រាស់របស់សត្វដែលមិនថោកថយ ទើបឈ្មោះថា **បញ្ញារតនំ** ។

ឈ្មោះថា **អមោហោ** ព្រោះអត្ថថា ជាហេតុមិនឲ្យសត្វវង្វេង ឬខ្លួនឯងក៏មិនវង្វេងក្នុងអារម្មណ៍ ។ បទថា **ធម្មវិចយ** មានអត្ថដូចពោលហើយ ព្រោះហេតុអ្វី ទើបលោកពោលទៀត ។ ព្រោះដើម្បីសម្ដែងភាពដែលអមោហៈជាបដិបក្ខចំពោះមោហៈ ដោយហេតុនោះ ទើបលោកសម្ដែងពាក្យនេះទុកថា អមោហៈនេះ មិនមែនធម៌ក្រៅចាកមោហៈតែម្យ៉ាងប៉ុណ្ណោះទេ តែគង់ជាបដិបក្ខចំពោះមោហៈ ក្នុងទីនេះ លោកបំណងយកអមោហៈ ពោល គឺការពិចារណាធម៌ ។

---

១- បិដកលេខ ៤២ ឃ្នាប ១៤៣-១៤៥ ។

បទថា **សម្មាទិដ្ឋិ** បានដល់ កុសលទិដ្ឋិដែលជាគ្រឿងនាំសត្វចេញទៅបានយ៉ាងពិតប្រាកដ ។

សួរថា ក្នុងញាណទាំងនោះ ទុក្ខសមុទយញ្ញាណ ទុក្ខនិរោធញ្ញាណ ទុក្ខ-និរោធគាមិនីបដិបទាញ្ញាណ តើដូចម្ដេច ( ទោះបីមិនបានឆ្លើយ ) លោកក៏បានពោលហើយ ដោយអំណាចបង្រួញសេចក្ដី ដោយប្រការដូច្នេះ ៕

**អដ្ឋកថាសច្ចញ្ញាណចតុក្កទ្វយនិទ្ទេស ចប់**

# សុត្តន្តបិដក

[ ២៦៨ ] អត្ថប្បដិសម្ភិទាញាណ ធម្មប្បដិសម្ភិទាញាណ និរុត្តិប្បដិសម្ភិទាញាណ បដិភាណប្បដិសម្ភិទាញាណ តើដូចម្តេច ។ ញាណក្នុងអត្ថទាំងឡាយ ឈ្មោះថា អត្ថប្បដិសម្ភិទាញាណ ញាណក្នុងធម៌ទាំងឡាយ ឈ្មោះថា ធម្មប្បដិសម្ភិទាញាណ ញាណក្នុងនិរុត្តិទាំងឡាយ ឈ្មោះថា និរុត្តិប្បដិសម្ភិទាញាណ ញាណក្នុងបដិភាណ ឈ្មោះថា បដិភាណប្បដិសម្ភិទាញាណ ប្រាជ្ញាក្នុងអត្ថផ្សេងៗ ឈ្មោះថា អត្ថប្បដិសម្ភិទាញាណ ប្រាជ្ញាក្នុងធម៌ផ្សេងៗ ឈ្មោះថា ធម្មប្បដិសម្ភិទាញាណ ប្រាជ្ញាក្នុងនិរុត្តិផ្សេងៗ ឈ្មោះថា និរុត្តិប្បដិសម្ភិទាញាណ ប្រាជ្ញាក្នុងបដិភាណផ្សេងៗ ឈ្មោះថា បដិភាណប្បដិសម្ភិទាញាណ ប្រាជ្ញាក្នុងការស្ទង់នូវអត្ថ ឈ្មោះថា អត្ថប្បដិសម្ភិទាញាណ ប្រាជ្ញាក្នុងការស្ទង់នូវធម៌ ឈ្មោះថា ធម្មប្បដិសម្ភិទាញាណ ប្រាជ្ញាក្នុងការស្ទង់នូវនិរុត្តិ ឈ្មោះថា និរុត្តិប្បដិសម្ភិទាញាណ ប្រាជ្ញាក្នុងការស្ទង់នូវបដិភាណ ឈ្មោះថា បដិភាណប្បដិសម្ភិទាញាណ ប្រាជ្ញាក្នុងការកំណត់នូវអត្ថ ឈ្មោះថា អត្ថប្បដិសម្ភិទាញាណ ប្រាជ្ញាក្នុងការកំណត់នូវធម៌ ឈ្មោះថា ធម្មប្បដិសម្ភិទាញាណ ប្រាជ្ញាក្នុងការកំណត់នូវនិរុត្តិ ឈ្មោះថា និរុត្តិប្បដិសម្ភិទាញាណ ប្រាជ្ញាក្នុងការកំណត់នូវបដិភាណ ឈ្មោះថា បដិភាណប្បដិសម្ភិទាញាណ ប្រាជ្ញាក្នុងការកត់សម្គាល់នូវអត្ថ ឈ្មោះថា អត្ថប្បដិសម្ភិទាញាណ ប្រាជ្ញាក្នុងការកត់សម្គាល់នូវធម៌ ឈ្មោះថា ធម្មប្បដិសម្ភិទាញាណ ប្រាជ្ញាក្នុងការកត់សម្គាល់នូវនិរុត្តិ ឈ្មោះថា និរុត្តិប្បដិសម្ភិទាញាណ ប្រាជ្ញាក្នុងការកត់

សម្គាល់នូវបដិភាណ ឈ្មោះថា បដិភាណប្បដិសម្ភិទាញាណ ប្រាជ្ញាក្នុងការបែកធ្លាយអត្ថ ឈ្មោះថា អត្ថប្បដិសម្ភិទាញាណ ប្រាជ្ញាក្នុងការបែកធ្លាយធម៌ ឈ្មោះថា ធម្មប្បដិសម្ភិទាញាណ ប្រាជ្ញាក្នុងការបែកធ្លាយនិរុត្តិ ឈ្មោះថា និរុត្តិប្បដិសម្ភិទាញាណ ប្រាជ្ញាក្នុងការបែកធ្លាយបដិភាណ ឈ្មោះថា បដិ-ភាណប្បដិសម្ភិទាញាណ ប្រាជ្ញាក្នុងការបង្កើតនូវអត្ថ ឈ្មោះថា អត្ថប្បដិ-សម្ភិទាញាណ ប្រាជ្ញាក្នុងការបង្កើតនូវធម៌ ឈ្មោះថា ធម្មប្បដិសម្ភិទាញាណ ប្រាជ្ញាក្នុងការបង្កើតនូវនិរុត្តិ ឈ្មោះថា និរុត្តិប្បដិសម្ភិទាញាណ ប្រាជ្ញាក្នុងការបង្កើតនូវបដិភាណ ឈ្មោះថា បដិភាណប្បដិសម្ភិទាញាណ ប្រាជ្ញាក្នុងការធ្វុះបំភ្លឺនូវអត្ថ ឈ្មោះថា អត្ថប្បដិសម្ភិទាញាណ ប្រាជ្ញាក្នុងការធ្វុះបំភ្លឺនូវធម៌ ឈ្មោះថា ធម្មប្បដិសម្ភិទាញាណ ប្រាជ្ញាក្នុងការធ្វុះបំភ្លឺនូវនិរុត្តិ ឈ្មោះថា និរុត្តិប្បដិសម្ភិទាញាណ ប្រាជ្ញាក្នុងការធ្វុះបំភ្លឺនូវបដិភាណ ឈ្មោះថា បដិភា-ណប្បដិសម្ភិទាញាណ ប្រាជ្ញាក្នុងការធ្វើអត្ថឲ្យភ្លឺរុងរឿង ឈ្មោះថា អត្ថប្បដិ-សម្ភិទាញាណ ប្រាជ្ញាក្នុងការធ្វើធម៌ឲ្យភ្លឺរុងរឿង ឈ្មោះថា ធម្មប្បដិសម្ភិទា-ញាណ ប្រាជ្ញាក្នុងការធ្វើនិរុត្តិឲ្យភ្លឺរុងរឿង ឈ្មោះថា និរុត្តិប្បដិសម្ភិទាញាណ ប្រាជ្ញាក្នុងការធ្វើបដិភាណឲ្យភ្លឺរុងរឿង ឈ្មោះថា បដិភាណប្បដិសម្ភិទា-ញាណ ប្រាជ្ញាក្នុងការប្រកាសនូវអត្ថ ឈ្មោះថា អត្ថប្បដិសម្ភិទាញាណ ប្រាជ្ញាក្នុងការប្រកាសនូវធម៌ ឈ្មោះថា ធម្មប្បដិសម្ភិទាញាណ ប្រាជ្ញាក្នុងការប្រកាសនូវនិរុត្តិ ឈ្មោះថា និរុត្តិប្បដិសម្ភិទាញាណ ប្រាជ្ញាក្នុងការប្រកាសនូវបដិភាណ ឈ្មោះថា បដិភាណប្បដិសម្ភិទាញាណ ឈ្មោះថា ញាណ

ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថា ប្រាជ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌ ហេតុនោះ លោកពោលថា អត្ថប្បដិសម្ភិទាញាណ ធម្មប្បដិសម្ភិទាញាណ និរុត្តិប្បដិសម្ភិទាញាណ បដិភាណប្បដិសម្ភិទាញាណ ។

# អដ្ឋកថា

# សុទ្ធិកបដិសម្ភិទាញាណនិទ្ទេស

[ ២៦៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសុទ្ធិកបដិសម្ភិទាញាណនិទ្ទេសដូចតទៅនេះថា ព្រះសារីបុត្តត្ថេរមិនបានសម្ដែងដល់ប្រភេទនៃញាណទាំងនេះ ដូចខាងដើម ព្រោះញាណទាំងនេះមិនមានសេចក្ដីផ្សេងគ្នា ទើបពោលបទថា **អត្ថេសុ ញាណំ អត្ថប្បដិសម្ភិទា** ដូច្នេះជាដើម ។ សូម្បីមិនមានការផ្សេងគ្នានៃបញ្ញា លោកក៏ពោលថា **អត្ថនានត្តេ បញ្ញា អត្ថប្បដិសម្ភិទេ ញាណំ** ប្រាជ្ញាក្នុងអត្ថផ្សេងៗ ឈ្មោះថា អត្ថប្បដិសម្ភិទាញាណ ព្រោះមានសេចក្ដីផ្សេងគ្នាដោយអំណាចត្រឹមតែសច្ចធម៌ ៤ ដែលខ្ញុំពោលហើយ ។

ក្នុងបទទាំងនោះ បទថា **នានត្តេ** បានដល់ ក្នុងការៈមិនតិចនៃអត្ថជាដើម ។ បទថា **វវត្ថានេ** បានដល់ ក្នុងការកាត់សម្រេចអត្ថជាដើម ។ បទថា **សល្លក្ខណេ** បានដល់ ក្នុងការឃើញអត្ថជាដើមដោយប្រពៃ ។ បទថា **ឧបលក្ខណេ** បានដល់ ក្នុងការឃើញអត្ថជាដើមយ៉ាងល្អក្រៃលែង ។ បទថា **បភេទេ** បានដល់ ក្នុងប្រភេទផ្សេងៗ នៃអត្ថជាដើម ។ បទថា **បភាវេ** បាន ដល់ ក្នុងការកើតនៃអត្ថជាដើមដោយធ្វើឲ្យប្រាកដ ។ បទថា **ជោតនេ** បាន ដល់ ក្នុងការបង្ហាញអត្ថជាដើម ។ បទថា **វិរោចនេ** បានដល់ ក្នុងការសម្ដែងអត្ថជាដើមច្រើនយ៉ាង ។ បទថា **បកាសនេ** បានដល់ ក្នុងការប្រកាសអត្ថជាដើម ។ លោកពោលធ្វើបទថា **នានត្តេ** ឲ្យជាមូលបទដោយអំណាចទូទៅដល់បទទាំងអស់ ។ ក្នុងបទទាំងនេះ គប្បីប្រកបអត្ថយ៉ាងនេះថា បទថា

**វិវដ្ដានេ** *លោកពោលដោយអំណាចព្រះសោតាបន្ន បទថា* **សល្លក្ខណា** *លោកពោលដោយអំណាចព្រះសកទាគាមី ។ បទថា* **បភេទេ បភាវេនេ** *លោកពោលដោយអំណាចព្រះអនាគាមី ។ បទថា* **ជោតនេ វិរោចនេ បកាសនេ** *លោកពោលដោយអំណាចព្រះអរហន្ត ។l៚*

## អដ្ឋកថាសុទ្ធិកបដិសម្ភិទាញាណនិទ្ទេស ចប់

# សុត្តន្តបិដក

[ ២៦៩ ] ឥន្ទ្រិយបរោបរិយត្តញ្ញាណរបស់តថាគត តើដូចម្តេច ។ ព្រះតថាគត ទ្រង់ឃើញពួកសត្វក្នុងលោកនេះដែលមានធូលីតិចក្នុងភ្នែក មានធូលីច្រើនក្នុងភ្នែក មានឥន្ទ្រិយចាស់ក្លា មានឥន្ទ្រិយទន់ មានអាការល្អ មានអាការអាក្រក់ ជាសត្វគួរឲ្យត្រាស់ដឹងបានដោយងាយ ឲ្យត្រាស់ដឹងបានដោយក្រ សត្វពួកខ្លះ ឃើញបរលោក និងទោស មានភគៈជាដើមថាជាភ័យ សត្វពួកខ្លះ មិនឃើញបរលោក និងទោស មានភគៈជាដើម ថាជាភ័យឡើយ ( ញាណបែបនេះ ឈ្មោះថា ឥន្ទ្រិយបរោបរិយត្តញ្ញាណរបស់ព្រះតថាគត ) ។

[ ២៧០ ] ត្រង់ពាក្យថា មានធូលីតិចក្នុងភ្នែក មានធូលីច្រើនក្នុងភ្នែក គឺបុគ្គលដែលមានសទ្ធា ឈ្មោះថា អ្នកមានធូលីតិចក្នុងភ្នែក បុគ្គលដែលឥតសទ្ធា ឈ្មោះថា អ្នកមានធូលីច្រើនក្នុងភ្នែក បុគ្គលដែលមានព្យាយាមប្រារព្ធហើយ ឈ្មោះថា អ្នកមានធូលីតិចក្នុងភ្នែក បុគ្គលដែលខ្ជិលច្រអូស ឈ្មោះថា អ្នកមានធូលីច្រើនក្នុងភ្នែក បុគ្គលដែលមានស្មារតីតម្កល់មាំ ឈ្មោះថា អ្នកមានធូលីតិចក្នុងភ្នែក បុគ្គលដែលភ្លេចស្មារតី ឈ្មោះថា អ្នកមានធូលីច្រើនក្នុងភ្នែក បុគ្គលដែលមានចិត្តតម្កល់មាំ ឈ្មោះថា អ្នកមានធូលីតិចក្នុងភ្នែក បុគ្គលដែលមានចិត្តមិនតម្កល់មាំ ឈ្មោះថា អ្នកមានធូលីច្រើនក្នុងភ្នែក បុគ្គលដែលមានប្រាជ្ញា ឈ្មោះថា អ្នកមានធូលីតិចក្នុងភ្នែក បុគ្គលដែលឥតប្រាជ្ញា ឈ្មោះថា អ្នកមានធូលីច្រើនក្នុងភ្នែក ។

[ ២៧១ ] ត្រង់ពាក្យថា មានឥន្ទ្រិយចាស់ក្លា មានឥន្ទ្រិយទន់ គឺបុគ្គល

ដែលមានសទ្ធា ឈ្មោះថា អ្នកមានឥន្ទ្រិយចាស់ក្លា បុគ្គលដែលឥតសទ្ធា ឈ្មោះថា អ្នកមានឥន្ទ្រិយទន់ បុគ្គលដែលមានព្យាយាមប្រារព្ធហើយ ឈ្មោះថា អ្នកមានឥន្ទ្រិយចាស់ក្លា បុគ្គលដែលខ្ជិលច្រអូស ឈ្មោះថា អ្នកមានឥន្ទ្រិយទន់ បុគ្គលដែលមានស្មារតីតម្កល់មាំ ឈ្មោះថា អ្នកមានឥន្ទ្រិយចាស់ក្លា បុគ្គលដែលភ្លេចស្មារតី ឈ្មោះថា អ្នកមានឥន្ទ្រិយទន់ បុគ្គលដែលមានចិត្តតម្កល់មាំ ឈ្មោះថា អ្នកមានឥន្ទ្រិយចាស់ក្លា បុគ្គលដែលមានចិត្តមិនតម្កល់មាំ ឈ្មោះថា អ្នកមានឥន្ទ្រិយទន់ បុគ្គលដែលមានប្រាជ្ញា ឈ្មោះថា អ្នកមានឥន្ទ្រិយចាស់ក្លា បុគ្គលដែលឥតប្រាជ្ញា ឈ្មោះថា ជាអ្នកមានឥន្ទ្រិយទន់ ។

[ ២៧២ ] ត្រង់ពាក្យថា មានអាការល្អ មានអាការអាក្រក់ គឺបុគ្គលដែលមានសទ្ធា ឈ្មោះថា អ្នកមានអាការល្អ បុគ្គលដែលឥតសទ្ធា ឈ្មោះថា អ្នកមានអាការអាក្រក់ បុគ្គលដែលមានព្យាយាមប្រារព្ធហើយ ឈ្មោះថា អ្នកមានអាការល្អ បុគ្គលដែលខ្ជិលច្រអូស ឈ្មោះថា អ្នកមានអាការអាក្រក់ បុគ្គលដែលមានស្មារតីតម្កល់មាំ ឈ្មោះថា អ្នកមានអាការល្អ បុគ្គលដែលភ្លេចស្មារតី ឈ្មោះថា អ្នកមានអាការអាក្រក់ បុគ្គលដែលមានចិត្តតម្កល់មាំ ឈ្មោះថា អ្នកមានអាការល្អ បុគ្គលដែលមានចិត្តមិនតម្កល់មាំ ឈ្មោះថា អ្នកមានអាការអាក្រក់ បុគ្គលដែលមានប្រាជ្ញា ឈ្មោះថា អ្នកមានអាការល្អ បុគ្គលដែលឥតប្រាជ្ញា ឈ្មោះថា អ្នកមានអាការអាក្រក់ ។

[ ២៧៣ ] ពាក្យថា គួរឲ្យត្រាស់ដឹងបានដោយងាយ គួរឲ្យត្រាស់ដឹង

បានដោយក្រ គឺបុគ្គលដែលមានសទ្ធា ឈ្មោះថា អ្នកគួរឲ្យត្រាស់ដឹងបាន ដោយងាយ បុគ្គលដែលឥតសទ្ធា ឈ្មោះថា អ្នកគួរឲ្យត្រាស់ដឹងបានដោយ ក្រ បុគ្គលដែលមានព្យាយាមប្រារព្ធហើយ ឈ្មោះថា អ្នកគួរឲ្យត្រាស់ដឹង បានដោយងាយ បុគ្គលដែលខ្ជិលច្រអូស ឈ្មោះថា អ្នកគួរឲ្យត្រាស់ដឹងបាន ដោយក្រ បុគ្គលដែលមានស្មារតីតម្កល់មាំ ឈ្មោះថា អ្នកគួរឲ្យត្រាស់ដឹង បានដោយងាយ បុគ្គលដែលភ្លេចស្មារតី ឈ្មោះថា អ្នកគួរឲ្យត្រាស់ដឹងបាន ដោយក្រ បុគ្គលដែលមានចិត្តតម្កល់មាំ ឈ្មោះថា អ្នកគួរឲ្យត្រាស់ដឹងបាន ដោយងាយ បុគ្គលដែលមានចិត្តមិនតម្កល់មាំ ឈ្មោះថា អ្នកគួរឲ្យត្រាស់ដឹង បានដោយក្រ បុគ្គលដែលមានប្រាជ្ញា ឈ្មោះថា អ្នកគួរឲ្យត្រាស់ដឹងបានដោយ ងាយ បុគ្គលដែលឥតប្រាជ្ញា ឈ្មោះថា អ្នកគួរឲ្យត្រាស់ដឹងបានដោយក្រ ។

[ ២៧៤ ] ពាក្យថា សត្វពួកខ្លះ ឃើញបរលោក និងទោស មានរាគៈជា ដើមថាជាភ័យ សត្វពួកខ្លះមិនឃើញបរលោក និងទោស មានរាគៈជាដើមថា ជាភ័យ សេចក្តីថា បុគ្គលដែលមានសទ្ធា ឈ្មោះថា អ្នកឃើញបរលោក និង ទោស មានរាគៈជាដើម ថាជាភ័យ បុគ្គលដែលឥតសទ្ធា ឈ្មោះថា អ្នកមិន ឃើញនូវបរលោក និងទោស មានរាគៈជាដើម ថាជាភ័យ បុគ្គលដែលមាន ព្យាយាមប្រារព្ធហើយ ឈ្មោះថា អ្នកឃើញនូវបរលោក និងទោស មានរាគៈ ជាដើម ថាជាភ័យ បុគ្គលដែលខ្ជិលច្រអូស ឈ្មោះថា អ្នកមិនឃើញនូវបរ- លោក និងទោស មានរាគៈជាដើមថាជាភ័យ បុគ្គលដែលមានស្មារតីតម្កល់មាំ ឈ្មោះថា អ្នកឃើញនូវបរលោក និងទោស មានរាគៈជាដើមថាជាភ័យ បុគ្គល

ដែលភ្លេចស្មារតី ឈ្មោះថា អ្នកមិនឃើញនូវបរលោក និងទោស មានរាគៈជាដើមថាជាភ័យ បុគ្គលដែលមានចិត្តតម្កល់មាំ ឈ្មោះថា អ្នកឃើញនូវបរលោក និងទោស មានរាគៈជាដើម ថាជាភ័យ បុគ្គលដែលមានចិត្តមិនតម្កល់មាំ ឈ្មោះថា អ្នកមិនឃើញនូវបរលោក និងទោស មានរាគៈជាដើម ថាជាភ័យ បុគ្គលដែលមានប្រាជ្ញា ឈ្មោះថា អ្នកឃើញនូវបរលោក និងទោស មានរាគៈជាដើមថាជាភ័យ បុគ្គលដែលឥតប្រាជ្ញា ឈ្មោះថា អ្នកមិនឃើញនូវបរលោក និងទោស មានរាគៈជាដើមថាជាភ័យ ។

[ ២៧៥ ] ពាក្យថា លោក បានដល់ ខន្ធលោក ធាតុលោក អាយតនលោក វិបត្តិភវលោក គឺអបាយលោក វិបត្តិសម្ភវលោក គឺអកុសលកម្មដែលនាំទៅកើតក្នុងអបាយ សម្បត្តិភវលោក គឺសុគតិលោក សម្បត្តិសម្ភវលោក គឺកុសលកម្មដែលនាំទៅកើតក្នុងសុគតិលោក លោក ១ បានដល់ ពួកសត្វទាំងអស់ ដែលតាំងនៅបានដោយអាហារ លោក ២ បានដល់ នាម ១ រូប ១ លោក ៣ បានដល់ វេទនា ៣ លោក ៤ បានដល់ អាហារ ៤ លោក ៥ បានដល់ ឧបាទានក្ខន្ធ ៥ លោក ៦ បានដល់ អាយតនៈខាងក្នុង ៦ លោក ៧ បានដល់ទីតាំងនៃវិញ្ញាណ ៧ លោក ៨ បានដល់លោកធម៌ ៨ លោក ៩ បានដល់ទីនៅរបស់សត្វ ៩ លោក ១០ បានដល់អាយតនៈទាំង ១០ លោក ១២ បានដល់អាយតនៈ ១២ លោក ១៨ បានដល់ធាតុ ១៨ ។

[ ២៧៦ ] ពាក្យថា ទោស សេចក្តីថា កិលេសទាំងអស់ ឈ្មោះថា ទោស ទុច្ចរិតទាំងអស់ ឈ្មោះថា ទោស អភិសង្ខារទាំងអស់ ឈ្មោះថា ទោស

កវតាមិកម្មទាំងអស់ ឈ្មោះថា ទោស សេចក្ដីសម្គាល់ថាភ័យដ៏ក្លៀវក្លា រមែងប្រាកដក្នុងលោកនេះផង ក្នុងទោសនេះផង ដោយការយល់ឃើញយ៉ាងនេះឯង ប្រៀបដូចពេជ្ឈឃាតលើកនូវដាវ ( ប្រុងនឹងប្រហារ ) ព្រះតថាគតទ្រង់ជ្រាប ឃើញ យល់ ចាក់ធ្លុះ នូវឥន្ទ្រិយទាំង ៥ នេះ ដោយអាការទាំង ៥០ នេះ នេះឯង ឈ្មោះថា ឥន្ទ្រិយបរោបរិយត្តញាណ របស់ព្រះតថាគត ។

# អដ្ឋកថា

## ឥន្ទ្រិយបរោបរិយត្តញ្ញាណនិទ្ទេស

[ ២៦៩ ] គប្បីជ្រាបវិនិច្ឆ័យ ក្នុងឥន្ទ្រិយបរោបរិយត្តញ្ញាណនិទ្ទេសដូចតទៅ បទថា **តថាគតស្ស** សូម្បីមិនមានដោយសរុបក្នុងឧទ្ទេសលោក ក៏ពោលថា **តថាគតស្ស** ព្រោះលោកពោលថា ញាណ ៦ មិនទូទៅដល់សាវកទាំងឡាយ ព្រោះហេតុនោះ ទើបក្នុងនិទ្ទេស ធ្វើការប្រារព្ធពាក្យថា តថាគតដែលសម្រេចហើយដោយអត្ថក្នុងឧទ្ទេស ។

បទថា **សត្តេ បស្សតិ** សេចក្តីថា ឈ្មោះថា សត្វ ព្រោះជាប់ គឺព្រោះជាប់ជំពាក់ដោយឆន្ទរាគៈក្នុងរូបជាដើម ។ ព្រះតថាគតទ្រង់ឃើញ ទ្រង់ប្រមើលមើលសត្វទាំងនោះ ដោយចក្ខុដែលជាឥន្ទ្រិយបរោបរិយត្តញ្ញាណ ។

បទថា **អប្បរជក្ខេ** នេះ មានវិគ្គហៈថា ឈ្មោះថា ដែលមានធូលីតិចក្នុងភ្នែក ព្រោះអត្ថថា សត្វទាំងនេះមានកិលេសដូចធូលី គឺរាគៈជាដើម តិចក្នុងភ្នែក គឺបញ្ញា ។ ឬព្រោះអត្ថថា សត្វទាំងនេះមានកិលេសដូចធូលី គឺរាគៈជាដើមតិច ។ នូវសត្វទាំងនោះដែលមានកិលេសដូចធូលីតិចក្នុងបញ្ញាចក្ខុ ។

បទថា **មហារជក្ខេ** មានវិគ្រោះថា ឈ្មោះថា មានធូលីច្រើនក្នុងភ្នែក ព្រោះអត្ថថា សត្វទាំងនេះមានកិលេសដូចធូលី គឺរាគៈជាដើម ច្រើនក្នុងភ្នែក គឺបញ្ញា ។ ឬព្រោះអត្ថថា សត្វទាំងនេះមានកិលេសដូចធូលី គឺរាគៈជាដើមច្រើន ។

បទថា **តិក្ខិន្ទ្រិយេ មុទិន្ទ្រិយេ** មានវិគ្គហៈថា ឈ្មោះថា មានឥន្ទ្រិយចាស់

ក្លា ព្រោះអត្ថថា សត្វទាំងនេះមានសទ្ធិន្ទ្រិយជាដើម ចាស់ក្លា ។ ឈ្មោះថា មានឥន្ទ្រិយទន់ ព្រោះអត្ថថា សត្វទាំងនេះ មានសទ្ធិន្ទ្រិយជាដើមទន់ ។

បទថា **ស្វាការេ ទ្វាការេ** មានវិគ្គហៈថា ឈ្មោះថា មានអាការល្អ ព្រោះអត្ថថា សត្វទាំងនេះ មានអាការ គឺមានចំណែកមានសទ្ធាជាដើមល្អ ។ ឈ្មោះថា មានអាការអាក្រក់ ព្រោះអត្ថថា សត្វទាំងនេះ មានអាការ គឺមានចំណែក មានសទ្ធាជាដើម គួរខ្ពើម គួរតិះដៀល ។

បទថា **សុវិញ្ញាបយេ ទុវិញ្ញាបយេ** សេចក្តីថា សត្វពួកណាកំណត់ហេតុដែលពោលហើយបាន ជាអ្នកអាចត្រាស់ដឹងច្បាស់បានដោយងាយ សត្វទាំងនោះ ឈ្មោះថា ជាសត្វគួរឲ្យត្រាស់ដឹងបានដោយងាយ ។ សត្វដែលផ្ទុយគ្នាជាមួយបុគ្គលដែលគប្បីឲ្យត្រាស់ដឹងបានដោយងាយនោះ ឈ្មោះថា ឲ្យត្រាស់ដឹងបានដោយក្រ ។

បទថា **អប្បេកច្ចេ បរលោកវជ្ជភយទស្សាវិនោ** បានដល់ ជនពួកខ្លះដែលឃើញបរលោក និងទោស មានរាគៈជាដើមដោយភាពជាភ័យ តែព្រោះក្នុងនិទ្ទេសក្នុងពាក្យនេះ មិនបានពោលចំពោះបរលោកប៉ុណ្ណោះ ទើបគួរកាន់យកអត្ថយ៉ាងនេះថា ឈ្មោះថា ឃើញបរលោក និងទោស មានរាគៈជាដើមជាជាភ័យ ព្រោះអត្ថថា មានប្រក្រតីឃើញភ័យខាងមុខក្នុងខន្ធលោកជាដើម និងក្នុងទោស មានរាគៈជាដើម ។ នូវសត្វទាំងនោះដែលមានប្រក្រតីឃើញភ័យក្នុងលោក និងក្នុងទោសខាងមុខ ។

បទថា **អប្បេកច្ចេ ន បរលោកវជ្ជភយទស្សាវិនោ** បានដល់ សត្វដែល

ផុយគ្នានឹងសត្វ ដែលមានប្រក្រតីឃើញបរលោក និងទោសដោយភាពជាភ័យនោះ ។ បទថា **លោកោ** ដោយអត្ថថា បែកធ្លាយ ។ ឈ្មោះថា **វជ្ជំ** ដោយអត្ថថា គួរវៀរ ។ ដោយបទប្រមាណប៉ុណ្ណេះ ឈ្មោះថា លោកចន្លុលបង្ហាញបទឧទ្ទេសហើយ ។

[ ២៧០ ] ព្រះសារីបុត្តត្ថេរ កាលនឹងធ្វើបដិនិទ្ទេស គឺការចន្លុលបង្ហាញត្រឡប់ចំពោះនិទ្ទេសទៀត ទើបពោលបទថា **អប្បរជក្ខេ មហារជក្ខេ** ជាដើម ។

ក្នុងបទទាំងនោះ ឈ្មោះថា **សទ្ធោ** ព្រោះអត្ថថា សទ្ធា ពោលគឺការជឿមាំទាំក្នុងព្រះរតនត្រ័យ ។ បុគ្គលដល់ព្រមដោយសទ្ធានោះ ឈ្មោះថា មានធូលីតិចក្នុងភ្នែក ព្រោះធូលី គឺការមិនមានសទ្ធា និងធូលី គឺអកុសលដ៏សេសដែលជាឫសគល់នៃការមិនមានសទ្ធា មានតិច ។ ឈ្មោះថា **អស្សទ្ធោ** ព្រោះអត្ថថា មិនមានសទ្ធា ។

បុគ្គលនោះ ឈ្មោះថា **មហារជក្ខោ** គឺមានធូលីច្រើនក្នុងភ្នែក ព្រោះមានធូលីមានប្រការដូចពោលហើយច្រើន ។ ឈ្មោះថា **អារទ្ធវីរិយោ** ព្រោះអត្ថថា បុគ្គលនេះ ប្រារព្ធសេចក្ដីព្យាយាមហើយ ។ បុគ្គលដែលប្រារព្ធសេចក្ដីព្យាយាមនោះ ឈ្មោះថា **អប្បរជក្ខោ** ព្រោះធូលី គឺការខ្ជិលច្រអូស និងធូលីគឺអកុសលដ៏សេសដែលជាឫសគល់នៃសេចក្ដីខ្ជិលច្រអូស មានតិច ។ ឈ្មោះថា **កុសីទោ** ព្រោះអត្ថថា លិចចុះដោយអាការគួរខ្ពើម ព្រោះមានការព្យាយាមអាក្រក់ ។ **កុសីទោ** នោះឯង ជា **កុសីតោ** ។ បុគ្គលអ្នកខ្ជិលច្រអូសនោះ

ឈ្មោះថា **មហារជក្ខោ** ព្រោះមានធូលី គឺការខ្ជិលច្រអូសមានប្រការដូចពោលហើយ ច្រើន ។ ឈ្មោះថា **ឧបដ្ឋិតស្សតិ** ព្រោះមានសតិចូលដល់អារម្មណ៍ហើយតាំងមាំ ។ បុគ្គលនោះ ឈ្មោះថា អ្នកមានធូលីតិចក្នុងភ្នែក ព្រោះធូលីគឺការមិនមានស្មារតី និងធូលី គឺអកុសលដ៏សេសដែលជាឫសគល់នៃការមិនមានស្មារតី មានតិច ។ ឈ្មោះថា **មុដ្ឋស្សតិ** ព្រោះអត្ថថា ភ្លេចស្មារតី គឺវិនាសទៅ ។ បុគ្គលនោះ ឈ្មោះថា អ្នកមានធូលីច្រើនក្នុងភ្នែក ព្រោះធូលីមានប្រការដូចពោលហើយ ច្រើន ។ ឈ្មោះថា **សមាហិតោ** ព្រោះអត្ថថា តាំងទុកស្មើ ឬដោយប្រពៃក្នុងអារម្មណ៍ដោយអប្បនាសមាធិ ឬដោយឧបចារសមាធិ ។ ម្យ៉ាងទៀត ឈ្មោះថា **សមាហិតោ** ព្រោះអត្ថថា មានចិត្តតាំងមាំ ។ បុគ្គលនោះ ឈ្មោះថា អ្នកមានធូលីតិចក្នុងភ្នែក ព្រោះធូលី គឺការរាយមាយ និងធូលី គឺអកុសលដ៏សេសដែលជាឫសគល់នៃសេចក្តីរាយមាយ មានតិច ។ បុគ្គលមានចិត្តមិនតាំងមាំ ឈ្មោះថា **អសមាហិតោ** បុគ្គលនោះ ឈ្មោះថា អ្នកមានធូលីច្រើនក្នុងភ្នែក ព្រោះមានធូលី មានប្រការដូចពោលហើយ ច្រើន ។ ឈ្មោះថា **បញ្ញវា** ព្រោះអត្ថថា មានបញ្ញាដែលឃើញការកើត និងការរលត់ ។ បុគ្គលអ្នកមានបញ្ញានោះ ឈ្មោះថា អ្នកមានធូលីតិចក្នុងភ្នែក ព្រោះធូលី គឺមោហៈ និងធូលី គឺអកុសលដ៏សេសដែលជាឫសគល់នៃមោហៈ មានតិច ។ ឈ្មោះថា **ទុប្បញ្ញោ** ព្រោះអត្ថថា មានបញ្ញាថោកថយ ព្រោះវង្វេងដោយមោហៈ ។ បុគ្គលនោះ ឈ្មោះថា អ្នកមានធូលីច្រើនក្នុងភ្នែក ព្រោះមានធូលី មានប្រការដូចពោលហើយ ច្រើន ។

[ ២៧១ ] បទថា **សទ្ធោ បុគ្គលោ តិក្ខិន្ទ្រិយោ** បានដល់ មានសទ្ធា ដោយសទ្ធាមានកម្លាំង ដែលកើតឡើងច្រើន ។ មានឥន្ទ្រិយចាស់ក្លាដោយសទ្ធិន្ទ្រិយនោះឯង ។ បទថា **អស្សទ្ធោ បុគ្គលោ មុទិន្ទ្រិយោ** បានដល់ មិនមានសទ្ធាដោយការមិនជឿកើតឡើង ច្រើន ជាបុគ្គលមានឥន្ទ្រិយទន់ខ្សោយ ដោយសទ្ធិន្ទ្រិយដែលមានកំលាំងតិចដែលកើតឡើងក្នុងចន្លោះៗ ។ សូម្បីក្នុងបទដ៏សេសក៏មានន័យនេះ ។

[ ២៧២ ] បទថា **សទ្ធោ បុគ្គលោ ស្វាការោ** បានដល់ មានអាការស្អាតដោយសទ្ធានោះឯង ។ បទថា **អស្សទ្ធោ បុគ្គលោ ទ្វាការោ** បានដល់ មានអាការអាក្រក់ដោយភាពជាអ្នកមិនជឿនោះឯង សូម្បីបទដ៏សេស ក៏មានន័យនេះ ។

[ ២៧៣ ] បទថា **សុវិញ្ញាបយោ** បានដល់ គប្បីឲ្យដឹងបានងាយ ។ បទថា **ទុវិញ្ញាបយោ** បានដល់ គប្បីឲ្យដឹងបានដោយក្រ ។

[ ២៧៤ ] ក្នុងបទថា **បរលោកវជ្ជភយទស្សាវី** នេះ គប្បីជ្រាបសេចក្តីដូចតទៅនេះថា ព្រោះសទ្ធាជាដើមរបស់អ្នកដល់ព្រមដោយបញ្ញា រមែងបរិសុទ្ធដោយល្អ ហេតុនោះ បុគ្គលដល់ព្រមដោយសទ្ធាដែលបរិសុទ្ធដោយល្អជាដើម រមែងជាអ្នកមានប្រក្រតីឃើញបរលោក និងទោសដោយភាពជាភ័យ ដោយបញ្ញាដែលសម្បយុត្តដោយសទ្ធាជាដើមនោះ ឬបុគ្គលដល់ព្រមដោយសទ្ធាដែលបរិសុទ្ធដោយល្អជាដើម រមែងជាអ្នកមានប្រក្រតី ឃើញបរលោក និងទោសដោយភាពជាភ័យ ដោយបញ្ញាដែលមានសទ្ធាជាដើមនោះជាបច្ច័យ

ព្រោះហេតុនោះឯង ទើបបុគ្គល ៤ ពួក មានអ្នកមានសទ្ធាជាដើម លោកពោលថា ឃើញបរលោក និងទោស មានរាគៈជាដើម ថាជាភ័យ ។

[ ២៧៥ ] ឥឡូវនេះ ព្រះសារីបុត្តត្ថេរ ដើម្បីនឹងសម្តែងលោក និងទោសដូចពោលហើយក្នុងបទនេះថា **បរលោកវជ្ជភយទស្សាវី** ទើបពោលពាក្យថា **លោកោ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ ខន្ធទាំងឡាយនោះឯង ឈ្មោះថា លោក ដោយអត្ថថា បែកធ្លាយទៅ ព្រោះហេតុនោះ ទើបឈ្មោះថា ខន្ធលោក សូម្បីក្នុងបទពីរដ៏សេសក៏មានន័យនេះដូចគ្នា ។

បទថា **វិបត្តិភវលោកោ** បានដល់ អបាយលោក ។ ព្រោះថា អបាយ-លោកនោះ ជាលោកអាក្រក់ ព្រោះមានផលមិនគួរប្រាថ្នា ព្រោះហេតុនោះទើបឈ្មោះថា វិបត្តិ ។ ឈ្មោះថា ភព ព្រោះអត្ថថា កើត ភព គឺការវិបត្តិនោះឯង ឈ្មោះថា ភពវិបត្តិ ។ លោក គឺភពវិបត្តិនោះឯង ឈ្មោះថា **វិបត្តិភវលោកោ** ។

បទថា **វិបត្តិសម្ភវលោកោ** បានដល់ កម្មដែលចូលដល់អបាយ ។ កម្មនោះ ឈ្មោះថា **សម្ភវ** ព្រោះជាដែនកើតនៃផល ដែនកើតនៃវិបត្តិ ឈ្មោះថា **សម្ភវវិបត្តិ** លោក គឺសម្ភវវិបត្តិនោះឯង ឈ្មោះថា **វិបត្តិសម្ភវលោកោ** ។

បទថា **សម្បត្តិភវលោកោ** បានដល់ សុគតិលោក ។ ព្រោះថា សុគតិ-លោកនោះជាលោកល្អ ព្រោះមានផលជាទីប្រាថ្នា ព្រោះហេតុនោះ ទើបឈ្មោះថា សម្បត្តិ ឈ្មោះថា ភព ព្រោះអត្ថថា កើត ភព គឺសម្បត្តិនោះឯង ឈ្មោះ

ថា **ភវសម្បត្តិ** លោក គឺភវសម្បត្តិនោះឯង ឈ្មោះថា **សម្បត្តិភវលោកោ** ។

បទថា **សម្បត្តិសម្ភវលោកោ** បានដល់ កម្មដែលចូលដល់សុគតិ ។ កម្មនោះ ឈ្មោះថា **សម្ភវ** ព្រោះជាដែនកើតនៃផល ដែនកើតនៃសម្បត្តិ ឈ្មោះថា **សម្ភវសម្បត្តិ** លោក គឺសម្ភវសម្បត្តិនោះឯង ឈ្មោះថា **សម្បត្តិ-សម្ភវលោកោ** ។

បទថា **ឯកោ លោកោ** ជាដើម មានអត្ថដូចបានពោលហើយក្នុងខាងដើមនោះឯង ។

[ ២៧៦ ] បទថា **វជ្ជំ** លោកធ្វើជានបុំសកលិង្គ ព្រោះមិនបានសម្ដែងថា វត្ថុនោះ ។ បទថា **កិលេសា** បានដល់ កិលេស មានរាគៈជាដើម ។ បទថា **ទុច្ចរិតា** បានដល់ ទុច្ចរិត មានបាណាតិបាតជាដើម ។ បទថា **អភិសង្ខារា** បានដល់ បុញ្ញាភិសង្ខារជាដើម ។ បទថា **ភវគាមិកម្មា** មានវិគ្គហៈថា ឈ្មោះថា **ភវគាមិ** ព្រោះអត្ថថា ទៅកាន់ភពដោយអំណាចឲ្យវិបាករបស់ខ្លួន ។ លោកពោលកម្មដែលឲ្យកើតវិបាកក្នុងអភិសង្ខារទាំងឡាយនោះឯង ។

បទថា **ឥតិ** ជាបទសម្ដែងប្រការដូចពោលហើយ ។ បទថា **ឥមស្មិំ លោកេ ឥមស្មិំ វជ្ជេ** បានដល់ ក្នុងលោក និងក្នុងទោស មានប្រការដូចពោលហើយ ។ បទថា **តិព្វា ភយសញ្ញា** បានដល់ ការសម្គាល់ថាជាភ័យដែលមានកម្លាំង ។

លោកពោលអត្ថនៃ **បរ** សព្ទថា **តិព្វា** ( ដែលខ្លាំងក្លា ) ។ លោកពោលអត្ថនៃ **ភយ** សព្ទថា **ភយសញ្ញា** ( សញ្ញាសម្គាល់ថាជាភ័យ ) ។ លោក

និងទោសទាំងពីរ ឈ្មោះថា ភ័យ ព្រោះជាទីតាំង និងជាទីកើតនៃភ័យ និង ព្រោះជាភ័យឯង ការសម្គាល់ថាភ័យ ឈ្មោះថា **ភយសញ្ញា** ។ បទថា **បច្ចុបដ្ឋិតា ហោតិ** បានដល់ ប្រាកដហើយព្រោះអាស្រ័យលោក និងទោស នោះៗ ។ បទថា **សេយ្យថាបិ ឧក្ខិត្តាសិកេ វធកេ** បានដល់ ការសម្គាល់ថា ជាភ័យដ៏ខ្លាំងក្លា ប្រាកដហើយក្នុងលោក និងក្នុងទោស ដូចការសម្គាល់ថា ជាភ័យដ៏ខ្លាំងក្លា ប្រាកដក្នុងសត្រូវដែលងាដាវដើម្បីប្រហារ ដូច្នោះ ។

បទថា **ឥមេហិ បញ្ញាសាយ អាការេហិ** បានដល់ ដោយអាការ ៥០ ដោយអំណាចនៃអាការនីមួយៗ ៥ ក្នុងបញ្ចកៈ ១០ មានអប្បរជក្ខបញ្ចកៈ ជាដើម បញ្ចកៈនីមួយៗ ។ បទថា **ឥមានិ បញ្ចិន្ទ្រិយានិ** បានដល់ ឥន្ទ្រិយ ៥ មានសទ្ធិន្ទ្រិយជាដើម ។ បទថា **ជានាតិ** បានដល់ ព្រះតថាគត រមែង ទ្រង់ដឹងដោយបញ្ញា ។ បទថា **បស្សតិ** បានដល់ ទ្រង់ធ្វើដូចឃើញដោយ ទិព្វចក្ខុ ។ បទថា **អញ្ញាតិ** បានដល់ ទ្រង់ជ្រាបអាការ និងមារយាទទាំង ពួង ។ បទថា **បដិវិជ្ឈតិ** បានដល់ ទ្រង់ទម្លាយដោយបញ្ញា ដោយអំណាច ការឃើញទាំងអស់ មិនមានសេសសល់ដោយចំណែកមួយ ។

## អដ្ឋកថាឥន្ទ្រិយបរោបរិយត្តញ្ញាណនិទ្ទេស ចប់

# សុត្តន្តបិដក

[ ២៧៧ ] សត្តាសយានុសយញ្ញាណរបស់ព្រះតថាគត តើដូចម្តេច ។ ព្រះតថាគតជ្រាបនូវអាសយធម៌ ជ្រាបនូវអនុសយធម៌ ជ្រាបនូវចរិត ជ្រាបនូវអធ្យាស្រ័យរបស់សត្វទាំងឡាយ ជ្រាបនូវពួកសត្វដែលមានភ័ព្វ និងឥតភ័ព្វ ក្នុងលោកនេះ ( ញាណបែបនេះ ឈ្មោះថា សត្តាសយានុសយញ្ញាណរបស់ព្រះតថាគត ) ។

[ ២៧៨ ] អាសយធម៌របស់ពួកសត្វ តើដូចម្តេច ។ ពួកសត្វដែលអាស្រ័យនូវភវទិដ្ឋិក្តី អាស្រ័យនូវវិភវទិដ្ឋិក្តី ថាលោកទៀង ឬថាលោកមិនទៀង ថាលោកមានទីបំផុត ថាលោកមិនមានទីបំផុត ថានោះជាជីវៈ នោះជាសរីរៈ ថាជីវៈដទៃ សរីរៈដទៃ ថាសត្វស្លាប់ទៅកើតទៀត ថាសត្វស្លាប់ទៅមិនកើតទៀត ថាសត្វស្លាប់ទៅកើតទៀតក៏មាន មិនកើតទៀតក៏មាន ឬថា សត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន មួយទៀត អនុលោមិកខន្តិក្នុងធម៌ទាំងឡាយ ដែលកើតឡើងព្រោះសត្វតែងបាន ព្រោះមិនអាស្រ័យនូវធម៌នេះជាបច្ច័យ អាស្រ័យនូវអន្តធម៌ទាំងពីរនេះ មួយវិញទៀត យថាភូតញ្ញាណរមែងដឹងនូវបុគ្គលអ្នកសេពកាម គឺដឹងនូវបុគ្គលអ្នកសេពកាមថា បុគ្គលនេះធ្ងន់ក្នុងកាម ដេកត្រាំក្នុងកាម ចុះចិត្តស៊ប់ក្នុងកាម ដឹងនូវបុគ្គលអ្នកសេពនូវនេក្ខម្មៈថា បុគ្គលនេះធ្ងន់ក្នុងនេក្ខម្មៈ ដេកត្រាំក្នុងនេក្ខម្មៈ ចុះចិត្តស៊ប់ក្នុងនេក្ខម្មៈ ដឹងនូវបុគ្គលអ្នកសេពនូវព្យាបាទថា បុគ្គលនេះធ្ងន់ក្នុងព្យាបាទ ដេកត្រាំក្នុងព្យាបាទ ចុះចិត្តស៊ប់ក្នុងព្យាបាទ ដឹងនូវបុគ្គលអ្នកសេពនូវអព្យាបាទថា បុគ្គល

នេះធ្ងន់ក្នុងអព្យាបាទ ដេកត្រាំក្នុងអព្យាបាទ ចុះចិត្តស៊ប់ក្នុងអព្យាបាទ ដឹងនូវបុគ្គលអ្នកសេពនូវថីនមិទ្ធៈថា បុគ្គលនេះធ្ងន់ក្នុងថីនមិទ្ធៈ ដេកត្រាំក្នុងថីនមិទ្ធៈ ចុះចិត្តស៊ប់ក្នុងថីនមិទ្ធៈ ដឹងនូវបុគ្គលអ្នកសេពនូវអាលោកសញ្ញាថា បុគ្គលនេះធ្ងន់ក្នុងអាលោកសញ្ញា ដេកត្រាំក្នុងអាលោកសញ្ញា ចុះចិត្តស៊ប់ក្នុងអាលោកសញ្ញា នេះឈ្មោះថា អាសយធម៌របស់ពួកសត្វ ។

[ ២៧៩ ] អនុសយធម៌របស់សត្វ តើដូចម្ដេច ។ អនុសយធម៌ ៧ គឺ កាមរាគានុស័យ ១ បដិឃានុស័យ ១ មានានុស័យ ១ ទិដ្ឋានុស័យ ១ វិចិកិច្ឆានុស័យ ១ ភវរាគានុស័យ ១ អវិជ្ជានុស័យ ១ អារម្មណ៍ណាមានសភាពគួរស្រឡាញ់ គួរត្រេកអរក្នុងលោក កាមរាគានុស័យរបស់ពួកសត្វរមែងដេកត្រាំក្នុងអារម្មណ៍នោះ អារម្មណ៍ណា មានសភាពមិនគួរស្រឡាញ់ មិនគួរត្រេកអរក្នុងលោក បដិឃានុស័យរបស់ពួកសត្វ រមែងដេកត្រាំក្នុងអារម្មណ៍នោះ អវិជ្ជាតែងជាប់តាមក្នុងធម៌ទាំងពីរនេះ ឯមានះ ទិដ្ឋិ និងវិចិកិច្ឆាដែលស្ថិតនៅជាមួយនឹងអវិជ្ជានោះ អ្នកប្រាជ្ញគប្បីយល់តាមន័យ ដូចបានពោលមកនេះឯង នេះឈ្មោះថា អនុសយធម៌របស់ពួកសត្វ ។

[ ២៨០ ] ចរិតរបស់ពួកសត្វ តើដូចម្ដេច ។ បុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារ អនេញ្ជាភិសង្ខារ ដែលជាភូមិតូច ឬភូមិធំ នេះឈ្មោះថា ចរិតរបស់ពួកសត្វ ។

[ ២៨១ ] អធ្យាស្រ័យរបស់ពួកសត្វ តើដូចម្ដេច ។ ពួកសត្វដែលមានអធ្យាស្រ័យថោកទាប ក៏មាន ពួកសត្វដែលមានអធ្យាស្រ័យខ្ពង់ខ្ពស់ ក៏មាន

ពួកសត្វដែលមានអធ្យាស្រ័យថោកទាប រមែងគប់រក សេពគប់ ចូលទៅអង្គុយជិតនូវពួកសត្វដែលមានអធ្យាស្រ័យថោកទាប ( ដូចគ្នា ) ពួកសត្វដែលមានអធ្យាស្រ័យខ្ពង់ខ្ពស់រមែងគប់រក សេពគប់ ចូលទៅអង្គុយជិតនូវពួកសត្វដែលមានអធ្យាស្រ័យខ្ពង់ខ្ពស់ ( ដូចគ្នា ) សូម្បីក្នុងកាលកន្លងទៅហើយ ពួកសត្វដែលមានអធ្យាស្រ័យថោកទាបគប់រកហើយ សេពគប់ហើយ ចូលទៅអង្គុយជិតហើយ នូវពួកសត្វដែលមានអធ្យាស្រ័យថោកទាប ( ដូចគ្នា ) ពួកសត្វដែលមានអធ្យាស្រ័យខ្ពង់ខ្ពស់ គប់រកហើយ សេពគប់ហើយ ចូលទៅអង្គុយជិតហើយនូវពួកសត្វ ដែលមានអធ្យាស្រ័យខ្ពង់ខ្ពស់ ( ដូចគ្នា ) សូម្បីក្នុងកាលជាអនាគត ពួកសត្វដែលមានអធ្យាស្រ័យថោកទាប នឹងគប់រក នឹងសេពគប់ នឹងចូលទៅអង្គុយជិតនូវពួកសត្វដែលមានអធ្យាស្រ័យថោកទាប ( ដូចគ្នា ) ពួកសត្វដែលមានអធ្យាស្រ័យខ្ពង់ខ្ពស់ នឹងគប់រក នឹងសេពគប់ នឹងចូលទៅអង្គុយជិតនូវពួកសត្វ ដែលមានអធ្យាស្រ័យខ្ពង់ខ្ពស់ ( ដូចគ្នា ) នេះឈ្មោះថា អធ្យាស្រ័យរបស់ពួកសត្វ ។

[ ២៨២ ] ពួកសត្វដែលឥតភ័ព្វ តើដូចម្តេច ។ ពួកសត្វណាដែលប្រកបដោយទំនប់ គឺកម្ម ប្រកបដោយទំនប់ គឺកិលេស ប្រកបដោយទំនប់ គឺវិបាក ជាសត្វមិនមានសទ្ធា មិនមានឆន្ទៈ ឥតប្រាជ្ញា មិនគួរដើម្បីចុះកាន់និយាម ( គន្លង ) ដែលត្រឹមត្រូវក្នុងកុសលធម៌ទាំងឡាយ ពួកសត្វទាំងនោះ ឈ្មោះថា អ្នកឥតភ័ព្វ ។

[ ២៨៣ ] ពួកសត្វដែលមានភ័ព្វ តើដូចម្តេច ។ ពួកសត្វណាដែលមិន

ប្រកបដោយទំនប់ គឺកម្ម មិនប្រកបដោយទំនប់ គឺកិលេស មិនប្រកបដោយទំនប់ គឺវិបាក ជាសត្វមានសទ្ធា មានឆន្ទៈ មានប្រាជ្ញា គួរដើម្បីចុះកាន់និយាម ( គន្លង ) ដែលត្រឹមត្រូវក្នុងកុសលធម៌ទាំងឡាយ ពួកសត្វទាំងនេះ ឈ្មោះថា អ្នកមានភ័ព្វ នេះឈ្មោះថា សត្តាសយានុសយញ្ញាណរបស់ព្រះតថាគត ។

# អដ្ឋកថា

# អាសយានុសយញ្ញាណនិទ្ទេស

[ ២៧៧ ] គប្បីជ្រាបវិនិច្ឆ័យ ក្នុងអាសយានុសយញ្ញាណនិទ្ទេសដូចតទៅ បទថា **ឥធ តថាគតោ** ជាដើម ជានិទ្ទេសដែលលោកតាំងទុក ៥ ចំណែក ។ ក្នុងបទទាំងនោះ បទថា **អាសយានុសយា** មានអត្ថដូចបានពោលហើយ ។ បទថា **ចរិតំ** បានដល់ កុសលកម្ម និងអកុសលកម្មដែលធ្វើហើយក្នុងជាតិមុន ។ បទថា **អធិមុត្តឹ** បានដល់ ការបណ្តោយចិត្តទៅក្នុងកុសល ឬអកុសលក្នុងជាតិនេះ ។ បទថា **ភព្វាភព្វេ** បានដល់ ភព្វសត្វផង អភព្វសត្វផង ។ ឈ្មោះថា **ភព្វ** ព្រោះអត្ថថា សម្ភព គឺកើតក្នុងអរិយជាតិ ពាក្យនេះ ជាពាក្យបច្ចុប្បន្នកាលជិតបច្ចុប្បន្នកាល ។ ម្យ៉ាងវិញទៀត ឈ្មោះថា **ភព្វ** ព្រោះនឹងកើត គឺនឹងកើត អធិប្បាយថា ជាភាជនៈទ្រ ។ សត្វដែលសមគួរដល់ការចាក់ធ្លុះអរិយមគ្គ ដែលដល់ព្រមដោយឧបនិស្ស័យ ជាភព្វសត្វ ។ អភព្វសត្វ ផ្ទុយគ្នានឹងភព្វសត្វដូចពោលហើយ ។

[ ២៧៨ ] បទថា **កតមោ ច សត្តានំ អាសយោ** ជាបដិនិទ្ទេស គឺជាការសម្តែងត្រឡប់នៃបទនិទ្ទេស ។

ក្នុងបទទាំងនោះ បទថា **សស្សតោ** បានដល់ ទៀង ។ បទថា **លោកោ** បានដល់ អត្តា ។ សត្វទាំងឡាយរមែងសម្គាល់ថា សរីរៈក្នុងលោកនេះប៉ុណ្ណោះវិនាសទៅ ចំណែកអត្តាគង់នៅជាអត្តានោះឯងក្នុងលោកនេះ និងលោកខាងមុខ ។ ពិតហើយ សត្វទាំងឡាយ រមែងសម្គាល់ថា អត្តានោះ ឈ្មោះថា

លោក ព្រោះឃើញទូទៅដោយខ្លួនឯងនោះឯង ។

បទថា **អសស្សតោ** បានដល់ មិនទៀង ។ សត្វទាំងឡាយសម្គាល់ថា អត្តារមែងសូន្យទៅព្រមជាមួយសរីរៈនោះឯង ។ បទថា **អន្តវា** បានដល់ សត្វទាំងឡាយញ៉ាំងឈានឲ្យកើតក្នុងបរិត្តកសិណហើយសម្គាល់ថា ចិត្តមានបរិត្តកសិណនោះជាអារម្មណ៍ ជាអត្តាមានទីបំផុត ។ បទថា **អនន្តវា** បានដល់ មិនមានទីបំផុត គឺសត្វទាំងឡាយញ៉ាំងឈាន ក្នុងកសិណមិនមានប្រមាណឲ្យកើត ហើយសម្គាល់ថា ចិត្តមានកសិណមិនមានប្រមាណនោះជាអារម្មណ៍ ជាអត្តាមិនមានទីបំផុត ។ បទថា **តំ ជីវំ តំ សរីរំ** បានដល់ ជីវៈនិងសរីរៈ ក៏ ( តែមួយ ) នោះឯង ។ បទថា **ជីវោ** គឺអត្តា ពាក្យនេះ លោកធ្វើឲ្យជានបុំសកលិង្គព្រោះលិង្គវិបល្លាស ។ បទថា **សរីរំ** បានដល់ ខន្ធបញ្ចកៈ ព្រោះមានសភាពជាគំនរ ។ បទថា **អញ្ញំ ជីវំ អញ្ញំ សរីរំ** បានដល់ ជីវៈក៏ដទៃ ខន្ធបញ្ចកៈក៏ដទៃ ។ បទថា **ហោតិ តថាគតោ បរម្មរណា** បានដល់ ខន្ធទាំងឡាយសូន្យទៅក្នុងលោកនេះប៉ុណ្ណោះ សត្វខាងមុខអំពីស្លាប់ទៅនៅមាន មិនសូន្យ ។ ក្នុងបទថា **តថាគតោ** នេះ អាចារ្យពួកខ្លះពោលថា ជាឈ្មោះរបស់សត្វ ។ តែពួកខ្លះពោលថា បទថា **តថាគតោ** គឺព្រះអរហន្ត ។ សត្វទាំងឡាយពួកនេះ ឃើញទោសក្នុងចំណែកថា មិនកើតទៀត ទើបកាន់យកយ៉ាងនេះ ។

បទថា **ន ហោតិ តថាគតោ បរម្មរណា** បានដល់ ខន្ធទាំងឡាយរមែងសូន្យទៅក្នុងលោកនេះប៉ុណ្ណោះ សត្វខាងមុខពីស្លាប់ហើយ រមែងមិនកើត

ទៀត គឺដាច់សូន្យ បានដល់ សូន្យទៅ ។ សត្វទាំងឡាយពួកនេះឃើញទោស ក្នុងចំណែកថា រមែងកើតទៀត ទើបកាន់យកយ៉ាងនេះ ។ បទថា **ហោតិ ច ន ច ហោតិ** បានដល់ សត្វទាំងនេះឃើញទោសក្នុងការកំណត់យកតែ ចំណែកមួយៗ ហើយកាន់យកចំណែកទាំងពីរ ។

បទថា **នេវ ហោតិ ន ន ហោតិ** បានដល់ សត្វទាំងនេះ ឃើញការ ដល់ទោសទាំងពីរ ក្នុងការកំណត់ទាំងពីរចំណែក ទើបកាន់យកចំណែកដែល មានការឃើញមិនពិតប្រាកដថា កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ។

ន័យរបស់អដ្ឋកថាក្នុងនិទ្ទេសនេះដូចតទៅនេះថា លោកពោលដល់ប្រភេទ នៃទិដ្ឋិដោយអាការ ១០ មានលោកទៀងខ្លះ ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **សស្សតោ លោកោ** បានដល់ ទិដ្ឋិដែលប្រព្រឹត្ត ទៅ ដោយអាការប្រកាន់ថា ទៀងរបស់បុគ្គលដែលប្រកាន់ថា ខន្ធបញ្ចកៈ ជា លោក ហើយប្រកាន់ថា លោកនេះទៀង ស្ថិតស្ថេរ ប្រព្រឹត្តទៅសព្វកាល ។ បទថា **អសស្សតោ** បានដល់ ទិដ្ឋិដែលប្រព្រឹត្តទៅ ដោយអាការប្រកាន់ថា សូន្យរបស់បុគ្គលដែលប្រកាន់លោកនោះឯងថា ដាច់សូន្យ ដាច់សូន្យទៅ ។ បទថា **អន្តវា** សេចក្ដីថា ទិដ្ឋិដែលប្រព្រឹត្តទៅដោយអាការប្រកាន់ថា លោក មានទីបំផុត របស់បុគ្គលដែលបានបរិត្តកសិណ ដែលចូលកសិណប្រមាណប៉ុន ចង្អេរ ឬប្រមាណប៉ុនផ្តិល ហើយប្រកាន់រូបធម៌ និងអរូបធម៌ដែលប្រព្រឹត្តទៅ ខាងក្នុងសមាបត្តិថាជាលោក និងថាមានទីបំផុត ដោយកំណត់យកកសិណជា ទីបំផុត ទិដ្ឋិនោះ ជាសស្សតទិដ្ឋិខ្លះ ឧច្ឆេទទិដ្ឋិខ្លះ ។ ចំណែកទិដ្ឋិដែលប្រព្រឹត្ត

ទៅដោយអាការប្រកាន់ថា លោកមិនមានទីបំផុត របស់បុគ្គលដែលបាន វិបុលកសិណ ( កសិណទូលាយ ) ដែលចូលកសិណនោះហើយ ប្រកាន់ រូបធម៌ និងអរូបធម៌ដែលប្រព្រឹត្តទៅខាងក្នុងសមាបត្តិ ថាជាលោក និងថា មិនមានទីបំផុត ដោយកំណត់យកកសិណជាទីបំផុត ទិដ្ឋិនោះ ជាសស្សតទិដ្ឋិខ្លះ ជាឧច្ឆេទទិដ្ឋិខ្លះ ។

បទថា **តំ ជីវំ តំ សរីរំ** បានដល់ ទិដ្ឋិដែលប្រព្រឹត្តទៅដោយអាការប្រកាន់ការដាច់សូន្យថា កាលសរីរៈដាច់សូន្យ សូម្បីជីវៈក៏ដាច់សូន្យ ព្រោះប្រកាន់សរីរៈដែលមានការបែកធ្លាយទៅជាធម្មតានោះឯង ថាជាជីវៈ ។ ក្នុងបទទីពីរ បានដល់ ទិដ្ឋិដែលប្រព្រឹត្តទៅដោយអាការប្រកាន់ការទៀងថា សូម្បីកាល សរីរៈដាច់សូន្យ ជីវៈក៏មិនដាច់សូន្យ ព្រោះប្រកាន់ជីវៈដទៃអំពីសរីរៈ ។

ក្នុងបទនេះថា **ហោតិ តថាគតោ** ជាដើម មានសេចក្តីដូចតទៅ សត្វឈ្មោះថា តថាគត ទិដ្ឋិទីមួយរបស់បុគ្គលដែលប្រកាន់ថា សត្វនោះស្លាប់ទៅហើយរមែងកើតទៀត ជាសស្សតទិដ្ឋិ ។ ទិដ្ឋិទីពីររបស់បុគ្គលដែលប្រកាន់ថា មិនកើតទៀត ជាឧច្ឆេទទិដ្ឋិ ទិដ្ឋិទីបីរបស់បុគ្គលដែលប្រកាន់ថា កើតទៀតក៏មាន មិនកើតទៀតក៏មាន ជាឯកច្ចសស្សតទិដ្ឋិ ។ ទិដ្ឋិទីបួនរបស់បុគ្គលដែលប្រកាន់ថា កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ជាអមរាវិក្ខេបទិដ្ឋិ ។

សព្ទថា **ឥតិ** ជាសព្ទសម្តែងទិដ្ឋិនិស្ស័យមានប្រការដូចពោលហើយ ។ បទថា **ភវទិដ្ឋិសន្និស្សិតា វា សត្តា ហោន្តិ វិភវទិដ្ឋិសន្និស្សិតា វា** សេចក្តី

ថា ការទៀង លោកពោលថា **ភវ** ទិដ្ឋិកើតដោយអំណាចការទៀង ឈ្មោះថា **ភវទិដ្ឋិ** អធិប្បាយថា ការឃើញថាមាន ថាកើត ។ ការសូន្យ ហៅថា **វិភវ** ទិដ្ឋិកើតដោយអំណាចការសូន្យ ឈ្មោះថា **វិភវទិដ្ឋិ** អធិប្បាយថា ការឃើញថាមិនមាន មិនកើត ។ ទិដ្ឋិ ១០ ដូចពោលហើយ មាន ២ យ៉ាង ប៉ុណ្ណោះ គឺភវទិដ្ឋិ ១ វិភវទិដ្ឋិ ១ ។ ក្នុងទិដ្ឋិទាំង ២ នោះ សត្វទាំងឡាយ រមែងអាស្រ័យ ពឹងផ្អែក ជាប់នូវទិដ្ឋិនីមួយៗ ។

**វា** សព្ទ ក្នុងបទនេះថា **ឯតេ វា បន ឧភោ អន្តេ អនុបគម្ម** ជាសមុច្ចយត្ថៈ ( មានអត្ថថាប្រមូលមក ) ដូចក្នុងប្រយោគ ( ទីឃនិកាយ មហាវារវគ្គ ) ជាដើមថា **អគ្គិតោ វា ឧទកតោ វា មិថុភេទា វា** អន្តរាយ ដោយភ្លើង ១ ដោយទឹក ១ ដោយការបែកគ្នា ១ អធិប្បាយថា មិនជំពាក់ គឺមិនជាប់ បានដល់ លះទាំងពីរចំណែកដោយអំណាចសស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិ មានប្រការដូចពោលហើយនោះ ។ **វា** សព្ទ ក្នុងបទថា **អនុលោមិកា វា ខន្តិ** ជាវិកប្បត្ថៈ ( មានអត្ថកំណត់ ) ។ បទថា **ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ** សេចក្តីថា បច្ច័យនៃជរា និងមរណៈជាដើម ឈ្មោះថា **ឥទប្បច្ចយ** ឥទប្បច្ចយៈនោះឯង ឈ្មោះថា **ឥទប្បច្ចយតា** ឬការប្រជុំឥទប្បច្ចយៈទាំងឡាយ ឈ្មោះថា **ឥទប្បច្ចយតា** ។ ម្យ៉ាងទៀត គប្បីស្វែងរកលក្ខណៈក្នុងបទនេះដោយសព្ទសាស្ត្រ ។ ធម៌ទាំងឡាយអាស្រ័យបច្ច័យនោះៗ កើតរួមគ្នា និងដោយប្រពៃ ឈ្មោះថា **បដិច្ចសមុប្បន្ន** ។ ក្នុងវត្ថុដែលជាបច្ច័យនោះឯង និងក្នុងធម៌ទាំងឡាយដែលអាស្រ័យគ្នាកើតឡើងទាំងនោះ ។

បទថា **អនុលោមិកា** បានដល់ អនុលោម ព្រោះជាធម៌សមគួរដល់លោកុត្តរធម៌ទាំងឡាយ ។ បទថា **ខន្តិ** បានដល់ ញាណ ។ ញាណឈ្មោះថា **ខន្តិ** ព្រោះការអត់ធន់ ។ បទថា **បដិលទ្ធា ហោតិ** បានដល់ ជាការដែលសត្វទាំងឡាយបានសម្រេចហើយ ។ ការមិនចូលទៅជាប់ជំពាក់ថាដាច់សូន្យ រមែងមានដោយខន្តិក្នុងឥទប្បច្ចយតា ព្រោះការឃើញដែលមិនវៀរចាកផលដោយការឃើញដែលមិនវៀរចាកបច្ច័យ ព្រោះធម៌ដែលអាស្រ័យបច្ច័យកើតឡើងទាំងឡាយប្រព្រឹត្តទៅបន្ត ព្រោះការដល់ព្រមនៃបច្ច័យ ។ ការមិនចូលទៅជាប់ជំពាក់ថាទៀង រមែងមានដោយខន្តិក្នុងធម៌ដែលអាស្រ័យគ្នាកើតឡើង ព្រោះឃើញការកើតឡើងនៃធម៌ទាំងឡាយថ្មីៗ ដែលអាស្រ័យបច្ច័យកើតឡើង ព្រោះការដល់ព្រមនៃបច្ច័យ ។ ការឃើញប្រពៃដែលមិនជាប់ជំពាក់ក្នុងទីបំផុតពីរយ៉ាងនោះ យ៉ាងនេះហើយ ប្រព្រឹត្តទៅថា មិនដាច់សូន្យ មិនទៀង ដោយការឃើញធម៌ដែលអាស្រ័យគ្នាកើតឡើង គឺបដិច្ចសមុប្បាទ គប្បីជ្រាបថា អនុលោមិកខន្តិ ។ ដោយប្រការដូច្នេះ ឈ្មោះថា លោកពោលដល់សម្មាទិដ្ឋិដែលជាបដិបក្ខចំពោះទិដ្ឋិទាំងពីរនោះ ។

បទថា **យថាភូតំ វា ញាណំ** បានដល់ ញាណដែលនាំទៅតាមសេចក្តីពិត គឺតាមសភាពដែលពិត ។ សូម្បីញាណដែលប្រព្រឹត្តទៅក្នុងធម៌ដែលមានវត្ថុនេះជាបច្ច័យ និងអាស្រ័យគ្នាកើតឡើងនោះ លោកក៏ពោលថា យថាភូតញ្ញាណដោយហៅតាមវិស័យ ។ ក្នុងនិទ្ទេសនេះ យថាភូតញ្ញាណនោះ លោកបំណងយកវិបស្សនាញាណដែលមានសង្ខារុបេក្ខាញាណជាទីបំផុត ។ តែខាង

ដើម លោកពោលភយតូបដ្ឋានញ្ញាណថា យថាភូតញ្ញាណទស្សនៈ ។ គួរសម្ពន្ធថា ឬយថាភូតញ្ញាណ រមែងឈ្មោះថា សត្វទាំងឡាយបានហើយ ។

ឥឡូវនេះ ព្រះសារីបុត្ត កាលសម្ដែងសន្តានសត្វដែលមិច្ឆាទិដ្ឋិអប់រំដោយពាក្យជាដើមថា **សស្សតោ លោកោ** ដែលសម្មាទិដ្ឋិអប់រំដោយពាក្យជាដើមថា **អត្ថិ ទិន្នំ** ហើយសម្ដែងសន្តានសត្វ ដែលអកុសលដ៏សេសនិងកុសលដ៏សេសអប់រំហើយដោយបទជាដើមថា **កាមំ សេវន្តញ្ញេវ** ។ ក្នុងបទនោះ គប្បីធ្វើការប្រកបសេចក្ដីថា ព្រះតថាគតទ្រង់រមែងជ្រាបបុគ្គលអ្នកសេពកាម ។ បទថា **សេវន្តញ្ញេវ** បានដល់ អ្នកសេពដោយការប្រព្រឹត្តរឿយៗ ។ ឈ្មោះថា **កាមគរុកោ** ព្រោះអត្ថថា មានកិលេសកាមធ្ងន់ដោយអំណាចសេពមកក្នុងកាលមុន ។ ឈ្មោះថា **កាមាសយោ** ព្រោះអត្ថថា មានកាមក្នុងសន្តានជាទីអាស្រ័យ ។ ឈ្មោះថា **កាមាធិមុត្តោ** ព្រោះអត្ថថា បង្អោនគឺជាប់ក្នុងកាមដោយអំណាចសន្តាននោះឯង ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។

បទថា **នេក្ខម្ម** ជាដើម មានអត្ថដូចពោលហើយ ។ គប្បីជ្រាបថា អកុសលដ៏សេស លោកកាន់យកដោយកិលេស ៣ យ៉ាង មានកាមជាដើម កុសលដ៏សេស លោកកាន់យកដោយគុណធម៌ ៣ យ៉ាង មាននេក្ខម្មៈជាដើម ។ ព្រះសារីបុត្តត្រេសម្ដែងសន្តានដែលលោកពោល ៣ យ៉ាងថា **អយំ សត្តានំ អាសយោ** ។

ចំណែកក្នុងនិទ្ទេសនេះ មានន័យរបស់អដ្ឋកថាដូចតទៅ បទថា **ឥតិ**

**ភវទិដ្ឋិសន្និស្សិតា វា** បានដល់ អាស្រ័យសស្សតទិដ្ឋិ យ៉ាងនេះក៏មាន ។ ពិតហើយ ក្នុងទីនេះ លោកពោលសស្សតទិដ្ឋិថាជាភវទិដ្ឋិ ហើយពោលឧច្ឆេទ-ទិដ្ឋិថាជាវិភវទិដ្ឋិ ព្រោះថា សត្វដែលមានទិដ្ឋិទាំងឡាយទាំងអស់នេះ រមែងអាស្រ័យទិដ្ឋិ ២ យ៉ាងទាំងនេះឯង ព្រោះលោកសង្គ្រោះទិដ្ឋិទាំងអស់ ចូលដោយសស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិ ។ សូម្បីសេចក្ដីនេះ ព្រះមានព្រះភាគក៏ត្រាស់ ( ក្នុងសំយុត្តនិកាយ និទានវគ្គ ) ថា ម្នាលកច្ចានៈ សត្វលោកនេះ ច្រើនតែអាស្រ័យនូវចំណែកពីរយ៉ាង គឺអត្ថិភាព ( សស្សតទិដ្ឋិ ) ១ នត្ថិភាព ( ឧច្ឆេទទិដ្ឋិ ) ១ ដូច្នេះ ។

ក្នុងពីរបទនេះ បទថា **អត្ថិភាព** បានដល់ សស្សតទិដ្ឋិ ។ បទថា **នត្ថិភាព** បានដល់ ឧច្ឆេទទិដ្ឋិ ។ នេះជាធន្ទៈដែលមកដេកត្រាំរបស់សត្វទាំងឡាយជាបុថុជ្ជនអាស្រ័យវដ្ដៈ ។

ឥឡូវនេះ ព្រះសារីបុត្ត កាលសម្ដែងធន្ទៈជាទីមកដេកត្រាំ របស់សត្វដែលបរិសុទ្ធដែលអាស្រ័យវិវដ្ដៈ ទើបពោលពាក្យជាដើមថា **ឯតេ វា បន ឧភោ អន្តេ អនុបគម្ម** ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា **ឯតេ វា បន** ក៏គឺ **ឯតេយេវ** ។ បទថា **ឧភោ អន្តេ** បានដល់ ទីបំផុត ២ យ៉ាង គឺសស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិ ។ បទថា **អនុបគម្ម** បានដល់ មិនជាប់ជំពាក់ ។ បទថា **ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ធម្មេសុ** បានដល់ ក្នុងកាលដែលមានវត្ថុនេះជាបច្ច័យ និងក្នុងធម៌ទាំងឡាយដែលអាស្រ័យគ្នាកើតឡើង ។ បទថា **អនុលោមិកា ខន្តិ** បានដល់ វិបស្សនាញាណ ។ បទថា **យថាភូតំ**

**ញាណំ** បានដល់ មគ្គញ្ញាណ ។ មានពាក្យអធិប្បាយថា វិបស្សនាណា ដែលបានហើយ ក្នុងបដិច្ចសមុប្បាទ និងក្នុងធម៌ដែលអាស្រ័យគ្នាកើតឡើង ព្រោះមិនជាប់ជំពាក់ក្នុងទីបំផុត ២ យ៉ាង គឺសស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិ និងមគ្គ-ញ្ញាណណា ដែលក្រៃលែងជាងវិបស្សនានោះដែលបានហើយ នេះឈ្មោះថា អាសយធម៌របស់ពួកសត្វ ។ វិបស្សនានេះជាឆន្ទៈ ជាទីមកដេក មគ្គញ្ញាណ នេះ ជាទីនៅអាស្រ័យរបស់សត្វទាំងឡាយដែលអាស្រ័យវដ្ដៈ និងអាស្រ័យ វិវដ្ដៈ ។ នេះជាអដ្ឋកថាដែលពួកអាចារ្យឃើញដូចគ្នា ។

ចំណែកអាចារ្យវិតណ្ឌវាទីពោលថា ឈ្មោះថា មគ្គទម្លាយនូវទីនៅរមែង ទៅ លោកនៅនិយាយថា មគ្គជាទីនៅដូច្នេះឬ ។ គួរសួរអាចារ្យនោះថា លោកជាអ្នកសូធ្យអរិយវាសមែន ឬមិនមែន បើអាចារ្យនោះឆ្លើយថា ខ្ញុំមិន មែនជាអ្នកសូធ្យ គួរប្រាប់ថា លោកមិនដឹង ព្រោះលោកមិនបានសូធ្យ បើ ឆ្លើយថា ខ្ញុំជាអ្នកសូធ្យ គួរប្រាប់ថា ចូរនាំព្រះសូត្រមកចុះ បើនាំមកបានជា ការល្អ បើនាំមកមិនបាន គួរនាំ ( សូត្រក្នុងអង្គុត្តរនិកាយ ទសកនិបាត ) មក ឯងថា ម្នាលភិក្ខុទាំងឡាយ អរិយវាស ( ធម៌ជាគ្រឿងអប់រំដ៏ប្រសើរ ) នេះមាន ១០ យ៉ាង ដែលពួកព្រះអរិយៈបានអប់រំហើយក្ដី កំពុងអប់រំក្ដី នឹង អប់រំក្ដី ដូច្នេះ ។ ពិតហើយ សូត្រនេះរមែងសម្ដែងភាពដែលមគ្គ ជាគ្រឿង នៅ ព្រោះហេតុនោះ ទើបសូត្រនេះ ឈ្មោះថា ត្រាស់ល្អហើយ មយ៉ាងទៀត ព្រះមានព្រះភាគ កាលទ្រង់ដឹងឆន្ទៈជាទីមកដេកត្រាំនេះ របស់សត្វទាំងឡាយ ទ្រង់រមែងដឹង សូម្បីក្នុងខណៈមិនប្រព្រឹត្តទៅនៃទិដ្ឋិទាំងនេះផង នៃវិបស្សនា-

ញាណ និងមគ្គញាណទាំងនោះផង ព្រោះហេតុនោះឯង ទើបលោកពោល

ពាក្យថា **កាមំ សេវន្តំយេវ ជានាតិ** ដូច្នេះជាដើម ។

[ ២៧៩ ] គប្បីជ្រាបអធិប្បាយ ក្នុងអនុសយនិទ្ទេសដូចតទៅនេះ បទ ថា **អនុសយា** ឈ្មោះថា អនុស័យ ដោយអត្ថថា ដូចម្តេច ដោយអត្ថថា ដេកត្រាំ ។ ឈ្មោះថា ដេកត្រាំនោះ មានអត្ថដូចម្តេច មានអត្ថថា មិនទាន់ លះបាន ។ ពិតហើយ កិលេសទាំងនេះ រមែងដេកត្រាំក្នុងសន្តាន របស់សត្វ នោះៗ ព្រោះអត្ថថា នៅមិនទាន់លះបាន ព្រោះហេតុនោះ ទើបលោកពោល ថា **អនុសយា** ។

បទថា **អនុសេន្តិ** បានដល់ បានហេតុដែលសមគួរហើយ ទើបកើត ។ កាលបើយ៉ាងនេះ គប្បីមានពាក្យនិយាយថា ការពោលថាអាការដែលនៅមិន ទាន់លះបាន ឈ្មោះថា ជាសភាពនៃអនុស័យ ហើយអនុស័យនោះរមែងកើត ឡើង ដូច្នេះ មិនត្រឹមត្រូវ ព្រោះហេតុនោះ អនុស័យកើតឡើងមិនបាន ។ ក្នុងសេចក្តីនោះ មានពាក្យឆ្លើយដូច្នេះថា អនុស័យមិនមែនអាការដែលមិន ទាន់លះបាន តែលោកពោលដល់កិលេសដែលមានកម្លាំង ដោយអត្ថថា មិន ទាន់លះបាន ថាជាអនុស័យ ។

អនុស័យនោះ សម្បយុត្តដោយចិត្ត មានអារម្មណ៍ មានហេតុ ព្រោះអត្ថ ថា មានបច្ច័យជាអកុសលដោយចំណែកមួយ ជាអតីតខ្លះ អនាគតខ្លះ បច្ចុប្បន្ន ខ្លះ ព្រោះហេតុនោះ ការពោលថា អនុស័យកើតឡើង ទើបត្រឹមត្រូវ ។ ក្នុង សេចក្តីនោះមានសេចក្តីសំខាន់ដូច្នេះថា ក្នុងសេចក្តីនោះឯង ក្នុងអភិសមយកថា

( បដិសម្ភិទាមគ្គ ) លោកតាំងសំណួរថា លះកិលេសដែលកើតចំពោះមុខ ហើយពោលវិសជ្ជនាថា អ្នកមានព្យាយាមលះអនុស័យ ដូច្នេះ ព្រោះភាពដែលអនុស័យ ជាកិលេសមានក្នុងបច្ចុប្បន្ន ។

ក្នុងបទភាជនីយ៍នៃមោហៈក្នុងធម្មសង្គណី ព្រះមានព្រះភាគ ត្រាស់ភាពដែលមោហៈកើតជាមួយអកុសលចិត្តថា អនុស័យ គឺអវិជ្ជា សេចក្ដីគ្របសង្កត់ គឺអវិជ្ជា គន្លឹះ គឺអវិជ្ជា គឺមោហៈ ជាអកុសលមូលណាក្នុងសម័យនោះ នេះមោហៈកើតមានក្នុងសម័យនោះ ដូច្នេះ ។ ក្នុងកថាវត្ថុ លោកពោលថា អនុស័យជាអព្យាក្រឹត អនុស័យមិនមានហេតុ អនុស័យប្រាសចាកចិត្ត វាទៈទាំងអស់ ត្រូវបដិសេធ ។ ក្នុងឧប្បជ្ជនវារៈ វារៈណាមួយនៃ ៧ វារៈ ក្នុងអនុសយយមកៈលោកពោលថា កាមរាគានុស័យរបស់បុគ្គលណាកើតឡើង បដិឃានុស័យរបស់បុគ្គលនោះកើតឡើងឬ ដូច្នេះជាដើម ។ ព្រោះហេតុនោះពាក្យដែលពោលថា **អនុសេន្តិ** បានដល់ បានហេតុដែលសមគួរហើយ ទើបកើត គប្បីជ្រាបថា ត្រឹមត្រូវដោយកំណត់បែបផែននេះ ។ សូម្បីពាក្យដែលលោកពោលថា អនុស័យនោះសម្បយុត្តដោយចិត្តមានអារម្មណ៍ដូច្នេះជាដើម ទើបជាការពោលល្អហើយ ។ ក្នុងទីនេះ គួរសម្រេចបានថា ឈ្មោះថា អនុស័យនេះ ជាអកុសលធម៌ពិត ដែលសម្បយុត្តដោយចិត្ត ។

ក្នុងបទថា **កាមរាគានុសយោ** ជាដើម មានសេចក្ដីដូចតទៅ ឈ្មោះថា កាមរាគានុស័យ ព្រោះអត្ថថា ជាកាមរាគៈផង ជាអនុស័យផង ដោយអត្ថថា មិនទាន់លះបាន ។ សូម្បីក្នុងបទដ៏សេសក៏មានន័យនេះដូចគ្នា ។

ម្យ៉ាងទៀត ក្នុងទីនេះ កាមរាគានុស័យ កាលកើតឡើងក្នុងចិត្តដែលសហគតៈដោយលោភៈ ដោយអំណាចសហជាតប្បច្ច័យ និងអារម្មណប្បច្ច័យ កាលកើតឡើងក្នុងកាមាវចរធម៌ដ៏សេស ដែលគួរពេញចិត្តដោយអំណាចអារម្មណប្បច្ច័យតែម្យ៉ាង លោកពោលថា ជាលោភៈ ។

ម្យ៉ាងទៀត បដិឃានុស័យ កាលកើតឡើងក្នុងចិត្តដែលសហគតៈដោយទោមនស្សដោយអំណាចសហជាតប្បច្ច័យ និងអារម្មណប្បច្ច័យ និងកាលកើតឡើងក្នុងកាមាវចរធម៌ដ៏សេស ដែលមិនគួរពេញចិត្ត ដោយអំណាចអារម្មណប្បច្ច័យតែម្យ៉ាង លោកពោលថា ជាទោសៈ ។

មានានុស័យ កាលកើតឡើងក្នុងចិត្តដែលសហគតៈដោយលោភៈ វិប្បយុត្តចាកទិដ្ឋិដោយអំណាចសហជាតប្បច្ច័យ និងអារម្មណប្បច្ច័យ និងកាលកើតឡើងក្នុងកាមាវចរធម៌ដ៏សេស ដែលវៀរទុក្ខវេទនា និងក្នុងរូបាវចរធម៌ អរូបាវចរធម៌ ដោយអំណាចអារម្មណប្បច្ច័យ លោកពោលថា ជាមានះ ។

ទិដ្ឋានុស័យ កើតក្នុងចិត្តសម្បយុត្តដោយទិដ្ឋិ ៤ ដួង ។

វិចិកិច្ឆានុស័យ កើតក្នុងចិត្តសហគតៈដោយវិចិកិច្ឆា ។

អវិជ្ជានុស័យ កើតក្នុងអកុសលចិត្ត ១២ ដោយអំណាចសហជាតប្បច្ច័យ និងអារម្មណប្បច្ច័យ ។ អនុស័យទាំង ៣ ( ទិដ្ឋានុស័យ វិចិកិច្ឆានុស័យ អវិជ្ជានុស័យ ) កាលកើតឡើងក្នុងធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដ៏សេស ដោយអំណាចអារម្មណប្បច្ច័យនោះឯង លោកពោលថា ជាទិដ្ឋិ វិចិកិច្ឆា និងមោហៈ ។

ភវរាគានុស័យ កាលកើតឡើងក្នុងចិត្តដែលវិប្បយុត្តចាកទិដ្ឋិ ៤ ដួង លោកក៏មិនពោលដល់ដោយអំណាចសហជាតប្បច្ច័យ តែកាលកើតឡើងក្នុងរូបាវចរធម៌ និងអរូបាវចរធម៌ ដោយអំណាចអារម្មណប្បច្ច័យនោះឯង លោកពោលថា ជាលោកៈ ។

ឥឡូវនេះ ព្រះសារីបុត្តត្ថេរ កាលនឹងសម្ដែងទីតាំងដែលជាទីដេកត្រាំនៃអនុសយក្កិលេស តាមដែលពោលមកហើយ ទើបពោលពាក្យថា **យំ លោកេ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **យំលោកេ បិយរូបំ** បានដល់ អារម្មណ៍ដែលគួរស្រឡាញ់ដោយកំណើតដែលគួរស្រឡាញ់ ដោយសភាវៈក្នុងលោកនេះ ។ បទថា **សាតរូបំ** បានដល់ អារម្មណ៍ដែលគួរត្រេកអរដោយកំណើតដែលមានភាពគួរត្រេកអរជាបទដ្ឋាន គឺឥដ្ឋារម្មណ៍ ។

បទថា **ឯត្ថ សត្តានំ កាមរាគានុសយោ អនុសេតិ** បានដល់ កាម-រាគានុស័យ មានសភាពលះមិនទាន់បានរបស់សត្វទាំងឡាយ រមែងដេកត្រាំក្នុងឥដ្ឋារម្មណ៍នេះ ។ ម្យ៉ាងទៀត កាមាវចរធម៌នោះឯង លោកបំណងយកក្នុងពាក្យនេះថា **បិយរូបំ សាតរូបំ** ។

ដូចបុគ្គលមុជទឹកទាំងខាងក្រោមទាំងខាងលើ និងដោយជុំវិញ ក៏ជាទឹកទាំងអស់យ៉ាងណា ឈ្មោះថា ការកើតឡើងនៃរាគៈក្នុងឥដ្ឋារម្មណ៍ក៏យ៉ាងនោះ ជាការប្រព្រឹត្តជាប្រចាំរបស់សត្វទាំងឡាយ ។ ការកើតឡើងនៃបដិឃៈ ក្នុងអនិដ្ឋារម្មណ៍ក៏យ៉ាងនោះដូចគ្នា ។

បទថា **ឥតិ ឥមេសុ ទ្វីសុ ធម្មេសុ** បានដល់ ក្នុងធម៌ដែលជាឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ពីរយ៉ាងនេះ ដោយប្រការដូច្នេះ ។

បទថា **អវិជ្ជានុបតិតា** បានដល់ អវិជ្ជាដែលសម្បយុត្តដោយកាមរាគៈ និងបដិឃៈធ្លាក់ទៅតាម គឺទៅតាមដោយអំណាចធ្វើឲ្យជាអារម្មណ៍ ។ បាឋៈ លោកកាត់បទថា **អវិជ្ជា អនុបតិតា អនុគតា** ក៏មាន ។

បទថា **តទេកដ្ឋោ** បានដល់ តាំងនៅដោយភាពតែមួយជាមួយអវិជ្ជានោះ ដោយកើតរួមគ្នា និងតាំងនៅក្នុងទីជាមួយគ្នា ។

បទថា **មានោ ច ទិដ្ឋិ ច វិចិកិច្ឆា ច** បានដល់ មានះ ៩ ទិដ្ឋិ ៦២ វិចិកិច្ឆា ៨ យោជនាលម្អិតថា មានះ ទិដ្ឋិ វិចិកិច្ឆាដែលតាំងនៅរួមគ្នាជាមួយ អវិជ្ជានោះ ។

បទថា **ទដ្ឋព្វា** បានដល់ គប្បីមើល គប្បីតាមទៅ ។ លោកធ្វើពាក្យ ទាំង ៣ រួមគ្នាឲ្យជាពហុវចនៈ ។ ម្យ៉ាងទៀត កវរាគានុស័យក្នុងនិទ្ទេសនេះ គប្បីជ្រាបថា លោកសង្គ្រោះដោយកាមរាគានុស័យ ។

[ ២៨០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងចរិតនិទ្ទេសដូចតទៅនេះថា ចេតនា ១៣ ជាបុញ្ញាភិសង្ខារ ចេតនា ១២ ជាអបុញ្ញាភិសង្ខារ ចេតនា ៤ ជាអនេញ្ជាភិសង្ខារ ។

ក្នុងបទទាំងនោះ កាមាវចរ ជាភូមិតូច ក្រៅពីនោះជាភូមិធំ ។ ម្យ៉ាងទៀត គប្បីជ្រាបថា ក្នុងអភិសង្ខារទាំង ៣ នេះ អភិសង្ខារណាមានវិបាកតិច ជា ភូមិតូច មានវិបាកច្រើន ជាភូមិធំ ។

[ ២៨១ ] គប្បីជ្រាបវិនិច្ឆ័យ ក្នុងអធិមុត្តិនិទ្ទេសដូចតទៅនេះ បទថា **សន្តិ** បានដល់ មាន ។ បទថា **ហីនាធិមុត្តិកា** បានដល់ មានអធ្យាស្រ័យថោកទាប ។ បទថា **បណីតាធិមុត្តិកា** បានដល់ មានអធ្យាស្រ័យល្អ ។ បទថា **សេវន្តិ** បានដល់ អាស្រ័យពឹងពាក់ ។ បទថា **ភជន្តិ** បានដល់ ចូលទៅជិត ។ បទថា **បយិរុបាសន្តិ** បានដល់ ទៅចូលរករឿយៗ ។

ប្រសិនបើអាចារ្យ និងឧបជ្ឈាយ៍ ជាអ្នកមិនមានសីល អន្តេវាសិក និងសទ្ធិវិហារិកជាអ្នកមានសីល ពួកគេនឹងមិនចូលទៅរក សូម្បីអាចារ្យ និងឧបជ្ឈាយ៍របស់ខ្លួន នឹងចូលទៅរកភិក្ខុដែលសមគួរដូចជាខ្លួនប៉ុណ្ណោះ ។

ប្រសិនបើអាចារ្យ និងឧបជ្ឈាយ៍ជាភិក្ខុសមគួរ គឺមានសីល ភិក្ខុក្រៅអំពីនោះ ( អន្តេវាសិក និងសទ្ធិវិហារិក ) មិនសមគួរ គឺមិនមានសីល ភិក្ខុទាំងនោះក៏នឹងមិនចូលទៅរកអាចារ្យ និងឧបជ្ឈាយ៍ នឹងចូលទៅរកភិក្ខុដែលមានអធិមុត្តិថោកទាបដូចនឹងខ្លួន ។

ម្យ៉ាងទៀត ការចូលទៅរកយ៉ាងនេះ មិនមែនមានតែក្នុងឥឡូវនេះប៉ុណ្ណោះទេ ព្រះសារីបុត្តត្ថេរ ដើម្បីសម្តែងថា សូម្បីក្នុងអតីត និងអនាគតក៏មាន ទើបពោលពាក្យថា **អតីតម្បិ អទ្ធានំ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **អតីតម្បិ អទ្ធានំ** បានដល់ ក្នុងអតីតកាល ។ ពាក្យនេះជាទុតិយាវិភត្តិ ចុះក្នុងអត្ថអច្ចន្តសំយោគ បទដ៏សេសមានអត្ថងាយយល់ហើយ ។ សួរថា អ្នកទ្រុស្តសីលសេពគប់អ្នកទ្រុស្តសីល អ្នកមានសីលសេពគប់អ្នកមានសីល អ្នកមានបញ្ញាថោកថយសេពគប់អ្នកមានបញ្ញាថោក

ថយ អ្នកមានបញ្ញាសេពគប់អ្នកមានបញ្ញា អ្នកណាកំណត់ ឆ្លើយថា ធាតុនៃអធ្យាស្រ័យកំណត់ ។

[ ២៨២-២៨៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងកញ្ចកញ្ចនិទ្ទេស ដូចតទៅនេះថា ព្រះសារីបុត្តត្ថេរ ដើម្បីសម្តែងរបស់ដែលគួរលះបង់មុន ហើយសម្តែងរបស់ដែលគួរកាន់យក ក្នុងកាលជាខាងក្រោយ ទើបសម្តែងអកញ្ចសត្វមុន ខុសលំដាប់នៃឧទ្ទេស ។ តែក្នុងឧទ្ទេសលោកប្រកប **ភព្វ** សព្ទមុនដោយអំណាចលក្ខណៈការដាក់ពាក្យដែលគួររាប់អាន និងមានអក្ខរៈតិច ក្នុងលំដាប់ដំបូងក្នុងទ្វន្ទសមាស ។

បទថា **កម្មាវរណេន** បានដល់ ដោយអនន្តរិយកម្ម ៥ ។ បទថា **សមង្គាគតា** បានដល់ ជាអ្នកដល់ព្រម ។ បទថា **កិលេសាវរណេន** បានដល់ ដោយនិយតមិច្ឆាទិដ្ឋិ ។ ធម៌ទាំងពីរនេះ ឈ្មោះថា **អាវរណា** ព្រោះរាំងស្ថានសួគ៌ និងមគ្គ ។ សូម្បីកម្មមានការប្រទូស្តភិក្ខុនីជាដើម លោកក៏សង្គ្រោះដោយកម្មាវរណៈនោះឯង ។

បទថា **វិបាកាវរណេន** បានដល់ ដោយអហេតុកបដិសន្ធិ ព្រោះការបាក់ធ្លុះអរិយមគ្គ រមែងមិនមានសូម្បីដល់ទុហេតុកសត្វទាំងឡាយ ហេតុនោះគប្បីជ្រាបថា សូម្បីបដិសន្ធិជាទុហេតុកៈ ក៏ជាវិបាកាវរណៈនោះឯង ។

បទថា **អស្សទ្ធា** បានដល់ មិនមានសទ្ធា ក្នុងព្រះពុទ្ធជាដើម ។ បទថា **អច្ឆន្ទិកា** បានដល់ មិនមានឆន្ទៈក្នុងកុសល គឺភាពជាអ្នកប្រាថ្នាដើម្បីនឹងធ្វើ ។ ពួកមនុស្សក្នុងឧត្តរកុរុទ្វីប រាប់ចូលក្នុងឋានៈដែលមិនមានឆន្ទៈ ។

បទថា **ឧប្បញ្ញា** បានដល់ សាបសូន្យចាកកវន្តប្បញ្ញា ។ ម្យ៉ាងទៀត សូម្បីកាលកវន្តប្បញ្ញាបរិបូរ កវន្តរបស់បុគ្គលណាមិនទាន់ជាបាទរបស់លោកុត្តរ សូម្បីបុគ្គលនោះក៏នៅឈ្មោះថា ជាអ្នកមានបញ្ញាថោកថយនោះឯង ។

បទថា **អភព្វា និយាមំ ឱក្កមិតុំ កុសលេសុ ធម្មេសុ សម្មត្តំ** បានដល់ មិនអាចឈមចុះកាន់អរិយមគ្គ ពោលគឺសម្មត្តនិយាមក្នុងកុសលធម៌ទាំងឡាយ ព្រោះថា អរិយមគ្គជាសភាវៈដោយប្រពៃ ព្រោះហេតុនោះ ទើបឈ្មោះថា **សម្មត្ត** អរិយមគ្គនោះឯង ឈ្មោះថា **និយាម** ព្រោះការឲ្យផលក្នុងលំដាប់ ឬថា ខ្លួនឯងមានសភាពមិនញាប់ញ័រ ។ មិនអាចឈមចុះ គឺចូលកាន់អរិយមគ្គនោះ ។ បទថា **ន កម្មាវរណេន** ជាដើម គប្បីជ្រាបដោយបរិយាយផ្ទុយគ្នានឹងពាក្យដែលពោលហើយនុ៎ះឯង ។៙

**អដ្ឋកថាអាសយានុសយញ្ញាណនិទ្ទេស ចប់**

# សុត្តន្តបិដក

[ ២៨៤ ] យមកប្បាដិហិរយញ្ញាណ របស់ព្រះតថាគត តើដូចម្តេច ។ ព្រះតថាគត ទ្រង់ធ្វើយមកប្បាដិហារ្យដែលមិនទូទៅដល់ពួកសាវ័កក្នុងលោកនេះ គឺគំនរភ្លើងចេញអំពីព្រះកាយខាងលើ ផ្ការទឹកចេញអំពីព្រះកាយខាងក្រោម គំនរភ្លើងចេញអំពីព្រះកាយខាងក្រោម ផ្ការទឹកចេញអំពីព្រះកាយខាងលើ គំនរភ្លើងចេញអំពីព្រះកាយខាងមុខ ផ្ការទឹកចេញអំពីព្រះកាយខាងក្រោយ គំនរភ្លើងចេញអំពីព្រះកាយខាងក្រោយ ផ្ការទឹកចេញអំពីព្រះកាយខាងមុខ គំនរភ្លើងចេញអំពីព្រះនេត្រខាងស្តាំ ផ្ការទឹកចេញអំពីព្រះនេត្រខាងឆ្វេង គំនរភ្លើងចេញអំពីព្រះនេត្រខាងឆ្វេង ផ្ការទឹកចេញអំពីព្រះនេត្រខាងស្តាំ គំនរភ្លើងចេញអំពីរន្ធព្រះកាណ៌ខាងស្តាំ ផ្ការទឹកចេញអំពីរន្ធព្រះកាណ៌ខាងឆ្វេង គំនរភ្លើងចេញអំពីរន្ធព្រះកាណ៌ខាងឆ្វេង ផ្ការទឹកចេញអំពីរន្ធព្រះកាណ៌ខាងស្តាំ គំនរភ្លើងចេញអំពីរន្ធព្រះនាសិកាខាងស្តាំ ផ្ការទឹកចេញអំពីរន្ធព្រះនាសិកាខាងឆ្វេង គំនរភ្លើង ចេញអំពីរន្ធព្រះនាសិកាខាងឆ្វេង ផ្ការទឹកចេញអំពីរន្ធព្រះនាសិកាខាងស្តាំ គំនរភ្លើងចេញអំពីចង្កួយព្រះអង្សាខាងស្តាំ ផ្ការទឹកចេញអំពីចង្កួយព្រះអង្សាខាងឆ្វេង គំនរភ្លើងចេញអំពីចង្កួយព្រះអង្សាខាងឆ្វេង ផ្ការទឹកចេញអំពីចង្កួយព្រះអង្សាខាងស្តាំ គំនរភ្លើងចេញអំពីព្រះហស្តខាងស្តាំ ផ្ការទឹកចេញអំពីព្រះហស្តខាងឆ្វេង គំនរភ្លើងចេញអំពីព្រះហស្តខាងឆ្វេង ផ្ការទឹកចេញអំពីព្រះហស្តខាងស្តាំ គំនរភ្លើងចេញអំពីខាងខាងស្តាំ ផ្ការទឹកចេញអំពីខាងខាងឆ្វេង គំនរភ្លើងចេញអំពីខាងខាងឆ្វេង ផ្ការទឹកចេញអំពី

ខាងខាងស្តាំ គំនរភ្លើងចេញអំពីព្រះបាទខាងស្តាំ ផ្កាទឹកចេញអំពីព្រះបាទខាងឆ្វេង គំនរភ្លើងចេញអំពីព្រះបាទខាងឆ្វេង ផ្កាទឹកចេញអំពីព្រះបាទខាងស្តាំ គំនរភ្លើងចេញអំពីព្រះអង្គុលីមួយៗ ផ្កាទឹកចេញអំពីចន្លោះនៃព្រះអង្គុលី គំនរភ្លើងចេញអំពីចន្លោះនៃព្រះអង្គុលី ផ្កាទឹកចេញអំពីព្រះអង្គុលីមួយៗ គំនរភ្លើងចេញអំពីព្រះលោមាមួយៗ ផ្កាទឹកចេញអំពីព្រះលោមាមួយៗ គំនរភ្លើងចេញអំពីរណ្តៅព្រះលោមាមួយៗ ផ្កាទឹកចេញអំពីរណ្តៅព្រះលោមាមួយៗ ( ព្រះមានព្រះភាគទ្រង់បញ្ចេញ ) នូវព្រះឆព្វណ្ណរង្សីខៀវ លឿង ក្រហម ស ហង្សបាទ ផ្លេកៗ ព្រះមានព្រះភាគទ្រង់ចង្រ្កម ព្រះពុទ្ធនិម្មិតទ្រង់ឈរ ឬទ្រង់គង់ ឬទ្រង់ផ្ទំ ព្រះមានព្រះភាគទ្រង់ឈរ ព្រះពុទ្ធនិម្មិតទ្រង់ចង្រ្កម ឬទ្រង់គង់ ឬទ្រង់ផ្ទំ ព្រះមានព្រះភាគទ្រង់គង់ ព្រះពុទ្ធនិម្មិតទ្រង់ចង្រ្កម ឬទ្រង់ឈរ ឬទ្រង់ផ្ទំ ព្រះមានព្រះភាគទ្រង់ផ្ទំ ព្រះពុទ្ធនិម្មិតទ្រង់ចង្រ្កម ឬទ្រង់ឈរ ឬទ្រង់គង់ ព្រះមានព្រះភាគទ្រង់ចង្រ្កម ឬទ្រង់គង់ ឬផ្ទំ ព្រះពុទ្ធនិម្មិត្តទ្រង់ឈរ ព្រះមានព្រះភាគទ្រង់ចង្រ្កម ឬទ្រង់ឈរ ឬទ្រង់ផ្ទំ ព្រះពុទ្ធនិម្មិតទ្រង់គង់ ព្រះមានព្រះភាគទ្រង់ឈរ ឬទ្រង់គង់ ឬទ្រង់ចង្រ្កម ព្រះពុទ្ធនិម្មិតទ្រង់ផ្ទំ នេះឈ្មោះថា យមកប្បាដិហិរយញ្ញាណរបស់ព្រះតថាគត ។

# អដ្ឋកថា
## យមកប្បាដិហីរញ្ញាណនិទ្ទេស

[ ២៨៤ ] គប្បីជ្រាបវិនិច្ឆ័យ ក្នុងយមកប្បាដិហីរញ្ញាណនិទ្ទេសដូចតទៅ បទថា **អសាធារណំ សាវកេហិ** លោកមិនបានពោលក្នុងអសាធារណញ្ញាណនិទ្ទេសដ៏សេស ព្រោះមានពាក្យដទៃៗ ទើបមិនមានឱកាស តែក្នុងនិទ្ទេសនេះ គប្បីជ្រាបថា លោកពោលព្រោះមិនមានពាក្យដទៃ ។

បទថា **ឧបរិមកាយតោ** បានដល់ អំពីព្រះសរីរៈតាំងអំពីព្រះនាភីឡើងទៅ ។ បទថា **អគ្គិក្ខន្ធោ បវត្តតិ** បានដល់ កាលព្រះមានព្រះភាគ ចូលឈានដែលជាបាទ មានតេជោកសិណជាអារម្មណ៍ កាលចេញហើយ ទ្រង់អាវជ្ជនៈថា ចូរអណ្ដាតភ្លើងផ្សាយចេញអំពីកាយខាងលើ ហើយធ្វើបរិកម្មអធិដ្ឋានមួយរំពេចដោយអភិញ្ញាណថា ចូរអណ្ដាតភ្លើងផ្សាយចេញអំពីកាយខាងលើ អណ្ដាតភ្លើងនឹងផ្សាយចេញអំពីព្រះកាយខាងលើ ដំណាលគ្នានឹងការអធិដ្ឋាន ។ ក្នុងនិទ្ទេសនេះ អណ្ដាតភ្លើងនោះ លោកហៅថា ខន្ធ ដោយអត្ថថា ជាគំនរ ។

បទថា **ហេដ្ឋិមកាយតោ** បានដល់ ចាកព្រះសរីរៈតាំងអំពីព្រះនាភីចុះទៅ ។ បទថា **ឧទកធារា បវត្តតិ** បានដល់ កាលព្រះមានព្រះភាគ ចូលឈានដែលជាបាទ មានអាបោកសិណជាអារម្មណ៍ កាលចេញហើយ ទ្រង់អាវជ្ជនៈថា ចូរផ្សារទឹកផ្សាយចេញអំពីកាយខាងក្រោម ហើយធ្វើបរិកម្ម អធិដ្ឋានមួយរំពេចដោយអភិញ្ញាញាណថា ចូរផ្សារទឹក ផ្សាយចេញអំពីកាយខាង

ក្រោម ផ្ការទឹកនឹងផ្សាយចេញអំពីព្រះកាយខាងក្រោម ដំណាលគ្នានឹងអធិដ្ឋាន ។ សូម្បីក្នុងបទទាំងពីរ លោកពោលថា ផ្សាយចេញដោយមិនដាច់ខ្សែ ។ កវគ្គចិត្ត ២ ដួងរមែងប្រព្រឹត្តទៅក្នុងវាងអធិដ្ឋាន និងអាវជ្ជនៈ ព្រោះហេតុនោះឯង ទើបផ្ការភ្លើង និងផ្ការទឹកផ្សាយចេញជាគូរមិនប្រាកដចន្លោះ ។ ឯការកំណត់កវគ្គចិត្ត មិនមានដល់សាវកពួកដទៃ ។ បទថា **បុរត្ថិមកាយតោ** បានដល់ អំពីខាងមុខ ។ បទថា **បច្ឆិមកាយតោ** បានដល់ អំពីខាងក្រោយ ។

បទថា **ទក្ខិណអក្ខិតោ វាមអក្ខិតោ** ជាដើម ជាបាឋសមាស មិនមែនបាឋៈដទៃ ។ បាឋៈថា **ទក្ខិណនាសិកាសោតតោ វាមនាសិកាសោតតោ** ដូច្នេះ ជាបាឋៈល្អ ។ អាចារ្យទាំងឡាយពោលធ្វើជារស្សៈក៏មាន ។

ក្នុងបទថា **អំសកូដតោ** នេះ មានសេចក្ដីដូច្នេះថា ឈ្មោះថា **កូដ** ព្រោះអត្ថថា ខ្ពស់ឡើងដូចកំពូល ចង្កួយ គឺអង្សានោះឯង ឈ្មោះថា **អំសកូដ** ។ បទថា **អង្គុលង្គុលេហិ** បានដល់ ចាកព្រះអង្គុលីទាំងឡាយ ។ បទថា **អង្គុលន្តរិកាហិ** បានដល់ ចាកចន្លោះព្រះអង្គុលីទាំងឡាយ ។ បទថា **ឯកេកលោមតោ អគ្គិក្ខន្ធោ បវត្តតិ ឯកេកលោមតោ ឧទកធារា បវត្តតិ** លោកអធិប្បាយថា ផ្ការភ្លើង ផ្ការទឹកចេញជាគូៗ អំពីព្រះលោមាមួយសរសៃៗ ព្រោះកាន់យកព្រះលោមាទាំងអស់ដោយវាចាដដែលៗ ក្នុងពាក្យទាំងពីរ ។

សូម្បីក្នុងបទថា **លោមកូបតោ លោមកូបតោ អគ្គិក្ខន្ធោ បវត្តតិ លោមកូបតោ លោមកូបតោ ឧទកធារា បវត្តតិ** ក៏មានន័យនេះដូចគ្នា ។ ក្នុងគម្ពីរជាច្រើនលោករចនាថា ផ្ការភ្លើងផ្សាយចេញអំពីព្រះលោមា

មួយសរសៃៗ ផ្ការទឹកផ្សាយចេញអំពីរណ្ដៅព្រះលោមាមួយសរសៃៗ ផ្ការភ្លើងផ្សាយចេញអំពីរណ្ដៅព្រះលោមាមួយសរសៃៗ ផ្ការទឹកផ្សាយចេញអំពីព្រះលោមាមួយសរសៃៗ ពាក្យទាំងនោះក៏ត្រឹមត្រូវ តែបាឋៈមុនល្អជាងព្រោះសម្ដែងសេចក្ដីល្អិតយ៉ាងក្រៃលែងនៃបាដិហារិយ៍ ។

បទថា **ឆន្នំ វណ្ណានំ** មានសម្ពន្ធដូចម្ដេច ក្នុងខាងដើមៗ លោកពោលដល់សរីរាវយវៈដោយពាក្យមិនមែនតិច មានពាក្យថា អំពីព្រះកាយខាងលើជាដើមដោយហេតុនោះ ការសម្ពន្ធដោយសរីរាវយវៈ រមែងប្រព្រឹត្តទៅ ។ ហេតុនោះ ទើបមានពាក្យអធិប្បាយថា រស្មីទាំងឡាយនៃពណ៌ ៦ ដែលជាសរីរាវយវៈ រមែងផ្សាយចេញជាគូៗ ដោយការសម្ពន្ធ ពាក្យពេចន៍ និងដោយអធិការនៃយមកប្បាដិហារិយ៍ ។ ម្យ៉ាងទៀត ដោយការសម្ពន្ធនៃឆដ្ឋីវិភត្តិគប្បីប្រាថ្នាបាឋៈដ៏សេសថា **រស្មិយោ** ( រស្មី ) ជាពិតប្រាកដ ( គឺឲ្យបន្ថែមពាក្យថា **ឆន្នំ វណ្ណានំ រស្មិយោ** ) ។

បទថា **នីលានំ** បានដល់ មានពណ៌ដូចផ្កាត្រកៀត ។ បទថា **បីតកានំ** បានដល់ មានពណ៌ដូចផ្កាកណិការ ។ បទថា **លោហិតកានំ** បានដល់ មានពណ៌ដូចមេភ្លៀង ។ បទថា **ឱទាតានំ** បានដល់ មានពណ៌ដូចផ្កាយព្រឹក ។ បទថា **មញ្ជិដ្ឋានំ** បានដល់ មានពណ៌ក្រហមខ្ចី ។ បទថា **បភស្សរានំ** បានដល់ មានពណ៌ផ្លេកតាមប្រក្រតី ។ ពណ៌ផ្លេកសូម្បីមិនចែកដោយឡែក កាលពោលដល់ពណ៌ ៥ រស្មីណារុងរឿង រស្មីនោះជាពណ៌ផ្លេក ។ ពិតហើយ កាលព្រះតថាគតទ្រង់ធ្វើយមកប្បាដិហារិយ៍ រស្មីមានពណ៌ខៀវ រមែងផ្សាយ

ចេញអំពីទីដែលមានពណ៌ខៀវ មានអំពីព្រះកេសា ព្រះមស្សុ និងព្រះនេត្រ ដោយកម្លាំងនៃយមកប្បាដិហីរញ្ញាណនោះឯង ដោយអំណាចរស្មីមានពណ៌ខៀវ ផ្ទៃមេឃរមែងដូចព្រោងព្រាត ទៅដោយលម្អិតផ្កាអញ្ចន ដូចដេរដាសទៅដោយត្របកផ្កាត្រកៀត និងដូចផ្កាឧប្បលខៀវ ដូចជាងត្នោតកែវមណីជ្រុះចុះមក និងដូចផ្ទាំងសម្ពត់ពណ៌ខៀវចាស់ដែលគេសន្ធឹង ។

រស្មីមានពណ៌លឿង រមែងផ្សាយចេញពីព្រះឆវី និងចេញពីកន្លែងពណ៌លឿងនៃព្រះនេត្រ ដោយអំណាចនៃរស្មីមានពណ៌លឿង ទិសាភាគរមែងរុងរឿង ដូចហូរចេញនូវទឹកពណ៌មាស ដូចលាតត្រដាងនូវផ្ទាំងសំពត់មាស និងដូចដេរដាសទៅដោយលម្អិតស្បូវក្លាំង និងផ្កាកណិការ ។

រស្មីមានពណ៌ក្រហមរមែងផ្សាយចេញពីព្រះមំសៈ ព្រះលោហិត និងចេញពីទីពណ៌ក្រហមនៃព្រះនេត្រ ដោយអំណាចនៃរស្មីពណ៌ក្រហម ទិសាភាគរមែងរុងរឿង ដូចជ្រលក់ដោយលម្អិតក្រហម ដូចហូរចេញនូវទឹកល័ក្តពណ៌ក្រហម ដូចព័ទ្ធដោយសំពត់កម្ពលពណ៌ក្រហម និងដូចដេរដាសដោយផ្កាពណ៌ក្រហម គឺផ្កាជ័យព្រឹក្ស ផ្ការលួសផ្អុង និងផ្កាច្បា ។

រស្មីពណ៌ស រមែងផ្សាយចេញពីព្រះអដ្ឋិ ព្រះទន្ត និងចេញពីទីពណ៌សនៃព្រះនេត្រ ដោយអំណាចនៃរស្មីមានពណ៌ស ទិសាភាគរមែងរុងរឿង ដូចជាលប្រវាត់ដោយផ្ការទឹកដោះដែលហូរចេញពីក្អមប្រាក់ ដូចពាសពិតានដោយផែនប្រាក់ ដូចជាងត្នោតប្រាក់ជ្រុះចុះមក និងដូចដេរដាសដោយផ្កា មានផ្កាម្លិះវល្លិ៍ ផ្កាឈូក-ស ផ្កាឈើទាលខ្យាច់ ផ្កាម្លិះ និងផ្កាម្លិះរួតជាដើម ។

រស្មីពណ៌ហង្សបាទ រមែងចេញចាកត្រង់ទីពណ៌ក្រហមខ្ចី មានបាតព្រះហស្ត និងបាតព្រះបាទជាដើម ដោយអំណាចនៃរស្មីមានពណ៌ហង្សបាទ ទិសាភាគ រមែងរុងរឿងដូចព័ទ្ធដោយបណ្តាញកែវប្រពាល និងដូចដេរដាសដោយផ្កាចប្បា និងផ្កាជកកគាំ ។

រស្មីមានពណ៌ផ្ទេក រមែងផ្សាយចេញអំពីទីដែលមានពណ៌ផ្ទេក មានព្រះឧណ្ណាលោម ព្រះទាឋៈ និងព្រះនខាជាដើម ដោយអំណាចនៃរស្មីមានពណ៌ផ្ទេក ទិសាភាគ រមែងរុងរឿងដូចពេញដោយហ្វូងផ្កាយព្រឹក និងពេញដោយផ្ទេកបន្ទោរជាដើម ។

ដោយបទថា **ភគវា ចង្កមតិ** ជាដើម លោកពោលដើម្បីសម្តែងថា ការធ្វើឥរិយាបថផ្សេងៗ របស់ព្រះមានព្រះភាគ និងព្រះពុទ្ធនិម្មិតទាំងឡាយ រមែងមានដោយយមកប្បាដិហារិយ៍ប៉ុណ្ណោះ ។ ព្រោះព្រះឥរិយាបថរបស់ព្រះពុទ្ធនិម្មិតទាំងនោះ រមែងប្រព្រឹត្តទៅជាគូ ។ ប្រសិនបើសួរថា ព្រះពុទ្ធនិម្មិតមានច្រើន ព្រោះហេតុអ្វី ទើបធ្វើជាឯកវចនៈថា **និម្មិតោ** ជាដើមទៅវិញ ឆ្លើយថា ដើម្បីសម្តែងឥរិយាបថផ្សេងៗ នៃព្រះពុទ្ធនិម្មិតមួយអង្គៗ បណ្តាព្រះពុទ្ធនិម្មិតទាំងឡាយ ។

កាលពោលជាពហុវចនៈ ព្រះពុទ្ធនិម្មិតសូម្បីទាំងអស់ ក៏ដូចជាមានឥរិយាបថផ្សេងៗ គ្នាក្នុងគ្រាតែមួយ ។ តែកាលពោលជាឯកវចនៈ បណ្តាព្រះពុទ្ធនិម្មិតមួយអង្គៗ រមែងប្រាកដថា មានព្រះឥរិយាបថផ្សេងៗ ។ ព្រោះហេតុនោះ ទើបលោកសម្តែងជាឯកវចនៈ ។ សូម្បីព្រះចូឡបន្ថកត្ថេរក៏និម្មិតភិក្ខុមានឥរិយាបថ

ផ្សេងៗ រាប់ពាន់រូបបាន ព្រះមានព្រះភាគ ទ្រង់នឹងមិនធ្វើព្រះពុទ្ធនិម្មិតជាច្រើន ក្នុងយមកប្បាដិហារិយ៍បានដូចម្ដេច ។ វៀរព្រះចូឡបន្ថកត្ថេរចេញហើយ ការនិម្មិតភិក្ខុ មានឥរិយាបថផ្សេងៗ និងមានរូបផ្សេងៗ ដោយអាវជ្ជនៈមួយ រមែងមិនសម្រេចដល់សាវកពួកដទៃ ។ ពិតហើយ រូបនិម្មិតទាំងឡាយដែលមិនបានកំណត់ រមែងដូចគ្នានឹងបុគ្គលសម្ដែងឫទ្ធិនោះឯង រមែងធ្វើវត្ថុដែលបុគ្គលមានឫទ្ធិធ្វើក្នុងឥរិយាបថ មានការឈរ និងអង្គុយជាដើម ឬក្នុងការចរចា ការស្ងៀមជាដើម ។ ការធ្វើមិនដូចគ្នា និងធ្វើកិរិយាផ្សេងៗ គ្នា រមែងសម្រេចដោយអាវជ្ជនៈផ្សេងៗ គ្នា ហើយអធិដ្ឋានថា រូបនិម្មិតប្រមាណប៉ុណ្ណេះ ចូរជាយ៉ាងនេះ រូបនិម្មិតប្រមាណប៉ុណ្ណេះ ចូរធ្វើវត្ថុនេះ ។ តែសម្រាប់ព្រះតថាគត ការនិម្មិតច្រើនយ៉ាង រមែងសម្រេចដោយអាវជ្ជនៈ និងអធិដ្ឋានមួយប៉ុណ្ណោះ ។ គប្បីជ្រាបក្នុងការនិម្មិតធ្មារភ្លើង និងធ្មារទឹក និងក្នុងការនិម្មិតពណ៌ផ្សេងៗ ដោយប្រការដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ភគវា ចង្កមតិ** បានដល់ ព្រះមានព្រះភាគទ្រង់ចង្ក្រមក្នុងអាកាស ឬលើផែនដី ។ បទថា **និម្មិតោ** បានដល់ រូបព្រះពុទ្ធដែលនិម្មិតដោយឫទ្ធិ ។ សូម្បីបទថា **តិដ្ឋតិ វា** ជាដើម បានដល់ ប្រថាប់ឈរក្នុងអាកាស ឬលើផែនដី ។ បទថា **កប្បេតិ** បានដល់ ធ្វើ ។ សូម្បីក្នុងបទថា **ភគវា តិដ្ឋតិ** ជាដើម ក៏មានន័យនេះដូចគ្នា ។៚

**អដ្ឋកថាយមកប្បាដិហីរញ្ញាណនិទ្ទេស ចប់**

# សុត្តន្តបិដក

[ ២៨៥ ] មហាករុណាសមាបត្តិញ្ញាណរបស់ព្រះតថាគត តើដូចម្តេច ។ កាលព្រះពុទ្ធមានព្រះភាគទាំងឡាយ ទ្រង់ឃើញដោយអាការច្រើន មហាករុណារមែងចុះស៊ប់ក្នុងពួកសត្វ គឺកាលព្រះពុទ្ធមានព្រះភាគ ទ្រង់ឃើញថា លោកសន្និវាសត្រូវភ្លើងឆេះសព្វហើយ មហាករុណាចុះស៊ប់ក្នុងពួកសត្វ កាលព្រះពុទ្ធមានព្រះភាគ ទ្រង់ឃើញថា លោកសន្និវាស មានសេចក្តីខ្វល់ខ្វាយ ( ជានិច្ច ) ។បេ។ ថាលោកសន្និវាសមានដំណើរទៅ ( ជានិច្ច ) ។បេ។ ព្រះសម្ពុទ្ធមានព្រះភាគ ទ្រង់ឃើញថា លោកសន្និវាសដើរទៅកាន់ផ្លូវខុស មហាករុណាក៏ចុះស៊ប់ក្នុងពួកសត្វ កាលព្រះពុទ្ធមានព្រះភាគ ទ្រង់ឃើញថា សត្វលោកមិនទៀង ត្រូវជរានាំចូលទៅ ( រកសេចក្តីស្លាប់ ) មហាករុណាក៏ចុះស៊ប់ក្នុងពួកសត្វ កាលព្រះពុទ្ធមានព្រះភាគ ទ្រង់ឃើញថា សត្វលោកឥតមានទីពឹង ឥតមានទីផ្អែក មហាករុណាក៏ចុះស៊ប់ក្នុងពួកសត្វ កាលព្រះពុទ្ធមានព្រះភាគទ្រង់ឃើញថា សត្វលោកគ្មានអ្វីជារបស់ខ្លួន ត្រូវលះចោលរបស់ទាំងអស់ហើយទៅ មហាករុណាក៏ចុះស៊ប់ក្នុងពួកសត្វ កាលព្រះពុទ្ធមានព្រះភាគ ទ្រង់ឃើញថា សត្វលោកមានសេចក្តីខ្វះខាត មិនឆ្អែត ជាទាសៈនៃតណ្ហា មហាករុណាក៏ចុះស៊ប់ក្នុងពួកសត្វ កាលព្រះពុទ្ធ ទ្រង់ឃើញថា លោកសន្និវាសឥតទីពឹង ។បេ។ កាលទ្រង់ឃើញថា លោកសន្និវាសឥតទីពួន ។បេ។ ទ្រង់ឃើញថា លោកសន្និវាសឥតទីរឭក ។បេ។ ទ្រង់ឃើញថា លោកសន្និវាសមិនមានវត្ថុជាទីរឭក ។បេ។ ទ្រង់ឃើញថា សត្វលោកកំពុងរវើរវាយ មិនស្ងប់រម្ងាប់ ។បេ។ ទ្រង់ឃើញថា លោកសន្និវាស ប្រកបដោយសរមុត

ហើយដោយសរផ្សេងៗ បុគ្គលដទៃទីមួយក្រៅពីតថាគត នឹងដកសររបស់លោកសន្និវាសនោះមិនមានឡើយ ទ្រង់ឃើញថា លោកសន្និវាសមានងងឹត គឺអវិជ្ជាជាគ្រឿងរារាំង ធ្លាក់ចុះក្នុងទ្រុង គឺកិលេស បុគ្គលដទៃទីមួយជាអ្នកបង្ហាញនូវពន្លឺ ដល់លោកសន្និវាសនោះក្រៅពីតថាគត មិនមានឡើយ ទ្រង់ឃើញថា លោកសន្និវាសលុះក្នុងអំណាចអវិជ្ជា ជាអ្នកងងឹតងងល់ ត្រូវអវិជ្ជារួបរឹត សាំញ៉ាំដូចអំបោះនៃជាងតម្បាញ ស្មុគស្មាញ ដូចអំបោះដែលជាងតម្បាញប្រឡាក់ដោយទឹកបាយ ដូចស្មៅយាប្លង និងស្មៅជំណោកទន្សាយ មិនប្រព្រឹត្តកន្លងនូវអបាយ ទុគ្គតិ វិនិបាត និងសង្សារបានឡើយ ទ្រង់ឃើញថា លោកសន្និវាសជាប់ដោយទោស គឺពិសនៃអវិជ្ជា ប្រកបដោយកំហុស គឺកិលេស ទ្រង់ឃើញថា លោកសន្និវាសត្រូវរាគៈ ទោសៈ មោហៈចាក់ស្រេះហើយ បុគ្គលដទៃទីមួយ ជាអ្នកដោះនូវបណ្តាញ របស់លោកសន្និវាសនោះក្រៅពីតថាគតមិនមានឡើយ ទ្រង់ឃើញថា លោកសន្និវាសស៊ក ចុះក្នុងឃ្នាប គឺតណ្ហា ទ្រង់ឃើញថា លោកសន្និវាស ត្រូវបណ្តាញ គឺតណ្ហារួបរឹត ទ្រង់ឃើញថា លោកសន្និវាស ត្រូវខ្សែតណ្ហាបន្សាត់ទៅហើយ ទ្រង់ឃើញថា លោក-សន្និវាសប្រកបហើយដោយចំណង គឺតណ្ហា ទ្រង់ឃើញថា លោកសន្និវាសត្រាំនៅក្នុងតម្រាំ គឺតណ្ហា ទ្រង់ឃើញថា លោកសន្និវាស ក្តៅដោយកម្តៅ គឺតណ្ហា ទ្រង់ឃើញថា លោកសន្និវាស ក្តៅក្រហាយដោយសេចក្តីក្តៅក្រហាយ គឺតណ្ហា ទ្រង់ឃើញថា លោកសន្និវាស ស៊កចុះក្នុងឃ្នាប គឺទិដ្ឋិ ទ្រង់ឃើញថា លោកសន្និវាស ត្រូវបណ្តាញ គឺទិដ្ឋិរួបរឹតហើយ ទ្រង់ឃើញថា លោក-

សន្និវាស ត្រូវខ្សែទិដ្ឋិបន្សាត់ទៅ ទ្រង់ឃើញថា លោកសន្និវាស ប្រកបដោយគ្រឿងប្រកប គឺទិដ្ឋិ ទ្រង់ឃើញថា លោកសន្និវាស ត្រាំនៅក្នុងតម្រាំ គឺទិដ្ឋិ ទ្រង់ឃើញថា លោកសន្និវាស ក្តៅដោយកម្តៅ គឺទិដ្ឋិ ទ្រង់ឃើញថា លោកសន្និវាស ក្តៅក្រហាយដោយសេចក្តីក្តៅក្រហាយ គឺទិដ្ឋិ ទ្រង់ឃើញថា លោកសន្និវាសប្រកបដោយជាតិជានិច្ច ។បេ។ ទ្រង់ឃើញថា លោកសន្និវាសត្រាំក្នុងជរា ។បេ។ ទ្រង់ឃើញថា លោកសន្និវាសត្រូវព្យាធិគ្របសង្កត់ហើយ ។បេ។ ទ្រង់ឃើញថា លោកសន្និវាសត្រូវមរណៈបៀតបៀន ។បេ។ ទ្រង់ឃើញថា លោកសន្និវាសមានទុក្ខធ្លាក់ត្រូវហើយ ទ្រង់ឃើញថា លោកសន្និវាសត្រូវតណ្ហាទាក់ជាប់ហើយ ទ្រង់ឃើញថា លោកសន្និវាស ស្រោបហើយដោយកំពែង គឺជរា ទ្រង់ឃើញថា លោកសន្និវាសត្រូវអន្ទាក់ គឺមច្ចុរឹតរួត ទ្រង់ឃើញថា លោកសន្និវាសជាប់ដោយចំណងច្រើន គឺចំណងរាគៈ ចំណងទោសៈ ចំណងមោហៈ ចំណងមានះ ចំណងទិដ្ឋិ ចំណងកិលេស ចំណងទុច្ចរិត បុគ្គលដទៃទីមួយ ជាអ្នកស្រាយនូវចំណងរបស់លោកសន្និវាសនោះ ក្រៅពីតថាគតមិនមានឡើយ ទ្រង់ឃើញថា លោកសន្និវាសដើរទៅកាន់ទីចង្អៀតខ្វាំង បុគ្គលដទៃទីមួយ ជាអ្នកបង្ហាញនូវពន្លឺដល់លោកសន្និវាសនោះ ក្រៅពីតថាគតមិនមានឡើយ ទ្រង់ឃើញថា លោកសន្និវាសមានកង្វល់ដោយកង្វល់ច្រើន បុគ្គលដទៃទីមួយ ជាអ្នកកាត់នូវកង្វល់របស់លោកសន្និវាសនោះ ក្រៅពីតថាគតមិនមានឡើយ ។បេ។ ទ្រង់ឃើញថា លោកសន្និវាស ធ្លាក់ចុះក្នុងជ្រោះធំ បុគ្គលដទៃទីមួយ ជាអ្នកស្រង់លោកសន្និវាសនោះឲ្យរួចពីជ្រោះ ក្រៅ

ពីតថាគតមិនមានឡើយ ទ្រង់ឃើញថា លោកសន្និវាសដើរទៅកាន់ផ្លូវលំបាកខ្លាំង បុគ្គលដទៃទីមួយជាអ្នកចម្លងលោកសន្និវាសនោះ ឲ្យឆ្លងផ្លូវលំបាកក្រៅពីតថាគតមិនមានឡើយ ទ្រង់ឃើញថា លោកសន្និវាសដើរទៅក្នុងមហាសង្គ្រាម បុគ្គលដទៃទីមួយជាអ្នកស្រោយលោកសន្និវាសនោះ ឲ្យរួចចាកសង្គ្រាមក្រៅពីតថាគតមិនមានឡើយ ទ្រង់ឃើញថា លោកសន្និវាសវិលវល់នៅក្នុងផ្លូវកម្រខ្លាំង បុគ្គលដទៃទីមួយជាអ្នកស្រង់លោកសន្និវាសនោះ ឲ្យរួចចាកផ្លូវកម្រក្រៅពីតថាគតមិនមានឡើយ ទ្រង់ឃើញថា លោកសន្និវាសលិចចុះក្នុងល្បាប់ជ្រៅ ត្រូវភ្លើង គឺរាគៈ ភ្លើង គឺទោសៈ ភ្លើង គឺមោហៈ និងជាតិ ជរា មរណៈ សោក បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាសៈ ញាំញីហើយ បុគ្គលដទៃទីមួយជាអ្នកលត់ភ្លើងរបស់លោកសន្និវាសនោះ ក្រៅពីតថាគតមិនមានឡើយ ទ្រង់ឃើញថា លោកសន្និវាសអណ្តែតឡើង ឥតមានទីពឹងជានិច្ច មានអាជ្ញាត្រូវហើយ ធ្វើតាមតែអាជ្ញានោះ រមែងលំបាក ទ្រង់ឃើញថា លោកសន្និវាស ជាប់ចំណងវដ្តៈប្រាកដក្នុងទីសម្រាប់សម្លាប់ បុគ្គលដទៃទីមួយជាអ្នកស្រោយចំណងឲ្យដល់លោកសន្និវាសនោះ ក្រៅពីតថាគតមិនមានឡើយ ទ្រង់ឃើញថា លោកសន្និវាសឥតមានទីពំនាក់ ដល់នូវភាពគួរអាណិតក្រៃពេក បុគ្គលដទៃទីមួយ ជាអ្នកជួយស្រោចស្រង់លោកសន្និវាសនោះ ក្រៅពីតថាគតមិនមានឡើយ ។បេ។ ទ្រង់ឃើញថា លោកសន្និវាស ត្រូវសេចក្តីទុក្ខចាក់ដោតហើយ ត្រូវសេចក្តីទុក្ខបៀតបៀនហើយអស់កាលយូរ ទ្រង់ឃើញថា លោកសន្និវាសជាប់ជំពាក់ជានិច្ច ស្រេកឃ្លានជានិច្ច ។បេ។ ទ្រង់ឃើញថា

លោកសន្និវាសខ្វាក់ ឥតមានចក្ខុ ទ្រង់ឃើញថា លោកសន្និវាសមានភ្នែកវិនាស ហើយ ឥតមានអ្នកដឹកដៃ ទ្រង់ឃើញថា លោកសន្និវាសស្ទុះទៅកាន់ផ្លូវខុស ដើរខុសផ្លូវ បុគ្គលដទៃទីមួយជាអ្នកនាំលោកសន្និវាសនោះ ឲ្យដើរទៅកាន់ផ្លូវ ដ៏ប្រសើរ ក្រៅពីតថាគតមិនមានឡើយ ទ្រង់ឃើញថា លោកសន្និវាសស្ទុះ ទៅក្នុងជំនន់ធំ បុគ្គលដទៃទីមួយជាអ្នកស្រង់នូវលោកសន្និវាសនោះ អំពីជំនន់ ក្រៅពីតថាគតមិនមានឡើយ ទ្រង់ឃើញថា លោកសន្និវាស ត្រូវទិដ្ឋិទាំងពីរ រួបរឹត ទ្រង់ឃើញថា លោកសន្និវាសប្រតិបត្តិខុស ព្រោះទុច្ចរិតទាំង ៣ ទ្រង់ ឃើញថា លោកសន្និវាសពេញដោយយោគធម៌ ប្រកបដោយយោគធម៌ទាំង ៤ ទ្រង់ឃើញថា លោកសន្និវាសចាក់ស្រែះហើយដោយគន្ថកិលេសទាំង ៤ ទ្រង់ឃើញថា លោកសន្និវាសប្រកាន់មាំដោយឧបាទានទាំង ៤ ទ្រង់ឃើញ ថា លោកសន្និវាសឡើងកាន់គតិទាំង ៥ ទ្រង់ឃើញថា លោកសន្និវាសរមែង ត្រេកអរដោយកាមគុណទាំង ៥ ទ្រង់ឃើញថា លោកសន្និវាស ត្រូវនីវរណៈ ទាំង ៥ គ្របសង្កត់ហើយ ទ្រង់ឃើញថា លោកសន្និវាស រមែងវិវាទដោយ វិវាទមូលទាំង ៦ ទ្រង់ឃើញថា លោកសន្និវាសរមែងត្រេកអរដោយតណ្ហា- កាយទាំង ៦ ទ្រង់ឃើញថា លោកសន្និវាសត្រូវទិដ្ឋិទាំង ៦ រួបរឹតហើយ ទ្រង់ឃើញថា លោកសន្និវាសត្រាំនៅហើយដោយតម្រាំទាំង ៧ ទ្រង់ឃើញ ថា លោកសន្និវាស ប្រកបហើយដោយសំយោជនៈទាំង ៧ ទ្រង់ឃើញថា លោកសន្និវាស ប៉ោងឡើងហើយដោយមានះទាំង ៧ ទ្រង់ឃើញថា លោក- សន្និវាសវិលវល់តាមលោកធម៌ទាំង ៨ ទ្រង់ឃើញថា លោកសន្និវាសទៀង

ដោយមិច្ឆត្តធម៌ទាំង ៨ ទ្រង់ឃើញថា លោកសន្និវាស រមែងប្រទូស្តដោយទោសសម្រាប់បុរស ៨ ទ្រង់ឃើញថា លោកសន្និវាសចងគំនុំដោយអាឃាតវត្ថុទាំង ៩ ទ្រង់ឃើញថា លោកសន្និវាសប៉ោងឡើងហើយដោយមានះទាំង ៩ ទ្រង់ឃើញថា លោកសន្និវាសរមែងត្រេកអរដោយតណ្ហាមូលកធម៌ ទាំង ៩ ទ្រង់ឃើញថា លោកសន្និវាស រមែងសៅហ្មងដោយកិលេសវត្ថុទាំង ១០ ទ្រង់ឃើញថា លោកសន្និវាសចងគំនុំដោយអាឃាតវត្ថុទាំង ១០ ទ្រង់ឃើញថា លោកសន្និវាស ប្រកបព្រមហើយដោយអកុសលកម្មបថទាំង ១០ ទ្រង់ឃើញថា លោកសន្និវាស ប្រកបដោយសញ្ញោជនៈទាំង ១០ ទ្រង់ឃើញថា លោកសន្និវាសទៀងដោយមិច្ឆត្តធម៌ទាំង ១០ ទ្រង់ឃើញថា លោកសន្និវាសប្រកបហើយដោយមិច្ឆាទិដ្ឋិមានវត្ថុ ១០ ទ្រង់ឃើញថា លោកសន្និវាសប្រកបហើយដោយសក្កាយទិដ្ឋិ មានវត្ថុ ១០ ព្រះពុទ្ធមានព្រះភាគទាំងឡាយ ទ្រង់ឃើញថា លោកសន្និវាសត្រូវបបញ្ចធម៌ គឺតណ្ហាទាំង ១០៨ ឲ្យយឺតយូរហើយ មហាករុណាក៏ចុះស៊ប់ក្នុងពួកសត្វ ព្រះពុទ្ធមានព្រះភាគទាំងឡាយទ្រង់ឃើញថា លោកសន្និវាសត្រូវទិដ្ឋិទាំង ៦២ រួបរឹតហើយ មហាករុណាក៏ចុះស៊ប់ក្នុងពួកសត្វ ព្រះពុទ្ធមានព្រះភាគទាំងឡាយ ទ្រង់ឃើញថា តថាគតឆ្លងរួចហើយ ឯសត្វលោកមិនទាន់ឆ្លងនៅឡើយ តថាគតរួចហើយ ឯសត្វលោកមិនទាន់រួចនៅឡើយ តថាគតហ្វឹកហ្វឺនហើយ ឯសត្វលោកមិនទាន់ហ្វឹកហ្វឺន នៅឡើយ តថាគតស្ងប់ហើយ ឯសត្វលោកមិនទាន់ស្ងប់នៅឡើយ តថាគតសប្បាយចិត្តហើយ ឯសត្វលោកមិនទាន់សប្បាយចិត្តនៅឡើយ តថាគតរលត់កិលេស

ហើយ ឯសត្វលោកមិនទាន់រលត់កិលេសនៅឡើយ តថាគតឆ្លងហើយដើម្បីចម្លង ( សត្វលោក ) តថាគតរួចហើយ ដើម្បីញ៉ាំងសត្វលោកឲ្យរួច តថាគតហ្វឹកហ្វឺនហើយដើម្បីហ្វឹកហ្វឺនសត្វលោក តថាគតស្ងប់រម្ងាប់ហើយ ដើម្បីញ៉ាំងសត្វលោកឲ្យស្ងប់រម្ងាប់ តថាគតសប្បាយចិត្តហើយដើម្បីញ៉ាំងសត្វលោក ឲ្យសប្បាយចិត្ត តថាគតរលត់កិលេសហើយ ដើម្បីញ៉ាំងសត្វលោកឲ្យរលត់កិលេស មហាករុណាក៏ចុះស៊ប់ក្នុងពួកសត្វនេះ ឈ្មោះថា មហាករុណា-សមាបត្តិញ្ញាណរបស់ព្រះតថាគត ។

## អដ្ឋកថា
## មហាករុណាញាណនិទ្ទេស

[ ២៨៥ ] គប្បីជ្រាបវិនិច្ឆ័យ ក្នុងមហាករុណាញាណនិទ្ទេសដូចតទៅនេះ បទថា **ពហុកេហិ អាការេហិ** បានដល់ ដោយប្រការ ៨៩ យ៉ាង ដែលនឹងពោលក្នុងឥឡូវនេះ ។ បទថា **បស្សន្តានំ** បានដល់ ទ្រង់ពិចារណាដោយញាណចក្ខុ និងដោយពុទ្ធចក្ខុ ។ បទថា **ឱក្កមតិ** បានដល់ ទ្រង់ឈមចុះ ទ្រង់ចូលទៅ ។ បទថា **អាទិត្តោ** បានដល់ ដែលភ្លើងឆេះសន្ធោសន្ធៅហើយ ដោយសភាពក្តៅក្រហាយ អំពីការបៀតបៀនដោយទុក្ខលក្ខណៈ គប្បីជ្រាបថា លោកពោលថា **អាទិត្តោ** ដោយអំណាចទុក្ខលក្ខណៈ ព្រោះសង្ខតធម៌ទាំងពួង ត្រូវបៀតបៀនដោយអំណាចទុក្ខលក្ខណៈ ដូចហេតុដែលព្រះមានព្រះភាគត្រាស់ថា របស់ណាមិនទៀង របស់នោះជាទុក្ខ និងព្រោះទុក្ខជាមូលហេតុនៃករុណា ។ តែនឹងពោលថា លោកក្តៅក្រហាយព្រោះរាគៈជាដើមខាងមុខ ។

ម្យ៉ាងទៀត បទថា **អាទិត្តោ** បានដល់ ឆេះហើយដោយរាគៈជាដើមនោះឯង ។ ចំណែកបទខាងមុខថា **តស្ស នត្តញ្ញោ កោចិ និព្វាបេតា** បុគ្គលដទៃណានីមួយ ជាអ្នកលត់ភ្លើងរបស់លោកសន្និវាសនោះ ក្រៅអំពីតថាគត មិនមានឡើយ គប្បីជ្រាបថា លោកពោលទៀតដោយអំណាចការសម្រឹងដល់ទីបំផុត ។

បទថា **លោកសន្និវាសោ** បានដល់ បញ្ចក្ខន្ធ ឈ្មោះថា លោក ដោយ

អត្ថថា បែកធ្លាយ ឈ្មោះថា សន្និវាស ព្រោះអត្ថថា ជាទីអាស្រ័យរបស់សត្វទាំងឡាយដោយអំណាចតណ្ហា និងទិដ្ឋិដែលអាស្រ័យ គឺលោកនោះឯង ឈ្មោះថា លោកសន្និវាស ។ សូម្បីពពួកសត្វ ក៏ឈ្មោះថា លោកសន្និវាស ព្រោះប្រកបការនៅក្នុងលោកដែលមានវោហារថា សត្វ ព្រោះអាស្រ័យខន្ធសន្តានដែលជាទុក្ខ ។ សូម្បីលោកសន្និវាសនោះ ក៏ប្រព្រឹត្តទៅជាមួយខន្ធដូចគ្នា ។

បទថា **ឧយ្យុត្តោ** បានដល់ ធ្វើសេចក្តីព្យាយាម ធ្វើឧស្សាហៈព្រោះខ្វល់ខ្វាយជានិច្ចក្នុងកិច្ចច្រើនយ៉ាង អធិប្បាយថា មានសេចក្តីខ្វល់ខ្វាយក្នុងកិច្ចជានិច្ច ឬលោកសន្និវាសដែលប្រកបដោយសេចក្តីព្យាយាម ក៏ឈ្មោះថា **ឧយ្យុត្តោ** ។

បទថា **បយាតោ** បានដល់ ដំណើរទៅកាន់សេចក្តីស្លាប់ដោយដល់នូវការតាំងនៅមិនបាន ដូចស្ទឹងដែលហូរអំពីភ្នំ ។ បទថា **កុម្មគ្គប្បដិបន្នោ** បានដល់ ដើរផ្លូវខុសដែលគួរវៀរ ។ ចំណែកខាងមុខ លោកពោលផ្សេងគ្នាដោយបទផ្សេងៗ ថា **វិបថបក្ខន្ទោ** ជាដើម ។ បទថា **ឧបនីយតិ** បានដល់ ដែលជរានាំចូលទៅរកមរណៈ ព្រោះលោកពោលជរាថា ដំណើរថយនៃអាយុ ។ បទថា **អទ្ធុវោ** បានដល់ មិនមាំទាំ មិនជាយ៉ាងនោះសព្វកាល ព្រោះមិនស្ថិតស្ថេរ ហេតុនោះ ទើបត្រូវជរានាំទៅបាន ព្រោះហេតុនោះ ទើបបទថា **អទ្ធុវោ** នេះ ជាពាក្យពោលដល់ហេតុរបស់ពាក្យមុន ។ ដោយបទនោះ លោកពោលដល់ជរាទុក្ខ មួយអន្លើដោយហេតុ ។ វិញ្ញូជនទាំងឡាយ កាលឃើញជរាទុក្ខនោះហើយ សូម្បីមិនមានការវិនាសព្រោះជរាក៏ចេញបួស ។

បទថា **អតាណោ** បានដល់ មិនមានវត្ថុដែលអាចជ្រកកោន គឺរក្សាបាន អធិប្បាយថា មិនមានគ្រឿងការពារ ។ បទថា **អនភិស្សរោ** បានដល់ មិនមានអ្នកអាចលួងលោមចិត្ត ព្រោះជាប់អ្នកជួយស្រោចស្រង់ អធិប្បាយថា មិនមានសម្លាញ់ព្រោះមិនជាធំ ហេតុនោះ ទើបមិនមានទីជ្រកកោន ព្រោះហេតុនោះ ទើបបទថា **អនភិស្សរោ** នេះ ជាពាក្យពោលដល់ហេតុរបស់បទមុន ។ ដោយបទនោះ លោកពោលដល់ទុក្ខកើតអំពីការព្រាត់ប្រាសចាករបស់ជាទីស្រឡាញ់ មួយអន្លើដោយហេតុ ។ វិញ្ញូជនទាំងឡាយកាលឃើញទុក្ខកើតអំពីការព្រាត់ប្រាសចាករបស់ដែលជាទីស្រឡាញ់នោះ សូម្បីមិនទាន់មានការវិនាសចាកញាតិ ក៏ចេញបួស ។

បទថា **អស្សកោ** បានដល់ មិនមានវត្ថុជារបស់ខ្លួន ។ បទថា **សព្វំ បហាយ គមនីយំ** បានដល់ សត្វលោកចាំបាច់ត្រូវលះបង់វត្ថុទាំងឡាយដែលកំណត់ថាជាវត្ថុរបស់ខ្លួនហើយទៅ ព្រោះចាំបាច់ត្រូវលះបង់វត្ថុទាំងពួងហើយទៅ ហេតុនោះ ទើបមិនមានអ្វីជារបស់ខ្លួន ព្រោះហេតុនោះ ទើបបទថា **សព្វំ បហាយ គមនីយំ** នេះ ជាពាក្យពោលដល់ហេតុរបស់ពាក្យមុន ។ ដោយពាក្យនោះ លោកពោលដល់មរណទុក្ខ មួយអន្លើដោយហេតុ ។ វិញ្ញូជនទាំងឡាយ កាលឃើញមរណទុក្ខនោះហើយ សូម្បីមិនទាន់មានការវិនាសចាកភោគៈក៏ចេញបួស ។ ក្នុងទីដទៃលោកពោល ( ក្នុងចូឡកម្ម វិភង្គសូត្រ ) ថា ម្នាលមាណព សត្វទាំងឡាយមានកម្មជារបស់ខ្លួន ដូច្នេះ ។ ចំណែកក្នុងទីនេះនិងក្នុងរដ្ឋបាលសូត្រ លោកពោលថា សត្វលោកសុទ្ធតែមិនមានអ្វី ជា

របស់ខ្លួន ដូច្នេះ ។ ប្រសិនបើសួរថា ពាក្យនោះ ត្រឹមត្រូវដូចម្ដេច ឆ្លើយថា លោកពោលថា មិនមានអ្វីជារបស់ខ្លួន សំដៅដល់វត្ថុដែលត្រូវលះបង់ហើយទៅ ។ ចំណែកកម្មជារបស់ដែលលះហើយទៅមិនបាន ព្រោះហេតុនោះ ទើបលោកពោលថា សត្វមានកម្មជារបស់ខ្លួន ។ ម្យ៉ាងវិញទៀត ក្នុងរដ្ឋបាលសូត្រនោះឯង លោកពោលពាក្យនេះ យ៉ាងនេះថា ចំណែកខាងខ្ញុំ នឹងទៅតាមយថាកម្ម ដូច្នេះ ។

បទថា **ឩនោ** បានដល់ មិនពេញ ។ បទថា **អតិត្តោ** បានដល់ មិនពេញចិត្តដោយការប្រាថ្នាក្រៃលែងឡើង ។ បទនេះ ជាបទពោលដល់ហេតុនៃសេចក្ដីខ្វះខាត ។ បទថា **តណ្ហាទាសោ** បានដល់ ជាខ្ញុំនៃតណ្ហា ព្រោះប្រព្រឹត្តទៅក្នុងអំណាចតណ្ហា ។ បទនេះ ជាពាក្យពោលដល់ហេតុនៃការមិនឆ្អែត ។ ដោយបទនេះ លោកពោលដល់ព្យាធិទុក្ខ ព្រមជាមួយនឹងហេតុដោយអាងដល់រោគ គឺចំណង់ ។ វិញ្ញូជនទាំងឡាយ កាលឃើញព្យាធិទុក្ខនោះហើយ សូម្បីមិនទាន់មានសេចក្ដីវិនាសអំពីព្យាធិ ក៏ចេញបួស ។

បទថា **អតាយនោ** បានដល់ មិនមានគ្រឿងជ្រកកោន មិនមានគ្រឿងការពារ ព្រោះមិនមានគ្រឿងជ្រកកោន អំពីបុត្តជាដើម ឬមិនគប្បីបាននូវការផុតភ័យ ។ បទថា **អលេណោ** បានដល់ មិនគួរជាប់ជំពាក់ គឺអាស្រ័យនៅនិងមិនមានអ្នកធ្វើកិច្ច គឺការពួនសង្ងំដល់បុគ្គលដែលជាប់ជំពាក់ ។ បទថា **អសរណោ** បានដល់ មិននាំភ័យរបស់អ្នកដែលអាស្រ័យនៅចេញទៅ គឺមិនធ្វើឲ្យអស់ភ័យ ។ បទថា **អសរណីភូតោ** បានដល់ ឈ្មោះថា **អសរណោ**

ព្រោះមិនជារបស់ខ្លួនខាងមុខអំពីកើតមក អធិប្បាយថា មិនមានបុគ្គលណាជាទីពឹង តាំងអំពីកើតមក ។ បទថា **ឧទ្ធតោ** បានដល់ លោកដែលស្អេកស្កះដោយអកុសល ព្រោះកើតការរេរីរវាយ ក្នុងអកុសលទាំងពួង និងព្រោះច្រើនទៅដោយការកើតឡើងនៃអកុសលក្នុងសន្តានសត្វ ឈ្មោះថា រេរីរវាយដោយការរេរីរវាយនោះ ។

បទថា **អវូបសន្តោ** បានដល់ មិនស្ងប់ ព្រោះប្រកបដោយឧទ្ធច្ចៈដែលមានលក្ខណៈមិនស្ងប់នោះឯងប្រៀបដូចម្រឹគផ្អើល ។ បទថា **លោកោ** មកហើយក្នុងទី ៥ កន្លែង គឺមកហើយក្នុងទី ៤ កន្លែង មាន **ឧបនីយតិ លោកោ** ជាដើម និងក្នុងទីមួយកន្លែងថា **ឧទ្ធតោ លោកោ** ឯបទថា **លោកសន្និវាសោ** មកហើយក្នុងបទដ៏សេស ។ សូម្បីក្នុងបទទាំងពីរនោះក៏ជាលោកដូចគ្នា ។

បទថា **សសល្លោ** បានដល់ ប្រព្រឹត្តទៅជាមួយនឹងកូនសរ មានរាគៈជាដើម ដែលឈ្មោះថា កូនសរព្រោះឲ្យកើតសេចក្តីបៀតបៀន ព្រោះទម្លុះចូលទៅក្នុងខាងក្នុង និងព្រោះនាំចេញបានលំបាក ។ បទថា **វិទ្ធោ** បានដល់ ម្រឹគជាដើម កាលខ្លះត្រូវអ្នកដទៃចាក់ តែលោក គឺពួកសត្វនេះ ខ្លួនឯងប៉ុណ្ណោះត្រូវខ្លួនឯងនោះឯងចាក់សព្វកាល ។ បទថា **បុថុសល្លេហិ** បានដល់ ត្រូវកូនសរ ៧ ដែលលោកពោលថា កូនសរ ៧ គឺសរ គឺរាគៈ ១ សរ គឺទោសៈ ១ សរគឺមោហៈ ១ សរ គឺមានះ ១ សរ គឺទិដ្ឋិ ១ សរ គឺកិលេស ១ សរ គឺទុច្ចរិត ១ ។ បទថា **តស្ស** បានដល់ របស់លោកសន្និវាសនោះ ។ បទថា **សល្លានំ ឧទ្ធតា** បានដល់ បុគ្គលដែលនឹងដកកូនសរទាំងនោះ ចាកសន្តាន

សត្ថុ ។ បទថា **អញ្ញាត្រ មយា** បានដល់ វៀរតថាគត ។ សាវកទាំងឡាយណារបស់ព្រះមានព្រះភាគដកកូនសរបាន ព្រះមានព្រះភាគប៉ុណ្ណោះ ឈ្មោះថា ដកបាន ព្រោះសាវកទាំងនោះ ដកបានតាមពាក្យទូន្មានរបស់ព្រះមានព្រះភាគនោះឯង ។

បទថា **អវិជ្ជន្ធការាវរណោ** មានវិគ្គហៈថា អវិជ្ជានោះឯង រមែងធ្វើនូវងងឹត ដោយបិទបាំងនូវការឃើញសភាវធម៌ ព្រោះហេតុនោះ ទើបឈ្មោះថា **អវិជ្ជន្ធការ** ការងងឹត គឺអវិជ្ជានោះឯង ជាគ្រឿងបិទបាំងនូវលោកសន្និវាសនោះ ដោយឃាត់ការឈមចុះកាន់សភាវធម៌ ព្រោះហេតុនោះ ទើបឈ្មោះថា **អវិជ្ជន្ធការាវរណោ** ។

បទថា **កិលេសបញ្ជរបក្ខិត្តោ** បានដល់ ឈ្មោះថា ទ្រុង គឺកិលេស ព្រោះអត្ថថា កិលេសនោះឯងជាទ្រុង ដោយបិទការចូលដល់កុសល ត្រូវដាក់ គឺឲ្យធ្លាក់ទៅក្នុងទ្រុងកិលេសដែលមានអវិជ្ជា ជាដែនកើត ។ បទថា **អាលោកំ ធារេស្សតា** បានដល់ មានប្រក្រតីបង្ហាញនូវពន្លឺ គឺបញ្ញា ម្យ៉ាងទៀត អធិប្បាយថា បង្ហាញពន្លឺ គឺបញ្ញា ។ បទថា **អវិជ្ជាគតោ** បានដល់ ចូលទៅកាន់អវិជ្ជា មិនមែនត្រឹមតែត្រូវអវិជ្ជាបិទបាំងតែម្យ៉ាង ដែលពិតចូលទៅខាងក្នុងចំណែករបស់អវិជ្ជាដូចទៅក្នុងទីស្អុក ព្រោះហេតុនោះ ទើបប្លែកអំពីពាក្យមុន ។ បទថា **អណ្ឌភូតោ** មានសេចក្តីផ្សេងគ្នា ។ បទថា **អណ្ឌភូតា** បានដល់ កើត គឺកើតឡើងក្នុងស៊ុត ។ សត្វពួកខ្លះកើតក្នុងស៊ុត លោកហៅថា **អណ្ឌភូតា** យ៉ាងណា ក្នុងលោកនេះ លោកហៅថា **អណ្ឌភូតោ** ព្រោះកើតក្នុងស៊ុត គឺ

អវិជ្ជា ។

បទថា **បរិយោនទ្ធោ** បានដល់ ត្រូវសម្បុកស៊ុត គឺអវិជ្ជានោះហ៊ុមព័ទ្ធដោយជុំវិញ ។ បទថា **តន្តាកុលជាតោ** បានដល់ ជាលោកដែលស្មុគស្មាញដូចសរសៃអំបោះ ។ សរសៃអំបោះរបស់ជាងតម្បាញ រក្សាទុកមិនល្អ ត្រូវកណ្ដុរកាត់ រមែងស្មុគស្មាញក្នុងទីនោះៗ ជាការលំបាកដែលនឹងពាល់ត្រូវនូវចុងដោយចុង ឬនូវដើមដោយដើមថា នេះជាចុង នេះជាដើមយ៉ាងណា សត្វទាំងឡាយក៏យ៉ាងនោះ ជាអ្នកក្លាំងក្លាត់ក្នុងបច្ចយាការហើយ រមែងស្មុគស្មាញចំពាក់ចំពិន មិនអាចធ្វើបច្ចយាការឲ្យត្រង់បាន ។ ក្នុងសេចក្ដីនោះ សត្វដែលតាំងនៅក្នុងកិច្ចដែលបុរសធ្វើបានចំពោះខ្លួនហើយ អាចធ្វើសរសៃអំបោះ ឲ្យរលាត្រង់បាន តែសត្វដទៃ វៀរព្រះពោធិសត្វ ២ ពួក[១] ឈ្មោះថា អាចធ្វើបច្ចយាការឲ្យត្រង់បាន ដោយធម្មតារបស់ខ្លួន រមែងមិនមាន ។ម្យ៉ាងទៀត សរសៃអំបោះដែលស្មុគស្មាញ ត្រូវជាងតម្បាញយកទៅជ្រលក់បាយម៉ាន ហើយជុសដោយច្រាស់ក៏ជាប់គ្នា នឹងចាក់ស្រែះគ្នា ជាកំណួចក្នុងទីនោះៗ យ៉ាងណា ក្នុងលោកនេះក៏យ៉ាងនោះ កាលក្លាំងក្លាត់ក្នុងបច្ច័យទាំងឡាយ មានអវិជ្ជាជាដើម មិនអាចធ្វើបច្ច័យទាំងឡាយឲ្យត្រង់បាន រមែងជាប់គ្នា និងចាក់ស្រែះគ្នាជាកំណួចដោយអំណាចទិដ្ឋិ ៦២ ។ សត្វពួកខ្លះទាំងឡាយណា អាស្រ័យទិដ្ឋិទាំងឡាយ សត្វទាំងអស់នោះ មិនអាចធ្វើបច្ច័យឲ្យត្រង់បាន ។

---

១- បច្ចេកពោធិសត្វ និងមហាពោធិសត្វ ។

បទថា **កុលាគណ្ឋិកជាតោ** បានដល់ ជាក្រុម ជាដុំដោយជ្រលក់បាយម៉ានរបស់ជាងតម្បាញ លោកហៅថា ជាក្រុម ជាដុំ ។ អាចារ្យពួកមួយពោលថា សម្បុកសត្វ ឈ្មោះថា **កុលា** បានដល់ សម្បុករបស់សត្វនោះ ។ ស្មុគស្មាញដូចរបស់ទាំងពីរយ៉ាង គប្បីប្រកបដោយន័យមុននោះឯងថាជាការលំបាកដែលនឹងពាល់ត្រូវនូវចុងដោយចុង ឬនូវដើមដោយដើម ។

បទថា **មុញ្ជបព្វជភូតោ** បានដល់ ដូចជាស្មៅយាប្លង និងស្មៅជំណោកទន្សាយ គឺកើតដូចជាស្មៅយាប្លង និងស្មៅជំណោកទន្សាយ ។ ខ្សែដែលគេវាយស្មៅទាំងនោះ ធ្វើឡើងជាការលំបាកដែលនឹងយកខ្សែដែលធ្លាក់ទៅក្នុងទីខ្លះ ក្នុងវេលាចាស់ហើយមកចាប់ពាល់នូវចុងដោយចុង ឬនូវដើមដោយដើមនៃស្មៅទាំងនោះថា នេះជាចុង នេះជាដើម បុគ្គលដែលតាំងនៅក្នុងកិច្ចដែលបុរសធ្វើបានចំពោះខ្លួនហើយ អាចធ្វើចុង និងដើមឲ្យរលោចេញត្រង់បាន ។ តែសត្វដទៃវៀរព្រះពោធិសត្វ ២ ពួក ឈ្មោះថា អាចធ្វើបច្ចយាការឲ្យត្រង់បានដោយធម្មតារបស់ខ្លួន រមែងមិនមានយ៉ាងណា លោកនេះក៏យ៉ាងនោះ មិនអាចធ្វើបច្ចយាការឲ្យត្រង់បាន កើតជាកំណួចដោយអំណាចទិដ្ឋិ ៦២ រមែងមិនផុតអបាយ ទុគ្គតិ វិនិបាត សង្សារទៅបាន ។ ក្នុងបទទាំងនោះ បទថា **អបាយោ** បានដល់ នរក កំណើតតិរច្ឆាន បិត្តិវិស័យ អសុរកាយ ។ ទាំងអស់នោះលោកហៅថា អបាយ ព្រោះមិនមានសេចក្តីចម្រើន គឺបញ្ញា ។ ឈ្មោះថា **ទុគ្គតិ** ព្រោះជាផ្លូវទៅរបស់ទុក្ខ ។ ឈ្មោះថា **វិនិបាតោ** ព្រោះធ្លាក់ទៅចាកការប្រជុំរួមគ្នានៃសុខ ។ ចំណែកក្រៅអំពីនេះ គឺ

លំដាប់នៃខន្ធ ធាតុ អាយតនៈ ដែលប្រព្រឹត្តទៅមិនដាច់ខ្សែ លោកហៅថា សង្សារ ។

លោកសន្និវាសរមែងមិនប្រព្រឹត្តទៅកន្លង គឺមិនកន្លងអបាយជាដើមទាំងអស់នោះដែលពិត កាលនៅចុតិ និងបដិសន្ធិរឿយៗ យ៉ាងនេះ គឺចាកចុតិកាន់យកបដិសន្ធិ ចាកបដិសន្ធិកាន់យកចុតិ រមែងវិលវល់ក្នុងភព ៣ ក្នុងកំណើត ៤ ក្នុងគតិ ៥ ក្នុងវិញ្ញាណដ្ឋិតិ ៧ ក្នុងសត្តាវាស ៩ ដូចទូកត្រូវខ្យល់ផាត់ទៅក្នុងមហាសមុទ្រ និងដូចគោដែលត្រូវទឹមដោយយន្ត ( ឈើវិល ) ដូច្នោះ ។

បទថា **អវិជ្ជាវិសទោសសល្លិត្តោ** មានវិគ្គហៈថា អវិជ្ជា ឈ្មោះថា ជាពិស ព្រោះធ្វើជីវិតដែលជាកុសលឲ្យវិនាស ទៅដោយការកើតនៃអកុសល ព្រោះហេតុនោះ ទើបឈ្មោះថា ពិស គឺអវិជ្ជា ។ ពិស គឺអវិជ្ជានោះឯង ឈ្មោះថា **អវិជ្ជាវិសទោសោ** ព្រោះប្រទូស្តសន្តាន លោកសន្និវាសត្រូវពិស គឺអវិជ្ជាដែលជាទោសនោះ ដែលជាអនុសយក្កិលេស បរិយុដ្ឋានក្កិលេស និងទុច្ចរិតបូកលាប ប្រឡាក់ប្រឡូសយ៉ាងខ្លាំង ព្រោះហេតុនោះ ទើបឈ្មោះថា **អវិជ្ជាវិសទោសសល្លិត្តោ** ។

បទថា **កិលេសកលលីភូតោ** មានវិគ្គហៈថា កិលេស មានអវិជ្ជាជាដើមជាមូលនោះឯង ឈ្មោះថា ជាភក់ ជាល្បាប់ ដោយអត្ថថា លិចចុះ ព្រោះហេតុនោះ ទើបឈ្មោះថា កិលេសជាភក់ កិលេសជាភក់នោះ មានដល់លោកសន្និវាសនេះ ព្រោះហេតុនោះ ទើបឈ្មោះថា កិលេសជាភក់ គឺមានសភាពយ៉ាងនោះ ។ បទថា **រាគទោសមោហជដាជដិតោ** បានដល់ រាគៈ ទោសៈ

មោហៈ ពោល គឺលោភៈ បដិឃៈ និងអវិជ្ជា ឈ្មោះថា ព្រៃស្អុក ព្រោះដូចព្រៃស្អុក ពោល គឺបណ្តាញមែកនៃគុម្ពឫស្សីជាដើម ដោយសភាពដែលចាក់ស្រេះគ្នា ព្រោះកើតឡើងក្នុងអារម្មណ៍ មានរូបជាដើមរឿយៗ ខ្ពស់ៗ ទាបៗ ព្រៃស្អុកដោយអត្ថ គឺរាគៈ ទោសៈ និងមោហៈនោះ អធិប្បាយថា លោកនេះ ត្រូវព្រៃស្អុកនោះធ្វើឲ្យស្អុក គឺចងរួបរឹតដូចឫស្សីជាដើម ត្រូវបន្ទារបស់ឫស្សីជាដើមធ្វើឲ្យស្អុក ដូច្នោះ ។

បទថា **ជដំ វិជដេតា** បានដល់ ក្តារ កាត់ ទម្លាយព្រៃស្អុកនេះ ដែលធ្វើលោកដែលមានត្រៃធាតុឲ្យស្អុក ហើយតាំងនៅយ៉ាងនេះបាន ។ បទថា **តណ្ហាសង្ឃាដប្បដិមុក្កោ** មានវិគ្គហៈថា ឈ្មោះថា ឃ្នាបតណ្ហា ព្រោះអត្ថថា តណ្ហានោះឯងជាឃ្នាប ដោយអត្ថថា ផ្សារភ្ជាប់ដោយល្អព្រោះប្រព្រឹត្តទៅមិនដាច់ខ្សែ ឈ្មោះថា ត្រូវតណ្ហាគាប ព្រោះអត្ថថា គាបចូលទៅនៅខាងក្នុង ក្នុងឃ្នាបតណ្ហានោះ ។ បទថា **តណ្ហាជាលេន ឱត្ថដោ** មានវិគ្គហៈថា ឈ្មោះថា **តណ្ហាជាល** ព្រោះអត្ថថា តណ្ហានោះឯងជាសំណាញ់ដោយសភាពរួបរឹត តាមន័យដូចពោលហើយខាងដើម លោកសន្និវាសត្រូវសំណាញ់ គឺតណ្ហានោះគ្រប គឺបិទរឹតរុំដោយជុំវិញ ។

បទថា **តណ្ហាសោតេន វុយ្ហតិ** មានវិគ្គហៈថា ឈ្មោះថា **តណ្ហាសោត** ព្រោះអត្ថថា តណ្ហានោះឯង ជាក្រសែ ដោយអត្ថថា ប្រាទទៅក្នុងសង្សារ លោកសន្និវាសត្រូវក្រសែតណ្ហានោះបន្សាត់ទៅ គឺប្រាទទៅ ។ បទថា **តណ្ហា-សញ្ញោជនេន សញ្ញុត្តោ** មានវិគ្គហៈថា ឈ្មោះថា **តណ្ហាសញ្ញោជន** ព្រោះ

អត្ថថា តណ្ហានោះឯងជាចំណងព្រោះចង គឺចងសត្វលោកទុកក្នុងវដ្តៈ លោកសន្និវាសត្រូវតណ្ហាជាគ្រឿងចងនោះស្រែះ គឺចងទុក ។ បទថា **តណ្ហានុសយេន អនុសដោ** មានវិគ្គហៈថា ឈ្មោះថា **តណ្ហានុសយ** ព្រោះអត្ថថា តណ្ហានោះឯងជាអនុស័យ ដោយអត្ថថា ដេកត្រាំក្នុងសន្តាន លោកសន្និវាសផ្សាយទៅ តាមទៅ មានកម្លាំងដោយតណ្ហានុស័យនោះ ។

បទថា **តណ្ហាសន្តាបេន សន្តប្បតិ** មានវិគ្គហៈថា ឈ្មោះថា **សន្តាប** ព្រោះអត្ថថា តណ្ហានោះឯងញុំាងលោកឲ្យក្តៅក្នុងកាលប្រព្រឹត្តទៅ និងក្នុងកាលឲ្យផល លោកសន្និវាស ក្តៅក្រហាយដោយការក្តៅក្រហាយព្រោះតណ្ហានោះ គឺក្តៅក្រហាយ ព្រោះតណ្ហានោះធ្វើឲ្យក្តៅក្រហាយ ។

បទថា **តណ្ហាបរិឡាហេន បរិឌយ្ហតិ** មានវិគ្គហៈថា ឈ្មោះថា **តណ្ហាបរិឡាហ** ព្រោះអត្ថថា តណ្ហាដែលមានកម្លាំងច្រើននោះឯងជាការក្តៅក្រហាយច្រើន ដោយអត្ថថា ការក្តៅក្រហាយដោយជុំវិញក្នុងកាលប្រព្រឹត្តទៅ និងក្នុងកាលឲ្យផល លោកសន្និវាស រមែងក្តៅក្រហាយដោយការក្តៅក្រហាយ ព្រោះតណ្ហានោះ គឺត្រូវការក្តៅក្រហាយព្រោះតណ្ហានេះ ធ្វើឲ្យក្តៅក្រហាយដោយជុំវិញ ។ គប្បីប្រកបបទថា **ឱឌ្ឌិសង្ឃាដ** ជាដើម ដោយន័យនេះ ។ បទថា **អនុគតោ** បានដល់ ចូលទៅតាម ។ បទថា **អនុសដោ** បានដល់ ស្ទុះទៅតាម ។ បទថា **អភិភូតោ** បានដល់ ត្រូវបៀតបៀន ។ បទថា **អភិហតោ** បានដល់ ត្រូវកម្ចាត់ ត្រូវទម្លាយយ៉ាងធ្ងន់ចំពោះមុខ ។ បទថា **ទុក្ខេ បតិ-ដ្ឋិតោ** បានដល់ តាំងនៅ គឺប្រកាន់មាំខន្ធបញ្ចកៈដែលជាទុក្ខ ដោយយល់ខុសថា

ជាសុខ ។

បទថា **តណ្ហាយ ឧឌ្ឌិតោ** បានដល់ ត្រូវតណ្ហាថ្កក់ឡើង ដ្បិតថា ចក្ខុត្រូវដោតក្រងដោយខ្សែ គឺតណ្ហាហើយ ពាក់ត្រង់ដែកគោល គឺរូប ត្រចៀកជាដើមត្រូវដោតក្រងដោយដោយខ្សែ គឺតណ្ហា ហើយពាក់ត្រង់ដែកគោល គឺសំឡេងជាដើម ។ លោកដែលដល់ព្រមដោយតណ្ហានោះ ក៏ឈ្មោះថា ត្រូវថ្កក់ដូចគ្នា ។

បទថា **ជរាបាការបរិក្ខិត្តោ** បានដល់ ត្រូវជរាដែលជាកំពែង ដោយអត្ថថា ឆ្លងទៅមិនបាន ព័ទ្ធទុក ។ បទថា **មច្ចុនាសេន បរិក្ខិត្តោ** បានដល់ត្រូវមរណៈដែលជាអន្ទាក់ ដោយអត្ថថា ស្រាយបានលំបាក ចងទុក ។ បទថា **មហាពន្ធនពទ្ធោ** បានដល់ ត្រូវចងដោយចំណងធំព្រោះជាប់មាំល្អ និងព្រោះកាត់បានដោយក្រ ។ បទថា **រាគពន្ធនេន** មានវិគ្គហៈថា ឈ្មោះថា **រាគ-ពន្ធន** ព្រោះអត្ថថា រាគៈនោះឯងចងមិនឲ្យរបូតចាកសង្សារបាន ។ ដោយគ្រឿងចង គឺរាគៈនោះ ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។ បទថា **កិលេសពន្ធនេន** បានដល់ ចំណង គឺកិលេសដែលសល់អំពីបទដែលបានពោលហើយ ។ បទថា **ទុច្ចរិតពន្ធនេន** បានដល់ ចំណង គឺទុច្ចរិត ៣ ។ ចំណែកសុចរិតជាហេតុឲ្យផុតចាកចំណង និងជាការផុតចាកចំណងមានព្រោះហេតុនោះ មិនគួរកាន់យកទុច្ចរិតនោះ ។

បទថា **ពន្ធនំ មោចេតា** បានដល់ ដែលមិនជួយស្រាយចំណងឲ្យដល់លោកសន្និវាសនោះ ។ បាឋៈថា **ពន្ធនា មោចេតា** ក៏មាន សេចក្តីថា ស្រាយលោកសន្និវាសនោះ ចាកចំណង ។ បទថា **មហាសម្ពាធប្បដិបន្នោ** បាន

ដល់ ដើរទៅកាន់ទីស្តុក គឺរាគៈ ទោសៈ មោហៈ មានះ ទិដ្ឋិ កិលេស និង ទុច្ចរិត ពោលគឺទីចង្អៀតដ៏ក្រៃលែងដោយការបៀតបៀនដំណើររបស់កុសល ។ បទថា **ឱកាសំ ឧបេន្តា** បានដល់ សម្តែងឱកាស គឺសមាធិ និងបញ្ញាដែល ជាលោកិយ និងលោកុត្តរ ។ បទថា **មហាបលិពោធេន** បលិពុទ្ធោ បាន ដល់ ត្រូវគ្រឿងរាំងធំបិទបាំង ឬត្រូវបូកលាបទុកដោយគ្រឿងបូកលាប ធំ ។ ម្យ៉ាងទៀត បទថា **បលិពោធោ** គឺកង្វល់ ៧ យ៉ាង មានរាគៈជាដើម ។ អាចារ្យខ្លះពោលថា កង្វល់ គឺតណ្ហា និងទិដ្ឋិ ។ បទថា **បលិពោធំ ធេទេតា** បានដល់ ដែលកាត់កង្វល់នោះ ។ បទថា **មហាបធាតេ** បានដល់ ក្នុងជ្រោះ គឺគតិ ៥ ឬក្នុងជ្រោះ គឺជាតិ ជរា និងមរណៈ ។ ទាំងអស់នោះឈ្មោះថា **បធាត** ព្រោះអត្ថថា ឡើងបានដោយក្រ ។ បទថា **បធាតា ឧទ្ធតា** បានដល់ ដែលជួយទាញឡើងផុតចាកជ្រោះនោះ ។ បទថា **មហាកន្តារប្បដិបន្នោ** បាន ដល់ ដើរផ្លូវកន្តារ គឺជាតិ ជរា ព្យាធិ មរណៈ សោក បរិទេវៈ ទុក្ខ ទោម- នស្ស និងឧបាយាសៈ ។ ទាំងអស់នោះឈ្មោះថា កន្តារ ដោយអត្ថថា ឈាន កន្លងឲ្យផុតទៅបានដោយក្រ ។ ដែលនឹងជួយឲ្យឆ្លងផុតផ្លូវកន្តារនោះ ។ បាឋៈ ថា **កន្តារា តារេតា** ក៏មាន ។

បទថា **មហាសំសារប្បដិបន្នោ** បានដល់ ដើរទៅកាន់ខន្ធសន្តាន ដែល មិនទាន់ដាច់ខ្សែ ។ បទថា **សំសារា មោចេតា** បានដល់ ជួយឲ្យផុតចាក សង្សារវដ្ត ។ បាឋៈថា **សំសារំ មោចេតា** ក៏មាន ។ បទថា **មហាវិទុគ្គេ** បានដល់ ក្នុងផ្លូវកម្រខ្លាំង គឺសង្សារវដ្ត ។ សង្សារវដ្តនោះឯង ឈ្មោះថា ផ្លូវ

កម្រខ្វាំង ដោយអត្ថថា ទៅបានលំបាក ។ បទថា **សម្បរិវត្តតិ** បានដល់ ត្រឡប់ទៅមកយ៉ាងលំបាក ។ បទថា **មហាបល្លេបេ** បានដល់ ក្នុងភក់ធំ គឺកាម ។ កាម ឈ្មោះថា ភក់ ព្រោះអត្ថថា លិចចុះ ។ បទថា **បលិបន្នោ** បានដល់ ជាប់ ។ បាឋៈថា **មហាបលិបបលិបន្នោ** ( ជាប់ក្នុងភក់ធំ ) ក៏មាន ។ បទថា **អត្តាហាតោ** បានដល់ ត្រូវអន្តរាយទាំងពួង គ្របសង្កត់ ។ បទថា **រាគគ្គិនា** បានដល់ រាគៈជាដើមនោះឯង ឈ្មោះថា ភ្លើង ដោយអត្ថថា តាមដុត ។ ដោយភ្លើង គឺរាគៈនោះ ។ សូម្បីក្នុងបទដ៏សេសក៏មានន័យនេះដូចគ្នា ។

បទថា **ឧឡីតកោ** បានដល់ ត្រូវចាប់នាំទៅ អធិប្បាយថា ត្រូវជាតិចាប់ហើយនាំទៅដើម្បីអន្តរាយ មានជរាជាដើម ។ គប្បីឃើញថា **ក** អក្ខរៈ ក្នុងបទនេះជាការបន្ថែមសេចក្តី ។ បទថា **ហញ្ញតិ និច្ចមតាណោ** បានដល់ មិនមានអ្នកទីពឹង ត្រូវបៀតបៀនជានិច្ច ។ បទថា **បត្តទណ្ឌោ** បានដល់ បានទទួលអាជ្ញាពីព្រះរាជាជាដើម ។ បទថា **តក្ករោ** បានដល់ ចោរ ។ បទថា **វជ្ជពន្ធនពទ្ធោ** បានដល់ ត្រូវចងដោយចំណងដែលមានទោស មានរាគៈជាដើម ។ បទថា **អាឃាតនបច្ចុបដ្ឋិតោ** បានដល់ ចូលទៅប្រាកដត្រង់កំណួចគឺមរណៈ ។ បទថា **កោចិ ពន្ធនា មោចេតា** ( សេចក្តីថា ) បុគ្គលដទៃនីមួយជាអ្នកស្រាយចំណងឲ្យ ។ បាឋៈថា **កោចិ ពន្ធនំ មោចេតា** ក៏មាន ។ បទថា **អនាថោ** មានវិគ្គហៈថា ឈ្មោះថា **អនាថ** ព្រោះអត្ថថា ដែលជាធំដែលជាទីពឹងមិនមាន ឬមិនជាធំ មិនជាទីពឹងដោយខ្លួនឯង ឬអធិប្បាយថា មិន

មានសរណៈ ។ បទថា **បរមការុញ្ញប្បត្តោ** បានដល់ ដល់នូវភាពគួរករុណាក្រៃលែង ព្រោះមិនត្រឹមល្មមក្នុងការហាមជរាជាដើម ។ បទថា **តាយេតា** បានដល់ អ្នករក្សា ។ បាឋៈថា **តាយិតា** ( អ្នកការពារ ) ល្អជាង ។

បទថា **ទុក្ខាភិតុន្នោ** បានដល់ ត្រូវទុក្ខមិនតិច មានជាតិទុក្ខជាដើមចាក់ដោតបៀតបៀន ធ្វើឲ្យញាប់ញ័រក្រៃលែង ។ បទថា **ចិររត្តំ បីឡិតោ** បានដល់ ត្រូវទុក្ខបៀតបៀន ខ្លាំងខ្ទប់មកអស់កាលយូរ ។ បទថា **គធិតោ** បានដល់ ប្រាថ្នាដោយការជាប់ចិត្ត ឬត្រូវចងដោយចំណង គឺអភិជ្ឈាកាយគន្ថៈ ។ បទថា **តិច្ចំ បិចាសិតោ** បានដល់ ស្រេកឃ្លានដើម្បីនឹងផឹក ដើម្បីនឹងបរិភោគ សេចក្ដីស្រេក គឺតណ្ហានោះឯង ។ សេចក្ដីស្រេកមិនមានចន្លោះ ឈ្មោះថា សេចក្ដីស្រេក គឺតណ្ហា ។

បទថា **អន្ធោ** បានដល់ ខ្វាក់ ព្រោះមិនមានបញ្ញាដែលបាន ឈ្មោះថា ចក្ខុ ដោយអត្ថថា ឃើញ ។ ដ្បិតថា បញ្ញារមែងឃើញសភាវធម៌ ។ បទថា **អចក្ខុកោ** បានដល់ ភាពជាអ្នកខ្វាក់នោះ មិនមែនកើតខាងក្រោយភាពជាអ្នកខ្វាក់នោះឯង រមែងពិសេសថាជាអ្នកមិនមានភ្នែកតាមប្រក្រតីនោះឯង ។

បទថា **ហតនេត្តោ** បានដល់ មានភ្នែកវិនាសទៅ ព្រោះមិនមានបញ្ញាដែលហៅថា នេត្រ ដោយអត្ថថា នាំទៅ ។ លោកហៅថា នេត្រ ព្រោះអត្ថថា ឲ្យឃើញទីស្មើ និងមិនស្មើ នាំអត្តភាពទៅ ។ នាំទៅកាន់ផ្លូវល្អ និងដែលមិនមានការទៅ ( និព្វាន ) ដោយបញ្ញា ។ ព្រះសារីបុត្ត កាលនឹងសម្ដែងដល់ការមិនមានអ្នកនាំទៅ របស់លោកសន្និវាសនោះ ព្រោះភ្នែកវិនាស ទើប

ពោលថា **អបរិណាយកោ** អធិប្បាយថា មិនមាននេត្រា ។ មានពាក្យ អធិប្បាយថា មិនមានអ្នកដទៃនាំលោកសន្និវាសនោះទៅបាន ។

បទថា **វិបថបក្ខន្ទោ** បានដល់ ឈ្មោះថា ផ្លូវខុស ព្រោះផ្លូវខុសប្រក្រតី ឬផ្លូវមិនរាបស្មើ ។ ឈ្មោះថា ស្ទុះទៅកាន់ផ្លូវខុស ព្រោះអត្ថថា ស្ទុះចូលទៅ គឺដើរទៅកាន់ផ្លូវខុសនោះ ។ អធិប្បាយថា ដើរទៅកាន់មិច្ឆាទិដ្ឋិ គឺផ្លូវខុស ។ បទថា **អញ្ញសាបរន្នោ** បានដល់ វង្វេង គឺភ្លាត់ក្នុងផ្លូវត្រង់ គឺផ្លូវត្រង់ដែលបានដល់មជ្ឈិមប្បដិបទា ។ បទថា **អរិយបថំ អានេតា** បានដល់ នាំចូលទៅឲ្យដល់អដ្ឋង្គិកមគ្គដ៏ប្រសើរ ។ បទថា **មហោឃបក្ខន្ទោ** មានវិគ្គហៈថា ឈ្មោះថា ឱឃៈ ព្រោះអត្ថថា ញុំាងសត្វដែលមានកិលេសឲ្យលិចចុះក្នុងវដ្តៈ ។ ឈ្មោះថា មហោឃៈ ព្រោះអត្ថថា ជាឱឃៈធំជាងឱឃៈប្រក្រតី ។ ឱឃៈទាំងនោះមាន ៤ យ៉ាង គឺកាមោឃៈ ១ ភវោឃៈ ១ ទិដ្ឋោឃៈ ១ អវិជ្ជោឃៈ ១ ។ ឈ្មោះថា **មហោឃបក្ខន្ទោ** ព្រោះអត្ថថា ស្ទុះចូលទៅកាន់ឱឃៈធំទាំងនោះ ឬថា ស្ទុះទៅកាន់ឱឃៈធំ គឺសង្សារវដ្ត ។

ឥឡូវនេះ គប្បីជ្រាបន័យដែលមានច្រើនជាង ១ ន័យ ។ ក្នុងបទទាំងនោះ បទថា **ទ្វីហិ ទិដ្ឋិគតេហិ** បានដល់ សស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិ ។

ក្នុងបទនោះ ទិដ្ឋិគតៈ គឺទិដ្ឋិនោះឯង ដូចប្រយោគជាដើមថា **គូថគតំ មុត្តគតំ** លាមកមូត្រ ។ម្យ៉ាងវិញទៀត ឈ្មោះថា **ទិដ្ឋិគតំ** ព្រោះអត្ថថា ត្រឹមតែទៅដោយទិដ្ឋិ ព្រោះមិនមានវត្ថុដទៃដែលគួរទៅ ឬព្រោះអត្ថថា ការឃើញនេះ ប្រព្រឹត្តទៅក្នុងទិដ្ឋិទាំងឡាយ ព្រោះឈមចុះក្នុងទិដ្ឋិ ៦២ ។ ពិត

ហើយ ទិដ្ឋិ ៦២ និងទិដ្ឋិ ៦៣ ក៏ជាទិដ្ឋិ ២ យ៉ាងនោះឯង គឺសស្សតទិដ្ឋិ និង ឧច្ឆេទទិដ្ឋិ ព្រោះហេតុនោះ កាលធ្វើទិដ្ឋិទាំងអស់ខាងក្នុងដោយសរុប ទើបលោកពោល **ទ្វីហិ ទិដ្ឋិគតេហិ** ដូច្នេះ ។

បទថា **បរិយុដ្ឋិតោ** បានដល់ ដល់នូវការរួបរឹត ដល់នូវការប្រកដ អធិប្បាយថា ដល់នូវការប្រកាន់អាចារដែលជាកុសលដោយមិនឲ្យកើតឡើង ។ សមដូចព្រះមានព្រះភាគ ត្រាស់ ( ក្នុងខុទ្ទកនិកាយ ឥតិវុត្តកៈ ) ថា ម្នាលភិក្ខុទាំងឡាយ ទេវតា និងមនុស្សទាំងឡាយ ត្រូវទិដ្ឋិទាំង ២ រួបរឹតហើយ ពួក ១ រមែងជាប់នៅ ពួក ១ រមែងស្ទុះទៅ ចំណែកឯពួកបុគ្គលមានចក្ខុរមែងឃើញ ដូច្នេះជាដើម ។

បទថា **តីហិ ទុច្ចរិតេហិ** បានដល់ ដោយកាយទុច្ចរិត ៣ វចីទុច្ចរិត ៤ និងដោយមនោទុច្ចរិត ៣ ។ បទថា **វិប្បដិបន្នោ** បានដល់ បដិបត្តិខុសផ្លូវ អធិប្បាយថា មិច្ឆាបដិបត្តិ ។ បទថា **យោគេហិ យុត្តោ** បានដល់ ឈ្មោះថា យោគៈ ព្រោះអត្ថថា ប្រកបក្នុងវដ្តៈ ឬឈ្មោះថា យោគៈ ដោយអត្ថថា ជាសេចក្តីទុក្ខលំបាក ។ ប្រកបដោយទៅដោយយោគៈទាំងនោះ ។ បទថា **ចតុយោគយោជិតោ** បានដល់ ទៅប្រកបក្នុងវដ្តៈ ដូចទឹមត្រង់រទេះដោយយោគៈទាំង ៤ នេះ គឺកាមយោគៈ ១ ភវយោគៈ ១ ទិដ្ឋិយោគៈ ១ អវិជ្ជាយោគៈ ១ ។ រាគៈប្រកបដោយកាមគុណ ៥ ឈ្មោះថា កាមយោគៈ ។ ឆន្ទរាគៈក្នុងរូបភព និងអរូបភព ការជាប់ចិត្តក្នុងឈាន រាគៈសហគតៈដោយសស្សតទិដ្ឋិ សេចក្តីប្រាថ្នាដោយអំណាចភព ឈ្មោះថា ភវយោគៈ ។ ទិដ្ឋិ

៦២ ឈ្មោះថា ទិដ្ឋិយោគៈ ។ ការមិនដឹងក្នុងឋានៈ ៨ យ៉ាង ឈ្មោះថា អវិជ្ជាយោគៈ ។ យោគៈទាំង ៤ នោះ ដែលមានកម្លាំងខ្លាំង ឈ្មោះថា ឱឃៈ ដែលមានកម្លាំងខ្សោយ ឈ្មោះថា យោគៈ ។

បទថា **ចតូហិ គន្ថេហិ** សេចក្ដីថា ឈ្មោះថា គន្ថៈ ព្រោះអត្ថថា ដោតក្រង គឺចងអ្នកមានកិលេសក្នុងវដ្ដៈ ដោយចុតិ និងបដិសន្ធិ ។ គន្ថៈមាន ៤ យ៉ាង គឺអភិជ្ឈាកាយគន្ថៈ ១ ព្យាបាទកាយគន្ថៈ ១ សីលព្វតបរាមាសកាយគន្ថៈ ១ ឥទំសច្ចាភិនិវេសកាយគន្ថៈ គឺការប្រកាន់វត្ថុនេះថាពិត ១ ។

ឈ្មោះថា អភិជ្ឈា ព្រោះអត្ថថា ជាហេតុសម្លឹងរំពៃ ឬសម្លឹងរំពៃឯង ឬត្រឹមតែការសម្លឹងប៉ុណ្ណោះ ។ បានដល់ លោភៈនោះឯង ។ ឈ្មោះថា កាយគន្ថៈ ព្រោះអត្ថថា ក្រងនាមកាយ គឺចងទុកក្នុងវដ្ដៈដោយចុតិ និងបដិសន្ធិ ។

ឈ្មោះថា ព្យាបាទ ព្រោះអត្ថថា ជាហេតុបៀតបៀន ចិត្តរមែងដល់នូវសេចក្ដីវិនាស ឬញុំាងរូបសម្បត្តិ គឺវិន័យ និងមារយាទ ប្រយោជន៍ និងសេចក្ដីសុខជាដើម ឲ្យដល់នូវសេចក្ដីវិនាស ។

ការប្រកាន់មាំជឿថា សេចក្ដីបរិសុទ្ធមានដោយសីលវត្ត ឬសីល និងវត្តមានដោយប្រការដូច្នេះ របស់សមណព្រាហ្មណ៍ខាងក្រៅ ឈ្មោះថា សីលព្វតបរាមាស ។

ឈ្មោះថា ឥទំសច្ចាភិនិវេសៈ ព្រោះអត្ថថា បដិសេធសូម្បីភាសិតរបស់ព្រះសព្វញ្ញូ ហើយកាន់យកដោយអាការថា លោកទៀងនេះប៉ុណ្ណោះពិត ដទៃជាមោឃៈជាដើម អធិប្បាយថា ដោតក្រង គឺចងទុកដោយគន្ថៈទាំង ៤

នោះ ។

បទថា **ចតូហិ ឧបាទានេហិ** ឈ្មោះថា ឧបាទាន ព្រោះអត្ថថា ប្រកាន់យ៉ាងខ្លាំងក្លា គឺចាប់យ៉ាងមាំ ។ ឧបាទានទាំងនោះមាន ៤ យ៉ាង គឺកាមុបាទាន ១ ទិដ្ឋុបាទាន ១ សីលព្វតុបាទាន ១ អត្តវាទុបាទាន ១ ។ ឈ្មោះថា កាមុបាទាន ព្រោះអត្ថថា ប្រកាន់មាំក្នុងកាម គឺវត្ថុ ។ម្យ៉ាងទៀត ឈ្មោះថា កាមុបាទាន ព្រោះអត្ថថា កាមនោះផង ជាឧបាទានផង ។ ឈ្មោះថា ទិដ្ឋុបាទាន ព្រោះអត្ថថា ទិដ្ឋិនោះផង ជាឧបាទានផង ។ ម្យ៉ាងទៀត ឈ្មោះថា ទិដ្ឋុបាទាន ព្រោះអត្ថថា ប្រកាន់មាំដោយទិដ្ឋិ ។ ពិតហើយ ក្នុងពាក្យថា អត្តា និងលោកទៀងជាដើម ទិដ្ឋិក្រោយរមែងប្រកាន់មាំទិដ្ឋិដែលមានក្នុងកាលមុន ។ ឈ្មោះថា សីលព្វតុបាទាន ព្រោះអត្ថថា ប្រកាន់សីល និងវត្ត ។ ម្យ៉ាងទៀត ឈ្មោះថា សីលព្វតុបាទាន ព្រោះអត្ថថា សីល និងវត្តនោះផង ជាឧបាទានផង ។ សីលគោ និងវត្តគោជាដើម ជាឧបាទានឯងនោះឯង ព្រោះប្រកាន់ថា សេចក្តីបរិសុទ្ធរមែងមានយ៉ាងនេះ ។ ឈ្មោះថា វាទៈ ព្រោះអត្ថថា ជាហេតុពោល ។ ឈ្មោះថា ឧបាទាន ព្រោះអត្ថថា ជាហេតុប្រកាន់មាំ ។ ពោលអ្វី ប្រកាន់មាំអ្វី ពោលអត្តាប្រកាន់មាំអត្តា ។ ការប្រកាន់មាំ ក្នុងវាទៈរបស់ខ្លួន ឈ្មោះថា អត្តវាទុបាទាន ។ ឬឈ្មោះថា អត្តវាទុបាទាន ព្រោះអត្ថថា ជាហេតុប្រកាន់មាំថា ខ្លួនត្រឹមតែជាវាទៈថាខ្លួនប៉ុណ្ណោះ ។ ទិដ្ឋិសូម្បីទាំងអស់ វៀរទិដ្ឋិទាំង ២ យ៉ាងនេះ ឈ្មោះថា ទិដ្ឋុបាទាន ។ ដោយឧបាទានទាំង ៤ នោះ ។

បទថា **ឧបាទីយតិ** បានដល់ កាន់យ៉ាងពិត ។ បាឋៈថា **ឧបាទិយតិ** ក៏មាន ។ សេចក្តីថា សត្វលោករមែងប្រកាន់យ៉ាងពិតនូវអារម្មណ៍នោះៗ ដោយឧបាទាន ។ បទថា **បញ្ចគតិសមារុឡ្ហោ** បានដល់ ឈ្មោះថា គតិ ព្រោះអត្ថថា ទៅ គឺចូលទៅជិតដោយហេតុធ្វើល្អ និងធ្វើអាក្រក់ គឺខន្ធទាំងឡាយមួយអន្លើដោយឱកាស ។ លោកសន្និវាសឡើងកាន់គតិទាំង ៥ នេះ គឺនរក ១ កំណើតតិរច្ឆាន ១ បិត្តិវិស័យ ១ មនុស្ស ១ ទេវតា ១ ដ៏មានកម្លាំងដោយការឈានចុះ ។ បទថា **បញ្ចហិកាមគុណេហិ** បានដល់ ដោយចំណែកនៃវត្ថុកាម ៥ ពោល គឺរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ។ បទថា **រជ្ជតិ** បានដល់ រមែងត្រេកត្រអាលដោយកាមគុណទាំងនោះ ព្រោះអាស្រ័យអយោនិសោមនសិការធ្វើឲ្យរាគៈកើត អធិប្បាយថា ត្រូវកាមគុណ ៥ ធ្វើឲ្យត្រេកត្រអាល ។

បទថា **បញ្ចហិ នីវរណេហិ** បានដល់ ឈ្មោះថា នីវរណៈ ព្រោះអត្ថថា រមែងរារាំង គឺគ្របសង្កត់ចិត្ត ។ ដោយនីវរណៈ ៥ គឺកាមច្ឆន្ទៈ ព្យាបាទ ថីនមិទ្ធៈ ឧទ្ធច្ចកុក្កុច្ចៈ វិចិកិច្ឆា ។ បទថា **ឱត្ថតោ** បានដល់ សង្កត់ គឺបិទអំពីខាងលើ ។ បទថា **ឆហិ វិវាទមូលេហិ** បានដល់ ដោយហេតុនៃវិវាទ ៦ យ៉ាង ។ ដូចព្រះមានព្រះភាគ ត្រាស់ ( ក្នុងអង្គុត្តរនិកាយ ឆក្កនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ មូលហេតុនៃសេចក្តីវិវាទនេះ មាន ៦ យ៉ាង ។ ៦ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មានសេចក្តីក្រោធ ចងសេចក្តីក្រោធទុក ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា មានសេចក្តី

ក្រោធ ចងសេចក្ដីក្រោធទុក ភិក្ខុនោះមិនមានសេចក្ដីគោរព មិនមានសេចក្ដីកោតក្រែងក្នុងព្រះសាស្ដាផង ... ក្នុងព្រះធម៌ផង ... ក្នុងព្រះសង្ឃផង ... ជាអ្នកមិនធ្វើឲ្យបរិបូណ៌ក្នុងសិក្ខាទេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាមិនមានសេចក្ដីគោរព មិនមានសេចក្ដីកោតក្រែង ក្នុងព្រះសាស្ដាផង ... ក្នុងព្រះធម៌ផង ... ក្នុងព្រះសង្ឃផង ... មិនធ្វើឲ្យបរិបូណ៌ក្នុងសិក្ខាទេ ។ ភិក្ខុនោះរមែងបង្កវិវាទឲ្យកើតឡើងក្នុងព្រះសង្ឃដែលជាវិវាទប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ដល់ជនច្រើន ដើម្បីមិនជាសុខដល់ជនច្រើន ដើម្បីមិនចម្រើនដល់ជនច្រើន មិនជាប្រយោជន៍ ជាទុក្ខដល់ទេវតា និងមនុស្សទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយពិចារណាឃើញមូលហេតុនៃវិវាទ មានសភាពយ៉ាងនេះជាខាងក្នុង ឬជាខាងក្រៅហើយ ម្នាលភិក្ខុទាំងឡាយ ក្នុងរឿងនោះអ្នកទាំងឡាយត្រូវព្យាយាម ដើម្បីលះបង់នូវវិវាទមូលដ៏លាមកនេះចេញ ។ ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយមិនឃើញមូលហេតុនៃវិវាទមានសភាពយ៉ាងនេះជាខាងក្នុង ឬជាខាងក្រៅទេ ម្នាលភិក្ខុទាំងឡាយ ក្នុងរឿងនោះអ្នកទាំងឡាយសមបីប្រតិបត្តិ ដើម្បីមិនឲ្យមូលហេតុនៃវិវាទដ៏លាមកនោះ ជាប់តាមតទៅទៀតបាន ។ យ៉ាងនេះ ឈ្មោះថា ការលះមូលហេតុនៃវិវាទដ៏លាមកនោះចេញ ។ យ៉ាងនេះ ឈ្មោះថា មិនមានមូលហេតុនៃវិវាទដ៏លាមកនុ៎ះ ជាប់តាមទៅទៀត ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកលុបគុណ និងវាយឫកស្មើ ១ ។បេ។ ជាអ្នកមានសេចក្ដីឫស្យា មានសេចក្ដីកំណាញ់ ១ ជាអ្នកអួតអាង មានពុតត្បុត ១ ជាអ្នកមានសេចក្ដីប្រាថ្នាដ៏លាមក មាន

សេចក្តីយល់ខុស ១ ជាអ្នកស្ទាបអង្អែលតាមសេចក្តីយល់របស់ខ្លួន ប្រកាន់មាំ លះបង់បានដោយក្រ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាស្ទាបអង្អែលតាមសេចក្តីយល់របស់ខ្លួន ប្រកាន់មាំ លះបង់បានដោយក្រ ភិក្ខុនោះមិនគោរព មិនកោតក្រែង ក្នុងព្រះសាស្តាផង ។បេ។ យ៉ាងនេះ ឈ្មោះថា មិនមានវិវាទមូលដ៏លាមកទុំះ ជាប់តាមតទៅទៀត ១ ។

ក្នុងពាក្យទាំងនោះ ពាក្យថា មានសេចក្តីក្រោធ បានដល់ ប្រកបដោយការអាក់អន់ ដែលមានអាការអាក់អន់ជាលក្ខណៈ ។ ពាក្យថា ចងសេចក្តីក្រោធទុក បានដល់ ប្រកបដោយការចងសេចក្តីក្រោធ មានការមិនលះបង់នូវពៀរជាលក្ខណៈ ។ ពាក្យថា មិនជាប្រយោជន៍ ជាទុក្ខដល់ទេវតា និងមនុស្សទាំងឡាយ សេចក្តីថា វិវាទរបស់ភិក្ខុ ២ រូប រមែងប្រព្រឹត្តទៅដើម្បីភាពមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខដល់ទេវតា និងមនុស្សទាំងឡាយ ដូចម្តេច កាលបើភិក្ខុ ២ រូប ទាស់ទែងគ្នាដូចក្នុងកោសម្ពិកក្ខន្ធកៈ អន្តេវាសិករបស់ភិក្ខុ ២ រូបនោះ ក្នុងវត្តនោះក៏វិវាទគ្នា ។ ភិក្ខុសង្ឃ ភិក្ខុនី សង្ឃអ្នកទទួលឱវាទរបស់ភិក្ខុ ២ រូបនោះក៏វិវាទគ្នា ។ បន្ទាប់អំពីនោះ ឧបដ្ឋាករបស់ភិក្ខុ ២ រូបនោះក៏វិវាទគ្នា ។ តមក ទេវតាអ្នករក្សាមនុស្សទាំងឡាយ ក៏បែកគ្នាជា ២ ពួក ។ ទេវតាដែលរក្សាធម្មវាទីក៏ជាបក្សពួកធម្មវាទី ទេវតាដែលរក្សាអធម្មវាទីក៏ជាបក្សពួកអធម្មវាទី ។ បន្ទាប់អំពីនោះ ភុម្មដ្ឋទេវតាដែលជាមិត្តរបស់អារក្ខទេវតាក៏បែកគ្នា ។ ទេវតា និងមនុស្សទាំងឡាយ វៀរព្រះអរិយ-សាវកបែកគ្នាជា ២ ចំណែកដោយតៗ គ្នាយ៉ាងនេះ រហូតដល់ព្រហ្មលោក ។

ពួកអធម្មវាទីច្រើនជាងពួកធម្មវាទី ។ ពេលនោះ វត្ថុទាំងពួងដែលពួកជនមានគ្នាច្រើនកាន់យកទើបជាសច្ចៈ ព្រោះហេតុនោះ ពួកជនដែលមានគ្នាច្រើននោះក៏លះបង់ធម៌ កាន់យកអធម៌ ។ ពួកអធម៌ទាំងនោះ កាន់យកអធម៌ជាគោលរមែងកើតក្នុងអបាយ ។ វិវាទរបស់ភិក្ខុ ២ រូបយ៉ាងនេះ រមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខដល់ទេវតា និងមនុស្សទាំងឡាយ ។

ពាក្យថា ជាខាងក្នុងក្តី បានដល់ ក្នុងបរិស័ទខាងក្នុងរបស់ពួកអ្នក ។ បទថា ជាខាងក្រៅក្តី បានដល់ ក្នុងបរិស័ទរបស់ពួកដទៃ ។ ពាក្យថា **ជា**អ្នកលុបគុណ បានដល់ ប្រកបដោយការលុបគុណដែលមានការលុបគុណជាលក្ខណៈ ។ ពាក្យថា វាយឫកស្មើ បានដល់ ប្រកបដោយការវាយឫកស្មើដែលមានការប្រណាំងប្រជែងជាលក្ខណៈ ។ ពាក្យថា ជាអ្នកមានសេចក្តីឫស្យា បានដល់ ប្រកបដោយសេចក្តីច្រណែន ដែលមានការច្រណែនក្នុងសក្ការៈជាដើម របស់អ្នកដទៃជាលក្ខណៈ ។ ពាក្យថា មានសេចក្តីកំណាញ់ បានដល់ ប្រកបដោយកំណាញ់ ៥ មានកំណាញ់អាវាសជាដើម ។ ពាក្យថា ជាអ្នកអួតអាង បានដល់ ពេញទៅដោយការបោកបញ្ឆោត ។ ពាក្យថា មានពុតត្បុត បានដល់ បិទបាំងអំពើអាក្រក់ ដែលខ្លួនបានធ្វើ ។ ពាក្យថា មានសេចក្តីប្រាថ្នាដ៏លាមក បានដល់ ប្រាថ្នាការសរសើរគុណដែលមិនមានគឺជាអ្នកទ្រុស្តសីល ។ ពាក្យថា មានសេចក្តីយល់ខុស បានដល់ នត្ថិកវាទី អហេតុកវាទី អកិរិយវាទី ។ ពាក្យថា ជាអ្នកស្ទាបអង្អែលតាមសេចក្តីយល់របស់ខ្លួន បានដល់ ស្ទាបអង្អែលទិដ្ឋិរបស់ខ្លួនឯងប៉ុណ្ណោះ ។ ពាក្យថា

**ប្រកាន់មាំ** បានដល់ ប្រកាន់មាំ ។ ពាក្យថា លះបង់បានដោយក្រ បានដល់ បុគ្គលណាមួយមិនអាចឲ្យបុគ្គលនោះលះបង់វត្ថុដែលប្រកាន់បាន ។ ចំណែកក្នុងខុទ្ទកវត្ថុវិភង្គលោកពោលដល់ធម៌មួយៗ ដោយអំណាចជាប្រធានថា បណ្ដាធម៌ទាំងនោះ មូលនៃវិវាទ ៦ តើដូចម្ដេច ។ សេចក្ដីក្រោធ ១ សេចក្ដីលុបគុណ ១ សេចក្ដីប្រណែន ១ សេចក្ដីអួតអាង ១ សេចក្ដីប្រាថ្នាដ៏លាមក ១ ការស្ទាបអង្អែលទិដ្ឋិរបស់ខ្លួន ១ នេះមូលនៃវិវាទ ៦ ដូច្នេះ ។

បទថា **ឆហិ តណ្ហាកាយេហិ** បានដល់ ដោយតណ្ហា ៦ ដូចព្រះតម្រាស់ ( ក្នុងអភិធម្ម វិភង្គ ) ថា រូបតណ្ហា ១ សទ្ទតណ្ហា ១ គន្ធតណ្ហា ១ រសតណ្ហា ១ ផោដ្ឋព្វតណ្ហា ១ ធម្មតណ្ហា ១ ដូច្នេះ ក្នុងតណ្ហាទាំងនោះ ព្រោះតណ្ហានីមួយៗ រមែងមានមិនមែនតិច ព្រោះកើតរឿយៗ ក្នុងអារម្មណ៍នីមួយៗ ព្រោះមានអារម្មណ៍ច្រើន ។ ហេតុនោះ ទើបលោកពោលថា **តណ្ហាកាយា** ព្រោះប្រកប **កាយ** សព្ទ ដែលមានអត្ថថា ពួក ។ សូម្បីកាលពោលថា **តណ្ហាកាយា** ក៏គឺតណ្ហានោះឯង ។ បទថា **រជ្ជតិ** បានដល់ តម្រេក គឺជាអ្នកត្រេកអរក្នុងអារម្មណ៍ដោយខ្លួនឯង ។ បទថា **ឆហិ ទិដ្ឋិគតេហិ** បានដល់ ទិដ្ឋិដែលត្រាស់ហើយក្នុងសព្វាសវសូត្រ ( សព្វាសវសំវរសូត្រ ) ក្នុងសូត្រនោះ ព្រះមានព្រះភាគ ត្រាស់ថា កាលបុថុជ្ជននោះធ្វើទុកក្នុងចិត្តដោយខុសទំនងយ៉ាងនេះហើយ បណ្ដាទិដ្ឋិទាំង ៦ ទិដ្ឋិណាមួយគង់កើតឡើងបាន ។ ទិដ្ឋិកើតឡើងដល់បុថុជ្ជននោះ ព្រោះប្រកាន់សេចក្ដីទៀងទាត់ ស្ថិតស្ថេរថា ខ្លួនរបស់អាត្មាអញមាន ១ ។ ទិដ្ឋិកើតឡើងដល់

បុថុជ្ជននោះព្រោះប្រកាន់សេចក្ដីទៀងទាត់ ស្ថិតស្ថេរថា ខ្ជួនរបស់អាត្មាអញមិនមាន ១ ។ ទិដ្ឋិកើតឡើងដល់បុថុជ្ជននោះព្រោះប្រកាន់សេចក្ដីទៀងទាត់ ស្ថិតស្ថេរថា អាត្មាអញដឹងច្បាស់នូវខ្លួនដោយសភាវៈ ថាជាខ្លួនពិត ១ ។ ទិដ្ឋិកើតឡើងដល់បុថុជ្ជននោះ ព្រោះប្រកាន់សេចក្ដីទៀងទាត់ ស្ថិតស្ថេរថា អាត្មាអញដឹងច្បាស់នូវសភាវៈមិនមែនខ្លួនដោយសភាវៈ ថាជាខ្លួនពិត ១ ។ ទិដ្ឋិកើតឡើងដល់បុថុជ្ជននោះ ព្រោះប្រកាន់សេចក្ដីទៀងទាត់ ស្ថិតស្ថេរថា **អាត្មា**អញដឹងច្បាស់នូវខ្លួនឯងដោយសភាវៈថា មិនមែនខ្លួនពិត ១ ។ ពុំនោះសោតបុថុជ្ជននោះ មានសេចក្ដីយល់ឃើញយ៉ាងនេះថា ខ្លួនរបស់អាត្មាអញ ( ជាអ្នកពោល ជាអ្នកដឹង )[១] ដែលត្រូវទទួល រមែងទទួលនូវផលកម្មល្អ និងអាក្រក់ក្នុងកំណើតនោះៗ តែខ្លួនរបស់អាត្មាអញនោះ ជាសភាវៈទៀងទាត់ប្រាកដ ស្ថិតស្ថេរ ជាសភាវៈមិនប្រែប្រួល តាំងនៅមាំដូចជាសស្សតិវត្ថុ ( ព្រះអាទិត្យ និងព្រះចន្ទជាដើម ) ដូច្នោះឯង ១ ។

ក្នុងពាក្យទាំងនោះទិដ្ឋិថា ខ្លួនរបស់អាត្មាអញមាន ជាសស្សតទិដ្ឋិ រមែងប្រកាន់ថា ខ្លួនមានក្នុងកាលទាំងពួង ។ ពាក្យថា សេចក្ដីទៀងទាត់ ស្ថិតស្ថេរ បានដល់ ដោយសេចក្ដីទៀងទាត់ និងដោយការស្ថិតស្ថេរ អធិប្បាយថា ដោយការស្ថិតស្ថេរយ៉ាងល្អថា វត្ថុនេះទៀង ។

---

១- ពាក្យក្នុងវង់ក្រចកនេះ ប្រែចេញមកពីបាលីថា វទោ វេទេយ្យោ តែបិដកខ្មែរមានតែ វេទេយ្យោ ដោយក្នុងអដ្ឋកថាខាងក្រោមលោកពន្យល់បទ វទោ និង វេទេយ្យោ នេះ ទើបយើងប្រែបញ្ចូលក្នុងវង់ក្រចកនេះ ។

ទិដ្ឋិថា ខ្លួនរបស់អាត្មាអញមិនមាន ជាឧច្ឆេទទិដ្ឋិ ព្រោះប្រកាន់ការមិនមាន មិនកើតក្នុងអត្តានោះៗ របស់សត្វដែលមាន ។ ម្យ៉ាងវិញទៀត ទិដ្ឋិដំបូង ជាសស្សតទិដ្ឋិ ព្រោះប្រកាន់ថា អត្តាមានក្នុងកាល ៣ ជាឧច្ឆេទទិដ្ឋិ ព្រោះប្រកាន់ថា មានចំពោះបច្ចុប្បន្នប៉ុណ្ណោះ សូម្បីទិដ្ឋិក្រោយ ជាឧច្ឆេទទិដ្ឋិ ព្រោះប្រកាន់ថា អត្តាមិនមានទាំងក្នុងអតីត និងក្នុងអនាគត ដូចទិដ្ឋិរបស់មេលទ្ធិដែលប្រកាន់ថា គ្រឿងបូជា មានផេះ និងធូលីជាទីបំផុត ជាសស្សតទិដ្ឋិ ព្រោះប្រកាន់ថា អត្តាមិនមានក្នុងអតីតទាំងអស់ ដូចរបស់បុគ្គលដែលមានការយល់ឃើញថា កើតឡើងដោយមិនមានហេតុ ។

ពាក្យថា អាត្មាអញដឹងច្បាស់នូវខ្លួនដោយសភាវៈ ថាជាខ្លួនពិត បានដល់ មានទិដ្ឋិថា អាត្មាអញរមែងស្គាល់អត្តានេះដោយខ្លួននេះ ព្រោះប្រកាន់ខន្ធទាំងឡាយថា ជាអត្តាដោយមានសញ្ញាខន្ធជាធំ ហើយស្គាល់ខន្ធដ៏សេសដោយសញ្ញាខន្ធ ។

ពាក្យថា អាត្មាអញដឹងច្បាស់នូវសភាវៈមិនមែនខ្លួន ដោយសភាវៈថាជាខ្លួនពិត បានដល់ មានទិដ្ឋិយ៉ាងនេះ ព្រោះប្រកាន់សញ្ញាខន្ធនោះឯងថា ជាអត្តា ប្រកាន់ខន្ធដ៏សេស ៤ យ៉ាង ក្រៅអំពីនេះថា ជាអនត្តា ហើយស្គាល់ខន្ធទាំងនោះដោយសញ្ញាខន្ធ ។

ពាក្យថា អាត្មាអញដឹងច្បាស់នូវខ្លួនឯងដោយសភាវៈថា មិនមែនខ្លួនពិត បានដល់ មានទិដ្ឋិយ៉ាងនេះ ព្រោះប្រកាន់សញ្ញាខន្ធថា ជាអនត្តា ប្រកាន់ខន្ធ ៤ ក្រៅអំពីនេះ ថាជាអត្តា ហើយស្គាល់ខន្ធទាំងនោះដោយសញ្ញាខន្ធ ។

ទិដ្ឋិសូម្បីទាំងអស់ ក៏ជាសស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិនោះឯង ។

ចំណែកពាក្យជាដើមថា **វទោ វេទេយ្យោ** ( ជាអ្នកពោល ជាអ្នកដឹង ) ជាអាការរបស់ការប្រកាន់មាំ ក្នុងសស្សតទិដ្ឋិនោះឯង ។ ក្នុងពាក្យទាំងនោះ ឈ្មោះថា **វទោ** ព្រោះអត្ថថា ពោល អធិប្បាយថា អ្នកធ្វើវចីកម្ម ។ ឈ្មោះថា **វេទេយ្យោ** ព្រោះអត្ថថា ដឹង អធិប្បាយថា ដឹង និងទទួល ។ ដឹង និងទទួលអ្វី ទទួលនូវផលកម្មល្អ និងអាក្រក់ក្នុងកំណើតនោះៗ ។

ពាក្យថា ក្នុងកំណើតនោះៗ បានដល់ ក្នុងកំណើត គតិ ឋិតិ និវាស និងនិកាយ ឬក្នុងអារម្មណ៍នោះៗ ។ ពាក្យថា ទៀងទាត់ បានដល់ មិនមានការកើតរលត់ ។ ពាក្យថា ប្រាកដ បានដល់ នាំមាំជាសារៈ ។ ពាក្យថា ស្ថិតស្ថេរ បានដល់ ប្រព្រឹត្តទៅអស់កាលទាំងពួង ។ បទថា ជាសភាវៈមិនប្រែប្រួល បានដល់ មិនលះបង់ភាវៈដើមរបស់ខ្លួន មិនដល់សភាពមានប្រការផ្សេងៗ ដូចសត្វបង្កួយ ។ ពាក្យថា តាំងនៅមាំដូចជាសស្សតិវត្ថុ លោកពោលព្រះចន្ទ ព្រះអាទិត្យ សមុទ្ទ មហាប្រឹថពី និងភ្នំ ថាជាសស្សតិវត្ថុដោយលោកវោហា ។ វត្ថុដែលស្មើដោយសស្សតិវត្ថុ ឈ្មោះថា តាំងនៅមាំដូចជាសស្សតិវត្ថុ ។ ទិដ្ឋិមានយ៉ាងនេះ ព្រោះប្រកាន់ថា នឹងតាំងនៅយ៉ាងនោះឯងដរាបស្មើគ្នានឹងសស្សតិវត្ថុនៅតាំងនៅ ។ តែក្នុងខុទ្ទកវត្ថុ វិភង្គ ទ្រង់ត្រាស់ដល់ទិដ្ឋិ ៦ ឲ្យផ្សេងចេញទៅយ៉ាងនេះថា រមែងទទួលនូវវិបាកនៃធម៌ល្អ និងអាក្រក់ អស់កាលដ៏វែង ក្នុងអារម្មណ៍នោះៗ ខ្លួននោះមិនកើតឡើងហើយក៏មិនមែន ខ្លួននោះនឹងកើតឡើងក៏មិនមែន ជាសភាវៈទៀង ស្ថិតស្ថេរ មាំមួន មិនប្រែប្រួល

ជាធម្មតា ១ ដូច្នេះ ។

ក្នុងពាក្យទាំងនោះ ពាក្យថា ខន្ធនោះមិនកើតឡើងហើយ មិនមានហើយ[១] បានដល់ អត្តានោះ ឈ្មោះថា មិនកើត ព្រោះមិនកើតជាធម្មតា អធិប្បាយថា មាននៅគ្រប់កាល ដោយហេតុនោះ អត្តាមិនមានក្នុងអតីត និងមិនមានក្នុងអនាគត ព្រោះថា អត្តាណាកើតហើយ អត្តានោះ ហៅថា មានហើយ និងអត្តាណា នឹងកើត អត្តានោះ ហៅថា នឹងមាន ។

ម្យ៉ាងវិញទៀត ពាក្យថា ខន្ធនោះមិនកើតឡើងហើយ មិនមានហើយ សេចក្ដីថា អត្តានោះមិនកើត មិនមានហើយសូម្បីក្នុងអតីត ព្រោះមានសព្វកាលសូម្បីក្នុងអនាគត ក៏នឹងមិនកើត នឹងមិនមាន ។ អនុស័យទាំងឡាយមានអត្ថដូចបានពោលហើយ ។

បទថា **សត្តហិ សញ្ញោជនេហិ** បានដល់ សំយោជនៈដែលទុកហើយក្នុងសត្តកនិបាត ដូចព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សញ្ញោជនៈនេះមាន ៧ យ៉ាង ។ ៧ យ៉ាង តើអ្វីខ្លះ ។ គឺអនុនយសញ្ញោជនៈ ១ បដិឃសញ្ញោជនៈ ១ ទិដ្ឋិសញ្ញោជនៈ ១ វិចិកិច្ឆាសញ្ញោជនៈ ១ មានសញ្ញោជនៈ ១ ភវរាគសញ្ញោជនៈ ១ អវិជ្ជាសញ្ញោជនៈ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងសញ្ញោជនៈ ៧ យ៉ាង ដូច្នេះ ។

ក្នុងពាក្យទាំងនោះ ពាក្យថា **អនុនយសញ្ញោជនំ** បានដល់ កាមរាគសំយោជនៈ ។ សំយោជនៈទាំងអស់នេះហៅថា សញ្ញោជនៈ ដោយអត្ថថា ជា

---

១- បិដកខ្មែរ ជាខន្ធនោះមិនកើតឡើងហើយ ក៏មិនមែន ។

គ្រឿងចង ។

បទថា **សត្តហិ មានេហិ** បានដល់ ព្រោះមានះដែលត្រាស់ហើយ ក្នុងខុទ្ទកវត្ថុវិភង្គ ។ ពិតហើយ ក្នុងវិភង្គនោះ ព្រះមានព្រះភាគត្រាស់ថា មានះ ១ អតិមានះ ១ មានាតិមានះ ១ ឱមានះ ១ អធិមានះ ១ អស្មិមានះ ១ មិច្ឆាមានះ ១ ដូច្នេះ ។

ក្នុងពាក្យទាំងនោះ ពាក្យថា មានះ បានដល់ ការប្រកាន់ខ្លួនដោយមិនពាល់ត្រូវបុគ្គលដែលល្អជាងជាដើម ហើយតាំងនៅក្នុងជាតិជាដើម ។

ពាក្យថា អតិមានះ បានដល់ លើកតម្កើងខ្លួនថា មិនមានបុគ្គលណាមួយដូចអញ ដោយជាតិជាដើម ។

បទថា **មានាតិមាន** បានដល់ ប្រកាន់ខ្លួនថា បុគ្គលនេះកាលមុនដូចអញឥឡូវនេះ អញប្រសើរជាង បុគ្គលនេះ ថោកទាបជាងអញ ។

ពាក្យថា ឱមានះ បានដល់ មានះដែលប្រកាន់ខ្លួនថាថោកទាបដោយជាតិជាដើម គឺមានះថា អញជាបុគ្គលថោកទាប ។

ពាក្យថា អធិមានះ បានដល់ មានះថា អញសម្រេចសច្ចធម៌ ៤ ដែលមិនមានអ្នកសម្រេចឡើយ អធិមានះនេះកើតដល់បុថុជ្ជនអ្នកមានសីលបរិសុទ្ធមិនប្រមាទក្នុងកម្មដ្ឋាន កំណត់នាមរូប ហើយឆ្លងសេចក្តីសង្ស័យដោយកំណត់បច្ច័យ លើកឡើងកាន់ត្រៃលក្ខណ៍ ហើយពិចារណាសង្ខារ ប្រារព្ធវិបស្សនា មិនកើតដល់អ្នកដទៃ ។

ពាក្យថា អស្មិមានះ បានដល់ មានះក្នុងខន្ធ មានរូបជាដើមថា ជាអញ

អធិប្បាយថា មានះកើតឡើងដោយអំណាចការគិតជាដើមថា អញ គឺរូប ។

ពាក្យថា មិច្ឆាមានះ បានដល់ មានះកើតឡើងដោយកម្មាយតនៈដ៏លាមក ( ប្រកបពកើតនៃការងារអោក្រក់ ) ជាដើម ។

បទថា **លោកធម្មា** មានអត្ថបានពោលហើយ ។ បទថា **សម្បរិវត្តតិ** បានដល់ វិលវល់ទៅដោយលោកធម៌ ដែលជាហេតុដោយការត្រេកអរ ក្នុងលោកធម៌ ៤ មានលាភជាដើម ដោយការមិនត្រេកអរ ក្នុងលោកធម៌ ៤ មានការមិនមានលាភជាដើម អធិប្បាយថា លះភាវៈប្រក្រតី ។ សូម្បីបទថា **មិច្ឆត្តា** ក៏មានអត្ថដូចពោលហើយ ។ បទថា **និយ្យាតោ** បានដល់ ទៅស្ុះទៅ អធិប្បាយថា គ្របសង្កត់ហើយ ។

បទថា **អដ្ឋហិ បុរិសទោសេហិ** បានដល់ បុរិសទោសដែលត្រាស់ក្នុងអដ្ឋកនិបាត មួយអន្លើដោយឧបមា ត្រាស់ក្នុងខុទ្ទកវត្ថុវិភង្គ មិនមានឧបមាសមដូចព្រះតម្រាស់ ( ក្នុងខុទ្ទកវត្ថុវិភង្គ ) ថា បណ្តាធម៌ទាំងនោះ ទោសរបស់បុរស ៨ តើដូចម្តេច ។ ពួកភិក្ខុក្នុងសាសនានេះ ចោទភិក្ខុផងគ្នាដោយអាបត្តិ ភិក្ខុនោះកាលបើត្រូវពួកភិក្ខុចោទដោយអាបត្តិ ក៏ដោះស្រាយដោយអស្សតិ ( ការគ្មានស្មារតី ) ថា ខ្ញុំនឹកមិនឃើញ ខ្ញុំនឹកមិនឃើញ នេះទោសរបស់បុរសទី ១ ។ មួយទៀត ពួកភិក្ខុចោទភិក្ខុផងគ្នាដោយអាបត្តិ ភិក្ខុនោះកាលបើត្រូវពួកភិក្ខុចោទដោយអាបត្តិ ក៏និយាយគេចកែនឹងភិក្ខុអ្នកចោទវិញថា ប្រយោជន៍អ្វី អ្នកជាមនុស្សល្ងង់មិនឈ្លាស មកស្តីថាឲ្យយើង អម្បាលយ៉ាងអ្នកហ៊ានសម្គាល់យើងថាគួរនឹងស្តីថាបាន នេះទោសរបស់បុរសទី ២ ។

មួយទៀត ពួកភិក្ខុចោទភិក្ខុផងគ្នាដោយអាបត្តិ ភិក្ខុនោះកាលបើត្រូវពួកភិក្ខុចោទដោយអាបត្តិ ក៏ត្រឡប់លើកពាក្យរបស់អ្នកចោទវិញថា លោកឯងត្រូវអាបត្តិឈ្មោះនេះ ចូរលោកសម្តែងមុនសិនទៅ នេះទោសរបស់បុរសទី ៣ ។ មួយទៀត ពួកភិក្ខុចោទភិក្ខុផងគ្នាដោយអាបត្តិ ភិក្ខុនោះកាលបើត្រូវពួកភិក្ខុចោទដោយអាបត្តិក៏បិទបាំងនូវហេតុដទៃដោយហេតុដទៃ យកពាក្យខាងក្រៅមកបញ្ចេញធ្វើនូវសេចក្តីក្រោធ ទឹង មិនត្រេកអរ ឲ្យប្រាកដឡើង នេះទោសរបស់បុរសទី ៤ ។ មួយទៀត ពួកភិក្ខុចោទភិក្ខុផងគ្នាដោយអាបត្តិ ភិក្ខុនោះកាលបើត្រូវពួកភិក្ខុចោទដោយអាបត្តិក៏និយាយគ្រវែងដៃក្នុងកណ្តាលសង្ឃ នេះទោសរបស់បុរសទី ៥ ។ មួយទៀត ពួកភិក្ខុចោទភិក្ខុផងគ្នាដោយអាបត្តិ ភិក្ខុនោះ កាលបើត្រូវពួកភិក្ខុចោទដោយអាបត្តិក៏នៅស្ងៀម ធ្វើសង្ឃឲ្យលំបាក នេះទោសរបស់បុរសទី ៦[១] ។ មួយទៀត ពួកភិក្ខុចោទភិក្ខុផងគ្នាដោយអាបត្តិ ភិក្ខុនោះកាលបើត្រូវពួកភិក្ខុចោទដោយអាបត្តិក៏**មិនអើពើ**នឹងសង្ឃ មិនអើពើនឹងភិក្ខុអ្នកចោទ ជាបុគ្គលមានអាបត្តិ ដើរចៀសចេញទៅតាមប្រាថ្នា នេះទោសរបស់បុរសទី ៧[២] ។ មួយទៀត ពួកភិក្ខុចោទភិក្ខុផងគ្នាដោយអាបត្តិ ភិក្ខុនោះកាលបើត្រូវពួកភិក្ខុចោទដោយអាបត្តិ ក៏និយាយយ៉ាងនេះថា បពិត្រលោកមានអាយុទាំងឡាយ លោកខ្វល់ខ្វាយនឹងខ្ញុំហួសប្រមាណធ្វើអ្វី ឥឡូវ

---

១- ច្បាប់ស្យាមក្តី ច្បាប់ឆដ្ឋសង្គាយនាក្តី ទោសរបស់បុរសទី ៦ នេះ នៅត្រង់លេខរៀងទោសរបស់បុរសទី ៧ ។

២- ច្បាប់ស្យាមក្តី ច្បាប់ឆដ្ឋសង្គាយនាក្តី ទោសរបស់បុរសទី ៧ នេះ នៅត្រង់លេខរៀងទោសរបស់បុរសទី ៦ ។

នេះខ្ញុំនឹងលាសិក្ខាវិលត្រឡប់ទៅកាន់ភេទជាគ្រហស្ថ ភិក្ខុនោះលុះលាសិក្ខាវិលត្រឡប់ទៅកាន់ភេទជាគ្រហស្ថហើយ ក៏និយាយយ៉ាងនេះថា បពិត្រលោកមានអាយុទាំងឡាយ ឥឡូវនេះ លោកទាំងឡាយ **ចូរជាអ្នកមានចិត្តត្រេកអរចុះ** នេះទោសរបស់បុរសទី ៨ នេះទោសរបស់បុរស ៨ ដូច្នេះ ។

ក្នុងពាក្យទាំងនោះ ពាក្យថា ទោសរបស់បុរស បានដល់ ទោសរបស់បុរស ឈ្មោះថា ទោស ព្រោះអត្ថថា ប្រទូស្តសន្តានបុរស ។ ពាក្យថា ខ្ញុំនឹកមិនឃើញ បានដល់ ភិក្ខុនោះលាងខ្លួន គឺដោះសារដោយមិនមានសតិយ៉ាងនេះថា ខ្ញុំចាំមិនបាន កំណត់មិនបាននូវទីដែលខ្ញុំធ្វើកម្ម ។

ពាក្យថា ក៏និយាយគេចកែ បានដល់ ប្រាទចោលនូវពាក្យចោទ តាំងនៅដោយភាពជាគន្ធឹះហើយ ឆ្លើយតប ។ ពាក្យថា ប្រយោជន៍អ្វី អ្នក បានដល់ អ្នកដែលត្រូវចោទពោលថា ប្រយោជន៍អ្វីដែលនឹងត្រូវនិយាយជាមួយអ្នកដែលល្ងង់មិនឈ្លាស ដែលមិនដឹងវត្ថុ មិនដឹងអាបត្តិ មិនដឹងការចោទ ។ សង្កត់សង្កិនថា លោកមិនដឹងអ្វីយ៉ាងនេះ ហ៊ានពោល ។

ពាក្យថា ត្រឡប់លើកពាក្យ បានដល់ ពោលត្រឡប់អាបត្តិជាដើមថា សូម្បីអ្នកក៏ ... ។ ពាក្យថា ចូរលោកសម្តែង បានដល់ អ្នកត្រូវចោទប្រាប់ថា ចូរអ្នកសម្តែងទេសនាគាមិនី គឺការសម្តែងអាបត្តិ ចូរអ្នកចេញចាកវុដ្ឋានគាមិនី គឺចេញចាកអាបត្តិ ។ បន្ទាប់អំពីនោះ អ្នកតាំងនៅក្នុងសេចក្តីបរិសុទ្ធហើយ សឹមចោទអ្នកដទៃ ។

ពាក្យថា បិទបាំងនូវហេតុដទៃដោយហេតុដទៃ បានដល់ បិទបាំងហេតុ

ដទៃដោយហេតុដទៃ ឬបិទបាំងពាក្យនិយាយដោយពាក្យដទៃ ។ អ្នកចោទពោលថា លោកត្រូវអាបត្តិហើយ ។ ភិក្ខុនោះពោលថា នរណាត្រូវអាបត្តិ ត្រូវអាបត្តិអ្វី ត្រូវអាបត្តិមួយណា ត្រូវអាបត្តិដូចម្តេច លោកពោលនឹងនរណា លោកពោលអ្វី កាលអ្នកចោទពោលថា អាបត្តិអ្វីលោកក៏ឃើញស្រាប់ហើយ ភិក្ខុនោះពោលថា ខ្ញុំមិនបានឮ ហើយបង្អោនត្រចៀកចូលទៅ ។

ពាក្យថា យកពាក្យខាងក្រៅមកបញ្ចេញ បានដល់ កាលបើអ្នកចោទសួរថា លោកត្រូវអាបត្តិមួយនេះឬ ភិក្ខុនោះក៏ពោលថា ខ្ញុំនឹងទៅនគរបាដលិបុត្ត កាលអ្នកចោទពោលដដែលទៀតថា ខ្ញុំមិនបានសួរដល់ការទៅនគរបាដលិបុត្តរបស់លោកទេ ខ្ញុំសួរអាបត្តិ ភិក្ខុនោះពោលថា បន្ទាប់អំពីនោះទៅ ខ្ញុំនឹងទៅនគររាជគ្រឹះ កាលអ្នកចោទពោលថា ទោះលោកទៅរាជគ្រឹះ ឬព្រាហ្មណគ្រឹះក៏ដោយ លោកត្រូវអាបត្តិហើយ ភិក្ខុនោះក៏ពោលពាក្យថា ខ្ញុំនឹងបានសាច់ជ្រូកក្នុងទីនោះ រមែងពោលក្រៅរឿងទៅ ។

ពាក្យថា សេចក្តីក្រោធ បានដល់ ភាពនៃសេចក្តីក្រោធ ។ ពាក្យថា ទោស បានដល់ ការប្រទូស្ត ។ ពាក្យទាំងពីរនេះ ជាឈ្មោះរបស់សេចក្តីក្រោធនោះឯង ។ ពាក្យថា មិនត្រេកអរ បានដល់ អាការមិនពេញចិត្ត ពាក្យនេះ ជាឈ្មោះរបស់ទោមនស្ស ។

ពាក្យថា ឲ្យប្រាកដឡើង បានដល់ សម្តែង ប្រកាស ។ ពាក្យថា និយាយក្តារដៃ បានដល់ គ្រវីដៃទៅមកហើយនិយាយពាក្យ មិនមានអៀនខ្មាស ។ ពាក្យថា មិនអើពើ បានដល់ មិនអើពើដោយការកោតក្រែង

អធិប្បាយថា មើលងាយ មិនដាក់ចិត្ត ។

ពាក្យថា ធ្វើ ( សង្ឃ ) ឲ្យលំបាក បានដល់ ឲ្យលំបាក រំខាន ។

ពាក្យថា ហួសប្រមាណ បានដល់ ធ្ងន់ខ្លាំង លើសប្រមាណ ។ ពាក្យថា លោកខ្វល់ខ្វាយនឹងខ្ញុំ បានដល់ ដល់នូវការខ្វល់ខ្វាយក្នុងខ្ញុំ ។ ពាក្យថា វិលត្រឡប់ទៅកាន់ភេទថោកទាបវិញ បានដល់ វិលមកដើម្បីភាពជាបុគ្គលថោកទាប គឺជាគ្រហស្ថ ។ ពាក្យថា ចូរជាអ្នកមានចិត្តត្រេកអរចុះ បានដល់ ភិក្ខុនោះ ពោលដោយបំណងថា ពួកលោកចូរពេញចិត្តចុះ ចូរលោកបានវត្ថុដែលខ្ញុំគួរបានចុះ ចូរលោកនៅក្នុងទីដែលខ្ញុំគួរនៅចុះ ខ្ញុំធ្វើនូវផាសុកឲ្យដល់ពួកលោកហើយ ។

បទថា **ទុស្សតិ** បានដល់ ត្រូវប្រទូស្ត ។ បទថា **នវហិ អាឃាតវត្ថូហិ** លោកពោលដោយអំណាចការកើតឡើងក្នុងសត្វទាំងឡាយ ។ សមដូចព្រះមានព្រះភាគ ត្រាស់ ( ក្នុងអង្គុត្តរនិកាយ នវកនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ អាឃាតវត្ថុ ( ហេតុជាទីតាំងនៃសេចក្តីគុំកួន ) នេះមាន ៩ យ៉ាង ។ អាឃាតវត្ថុទាំង ៩ យ៉ាង តើដូចម្តេចខ្លះ ។ គឺបុគ្គលចងគំនុំដោយគិតថា ជនឯណោះបានប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់អាត្មាអញ ១ ចងគំនុំដោយគិតថា ជនឯណោះកំពុងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់អាត្មាអញ ១ ចងគំនុំដោយគិតថា ជនឯណោះនឹងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់អាត្មាអញ ១ ចងគំនុំដោយគិតថា ជនឯណោះបានប្រព្រឹត្តហើយនូវអំពើមិនជាប្រយោជន៍ដល់សត្វ និងសង្ខារជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់អាត្មា

អញ ១ ចងគំនុំដោយគិតថា ជនឯណោះកំពុងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ ដល់សត្វ និងសង្ខារជាទីស្រឡាញ់ ជាទីពេញចិត្តរបស់អាត្មាអញ ១ ចងគំនុំ ដោយគិតថា ជនឯណោះនឹងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ ដល់សត្វ និង សង្ខារជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់អាត្មាអញ ១ ចងគំនុំដោយគិតថា ជនឯណោះបានប្រព្រឹត្តនូវអំពើជាប្រយោជន៍ ដល់សត្វ និងសង្ខារមិនជាទី ស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញ ១ ចងគំនុំដោយគិតថា ជនឯណោះ កំពុងប្រព្រឹត្តនូវអំពើជាប្រយោជន៍ដល់សត្វ និងសង្ខារមិនជាទីស្រឡាញ់ មិន ជាទីគាប់ចិត្តរបស់អាត្មាអញ ១ ចងគំនុំដោយគិតថា ជនឯណោះនឹងប្រព្រឹត្ត នូវអំពើជាប្រយោជន៍ដល់សត្វ និងសង្ខារមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្ត របស់អាត្មាអញ ១ ។ ម្នាលភិក្ខុទាំងឡាយ អាឃាតវត្ថុមាន ៩ យ៉ាងនេះ ឯង ។

ក្នុងពាក្យទាំងនោះ ពាក្យថា អាឃាតវត្ថុ បានដល់ ហេតុនៃការចងគំនុំ ។ ម្យ៉ាងទៀត ក្នុងពាក្យថា អាឃាត នេះ បានដល់ សេចក្ដីក្រោធ សេចក្ដីក្រោធ នោះឯង លោកហៅថា អាឃាតវត្ថុ ព្រោះជាទីតាំងនៃសេចក្ដីក្រោធក្រៃលែង ឡើងៗ ។ ពាក្យថា ចងគំនុំ បានដល់ ចង ធ្វើ ញ៉ាំងសេចក្ដីក្រោធឲ្យកើត ។ អាឃាតវត្ថុ ៩ សូម្បីដទៃដែលលោកពោល ( ក្នុងខុទ្ទកនិកាយ មហា- និទ្ទេស ) ថា គេបានប្រព្រឹត្តនូវហេតុមិនជាប្រយោជន៍ដល់អញ គេកំពុងប្រព្រឹត្ត នូវហេតុមិនជាប្រយោជន៍ដល់អញ គេនឹងប្រព្រឹត្តនូវហេតុ មិនជាប្រយោជន៍ ដល់អញ គេបានប្រព្រឹត្តនូវហេតុមិនជាប្រយោជន៍ កំពុងប្រព្រឹត្តនូវហេតុមិន

ជាប្រយោជន៍ នឹងប្រព្រឹត្តនូវហេតុមិនជាប្រយោជន៍ដល់បុគ្គលដែលជាទីស្រឡាញ់ ជាទីពេញចិត្តរបស់អញ គេបានប្រព្រឹត្តនូវហេតុជាប្រយោជន៍ កំពុងប្រព្រឹត្តនូវហេតុជាប្រយោជន៍ នឹងប្រព្រឹត្តនូវហេតុជាប្រយោជន៍ដល់បុគ្គលមិនជាទីស្រឡាញ់ មិនជាទីពេញចិត្តរបស់អញ ដូច្នេះ លោកសង្គ្រោះចូលដោយអាឃាតវត្ថុ ៩ យ៉ាងនេះដូចគ្នា ។

បទថា **អាឃាតិតោ** បានដល់ បៀតបៀនគ្នា ។ បទថា **នវវិធមានេហិ** សេចក្ដីថា មានះ ៩ តើដូចម្ដេច ។ សេចក្ដីប្រកាន់ថា អញប្រសើរជាងគេ សេចក្ដីប្រកាន់ថា អញស្មើនឹងគេ សេចក្ដីប្រកាន់ថា អញថោកទាបជាងគេ សេចក្ដីប្រកាន់នៃបុគ្គលប្រសើរជាងគេថា អញប្រសើរជាងគេ សេចក្ដីប្រកាន់នៃបុគ្គលប្រសើរជាងគេថា អញស្មើនឹងគេ សេចក្ដីប្រកាន់នៃបុគ្គលប្រសើរជាងគេថា អញថោកទាបជាងគេ សេចក្ដីប្រកាន់នៃបុគ្គលស្មើនឹងគេថា អញប្រសើរជាងគេ សេចក្ដីប្រកាន់នៃបុគ្គលស្មើនឹងគេថា អញស្មើនឹងគេ សេចក្ដីប្រកាន់នៃបុគ្គលស្មើនឹងគេថា អញថោកទាបជាងគេ សេចក្ដីប្រកាន់នៃបុគ្គលថោកទាបជាងគេថា អញប្រសើរជាងគេ សេចក្ដីប្រកាន់នៃបុគ្គលថោកទាបជាងគេថា អញស្មើនឹងគេ សេចក្ដីប្រកាន់នៃបុគ្គលថោកទាបជាងគេថា អញថោកទាបជាងគេ ។ មានះមាន ៩ យ៉ាងនេះឯង ។

គប្បីជ្រាបសេចក្ដីក្នុងពាក្យនេះដូចតទៅ មានះថា សេចក្ដីប្រកាន់នៃបុគ្គលប្រសើរជាងគេថា អញប្រសើរជាងគេ រមែងកើតដល់ព្រះរាជា និងបព្វជិតទាំងឡាយ ។ ព្រោះព្រះរាជារមែងទ្រង់ធ្វើមានះនេះថា មាននរណាដូច

អញដោយដែន ទ្រព្យ ឬពាហនៈ ។ សូម្បីបព្វជិតក៏ធ្វើមានះថា មាននរណាដូចអញ ដោយសីល និងធុតង្គជាដើម ។

មានះថា សេចក្ដីប្រកាន់នៃបុគ្គលប្រសើរជាងគេថា អញស្មើនឹងគេ ក៏រមែងកើតដល់ព្រះរាជា និងបព្វជិតទាំងនោះដូចគ្នា ព្រោះថា ព្រះរាជារមែងធ្វើមានះនេះថា អ្វីធ្វើឲ្យអញផ្សេងអំពីព្រះរាជាដទៃដោយដែន ទ្រព្យ ឬពាហនៈ បព្វជិត ក៏ធ្វើមានះនេះថា អ្វីធ្វើឲ្យអញផ្សេងគ្នាអំពីភិក្ខុដទៃដោយគុណ មានសីល និងធុតង្គជាដើម ។

មានះថា សេចក្ដីប្រកាន់នៃបុគ្គលប្រសើរជាងគេថា អញថោកទាបជាងគេ ក៏រមែងកើតដល់ព្រះរាជា និងបព្វជិតទាំងឡាយនោះដូចគ្នា ព្រោះថា ដែន ទ្រព្យ ឬពាហនៈជាដើម របស់ព្រះរាជាណា មិនសូវសម្បូណ៌ ព្រះរាជានោះទ្រង់រមែងធ្វើមានះនេះថា ពាក្យថា ព្រះរាជារបស់អញ ត្រឹមតែជាសេចក្ដីសុខ ព្រោះវាចាប៉ុណ្ណោះ អញជាព្រះរាជាបានដូចម្ដេច សូម្បីបព្វជិតមានលាភសក្ការៈតិចរមែងធ្វើមានះនេះថា វាចាថា អញជាធម្មកថិក ជាពហូសូត្រ ជាមហាថេរត្រឹមតែជាវាចាប៉ុណ្ណោះ អញមិនមានលាភសក្ការៈ ជាធម្មកថិកបានដូចម្ដេច ជាពហូសូត្របានដូចម្ដេច ជាមហាថេរបានដូចម្ដេច ។

មានះថា សេចក្ដីប្រកាន់នៃបុគ្គលស្មើនឹងគេថា អញប្រសើរជាងគេជាដើម រមែងកើតដល់ពួកអមាត្យជាដើម ព្រោះថា អមាត្យក្ដី ខុំរាជការក្ដី រមែងធ្វើមានះនេះថា មានរាជបុរសដទៃណាដូចគ្នានឹងអញដោយភោគៈ យាន និងពាហនៈជាដើម ឬថា អញមានអ្វីធ្វើឲ្យផ្សេងគ្នាពីអ្នកដទៃ ឬថា អញមាន

ឈ្មោះថា ជាអមាត្យប៉ុណ្ណោះ សូម្បីត្រឹមតែរបស់បរិភោគ និងគ្រឿងស្លៀកដណ្តប់របស់អញក៏មិនមាន អញជាអមាត្យបានដូចម្តេច ។

មានះថា សេចក្តីប្រកាន់នៃបុគ្គលថោកទាបជាងគេថា អញប្រសើរជាងគេជាដើម រមែងកើតដល់ពួកទាសៈជាដើម ព្រោះថា ទាសៈរមែងធ្វើមានះនេះថា មានទាសៈដទៃណាដូចអញដោយចំណែកខាងមាតា ឬខាងបិតា អ្នកដទៃមិនអាចចិញ្ចឹមជីវិតបាន ទើបកើតជាទាសៈព្រោះហេតុនៃផ្ទៃ តែអញជាបុគ្គលប្រសើរជាង ព្រោះមកដោយខ្សែស្រឡាយ ឬថា អញមានអ្វីធ្វើឲ្យផ្សេងគ្នាជាមួយទាសៈនោះដោយភាពជាទាសៈសុទ្ធៗ ទាំងពីរចំណែក ព្រោះមកដោយខ្សែស្រឡាយ ឬថា អញដល់ភាពជាទាសៈព្រោះផ្ទៃ តែស្រាវជ្រាវទៅដល់មាតាបិតា ឋានៈជាទាសៈរបស់អញមិនមាន អញ ឈ្មោះថា ជាទាសៈអ្វី ។ សូម្បីអ្នកចាក់សំរាម និងមនុស្សចណ្ឌាលជាដើម ក៏ធ្វើមានះនោះដូចទាសៈដូចគ្នា ។ មយ៉ាងទៀត ក្នុងមានះនេះ មានះដែលកើតឡើងថា ជាអ្នកប្រសើរជាងគេ សម្គាល់ខ្លួនថា ប្រសើរជាងគេ ជាមានះពិតប្រាកដ ។ ពីរពួកដទៃពីនេះជាមានះមិនពិតប្រាកដ ។ មានះដែលកើតឡើងថា ជាអ្នកស្មើគេ សម្គាល់ខ្លួនថា ស្មើគេ ជាអ្នកថោកទាបជាងគេ សម្គាល់ខ្លួនថា ថោកទាបជាងគេ ជាមានះពិតប្រាកដ ។ ពីរពួកក្រៅអំពីនេះជាមានះមិនពិតប្រាកដ ។ ក្នុងមានះទាំងនោះ មានះតាមពិត ទម្លាយបានដោយអរហត្តមគ្គ មានះមិនពិតប្រាកដទម្លាយបានដោយសោតាបត្តិមគ្គ ។

បទថា **តណ្ហាមូលកា** បានពោលហើយ ។ បទថា **រជ្ជតិ** អធិប្បាយ

ថា មិនមែនត្រេកអរដោយរាគៈតែម្យ៉ាងប៉ុណ្ណោះ ដែលពិត រមែងត្រេកអរ រមែងប្រកប រមែងជាប់ជំពាក់ដោយអកុសលធម៌ទាំងអស់ ដែលមានតណ្ហាជាមូល ព្រោះមានការស្វែងរកជាដើម ដែលមានតណ្ហាជាមូល ។

បទថា **ទសហិ កិលេសវត្ថូហិ** សេចក្តីថា **កិលេសវត្ថុ** ១០ តើដូចម្តេច ។ លោភៈ ១ ទោសៈ ១ មោហៈ ១ មានះ ១ ទិដ្ឋិ ១ វិចិកិច្ឆា ១ ថីនៈ ១ ឧទ្ធច្ចៈ ១ អហិរិកៈ ១ អនោត្តប្បៈ ១ ។

ក្នុងបទទាំងនោះកិលេសនោះឯង គឺកិលេសវត្ថុ ឬដែលឈ្មោះថា វត្ថុ ព្រោះអត្ថថា ជាលំនៅរបស់សត្វដែលមិនមែនជាព្រះខីណាស្រព ព្រោះតាំងនៅក្នុងលោភៈជាដើម ឈ្មោះថា **កិលេសវត្ថុ** ព្រោះអត្ថថា កិលេសទាំងនេះផងជាលំនៅរបស់សត្វទាំងឡាយ ដែលតាំងនៅក្នុងកិលេសផង ។ ម្យ៉ាងទៀត ព្រោះកិលេសទាំងឡាយ សូម្បីកើតឡើងដោយភាពជាអនន្តរប្បច្ច័យជាដើមក៏ឈ្មោះថា រមែងនៅដូចគ្នា ហេតុនោះ ទើបឈ្មោះថា **កិលេសវត្ថុ** ព្រោះអត្ថថា ជាទីនៅរបស់កិលេសទាំងឡាយ ។ ឈ្មោះថា **លោភ** ព្រោះអត្ថថា ជាហេតុបាន ឬរមែងបានដោយខ្លួនឯង ឬត្រឹមតែបានប៉ុណ្ណោះ ។ ឈ្មោះថា **ទោស** ព្រោះអត្ថថា ជាហេតុប្រទូស្ត ឬប្រទូស្តដោយខ្លួនឯង ឬត្រឹមតែប្រទូស្តប៉ុណ្ណោះ ។ ឈ្មោះថា **មោហ** ព្រោះអត្ថថា ជាហេតុវង្វេង ឬវង្វេងដោយខ្លួនឯង ឬត្រឹមតែការវង្វេងប៉ុណ្ណោះ ។ ឈ្មោះថា **មាន** ព្រោះអត្ថថា សម្គាល់ ។ បទថា **ទិដ្ឋិ** ជាដើម មានអត្ថដូចពោលហើយនោះឯង ។ ឈ្មោះថា **អហិរិក** ព្រោះអត្ថថា មិនខ្មាស ភាពជាអ្នកមិនខ្មាសនោះ ឈ្មោះថា **អហិរិក** ។ ឈ្មោះថា

**អនោត្តប្បំ** ព្រោះអត្ថថា មិនខ្លាចក្រែង ភាពជាអ្នកមិនខ្លាចក្រែងនោះ ឈ្មោះថា **អនោត្តប្បំ** ។ ក្នុងពីរបទនោះ អហិរិកៈ មានការមិនខ្មាសដោយកាយទុច្ចរិតជាដើមជាលក្ខណៈ ។ អនោត្តប្បៈ មានការមិនខ្លាចដោយកាយទុច្ចរិតជាដើមជាលក្ខណៈ ។

បទថា **កិលិស្សតិ** បានដល់ រមែងដុត រមែងបៀតបៀន ។ បទថា **ទសហិ អាឃាតវត្ថូហិ** អធិប្បាយថា ១០ គឺអាឃាតវត្ថុ ៩ ដែលពោលហើយខាងដើម និងអាឃាតវត្ថុ ១ ដែលពោលបន្ថែមថា ឬថា គំនុំកើតឡើងក្នុងទីមិនគួរ ។ ព្រោះអាឃាត រមែងកើតក្នុងឋានៈដែលមិនសមគួរ មានដង្គត់ និងបន្លាជាដើម មិនចាត់ចូលជាមួយពាក្យជាដើមថា គំនុំកើតឡើងថា ជនឯណោះ បានប្រព្រឹត្តហើយនូវអំពើមិនមានប្រយោជន៍ដល់អញឡើយ ។

បទថា **ទសហិ អកុសលកម្មបថេហិ** អធិប្បាយថា អកុសលកម្មបថ ១០ តើដូចម្តេច ។ បាណាតិបាត ១ អទិន្នាទាន ១ កាមេសុមិច្ឆាចារ ១ មុសាវាទ ១ បិសុណាវាចា ១ ផរុសវាចា ១ សម្ផប្បលាបៈ ១ អភិជ្ឈា ១ ព្យាបាទ ១ មិច្ឆាទិដ្ឋិ ១ ។

ក្នុងពាក្យនោះ ឈ្មោះថា អកុសលកម្មបថ ព្រោះអត្ថថា អកុសលកម្មទាំងនោះផង ជាផ្លូវនៃទុគ្គតិផង ។

បទថា **សមន្នាគតោ** បានដល់ មានការដល់ព្រម ។ បទថា **ទសហិ សញ្ញោជនេហិ** អធិប្បាយថា សញ្ញោជនៈ ១០ តើដូចម្តេច ។ កាមរាគសញ្ញោជនៈ ១ បដិឃសញ្ញោជនៈ ១ មានសញ្ញោជនៈ ១ ទិដ្ឋិសញ្ញោជនៈ

១ វិចិកិច្ឆាសញ្ញោជនៈ ១ សីលព្វតបរាមាសសញ្ញោជនៈ ១ ភវរាគសញ្ញោជនៈ ១ ឥស្សាសញ្ញោជនៈ ១ មច្ឆរិយសញ្ញោជនៈ ១ អវិជ្ជាសញ្ញោជនៈ ១ នេះ សញ្ញោជនៈ ១០ ។

បទថា **មិច្ឆត្តា** បានពោលហើយ ។ បទថា **ទសវត្ថុកាយ មិច្ឆាទិដ្ឋិយា** អធិប្បាយថា មិច្ឆាទិដ្ឋិ**មានវត្ថុ ១០** តើដូចម្តេច ។ ទានដែលបុគ្គល**ឲ្យ**ហើយមិនមានផល ១ ការបូជាធំមិនមានផល ១ ការបូជាតូចមិនមានផល ១ ផលវិបាកនៃកម្មដែលសត្វធ្វើល្អ និងធ្វើអាក្រក់មិនមាន ១ លោកនេះមិនមាន ១ លោកដទៃមិនមាន ១ មាតាមិនមានគុណ ១ បិតាមិនមានគុណ ១ សត្វជា**ឱបបា**តិកកំណើតមិនមាន ១ សមណព្រាហ្មណ៍ទាំងឡាយ ក្នុងលោកអ្នកប្រព្រឹត្តល្អ ប្រតិបត្តិល្អ ដែលបានធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ឧត្តមខ្លួនឯងនូវលោកនេះ និងលោកខាងមុខ ហើយប្រកាសមិនមាន ១ នេះ មិច្ឆាទិដ្ឋិ មានវត្ថុ ១០ ។

ក្នុងពាក្យទាំងនោះ ពាក្យថា មានវត្ថុ ១០ មានវិគ្គហៈថា ឈ្មោះថា មានវត្ថុ ១០ ព្រោះអត្ថថា មិច្ឆាទិដ្ឋិមានវត្ថុ ១០ ។

ពាក្យថា ទានដែលបុគ្គល**ឲ្យ**ហើយមិនមានផល បានដល់ រមែងសន្មតថា ឈ្មោះថា ទានដែលឲ្យហើយមាន បុគ្គលអាចឲ្យរបស់ណាមួយដល់បុគ្គលណាមួយក៏បាន តែបុគ្គលមិច្ឆាទិដ្ឋិ រមែងប្រកាន់ថា វិបាកដែលជាផលរបស់ទានដែលឲ្យហើយមិនមាន ។

ពាក្យថា ការបូជាធំមិនមានផល បានដល់ មហាយាគៈ លោកហៅថា

ការបូជាធំ រមែងសន្មតថា បុគ្គលអាចបូជាធំបាន តែបុគ្គលមិច្ឆាទិដ្ឋិ រមែងប្រកាន់ថា វិបាកដែលជាផលនៃការបូជាធំនោះ រមែងមិនមាន ។

ពាក្យថា ការបូជាតូច បានដល់ ការធ្វើមង្គលដោយការទទួល ។ រមែងសន្មតថា បុគ្គលអាចធ្វើការទទួលនោះបាន តែបុគ្គលមិច្ឆាទិដ្ឋិ រមែងប្រកាន់ថា វិបាកដែលជាផលនៃការបូជានោះមិនមាន ។

ក្នុងពាក្យថា ដែលសត្វធ្វើល្អ ធ្វើអាក្រក់នេះ កុសលកម្មបថ ១០ ឈ្មោះថា កម្មល្អ អកុសលកម្មបថ ១០ ឈ្មោះថា កម្មអាក្រក់ ។ បុគ្គលរមែងដឹងភាពដែលកម្មទាំងនោះមាន ។ តែបុគ្គលមិច្ឆាទិដ្ឋិរមែងប្រកាន់ថា វិបាកដែលជាផលមិនមាន ។

ពាក្យថា លោកនេះមិនមាន បានដល់ បុគ្គលដែលតាំងនៅក្នុងលោកដទៃ រមែងប្រកាន់នូវលោកនេះថា មិនមាន ។

ពាក្យថា លោកដទៃមិនមាន បានដល់ បុគ្គលដែលតាំងនៅក្នុងលោកនេះ រមែងប្រកាន់នូវលោកដទៃថា មិនមាន ។

ពាក្យថា មាតាមិនមានគុណ បិតាមិនមានគុណ បានដល់ រមែងសន្មតថា មាតាបិតាមាន តែបុគ្គលមិច្ឆាទិដ្ឋិរមែងប្រកាន់ថា វិបាកណាមួយដែលជាផល ព្រោះកម្មដែលខ្លួនធ្វើហើយ ក្នុងមាតាបិតាទាំងនោះជាបច្ច័យ រមែងមិនមាន ។

ពាក្យថា សត្វជាឱបបាតិកកំណើតមិនមាន បានដល់ រមែងប្រកាន់ថា សត្វ ( ឱបបាតិកៈ ) ចុតិ និងកើត មិនមាន ។

ពាក្យថា អ្នកប្រព្រឹត្តល្អ ប្រតិបត្តិល្អ បានដល់ រមែងប្រកាន់ថា សមណព្រាហ្មណ៍ អ្នកតាំងនៅក្នុងធម៌ បដិបត្តិបដិបទាដែលសមគួរ មិនមានក្នុងលោក ។

ពាក្យថា ដែលបានធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ឧត្តមខ្លួនឯងនូវលោកនេះ និងលោកខាងមុខ ហើយប្រកាស បានដល់ រមែងប្រកាន់ថា ព្រះពុទ្ធដែលជាសព្វញ្ញូ អាចដឹងលោកនេះ និងលោកខាងមុខ ដោយព្រះញាណដ៏ប្រសើរ ដោយព្រះអង្គឯង ហើយទ្រង់ប្រកាស មិនមាន ។

បទថា **អន្តគ្គាហិកាយ ទិដ្ឋិយា** មានវិគ្គហៈថា ឈ្មោះថា អន្តគ្គាហិកៈ ព្រោះអត្ថថា កាន់យកទីបំផុតឯណាទីមួយ មានលោកទៀងជាដើម ។ម្យ៉ាងទៀត ការកាន់យកនូវទីបំផុត ឈ្មោះថា អន្តគ្គាហៈ ។ ទិដ្ឋិមានការកាន់យកទីបំផុត ព្រោះហេតុនោះ ទើបឈ្មោះថា អន្តគ្គាហិកៈ ។ ដោយការកាន់យកទីបំផុតនោះ ។ អន្តគ្គាហិកទិដ្ឋិនោះ បានពោលហើយ ។

បទថា **អដ្ឋសតតណ្ហាបបញ្ចសតំ** អធិប្បាយថា ១០០ លើស ៨ ឈ្មោះថា ១០៨ ឈ្មោះថា **បបញ្ចៈ** ព្រោះឲ្យយឺតយូរក្នុងសង្សារវដ្ត គឺឲ្យនៅយូរ ។ គ្រឿងឲ្យយឺតយូរ គឺតណ្ហា ឈ្មោះថា តណ្ហាបបញ្ចៈ ។ តណ្ហាគ្រឿងឲ្យយឺតយូរ ១០០ លោកធ្វើឲ្យជាពហុវចនៈ ព្រោះតណ្ហាមានច្រើនដោយប្រភេទនៃអារម្មណ៍ និងដោយការកើតឡើងរឿយៗ ទើបឈ្មោះថា **តណ្ហាបបញ្ចសតំ** ដោយហេតុនោះ កាលគួរនឹងពោលថា **តណ្ហាបបញ្ចសតេន** ដោយការឃ្លៀងឃ្លាតរបស់វចនៈ ទើបលោកធ្វើនិទ្ទេសជាពហុវចនៈថា **តណ្ហាបបញ្ចសតេហិ** ។

គប្បីឃើញអត្ថថា ដោយតណ្ហាគ្រឿងឲ្យឃើតយូរ ១០០ គឺ ១០៨ ។ គប្បីជ្រាបថា លោកកាន់យក ១០០ ប៉ុណ្ណោះ ព្រោះធ្វើ ៨ ជាអព្វោហារិកៈ ( គឺមានដូចមិនមាន ) ពាក្យថា តណ្ហាវិចរិតមកក្នុងខុទ្ទកវត្ថុវិភង្គ ដូចព្រះមានព្រះភាគ ត្រាស់ថា តណ្ហាវិចរិត ( ការប្រព្រឹត្តនៃតណ្ហា ) ១៨ អាស្រ័**យខន្ធ**-បញ្ចកៈខាងក្នុង តណ្ហាវិចរិត ១៨ អាស្រ័យខន្ធបញ្ចកៈខាងក្រៅ ត្រូវជាតណ្ហាវិចរិត ៣៦ ព្រោះប្រមូលរួបរួមតណ្ហាវិចរិតទាំង ២ ពួកនោះក្នុងទីជាមួយគ្នា តណ្ហាវិចរិតជាអតីត ៣៦ តណ្ហាវិចរិតជាអនាគត ៣៦ តណ្ហាវិចរិតជាបច្ចុប្បន្ន ៣៦ ត្រូវជាតណ្ហាវិចរិត ១០៨ ដូច្នេះ ។

ម្យ៉ាងទៀត ក្នុងខុទ្ទកវត្ថុវិភង្គនេះ លោកពោលតណ្ហាជាគ្រឿងឲ្យឃើតយូរនោះថា តណ្ហាវិចរិត អធិប្បាយថា ការផ្សាយទៅនៃតណ្ហា គឺការប្រព្រឹត្តនៅនៃតណ្ហា ។

ពាក្យថា អាស្រ័យខន្ធបញ្ចកៈខាងក្នុង បានដល់ អាស្រ័យខន្ធ ៥ ដែលជាខាងក្នុង ។ ពាក្យនេះជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថនៃទុតិយាវិភត្តិ ។ ចំណែកសេចក្ដីពិស្តាររបស់ពាក្យនោះ គប្បីជ្រាបដោយន័យដូចពោលហើយ ក្នុងនិទ្ទេសនៃខុទ្ទកវត្ថុវិភង្គនោះ ។ តែក្នុងនិទ្ទេសនេះ គប្បីជ្រាបន័យយ៉ាងដទៃតទៅថា តណ្ហា ៣ គឺកាមតណ្ហា ១ ភវតណ្ហា ១ វិភវតណ្ហា ១ មានរូបជាអារម្មណ៍តែម្យ៉ាង ដែលមានសំឡេងជាដើម ជាអារម្មណ៍ក៏ដូចគ្នា ព្រោះហេតុនោះ ក្នុងអារម្មណ៍ ៦ ទើបជាតណ្ហា ១៨ តណ្ហាមានអារម្មណ៍ខាងក្នុង ១៨ ខាងក្រៅ ១៨ រួមជាតណ្ហា ៣៦ តណ្ហាទាំងនោះ មានអារម្មណ៍ក្នុងអតីត ៣៦ អារម្មណ៍ក្នុង

អនាគត ៣៦ អារម្មណ៍ក្នុងបច្ចុប្បន្ន ៣៦ រួមជាតណ្ហាវិចរិត ១០៨ ។

បទថា **បបញ្ចិតោ** បានដល់ ត្រូវយឺតយូរនៅយូរក្នុងអារម្មណ៍ ឬក្នុងសង្សារវដ្ត ។

បទថា **ទ្វាសដ្ឋិយា ទិដ្ឋិគតេហិ** អធិប្បាយថា ទិដ្ឋិ ៦២ តើដូចម្តេច ។ ( ទិដ្ឋិ ៦២ ) ដែលព្រះមានព្រះភាគសម្តែងហើយ ក្នុងវេយ្យាករណ៍ឈ្មោះព្រហ្មជាលសូត្រ គឺសស្សតវាទ ៤ ឯកច្ចសស្សតវាទ ៤ អន្តានន្តិកវាទ ៤ អមរាវិក្ខេបិកវាទ ៤ អធិច្ចសមុប្បន្និកវាទ ២ សញ្ញិវាទ ១៦ អសញ្ញិវាទ ៨ នេវសញ្ញីនាសញ្ញីវាទ ៨ ឧច្ឆេទវាទ ៧ ទិដ្ឋធម្មនិព្វានវាទ ៥ នេះទិដ្ឋិ ៦២ ដែលព្រះមានព្រះភាគសម្តែងហើយក្នុងវេយ្យាករណ៍ ឈ្មោះព្រហ្មជាលសូត្រ ។ ចំណែកសេចក្តីពិស្តារក្នុងនិទ្ទេសនេះ គប្បីជ្រាបដោយន័យដែលត្រាស់ហើយ ក្នុងព្រហ្មជាលសូត្រនោះឯង ។

បទថា **អហាញ្ហម្មិ តិណ្ណោ** បានដល់ តថាគតជាអ្នកឆ្លងឱឃៈ ៤ ឬសមុទ្ទ គឺសង្សារវដ្តបានហើយ ។ បទថា **មុត្តោ** បានដល់ ផុតចាកចំណង គឺរាគៈជាដើម ។ បទថា **ទន្តោ** បានដល់ អស់ព្យសន៍ មិនអន្ទះអន្ទែងហើយ ។ បទថា **សន្តោ** បានដល់ មានសេចក្តីត្រជាក់ ។ បទថា **អស្សាត្ថោ** បានដល់ បាននូវការក្សេម ព្រោះឃើញនិព្វាន ។

បទថា **បរិនិព្វុតោ** បានដល់ រលត់ដោយការរលត់កិលេស ។ បទថា **បហោមិ** បានដល់ ជាអ្នកអាច ។ បទថា **ខោ** ជានិបាត ចុះក្នុងអត្ថនៃឯកំសៈ គឺចំណែកមួយ ។

សព្ទថា **បរេ ច** ក្នុងបទថា **បរេ ច បរិនិព្វាបេតុំ** គប្បីប្រកបជាមួយបទជាដើមថា **បរេ ច តារេតុំ** ( នឹងជួយឲ្យសត្វលោកឆ្លងបានផង ) ។៙

**អដ្ឋកថាមហាករុណាញាណនិទ្ទេស ចប់**

# សុត្តន្តបិដក

[ ២៨៦ ] សព្វញ្ញុតញ្ញាណរបស់ព្រះតថាគត តើដូចម្តេច ។ ព្រះតថាគត ទ្រង់ជ្រាបសង្ខតធម៌ និងអសង្ខតធម៌ទាំងអស់មិនមានសេសសល់ ហេតុនោះ ឈ្មោះថា សព្វញ្ញុតញ្ញាណ គ្រឿងរាំងក្នុងញាណនោះមិនមាន ហេតុនោះ ឈ្មោះថា អនាវរណញ្ញាណ ព្រះតថាគត ទ្រង់ជ្រាបសព្វនូវហេតុជាអនាគត ហេតុនោះ ឈ្មោះថា សព្វញ្ញុតញ្ញាណ គ្រឿងរាំងក្នុងញាណនោះមិនមាន ហេតុនោះ ឈ្មោះថា អនាវរណញ្ញាណ ព្រះតថាគតទ្រង់ជ្រាបសព្វនូវហេតុជា អតីត ហេតុនោះឈ្មោះថា សព្វញ្ញុតញ្ញាណ គ្រឿងរាំងក្នុងញាណនោះមិន មាន ហេតុនោះឈ្មោះថា អនាវរណញ្ញាណ ព្រះតថាគតទ្រង់ជ្រាបសព្វនូវ ហេតុជាបច្ចុប្បន្ន ហេតុនោះឈ្មោះថា សព្វញ្ញុតញ្ញាណ គ្រឿងរាំងក្នុងញាណ នោះមិនមាន ហេតុនោះឈ្មោះថា អនាវរណញ្ញាណ ភ្នែក និងរូប ( យ៉ាង ណា ) ព្រះតថាគតទ្រង់ជ្រាបសព្វនូវធម៌នោះយ៉ាងនោះដែរ ហេតុនោះឈ្មោះ ថា សព្វញ្ញុតញ្ញាណ គ្រឿងរាំងក្នុងញាណនោះមិនមាន ហេតុនោះឈ្មោះ ថា អនាវរណញ្ញាណ ត្រចៀក និងសំឡេង ។បេ។ ច្រមុះ និងក្លិន អណ្តាត និងរស កាយ និងសម្ផស្ស ចិត្ត និងធម្មារម្មណ៍ យ៉ាងណា ព្រះតថាគត ទ្រង់ជ្រាបសព្វនូវធម៌នោះទាំងអស់យ៉ាងនោះដែរ ហេតុនោះឈ្មោះថា សព្វញ្ញុ-តញ្ញាណ គ្រឿងរាំងក្នុងញាណនោះមិនមាន ហេតុនោះឈ្មោះថា អនាវរណញ្ញាណ ។

[ ២៨៧ ] ព្រះតថាគត ទ្រង់ជ្រាបសព្វនូវអត្ថនៃអនិច្ចធម៌ នូវអត្ថនៃទុក្ខធម៌ នូវអត្ថនៃអនត្តធម៌ទាំងប៉ុន្មាន ហេតុនោះឈ្មោះថា សព្វញ្ញុតញ្ញាណ គ្រឿង

រារាំងក្នុងញាណនោះមិនមាន ហេតុនោះឈ្មោះថា អនាវរណញ្ញាណ ព្រះតថាគតទ្រង់ជ្រាបសព្វនូវអត្ថនៃអនិច្ចធម៌ នូវអត្ថនៃទុក្ខធម៌ នូវអត្ថនៃអនត្តធម៌ របស់រូបទាំងប៉ុន្មាន ហេតុនោះឈ្មោះថា សព្វញ្ញុតញ្ញាណ គ្រឿងរារាំងក្នុងញាណនោះមិនមាន ហេតុនោះឈ្មោះថា អនាវរណញ្ញាណ ព្រះតថាគតទ្រង់ជ្រាបសព្វនូវអត្ថនៃអនិច្ចធម៌ នូវអត្ថនៃទុក្ខធម៌ នូវអត្ថនៃអនត្តធម៌របស់វេទនាទាំងប៉ុន្មាន របស់សញ្ញាទាំងប៉ុន្មាន របស់សង្ខារទាំងប៉ុន្មាន របស់វិញ្ញាណទាំងប៉ុន្មាន របស់ចក្ខុទាំងប៉ុន្មាន ។បេ។ របស់ជរាមរណៈទាំងប៉ុន្មាន ហេតុនោះឈ្មោះថា សព្វញ្ញុតញ្ញាណ គ្រឿងរារាំងក្នុងញាណនោះមិនមាន ហេតុនោះឈ្មោះថា អនាវរណញ្ញាណ ។

[ ២៨៨ ] ព្រះតថាគត ទ្រង់ជ្រាបសព្វនូវអត្ថនៃការដឹងច្បាស់ របស់អភិញ្ញាទាំងប៉ុន្មាន ហេតុនោះឈ្មោះថា សព្វញ្ញុតញ្ញាណ គ្រឿងរារាំងក្នុងញាណនោះមិនមាន ហេតុនោះឈ្មោះថា អនាវរណញ្ញាណ ព្រះតថាគតទ្រង់ជ្រាបសព្វនូវអត្ថនៃការកំណត់ដឹង របស់បរិញ្ញាទាំងប៉ុន្មាន នូវអត្ថនៃការលះបង់របស់បហានទាំងប៉ុន្មាន នូវអត្ថនៃការចម្រើនរបស់ភាវនាទាំងប៉ុន្មាន នូវអត្ថនៃការធ្វើឲ្យជាក់ច្បាស់របស់សច្ឆិកិរិយាទាំងប៉ុន្មាន ហេតុនោះឈ្មោះថា សព្វញ្ញុតញ្ញាណ គ្រឿងរារាំងក្នុងញាណនោះមិនមាន ហេតុនោះឈ្មោះថា អនាវរណញ្ញាណ ព្រះតថាគត ទ្រង់ជ្រាបសព្វនូវអត្ថនៃគំនររបស់ខន្ធទាំងប៉ុន្មាន ហេតុនោះឈ្មោះថា សព្វញ្ញុតញ្ញាណ គ្រឿងរារាំងក្នុងញាណនោះ មិនមាន ហេតុនោះឈ្មោះថា អនាវរណញ្ញាណ ព្រះតថាគតទ្រង់ជ្រាបសព្វនូវអត្ថនៃ

ធាតុរបស់ធាតុទាំងប៉ុន្មាន នូវអត្ថនៃអាយតនៈរបស់អាយតនៈទាំងប៉ុន្មាន នូវអត្ថនៃសង្ខតធម៌ របស់សង្ខតធម៌ទាំងប៉ុន្មាន នូវអត្ថនៃអសង្ខតធម៌របស់អសង្ខតធម៌ទាំងប៉ុន្មាន ហេតុនោះឈ្មោះថា សព្វញ្ញុតញ្ញាណ គ្រឿងរារាំងក្នុងញាណនោះមិនមាន ហេតុនោះឈ្មោះថា អនាវរណញ្ញាណ ។

[ ២៨៩ ] ព្រះតថាគត ទ្រង់ជ្រាបសព្វនូវកុសលធម៌ទាំងប៉ុន្មាន ហេតុនោះឈ្មោះថា សព្វញ្ញុតញ្ញាណ គ្រឿងរារាំងក្នុងញាណនោះមិនមាន ហេតុនោះឈ្មោះថា អនាវរណញ្ញាណ ព្រះតថាគតទ្រង់ជ្រាបសព្វនូវអកុសលធម៌ទាំងប៉ុន្មាន នូវអព្យាកតធម៌ទាំងប៉ុន្មាន នូវកាមាវចរធម៌ទាំងប៉ុន្មាន នូវរូបាវចរធម៌ទាំងប៉ុន្មាន នូវអរូបាវចរធម៌ទាំងប៉ុន្មាន នូវអបរិយាបន្នធម៌ទាំងប៉ុន្មាន ហេតុនោះឈ្មោះថា សព្វញ្ញុតញ្ញាណ គ្រឿងរារាំងក្នុងញាណនោះមិនមាន ហេតុនោះឈ្មោះថា អនាវរណញ្ញាណ ព្រះតថាគតទ្រង់ជ្រាបសព្វនូវអត្ថនៃទុក្ខរបស់ទុក្ខសច្ចទាំងប៉ុន្មាន ហេតុនោះឈ្មោះថា សព្វញ្ញុតញ្ញាណ គ្រឿងរារាំងក្នុងញាណនោះមិនមាន ហេតុនោះឈ្មោះថា អនាវរណញ្ញាណ ព្រះតថាគតទ្រង់ជ្រាបសព្វនូវអត្ថនៃសមុទ័យរបស់សមុទយសច្ចទាំងប៉ុន្មាន នូវអត្ថនៃនិរោធរបស់និរោធសច្ចទាំងប៉ុន្មាន នូវអត្ថនៃមគ្គរបស់មគ្គសច្ចទាំងប៉ុន្មាន ហេតុនោះឈ្មោះថា សព្វញ្ញុតញ្ញាណ គ្រឿងរារាំងក្នុងញាណនោះមិនមាន ហេតុនោះឈ្មោះថា អនាវរណញ្ញាណ ។

[ ២៩០ ] ព្រះតថាគត ទ្រង់ជ្រាបសព្វនូវអត្ថនៃការបែកធ្លាយអត្ថ របស់អត្ថប្បដិសម្ភិទាទាំងប៉ុន្មាន ហេតុនោះឈ្មោះថា សព្វញ្ញុតញ្ញាណ ។បេ។ ព្រះ

តថាគតទ្រង់ជ្រាបសព្វនូវអត្ថនៃការបែកធ្លាយធម៌ របស់ធម្មប្បដិសម្ភិទាទាំងប៉ុន្មាន នូវអត្ថនៃការបែកធ្លាយនិរុត្តិរបស់និរុត្តិប្បដិសម្ភិទាទាំងប៉ុន្មាន នូវអត្ថនៃការបែកធ្លាយបដិភាណរបស់បដិភាណប្បដិសម្ភិទាទាំងប៉ុន្មាន ហេតុនោះឈ្មោះថា សព្វញ្ញុតញ្ញាណ គ្រឿងរាំងក្នុងញាណនោះមិនមាន ហេតុនោះឈ្មោះថា អនាវរណញ្ញាណ ព្រះតថាគតទ្រង់ជ្រាបសព្វនូវឥន្ទ្រិយបរោបរិយត្តញ្ញាណទាំងប៉ុន្មាន ហេតុនោះឈ្មោះថា សព្វញ្ញុតញ្ញាណ គ្រឿងរាំងក្នុងញាណនោះមិនមាន ហេតុនោះឈ្មោះថា អនាវរណញ្ញាណ ព្រះតថាគតទ្រង់ជ្រាបសព្វនូវសត្តាសយានុសយញ្ញាណទាំងប៉ុន្មាន នូវយមកប្បាដិហិរញ្ញាណទាំងប៉ុន្មាន នូវមហាករុណាសមាបត្តិញ្ញាណទាំងប៉ុន្មាន ហេតុនោះឈ្មោះថា សព្វញ្ញុតញ្ញាណ គ្រឿងរាំងក្នុងញាណនោះមិនមាន ហេតុនោះឈ្មោះថា អនាវរណញ្ញាណ ។

[ ២៩១ ] ព្រះតថាគត ទ្រង់ជ្រាបសព្វដោយព្រះហឫទ័យនូវអារម្មណ៍ ដែលលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ដែលពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេសទាំងប៉ុន្មាន បានឃើញ ឮ ពាល់ត្រូវ ដឹង សម្រេច ស្វែងរក ត្រាច់រង្គាត់តាមហើយ ព្រោះហេតុនោះ ឈ្មោះថាសព្វញ្ញុតញ្ញាណ គ្រឿងរាំងក្នុងញាណនោះមិនមាន ហេតុនោះឈ្មោះថា អនាវរណញ្ញាណ ។

របស់អ្វីមួយក្នុងលោកនេះ ដែលព្រះតថាគតនោះ មិនឃើញ
ហើយ មិនមានឡើយ មួយទៀត របស់ណាដែលគេគប្បី

ដឹងហើយ តែសត្វលោកមិនដឹង មិនស្គាល់ ព្រះតថាគតទ្រង់ជ្រាបច្បាស់នូវរបស់នោះទាំងអស់ ហេតុនោះ ទើបឈ្មោះថា សមន្តចក្ខុ ។

[ ២៩២ ] សំណួរត្រង់ពាក្យថា សមន្តចក្ខុ តើសមន្តចក្ខុ ដោយអត្ថដូចម្តេច ។ ពុទ្ធញ្ញាណ ១៤ គឺទុក្ខញ្ញាណ ឈ្មោះថា ពុទ្ធញ្ញាណ ១ ទុក្ខសមុទយញ្ញាណ ឈ្មោះថា ពុទ្ធញ្ញាណ ១ ទុក្ខនិរោធញ្ញាណ ឈ្មោះថា ពុទ្ធញ្ញាណ ១ ទុក្ខនិរោធគាមិនីបដិបទាញ្ញាណ ឈ្មោះថា ពុទ្ធញ្ញាណ ១ អត្ថប្បដិសម្ភិទាញ្ញាណ ឈ្មោះថាពុទ្ធញ្ញាណ ១ ធម្មប្បដិសម្ភិទាញ្ញាណ ឈ្មោះថាពុទ្ធញ្ញាណ ១ និរុត្តិប្បដិសម្ភិទាញ្ញាណ ឈ្មោះថា ពុទ្ធញ្ញាណ ១ បដិភាណប្បដិសម្ភិទាញ្ញាណ ឈ្មោះថា ពុទ្ធញ្ញាណ ១ ឥន្ទ្រិយបរោបរិយត្តញ្ញាណ ឈ្មោះថា ពុទ្ធញ្ញាណ ១ សត្តាសយានុសយញ្ញាណ ឈ្មោះថា ពុទ្ធញ្ញាណ ១ យមកប្បាដិហិរញ្ញាណ ឈ្មោះថា ពុទ្ធញ្ញាណ ១ មហាករុណាសមាបត្តិញ្ញាណ ឈ្មោះថា ពុទ្ធញ្ញាណ ១ សព្វញ្ញុតញ្ញាណ ឈ្មោះថា ពុទ្ធញ្ញាណ ១ អនាវរណញ្ញាណ ឈ្មោះថា ពុទ្ធញ្ញាណ ១ ទាំង ១៤ នេះឈ្មោះថា ពុទ្ធញ្ញាណ បណ្តាពុទ្ធញ្ញាណទាំង ១៤ នេះញាណ ៨ ខាងដើមទូទៅដល់ពួកសាវ័ក ឯញាណ ៦ ( ខាងចុង ) មិនទូទៅដល់ពួកសាវ័កឡើយ ។

[ ២៩៣ ] អត្ថនៃទុក្ខរបស់ទុក្ខសច្ចទាំងប៉ុន្មាន ព្រះតថាគតទ្រង់ជ្រាបសព្វហើយ អត្ថនៃទុក្ខ ឈ្មោះថា ព្រះតថាគតមិនជ្រាប មិនមានឡើយ ហេតុនោះ ឈ្មោះថា សព្វញ្ញុតញ្ញាណ គ្រឿងរារាំងក្នុងញាណនោះមិនមាន ហេតុ

នោះ ឈ្មោះថា អនាវរណញ្ញាណ អត្ថនៃទុក្ខរបស់ទុក្ខសច្ចទាំងប៉ុន្មាន ព្រះតថាគតទ្រង់ជ្រាបសព្វហើយ ឃើញសព្វហើយ ដឹងច្បាស់សព្វហើយ ធ្វើឲ្យជាក់ច្បាស់សព្វហើយ ពាល់ត្រូវសព្វហើយដោយប្រាជ្ញា អត្ថនៃទុក្ខ ឈ្មោះថា ព្រះតថាគតមិនពាល់ត្រូវហើយដោយប្រាជ្ញា មិនមានឡើយ ហេតុនោះ ឈ្មោះថា សព្វញ្ញុតញ្ញាណ គ្រឿងរារាំងក្នុងញាណនោះមិនមាន ហេតុនោះ ឈ្មោះថា អនាវរណញ្ញាណ អត្ថនៃសមុទ័យរបស់សមុទយសច្ចទាំងប៉ុន្មាន អត្ថនៃនិរោធរបស់និរោធសច្ចទាំងប៉ុន្មាន អត្ថនៃមគ្គរបស់មគ្គសច្ចទាំងប៉ុន្មាន អត្ថនៃការបែកធ្លាយនូវអត្ថរបស់អត្ថប្បដិសម្ភិទាទាំងប៉ុន្មាន អត្ថនៃការបែកធ្លាយធម៌របស់ធម្មប្បដិសម្ភិទាទាំងប៉ុន្មាន អត្ថនៃការបែកធ្លាយនិរុត្តិរបស់និរុត្តិប្បដិសម្ភិទាទាំងប៉ុន្មាន អត្ថនៃការបែកធ្លាយបដិភាណរបស់បដិភាណប្បដិសម្ភិទាទាំងប៉ុន្មាន ព្រះតថាគតទ្រង់ជ្រាបសព្វហើយ ឃើញសព្វហើយ ដឹងច្បាស់សព្វហើយ ធ្វើឲ្យជាក់ច្បាស់សព្វហើយ ពាល់ត្រូវសព្វហើយដោយប្រាជ្ញា អត្ថនៃការបែកធ្លាយបដិភាណ ឈ្មោះថា ព្រះតថាគតមិនពាល់ត្រូវហើយដោយប្រាជ្ញាមិនមានឡើយ ហេតុនោះ ឈ្មោះថា សព្វញ្ញុតញ្ញាណ គ្រឿងរារាំងក្នុងញាណនោះមិនមាន ហេតុនោះឈ្មោះថា អនាវរណញ្ញាណ ឥន្ទ្រិយបរោបរិយត្តញ្ញាណទាំងប៉ុន្មាន សត្តាសយានុសយញ្ញាណទាំងប៉ុន្មាន យមកប្បាដិហិរញ្ញាណទាំងប៉ុន្មាន មហាករុណាសមាបត្តិញ្ញាណទាំងប៉ុន្មាន ព្រះតថាគត ទ្រង់ជ្រាបសព្វហើយ ឃើញសព្វហើយ ដឹងច្បាស់សព្វហើយ ធ្វើឲ្យជាក់ច្បាស់សព្វហើយ ពាល់ត្រូវសព្វហើយដោយប្រាជ្ញា មហាករុណាសមាបត្តិញ្ញាណ ឈ្មោះថា ព្រះ

តថាគត មិនពាល់ត្រូវហើយដោយប្រាជ្ញាមិនមានឡើយ ហេតុនោះ ឈ្មោះថា សព្វញ្ញុតញ្ញាណ គ្រឿងរារាំងក្នុងញាណនោះមិនមាន ហេតុនោះ ឈ្មោះថា អនាវរណញ្ញាណ របស់អ្វីមួយដែលសត្វ លោកព្រមទាំងទេវលោក មារលោក ព្រហ្មលោក ដែលពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេសទាំងប៉ុន្មាន ឃើញហើយ ឮហើយ ពាល់ត្រូវហើយ ដឹង ហើយ សម្រេចហើយ ស្វែងរកហើយ ត្រាច់រង្គាត់តាមហើយ ព្រះតថាគត ទ្រង់ជ្រាបសព្វហើយ ឃើញសព្វហើយ ជ្រាបច្បាស់សព្វហើយ ធ្វើឲ្យជាក់ ច្បាស់សព្វហើយ ពាល់ត្រូវសព្វហើយដោយប្រាជ្ញា របស់អ្វីមួយ ឈ្មោះថា ព្រះតថាគត មិនពាល់ត្រូវដោយប្រាជ្ញាមិនមានឡើយ ហេតុនោះ ឈ្មោះថា សព្វញ្ញុតញ្ញាណ គ្រឿងរារាំងក្នុងញាណនោះមិនមាន ព្រោះហេតុនោះ ឈ្មោះថា អនាវរណញ្ញាណ ។

របស់អ្វីមួយក្នុងលោកនេះ ដែលព្រះតថាគតនោះមិនឃើញ
ហើយមិនមានឡើយ មួយទៀត របស់ណាដែលគេគប្បីដឹង តែ
សត្វលោកមិនដឹង មិនស្គាល់ ព្រះតថាគតទ្រង់ជ្រាបច្បាស់នូវ
របស់នោះទាំងអស់ ហេតុនោះ ទើបឈ្មោះថា សមន្តចក្ខុ ។

## ញាណកថា ចប់

# អដ្ឋកថា

## សព្វញ្ញុតញ្ញាណនិទ្ទេស

[ ២៨៦ ] គប្បីជ្រាបវិនិច្ឆ័យ ក្នុងសព្វញ្ញុតញ្ញាណនិទ្ទេសដូចតទៅ ព្រះសារីបុត្តត្ថេរសួរថា ព្រះសព្វញ្ញុតញ្ញាណរបស់ព្រះតថាគត តើដូចម្តេច ហើយសម្តែងអនាវរណញ្ញាណ មួយអន្លើដោយសព្វញ្ញុតញ្ញាណនោះឯង ព្រោះមានគតិស្មើគ្នាដោយសព្វញ្ញុតញ្ញាណនោះ ។

ពិតហើយ អនាវរណញ្ញាណ ពោលដោយធម៌មិនបានចែកចេញដោយឡែក ព្រោះញាណនេះមួយប៉ុណ្ណោះលោកពោលឲ្យជា ២ ដោយប្រភេទនៃអាការ ដូចសទ្ធិន្ទ្រិយ និងសទ្ធាពលជាដើម ។ ព្រះសព្វញ្ញុតញ្ញាណនោះឯង លោកពោលថា អនាវរណៈ ព្រោះអត្ថថា ញាណមិនមានគ្រឿងរារាំង ព្រោះធម៌ណាមួយ ឬបុគ្គលណាមួយមិនអាចធ្វើការរារាំងបាន ព្រោះធម៌ទាំងពួងជាប់ទាក់ទងដោយការនឹករាវរក តែបុគ្គលដទៃសូម្បីនឹករាវរកហើយ ក៏ដឹងមិនបាន ។ ចំណែកអាចារ្យពួកខ្លះពោលថា ឈ្មោះថា សព្វញ្ញុតញ្ញាណ ព្រោះប្រព្រឹត្តទៅក្នុងអារម្មណ៍ទាំងពួងដូចមនោវិញ្ញាណ ។ សព្វញ្ញុតញ្ញាណនោះឯង ជាអនា-វរណញ្ញាណ ព្រោះមិនមានអ្វីរាំងក្នុងអារម្មណ៍ទាំងឡាយ ដូចវជិរាវុធរបស់ព្រះឥន្ទ ។ ព្រះសព្វញ្ញុតញ្ញាណ បដិសេធការដឹងវត្ថុទាំងពួងតាមលំដាប់ ។ អនាវរណញ្ញាណ បដិសេធការដឹងវត្ថុទាំងពួងម្តង ព្រះមានព្រះភាគដែលបណ្ឌិតហៅថាសព្វញ្ញូ ព្រោះការបានសព្វញ្ញុតញ្ញាណ មិនហៅថាអនុបុព្វសព្វញ្ញូ ( ដឹងវត្ថុទាំងពួងតាមលំដាប់ ) ។ ហៅថា សព្វញ្ញូ ព្រោះការបានអនាវរ-

ណញ្ញាណ មិនហៅថា **សក៏ សព្វញ្ញូ** ( ដឹងវត្ថុទាំងពួងមួង ) ។

បទថា **សព្វំ** ក្នុងបទនេះថា **សព្វំ សង្ខតមសង្ខតំ អនវសេសំ ជានាតិ** ជាពាក្យកាន់យកការមិនមានចំណែកសេសសល់នៃធម៌ទាំងពួងដោយជាតិ ។

បទថា **អនវសេសំ** ជាពាក្យកាន់យកសេចក្តីមិនមានចំណែកសេសសល់នៃធម៌នីមួយៗ ដោយអំណាចអាការទាំងពួង ។

បទថា **សង្ខតមសង្ខតំ** ជាបទសម្តែងប្រភេទ ២ យ៉ាង ព្រោះសង្ខតៈជាប្រភេទមួយ អសង្ខតៈជាប្រភេទមួយ ។ ខន្ធ ៥ ជាសង្ខតៈ ព្រោះបច្ច័យប្រជុំតាក់តែង ។ និព្វានជាអសង្ខតៈ ព្រោះបច្ច័យមិនប្រជុំតាក់តែងយ៉ាងនោះ ។ រមែងដឹងសង្ខតៈមិនមានចំណែកសល់ដោយអាការ មានការមិនទៀង ជាទុក្ខជាអនត្តាជាដើម ។ រមែងដឹងអសង្ខតៈ មិនមានចំណែកសល់ដោយអាការមានសុញ្ញតៈ អនិមិត្ត និងអប្បណិហិតជាដើម ។ ឈ្មោះថា **អនវសេសំ** ព្រោះមិនមានសង្ខតៈ និងអសង្ខតៈសេសសល់ ។ នូវសង្ខតៈ និងអសង្ខតៈ ( នោះ ) ។ បញ្ញត្តិសូម្បីច្រើនប្រភេទ រមែងចូលខាងចំណែកអសង្ខតៈ ព្រោះបច្ច័យមិនបានតាក់តែង ។ ពិតហើយ សព្វញ្ញុតញ្ញាណរមែងដឹងបញ្ញត្តិទាំងពួងដោយប្រភេទមិនមែនតិច ។ ម្យ៉ាងទៀត បទថា **សព្វំ** ជាពាក្យកាន់យកធម៌ទាំងអស់ ។ បទថា **អនវសេសំ** ជាពាក្យកាន់យកដោយមិនមានចំណែកសល់ ។

បទថា **តត្ថ អាវរណំ នត្ថិ** សេចក្តីថា គ្រឿងរាំងសព្វញ្ញុតញ្ញាណមិនមាន ព្រោះមិនមានគ្រឿងជាប់ជំពាក់ ក្នុងសង្ខតៈ និងអសង្ខតៈដែលមិនមានចំណែកសល់នោះ ព្រោះហេតុនោះ ទើបសព្វញ្ញុតញ្ញាណនោះឯង ឈ្មោះថា

អនាវរណញ្ញាណ ។

ឥឡូវនេះ ព្រះសារីបុត្ត ដើម្បីនឹងសម្តែងដោយប្រភេទនៃអារម្មណ៍ច្រើនយ៉ាង ទើបពោលពាក្យថា **អតីតំ** ជាដើម ។ ក្នុងបទទាំងនោះ បទថា **អតីតំ អនាគតំ បច្ចុប្បន្នំ** លោកសម្តែងដោយប្រភេទនៃកាល ។

បទថា **ចក្ខុញ្ចេវ រូបា** ច ជាដើម លោកសម្តែងដោយប្រភេទនៃវត្ថុនិងអារម្មណ៍ ។

បទថា **ឃាវំ តំ សព្វំ** ជាពាក្យកាន់យកដោយមិនមានចំណែកសេសសល់របស់ចក្ខុ និងរូបទាំងនោះ ។ ក្នុងបទដ៏សេសក៏យ៉ាងនេះ ។

[ ២៨៧ ] បទថា **យាវតា** ជាពាក្យកាន់យកដោយមិនមានចំណែកសេសសល់ ។

បទថា **អនិច្ចដ្ឋំ** ជាដើម លោកសម្តែងដោយប្រភេទនៃសាមញ្ញលក្ខណៈ ។

បទថា **អនិច្ចដ្ឋំ** បានដល់ មានអាការមិនទៀង ។ ម្យ៉ាងទៀត បទថា **អនិច្ចដ្ឋំ** ជាទុតិយាវិភត្តិ ចុះក្នុងអត្ថបឋមាវិភត្តិ ។ ក្នុងពាក្យបែបនេះ ក៏មានន័យនេះ ។

បទថា **រូបស្ស** ជាដើម លោកសម្តែងដោយប្រភេទនៃខន្ធ ។ បទថា **ចក្ខុស្ស ។បេ។ ជរាមរណស្ស** គប្បីប្រកបដោយន័យរបស់បេយ្យាល ដែលធ្លាប់ពោលទុកហើយ ។

[ ២៨៨ ] ក្នុងបទថា **អភិញ្ញាយ** ជាដើម បានដល់ ញាណ ដូចបានពោលហើយខាងដើមនោះឯង ។ បទថា **អភិញ្ញដ្ឋំ** បានដល់ សភាវៈ គឺការ

ដឹងក្រៃលែង ។ ក្នុងពាក្យបែបនេះ ក៏មានន័យនេះ ។

បទថា **ឯកន្នាគំ ឯកន្ទរំ** ជាដើម គប្បីជ្រាបដោយន័យដូចពោលហើយខាងដើមនោះឯង ។

[ ២៨៩ ] បទថា **កុសលេ ធម្មេ** ជាដើម ជាប្រភេទដោយអំណាចនៃកុសលត្តិកៈ ( ពួក ៣ នៃកុសល ) ។

បទថា **កាមាវចរេ ធម្មេ** ជាដើម ជាប្រភេទដោយអំណាចនៃធម៌ប្រព្រឹត្តទៅក្នុងភូមិ ៤ ។ សូម្បីក្នុងទីទាំងពីរ បាឋៈជាពហុវចនៈថា **សព្វេ ជានាតិ** ( ដឹងធម៌ទាំងអស់ ) ជាបាឋៈល្អជាង ។ តែព្រោះធ្លាក់ទៅក្នុងក្រសែនៃឯកវចនៈ ទើបក្នុងគម្ពីរ លោករចនាដោយឯកវចនៈ ។ បទថា **ទុក្ខស្ស** ជាដើម ជាប្រភេទនៃអារម្មណ៍ពុទ្ធញ្ញាណ ១៤ យ៉ាង ។

[ ២៩០ ] បើសួរថា ព្រះសារីបុត្តត្ថេរពោលញាណ ៤ មាន **ឥន្ទ្រិយ-បរោបរិយត្តេ ញាណំ** ជាដើមហើយ ហេតុអ្វីមិនពោលសព្វញ្ញុតញ្ញាណ ឆ្លើយថា ព្រោះញាណ ៤ ដែលលោកពោល ជាសព្វញ្ញុតញ្ញាណ ។ កាលពោលសព្វញ្ញុតញ្ញាណដោយប្រភេទនៃអារម្មណ៍ ក៏មិនគួរពោលដល់ញាណនោះ ម្យ៉ាងទៀត សព្វញ្ញុតញ្ញាណ រមែងជាអារម្មណ៍នៃសព្វញ្ញុតញ្ញាណនោះឯង ។

[ ២៩១ ] ព្រះសារីបុត្តត្ថេរ កាលនឹងសម្ដែងភូមិនៃសព្វញ្ញុតញ្ញាណដោយន័យដូចពោលហើយក្នុងកាឡការាមសូត្រជាដើម ទើបពោលបទថា **យាវតា សទេវកស្ស លោកស្ស** ជាដើម ។

ក្នុងបទទាំងនោះ គប្បីជ្រាបសេចក្តីដូចតទៅនេះ លោក ព្រមទាំងទេវតាទាំងឡាយ ឈ្មោះថា **សទេវកស្ស** ។ ព្រមទាំងមារ ឈ្មោះថា **សមារកស្ស** ។ ព្រមទាំងព្រហ្ម ឈ្មោះថា **សព្រហ្មកស្ស** ។ ពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ឈ្មោះថា **សស្សមណព្រាហ្មណិយា** ។ ព្រមដោយទេវតា និងមនុស្ស ឈ្មោះថា **សទេវមនុស្សាយ** ។ បទថា **បជា** នេះ ជាពាក្យពោលដោយបរិយាយរបស់សត្វលោក ព្រោះជាអ្នកកើតហើយ ។

ក្នុងបទទាំងនោះ គប្បីជ្រាបការកាន់យកកាមាវចរទេវតា ៥ ជាន់ ដោយពាក្យថា **សទេវក** ។ កាន់យកកាមាវចរទេវតាជាន់ទី ៦ ដោយពាក្យថា **សមារក** ។ កាន់យកពួកព្រហ្ម មានព្រហ្មកាយិកាជាដើម ដោយពាក្យថា **សព្រហ្មក** ។ កាន់យកសមណព្រាហ្មណ៍ ដែលជាសត្រូវចំពោះសាសនា និងកាន់យកសមណព្រាហ្មណ៍អ្នកស្ងប់បាប អ្នកបន្សាត់បាបហើយ ដោយពាក្យថា **សស្សមណព្រាហ្មណិ** ។ កាន់យកសត្វលោកដោយពាក្យថា **បជា** ។ កាន់យកសម្មតិទេព និងមនុស្សដ៏សេស ដោយពាក្យថា **សទេវមនុស្ស** ។

ក្នុងនិទ្ទេសនេះ គប្បីជ្រាបថា លោកកាន់យកឱកាសលោក ដោយ ៣ បទ ។ កាន់យកសត្វលោក ដោយអំណាចពួកសត្វ ដោយ ២ បទ ។

គប្បីជ្រាបន័យដទៃតទៅថា លោកកាន់យកអរូបាវចរលោក ដោយសព្ទថា **សទេវក** ។ កាន់យកឆកាមាវចរទេវលោក ដោយសព្ទថា **សមារក** ។ កាន់យករូបាវចរព្រហ្មលោក ដោយសព្ទថា **សព្រហ្មក** ។ កាន់យកមនុស្ស-លោក ឬសត្វលោកដ៏សេស ព្រមដោយបរិស័ទ ៤ ឬសម្មតិទេព ដោយ

សព្ទថា **សស្សមណព្រាហ្មណា** ជាដើម ។

ម្យ៉ាងទៀត ក្នុងនិទ្ទេសនេះ ព្រះសារីបុត្តត្ថេរ ញ៉ាំងការដឹង មានអារម្មណ៍ដែលបានឃើញជាដើមនៃសត្វលោកទាំងអស់ ឲ្យសម្រេចដោយកំណត់យ៉ាងឧក្រិដ្ឋ ដោយពាក្យថា **សទេវក**។ បន្ទាប់អំពីនោះ ព្រះសារីបុត្តត្ថេរ កាលនឹងកម្ចាត់សេចក្ដីសង្ស័យរបស់ជនទាំងឡាយដែលសង្ស័យថា មារមានអានុភាពច្រើន ជាធំក្នុងឆកាមាវចរទេវតា ជាអ្នកមានអំណាច សព្វញ្ញុតញ្ញាណរមែងដឹងអារម្មណ៍ដែលបានឃើញជាដើម របស់មារនោះបានឬ ទើបពោលថា **សមារកស្ស** ។ ម្យ៉ាងទៀត ព្រះសារីបុត្ត កាលនឹងកម្ចាត់សេចក្ដីសង្ស័យរបស់ជនទាំងឡាយដែលសង្ស័យថា ព្រហ្មមានអានុភាពច្រើន រមែងផ្សាយពន្លឺក្នុងមួយពាន់ចក្កវាឡដោយម្រាមដៃ ១ រមែងផ្សាយពន្លឺ ក្នុង ២០០០ ចក្កវាឡដោយម្រាមដៃ ២ ។បេ។ ក្នុងមួយម៉ឺនចក្កវាឡដោយម្រាមដៃ ១០ និងរមែងសោយសុខក្នុងឈានសមាបត្តិដ៏កំពូល ព្រះសព្វញ្ញុតញ្ញាណរមែងដឹងអារម្មណ៍ដែលបានឃើញជាដើមរបស់ព្រហ្មនោះបានឬ ទើបពោលថា **សព្រហ្មកស្ស** ។ បន្ទាប់អំពីនោះ ព្រះសារីបុត្តត្ថេរ កាលនឹងកម្ចាត់សេចក្ដីសង្ស័យរបស់ជនទាំងឡាយដែលសង្ស័យថា សមណព្រាហ្មណ៍ជាច្រើន ជាសត្រូវរបស់សាសនា សព្វញ្ញុតញ្ញាណ រមែងដឹងអារម្មណ៍ដែលបានឃើញជាដើម របស់សមណ-ព្រាហ្មណ៍ទាំងនោះបានឬ ទើបពោលថា **សស្សមណព្រាហ្មណិយា បជាយ** ។ ព្រះសារីបុត្តត្ថេរ កាលប្រកាសការដឹងអារម្មណ៍ដែលបានឃើញជាដើមរបស់សត្វជាន់ខ្ពស់យ៉ាងនេះហើយ បន្ទាប់អំពីនោះ ទើបប្រកាសការដឹងអារម្មណ៍

ដែលបានឃើញជាដើម របស់សត្វលោកដ៏សេសដោយកំណត់យ៉ាងឧក្រិដ្ឋ អាស្រ័យសម្មតិទេព និងមនុស្សដ៏សេស ។ នេះជាលំដាប់អនុសន្ធិក្នុងនិទ្ទេសនេះ ។ ចំណែកបុរាណាចារ្យពោលថា បទថា **សទេវកស្ស** បានដល់ លោកដ៏សេស ព្រមទាំងទេវតាទាំងឡាយ ។ បទថា **សមារកស្ស** បានដល់ លោកដ៏សេស ព្រមដោយមារ ។ បទថា **សព្រហ្មកស្ស** បានដល់ លោកដ៏សេស ព្រមដោយព្រហ្ម ។

ព្រះសារីបុត្តត្ថេរ ដើម្បីប្រារព្ធសត្វទាំងឡាយដែលកើតក្នុងភព ៣ សូម្បីទាំងអស់យ៉ាងនេះ ចូលក្នុង ៣ បទដោយអាការ ៣ ហើយកាន់យកដោយអាការ ២ ទៀត ទើបពោលថា **សស្សមណព្រាហ្មណិយា បជាយ សទេវ-មនុស្សាយ** ។ ឈ្មោះថា លោកកាន់យកត្រៃធាតុនោះឯង ដោយអាការនោះៗ ដោយបទ ៥ ដោយប្រការដូច្នេះ ។

បទថា **ទិដ្ឋំ** បានដល់ រូបាយតនៈ ។ បទថា **សុតំ** បានដល់ សទ្ទា-យតនៈ ។ បទថា **មុតំ** បានដល់ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ ព្រោះដល់ហើយ ទើបកំណត់បាន ។ បទថា **វិញ្ញាតំ** បានដល់ ធម្មារម្មណ៍មានសុខទុក្ខជាដើម ។ បទថា **បត្តំ** បានដល់ អារម្មណ៍ដែលដល់ហើយ ព្រោះស្វែងរកក្តី មិនស្វែងរកក្តី ។ បទថា **បរិយេសិតំ** បានដល់ អារម្មណ៍ដែលស្វែងរកហើយដល់ក្តី មិនដល់ក្តី ។ បទថា **អនុវិចរិតំ មនសា** បានដល់ អារម្មណ៍ដែលត្រាច់ស្វែងរកដោយចិត្ត ។ ព្រះសារីបុត្តត្ថេរ សម្តែងបទនេះដោយពាក្យនេះថា **សព្វំ ជានាតិ** ។

រូបារម្មណ៍ណា មានខៀវ លឿងជាដើម មកកាន់គន្លងក្នុងចក្ខុទ្វារ របស់លោក ព្រមទាំងទេវលោកនេះ ក្នុងលោកធាតុដែលប្រមាណមិនបាន សព្វញ្ញុតញ្ញាណរបស់ព្រះតថាគតរមែងដឹងរូបារម្មណ៍ទាំងពួងនោះថា សត្វនេះឃើញរូបារម្មណ៍ឈ្មោះនេះក្នុងខណៈនេះ ហើយជាអ្នកត្រេកអរ ទោមនស្ស ឬជាកណ្តាល ។ ម្យ៉ាងទៀត សទ្ទារម្មណ៍ណា មានសំឡេងស្គរ សំឡេងសម្ភោរជាដើមមកកាន់គន្លងក្នុងសោតទ្វារ គន្ធារម្មណ៍ មានក្លិនឫស ក្លិនសម្បកជាដើមមកកាន់គន្លងឃានទ្វារ រសារម្មណ៍មានរសឫស រសដើមជាដើមមកកាន់គន្លងក្នុងជិវ្ហាទ្វារ ផោដ្ឋារម្មណ៍ មាន ៣ ប្រភេទ គឺបឋវីធាតុ តេជោធាតុ វាយោធាតុ មានរឹង ទន់ជាដើមមកកាន់គន្លងក្នុងកាយទ្វាររបស់លោក ព្រមទាំងទេវលោកនេះ ក្នុងលោកធាតុប្រមាណមិនបាន ។ សព្វញ្ញុតញ្ញាណរបស់ព្រះតថាគត រមែងដឹងអារម្មណ៍ទាំងអស់នោះថា សត្វនេះពាល់ត្រូវផោដ្ឋព្វារម្មណ៍ឈ្មោះនេះ ក្នុងខណៈនេះហើយ ជាអ្នកត្រេកអរ ទោមនស្ស ឬជាកណ្តាល ។ ម្យ៉ាងទៀត ធម្មារម្មណ៍ណាមានប្រភេទជាសុខ និងទុក្ខជាដើម មកកាន់គន្លងក្នុងមនោទ្វាររបស់លោក ព្រមទាំងទេវលោកនេះ ក្នុងលោកធាតុប្រមាណមិនបាន សព្វញ្ញុតញ្ញាណរបស់ព្រះតថាគត រមែងដឹងធម្មារម្មណ៍ទាំងអស់នោះថា សត្វនេះដឹងធម្មារម្មណ៍ឈ្មោះនេះ ក្នុងខណៈនេះ ហើយជាអ្នកត្រេកអរ ទោមនស្ស ឬជាកណ្តាល ។ ម្យ៉ាងទៀត មហាជននេះ ស្វែងរកហើយមិនបានសម្រេចក៏មាន ស្វែងរកហើយសម្រេចក៏មាន ។ មិនស្វែងរកហើយមិនសម្រេចក៏មាន មិនស្វែងរកហើយសម្រេចក៏មាន វត្ថុទាំងអស់ដែលសព្វញ្ញុតញ្ញាណរបស់ព្រះ

តថាគតមិនសម្រេចមិនមាន ។

ព្រះសារីបុត្តត្ថេរពោលគាថាថា **ន តស្ស** ជាដើម ដើម្បីសម្រេចភាពជាសព្វញ្ញុតញ្ញាណដោយបរិយាយដទៃទៀត ។

ក្នុងបទទាំងនោះ បទថា **ន តស្ស អទិដ្ឋមិធត្ថិ កិញ្ចិ** សេចក្តីថា បទធម៌ណាមួយសូម្បីត្រឹមតែបន្តិចបន្តួចដែលព្រះតថាគតនោះ ទ្រង់មិនបានឃើញហើយដោយបញ្ញាចក្ខុ ក្នុងលោកដែលជាត្រៃធាតុនេះ ឬក្នុងបច្ចុប្បន្នកាលនេះ មិនមាន គឺរកមិនបាន ។

បទថា **អត្ថិ** នេះ ជាបទអាខ្យាត ប្រព្រឹត្តទៅក្នុងបច្ចុប្បន្នកាល ។ ដោយបទនេះ ព្រះសារីបុត្តត្ថេរសម្តែងភាពដែលព្រះតថាគត ទ្រង់ដឹងធម៌ទាំងពួងក្នុងបច្ចុប្បន្នកាល ។ ម្យ៉ាងទៀត ក្នុងបទនេះ លោកប្រើ ធ អក្ខរៈ ដើម្បីងាយស្រួលក្នុងការចងគាថា ។

បទថា **អថោ** ក្នុងបទនេះថា **អថោ អវិញ្ញាតំ** ជានិបាត ប្រើបញ្ជាក់នូវពាក្យ ។ បទថា **អវិញ្ញាតំ** បានដល់ ធម៌ណាមួយដែលព្រះតថាគត ទ្រង់មិនដឹងហើយក្នុងអតីតកាល ។ ចុះបាឋៈថា **នាហោសិ** ទៅ ។ ក្នុងការកាន់យក **អត្ថិ** សព្ទ ជាអព្យយសព្ទ សូម្បីចុះបាឋៈទៅក៏ប្រើបាន ។ ដោយពាក្យនេះ ព្រះសារីបុត្តត្ថេរសម្តែងភាពដែលព្រះតថាគត ទ្រង់ដឹងធម៌ទាំងពួងដែលជាអតីតកាល ។

បទថា **អជានិតព្វំ** បានដល់ ធម៌ដែលដឹងមិនបាន ដែលជាចំណែកអនាគតកាលនឹងមិនមាន ឬមិនមាន ។ ដោយបទនេះ ព្រះសារីបុត្ត សម្តែងភាព

ដែលព្រះតថាគត ទ្រង់ដឹងធម៌ទាំងពួងដែលជាចំណែកអនាគតកាល ។ ម្យ៉ាងទៀត **អ** អក្ខរៈ ក្នុងបទនេះ ត្រឹមតែជាកិរិយាវិសេសនៈរបស់ការដឹង ។

គប្បីជ្រាបសេចក្ដីក្នុងបទនេះថា **សព្វំ អភិញ្ញាសិ យទត្ថិ នេយ្យំ** ដូចតទៅនេះថា ព្រះតថាគតទ្រង់ជ្រាបក្រៃលែង គឺទ្រង់ដឹង ទ្រង់ចាក់ធ្លុះធម៌ទាំងពួងជាគ្រឿងនាំទៅ គឺការដឹងក្នុងកាលទាំង ៣ ឬផុតចាកកាលដោយសព្វញ្ញុតញ្ញាណដ៏ក្រៃលែង ។ ការកាន់យកកាល ៣ និងផុតចាកកាលដោយ **អត្ថិ** សព្ទ ក្នុងបទនេះ គប្បីជ្រាបថា **អត្ថិ** ជាអព្យយសព្ទ ។

បទថា **តថាគតោ តេន សមន្តចក្ខុ** សេចក្ដីថា ឈ្មោះថា សមន្តចក្ខុ ព្រោះមានញាណចក្ខុ ប្រព្រឹត្តទៅហើយដោយជុំវិញ គឺដោយប្រការទាំងពួង ព្រោះមិនមានចំណែកសេសសល់ដោយកាល និងដោយឱកាស ។ ដោយហេតុតាមដែលពោលហើយនោះ ទើបព្រះតថាគតជាព្រះសមន្តចក្ខុ អធិប្បាយថា ជាព្រះសព្វញ្ញូ ។ ដោយបុគ្គលាធិដ្ឋានទេសនានៃគាថានេះ ទើបសម្រេចជាព្រះសព្វញ្ញុតញ្ញាណ ។

[ ២៩២ ] ព្រះសារីបុត្តត្ថេរ បំណងនឹងសម្ដែងព្រះសព្វញ្ញុតញ្ញាណដោយវិស័យនៃព្រះពុទ្ធញ្ញាណ ទើបពោលបទថា **សមន្តចក្ខូតិ កេនដ្ឋេន សមន្តចក្ខុ** ជាដើម ។

ក្នុងពាក្យដែលលោកពោលថា សមន្តចក្ខុក្នុងគាថានោះ មានអធិប្បាយថា សមន្តចក្ខុនោះ ឈ្មោះថា សមន្តចក្ខុ ព្រោះអត្ថដូចម្ដេច ។

ព្រះសារីបុត្តត្ថេរ ពោលអត្ថនៃពាក្យនោះ ដោយបទថា **យាវតា ទុក្ខស្ស**

**ឧក្កដ្ឋា** ជាដើម ពិតហើយ សមន្តចក្ខុ គឺសព្វញ្ញុតញ្ញាណ ។ សមដូចព្រះសារីបុត្តត្ថេរពោល ( ក្នុងខុទ្ទកនិកាយ ចូឡនិទ្ទេស ) ថា សព្វញ្ញុតញ្ញាណ លោកហៅថា សមន្តចក្ខុ ដូច្នេះ ។ កាលពោលដល់អត្ថនៃសព្វញ្ញុតញ្ញាណនោះ ឈ្មោះថា ពោលដល់អត្ថនៃសមន្តចក្ខុនោះឯង ។ ញាណរបស់ព្រះពុទ្ធនោះឯង ឈ្មោះថា ពុទ្ធញ្ញាណ ។

សូម្បីបទថា **ឧក្កេ ញាណំ** ជាដើម ក៏រមែងមានដល់ព្រះពុទ្ធមានព្រះភាគដោយអាការទាំងពួង ប្រព្រឹត្តទៅដល់សាវកត្រឹមតែចំណែកខ្លះប៉ុណ្ណោះ ។ម្យ៉ាងទៀត បទថា **សាវកសាធារណានិ** លោកពោលសំដៅដល់ការមានដោយចំណែកខ្លះ ។

[ ២៩៣ ] បទថា **សព្វោ ញាតោ** បានដល់ ព្រះមានព្រះភាគទ្រង់ជ្រាបទាំងអស់ដោយព្រះញាណ ។ ព្រះសារីបុត្តត្ថេរ អធិប្បាយអត្ថដែលលោកពោលថា **អញ្ញាតោ ឧក្កដ្ឋា នត្ថិ** ដោយការបដិសេធ ។

បទថា **សព្វោ ទិដ្ឋោ** បានដល់ មិនមែនត្រឹមតែទ្រង់ដឹងម្យ៉ាងប៉ុណ្ណោះដែលពិតទ្រង់ធ្វើដូចឃើញដោយចក្ខុទៀតផង ។ បទថា **សព្វោ វិទិតោ** បានដល់ មិនមែនទ្រង់ឃើញត្រឹមតែម្យ៉ាងប៉ុណ្ណោះ ដែលពិត ទ្រង់ធ្វើឲ្យប្រាកដទៀតផង ។ បទថា **សព្វោ សច្ឆិកតោ** បានដល់ មិនមែនត្រឹមតែទ្រង់ដឹងច្បាស់តែម្យ៉ាងប៉ុណ្ណោះទេ ដែលពិត ទ្រង់ធ្វើឲ្យប្រចក្សដោយការបានព្រះញាណ ក្នុងញាណនោះទៀតផង ។ បទថា **សព្វោ ផស្សិតោ** បានដល់ មិនមែនទ្រង់ធ្វើឲ្យច្បាស់តែម្យ៉ាងប៉ុណ្ណោះទេ ដែលពិត ទ្រង់ពាល់ត្រូវដោយអំណាច ទ្រង់

ប្រព្រឹត្តតាមគាប់ចិត្តរឿយៗ ។

ម្យ៉ាងទៀត ឈ្មោះថា **ញាណោ** ដោយអំណាចលក្ខណៈតាមសេចក្ដីពិត ។ ឈ្មោះថា **ចក្ខុ** ដោយអំណាចសាមញ្ញលក្ខណៈ ។ ឈ្មោះថា **វិជ្ជា** ដោយអំណាចកិច្ច ។ ឈ្មោះថា **សច្ចិករណោ** ដោយអំណាចបច្ចុប្បដ្ឋាន ( អាការប្រាកដ ) ។ ឈ្មោះថា **ជស្សិតោ** ដោយអំណាចបទដ្ឋាន ( ហេតុជិត ) ។

ម្យ៉ាងវិញទៀត ឈ្មោះថា **ញាណោ** ដោយអំណាចការកើតឡើងនៃញាណ ។ ឈ្មោះថា **ចក្ខុ** ដោយអំណាចការកើតឡើងនៃចក្ខុ ។ ឈ្មោះថា **វិជ្ជា** ដោយអំណាចការកើតឡើងនៃបញ្ញា ។ ឈ្មោះថា **សច្ចិករណោ** ដោយអំណាចការកើតឡើងនៃវិជ្ជា ។ ឈ្មោះថា **ជស្សិតោ** ដោយអំណាចការកើតឡើងនៃពន្លឺ ។ គប្បីជ្រាបសេចក្ដីពិស្ដារដោយន័យជាដើមថា សភាពដែលទ្រាំបានដោយក្រនៃទុក្ខដែលព្រះតថាគតទ្រង់ឃើញហើយទាំងអស់ ដែលទ្រង់មិនបានឃើញមិនមាន និងដោយន័យជាដើមថា អត្ថនៃទុក្ខរបស់ទុក្ខសច្ចទាំងប៉ុន្មានព្រះតថាគតទ្រង់ជ្រាបសព្វហើយ ឃើញសព្វហើយ អត្ថនៃទុក្ខ ឈ្មោះថា

*ព្រះតថាគតមិនឃើញ មិនមានឡើយ ។ និងដោយន័យជាដើមថា របស់អ្វីមួយ ដែលសត្វលោក ព្រមទាំងទេវលោក ។បេ។ ត្រាច់រង្គាត់តាមហើយ ព្រះតថាគតទ្រង់ជ្រាបសព្វហើយដោយប្រាជ្ញា ( ធម្មជាតដែលព្រះមានព្រះភាគនោះ ) មិនបានដឹង មិនមានឡើយ ដូច្នេះ ។ គាថាដែលពោលដំបូង លោកពោលដដែលទៀត ដោយអំណាចសរុបសេចក្តី ។ កាលធ្វើការសរុបគាថានោះហើយ ឈ្មោះថា ធ្វើការសរុបញាណផងដែរ ។*

**អដ្ឋកថាសព្វញ្ញុតញ្ញាណនិទ្ទេស ចប់**

**អដ្ឋកថាបដិសម្ភិទាមគ្គឈ្មោះថាសទ្ធម្មបកាសិនី ចប់**

**អដ្ឋកថាញាណកថា ចប់**

# សុត្តន្តបិដក
# ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ
# ទុតិយភាគ
## មហាវគ្គ ទិដ្ឋិកថា

[ ១ ] ហេតុនៃទិដ្ឋិប៉ុន្មានយ៉ាង ការរួបរឹត គឺទិដ្ឋិប៉ុន្មានយ៉ាង ទិដ្ឋិប៉ុន្មានយ៉ាង ការប្រកាន់ស្អិត គឺទិដ្ឋិប៉ុន្មានយ៉ាង ធម៌ជាគ្រឿងដកឡើងនូវហេតុនៃទិដ្ឋិ តើដូចម្ដេច ទិដ្ឋិ គឺការប្រកាន់ស្អិត និងការស្ទាបអង្អែល តើដូចម្ដេច ។

ត្រង់សំណួរថា ហេតុនៃទិដ្ឋិប៉ុន្មានយ៉ាង ចម្លើយថា ហេតុនៃទិដ្ឋិ ៨ យ៉ាង ។ សំណួរថា ការរួបរឹត គឺទិដ្ឋិប៉ុន្មានយ៉ាង ការរួបរឹត គឺទិដ្ឋិ ១៨ យ៉ាង ។ សំណួរថា ទិដ្ឋិប៉ុន្មានយ៉ាង ទិដ្ឋិ ១៦ យ៉ាង ។ សំណួរថា ការប្រកាន់ស្អិត គឺទិដ្ឋិប៉ុន្មានយ៉ាង ការប្រកាន់ស្អិត គឺទិដ្ឋិ ១៣០ យ៉ាង ។ សំណួរថា ធម៌ជាគ្រឿងដកឡើងនូវហេតុនៃទិដ្ឋិ តើដូចម្ដេច សោតាបត្តិមគ្គជាគ្រឿងដកឡើងនូវហេតុនៃទិដ្ឋិ ។

[ ២ ] សំណួរថា ទិដ្ឋិ គឺការប្រកាន់ស្អិត និងការស្ទាបអង្អែល តើដូចម្ដេច ទិដ្ឋិ គឺការប្រកាន់ស្អិត និងការស្ទាបអង្អែល ចំពោះរូបថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ទិដ្ឋិ គឺការប្រកាន់ស្អិត និងការស្ទាបអង្អែល ចំពោះវេទនាថា នុ៎ះរបស់អញ ។បេ។ ចំពោះសញ្ញាថា នុ៎ះរបស់អញ ចំពោះសង្ខារថា នុ៎ះរបស់អញ ចំពោះវិញ្ញាណថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ។ ទិដ្ឋិ គឺការប្រកាន់ស្អិត និងការស្ទាបអង្អែលចំពោះចក្ខុថា នុ៎ះរបស់អញ

ចំពោះសោតៈថា នុ៎ះរបស់អញ ចំពោះឃានៈថា នុ៎ះរបស់អញ ចំពោះជិវ្ហាថា នុ៎ះរបស់អញ ចំពោះកាយថា នុ៎ះរបស់អញ ចំពោះចិត្តថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ទិដ្ឋិ គឺការប្រកាន់ស្អិត និងការស្ទាបអង្អែលចំពោះរូបថា នុ៎ះរបស់អញ ចំពោះសំឡេងថា នុ៎ះរបស់អញ ចំពោះក្លិនថា នុ៎ះរបស់អញ ចំពោះរសថា នុ៎ះរបស់អញ ចំពោះផ្សព្វថា នុ៎ះរបស់អញ ចំពោះធម្មារម្មណ៍ថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ។

[ ៣ ] ទិដ្ឋិ គឺការប្រកាន់ស្អិត និងការស្ទាបអង្អែល ចំពោះចក្ខុវិញ្ញាណថា នុ៎ះរបស់អញ ចំពោះសោតវិញ្ញាណថា នុ៎ះរបស់អញ ចំពោះឃានវិញ្ញាណថា នុ៎ះរបស់អញ ចំពោះជិវ្ហាវិញ្ញាណថា នុ៎ះរបស់អញ ចំពោះកាយវិញ្ញាណថា នុ៎ះរបស់អញ ចំពោះមនោវិញ្ញាណថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ។ ទិដ្ឋិ គឺការប្រកាន់ស្អិត និងការស្ទាបអង្អែល ចំពោះចក្ខុសម្ផស្សថា នុ៎ះរបស់អញ ចំពោះសោតសម្ផស្សថា នុ៎ះរបស់អញ ចំពោះឃានសម្ផស្សថា នុ៎ះរបស់អញ ចំពោះជិវ្ហាសម្ផស្សថា នុ៎ះរបស់អញ ចំពោះកាយសម្ផស្សថា នុ៎ះរបស់អញ ចំពោះមនោសម្ផស្សថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ។ ទិដ្ឋិ គឺការប្រកាន់ស្អិត និងការស្ទាបអង្អែល ចំពោះវេទនាដែលកើតអំពីចក្ខុសម្ផស្ស ចំពោះវេទនាដែលកើតអំពីសោតសម្ផស្ស ចំពោះវេទនាដែលកើតអំពីឃានសម្ផស្ស ចំពោះវេទនាដែលកើតអំពីជិវ្ហាសម្ផស្ស ចំពោះវេទនាដែលកើតអំពីកាយសម្ផស្ស ចំពោះវេទនាដែលកើតអំពីមនោសម្ផស្សថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ។

[ ៤ ] ទិដ្ឋិ គឺការប្រកាន់ស្អិត និងការស្ទាបអង្អែលចំពោះរូបសញ្ញាថា នុ៎ះរបស់អញ ចំពោះសទ្ទសញ្ញា ចំពោះគន្ធសញ្ញា ចំពោះរសសញ្ញា ចំពោះផោដ្ឋព្វសញ្ញា ចំពោះធម្មសញ្ញាថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ។ ទិដ្ឋិ គឺការប្រកាន់ស្អិត និងការស្ទាបអង្អែលចំពោះរូបសញ្ចេតនាថា នុ៎ះរបស់អញ ចំពោះសទ្ទសញ្ចេតនា ចំពោះគន្ធសញ្ចេតនា ចំពោះរសសញ្ចេតនា ចំពោះផោដ្ឋព្វសញ្ចេតនា ចំពោះធម្មសញ្ចេតនាថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ។ ទិដ្ឋិ គឺការប្រកាន់ស្អិត និងការស្ទាបអង្អែល ចំពោះរូប-តណ្ហាថា នុ៎ះរបស់អញ ចំពោះសទ្ទតណ្ហាថា នុ៎ះរបស់អញ ចំពោះគន្ធតណ្ហា ចំពោះរសតណ្ហា ចំពោះផោដ្ឋព្វតណ្ហា ចំពោះធម្មតណ្ហាថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ។ ទិដ្ឋិ គឺការប្រកាន់ស្អិត និងការស្ទាបអង្អែលចំពោះរូបវិតក្កថា នុ៎ះរបស់អញ ចំពោះសទ្ទវិតក្ក ចំពោះគន្ធវិតក្ក ចំពោះរសវិតក្ក ចំពោះផោដ្ឋព្វវិតក្ក ចំពោះធម្មវិតក្កថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ។ ទិដ្ឋិ គឺការប្រកាន់ស្អិត និងការស្ទាបអង្អែលចំពោះរូបវិចារថា នុ៎ះរបស់អញ ចំពោះសទ្ទវិចារថា នុ៎ះរបស់អញ ចំពោះគន្ធវិចារថា នុ៎ះរបស់អញ ចំពោះរសវិចារថា នុ៎ះរបស់អញ ចំពោះផោដ្ឋព្វវិចារថា នុ៎ះរបស់អញ ចំពោះធម្មវិចារថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ។

[ ៥ ] ទិដ្ឋិ គឺការប្រកាន់ស្អិត និងការស្ទាបអង្អែលចំពោះបឋវីធាតុថា នុ៎ះរបស់អញ ចំពោះអាបោធាតុថា នុ៎ះរបស់អញ ចំពោះតេជោធាតុថា នុ៎ះរបស់អញ ចំពោះវាយោធាតុថា នុ៎ះរបស់អញ ចំពោះអាកាសធាតុថា នុ៎ះរបស់

អញ ចំពោះវិញ្ញាណធាតុថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ។ ទិដ្ឋិ គឺការប្រកាន់ស្អិត និងការស្ទាបអង្អែលចំពោះបឋវីកសិណ អាបោកសិណ តេជោកសិណ វាយោកសិណ នីលកសិណ បីតកសិណ លោហិតកសិណ ឱទាតកសិណ អាកាសកសិណ និងវិញ្ញាណកសិណថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ។

[ ៦ ] ទិដ្ឋិ គឺការប្រកាន់ស្អិត និងការស្ទាបអង្អែលចំពោះសក់ថា នុ៎ះរបស់អញ ចំពោះរោមថា នុ៎ះរបស់អញ ចំពោះក្រចកថា នុ៎ះរបស់អញ ចំពោះធ្មេញថា នុ៎ះរបស់អញ ចំពោះស្បែកថា នុ៎ះរបស់អញ ចំពោះសាច់ថា នុ៎ះរបស់អញ ចំពោះសរសៃរថា នុ៎ះរបស់អញ ចំពោះឆ្អឹងថា នុ៎ះរបស់អញ ចំពោះខួរក្នុងឆ្អឹងថា នុ៎ះរបស់អញ ចំពោះទាចថា នុ៎ះរបស់អញ ចំពោះបេះដូងថា នុ៎ះរបស់អញ ចំពោះថ្លើមថា នុ៎ះរបស់អញ ចំពោះវាវថា នុ៎ះរបស់អញ ចំពោះក្រពះថា នុ៎ះរបស់អញ ។បេ។ ចំពោះទឹកមាត់ថា នុ៎ះរបស់អញ ចំពោះទឹកសម្បោរថា នុ៎ះរបស់អញ ចំពោះទឹករំអិលថា នុ៎ះរបស់អញ ចំពោះទឹកមូត្រថា នុ៎ះរបស់អញ ចំពោះខួរក្នុងក្បាលថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ។

[ ៧ ] ទិដ្ឋិ គឺការប្រកាន់ស្អិត និងការស្ទាបអង្អែលចំពោះចក្ខាយតនៈថា នុ៎ះរបស់អញ ចំពោះរូបាយតនៈថា នុ៎ះរបស់អញ ចំពោះសោតាយតនៈថា នុ៎ះរបស់អញ ចំពោះសទ្ទាយតនៈថា នុ៎ះរបស់អញ ចំពោះឃានាយតនៈថា នុ៎ះរបស់អញ ចំពោះគន្ធាយតនៈថា នុ៎ះរបស់អញ ចំពោះជិវ្ហាយតនៈ រសា-

យតនៈ កាយាយតនៈ ផោដ្ឋព្វាយតនៈ មនាយតនៈ និងធម្មាយតនៈថា នុ៎ះរបស់អញ ចំពោះចក្ខុធាតុថា នុ៎ះរបស់អញ ចំពោះរូបធាតុថា នុ៎ះរបស់អញ ចំពោះចក្ខុវិញ្ញាណធាតុថា នុ៎ះរបស់អញ ចំពោះសោតធាតុថា នុ៎ះរបស់អញ ចំពោះសទ្ទធាតុថា នុ៎ះរបស់អញ ចំពោះសោតវិញ្ញាណធាតុថា នុ៎ះរបស់អញ ចំពោះឃានធាតុ គន្ធធាតុ ឃានវិញ្ញាណធាតុ ជិវ្ហាធាតុ រសធាតុ ជិវ្ហា-វិញ្ញាណធាតុ កាយធាតុ ផោដ្ឋព្វធាតុ កាយវិញ្ញាណធាតុ និងមនោធាតុថា នុ៎ះរបស់អញ ចំពោះធម្មធាតុថា នុ៎ះរបស់អញ ចំពោះមនោវិញ្ញាណធាតុថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ។

[ ៨ ] ទិដ្ឋិ គឺការប្រកាន់ស្អិត និងការស្ទាបអង្អែលចំពោះចក្ខុន្ទ្រិយថា នុ៎ះរបស់អញ ចំពោះសោតិន្ទ្រិយថា នុ៎ះរបស់អញ ចំពោះឃានិន្ទ្រិយថា នុ៎ះរបស់អញ ចំពោះជិវ្ហិន្ទ្រិយ កាយិន្ទ្រិយ ជីវិតិន្ទ្រិយ សោមនស្សិន្ទ្រិយ ទោម-នស្សិន្ទ្រិយ ឧបេក្ខិន្ទ្រិយ សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ និងបញ្ញិន្ទ្រិយថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ។

[ ៩ ] ទិដ្ឋិ គឺការប្រកាន់ស្អិត និងការស្ទាបអង្អែលចំពោះកាមធាតុថា នុ៎ះរបស់អញ ចំពោះរូបធាតុថា នុ៎ះរបស់អញ ចំពោះអរូបធាតុថា នុ៎ះរបស់អញ ចំពោះកាមភពថា នុ៎ះរបស់អញ ចំពោះរូបភពថា នុ៎ះរបស់អញ ចំពោះអរូប-ភពថា នុ៎ះរបស់អញ ចំពោះសញ្ញាភពថា នុ៎ះរបស់អញ ចំពោះអសញ្ញាភពថា នុ៎ះរបស់អញ ចំពោះនេវសញ្ញានាសញ្ញាភពថា នុ៎ះរបស់អញ ចំពោះឯកវោការភពថា នុ៎ះរបស់អញ ចំពោះចតុវោការភពថា នុ៎ះរបស់អញ ចំពោះ

បញ្ចវោការភពថា នុ៎ះរបស់អញ ចំពោះបឋមជ្ឈានថា នុ៎ះរបស់អញ ចំពោះទុតិយជ្ឈានថា នុ៎ះរបស់អញ ចំពោះតតិយជ្ឈានថា នុ៎ះរបស់អញ ចំពោះចតុត្ថជ្ឈានថា នុ៎ះរបស់អញ ចំពោះមេត្តាចេតោវិមុត្តិថា នុ៎ះរបស់អញ ចំពោះករុណាចេតោវិមុត្តិថា នុ៎ះរបស់អញ ចំពោះមុទិតាចេតោវិមុត្តិថា នុ៎ះរបស់អញ ចំពោះឧបេក្ខាចេតោវិមុត្តិថា នុ៎ះរបស់អញ ចំពោះអាកាសានញ្ចាយតនសមាបត្តិ វិញ្ញាណញ្ចាយតនសមាបត្តិ អាកិញ្ចញ្ញាយតនសមាបត្តិ និងនេវសញ្ញានាសញ្ញាយតនសមាបត្តិថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ។

[ ១០ ] ទិដ្ឋិ គឺការប្រកាន់ស្អិត និងស្ទាបអង្អែលចំពោះអវិជ្ជាថា នុ៎ះរបស់អញ ចំពោះសង្ខារទាំងឡាយថា នុ៎ះរបស់អញ ចំពោះវិញ្ញាណថា នុ៎ះរបស់អញ ចំពោះនាមរូបថា នុ៎ះរបស់អញ ចំពោះសឡាយតនៈថា នុ៎ះរបស់អញ ចំពោះផស្សៈថា នុ៎ះរបស់អញ ចំពោះវេទនាថា នុ៎ះរបស់អញ ចំពោះតណ្ហាថា នុ៎ះរបស់អញ ចំពោះឧបាទានថា នុ៎ះរបស់អញ ចំពោះភពថា នុ៎ះរបស់អញ ចំពោះជាតិថា នុ៎ះរបស់អញ ចំពោះជរាមរណៈថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ទិដ្ឋិ គឺការប្រកាន់ស្អិត និងការស្ទាបអង្អែលយ៉ាងនេះឯង ។

[ ១១ ] ហេតុនៃទិដ្ឋិ ៨ យ៉ាង តើដូចម្តេចខ្លះ ។ ខន្ធជាហេតុនៃទិដ្ឋិ ១ អវិជ្ជាជាហេតុនៃទិដ្ឋិ ១ ផស្សៈជាហេតុនៃទិដ្ឋិ ១ សញ្ញាជាហេតុនៃទិដ្ឋិ ១ វិតក្កជាហេតុនៃទិដ្ឋិ ១ អយោនិសោមនសិការជាហេតុនៃទិដ្ឋិ ១ បាបមិត្តជាហេតុនៃទិដ្ឋិ ១ បរតោឃោសៈ ( សម្តីឃោសនារបស់បុគ្គលដទៃ ) ជាហេតុនៃទិដ្ឋិ

១ ។

ខន្ធជាហេតុ ខន្ធជាបច្ច័យ ដោយអត្ថថា តាំងឡើងព្រម ព្រោះអាស្រ័យនូវហេតុនៃទិដ្ឋិ ខន្ធ ឈ្មោះថា ហេតុនៃទិដ្ឋិយ៉ាងនេះ ១ អវិជ្ជាជាហេតុ អវិជ្ជាជាបច្ច័យ ដោយអត្ថថា តាំងឡើងព្រម ព្រោះអាស្រ័យនូវហេតុនៃទិដ្ឋិ អវិជ្ជា ឈ្មោះថា ហេតុនៃទិដ្ឋិយ៉ាងនេះ ១ ផស្សជាហេតុ ផស្សជាបច្ច័យ ដោយអត្ថថា តាំងឡើងព្រម ព្រោះអាស្រ័យនូវហេតុនៃទិដ្ឋិ ផស្សៈ ឈ្មោះថា ហេតុនៃទិដ្ឋិយ៉ាងនេះ ១ សញ្ញាជាហេតុ សញ្ញាជាបច្ច័យ ដោយអត្ថថា តាំងឡើងព្រម ព្រោះអាស្រ័យនូវហេតុនៃទិដ្ឋិ សញ្ញា ឈ្មោះថា ហេតុនៃទិដ្ឋិយ៉ាងនេះ ១ វិតក្កជាហេតុ វិតក្កជាបច្ច័យ ដោយអត្ថថា តាំងឡើងព្រម ព្រោះអាស្រ័យនូវហេតុនៃទិដ្ឋិ វិតក្ក ឈ្មោះថា ហេតុនៃទិដ្ឋិយ៉ាងនេះ ១ អយោនិសោមនសិការជាហេតុ អយោនិសោមនសិការជាបច្ច័យ ដោយអត្ថថា តាំងឡើងព្រម ព្រោះអាស្រ័យនូវហេតុនៃទិដ្ឋិ អយោនិសោមនសិការ ឈ្មោះថា ហេតុនៃទិដ្ឋិយ៉ាងនេះ ១ បាបមិត្តជាហេតុ បាបមិត្តជាបច្ច័យ ដោយអត្ថថា តាំងឡើងព្រម ព្រោះអាស្រ័យនូវហេតុនៃទិដ្ឋិ បាបមិត្ត ឈ្មោះថា ហេតុនៃទិដ្ឋិយ៉ាងនេះ ១ បរតោឃោសៈ ( សម្លេងឃោសនារបស់បុគ្គលដទៃ ) ជាហេតុ បរតោឃោសៈជាបច្ច័យ ដោយអត្ថថា តាំងឡើងព្រម ព្រោះអាស្រ័យនូវហេតុនៃទិដ្ឋិ បរតោឃោសៈ ឈ្មោះថា ហេតុនៃទិដ្ឋិយ៉ាងនេះ ១ នេះហេតុនៃទិដ្ឋិ ៨ យ៉ាង ។

[ ១២ ] ការវេបរីត គឺទិដ្ឋិ ១៨ យ៉ាង តើដូចម្តេចខ្លះ ។ ទិដ្ឋិ ដំណើរ គឺទិដ្ឋិ ១ ការប្រកាន់ គឺទិដ្ឋិ ១ ផ្លូវកន្តារ គឺទិដ្ឋិ ១ ចម្រូង គឺទិដ្ឋិ ១ ការ

វិបត្តិ គឺទិដ្ឋិ ១ សំយោជនៈ គឺទិដ្ឋិ ១ សរ គឺទិដ្ឋិ ១ ការបង្កៀតចិត្ត គឺទិដ្ឋិ ១ ការកង្វល់ គឺទិដ្ឋិ ១ ចំណង គឺទិដ្ឋិ ១ ជ្រោះ គឺទិដ្ឋិ ១ អនុស័យ គឺទិដ្ឋិ ១ កម្តៅ គឺទិដ្ឋិ ១ ក្រហល់ក្រហាយ គឺទិដ្ឋិ ១ គ្រឿងចាក់ស្រែះ គឺទិដ្ឋិ ១ គ្រឿងប្រកាន់ គឺទិដ្ឋិ ១ ការប្រកាន់ស្អិត គឺទិដ្ឋិ ១ ការស្ទាបអង្អែល គឺទិដ្ឋិ ១ នេះការរួបរឹត គឺទិដ្ឋិ ១៨ យ៉ាង ។

[ ១៣ ] ទិដ្ឋិ ១៦ យ៉ាង តើដូចម្តេចខ្លះ ។ អស្សាទទិដ្ឋិ ១ អត្តានុទិដ្ឋិ ១ មិច្ឆាទិដ្ឋិ ១ សក្កាយទិដ្ឋិ ១ សក្កាយវត្ថុកសស្សតទិដ្ឋិ ១ សក្កាយវត្ថុក-ឧច្ឆេទទិដ្ឋិ ១ អន្តគ្គាហិកទិដ្ឋិ ១ បុព្វន្តានុទិដ្ឋិ ១ អបរន្តានុទិដ្ឋិ ១ សញ្ញោ-ជនិកទិដ្ឋិ ១ ទិដ្ឋិដែលជាប់ដោយមានះថាអញ ១ ទិដ្ឋិដែលជាប់ដោយមានះថារបស់អញ ១ អត្តវាទប្បដិសំយុត្តទិដ្ឋិ ១ លោកវាទប្បដិសំយុត្តទិដ្ឋិ ១ ភវទិដ្ឋិ ១ វិភវទិដ្ឋិ ១ នេះទិដ្ឋិ ១៦ យ៉ាង ។

[ ១៤ ] ការប្រកាន់ស្អិតនៃអស្សាទទិដ្ឋិ ដោយអាការប៉ុន្មានយ៉ាង ការប្រកាន់ស្អិតនៃអត្តានុទិដ្ឋិ ដោយអាការប៉ុន្មានយ៉ាង ការប្រកាន់ស្អិតនៃមិច្ឆាទិដ្ឋិ ដោយអាការប៉ុន្មានយ៉ាង ការប្រកាន់ស្អិតនៃសក្កាយទិដ្ឋិ ដោយអាការប៉ុន្មានយ៉ាង ការប្រកាន់ស្អិតនៃសក្កាយវត្ថុកសស្សតទិដ្ឋិ ដោយអាការប៉ុន្មានយ៉ាង ការប្រកាន់ស្អិតនៃសក្កាយវត្ថុកឧច្ឆេទទិដ្ឋិ ដោយអាការប៉ុន្មានយ៉ាង ការប្រកាន់ស្អិតនៃអន្តគ្គាហិកទិដ្ឋិ ដោយអាការប៉ុន្មានយ៉ាង ការប្រកាន់ស្អិតនៃបុព្វន្តានុទិដ្ឋិ ដោយអាការប៉ុន្មានយ៉ាង ការប្រកាន់ស្អិតនៃអបរន្តានុទិដ្ឋិ ដោយអាការប៉ុន្មានយ៉ាង ការប្រកាន់ស្អិតនៃសញ្ញោជនិកទិដ្ឋិ ដោយអាការប៉ុន្មានយ៉ាង ការប្រកាន់

ស្អិតនៃទិដ្ឋិដែលជាប់ដោយមានះថាអញ ដោយអាការប៉ុន្មានយ៉ាង ការប្រកាន់ស្អិតនៃទិដ្ឋិដែលជាប់ដោយមានះ ថារបស់អញ ដោយអាការប៉ុន្មានយ៉ាង ការប្រកាន់ស្អិតនៃអត្តវាទប្បដិសំយុត្តទិដ្ឋិ ដោយអាការប៉ុន្មានយ៉ាង ការប្រកាន់ស្អិតនៃលោកវាទប្បដិសំយុត្តទិដ្ឋិ ដោយអាការប៉ុន្មានយ៉ាង ការប្រកាន់ស្អិតនៃភវទិដ្ឋិ ដោយអាការប៉ុន្មានយ៉ាង ការប្រកាន់ស្អិតនៃវិភវទិដ្ឋិ ដោយអាការប៉ុន្មានយ៉ាង ។

[ ១៥ ] ការប្រកាន់ស្អិតនៃអស្សាទទិដ្ឋិ ដោយអាការ ៣៥ យ៉ាង ការប្រកាន់ស្អិតនៃអត្តានុទិដ្ឋិ ដោយអាការ ២០ យ៉ាង ការប្រកាន់ស្អិតនៃមិច្ឆាទិដ្ឋិ ដោយអាការ ១០ យ៉ាង ការប្រកាន់ស្អិតនៃសក្កាយទិដ្ឋិ ដោយអាការ ២០ យ៉ាង ការប្រកាន់ស្អិតនៃសក្កាយវត្ថុកសស្សតទិដ្ឋិដោយអាការ ១៥ យ៉ាង ការប្រកាន់ស្អិតនៃសក្កាយវត្ថុកឧច្ឆេទទិដ្ឋិ ដោយអាការ ៥ យ៉ាង ការប្រកាន់ស្អិតនៃអន្តគ្គាហិកទិដ្ឋិ ដោយអាការ ៥០ យ៉ាង ការប្រកាន់ស្អិតនៃបុព្វន្តានុទិដ្ឋិ ដោយអាការ ១៨ យ៉ាង ការប្រកាន់ស្អិតនៃអបរន្តានុទិដ្ឋិ ដោយអាការ ៤៤ យ៉ាង ការប្រកាន់ស្អិតនៃសញ្ញោជនិកទិដ្ឋិ ដោយអាការ ១៨ យ៉ាង ការប្រកាន់ស្អិតនៃទិដ្ឋិដែលជាប់ដោយមានះថាអញ ដោយអាការ ១៨ យ៉ាង ការប្រកាន់ស្អិតនៃទិដ្ឋិដែលជាប់ដោយមានះថា របស់អញ ដោយអាការ ១៨ យ៉ាង ការប្រកាន់ស្អិតនៃអត្តវាទប្បដិសំយុត្តទិដ្ឋិ ដោយអាការ ២០ យ៉ាង ការប្រកាន់ស្អិតនៃលោកវាទប្បដិសំយុត្តទិដ្ឋិ ដោយអាការ ៨ យ៉ាង ការប្រកាន់ស្អិតនៃភវទិដ្ឋិ ដោយអាការ ១៩ យ៉ាង ការប្រកាន់ស្អិតនៃវិភវទិដ្ឋិ ដោយអាការ ១៩ យ៉ាង ។

[ ១៦ ] ការប្រកាន់ស្អិតនៃអស្សាទទិដ្ឋិ ដោយអាការ ៣៥ យ៉ាង តើដូចម្តេច ។ ទិដ្ឋិ គឺការប្រកាន់ស្អិត និងការស្ទាបអង្អែលថាសុខ និងសោមនស្សកើតឡើង ព្រោះអាស្រ័យរូប នេះ ឈ្មោះថា អស្សាទ ( តម្រេក ) ចំពោះរូបនោះ ទិដ្ឋិមិនមែនអស្សាទ អស្សាទក៏មិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក អស្សាទដោយឡែក ទិដ្ឋិណា និងអស្សាទណា នេះលោកហៅថា អស្សាទទិដ្ឋិ អស្សាទទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ជាទិដ្ឋិវិបត្តិ បុគ្គលដែលប្រកបដោយទិដ្ឋិវិបត្តិនោះ ឈ្មោះថា អ្នកវិបត្តិព្រោះទិដ្ឋិ បុគ្គលដែលវិបត្តិព្រោះទិដ្ឋិ គេមិនត្រូវសេពគប់ គេមិនត្រូវគប់រក គេមិនត្រូវចូលទៅអង្គុយជិតទេ ដំណើរនោះ ព្រោះហេតុអ្វី ព្រោះថា ទិដ្ឋិរបស់បុគ្គលនោះ ជាធម្មជាតដ៏លាមក ទិដ្ឋិណា រាគៈណា រាគៈនោះមិនមែនទិដ្ឋិ ទិដ្ឋិក៏មិនមែនរាគៈ ទិដ្ឋិដោយឡែក រាគៈដោយឡែក ទិដ្ឋិណា និងរាគៈណា នេះហៅថា ទិដ្ឋិរាគៈ បុគ្គលប្រកបដោយទិដ្ឋិនោះផង ដោយរាគៈនោះផង ឈ្មោះថា អ្នកត្រេកអរក្នុងទិដ្ឋិរាគៈ ទានដែលបុគ្គលឲ្យហើយ ដល់បុគ្គលអ្នកត្រេកអរក្នុងទិដ្ឋិរាគៈ ជាទានមិនមានផលច្រើន មិនមានអានិសង្សច្រើនទេ ដំណើរនោះព្រោះហេតុអ្វី ព្រោះថា ទិដ្ឋិរបស់បុគ្គលនោះ ជាធម្មជាតដ៏លាមក ជាអស្សាទទិដ្ឋិ ជាមិច្ឆាទិដ្ឋិ បុរសបុគ្គលប្រកបដោយមិច្ឆាទិដ្ឋិ មានគតិ ២ យ៉ាង គឺនរក ១ កំណើតតិរច្ឆាន ១ កាយកម្មណាបរិបូណ៌ដោយទិដ្ឋិ ដែលបុរសបុគ្គលប្រកបដោយមិច្ឆាទិដ្ឋិកាន់យកហើយក្តី វចីកម្មណា មនោកម្មណាបរិបូណ៌ដោយទិដ្ឋិដែលបុរសបុគ្គលកាន់យកហើយក្តី ចេតនាណាក្តី សេចក្តីប្រាថ្នាណាក្តី ការតម្កល់ទុកណាក្តី សង្ខារទាំងឡាយណាក្តី ( ដែលបុរសបុគ្គលប្រកប

ដោយមិច្ឆាទិដ្ឋិកាន់យកហើយ ) ធម៌ទាំងអស់នោះ រមែងប្រព្រឹត្តទៅដើម្បីមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្ត មិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ដំណើរនោះ ព្រោះហេតុអ្វី ព្រោះថា ទិដ្ឋិរបស់បុគ្គលនោះ ជាធម្មជាតដ៏លាមក ប្រៀបដូចពូជស្តៅក្តី ពូជនទោនព្រៃក្តី ពូជឃ្លោកល្វីងក្តី ដែលគេដាំក្នុងផែនដីសើម រមែងជញ្ជក់យករសផែនដីណាក្តី ជញ្ជក់យករសទឹកណាក្តី ពូជទាំងអស់នោះ រមែងប្រព្រឹត្តទៅដើម្បីល្វីង ដើម្បីក្រពុល ដើម្បីមិនឆ្ងាញ់ពិសា ដំណើរនោះ ព្រោះហេតុអ្វី ព្រោះថា ពូជឈើនោះជាវត្ថុដ៏អាក្រក់ មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចជាកាយកម្មណាបរិបូណ៌ដោយទិដ្ឋិ ដែលបុរសបុគ្គលប្រកបដោយមិច្ឆាទិដ្ឋិកាន់យកហើយក្តី វចីកម្មណា មនោកម្មណាបរិបូណ៌ដោយទិដ្ឋិ ដែលបុរសបុគ្គលប្រកបដោយមិច្ឆាទិដ្ឋិ កាន់យកហើយក្តី ចេតនាណាក្តី សេចក្តីប្រាថ្នាណាក្តី ការតម្កល់ទុកណាក្តី សង្ខារទាំងឡាយណាក្តី ( ដែលបុរសបុគ្គលប្រកបដោយមិច្ឆាទដ្ឋិកាន់យកហើយ ) ធម៌ទាំងអស់នោះ រមែងប្រព្រឹត្តទៅដើម្បីមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្ត មិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ដំណើរនោះ ព្រោះហេតុអ្វី ព្រោះថា ទិដ្ឋិរបស់បុគ្គលនោះ ជាធម្មជាតិដ៏លាមក ជាអស្សាទទិដ្ឋិ ជាមិច្ឆាទិដ្ឋិ បានខាងទិដ្ឋិ ដំណើរ គឺទិដ្ឋិ ញៀតស្បាត គឺទិដ្ឋិ ។បេ។ ការប្រកាន់ស្អិត និងការស្ទាបអង្អែល គឺទិដ្ឋិ ។

[ ១៧ ] ទិដ្ឋិ គឺការប្រកាន់ស្អិត និងការស្ទាបអង្អែលថា សុខ និងសោមនស្សកើតឡើងព្រោះអាស្រ័យវេទនា ព្រោះអាស្រ័យសញ្ញា ព្រោះអាស្រ័យសង្ខារ

ទាំងឡាយ ព្រោះអាស្រ័យវិញ្ញាណ ព្រោះអាស្រ័យចក្ខុ ព្រោះអាស្រ័យសោតៈ ព្រោះអាស្រ័យឃានៈ ព្រោះអាស្រ័យជិវ្ហា ព្រោះអាស្រ័យកាយ ព្រោះអាស្រ័យចិត្ត ព្រោះអាស្រ័យរូប ព្រោះអាស្រ័យសទ្ទៈ ព្រោះអាស្រ័យគន្ធៈ ព្រោះអាស្រ័យរសៈ ព្រោះអាស្រ័យផោដ្ឋព្វៈ ព្រោះអាស្រ័យធម្មារម្មណ៍ ព្រោះអាស្រ័យចក្ខុវិញ្ញាណ ព្រោះអាស្រ័យសោតវិញ្ញាណ ព្រោះអាស្រ័យឃានវិញ្ញាណ ព្រោះអាស្រ័យជិវ្ហាវិញ្ញាណ ព្រោះអាស្រ័យកាយវិញ្ញាណ ព្រោះអាស្រ័យមនោវិញ្ញាណ ព្រោះអាស្រ័យចក្ខុសម្ផស្ស ព្រោះអាស្រ័យសោតសម្ផស្ស ព្រោះអាស្រ័យឃានសម្ផស្ស ព្រោះអាស្រ័យជិវ្ហាសម្ផស្ស ព្រោះអាស្រ័យកាយសម្ផស្ស ព្រោះអាស្រ័យមនោសម្ផស្ស ព្រោះអាស្រ័យវេទនាដែលកើតអំពីចក្ខុសម្ផស្ស ព្រោះអាស្រ័យវេទនាដែលកើតអំពីសោតសម្ផស្ស ព្រោះអាស្រ័យវេទនាដែលកើតអំពីឃានសម្ផស្ស ព្រោះអាស្រ័យវេទនាដែលកើតអំពីជិវ្ហាសម្ផស្ស ព្រោះអាស្រ័យវេទនាដែលកើតអំពីកាយសម្ផស្ស ព្រោះអាស្រ័យវេទនា ដែលកើតអំពីមនោសម្ផស្ស នេះជាអស្សាទៈ ចំពោះវេទនាដែលកើតអំពីមនោសម្ផស្ស ទិដ្ឋិមិនមែនអស្សាទៈ អស្សាទៈ ក៏មិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក អស្សាទៈដោយឡែក ទិដ្ឋិណា និងអស្សាទៈណា នេះលោកហៅថា អស្សាទទិដ្ឋិ អស្សាទទិដ្ឋិជាមិច្ឆាទិដ្ឋិ ជាទិដ្ឋិវិបត្តិ បុគ្គលប្រកបដោយទិដ្ឋិវិបត្តិនោះ ឈ្មោះថា អ្នកវិបត្តិព្រោះទិដ្ឋិ បុគ្គលដែលវិបត្តិព្រោះទិដ្ឋិ គេមិនត្រូវសេពគប់ គេមិនត្រូវគប់រក គេមិនត្រូវចូលទៅអង្គុយជិតទេ ដំណើរនោះព្រោះហេតុអ្វី ព្រោះថា ទិដ្ឋិរបស់បុគ្គលនោះជាធម្មជាតដ៏លាមក ទិដ្ឋិណា រាគៈ

ណា រាគៈនោះមិនមែនទិដ្ឋិ ទិដ្ឋិក៏មិនមែនរាគៈ ទិដ្ឋិដោយឡែក រាគៈដោយឡែក ទិដ្ឋិណា និងរាគៈណា នេះលោកហៅថា ទិដ្ឋិរាគៈ បុគ្គលប្រកបដោយទិដ្ឋិនោះផង ដោយរាគៈនោះផង ឈ្មោះថា អ្នកត្រេកអរក្នុងទិដ្ឋិរាគៈ ទានដែលទាយកឲ្យហើយដល់បុគ្គលអ្នកត្រេកអរក្នុងទិដ្ឋិរាគៈ ជាទានមិនមានផលច្រើន មិនមានអានិសង្សច្រើនទេ ដំណើរនោះ ព្រោះហេតុអ្វី ព្រោះថា ទិដ្ឋិរបស់បុគ្គលនោះជាធម្មជាតដ៏លាមក ជាអស្សាទទិដ្ឋិ ជាមិច្ឆាទិដ្ឋិ បុរសបុគ្គលប្រកបដោយមិច្ឆាទិដ្ឋិមានគតិ ២ យ៉ាង គឺនរក ១ កំណើតតិរច្ឆាន ១ កាយកម្មណាបរិបូណ៌ដោយទិដ្ឋិដែលបុរសបុគ្គលប្រកបដោយមិច្ឆាទិដ្ឋិ កាន់យកហើយក្តី វចីកម្មណា មនោកម្មណាបរិបូណ៌ដោយទិដ្ឋិដែលបុរសបុគ្គល កាន់យកហើយក្តី ចេតនាណាក្តី សេចក្តីប្រាថ្នាណាក្តី ការតម្កល់ទុកណាក្តី សង្ខារទាំងឡាយណាក្តី ( ដែលបុរសបុគ្គលប្រកបដោយមិច្ឆាទិដ្ឋិកាន់យកហើយ ) ធម៌ទាំងអស់នោះប្រព្រឹត្តទៅដើម្បីមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្ត មិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ដំណើរនោះ ព្រោះហេតុអ្វី ព្រោះថា ទិដ្ឋិរបស់បុគ្គលនោះជាធម្មជាតដ៏លាមក ប្រៀបដូចពូជស្ដៅក្តី ពូជនោងព្រៃក្តី ពូជឃ្លោកល្វីងក្តី ដែលគេដាំក្នុងផែនដីសើម រមែងជញ្ជក់យករសផែនដីណាក្តី ជញ្ជក់យករសទឹកណាក្តី ពូជទាំងអស់នោះ រមែងប្រព្រឹត្តទៅដើម្បីល្វីង ដើម្បីក្រពុល ដើម្បីមិនឆ្ងាញ់ពិសា ដំណើរនោះ ព្រោះហេតុអ្វី ព្រោះថា ពូជឈើនោះជាវត្ថុដ៏អាក្រក់ មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចជាកាយកម្មណាបរិបូណ៌ដោយទិដ្ឋិ ដែលបុរសបុគ្គលប្រកបដោយមិច្ឆាទិដ្ឋិ កាន់យក

ហើយក្តី វចីកម្មណា មនោកម្មណាបរិបូណ៌ដោយទិដ្ឋិ ដែលបុរសបុគ្គលប្រកប ដោយមិច្ឆាទិដ្ឋិកាន់យកហើយក្តី ចេតនាណាក្តី សេចក្តីប្រាថ្នាណាក្តី ការតម្កល់ ទុកណាក្តី សង្ខារទាំងឡាយណាក្តី ( ដែលបុរសបុគ្គលប្រកបដោយមិច្ឆាទិដ្ឋិ កាន់យកហើយ ) ធម៌ទាំងអស់នោះ រមែងប្រព្រឹត្តទៅដើម្បីមិនជាទីប្រាថ្នា មិន ជាទីត្រេកអរ មិនជាទីពេញចិត្ត មិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ដំណើរ នោះព្រោះហេតុអ្វី ព្រោះថា ទិដ្ឋិរបស់បុគ្គលនោះជាធម្មជាតដ៏លាមក ជាអស្សា-ទទិដ្ឋិ ជាមិច្ឆាទិដ្ឋិ បានខាងទិដ្ឋិ ដំណើរ គឺទិដ្ឋិ ញៀតស្បាត គឺទិដ្ឋិ ។បេ។ ការ ប្រកាន់ស្អិត និងការស្ទាបអង្អែល គឺទិដ្ឋិ ការប្រកបព្រមនៃចិត្តដែលត្រូវ កិលេសរួបរឹត គឺមិច្ឆាទិដ្ឋិ ជាអស្សាទទិដ្ឋិដោយអាការ ១៨ យ៉ាងនេះឯង ។

[ ១៨ ] សំយោជនៈផង ទិដ្ឋិផងក៏មាន សំយោជនៈមិនមែនទិដ្ឋិក៏មាន ។ សំយោជនៈផង ទិដ្ឋិផង តើដូចម្តេចខ្លះ ។ សក្កាយទិដ្ឋិ បរាមាសៈ និងសក្កា-យទិដ្ឋិ សីលព្វតបរាមាសៈទាំងនេះ ឈ្មោះថា សំយោជនៈផង ទិដ្ឋិផង ។ សំយោជនៈមិនមែនទិដ្ឋិ តើដូចម្តេចខ្លះ ។ កាមរាគសំយោជនៈ បដិឃសំយោជនៈ មានសំយោជនៈ វិចិកិច្ឆាសំយោជនៈ ភវរាគសំយោជនៈ ឥស្សាសំយោជនៈ មច្ឆរិយសំយោជនៈ អនុសយសំយោជនៈ អវិជ្ជាសំយោជនៈ ទាំងនេះ ឈ្មោះថា សំយោជនៈមិនមែទិដ្ឋិ ។ នេះឯង ការប្រកាន់ស្អិតនៃអស្សាទទិដ្ឋិ ដោយអាការ ៣៥ ។

[ ១៩ ] ការប្រកាន់ស្អិតនៃអត្តានុទិដ្ឋិ ដោយអាការ ២០ យ៉ាង តើដូច ម្តេចខ្លះ ។ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនចេះដឹង មិនបានជួបប្រទះនឹងពួកព្រះ

អរិយៈ មិនឈ្លាសវៃក្នុងធម៌របស់ព្រះអរិយៈ មិនបានហាត់ចិត្តក្នុងធម៌របស់ព្រះអរិយៈ មិនឈ្លាសវៃចំពោះធម៌របស់សប្បុរស មិនបានហាត់ចិត្តក្នុងធម៌របស់សប្បុរស ពិចារណាឃើញរូបថាជាខ្លួន ១ ពិចារណាឃើញខ្លួន ថាមានរូប ១ ពិចារណាឃើញរូបថាមានក្នុងខ្លួន ១ ពិចារណាឃើញខ្លួនថាមានក្នុងរូប ១ ពិចារណាឃើញវេទនា ... សញ្ញា ... សង្ខារទាំងឡាយ ... ពិចារណាឃើញវិញ្ញាណថាជាខ្លួន ១ ពិចារណាឃើញខ្លួនថាមានវិញ្ញាណ ១ ពិចារណាឃើញវិញ្ញាណថាមានក្នុងខ្លួន ១ ពិចារណាឃើញខ្លួនថាមានក្នុងវិញ្ញាណ ១ ( នេះការប្រកាន់ស្អិតនៃអត្តានុទិដ្ឋិ ដោយអាការ ២០ យ៉ាង ) ។

[ ២០ ] បុគ្គលពិចារណាឃើញរូបថាជាខ្លួន តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញបឋវីកសិណថាជាខ្លួន ថាណាជាបឋវីកសិណនោះគឺអញ ណាជាអញនោះ គឺបឋវីកសិណ ឈ្មោះថា ពិចារណាឃើញបឋវីកសិណនិងខ្លួនថាមិនមែនពីរ គឺតែមួយ ប្រៀបដូចប្រទីបប្រេងដែលឆេះឡើង មានអណ្តាតភ្លើងណា នោះគឺរស្មី ណាជារស្មី នោះក៏គឺអណ្តាតភ្លើង ឈ្មោះថា ពិចា-រណាឃើញអណ្តាតភ្លើង និងរស្មី ថាមិនមែនពីរ មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចជាបុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញបឋវីកសិណថាជាខ្លួន ថាធម្មជាតណាជាបឋវីកសិណ សភាពនោះគឺអញ សភាពណាជាអញធម្មជាតនោះ គឺបឋវីកសិណ ឈ្មោះថា ពិចារណាឃើញបឋវីកសិណ និងខ្លួនថាមិនមែនពីរ គឺតែមួយ ការប្រកាន់ស្អិត និងការស្ទាបអង្អែល ឈ្មោះថា ទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុក៏មិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និងវត្ថុ

ណា នេះឈ្មោះថា អត្តានុទិដ្ឋិ ជារូបវត្ថុកៈទី ១ អត្តានុទិដ្ឋិជាមិច្ឆាទិដ្ឋិ ជាទិដ្ឋិ-វិបត្តិ បុរសបុគ្គលប្រកបដោយអត្តានុទិដ្ឋិមានគតិ ២ យ៉ាង ។បេ។ នេះឈ្មោះថា សំយោជនៈ មិនមែនទិដ្ឋិ បុគ្គលក្នុងលោកនេះ ពិចារណាឃើញអាបោកសិណ តេជោកសិណ វាយោកសិណ នីលកសិណ បីតកសិណ លោហិតកសិណ ឱទាតកសិណថាជាខ្លួន ថាធម្មជាតណា ជាឱទាតកសិណ សភាពនោះគឺអញ សភាពណាជាអញ ធម្មជាតនោះ គឺឱទាតកសិណ ឈ្មោះថា ពិចារណាឃើញឱទាតកសិណ និងខ្លួនថាមិនមែនពីរ ប្រៀបដូចប្រទីបប្រេងដែលឆេះឡើង មានអណ្តាតភ្លើងណា សភាពនោះក៏គឺរស្មី សភាពណាជារស្មី ធម្មជាតនោះ គឺអណ្តាតភ្លើង ឈ្មោះថា ពិចារណាឃើញអណ្តាតភ្លើង និងរស្មី ថាមិនមែនពីរ មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចជាបុគ្គលខ្លះ ក្នុងលោកនេះ ។បេ។ ឈ្មោះថា ពិចារណាឃើញឱទាតកសិណ និងខ្លួនថាមិនមែនពីរ ការប្រកាន់ស្អិត និងការស្ទាបអង្អែល ឈ្មោះថា ទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុក៏មិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និងវត្ថុណា នេះឈ្មោះថា អត្តានុទិដ្ឋិ ជារូបវត្ថុកៈទី ១ អត្តានុទិដ្ឋិជាមិច្ឆាទិដ្ឋិ ជាទិដ្ឋិវិបត្តិ ។បេ។ នេះឈ្មោះថា សំយោជនៈ មិនមែនទិដ្ឋិ បុគ្គលពិចារណាឃើញរូប ថាជាខ្លួនយ៉ាងនេះឯង ។

[ ២១ ] បុគ្គលពិចារណាឃើញខ្លួនថាមានរូប តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញវេទនា សញ្ញា សង្ខារ និងវិញ្ញាណ ថាជាខ្លួន បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា នេះឯងជាខ្លួនរបស់អញ តែខ្លួនរបស់អញនោះឯង មានរូបព្រោះរូបនេះ ឈ្មោះថា ពិចារណាឃើញខ្លួន ថាមានរូប

*ប្រៀបដូចដើមឈើបរិបូណ៌ដោយម្លប់ បុរសគប្បីពោលចំពោះដើមឈើនោះយ៉ាងនេះថា នេះដើមឈើ នេះម្លប់ឈើ ដើមឈើដោយឡែក ម្លប់ដោយឡែក តែដើមឈើនោះឯង មានម្លប់ព្រោះម្លប់នេះ ឈ្មោះថា ពិចារណាឃើញដើមឈើថាមានម្លប់ មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចជាបុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញវេទនា សញ្ញា សង្ខារ និងវិញ្ញាណ ថាជាខ្លួន បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា នេះឯងជាខ្លួនរបស់អញ តែខ្លួនរបស់អញនោះឯង មានរូបព្រោះរូបនេះ ឈ្មោះថា ពិចារណាឃើញខ្លួនថាមានរូប ការប្រកាន់ស្អិត និងការស្ទាបអង្អែល ឈ្មោះថា ទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុក៏មិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និងវត្ថុណា នេះឈ្មោះថា អត្តានុទិដ្ឋិ ជារូបវត្ថុកៈទី ២ អត្តានុទិដ្ឋិជាមិច្ឆាទិដ្ឋិ ។បេ។ នេះឈ្មោះថា សំយោជនៈ មិនមែនទិដ្ឋិ បុគ្គលពិចារណាឃើញខ្លួន ថាមានរូបយ៉ាងនេះឯង ។*

*[ ២២ ] បុគ្គលពិចារណាឃើញរូប ថាមានក្នុងខ្លួន តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ពិចារណាឃើញវេទនា សញ្ញា សង្ខារ និងវិញ្ញាណថាជាខ្លួន បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា នេះឯងជាខ្លួនរបស់អញ ឯរូបនេះ ( ក៏មាន ) ក្នុងខ្លួននេះដែរ ឈ្មោះថា ពិចារណាឃើញរូបថាមានក្នុងខ្លួន ប្រៀបដូចផ្កាដែលបរិបូណ៌ដោយក្លិន បុរសគប្បីពោលចំពោះផ្កានោះយ៉ាងនេះថា នេះផ្កា នេះក្លិន ផ្កាដោយឡែក ក្លិនដោយឡែក តែក្លិននោះឯង ( មាន ) ក្នុងផ្កានេះ ឈ្មោះថា ពិចារណាឃើញក្លិន ថាមានក្នុងផ្កា មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចជាបុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញវេទនា សញ្ញា*

សង្ខារ និងវិញ្ញាណថាជាខ្លួន បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា នេះឯង ជាខ្លួនរបស់អញ ឯរូបនេះ ( ក៏មាន ) ក្នុងខ្លួននេះដែរ ឈ្មោះថា ពិចារណា ឃើញរូបថាមានក្នុងខ្លួន ការប្រកាន់ស្អិត និងការស្ទាបអង្អែល ឈ្មោះថា ទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុក៏មិនមែនជាទិដ្ឋិ ។បេ។ នេះឈ្មោះថា អត្តានុទិដ្ឋិ ជារូប-វត្ថុកៈទី ៣ អត្តានុទិដ្ឋិជាមិច្ឆាទិដ្ឋិ ជាទិដ្ឋិវិបត្តិ ។បេ។ នេះសំយោជនៈមិនមែនទិដ្ឋិ បុគ្គលពិចារណាឃើញរូប ថាមានក្នុងខ្លួនយ៉ាងនេះឯង ។

[ ២៣ ] បុគ្គលពិចារណាឃើញខ្លួន ថាមានក្នុងរូប តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ពិចារណាឃើញវេទនា សញ្ញា សង្ខារ និងវិញ្ញាណ ថាជាខ្លួន បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា នេះឯងជាខ្លួនរបស់អញ តែខ្លួនរបស់អញនោះឯង ( មាន ) ក្នុងរូបនេះ ឈ្មោះថា ពិចារណាឃើញខ្លួនថាមានក្នុងរូប ប្រៀបដូចកែវមណីដែលគេដាក់ក្នុងដប បុរសគប្បីពោលចំពោះកែវមណីនោះយ៉ាងនេះថា នេះកែវមណី នេះដប កែវមណីដោយឡែក ដបដោយឡែក តែកែវមណីនោះឯងមានក្នុងដបនេះ ឈ្មោះថា ពិនិត្យឃើញកែវមណី ថាមានក្នុងដប មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចជាបុគ្គលខ្លះ ក្នុងលោកនេះ ពិចារណាឃើញវេទនា សញ្ញា សង្ខារ និងវិញ្ញាណថាជាខ្លួន បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា នេះឯងជាខ្លួនរបស់អញ តែខ្លួនរបស់អញនោះឯង ( មាន ) ក្នុងរូបនេះ ឈ្មោះថា ពិចារណាឃើញខ្លួនថាមានក្នុងរូប ការប្រកាន់ស្អិត និងការស្ទាបអង្អែល ឈ្មោះថា ទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុក៏មិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និងវត្ថុណា នេះឈ្មោះ ថាអត្តានុទិដ្ឋិ ជា

រូបវត្ថុកៈទី ៤ អត្តានុទិដ្ឋិជាមិច្ឆាទិដ្ឋិ ជាទិដ្ឋិវិបត្តិ ។បេ។ នេះសំយោជនៈ មិនមែនទិដ្ឋិ បុគ្គលពិចារណាឃើញខ្លួន ថាមានក្នុងរូបយ៉ាងនេះឯង ។

[ ២៤ ] បុគ្គលពិចារណាឃើញវេទនា ថាជាខ្លួនដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ពិចារណាឃើញវេទនាដែលកើតអំពីចក្ខុសម្ផស្ស វេទនាដែលកើតអំពីសោតសម្ផស្ស វេទនាដែលកើតអំពីឃានសម្ផស្ស វេទនាដែលកើតអំពីជិវ្ហាសម្ផស្ស វេទនាដែលកើតអំពីកាយសម្ផស្ស វេទនាដែលកើតអំពីមនោ-សម្ផស្សថាជាខ្លួន ថាធម្មជាតិណាជាវេទនា ដែលកើតអំពីមនោសម្ផស្ស សភាពនោះគឺអញ សភាពណាជាអញ ធម្មជាតនោះ គឺវេទនាដែលកើតអំពីមនោ-សម្ផស្ស ឈ្មោះថា ពិចារណាឃើញនូវវេទនា ដែលកើតអំពីមនោសម្ផស្សផង នូវខ្លួនផង ថាមិនមែនពីរ ប្រៀបដូចប្រទីបប្រេងដែលឆេះឡើង មានអណ្តាតភ្លើងណា សភាពនោះជារស្មី សភាពណាជារស្មី ធម្មជាតនោះ គឺអណ្តាតភ្លើង ឈ្មោះថា ពិចារណាឃើញអណ្តាតភ្លើង និងរស្មី ថាមិនមែនពីរ មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចជាបុគ្គលខ្លះ ក្នុងលោកនេះ ពិចារណាឃើញវេទនាដែលកើតអំពីមនោសម្ផស្សថាជាខ្លួន ថាធម្មជាតណា ជាវេទនាដែលកើតអំពីមនោសម្ផស្ស សភាពនោះ គឺអញ សភាពណាជាអញ ធម្មជាតនោះគឺវេទនាដែលកើតអំពីមនោសម្ផស្ស ឈ្មោះថា ពិចារណាឃើញនូវវេទនា ដែលកើតអំពីមនោសម្ផស្សផង នូវខ្លួនផង ថាមិនមែនពីរ ការប្រកាន់ស្អិត និងការស្ទាបអង្អែល ឈ្មោះថា ទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ ឯវត្ថុក៏មិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និងវត្ថុណា នេះឈ្មោះថា អត្តានុទិដ្ឋិ ជាវេទនាវត្ថុកៈទី ១

អត្តានុទិដ្ឋិជាមិច្ឆាទិដ្ឋិ ជាទិដ្ឋិវិបត្តិ ។បេ។ នេះសំយោជនៈ មិនមែនទិដ្ឋិ បុគ្គល ពិចារណាឃើញវេទនាថាជាខ្លួនយ៉ាងនេះឯង ។

[ ២៥ ] បុគ្គលពិចារណាឃើញខ្លួនថាមានវេទនា តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ពិចារណាឃើញសញ្ញា សង្ខារ វិញ្ញាណ និងរូបថាជាខ្លួន បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា នេះឯងជាខ្លួនរបស់អញ តែខ្លួនរបស់អញនោះឯង មានវេទនាព្រោះវេទនានេះ ឈ្មោះថា ពិចារណាឃើញខ្លួនថាមានវេទនា ប្រៀបដូចដើមឈើដែលបរិបូណ៌ដោយម្លប់ បុរសគប្បីពោលចំពោះដើមឈើនោះយ៉ាងនេះថា នេះដើមឈើ នេះម្លប់ ដើមឈើដោយឡែក ម្លប់ដោយឡែក តែដើមឈើនោះឯង មានម្លប់ព្រោះម្លប់នេះ ឈ្មោះថា ពិចារណាឃើញដើមឈើថាមានម្លប់ មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចជាបុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញសញ្ញា សង្ខារ វិញ្ញាណ និងរូបថាជាខ្លួន បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា នេះឯងជាខ្លួនរបស់អញ តែខ្លួនរបស់អញនោះឯងមានវេទនាព្រោះវេទនានោះ ឈ្មោះថា ពិចារណាឃើញខ្លួនថាមានវេទនា ការប្រកាន់ស្អិត និងការស្ទាបអង្អែល ឈ្មោះថា ទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ ឯវត្ថុក៏មិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និងវត្ថុណា នេះឈ្មោះថា អត្តានុទិដ្ឋិ ជាវេទនាវត្ថុកៈទី ២ អត្តានុទិដ្ឋិជាមិច្ឆាទិដ្ឋិ ជាទិដ្ឋិវិបត្តិ ។បេ។ នេះសំយោជនៈ មិនមែនទិដ្ឋិ បុគ្គលពិចារណាឃើញខ្លួន ថាមានវេទនាយ៉ាងនេះឯង ។

[២៦] បុគ្គលពិចារណាឃើញវេទនាថាមានក្នុងខ្លួន តើដូចម្តេច ។ បុគ្គល

ខ្លះក្នុងលោកនេះ ពិចារណាឃើញសញ្ញា សង្ខារ វិញ្ញាណ និងរូប ថាជាខ្លួន បុគ្គលនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា នេះឯងជាខ្លួនរបស់អញ ឯវេទនានេះ ( ក៏មាន ) ក្នុងខ្លួននេះដែរ ឈ្មោះថា ពិចារណាឃើញវេទនាថាមានក្នុងខ្លួន ប្រៀបដូចផ្កាឈើដែលបរិបូណ៌ដោយក្លិន បុរសគប្បីពោលចំពោះផ្កាឈើនោះយ៉ាងនេះថា នេះផ្កា នេះក្លិន ផ្កាដោយឡែក ក្លិនដោយឡែក តែក្លិននោះឯងក៏មានក្នុងផ្កានេះ ឈ្មោះថា ពិចារណាឃើញក្លិន ថាមានក្នុងផ្កា មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចជាបុគ្គលខ្លះ ក្នុងលោកនេះ ពិចារណាឃើញសញ្ញា សង្ខារ វិញ្ញាណ និងរូបថាជាខ្លួន បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា នេះឯងជាខ្លួនរបស់អញ ឯវេទនានេះ ( ក៏មាន ) ក្នុងខ្លួននេះដែរ ឈ្មោះថា ពិចារណាឃើញវេទនា ថាមានក្នុងខ្លួន ការប្រកាន់ស្អិត និងការស្ទាបអង្អែល ឈ្មោះថា ទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ ទាំងវត្ថុក៏មិនមែនទិដ្ឋិ ។បេ។ នេះឈ្មោះថា អត្តានុទិដ្ឋិ ជាវេទនាវត្ថុកៈទី ៣ អត្តានុទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ជាទិដ្ឋិវិបត្តិ ។បេ។ នេះសំយោជនៈ មិនមែនទិដ្ឋិ បុគ្គលពិចារណាឃើញវេទនាថាមានក្នុងខ្លួនយ៉ាងនេះឯង ។

[ ២៧ ] បុគ្គលពិចារណាឃើញខ្លួន ថាមានក្នុងវេទនា តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញសញ្ញា សង្ខារ វិញ្ញាណ និងរូបថាជាខ្លួន បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា នេះឯងជាខ្លួនរបស់អញ តែខ្លួនរបស់អញនោះឯង ( មាន ) ក្នុងវេទនានេះ ឈ្មោះថា ពិចារណាឃើញខ្លួនថាមានក្នុងវេទនា ប្រៀបដូច ។បេ។ ឈ្មោះថា ពិចារណាឃើញកែវមណី ថាមានក្នុង

ដប មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចជា បុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញសញ្ញា សង្ខារ វិញ្ញាណ និងរូបថាជាខ្លួន បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា នេះឯងជាខ្លួនរបស់អញ តែខ្លួនរបស់អញនោះឯង ( មាន ) ក្នុងវេទនានេះ ឈ្មោះថា ពិចារណាឃើញខ្លួនថាមានក្នុងវេទនា ការប្រកាន់ស្អិតនិងការស្ទាបអង្អែល ឈ្មោះថា ទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ ទាំងវត្ថុ ក៏មិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និងវត្ថុណា នេះឈ្មោះថា អត្តានុទិដ្ឋិ ជាវេទនាវត្ថុកៈទី ៤ អត្តានុទិដ្ឋិជាមិច្ឆាទិដ្ឋិ ជាទិដ្ឋិវិបត្តិ ។បេ។ នេះសំយោជនៈ មិនមែនទិដ្ឋិ បុគ្គលពិចារណាឃើញខ្លួន ថាមានក្នុងវេទនាយ៉ាងនេះឯង ។

[ ២៨ ] បុគ្គលពិចារណាឃើញសញ្ញាថាជាខ្លួន តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញសញ្ញា ដែលកើតអំពីចក្ខុសម្ផស្ស សញ្ញាដែលកើតអំពីសោតសម្ផស្ស សញ្ញាដែលកើតអំពីឃានសម្ផស្ស សញ្ញាដែលកើតអំពីជិវ្ហាសម្ផស្ស សញ្ញាដែលកើតអំពីកាយសម្ផស្ស សញ្ញាដែលកើតអំពីមនោសម្ផស្សថាជាខ្លួន ថាសញ្ញាណាដែលកើតអំពីមនោសម្ផស្ស សភាពនោះគឺអញ សភាពណាជាអញ ធម្មជាតិនោះ គឺសញ្ញាដែលកើតអំពីមនោ-សម្ផស្ស ឈ្មោះថា ពិចារណាឃើញនូវសញ្ញាដែលកើតអំពីមនោសម្ផស្សផងនូវខ្លួនផងថាមិនមែនពីរ ប្រៀបដូចប្រទីបប្រេងដែលឆេះឡើង មានអណ្តាតភ្លើងណា សភាពនោះ ក៏គឺរស្មី សភាពណាជារស្មី ធម្មជាតនោះក៏គឺអណ្តាតភ្លើង ឈ្មោះថា ពិចារណាឃើញអណ្តាតភ្លើង និងរស្មី ថាមិនមែនពីរ មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចជាបុគ្គលខ្លះ ក្នុងលោកនេះ ពិចារណាឃើញនូវ

សញ្ញាដែលកើតអំពីមនោសម្ផស្ស ថាជាខ្លួន ថាសញ្ញាណាដែលកើតអំពីមនោ-សម្ផស្ស សភាពនោះ គឺអញ សភាពណាជាអញ ធម្មជាតនោះ គឺសញ្ញាដែលកើតអំពីមនោសម្ផស្ស ឈ្មោះថា ពិចារណាឃើញសញ្ញាដែលកើតអំពីមនោ-សម្ផស្សផង នូវខ្លួនផង ថាមិនមែនពីរ ការប្រកាន់ស្អិត និងការស្ទាបអង្អែល ឈ្មោះថា ទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ ទាំងវត្ថុក៏មិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និងវត្ថុណា នេះឈ្មោះថា អត្តានុទិដ្ឋិ ជាសញ្ញាវត្ថុកៈទី ១ អត្តា-នុទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ។បេ។ នេះសំយោជនៈ មិនមែនទិដ្ឋិ បុគ្គលពិចារណាឃើញសញ្ញាថាជាខ្លួន យ៉ាងនេះឯង ។

[ ២៩ ] បុគ្គលពិចារណាឃើញខ្លួន ថាមានសញ្ញា តើដូចម្តេច ។ បុគ្គលក្នុងលោកនេះពិចារណាឃើញសង្ខារ វិញ្ញាណ រូប និងវេទនាថាជាខ្លួន បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា នេះឯងខ្លួនរបស់អញ តែខ្លួនរបស់អញនេះឯងមានសញ្ញា ព្រោះសញ្ញានេះ ឈ្មោះថា ពិចារណាឃើញខ្លួន ថាមានសញ្ញា ប្រៀបដូចដើមឈើដែលបរិបូណ៌ដោយម្លប់ បុរសគប្បីពោលចំពោះដើមឈើនោះយ៉ាងនេះថា នេះដើមឈើ នេះម្លប់ ដើមឈើដោយឡែក ម្លប់ដោយឡែក តែដើមឈើនេះឯងមានម្លប់ព្រោះម្លប់នេះ ឈ្មោះថា ពិចារណាឃើញដើមឈើថាមានម្លប់ មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចជាបុគ្គលខ្លះក្នុងលោកនេះពិចារណាឃើញសង្ខារ វិញ្ញាណ រូប និងវេទនាថាជាខ្លួន បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា នេះឯងខ្លួនរបស់អញ តែខ្លួនរបស់អញនេះឯងមានសញ្ញា ព្រោះសញ្ញានេះ ឈ្មោះថា ពិចារណាឃើញខ្លួនថាមានសញ្ញា ការប្រកាន់

ស្អិត និងការស្ទាបអង្អែល ឈ្មោះថា ទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ ទាំងវត្ថុក៏មិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និងវត្ថុណា នេះឈ្មោះថា អត្តានុទិដ្ឋិ ជាសញ្ញាវត្ថុកៈទី ២ អត្តានុទិដ្ឋិជាមិច្ឆាទិដ្ឋិ ។បេ។ នេះសំយោជនៈ មិនមែនទិដ្ឋិ បុគ្គលពិចារណាឃើញខ្លួន ថាមានសញ្ញាយ៉ាងនេះឯង ។

[ ៣០ ] បុគ្គលពិចារណាឃើញសញ្ញា ថាមានក្នុងខ្លួន តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញសង្ខារ វិញ្ញាណ រូប និងវេទនាថាជាខ្លួន បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា នេះឯងខ្លួនរបស់អញ ឯសញ្ញានេះ ( ក៏មាន ) ក្នុងខ្លួននេះដែរ ឈ្មោះថា ពិចារណាឃើញសញ្ញា ថាមានក្នុងខ្លួន ប្រៀបដូចផ្កាដែលបរិបូណ៌ដោយក្លិន បុរសគប្បីពោលចំពោះផ្កានោះយ៉ាងនេះថា នេះផ្កា នេះក្លិន ផ្កាដោយឡែក ក្លិនដោយឡែក តែក្លិននោះឯង ( មាន ) ក្នុងផ្កានេះ ឈ្មោះថា ពិចារណាឃើញក្លិន ថាមានក្នុងផ្កា មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចជាបុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញសង្ខារ វិញ្ញាណ រូប និងវេទនាថាជាខ្លួន បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា នេះឯងខ្លួនរបស់អញ ឯសញ្ញានេះ ( ក៏មាន ) ក្នុងខ្លួននេះដែរ ឈ្មោះថា ពិចារណាឃើញសញ្ញាថាមានក្នុងខ្លួន ការប្រកាន់ស្អិត និងការស្ទាបអង្អែល ឈ្មោះថា ទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុក៏មិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និងវត្ថុណា នេះឈ្មោះថា អត្តានុទិដ្ឋិ ជាសញ្ញាវត្ថុកៈទី ៣ អត្តានុទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ។បេ។ នេះសំយោជនៈ មិនមែនទិដ្ឋិ បុគ្គលពិចារណាឃើញសញ្ញា ថាមានក្នុងខ្លួន យ៉ាងនេះឯង ។

[ ៣១ ] បុគ្គលពិចារណាឃើញខ្លួន ថាមានក្នុងសញ្ញា តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញសង្ខារ វិញ្ញាណ រូប និងវេទនាថាជាខ្លួន បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា នេះឯងខ្លួនរបស់អញ តែខ្លួនរបស់អញនេះឯង ( មាន ) ក្នុងសញ្ញានេះ ឈ្មោះថា ពិចារណាឃើញខ្លួនថាមានក្នុងសញ្ញា ប្រៀបដូចកែវមណីដែលបុគ្គលដាក់ក្នុងដប បុរសគប្បីពោលចំពោះកែវមណីនោះយ៉ាងនេះថា នេះកែវមណី នេះដប កែវមណីដោយឡែក ដបដោយឡែក តែកែវមណីនេះឯង ( មាន ) ក្នុងដបនេះ ឈ្មោះថា ពិចារណាឃើញកែវមណីថាមានក្នុងដប មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចជាបុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញសង្ខារ វិញ្ញាណ រូប និងវេទនាថាជាខ្លួន បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា នេះឯងខ្លួនរបស់អញ តែខ្លួនរបស់អញនេះឯង ( មាន ) ក្នុងសញ្ញានេះ ឈ្មោះថា ពិចារណាឃើញខ្លួនថាមានក្នុងសញ្ញា ការប្រកាន់ស្អិត និងការស្ទាបអង្អែល ឈ្មោះថា ទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុក៏មិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និងវត្ថុណានេះឈ្មោះថា អត្តានុទិដ្ឋិ ជាសញ្ញាវត្ថុកៈទី ៤ អត្តានុទិដ្ឋិជាមិច្ឆាទិដ្ឋិ ។បេ។ នេះសំយោជនៈ មិនមែនទិដ្ឋិ បុគ្គលពិចារណាឃើញខ្លួន ថាមានក្នុងសញ្ញាយ៉ាងនេះឯង ។

[ ៣២ ] បុគ្គលពិចារណាឃើញសង្ខារថាជាខ្លួន តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញចេតនា ដែលកើតអំពីចក្ខុសម្ផស្ស ចេតនាដែលកើតអំពីសោតសម្ផស្ស ចេតនាដែលកើតអំពីឃានសម្ផស្ស ចេតនាដែល

កើតអំពីជិវ្ហាសម្ផស្ស ចេតនាដែលកើតអំពីកាយសម្ផស្ស ចេតនាដែលកើតអំពីមនោសម្ផស្សថាជាខ្លួន ថាធម្មជាតណា ជាចេតនាដែលកើតអំពីមនោសម្ផស្ស សភាពនោះគឺអញ សភាពណាជាអញ ធម្មជាតនោះ គឺចេតនាដែលកើតអំពីមនោសម្ផស្ស ឈ្មោះថា ពិចារណាឃើញនូវចេតនាដែលកើតអំពីមនោ-សម្ផស្សផង នូវខ្លួនផង ថាមិនមែនពីរ ប្រៀបដូចប្រទីបប្រេងដែលឆេះឡើងមានអណ្តាតភ្លើងណា សភាពនោះ គឺរស្មី សភាពណាជារស្មី ធម្មជាតនោះ គឺអណ្តាតភ្លើង ឈ្មោះថា ពិចារណាឃើញអណ្តាតភ្លើង និងរស្មីថាមិនមែនពីរ មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចជាបុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញចេតនាដែលកើតអំពីមនោសម្ផស្សថាជាខ្លួន ថាធម្មជាតណា ជាចេតនាដែលកើតអំពីមនោសម្ផស្ស សភាពនោះ គឺអញ សភាពណាជាអញ ធម្មជាតនោះ គឺចេតនាដែលកើតអំពីមនោសម្ផស្ស ឈ្មោះថា ពិចារណាឃើញនូវចេតនាដែលកើតអំពីមនោសម្ផស្សផង នូវខ្លួនផង ថាមិនមែនពីរ ការប្រកាន់ស្អិត និងការស្ទាបអង្អែល ឈ្មោះថា ទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុក៏មិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និងវត្ថុណា នេះឈ្មោះ ថាអត្តានុទិដ្ឋិជាសង្ខារវត្ថុកៈទី ១ អត្តានុទិដ្ឋិជាមិច្ឆាទិដ្ឋិ ។បេ។ នេះសំយោជនៈ មិនមែនទិដ្ឋិ បុគ្គលពិចារណាឃើញសង្ខារថាជាខ្លួន យ៉ាងនេះឯង ។

[ ៣៣ ] បុគ្គលពិចារណាឃើញខ្លួនថាមានសង្ខារ តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញវិញ្ញាណ រូប វេទនា និងសញ្ញា ថាជាខ្លួន បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា នេះឯងខ្លួនរបស់អញ តែខ្លួនរបស់

អញនេះឯងមានសង្ខារ ព្រោះសង្ខារនេះ ឈ្មោះថា ពិចារណាឃើញខ្លួនថាមានសង្ខារ ប្រៀបដូចដើមឈើដែលបរិបូណ៌ដោយម្លប់ បុរសគប្បីពោលចំពោះដើមឈើនោះយ៉ាងនេះថា នេះដើមឈើ នេះម្លប់ ដើមឈើដោយឡែក ម្លប់ដោយឡែក តែដើមឈើនេះឯង មានម្លប់ព្រោះម្លប់នេះ ឈ្មោះថា ពិចារណាឃើញដើមថាមានម្លប់ មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចជាបុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញវិញ្ញាណ រូប វេទនា និងសញ្ញា ថាជាខ្លួន បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា នេះឯងខ្លួនរបស់អញ តែខ្លួនរបស់អញនេះឯងមានសង្ខារ ព្រោះសង្ខារទាំងនេះ ឈ្មោះថា ពិចារណាឃើញខ្លួនថាមានសង្ខារ ការប្រកាន់ស្អិត និងការស្ទាបអង្អែល ឈ្មោះថា ទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុក៏មិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក នេះឈ្មោះថា អត្តានុទិដ្ឋិ ជាសង្ខារវត្ថុកៈទី ២ អត្តានុទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ។បេ។ នេះសំយោជនៈមិនមែនទិដ្ឋិ បុគ្គលពិចារណាឃើញខ្លួន ថាមានសង្ខារ យ៉ាងនេះឯង ។

[ ៣៤ ] បុគ្គលពិចារណាឃើញសង្ខារ ថាមានក្នុងខ្លួន តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញវិញ្ញាណ រូប វេទនា និងសញ្ញាថាជាខ្លួន បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា នេះឯងខ្លួនរបស់អញ ឯសង្ខារទាំងនេះ ( ក៏មាន ) ក្នុងខ្លួននេះឯង ឈ្មោះថា ពិចារណាឃើញសង្ខារថាមានក្នុងខ្លួន ប្រៀបដូចផ្កាដែលបរិបូណ៌ដោយក្លិន បុរសគប្បីពោលចំពោះផ្កានោះយ៉ាងនេះថា នេះផ្កា នេះក្លិន ផ្កាដោយឡែក ក្លិនដោយឡែក តែក្លិននេះឯង ( ក៏មាន ) ក្នុងផ្កានេះ ឈ្មោះថា ពិចារណាឃើញក្លិនថាមានក្នុងផ្កា មានឧបមា

ដូចម្តេចមិញ មានឧបមេយ្យដូចជាបុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញវិញ្ញាណ រូប វេទនា និងសញ្ញាថាជាខ្លួន បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា នេះឯងខ្លួនរបស់អញ ឯសង្ខារទាំងនេះ ( ក៏មាន ) ក្នុងខ្លួននេះឯង ឈ្មោះថា ពិចារណាឃើញសង្ខារ ថាមានក្នុងខ្លួន ការប្រកាន់ស្អិត និងការស្ទាបអង្អែល ឈ្មោះថា ទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុក៏មិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និងវត្ថុណា នេះឈ្មោះថា អត្តានុទិដ្ឋិ ជាសង្ខារវត្ថុកៈទី ៣ អត្តានុទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ។បេ។ នេះសំយោជនៈ មិនមែនទិដ្ឋិ បុគ្គលពិចារណាឃើញសង្ខារថាមានក្នុងខ្លួន យ៉ាងនេះឯង ។

[ ៣៥ ] បុគ្គលពិចារណាឃើញខ្លួន ថាមានក្នុងសង្ខារ តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញវិញ្ញាណ រូប វេទនា និងសញ្ញាថាជាខ្លួន បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា នេះឯងខ្លួនរបស់អញ តែខ្លួនរបស់អញនេះឯង ( មាន ) ក្នុងសង្ខារទាំងនេះ ឈ្មោះថា ពិចារណាឃើញខ្លួនថាមានក្នុងសង្ខារ ប្រៀបដូចកែវមណីដែលគេដាក់ក្នុងជប បុរសគប្បីពោលចំពោះកែវមណីនោះយ៉ាងនេះថា នេះកែវមណី នេះជប កែវមណីដោយឡែក ជបដោយឡែក តែកែវមណីនេះឯង ( មាន ) ក្នុងជបនេះ ឈ្មោះថា ពិចារណាឃើញកែវមណីថាមានក្នុងជប មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចជាបុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញវិញ្ញាណ រូប វេទនា និងសញ្ញាថាជាខ្លួន បុគ្គលនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា នេះឯងខ្លួនរបស់អញ តែខ្លួនរបស់អញនេះឯងមានក្នុងសង្ខារនេះ ឈ្មោះថា ពិចារណាឃើញខ្លួន

ថាមានក្នុងសង្ខារ ការប្រកាន់ស្អិត និងការស្ទាបអង្អែល ឈ្មោះថា ទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុក៏មិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និងវត្ថុណា នេះឈ្មោះថា អត្តានុទិដ្ឋិជាសង្ខារវត្ថុកៈទី ៤ អត្តានុទិដ្ឋិជាមិច្ឆាទិដ្ឋិ ។បេ។ នេះសំយោជនៈ មិនមែនទិដ្ឋិ បុគ្គលពិចារណាឃើញខ្លួន ថាមានក្នុងសង្ខារ យ៉ាងនេះឯង ។

[ ៣៦ ] បុគ្គលពិចារណាឃើញវិញ្ញាណថាជាខ្លួន តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ មនោវិញ្ញាណថាជាខ្លួន ថាធម្មជាតណា ជាមនោ-វិញ្ញាណ សភាពនោះគឺអញ សភាពណាជាអញ ធម្មជាតនោះគឺមនោវិញ្ញាណ ឈ្មោះថា ពិចារណាឃើញនូវមនោវិញ្ញាណផង នូវខ្លួនផង ថាមិនមែនពីរ ប្រៀបដូចប្រទីបប្រេងដែលឆេះឡើងមានអណ្តាតភ្លើងណា សភាពនោះ គឺរស្មី សភាពណាជារស្មី ធម្មជាតនោះ គឺអណ្តាតភ្លើង ឈ្មោះថា ពិចារណាឃើញអណ្តាតភ្លើង និងរស្មីថាមិនមែនពីរ មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចជាបុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញមនោវិញ្ញាណថាជាខ្លួន ថាធម្មជាតណាជាមនោវិញ្ញាណ សភាពនោះគឺអញ សភាពណាជាអញ ធម្មជាតនោះគឺមនោវិញ្ញាណ ឈ្មោះថា ពិចារណាឃើញនូវមនោវិញ្ញាណផង នូវខ្លួនផង ថាមិនមែនពីរ ការប្រកាន់ស្អិត និងការស្ទាបអង្អែល ឈ្មោះថា ទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុក៏មិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និងវត្ថុណានេះ ឈ្មោះថា អត្តានុទិដ្ឋិ ជាវិញ្ញាណវត្ថុកៈទី ១ អត្តានុទិដ្ឋិជាមិច្ឆាទិដ្ឋិ ។បេ។

នេះសំយោជនៈ មិនមែនទិដ្ឋិ បុគ្គលពិចារណាឃើញវិញ្ញាណ ថាជាខ្លួន យ៉ាងនេះឯង ។

[ ៣៧ ] បុគ្គលពិចារណាឃើញខ្លួនថាមានវិញ្ញាណ តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញរូប វេទនា សញ្ញា និងសង្ខារ ថាជាខ្លួន បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា នេះឯងខ្លួនរបស់អញ តែខ្លួនរបស់អញនេះឯងមានវិញ្ញាណ ព្រោះវិញ្ញាណនេះ ឈ្មោះថា ពិចារណាឃើញខ្លួន ថាមានវិញ្ញាណ ប្រៀបដូចដើមឈើដែលបរិបូណ៌ដោយម្លប់ បុរសគប្បីពោលចំពោះដើមនោះយ៉ាងនេះថា នេះដើមឈើ នេះម្លប់ ដើមឈើដោយឡែក ម្លប់ដោយឡែក តែដើមឈើនេះឯង មានម្លប់ព្រោះម្លប់នេះ ឈ្មោះថា ពិចារណាឃើញដើមឈើ ថាមានម្លប់ មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចជាបុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញរូប វេទនា សញ្ញា និងសង្ខារ ថាជាខ្លួន បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា នេះឯងខ្លួនរបស់អញ តែខ្លួនរបស់អញនេះឯងមានវិញ្ញាណ ព្រោះវិញ្ញាណនេះ ឈ្មោះថា ពិចារណាឃើញខ្លួន ថាមានវិញ្ញាណ ការប្រកាន់ស្អិត និងការស្ទាបអង្អែល ឈ្មោះថា ទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុក៏មិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និងវត្ថុណា នេះឈ្មោះថា អត្តានុទិដ្ឋិ ជាវិញ្ញាណវត្ថុកៈទី ២ អត្តានុទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ។បេ។ នេះសំយោជនៈ មិនមែនទិដ្ឋិ បុគ្គលពិចារណាឃើញខ្លួន ថាមានវិញ្ញាណ យ៉ាងនេះឯង ។

[ ៣៨ ] បុគ្គលពិចារណាឃើញវិញ្ញាណ ថាមានក្នុងខ្លួន តើដូចម្តេច ។

បុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញរូប វេទនា សញ្ញា សង្ខារថាជាខ្លួន បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា នេះឯងខ្លួនរបស់អញ ឯវិញ្ញាណនេះក៏មានក្នុងខ្លួននេះដែរ ឈ្មោះថា ពិចារណាឃើញវិញ្ញាណថាមានក្នុងខ្លួន ប្រៀបដូចផ្កាដែលបរិបូណ៌ដោយក្លិន បុរសគប្បីពោលចំពោះផ្កានោះយ៉ាងនេះថា នេះផ្កា នេះក្លិន ផ្កាដោយឡែក ក្លិនដោយឡែក តែក្លិននេះឯង ( មាន ) ក្នុងផ្កានេះ ឈ្មោះថា ពិចារណាឃើញក្លិនថាមានក្នុងផ្កា មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចជាបុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញរូប វេទនា សញ្ញា សង្ខារថាជាខ្លួន បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា នេះឯងខ្លួនរបស់អញ ឯវិញ្ញាណនេះក៏មានក្នុងខ្លួននេះដែរ ឈ្មោះថា ពិចារណាឃើញវិញ្ញាណថាមានក្នុងខ្លួន ការប្រកាន់ស្អិត និងការស្ទាបអង្អែលឈ្មោះថាទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុមិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និងវត្ថុណា នេះឈ្មោះថា អត្តានុទិដ្ឋិ ជាវិញ្ញាណវត្ថុកៈទី ៣ អត្តានុទិដ្ឋិ ជាមិច្ឆា-ទិដ្ឋិ ។បេ។ នេះសំយោជនៈ មិនមែនទិដ្ឋិ បុគ្គលពិចារណាឃើញវិញ្ញាណថាមានក្នុងខ្លួន យ៉ាងនេះឯង ។

[ ៣៩ ] បុគ្គលពិចារណាឃើញខ្លួន ថាមានក្នុងវិញ្ញាណ តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញរូប វេទនា សញ្ញា សង្ខារថាជាខ្លួន បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា នេះឯងខ្លួនរបស់អញ តែខ្លួនរបស់អញនេះឯងមានក្នុងវិញ្ញាណនេះ ឈ្មោះថា ពិចារណាឃើញខ្លួន ថាមានក្នុងវិញ្ញាណ ប្រៀបដូចកែវមណីដែលបុគ្គលដាក់ក្នុងដប បុរសគប្បីពោលចំពោះ

កែវមណីនោះយ៉ាងនេះថា នេះកែវមណី នេះពន្លឺ កែវមណីដោយឡែក ពន្លឺដោយឡែក តែកែវមណីនេះឯងមានក្នុងពន្លឺនេះ ឈ្មោះថា ពិចារណាឃើញកែវមណីថាមានក្នុងពន្លឺ មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចជាបុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញរូប វេទនា សញ្ញា សង្ខារថាជាខ្លួន បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា នេះឯងខ្លួនរបស់អញ តែខ្លួនរបស់អញនេះឯងមានក្នុងវិញ្ញាណនេះ ឈ្មោះថា ពិចារណាឃើញខ្លួនថាមានក្នុងវិញ្ញាណ ការប្រកាន់ស្អិត និងការស្ទាបអង្អែល ឈ្មោះថាទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុក៏មិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និងវត្ថុណា នេះឈ្មោះថា អត្តានុទិដ្ឋិជាវិញ្ញាណវត្ថុកៈទី ៤ អត្តានុទិដ្ឋិជាមិច្ឆាទិដ្ឋិ ។បេ។ នេះសំយោជនៈមិនមែនទិដ្ឋិ បុគ្គលពិចារណាឃើញខ្លួន ថាមានក្នុងវិញ្ញាណយ៉ាងនេះឯង នេះឯងការប្រកាន់ស្អិត និងការស្ទាបអង្អែលរបស់អត្តានុទិដ្ឋិដោយអាការ ២០ យ៉ាង ។

[ ៤០ ] ការប្រកាន់ស្អិតរបស់មិច្ឆាទិដ្ឋិដោយអាការ ១០ តើដូចម្តេច ។ ការប្រកាន់ពោលយ៉ាងនេះចំពោះវត្ថុថា ទានដែលបុគ្គលឲ្យហើយមិនមានផលដូច្នេះ ឈ្មោះថា ទិដ្ឋិ គឺការប្រកាន់ស្អិត និងការស្ទាបអង្អែលនៃមិច្ឆាទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុមិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និងវត្ថុណានេះឈ្មោះថា មិច្ឆាទិដ្ឋិ ជាមិច្ឆាវត្ថុកៈទី ១ មិច្ឆាទិដ្ឋិ ជាទិដ្ឋិវិបត្តិ ។បេ។ នេះសំយោជនៈ មិនមែនទិដ្ឋិ ។ ចំពោះវត្ថុថា ការបូជាធំមិនមានផល ។បេ។ ចំពោះវត្ថុថា ការបូជាតូចមិនមានផល ចំពោះវត្ថុថា ផលវិបាកនៃកម្មដែលបុគ្គលធ្វើល្អ និងអាក្រក់មិនមាន ចំពោះវត្ថុថា លោកនេះមិនមាន ចំពោះវត្ថុថា លោកខាងមុខមិន

មាន ចំពោះវត្ថុថា មាតាមិនមានគុណ ចំពោះវត្ថុថា បិតាមិនមានគុណ ចំពោះវត្ថុថា សត្វជាឱបបាតិកកំណើតមិនមាន ការប្រកាន់ពោលយ៉ាងនេះចំពោះវត្ថុថា ពួកសមណ និងព្រាហ្មណ៍ក្នុងលោកដែលជាអ្នកព្រមព្រៀងគ្នាប្រតិបត្តិត្រឹមត្រូវ ធ្វើឲ្យជាក់ច្បាស់ដោយបញ្ញារបស់ខ្លួននូវលោកនេះ និងលោកខាងមុខ ហើយប្រកាសបាន មិនមានឡើយដូច្នេះ ឈ្មោះថា ទិដ្ឋិ គឺការប្រកាន់ស្អិត និងការស្ទាបអង្អែលនៃមិច្ឆាទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុមិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និងវត្ថុណា នេះឈ្មោះថា មិច្ឆាទិដ្ឋិមានវត្ថុ ១០ មិច្ឆា-ទិដ្ឋិ ជាទិដ្ឋិវិបត្តិ ។បេ។ បុរសបុគ្គលអ្នកប្រកបដោយមិច្ឆាទិដ្ឋិ តែងមានគតិ ២ យ៉ាង ។បេ។ នេះសំយោជនៈ មិនមែនទិដ្ឋិ នេះឯងការប្រកាន់ស្អិតនៃមិច្ឆាទិដ្ឋិ ដោយអាការ ១០ យ៉ាង ។

[ ៤១ ] ការប្រកាន់ស្អិតនៃសក្កាយទិដ្ឋិ ដោយអាការ ២០ តើដូចម្តេច ។ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនចេះដឹង មិនបានឃើញពួកព្រះអរិយៈ មិនឈ្លាសវៃក្នុងធម៌របស់ព្រះអរិយៈ មិនទូន្មានខ្លួនក្នុងធម៌របស់ព្រះអរិយៈ មិនបានជួបប្រទះនឹងពួកសប្បុរស មិនឈ្លាសវៃក្នុងធម៌របស់សប្បុរស មិនទូន្មានខ្លួនក្នុងធម៌របស់សប្បុរស តែងពិចារណាឃើញរូបថាជាខ្លួន ពិចារណាឃើញខ្លួនថាមានរូបខ្លះ ពិចារណាឃើញរូបថាមានក្នុងខ្លួនខ្លះ ពិចារណាឃើញខ្លួនថាមានក្នុងរូបខ្លះ ពិចារណាឃើញវេទនា សញ្ញា សង្ខារ វិញ្ញាណ ថាជាខ្លួន ពិចារណាឃើញខ្លួន ថាមានវិញ្ញាណខ្លះ ពិចារណាវិញ្ញាណ ថាមានក្នុងខ្លួនខ្លះ ពិចារណាឃើញខ្លួន ថាមានក្នុងវិញ្ញាណខ្លះ ។

បុគ្គលពិចារណាឃើញរូបថាជាខ្លួន តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញបឋវីកសិណ ។បេ។ ពិចារណាឃើញឱទាតកសិណថាជាខ្លួន ថាធម្មជាតណាជាឱទាតកសិណ សភាពនោះ គឺអញ សភាពណា គឺអញ ធម្មជាតនោះ គឺឱទាតកសិណ ឈ្មោះថា ពិចារណាឃើញឱទាតកសិណ និងខ្លួនថា មិនមែនពីរ ប្រៀបដូចប្រទីបប្រេងដែលឆេះ ។បេ។ មានឧបមេយ្យដូចជា បុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញឱទាតកសិណថាជាខ្លួន ការប្រកាន់ស្អិត និងការស្ទាបអង្អែល ឈ្មោះថា ទិដ្ឋិ ។បេ។ នេះឈ្មោះថា សក្កាយទិដ្ឋិជារូបវត្ថុកៈទី ១ សក្កាយទិដ្ឋិជាមិច្ឆាទិដ្ឋិ ។បេ។ នេះសំយោជនៈ មិនមែនទិដ្ឋិ បុគ្គលពិចារណាឃើញរូបថាជាខ្លួនយ៉ាងនេះឯង ។បេ។ នេះឯងការប្រកាន់ស្អិតនៃសក្កាយទិដ្ឋិ ដោយអាការ ២០ យ៉ាង ។

[ ៤២ ] ការប្រកាន់ស្អិតនៃសស្សតទិដ្ឋិ ជាសក្កាយវត្ថុកៈដោយអាការ ១៥ យ៉ាង តើដូចម្តេច ។ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនចេះដឹង មិនបានឃើញពួកព្រះអរិយៈ មិនឈ្លាសវៃក្នុងធម៌របស់ព្រះអរិយៈ មិនទូន្មានខ្លួនក្នុងធម៌របស់ព្រះអរិយៈ មិនបានជួបប្រទះនឹងពួកសប្បុរស មិនឈ្លាសវៃក្នុងធម៌របស់សប្បុរស មិនទូន្មានខ្លួនក្នុងធម៌របស់សប្បុរស តែងពិចារណាឃើញនូវខ្លួនថាមានរូបខ្លះ នូវរូបថាមានក្នុងខ្លួនខ្លះ នូវខ្លួនថាមានក្នុងរូបខ្លះ នូវខ្លួនថាមានវេទនាខ្លះ នូវខ្លួនថា មានសញ្ញាខ្លះ នូវខ្លួនថា មានសង្ខារខ្លះ នូវខ្លួនថាមានវិញ្ញាណខ្លះ នូវវិញ្ញាណថាមានក្នុងខ្លួនខ្លះ នូវខ្លួនថាមានក្នុងវិញ្ញាណខ្លះ ។

បុគ្គលពិចារណាឃើញខ្លួនថាមានរូប តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោក

នេះ ពិចារណាឃើញវេទនា សញ្ញា សង្ខារ វិញ្ញាណថាជាខ្លួន បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា នេះឯងខ្លួនរបស់អញ តែខ្លួនរបស់អញនេះឯងមានរូប ព្រោះរូបនេះ ឈ្មោះថា ពិចារណាឃើញខ្លួនថាមានរូប ប្រៀបដូចដើមឈើដែលបរិបូណ៌ដោយម្លប់ បុរសគប្បីពោលចំពោះដើមឈើនុ៎ះយ៉ាងនេះថា នេះដើមឈើ នេះម្លប់ ដើមឈើដោយឡែក ម្លប់ដោយឡែក តែដើមឈើនេះឯងមានម្លប់ព្រោះម្លប់នេះ ឈ្មោះថា ពិចារណាឃើញដើមឈើ ថាមានម្លប់មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចជាបុគ្គលខ្លះក្នុងលោកនេះ ( ពិចា-រណាឃើញ ) នូវវេទនា ។បេ។ នេះឈ្មោះថា សស្សតទិដ្ឋិ ជាសក្កាយវត្ថុកៈទី ១ សស្សតទិដ្ឋិជាមិច្ឆាទិដ្ឋិ ។បេ។ នេះសំយោជនៈមិនមែនទិដ្ឋិ បុគ្គលពិចារណាឃើញខ្លួន ថាមានរូបយ៉ាងនេះឯង ។បេ។ នេះឯងការប្រកាន់ស្អិតនៃ សស្សតទិដ្ឋិ ជាសក្កាយវត្ថុកៈ ដោយអាការ ១៥ យ៉ាង ។

[ ៤៣ ] ការប្រកាន់ស្អិតនៃឧច្ឆេទទិដ្ឋិ ជាសក្កាយវត្ថុកៈ ដោយអាការ ៥ យ៉ាង តើដូចម្តេច ។ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនចេះដឹង មិនបានឃើញពួកព្រះអរិយៈ មិនឈ្លាសវៃក្នុងធម៌របស់ព្រះអរិយៈ មិនទូន្មានខ្លួន ក្នុងធម៌របស់ព្រះអរិយៈ មិនបានជួបប្រទះនឹងពួកសប្បុរស មិនឈ្លាសវៃ ក្នុងធម៌របស់សប្បុរស មិនទូន្មានខ្លួនក្នុងធម៌របស់សប្បុរស តែងពិចារណាឃើញរូបថាជាខ្លួន ពិចារណាឃើញវេទនាថាជាខ្លួន ពិចារណាឃើញសញ្ញាថាជាខ្លួន ពិចារណាឃើញសង្ខារថាជាខ្លួន ពិចារណាឃើញវិញ្ញាណថាជាខ្លួន ។

បុគ្គលពិចារណាឃើញរូបថាជាខ្លួន តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ

ពិចារណាឃើញបបរិកសិណ ។បេ។ ពិចារណាឃើញឱទាតកសិណថាជាខ្លួន ជាធម្មជាតណាជាឱទាតកសិណ សភាពនោះ គឺអញ សភាពណា គឺអញ ធម្មជាតនោះ គឺឱទាតកសិណ ឈ្មោះថា ពិចារណាឃើញឱទាតកសិណផង នូវខ្លួនផង ថាមិនមែនពីរ ប្រៀបដូចប្រទីបប្រេងដែលឆេះ ។បេ។ នេះឧច្ឆេទទិដ្ឋិជាសក្កាយវត្ថុកៈទី ១ ឧច្ឆេទទិដ្ឋិជាមិច្ឆាទិដ្ឋិ ។បេ។ នេះសំយោជនៈ មិនមែនទិដ្ឋិ បុគ្គលពិចារណាឃើញរូបថាជាខ្លួនយ៉ាងនេះឯង ។បេ។ នេះការប្រកាន់ស្អិតនៃឧច្ឆេទទិដ្ឋិ ជាសក្កាយវត្ថុកៈ ដោយអាការ ៥ យ៉ាង ។

[ ៤៤ ] ការប្រកាន់ស្អិតនៃអន្តគ្គាហិកទិដ្ឋិ ដោយអាការ ៥០ តើដូចម្តេច ។ ការប្រកាន់ស្អិតនៃអន្តគ្គាហិកទិដ្ឋិថា លោកទៀងដោយអាការប៉ុន្មាន ការប្រកាន់ស្អិតនៃអន្តគ្គាហិកទិដ្ឋិថា លោកមិនទៀងដោយអាការប៉ុន្មាន ការប្រកាន់ស្អិតនៃអន្តគ្គាហិកទិដ្ឋិ ថាលោកមានទីបំផុត នៃអន្តគ្គាហិកទិដ្ឋិថាលោកមិនមានទីបំផុត នៃអន្តគ្គាហិកទិដ្ឋិថា ជីវៈនោះ សរីរៈនោះ នៃអន្តគ្គាហិកទិដ្ឋិថា ជីវៈដទៃ សរីរៈដទៃ ថាសត្វខាងមុខអំពីសេចក្តីស្លាប់កើតទៀត ។បេ។ ថាសត្វខាងមុខអំពីសេចក្តីស្លាប់មិនកើតទៀត ថាសត្វខាងមុខអំពីសេចក្តីស្លាប់ កើតទៀតក៏មាន មិនកើតទៀតក៏មាន ការប្រកាន់ស្អិតនៃអន្តគ្គាហិកទិដ្ឋិថាសត្វខាងមុខអំពីសេចក្តីស្លាប់កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន តើដោយអាការប៉ុន្មាន ។ ការប្រកាន់ស្អិតនៃអន្តគ្គាហិកទិដ្ឋិ ថាលោកទៀងដោយអាការ ៥ យ៉ាង ។បេ។ ការប្រកាន់ស្អិតនៃអន្តគ្គាហិកទិដ្ឋិថា សត្វខាងមុខអំពីសេចក្តីស្លាប់កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ដោយអាការ ៥ យ៉ាង ។

[ ៤៥ ] ការប្រកាន់ស្អិតនៃអន្តគ្គាហិកទិដ្ឋិថា លោកទៀងដោយអាការ ៥ យ៉ាង តើដូចម្ដេច ។ ទិដ្ឋិ គឺការប្រកាន់ស្អិត និងការស្ទាបអង្អែលថា រូបជាលោកផង ជាធម្មជាតទៀងផង បុគ្គលប្រកាន់ទីបំផុតនោះដោយទិដ្ឋិនោះ ព្រោះហេតុនោះ ឈ្មោះថា អន្តគ្គាហិកទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុមិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និងវត្ថុណា នេះឈ្មោះថា អន្តគ្គាហិកទិដ្ឋិ ថាលោកទៀងជាទិដ្ឋិទី ១ អន្តគ្គាហិកទិដ្ឋិ ឈ្មោះថា មិច្ឆាទិដ្ឋិ ។បេ។ នេះសំយោជនៈ មិនមែនទិដ្ឋិ ។ ថាវេទនាជាលោកផង ជាធម្មជាតទៀងផង ។បេ។ ថាសញ្ញាជាលោកផង ជាធម្មជាតទៀងផង ។បេ។ ថាសង្ខារជាលោកផង ជាធម្មជាតទៀងផង ។បេ។ ទិដ្ឋិ គឺការប្រកាន់ស្អិត និងការស្ទាបអង្អែលថាវិញ្ញាណជាលោកផង ជាធម្មជាតទៀងផង បុគ្គលប្រកាន់ទីបំផុតនោះដោយទិដ្ឋិនោះ ព្រោះហេតុនោះ ឈ្មោះថា អន្តគ្គាហិកទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុមិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និងវត្ថុណា នេះឈ្មោះថា អន្តគ្គា-ហិកទិដ្ឋិ ថាលោកទៀងជាទិដ្ឋិទី ៥ អន្តគ្គាហិកទិដ្ឋិជាមិច្ឆាទិដ្ឋិ ។បេ។ នេះសំយោជនៈ មិនមែនទិដ្ឋិ នេះឯងការប្រកានក់ស្អិតនៃអន្តគ្គាហិកទិដ្ឋិ ថាលោកទៀងដោយអាការ ៥ យ៉ាង ។

[ ៤៦ ] ការប្រកាន់ស្អិតនៃអន្តគ្គាហិកទិដ្ឋិថា លោកមិនទៀង ដោយអាការ ៥ តើដូចម្ដេច ។ ទិដ្ឋិ គឺការប្រកាន់ស្អិត និងការស្ទាបអង្អែលថា រូបជាលោកផង ជាធម្មជាតមិនទៀងផង បុគ្គលប្រកាន់ទីបំផុតនោះដោយទិដ្ឋិនោះ ព្រោះហេតុនោះ ឈ្មោះថា អន្តគ្គាហិកទិដ្ឋិ ។បេ។ នេះឈ្មោះថា អន្តគ្គាហិកទិដ្ឋិ ថា

លោកមិនទៀង ជាទិដ្ឋិទី ១ អន្តគ្គាហិកទិដ្ឋិ ជាមិច្ឆាទិដ្ឋិជាទិដ្ឋិវិបត្តិ ។បេ។ នេះសំយោជនៈ មិនមែនទិដ្ឋិ ។បេ។ ថាវេទនាជាលោកផង ជាធម្មជាតមិនទៀងផង ។បេ។ ថាសញ្ញាជាលោកផង ជាធម្មជាតមិនទៀងផង ។បេ។ ថាសង្ខារជាលោកផង ជាធម្មជាតមិនទៀងផង ។បេ។ ទិដ្ឋិ គឺការប្រកាន់ស្អិត និងការស្ទាបអង្អែលថា វិញ្ញាណជាលោកផង ជាធម្មជាតមិនទៀងផង បុគ្គលប្រកាន់ទីបំផុតនោះដោយទិដ្ឋិនោះ ព្រោះហេតុនោះ ឈ្មោះថា អន្តគ្គាហិកទិដ្ឋិ អន្តគ្គាហិកទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ។បេ។ នេះសំយោជនៈ មិនមែនទិដ្ឋិ នេះឯងការប្រកាន់ស្អិតនៃអន្តគ្គាហិកទិដ្ឋិ ថាលោកមិនទៀង ដោយអាការ ៥ យ៉ាង ។

[ ៤៧ ] ការប្រកាន់ស្អិតនៃអន្តគ្គាហិកទិដ្ឋិថា លោកមានទីបំផុតដោយអាការ ៥ តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ មាននីលកសិណបរិកម្មហើយ តែងផ្សាយទៅកាន់ឱកាសតិចតួច បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា លោកនេះមានទីបំផុត មានផ្លូវជុំវិញ បុគ្គលនោះ ឈ្មោះថា អ្នកមានសេចក្តីសម្គាល់នូវទីបំផុត ទិដ្ឋិ គឺការប្រកាន់ស្អិត និងការស្ទាបអង្អែលថា ធម្មជាតណាផ្សាយទៅ ធម្មជាតនោះ ឈ្មោះថា វត្ថុផង ឈ្មោះថា លោកផង វត្ថុ និងលោកផ្សាយទៅដោយសភាវៈណា សភាវៈនោះ ឈ្មោះថា ខ្លួនផង ឈ្មោះថា លោកផង បុគ្គលប្រកាន់ទីបំផុតនោះដោយទិដ្ឋិនោះ ព្រោះហេតុនោះ ឈ្មោះថា អន្តគ្គាហិកទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុមិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និងវត្ថុណា នេះឈ្មោះថា អន្តគ្គាហិកទិដ្ឋិ ថាលោកមានទីបំផុត ជាទិដ្ឋិទី ១ អន្តគ្គាហិកទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ។បេ។ នេះសំយោជនៈ មិនមែនទិដ្ឋិ

បុគ្គលខ្លះក្នុងលោកនេះ មានបីតកសិណាបរិកម្មហើយ តែងផ្សាយទៅកាន់ឱកាសតិចតួច មានលោហិតកសិណាបរិកម្មហើយ តែងផ្សាយទៅ មានឱទាតកសិណាបរិកម្មហើយ តែងផ្សាយទៅ មានឱកាសកសិណាបរិកម្មហើយ តែងផ្សាយទៅ បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា លោកនេះមានទីបំផុត មានផ្លូវជុំវិញ បុគ្គលនោះ ឈ្មោះថា មានសេចក្តីសម្គាល់នូវទីបំផុត ទិដ្ឋិ គឺការប្រកាន់ស្អិត និងការស្ទាបអង្អែលថា ធម្មជាតណាផ្សាយទៅ ធម្មជាតនោះ ឈ្មោះថា វត្ថុផង ឈ្មោះថា លោកផង វត្ថុ និងលោក ផ្សាយទៅដោយសភាវៈណា សភាវៈនោះ ឈ្មោះថា ខ្លួនផង ឈ្មោះថា លោកផង បុគ្គលប្រកាន់ទីបំផុតនោះដោយទិដ្ឋិនោះ ព្រោះហេតុនោះ ឈ្មោះថា អន្តគ្គាហិកទិដ្ឋិ។បេ។នេះឯងការប្រកាន់ស្អិតនៃអន្តគ្គាហិកទិដ្ឋិថា លោកមានទីបំផុតដោយអាការ ៥ យ៉ាង ។

[ ៤៨ ] ការប្រកាន់ស្អិតនៃអន្តគ្គាហិកទិដ្ឋិថា លោកមិនមានទីបំផុតដោយអាការ ៥ តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ មាននីលកសិណាបរិកម្មហើយ តែងផ្សាយទៅកាន់ឱកាសដ៏ធំទូលាយ បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា លោកនេះមិនមានទីបំផុត មិនមានទីបំផុតដោយជុំវិញ បុគ្គលនោះ ឈ្មោះថា អ្នកមានសេចក្តីសម្គាល់ថាមិនមានទីបំផុត ទិដ្ឋិ គឺការប្រកាន់ស្អិត និងការស្ទាបអង្អែលថា ធម្មជាតណាផ្សាយទៅ ធម្មជាតនោះ ឈ្មោះថា វត្ថុផង ឈ្មោះថា លោកផង វត្ថុ និងលោកផ្សាយទៅដោយសភាវៈណា សភាវៈនោះ ឈ្មោះថា ខ្លួនផង ឈ្មោះថា លោកផង បុគ្គលប្រកាន់ទីបំផុតនោះដោយទិដ្ឋិនោះ ព្រោះហេតុនោះ ឈ្មោះថា អន្តគ្គាហិកទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុមិនមែនទិដ្ឋិ

ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និងវត្ថុណា នេះឈ្មោះថា អន្តគ្គាហិកទិដ្ឋិថា លោកមិនមានទីបំផុត ជាទិដ្ឋិទី ១ អន្តគ្គាហិកទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ។បេ។ នេះសំយោជនៈ មិនមែនទិដ្ឋិ បុគ្គលខ្លះក្នុងលោកនេះ មានបីតកសិណបរិកម្មហើយ តែងផ្សាយទៅកាន់ឱកាសដ៏ធំទូលាយ មានលោហិតកសិណបរិកម្មហើយ តែងផ្សាយទៅ មានឱទាតកសិណបរិកម្មហើយ តែងផ្សាយទៅ មានឱកាសកសិណបរិកម្មហើយ តែងផ្សាយទៅ បុគ្គលនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា លោកនេះមិនមានទីបំផុត មិនមានទីបំផុតដោយជុំវិញ បុគ្គលនោះ ឈ្មោះថា អ្នកមានសេចក្តីសម្គាល់ថាមិនមានទីបំផុត ទិដ្ឋិ គឺការប្រកាន់ស្អិត និងការស្ទាបអង្អែលថា ធម្មជាតណាផ្សាយទៅ ធម្មជាតនោះ ឈ្មោះថាវត្ថុផង ឈ្មោះថា លោកផងវត្ថុ និងលោក តែងផ្សាយទៅដោយសភាវៈណា សភាវៈនោះ ឈ្មោះថា ខន្ធផង ឈ្មោះថា លោកផង បុគ្គលប្រកាន់ទីបំផុតនោះដោយទិដ្ឋិនោះ ព្រោះហេតុនោះ ឈ្មោះថា អន្តគ្គាហិកទិដ្ឋិ ។បេ។ នេះឯងការប្រកាន់ស្អិតនៃអន្តគ្គាហិកទិដ្ឋិថា លោកមិនមានទីបំផុតដោយអាការ ៥ យ៉ាង ។

[ ៤៩ ] ការប្រកាន់ស្អិតនៃអន្តគ្គាហិកទិដ្ឋិថា ជីវិតនោះ សរីរៈនោះ ដោយអាការ ៥ តើដូចម្តេច ។ ទិដ្ឋិ គឺការប្រកាន់ស្អិត និងការស្ទាបអង្អែលថា រូបជាជីវិតផង ជាសរីរៈផង ធម្មជាតណាជាជីវិត ធម្មជាតនោះជាសរីរៈ បុគ្គលប្រកាន់ទីបំផុតនោះដោយទិដ្ឋិនោះ ព្រោះហេតុនោះ ឈ្មោះថា អន្តគ្គាហិកទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុមិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និងវត្ថុណា នេះឈ្មោះថា អន្តគ្គាហិកទិដ្ឋិថា ជីវិតនោះ សរីរៈនោះជាទិដ្ឋិទី ១ អន្តគ្គា-

ហិកទិដ្ឋិជាមិច្ឆាទិដ្ឋិ ។បេ។ នេះសំយោជនៈ មិនមែនទិដ្ឋិ ទិដ្ឋិ គឺការប្រកាន់ស្អិត និងការស្ទាបអង្អែលថា វេទនាជាជីវិតផង ជាសរីរៈផង សញ្ញាជាជីវិតផង ជាសរីរៈផង សង្ខារជាជីវិតផង ជាសរីរៈផង វិញ្ញាណជាជីវិតផង ជាសរីរៈផង ធម្មជាតណាជាជីវិត ធម្មជាតនោះជាសរីរៈ បុគ្គលប្រកាន់ទីបំផុតនោះដោយទិដ្ឋិនោះ ព្រោះហេតុនោះ ឈ្មោះថា អន្តគ្គាហិកទិដ្ឋិ ។បេ។ នេះឯងការប្រកាន់ស្អិតនៃអន្តគ្គាហិកទិដ្ឋិថា ជីវិតនោះ សរីរៈនោះ ដោយអាការ ៥ យ៉ាង ។

[ ៥០ ] ការប្រកាន់ស្អិតនៃអន្តគ្គាហិកទិដ្ឋិថា ជីវិតដទៃ សរីរៈដទៃដោយអាការ ៥ តើដូចម្តេច ។ ទិដ្ឋិ គឺការប្រកាន់ស្អិត និងការស្ទាបអង្អែលថា រូបជាសរីរៈ មិនមែនជាជីវិតទេ រូបនោះពិតជាសរីរៈ ជីវិតដទៃ សរីរៈដទៃ បុគ្គលប្រកាន់ទីបំផុតនោះដោយទិដ្ឋិនោះ ព្រោះហេតុនោះ ឈ្មោះថា អន្តគ្គាហិកទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុមិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និងវត្ថុណា នេះឈ្មោះថា អន្តគ្គាហិកទិដ្ឋិថា ជីវិតដទៃ សរីរៈដទៃ ជាទិដ្ឋិទី ១ អន្តគ្គាហិកទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ។បេ។ នេះសំយោជនៈ មិនមែនទិដ្ឋិ ទិដ្ឋិ គឺការប្រកាន់ស្អិត និងការស្ទាបអង្អែលថា វេទនាជាសរីរៈ មិនមែនជាជីវិតទេ សញ្ញាជាសរីរៈ មិនមែនជាជីវិតទេ សង្ខារជាសរីរៈ មិនមែនជាជីវិតទេ វិញ្ញាណជាសរីរៈ មិនមែនជាជីវិតទេ វិញ្ញាណនោះ ពិតជាសរីរៈ ជីវិតដទៃ សរីរៈដទៃ បុគ្គលប្រកាន់ទីបំផុតនោះដោយទិដ្ឋិនោះ ព្រោះហេតុនោះ ឈ្មោះថា អន្តគ្គាហិកទិដ្ឋិ ។បេ។ នេះឯងការប្រកាន់ស្អិតនៃអន្តគ្គាហិកទិដ្ឋិថា ជីវិតដទៃ សរីរៈដទៃ ដោយអាការ ៥ យ៉ាង ។

[ ៥១ ] ការប្រកាន់ស្អិតនៃអន្តគ្គាហិកទិដ្ឋិថា សត្វខាងមុខអំពីសេចក្តីស្លាប់កើតទៀតដោយអាការ ៥ តើដូចម្តេច ។ ទិដ្ឋិ គឺការប្រកាន់ស្អិត និងការស្ទាបអង្អែលថា រូបក្នុងលោកនេះឯង មានមរណៈជាធម្មតា សត្វលុះទម្លាយរាងកាយស្លាប់ទៅ កើតទៀតខ្លះ តាំងនៅខ្លះ កើតឡើងខ្លះ កើតប្រាកដខ្លះ បុគ្គលប្រកាន់ទីបំផុតនោះ ដោយទិដ្ឋិនោះ ព្រោះហេតុនោះ ឈ្មោះថា អន្តគ្គាហិក-ទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុមិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និងវត្ថុណា នេះឈ្មោះថា អន្តគ្គាហិកទិដ្ឋិថា សត្វខាងមុខអំពីសេចក្តីស្លាប់កើតទៀត ជាទិដ្ឋិទី ១ អន្តគ្គាហិកទិដ្ឋិជាមិច្ឆាទិដ្ឋិ ។បេ។ នេះសំយោជនៈ មិនមែនទិដ្ឋិ ទិដ្ឋិ គឺការប្រកាន់ស្អិត និងការស្ទាបអង្អែលថា វេទនាក្នុងលោកនេះឯង មានមរណៈជាធម្មតា សញ្ញាក្នុងលោកនេះឯង មានមរណៈជាធម្មតា សង្ខារក្នុងលោកនេះឯង មានមរណៈជាធម្មតា វិញ្ញាណក្នុងលោកនេះឯង មានមរណៈជាធម្មតា សត្វលុះទម្លាយរាងកាយស្លាប់ទៅកើតទៀតខ្លះ តាំងនៅខ្លះ កើតឡើងខ្លះ កើតប្រាកដខ្លះ បុគ្គលប្រកាន់ទីបំផុតនោះ ដោយទិដ្ឋិនោះ ព្រោះហេតុនោះ ឈ្មោះថា អន្តគ្គាហិកទិដ្ឋិ ។បេ។ នេះឯងការប្រកាន់ស្អិតនៃអន្តគ្គាហិកទិដ្ឋិថា សត្វខាងមុខអំពីសេចក្តីស្លាប់កើតទៀត ដោយអាការ ៥ យ៉ាង ។

[ ៥២ ] ការប្រកាន់ស្អិតនៃអន្តគ្គាហិកទិដ្ឋិថា សត្វខាងមុខអំពីសេចក្តីស្លាប់មិនកើតទៀត ដោយអាការ ៥ តើដូចម្តេច ។ ទិដ្ឋិ គឺការប្រកាន់ស្អិត និងការស្ទាបអង្អែលថា រូបក្នុងលោកនេះឯង មានមរណៈជាធម្មតា សត្វលុះទម្លាយរាងកាយស្លាប់ទៅតែងសូន្យ តែងវិនាស សត្វខាងមុខអំពីសេចក្តីស្លាប់ មិន

កើតទៀតទេ បុគ្គលប្រកាន់ទីបំផុតនោះដោយទិដ្ឋិនោះ ព្រោះហេតុនោះ ឈ្មោះថា អន្តគ្គាហិកទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុមិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និងវត្ថុណា នេះឈ្មោះថា អន្តគ្គាហិកទិដ្ឋិថា សត្វខាងមុខអំពីសេចក្ដីស្លាប់ មិនកើតទៀត ជាទិដ្ឋិទី ១ អន្តគ្គាហិកទិដ្ឋិជាមិច្ឆាទិដ្ឋិ ។បេ។ នេះសំយោជនៈ មិនមែនទិដ្ឋិ ទិដ្ឋិ គឺការប្រកាន់ស្អិត និងការស្ទាបអង្អែលថា វេទនាក្នុងលោកនេះឯងមានមរណៈជាធម្មតា សញ្ញាក្នុងលោកនេះឯងមានមរណៈជាធម្មតា សង្ខារក្នុងលោកនេះឯងមានមរណៈជាធម្មតា វិញ្ញាណក្នុងលោកនេះឯងមានមរណៈជាធម្មតា សត្វលុះទម្លាយរាងកាយស្លាប់ទៅតែងសូន្យ តែងវិនាស សត្វខាងមុខអំពីសេចក្ដីស្លាប់ មិនកើតទៀតទេ បុគ្គលប្រកាន់ទីបំផុតនោះដោយទិដ្ឋិនោះ ព្រោះហេតុនោះ ឈ្មោះថា អន្តគ្គាហិកទិដ្ឋិ ។បេ។ នេះឯងការប្រកាន់ស្អិតនៃអន្តគ្គាហិកទិដ្ឋិថា សត្វខាងមុខអំពីសេចក្ដីស្លាប់ មិនកើតទៀតដោយអាការ ៥ យ៉ាង ។

[ ៥៣ ] ការប្រកាន់ស្អិតនៃអន្តគ្គាហិកទិដ្ឋិថា សត្វខាងមុខអំពីសេចក្ដីស្លាប់ កើតទៀតក៏មាន មិនកើតទៀតក៏មាន ដោយអាការ ៥ តើដូចម្ដេច ។ ទិដ្ឋិ គឺការប្រកាន់ស្អិត និងការស្ទាបអង្អែលថា រូបក្នុងលោកនេះឯងមានមរណៈជាធម្មតា សត្វលុះទម្លាយរាងកាយស្លាប់ទៅ កើតទៀតក៏មាន មិនកើតទៀតក៏មាន បុគ្គលប្រកាន់ទីបំផុតនោះដោយទិដ្ឋិនោះ ព្រោះហេតុនោះ ឈ្មោះថា អន្តគ្គាហិកទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុមិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និងវត្ថុណា នេះឈ្មោះថា អន្តគ្គាហិកទិដ្ឋិថា សត្វខាងមុខអំពីសេចក្ដី

ស្លាប់ទៅ កើតទៀតក៏មាន មិនកើតទៀតក៏មាន ជាទិដ្ឋិទី ១ អន្តគ្គាហិកទិដ្ឋិជា មិច្ឆាទិដ្ឋិ ។បេ។ នេះសំយោជនៈ មិនមែនទិដ្ឋិ ទិដ្ឋិ គឺការប្រកាន់ស្អិត និងការស្ទាប អង្អែលថា វេទនាក្នុងលោកនេះឯងមានមរណៈជាធម្មតា សញ្ញាក្នុងលោកនេះ ឯងមានមរណៈជាធម្មតា សង្ខារក្នុងលោកនេះឯង មានមរណៈជាធម្មតា វិញ្ញាណក្នុងលោកនេះឯងមានមរណៈជាធម្មតា សត្វលុះទម្លាយរាងកាយស្លាប់ ទៅ កើតទៀតក៏មាន មិនកើតទៀតក៏មាន បុគ្គលប្រកាន់ទីបំផុតនោះដោយ ទិដ្ឋិនោះ ព្រោះហេតុនោះ ឈ្មោះថា អន្តគ្គាហិកទិដ្ឋិ ។បេ។ នេះឯងការប្រកាន់ ស្អិតនៃអន្តគ្គាហិកទិដ្ឋិថា សត្វខាងមុខអំពីសេចក្តីស្លាប់ កើតទៀតក៏មាន មិន កើតទៀតក៏មាន ដោយអាការ ៥ យ៉ាង ។

[ ៥៤ ] ការប្រកាន់ស្អិតនៃអន្តគ្គាហិកទិដ្ឋិថា សត្វខាងមុខអំពីសេចក្តី ស្លាប់ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ដោយអការ ៥ តើដូច ម្តេច ។ ទិដ្ឋិ គឺការប្រកាន់ស្អិត និងការស្ទាបអង្អែលថា រូបក្នុងលោកនេះឯងមាន មរណៈជាធម្មតា សត្វលុះទម្លាយរាងកាយស្លាប់ទៅ កើតទៀតក៏មិនមែន មិន កើតទៀតក៏មិនមែន បុគ្គលប្រកាន់ទីបំផុតនោះដោយទិដ្ឋិនោះ ព្រោះហេតុនោះ ឈ្មោះថា អន្តគ្គាហិកទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុមិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុ ដោយឡែក ទិដ្ឋិណា និងវត្ថុណា នេះឈ្មោះថា អន្តគ្គាហិកទិដ្ឋិថា សត្វខាងមុខ អំពីសេចក្តីស្លាប់ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ជាទិដ្ឋិទី ១ អន្តគ្គាហិកទិដ្ឋិជាមិច្ឆាទិដ្ឋិ ។បេ។ នេះសំយោជនៈ មិនមែនទិដ្ឋិ ទិដ្ឋិ គឺការប្រកាន់ ស្អិត និងការស្ទាបអង្អែលថា វេទនាក្នុងលោកនេះឯង មានមរណៈជាធម្មតា

សញ្ញាក្នុងលោកនេះឯង មានមរណៈជាធម្មតា សង្ខារក្នុងលោកនេះឯង មានមរណៈជាធម្មតា វិញ្ញាណក្នុងលោកនេះឯង មានមរណៈជាធម្មតា សត្វលុះទម្លាយរាងកាយស្លាប់ទៅ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន បុគ្គលប្រកាន់ទីបំផុតនោះដោយទិដ្ឋិនោះ ព្រោះហេតុនោះ ឈ្មោះថា អន្តគ្គាហិកទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុមិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និងវត្ថុណា នេះឈ្មោះថា អន្តគ្គាហិកទិដ្ឋិថា សត្វខាងមុខអំពីសេចក្ដីស្លាប់កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ជាទិដ្ឋិទី ៥ អន្តគ្គាហិកទិដ្ឋិជាមិច្ឆាទិដ្ឋិ ។បេ។ នេះសំយោជនៈ មិនមែនទិដ្ឋិ នេះការប្រកាន់ស្អិតនៃអន្តគ្គាហិកទិដ្ឋិថា សត្វខាងមុខអំពីសេចក្ដីស្លាប់ កើតទៀតក៏មិមែន មិនកើតទៀតក៏មិមែន ដោយអាការ ៥ យ៉ាងនេះឯង ការប្រកាន់នៃអន្តគ្គាហិកទិដ្ឋិ ដោយអាការ ៥០ យ៉ាង ។

[ ៥៥ ] ការប្រកាន់ស្អិតនៃបុព្វន្តានុទិដ្ឋិដោយអាការ ១៨ តើដូចម្ដេច ។ សស្សតវាទ ៤ ឯកច្ចសស្សតវាទ ៤ អន្តានន្តវាទ ៤ អមរាវិក្ខេបវាទ ៤ អធិច្ចសមុប្បន្នវាទ ២ នេះការប្រកាន់ស្អិតនៃបុព្វន្តានុទិដ្ឋិដោយការ ១៨ យ៉ាង ។

[ ៥៦ ] ការប្រកាន់ស្អិតនៃអបរន្តានុទិដ្ឋិដោយអាការ ៤៤ តើដូចម្ដេច ។ សញ្ញិវាទ ១៦ អសញ្ញិវាទ ៨ នេវសញ្ញិនាសញ្ញិវាទ ៨ ឧច្ឆេទវាទ ៧ ទិដ្ឋធម្មនិព្វានវាទ ៥ នេះការប្រកាន់ស្អិតនៃអបរន្តានុទិដ្ឋិដោយអាការ ៤៤ យ៉ាង ។

[ ៥៧ ] ការប្រកាន់ស្អិតនៃទិដ្ឋិប្រកបដោយសំយោជនៈ ដោយអាការ ១៨ តើដូចម្ដេច ។ ទិដ្ឋិ ដំណើរ គឺទិដ្ឋិ ការប្រកាន់ គឺទិដ្ឋិ ។បេ។ ការប្រកាន់ស្អិត គឺទិដ្ឋិ ការស្ទាបអង្អែល គឺទិដ្ឋិឯណា នេះការប្រកាន់ស្អិតនៃទិដ្ឋិ ប្រកប

ដោយសំយោជនៈ ដោយអាការ ១៨ យ៉ាង ។

[ ៥៨ ] ការប្រកាន់ស្អិតនៃមានវិនិពន្ធទិដ្ឋិថាអញ ដោយអាការ ១៨ តើដូចម្តេច ។ ការប្រកាន់ស្អិតថា ភ្នែកជាអញ ឈ្មោះថា មានវិនិពន្ធទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុមិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និងវត្ថុណា នេះឈ្មោះថា មានវិនិពន្ធទិដ្ឋិថាអញ ជាទិដ្ឋិទី ១ មានវិនិពន្ធទិដ្ឋិជាមិច្ឆាទិដ្ឋិ ។បេ។ នេះសំយោជនៈ មិនមែនទិដ្ឋិ ។ ការប្រកាន់ស្អិតថាត្រចៀកជាអញ ។បេ។ ថាច្រមុះជាអញ ថាអណ្តាតជាអញ ថាកាយជាអញ ថាចិត្តជាអញ ។បេ។ ថាធម៌ទាំងឡាយជាអញ ថាចក្ខុវិញ្ញាណជាអញ ។បេ។ ការប្រកាន់ស្អិត និងការស្ទាបអង្អែលថាមនោវិញ្ញាណជាអញ ឈ្មោះថា មានវិនពន្ធទិដ្ឋិថាអញ ទិដ្ឋិមិនមែនវត្ថុ វត្ថុមិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និងវត្ថុណា នេះឈ្មោះថា មានវិនិពន្ធទិដ្ឋិថាអញ ជាទិដ្ឋិទី ១៨ មានវិនិពន្ធទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ។បេ។ នេះសំយោជនៈមិនមែនទិដ្ឋិ នេះឯងការប្រកាន់ស្អិតនៃមានវិនិពន្ធទិដ្ឋិថាអញ ដោយអាការ ១៨ យ៉ាង ។

[ ៥៩ ] ការប្រកាន់ស្អិតនៃមានវិនិពន្ធទិដ្ឋិថារបស់អញ ដោយអាការ ១៨ តើដូចម្តេច ។ ការប្រកាន់ស្អិតថាភ្នែករបស់អញ ឈ្មោះថា មានវិនិពន្ធទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុមិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និងវត្ថុណា នេះឈ្មោះថា មានវិនិពន្ធទិដ្ឋិថារបស់អញ ជាទិដ្ឋិទី ១ មានវិនិពន្ធទិដ្ឋិជាមិច្ឆាទិដ្ឋិ ។បេ។ នេះសំយោជនៈ មិនមែនទិដ្ឋិ ។ ការប្រកាន់ស្អិតថាត្រចៀករបស់អញ ។បេ។ ថាច្រមុះរបស់អញ ថាអណ្តាតរបស់អញ ។បេ។ ថាចិត្ត

របស់អញ ។បេ។ ជាធម៌ទាំងឡាយរបស់អញ ជាចក្ខុវិញ្ញាណរបស់អញ ។បេ។ ការប្រកាន់ស្អិត និងការស្ទាបអង្អែលថា មនោវិញ្ញាណរបស់អញ ឈ្មោះថា មានវិនិពន្ធទិដ្ឋិថារបស់អញ ទិដ្ឋិមិនមែនវត្ថុ វត្ថុមិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និងវត្ថុណា នេះឈ្មោះថា មានវិនិពន្ធទិដ្ឋិថារបស់អញ ជាទិដ្ឋិទី ១៨ មានវិនិពន្ធទិដ្ឋិជាមិច្ឆាទិដ្ឋិ ។បេ។ នេះសំយោជនៈ មិនមែនទិដ្ឋិ នេះឯងការប្រកាន់ស្អិតនៃមានវិនិពន្ធទិដ្ឋិថារបស់អញដោយអាការ ១៨ យ៉ាង ។

[ ៦០ ] ការប្រកាន់ស្អិតនៃអត្តវាទប្បដិសំយុត្តទិដ្ឋិ ដោយអាការ ២០ តើដូចម្ដេច ។ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនចេះដឹង មិនបានឃើញពួកព្រះអរិយៈ មិនឈ្លាសវៃក្នុងធម៌របស់ព្រះអរិយៈ មិនទូន្មានខ្លួនក្នុងធម៌របស់ព្រះអរិយៈ មិនបានជួបប្រទះនឹងពួកសប្បុរស មិនឈ្លាសវៃក្នុងធម៌របស់សប្បុ-រស មិនទូន្មានខ្លួនក្នុងធម៌របស់សប្បុរស តែងពិចារណាឃើញនូវរូបថាជាខ្លួន នូវខ្លួនថាមានរូបខ្លះ នូវរូបថាមានក្នុងខ្លួនខ្លះ នូវខ្លួនថាមានក្នុងរូបខ្លះ ។បេ។ ពិចារណាឃើញនូវវេទនា សញ្ញា សង្ខារ វិញ្ញាណថាជាខ្លួន នូវខ្លួនថាមានវិញ្ញាណខ្លះ នូវវិញ្ញាណថាមានក្នុងខ្លួនខ្លះ នូវខ្លួនថាមានក្នុងវិញ្ញាណខ្លះ ។បេ។

បុគ្គលពិចារណាឃើញរូបថាជាខ្លួន តើដូចម្ដេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ពិចារណាឃើញបឋវីកសិណ ។បេ។ ពិចារណាឃើញឱទាតកសិណថាជាខ្លួន ថាធម្មជាតណាជាឱទាតកសិណ សភាពនោះ គឺអញ សភាពណាជាអញ ធម្មជាតនោះ គឺឱទាតកសិណ ឈ្មោះថា ពិចារណាឃើញឱទាតកសិណ និងខ្លួនថាមិនមែនពីរ ប្រៀបដូចប្រទីបប្រេងដែលឆេះមានអណ្ដាតភ្លើងណា សភាព

នោះ គឺរស្មី សភាពណាជារស្មី ធម្មជាតនោះ គឺអណ្តាតភ្លើង ឈ្មោះថា ពិចា-រណាឃើញអណ្តាតភ្លើង និងរស្មី ថាមិនមែនពីរ មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចជាបុគ្គលខ្លះក្នុងលោកនេះ ពិចារណាឃើញឱទាតកសិណ ថាជាខ្លួន ។បេ។ នេះឈ្មោះថា អត្តវាទប្បដិសំយុត្តទិដ្ឋិ ជារូបវត្ថុកៈទី ១ អត្ត-វាទប្បដិសំយុត្តទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ។បេ។ នេះសំយោជនៈ មិនមែនទិដ្ឋិ នេះឯង ការប្រកាន់ស្អិតនៃអត្តវាទប្បដិសំយុត្តទិដ្ឋិ ដោយអាការ ២០ យ៉ាង ។

[ ៦១ ] ការប្រកាន់ស្អិតនៃលោកវាទប្បដិសំយុត្តទិដ្ឋិ ដោយអាការ ៨ តើដូចម្តេច ។ ការប្រកាន់ស្អិត និងការស្ទាបអង្អែល ថាខ្លួនក្តី លោកក្តីទៀង ឈ្មោះថា លោកវាទប្បដិសំយុត្តទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុមិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និងវត្ថុណា នេះឈ្មោះថា លោកវាទប្បដិសំ-យុត្តទិដ្ឋិទី ១ លោកវាទប្បដិសំយុត្តទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ។បេ។ នេះសំយោជនៈ មិនមែនទិដ្ឋិ ( ការប្រកាន់ស្អិត និងការស្ទាបអង្អែល ) ថាខ្លួនក្តី លោកក្តីមិន ទៀង ថាខ្លួនក្តី លោកក្តីទៀងក៏មាន មិនទៀងក៏មិនមាន ។បេ។ ការប្រកាន់ ស្អិត និងការស្ទាបអង្អែលថាខ្លួនក្តី លោកក្តីទៀងក៏មិនមែន មិនទៀងក៏មិនមែន ថាខ្លួនក្តី លោកក្តីមានទីបំផុត ថាខ្លួនក្តី លោកក្តី មិនមានទីបំផុត ថាខ្លួនក្តី លោកក្តីមានទីបំផុតក៏មាន មិនមានទីបំផុតក៏មាន ឈ្មោះថា លោកវាទប្បដិ-សំយុត្តទិដ្ឋិ ទិដ្ឋិមិនមែនវត្ថុ វត្ថុមិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ទិដ្ឋិណា និងវត្ថុណា នេះឈ្មោះថា លោកវាទប្បដិសំយុត្តទិដ្ឋិទី ៨ លោកវា-ទប្បដិសំយុត្តទិដ្ឋិ ជាមិច្ឆាទិដ្ឋិ ។បេ។ នេះសំយោជនៈ មិនមែនទិដ្ឋិ នេះឯងការ

ប្រកាន់ស្អិតនៃលោកវាទប្បដិសំយុត្តទិដ្ឋិ ដោយអាការ ៨ យ៉ាង ។

[ ៦២ ] ការប្រកាន់ស្អិត ដោយការក្រាញនៅ ឈ្មោះថា ភវទិដ្ឋិ ការប្រកាន់ស្អិតដោយការស្ទុះទៅក្រៃលែង ឈ្មោះថា វិភវទិដ្ឋិ អស្សាទទិដ្ឋិ មានការប្រកាន់ស្អិតដោយអាការ ៣៥ តើជាភវទិដ្ឋិប៉ុន្មាន ជាវិភវទិដ្ឋិប៉ុន្មាន អត្តានុទិដ្ឋិមានការប្រកាន់ស្អិតដោយអាការ ២០ តើជាភវទិដ្ឋិប៉ុន្មាន ជាវិភវទិដ្ឋិប៉ុន្មាន ។បេ។ លោកវាទប្បដិសំយុត្តទិដ្ឋិ មានការប្រកាន់ស្អិតដោយអាការ ៨ តើជាភវទិដ្ឋិប៉ុន្មាន ជាវិភវទិដ្ឋិប៉ុន្មាន ។ អស្សាទទិដ្ឋិ មានការប្រកាន់ស្អិតដោយអាការ ៣៥ គឺជាភវទិដ្ឋិក៏មាន ជាវិភវទិដ្ឋិក៏មាន អត្តានុទិដ្ឋិ មានការប្រកាន់ស្អិតដោយអាការ ២០ គឺជាភវទិដ្ឋិ ១៥ ជាវិភវទិដ្ឋិ ៥ មិច្ឆាទិដ្ឋិ មានការប្រកាន់ស្អិតដោយអាការ ១០ គឺជាវិភវទិដ្ឋិទាំងអស់ សក្កាយទិដ្ឋិមានការប្រកាន់ស្អិតដោយអាការ ២០ គឺជាភវទិដ្ឋិ ១៥ ជាវិភវទិដ្ឋិ ៥ សស្សតទិដ្ឋិជាសក្កាយវត្ថុកៈ មានការប្រកាន់ស្អិតដោយអាការ ១៥ គឺជាភវទិដ្ឋិទាំងអស់ ឧច្ឆេទទិដ្ឋិជាសក្កាយវត្ថុកៈ មានការប្រកាន់ស្អិតដោយអាការ ៥ គឺជាវិភវទិដ្ឋិទាំងអស់ អន្តគ្គាហិកទិដ្ឋិថាលោកទៀង មានការប្រកាន់ស្អិតដោយអាការ ៥ គឺជាភវទិដ្ឋិទាំងអស់ អន្តគ្គាហិកទិដ្ឋិថាលោកមិនទៀង មានការប្រកាន់ស្អិតដោយអាការ ៥ គឺជាវិភវទិដ្ឋិទាំងអស់ អន្តគ្គាហិកទិដ្ឋិថាលោកមានទីបំផុត មានការប្រកាន់ស្អិតដោយអាការ ៥ គឺជាភវទិដ្ឋិក៏មាន ជាវិភវទិដ្ឋិក៏មាន អន្តគ្គាហិកទិដ្ឋិថាលោកមិនមានទីបំផុត មានការប្រកាន់ស្អិតដោយអាការ ៥ គឺជាភវទិដ្ឋិក៏មាន ជាវិភវទិដ្ឋិក៏មាន អន្តគ្គាហិកទិដ្ឋិថា ជីវិតនោះ សរីរៈនោះ

មានការប្រកាន់ស្អិតដោយអាការ ៥ គឺជាវិភវទិដ្ឋិទាំងអស់ អន្តគ្គាហិកទិដ្ឋិថា ជីវិតដទៃ សរីរៈដទៃ មានការប្រកាន់ស្អិតដោយអាការ ៥ គឺជាភវទិដ្ឋិទាំងអស់ អន្តគ្គាហិកទិដ្ឋិថា សត្វខាងមុខអំពីសេចក្តីស្លាប់កើតទៀត មានការប្រកាន់ស្អិតដោយអាការ ៥ គឺជាភវទិដ្ឋិទាំងអស់ អន្តគ្គាហិកទិដ្ឋិថា សត្វខាងមុខអំពីសេចក្តីស្លាប់មិនកើតទៀត មានការប្រកាន់ស្អិតដោយអាការ ៥ គឺជាវិភវទិដ្ឋិទាំងអស់ អន្តគ្គាហិកទិដ្ឋិថា សត្វខាងមុខអំពីសេចក្តីស្លាប់កើតទៀតក៏មាន មិនកើតទៀតក៏មាន មានការប្រកាន់ស្អិតដោយអាការ ៥ គឺជាភវទិដ្ឋិក៏មាន ជាវិភវទិដ្ឋិក៏មាន អបរន្តានុទិដ្ឋិ មានការប្រកាន់ស្អិតដោយអាការ ៤៤ គឺជាភវទិដ្ឋិក៏មាន ជាវិភវទិដ្ឋិក៏មាន ទិដ្ឋិប្រកបដោយសំយោជនៈ មានការប្រកាន់ស្អិតដោយអាការ ១៨ គឺជាភវទិដ្ឋិក៏មាន ជាវិភវទិដ្ឋិក៏មាន មានវិនិពន្ធទិដ្ឋិថាអញ មានការប្រកាន់ស្អិតដោយអាការ ១៨ គឺជាវិភវទិដ្ឋិទាំងអស់ មានវិនិពន្ធទិដ្ឋិថារបស់អញ មានការប្រកាន់ស្អិតដោយអាការ ១៨ គឺជាភវទិដ្ឋិទាំងអស់ អត្តវាទប្បដិសំយុត្តទិដ្ឋិ មានការប្រកាន់ស្អិតដោយអាការ ២០ គឺជាភវទិដ្ឋិ ១៥ ជាវិភវទិដ្ឋិ ៥ លោកវាទប្បដិសំយុត្តទិដ្ឋិ មានការប្រកាន់ស្អិតដោយអាការ ៨ គឺភវទិដ្ឋិក៏មាន ជាវិភវទិដ្ឋិក៏មាន ទិដ្ឋិទាំងអស់ ឈ្មោះថា អត្តានុទិដ្ឋិ ទិដ្ឋិទាំងអស់ ឈ្មោះថា មិច្ឆាទិដ្ឋិ ទិដ្ឋិទាំងអស់ ឈ្មោះថា សក្កាយទិដ្ឋិ ទិដ្ឋិទាំងអស់ ឈ្មោះថា អន្តគ្គាហិកទិដ្ឋិ ទិដ្ឋិទាំងអស់ ឈ្មោះថា សញ្ញោជនិកទិដ្ឋិ ឈ្មោះថាអត្តវាទប្បដិសំយុត្តទិដ្ឋិ ឈ្មោះថា ភវទិដ្ឋិ ឈ្មោះថា វិភវទិដ្ឋិ ពួកជនណាជាអ្នកត្រិះរិះ ហើយអាស្រ័យនូវទិដ្ឋិទាំងពីរនុ៎ះ ការដឹងក្នុងនិរោធរបស់ពួកជន

នោះ មិនមានឡើយ ដ្បិតថា សត្វលោកនេះតែងមានសេចក្តីសម្គាល់ខុស ។

[ ៦៣ ] ម្នាលភិក្ខុទាំងឡាយ ទេវតា និងមនុស្សមួយពួកដែលត្រូវទិដ្ឋិទាំង ២ រួបរឹតហើយ តែងក្រាញ មួយពួកតែងស្ទុះស្ទា ឯពួកបុគ្គលអ្នកមានចក្ខុ តែងឃើញច្បាស់ ។

ម្នាលភិក្ខុទាំងឡាយ ចុះទេវតា និងមនុស្សមួយពួកតែងក្រាញ តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ ទេវតា និងមនុស្សទាំងឡាយ មានភពជាទីត្រេកអរ ត្រេកអរក្នុងភព រីករាយក្នុងភព កាលដែលតថាគតកំពុងសម្តែងធម៌ ( ឲ្យស្តាប់ ) ដើម្បីរម្ងត់ភព ចិត្តរបស់ទេវតា និងមនុស្សទាំងនោះរមែងមិនស្ទុះស្ទា មិនជ្រះថ្លា មិនតាំងនៅ មិនជឿស៊ប់ ម្នាលភិក្ខុទាំងឡាយ ទេវតា និងមនុស្សមួយពួក តែងក្រាញយ៉ាងនេះឯង ។

ម្នាលភិក្ខុទាំងឡាយ ចុះទេវតា និងមនុស្សមួយពួក តែងស្ទុះស្ទា តើដូចម្តេច ទេវតា និងមនុស្សមួយពួកកាលនឿយណាយ ធុញទ្រាន់ ជិនឆ្អន់ដោយសារភព ក៏ត្រេកអរចំពោះការប្រាសចាកភព ដោយគិតថា ឱហ្ន៎ អន្តាល់ណាខ្លួននឹងទម្លាយកាយទៅហើយសូន្យវិនាស ខាងមុខអំពីសេចក្តីស្លាប់ មិនកើតទៀតឬ ដោយគិតថា នេះជាធម្មជាតស្ងប់ នេះធម្មជាតដ៏ឧត្តមដោយពិត ម្នាលភិក្ខុទាំងឡាយ ទេវតា និងមនុស្សមួយពួក តែងស្ទុះស្ទាយ៉ាងនេះឯង ។

ម្នាលភិក្ខុទាំងឡាយ ចុះពួកបុគ្គលអ្នកមានចក្ខុតែងឃើញច្បាស់ តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឃើញនូវភូតរូប ថាជាភូតរូប លុះឃើញនូវភូតរូបថាជាភូតរូបហើយ តែងជាអ្នកប្រតិបត្តិដើម្បីនឿយណាយ

ដើម្បីប្រាសចាកភគៈ ដើម្បីរម្ងត់នូវភូតរូប ម្នាលភិក្ខុទាំងឡាយ ពួកបុគ្គល អ្នកមានចក្ខុ តែងឃើញច្បាស់យ៉ាងនេះឯង ។

ភិក្ខុណាឃើញនូវភូតរូប ថាជាភូតរូប ហើយប្រព្រឹត្តកន្លងនូវភូតរូប រមែងជឿស៊ប់ក្នុងការពិត ព្រោះការអស់ទៅនៃភវតណ្ហា ថាបើភិក្ខុនោះបានកំណត់ដឹងនូវភូតរូបហើយ ទាំងជាអ្នកមានតណ្ហាទៅប្រាសហើយ ក្នុងរូបភព និងអរូបភព រមែងមិនបាននូវភពថ្មីទៀតទេ ព្រោះការមិនមានភូតរូប ។

[ ៦៤ ] បុគ្គល ៣ ពួកមានទិដ្ឋិវិបត្តិ បុគ្គល ៣ ពួកបរិបូណ៌ដោយទិដ្ឋិ ។ បុគ្គល ៣ ពួកមានទិដ្ឋិវិបត្តិ តើដូចម្តេច ។ ពួកតិរ្ថិយ ១ ពួកសាវកនៃតិរ្ថិយ ១ ពួកជនដែលជាមិច្ឆាទិដ្ឋិ ១ នេះបុគ្គល ៣ ពួកដែលមានទិដ្ឋិវិបត្តិ ។

បុគ្គល ៣ ពួកបរិបូណ៌ដោយទិដ្ឋិ តើដូចម្តេច ព្រះតថាគត ១ សាវកនៃព្រះតថាគត ១ ពួកជនដែលជាសម្មាទិដ្ឋិ ១ នេះបុគ្គល ៣ ពួកដែលបរិបូណ៌ដោយទិដ្ឋិ ។

នរជនណាមានសេចក្តីក្រោធផង ចងសេចក្តីក្រោធទុកផង ជាសត្វលាមក លុបគុណគេផង មានទិដ្ឋិវិបត្តិផង មានពុតត្បុតផង បុគ្គលគប្បីដឹងនូវនរជននោះថា អ្នកទាំងនេះ ជាមនុស្សថោកទាប ។ អ្នកប្រាជ្ញមិនមានសេចក្តីក្រោធ មិនចងសេចក្តីក្រោធទុក មិនលុបគុណគេ ដល់នូវភាពជាអ្នកបរិសុទ្ធ មាន

ទិដ្ឋិបរិបូណ៌ បុគ្គលគប្បីដឹងនូវអ្នកប្រាជ្ញនោះថា អ្នកនេះជាមនុស្សប្រសើរ ។

[ ៦៥ ] ទិដ្ឋិវិបត្តិ ៣ យ៉ាង ទិដ្ឋិសម្បត្តិ ៣ យ៉ាង ។

ទិដ្ឋិវិបត្តិ ៣ យ៉ាង តើដូចម្តេចខ្លះ ។ ការយល់ឃើញថា នុ៎ះជារបស់អញ ឈ្មោះថា ទិដ្ឋិវិបត្តិ ការយល់ឃើញថា នុ៎ះជាអញ ឈ្មោះថា ទិដ្ឋិវិបត្តិ ការយល់ឃើញថា នុ៎ះជាខ្លួនរបស់អញ ឈ្មោះថា ទិដ្ឋិវិបត្តិ នេះឯងទិដ្ឋិវិបត្តិ ៣ យ៉ាង ។

ទិដ្ឋិសម្បត្តិ ៣ យ៉ាង តើដូចម្តេចខ្លះ ។ ការយល់ឃើញថា នុ៎ះមិនមែនជារបស់អញ ឈ្មោះថា ទិដ្ឋិសម្បត្តិ ការយល់ឃើញថា នុ៎ះមិនមែនជាអញ ឈ្មោះថា ទិដ្ឋិសម្បត្តិ ការយល់ឃើញថា នុ៎ះមិនមែនជាខ្លួនរបស់អញ ឈ្មោះថា ទិដ្ឋិសម្បត្តិ នេះឯងទិដ្ឋិសម្បត្តិ ៣ យ៉ាង ។

[ ៦៦ ] ការយល់ឃើញថា នុ៎ះរបស់អញ ឈ្មោះទិដ្ឋិអ្វី មានទិដ្ឋិប៉ុន្មាន ទិដ្ឋិទាំងនោះ គេប្រកាន់យកចំណែកដូចម្តេច ការយល់ឃើញថា នុ៎ះជាអញ ឈ្មោះទិដ្ឋិអ្វី មានទិដ្ឋិប៉ុន្មាន ទិដ្ឋិទាំងនោះ គេប្រកាន់យកចំណែកដូចម្តេច ការយល់ឃើញថា នុ៎ះជាខ្លួនរបស់អញ ឈ្មោះទិដ្ឋិអ្វី មានទិដ្ឋិប៉ុន្មាន ទិដ្ឋិទាំងនោះ គេប្រកាន់យកចំណែកដូចម្តេច ។ ការយល់ឃើញថា នុ៎ះរបស់អញ ឈ្មោះបុព្វន្តានុទិដ្ឋិ មានទិដ្ឋិ ១៨ ទិដ្ឋិទាំងនោះគេប្រកាន់យកចំណែកខាងដើម ការយល់ឃើញថា នុ៎ះជាអញ ឈ្មោះអបរន្តានុទិដ្ឋិមានទិដ្ឋិ ៤៤ ទិដ្ឋិទាំងនោះគេប្រកាន់យកចំណែកខាងចុង ការយល់ឃើញថា នុ៎ះជាខ្លួនរបស់អញ ឈ្មោះ

វីសតិវត្ថុកអត្តានុទិដ្ឋិ ឈ្មោះវីសតិវត្ថុកសក្កាយទិដ្ឋិមានទិដ្ឋិ ៦២ ដោយមានសក្កាយទិដ្ឋិជាប្រធាន ទិដ្ឋិទាំងនោះ គេប្រកាន់យកចំណែកខាងដើម និងចំណែកខាងចុង ។

[ ៦៧ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលណាមួយ ដល់នូវការសម្រេចព្រោះតថាគត បុគ្គលទាំងអស់នោះ ឈ្មោះថា អ្នកបរិបូណ៌ដោយទិដ្ឋិ បុគ្គល ៥ ពួក សម្រេចក្នុងលោកនេះ បុគ្គល ៥ ពួក លះលោកនេះហើយសម្រេច ។

បុគ្គល ៥ ពួក សម្រេចក្នុងលោកនេះ តើដូចម្តេច ។ សត្តក្ខត្តុបរមបុគ្គល ១ កោលង្កោលបុគ្គល ១ ឯកពីជិបុគ្គល ១ សកទាគាមិបុគ្គល ១ បុគ្គលដែលជាព្រះអរហន្តក្នុងបច្ចុប្បន្ន ១ នេះបុគ្គល ៥ ពួកសម្រេចក្នុងលោកនេះ ។

បុគ្គល ៥ ពួក លះលោកនេះហើយសម្រេច តើដូចម្តេច ។ អន្តរាបរិនិព្វាយិបុគ្គល ១ ឧបហច្ចបរិនិព្វាយិបុគ្គល ១ អសង្ខារបរិនិព្វាយិបុគ្គល ១ សសង្ខារបរិនិព្វាយិបុគ្គល ១ ឧទ្ធំសោតអកនិដ្ឋគាមិបុគ្គល ១ នេះបុគ្គល ៥ ពួក លះលោកនេះហើយសម្រេច ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលណាមួយ ដល់នូវការសម្រេច ព្រោះតថាគត បុគ្គលទាំងអស់នោះ ឈ្មោះថា អ្នកបរិបូណ៌ដោយទិដ្ឋិ នេះឯងបុគ្គល ៥ ពួក សម្រេចក្នុងលោកនេះ នេះឯងបុគ្គល ៥ ពួក លះលោកនេះហើយសម្រេច ។

[ ៦៨ ] ម្នាលភិក្ខុទាំងឡាយ ពួកបុគ្គលណានីមួយ ជ្រះថ្លាមិនកម្រើកចំពោះតថាគត បុគ្គលទាំងអស់នោះ ឈ្មោះថា សោតាបន្នបុគ្គល សោតា-

បន្នបុគ្គលទាំង ៥ ពួកនេះ សម្រេចក្នុងលោកនេះ ឯបុគ្គល ៥ ពួកទៀត លះលោកនេះហើយសម្រេច ។

បុគ្គល ៥ ពួកសម្រេចក្នុងលោកនេះ តើដូចម្តេច ។ សត្តក្ខត្តុបរមបុគ្គល ១ កោលង្កោលបុគ្គល ១ ឯកពីជិបុគ្គល ១ សកទាគាមិបុគ្គល ១ បុគ្គលដែលជាព្រះអរហន្តក្នុងបច្ចុប្បន្ន ១ នេះបុគ្គល ៥ ពួកសម្រេចក្នុងលោកនេះ ។

បុគ្គល ៥ ពួកលះលោកនេះហើយសម្រេច តើដូចម្តេច ។ អន្តរាបរិនិព្វាយិបុគ្គល ១ ឧបហច្ចបរិនិព្វាយិបុគ្គល ១ អសង្ខារបរិនិព្វាយិបុគ្គល ១ សសង្ខារបរិនិព្វាយិបុគ្គល ១ ឧទ្ធំសោតអកនិដ្ឋគាមិបុគ្គល ១ នេះបុគ្គល ៥ ពួកលះលោកនេះហើយសម្រេច ។

ម្នាលភិក្ខុទាំងឡាយ ពួកបុគ្គលណានីមួយជ្រះថ្លាមិនកម្រើក ចំពោះតថាគត បុគ្គលទាំងអស់នោះ ឈ្មោះថា សោតាបន្នបុគ្គល នេះឯងសោតបន្នបុគ្គលទាំង ៥ ពួកនោះ សម្រេចក្នុងលោកនេះ នេះឯងបុគ្គល ៥ ពួកលះលោកនេះហើយសម្រេច ។

**ទិដ្ឋិកថា ចប់**

# សទ្ធម្មប្បកាសិនី

# អដ្ឋកថា ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ

# ទុតិយភាគ

## អដ្ឋកថា ទិដ្ឋិកថា

## អស្សាទទិដ្ឋិនិទ្ទេស

[ ១ ] ឥឡូវនេះ ដល់វេលាដែលពណ៌នាតាមលំដាប់នៃទិដ្ឋិកថា ដែលលោកពោលហើយ ក្នុងលំដាប់នៃញាណកថា ។ ពិតហើយ សម្រាប់បុគ្គលសម្រេចសម្មាទិដ្ឋិដែលសន្សំញាណ ធ្វើហើយក្នុងញាណកថា ការជម្រះមន្ទិល គឺមិច្ឆាទិដ្ឋិ រមែងធ្វើបានងាយ ឯសម្មាទិដ្ឋិ រមែងបរិសុទ្ធល្អ ព្រោះហេតុនោះ ទើបទិដ្ឋិកថានេះ លោកពោលក្នុងលំដាប់ញាណកថា ។

ក្នុងទិដ្ឋិកថានោះមាន ៤ បរិច្ឆេទយ៉ាងនេះ គឺពាក្យថា ទិដ្ឋិ គឺអ្វីជាដើម ជាពាក្យសួរ ពាក្យថា ទិដ្ឋិ គឺអ្វី បានដល់ ទិដ្ឋិ គឺការស្ទាបអង្អែលដោយការប្រកាន់ខុសជាដើម ជាពាក្យឆ្លើយនូវពាក្យដែលសួរ ពាក្យថា ទិដ្ឋិ គឺការស្ទាបអង្អែលដោយការប្រកាន់ខុសប៉ុន្មានជាដើម ជាការសម្តែងសេចក្តីពិស្តារនៃចម្លើយ ដែលឆ្លើយហើយ ពាក្យថា ទិដ្ឋិទាំងអស់ ជាអស្សាទទិដ្ឋិជាដើម ជាការប្រៀបធៀបគ្នាជាមួយទិដ្ឋិសូត្រ ។

ក្នុង ៤ បរិច្ឆេទនោះ គប្បីជ្រាបវិនិច្ឆ័យក្នុងបុច្ឆាបរិច្ឆេទមុន ។ ពាក្យសួរថា **កា ទិដ្ឋិ** ជាពាក្យសួរដល់ធម៌ ជាពាក្យសួរដល់សភាវៈ ។

ពាក្យសួរថា **កតិ ទិដ្ឋិដ្ឋានានិ** ជាការសួរដល់ហេតុ សួរដល់បច្ច័យ អធិប្បាយថា ហេតុនៃទិដ្ឋិទាំងឡាយមានប៉ុន្មាន ។

ពាក្យសួរថា **កតិ ទិដ្ឋិបរិយុដ្ឋានានិ** ជាការសួរដល់ការផ្សាយឡើង សួរដល់វិការ ។ ទិដ្ឋិទាំងឡាយនោះឯង ឈ្មោះថា **ទិដ្ឋិបរិយុដ្ឋានានិ** ព្រោះតាំងឡើងរឹតរុំចិត្តដោយអំណាចនៃការផ្សាយឡើង ។

ពាក្យសួរថា **កតិ ទិដ្ឋិយោ** ជាការសួរដល់ចំនួន សួរដល់ការរាប់នៃទិដ្ឋិទាំងឡាយ ។

ពាក្យសួរថា **កតិ ទិដ្ឋាភិនិវេសា** ជាការសួរតាមប្រភេទនៃទិដ្ឋិ ដោយប្រភេទនៃវត្ថុដោយការផ្សេងគ្នានៃអារម្មណ៍ ។ ព្រោះថា ទិដ្ឋិទាំងឡាយ រមែងប្រកាន់ រមែងស្ទាបអង្អែលវត្ថុនោះៗ អារម្មណ៍នោះៗ ព្រោះហេតុនោះ ទើបលោកពោលថា ទិដ្ឋិបរាមាស ។

ពាក្យសួរថា **កតមោ ទិដ្ឋិដ្ឋានសមុគ្ឃាតោ** ជាការសួរដល់ធម៌ដែលជាបដិបក្ខ សួរដល់ឧបាយនៃការលះទិដ្ឋិទាំងឡាយ ។ ពិតហើយ ខន្ធជាដើមជាហេតុនៃទិដ្ឋិ ហេតុនៃទិដ្ឋិទាំងនោះ រមែងមិនមានព្រោះដកទិដ្ឋិបានហើយ ព្រោះហេតុនោះ ទើបហេតុទាំងនោះ ឈ្មោះថា ត្រូវដកបានហើយ ។ ព្រោះហេតុនោះ ទើបលោកពោលថា **ទិដ្ឋិដ្ឋានសមុគ្ឃាតោ** ព្រោះជាហេតុទម្លាយទីតាំងនៃទិដ្ឋិដ៏អាក្រក់ ។

ឥឡូវនេះ គប្បីជ្រាបពាក្យឆ្លើយ ៦ ប្រការនៃពាក្យសួរទាំង ៦ នោះ មានពាក្យថា **កា ទិដ្ឋិ** ជាដើម ។ ក្នុងពាក្យសួរទាំងនោះ ពាក្យសួរថា **កា ទិដ្ឋិ**

( ទិដ្ឋិដូចម្តេច ) ជាពាក្យសួរដែលគប្បីឆ្លើយ ។

បទថា **ទិដ្ឋិ** គឺការស្ទាបអង្អែលដោយការឃើញខុស ជាពាក្យឆ្លើយ ទិដ្ឋិនោះ ឈ្មោះថា **អភិនិវេស** ព្រោះអត្ថថា ប្រកាន់ តាំងមាំ ប្រកាន់មាំដោយអំណាចនៃការទៀងជាដើម ក្នុងវត្ថុដែលមិនទៀងជាដើម ។

ឈ្មោះថា **បរាមាស** ព្រោះអត្ថថា ឈានកន្លងអាការមិនទៀងជាដើម ហើយប្រព្រឹត្តទៅដោយអំណាចនៃការទៀងជាដើម ហើយស្ទាបអង្អែលប្រកាន់តទៅ ។

ម្យ៉ាងទៀត ឈ្មោះថា **បរាមាស** ព្រោះអត្ថថា ស្ទាបអង្អែល ប្រកាន់នូវវត្ថុដទៃ ( ចាកសេចក្តីពិត ) មានប្រកាន់ថាជារបស់ទៀង ថាជារបស់ពិតដ៏ប្រសើរជាដើម ការប្រកាន់ខុសនោះផង ការស្ទាបអង្អែលផង ទើបឈ្មោះថា **អភិនិវេសបរាមាសោ** ។ ព្រះសារីបុត្តត្ថេរសម្តែងឆ្លើយសភាវៈរបស់ទិដ្ឋិដោយកិច្ចថា ការប្រកាន់ខុស និងការស្ទាបអង្អែល មានប្រការយ៉ាងនេះជាទិដ្ឋិ ។

បទថា **តីណិ សតំ** បានដល់ **តីណិ សតានិ** ជាវចនៈវិបល្លាស ជាការលើកពាក្យសួរឡើង ហើយលោកធ្វើការឆ្លើយថា សោតាបត្តិមគ្គជាគ្រឿងដកឡើងនូវហេតុនៃទិដ្ឋិដោយមិនអើរពើ និងពាក្យសួរថា ការដកទីតាំងនៃទិដ្ឋិ តើដូចម្តេច ។

ឥឡូវនេះ គប្បីជ្រាបការសម្តែងដោយពិស្តារនៃពាក្យថា **កថំ អភិនិ-វេសបរាមាសោ** ជាដើមដូចតទៅនេះ

[ ២-១០ ] ក្នុងបទទាំងនោះ បទថា **រូបំ** ជាទុតិយាវិភត្តិ ភ្ជាប់សេចក្តី

ថា ស្ទាបអង្អែលដោយការប្រកាន់ខុសនូវរូប ។ មយ៉ាងទៀត ក្នុងបទថា **រូបំ** នេះ បានដល់ រូបូបាទានក្ខន្ធ និងកសិណរូប ។ គប្បីប្រកបចំពោះថា ទិដ្ឋិ គឺការស្ទាបអង្អែល ដោយការប្រកាន់ខុសថា នុ៎ះរបស់អញ ទិដ្ឋិ គឺការស្ទាបអង្អែល ដោយការប្រកាន់ខុសថា នុ៎ះជាអញ ទិដ្ឋិ គឺការស្ទាបអង្អែលដោយការប្រកាន់ខុសថា នុ៎ះជាខ្លួនរបស់អញ ។

បទថា **ឯតំ** ជាពាក្យទូទៅ ។ ដោយបទនោះលោកធ្វើឲ្យជានបុំសកលិង្គ និងឯកវចនៈថា នុ៎ះវេទនារបស់អញ នុ៎ះសញ្ញារបស់អញ ។ តែបទថា **ឯសោ** លោកសម្ដីងដល់វត្ថុដែលគួរពោលដល់ ទើបធ្វើឲ្យជាបុំលិង្គ ។

បទថា **ឯតំ មម** ជាទិដ្ឋិដែលមានការសម្គាល់ដោយអំណាចតណ្ហាជាមូល ។

បទថា **ឯសោហមស្មិ** ជាទិដ្ឋិដែលមានការសម្គាល់ដោយអំណាចមានៈជាមូល ។

បទថា **ឯសោ មេ អត្តា** មានការសម្គាល់ដោយអំណាចទិដ្ឋិនោះឯង ។ ចំណែកអាចារ្យពួកខ្លះពណ៌នាពាក្យទាំង ៣ នេះថា ពាក្យថា នុ៎ះជារបស់អញ ជាការត្រិះរិះដោយមមង្ការ ពាក្យថា នុ៎ះជាអញ ជាការត្រិះរិះដោយអហង្ការ ពាក្យថា នុ៎ះជាតួខ្លួនរបស់អញ ជាការប្រកាន់មាំក្នុងតួខ្លួនដែលត្រិះរិះដោយអហង្ការ និងមមង្ការ ។ ដោយចាត់តាមលំដាប់ដូចគ្នានោះឯង ពាក្យទី ១ ជាការប្រកាន់មាំដោយមានតណ្ហាជាមូល ពាក្យទី ២ ជាការប្រកាន់មាំដោយមានៈ ពាក្យទី ៣ ជាការប្រកាន់មាំក្នុងតួខ្លួនដែលតាំងមាំដោយមានតណ្ហាជា

មូល និងដែលប្រកាន់មាំដោយមានៈ ។ ម្យ៉ាងទៀត ពាក្យទី ១ ជាការមិនឃើញលក្ខណៈដែលជាទុក្ខនៃសង្ខារទាំងឡាយ ពាក្យទី ២ ជាការមិនឃើញលក្ខណៈដែលជារបស់មិនទៀងនៃសង្ខារទាំងឡាយ ពាក្យទី ៣ ជាការប្រកាន់មាំ ក្នុងតួខ្លួន ដែលជាហេតុមិនឃើញត្រៃលក្ខណ៍នៃសង្ខារទាំងឡាយ ។ ម្យ៉ាងទៀត ពាក្យទី ១ ជាការប្រកាន់មាំក្នុងតួខ្លួនរបស់បុគ្គល ដែលដល់នូវភាពវិបល្លាស ក្នុងទុក្ខថាជាសេចក្តីសុខ និងក្នុងការមិនស្អាត ថាជាការស្អាត ពាក្យទី ២ ជាការប្រកាន់មាំក្នុងតួខ្លួនរបស់បុគ្គលដែលដល់នូវវិបល្លាស ក្នុងភាពជារបស់មិនទៀងថាជារបស់ទៀង ពាក្យទី ៣ ជាការប្រកាន់មាំក្នុងតួខ្លួនរបស់បុគ្គលដែលដល់នូវវិបល្លាស ៤ យ៉ាង ។ ម្យ៉ាងទៀត ពាក្យទី ១ ជាការត្រិះរិះដល់អាការនៃបុព្វេនិវាសញ្ញាណ ពាក្យទី ២ ជាការត្រិះរិះដើម្បីបានទិព្វចក្ខុញ្ញាណ ក្នុងអនាគត ពាក្យទី ៣ ជាការប្រកាន់មាំក្នុងតួខ្លួនរបស់បុគ្គលដែលអាស្រ័យការត្រិះរិះក្នុងធម៌ទាំងឡាយដែលជាចំណែកអតីត ចំណែកអនាគត ឥទប្បច្ចយតា ( វត្ថុនេះជាបច្ច័យរបស់វត្ថុនេះ ) និងបដិច្ចសមុប្បាទ ។ ម្យ៉ាងទៀត ពាក្យទី ១ ជាការប្រកាន់មាំក្នុងតួខ្លួន របស់បុគ្គលដែលពិចារណាដល់អតីតដោយការពេញចិត្ត ពាក្យទី ២ របស់បុគ្គលដែលសង្ឃឹមអនាគតដោយការពេញចិត្ត ពាក្យទី ៣ របស់បុគ្គលដែលឃ្វេងឃ្វាងក្នុងធម៌ដែលជាបច្ចុប្បន្ន ។ ម្យ៉ាងទៀត ពាក្យទី ១ ជាទិដ្ឋិ មានការមិនដឹង ជាហេតុក្នុងចំណែកអតីត ពាក្យទី ២ ជាទិដ្ឋិមានការមិនដឹងជាហេតុ ក្នុងចំណែកអនាគត ពាក្យទី ៣ ជាការប្រកាន់មាំក្នុងតួខ្លួនដែលមានការមិនដឹងជាហេតុ ក្នុងចំណែកអតីត និងអនាគត

ក្នុងធម៌ទាំងឡាយដែលជាឥទប្បច្ចយតា និងបដិច្ចសមុប្បាទ ។

ម្យ៉ាងទៀត ទិដ្ឋិទាំងឡាយក្នុងទិដ្ឋិកថានេះ លោកពោលដល់ទិដ្ឋិទាំងឡាយដែលមានខន្ធ ៥ ជាទីតាំង អាស្រ័យលំដាប់ដំបូង បន្ទាប់អំពីនោះ លោកពោលដល់ទិដ្ឋិទាំងឡាយ ដែលមានអាយតនៈក្នុង ៦ ខាងក្រៅ ៦ ពួកវិញ្ញាណ ពួកសម្ផស្ស ពួកវេទនា ពួកសញ្ញា ពួកចេតនា ពួកតណ្ហា វិតក្កវិចារ ធាតុ កសិណ ១០ អាការ ៣២ ជាទីតាំងអាស្រ័យ ។

ក្នុងអាការ ៣២ គប្បីជ្រាបថា ក្នុងទីណាការប្រកាន់មាំចែកចំណែកមិនសមគួរ ក្នុងទីនោះ ការប្រកាន់មាំដោយអំណាចការប្រកាន់មាំក្នុងសរីរៈទាំងមូលជាការធ្វើហើយ ឲ្យដូចជាការប្រកាន់មាំចែកជាចំណែក ។ បន្ទាប់អំពីនោះ ក៏ធ្វើការប្រកបដោយអំណាចអាយតនៈ ១២ ធាតុ ១៨ ឥន្ទ្រិយ ១៩ ។ មិនប្រកបឥន្ទ្រិយ ៣ ដែលជាលោកុត្តរសុទ្ធៗ ព្រោះទិដ្ឋិទាំងឡាយរមែងមិនមានលោកុត្តរជាទីតាំងអាស្រ័យ ។ ក្នុងធម៌ទាំងឡាយ ដែលលាយឡំដោយលោកិយ និងលោកុត្តរក្នុងទីទាំងអស់ គប្បីកាន់យកលោកិយតែម្យ៉ាង វៀរលោកុត្តរ និងមិនគួរប្រកាន់រូប ដែលទាក់ទងដោយអនិន្ទ្រិយឡើយ បន្ទាប់ពីនោះ ក៏ធ្វើការប្រកបដោយធាតុ ៣ ភព ៩ ឈាន ព្រហ្មវិហារ សមាបត្តិ និងអង្គនៃបដិច្ចសមុប្បាទ ។ ការបរិហារក្នុងការប្រកាន់ជាតិ ជរា និងមរណៈដោយឡែក មានន័យដូចបានពោលហើយ ។ បទទាំងឡាយ មានរូបជាដើមទាំងអស់នេះ ដែលមានជរា និងមរណៈជាទីបំផុត មាន ១៩៨ បទ ។

[ ១១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទីតាំងនៃទិដ្ឋិទាំងឡាយដូចតទៅ

បទថា **ខន្ធាបិ ទិដ្ឋិដ្ឋានំ** សូម្បីខន្ធទាំងឡាយ សេចក្តីថា ឧបាទានក្ខន្ធ ៥ ឈ្មោះថា ជាហេតុនៃទិដ្ឋិទាំងឡាយ ព្រោះខន្ធ ៥ នោះឯង ជាទីតាំងអាស្រ័យនៃសក្កាយទិដ្ឋិដែលមានវត្ថុ ២០ និងព្រោះព្រះមានព្រះភាគ ត្រាស់ ( ក្នុងសំយុត្តនិកាយ ខន្ធវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ ពួកសមណៈ ឬព្រាហ្មណ៍ណាមួយ កាលយល់ឃើញ តែងយល់ឃើញនូវខ្លួនជាច្រើនប្រការ សមណៈឬព្រាហ្មណ៍ទាំងអស់នោះ រមែងយល់ឃើញនូវឧបាទានក្ខន្ធទាំង ៥ ឬបណ្តាឧបាទានក្ខន្ធទាំង ៥ នុ៎ះ ឧបាទានក្ខន្ធណាមួយ ដូច្នេះ ។

បទថា **អវិជ្ជាបិ ទិដ្ឋិដ្ឋានំ** សេចក្តីថា អវិជ្ជាជាហេតុនៃទិដ្ឋិទាំងឡាយ ព្រោះទិដ្ឋិកើតឡើងដល់បុគ្គលដែលត្រូវអវិជ្ជាធ្វើឲ្យខ្វាក់ និងព្រោះបាលី ( ក្នុងសំយុត្តនិកាយ និទានវគ្គ ) ថា បពិត្រព្រះអង្គដ៏ចម្រើន ទិដ្ឋិ គឺសេចក្តីយល់ឃើញណា ក្នុងបុគ្គលមិនមែនជាសម្មាសម្ពុទ្ធ ថាជាសម្មាសម្ពុទ្ធ បពិត្រព្រះអង្គដ៏ចម្រើន ចុះទិដ្ឋិនេះប្រាកដឡើងព្រោះអាស្រ័យអ្វី ។ ម្នាលកច្ចានៈ ធាតុដែលធំនុ៎ះ គឺអវិជ្ជាធាតុ ។ ម្នាលកច្ចានៈ សញ្ញាដ៏ថោកទាប ទិដ្ឋិដ៏ថោកទាប ... កើតឡើង ព្រោះអាស្រ័យធាតុដ៏ថោកទាប ដូច្នេះ ។

បទថា **ផស្សោបិ ទិដ្ឋិដ្ឋានំ** សេចក្តីថា ផស្សៈជាហេតុនៃទិដ្ឋិទាំងឡាយ ព្រោះទិដ្ឋិកើតឡើងដល់បុគ្គលដែលត្រូវផស្សៈនោះប៉ះខ្ទប់ហើយ និងព្រោះបាលីថា ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណ-ព្រាហ្មណ៍ ដែលជាអ្នកប្រកបដោយបុព្វន្តកប្បទិដ្ឋិ មានសេចក្តីយល់ឃើញរឿយៗ នូវខន្ធជាចំណែកខាងដើម ប្រារព្ធនូវខន្ធជាចំណែកខាងដើម ហើយ

សម្ដែងនូវចំណែកនៃសេចក្ដីយល់ឃើញជាច្រើនប្រការ ឯអារម្មណ៍នៃទិដ្ឋិនោះ ព្រោះមានផស្សៈជាបច្ច័យ ។

បទថា **សញ្ញាបិ ទិដ្ឋិដ្ឋានំ** សេចក្ដីថា សញ្ញាជាហេតុនៃទិដ្ឋិទាំងឡាយ ព្រោះសញ្ញាជាហេតុកាន់យកតាមសភាពដែលមិនពិត ដោយកាន់យកត្រឹមអាការ និងព្រោះពាក្យដែលសភិយបរិព្វាជក ទូលសួរព្រះមានព្រះភាគដោយគាថាថា

បពិត្រព្រះអង្គជាបុគ្គលមានប្រាជ្ញា ស្មើដោយផែនដី ទិដ្ឋិទាំងឡាយ ៣ ណា និងទិដ្ឋិទាំងឡាយ ៦០ ណា ដែលអាស្រ័យនៅដោយវាទសាស្ត្ររបស់សមណៈ ( ជាអន្យតិរ្ថិយ ) អាស្រ័យនៅនឹងពាក្យ ( ថាស្ត្រី-បុរស ) និងសញ្ញា ( ខុសរបស់មនុស្សពាល ) ជាកំពង់ ជាទីចុះរបស់សត្វ ព្រះមានព្រះភាគបានកម្ចាត់ចោល ( នូវទិដ្ឋិទាំងនោះ ) បានកន្លងផុតនូវងងឹត គឺឱឃៈ ដូច្នេះ ។

និងព្រោះព្រះបាលីថា ធម៌ជាចំណែកនៃសេចក្ដីយឺតយូរទាំងឡាយ មានសញ្ញាជាហេតុ ដូច្នេះ ។

បទថា **វិតក្កោបិ ទិដ្ឋិដ្ឋានំ** សេចក្ដីថា វិតក្កជាហេតុនៃទិដ្ឋិទាំងឡាយ ព្រោះទិដ្ឋិកើតឡើងដោយការត្រិះរិះដល់អាការ និងព្រោះបាលីថា

( ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា ) សច្ចៈទាំងឡាយច្រើនផ្សេងៗ គ្នាក្នុងលោកមិនមានទេ លើកលែងតែសេចក្ដីប្រកាន់ថាទៀង

ដោយសញ្ញាចេញ គឺមានតែបរមត្ថសច្ចមួយប៉ុណ្ណោះ មួយទៀត សមណព្រាហ្មណ៍ទាំងឡាយ កំណត់ទុកនូវសេចក្តីត្រិះរិះ ឲ្យប្រជុំចុះក្នុងទិដ្ឋិទាំងឡាយ ហើយនិយាយនូវហេតុមួយគូជាធម្មតា គឺសេចក្តីពិត ១ មុសា ១ ។

បទថា **អយោនិសោមនសិការោបិ ទិដ្ឋិដ្ឋានំ** សេចក្តីថា អយោនិសោមនសិការ ជាហេតុនៃទិដ្ឋិទាំងឡាយ ព្រោះអយោនិសោមនសិការជាហេតុចំពោះនៃអកុសលទាំងឡាយ និងព្រោះបាលីថា កាលបុថុជ្ជននោះធ្វើទុកក្នុងចិត្តដោយខុសទំនងយ៉ាងនេះហើយ បណ្តាទិដ្ឋិទាំង ៦ ទិដ្ឋិណាមួយ គង់កើតឡើងបាន ដូច្នេះ ។

បទថា **បាបមិត្តោបិ ទិដ្ឋិដ្ឋានំ** សេចក្តីថា មិត្តអាក្រក់ជាហេតុនៃទិដ្ឋិទាំងឡាយ ព្រោះទិដ្ឋិកើតឡើងដោយកាន់យកមិត្តអាក្រក់ ជាទិដ្ឋានុគតិ និងព្រោះបាលីថា ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញអង្គដទៃដែលជាអង្គខាងក្រៅ ដែលប្រព្រឹត្តទៅដើម្បីឲ្យខូចប្រយោជន៍ច្រើន ដូចការមានបាបមិត្តនេះសោះឡើយ ។

បទថា **បរតោឃោសោបិ ទិដ្ឋិដ្ឋានំ** សេចក្តីថា សំឡេងអំពីទីដទៃធ្វើឲ្យជាមិច្ឆាទិដ្ឋិ កជាប្រកបដោយមិច្ឆាទិដ្ឋិជាហេតុនៃទិដ្ឋិទាំងឡាយ ព្រោះទិដ្ឋិកើតឡើងដោយការស្តាប់ធម៌ដែលពោលមិនល្អ និងព្រោះព្រះបាលីថា ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយពីរយ៉ាងនេះជាបច្ច័យ ដើម្បីនាំឲ្យមិច្ឆាទិដ្ឋិកើតឡើង គឺសូរសំឡេងគឹកកងអំពីសម្នាក់អ្នកដទៃ ( ការស្តាប់អសទ្ធម្ម ) ១ អយោ-

និសោមនសិការ ១ ។ ឥឡូវនេះ ព្រះសារីបុត្ត កាលនឹងអធិប្បាយសេចក្តីនៃពាក្យថា **ទិដ្ឋិដ្ឋានំ** ទើបពោលពាក្យជាដើមថា **ខន្ធា ហេតុ ខន្ធា បច្ចយា** ដូច្នេះ អធិប្បាយថា ខន្ធទាំងឡាយប៉ុណ្ណោះជាហេតុកើត និងជាបច្ច័យឧបត្ថម្ភព្រោះអាស្រ័យទិដ្ឋិទាំងឡាយ ។ បទថា **សមុដ្ឋានដ្ឋេន** មានវិគ្គហៈថា ឈ្មោះថា **សមុដ្ឋានដ្ឋេន** ព្រោះអត្ថថា ជាហេតុតាំងឡើង គឺកើតឡើង អធិប្បាយថា ជាហេតុ ព្រោះអត្ថថា ជាទីតាំងឡើងនោះ គឺព្រោះភាពជាហេតុនៃទិដ្ឋិ ។

[ ១២ ] ឥឡូវនេះ ព្រះសារីបុត្តត្ថេរ កាលនឹងសម្តែងដល់ប្រភេទរបស់ទិដ្ឋិដោយប្រភេទនៃកិច្ច ទើបពោលពាក្យថា **កតមានិ អដ្ឋារស ទិដ្ឋិបរិយុដ្ឋានានិ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **យា ទិដ្ឋិ** ជាពាក្យផ្តើម ទូទៅនៃបទ ១៨ ដែលនឹងពោលក្នុងកាលឥឡូវនេះ ។

គប្បីធ្វើការភ្ជាប់បទទាំងពួងថា ទិដ្ឋិ គឺទិដ្ឋិគតៈនោះឯង ទិដ្ឋិ គឺទិដ្ឋិ ដូចព្រៃស្មុកនោះឯង ។ ឈ្មោះថា **ទិដ្ឋិ** ព្រោះអត្ថថា មិនឃើញតាមសេចក្តីពិត ការឃើញក្នុងទិដ្ឋិទាំងឡាយនោះឯង ឈ្មោះថា ទិដ្ឋិគតៈ ព្រោះឈមចុះខាងក្នុងទិដ្ឋិ ៦២ ។ ខ្ញុំធ្លាប់ពោលអត្ថនៃទិដ្ឋិគតៈនោះហើយ ។ ឈ្មោះថា ទិដ្ឋិគតៈ ព្រោះកាន់យកអន្តធម៌ណាមួយ ក្នុងបណ្តាអន្តធម៌ ២ យ៉ាង ។

ទិដ្ឋិនោះឯង ឈ្មោះថា **ទិដ្ឋិគហនំ** ព្រោះអត្ថថា ឈានកន្លងទៅបានលំបាកដូចស្មៅក្រាស់ ព្រៃ និងភ្នំ ។ ឈ្មោះថា **ទិដ្ឋិកន្តារំ** ព្រោះអត្ថថា មានសេចក្តីរង្កៀស និងមានភ័យចំពោះមុខ ដូចកន្តារព្រោះចោរ ព្រោះសត្វសាហាវ ព្រោះ

*មិនមានទឹក ព្រោះរកកិច្ចបានដោយក្រ ។ ក្នុងធម្មសង្គណីមកហើយដោយលិង្គរបស់ខ្លួនថា* **ទិដ្ឋិកន្តារោ** *( កន្តារ គឺទិដ្ឋិ ) ឈ្មោះថា* **ទិដ្ឋិវិសូកំ** *ព្រោះអត្ថថា ចាក់ដោត និងផ្ទុយគ្នាជាមួយសម្មាទិដ្ឋិ ។*

*ពិតហើយ ការឃើញខុស កាលកើតឡើង រមែងចាក់ទម្លុះ និងបញ្ច្រាស់ផ្លូវជាមួយសម្មាទិដ្ឋិ ។ ក្នុងធម្មសង្គណីមកហើយថា* **ទិដ្ឋិវិសូកាយិកំ** *( ជាសត្រូវរបស់ទិដ្ឋិ ) ។ ឈ្មោះថា* **ទិដ្ឋិវិប្ផន្ទិតំ** *ព្រោះអត្ថថា ជាទិដ្ឋិវិបរិតខុសប្រក្រតី ព្រោះជួនកាលកាន់យកសស្សតទិដ្ឋិ ជួនកាលកាន់ឧច្ឆេទទិដ្ឋិ ។*

*ពិតហើយ អ្នកមានទិដ្ឋិ មិនអាចតាំងនៅក្នុងទិដ្ឋិមួយបាន ជួនកាលវៀកដល់សស្សតទិដ្ឋិ ជួនកាលវៀកដល់ឧច្ឆេទទិដ្ឋិ ។ ឈ្មោះថា* **ទិដ្ឋិសំយោជនំ** *ព្រោះអត្ថថា ទិដ្ឋិនោះឯង ប្រកបក្នុងវត្ថុមិនជាប្រយោជន៍ ។*

*ឈ្មោះថា* **ទិដ្ឋិសល្លំ** *ព្រោះអត្ថថា ទិដ្ឋិនោះឯង ឈ្មោះថា ជាកូនសរ ដោយអត្ថថា មុតចូលទៅខាងក្នុង និងព្រោះអត្ថថា នាំចេញបានលំបាក ។*

*ឈ្មោះថា* **ទិដ្ឋិសម្ពាធោ** *ព្រោះអត្ថថា ទិដ្ឋិនោះឯង ជាការចង្អៀតចង្អល់ ដោយអត្ថថា ធ្វើនូវការបៀតបៀន ។*

*ឈ្មោះថា* **ទិដ្ឋិបលិពោធោ** *ព្រោះអត្ថថា ទិដ្ឋិនោះឯង ជាគ្រឿងកង្វល់ ដោយអត្ថថា រារាំងនូវការរួចផុត ។*

*ឈ្មោះថា* **ទិដ្ឋិពន្ធនំ** *ព្រោះអត្ថថា ទិដ្ឋិនោះឯង ជាគ្រឿងចង ដោយអត្ថថា ស្រាយបានដោយក្រ ។*

*ឈ្មោះថា* **ទិដ្ឋិបបាតោ** *ព្រោះអត្ថថា ទិដ្ឋិនោះឯងជាជ្រោះ ដោយអត្ថថា*

ធ្ងន់ឡើងបានលំបាក ។

ឈ្មោះថា **ទិដ្ឋានុសយោ** ព្រោះអត្ថថា ទិដ្ឋិនោះឯងជាអនុស័យ ដោយអត្ថថា ជាសភាវៈមានកម្លាំង ។

ឈ្មោះថា **ទិដ្ឋិសន្តាបោ** ព្រោះអត្ថថា ទិដ្ឋិនោះឯងធ្វើខ្លួនឲ្យក្តៅក្រហាយ ។

ឈ្មោះថា **ទិដ្ឋិបរិឡាហោ** ព្រោះអត្ថថា ទិដ្ឋិនោះឯងតាមដុតរោលខ្លួន ។

ឈ្មោះថា **ទិដ្ឋិគន្ថោ** ព្រោះអត្ថថា ទិដ្ឋិនោះឯងរួបរឹតគំនរកិលេស ។

ឈ្មោះថា **ទិដ្ឋុបាទានំ** ព្រោះអត្ថថា ទិដ្ឋិនោះឯងប្រកាន់យ៉ាងមាំ ។

ឈ្មោះថា **ទិដ្ឋាភិនិវេសោ** ព្រោះអត្ថថា ទិដ្ឋិនោះឯងប្រកាន់ខុស ដោយអំណាចថាពិតជាដើម ។

ឈ្មោះថា **ទិដ្ឋិបរាមាសោ** ព្រោះអត្ថថា ទិដ្ឋិនោះឯងរមែងស្ទាបអង្អែលថា នេះជារបស់ដទៃ ឬស្ទាបអង្អែលដោយភាពជារបស់ដទៃ ។

[ ១៣ ] ឥឡូវនេះ ព្រះសារីបុត្តត្ថេរកាលសម្តែងទិដ្ឋិ ១៦ ដោយអំណាចជាគំនរ ទើបពោលពាក្យថា **កតមា សោឡស ទិដ្ឋិយោ** ដូច្នេះជាដើម ។

គប្បីជ្រាបវិនិច្ឆ័យក្នុងទិដ្ឋិ ១៦ នោះដូចតទៅនេះ

ទិដ្ឋិក្នុងសេចក្តីពេញចិត្ត គឺសុខ និងសោមនស្ស ឈ្មោះថា **អស្សាទទិដ្ឋិ**។ ទិដ្ឋិដែលទៅតាមខ្លួន ឈ្មោះថា **អត្តានុទិដ្ឋិ**។ ទិដ្ឋិដែលវិបរិតព្រោះប្រព្រឹត្តទៅថាមិនមានឈ្មោះថា **មិច្ឆាទិដ្ឋិ** ។ ទិដ្ឋិក្នុងកាយដែលមាន ឬទិដ្ឋិដែលមានក្នុងកាយ ឈ្មោះថា **សក្កាយទិដ្ឋិ** ។ ម្យ៉ាងទៀត ក្នុងបទថា **កាយោ** នេះ គឺខន្ធបញ្ចកៈ ។ ឈ្មោះថា **សក្កាយវត្ថុកា** ព្រោះអត្ថថា មានសក្កាយ គឺខន្ធ-

បញ្ចក្ខន្ធៈជាវត្ថុ គឺជាទីតាំង ។ ទិដ្ឋិដែលប្រព្រឹត្តទៅហើយថាទៀង ឈ្មោះថា **សស្សតទិដ្ឋិ** ។ ទិដ្ឋិដែលប្រព្រឹត្តទៅហើយថាសូន្យ ឈ្មោះថា **ឧច្ឆេទទិដ្ឋិ** ។ ឈ្មោះថា **អន្តគ្គាហិកា** ព្រោះអត្ថថា កាន់យកទីបំផុត មានសស្សតទិដ្ឋិជាដើម ឬព្រោះមានការកាន់យកទីបំផុត ។ ទិដ្ឋិដែលទៅតាមទីបំផុតខាងដើម គឺអតីត ឈ្មោះថា **បុព្វន្តានុទិដ្ឋិ** ។ ទិដ្ឋិដែលទៅតាមទីបំផុតខាងចុង គឺអនាគត ឈ្មោះថា **អបរន្តានុទិដ្ឋិ** ។ ឈ្មោះថា **សញ្ញោជនិកា** ព្រោះអត្ថថា ប្រកបក្នុងវត្ថុមិនមានប្រយោជន៍ ។ ទិដ្ឋិដែលជាគ្រឿងចងបន្តឲ្យកើតឡើងដោយមានះដែលកើតឡើង ថាជាអញដោយអំណាចអហង្ការ ដែលជាមូលនៃទិដ្ឋិ ឈ្មោះថា **អហន្តិ មានវិនិពទ្ធា ទិដ្ឋិ** ។ មួយវិញទៀត ទិដ្ឋិដែលចងដោយមានះ ដែលកើតឡើងថា របស់អញ ដោយអំណាចមមង្ការ ឈ្មោះថា **មមន្តិ មានវិនិពទ្ធា ទិដ្ឋិ** ។ ការនិយាយ ការពោលរបស់ខ្លួន ឈ្មោះថា **អត្តវាទ** ។ ទិដ្ឋិដែលសម្បយុត្តទាក់ទងដោយអត្តវាទនោះ ឈ្មោះថា **អត្តវាទប្បដិសំយុត្តា ទិដ្ឋិ** ។

ការនិយាយ ការពោលនូវខ្លួនថាជាលោក ឈ្មោះថា **លោកវាទ** ។ ទិដ្ឋិដែលសម្បយុត្តដោយលោកវាទៈនោះ ឈ្មោះថា **លោកវាទប្បដិសំយុត្តា ទិដ្ឋិ** ។ សភាពទៀង ហៅថា **ភវ** ។ ទិដ្ឋិដែលកើតឡើងដោយអំណាចនៃការទៀង ឈ្មោះថា **ភវទិដ្ឋិ** ។ ការដាច់សូន្យ ហៅថា **វិភវ** ។ ទិដ្ឋិដែលកើតឡើងដោយអំណាចនៃការដាច់សូន្យ ឈ្មោះថា **វិភវទិដ្ឋិ** ។

[ ១៤-១៥ ] ឥឡូវនេះ ព្រះសារីបុត្តត្ថេរបំណងនឹងសម្ដែងការប្រកាន់ខុសដោយទិដ្ឋិ ៣០០ មិនសួរថា ការប្រកាន់ខុសដោយទិដ្ឋិ ៣០០ តើដូចម្ដេច

ហើយធ្វើយការប្រកាន់ខុសទាំងនោះទុកឡើយ តែបំណងនឹងធ្វើយការប្រកាន់ខុសទាំងនោះ ដោយធ្វើយការប្រកាន់ខុសដោយឡែកៗ ទើបសួរដល់ចំនួននៃការប្រកាន់ខុសនៃទិដ្ឋិ ១៦ ដោយន័យជាដើមថា ការប្រកាន់ស្អិតនៃអស្សាទ-ទិដ្ឋិ ដោយអាការប៉ុន្មានយ៉ាង ។ ហើយធ្វើយចំនួនអាការនៃការប្រកាន់ស្អិតនៃទិដ្ឋិទាំង ១៦ នោះថា ការប្រកាន់ស្អិតនៃអស្សាទទិដ្ឋិដោយអាការ ៣៥ យ៉ាង ដូច្នេះជាដើម កាលធ្វើយចំនួនទាំងនោះទៀត ទើបពោលពាក្យថា ការប្រកាន់ស្អិតនៃអស្សាទទិដ្ឋិ ដោយអាការ ៣៥ យ៉ាង តើដូចម្តេច ដូច្នេះជាដើម ។

[ ១៦ ] ក្នុងបទទាំងនោះ បទថា **រូបំ បដិច្ច** បានដល់ អាស្រ័យ រូបក្ខន្ធ ។ បទថា **ឧប្បជ្ជតិ សុខំ សោមនស្សំ** សេចក្តីថា សុខ សោមនស្សសម្បយុត្តដោយរាគៈអាស្រ័យផ្ទះ រមែងកើតឡើងព្រោះអាស្រ័យរូបសម្បត្តិថា កាយរបស់អញនេះ ជាយ៉ាងនេះ ។ សុខ និងសោមនស្ស ដោយអត្ថបានពោលហើយក្នុងខាងដើម ។ សុខ សោមនស្សនោះឯង ជាតម្រេកចំពោះរូប ព្រោះហេតុនោះ ទើបឈ្មោះថា **រូបស្ស អស្សាទោ**។ ឈ្មោះថា អស្សាទ ព្រោះអត្ថថា បុគ្គលត្រេកអរសោយសុខនោះ ដោយអំណាចនៃតណ្ហា ។

បទថា **អភិនិវេសបរាមាសោ ទិដ្ឋិ** សេចក្តីថា ស្ទាបអង្អែលដោយការប្រកាន់ស្អិតថា អស្សាទនោះទៀងក្តី សូន្យក្តី រមែងធ្វើខ្លួនដែលទៀង ឬសូន្យឲ្យមានសេចក្តីសុខក្តី ។ ព្រោះហេតុនោះ បទថា **យា ច ទិដ្ឋិ យោ ច អស្សាទោ** សេចក្តីថា ទិដ្ឋិ និងអស្សាទទាំង ២ លោករួមគ្នា ព្រោះអធិប្បាយថា អស្សាទ ទោះជាទិដ្ឋិក្តី មិនជាទិដ្ឋិក្តី ទិដ្ឋិនោះវៀរអស្សាទ មានមិនបាន ។

បទថា **អស្សាទទិដ្ឋិ** មានអធិប្បាយថា ទិដ្ឋិដែលប្រព្រឹត្តទៅក្នុងការត្រេកអរ ។

ឥឡូវនេះ ព្រះសារីបុត្តត្ថេរ បំណងនឹងប្រៀបធៀបដោយសូត្រផ្សេងៗ ហើយតិះដៀលមិច្ឆាទិដ្ឋិ និងបុគ្គលជាមិច្ឆាទិដ្ឋិ ទើបពោលពាក្យថា **អស្សាទទិដ្ឋិ មិច្ឆាទិដ្ឋិ** ជាដើម ។

ក្នុងបទទាំងនោះ បទថា **ទិដ្ឋិវិបត្តិ** បានដល់ វិបត្តិដោយទិដ្ឋិ ពោល គឺ មិច្ឆាទិដ្ឋិដែលធ្វើសម្មាទិដ្ឋិឲ្យវិនាស ។ បទថា **ទិដ្ឋិវិបន្នោ** មានវិគ្គហៈថា ឈ្មោះថា ទិដ្ឋិវិបន្ន អធិប្បាយថា មានទិដ្ឋិវិបត្តិ ព្រោះអត្ថថា មានសម្មាទិដ្ឋិវិបត្តិ□ឺ វិនាស ។ ម្យ៉ាងទៀត ឈ្មោះថា ទិដ្ឋិវិបន្ន ព្រោះអត្ថថា ត្រូវមិច្ឆាទិដ្ឋិធ្វើឲ្យវិបត្តិ និងវិនាស ។ បុគ្គលដែលមានទិដ្ឋិវិបត្តិ មិនត្រូវសេពគប់ដោយការចូលទៅរក មិនត្រូវគប់រកដោយចិត្ត មិនត្រូវអង្គុយជិតដោយការចូលទៅរកហើយអង្គុយ ។

បទថា **តំ កិស្ស ហេតុ** ជាការណបុច្ឆា ( សួរដល់ហេតុ ) នៃកិរិយានោះថា ព្រោះហេតុអ្វី ទើបមិនត្រូវសេពគប់ជាដើមនោះ ។ បទថា **ទិដ្ឋិ ហិស្ស បាបិកា** ជាពាក្យឆ្លើយដល់ហេតុ អធិប្បាយថា ព្រោះបុគ្គលនោះមានទិដ្ឋិលាមក ហេតុនោះ ទើបមិនត្រូវធ្វើការសេពគប់ជាដើមនោះ ។

បទថា **ទិដ្ឋិយា រាគោ** សេចក្តីថា រាគៈកើតឡើងដោយទិដ្ឋិ ប្រារព្ធទិដ្ឋិថា ទិដ្ឋិរបស់អញល្អ ។ បទថា **ទិដ្ឋិរាគរត្តោ** សេចក្តីថា ជាអ្នកត្រេកអរដោយទិដ្ឋិរាគៈនោះ ដូចសំពត់ជ្រលក់ដោយពណ៌ ។ បទថា **ន មហប្ផលំ** បានដល់ ដោយផលដែលជាវិបាក ។ បទថា **ន មហានិសំសំ** បានដល់

ដោយផលដែលហូរចុះមក ។ បទថា **បុរិសបុគ្គលស្ស** បានដល់ បុគ្គល ពោល គឺបុរស ។ ព្រោះដោយលោកវោហារ សរីរៈ លោកហៅថា **បុំ** ។ ឈ្មោះ **បុរិស** ព្រោះទៅ គឺប្រព្រឹត្តទៅក្នុងសរីរៈនោះ ។ នរក ហៅថា **បុំ** ឈ្មោះថា បុគ្គល ព្រោះឃ្លាតទៅកាន់នរកនោះ ។ ពិតហើយ ដោយច្រើន សត្វទាំងឡាយចុតិចាកសុគតិហើយ រមែងកើតឡើងក្នុងទុគ្គតិទាំងនោះ ។

បទថា **តំ កិស្ស ហេតុ** បានដល់ ភាពដែលទានមិនមានផលច្រើននោះ កើតព្រោះហេតុអ្វី ។ បទថា **ទិដ្ឋិ ហិស្ស ទាបិកា** សេចក្តីថា ព្រោះបុគ្គល នោះមានទិដ្ឋិលាមក ហេតុនោះ ទើបទានមិនមានផលច្រើន ។ បទថា **ទ្វេវ គតិយោ** បានដល់ មានគតិ ២ ក្នុងគតិ ៥ ។ ឈ្មោះថា **និរយោ** ព្រោះ ទិដ្ឋិវិបត្តិ ។ ឈ្មោះថា **តិរច្ឆានយោនិ** ព្រោះទិដ្ឋិវិបត្តិ ។

បទថា **យញ្ចេវ កាយកម្មំ** បានដល់ កាយកម្ម មានការតាំងភេទរបស់ ខ្លួនការប្រកបកិច្ចបដិបត្តិ អភិវាទ ក្រោកទទួល និងធ្វើអញ្ជលីជាដើម ។

បទថា **យញ្ច វចីកម្មំ** បានដល់ វចីកម្ម មានការសូត្ររៀន ទន្ទេញ សម្តែង ដឹកនាំក្នុងលទ្ធិរបស់ខ្លួនជាដើម ។

បទថា **យញ្ច មនោកម្មំ** បានដល់ មនោកម្មប្រកបដោយការនឹកគិតដល់ លោកនេះ លោកខាងមុខ និងវត្ថុដែលធ្វើហើយ និងមិនទាន់បានធ្វើ ។ កាយកម្ម វចីកម្ម មនោកម្មក្នុងស្មៅ កំណាត់ឈើ ស្រូវពូជទាំងឡាយ និងក្នុងការបង្អួន ឲ្យទទួលបរិភោគទាន របស់អ្នកមានទិដ្ឋិ ៧ ។ បទថា **យថាទិដ្ឋិ** បានដល់ សមគួរដល់ទិដ្ឋិនោះ ។ បទថា **សមត្តំ** បានដល់ ឲ្យពេញបរិបូរណ៍ ។ បទ

ថា **សមាទិន្នំ** បានដល់ កាន់យក ។

តែក្នុងអដ្ឋកថា លោកពោលថា កាយកម្មនោះមាន ៣ យ៉ាង គឺកាយ-កម្មតាំងទុកតាមទិដ្ឋិ ១ កាយកម្មកើតរួមជាមួយទិដ្ឋិ ១ កាយកម្មអនុលោមតាមទិដ្ឋិ ១ ។ ក្នុងកាយកម្ម ៣ យ៉ាងនោះ កាយកម្ម ពោល គឺបាណាតិបាត អទិន្នាទាន និងមិច្ឆាចាររបស់អ្នកមានទិដ្ឋិយ៉ាងនេះថា អ្នកសម្លាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តខុសក្នុងកាម មិនមានបាបដែលមានការសម្លាប់សត្វជាដើមនោះជាហេតុ បាបមិនមកដល់ នេះឈ្មោះថា កាយកម្មតាំងទុកតាមទិដ្ឋិ ។ កាយ-កម្មកើតរួមគ្នាជាមួយនឹងទិដ្ឋិ គឺយល់ឃើញថា អ្នកសម្លាប់សត្វ អ្នកលួចទ្រព្យអ្នកប្រព្រឹត្តខុសក្នុងកាម មិនមានបាបដែលមានការសម្លាប់សត្វជាដើមនោះជាហេតុ បាបមិនមកដល់ នេះឈ្មោះថា កាយកម្មកើតរួមជាមួយទិដ្ឋិ ។ កាយកម្មនោះឯងដែលប្រកបដោយមិច្ឆាទិដ្ឋិចំពោះអ្នកសមាទានហើយ កាន់យកហើយស្ទាបអង្អែលហើយ ឲ្យបរិបូរណ៍ ឈ្មោះថា កាយកម្មអនុលោមតាមទិដ្ឋិ ។ សូម្បីក្នុងវចីកម្ម មនោកម្មក៏មានន័យនេះដូចគ្នា ។ ម្យ៉ាងទៀត ក្នុងវចីកម្មមនោកម្មនេះ គប្បីប្រកបថា អ្នកនិយាយកុហក និយាយញុះញង់ និយាយពាក្យទ្រគោះ និយាយរោយរាយឥតប្រយោជន៍ មានសេចក្ដីលោភ មានចិត្តព្យាបាទមានការយល់ខុស មិនមានបាបដែលមានការនិយាយកុហកជាដើមនោះជាហេតុ បាបមិនមកដល់ ម្យ៉ាងទៀត ន័យដែលពោលដោយការទ្រទ្រង់គេទជាដើម ការសួរបរៀនជាដើម និងការគិតរបស់សត្វលោកជាដើម ជាន័យដែលល្អ ក្នុងសេចក្ដីនេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងចេតនាជាដើមដូចតទៅនេះថា ការគិតដែលកើតរួមជាមួយទិដ្ឋិ ឈ្មោះថា **ចេតនា** ។ សេចក្តីត្រូវការ ដែលកើតរួមជាមួយទិដ្ឋិ ឈ្មោះថា **បត្ថនា** ។ ការតាំងចិត្តដោយអំណាចនៃចេតនា និងការប្រាថ្នា ឈ្មោះថា **បណិធិ** ។ ធម៌ទាំងឡាយដែលទាក់ទងក្នុងសង្ខារក្ខន្ធ មានផស្សៈជាដើម ដែលសម្បយុត្តដោយចេតនាជាដើមទាំងនោះ ឈ្មោះថា **សង្ខារា** ។

ដោយបទថា **អនិដ្ឋាយ** ជាដើម លោកពោលដល់ទុក្ខទាំងនោះ ។ ពិតហើយ ទុក្ខ ឈ្មោះថា **អនិដ្ឋំ** ព្រោះសត្វទាំងឡាយអ្នកប្រាថ្នាសេចក្តីសុខមិន ស្វែងរក ឈ្មោះថា **អកន្តំ** ព្រោះមិនជាទីស្រឡាញ់ ឈ្មោះថា **អមនាបំ** ព្រោះមិនធ្វើឲ្យចម្រើនចិត្ត និងព្រោះមិនជាទីពេញចិត្ត ឈ្មោះថា **អហិតំ** ព្រោះមិនចម្រើនតទៅ ឈ្មោះថា **ទុក្ខំ** ព្រោះបៀតបៀន ។

បទថា **តំ កិស្ស ហេតុ** សេចក្តីថា ការប្រព្រឹត្តទៅយ៉ាងនោះ រមែងមានព្រោះហេតុអ្វី ។ ហេតុនៃការប្រព្រឹត្តទៅនោះ ក្នុងឥឡូវនេះ ក៏គឺទិដ្ឋិរបស់បុគ្គលនោះ ជាធម្មជាតដ៏លាមក អធិប្បាយថា ព្រោះទិដ្ឋិរបស់បុគ្គលនោះអាក្រក់លាមក ហេតុនោះ ទើបប្រព្រឹត្តទៅយ៉ាងនោះ ។

បទថា **អល្លាយ បឋវិយា និក្ខិត្តំ** បានដល់ ដាំក្នុងផែនដីដែលសើមដោយទឹក ។ បទថា **បឋវីរសំ អាបោរសំ** បានដល់ ការបរិបូរណ៍នៃផែនដី និងការបរិបូរណ៍នៃទឹកក្នុងទីនោះៗ ព្រោះក្នុងទីដែលដាំពូជ ផែនដីទាំងអស់ និងទឹកទាំងអស់មិនធ្វើពូជឲ្យចេញផ្លែបាន ។ ចំណែករបស់ផែនដី និងទឹកទាំងនោះប៉ុណ្ណោះដែលពាល់ត្រូវនឹងពូជ រមែងធ្វើពូជឲ្យចេញផ្លែបាន ព្រោះហេតុនោះ

ផែនដីនោះ ដែលជាបច្ច័យដើម្បីចិញ្ចឹមពូជ គប្បីជ្រាបថាជារសផែនដី ជារសទឹក ។ ព្រោះ **រស** សព្ទ មានអត្ថថា សម្បត្តិ ដូចលោកពោលថា ហៅថារស ដោយអត្ថថា កិច្ច និងសម្បត្តិ ។ ម្យ៉ាងទៀត កាលសត្វលោកពោលថា គន្ធពូមានរសល្អ រមែងដឹងសេចក្តីថា គន្ធពូសម្បូរល្អហើយ ។

បទថា **ឧបាទិយតិ** បានដល់ កាន់យក ។ ព្រោះពូជបានផែនដីដែលជាបច្ច័យ រមែងកាន់យករសផែនដី និងរសទឹកនោះបាន ។ បទថា **សព្វំ តំ** បានដល់ រសទាំងពួងនោះ ។ បទថា **តិត្តកត្តាយ** បានដល់ រសផែនដី និងរសទឹកនោះសូម្បីមិនមានរសល្វីងអាស្រ័យពូជដែលល្វីង រមែងក្លាយជារបស់ល្វីងនៃដើមស្តៅជាដើម និងនៃផ្លែទាំងនោះ ។ បទថា **កដុកត្តាយ** នេះ ជាវេវចនៈរបស់បទមុននោះឯង ។ គប្បីជ្រាបថា រសល្វីងក្នុងទីនេះ ឈ្មោះថា រសក្រពុល ព្រោះមិនជាទីពេញចិត្តដូចក្នុងអាគតដ្ឋាន ( ទធិវាហនជាតក ) ថា

> ក្នុងកាលមុន ដើមស្វាយនេះ ប្រកបដោយពណ៌ក្លិន និងរស
> បាននូវគ្រឿងសក្ការបូជានោះដដែល ហេតុអ្វី ស្វាយក៏មាន
> ផ្លែល្វីងទៅវិញ ដូច្នេះ ។

បទថា **អសាតតាយ** បានដល់ មិនមានរសផ្អែម ។ បាឋៈថា **អសាទុត្តាយ** ក៏មាន សេចក្តីថា មានរសមិនឆ្ងាញ់ ។

ពិតហើយ បទថា **សាទុ** បានដល់ ឆ្ងាញ់ ។ បទថា **ពីជំ ហិស្ស** បានដល់ ពូជរបស់ស្តៅជាដើមនោះ ។ បទថា **ឯវមេវំ** កាត់បទជា **ឯវំ ឯវំ** ។ ព្រោះសុខវេទនា ជាសេចក្តីត្រេកអរយ៉ាងក្រៃលែង ហេតុនោះ ទើបលោកសម្តែងដល់ទោសនៃមិច្ឆាទិដ្ឋិដោយអំណាចនៃទុក្ខវេទនា ។ ព្រះសារីបុត្តត្ថេរ

ដើម្បីសម្ដែងដល់ទោសនៃទិដ្ឋិដោយប្រភេទ ១៨ យ៉ាង ទើបពោលពាក្យថា **អស្សាទទិដ្ឋិ មិច្ឆាទិដ្ឋិ** ជាដើម ។ បទនោះ មានសេចក្ដីដូចបានពោលហើយ ។

[ ១៧ ] បទថា **ឥមេហិ អដ្ឋារសហិ អាការេហិ បរិយុដ្ឋិតចិត្តស្ស សញ្ញោគោ** លោកសម្ដែងដល់ការចងភ្ជាប់ក្នុងសង្សារដោយទិដ្ឋិនោះឯង ។

[ ១៨ ] ព្រោះសំយោជនៈជាទិដ្ឋិក៏មាន មិនមែនជាទិដ្ឋិក៏មាន ហេតុនោះ ព្រះសារីបុត្តត្ថេរ កាលសម្ដែងប្រភេទនោះ ទើបលោកពោលពាក្យថា **អត្ថិ សញ្ញោជនានិ ចេវ** ជាដើម ។

ក្នុងបទទាំងនោះ ព្រោះកាមរាគសំយោជនៈមកថា **អនុនយសញ្ញោជនំ** ខ្លះក៏មាន ហេតុនោះ ទើបលោកពោលថា **អនុនយសញ្ញោជនំ** ។

គប្បីជ្រាបថា អនុនយសញ្ញោជនៈនេះ លោកពោលសំដៅដល់សេចក្ដីលោភដែលប្រព្រឹត្តទៅមិនទាន់ដល់ភាពជាកាមរាគៈ ។ ក្នុងវារៈសូម្បីជាមូលហេតុ មានខន្ធ និងអាយតនៈដ៏សេសជាដើម ក៏គប្បីជ្រាបសេចក្ដីដោយន័យនេះដូចគ្នា ។

ម្យ៉ាងទៀត ព្រោះអស្សាទៈមានវេទនាដ៏ក្រៃលែង ទើបលោកធ្វើទេសនាមានវេទនាជាទីបំផុត ។ មិនកាន់យកសញ្ញាជាដើម ។

បទថា **ឥមេហិ បញ្ចត្តឹសាយ អាការេហិ** បានដល់ ដោយអាការ ៣៥ ដោយអំណាចនៃអារម្មណ៍ គឺអស្សាទៈដែលកើតឡើងព្រោះអាស្រ័យវត្ថុ ៣៥ ទាំងនេះ គឺបញ្ចក្ខន្ធ និងពួក ៦ ទៀត ៥ ពួកមានអាយតនៈខាងក្នុងជាដើម ៕

**អដ្ឋកថាអស្សាទទិដ្ឋិនិទ្ទេស ចប់**

# អដ្ឋកថា
## អត្តានុទិដ្ឋិនិទ្ទេស

[ ១៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអត្តានុទិដ្ឋិដូចតទៅ បទថា **អស្សុតវា បុថុជ្ជនោ** បានដល់ បុថុជ្ជនដែលបុគ្គលគប្បីដឹងថា មិនបានស្តាប់ ព្រោះមិនមានការសិក្សារៀនសូត្រ និងការសម្រេច ។

បុថុជ្ជនអ្នកមិនមានការសិក្សាដែលជាគ្រឿងបដិសេធអត្តានុទិដ្ឋិ ព្រោះវៀរចាកការរៀនសូត្រ ការសាកសួរ និងការវិនិច្ឆ័យ ក្នុងខន្ធ ធាតុ អាយតនៈ សច្ចៈ បច្ចយាការ និងសតិប្បដ្ឋានជាដើម និងមិនមានការសម្រេចព្រោះមិនចាក់ធ្លុះនូវវត្ថុដែលគួរចាក់ធ្លុះដោយបដិបទា ដែលបុគ្គលគប្បីដឹងថា ជាអ្នកមិនបានស្តាប់ ព្រោះមិនមានការសិក្សា និងការសម្រេច ។

ពិតហើយ បទថា **សុតំ** បានដល់ ការសិក្សាព្រះពុទ្ធវចនៈ និងការសម្រេចដោយវោហារថា សុតៈជាហេតុ ព្រោះជាផលនៃសុតៈ ឈ្មោះថា **សុតវា** ព្រោះមានសុតៈនោះ អ្នកមិនមានសុតៈ ឈ្មោះថា អ្នកមិនបានស្តាប់ ។ បុគ្គលអ្នកមិនបានស្តាប់នោះជាបុថុជ្ជន ដោយហេតុញ៉ាំងកិលេសដ៏ក្រាស់ឲ្យកើតជាដើម ជននេះ ឈ្មោះថា មានកិលេសក្រាស់ ព្រោះរាប់ចូលខាងក្នុងនៃបុគ្គលដែលមានកិលេសក្រាស់ ។

ពិតហើយ ជននោះជាបុថុជ្ជន ដោយហេតុញ៉ាំងកិលេសជាដើមដ៏ក្រាស់មានប្រការផ្សេងៗ ឲ្យកើតជាដើម ។ សមដូចដែលលោកពោល ( ក្នុងខុទ្ទកនិកាយ មហានិទ្ទេស ) ថា ឈ្មោះថា បុថុជ្ជន ព្រោះញ៉ាំងកិលេសក្រាស់

ឲ្យកើត ។ ឈ្មោះថា បុថុជ្ជន ព្រោះជាអ្នកមានសក្កាយទិដ្ឋិដ៏ក្រាស់ មិនទាន់លះបង់ ។ ឈ្មោះថា បុថុជ្ជន ព្រោះជាអ្នកពោលប្តេជ្ញាចំពោះមុខសាស្តាទាំងឡាយច្រើន ។ ឈ្មោះថា បុថុជ្ជន ព្រោះជាអ្នកត្រូវគតិទាំងពួងដ៏ក្រាស់ចាក់ស្រែះ ។ ឈ្មោះថា បុថុជ្ជន ព្រោះតាក់តែងដោយអភិសង្ខារផ្សេងៗ ដ៏ក្រាស់ ។ ឈ្មោះថា បុថុជ្ជន ព្រោះត្រូវឱឃៈផ្សេងៗ ដ៏ក្រាស់បន្សាត់ទៅ ។ ឈ្មោះថា បុថុជ្ជន ព្រោះក្តៅក្រហាយដោយកម្តៅផ្សេងៗ ដ៏ក្រាស់ ។ ឈ្មោះថា បុថុជ្ជន ព្រោះរោលរាលដោយកម្តៅរោលរាលផ្សេងៗ ដ៏ក្រាស់ ។ ឈ្មោះថា បុថុជ្ជន ព្រោះត្រេកអរ ញ៉ាម ជាប់ចិត្ត ជ្រប់ ងល់ងប់ ជាប់ជំពាក់ ចាក់ស្រែះ រួបរឹតក្នុងកាមគុណ ៥ ដ៏ក្រាស់ ។ ឈ្មោះថា បុថុជ្ជន ព្រោះត្រូវនីវរណៈ ៥ ដ៏ក្រាស់ចាក់ស្រែះ រួបរឹត គ្របសង្កត់ សន្ធប់ បិទបាំង សណ្តំជាប់ ដូច្នេះ ។

ម្យ៉ាងវិញទៀត ឈ្មោះថា បុថុជ្ជន ព្រោះរាប់ចូលខាងក្នុងនៃជនជាច្រើន ហួសទីងរាប់បានដែលបែរខ្នងដាក់អរិយធម៌ ប្រព្រឹត្តធម៌ថោកទាប ឬព្រោះជនអ្នកមានកិលេសក្រាស់នេះ បំបែកខ្លួនចេញទៅ មិនសេពគប់ជាមួយព្រះអរិយៈ ដែលប្រកបដោយគុណ មានសីល និងសុតៈជាដើម ។

ដោយប្រការដូច្នេះ បទ ២ នេះថា **អស្សុតវា បុថុជ្ជនោ** លោកពោលបុថុជ្ជនទាំង ២ ជំពូកនោះថា

ព្រះសម្ពុទ្ធជាផៅពង្សនៃព្រះអាទិត្យ ត្រាស់ដល់បុថុជ្ជនទុក ២ ពួក គឺអន្ធបុថុជ្ជន ១ កល្យាណបុថុជ្ជន ១ ។

ក្នុងបុថុជ្ជន ២ ពួកនោះ គប្បីជ្រាបថា លោកពោលសំដៅដល់អន្ធ-

បុថុជ្ជន ។ ក្នុងបទថា **អរិយានំ អទស្សាវី** ជាដើម មានវិនិច្ឆ័យដូចតទៅ ព្រះពុទ្ធទាំងឡាយ ព្រះបច្ចេកពុទ្ធទាំងឡាយ និងព្រះពុទ្ធសាវ□ាំងឡាយ ហៅថា អរិយៈ ព្រោះជាអ្នកឆ្ងាយចាកកិលេស ព្រោះមិនប្រព្រឹត្តទៅក្នុងផ្លូវវិនាស ព្រោះប្រព្រឹត្តទៅក្នុងផ្លូវចម្រើន និងព្រោះលោក ព្រមទាំងទេវលោក គប្បីចូលទៅរក ឯក្នុងទីនេះ ព្រះសម្ពុទ្ធប៉ុណ្ណោះ ហៅថា អរិយៈ សមដូចព្រះមានព្រះភាគត្រាស់ថា **សទេវកេ ភិក្ខវេ លោកេ ។បេ។ តថាគតោ អរិយោតិ វុច្ចតិ** ម្នាលភិក្ខុទាំងឡាយ ក្នុងលោកនេះ ព្រមទាំងទេវលោក ។បេ។ តថាគត គេហៅថា អរិយៈ ដូច្នេះ ។

ម្យ៉ាងទៀត ព្រះបច្ចេកពុទ្ធ និងព្រះសាវករបស់ព្រះតថាគត គប្បីជ្រាបថាជាសប្បុរស ក្នុងបទថា **សប្បុរិសា** នេះ ។ ពិតហើយ លោកទាំងនោះឈ្មោះថា ជាសប្បុរស ព្រោះជាសប្បុរសដ៏ប្រសើរដោយការប្រកបលោកុត្តរគុណ ។ ម្យ៉ាងវិញទៀត លោកទាំងអស់នោះ លោកក៏ពោលជាពីរប្រភេទ ។ ព្រះពុទ្ធទាំងឡាយ ជាអរិយៈផង ជាសប្បុរសផង ព្រះបច្ចេកពុទ្ធទាំងឡាយ ព្រះពុទ្ធសាវកទាំងឡាយក៏ដូច្នោះ ។ សមដូចសរភង្គតាបសពោល ( ក្នុងសរភង្គជាតក ) ថា

> បុគ្គលណាជាកតញ្ញូកតវេទី មានប្រាជ្ញា មានមិត្តល្អ មានការ
> សេពគប់មាំ ធ្វើនូវកិច្ចដោយគោរព ចំពោះបុគ្គលអ្នកដល់នូវ
> សេចក្តីទុក្ខ បណ្ឌិតទាំងឡាយ ពោលនូវបុគ្គលបែបនោះថា
> ជាអ្នកសប្បុរស ដូច្នេះ ។

ក្នុងគាថានេះ លោកពោលព្រះបច្ចេកសម្ពុទ្ធថា ជាអ្នកកតញ្ញូកតវេទី ជាអ្នកប្រាជ្ញ លោកពោលព្រះពុទ្ធសាវកថា ជាកល្យាណមិត្ត និងជាអ្នកមានការសេពគប់មាំមួន ពោលចំពោះព្រះសម្មាសម្ពុទ្ធថា រមែងធ្វើកិច្ចដោយពេញចិត្ត ដល់បុគ្គលដែលបានទទួលទុក្ខ ។

ឥឡូវនេះ បុគ្គលណា មានប្រក្រតីមិនឃើញព្រះអរិយៈទាំងនោះ និងមិនធ្វើសេចក្តីល្អ ក្នុងការឃើញព្រះអរិយៈទាំងនោះ បុគ្គលនោះ គប្បីជ្រាបថាមិនបានជួបប្រទះនឹងពួកព្រះអរិយៈ ។ ជននោះមាន ២ យ៉ាង គឺមិនឃើញដោយចក្ខុ ១ មិនឃើញដោយញាណ ១ ។ ក្នុង ២ យ៉ាងនោះ ក្នុងទីនេះលោកបំណងយកបុគ្គលមិនឃើញដោយញាណ ។ ពិតហើយ បុគ្គលសូម្បីឃើញព្រះអរិយៈទាំងឡាយដោយមំសចក្ខុ ឬដោយទិព្វចក្ខុ ក៏ឈ្មោះថា មិនឃើញ ព្រោះចក្ខុទាំងនោះ កាន់យកត្រឹមតែពណ៌ ព្រោះមិនមែនជាអារម្មណ៍នៃភាពជាអរិយៈ ។ ព្រោះថា សូម្បីឆ្កែស្រុក និងឆ្កែចចកជាដើម ក៏ឃើញព្រះអរិយៈដោយចក្ខុ ទើបជនទាំងនោះ ឈ្មោះថា មិនបានឃើញព្រះអរិយៈ ព្រោះហេតុនោះ ទើបការឃើញដោយចក្ខុ មិនជាការឃើញ ការឃើញដោយញាណប៉ុណ្ណោះ ទើបជាការឃើញ ។ សមដូចព្រះមានព្រះភាគ ត្រាស់ ( ក្នុងសំយុត្តនិកាយ ខន្ធវារវគ្គ ) ថា វក្កលិ ប្រយោជន៍អ្វី ដោយកាយស្អុយដែលអ្នកឃើញហើយនេះ ។ ម្នាលវក្កលិ បុគ្គលណាមួយឃើញធម៌ បុគ្គលនោះឈ្មោះថា ឃើញតថាគត ដូច្នេះ ។ ព្រោះហេតុនោះ បុគ្គលសូម្បីឃើញដោយចក្ខុ ក៏មិនបានឃើញដោយលក្ខណៈ មានអនិច្ចលក្ខណៈជាដើម ដែល

ព្រះអរិយៈឃើញហើយដោយញាណ និងមិនចាក់ធ្លុះធម៌ដែលព្រះអរិយៈសម្រេចហើយ គប្បីជ្រាបថា មិនបានឃើញព្រះអរិយៈទាំងឡាយ ព្រោះមិនឃើញធម៌ដែលធ្វើឲ្យជាអរិយៈ និងភាពជាអរិយៈ ។

បទថា **អរិយធម្មស្ស អកោវិទោ** បានដល់ មិនឈ្លាសក្នុងធម៌របស់ព្រះអរិយៈ មានប្រភេទនៃសតិប្បដ្ឋានជាដើម ។ ម្យ៉ាងទៀត គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **អរិយធម្មេ អវិនីតោ** នេះ ដូចតទៅ

> ឈ្មោះថា វិន័យមាន ២ យ៉ាង ក្នុងវិន័យ ២ យ៉ាងនេះ វិន័យ
> នីមួយៗ មាន ៥ យ៉ាង ព្រោះមិនមានវិន័យនោះ ទើបលោក
> ពោលថា បុថុជ្ជនក្នុងលោកនេះ មិនបានហាត់ចិត្ត ។

ពិតហើយ វិន័យនេះមាន ២ យ៉ាង គឺសំវរវិន័យ ១ បហានវិន័យ ១ ។ ក្នុងវិន័យ ២ យ៉ាងនេះ វិន័យនីមួយៗ បែកជា ៥ យ៉ាង ។

សូម្បីសំវរវិន័យក៏មាន ៥ យ៉ាង គឺសីលសំវរៈ ១ សតិសំវរៈ ១ ញាណសំវរៈ ១ ខន្តិសំវរៈ ១ វីរិយសំវរៈ ១ ។

សូម្បីបហានវិន័យក៏មាន ៥ យ៉ាង គឺតទង្គប្បហាន ១ វិក្ខម្ភនប្បហាន ១ សមុច្ឆេទប្បហាន ១ បដិបស្សទ្ធិប្បហាន ១ និស្សរណប្បហាន ១ ។

ក្នុងសំវរវិន័យនោះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ សំវរៈនេះថា ចូលទៅជិតអែបនែបដោយការសង្រួមក្នុងបាតិមោក្ខនេះ ឈ្មោះថា សីលសំវរៈ ។

សំវរៈនេះថា រក្សានូវចក្ខុន្ទ្រិយ ដល់នូវសេចក្ដីសង្រួមក្នុងចក្ខុន្ទ្រិយ ឈ្មោះថា សតិសំវរៈ ។

សំវរៈនេះថា សតិជាគ្រឿងទប់ខ្សែតណ្ហាទាំងឡាយនោះ ដែលមាននៅក្នុងលោក តថាគតពោលថា សតិជាគ្រឿងរាំងខ្សែតណ្ហាទាំងឡាយ បុគ្គលគប្បីបិទខ្សែតណ្ហាទាំងនោះ ដោយបញ្ញា ឈ្មោះថា ញាណសំវរៈ ។

សំវរៈនេះថា អត់ធន់ចំពោះត្រជាក់ ក្តៅ ឈ្មោះថា ខន្តិសំវរៈ ។

សំវរៈនេះថា អត់ធន់នូវកាមវិតក្ក ដែលកើតឡើងហើយ ឈ្មោះថា វិរិយសំវរៈ ។

សំវរៈទាំងអស់នេះ លោកពោលថា **សំវរ** ព្រោះសង្រួមកាយទុច្ចរិតជាដើមដែលគួរសង្រួម និងដែលគួរកម្ចាត់ចេញតាមកិច្ចរបស់ខ្លួន ។ លោកពោលថា វិន័យ ព្រោះកម្ចាត់ចេញទៅ ។ សំវរវិន័យគប្បីជ្រាបថា បែកចេញជា ៥ ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត ការលះវត្ថុមិនជាប្រយោជន៍នោះៗ ដោយវិបស្សនាញាណនោះៗ បណ្តាវិបស្សនាញាណទាំងឡាយ មាននាមរូបបរិច្ឆេទញាណជាដើម ដោយភាពជាសត្រូវចំពោះគ្នា ដូចការលះងងឹតដោយពន្លឺប្រទីប ដូច្នោះ គឺការលះសក្កាយទិដ្ឋិដោយកំណត់នាមរូប លះការយល់ឃើញថា មិនមានហេតុនិងជាហេតុមិនស្មើដោយកំណត់បច្ច័យ លះសេចក្តីសង្ស័យដោយឆ្លងផុតសេចក្តីសង្ស័យ លះបង់ការប្រកាន់ថាជាអញ ជារបស់អញដោយពិចារណាជាកលាបៈ លះសេចក្តីសម្គាល់ក្នុងវត្ថុមិនមែនមគ្គ ថាជាមគ្គដោយកំណត់មគ្គនិងមិនមែនមគ្គ លះឧច្ឆេទទិដ្ឋិដោយឃើញការកើត លះសស្សតទិដ្ឋិ ដោយឃើញការវិនាស លះការសម្គាល់ក្នុងវត្ថុមានភ័យ ថាមិនមានភ័យ ដោយការ

ឃើញភ័យ លះការសម្គាល់ក្នុងវត្ថុដែលគួរពេញចិត្ត ដោយការឃើញទោស លះការសម្គាល់ក្នុងវត្ថុដែលគួរត្រេកអរ ដោយនិព្វិទាវិបស្សនាញាណ លះការមិនចង់រួចផុតដោយញាណ គឺសេចក្តីប្រាថ្នាក្នុងទីដែលនឹងរួចផុត លះការមិនព្រងើយដោយឧបេក្ខាញាណ លះការប្រកែកប្រណាំង ចំពោះវត្ថុដែលតាំងនៅក្នុងធម៌ និងការប្រកែកប្រណាំងក្នុងនិព្វានដោយអនុលោមញ្ញាណ លះការប្រកាន់ក្នុងសង្ខារនិមិត្តដោយគោត្រភូញាណ នេះឈ្មោះថា តទង្គប្បហាន ។

ការលះបង់ធម៌ មាននីវរណៈជាដើមទាំងនោះ ដោយហាមការប្រព្រឹត្តទៅដោយសមាធិ ដែលជាឧបចារសមាធិ និងអប្បនាសមាធិ ដូចការយកឆ្នាំងសង្កត់ចកលើផ្ទៃទឹក នេះឈ្មោះថា វិក្ខម្ភនប្បហាន ។

ការលះពួកកិលេសដែលជាចំណែកនៃសមុទ័យ ដែលលោកពោលដោយន័យជាដើមថា ដើម្បីលះបង់នូវទិដ្ឋិ ក្នុងសន្តានរបស់ខ្លួនដែលមានមគ្គនោះៗ ព្រោះចម្រើនអរិយមគ្គ ៤ ដោយការមិនឲ្យប្រព្រឹត្តទៅដោយចំណែក នេះឈ្មោះថា សមុច្ឆេទប្បហាន ។ ភាពដែលកិលេសទាំងឡាយស្ងប់រម្ងាប់ក្នុងខណៈនៃផល នេះឈ្មោះថា បដិបស្សទ្ធិប្បហាន ។

ការរម្ងត់ដែលជាការលះគ្រឿងតាក់តែងទាំងអស់ ព្រោះរលាស់ចេញនូវគ្រឿងតាក់តែងទាំងអស់បានហើយ នេះឈ្មោះថា និស្សរណប្បហាន ។

បហានទាំងអស់នេះ ឈ្មោះថា បហាន ព្រោះអត្ថថា លះបង់ ឈ្មោះថាវិន័យ ព្រោះអត្ថថា កម្ចាត់ ហេតុនោះ ទើបលោកហៅថា បហានវិន័យ ។ ម្យ៉ាងវិញទៀត បហាននេះ ហៅថា បហានវិន័យ ព្រោះមានវិន័យនោះៗ ដែល

លះវត្ថុនោះៗ ។ បហានវិន័យ គប្បីជ្រាបថា ចែកចេញជា ៥ យ៉ាង ដោយប្រការដូច្នេះ ។

វិន័យនេះ ដោយសង្ខេបមាន ២ យ៉ាង និងដោយប្រភេទមាន ១០ យ៉ាង មិនមានដល់បុថុជ្ជនអ្នកមិនបានស្ដាប់ ព្រោះខ្វះសំវរៈ និងព្រោះមិនលះវត្ថុដែលគួរលះ ហេតុនោះ ទើបបុថុជ្ជននេះ លោកពោលថា មិនបានហាត់ចិត្ត ព្រោះមិនមានវិន័យនោះ ។ សូម្បីក្នុងបទថា **សប្បុរិសានំ អទស្សាវី សប្បុរិសធម្មស្ស អកោវិទោ សប្បុរិសធម្មេ អវិនីតោ** ក៏មាននន័យនេះ ។ ដោយអត្ថបទនេះ មិនមានហេតុផ្សេងគ្នាឡើយ ។

សមដូចលោកពោលថា អ្នកណាជាអរិយៈ អ្នកនោះ ជាសប្បុរស ។ អ្នកណាជាសប្បុរស អ្នកនោះ ជាអរិយៈ ។ ធម៌ណាជាធម៌របស់ព្រះអរិយៈ ធម៌នោះក៏ជាធម៌របស់សប្បុរស ។ ធម៌ណាជាធម៌របស់សប្បុរស ធម៌នោះក៏ជាធម៌របស់ព្រះអរិយៈ ។ វិន័យណាជាវិន័យរបស់ព្រះអរិយៈ វិន័យនោះជាវិន័យរបស់សប្បុរស ។ វិន័យណាជាវិន័យរបស់សប្បុរស វិន័យនោះជាវិន័យរបស់ព្រះអរិយៈ ។ រួមសេចក្ដីថា អរិយៈក្ដី សប្បុរសក្ដី ធម៌របស់អរិយៈក្ដី ធម៌របស់សប្បុរសក្ដី វិន័យរបស់អរិយៈក្ដី វិន័យរបស់សប្បុរសក្ដី ទាំងនោះ គឺដូចគ្នា តាំងនៅក្នុងឋានៈតែមួយ ស្មើគ្នាដោយចំណែក សមគ្នាដូចគ្នា ។ ព្រោះហេតុអ្វី ទើបព្រះថេរៈសួរថា អត្តានុទិដ្ឋិដោយអាការ ២០ តើដូចម្ដេចខ្លះ ហើយមិនឆ្លើយពាក្យសួរនោះ ត្រឡប់ជាពោលអាងដល់បុថុជ្ជនយ៉ាងនេះថា បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនចេះដឹង ។ គប្បីជ្រាបថា ព្រះ

ថេរៈ ដើម្បីធ្វើសេចក្តីនោះឲ្យជាក់ច្បាស់ដោយទេសនា ដែលជាបុគ្គលាធិដ្ឋាន ទើបអាងដល់បុថុជ្ជនមុន ។

ព្រះថេរៈ លុះពោលអាងដល់បុថុជ្ជនយ៉ាងនេះហើយ ឥឡូវនេះ កាលនឹងសម្តែងដល់ឧទ្ទេសនៃការប្រកាន់ខុស ទើបពោលពាក្យថា **រូបំ អត្តតោ សមនុបស្សតិ** ជាដើម ។

ក្នុងបទទាំងនោះ បទថា **រូបំ អត្តតោ សមនុបស្សតិ** បានដល់ រមែងឃើញរូបក្ខន្ធ និងកសិណរូបដោយយល់ដោយទិដ្ឋិថាជាតួខ្លួន ។ តែក្នុងនិទ្ទេសគប្បីជ្រាបថា លោកមិនបានពោលដល់រូបនោះថា ការប្រកាន់ខុសក្នុងរូបក្ខន្ធរបស់បុថុជ្ជននោះប្រាកដ ព្រោះអធិការនៃបញ្ចក្ខន្ធ ហើយពោលដល់កសិណរូបនោះឯង ដោយជាសាមញ្ញថា រូប ។

បទថា **រូបវន្តំ វា អត្តានំ** បានដល់ ប្រកាន់វត្ថុមិនមានរូបថា តួខ្លួន ហើយពិចារណាឃើញខ្លួននោះថា មានរូប ។

បទថា **អត្តនិ វា រូបំ** បានដល់ ប្រកាន់វត្ថុមិនមានរូបនោះឯងថា ជាតួខ្លួន ហើយឃើញរូបក្នុងខ្លួននោះ ។

បទថា **រូបស្មឹ វា អត្តានំ** បានដល់ ប្រកាន់វត្ថុមិនមានរូបនោះឯងថា តួខ្លួន ហើយឃើញខ្លួននោះក្នុងរូប ។

ក្នុងបទទាំងនោះ បទថា **រូបំ អត្តតោ សមនុបស្សតិ** លោកពោលដល់រូបសុទ្ធៗ ថាជាតួខ្លួន ។ វត្ថុមិនមែនរូបក្នុងឋានៈទាំង ៧ នេះ គឺឃើញខ្លួនថាមានរូប ១ ឃើញរូបក្នុងខ្លួន ១ ឃើញខ្លួនក្នុងរូប ១ ឃើញវេទនា ១

សញ្ញា ១ សង្ខារ ១ វិញ្ញាណ ១ ដោយភាពជាខ្លួន លោកពោលថា ជាតួខ្លួន ។

លោកពោលដល់តួខ្លួនឈាយដោយរូប និងអរូបក្នុងឋានៈ ១២ យ៉ាងដោយអំណាចនៃវេទនា ៣ ក្នុងខន្ធ ៤ យ៉ាងនេះថា ឃើញខ្លួនថាមានវេទនា ឃើញវេទនាក្នុងខ្លួន ឃើញខ្លួនក្នុងវេទនា ។ ម្យ៉ាងទៀត ទិដ្ឋិទាំង ២០ នោះ ហាមមគ្គ មិនហាមសួគ៌ កម្ចាត់បានដោយសោតាបត្តិមគ្គ ។

[ ២០ ] ឥឡូវនេះ ព្រះថេរៈ កាលនឹងចង្អុលបង្ហាញដល់រូបនោះ ទើបពោលពាក្យថា **កថំ រូបំ** ជាដើម ។

ក្នុងបទទាំងនោះ បទថា **បថវីកសិណំ** បានដល់ បឋវីកសិណដែលជាបដិភាគនិមិត្តដែលឲ្យកើតឡើង ព្រោះអាស្រ័យបឋវីមណ្ឌលដោយការផ្សាយទូទៅ ។ បទថា **អហំ** លោកសំដៅដល់ខ្លួននោះឯង ។ បទថា **អត្តំ** បានដល់ **អត្តានំ** ។ បទថា **អទ្វយំ** បានដល់ មួយនោះឯង ។ បទថា **តេលប្បទីបស្ស** បានដល់ ប្រទីបមានប្រេង ។ បទថា **ឈាយតោ** បានដល់ ឆេះឡើង ។ បទថា **យា អច្ចិ សោ វណ្ណោ** ជាដើម លោកពោលព្រោះ ប្រាសចាកអណ្តាតភ្លើងហើយក៏មិនមានពន្លឺ ។

បទថា **យា ច ទិដ្ឋិ យញ្ច វត្ថុ** អធិប្បាយថា លោកធ្វើទាំងពីរយ៉ាងនោះរួមគ្នា ហើយពោលដល់អត្តានុទិដ្ឋិដែលមានរូបជាវត្ថុ ។

អាបោកសិណជាដើម ជាកសិណនិមិត្តដែលអាស្រ័យទឹកជាដើម កើតឡើង ។ ម្យ៉ាងទៀត បរិច្ឆិន្នាកាសកសិណ សូម្បីជាអារម្មណ៍នៃរូបជ្ឈាន

កាលលោកពោលថា អាកាសកសិណ ក៏ជាការពោលលាយឡំគ្នាហើយ ដោយកសិណុគ្ឃាដិមាកាស ដែលជាអារម្មណ៍នៃអរូបជ្ឈាន ព្រោះហេតុនោះ គប្បីជ្រាបថា លោកមិនកាន់យក ។ មិនគួរកាន់យកវិញ្ញាណកសិណ ដោយពិត ព្រោះកំពុងពោលដល់រូប ។

[ ២១ ] បទថា **ឯកេកតោ វេទនំ សញ្ញំ សង្ខារេ វិញ្ញាណំ អត្តតោ សមនុបស្សតិ** លោកមិនញែកខន្ធ ៤ ហើយពោលដោយអំណាចការកាន់យករួមគ្នា ។ ពិតហើយ ព្រោះមិនអាចញែកចិត្ត និងចេតសិកឲ្យផ្សេងគ្នាបាន ទើបធ្វើខន្ធទាំងអស់រួមគ្នា ហើយកាន់យកថាជាតួខ្លួន ។

ក្នុងបទថា **ឥមិនា រូបេន រូបវា** រមែងបានសរីររូបខ្លះ កសិណរូបខ្លះ ។ បទថា **ឆាយាសម្បន្នោ** បានដល់ សម្បូរដោយម្លប់ គឺមិនស្រឡះ ។ **ឯវ** សព្ទ ក្នុងបទថា **តមេវ** ត្រឹមតែជានិបាត អធិប្បាយថា **តមេតំ** ក៏មាន ។ បទថា **ឆាយាវ** បានដល់ ម្លប់ដែលមាន ។ លោកពោលថា ជារូបវត្ថុកៈ ព្រោះសូម្បីកាលមិនប្រកាន់ថា រូប ជាតួខ្លួន ទិដ្ឋិក៏គង់កើតឡើងដោយមិនលះបង់នូវរូប ។

[ ២២ ] បទថា **អត្តនិ រូបំ សមនុបស្សតិ** បានដល់ ឃើញរូបនោះក្នុងខ្លួនដែលជាគំនរនៃអរូបនោះ ព្រោះសរីររូប និងកសិណរូបអាស្រ័យចិត្ត ។ ដោយបទថា **អយំ គន្ធោ** នេះ លោកពោលដល់ក្លិនដែលហិតចូលទៅ ។ បទថា **ឥមស្មឹ បុប្ផេ** សេចក្តីថា ពោលយ៉ាងនេះ ព្រោះក្លិនក្រអូបអាស្រ័យផ្កាឈើ ។

[ ២៣ ] *បទថា* **រូបស្មឹ អត្តានំ សមនុបស្សតិ** *បានដល់ រូបទៅក្នុងទីណា ចិត្តរមែងទៅក្នុងទីនោះ ។ ព្រោះហេតុនោះ ទើបបុថុជ្ជនកាន់យកចិត្តដែលអាស្រ័យរូប ហើយឃើញខ្លួនដែលជាគំនរអរូបនោះក្នុងរូបនោះ ។ លោកពោលដល់ហិបដែលជាគ្រឿងទ្រគ្រោតគ្រាត ព្រោះរូបជារបស់គ្រោតគ្រាត ។*

[ ២៤ ] *បទថា* **ឥធេកច្ចោ ចក្ខុសម្ផស្សជំ វេទនំ** *ជាដើម សេចក្តីថា កាលមិនមានការកាន់យកទិដ្ឋិ ក្នុងវេទនាផ្សេងអំពីគ្នា កាលកាន់យកដោយប្រកាន់ជាមួយគ្នាថាវេទនា រមែងឈ្មោះថា កាន់យកផ្សេងគ្នានោះឯង ព្រោះទិដ្ឋិ ឈមចុះខាងក្នុងនៃវេទនាទាំងពួង ព្រោះហេតុនោះ គប្បីជ្រាបថា លោកប្រកបញែកផ្សេងគ្នា ។ ពិតហើយ បុថុជ្ជននោះ រមែងប្រកាន់វេទនានោះឯងថាជាតួខ្លួន ព្រោះវេទនាជារបស់គ្រោតគ្រាត ដោយអំណាចការសោយ ។*

[ ២៥ ] *បទថា* **សញ្ញំ សង្ខារេ វិញ្ញាណំ រូបំ អត្តតោ សមនុបស្សតិ** *សេចក្តីថា បុគ្គលពួកខ្លះ ធ្វើអរូបធម៌ទាំងឡាយ មានសញ្ញាជាដើម និងរូបរួមគ្នាតែមួយ ហើយរមែងឃើញថាជាខ្លួន ព្រោះបុថុជ្ជន រមែងប្រកាន់តាមដែលប្រាកដ ដូចមនុស្សឆ្កួត ដូច្នោះ ។*

[ ២៨ ] *ក□ទថា* **ចក្ខុសម្ផស្សជំ សញ្ញំ** *ជាដើម មានអធិប្បាយថា បុគ្គលខ្លះ រមែងប្រកាន់សញ្ញាថាជាតួខ្លួន ព្រោះសញ្ញាប្រាកដដោយអំណាចនៃការដឹងព្រម ។ បទដ៏សេសគប្បីជ្រាបដោយន័យដូចពោលហើយក្នុងវេទនា ។*

[ ៣២ ] *ក□ទថា* **ចក្ខុសម្ផស្សជំ ចេតនំ** *ជាដើម មានអធិប្បាយថា លោកសម្តែងដល់ចេតនាប៉ុណ្ណោះ ព្រោះចេតនាជាប្រធាន និងប្រាកដក្នុងធម៌*

ទាំងឡាយដែលទាក់ទងក្នុងសន្តារក្ខន្ធ ។ សូម្បីធម៌ក្រៅអំពីនេះ ក៏ឈ្មោះថា លោកសម្តែងហើយដោយចេតនានោះ ។ ចំណែកបុថុជ្ជនទោះ រមែងប្រកាន់ចេតនាថាជាតួខ្លួន ព្រោះប្រាកដដោយអំណាចភាពជាចេតសិក ។ បទដ៏សេស មានន័យដូចពោលហើយនោះឯង ។

[ ៣៦ ] បទថា **ចក្ខុវិញ្ញាណំ** ជាដើម មានអធិប្បាយថា បុគ្គលខ្លះរមែងប្រកាន់ចិត្តថា ជាតួខ្លួន ព្រោះចិត្តប្រាកដដោយអំណាចនៃការដឹងច្បាស់អារម្មណ៍ ។ បទដ៏សេសក្នុងទីនេះ ក៏មានន័យដូចពោលហើយនោះឯង ។ល។

**អដ្ឋកថាអត្តានុទិដ្ឋិនិទ្ទេស ចប់**

# អដ្ឋកថា

## មិច្ឆាទិដ្ឋិនិទ្ទេស

[ ៤០ ] មិច្ឆាទិដ្ឋិ មានសេចក្តីដូចបានពោលហើយក្នុងខាងដើម តែគប្បីជ្រាបន័យដទៃដូចតទៅ

បទថា **នត្ថិ ទិន្នំ** បានដល់ បដិសេធផលរបស់ទាន ព្រោះជាឧច្ឆេទទិដ្ឋិ ។ បទថា **យិដ្ឋំ** ក្នុងបទថា **នត្ថិ យិដ្ឋំ** នេះ ជាយញ្ញតូច ។ បទថា **ហុតំ** បានដល់ យញ្ញធំ ។ មិច្ឆាទិដ្ឋិ រមែងបដិសេធផលរបស់យញ្ញទាំងពីរ ។

បទថា **នត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោ** បានដល់ បដិសេធផលនៃបុញ្ញកម្ម មានសីលជាដើម បដិសេធផលនៃបាបកម្ម មានបាណាតិបាតជាដើម ព្រោះបដិសេធផលនៃទាន ។ បទថា **នត្ថិ អយំ លោកោ** បានដល់ មិនមានដោយកម្មដែលធ្វើទុកក្នុងកាលមុន ។ បទថា **នត្ថិ បរោ លោកោ** បានដល់ មិនមានដោយកម្មដែលធ្វើទុកក្នុងលោកនេះ ។ បទថា **នត្ថិ មាតា នត្ថិ បិតា** បានដល់ បដិសេធផលរបស់កម្មដែលធ្វើទុក ក្នុងមាតាបិតាទាំងនោះ ។ បទថា **នត្ថិ សត្តា ឱបបាតិកា** បានដល់ បដិសេធការកើតឡើងឯងដែលមានកម្មជាហេតុ ។ បទថា **នត្ថិ លោកេ សមណព្រាហ្មណា ។បេ។ បវេទេន្តិ** បានដល់ បដិសេធបដិបទាក្នុងការបានអភិញ្ញា ដើម្បីឃើញលោកនេះ និងលោកខាងមុខ ។

តែក្នុងបាលីក្នុងទីនេះ បទថា **នត្ថិ ទិន្នន្តិ វត្ថុ** បានដល់ ទានដែលមិច្ឆាទិដ្ឋិបុគ្គលពោលថា ទានដែលឲ្យហើយមិនមានផល អធិប្បាយថា ទីតាំង ទីអាស្រ័យនៃទិដ្ឋិនោះ ។

បទថា **វាទោ មិច្ឆា** បានដល់ វាទៈ គឺវាចាថា ទានដែលឲ្យហើយមិនមានផល យ៉ាងនេះខុស គឺវិបរិត ។ល។

**អដ្ឋកថាមិច្ឆាទិដ្ឋិនិទ្ទេស ចប់**

# អដ្ឋកថា

# សក្កាយទិដ្ឋិនិទ្ទេស

[ ៤១ ] *បទថា* **សក្កាយទិដ្ឋិ** *បានដល់ អត្តានុទិដ្ឋិនោះឯង គប្បីជ្រាបថា លោកពោលទុកដើម្បីសម្តែងពាក្យដោយបរិយាយ ដែលមកហើយក្នុងទីដទៃ ។l៙៚*

**អដ្ឋកថាសក្កាយទិដ្ឋិនិទ្ទេស ចប់**

# អដ្ឋកថា

# សស្សតទិដ្ឋិនិទ្ទេស

[ ៤២ ] បទថា **សក្កាយវត្ថុកាយ សស្សតទិដ្ឋិយា** ជាកម្មធារយ-សមាស ។ គប្បីភ្ជាប់បទថា **សមនុបស្សតិ** ខាងចុងនៃបទ ១៥ មានបទថា **រូបវន្តំ វា អត្តានំ** ជាដើម ។ ម្យ៉ាងទៀត បាឋៈយ៉ាងនេះក៏មានពិតហើយ រមែងភ្ជាប់មិនបានដោយប្រការដទៃ ។ លោកសម្ដែងតែម្យ៉ាងប៉ុណ្ណោះ យ៉ាងនេះថា **រូបវន្តំ វា អត្តានំ សមនុបស្សតិ** ហើយសង្ខេបបទ ១៤ ដ៏សេស ។៚

**អដ្ឋកថាសស្សតទិដ្ឋិនិទ្ទេស ចប់**

# អដ្ឋកថា

## ឧច្ឆេទទិដ្ឋិនិទ្ទេស

[ ៤៣ ] *បទថា* **សក្កាយវត្ថុកាយ ឧច្ឆេទទិដ្ឋិយា** *លោកសម្តែងតែម្យ៉ាងប៉ុណ្ណោះ យ៉ាងនេះថា តែងពិចារណាឃើញរូបថាជាខ្លួន ហើយសន្ទេបបទ ៤ ដ៏សេស ។ល។*

**អដ្ឋកថាឧច្ឆេទទិដ្ឋិនិទ្ទេស ចប់**

# អដ្ឋកថា
## អន្តគ្គាហិកទិដ្ឋិនិទ្ទេស

[ ៤៤ ] ក្នុងវារៈទីមួយនៃអន្តគ្គាហិកទិដ្ឋិ ជាការសួរដល់អាការ ក្នុងវារៈទីពីរ ជាការកាន់យកអាការ ក្នុងវារៈទីបី ជាការឆ្លើយអាការ ។ ក្នុងបទទាំងនោះ បទថា **លោកោ** គឺតួខ្លួន ។

[ ៤៥ ] បទថា **សោ អន្តោ** បានដល់ ក្នុងទីបំផុតនៃសភាពទៀង និងសភាពសូន្យដែលជាបដិបក្ខចំពោះគ្នា ទីបំផុតនៃសភាពទៀងរមែងមានក្នុងការប្រកាន់ថាទៀង ទីបំផុតនៃសភាពសូន្យរមែងមានក្នុងការប្រកាន់ថាមិនទៀង ។

[ ៤៧ ] បទថា **បរិត្តំ ឱកាសំ** បានដល់ កាន់យកទីតិចតួចត្រឹមតែប៉ុនចង្អេរ ឬផ្តិល ។ បទថា **នីលកតោ ផរតិ** បានដល់ ធ្វើអារម្មណ៍ថា ពណ៌ខៀវ ។ បទថា **អយំ លោកោ** លោកពោលសំដៅដល់ខ្លួន ។ បទថា **បរិវដុមោ** បានដល់ មានកំណត់ដោយជុំវិញ ។ បទថា **អន្តសញ្ញី** បានដល់ មានការសម្គាល់ថា មានទីបំផុត ។ គប្បីកាន់យកថា ឈ្មោះថា លោកមានទីបំផុត ព្រោះអត្ថថា មានទីបំផុត ។ បទថា **យំ ផរតិ** បានដល់ ទីដែលកសិណរូបផ្សាយទៅ ( ទីដែលកសិណរូបពាល់ត្រូវ ) ។ បទថា **តំ វត្ថុ ចេវ លោកោ ច** បានដល់ កសិណរូបនោះជាអារម្មណ៍ និងជាលោក ដោយអត្ថថា គប្បីសម្លឹងមើល ។ បទថា **យេន ផរតិ** បានដល់ ចិត្តដែលផ្សាយទៅ ។ បទថា **សោ អត្តា ចេវ លោកោ ច** លោកធ្វើឲ្យជាបុំលិង្គ ព្រោះសម្ល៊ឹងដល់អត្តា មានអធិប្បាយថា ចិត្តនោះ ជាអត្តា និងជាលោក ដោយ

អត្ថថា គប្បីសម្លឹងមើល ។

បទថា **អន្តវា** បានដល់ ទីបំផុត ។ បទថា **ឱភាសកតោ ផរតិ** បានដល់ ធ្វើពន្លឺផ្សាយទៅដោយអំណាចអាលោកកសិណ តេជោកសិណ ឬឱទាតកសិណ ។ ព្រោះទាញយកកសិណដែលមានពន្លឺ ៥ ប្រភេទ មាននីលកសិណជាដើម ទើបគួរកាន់យកថា មិនមានការប្រកាន់ខុសថាជាខ្លួនដោយអំណាចបឋវីកសិណ អាបោកសិណ និងវាយោកសិណ ។

[ ៤៨ ] បទថា **វិបុលំ ឱកាសំ** បានដល់ កាន់យកទីធំ ដោយមានប្រមាណប៉ុនបរិវេណលានស្រូវជាដើម ។ បទថា **អនន្តវា** បានដល់ ពង្រីក ( បដិភាគនិមិត្ត ) ទៅ មិនមានទីបំផុត ។ បទថា **អបរិយន្តោ** បានដល់ ផ្សាយទៅមិនមានទីបំផុត ។ បទថា **អនន្តសញ្ញី** បានដល់ មានសេចក្តីសម្គាល់ថា លោកមិនមានទីបំផុត ។

[ ៤៩ ] បទថា **តំ ជីវំ** បានដល់ ជីវៈនោះ ពាក្យនោះ លោកធ្វើឲ្យជាលិង្គវិបល្លាស ។ម្យ៉ាងទៀត បទថា **ជីវោ** បានដល់ តួខ្លួននោះឯង ។ សូម្បីខន្ធ ៥ មានរូបក្ខន្ធជាដើម ក៏ឈ្មោះថា សរីរៈ ព្រោះអត្ថថា ប្រព្រឹត្តទៅដោយជុំវិញ ។ បទថា **ជីវំ ន សរីរំ** បានដល់ ជីវៈ ពោល គឺខ្លួន មិនមែនសរីរៈ ពោល គឺរូប ។ ក្នុងវេទនាជាដើម ក៏មានន័យនេះ ។

[ ៥១ ] បទថា **តថាគតោ** បានដល់ សត្វដែលជាប់ជំពាក់ ។ អាចារ្យពួកមួយពោលថា ព្រះអរហន្ត ។ បទថា **បរម្មរណា** បានដល់ ក្រោយអំពីស្លាប់ទៅ អធិប្បាយថា ក្នុងលោកដទៃ ។ បទថា **រូបំ ឥធេវ មរណធម្មំ**

បានដល់ ការប្រកាន់បញ្ចក្ខន្ធ ដោយមាតិកានៃខន្ធ ដែលប្រាកដដល់ខ្លួន អធិប្បាយថា រូបនោះ ជាប្រក្រតីសូន្យទៅក្នុងលោកនេះឯង សូម្បីក្នុងខន្ធដ៏សេស ក៏មានន័យនេះដូចគ្នា ។

បទថា **កាយស្ស ភេទា** បានដល់ ខាងមុខអំពីកាយ ពោល គឺខន្ធ ៥ បែកធ្លាយ ។ លោកពោលសេចក្ដីនៃឧទ្ទេសនេះថា បរម្មរណា ខាងមុខអំពីសេចក្ដីស្លាប់ ដោយពាក្យនេះ ។

បទថា **ហោតិ** ក្នុងបទថា **ហោតិបិ** ជាដើម ជាពាក្យដើម ។ **អបិ** សព្ទក្នុងបទទាំង ៤ ជាសមុច្ចយត្ថៈ ( មានសេចក្ដីរួម ) ។ បទថា **តិដ្ឋតិ** បានដល់ ស្ថិតនៅ ព្រោះជារបស់ទៀង អធិប្បាយថា មិនចុតិ ។ម្យ៉ាងទៀត គប្បីជ្រាបថា លោកពោលបទថា **តិដ្ឋតិ** ដើម្បីភាពផ្សេងគ្នានៃអត្ថរបស់បទថា **ហោតិ** ។

បទថា **ឧប្បជ្ជតិ** បានដល់ ឧប្បត្តិឡើងដោយចូលទៅកាន់កំណើតដែលជាអណ្ឌជៈ ( កើតពីស៊ុត ) និងជលាពុជៈ ( កើតពីគភ៌ ) ។

បទថា **និព្វត្តតិ** បានដល់ កើតដោយចូលទៅកាន់កំណើតដែលជាសំសេទជៈ ( កើតពីញើសក្អែល ) និងឱបបាតិកៈ ( កើតឡើងឯង ) ។ គប្បីជ្រាបការប្រកបសេចក្ដីដូច្នេះឯង ។

[ ៥២ ] បទថា **ឧច្ឆិជ្ជតិ** បានដល់ ដោយមិនមានការទាក់ទងគ្នា ។ បទថា **វិនស្សតិ** បានដល់ ដោយការបែកធ្លាយទៅ ។ បទថា **ន ហោតិ បរម្មរណា** ជាការពង្រីកសេចក្ដីនៃបទមុន អធិប្បាយថា ខាងមុខអំពីចុតិហើយ រមែង

មិនមានទៀត ។

[ ៥៣ ] បទថា **ហោតិ ច ន ច ហោតិ** ជាទិដ្ឋិរបស់ពួកជនអ្នកប្រកាន់ថាទៀងដោយចំណែកខ្លះ អធិប្បាយថា សត្វរមែងកើតដោយបរិយាយមួយក៏មាន មិនកើតដោយបរិយាយមួយក៏មាន មានពាក្យអធិប្បាយថា រមែងកើតព្រោះភាពជាជីវៈ មិនកើតព្រោះមិនមានជីវៈមកអំពីមុន ។

បទថា **នេវ ហោតិ ន ន ហោតិ** ជាទិដ្ឋិរបស់ពួកអមរាវិក្ខេបិកា អធិប្បាយថា មានក៏មិនមែន មិនមានក៏មិនមែន រមែងធ្វើត្រឹមតែបដិសេធន័យ ដែលលោកពោលមុនហើយ ព្រោះខ្លាចត្រូវតិះដៀល និងព្រោះខ្លាចនិយាយកុហក ព្រោះមានបញ្ញាទន់ខ្សោយ និងព្រោះភាពវង្វេង ។

បទថា **ឥមេហិ បញ្ញាសាយ អាការេហិ** បានដល់ ដោយអាការ ៥០ ដោយអំណាចនៃពួក ៥ ពួកមួយៗ មាន ១០ តាមដែលពោលហើយ ។

**អដ្ឋកថាអន្តគ្គាហិកទិដ្ឋិនិទ្ទេស ចប់**

# អដ្ឋកថា

## បុព្វន្តានុទិដ្ឋិនិទ្ទេស

[ ៥៥ ] មេលទ្ធិ ឈ្មោះថា សស្សតវាទ ព្រោះអត្ថថា ពោលដល់ការទៀងក្នុងបុព្វន្តានុទិដ្ឋិ ( ការតាមឃើញខន្ធក្នុងចំណែកអតីត ) និងអបរន្តានុទិដ្ឋិ ( ការតាមឃើញខន្ធចំណែកអនាគត ) ។ មួយ៉ាងទៀត ឈ្មោះថា វាទៈ ព្រោះអត្ថថា ជាហេតុឲ្យពោលពាក្យនេះជាឈ្មោះរបស់ទិដ្ឋិ សូម្បីវាទៈថាទៀងក៏ឈ្មោះថា សស្សត ព្រោះប្រកបដោយសស្សតទិដ្ឋិ ឈ្មោះថា សស្សតវាទ ព្រោះអត្ថថា មានវាទៈថាទៀង ។ មួយ៉ាងទៀត វាទៈថាទៀងចំណែកខ្លះ ឈ្មោះថា ឯកច្ចសស្សត ឈ្មោះថា **ឯកច្ចសស្សតិកា** ព្រោះអត្ថថា មានវាទៈថាទៀងចំណែកខ្លះ ។ មួយ៉ាងទៀត វាទៈប្រព្រឹត្តទៅថា លោកមានទីបំផុត មិនមានទីបំផុត មានទីបំផុតខ្លះ មិនមានទីផុតខ្លះ មានទីបំផុតក៏មិនមែន មិនមានទីបំផុតក៏មិនមែន ឈ្មោះថា **អន្តានន្ត** ឈ្មោះថា **អន្តានន្តិកា** ព្រោះអត្ថថា មានវាទៈថា **អន្តានន្ត** ។ ឈ្មោះថា **អមរា** ព្រោះមិនស្លាប់ ។ អ្វីមិនស្លាប់ ។ ទិដ្ឋិ និងវាចារបស់មេលទ្ធិ ដែលប្រាសចាកទីបំផុត ដោយន័យជាដើមថា សេចក្តីយល់ឃើញរបស់ខ្ញុំថាយ៉ាងនេះក៏មិនមែន ។ ការបោះពាក្យសម្តីមានបែបផ្សេងៗ ឈ្មោះថា **វិក្ខេប** បោះពាក្យសម្តីដោយទិដ្ឋិ ឬវាចាដែលពោលមិនឲ្យស្លាប់ខ្លួន ឈ្មោះថា **អមរាវិក្ខេប** ឈ្មោះថា **អមរាវិក្ខេបិកា** ព្រោះអត្ថថា មានការបោះពាក្យសម្តីមិនឲ្យស្លាប់ខ្លួន ។

មួយ៉ាងទៀត ត្រី ឈ្មោះអមរា ( អន្ទង់ ) កាលហែលទៅក្នុងទឹក ផុស

*ឡើង មុជចុះជាដើម បុគ្គលណាមួយមិនអាចចាប់បាន វាទៈនេះ ក៏យ៉ាង នោះដូចគ្នា រមែងស្ទុះទៅខាងនោះ ខាងនេះ គឺចាប់ចំណុចមិនបាន ព្រោះ ហេតុនោះ ទើបហៅថា បោះពាក្យសម្ដីមិនឲ្យស្លាប់ខ្លួន ឈ្មោះថា* **អមរា-វិក្ខេបិកា** *ព្រោះអត្ថថា បោះវាទៈមិនឲ្យស្លាប់ខ្លួន ។*

*បទថា* **អធិច្ចសមុប្បន្នោ** *មានវិគ្គហៈថា ការឃើញថា ខ្លួន និងលោក កើតឡើងមិនមានហេតុ ឈ្មោះថា* **អធិច្ចសមុប្បន្ន** *ឈ្មោះថា* **អធិច្ច-សមុប្បន្និកា** *ព្រោះអត្ថថា មានការយល់ថា កើតឡើងឯងៗ ។៙*

## អដ្ឋកថាបុព្វន្តានុទិដ្ឋិនិទ្ទេស ចប់

# អដ្ឋកថា
# អបរន្តានុទិដ្ឋិនិទ្ទេស

[ ៥៦ ] មេលទ្ធិ ឈ្មោះថា សញ្ញីវាទ ព្រោះអត្ថថា ពោលថា សត្វកាលស្លាប់ហើយមានសញ្ញា ។ ឈ្មោះថា អសញ្ញីវាទ ព្រោះអត្ថថា ពោលថា សត្វកាលស្លាប់ហើយមិនមានសញ្ញា ។ ឈ្មោះថា នេវសញ្ញីនាសញ្ញីវាទ ព្រោះអត្ថថា ពោលថា សត្វកាលស្លាប់ហើយមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ។

ម្យ៉ាងទៀត វាទៈដែលប្រព្រឹត្តទៅថា មានសញ្ញា ឈ្មោះថា សញ្ញីវាទ មេលទ្ធិទាំងនោះ ឈ្មោះថា សញ្ញីវាទ ព្រោះអត្ថថា មានវាទៈថា មានសញ្ញា ។ អសញ្ញីវាទ និងនេវសញ្ញីនាសញ្ញីវាទ ក៏យ៉ាងនោះ ។

មេលទ្ធិ ឈ្មោះថា ឧច្ឆេទវាទ ព្រោះអត្ថថា សត្វស្លាប់ហើយសូន្យ ។ បទថា **ទិដ្ឋធម្មោ** បានដល់ ធម៌ដែលឃើញប្រចក្ស ( ធម៌ជាបច្ចុប្បន្ន ) ។ បទនេះ ជាឈ្មោះនៃអត្តភាពដែលបានក្នុងបច្ចុប្បន្ននោះៗ ។ និព្វានក្នុងបច្ចុប្បន្ន ឈ្មោះថា ទិដ្ឋធម្មនិព្វាន សេចក្តីថា ការចូលទៅស្ងប់ទុក្ខ ក្នុងអត្តភាពនេះ

ឯង ៗ ឈ្មោះថា ទិដ្ឋធម្មនិព្វានវាទ ព្រោះអត្ថថា ពោលដល់និព្វានជាបច្ចុប្បន្ន-ធម៌នោះ ៗ

ម្យ៉ាងទៀត ដើម្បីសម្តែងអត្ថនេះឲ្យពិស្តារក្នុងនិទ្ទេសនេះ គួរនាំព្រហ្ម-ជាលសូត្រទាំងមូល មួយអន្លើដោយអដ្ឋកថាមកពោល តែកាលបើយ៉ាងនេះ រមែងយឺតយូរពន់ពេក ព្រោះហេតុនោះ ទើបមិនឲ្យពិស្តារ ៗ បុគ្គលមានសេចក្តីត្រូវការសូត្រនោះ គួរស្រាវជ្រាវរកមើលខ្លួនឯង ៗ៚

**អដ្ឋកថាអបរន្តានុទិដ្ឋិនិទ្ទេស ចប់**

# អដ្ឋកថា
## សញ្ញោជនិកាទិទិដ្ឋិនិទ្ទេស

[ ៥៧ ] ព្រោះសំយោជនិកាទិដ្ឋិ ( ទិដ្ឋិជាគ្រឿងប្រកបសត្វទុកក្នុងភព ) ជាទិដ្ឋិទូទៅដល់ទិដ្ឋិទាំងអស់ ព្រោះហេតុនោះ ទើបលោកសម្តែងសេចក្តីទូទៅដល់ទិដ្ឋិទាំងអស់ ព្រោះសំយោជនិកាទិដ្ឋិនោះ ជាគ្រឿងប្រកបទិដ្ឋិទាំងអស់ ។ គប្បីជ្រាបសេចក្តីនោះ ដោយការចោមរោមនៃទិដ្ឋិដូចបានពោលហើយក្នុងខាងដើម ( ត្រង់លេខឃ្នាប ១២ ) នោះឯង ។ល។

**អដ្ឋកថាសញ្ញោជនិកាទិទិដ្ឋិនិទ្ទេស ចប់**

# អដ្ឋកថា
# មានវិនិពន្ធទិដ្ឋិនិទ្ទេស

[ ៥៨ ] ទិដ្ឋិដែលត្រូវចងដោយមានះទាំងឡាយ គប្បីជ្រាបវិនិច្ឆ័យដូចតទៅ បទថា **ចក្ខុ អហន្តិ អភិនិវេសបរាមាសោ** បានដល់ ការស្ទាបអង្អែលដោយការប្រកាន់ខុស ដែលមានមានះនាំមុខ ។ ព្រោះទិដ្ឋិមិនបានសម្បយុត្តដោយមានះ ដោយហេតុនោះ ទើបលោកពោលថា **មានវិនិពន្ធា** អធិប្បាយថា ត្រូវចងចំពោះដោយមានះ គឺមានមានះជាមូល ។

[ ៥៩ ] សូម្បីក្នុងបទនេះថា **ចក្ខុំ មមន្តិ អភិនិវេសបរាមាសោ** ក៏មានន័យនេះដូចគ្នា ។ម្យ៉ាងទៀត ក្នុងបទនេះ កាលគួរពោលថា **មម** គប្បីជ្រាបថា ចុះនិគ្គហិតអាគមជា **មមំ** ។ សម្រាប់ការចងដោយមានះថាជាអញ សូម្បីអាយតនៈខាងក្រៅ មានរូបជាដើម ក៏ចាត់ជាអាយតនៈខាងក្នុងបានដូចគ្នា ពិតហើយ បុថុជ្ជន រមែងមិនប្រកាន់អាយតនៈខាងក្រៅ វៀរកសិណរូបថាជាអញ តែសម្រាប់ការចងដោយមានះថារបស់អញ រមែងរួមអាយតនៈខាងក្រៅចូលផង ដ្បិតថា បុថុជ្ជនរមែងកាន់យកសូម្បីអាយតនៈខាងក្រៅថា របស់អញ ព្រោះថា ទុក្ខវេទនាមិនមានមានះជាវត្ថុ ព្រោះជាវត្ថុមិនគួរប្រាថ្នា ហេតុនោះ ទើបលោកមិនកាន់យកវេទនា ៦ និងផស្សៈ ៦ ដែលជាមូលបច្ច័យនៃវេទនាទាំងនោះ តែសញ្ញាជាដើម គប្បីជ្រាបថា លោកមិនកាន់យក ព្រោះកាត់ឲ្យអស់ហើយក្នុងទីនេះ ៗ។ល។

**អដ្ឋកថាមានវិនិពន្ធទិដ្ឋិនិទ្ទេស ចប់**

# អដ្ឋកថា

# អត្តវាទប្បដិសំយុត្តទិដ្ឋិនិទ្ទេស

[ ៦០ ] ទិដ្ឋិដែលសម្បយុត្តដោយអត្តវាទ បានដល់ អត្តានុទិដ្ឋិនោះឯង ។ លោកពោលដល់ទិដ្ឋិយ៉ាងនេះទៀត ព្រោះប្រកបដោយវាទៈជាតួខ្លួន ។ល។

**អដ្ឋកថាអត្តវាទប្បដិសំយុត្តទិដ្ឋិនិទ្ទេស ចប់**

# អដ្ឋកថា
## លោកវាទប្បដិសំយុត្តទិដ្ឋិនិទ្ទេស

[ ៦១ ] បទថា **អត្តា ច លោកោ ច** សេចក្តីថា ខ្លួននោះឯងផង លោក ដោយអត្ថថា គប្បីសម្លឹងមើលផង ។ បទថា **សស្សតោ** បានដល់ ទិដ្ឋិរបស់អ្នកមានវាទៈថាទៀង ។ បទថា **អសស្សតោ** បានដល់ ទិដ្ឋិរបស់អ្នកមានវាទៈថាសូន្យ ។ បទថា **សស្សតោ ច អសស្សតោ ច** បានដល់ ទិដ្ឋិរបស់អ្នកឃើញថាទៀងចំណែកខ្លះ ។ បទថា **នេវ សស្សតោ នាសស្សតោ** បានដល់ ទិដ្ឋិរបស់អ្នកបោះពាក្យបោះសម្តីមិនឲ្យស្លាប់ខ្លួន ។ បទថា **អន្តវា** បានដល់ ទិដ្ឋិរបស់អ្នកគិត និងរបស់និគ្រន្ថ ឬអាជីវកអ្នកបានបរិត្តកសិណ ។ ម្យ៉ាងទៀត ពួកឧច្ឆេទទិដ្ឋិរមែងពោលថា សត្វមានខន្ធចំណែកអតីតដោយកំណើត មានខន្ធចំណែកអនាគតដោយការស្លាប់ ។ ពួកឃើញថា ខ្លួន និងលោក កើតឡើងឯងៗ ពោលថា សត្វមានខន្ធចំណែកអតីតដោយកំណើត ។ បទថា **អនន្តវា** បានដល់ ទិដ្ឋិរបស់អ្នកបានអប្បមាណកសិណ ។ តែពួកអ្នកមានវាទៈថាទៀង រមែងពោលថា សត្វទាំងឡាយ មិនមានខន្ធចំណែក

អតីត និងចំណែកអនាគត ដោយហេតុនោះ ទើបខ្លួន និងលោក មិនមានទីបំផុត ។ ពួកអ្នកឃើញថាខ្លួន និងលោក កើតឡើងឯងៗ ពោលថា មិនមានទីបំផុតដោយខន្ធចំណែកអនាគត ។ បទថា **អន្តវា ច អនន្តវា ច** បានដល់ ទិដ្ឋិរបស់បុគ្គលអ្នកមានកសិណឡើងលើ និងចុះក្រោម មិនចម្រើនចម្រើនទៅខាងទទឹង ។ បទថា **នេវ អន្តវា ន អនន្តវា** បានដល់ទិដ្ឋិរបស់អ្នកមានការបោះពាក្យសម្ដីមិនឲ្យស្ដាប់ខ្លួន ។

**អដ្ឋកថាលោកវារបដិសំយុត្តទិដ្ឋិនិទ្ទេស ចប់**

# អដ្ឋកថា
# ភវវិភវទិដ្ឋិនិទ្ទេស

[ ៦២ ] ព្រះសារីបុត្តត្ថេរ មិនធ្វើនិទ្ទេសនៃភវទិដ្ឋិ និងវិភវទិដ្ឋិ ឲ្យផ្សេងគ្នា ព្រោះមិនមានការប្រកាន់ផ្សេងគ្នាពីទិដ្ឋិ តាមដែលពោលហើយ និងមិនធ្វើការសួរដើម្បីសម្តែងអាការមួយៗ គឺការក្រាញនៅ ការស្ទុះទៅដោយអំណាចនៃទិដ្ឋិ តាមដែលពោលហើយនោះឯង តែពោលថា ការប្រកាន់ស្អិតដោយការក្រាញនៅ ឈ្មោះថា ភវទិដ្ឋិ ការប្រកាន់ស្អិតដោយការស្ទុះទៅក្រៃលែង ឈ្មោះថា វិភវទិដ្ឋិ ។

គប្បីជ្រាបសេចក្តីក្នុងបទនោះ ដូចតទៅនេះថា ការប្រកាន់ខុសដោយការក្រាញនៅ ដូចព្រះមានព្រះភាគ ទ្រង់ត្រាស់ ( ក្នុងខុទ្ទកនិកាយ ឥតិវុត្តកៈ ) ថា កាលតថាគតសម្តែងធម៌ដើម្បីរម្ងាត់ភព ចិត្តរបស់ទេវតា និងមនុស្សទាំងឡាយនោះក៏មិនស្ទុះទៅ អធិប្បាយថា ការប្រកាន់ខុសដោយការនឿយណាយចាកព្រះនិព្វាន ដោយការសម្គាល់ថាទៀង ។ ការប្រកាន់ខុសដោយការស្ទុះទៅ ដូចព្រះមានព្រះភាគ ទ្រង់ត្រាស់ ( ក្នុងខុទ្ទកនិកាយ ឥតិវុត្តកៈ ) ថា ទេវតា និងមនុស្សទាំងឡាយពួក ១ កាលជិនឆ្អន់នឿយណាយ ស្អប់ខ្ពើមភព រមែងត្រេកអរចំពោះការប្រាសចាកភព អធិប្បាយថា ការប្រកាន់ខុសដោយការលះបង់បដិបទាដែលនាំទៅកាន់ការរម្ងាត់ទុក្ខ ដោយសម្គាល់ថាសូន្យ ។

ឥឡូវនេះ ព្រះសារីបុត្ត ដើម្បីសម្តែងការប្រកបភវទិដ្ឋិ និងវិភវទិដ្ឋិ ទុកក្នុងទិដ្ឋិទាំងពួង ទើបពោលពាក្យថា **អស្សាទទិដ្ឋិយា** ជាដើម ។ ក្នុងបទនោះ

ព្រោះអ្នកមានអស្សាទទិដ្ឋិ អាស្រ័យការទៀង ឬការសូន្យ រមែងប្រកាន់ថា ទោសក្នុងកាមទាំងឡាយមិនមាន ហេតុនោះ សូម្បីអស្សាទទិដ្ឋិ មានអាការ ៣៥ លោកក៏ពោលថា ជាភវទិដ្ឋិក៏មាន ជាវិភវទិដ្ឋិក៏មាន ។

ព្រោះក្នុងពាក្យនោះ មានអធិប្បាយថា ទិដ្ឋិសូម្បីនីមួយៗ ក៏ជាភវទិដ្ឋិដោយការប្រកាន់ថាទៀង ជាវិភវទិដ្ឋិដោយការប្រកាន់ថាសូន្យ ។ សម្រាប់អត្តានុទិដ្ឋិ លោកពោលថាជាវិភវទិដ្ឋិ ៥ ព្រោះប្រកាន់ថា ព្រោះខ្លួនមិនជាដទៃអំពីរូបជាដើមក្នុងឋានៈ ៥ គឺបុថុជ្ជនរមែងឃើញរូបដោយភាពជាខ្លួន រមែងឃើញវេទនា សញ្ញា សង្ខារ វិញ្ញាណដោយភាពជាខ្លួន កាលខន្ធទាំង ៥ នោះដាច់សូន្យ ខ្លួនក៏ដាច់សូន្យ ។ លោកពោលថា ជាភវទិដ្ឋិ ១៥ ព្រោះប្រកាន់ថា ព្រោះខ្លួនដទៃអំពីរូបជាដើមក្នុងឋានៈ ១៥ ដ៏សេស កាលខន្ធទាំង ៥ នោះដាច់សូន្យ ខ្លួនក៏ទៀង ។ សម្រាប់មិច្ឆាទិដ្ឋិ បុគ្គលដែលបានឈានដែលជាបរិត្តារម្មណ៍ និងអប្បមាណារម្មណ៍ ក្នុងទិដ្ឋិមានទីបំផុត និងមិនមានទីបំផុត ឃើញសត្វទាំងឡាយដែលឃ្លាតចាករូបធាតុ ហើយកើតក្នុងទីដទៃដោយទិព្វចក្ខុ មិនឃើញភវទិដ្ឋិ រមែងកាន់យកវិភវទិដ្ឋិ ព្រោះទិដ្ឋិ ប្រព្រឹត្តទៅដោយដាច់សូន្យថា គឺជាវិភវទិដ្ឋិទាំងអស់ ហេតុនោះ ក្នុងទិដ្ឋិទាំងនោះ លោកក៏ពោលថា ជាភវទិដ្ឋិក៏មាន ជាវិភវទិដ្ឋិក៏មាន ។

បទថា **ហោតិ ច ន ច ហោតិ** បទថា **ហោតិ ច** ជាភវទិដ្ឋិ បទថា **ន ច ហោតិ** ជាវិភវទិដ្ឋិ ។

បទថា **នេវ ហោតិ ន ន ហោតិ** បទថា **នេវ ហោតិ** ជាវិភវទិដ្ឋិ ។

បទថា **ឆ ឆ ហោតិ** ជាភវទិដ្ឋិ ។ ព្រោះហេតុនោះ ទើបក្នុងទិដ្ឋិទាំងនោះ លោកពោលថា **សិយា** ( ជា ) ។

សម្រាប់ការតាមឃើញខន្ធចំណែកអតីត ពួកជនដែលឃើញថាទៀងដោយចំណែកខ្លះ រមែងបញ្ញត្តថា ទៀង និងបញ្ញត្តថា មិនទៀង ព្រោះហេតុនោះ ទើបទិដ្ឋិនោះជាភវទិដ្ឋិផង វិភវទិដ្ឋិផង ។ ពួកអ្នកដែលឃើញថា មានទីបំផុត និងមិនមានទីបំផុត ៤ ពួក រមែងបញ្ញត្តខ្លួនថា មានទីបំផុត និងមិនមានទីបំផុត ព្រោះហេតុនោះ ទើបទិដ្ឋិនោះ ជាភវទិដ្ឋិផង វិភវទិដ្ឋិផង ដូចគ្នានឹងអត្តានុទិដ្ឋិ ។ ពួកអ្នកមានការឃើញដោយការបោះពាក្យសម្តីមិនឲ្យស្លាប់ខ្លួន ៤ ពួក អាស្រ័យភវទិដ្ឋិ ឬវិភវទិដ្ឋិ រមែងដល់នូវការរាយមាយតាមវាចា ចំណែកដ៏សេសជាភវទិដ្ឋិទាំងអស់ ព្រោះហេតុនោះ ទើបលោកពោលថា **សិយា** សំដៅដល់ពួកមិច្ឆាទិដ្ឋិនោះៗ ។ សម្រាប់បុគ្គលដែលតាមឃើញខន្ធ ចំណែកអនាគត បុគ្គលដែលពោលថាសូន្យ ៧ ពួក ជាវិភវទិដ្ឋិ ដ៏សេសជាភវទិដ្ឋិ ព្រោះហេតុនោះ ទើបលោកពោលថា **សិយា** ព្រោះសំដៅដល់ពួកអ្នកមានទិដ្ឋិនោះៗ ។ លោកពោលថា **សិយា** សម្រាប់សញ្ញោជនិកាទិដ្ឋិ ក៏ដោយអំណាចនៃទិដ្ឋិទាំងពួង ។ សម្រាប់ទិដ្ឋិដែលចងដោយមានះថាជាអញ ព្រោះប្រកាន់ចក្ខុជាដើមថាជាអញ តួខ្លួន ឈ្មោះថា វិនាសទៅ ព្រោះការវិនាសនៃទិដ្ឋិទាំងនោះ ព្រោះហេតុនោះ ទើបលោកពោលថា គឺជាវិភវទិដ្ឋិទាំងអស់ ។

សម្រាប់ទិដ្ឋិដែលចងដោយមានះថា របស់អញ ដូចគ្នានឹងអត្តានុទិដ្ឋិ ខ្លួនរមែងវិនាសទៅ ព្រោះការវិនាសនៃទិដ្ឋិទាំងនោះ ព្រោះខ្លួនដទៃអំពីចក្ខុជាដើម

ព្រោះហេតុនោះ ទើបលោកពោលថា គឺជាភវទិដ្ឋិទាំងអស់ ។

សម្រាប់ទិដ្ឋិដែលសម្បយុត្តដោយលោកវាទៈ ទាំងភវទិដ្ឋិ និងវិភវទិដ្ឋិ ប្រាកដហើយ ព្រោះលោកពោលដោយន័យជាដើមថា ខ្លួនក្តី លោកក្តី ទៀត ។ ដោយហេតុមានប្រមាណប៉ុណ្ណេះ ឈ្មោះថា លោកសម្តែងដល់ទិដ្ឋិ ១៦ មានអស្សាទទិដ្ឋិជាខាងដើម មានវិភវទិដ្ឋិជាទីបំផុត និងសម្តែងដល់ការប្រកាន់មិច្ឆាទិដ្ឋិ ៣០០ ។ អត្តានុទិដ្ឋិ សក្កាយទិដ្ឋិ និងទិដ្ឋិដែលសម្បយុត្តដោយអត្តវាទ លោកពោលដោយជាចំណែកដូចគ្នា ដោយអត្ថ ៣ យ៉ាង ដោយបរិយាយ ។ ចំណែកសញ្ញោជនិកាទិដ្ឋិ គឺទិដ្ឋិសូម្បីទាំងអស់ដោយប្រភេទនៃការកំណត់ ។

ឥឡូវនេះ បទថា **សព្វាវ តា ទិដ្ឋិយោ អស្សាទទិដ្ឋិយោ** ជាដើម ជាការប្រៀបធៀបទិដ្ឋិ តាមដែលប្រកបដោយបរិយាយដទៃ ។

ក្នុងបទទាំងនោះ បទថា **សព្វាវ តា ទិដ្ឋិយោ** បានដល់ ទិដ្ឋិដែលមិនមានសល់តាមដែលពោលហើយ ។ ទិដ្ឋិ ៧ គឺឈ្មោះថា អស្សាទទិដ្ឋិ ព្រោះត្រេកអរដោយទិដ្ឋិរាគៈ និងព្រោះអាស្រ័យការពេញចិត្តដោយតណ្ហា ឈ្មោះថា អត្តានុទិដ្ឋិ ព្រោះទៅតាមសេចក្តីស្នេហាក្នុងខ្លួន ឈ្មោះថា មិច្ឆាទិដ្ឋិ ព្រោះការឃើញវិបរិត ឈ្មោះថា សក្កាយទិដ្ឋិ ព្រោះមានខន្ធជាទីតាំងអាស្រ័យ ឈ្មោះថា អន្តគ្គាហិកទិដ្ឋិ ព្រោះកាន់យកទីបំផុតនីមួយៗ ឈ្មោះថា សញ្ញោជនិកាទិដ្ឋិ ព្រោះប្រកបដោយវត្ថុ មិនមានប្រយោជន៍ ឈ្មោះថា អត្តវាទបដិសំយុត្តទិដ្ឋិ ព្រោះប្រកបដោយអត្តវាទ សង្គ្រោះចូលក្នុងទិដ្ឋិទាំងអស់

ចំណែកទិដ្ឋិ ៩ ដ៏សេស មិនសង្គ្រោះចូលក្នុងទិដ្ឋិទាំងអស់ ។

ឥឡូវនេះ ព្រះសារីបុត្តត្ថេរ កាលសង្ខេបទិដ្ឋិទាំងអស់នោះ ដែលពោលហើយដោយពិស្តារចូលក្នុងទិដ្ឋិ ២ យ៉ាងប៉ុណ្ណោះ ហើយសម្តែងថា សត្វទាំងឡាយអាស្រ័យទិដ្ឋិ ២ យ៉ាង ទើបពោលគាថាថា **ភវញ្ច ទិដ្ឋឹ** ជាដើម ។ ពិតហើយ ទិដ្ឋិទាំងអស់នោះ ជាភវទិដ្ឋិ និងវិភវទិដ្ឋិ ។

ច សព្ទ ក្នុងបទនេះថា **ភវញ្ច ទិដ្ឋឹ វិភវញ្ច ទិដ្ឋឹ** រួមទិដ្ឋិប៉ុណ្ណោះ មិនរួមសត្វដែលអាស្រ័យ ។ ព្រោះសត្វមួយមិនបានអាស្រ័យភវទិដ្ឋិ និងវិភវទិដ្ឋិទាំង ២ យ៉ាង សមដូចលោកពោលថា ពួកសត្វដែលអាស្រ័យនូវភវទិដ្ឋិក្តី អាស្រ័យនូវវិភវទិដ្ឋិក្តី ដូច្នេះ ។

បទថា **តក្កិកា** មានវិគ្គហៈថា ឈ្មោះថា **តក្កិកា** ព្រោះពោលដោយការគិតដោយក ព្រោះមេលទ្ធិទាំងនោះ រមែងប្រព្រឹត្តទៅដោយការគិតដោយកតែម្យ៉ាង ព្រោះមិនមានបញ្ញាចាក់ធ្លុះសេចក្តីពិត ។ ម្យ៉ាងទៀត ជនពួកណាបានឈានក្តី បានអភិញ្ញាក្តី រមែងប្រកាន់ទិដ្ឋិ សូម្បីជនទាំងនោះ ក៏ជាអ្នកត្រិះរិះព្រោះគិតហើយកាន់យក ។ បទថា **និស្សិតា សេ** សេចក្តីថា អាស្រ័យហើយ ឬថា បទមួយប៉ុណ្ណោះថា **សេ** ត្រឹមតែជានិបាត ។ បទថា **តេសំ និរោធម្ហិ ន ហត្ថិ ញាណំ** ជាពាក្យពោលដល់ហេតុនៃបុគ្គលអាស្រ័យទិដ្ឋិ សេចក្តីថា ព្រោះញាណក្នុងការរម្ងត់សក្កាយទិដ្ឋិ គឺនិព្វានមិនមានដល់ជនទាំងនោះ ហេតុនោះ ទើបជនទាំងឡាយប្រកាន់ទិដ្ឋិ ២ យ៉ាងនេះ ។ **ហិ** អក្ខរៈក្នុងបទថា **ន ហិ អត្ថិ ញាណំ** នេះ ជានិបាត ចុះក្នុងការសម្តែងដល់ហេតុ ។

បទថា **យត្ថាយំ លោកោ វិបរីតសញ្ញី** គប្បីជ្រាបថា លោក ព្រមទាំងទេវលោកនេះ ជាអ្នកមានសញ្ញាវិបរិតក្នុងនិរោធដែលជាសុខណា ថាជាទុក្ខ ញាណក្នុងនិរោធនោះ រមែងមិនមាន ព្រោះជាអ្នកមានសញ្ញាវិបរិត ថាជាទុក្ខ ទើបព្រះមានព្រះភាគត្រាស់គាថាព័ន្ធ ( ក្នុងខុទ្ទកនិកាយ សុត្តនិបាត ) នេះថា

រូប សំឡេង ក្លិន រស ផស្សៈ ធម្មារម្មណ៍ទាំងអស់ ជាទីប្រាថ្នា ជាទីស្រឡាញ់ និងជាទីពេញចិត្ត លោកពោលថា មាននៅដរាបណា អារម្មណ៍ទាំងនុ៎ះ សត្វលោក ព្រមទាំងទេវលោក សន្មតថាជាសុខ ( ដរាបនោះ ) អារម្មណ៍ទាំងនោះ តែងរលត់ទៅក្នុងព្រះនិព្វានណា ព្រះនិព្វាននោះ ពួកសត្វលោកទាំងនោះ សន្មតថាជាទុក្ខវិញ ។ ការរលត់នូវសក្កាយ គឺខន្ធទាំង ៥ ព្រះអរិយៈទាំងឡាយ ឃើញថាជាសុខពិត ការឃើញ ( របស់ព្រះអរិយៈ ) អ្នកយល់នេះជាទំនាស់នឹងសត្វលោកទាំងពួង ។ ពួកជនពាលដទៃពោលនូវវត្ថុកាមណា ថាជាសុខ ព្រះអរិយៈទាំងឡាយ ពោលនូវវត្ថុកាមនោះថាជាទុក្ខ ពួកជនពាលដទៃពោលនូវព្រះនិព្វានណា ថាទុក្ខ ព្រះអរិយៈទាំងឡាយ ដឹងច្បាស់នូវព្រះនិព្វាននោះថាជាសុខ ចូរអ្នកឃើញនូវនិព្វានធម៌ដែលដឹងបានដោយក្រ ពួកអ្នកមិនដឹង វង្វេងហើយក្នុងធម៌នុ៎ះ ។ សេចក្ដីងងឹតធ្វើនូវភាពខ្វាក់តែងប្រាកដដល់ពួកជនពាលដែលអវិជ្ជាបិទបាំង មិនឃើញនូវព្រះនិព្វាន ឯព្រះនិព្វានដូចជា

ពន្លឺ រមែងបើកបង្ហាញដល់ពួកសប្បុរសអ្នកឃើញ ពួកជនអ្នកមិនឈ្លាសវៃនូវធម៌ គឺព្រះនិព្វាន រមែងមិនដឹងច្បាស់ ( នូវព្រះនិព្វានសូម្បីមាន ) ក្នុងទីជិតឡើយ ។ ព្រះនិព្វាននេះ ពួកជនពាលដែលមានភវរាគៈ គ្របសង្កត់ហើយ កំពុងអន្ទោលទៅតាមខ្សែក្នុងភព កើតហើយក្នុងកន្ទែងរបស់មារ មិនងាយនឹងត្រាស់ដឹងបានឡើយ ។ នរណាហ្ន៎ វៀរលែងតែព្រះអរិយៈចេញ គួរនឹងត្រាស់ដឹងនូវព្រះនិព្វានបាន ព្រះអរហន្តទាំងឡាយមិនមានអាសវធម៌ បរិនិព្វានហើយ ព្រោះបានត្រាស់ដឹងដោយប្រពៃ នូវព្រះនិព្វាន ដូច្នេះ ។

[ ៦៣ ] ឥឡូវនេះ ព្រះសារីបុត្តត្ថេរបំណងនឹងសម្ដែងទិដ្ឋិទាំងអស់ជា ២ យ៉ាង និងសម្ដែងសម្មាទិដ្ឋិដែលជាគ្រឿងដកទិដ្ឋិដោយព្រះសូត្រ ទើបនាំព្រះសូត្រមកថា **ទ្វីហិ ភិក្ខវេ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ សូម្បីព្រហ្មទាំងឡាយ លោកក៏ហៅថា **ទេវ** ។ បទថា **ឱលីយន្តិ** បានដល់ ក្តាប់ទុក្ខ ។ បទថា **អតិធាវន្តិ** បានដល់ ស្ទុះស្ទា ។ បទថា **ចក្ខុមន្តោ** បានដល់ មានបញ្ញា ។ ច សព្ទ មានអត្ថជា **អតិរេក** ( ក្រៃលែងឡើង ) ។

បទថា **ភវារាមា** មានវិគ្គហៈថា ឈ្មោះថា **ភវារាម** ព្រោះអត្ថថាមានភពជាទីត្រេកអរ ជាទីអភិរម្យ ។ បទថា **ភវរតា** បានដល់ ត្រេកអរក្រៃលែងក្នុងភព ។ បទថា **ភវសម្មុទិតា** បានដល់ ពេញចិត្តក្នុងភព ។

បទថា **ទេសិយមានេ** បានដល់ កាលធម៌ដែលព្រះតថាគត ឬព្រះសាវករបស់ព្រះតថាគតសម្តែង ។ បទថា **ន បក្ខន្ទតិ** បានដល់ មិនចូលដល់ព្រះធម្មទេសនា ឬការរម្ងាប់កព ។ បទថា **ន បសីទតិ** បានដល់ មិនដល់នូវការជ្រះថ្លាក្នុងធម៌នោះ ។ បទថា **ន សន្តិដ្ឋតិ** បានដល់ មិនតាំងនៅក្នុងធម៌នោះ ។ បទថា **នាធិមុច្ចតិ** បានដល់ មិនដល់នូវការចុះស៊ប់ ក្នុងធម៌នោះ ។ លោកពោលដល់សស្សតទិដ្ឋិ ដោយហេតុមានប្រមាណប៉ុណ្ណោះ ។

បទថា **អដ្ដីយមានា** បានដល់ ដល់នូវសេចក្តីជាទុក្ខ ។ បទថា **ហរាយមានា** បានដល់ ដល់នូវការខ្មាស ។ បទថា **ជិគុច្ឆមានា** បានដល់ ដល់នូវការខ្ពើម ។ បទថា **វិភវំ អភិនន្ទន្តិ** សេចក្តីថា រមែងត្រេកអរ អាស្រ័យការសូន្យ ឬប្រាថ្នាការសូន្យ ។ បទថា **កិរ** ជានិបាត ចុះក្នុងអត្ថអនុស្សវនៈ ( ការបានឮមក ) ។ បទថា **ភោ** ជាពាក្យហៅ ។ បទថា **សន្តំ** បានដល់ រម្ងាប់ហើយ ។ បទថា **បណីតំ** មានវិគ្គហៈថា ឈ្មោះថា **បណីត** ព្រោះអត្ថថា មិនមានទុក្ខ ឬព្រោះនាំទៅកាន់ភាពជាប្រធាន ។ បទថា **យាថាវំ** បានដល់ តាមសេចក្តីពិត ។ លោកសម្តែងឧច្ឆេទទិដ្ឋិ ដោយហេតុ មានប្រមាណប៉ុណ្ណោះ ។ បទថា **ឥធ** បានដល់ ក្នុងសាសនានេះ ។ បទថា **ភូតំ** បានដល់ ទុក្ខ ពោល គឺខន្ធ ៥ ដែលកើតពីហេតុ ។ បទថា **ភូតតោ បស្សតិ** បានដល់ ឃើញខន្ធ ៥ នេះថាជាទុក្ខ ។ បទថា **និព្វិទាយ** បានដល់ ដើម្បីការឃើញច្បាស់ ។ បទថា **វិរាគាយ** បានដល់ ដើម្បីអរិយមគ្គ ។ បទថា **និរោធាយ** បានដល់ ដើម្បីព្រះនិព្វាន ។

បទថា **បដិបន្នោ ហោតិ** បានដល់ ជាអ្នកបដិបត្តិបដិបទាដែលសមគួរដល់និព្វាននោះ ។ បទថា **ឯវំ បស្សន្តិ** បានដល់ ឃើញដោយលោកិយញ្ញាណក្នុងចំណែកខាងដើម ដោយលោកុត្តរញ្ញាណក្នុងកាលចាក់ធ្លុះ ដោយប្រការដូច្នេះ ។ លោកពោលសម្មាទិដ្ឋិដោយហេតុមានប្រមាណប៉ុណ្ណេះ ។

ឥឡូវនេះ ព្រះសារីបុត្តត្ថេរ សម្ដែងអានិសង្សនៃសម្មាទិដ្ឋិនោះ ដោយគាថា ២ គាថា ។

ក្នុងបទទាំងនោះ បទថា **យោ ភូតំ ភូតតោ ទិស្វា** សេចក្ដីថា ត្រាស់ដឹងទុក្ខដោយត្រាស់ដឹងដោយការកំណត់ដឹង ។ បទថា **ភូតស្ស ច អតិក្កមំ** សេចក្ដីថា ត្រាស់ដឹងការរម្ងត់ទុក្ខដោយត្រាស់ដឹង ដោយការធ្វើឲ្យជាក់ច្បាស់ ។ បទថា **យថាភូតេធិមុច្ចតិ** បានដល់ បង្អោនចិត្តទៅក្នុងការរម្ងត់ទុក្ខ តាមសេចក្ដីពិត ដោយអំណាចនៃការត្រាស់ដឹងដោយមគ្គភាវនា ថានេះស្ងប់ នេះប្រណីត ។ បទថា **ភវតណ្ហា បរិក្ខយា** សេចក្ដីថា ដោយការលះហេតុឲ្យកើតទុក្ខ ។

មួយ៉ាងទៀត កាលការត្រាស់ដឹងសច្ចៈផ្សេងៗ មិនមាន គប្បីជ្រាបថា លោកពោលពាក្យក្នុងខាងដើមថា **ទិស្វា** ដោយអំណាចវោហារដែលជាបដិបទាក្នុងចំណែកខាងដើម ព្រោះមិនមែនឃើញមុន ហើយខាងក្រោយ ទើបបង្អោនចិត្តទៅ ។ ការត្រាស់ដឹងអរិយសច្ច ៤ រមែងមានព្រមគ្នានោះឯង ។ មួយ៉ាងវិញទៀត បទទាំងឡាយដែលពោលក្នុងខាងដើម រមែងមានបានក្នុងកាលព្រមគ្នា ព្រោះហេតុនោះ ទើបមិនខុស ។

បទថា **សវេ** បានដល់ ព្រះអរហន្តនោះ ដោយចំណែកមួយ ។ បទថា **ភូតបរិញ្ញាតោ** បានដល់ ជាអ្នកកំណត់ដឹងទុក្ខ ។ បទថា **វីតតណ្ហោ** បានដល់ មានតណ្ហាទៅប្រាសហើយ ។ បទថា **ភវាភវេ** បានដល់ ក្នុងភពតូចនិងក្នុងភពធំ ។ បទថា **អភវោ** បានដល់ ភពធំ ព្រោះមាន **អ** អក្ខរៈប្រព្រឹត្តទៅក្នុងអត្ថថា ចម្រើន ។ គប្បីជ្រាបភពតូចភពធំនោះ ដោយការប្រៀបធៀបគ្នា ។

ម្យ៉ាងវិញទៀត បទថា **ភវេ** បានដល់ សស្សតទិដ្ឋិ ។ បទថា **វិភវេ** បានដល់ ឧច្ឆេទទិដ្ឋិ ។ ឈ្មោះថា **វីតតណ្ហោ** ព្រោះមិនមានទិដ្ឋិរាគៈសូម្បីក្នុងទិដ្ឋិ ២ យ៉ាងនោះ ។ បទថា **ភូតស្ស វិភវា** បានដល់ ព្រោះផ្តាច់ផ្តិលវដ្ដ-ទុក្ខ ។ បទថា **ឆាគច្ឆតិ បុនព្ភវំ** លោកពោលដល់បរិនិព្វាននៃព្រះអរហន្ត ។

[ ៦៤ ] បទថា **តយោ បុគ្គលា** ជាដើម លោកពោលដើម្បីតិះដៀលបុគ្គលដែលជាមិច្ឆាទិដ្ឋិ និងដើម្បីសរសើរបុគ្គលដែលជាសម្មាទិដ្ឋិ ។ ឈ្មោះថា **វិបន្នទិដ្ឋិ** ព្រោះអត្ថថា មានទិដ្ឋិដល់ គឺទៅកាន់ភាពគួរខ្ពើម ។ ឈ្មោះថា **សម្បន្នទិដ្ឋិ** ព្រោះអត្ថថា មានទិដ្ឋិដល់ គឺទៅកាន់សេចក្តីល្អ ។

បទថា **តិត្ថិយោ** មានវិគ្គហៈថា ទិដ្ឋិ លោកហៅថា តិត្ថៈ ( លទ្ធិ ) ឈ្មោះថា **តិត្ថិយ** ព្រោះអត្ថថា ញុំាងប្រយោជន៍ឲ្យសម្រេចក្នុងលទ្ធិ ព្រោះបដិបត្តិនូវទិដ្ឋិនោះ ឬមានលទ្ធិ ។ ចូលដល់បព្វជ្ជាខាងក្រៅសាសនានេះ ។ បទថា **តិត្ថិយសាវកោ** បានដល់ គ្រហស្ថដែលដល់នូវទិដ្ឋានុគតិរបស់តិរ្ថិយទាំងនោះ ។ បទថា **យោ ច មិច្ឆាទិដ្ឋិកោ** បានដល់ បុគ្គលមានមិច្ឆាទិដ្ឋិ

ដោយទិដ្ឋិឯណានីមួយ មិនចូលដល់ទិដ្ឋិទាំង ២ យ៉ាងនោះ ។

បទថា **តថាគតោ** បានដល់ ព្រះសម្មាសម្ពុទ្ធ ។ សូម្បីព្រះបច្ចេកពុទ្ធ□ ក៏សង្គ្រោះចូលក្នុងបទនេះដូចគ្នា ។ បទថា **តថាគតសាវកោ** បានដល់ អ្នកសម្រេចមគ្គ និងអ្នកសម្រេចផល ។ បទថា **យោ ច សម្មាទិដ្ឋិកោ** បានដល់ អ្នកមានសម្មាទិដ្ឋិដោយលោកិយសម្មាទិដ្ឋិដែលផុតចាកទិដ្ឋិ ២ យ៉ាងនោះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទាំងឡាយដូចតទៅ បទថា **កោធនោ** បានដល់ បុគ្គលដែលក្រោធរឿយៗ ។ បទថា **ឧបនាហី** បានដល់ មានប្រក្រតីបន្ថែមសេចក្តីក្រោធនោះហើយចងទុក ។ បទថា **បាបមក្ខី** បានដល់ មានការលុបគុណដែលជាសេចក្តីលាមក ។ បទថា **មាយាវី** បានដល់ មានការបិទបាំងសេចក្តីអាក្រក់ដែលធ្វើហើយ ។ បទថា **វសលោ** បានដល់ មានជាតិជាមនុស្សអាក្រក់ ។ បទថា **វិសុទ្ធោ** បានដល់ ជាអ្នកបរិសុទ្ធដោយញាណទស្សនវិសុទ្ធិ ។ បទថា **សុទ្ធតំ គតោ** បានដល់ ដល់នូវភាពបរិសុទ្ធ ពោល គឺមគ្គផល ។ បទថា **មេធាវី** បានដល់ អ្នកមានបញ្ញា ។

ដោយគាថានេះ លោកសរសើរចំពោះបុគ្គលដែលដល់ព្រមដោយសម្មាទិដ្ឋិដែលជាលោកុត្តរ ។

[ ៦៥ ] បទថា **វិបន្នទិដ្ឋិយោ សម្បន្នទិដ្ឋិយោ** ព្រះសារីបុត្តត្ថេរពោលលះវោហារថា បុគ្គលតិះដៀល និងសរសើរធម៌ប៉ុណ្ណោះ ។ បទថា **ឃតំ មមំ** បានដល់ ទិដ្ឋិដោយអំណាចនៃការសម្គាល់ដោយតណ្ហា ។ បទថា **ឃសោ-ហាមស្មិ** បានដល់ ទិដ្ឋិមានការសម្គាល់ដោយមានះជាមូល ។ បទថា **ឃសោ**

**មេ អត្តា** បានដល់ ការសម្គាល់ដោយទិដ្ឋិនោះឯង ។

[ ៦៦ ] លោកសួរការចែក ការរាប់ និងការសង្គ្រោះកាលនៃទិដ្ឋិវិបត្តិ ៣ ដោយបទថា **ឯតំ មមន្តិ កោ ធិដ្ឋិ** ហើយធ្វើការឆ្លើយ ។

ក្នុងបទទាំងនោះ បទថា **កោ ធិដ្ឋិ** សេចក្តីថា បណ្តាទិដ្ឋិដ៏ច្រើន ទិដ្ឋិអ្វី ។ បទថា **កតមន្តានុគ្គហិតា** សេចក្តីថា ក្នុងកាល ២ ពោល គឺកាលមានខន□ ជាចំណែកអតីត និងកាលមានខន្ធជាចំណែកអនាគត តាមប្រកាន់ គឺតាមចង ដោយកាលណា ។ ព្រោះកាលស្ទាបអង្អែលថា នុ៎ះរបស់អញ អាងដល់វត្ថុ ក្នុងអតីតថា នុ៎ះបានជារបស់អញហើយ បានជារបស់អញហើយយ៉ាងនេះ បានជារបស់អញហើយប្រមាណប៉ុណ្ណេះ ហើយស្ទាបអង្អែល ហេតុនោះ ទើបជាបុព្វន្តានុទិដ្ឋិ ( ការតាមឃើញខន្ធចំណែកអតីត ) ។ ហើយទិដ្ឋិទាំងនោះ ទើបជាទិដ្ឋិតាមប្រកាន់ខន្ធចំណែកអតីត ។

ព្រោះកាលបើស្ទាបអង្អែលថា នុ៎ះជាអញ រមែងស្ទាបអង្អែលអាស្រ័យផលក្នុងអនាគតថា នុ៎ះជាអញ គឺនឹងបរិសុទ្ធបានដោយសីល វត្ត តបៈ ព្រហ្មចរិយៈនេះ ហេតុនោះ ទើបជាអបរន្តានុទិដ្ឋិ ( ទិដ្ឋិដែលតាមឃើញខន្ធចំណែកអនាគត ) ហើយទិដ្ឋិទាំងនោះ ទើបជាទិដ្ឋិតាមប្រកាន់ខន្ធចំណែកអនាគត ។

ព្រោះកាលបើស្ទាបអង្អែលថា នុ៎ះជាខ្លួនរបស់អញ អាស្រ័យការបន្តដែលកើតឡើងក្នុងអតីត និងអនាគត រមែងស្ទាបអង្អែលថា នុ៎ះជាខ្លួនរបស់អញ ហើយរមែងស្ទាបអង្អែលដោយសក្កាយទិដ្ឋិ ហេតុនោះ ទើបជា

សក្កាយទិដ្ឋិ ។ ហើយទិដ្ឋិទាំងនោះ ជាទិដ្ឋិតាមឃើញខន្ធចំណែកអតីតផង ចំណែកអនាគតផង ។

ម្យ៉ាងទៀត ព្រោះទិដ្ឋិ ៦២ មានសក្កាយទិដ្ឋិជាប្រធាន ហើយទិដ្ឋិ ៦២ រមែងដល់ការដកដោយការដកសក្កាយទិដ្ឋិនោះឯង ហេតុនោះ ទើបលោកពោលថាទិដ្ឋិ ៦២ ដោយមានសក្កាយទិដ្ឋិជាប្រធាន សេចក្ដីថា ទិដ្ឋិ ៦២ រមែងមានដោយទ្វារនៃសក្កាយទិដ្ឋិដែលមានសក្កាយទិដ្ឋិជាប្រធាន ។ បាឋៈថា **សក្កាយទិដ្ឋិប្បមុខានិ** ដូច្នេះល្អជាង ។ ឈ្មោះថា **សក្កាយទិដ្ឋិប្បមុខានិ** ព្រោះអត្ថថា មានសក្កាយទិដ្ឋិជាប្រធាន គឺជាខាងដើម ។ សក្កាយទិដ្ឋិទាំងនោះ គឺទិដ្ឋិអ្វី គឺទិដ្ឋិ ៦២ ។

ក្នុងពាក្យសួរថា គឺទិដ្ឋិអ្វី លោកឆ្លើយថា គឺអត្តានុទិដ្ឋិដែលមានវត្ថុ ២០ និងសក្កាយទិដ្ឋិដែលមានវត្ថុ ២០ ។ ដោយពាក្យសួរថា ទិដ្ឋិប៉ុន្មាន លោកឆ្លើយថា ទិដ្ឋិ ៦២ មានសក្កាយទិដ្ឋិជាប្រធាន ។ ម្យ៉ាងទៀត សក្កាយទិដ្ឋិនោះឯង លោកពោលថា អត្តានុទិដ្ឋិ ដោយពាក្យសម្គាល់ថា នុ៎ះជាខ្លួនរបស់អញ ។ កាលពោលដល់អត្តានុទិដ្ឋិនោះ ក៏ឈ្មោះថា ពោលដល់ទិដ្ឋិដែលសម្បយុត្តដោយអត្តវាទនោះឯង ។

[ ៦៧ ] ដើម្បីសម្ដែងការចែកបុគ្គលដែលដល់ព្រមដោយទិដ្ឋិ ដោយសម្ពន្ធនឹងបុគ្គលដែលដល់ព្រមដោយទិដ្ឋិ ទើបលោកនាំព្រះសូត្រមកថា **យេ កេចិ ភិក្ខវេ** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **និដ្ឋំ គតា** សេចក្ដីថា ដល់នូវការសម្រេចចិត្ត គឺអស់សេចក្ដីសង្ស័យ ដោយអំណាចនៃមគ្គញាណ

ថា ព្រះមានព្រះភាគ ត្រាស់ដឹងដោយប្រពៃដោយព្រះអង្គឯង ។ បាឋៈថា **និដ្ឋាគតា** ជាបទសមាស ឯសេចក្ដីដូចគ្នា ។ បទថា **ទិដ្ឋិសម្បន្នា** បាន ដល់ ដល់នូវការស្អាតដោយទិដ្ឋិ ។ បទថា **ឥធ និដ្ឋា** បានដល់ និព្វានក្នុង កាមធាតុនេះ ។ បទថា **ឥធ វិហាយ និដ្ឋា** បានដល់ លះកាមភពនេះហើយ បរិនិព្វានក្នុងព្រហ្មលោក ជាន់សុទ្ធាវាស ។

បទថា **សត្តក្ខត្តុបរមស្ស** មានវិគ្គហៈថា ការចូលដល់ភព គឺការកាន់ យកអត្តភាពគប្បីមាន ៧ ដង គឺ ៧ ជាតិជាយ៉ាងក្រៃលែង បន្ទាប់អំពីនោះ រមែងមិនកាន់យកភពទី ៨ ព្រោះហេតុនោះ ទើបឈ្មោះថា **សត្តក្ខត្តុបរម** ។ បានដល់ ព្រះសត្តក្ខត្តុបរមសោតាបន្ននោះ ។ បទថា **កោលំកោលស្ស** មាន វិគ្គហៈថា ឈ្មោះថា **កោលំកោល** ព្រោះទៅកាន់ត្រកូល អំពីត្រកូល ។ សេចក្ដីថា ព្រោះមិនកើតក្នុងត្រកូលថោកទាប ចាប់ផ្ដើមតាំងអំពីធ្វើឲ្យជាក់ ច្បាស់សោតាបត្តិផល រមែងកើតក្នុងត្រកូលមានភោគសម្បត្តិច្រើនប៉ុណ្ណោះ ។ បានដល់ ព្រះកោលំកោលសោតាបន្ននោះ ។ បទថា **ឯកពីជិស្ស** លោកពោល ពូជ គឺខន្ធ ។ ព្រោះព្រះសោតាបន្នមានពូជ គឺខន្ធមួយប៉ុណ្ណោះ គឺកាន់យក អត្តភាពមួយទើបឈ្មោះថា **ឯកពីជី** ។ បានដល់ ព្រះឯកពីជីសោតាបន្ននោះ ។ ឈ្មោះរបស់បុគ្គលទាំងនេះ ជាឈ្មោះដែលព្រះមានព្រះភាគទ្រង់តាំងទុក ព្រោះ បុគ្គលដែលដល់នូវឋានៈប្រមាណប៉ុណ្ណោះ ឈ្មោះថា **សត្តក្ខត្តុបរម** ប្រមាណ ប៉ុណ្ណោះ ឈ្មោះថា **កោលំកោល** ប្រមាណប៉ុណ្ណោះ ឈ្មោះថា **ឯកពីជី** ព្រោះ ហេតុនោះ ទើបជាឈ្មោះដែលព្រះមានព្រះភាគ ទ្រង់ដាក់ឲ្យដល់បុគ្គលទាំងនេះ ។

ពិតហើយ ព្រះមានព្រះភាគទ្រង់ដឹងថា បុគ្គលនេះនឹងដល់ឋានៈប្រមាណប៉ុណ្ណោះ បុគ្គលនេះនឹងដល់ឋានៈប្រមាណប៉ុណ្ណោះ ហើយទើបទ្រង់តាំងឈ្មោះនោះៗ ដល់បុគ្គលទាំងនោះ ។

ពិតហើយ ព្រះសោតាបន្ន មានបញ្ញាទន់ កើត ៧ ដង ទើបឈ្មោះថា សត្តក្ខត្តុបរមៈ មានបញ្ញាបែបកណ្តាល កើតទៀតមិនលើសភពទី ៦ ទើបឈ្មោះថា កោលំកោលៈ មានបញ្ញាខ្លាំងក្លាកើតត្រឹមតែភពមួយ ទើបឈ្មោះថា ឯកពីជី ។ ការដែលព្រះសោតាបន្នទាំងនោះមានបញ្ញាទន់ កណ្តាល និងខ្លាំងក្លានោះ រមែងកំណត់ ព្រោះបុព្វហេតុ ។ ព្រះសោតាបន្នសូម្បីទាំង ៣ នេះ លោកពោលដោយអំណាចនៃកាមភព តែក្នុងរូបភព និងអរូបភព រមែងបដិសន្ធិសូម្បីច្រើន ។

បទថា **សកទាគាមិស្ស** មានវិគ្គហៈថា ឈ្មោះថា សកទាគាមី ព្រោះអត្ថថា មកកាន់កាមភពមួយដង ដោយអំណាចនៃបដិសន្ធិ ។ បានដល់ ព្រះសកទាគាមីនោះ ។ បទថា **ទិដ្ឋេវ ធម្មេ អរហា** បានដល់ ព្រះអរហន្តក្នុងអត្តភាពនេះឯង ។ បាឋៈថា **អរហំ** ដូច្នេះក៏មាន ។ បទថា **ឥធ និដ្ឋា** លោកពោលសំដៅដល់អ្នកត្រាច់ទៅកាន់កាមភពប៉ុណ្ណោះ ។ ចំណែកព្រះអរិយៈទាំងឡាយ ដែលកើតក្នុងរូបភព និងអរូបភព រមែងមិនកើតក្នុងកាមភព រមែងបរិនិព្វានក្នុងភពនោះឯង ។

បទថា **អន្តរាបរិនិព្វាយិស្ស** បានដល់ ឈ្មោះថា អន្តរាបរិនិព្វាយី ព្រោះនឹងបរិនិព្វានដោយការរម្ងត់កិលេស ក្នុងរវាងពាក់កណ្តាលអាយុនោះឯង ។

ម្យ៉ាងទៀត ព្រះអនាគាមីនោះ មាន ៣ ពួក គឺលោកអ្នកដែលបរិនិព្វានក្នុងវាងកើតហើយមិនទាន់បានយូរ ១ លោកអ្នកដែលបរិនិព្វាន ក្នុងវាងអាយុមិនទាន់ដល់ពាក់កណ្តាល ១ លោកអ្នកដែលបរិនិព្វាន ក្នុងវាងអាយុដល់ពាក់កណ្តាល ១ ។ បានដល់ ព្រះអន្តរាបរិនិព្វាយីអនាគាមីនោះ ។

បទថា **ឧបហច្ចបរិនិព្វាយិស្ស** បានដល់ ព្រះអនាគាមីអ្នកផុតអាយុពាក់កណ្តាល ឬជិតនឹងដល់កាលកិរិយាហើយបរិនិព្វានដោយការរម្ងាប់កិលេស ។

បទថា **អសង្ខារបរិនិព្វាយិស្ស** បានដល់ ព្រះអនាគាមីដែលនឹងបរិនិព្វានជាធម្មតា មិនចាំបាច់ធ្វើសេចក្តីព្យាយាមច្រើន ហើយរម្ងាប់កិលេសបាន មិនចាំបាច់ដាស់តឿន មិនចាំបាច់ប្រើសេចក្តីព្យាយាម ។

បទថា **សសង្ខារបរិនិព្វាយិស្ស** បានដល់ ព្រះអនាគាមីដែលនឹងបរិនិព្វានជាធម្មតា តែត្រូវធ្វើសេចក្តីព្យាយាមច្រើន ទើបរម្ងាប់កិលេសបាន ដោយមានការដាស់តឿន និងដោយសេចក្តីលំបាក ។

បទថា **ឧទ្ធំសោតស្ស អកនិដ្ឋគាមិនោ** មានវិគ្គហៈថា ឈ្មោះថា ឧទ្ធំ-សោតៈ ព្រោះអត្ថថា មានក្រសែតណ្ហា ឬក្រសែវដ្តៈក្នុងខាងលើ ព្រោះនាំទៅក្នុងខាងលើ ម្យ៉ាងទៀត ឈ្មោះថា ឧទ្ធំសោតៈ ព្រោះអត្ថថា មានក្រសែមគ្គក្នុងខាងលើ ព្រោះទៅហើយគប្បីបានខាងលើ ។ ឈ្មោះថា **អកនិដ្ឋគាមី** ព្រោះអត្ថថា ទៅកាន់អកនិដ្ឋភព ។ បានដល់ ព្រះអនាគាមីដែលជាឧទ្ធំសោ-តោអកនិដ្ឋគាមីនោះ ។ ព្រះអនាគាមីនេះ មាន ៤ ពួក ។

លោកអ្នកធ្វើព្រហ្មលោក ៤ តាំងអំពីអវិហាឲ្យបរិសុទ្ធ ហើយទៅកាន់

អកនិដ្ឋភព ទើបបរិនិព្វាន នេះឈ្មោះថា **ឧទ្ធំសោតោអកនិដ្ឋគាមី ។**

លោកអ្នកធ្វើព្រហ្មលោក ៣ ខាងក្រោមឲ្យបរិសុទ្ធិ ហើយតាំងនៅក្នុងសុទស្សីព្រហ្មលោក ទើបបរិនិព្វាន នេះឈ្មោះថា **ឧទ្ធំសោតោ ន អកនិដ្ឋគាមី ។**

លោកអ្នកទៅអំពីលោកនេះ ទៅកាន់អកនិដ្ឋភព ហើយបរិនិព្វាន នេះឈ្មោះថា **ន ឧទ្ធំសោតោអកនិដ្ឋាគាមី ។**

លោកអ្នកបរិនិព្វានក្នុងទីនោះៗ ក្នុងព្រហ្មលោក ៤ ខាងក្រោមនេះឈ្មោះថា **ន ឧទ្ធំសោតោ ន អកនិដ្ឋគាមី ។**

ព្រះអនាគាមីទាំង ៥ នេះ លោកពោលកាន់យកជាន់សុទ្ធាវាស ។ ចំណែកព្រះអនាគាមីទាំងឡាយនៅសង្ស័ម ព្រោះមិនទាន់លះរូបរាគៈ អរូបរាគៈបានរមែងកើតក្នុងរូបភព និងអរូបភពដ៏សេស តែព្រះអនាគាមីទាំងឡាយដែលកើតក្នុងសុទ្ធាវាសហើយ មិនកើតក្នុងទីដទៃ ។

[ ៦៨ ] បទថា **អវេច្ចប្បសន្នា** បានដល់ ដឹង គឺត្រាស់ដោយអរិយមគ្គ ហើយជាអ្នកជ្រះថ្លាដោយសេចក្ដីជ្រះថ្លាមិនញាប់ញ័រ ។ បទថា **សោតាបន្នា** បានដល់ លោកអ្នកដល់ក្រសែអរិយមគ្គ ។ សូម្បីបុគ្គលអ្នកតាំងនៅក្នុងអរិយផលទាំងពួង លោកក៏កាន់យកដោយបទនេះ ។៚

**អដ្ឋកថាភវិកវនិទ្ទេស ចប់**

**ទិដ្ឋិកថា ចប់**

# សុត្តន្តបិដក

## មហាវគ្គ អានាបានកថា

[ ៦៩ ] កាលភិក្ខុចម្រើនអានាបានស្សតិសមាធិ មានវត្ថុ ១៦ ញាណចំនួន ២២០ ក៏កើតឡើង គឺបរិបន្ថញ្ញាណ ៨ ឧបការញ្ញាណ ៨ ឧបក្កិលេសញ្ញាណ ១៨ វោទានញ្ញាណ ១៣ សតោការិញ្ញាណ ៣២ សមាធិញ្ញាណ ២៤ វិបស្សនាញាណ ៧២ និព្វិទាញាណ ៨ និព្វិទានុលោមញ្ញាណ ៨ និព្វិទាបដិប្បស្សទ្ធិញ្ញាណ ៨ វិមុត្តិសុខញ្ញាណ ២១ ។

[ ៧០ ] បរិបន្ថញ្ញាណ ៨ និងឧបការញ្ញាណ ៨ តើដូចម្តេច ។ កាមច្ឆន្ទៈ ជាសត្រូវដល់សមាធិ នេក្ខម្មៈជាឧបការៈដល់សមាធិ ព្យាបាទជាសត្រូវដល់សមាធិ អព្យាបាទជាឧបការៈដល់សមាធិ ថីនមិទ្ធៈជាសត្រូវដល់សមាធិ អាលោកសញ្ញាជាឧបការៈដល់សមាធិ ឧទ្ធច្ចៈជាសត្រូវដល់សមាធិ អវិក្ខេបៈជាឧបការៈដល់សមាធិ វិចិកិច្ឆាជាសត្រូវដល់សមាធិ ធម្មវវត្ថានជាឧបការៈដល់សមាធិ អវិជ្ជាជាសត្រូវដល់សមាធិ ញាណជាឧបការៈដល់សមាធិ អរតិជាសត្រូវដល់សមាធិ បាមុជ្ជជាឧបការៈដល់សមាធិ អកុសលធម៌ទាំងអស់សុទ្ធតែជាសត្រូវដល់សមាធិ កុសលធម៌ទាំងអស់សុទ្ធតែជាឧបការៈដល់សមាធិ ទាំងនេះ ឈ្មោះថា បរិបន្ថញ្ញាណ ៨ និងឧបការញ្ញាណ ៨ ចិត្តដែលស្ទុះខ្ពស់ឡើង ចិត្តដែលអណ្តែតត្រសែតផុតឡើង រមែងតាំងនៅស៊ប់ក្នុងឯកត្តៈ រមែងស្អាតចាកនីវរណៈដោយអាការទាំង ១៦ នេះ ។

[ ៧១ ] ឯកត្តៈទាំងនោះ តើដូចម្តេច ។ នេក្ខម្មៈ ឈ្មោះថា ឯកត្តៈ ព្យាបាទ

ឈ្មោះថា ឯកត្ត: អាលោកសញ្ញា ឈ្មោះថា ឯកត្ត: អវិក្ខេប: ឈ្មោះថា ឯកត្ត: ធម្មវវត្ថាន ឈ្មោះថា ឯកត្ត: ញាណ ឈ្មោះថា ឯកត្ត: បាមុជ្ជ ឈ្មោះថា ឯកត្ត: កុសលធម៌ទាំងអស់ ឈ្មោះថា ឯកត្ត: ។ នីវរណ:ទាំងនោះ តើដូចម្ដេច ។ កាមច្ឆន្ទ: ឈ្មោះថា នីវរណ: ព្យាបាទ ឈ្មោះថា នីវរណ: ថីនមិទ្ធ: ឈ្មោះថា នីវរណ: ឧទ្ធច្ចកុក្កុច្ច: ឈ្មោះថា នីវរណ: វិចិកិច្ឆា ឈ្មោះថា នីវរណ: អវិជ្ជា ឈ្មោះថា នីវរណ: អរតិ ឈ្មោះថា នីវរណ: អកុសលធម៌ទាំងអស់ ឈ្មោះថា នីវរណ: ។

[ ៧២ ] សំណួរត្រង់ពាក្យថា នីវរណ: ចុះនីវរណ:ដោយអត្ថដូចម្ដេច ។ នីវរណ: ដោយអត្ថថា ធម៌ជាគ្រឿងរារាំងដំណើរទៅ ( កាន់ព្រះនិព្វាន ) ។ ដំណើរទៅ ( កាន់ព្រះនិព្វាន ) ទាំងនោះ តើដូចម្ដេច ។ នេក្ខម្ម: ឈ្មោះថា ដំណើរទៅ ( កាន់ព្រះនិព្វាន ) របស់ពួកអរិយជន ទាំងពួកអរិយជនតែងដើរទៅ ( កាន់ព្រះនិព្វាន ) ដោយសារនេក្ខម្ម:នោះ កាមច្ឆន្ទ: ឈ្មោះថា ធម៌ជាគ្រឿងរារាំងដំណើរទៅ ( កាន់ព្រះនិព្វាន ) បុគ្គលមិនស្គាល់ច្បាស់នេក្ខម្ម: ដែលជាដំណើរទៅ ( កាន់ព្រះនិព្វាន ) របស់ពួកអរិយជន ព្រោះត្រូវកាមច្ឆន្ទ:នោះបិទបាំង ហេតុនោះ កាមច្ឆន្ទ: ឈ្មោះថា ធម៌ជាគ្រឿងរារាំង ដំណើរទៅ ( កាន់ព្រះនិព្វាន ) អព្យាបាទ ឈ្មោះថា ដំណើរទៅ ( កាន់ព្រះនិព្វាន ) របស់ពួកអរិយជន ទាំងពួកអរិយជនតែងដើរទៅ ( កាន់ព្រះនិព្វាន ) ដោយសារអព្យាបាទនោះ ។ ព្យាបាទ ឈ្មោះថា ធម៌ជាគ្រឿងរារាំងដំណើរទៅ ( កាន់ព្រះនិព្វាន ) បុគ្គលមិនស្គាល់ច្បាស់អព្យាបាទ ដែលជាដំណើរទៅ ( កាន់ព្រះ

និព្វាន ) របស់ពួកអរិយជន ព្រោះត្រូវព្យាបាទនោះបិទបាំង ហេតុនោះ ព្យាបាទ ឈ្មោះថា ធម៌ជាគ្រឿងរាំងដំណើរទៅ ( កាន់ព្រះនិព្វាន ) អលោកសញ្ញា ឈ្មោះថា ដំណើរទៅ ( កាន់ព្រះនិព្វាន ) របស់ពួកអរិយជន ទាំងពួកអរិយ-ជនតែងដើរទៅ ( កាន់ព្រះនិព្វាន ) ដោយសារអាលោកសញ្ញានោះ ថីន-មិទ្ធៈ ឈ្មោះថា ធម៌ជាគ្រឿងរាំងដំណើរទៅ ( កាន់ព្រះនិព្វាន ) បុគ្គលមិនស្គាល់ច្បាស់អាលោកសញ្ញាដែលជាដំណើរទៅ ( កាន់ព្រះនិព្វាន ) របស់ពួកអរិយជន ព្រោះត្រូវថីនមិទ្ធៈនោះបិទបាំង ហេតុនោះ ថីនមិទ្ធៈ ឈ្មោះថា ធម៌ជាគ្រឿងរាំងដំណើរទៅ ( កាន់ព្រះនិព្វាន ) អវិក្ខេបៈ ឈ្មោះថា ដំណើរទៅ ( កាន់ព្រះនិព្វាន ) របស់ពួកអរិយជន ទាំងពួកអរិយជនតែងដើរទៅ ( កាន់ព្រះនិព្វាន ) ដោយសារអវិក្ខេបៈនោះ ឧទ្ធច្ចៈ ឈ្មោះថា ធម៌ជាគ្រឿងរាំងដំណើរទៅ ( កាន់ព្រះនិព្វាន ) បុគ្គលមិនស្គាល់ច្បាស់អវិក្ខេបៈដែលជាដំណើរទៅ ( កាន់ព្រះនិព្វាន ) របស់ពួកអរិយជន ព្រោះត្រូវឧទ្ធច្ចៈនោះបិទបាំង ហេតុនោះ ឧទ្ធច្ចៈ ឈ្មោះថា ធម៌ជាគ្រឿងរាំងដំណើរទៅ ( កាន់ព្រះនិព្វាន ) ធម្មវវត្ថាន ឈ្មោះថា ដំណើរទៅ ( កាន់ព្រះនិព្វាន ) របស់ពួកអរិយជន ទាំងពួកអរិយជន តែងដើរទៅ ( កាន់ព្រះនិព្វាន ) ដោយសារធម្មវវត្ថាននោះ វិចិកិច្ឆា ឈ្មោះថា ធម៌ជាគ្រឿងរាំងដំណើរទៅ ( កាន់ព្រះនិព្វាន ) បុគ្គលមិនស្គាល់ច្បាស់ធម្មវវត្ថានដែលជាដំណើរទៅ ( កាន់ព្រះនិព្វាន ) របស់ពួកអរិយជន ព្រោះត្រូវវិចិកិច្ឆានោះបិទបាំង ហេតុនោះ វិចិកិច្ឆា ឈ្មោះថា ធម៌ជាគ្រឿងរាំងដំណើរទៅ ( កាន់ព្រះនិព្វាន ) ញាណ ឈ្មោះថា ដំណើរទៅ

( កាន់ព្រះនិព្វាន ) របស់ពួកអរិយជន ទាំងពួកអរិយជន តែងដើរទៅ ( កាន់ព្រះនិព្វាន ) ដោយសារញាណនោះ អវិជ្ជា ឈ្មោះថា ធម៌ជាគ្រឿងរាំង ដំណើរទៅ ( កាន់ព្រះនិព្វាន ) បុគ្គលមិនដឹងច្បាស់ញាណដែលជាដំណើរទៅ ( កាន់ព្រះនិព្វាន ) របស់ពួកអរិយជន ព្រោះត្រូវអវិជ្ជានោះបិទបាំង ហេតុនោះ អវិជ្ជា ឈ្មោះថា ជាគ្រឿងរាំងដំណើរទៅ ( កាន់ព្រះនិព្វាន ) បាមុជ្ជ ឈ្មោះថា ដំណើរទៅ ( កាន់ព្រះនិព្វាន ) របស់ពួកអរិយជន ទាំងពួកអរិយជន តែងដើរទៅ ( កាន់ព្រះនិព្វាន ) ដោយសារបាមុជ្ជនោះ អរតិ ឈ្មោះថា ធម៌ជាគ្រឿងរាំង ដំណើរទៅ ( កាន់ព្រះនិព្វាន ) បុគ្គលមិនដឹងច្បាស់បាមុជ្ជ ដែលជាដំណើរទៅ ( កាន់ព្រះនិព្វាន ) របស់ពួកអរិយជន ព្រោះត្រូវអរតិនោះបិទបាំង ហេតុនោះ អរតិ ឈ្មោះថា ជាគ្រឿងរាំងដំណើរទៅ ( កាន់ព្រះនិព្វាន ) កុសលធម៌ទាំងអស់ ជាដំណើរទៅ ( កាន់ព្រះនិព្វាន ) របស់ពួកអរិយជន ទាំងពួកអរិយជន តែងដើរទៅ ( កាន់ព្រះនិព្វាន ) ដោយសារធម៌ទាំងឡាយនោះ អកុសលធម៌ទាំងអស់ សុទ្ធតែជាគ្រឿងរាំងដំណើរទៅ ( កាន់ព្រះនិព្វាន ) បុគ្គលមិនស្គាល់ច្បាស់នូវកុសលធម៌ដែលជាដំណើរទៅ ( កាន់ព្រះនិព្វាន ) របស់ពួកអរិយជន ព្រោះត្រូវពួកអកុសលធម៌នោះបិទបាំង ហេតុនោះ ពួកអកុសលធម៌ទាំងអស់នោះ ឈ្មោះថា ជាគ្រឿងរាំងដំណើរទៅ ( កាន់ព្រះនិព្វាន ) កាលភិក្ខុមានចិត្តបរិសុទ្ធ ចាកនីវរណធម៌ទាំងនេះ ចម្រើនអានាបានស្សតិសមាធិ ដែលមានវត្ថុ ១៦ ខណិកសមោធាន ( ក៏កើតមាន ) ។

[ ៧៣ ] ឧបក្កិលេសញ្ញាណ ១៨ កើតឡើង តើដូចម្តេច ។ កាលបុគ្គលផ្ចង់ស្មារតី ទៅកាន់ខ្យល់ដកដង្ហើមចេញខាងដើម កណ្តាល និងខាងចុង ចិត្តដែលបោះទៅក្នុងខ្យល់ដង្ហើមខាងក្នុង ជាសត្រូវរបស់សមាធិ កាលបុគ្គលផ្ចង់ស្មារតី ទៅកាន់ខ្យល់ដកដង្ហើមចូលខាងដើម កណ្តាល និងខាងចុង ចិត្តដែលបោះទៅក្នុងខ្យល់ដង្ហើមខាងក្រៅ ជាសត្រូវរបស់សមាធិ សេចក្តីប្រាថ្នាចំពោះខ្យល់ដកដង្ហើមចេញ សេចក្តីត្រេកត្រអាល សេចក្តីប្រព្រឹត្តនៃចំណង់ ជាសត្រូវរបស់សមាធិ សេចក្តីប្រាថ្នាចំពោះខ្យល់ដកដង្ហើមចូល សេចក្តីត្រេក-ត្រអាល សេចក្តីប្រព្រឹត្តនៃចំណង់ ជាសត្រូវរបស់សមាធិ កាលជ្រប់ចិត្តក្នុងការបានចំពោះនូវខ្យល់ដកដង្ហើមចូល សម្រាប់បុគ្គលដែលលំបាកដោយខ្យល់ដង្ហើមចេញ ជាសត្រូវរបស់សមាធិ ការជ្រប់ចិត្តក្នុងការបានចំពោះនូវខ្យល់ដកដង្ហើមចេញ សម្រាប់បុគ្គលដែលទប់ខ្យល់ដកដង្ហើមចូល ជាសត្រូវរបស់សមាធិ ។

ប្រសិនបើចិត្តរបស់បុគ្គល កាលនៅញាប់ញ័រមិនទាន់ផុតស្រឡះ
ចាកឧបក្កិលេសទាំងឡាយណា ឧបក្កិលេសរបស់អានាបា-
នស្សតិសមាធិនោះ មាន ៦ គឺការផ្ចង់ស្មារតី ទៅកាន់ខ្យល់
ដកដង្ហើមចេញ ១ ការផ្ចង់ស្មារតីទៅកាន់ខ្យល់ដកដង្ហើមចូល ១
សតិ ១ ការបោះចិត្តទៅក្នុងខ្យល់ដង្ហើមខាងក្នុង ១ សេចក្តី
ប៉ុនប៉ង ១ សេចក្តីប្រាថ្នា ក្នុងការបោះចិត្តទៅក្នុងខ្យល់ដង្ហើម
ខាងក្រៅ ១ ពួកជននោះ កាលដែលមិនទាន់ដឹងច្បាស់នូវ

វិមោក្ខ តែងនៅជឿអ្នកដទៃ ។

[ ៧៤ ] កាលបុគ្គលកំពុងនឹកនិមិត្ត ចិត្តរមែងញាប់ញ័រក្នុងខ្យល់ដកដង្ហើមចេញជាសត្រូវរបស់សមាធិ កាលបុគ្គលកំពុងនឹកខ្យល់ដកដង្ហើមចេញ ចិត្តរមែងញាប់ញ័រក្នុងនិមិត្ត ជាសត្រូវរបស់សមាធិ កាលបុគ្គលកំពុងនឹកនិមិត្ត ចិត្តរមែងញាប់ញ័រក្នុងខ្យល់ដកដង្ហើមចូលជាសត្រូវរបស់សមាធិ កាលបុគ្គលកំពុងនឹកខ្យល់ដកដង្ហើមចូល ចិត្តរមែងញាប់ញញ័រក្នុងនិមិត្ត ជាសត្រូវរបស់សមាធិ កាលបុគ្គលកំពុងនឹកខ្យល់ដកដង្ហើមចេញ ចិត្តរមែងញាប់ញ័រ ក្នុងខ្យល់ដកដង្ហើមចូល ជាសត្រូវរបស់សមាធិ កាលបុគ្គលកំពុងនឹកខ្យល់ដកដង្ហើមចូល ចិត្តរមែងញាប់ញ័រ ក្នុងខ្យល់ដកដង្ហើមចេញជាសត្រូវរបស់សមាធិ ។

ប្រសិនបើចិត្តរបស់បុគ្គល កាលនៅញាប់ញ័រមិនទាន់ផុតស្រឡះ ចាកឧបក្កិលេសទាំងឡាយណា ឧបក្កិលេសទាំងឡាយនោះ របស់អានាបានស្សតិសមាធិ មាន ៦ យ៉ាង គឺកាលបុគ្គលកំពុងនឹកនិមិត្ត ចិត្តរមែងញាប់ញ័រក្នុងខ្យល់ដកដង្ហើមចេញ ១ កាលបុគ្គលកំពុងនឹកខ្យល់ដកដង្ហើមចេញ ចិត្តរមែងញាប់ញ័រ ក្នុងនិមិត្ត ១ កាលបុគ្គលកំពុងនឹកនិមិត្ត ចិត្តរមែងញាប់ញ័រ ក្នុងខ្យល់ដកដង្ហើមចូល ១ កាលបុគ្គលកំពុងនឹកខ្យល់ដកដង្ហើមចូល ចិត្តរមែងញាប់ញ័រ ក្នុងនិមិត្ត ១ កាលបុគ្គលកំពុងនឹកខ្យល់ដកដង្ហើមចេញ ចិត្តរមែងញាប់ញ័រ ក្នុងខ្យល់ដកដង្ហើម

ចូល ១ កាលបុគ្គលកំពុងនឹកខ្យល់ដកដង្ហើមចូល ចិត្តរមែងញាប់ញ័រក្នុងខ្យល់ដកដង្ហើមចេញ ១ ជនទាំងនោះ កាលមិនទាន់ដឹងច្បាស់នូវវិមោក្ខ តែងនៅជឿអ្នកដទៃ ។

[ ៧៥ ] ចិត្តស្ទុះទៅរកអារម្មណ៍ជាអតីត ដែលធ្លាក់ទៅក្នុងសេចក្តីរាយមាយជាសត្រូវរបស់សមាធិ ចិត្តប្រាថ្នារកអារម្មណ៍ជាអនាគតដែលញាប់ញ័រជាសត្រូវរបស់សមាធិ ចិត្តរួញរាដែលធ្លាក់ទៅក្នុងសេចក្តីខ្ជិលច្រអូស ជាសត្រូវរបស់សមាធិ ចិត្តផ្គងហួសពេកដែលធ្លាក់ទៅក្នុងឧទ្ធច្ចៈ ជាសត្រូវរបស់សមាធិ ចិត្តប្រាកដដែលធ្លាក់ទៅក្នុងរាគៈ ជាសត្រូវរបស់សមាធិ ចិត្តមិនប្រាកដ ដែលធ្លាក់ទៅក្នុងព្យាបាទ ជាសត្រូវរបស់សមាធិ ។

បុគ្គលមានសង្កប្បសៅហ្មងហើយ រមែងមិនស្គាល់ច្បាស់នូវអធិចិត្ត ដោយសារពួកឧបក្កិលេសណា ឧបក្កិលេសទាំងឡាយនោះ របស់អានាបានស្សតិសមាធិ មាន ៦ យ៉ាង គឺចិត្តស្ទុះទៅរកអារម្មណ៍ជាអតីត ១ ចិត្តប្រាថ្នារកអារម្មណ៍ជាអនាគត ១ ចិត្តរួញរា ១ ចិត្តផ្គងហួសពេក ១ ចិត្តប្រាកដ ១ ចិត្តមិនប្រាកដ ១ រមែងមិនតម្កល់នៅមាំឡើយ ។

[ ៧៦ ] កាលភិក្ខុផ្ចង់ស្មារតី ទៅកាន់ខ្យល់ដកដង្ហើមចេញខាងដើម កណ្តាល និងខាងចុង កាយ និងចិត្តរមែងជាសភាវៈរញ្ជួយផង រំភើបផង ញាប់ញ័រផង ដោយសារចិត្តដែលបោះទៅក្នុងខ្យល់ដង្ហើមខាងក្នុង កាលភិក្ខុផ្ចង់ស្មារតី ទៅកាន់ខ្យល់ដកដង្ហើមចូលខាងដើម កណ្តាល និងខាងចុង កាយ

និងចិត្ត រមែងជាសភាវៈរព្ធយផង រំភើបផង ញាប់ញ័រផង ដោយសារចិត្ត ដែលបោះទៅក្នុងខ្យល់ដង្ហើមខាងក្រៅ កាយ និងចិត្ត រមែងជាសភាវៈរព្ធយផង រំភើបផង ញាប់ញ័រផង ដោយសេចក្តីប្រាថ្នារកខ្យល់ដកដង្ហើមចេញ ដោយសេចក្តីត្រេកអរ ដោយសេចក្តីប្រព្រឹត្តនៃចំណង់ កាយ និងចិត្ត រមែងជាសភាវៈរព្ធយផង រំភើបផង ញាប់ញ័រផង ដោយសារសេចក្តីប្រាថ្នារកខ្យល់ដកដង្ហើមចូល ដោយសេចក្តីត្រេកអរ ដោយសេចក្តីប្រព្រឹត្តនៃចំណង់ កាយ និងចិត្តរមែងជាសភាវៈរព្ធយផង រំភើបផង ញាប់ញ័រផង ព្រោះជ្រប់ចិត្តក្នុងការបាទចំពោះនូវខ្យល់ដកដង្ហើមចូល សម្រាប់អ្នកទប់ខ្យល់ដកដង្ហើមចេញ កាលភិក្ខុនឹកនិមិត្ត កាយ និងចិត្តរមែងជាសភាវៈរព្ធយផង រំភើបផង ញាប់ញ័រផង ព្រោះចិត្តញាប់ញ័រ ក្នុងខ្យល់ដកដង្ហើមចេញ កាលភិក្ខុនឹកខ្យល់ដកដង្ហើមចេញ កាយ និងចិត្ត រមែងជាសភាវៈរព្ធយផង រំភើបផង ញាប់ញ័រផង ព្រោះចិត្តញាប់ញ័រក្នុងនិមិត្ត កាលភិក្ខុនឹកនិមិត្ត កាយ និងចិត្ត រមែងជាសភាវៈរព្ធយផង រំភើបផង ញាប់ញ័រផង ព្រោះចិត្តញាប់ញ័រក្នុងខ្យល់ដកដង្ហើមចូល កាលភិក្ខុនឹកខ្យល់ដកដង្ហើមចូល កាយ និងចិត្ត រមែងជាសភាវៈរព្ធយផង រំភើបផង ញាប់ញ័រផង ព្រោះចិត្តញាប់ញ័រក្នុងនិមិត្ត កាលភិក្ខុនឹកខ្យល់ដកដង្ហើមចេញ កាយ និងចិត្ត រមែងជាសភាវៈរព្ធយផង រំភើបផង ញាប់ញ័រផង ព្រោះចិត្តញាប់ញ័រក្នុងខ្យល់ដកដង្ហើមចូល កាលភិក្ខុនឹកខ្យល់ដកដង្ហើមចូល កាយ និងចិត្ត រមែងជាសភាវៈរព្ធយផង រំភើបផង ញាប់ញ័រផង ព្រោះចិត្តញាប់ញ័រក្នុងខ្យល់ដកដង្ហើមចេញ កាយ និងចិត្ត រមែង

ជាសភាវៈរញ្ជួយផង រំភើបផង ញាប់ញ័រផង ព្រោះចិត្តស្ទុះទៅរកអារម្មណ៍ ជាអតីត ដែលធ្លាក់ទៅក្នុងសេចក្ដីរាយមាយ កាយ និងចិត្ត រមែងជាសភាវៈរញ្ជួយផង រំភើបផង ញាប់ញ័រផង ព្រោះចិត្តប្រាថ្នារកអារម្មណ៍ ជាអនាគត ដែលញាប់ញ័រ កាយ និងចិត្ត រមែងជាសភាវៈរញ្ជួយផង រំភើបផង ញាប់ញ័រផង ព្រោះចិត្តរួញរាដែលធ្លាក់ទៅក្នុងសេចក្ដីខ្ជិលច្រអូស កាយ និងចិត្ត រមែងជាសភាវៈរញ្ជួយផង រំភើបផង ញាប់ញ័រផង ព្រោះចិត្តផ្គងហួសពេក ដែលធ្លាក់ទៅក្នុងឧទ្ធច្ចៈ កាយ និងចិត្ត រមែងជាសភាវៈរញ្ជួយផង រំភើបផង ញាប់ញ័រផង ព្រោះចិត្តដែលប្រាកដដែលធ្លាក់ទៅក្នុងរាគៈ កាយ និងចិត្តរមែងជាសភាវៈរញ្ជួយផង រំភើបផង ញាប់ញ័រផង ព្រោះចិត្តមិនប្រាកដដែលធ្លាក់ទៅក្នុងព្យាបាទ ។

បុគ្គលណា មិនបានបំពេញ មិនបានចម្រើនអានាបានស្សតិ បុគ្គលនោះ រមែងមានកាយរំភើបផង មានចិត្តរំភើបផង មានកាយញាប់ញ័រផង មានចិត្តញាប់ញ័រផង បុគ្គលណា បានបំពេញ បានចម្រើនល្អ នូវអានាបានស្សតិ បុគ្គលនោះ រមែងមានកាយ មិនរំភើបផង មានចិត្តមិនរំភើបផង មានកាយមិនញាប់ញ័រផង មានចិត្តមិនញាប់ញ័រផង ។

កាលភិក្ខុមានចិត្តស្អាតចាកនីវរណធម៌ទាំងនោះ ចម្រើនអានាបានស្សតិ-សមាធិ មានវត្ថុ ១៦ ខណិកសមោធាន ( ក៏កើតមាន ) នេះឯងឧបក្កិលេសទាំង ១៨ កើតឡើង ។

[ ៧៧ ] វោទានញ្ញាណ ១៣ តើដូចម្ដេច ។ ចិត្តស្ទុះទៅរកអារម្មណ៍ជាអតីត ដែលធ្លាក់ទៅក្នុងសេចក្ដីរាយមាយ បុគ្គលវៀរនូវចិត្តនោះហើយ តម្កល់ទុកក្នុងឋាន ១ ចិត្តមិនដល់សេចក្ដីរាយមាយយ៉ាងនេះខ្លះ ចិត្តប្រាថ្នារកអារម្មណ៍ជាអនាគតដែលញាប់ញ័រ បុគ្គលវៀរនូវចិត្តនោះហើយ រមែងរួចស្រឡះចាកចិត្តនោះឯង ចិត្តមិនដល់សេចក្ដីរាយមាយ យ៉ាងនេះខ្លះ ចិត្តរួញរាដែលធ្លាក់ទៅក្នុងសេចក្ដីខ្ជិលច្រអូស បុគ្គលផ្គងនូវចិត្តនោះហើយ លះបង់សេចក្ដីខ្ជិលច្រអូស ចិត្តមិនដល់សេចក្ដីរាយមាយយ៉ាងនេះខ្លះ ចិត្តផ្គងហួសពេក ដែលធ្លាក់ទៅក្នុងឧទ្ធច្ចៈ បុគ្គលសង្កត់សង្កិនចិត្តនោះហើយ លះបង់ឧទ្ធច្ចៈ ចិត្តរមែងមិនដល់សេចក្ដីរាយមាយ យ៉ាងនេះខ្លះ ចិត្តប្រាកដដែលធ្លាក់ទៅក្នុងរាគៈ បុគ្គលជាអ្នកស្គាល់ចិត្តនោះច្បាស់ លះបង់រាគៈ ចិត្តរមែងមិនដល់សេចក្ដីរាយមាយយ៉ាងនេះខ្លះ ចិត្តមិនប្រាកដដែលធ្លាក់ទៅក្នុងព្យាបាទ បុគ្គលជាអ្នកស្គាល់ចិត្តមិនច្បាស់ លះបង់ព្យាបាទ ចិត្តរមែងមិនដល់សេចក្ដីរាយមាយ យ៉ាងនេះខ្លះ ចិត្តរមែងស្អាតផូរផង់ដល់នូវឯកត្តៈ ដោយឋានទាំងឡាយ ៦ នេះឯង ។

[ ៧៨ ] ឯកត្តៈទាំងនោះ តើដូចម្ដេច ។ ទានវោស្សគ្គុបដ្ឋាន ឈ្មោះថាឯកត្តៈ សមថនិមិត្តុបដ្ឋាន ឈ្មោះថា ឯកត្តៈ វយលក្ខណុបដ្ឋាន ឈ្មោះថាឯកត្តៈ និរោធុបដ្ឋាន ឈ្មោះថា ឯកត្តៈ ទានវោស្សគ្គុបដ្ឋាន របស់បុគ្គលអ្នកចុះចិត្តស៊ប់ ក្នុងកាលលះបង់ ឈ្មោះថា ឯកត្តៈ សមថនិមិត្តុបដ្ឋានរបស់ពួកបុគ្គលអ្នកប្រកបរឿយៗ ក្នុងអធិចិត្ត ឈ្មោះថា ឯកត្តៈ វយលក្ខណុបដ្ឋានរបស់បុគ្គលអ្នកពិចារណា ឈ្មោះថា ឯកត្តៈ និងនិរោធុបដ្ឋានរបស់ពួកអរិយ-

បុគ្គល ឈ្មោះថា ឯកត្តៈ ចិត្តដែលដល់នូវឯកត្តៈដោយឋានទាំង ៤ នេះ ឈ្មោះថា ជាធម្មជាតជ្រះថ្លា ដោយបដិបទាវិសុទ្ធិផង ឈ្មោះថា ការចម្រើនរឿយៗ នៃការសម្លឹងពិនិត្យផង ឈ្មោះថា រីករាយដោយញាណផង ។

[ ៧៩ ] បឋមជ្ឈាន មានអ្វីជាខាងដើម មានអ្វីជាកណ្តាល មានអ្វីជាខាងចុង ។ បឋមជ្ឈាន មានបដិបទាវិសុទ្ធិជាខាងដើម មានការចម្រើនរឿយៗ នៃការសម្លឹងពិនិត្យជាកណ្តាល មានការរីករាយព្រមជាខាងចុង ។

[ ៨០ ] បឋមជ្ឈាន មានបដិបទាវិសុទ្ធិជាខាងដើម តើបដិបទាវិសុទ្ធិជាខាងដើម មានលក្ខណៈប៉ុន្មានយ៉ាង ។ បដិបទាវិសុទ្ធិជាខាងដើម មានលក្ខណៈ ៣ យ៉ាង គឺធម៌ណាជាសត្រូវនៃបឋមជ្ឈាននោះ ចិត្តរមែងបរិសុទ្ធចាកធម៌នោះ ចិត្តរមែងដើរឆ្ពោះទៅកាន់សមថនិមិត្តជាកណ្តាល ព្រោះសេចក្តីស្អាត ចិត្តរមែងស្ទុះទៅក្នុងសមថនិមិត្តនោះ ព្រោះការដើរឆ្ពោះ គឺត្រង់ដែលចិត្តបរិសុទ្ធចាកធម៌ជាសត្រូវ ១ ត្រង់ដែលចិត្តដើរឆ្ពោះទៅកាន់សមថនិមិត្តជាកណ្តាល ព្រោះសេចក្តីស្អាត ១ ត្រង់ដែលចិត្តស្ទុះទៅក្នុងសមថនិមិត្តនោះ ព្រោះការដើរឆ្ពោះ ១ ( ទាំង ៣ នេះ ) ឈ្មោះថា បដិបទាវិសុទ្ធិជាខាងដើមរបស់បឋមជ្ឈាន នេះឯងលក្ខណៈ ៣ យ៉ាងរបស់បដិបទាវិសុទ្ធិជាខាងដើម ហេតុនោះ លោកពោលថា បឋមជ្ឈានមានលម្អខាងដើមផង បរិបូណ៌ដោយលក្ខណៈផង ។

[ ៨១ ] បឋមជ្ឈាន មានការចម្រើនរឿយៗ នៃការសម្លឹងពិនិត្យជាកណ្តាល តើការសម្លឹងពិនិត្យជាកិច្ចកណ្តាល មានលក្ខណៈប៉ុន្មានយ៉ាង ។ ការសម្លឹងពិនិត្យទុកជាកិច្ចកណ្តាល មានលក្ខណៈ ៣ យ៉ាង គឺចិត្តដែលបរិសុទ្ធ រមែង

សម្ងឹងផ្ទៀងផ្ទាត់ ចិត្តដែលដើរឆ្ពោះទៅរកសមថៈ រមែងសម្ងឹងផ្ទៀងផ្ទាត់ ចិត្តដែលតាំងឡើងក្នុងឯកត្តៈរមែងសម្ងឹងផ្ទៀងផ្ទាត់ គឺត្រង់ដែលចិត្តបរិសុទ្ធសម្ងឹងផ្ទៀងផ្ទាត់ ១ ត្រង់ដែលចិត្តដើរឆ្ពោះទៅរកសមថៈសម្ងឹងផ្ទៀងផ្ទាត់ ១ ត្រង់ដែលចិត្តតាំងឡើងក្នុងឯកត្តៈសម្ងឹងផ្ទៀងផ្ទាត់ ១ ( ទាំង ៣ នេះ ) ឈ្មោះថា ការចម្រើនរឿយៗ នៃការសម្ងឹងពិនិត្យ ទុកជាកិច្ចកណ្តាលនៃបឋមជ្ឈាន នេះឯងលក្ខណៈ ៣ យ៉ាងរបស់ការចម្រើនរឿយៗ នៃការសម្ងឹងពិនិត្យ ជាកិច្ចកណ្តាល ហេតុនោះ លោកពោលថា បឋមជ្ឈាន មានលម្អក្នុងកណ្តាលផង បរិបូណ៌ដោយលក្ខណៈផង ។

[ ៨២ ] បឋមជ្ឈាន មានការរីករាយព្រមជាខាងចុង តើការរីករាយព្រមជាខាងចុង មានលក្ខណៈប៉ុន្មានយ៉ាង ។ ការរីករាយព្រមជាខាងចុង មានលក្ខណៈ ៤ យ៉ាង គឺការរីករាយព្រម ដោយអត្ថថា មិនប្រព្រឹត្តកន្លងនូវពួកធម៌ ដែលកើតក្នុងបឋមជ្ឈាននោះ ១ ការរីករាយព្រម ដោយអត្ថថា ឥន្ទ្រិយទាំងឡាយមានរសតែមួយ ១ ការរីករាយព្រម ដោយអត្ថថា នាំទៅនូវព្យាយាមគួរដល់ឥន្ទ្រិយនោះ ១ ការរីករាយព្រម ដោយអត្ថថា សេព ១ ( ទាំង ៤ នេះ ) ឈ្មោះថា ការរីករាយព្រម ជាខាងចុងរបស់បឋមជ្ឈាន នេះឯងការរីករាយព្រមជាខាង ចុងមានលក្ខណៈ ៤ យ៉ាង ហេតុនោះ លោកពោលថា បឋមជ្ឈាន មានលម្អខាងចុងផង បរិបូណ៌ដោយលក្ខណៈផង ចិត្តដែលប្រព្រឹត្តទៅក្នុងវត្ត ៣ ប្រការ មានលម្អ ៣ ប្រការ ដូចពោលមកហើយយ៉ាងនេះឯងរមែងជាចិត្តបរិបូណ៌ដោយលក្ខណៈ ១០ យ៉ាង គឺបរិបូណ៌ដោយវិតក្ក ១

បរិបូណ៌ដោយវិចារ ១ បរិបូណ៌ដោយបីតិ ១ បរិបូណ៌ដោយសុខ ១ បរិបូណ៌ដោយអធិដ្ឋានចិត្ត ១ បរិបូណ៌ដោយសទ្ធា ១ បរិបូណ៌ដោយវិរិយៈ ១ បរិបូណ៌ដោយសតិ ១ បរិបូណ៌ដោយសមាធិ ១ បរិបូណ៌ដោយបញ្ញា ១ ។

[ ៨៣ ] ទុតិយជ្ឈាន មានអ្វីជាខាងដើម មានអ្វីជាកណ្តាល មានអ្វីជាខាងចុង ។ ទុតិយជ្ឈាន មានបដិបទាវិសុទ្ធិជាខាងដើម មានការចម្រើនរឿយៗ នៃការសម្លឹងពិនិត្យជាកណ្តាល មានការរីករាយព្រមជាខាងចុង ។បេ។ ចិត្តដែលប្រព្រឹត្តទៅក្នុងវត្ថុ ៣ ប្រការ មានលម្អ ៣ ប្រការ ដូចពោលមកហើយយ៉ាងនេះឯង រមែងជាចិត្តបរិបូណ៌ដោយលក្ខណៈ ១០ យ៉ាង គឺបរិបូណ៌ដោយវិចារ ១ បរិបូណ៌ដោយបីតិ ១ បរិបូណ៌ដោយសុខ ១ បរិបូណ៌ដោយអធិដ្ឋានចិត្ត ១ បរិបូណ៌ដោយសទ្ធា ១ បរិបូណ៌ដោយវិរិយៈ ១ បរិបូណ៌ដោយសតិ ១ បរិបូណ៌ដោយសមាធិ ១ បរិបូណ៌ដោយបញ្ញា ១ ។

[ ៨៤ ] តតិយជ្ឈាន មានអ្វីជាខាងដើម មានអ្វីជាកណ្តាល មានអ្វីជាខាងចុង ។បេ។ ចិត្តដែលប្រព្រឹត្តក្នុងវត្ថុ ៣ ប្រការ មានលម្អ ៣ ប្រការ ដូចពោលមកហើយយ៉ាងនេះឯង រមែងជាចិត្តបរិបូណ៌ដោយលក្ខណៈ ១០ យ៉ាង គឺបរិបូណ៌ដោយបីតិ ១ បរិបូណ៌ដោយសុខ ១ បរិបូណ៌ដោយអធិដ្ឋានចិត្ត ១ បរិបូណ៌ដោយសទ្ធា ១ បរិបូណ៌ដោយវិរិយៈ ១ បរិបូណ៌ដោយសតិ ១ បរិបូណ៌ដោយសមាធិ ១ បរិបូណ៌ដោយបញ្ញា ១ ។

[ ៨៥ ] ចតុត្ថជ្ឈាន មានអ្វីជាខាងដើម មានអ្វីជាកណ្តាល មានអ្វីជាខាងចុង ។បេ។ ចិត្តដែលប្រព្រឹត្តទៅក្នុងវត្ថុ ៣ ប្រការ មានលម្អ ៣ ប្រការ

ដូចពោលមកហើយយ៉ាងនេះឯង រមែងជាចិត្តបរិបូណ៌ដោយលក្ខណៈ ១០ យ៉ាង គឺបរិបូណ៌ដោយឧបេក្ខា ១ បរិបូណ៌ដោយអធិដ្ឋានចិត្ត ១ បរិបូណ៌ដោយសទ្ធា ១ បរិបូណ៌ដោយវិរិយៈ ១ បរិបូណ៌ដោយសតិ ១ បរិបូណ៌ដោយសមាធិ ១ បរិបូណ៌ដោយបញ្ញា ១ ។

[ ៨៦ ] អាកាសានញ្ចាយតនសមាបត្តិ វិញ្ញាណញ្ចាយតនសមាបត្តិ អាកិញ្ចញ្ញាយតនសមាបត្តិ និងនេវសញ្ញានាសញ្ញាយតនសមាបត្តិ មានអ្វីជាខាងដើម មានអ្វីជាកណ្តាល មានអ្វីជាខាងចុង ។បេ។ ចិត្តដែលប្រព្រឹត្តទៅក្នុងវត្ត ៣ ប្រការ មានលម្អ ៣ ប្រការ ដូចពោលមកហើយយ៉ាងនេះឯង រមែងជាចិត្តបរិបូណ៌ដោយលក្ខណៈ ១០ យ៉ាង គឺបរិបូណ៌ដោយឧបេក្ខា ១ បរិបូណ៌ដោយអធិដ្ឋានចិត្ត ១ ។បេ។ បរិបូណ៌ដោយបញ្ញា ១ ។

[ ៨៧ ] អនិច្ចានុបស្សនា មានអ្វីជាខាងដើម មានអ្វីជាកណ្តាល មានអ្វីជាខាងចុង ។បេ។ ចិត្តដែលប្រព្រឹត្តទៅក្នុងវត្ត ៣ ប្រការ មានលម្អ ៣ ប្រការ ដូចពោលមកហើយយ៉ាងនេះឯង រមែងជាចិត្តបរិបូណ៌ដោយលក្ខណៈ ១០ យ៉ាង គឺបរិបូណ៌ដោយវិចារ ១ បរិបូណ៌ដោយបីតិ ១ បរិបូណ៌ដោយសុខ ១ បរិបូណ៌ដោយអធិដ្ឋានចិត្ត ១ បរិបូណ៌ដោយសទ្ធា ១ បរិបូណ៌ដោយវិរិយៈ ១ បរិបូណ៌ដោយសតិ ១ បរិបូណ៌ដោយសមាធិ ១ បរិបូណ៌ដោយបញ្ញា ១ ។ ទុក្ខានុបស្សនា អនត្តានុបស្សនា និព្វិទានុបស្សនា វិរាគានុបស្សនា និរោធានុបស្សនា បដិនិស្សគ្គានុបស្សនា ខយានុបស្សនា វយានុបស្សនា វិបរិណាមានុបស្សនា អនិមិត្តានុបស្សនា អប្បណិហិតានុ-

បស្សនា សុញ្ញតានុបស្សនា អធិប្បញ្ញាធម្មានុបស្សនា យថាភូតញ្ញាណទស្សនៈ អាទីនវានុបស្សនា បដិសង្ខានុបស្សនា វិវដ្តនានុបស្សនា សោតាបត្តិមគ្គ សកទាគាមិមគ្គ និងអនាគាមិមគ្គ ( មានអ្វីជាខាងដើម មានអ្វីជាកណ្តាល មានអ្វីជាខាងចុង ) ។បេ។

[ ៨៨ ] អរហត្តមគ្គ មានអ្វីជាខាងដើម មានអ្វីជាកណ្តាល មានអ្វីជាខាងចុង អរហត្តមគ្គ មានបដិបទាវិសុទ្ធិជាខាងដើម មានការចម្រើនរឿយៗ នៃការសម្លឹងពិនិត្យជាកណ្តាល មានការរីករាយព្រមជាខាងចុង ។ អរហត្តមគ្គ មានបដិបទាវិសុទ្ធិជាខាងដើម តើបដិបទាវិសុទ្ធិជាខាងដើម មានលក្ខណៈប៉ុន្មានយ៉ាង ។ បដិបទាវិសុទ្ធិជាខាងដើម មានលក្ខណៈ ៣ យ៉ាង គឺធម៌ណាជាសត្រូវរបស់អរហត្តមគ្គនោះ ចិត្តបរិសុទ្ធចាកធម៌នោះ ចិត្តរមែងដើរឆ្ពោះទៅកាន់សមថនិមិត្តជាកណ្តាល ព្រោះសេចក្តីស្អាត ចិត្តស្ទុះទៅក្នុងសមថនិមិត្តនោះ ព្រោះការដើរឆ្ពោះ គឺត្រង់ដែលចិត្តស្អាតចាកធម៌ជាសត្រូវ ១ ត្រង់ដែលចិត្តដើរឆ្ពោះទៅកាន់សមថនិមិត្តជាកណ្តាល ព្រោះសេចក្តីស្អាត ១ ត្រង់ដែលចិត្តស្ទុះទៅក្នុងសមថនិមិត្តនោះ ព្រោះការដើរឆ្ពោះ ១ ( ទាំង ៣ នេះ ) ឈ្មោះថា បដិបទាវិសុទ្ធិជាខាងដើម របស់អរហត្តមគ្គ នេះឯងលក្ខណៈ ៣ យ៉ាងរបស់បដិបទាវិសុទ្ធិជាខាងដើម ហេតុនោះ លោកពោលថា អរហត្តមគ្គ មានលម្អខាងដើមផង បរិបូណ៌ដោយលក្ខណៈផង ។

[ ៨៩ ] អរហត្តមគ្គ មានការចម្រើនរឿយៗ នៃការសម្លឹងពិនិត្យជាកណ្តាល តើការសម្លឹងពិនិត្យជាកិច្ចកណ្តាល មានលក្ខណៈប៉ុន្មាន ។ ការសម្លឹងពិនិត្យ

ជាកិច្ចកណ្តាល មានលក្ខណៈ ៣ យ៉ាង គឺចិត្តដែលស្អាត រមែងសម្ទឹងផ្ទៀងផ្ទាត់ ចិត្តដែលដើរឆ្ពោះទៅរកសមថៈ រមែងសម្ទឹងផ្ទៀងផ្ទាត់ ចិត្តដែលតាំងឡើងក្នុងឯកត្តៈ រមែងសម្ទឹងផ្ទៀងផ្ទាត់ គឺត្រង់ដែលចិត្តស្អាតសម្ទឹងផ្ទៀងផ្ទាត់ ១ ត្រង់ដែលចិត្តដើរឆ្ពោះទៅរកសមថៈសម្ទឹងផ្ទៀងផ្ទាត់ ១ ត្រង់ដែលចិត្តតាំងឡើងក្នុងឯកត្តៈសម្ទឹងផ្ទៀងផ្ទាត់ ១ ហេតុនោះ លោកពោលថា អរហត្តមគ្គមានលម្អត្រង់កណ្តាលផង បរិបូណ៌ដោយលក្ខណៈផង ។

[ ៩០ ] អរហត្តមគ្គ មានការរីករាយព្រមជាខាងចុង តើការរីករាយព្រមជាខាងចុង មានលក្ខណៈប៉ុន្មាន ។ ការរីករាយព្រមជាខាងចុង មានលក្ខណៈ ៤ យ៉ាង គឺការរីករាយព្រម ដោយអត្ថថា មិនប្រព្រឹត្តកន្លងនូវពួកធម៌ដែលកើតហើយ ក្នុងអរហត្តមគ្គនោះ ១ ការរីករាយព្រម ដោយអត្ថថា ឥន្ទ្រិយទាំងឡាយ មានរសតែមួយ ១ ការរីករាយព្រម ដោយអត្ថថា នាំទៅនូវព្យាយាមគួរដល់ឥន្ទ្រិយនោះ ១ ការរីករាយព្រម ដោយអត្ថថា សេព ១ ( ទាំង ៤ នេះ ) ឈ្មោះថា ការរីករាយព្រមជាខាងចុងរបស់អរហត្តមគ្គ នេះឯងការរីករាយព្រមជាខាងចុង មានលក្ខណៈ ៤ យ៉ាង ហេតុនោះ លោកពោលថា អរហត្តមគ្គ មានលម្អខាងចុងផង បរិបូណ៌ដោយលក្ខណៈផង ចិត្តដែលប្រព្រឹត្តទៅក្នុងវត្ត ៣ ប្រការ មានលម្អ ៣ ប្រការ ដូចពោលមកហើយយ៉ាងនេះឯង រមែងជាចិត្តបរិបូណ៌ដោយលក្ខណៈ ១០ យ៉ាង គឺបរិបូណ៌ដោយវិតក្ក ១ បរិបូណ៌ដោយវិចារ ១ បរិបូណ៌ដោយបីតិ ១ បរិបូណ៌ដោយសុខ ១ បរិបូណ៌ដោយអធិដ្ឋានចិត្ត ១ បរិបូណ៌ដោយសទ្ធា ១ បរិបូណ៌

ដោយវីរិយៈ ១ បរិបូណ៌ដោយសតិ ១ បរិបូណ៌ដោយសមាធិ ១ បរិបូណ៌ដោយបញ្ញា ១ ។បេ។

[ ៩១ ] កាលបុគ្គលមិនស្គាល់នូវអនារម្មណ៍ របស់ចិត្តតែមួយ ការចម្រើននូវធម៌ ៣ ប្រការ គឺនិមិត្ត ១ អស្សាសៈ ១ បស្សាសៈ ១ គេរមែងមិនបាន កាលបុគ្គលដឹងនូវអនារម្មណ៍នៃចិត្តតែមួយ ការចម្រើននូវធម៌ ៣ ប្រការ គឺនិមិត្ត ១ អស្សាសៈ ១ បស្សាសៈ ១ គេរមែងបាន ។

[ ៩២ ] ធម៌ទាំង ៣ យ៉ាងនេះ មិនមែនជាអារម្មណ៍នៃចិត្តមួយផង ធម៌ទាំង ៣ យ៉ាងនេះ មិនមែនជាមិនប្រាកដផង តើដូចម្តេច ចិត្តមិនដល់នូវសេចក្តីរាយមាយ ១ ព្យាយាមប្រាកដ ១ ភិក្ខុញុំាងព្យាយាមឲ្យសម្រេចបាននូវគុណវិសេស ១ ។ ប្រៀបដូចដើមឈើដែលគេដាំលើភូមិភាគរាបស្មើ បុរសអារដើមឈើនោះដោយរណារ ស្មារតីបុរសរមែងតាំងឡើងចំពោះដើមឈើដោយអំណាចនៃធ្មេញរណារដែលពាល់ត្រូវ បុរសមិនធ្វើទុកក្នុងចិត្តត្រង់ធ្មេញរណារដែលទាញមកទាញទៅ ធ្មេញរណារដែលទាញមកក្តី ទាញទៅក្តី មិនមែនជាមិនប្រាកដទេ ព្យាយាមរមែងប្រាកដផង បុរសរមែងញុំាងព្យាយាមឲ្យសម្រេចបាននូវគុណវិសេសផង ឯការចូលទៅជិតចងនិមិត្ត ដូចដើមឈើដែលគេដាំលើភូមិភាគដ៏រាបស្មើ ខ្យល់ដកដង្ហើមចេញ និងដកដង្ហើមចូល ទុកដូចធ្មេញរណារ ភិក្ខុតម្កល់ទុកនូវស្មារតីត្រង់ចុងច្រមុះ ឬទ្វារមាត់ ហើយអង្គុយ មិនធ្វើទុកក្នុងចិត្តនូវខ្យល់ដកដង្ហើមចេញ និងខ្យល់ដកដង្ហើមចូល ទាំង

ដែលមក ទាំងដែលទៅ ខ្យល់ដកដង្ហើមចេញ និងដកដង្ហើមចូល ដែលមកក្តី ដែលទៅក្តី មិនមែនជាមិនប្រាកដទេ ព្យាយាមរមែងប្រាកដផង ភិក្ខុញុំាង ព្យាយាមឲ្យសម្រេចបាននូវគុណវិសេសផង ប្រៀបដូចជាស្នាតើបុរសតាំង ឡើងចំពោះ ដើម្បីឈើដោយអំណាចនៃធ្មេញរណារដែលពាល់ត្រូវ បុរស មិនធ្វើទុកក្នុងចិត្តត្រង់ធ្មេញរណារ ដែលទាញមកទាញទៅ ធ្មេញរណារដែល ទាញមកក្តី ទាញទៅក្តី មិនមែនជាមិនប្រាកដទេ ព្យាយាមប្រាកដផង បុរសញុំាងព្យាយាម ឲ្យសម្រេចបានគុណវិសេសផង ។

[ ៩៣ ] ការព្យាយាម តើដូចម្តេច ។ ភិក្ខុមានព្យាយាមប្រារព្ធហើយ តែងមានកាយ និងចិត្តគួរដល់ការងារ នេះឈ្មោះថា ការព្យាយាម ។ ការ ប្រកបព្យាយាម តើដូចម្តេច ។ ភិក្ខុមានព្យាយាមប្រារព្ធហើយ រមែងលះបង់ នូវពួកឧបក្កិលេស មានវិតក្កស្ងប់រម្ងាប់ នេះឈ្មោះថា ការប្រកបព្យាយាម ។ គុណវិសេស តើដូចម្តេច ។ ភិក្ខុមានព្យាយាមប្រារព្ធហើយ រមែងលះបង់ ស្រឡះនូវពួកសំយោជនៈ មានពួកអនុស័យធម៌វិនាស នេះឈ្មោះថា គុណ វិសេស ។ នេះធម៌ ៣ យ៉ាង ដែលមិនមែនជាអារម្មណ៍នៃឯកចិត្ត នេះធម៌ ៣ យ៉ាង ដែលភិក្ខុមិនមែនជាមិនដឹង គឺចិត្តមិនដល់នូវសេចក្តីរាយមាយ ១ ព្យាយាមប្រាកដ ១ ភិក្ខុញុំាងព្យាយាម ឲ្យសម្រេចបាននូវគុណវិសេស ១ យ៉ាងនេះឯង ។

[ ៩៤ ] អានាបានស្សតិ បុគ្គលណាបានបំពេញហើយ ចម្រើន
ហើយដោយប្រពៃ សន្សំហើយដោយលំដាប់ ឲ្យដូចព្រះពុទ្ធ

ទ្រង់សម្តែងទុកហើយ បុគ្គលនោះ រមែងញ៉ាំងលោកនេះ
ឲ្យភ្លឺច្បាស់ ដូចព្រះចន្ទដែលផុតស្រឡះចាកពពក ។

ពាក្យថា **អាន** ប្រែថា ខ្យល់ដកដង្ហើមចេញ មិនមែនប្រែថា ខ្យល់ដកដង្ហើមចូលទេ ។ ពាក្យថា **អបាន** ប្រែថា ខ្យល់ដកដង្ហើមចូល មិនមែនប្រែថា ខ្យល់ដកដង្ហើមចេញទេ ។ សតិ ( ស្មារតី ) ជាទីតាំងមាំ រមែងតាំងមាំដល់ភិក្ខុដែលដកដង្ហើមចេញ តាំងមាំដល់ភិក្ខុដែលដកដង្ហើមចូល ដោយអំណាចនៃខ្យល់ដកដង្ហើមចេញ និងដកដង្ហើមចូល ។ ពាក្យថា បានបំពេញហើយ គឺបានបំពេញហើយ ដោយអត្ថថា ថែថួន បានបំពេញហើយ ដោយអត្ថថា ជាបរិវារ បានបំពេញហើយ ដោយអត្ថថា គ្រប់គ្រាន់ ។

ពាក្យថា ចម្រើនហើយដោយប្រពៃ បានដល់ ភាវនា ៤ យ៉ាង គឺភាវនាដោយអត្ថថា មិនប្រព្រឹត្តកន្លងនូវពួកធម៌ដែលកើតក្នុងមគ្គនោះ ១ ភាវនា ដោយអត្ថថា ឥន្ទ្រិយទាំងឡាយមានរសតែមួយ ១ ភាវនា ដោយអត្ថថា នាំទៅនូវព្យាយាមគួរដល់ឥន្ទ្រិយនោះ ១ ភាវនា ដោយអត្ថថា សេព ១ នេះឯងអត្ថរបស់ភាវនា ៤ យ៉ាង ដែលគេធ្វើឲ្យដូចជាយាន ធ្វើឲ្យដូចជាវត្ថុជាទីតាំងឲ្យតាំងឡើងរឿយៗ សន្សំហើយ ប្រារព្ធសេចក្តីស្ងប់ប្រពៃហើយ ។

ពាក្យថា ធ្វើឲ្យដូចជាយាន សេចក្តីថា ភិក្ខុប៉ុនប៉ងធម៌ណាៗ រមែងជាអ្នកដល់នូវការស្ទាត់ជំនាញ ដល់នូវកម្លាំង ដល់នូវសេចក្តីក្លៀវក្លាក្នុងធម៌នោះៗ ធម៌ទាំងឡាយនោះៗ របស់ភិក្ខុនោះ រមែងជាប់ចំពោះដោយការនឹករំពឹង ជាប់ចំពោះដោយការប៉ុនប៉ង ជាប់ចំពោះដោយការធ្វើទុកក្នុងចិត្ត ជាប់ចំពោះ ដោយ

ការកើតឡើងនៃចិត្ត ហេតុនោះ ទើបលោកពោលថា ធ្វើឲ្យដូចជាយាន ។

ពាក្យថា ធ្វើឲ្យដូចជាវត្ថុជាទីតាំង សេចក្តីថា ចិត្តដែលភិក្ខុអធិដ្ឋានល្អ ចំពោះវត្ថុណាៗ ស្មារតីរមែងតម្កល់ស៊ប់ចំពោះវត្ថុនោះៗ ឬក៏ស្មារតីតម្កល់ស៊ប់ ចំពោះវត្ថុណាៗ ចិត្តភិក្ខុនោះ ក៏អធិដ្ឋានល្អក្នុងវត្ថុនោះៗ ហេតុនោះ ទើបលោកពោលថា ធ្វើឲ្យដូចជាវត្ថុជាទីតាំង ។

ពាក្យថា ឲ្យតាំងឡើងរឿយៗ សេចក្តីថា ចិត្តឱនទៅក្នុងធម៌ណាៗ ស្មារតីក៏ប្រព្រឹត្តទៅក្នុងធម៌នោះៗ ឬក៏ស្មារតីប្រព្រឹត្តទៅក្នុងធម៌ណាៗ ចិត្តភិក្ខុនោះ ក៏ឱនទៅក្នុងធម៌នោះៗ ហេតុនោះ ទើបលោកពោលថា ឲ្យតាំងឡើងរឿយៗ ។

ពាក្យថា សន្សំហើយ សេចក្តីថា សន្សំហើយ ដោយអត្ថថា គ្រប់គ្រង សន្សំហើយ ដោយអត្ថថា ជាបរិវារ សន្សំហើយ ដោយអត្ថថា បំពេញ បុគ្គលកាលគ្រប់គ្រង ( ធម៌ ) ដោយស្មារតី រមែងឈ្នះពួកអកុសលធម៌ដ៏លាមក ហេតុនោះ ទើបលោកពោលថា សន្សំហើយ ។

ពាក្យថា ប្រារព្ធសេចក្តីស្ងប់ប្រពៃ សេចក្តីថា ការប្រារព្ធសេចក្តីស្ងប់ប្រពៃ ៤ យ៉ាង គឺការប្រារព្ធនូវសេចក្តីស្ងប់ប្រពៃ ដោយអត្ថថា មិនប្រព្រឹត្តកន្លងនូវពួកធម៌ដែលកើតក្នុងមគ្គនោះ ១ ការប្រារព្ធសេចក្តីស្ងប់ប្រពៃ ដោយអត្ថថា ពួកឥន្ទ្រិយមានរសតែមួយ ១ ការប្រារព្ធសេចក្តីស្ងប់ប្រពៃ ដោយអត្ថថា នាំទៅនូវព្យាយាម គួរដល់ឥន្ទ្រិយនោះ ១ ការប្រារព្ធសេចក្តីស្ងប់ប្រពៃ ព្រោះគាស់រម្លើងនូវពួកកិលេសជាសត្រូវរបស់មគ្គនោះ ១ ។

ពាក្យថា សេចក្តីស្ងប់ប្រពៃ សេចក្តីថា ការស្ងប់ក៏មាន ការស្ងប់ប្រពៃ

ក៏មាន ។ ការស្ងប់ តើដូចម្តេច ។ ពួកពោធិបក្ខិយធម៌ណា ដែលកើតក្នុងការនោះ ជាធម៌មិនមានទោស ជាកុសល នេះឈ្មោះថា ការស្ងប់ ។ ការស្ងប់ប្រពៃ តើដូចម្តេច ។ អារម្មណ៍ គឺការរលត់ ការរម្ងាប់នូវពួកធម៌នោះឯណា នេះឈ្មោះថា ការស្ងប់ប្រពៃ ។ ឯការស្ងប់ និងការស្ងប់ប្រពៃនេះ ព្រះអរិយៈទាំងឡាយដឹងហើយ ឃើញហើយ ជ្រាបច្បាស់ហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយដោយបញ្ញា ព្យាយាមដ៏មិនថោកថយ ព្រះអរិយៈទាំងឡាយប្រារព្ធហើយ ស្មារតីដែលលោកតម្កល់មាំហើយ រមែងមិនវង្វេងភ្លេច កាយដែលស្ងប់ហើយ ព្រះអរិយៈទាំងឡាយប្រារព្ធហើយ ចិត្តដែលតម្កល់មាំហើយ រមែងមានអារម្មណ៍តែមួយ ហេតុនោះ ទើបលោកពោលថា ប្រារព្ធសេចក្តីស្ងប់ប្រពៃ ដោយប្រការដូច្នេះឯង ។

ពាក្យថា សន្សំហើយដោយលំដាប់ គឺអានាបានស្សតិការនាខាងដើមៗ បុគ្គលសន្សំហើយ អានាបានស្សតិការនាខាងចុងៗ បុគ្គលសន្សំរឿយៗ ហើយដោយអំណាចនៃខ្យល់ដកដង្ហើមចេញវែង អានាបានស្សតិការនាខាងដើមៗ បុគ្គលសន្សំហើយ អានាបានស្សតិការនាខាងចុងៗ បុគ្គលសន្សំរឿយៗ ហើយដោយអំណាចនៃខ្យល់ដកដង្ហើមចូលវែង អានាបានស្សតិការនាខាងដើមៗ បុគ្គលសន្សំហើយ អានាបានស្សតិការនាខាងចុងៗ បុគ្គលសន្សំរឿយៗ ហើយដោយអំណាចនៃខ្យល់ដកដង្ហើមចេញខ្លី អានាបានស្សតិការនាខាងដើមៗ បុគ្គលសន្សំហើយ អានាបានស្សតិការនាខាងចុងៗ បុគ្គលសន្សំរឿយៗ ហើយដោយអំណាចនៃខ្យល់ដកដង្ហើមចូលខ្លី ។បេ។ អានាបានស្សតិការនាខាងដើមៗ

បុគ្គលសន្សំហើយ អានាបានស្សតិការនាខាងចុងៗ បុគ្គលសន្សំរឿយៗ ហើយ ដោយអំណាចនៃខ្យល់ដកដង្ហើមចេញ របស់បុគ្គលអ្នកពិចារណានូវការលះបង់ស្រឡះ អានាបានស្សតិការនាខាងដើមៗ បុគ្គលសន្សំហើយ អានាបានស្សតិ-ការនាខាងចុងៗ បុគ្គលសន្សំរឿយៗ ហើយ ដោយអំណាចនៃខ្យល់ដកដង្ហើមចូល របស់បុគ្គលអ្នកពិចារណានូវការលះបង់ស្រឡះ រួមអានាបានស្សតិទាំងអស់ មានវត្ថុ ១៦ បុគ្គលសន្សំហើយផង សន្សំរឿយៗ ហើយ ទៅវិញទៅមកផង ហេតុនោះ ទើបលោកពោលថា សន្សំហើយ ដោយលំដាប់ ។

ពាក្យថា ដូចជា សេចក្តីថា អត្ថថា ដូចជា មាន ១០ យ៉ាង គឺអត្ថថា ទូន្មាននូវខ្លួន ឈ្មោះ អត្ថថា ដូចជា ១ អត្ថថា រម្ងាប់នូវខ្លួន ឈ្មោះ អត្ថថា ដូចជា ១ អត្ថថា រលត់នូវខ្លួន ឈ្មោះ អត្ថថា ដូចជា ១ អត្ថថា ដឹងច្បាស់ ឈ្មោះ អត្ថថា ដូចជា ១ អត្ថថា កំណត់ដឹង ឈ្មោះ អត្ថថា ដូចជា ១ អត្ថថា លះបង់ ឈ្មោះ អត្ថថា ដូចជា ១ អត្ថថា ចម្រើន ឈ្មោះ អត្ថថា ដូចជា ១ អត្ថថា ធ្វើឲ្យជាក់ច្បាស់ ឈ្មោះ អត្ថថា ដូចជា ១ អត្ថថា ត្រាស់ដឹងនូវសច្ចៈ ឈ្មោះ អត្ថថា ដូចជា ១ អត្ថថា តម្កល់ខ្លួនស៊ប់ក្នុងនិរោធ ឈ្មោះ អត្ថថា ដូចជា ១ ។

ពាក្យថា ព្រះពុទ្ធ បានដល់ ព្រះមានព្រះភាគដែលត្រាស់ដឹងដោយព្រះអង្គឯង ទ្រង់ពុំមានអាចារ្យ ទ្រង់ត្រាស់ដឹងនូវសច្ចៈ ក្នុងធម៌ទាំងឡាយដែលទ្រង់មិនធ្លាប់ឮក្នុងពេលមុន ដោយព្រះអង្គឯង ទ្រង់ដល់នូវសព្វញ្ញុតញ្ញាណក្នុងធម៌ទាំងឡាយនោះ ទ្រង់ដល់នូវសេចក្តីស្ទាត់ក្នុងពលទាំងឡាយផង ។

សំណួរត្រង់ពាក្យថា ព្រះពុទ្ធ តើព្រះពុទ្ធដោយអត្ថថាដូចម្តេច ។ ឈ្មោះថា ព្រះពុទ្ធ ព្រោះហេតុត្រាស់ដឹងនូវសច្ចៈទាំងឡាយ ឈ្មោះថា ព្រះពុទ្ធ ព្រោះហេតុព្រះអង្គញ៉ាំងពពួកសត្វ ឲ្យត្រាស់ដឹង ឈ្មោះថា ព្រះពុទ្ធ ព្រោះព្រះអង្គត្រាស់ដឹងសព្វ ឈ្មោះថា ព្រះពុទ្ធ ព្រោះទ្រង់ឃើញសព្វ ឈ្មោះថា ព្រះពុទ្ធ ព្រោះព្រះអង្គឥតមានបុគ្គលដទៃណែនាំ ឈ្មោះថា ព្រះពុទ្ធ ព្រោះព្រះអង្គមានការរីកដោយវិសេស ឈ្មោះថា ព្រះពុទ្ធ ព្រោះគេអាចរាប់ថាព្រះអង្គមានអាសវៈអស់ហើយ ឈ្មោះថា ព្រះពុទ្ធ ព្រោះគេអាចរាប់ថា ព្រះអង្គមិនមានឧបក្កិលេស ឈ្មោះថា ព្រះពុទ្ធ ព្រោះហេតុព្រះអង្គប្រាសចាករាគៈដោយដាច់ខាត ឈ្មោះថា ព្រះពុទ្ធ ព្រោះហេតុព្រះអង្គប្រាសចាកទោសៈដោយដាច់ខាត ឈ្មោះថា ព្រះពុទ្ធ ព្រោះហេតុព្រះអង្គប្រាសចាកមោហៈដោយដាច់ខាត ឈ្មោះថា ព្រះពុទ្ធ ព្រោះហេតុព្រះអង្គមិនមានកិលេសដោយដាច់ខាត ឈ្មោះថា ព្រះពុទ្ធ ព្រោះហេតុព្រះអង្គទ្រង់ស្តេចទៅកាន់ផ្លូវជាទីទៅនៃបុគ្គលម្នាក់ឯង ឈ្មោះថា ព្រះពុទ្ធ ព្រោះហេតុព្រះអង្គតែម្នាក់ឯង ត្រាស់ដឹងនូវសម្មាសម្ពោធិដ៏ប្រសើរ ឈ្មោះថា ព្រះពុទ្ធ ព្រោះការបានចំពោះនូវបញ្ញា ដោយហេតុព្រះអង្គកម្ចាត់បោលនូវធម្មជាតផ្ទុយនឹងប្រាជ្ញាចេញ ។

ព្រះនាមថា ព្រះពុទ្ធនេះ មិនមែនជាព្រះនាមដែលព្រះមាតាថ្វាយទេ មិនមែនព្រះបិតាថ្វាយទេ មិនមែនព្រះភាតាថ្វាយទេ មិនមែនព្រះភគិនីថ្វាយទេ មិនមែនពួកមិត្ត និងអាមាត្យថ្វាយទេ មិនមែនពួកញាតិសាលោហិតថ្វាយទេ មិនមែនពួកសមណព្រាហ្មណ៍ថ្វាយទេ មិនមែនពួកទេវតាថ្វាយទេ ព្រះនាមថា

ព្រះពុទ្ធនេះ ជាវិមោក្ខន្តិកនាម របស់ព្រះពុទ្ធទាំងឡាយ ទ្រង់មានព្រះភាគ ជានាមបញ្ញត្តិ ព្រោះការត្រាស់ដឹងដំណាលនឹងការបាននូវសព្វញ្ញុតញ្ញាណ ក្រោមម្លប់ពោធិព្រឹក្ស ។

ពាក្យថា ទ្រង់សម្តែងហើយ សេចក្តីថា អត្ថថា ទុក្ខនូវខ្លួន ឈ្មោះ អត្ថថា ដូចជា គឺដូចជាព្រះពុទ្ធទ្រង់សម្តែងហើយ អត្ថថាវ ម្ចាប់នូវខ្លួន ឈ្មោះ អត្ថថា ដូចជា គឺដូចជាព្រះពុទ្ធទ្រង់សម្តែងហើយ អត្ថថា រម្ងត់នូវខ្លួន ឈ្មោះ អត្ថថា ដូចជា គឺដូចជាព្រះពុទ្ធទ្រង់សម្តែងហើយ ។បេ។ អត្ថថា ឲ្យតម្កល់ ខ្លួនស៊ប់ ក្នុងនិរោធធម៌ ឈ្មោះ អត្ថថា ដូចជា គឺព្រះពុទ្ធទ្រង់សម្តែងហើយ ទោះជាគ្រហស្ថក្តី បព្វជិតក្តី ។

ពាក្យថា លោក បានដល់ ខន្ធលោក ធាតុលោក អាយតនលោក វិបត្តិភវលោក វិបត្តិសម្ភវលោក សម្បត្តិភវលោក សម្បត្តិសម្ភវលោក លោក ១ បានដល់ ពួកសត្វទាំងអស់ ដែលតាំងនៅដោយអាហារ ។បេ។ លោក ១៨ បានដល់ ធាតុ ១៨ ។

ពាក្យថា រមែងឲ្យភ្លឺច្បាស់ គឺបុគ្គលនោះរមែងញុំាងលោកនេះឲ្យភ្លឺស្វាង ឲ្យភ្លឺច្បាស់ព្រោះត្រាស់ដឹងនូវអត្ថថាទុក្ខនូវខ្លួន ឈ្មោះ អត្ថថា ដូចជា បុគ្គល នោះរមែងញុំាងលោកនេះ ឲ្យភ្លឺស្វាង ឲ្យភ្លឺច្បាស់ ព្រោះត្រាស់ដឹងនូវអត្ថថា រម្ចាប់នូវខ្លួន ឈ្មោះ អត្ថថា ដូចជា បុគ្គលនោះរមែងញុំាងលោកនេះឲ្យភ្លឺស្វាង ព្រោះត្រាស់ដឹងនូវអត្ថថារម្ងត់នូវខ្លួន ឈ្មោះ អត្ថថា ដូចជា ។បេ។ បុគ្គលនោះ រមែងញុំាងលោកនេះឲ្យភ្លឺស្វាង ឲ្យភ្លឺច្បាស់ ព្រោះត្រាស់ដឹងនូវអត្ថថាតម្កល់

ខ្ជួនស៊ប់ក្នុងនិរោធធម៌ ឈ្មោះ អត្ថថា ដូចជា ។

ពាក្យថា ដូចជាព្រះចន្ទដែលផុតស្រឡះចាកពពក គឺពពកយ៉ាងណា កិលេសយ៉ាងនោះ ព្រះចន្ទយ៉ាងណា អរិយញ្ញាណយ៉ាងនោះ ចន្ទិមទេវបុត្ត យ៉ាងណា ភិក្ខុយ៉ាងនោះ ព្រះចន្ទដែលផុតស្រឡះហើយចាកពពក ផុតស្រឡះហើយចាកផ្សែង និងធូលីលើផែនដី ផុតស្រឡះហើយ ចាកបាតដៃនៃរាហុ រមែងភ្លឺផង រុងរឿងផង ច្រើនថ្កានផងយ៉ាងណា ភិក្ខុដែលផុតស្រឡះហើយ ចាកកិលេសទាំងអស់រមែងភ្លឺផង រុងរឿងផង ច្រើនថ្កានផងយ៉ាងនោះដែរ ។ ហេតុនោះ លោកពោលថា ដូចជាព្រះចន្ទដែលផុតស្រឡះចាកពពក ទាំងនេះ ឈ្មោះថា វោទានញ្ញាណ ១៣ ប្រការ ។

## ភាណវារៈ ចប់

[ ៩៥ ] សតោការិញ្ញាណ ៣២ តើដូចម្ដេច ។ ភិក្ខុក្នុងសាសនានេះ ទៅកាន់ព្រៃក្ដី ទៅកាន់គល់ឈើក្ដី ទៅកាន់ផ្ទះស្ងាត់ក្ដី អង្គុយពែនភ្នែន តាំងកាយឲ្យត្រង់ តាំងសតិឲ្យមានមុខឆ្ពោះទៅរក ( កម្មដ្ឋាន ) ភិក្ខុនោះ មានសតិដកដង្ហើមចេញ ។បេ។ សិក្សាថា អាត្មាអញជាអ្នកកំណត់ដឹងនូវកាយ គឺខ្យល់ចេញទាំងពួង នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញជាអ្នកកំណត់ដឹងច្បាស់នូវកាយ គឺខ្យល់ចូលទាំងពួង នឹងដកដង្ហើមចូល សិក្សាថា អាត្មាអញកាលរម្ងាប់កាយសង្ខារ នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញកាលរម្ងាប់កាយ-

សង្ខារ នឹងដកដង្ហើមចូល សិក្សាថា អាត្មាអញជាអ្នកកំណត់ដឹងច្បាស់នូវបីតិ កំណត់ដឹងច្បាស់នូវសេចក្តីសុខ កំណត់ដឹងច្បាស់នូវចិត្តសង្ខារ គឺវេទនា និង សញ្ញា កាលរម្ងាប់នូវចិត្តសង្ខារ ជាអ្នកកំណត់ដឹងច្បាស់ចិត្ត កាលញ៉ាំងចិត្តឲ្យ រីករាយខ្លាំង កាលតម្កល់ចិត្ត កាលដោះចិត្ត ជាអ្នកពិចារណានូវអនិច្ចលក្ខណៈ ជាអ្នកពិចារណានូវការប្រាសចាករាគៈ ជាអ្នកពិចារណានូវធម៌ជាទីរលត់ ជា អ្នកពិចារណានូវធម៌ជាគ្រឿងរលាស់ចិត្ត ចេញចាកកិលេស នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញជាអ្នកពិចារណានូវធម៌ ជាគ្រឿងរលាស់ចិត្តចេញចាក កិលេស នឹងដកដង្ហើមចូល ។

[ ៩៦ ] ពាក្យថា ក្នុងសាសនានេះ គឺក្នុងទិដ្ឋិនេះ ក្នុងសេចក្តីពេញចិត្ត នេះ ក្នុងសេចក្តីគាប់ចិត្តនេះ ក្នុងសេចក្តីប្រកាន់នេះ ក្នុងធម៌នេះ ក្នុងវិន័យនេះ ក្នុងធម្មវិន័យនេះ ក្នុងពាក្យជាប្រធាននេះ ក្នុងព្រហ្មចរិយៈនេះ ក្នុងសាសនា នៃព្រះសាស្តានេះ ហេតុនោះ លោកពោលថា ក្នុងសាសនានេះ ។

ពាក្យថា ភិក្ខុ បានដល់ ភិក្ខុជាកល្យាណបុថុជ្ជន ឬជាសេក្ខៈ ឬក៏ជា អរហន្តដែលមានធម៌មិនកម្រើក ។

ពាក្យថា ព្រៃ បានដល់ ទីចេញទៅខាងក្រៅអំពីសសរគោលទាំងអស់ នេះឈ្មោះថា ព្រៃ ។

ពាក្យថា គល់ឈើ បានដល់ អាសនៈ គឺគ្រែក្តី តាំងក្តី ពូកក្តី កន្ទេល ក្តី ផ្ទាំងស្បែកក្តី កម្រាលស្មៅក្តី កម្រាលស្លឹកឈើក្តី កម្រាលចំបើងក្តី ដែល គេក្រាលសម្រាប់ភិក្ខុទៀបគល់ឈើនោះ ភិក្ខុចង្ក្រមក៏បាន ឈរក៏បាន អង្គុយ

ក៏បាន សិងក៏បាន លើអាសនៈនោះ ។

ពាក្យថា ស្ងាត់ គឺមិនកុះករដោយពួកគ្រហស្ថ ឬពួកបព្វជិតណាមួយ ។

ពាក្យថា ផ្ទះ បានដល់ វិហារ អឌ្ឍយោគ ប្រាសាទវែង ប្រាសាទមានដំបូលរលីង គុហា ។

ពាក្យថា អង្គុយពែនភ្នែន គឺជាអ្នកអង្គុយពែនភ្នែន តាំងកាយឲ្យត្រង់ មានកាយត្រង់ នឹងធឹង នឹងនួន ។

អធិប្បាយពាក្យថា តាំងសតិឲ្យមានមុខឆ្ពោះទៅរក ( កម្មដ្ឋាន ) ត្រង់ពាក្យថា បរិ មានអត្ថថា កំណត់ ពាក្យថា មុខ មានអត្ថថា ធម៌ជាគ្រឿងចេញទៅ ពាក្យថា សតិ មានអត្ថថា ប្រុងប្រយ័ត្ន ហេតុនោះ លោកពោលថា តាំងសតិឲ្យមានមុខឆ្ពោះទៅរក ( កម្មដ្ឋាន ) ។

[ ៩៧ ] ពាក្យថា មានសតិដកដង្ហើមចេញ អធិប្បាយថា បុគ្គលធ្វើសតិដោយអាការ ៣២ គឺកាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្តមានអារម្មណ៍តែមួយ មិនរាយមាយដោយអំណាចនៃដង្ហើមចេញវែង សតិក៏តម្កល់មាំ បុគ្គលធ្វើសតិដោយស្មារតីនោះ ដោយញាណនោះ កាលបុគ្គលដឹងច្បាស់នូវសភាពនៃចិត្តមានអារម្មណ៍តែមួយ មិនរាយមាយដោយអំណាចនៃដង្ហើមចូលវែង សតិក៏តម្កល់មាំ បុគ្គលធ្វើសតិដោយស្មារតីនោះ ដោយញាណនោះ កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្ត មានអារម្មណ៍តែមួយ មិនរាយមាយដោយអំណាចនៃដង្ហើមចេញខ្លី សតិក៏តម្កល់មាំ បុគ្គលធ្វើសតិដោយស្មារតីនោះ ដោយញាណនោះ កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្តមានអារម្មណ៍តែមួយ

មិនរាយមាយដោយអំណាចនៃដង្ហើមចូលខ្វី សតិក៏តម្កល់មាំ បុគ្គលធ្វើសតិដោយស្មារតីនោះ ដោយញាណនោះ ។បេ។ កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្តមានអារម្មណ៍តែមួយ មិនរាយមាយដោយអំណាចនៃដង្ហើមចេញ សម្រាប់អ្នកពិចារណាឃើញនូវធម៌ ជាគ្រឿងរលាស់ចេញចាកកិលេសដោយអំណាចនៃដង្ហើមចូល សម្រាប់អ្នកពិចារណាឃើញនូវធម៌ជាគ្រឿងរលាស់ចេញចាកកិលេស សតិក៏តម្កល់មាំ បុគ្គលធ្វើសតិដោយស្មារតីនោះដោយញាណនោះ ។

[ ៩៨ ] ភិក្ខុកាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញវែង កាលដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលវែង តើដូចម្តេច ។ ភិក្ខុដកចេញនូវដង្ហើមចេញវែង ក្នុងចំណែកនៃកាលវែង ដកចូលនូវដង្ហើមចូលវែង ក្នុងចំណែកនៃកាលវែង ដកចេញក្តី ដកចូលក្តី នូវដង្ហើមចេញ ឬដង្ហើមចូលវែង ក្នុងចំណែកនៃកាលវែង កាលភិក្ខុដកចេញក្តី ដកចូលក្តី នូវដង្ហើមចេញ ឬដង្ហើមចូលវែង ក្នុងចំណែកនៃកាលវែង ( ច្រើនដង ) ឆន្ទៈ ( ចំណង់ក្នុងអ្វីមួយ ) រមែងកើតឡើង ភិក្ខុដកចេញនូវដង្ហើមចេញវែង ល្អិតក្រៃលែងជាងនោះ ក្នុងចំណែកនៃកាលវែងដោយអំណាចនៃឆន្ទៈ ដកចូលនូវដង្ហើមចូលវែង ដ៏ល្អិតក្រៃលែងជាងនោះក្នុងចំណែកនៃកាលវែង ដោយអំណាចឆន្ទៈ ដកចេញក្តី ដកចូលក្តី នូវដង្ហើមចេញ ឬដង្ហើមចូលវែង ដ៏ល្អិតក្រៃលែងជាងនោះ ក្នុងចំណែកនៃកាលវែងដោយអំណាចនៃឆន្ទៈ កាលភិក្ខុដកចេញក្តី ដកចូលក្តី នូវដង្ហើមចេញ ឬដង្ហើមចូលវែង ដ៏ល្អិតក្រៃលែងជាងនោះ ក្នុងចំណែកនៃកាលវែងដោយអំណាច

នៃឆន្ទៈ ( ប្រើនដង ) បាមុជ្ជ រមែងកើតឡើង ភិក្ខុដកចេញនូវដង្ហើមចេញវែង ដ៏ល្អិតក្រៃលែងជាងនោះ ក្នុងចំណែកនៃកាលវែង ដោយអំណាចនៃបាមុជ្ជ ដកចូលនូវដង្ហើមចូលវែង ដ៏ល្អិតក្រៃលែងជាងនោះ ក្នុងចំណែកនៃកាលវែង ដោយអំណាចនៃបាមុជ្ជ ដកចេញក្តី ដកចូលក្តី នូវដង្ហើមចេញ ឬដង្ហើមចូលវែង ដ៏ល្អិតក្រៃលែងជាងនោះ ក្នុងចំណែកនៃកាលវែង ដោយអំណាចនៃបាមុជ្ជ កាលភិក្ខុដកចេញក្តី ដកចូលក្តី នូវដង្ហើមចេញ ឬដង្ហើមចូលវែង ដ៏ល្អិតក្រៃលែងជាងនោះ ក្នុងចំណែកនៃកាលវែង ដោយអំណាចនៃបាមុជ្ជ ( ប្រើនដង ) ចិត្តក៏ឃ្លាតចេញអំពីដង្ហើមចេញ ឬដង្ហើមចូលវែង ឧបេក្ខាក៏តាំងនៅស៊ប់ នេះកាយ គឺដង្ហើមចេញ និងដង្ហើមចូលវែង ដោយអាការ ៩ យ៉ាងដែល ឈ្មោះថា ឧបដ្ឋាន សតិ ឈ្មោះថា អនុបស្សនាញាណ កាយឈ្មោះថា ឧបដ្ឋាន មិនមែនឈ្មោះថា សតិទេ សតិ ឈ្មោះថា ឧបដ្ឋានផង ឈ្មោះថា សតិផង ភិក្ខុពិចារណាឃើញនូវកាយនោះ ដោយសតិនោះ ដោយញាណនោះ ហេតុនោះ លោកពោលថា កាយេកាយានុបស្សនាសតិប្បដ្ឋានភាវនា ដោយប្រការដូច្នេះ ។

[ ៩៩ ] សំណួរត្រង់ពាក្យថា ភិក្ខុពិចារណាឃើញ តើភិក្ខុពិចារណាឃើញនូវកាយនោះដូចម្តេច ។ ភិក្ខុពិចារណាឃើញថាមិនទៀង មិនមែនថាទៀងទេ ពិចារណាឃើញថាជាទុក្ខ មិនមែនថាជាសុខទេ ពិចារណាឃើញថាមិនមែនខ្លួន មិនមែនថាខ្លួនទេ ( តមក ) តែងនឿយណាយ មិនមែនរីករាយទេ តែងជិនឆ្អន់ មិនមែនត្រេកត្រអាលទេ តែងរម្ងាប់បង់ មិនមែនឲ្យ

កើតទេ តែងរលាស់ចោល មិនមែនក្ដួចកាន់ទេ ភិក្ខុកាលពិចារណាឃើញថា មិនទៀង រមែងលះបង់នូវនិច្ចសញ្ញា កាលពិចារណាឃើញថាជាទុក្ខ រមែងលះបង់នូវសុខសញ្ញា កាលពិចារណាឃើញថាមិនមែនខ្លួន រមែងលះបង់នូវអត្តសញ្ញា កាលនឿយណាយ រមែងលះបង់នូវសេចក្ដីរីករាយ កាលជិនឆ្អន់ រមែងលះបង់នូវរាគៈ កាលរម្ងត់ រមែងលះបង់នូវហេតុ ជាគ្រឿងឲ្យកើត កាលរលាស់ចោល រមែងលះបង់នូវសេចក្ដីប្រកាន់ ភិក្ខុពិចារណាឃើញនូវកាយនោះ យ៉ាងនេះឯង ។

[ ១០០ ] ពាក្យថា ភាវនា បានដល់ ភាវនា ៤ យ៉ាង គឺភាវនាដោយអត្ថថា មិនប្រព្រឹត្តកន្លងនូវពួកធម៌ ដែលកើតក្នុងមគ្គនោះ ១ ភាវនាដោយអត្ថថា ឥន្ទ្រិយទាំងឡាយមានរសតែមួយ ១ ភាវនា ដោយអត្ថថា នាំទៅនូវព្យាយាមដែលគួរដល់ឥន្ទ្រិយនោះ ១ ភាវនា ដោយអត្ថថា សេព ១ កាលភិក្ខុដឹងច្បាស់នូវភាពនៃចិត្ត មានអារម្មណ៍តែមួយ ដែលមិនរាយមាយដោយអំណាចនៃខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលវែង វេទនាដ៏ប្រាកដរមែងកើតឡើង វេទនាដ៏ប្រាកដរមែងតាំងឡើង វេទនាដ៏ប្រាកដរមែងដល់នូវសេចក្ដីវិនាស សញ្ញាដ៏ប្រាកដរមែងកើតឡើង សញ្ញាដ៏ប្រាកដរមែងតាំងឡើង សញ្ញាដ៏ប្រាកដ រមែងដល់នូវសេចក្ដីវិនាស វិតក្កដ៏ប្រាកដ រមែងកើតឡើង វិតក្កដ៏ប្រាកដ រមែងតាំងឡើង វិតក្កដ៏ប្រាកដ រមែងដល់នូវសេចក្ដីវិនាស ។

[ ១០១ ] វេទនាដ៏ប្រាកដរមែងកើតឡើង វេទនាដ៏ប្រាកដរមែងតាំងឡើង វេទនាដ៏ប្រាកដរមែងដល់នូវសេចក្ដីវិនាស តើដូចម្ដេច ។

ការកើតឡើងនៃវេទនាដ៏ប្រាកដ តើដូចម្តេច ។ ការកើតឡើងនៃវេទនាដ៏ប្រាកដ ដោយអត្ថថា កើតឡើងព្រោះបច្ច័យ ព្រោះយល់ថា ការកើតឡើងនៃវេទនា ព្រោះការកើតឡើងនៃអវិជ្ជា ការកើតឡើងនៃវេទនាដ៏ប្រាកដ ដោយអត្ថថា កើតឡើងព្រោះបច្ច័យ ព្រោះយល់ថា ការកើតឡើងនៃវេទនា ព្រោះការកើតឡើងនៃតណ្ហា ព្រោះយល់ថា ការកើតឡើងនៃវេទនា ព្រោះការកើតឡើងនៃកម្ម ព្រោះយល់ថា ការកើតឡើងនៃវេទនា ព្រោះការកើតឡើងនៃផស្សៈ កាលភិក្ខុពិចារណាឃើញនូវលក្ខណៈនៃកំណើត ការកើតឡើងនៃវេទនា ក៏ប្រាកដឡើង ការកើតឡើងនៃវេទនាដ៏ប្រាកដយ៉ាងនេះឯង ។

ការតាំងឡើងនៃវេទនាដ៏ប្រាកដ តើដូចម្តេច ។ កាលភិក្ខុធ្វើទុកក្នុងចិត្តថាមិនទៀង ការតាំងឡើងថា អស់ទៅរមែងប្រាកដ កាលភិក្ខុធ្វើទុកក្នុងចិត្តថាជាទុក្ខ ការតាំងឡើងថាគួរខ្លាចរមែងប្រាកដ កាលភិក្ខុធ្វើទុកក្នុងចិត្តថាមិនមែនខ្លួន ការតាំងឡើងថាសូន្យរមែងប្រាកដ ការតាំងឡើងនៃវេទនាដ៏ប្រាកដយ៉ាងនេះឯង ។

ការដល់នូវសេចក្តីវិនាសនៃវេទនាដ៏ប្រាកដ តើដូចម្តេច ។ ការដល់នូវសេចក្តីវិនាសនៃវេទនារមែងប្រាកដ ដោយអត្ថថា រលត់នៃបច្ច័យ ព្រោះយល់ថា ការរលត់វេទនា ព្រោះការរលត់អវិជ្ជា ការដល់នូវសេចក្តីវិនាសនៃវេទនារមែងប្រាកដ ដោយអត្ថថា រលត់នៃបច្ច័យ ព្រោះយល់ថា ការរលត់វេទនា ព្រោះការរលត់តណ្ហា ព្រោះយល់ថា ការរលត់វេទនា ព្រោះការរលត់កម្ម ព្រោះយល់ថា ការរលត់វេទនា ព្រោះការរលត់ផស្សៈ កាលភិក្ខុពិចារណា

ឃើញនូវលក្ខណៈនៃការប្រែប្រួល ការដល់នូវសេចក្តីវិនាសនៃវេទនា រមែងប្រាកដយ៉ាងនេះ វេទនាដ៏ប្រាកដរមែងកើតឡើង វេទនាដ៏ប្រាកដរមែងតាំងឡើង វេទនាដ៏ប្រាកដរមែងដល់នូវសេចក្តីវិនាស យ៉ាងនេះឯង ។

[ ១០២ ] សញ្ញាដ៏ប្រាកដរមែងកើតឡើង សញ្ញាដ៏ប្រាកដរមែងតាំងឡើង សញ្ញាដ៏ប្រាកដរមែងដល់នូវសេចក្តីវិនាស តើដូចម្តេច ។

ការកើតឡើងនៃសញ្ញាដ៏ប្រាកដ តើដូចម្តេច ។ ការកើតឡើងនៃសញ្ញារមែងប្រាកដ ដោយអត្ថថា កើតឡើងព្រោះបច្ច័យ ព្រោះយល់ថា ការកើតឡើងនៃសញ្ញា ព្រោះការកើតឡើងនៃអវិជ្ជា ការកើតឡើងនៃសញ្ញា រមែងប្រាកដដោយអត្ថថា កើតឡើងព្រោះបច្ច័យ ព្រោះយល់ថា ការកើតឡើងនៃសញ្ញា ព្រោះការកើតឡើងនៃតណ្ហា ព្រោះយល់ថា ការកើតឡើងនៃសញ្ញា ព្រោះការកើតឡើងនៃកម្ម ព្រោះយល់ថា ការកើតឡើងនៃសញ្ញា ព្រោះការកើតឡើងនៃផស្សៈ កាលភិក្ខុពិចារណាឃើញនូវលក្ខណៈនៃកំណើត ការកើតឡើងនៃសញ្ញារមែងប្រាកដ ការកើតឡើងនៃសញ្ញារមែងប្រាកដ យ៉ាងនេះឯង ។

ការតាំងឡើងនៃសញ្ញាដ៏ប្រាកដ តើដូចម្តេច ។ កាលភិក្ខុធ្វើទុកក្នុងចិត្តថាមិនទៀង ការតាំងឡើងថា អស់ទៅរមែងប្រាកដ កាលភិក្ខុធ្វើទុកក្នុងចិត្តថាជាទុក្ខ ការតាំងឡើងថាគួរខ្លាច រមែងប្រាកដ កាលភិក្ខុធ្វើទុកក្នុងចិត្តថាមិនមែនខ្លួន ការតាំងឡើងថា សូន្យ រមែងប្រាកដ ការតាំងឡើងនៃសញ្ញាដ៏ប្រាកដ យ៉ាងនេះឯង ។

ការដល់នូវសេចក្តីវិនាសនៃសញ្ញាដ៏ប្រាកដ តើដូចម្តេច ។ ការដល់នូវ

សេចក្តីវិនាសនៃសញ្ញារមែងប្រាកដ ដោយអត្ថថា រលត់បច្ច័យ ព្រោះយល់ថា ការរលត់សញ្ញា ព្រោះការរលត់អវិជ្ជា ការដល់នូវសេចក្តីវិនាសនៃសញ្ញា រមែងប្រាកដ ដោយអត្ថថា រលត់បច្ច័យ ព្រោះយល់ថា ការរលត់សញ្ញា ព្រោះការរលត់តណ្ហា ព្រោះយល់ថា ការរលត់សញ្ញា ព្រោះការរលត់កម្ម ព្រោះយល់ថា ការរលត់សញ្ញា ព្រោះការរលត់ផស្សៈ កាលភិក្ខុពិចារណាឃើញនូវលក្ខណៈនៃការប្រែប្រួល ការដល់នូវសេចក្តីវិនាសនៃសញ្ញា រមែងប្រាកដ ការដល់នូវសេចក្តីវិនាសនៃសញ្ញា រមែងប្រាកដយ៉ាងនេះ សញ្ញាដ៏ប្រាកដ រមែងកើតឡើង សញ្ញាដ៏ប្រាកដ រមែងតាំងឡើង សញ្ញាដ៏ប្រាកដ រមែងដល់នូវសេចក្តីវិនាស យ៉ាងនេះឯង ។

[ ១០៣ ] វិតក្កដ៏ប្រាកដ រមែងកើតឡើង វិតក្កដ៏ប្រាកដ រមែងតាំងឡើង វិតក្កដ៏ប្រាកដ រមែងដល់នូវសេចក្តីវិនាស តើដូចម្តេច ។

ការកើតឡើងនៃវិតក្កដ៏ប្រាកដ តើដូចម្តេច ។ ការកើតឡើងនៃវិតក្ក រមែងប្រាកដ ដោយអត្ថថា កើតឡើងព្រោះបច្ច័យ ព្រោះយល់ថា ការកើតឡើងនៃវិតក្ក ព្រោះការកើតឡើងនៃអវិជ្ជា ការកើតឡើងនៃវិតក្ក រមែងប្រាកដ ដោយអត្ថថា កើតឡើងព្រោះបច្ច័យ ព្រោះយល់ថា ការកើតឡើងនៃវិតក្ក ព្រោះការកើតឡើងនៃតណ្ហា ព្រោះយល់ថា ការកើតឡើងនៃវិតក្ក ព្រោះការកើតឡើងនៃកម្ម ព្រោះយល់ថា ការកើតឡើងនៃវិតក្ក ព្រោះការកើតឡើងនៃសញ្ញា កាលភិក្ខុពិចារណាឃើញនូវលក្ខណៈនៃកំណើត ការកើតឡើងនៃវិតក្ក រមែងប្រាកដ ការកើតឡើងនៃវិតក្ក រមែងប្រាកដយ៉ាងនេះឯង ។

ការតាំងឡើងនៃវិតក្កដ៏ប្រាកដ តើដូចម្តេច ។ កាលភិក្ខុធ្វើទុកក្នុងចិត្តថា មិនទៀង ការតាំងឡើងថា អស់ទៅ រមែងប្រាកដ កាលភិក្ខុធ្វើទុកក្នុងចិត្តថា ជាទុក្ខ ការតាំងឡើងថា គួរខ្លាចរមែងប្រាកដ កាលភិក្ខុធ្វើទុកក្នុងចិត្តថា មិនមែនខ្លួន ការតាំងឡើងថា សូន្យរមែងប្រាកដ ការតាំងឡើងនៃវិតក្ក រមែងប្រាកដយ៉ាងនេះឯង ។

ការដល់នូវសេចក្តីវិនាសនៃវិតក្កដ៏ប្រាកដ តើដូចម្តេច ។ ការដល់នូវសេចក្តីវិនាសនៃវិតក្ករមែងប្រាកដ ដោយអត្ថថា រលត់បច្ច័យ ព្រោះយល់ថា ការរលត់វិតក្ក ព្រោះការរលត់អវិជ្ជា ការដល់នូវសេចក្តីវិនាសនៃវិតក្ក រមែងប្រាកដ ដោយអត្ថថា រលត់បច្ច័យ ព្រោះយល់ថា ការរលត់វិតក្ក ព្រោះការរលត់តណ្ហា ព្រោះយល់ថា ការរលត់វិតក្ក ព្រោះការរលត់កម្ម ព្រោះយល់ថា ការរលត់វិតក្ក ព្រោះការរលត់សញ្ញា កាលភិក្ខុពិចារណាឃើញនូវលក្ខណៈនៃការប្រែប្រួល ការដល់នូវសេចក្តីវិនាសនៃវិតក្ក រមែងប្រាកដ ការដល់នូវសេចក្តីវិនាសនៃវិតក្ក រមែងប្រាកដយ៉ាងនេះ វិតក្កដ៏ប្រាកដ រមែងកើតឡើង វិតក្កដ៏ប្រាកដ រមែងតាំងឡើង វិតក្កដ៏ប្រាកដ រមែងដល់នូវសេចក្តីវិនាសយ៉ាងនេះឯង ។

[ ១០៤ ] បុគ្គលកាលដឹងច្បាស់ នូវភាពនៃចិត្តមានអារម្មណ៍តែមួយដែលមិនរាយមាយ រមែងប្រមូលឥន្ទ្រិយទាំងឡាយ ដោយអំណាចនៃខ្យល់ដង្ហើមចេញ និងខ្យល់ដកដង្ហើមចូលវែង រមែងដឹងច្បាស់នូវគោចរផង រមែងចាក់ធ្លុះនូវអត្ថនៃការស្ងប់ផង ។បេ។ រមែងប្រមូលនូវធម៌ទាំងឡាយ រមែងដឹងច្បាស់

នូវគោចរផង រមែងចាក់ធ្លុះនូវអត្ថនៃការស្ងប់ផង ។

សំណួរត្រង់ពាក្យថា ប្រមូលនូវឥន្ទ្រិយទាំងឡាយ តើប្រមូលឥន្ទ្រិយទាំងឡាយដូចម្តេច ។ បុគ្គលប្រមូលនូវសទ្ធិន្ទ្រិយ ដោយអត្ថថា ជឿស៊ប់ ប្រមូលនូវវីរិយិន្ទ្រិយ ដោយអត្ថថា ផ្គងឡើង ប្រមូលនូវសតិន្ទ្រិយ ដោយអត្ថថា ប្រុងប្រយ័ត្ន ប្រមូលនូវសមាធិន្ទ្រិយ ដោយអត្ថថា មិនរាយមាយ ប្រមូលនូវបញ្ញិន្ទ្រិយ ដោយអត្ថថា ឃើញ បុគ្គលនេះ ឈ្មោះថា ប្រមូលនូវឥន្ទ្រិយទាំងឡាយនេះទុកក្នុងអារម្មណ៍នេះ ហេតុនោះ លោកពោលថា ប្រមូលនូវឥន្ទ្រិយទាំងឡាយ ដោយប្រការដូច្នេះ ។

ពាក្យថា ដឹងច្បាស់នូវគោចរ សេចក្តីថា បុគ្គលដឹងច្បាស់ថា ធម្មជាតណា ជាអារម្មណ៍នៃចិត្តនោះ ធម្មជាតនោះ ជាគោចរនៃចិត្តនោះ ធម្មជាតណា ជាគោចរនៃចិត្តនោះ ធម្មជាតនោះ ជាអារម្មណ៍ចិត្តនោះ ព្រោះហេតុនោះ ការដឹងច្បាស់ ឈ្មោះថា បញ្ញា ។

ពាក្យថា ការស្ងប់ គឺការតម្កល់អារម្មណ៍ ឈ្មោះថា ការស្ងប់ ការមិនរាយមាយ ចិត្ត ឈ្មោះថា ការស្ងប់ ការអធិដ្ឋានចិត្ត ឈ្មោះថា ការស្ងប់ សេចក្តីផូរផង់នៃចិត្ត ឈ្មោះថា ការស្ងប់ ។

អត្ថនៃការមិនមានទោស អត្ថនៃការមិនសៅហ្មង អត្ថនៃការផូរផង់ អត្ថនៃគុណក្រៃលែង ឈ្មោះថា អត្ថ ។

ពាក្យថា ចាក់ធ្លុះ គឺចាក់ធ្លុះនូវអត្ថនៃការតម្កល់មាំនូវអារម្មណ៍ ចាក់ធ្លុះនូវអត្ថនៃការមិនរាយមាយចិត្ត ចាក់ធ្លុះនូវអត្ថនៃការអធិដ្ឋានចិត្ត ចាក់ធ្លុះនូវអត្ថ

នៃការផ្សផង់ចិត្ត ហេតុនោះលោកពោលថា រមែងចាក់ចុះនូវអត្ថនៃការស្ងប់ ។

[ ១០៥ ] សំណួរត្រង់ពាក្យថា ប្រមូលមកនូវកម្លាំងទាំងឡាយ តើប្រមូលមកនូវកម្លាំងដូចម្ដេច ។ ប្រមូលមកនូវសទ្ធាពល ដោយអត្ថថា មិនកម្រើកព្រោះសេចក្ដីមិនជឿ ប្រមូលមកនូវវីរិយពល ដោយអត្ថថា មិនកម្រើកព្រោះសេចក្ដីខ្ជិល ប្រមូលមកនូវសតិពល ដោយអត្ថថា មិនកម្រើកព្រោះបមាទៈ ប្រមូលមកនូវសមាធិពល ដោយអត្ថថា មិនកម្រើកព្រោះឧទ្ធច្ចៈ ប្រមូលមកនូវបញ្ញាពល ដោយអត្ថថា មិនកម្រើកព្រោះអវិជ្ជា បុគ្គលនេះឈ្មោះថា ប្រមូលមកនូវកម្លាំងទាំងឡាយនេះទុកក្នុងអារម្មណ៍នេះ ហេតុនោះលោកពោលថា ប្រមូលមកនូវកម្លាំងទាំងឡាយ ដោយប្រការដូច្នេះ ។

ពាក្យថា រមែងដឹងច្បាស់នូវគោចរ ( អារម្មណ៍ ) ។បេ។ ហេតុនោះលោកពោលថា រមែងចាក់ចុះនូវអត្ថនៃការស្ងប់ ។

[ ១០៦ ] សំណួរត្រង់ពាក្យថា ប្រមូលមកនូវពោជ្ឈង្គទាំងឡាយ តើប្រមូលមកនូវពោជ្ឈង្គដូចម្ដេច ។ ប្រមូលមកនូវសតិសម្ពោជ្ឈង្គ ដោយអត្ថថា ប្រុងប្រយ័ត្ន ប្រមូលមកនូវធម្មវិចយសម្ពោជ្ឈង្គ ដោយអត្ថថា ឈ្វេចឈ្វីរក ប្រមូលមកនូវវីរិយសម្ពោជ្ឈង្គ ដោយអត្ថថា ផ្គងឡើង ប្រមូលមកនូវបីតិសម្ពោជ្ឈង្គ ដោយអត្ថថា ផ្សាយទៅ ប្រមូលមកនូវបស្សទ្ធិសម្ពោជ្ឈង្គ ដោយអត្ថថា ស្ងប់រម្ងាប់ ប្រមូលមកនូវសមាធិសម្ពោជ្ឈង្គ ដោយអត្ថថា មិនរាយមាយ ប្រមូលមកនូវឧបេក្ខាសម្ពោជ្ឈង្គ ដោយអត្ថថា ពិចារណាឃើញច្បាស់ បុគ្គលនេះ ឈ្មោះថា ប្រមូលមកនូវពោជ្ឈង្គទាំងឡាយនេះ ទុកក្នុងអារម្មណ៍នេះ

ហេតុនោះ លោកពោលថា ប្រមូលមកនូវពោជ្ឈង្គទាំងឡាយ ដោយប្រការដូច្នេះ ។

ពាក្យថា រមែងដឹងច្បាស់នូវគោចរ ( អារម្មណ៍ ) ។បេ។ ហេតុនោះ លោកពោលថា រមែងចាក់ធ្លុះនូវអត្ថនៃការស្ងប់ ។

[ ១០៧ ] សំណួរត្រង់ពាក្យថា ប្រមូលមកនូវមគ្គ តើប្រមូលមកនូវមគ្គដូចម្ដេច ។ ប្រមូលមកនូវសម្មាទិដ្ឋិ ដោយអត្ថថា ឃើញ ប្រមូលមកនូវសម្មាសង្កប្ប ដោយអត្ថថា លើកចិត្តឡើងកាន់អារម្មណ៍ ប្រមូលមកនូវសម្មាវាចា ដោយអត្ថថា រក្សាទុក ប្រមូលមកនូវសម្មាកម្មន្តៈ ដោយអត្ថថា តាំងឡើងដោយប្រពៃ ប្រមូលមកនូវសម្មាអាជីវៈ ដោយអត្ថថា ផូរផង់ ប្រមូលមកនូវសម្មាវាយាមៈ ដោយអត្ថថា ផ្គងឡើង ប្រមូលមកនូវសម្មាសតិ ដោយអត្ថថា ប្រុងប្រយ័ត្ន ប្រមូលមកនូវសម្មាសមាធិ ដោយអត្ថថា មិនរាយមាយ បុគ្គលនេះ ឈ្មោះថា ប្រមូលមកនូវមគ្គនេះ ទុកក្នុងអារម្មណ៍នេះ ហេតុនោះ លោកពោលថា ប្រមូលមកនូវមគ្គ ដោយប្រការដូច្នេះ ។

ពាក្យថា រមែងដឹងច្បាស់នូវគោចរ ( អារម្មណ៍ ) ។បេ។ ហេតុនោះ លោកពោលថា រមែងចាក់ធ្លុះនូវអត្ថនៃការស្ងប់ ។

[ ១០៨ ] សំណួរត្រង់ពាក្យថា ប្រមូលមកនូវធម៌ទាំងឡាយ តើប្រមូលមកនូវធម៌ដូចម្ដេច ។ ប្រមូលមកនូវឥន្ទ្រិយទាំងឡាយ ដោយអត្ថថា ជាធំ ប្រមូលមកនូវពលទាំងឡាយ ដោយអត្ថថា មិនកម្រើក ប្រមូលមកនូវពោជ្ឈង្គទាំងឡាយ ដោយអត្ថថា ចេញទៅ ( ចាកធម៌ជាសត្រូវ ) ប្រមូល

មកនូវមគ្គ ដោយអត្ថថា ជាហេតុ ប្រមូលមកនូវសតិប្បដ្ឋាន ដោយអត្ថថា ប្រុងប្រយ័ត្ន ប្រមូលមកនូវសម្មប្បធាន ដោយអត្ថថា តម្កល់មាំ ប្រមូលមកនូវឥទ្ធិបាទ ដោយអត្ថថា សម្រេច ប្រមូលមកនូវសច្ចៈ ដោយអត្ថថា ពិត ប្រមូលមកនូវសមថៈ ដោយអត្ថថា មិនរាយមាយ ប្រមូលមកនូវវិបស្សនា ដោយអត្ថថា ពិចារណាឃើញរឿយៗ ប្រមូលមកនូវសមថៈ និងវិបស្សនា ដោយអត្ថថា មានរសតែមួយ ប្រមូលមកនូវធម៌ ដែលជាប់គ្នាជាគូ ដោយអត្ថថា មិនកន្លងគ្នា ប្រមូលមកនូវសីលវិសុទ្ធិ ដោយអត្ថថា សង្រួម ប្រមូលមកនូវចិត្តវិសុទ្ធិ ដោយអត្ថថា មិនរាយមាយ ប្រមូលមកនូវទិដ្ឋិវិសុទ្ធិ ដោយអត្ថថា ឃើញ ប្រមូលមកនូវវិមោក្ខ ដោយអត្ថថា រួច ប្រមូលមកនូវវិជ្ជា ដោយអត្ថថា ចាក់ធ្លុះ ប្រមូលមកនូវវិមុត្តិ ដោយអត្ថថា លះស្រឡះ ប្រមូលមកនូវខយញ្ញាណ ដោយអត្ថថា ផ្តាច់បង់ ប្រមូលមកនូវអនុប្បាទញ្ញាណ ដោយអត្ថថា ស្ងប់ ប្រមូលមកនូវឆន្ទៈ ដោយអត្ថថា ជាឫសគល់ ប្រមូលមកនូវមនសិការ ដោយអត្ថថា តាំងឡើងព្រម ប្រមូលមកនូវផស្សៈ ដោយអត្ថថា ប្រមូលមក ( នូវអារម្មណ៍ ) ប្រមូលមកនូវវេទនា ដោយអត្ថថា ប្រជុំចុះ ប្រមូលមកនូវសមាធិ ដោយអត្ថថា ជាប្រធាន ប្រមូលមកនូវសតិ ដោយអត្ថថា ជាធំ ប្រមូលមកនូវសតិសម្បជញ្ញៈ ដោយអត្ថថា ប្រសើរជាងធម៌នោះ ប្រមូលមកនូវវិមុត្តិ ដោយអត្ថថា ជាខ្លឹម ប្រមូលមកនូវនិព្វានឈ្មោះអមតៈ ( ជាទីពឹងរបស់សត្វ ) ដោយអត្ថថា ជាទីបំផុត ( នៃកិច្ចក្នុងសាសនា ) បុគ្គលនោះ ឈ្មោះថា ប្រមូលមកនូវធម៌ទាំងឡាយនេះ ទុកក្នុងអារម្មណ៍នេះ

ហេតុនោះលោកពោលថា ប្រមូលមក នូវធម៌ទាំងឡាយដោយប្រការដូច្នេះ ។

ពាក្យថា រមែងដឹងច្បាស់នូវគោចរ សេចក្តីថា បុគ្គលតែងដឹងច្បាស់ថា ធម្មជាតណាជាអារម្មណ៍នៃចិត្តនោះ ធម្មជាតនោះ ជាគោចរនៃចិត្តនោះ ធម្មជាតណា ជាគោចរនៃចិត្តនោះ ធម្មជាតនោះ ជាអារម្មណ៍នៃចិត្តនោះ ព្រោះហេតុ នោះការដឹងច្បាស់ឈ្មោះថា បញ្ញា ។

ពាក្យថា ការស្ងប់ គឺការតម្កល់ទុកនូវអារម្មណ៍ ឈ្មោះថា ការស្ងប់ ការមិនរាយមាយនៃចិត្ត ឈ្មោះថា ការស្ងប់ ការអធិដ្ឋានចិត្ត ឈ្មោះថា ការស្ងប់ ការផូរផង់នៃចិត្ត ឈ្មោះថា ការស្ងប់ ។

អត្ថនៃការមិនមានទោស អត្ថនៃការមិនមានកិលេស អត្ថនៃការផូរផង់ អត្ថនៃគុណដ៏ក្រៃលែង ឈ្មោះថា អត្ថ ។

ពាក្យថា ចាក់ធ្លុះ គឺចាក់ធ្លុះនូវអត្ថនៃការតម្កល់មាំនូវអារម្មណ៍ ចាក់ធ្លុះនូវអត្ថនៃការមិនរាយមាយចិត្ត ចាក់ធ្លុះនូវអត្ថនៃការអធិដ្ឋានចិត្ត ចាក់ធ្លុះនូវអត្ថនៃការផូរផង់ចិត្ត ហេតុនោះ លោកពោលថា ចាក់ធ្លុះនូវអត្ថនៃការស្ងប់ ។

[ ១០៩ ] បុគ្គលកាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញវែង កាលដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលវែង តើដូចម្តេច ។ បុគ្គលដកចេញនូវដង្ហើមចេញវែង ក្នុងចំណែកកាលវែង ដកចូលនូវដង្ហើមចូលវែង ក្នុងចំណែកកាលវែង ដកចេញក្តី ដកចូលក្តីនូវដង្ហើមចេញ ឬដង្ហើមចូលវែង ក្នុងចំណែកកាលវែង កាលបុគ្គលដកចេញក្តី ដកចូលក្តីនូវដង្ហើមចេញ ឬដង្ហើមចូលវែង ក្នុងចំណែកកាលវែង ( ច្រើនដង ) ឆន្ទៈ ( ចំណង់

ក្នុងអ្វីមួយ ) រមែងកើតឡើង បុគ្គលដកចេញនូវដង្ហើមចេញវី្វ ល្អិតក្រៃលែងជាងនោះ ក្នុងចំណែកកាលវី្វ ដោយអំណាចឆន្ទៈ ដកចូលនូវដង្ហើមចូលវី្វ ល្អិតក្រៃលែងជាងនោះ ក្នុងចំណែកកាលវី្វ ដោយអំណាចឆន្ទៈ ដកចេញក្តី ដកចូលក្តី នូវដង្ហើមចេញ ឬដង្ហើមចូលវី្វ ល្អិតក្រៃលែងជាងនោះ ក្នុងចំណែកកាលវី្វ ដោយអំណាចឆន្ទៈ កាលបុគ្គលដកចេញក្តី ដកចូលក្តី នូវដង្ហើមចេញ ឬដង្ហើមចូលវី្វ ល្អិតក្រៃលែងជាងនោះ ក្នុងចំណែកកាលវី្វ ដោយអំណាចឆន្ទៈ ( ច្រើនដង ) បាមុជ្ជរមែងកើតឡើង បុគ្គលដកចេញ នូវដង្ហើមចេញវី្វ ល្អិតក្រៃលែងជាងនោះ ក្នុងចំណែកកាលវី្វ ដោយអំណាចបាមុជ្ជ ដកចូលនូវដង្ហើមចូលវី្វ ល្អិតក្រៃលែងជាងនោះ ក្នុងចំណែកកាលវី្វ ដោយអំណាចបាមុជ្ជ ដកចេញក្តី ដកចូលក្តី នូវដង្ហើមចេញ ឬដង្ហើមចូលវី្វ ល្អិតក្រៃលែងជាងនោះ ក្នុងចំណែកកាលវី្វ ដោយអំណាចបាមុជ្ជ កាលបុគ្គលដកចេញក្តី ដកចូលក្តី នូវដង្ហើមចេញ ឬដង្ហើមចូលវី្វ ល្អិតក្រៃលែងជាងនោះ ក្នុងចំណែកកាលវី្វ ដោយអំណាចបាមុជ្ជ ( ច្រើនដង ) ចិត្តក៏ឃ្លាតចេញអំពីដង្ហើមចេញ ឬដង្ហើមចូលវី្វ ឧបេក្ខាក៏តាំងនៅស៊ប់ កាយ គឺដង្ហើមចេញនិងដង្ហើមចូលវី្វ ដោយអាការ ៩ នេះ ឈ្មោះថា ឧបដ្ឋាន សតិ ឈ្មោះថា អនុបស្សនាញាណ កាយ ឈ្មោះថា ឧបដ្ឋាន មិនមែនឈ្មោះថាសតិទេ ចំណែកខាងសតិ ឈ្មោះថា ឧបដ្ឋានផង ឈ្មោះថា សតិផង បុគ្គលរមែងពិចារណាឃើញនូវកាយនោះ ដោយសតិនោះ ដោយញាណនោះ ហេតុនោះ លោកពោលថា កាយេកាយានុបស្សនាសតិប្បដ្ឋានភាវនា ដោយប្រការដូច្នេះ ។

[ ១១០ ] ពាក្យថា ពិចារណាឃើញ តើពិចារណាឃើញនូវកាយនោះដូចម្តេច ។បេ។ បុគ្គលពិចារណាឃើញនូវកាយនោះ យ៉ាងនេះឯង ។

ពាក្យថា ភាវនា បានដល់ ភាវនា ៤ យ៉ាង ។បេ។ ភាវនា ដោយអត្ថថា សេព កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្ត មានអារម្មណ៍មូលតែមួយ ដែលមិនរាយមាយដោយអំណាចនៃដង្ហើមចេញ ឬដង្ហើមចូលវែង ភាវនាទាំងឡាយដែលប្រាកដ រមែងកើតឡើង ។បេ។ កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្ត មានអារម្មណ៍មូលតែមួយ ដែលមិនរាយមាយដោយអំណាចនៃដង្ហើមចេញ ឬដង្ហើមចូលវែង ឈ្មោះថា ប្រមូលមកនូវឥន្ទ្រិយទាំងឡាយ ។បេ។ ហេតុនោះ លោកពោលថា ចាក់ធ្លុះនូវអត្ថនៃការស្ងប់ ។

[ ១១១ ] បុគ្គលសិក្សាថា អាត្មាអញកំណត់ដឹងនូវកាយ គឺដង្ហើមចេញទាំងពួង ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញកំណត់ដឹងនូវកាយ គឺដង្ហើមចូលទាំងពួង ទើបដកដង្ហើមចូល តើដូចម្តេច ។

ពាក្យថា កាយ បានដល់ កាយ ២ យ៉ាង គឺនាមកាយ ១ រូបកាយ ១ នាមកាយ តើដូចម្តេច ។ វេទនា សញ្ញា ចេតនា ផស្សៈ មនសិការ ឈ្មោះថា នាមផង ឈ្មោះថា នាមកាយផង មួយទៀត ពួកធម៌ណា ដែលលោកពោលថា ចិត្តសង្ខារ នេះឈ្មោះថា នាមកាយ ។ រូបកាយ តើដូចម្តេច ។ មហាភូតរូប ៤ ផង ឧបាទាយរូបរបស់មហាភូតរូប ៤ ផង ដង្ហើមចេញផង ដង្ហើមចូលផង និមិត្តផង ជាឧបនិពន្ធ ( ជាប់គ្នា ) ( ឈ្មោះថា រូបកាយ ) មួយទៀត ពួកធម៌ណា ដែលលោកពោលថា កាយសង្ខារ នេះ

ឈ្មោះថា រូបកាយ ។

[ ១១២ ] កាយទាំងឡាយនោះ ដែលបុគ្គលដឹងច្បាស់ហើយ តើដូចម្ដេច ។ កាលបុគ្គលដឹងនូវភាពនៃចិត្ត មានអារម្មណ៍មូលតែមួយ ដែលមិនរាយមាយ សតិក៏ប្រុងទុកហើយដោយអំណាចនៃដង្ហើមចេញវែង កាយទាំងនោះ ឈ្មោះថា បុគ្គលដឹងច្បាស់ហើយដោយសតិនោះ ដោយញាណនោះ កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្តមានអារម្មណ៍មូលតែមួយ ដែលមិនរាយមាយ សតិក៏ប្រុងទុកហើយ ដោយអំណាចនៃដង្ហើមចូលវែង កាយទាំងឡាយនោះ ឈ្មោះថា បុគ្គលដឹងច្បាស់ហើយដោយសតិនោះ ដោយញាណនោះ កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្តមានអារម្មណ៍មូលតែមួយ ដែលមិនរាយមាយ សតិក៏ប្រុងទុកហើយដោយអំណាចនៃដង្ហើមចេញខ្លី កាយទាំងឡាយនោះ ឈ្មោះថា បុគ្គលដឹងច្បាស់ហើយដោយសតិនោះ ដោយញាណនោះ កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្តមានអារម្មណ៍មូលតែមួយ ដែលមិនរាយមាយ សតិក៏ប្រុងទុកហើយដោយអំណាចនៃដង្ហើមចូលខ្លី កាយទាំងឡាយនោះ ឈ្មោះថា បុគ្គលដឹងច្បាស់ហើយដោយសតិនោះ ដោយញាណនោះ កាលបុគ្គលរំពឹងកាយទាំងឡាយនោះឈ្មោះថា គេដឹងច្បាស់ហើយ កាលបុគ្គលដឹងកាយទាំងឡាយនោះ ឈ្មោះថា គេដឹងច្បាស់ហើយ កាលបុគ្គលឃើញ កាយទាំងឡាយនោះ ឈ្មោះថា គេដឹងច្បាស់ហើយ កាលបុគ្គលពិចារណាកាយទាំងឡាយនោះ ឈ្មោះថា គេដឹងច្បាស់ហើយ កាលបុគ្គលអធិដ្ឋានចិត្ត កាយទាំងឡាយនោះ ឈ្មោះថា គេដឹងច្បាស់ហើយ កាលបុគ្គលជឿស៊ប់ដោយសទ្ធា កាយទាំងឡាយនោះ

ឈ្មោះថា គេដឹងច្បាស់ហើយ កាលបុគ្គលផ្គងព្យាយាម កាយទាំងឡាយនោះ ឈ្មោះថា គេដឹងច្បាស់ហើយ កាលបុគ្គលតម្កល់សតិ កាយទាំងឡាយនោះ ឈ្មោះថា គេដឹងច្បាស់ហើយ កាលបុគ្គលតម្កល់ចិត្ត កាយទាំងឡាយនោះ ឈ្មោះថា គេដឹងច្បាស់ហើយ កាលបុគ្គលដឹងច្បាស់ដោយប្រាជ្ញា កាយទាំងឡាយនោះ ឈ្មោះថា គេដឹងច្បាស់ហើយ កាលបុគ្គលត្រាស់ដឹងនូវធម៌ដែលគួរត្រាស់ដឹង កាយទាំងឡាយនោះ ឈ្មោះថា គេដឹងច្បាស់ហើយ កាលបុគ្គលកំណត់ដឹងនូវធម៌ ដែលគួរកំណត់ដឹង កាយទាំងឡាយនោះ ឈ្មោះថា គេដឹងច្បាស់ហើយ កាលបុគ្គលលះបង់នូវធម៌ដែលគួរលះបង់ កាយទាំងឡាយនោះ ឈ្មោះថា គេដឹងច្បាស់ហើយ កាលបុគ្គលចម្រើននូវធម៌ដែលគួរចម្រើន កាយទាំងឡាយនោះ ឈ្មោះថា គេដឹងច្បាស់ហើយ កាលបុគ្គលធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ កាយទាំងឡាយនោះ ឈ្មោះថា គេដឹងច្បាស់ហើយ កាយទាំងឡាយនោះ ដែលបុគ្គលដឹងច្បាស់ហើយយ៉ាងនេះឯង កាយ គឺដង្ហើមចេញ និងដង្ហើមចូលសម្រាប់អ្នកកំណត់ដឹងនូវកាយទាំងពួង ឈ្មោះថា ឧបដ្ឋានសតិ ឈ្មោះថា អនុបស្សនាញាណ កាយ ឈ្មោះថា ឧបដ្ឋាន មិនឈ្មោះថាសតិទេ ចំណែកខាងសតិ ទើបឈ្មោះថា ឧបដ្ឋានផង ឈ្មោះថា សតិផង បុគ្គលពិចារណាឃើញនូវកាយនោះ ដោយសតិនោះ ដោយញាណនោះ ហេតុនោះ លោកពោលថា កាយេកាយានុបស្សនាសតិប្បដ្ឋានភាវនា ដោយប្រការដូច្នេះ ។

[ ១១៣ ] ពាក្យថា ពិចារណាឃើញ ។បេ។ ខ្យល់ដង្ហើមចេញ និងខ្យល់

ដង្ហើមចូលនៃបុគ្គលអ្នកកំណត់ដឹងនូវកាយទាំងពួង ឈ្មោះថា សីលវិសុទ្ធិ ដោយអត្ថថា សង្រួម ឈ្មោះថា ចិត្តវិសុទ្ធិ ដោយអត្ថថា មិនរាយមាយ ឈ្មោះថា ទិដ្ឋិវិសុទ្ធិ ដោយអត្ថថា ឃើញ បណ្ដាធម៌ទាំងនោះ ធម៌ណា មាន អត្ថថា សង្រួម ធម៌នេះ ឈ្មោះថា អធិសីលសិក្ខា បណ្ដាធម៌ទាំងនោះ ធម៌ ណា មានអត្ថថា មិនរាយមាយ ធម៌នេះ ឈ្មោះថា អធិចិត្តសិក្ខា បណ្ដា ធម៌ទាំងនោះ ធម៌ណា មានអត្ថថា ឃើញ ធម៌នេះ ឈ្មោះថា អធិប្បញ្ញាសិក្ខា បុគ្គលកាលរំពឹងនូវសិក្ខាទាំង ៣ នេះ ឈ្មោះថា សិក្សា កាលដឹង ឈ្មោះ ថា សិក្សា កាលឃើញ ឈ្មោះថា សិក្សា កាលពិចារណា ឈ្មោះថា សិក្សា កាលអធិដ្ឋានចិត្ត ឈ្មោះថា សិក្សា កាលជឿស៊ប់ដោយសទ្ធា ឈ្មោះថា សិក្សា កាលផ្គងនូវវីរិយៈ ឈ្មោះថា សិក្សា កាលប្រុងសតិ ឈ្មោះ ថា សិក្សា កាលតម្កល់ចិត្ត ឈ្មោះថា សិក្សា កាលដឹងច្បាស់ដោយប្រាជ្ញា ឈ្មោះថា សិក្សា កាលត្រាស់ដឹងធម៌ដែលគួរត្រាស់ដឹង ឈ្មោះថា សិក្សា កាលកំណត់ដឹងនូវធម៌ដែលគួរកំណត់ដឹង ឈ្មោះថា សិក្សា កាលលះនូវធម៌ ដែលគួរលះ ឈ្មោះថា សិក្សា កាលចម្រើននូវធម៌ដែលគួរចម្រើន ឈ្មោះ ថា សិក្សា កាលធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ឈ្មោះថា សិក្សា កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្ត មានអារម្មណ៍តែមួយ ដែលមិន រាយមាយ ដោយអំណាចនៃដង្ហើមចេញ និងដង្ហើមចូល សម្រាប់អ្នកកំណត់ ដឹងនូវកាយទាំងពួង វេទនាទាំងឡាយដែលប្រាកដ រមែងកើតឡើង ។បេ។ បុគ្គលកាលដឹងច្បាស់នូវភាពនៃចិត្ត មានអារម្មណ៍តែមួយ ដែលមិនរាយមាយ

ដោយអំណាចនៃដង្ហើមចេញ និងដង្ហើមចូល សម្រាប់អ្នកកំណត់ដឹងនូវកាយទាំងពួង រមែងប្រមូលមកនូវឥន្ទ្រិយទាំងឡាយ ។បេ។ ហេតុនោះ លោកពោលថា រមែងចាក់ធ្លុះនូវអត្ថនៃការស្ងប់ ។

[ ១១៤ ] បុគ្គលសិក្សាថា អាត្មាអញកាលរម្ងាប់នូវកាយសង្ខារ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញ កាលរម្ងាប់នូវកាយសង្ខារ ទើបដកដង្ហើមចូល តើដូចម្តេច ។

កាយសង្ខារ តើដូចម្តេច ។ ពួកខ្យល់ដង្ហើមចេញវែង ដែលប្រព្រឹត្តទៅក្នុងកាយ ធម៌ទាំងនេះជាប់ដោយកាយ ឈ្មោះថា កាយសង្ខារ បុគ្គលកាលរម្ងាប់ រម្ងត់ បង្ក្រាបនូវកាយសង្ខារទាំងនោះ ឈ្មោះថា សិក្សា ពួកខ្យល់ដង្ហើមចូលវែង ដែលប្រព្រឹត្តទៅក្នុងកាយ ធម៌ទាំងនេះជាប់ដោយកាយ ឈ្មោះថា កាយសង្ខារ បុគ្គលកាលរម្ងាប់ រម្ងត់ បង្ក្រាបនូវកាយសង្ខារទាំងនោះ ឈ្មោះថា សិក្សា ពួកខ្យល់ដង្ហើមចេញខ្លី ដង្ហើមចូលខ្លី ឬដង្ហើមចេញ សម្រាប់បុគ្គលអ្នកកំណត់ដឹងនូវកាយទាំងពួង ដែលប្រព្រឹត្តទៅក្នុងកាយ ធម៌ទាំងនេះជាប់ដោយកាយ ឈ្មោះថា កាយសង្ខារ បុគ្គលកាលរម្ងាប់ រម្ងត់ បង្ក្រាបនូវកាយសង្ខារទាំងនោះ ឈ្មោះថា សិក្សា ការឱន ការងោក ការទម្រេត ការឈម ការរញ្ជួយ ការអន្ទះសា ការកម្រើក ការញាប់ញ័រណានៃកាយដោយកាយសង្ខារទាំងឡាយ មានសភាពយ៉ាងណា បុគ្គលសិក្សាថា អាត្មាអញកាលរម្ងាប់នូវកាយសង្ខារ មានសភាពយ៉ាងនោះ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញ កាលរម្ងាប់នូវកាយសង្ខារ ទើបដកដង្ហើមចូល ការមិនឱន

ការមិនឆាក ការមិនទម្រេត ការមិនឈម ការមិនរញ្ជួយ ការមិនអន្ទះសា ការមិនកម្រើក ការមិនញាប់ញ័រណានៃកាយ ដោយកាយសង្ខារទាំងឡាយ មានសភាពយ៉ាងណា បុគ្គលសិក្សាថា អាត្មាអញ កាលរម្ងាប់នូវកាយសង្ខារ ដ៏ល្អិតសុខុម មានសភាពយ៉ាងនោះ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញ កាលរម្ងាប់នូវកាយសង្ខារ ទើបដកដង្ហើមចូល បានឮថា បុគ្គលសិក្សាថា អាត្មាអញ កាលរម្ងាប់នូវកាយសង្ខារ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញ កាលរម្ងាប់នូវកាយសង្ខារ ទើបដកដង្ហើមចូល ដោយអាការយ៉ាងនេះហើយ កាលបើយ៉ាងនេះ ការប្រាកដនៃការបាននូវខ្យល់មិនទាន់មាន ការប្រាកដនៃដង្ហើមចេញ និងដង្ហើមចូល ក៏មិនទាន់មាន ការប្រាកដនៃអានាបានស្សតិក៏មិនទាន់មាន ទាំងការប្រាកដនៃអានាបានស្សតិសមាធិ ក៏មិនទាន់មានទេ បណ្ឌិតទាំងឡាយរមែងមិនចូលកាន់សមាបត្តិនោះផង មិនចេញចាកសមាបត្តិនោះផង ឮថា បុគ្គលសិក្សាថា អាត្មាអញ កាលរម្ងាប់នូវកាយ-សង្ខារ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញ កាលរម្ងាប់នូវកាយសង្ខារ ទើបដកដង្ហើមចូល ដោយអាការយ៉ាងនេះហើយ កាលបើយ៉ាងនេះ ការប្រាកដនៃការបាននូវខ្យល់ក៏មាន ការប្រាកដនៃខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលក៏មាន ការប្រាកដនៃអានាបានស្សតិក៏មាន ទាំងការប្រាកដនៃអានាបានស្សតិសមាធិក៏មាន ទើបបណ្ឌិតទាំងឡាយ ចូលកាន់សមាបត្តិនោះផង ចេញចាកសមាបត្តិនោះផង ដំណើរនោះ ប្រៀបដូចជាអ្វី ប្រៀបដូចជារគាំងដែលគេគោះ សំឡេងគ្រោតគ្រាត រមែងប្រព្រឹត្តទៅជាដំបូង ព្រោះបុគ្គល

កាន់យកល្អ ព្រោះធ្វើទុកក្នុងចិត្តល្អ ព្រោះចាំទុកល្អនូវនិមិត្តនៃសំឡេងដ៏គ្រោតគ្រាត កាលបើសំឡេងគ្រោតគ្រាតរលត់ហើយ បន្ទាប់មក សំឡេងដ៏ល្អិត រមែងប្រព្រឹត្តទៅជាខាងក្រោយ ព្រោះបុគ្គលកាន់យកល្អ ព្រោះធ្វើទុកក្នុងចិត្តល្អ ព្រោះចាំទុកល្អនូវនិមិត្តនៃសំឡេងដ៏ល្អិត កាលសំឡេងដ៏ល្អិតរលត់ហើយ បន្ទាប់មក ចិត្តក៏រមែងប្រព្រឹត្តទៅជាខាងក្រោយ ព្រោះចិត្ត មាននិមិត្តដ៏ល្អិតជាអារម្មណ៍ មានឧបមាដូចម្តេចមិញ មានឧបមេយ្យ ដូចជាខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលដ៏គ្រោតគ្រាត រមែងប្រព្រឹត្តទៅជាដំបូង ព្រោះបុគ្គលកាន់យកល្អ ព្រោះធ្វើទុកក្នុងចិត្តល្អ ព្រោះចាំទុកល្អនូវនិមិត្តនៃខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលដ៏គ្រោតគ្រាត កាលបើខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលដ៏គ្រោតគ្រាតរលត់ហើយ បន្ទាប់មក ខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលដ៏ល្អិត រមែងប្រព្រឹត្តទៅជាខាងក្រោយ ព្រោះបុគ្គលកាន់យកល្អ ព្រោះធ្វើទុកក្នុងចិត្តល្អ ព្រោះចាំទុកល្អនូវនិមិត្តនៃខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលដ៏ល្អិត កាលបើខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលដ៏ល្អិតរលត់ហើយ បន្ទាប់មក ចិត្តក៏មិនដល់នូវសេចក្តីរាយមាយក្នុងកាលខាងក្រោយ ព្រោះចិត្តយកនិមិត្តនៃខ្យល់ដង្ហើមចេញ និងដង្ហើមចូលដ៏ល្អិត ជាអារម្មណ៍ ក៏យ៉ាងនោះដែរ កាលបើយ៉ាងនេះ ការប្រាកដនៃការបាននូវខ្យល់ក៏មានការប្រាកដនៃខ្យល់ដង្ហើមចេញ និងដង្ហើមចូលក៏មាន ការប្រាកដនៃអានាបានស្សតិក៏មាន ការប្រាកដនៃអានាបានស្សតិសមាធិក៏មាន បណ្ឌិតទាំងឡាយ រមែងចូលកាន់សមាបត្តិនោះផង រមែងចេញចាកសមាបត្តិនោះផង កាយ គឺខ្យល់

ដង្ហើមចេញ និងដង្ហើមចូលរបស់បុគ្គល កាលរម្ងាប់នូវកាយសង្ខារ ឈ្មោះថា ឧបដ្ឋាន សតិ ឈ្មោះថា អនុបស្សនាញាណ កាយ ឈ្មោះថា ឧបដ្ឋាន មិនឈ្មោះថាសតិទេ ចំណែកខាងសតិ ទើបឈ្មោះថា ឧបដ្ឋានផង ឈ្មោះថាសតិផង បុគ្គលរមែងពិចារណាឃើញនូវកាយនោះ ដោយសតិ ដោយញាណនោះ ហេតុនោះ លោកពោលថា កាយេកាយានុបស្សនាសតិប្បដ្ឋានភាវនា ។

[ ១១៥ ] សំណួរត្រង់ពាក្យថា ពិចារណាឃើញ តើបុគ្គលពិចារណាឃើញនូវកាយនោះដូចម្ដេច ។បេ។ បុគ្គលពិចារណាឃើញនូវកាយនោះយ៉ាងនេះឯង ។

ពាក្យថា ភាវនា បានដល់ ភាវនា ៤ យ៉ាង ។បេ។ ឈ្មោះថា ភាវនា ដោយអត្ថថា សេព ។ ការដកដង្ហើមចេញ និងដកដង្ហើមចូលរបស់បុគ្គល កាលរម្ងាប់នូវកាយសង្ខារ ឈ្មោះថា សីលវិសុទ្ធិ ដោយអត្ថថា សង្រួម ឈ្មោះថា ចិត្តវិសុទ្ធិ ដោយអត្ថថា មិនរាយមាយ ឈ្មោះថា ទិដ្ឋិវិសុទ្ធិ ដោយអត្ថថា ឃើញ បណ្ដាធម៌ទាំងនោះ ធម៌ណា មានអត្ថថា សង្រួម ធម៌នេះឈ្មោះថា អធិសីលសិក្ខា បណ្ដាធម៌ទាំងនោះ ធម៌ណា មានអត្ថថា មិនរាយមាយ ធម៌នេះ ឈ្មោះថា អធិចិត្តសិក្ខា បណ្ដាធម៌ទាំងនោះ ធម៌ណា មានអត្ថថា ឃើញ ធម៌នេះ ឈ្មោះថា អធិប្បញ្ញាសិក្ខា បុគ្គលកាលរំពឹងឃើញនូវសិក្ខាទាំង ៣ នេះ ឈ្មោះថា សិក្សា ។បេ។ បុគ្គលកាលធ្វើឲ្យជាក់ច្បាស់នូវធម៌ ដែលគួរធ្វើឲ្យជាក់ច្បាស់ ឈ្មោះថា សិក្សា កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្ត មានអារម្មណ៍តែមួយ ដែលមិនរាយមាយដោយ

អំណាចនៃខ្យល់ដង្ហើមចេញ និងដង្ហើមចូល របស់អ្នកកាលរម្ងាប់នូវកាយ-សង្ខារ វេទនាទាំងឡាយដែលប្រាកដ រមែងកើតឡើង ។បេ។ បុគ្គលកាលដឹងច្បាស់នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលរបស់អ្នក កាលរម្ងាប់នូវកាយសង្ខារ ឈ្មោះថា ប្រមូលមកនូវឥន្ទ្រិយទាំងឡាយ ។បេ។ ហេតុនោះ លោកពោលថា ចាក់ធ្លុះនូវអត្ថនៃការស្ងប់ អនុបស្សនាញាណ ៨ ឧបដ្ឋានានុបស្សតិ ៨ និងសុត្តន្តិកវត្ថុ ៤ ( រមែងមាន ) ក្នុងកាយេកាយានុបស្សនា ។

## ភាណវារៈ ចប់

[ ១១៦ ] បុគ្គលសិក្សាថា អាត្មាអញ ជាអ្នកកំណត់ដឹងច្បាស់នូវបីតទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញ ជាអ្នកកំណត់ដឹងច្បាស់នូវបីតិទើបដកដង្ហើមចូល តើដូចម្តេច ។

បីតិ តើដូចម្តេច កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្ត មានអារម្មណ៍តែមួយ ដែលមិនរាយមាយដោយអំណាចនៃដង្ហើមចេញវែង បីតិ និងបាមុជ្ជរមែងកើតឡើង ។បេ។ កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្ត មានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចូលវែង បីតិ និងបាមុជ្ជរមែងកើតឡើង ។បេ។ កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញខ្លី ដោយអំណាចនៃដង្ហើមចូលខ្លី ដោយអំណាចនៃដង្ហើមចេញ របស់អ្នកកំណត់ដឹងនូវកាយទាំងពួង ដោយអំណាចនៃដង្ហើមចូល របស់អ្នកកំណត់ដឹងនូវកាយទាំងពួង

ដោយអំណាចនៃដង្ហើមចេញរបស់អ្នក កាលរម្ងាប់នូវកាយសង្ខារ ដោយអំណាចនៃដង្ហើមចូលរបស់អ្នក កាលរម្ងាប់នូវកាយសង្ខារ បីតិ និងបាមុជ្ជ គឺធម្មជាតជាគ្រឿងរីករាយ និងរីករាយខ្លាំង ការត្រេកអរ ត្រេកអរខ្លាំង ការស្រស់ស្រាយ ស្រស់ស្រាយខ្លាំង ភាពនៃចិត្តខ្ពស់ឡើង ភាពនៃចិត្តសប្បាយរមែងកើតឡើង នេះឈ្មោះថា បីតិដែលបុគ្គលដឹងច្បាស់ហើយ កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយដោយអំណាចនៃដង្ហើមចេញវែង សតិក៏តម្កល់មាំ បីតិនោះ ឈ្មោះថា បុគ្គលដឹងច្បាស់ហើយដោយសតិនោះ ដោយញាណនោះ កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្ត មានអារម្មណ៍តែមួយ ដែលមិនរាយមាយដោយអំណាចនៃដង្ហើមចូលវែង សតិក៏តម្កល់មាំ បីតិនោះ ឈ្មោះថា បុគ្គលដឹងច្បាស់ហើយដោយសតិនោះ ដោយញាណនោះ កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្ត មានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញខ្លី ដោយអំណាចនៃដង្ហើមចូលខ្លី ដោយអំណាចនៃដង្ហើមចេញរបស់អ្នកកំណត់ដឹងនូវកាយទាំងពួង ដោយអំណាចនៃដង្ហើមចេញរបស់អ្នក កាលរម្ងាប់នូវកាយសង្ខារ ដោយអំណាចនៃដង្ហើមចូលរបស់អ្នក កាលរម្ងាប់នូវកាយសង្ខារ សតិក៏តម្កល់មាំ បីតិនោះ ឈ្មោះថា បុគ្គលដឹងច្បាស់ហើយដោយសតិនោះ ដោយញាណនោះ កាលបុគ្គលរំពឹងបីតិនោះ ឈ្មោះថា គេដឹងច្បាស់ហើយ កាលបុគ្គលដឹង ... កាលឃើញ កាលពិចារណា កាលអធិដ្ឋាននូវចិត្ត កាលជឿស៊ប់ដោយសទ្ធា កាលផ្គងនូវវីរិយៈ កាលប្រុងនូវសតិ កាលតម្កល់នូវ

ចិត្ត កាលដឹងច្បាស់ដោយបញ្ញា កាលត្រាស់ដឹងនូវធម៌ដែលគួរត្រាស់ដឹង កាលកំណត់ដឹងនូវធម៌ដែលគួរកំណត់ដឹង កាលលះនូវធម៌ដែលគួរលះ កាលចម្រើននូវធម៌ដែលគួរចម្រើន កាលធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ បីតិនោះ ឈ្មោះថា គេដឹងច្បាស់ហើយ វេទនា ដោយអំណាចនៃដង្ហើមចេញ និងដង្ហើមចូល របស់អ្នកកំណត់ដឹងនូវបីតិនោះ ឈ្មោះថា ឧបដ្ឋាន សតិ ឈ្មោះថា អនុបស្សនាញាណ វេទនា ឈ្មោះថា ឧបដ្ឋាន មិនឈ្មោះថាសតិទេ ចំណែកខាងសតិ ទើបឈ្មោះថា ឧបដ្ឋានផង ឈ្មោះថា សតិផង យ៉ាងនេះឯង បុគ្គលរមែងពិចារណាឃើញនូវវេទនានោះ ដោយសតិនោះ ដោយញាណនោះ ហេតុនោះ លោកទើបពោលថា វេទនាសុវេទនា-នុបស្សនាសតិប្បដ្ឋានភាវនា ។

សំណួរត្រង់ពាក្យថា ពិចារណាឃើញ តើពិចារណាឃើញនូវវេទនានោះដូចម្តេច ។បេ។ បុគ្គលរមែងពិចារណាឃើញនូវវេទនានោះ យ៉ាងនេះឯង ។

ពាក្យថា ភាវនា បានដល់ ភាវនា ៤ យ៉ាង ។បេ។ ឈ្មោះថា ភាវនា ដោយអត្ថថា សេព ។ ខ្យល់ដង្ហើមចេញ និងដង្ហើមចូលរបស់បុគ្គលអ្នកកំណត់ដឹងនូវបីតិ ឈ្មោះថា សីលវិសុទ្ធិ ដោយអត្ថថា សង្រួម ។បេ។ កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្ត មានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញ និងដង្ហើមចូលរបស់អ្នកកំណត់ដឹងនូវបីតិ ។បេ។ បុគ្គលកាលដឹងច្បាស់ ឈ្មោះថា ប្រមូលមកនូវឥន្ទ្រិយទាំងឡាយ ហេតុនោះ លោកពោលថា បុគ្គលរមែងចាក់ធ្លុះនូវអត្ថនៃការស្ងប់ ។

[ ១១៧ ] បុគ្គលសិក្សាថា អាត្មាអញជាអ្នកកំណត់ដឹងនូវសេចក្តីសុខ ទើបដកដង្ហើមចូល តើដូចម្តេច ។

ពាក្យថា សុខ បានដល់ សុខ ២ យ៉ាង គឺកាយិកសុខ ១ ចេតសិក-សុខ ១ ។

កាយិកសុខ តើដូចម្តេច ។ សេចក្តីឆ្ងាញ់ពិសាដែលប្រព្រឹត្តទៅក្នុងកាយ សេចក្តីសោយអារម្មណ៍ ជាសុខដែលប្រព្រឹត្តទៅក្នុងកាយ សុខវេទនាដ៏ឆ្ងាញ់ពិសាដែលកើតអំពីកាយសម្ផស្សឯណា នេះឈ្មោះថា កាយិកសុខ ។ ចេត-សិកសុខ តើដូចម្តេច ។ សេចក្តីសុខដែលប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីសោយអារម្មណ៍ជាសុខដ៏ឆ្ងាញ់ពិសា ដែលកើតអំពីចេតោសម្ផស្ស សុខវេទនាដ៏ឆ្ងាញ់ពិសា ដែលកើតអំពីចេតោសម្ផស្សឯណា នេះឈ្មោះថា ចេតសិកសុខ ។

សេចក្តីសុខទាំងនោះ បុគ្គលដឹងច្បាស់ហើយ តើដូចម្តេច ។ កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្ត មានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញវែង សតិក៏តម្កល់មាំ សេចក្តីសុខទាំងនោះ ឈ្មោះថា បុគ្គលដឹងច្បាស់ហើយ ដោយសតិនោះ ដោយញាណនោះ កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចូលវែង សតិក៏តម្កល់មាំ សេចក្តីសុខទាំងនោះ ឈ្មោះថា បុគ្គលដឹងច្បាស់ហើយ ដោយសតិនោះ ដោយញាណនោះ ។បេ។ កាលបុគ្គលធ្វើឲ្យជាក់ច្បាស់នូវធម៌ ដែលគួរធ្វើឲ្យជាក់ច្បាស់ សេចក្តីសុខទាំងនោះ ឈ្មោះថា បុគ្គលដឹងច្បាស់ហើយ សេចក្តីសុខទាំងនុ៎ះ បុគ្គលដឹងច្បាស់ហើយយ៉ាងនេះ

ឯង វេទនា ដោយអំណាចនៃដង្ហើមចេញ និងដង្ហើមចូល របស់បុគ្គលអ្នកកំណត់ដឹងនូវសុខ ឈ្មោះថា ឧបដ្ឋាន សតិ ឈ្មោះថា អនុបស្សនាញាណ វេទនា ឈ្មោះថា ឧបដ្ឋាន មិនឈ្មោះថាសតិទេ ចំណែកខាងសតិ ទើបឈ្មោះថា ឧបដ្ឋានផង ឈ្មោះថា សតិផង បុគ្គលពិចារណាឃើញនូវវេទនានោះ ដោយសតិនោះ ដោយញាណនោះ ហេតុនោះ លោកពោលថា វេទនាសុវេទនានុបស្សនាសតិប្បដ្ឋានភាវនា ដោយប្រការដូច្នេះ ។

សំណួរត្រង់ពាក្យថា ពិចារណាឃើញ តើពិចារណាឃើញនូវវេទនា ដូចម្ដេច ។ បុគ្គលពិចារណាឃើញថា មិនទៀង ។បេ។ បុគ្គលពិចារណាឃើញនូវវេទនានោះ យ៉ាងនេះឯង ។

ពាក្យថា ភាវនា បានដល់ ភាវនា ៤ យ៉ាង ។បេ។ ឈ្មោះថា ភាវនា ដោយអត្ថថា សេព ខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូល របស់បុគ្គលអ្នកកំណត់ដឹងនូវសុខ ឈ្មោះថា សីលវិសុទ្ធិ ដោយអត្ថថា សង្រួម ។បេ។ កាលបុគ្គលដឹងនូវភាពនៃចិត្ត មានអារម្មណ៍តែមួយ ដែលមិនរាយមាយដោយអំណាចនៃដង្ហើមចេញ និងដង្ហើមចូលរបស់បុគ្គលអ្នកកំណត់ដឹងនូវសុខ ។បេ។ បុគ្គលកាលដឹងច្បាស់ ឈ្មោះថា ប្រមូលមកនូវឥន្ទ្រិយទាំងឡាយ ហេតុនោះ លោកពោលថា បុគ្គលចាក់ធ្លុះនូវអត្ថនៃការស្ងប់ ។

[ ១១៨ ] បុគ្គលសិក្សាថា អាត្មាអញជាអ្នកកំណត់ដឹងនូវចិត្តសង្ខារ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញជាអ្នកកំណត់ដឹងនូវចិត្តសង្ខារ ទើបដកដង្ហើមចូល តើដូចម្ដេច ។

ចិត្តសង្ខារ តើដូចម្តេច ។ សញ្ញា និងវេទនាជាតួចេតសិក ធម៌ទាំងនុ៎ះជាប់ចំពោះដោយចិត្តដោយអំណាចនៃដង្ហើមចេញវែង ឈ្មោះថា ចិត្តសង្ខារ សញ្ញា និងវេទនាជាតួចេតសិក ធម៌ទាំងនុ៎ះ ជាប់ចំពោះដោយចិត្ត ដោយអំណាចនៃដង្ហើមចូលវែង ឈ្មោះថា ចិត្តសង្ខារ ។បេ។ សញ្ញា និងវេទនា ជាតួចេតសិក ធម៌ទាំងនេះ ជាប់ចំពោះដោយចិត្ត ដោយអំណាចនៃដង្ហើមចេញរបស់បុគ្គលអ្នកកំណត់ដឹងនូវសេចក្តីសុខ ដោយអំណាចនៃដង្ហើមចូលរបស់បុគ្គលអ្នកកំណត់ដឹងនូវសេចក្តីសុខ ឈ្មោះថា ចិត្តសង្ខារ នេះឯង ឈ្មោះថា ចិត្តសង្ខារ ។

ចិត្តសង្ខារទាំងនោះ បុគ្គលដឹងច្បាស់ហើយ តើដូចម្តេច ។ កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្ត មានអារម្មណ៍តែមួយ ដែលមិនរាយមាយដោយអំណាចនៃដង្ហើមចេញវែង សតិក៏តម្កល់មាំ ចិត្តសង្ខារទាំងនោះ ឈ្មោះថា បុគ្គលដឹងច្បាស់ហើយដោយសតិនោះ ដោយញាណនោះ កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយដោយអំណាចនៃដង្ហើមចូលវែង សតិក៏តម្កល់មាំ ចិត្តសង្ខារទាំងឡាយនោះ ឈ្មោះថា បុគ្គលដឹងច្បាស់ហើយដោយសតិនោះ ដោយញាណនោះ ។បេ។ កាលបុគ្គលធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ចិត្តសង្ខារទាំងនោះ ឈ្មោះថា បុគ្គលដឹងច្បាស់ហើយ ចិត្តសង្ខារទាំងនោះ បុគ្គលដឹងច្បាស់ហើយយ៉ាងនេះឯង វេទនា ដោយអំណាចនៃដង្ហើមចេញ និងដង្ហើមចូល របស់បុគ្គលអ្នកកំណត់ដឹងនូវចិត្តសង្ខារ ឈ្មោះថា ឧបដ្ឋាន សតិ ឈ្មោះថា អនុបស្សនា-

ញាណ វេទនា ឈ្មោះថា ឧបដ្ឋាន មិនឈ្មោះថាសតិទេ ចំណែកខាងសតិ ទើបឈ្មោះថា ឧបដ្ឋានផង ឈ្មោះថា សតិផង បុគ្គលពិចារណាឃើញនូវវេទនានោះ ដោយសតិនោះ ដោយញាណនោះ ហេតុនោះ លោកពោលថា វេទនាសុវេទនានុបស្សនាសតិប្បដ្ឋានភាវនា ។

សំណួរត្រង់ពាក្យថា ពិចារណាឃើញ តើពិចារណាឃើញនូវវេទនានោះ ដូចម្តេច ។ បុគ្គលពិចារណាឃើញថាមិនទៀង ។បេ។ បុគ្គលពិចារណាឃើញនូវវេទនានោះ យ៉ាងនេះឯង ។

ពាក្យថា ភាវនា បានដល់ ភាវនា ៤ យ៉ាង ។បេ។ ឈ្មោះថា ភាវនា ដោយអត្ថថា សេព ។ ខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូល របស់បុគ្គលអ្នកកំណត់ដឹងនូវចិត្តសង្ខារ ឈ្មោះថា សីលវិសុទ្ធិ ដោយអត្ថថា សង្រួម ។បេ។ កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញ និងដង្ហើមចូល របស់បុគ្គលអ្នកកំណត់ដឹងនូវចិត្តសង្ខារ ។បេ។ បុគ្គលកាលដឹងច្បាស់ ឈ្មោះថា ប្រមូលមកនូវឥន្ទ្រិយទាំងឡាយ ហេតុនោះ លោកពោលថា បុគ្គលចាក់ធ្លុះនូវអត្ថនៃការស្ងប់ ។

[ ១១៩ ] បុគ្គលសិក្សាថា អាត្មាអញ កាលរម្ងាប់នូវចិត្តសង្ខារ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញ កាលរម្ងាប់នូវចិត្តសង្ខារ ទើបដកដង្ហើមចូល តើដូចម្តេច ។

ចិត្តសង្ខារ តើដូចម្តេច ។ សញ្ញា និងវេទនា ជាតួចេតសិក ធម៌ទាំងនុ៎ះ

ជាប់ចំពោះដោយចិត្ត ដោយអំណាចនៃដង្ហើមចេញវែង ឈ្មោះថា ចិត្តសង្ខារ បុគ្គលកាលរម្ងាប់ រម្ងត់ បង្ក្រាបនូវចិត្តសង្ខារទាំងនោះ ឈ្មោះថា សិក្សា សញ្ញា និងវេទនា ជាតួចេតសិក ធម៌ទាំងនុ៎ះ ជាប់ចំពោះដោយចិត្ត ដោយអំណាចនៃដង្ហើមចូលវែង ឈ្មោះថា ចិត្តសង្ខារ បុគ្គលកាលរម្ងាប់ រម្ងត់ បង្ក្រាបនូវចិត្តសង្ខារទាំងនោះ ឈ្មោះថា សិក្សា សញ្ញា និងវេទនា ជាតួចេតសិក ធម៌ទាំងនុ៎ះ ជាប់ចំពោះដោយចិត្ត ដោយអំណាចនៃដង្ហើមចេញរបស់បុគ្គលអ្នកកំណត់ដឹងនូវចិត្តសង្ខារ ដោយអំណាចនៃដង្ហើមចូលរបស់បុគ្គលអ្នកកំណត់ដឹងនូវចិត្តសង្ខារ ឈ្មោះថា ចិត្តសង្ខារ បុគ្គលកាលរម្ងាប់ រម្ងត់ បង្ក្រាបនូវចិត្តសង្ខារទាំងនោះ ឈ្មោះថា សិក្សា វេទនាដោយអំណាចនៃដង្ហើមចេញ និងដង្ហើមចូលរបស់បុគ្គល កាលរម្ងាប់នូវចិត្តសង្ខារ ឈ្មោះថា ឧបដ្ឋានសតិ ឈ្មោះថា អនុបស្សនាញាណ វេទនា ឈ្មោះថា ឧបដ្ឋាន មិនឈ្មោះថាសតិទេ ចំណែកខាងសតិ ទើបឈ្មោះថា ឧបដ្ឋានផង ឈ្មោះថា សតិផង បុគ្គលរមែងពិចារណាឃើញនូវវេទនានោះ ដោយសតិនោះ ដោយញាណនោះ ហេតុនោះ លោកពោលថា វេទនាសុវេទនានុបស្សនា-សតិប្បដ្ឋានភាវនា ។

សំណួរត្រង់ពាក្យថា ពិចារណាឃើញ តើពិចារណាឃើញនូវវេទនានោះដូចម្ដេច ។បេ។ បុគ្គលរមែងពិចារណាឃើញនូវវេទនានោះ យ៉ាងនេះឯង ។

ពាក្យថា ភាវនា បានដល់ ភាវនា ៤ យ៉ាង ។បេ។ ឈ្មោះថា ភាវនា ដោយអត្ថថា សេព ។ ខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលរបស់បុគ្គល

កាលរម្ងាប់នូវចិត្តសង្ខារ ឈ្មោះថា សីលវិសុទ្ធិ ដោយអត្ថថា សង្រួម ។បេ។ បុគ្គលកាលដឹងច្បាស់នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញ និងដង្ហើមចូលរបស់បុគ្គល កាលរម្ងាប់នូវចិត្ត-សង្ខារ ។បេ។ បុគ្គលកាលដឹងច្បាស់ ឈ្មោះថា ប្រមូលមកនូវឥន្ទ្រិយទាំងឡាយ ហេតុនោះ លោកពោលថា បុគ្គលចាក់ធ្លុះនូវអត្ថនៃការស្ងប់ អនុ-បស្សនាញាណ ៨ ឧបដ្ឋានានុស្សតិ ៨ និងសុត្តន្តិកវត្ថុ ៤ ( រមែងមាន ) ក្នុងវេទនាសុវេទនានុបស្សនា ។

ភាណវារៈ ចប់

[ ១២០ ] បុគ្គលសិក្សាថា អាត្មាអញ ជាអ្នកកំណត់ដឹងនូវចិត្ត ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញ ជាអ្នកកំណត់ដឹងនូវចិត្ត ទើបដកដង្ហើមចូល តើដូចម្តេច ។

ចិត្តនោះ តើដូចម្តេច ។ ដោយអំណាចនៃដង្ហើមចេញវែង វិញ្ញាណចិត្ត បានដល់ ចិត្ត ការដឹងអារម្មណ៍ សេចក្តីប្រាថ្នាក្នុងចិត្ត ហឫទ័យ ធម្មជាតដ៏ផូរផង់ គឺភវង្គចិត្ត មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោ-វិញ្ញាណធាតុដែលកើតអំពីវិញ្ញាណក្ខន្ធ ( នេះឈ្មោះថាចិត្ត ) ដោយអំណាចនៃដង្ហើមចូលវែង ។បេ។ ដោយអំណាចនៃដង្ហើមចេញ របស់បុគ្គលកាលរម្ងាប់នូវចិត្តសង្ខារ វិញ្ញាណចិត្ត បានដល់ ចិត្ត ការដឹងអារម្មណ៍ សេចក្តីប្រាថ្នាក្នុងចិត្ត ហឫទ័យ ធម្មជាតដ៏ផូរផង់ គឺភវង្គចិត្ត មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោវិញ្ញាណធាតុដែលកើតអំពីវិញ្ញាណក្ខន្ធ នេះ

ឈ្មោះថា ចិត្ត ។

ចិត្តនោះ បុគ្គលដឹងច្បាស់ហើយ តើដូចម្តេច ។ កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្ត មានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញវែង សតិក៏តម្កល់មាំ ចិត្តនោះ ឈ្មោះថា បុគ្គលដឹងច្បាស់ហើយ ដោយសតិនោះ ដោយញាណនោះ កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចូលវែង សតិក៏តម្កល់មាំ ចិត្តនោះ ឈ្មោះថា បុគ្គលដឹងច្បាស់ហើយ ដោយសតិនោះ ដោយញាណនោះ ។បេ។ កាលបុគ្គលធ្វើឲ្យជាក់ច្បាស់ នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ចិត្តនោះ ឈ្មោះថា បុគ្គលដឹងច្បាស់ហើយ ចិត្តនោះ បុគ្គលដឹងច្បាស់ហើយ យ៉ាងនេះឯង វិញ្ញាណចិត្តដោយអំណាចនៃដង្ហើមចេញរបស់បុគ្គលអ្នកកំណត់ដឹងនូវចិត្ត ឈ្មោះថា ឧបដ្ឋាន សតិ ឈ្មោះថា អនុ-បស្សនាញាណ ចិត្ត ឈ្មោះថា ឧបដ្ឋាន មិនឈ្មោះថាសតិទេ ចំណែកខាងសតិ ទើបឈ្មោះថា ឧបដ្ឋានផង ឈ្មោះថា សតិផង បុគ្គលពិចារណាឃើញនូវចិត្តនោះ ដោយសតិនោះ ដោយញាណនោះ ហេតុនោះ លោកពោលថា ចិត្តេចិត្តានុបស្សនាសតិប្បដ្ឋានភាវនា ។

សំណួរត្រង់ពាក្យថា ពិចារណាឃើញ តើពិចារណាឃើញនូវចិត្តនោះដូចម្តេច ។បេ។ បុគ្គលពិចារណាឃើញនូវចិត្តនោះ យ៉ាងនេះឯង ។

ពាក្យថា ភាវនា បានដល់ ភាវនា ៤ យ៉ាង ។បេ។ ឈ្មោះថា ភាវនាដោយអត្ថថា សេព ។ ខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលរបស់បុគ្គលអ្នក

កំណត់ដឹងនូវចិត្ត ឈ្មោះថា សីលវិសុទ្ធិ ដោយអត្ថថា សង្រួម ។បេ។ កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្ត មានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញ និងដង្ហើមចូលរបស់បុគ្គលអ្នកកំណត់ដឹងនូវចិត្ត ។បេ។ បុគ្គលកាលដឹងច្បាស់ ឈ្មោះថា ប្រមូលមកនូវឥន្ទ្រិយទាំងឡាយ ហេតុនោះ លោកពោលថា បុគ្គលចាក់ធ្លុះនូវអត្ថនៃការស្ងប់ ។

[ ១២១ ] បុគ្គលសិក្សាថា អាត្មាអញ កាលញុំាងចិត្តឲ្យរីករាយខ្លាំង ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញ កាលញុំាងចិត្តឲ្យរីករាយខ្លាំង ទើបដកដង្ហើមចូល តើដូចម្ដេច ។

សេចក្ដីរីករាយខ្លាំងនៃចិត្ត តើដូចម្ដេច ។ កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្ត មានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញវែង សេចក្ដីរីករាយខ្លាំងនៃចិត្ត បានដល់ ការរីករាយទូទៅ ការរីករាយខ្លាំង ការត្រេកអរ ការត្រេកអរខ្លាំង ភាពនៃចិត្តខ្ពស់ ភាពនៃចិត្តសប្បាយ ក៏កើតឡើង កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្ត មានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចូលវែង សេចក្ដីរីករាយខ្លាំងនៃចិត្ត បានដល់ ការរីករាយទូទៅ ការរីករាយខ្លាំង ការត្រេកអរ ការត្រេកអរខ្លាំង ភាពនៃចិត្តខ្ពស់ ភាពនៃចិត្តសប្បាយ ក៏កើតឡើង ។បេ។ កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្ត មានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញ របស់បុគ្គលអ្នកកំណត់ដឹងនូវចិត្ត ដោយអំណាចនៃដង្ហើមចូលរបស់បុគ្គល អ្នកកំណត់ដឹងនូវចិត្ត សេចក្ដីរីករាយខ្លាំងនៃចិត្ត បាន

ដល់ ការរីករាយទូទៅ ការរីករាយខ្លាំង ការត្រេកអរ ការត្រេកអរខ្លាំង ភាពនៃចិត្តខ្ពស់ ភាពនៃចិត្តសប្បាយ ក៏កើតឡើង នេះឈ្មោះថា សេចក្តីរីករាយខ្លាំងនៃចិត្ត ។ វិញ្ញាណចិត្ត ដោយអំណាចនៃដង្ហើមចេញ និងដង្ហើមចូលរបស់បុគ្គលកាលញុំាងចិត្តឲ្យរីករាយខ្លាំង ឈ្មោះថា ឧបដ្ឋាន សតិ ឈ្មោះថាអនុបស្សនាញាណ ចិត្ត ឈ្មោះថា ឧបដ្ឋាន មិនឈ្មោះថាសតិទេ ចំណែកខាងសតិ ទើបឈ្មោះថា ឧបដ្ឋានផង ឈ្មោះថា សតិផង បុគ្គលពិចារណាឃើញនូវចិត្តនោះ ដោយសតិនោះ ដោយញាណនោះ ហេតុនោះ លោកពោលថា ចិត្តេចិត្តានុបស្សនាសតិប្បដ្ឋានភាវនា ។

សំណួរត្រង់ពាក្យថា ពិចារណាឃើញ តើពិចារណាឃើញនូវចិត្តនោះដូចម្តេច ។បេ។ បុគ្គលពិចារណាឃើញនូវចិត្តនោះ យ៉ាងនេះឯង ។

ពាក្យថា ភាវនា បានដល់ ភាវនា ៤ យ៉ាង ។បេ។ ឈ្មោះថា ភាវនាដោយអត្ថថា សេព ។

ខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលរបស់បុគ្គល កាលញុំាងចិត្តឲ្យរីករាយខ្លាំង ឈ្មោះថា សីលវិសុទ្ធិ ដោយអត្ថថា សង្រួម ។បេ។ កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្ត មានអារម្មណ៍តែមួយ ដែលមិនរាយមាយដោយអំណាចនៃដង្ហើមចេញ និងដង្ហើមចូលរបស់បុគ្គល កាលញុំាងចិត្តឲ្យរីករាយខ្លាំង ។បេ។ បុគ្គលកាលដឹងច្បាស់ ឈ្មោះថា ប្រមូលមកនូវឥន្ទ្រិយទាំងឡាយ ហេតុនោះ លោកពោលថា បុគ្គលចាក់ធ្លុះនូវអត្ថនៃការស្ងប់ ។

[ ១២២ ] បុគ្គលសិក្សាថា អាត្មាអញ កាលតម្កល់ទុកនូវចិត្ត ទើបដក

ដង្ហើមចេញ សិក្សាថា អាត្មាអញ កាលតម្កល់ទុកនូវចិត្ត ទើបដកដង្ហើមចូល តើដូចម្ដេច ។

សមាធិ តើដូចម្ដេច ។ ភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញវែង ឈ្មោះថា សមាធិ ភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចូលវែង ឈ្មោះថា សមាធិ ភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញរបស់បុគ្គល កាលតម្កល់នូវចិត្ត ឈ្មោះថា សមាធិ បានដល់ ការស្ថិតនៅនៃចិត្ត ការតម្កល់នៅនឹង ការតាំងមាំ ការមិនឃ្លេងឃ្លោង ការមិនរាយមាយ ភាពនៃចិត្តមិនឃ្លេងឃ្លោង ការស្ងប់រម្ងាប់ សមាធិន្ទ្រិយ សមាធិពល សម្មាសមាធិ នេះឈ្មោះថា សមាធិវិញ្ញាណចិត្ត ដោយអំណាចនៃដង្ហើមចេញរបស់បុគ្គល កាលតម្កល់ទុកនូវចិត្ត ឈ្មោះថា ឧបដ្ឋាន សតិ ឈ្មោះថា អនុបស្សនាញាណ ចិត្ត ឈ្មោះថា ឧបដ្ឋាន មិនឈ្មោះថា សតិទេ ចំណែកខាងសតិ ទើបឈ្មោះថា ឧបដ្ឋានផង ឈ្មោះថា សតិផង បុគ្គលពិចារណាឃើញនូវចិត្តនោះ ដោយសតិនោះ ដោយញាណនោះ ហេតុនោះ លោកពោលថា ចិត្តេចិត្តានុបស្សនាសតិប្បដ្ឋាន-ភាវនា ។

សំណួរត្រង់ពាក្យថា ពិចារណាឃើញ តើពិចារណាឃើញនូវចិត្តនោះដូចម្ដេច ។បេ។ បុគ្គលពិចារណាឃើញនូវចិត្តនោះ យ៉ាងនេះឯង ។

ពាក្យថា ភាវនា បានដល់ ភាវនា ៤ យ៉ាង ។បេ។ ឈ្មោះថា ភាវនា

ដោយអត្ថថា សេព ។ ខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលរបស់បុគ្គល កាលតម្កល់ទុកក្នុងចិត្ត ឈ្មោះថា សីលវិសុទ្ធិ ដោយអត្ថថាសង្រួម ។បេ។ កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្ត មានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញរបស់បុគ្គល កាលតម្កល់ទុកនូវចិត្ត ។បេ។ បុគ្គល កាលដឹងច្បាស់ ឈ្មោះថា ប្រមូលមកនូវឥន្ទ្រិយទាំងឡាយ ហេតុនោះ លោកពោលថា បុគ្គលចាក់ដុះនូវអត្ថនៃការស្ងប់ ។

[ ១២៣ ] បុគ្គលសិក្សាថា អាត្មាអញកាលញុំាងចិត្តឲ្យរួច ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញ កាលញុំាងចិត្តឲ្យរួច ទើបដកដង្ហើមចូល តើដូចម្តេច ។ បុគ្គលសិក្សាថា អាត្មាអញ កាលញុំាងចិត្តឲ្យរួចចាករាគៈ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញ កាលញុំាងចិត្តឲ្យរួចចាករាគៈ ទើបដកដង្ហើមចូល សិក្សាថា អាត្មាអញ កាលញុំាងចិត្តឲ្យរួចចាកទោសៈ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញ កាលញុំាងចិត្តឲ្យរួចចាកទោសៈ ទើបដកដង្ហើមចូល សិក្សាថា អាត្មាអញ កាលញុំាងចិត្តឲ្យរួចចាកមោហៈ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញ កាលញុំាងចិត្តឲ្យរួចចាកមោហៈ ទើបដកដង្ហើមចូល ។បេ។ សិក្សាថា អាត្មាអញ កាលញុំាងចិត្តឲ្យរួចចាកមានះ កាលញុំាងចិត្តឲ្យរួចចាកទិដ្ឋិ កាលញុំាងចិត្តឲ្យរួចចាកវិចិកិច្ឆា កាលញុំាងចិត្តឲ្យរួចចាកថីនមិទ្ធៈ កាលញុំាងចិត្តឲ្យរួចចាកឧទ្ធច្ចៈ កាលញុំាងចិត្តឲ្យរួចចាកអហិរិកៈ កាលញុំាងចិត្តឲ្យរួចចាកអនោត្តប្បៈ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញ កាលញុំាងចិត្តឲ្យរួចចាកអនោត្តប្បៈ ទើបដកដង្ហើមចូល វិញ្ញាណចិត្ត

ដោយអំណាចនៃដង្ហើមចេញ និងដង្ហើមចូលរបស់បុគ្គល កាលញុំាំងចិត្តឲ្យរួច ឈ្មោះថា ឧបដ្ឋាន ។បេ។

សំណួរត្រង់ពាក្យថា ពិចារណាឃើញ តើពិចារណាឃើញនូវចិត្តនោះដូចម្តេច ។បេ។ បុគ្គលពិចារណាឃើញនូវចិត្តនោះ យ៉ាងនេះឯង ។ ពាក្យថា ភាវនា បានដល់ ភាវនា ៤ យ៉ាង ។បេ។ ឈ្មោះថា ភាវនា ដោយអត្ថថា សេព ។ ខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលរបស់បុគ្គល កាលញុំាំងចិត្តឲ្យរួច ឈ្មោះថា សីលវិសុទ្ធិ ដោយអត្ថថា សង្រួម ។បេ។ កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញ និងដង្ហើមចូលរបស់បុគ្គល កាលញុំាំងចិត្តឲ្យរួច ។បេ។ បុគ្គលកាលដឹងច្បាស់ ឈ្មោះថា ប្រមូលមកនូវឥន្ទ្រិយទាំងឡាយ ហេតុនោះ លោកពោលថា បុគ្គលចាក់ធ្លុះនូវអត្ថនៃការស្ងប់ ។ អនុបស្សនាញាណ ៨ ឧបដ្ឋានានុស្សតិ ៨ និងសុត្តន្តិកវត្ថុ ៤ ( រមែងមាន ) ក្នុងចិត្តេចិត្តានុបស្សនា ។

[ ១២៤ ] បុគ្គលសិក្សាថា អាត្មាអញ ជាអ្នកពិចារណាឃើញថាមិនទៀង ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញ ជាអ្នកពិចារណាឃើញថាមិនទៀង ទើបដកដង្ហើមចូល តើដូចម្តេច ។

សំណួរត្រង់ពាក្យថា មិនទៀង តើអ្វីមិនទៀង ។ ខន្ធទាំង ៥ មិនទៀង ។ ខន្ធ ៥ មិនទៀង ដោយអត្ថថា ដូចម្តេច ។ មិនទៀង ដោយអត្ថថា កើតឡើងហើយ សូន្យទៅវិញ ។ បុគ្គលកាលឃើញនូវការកើតឡើងនៃខន្ធ ៥ រមែង

ឃើញនូវលក្ខណៈប៉ុន្មានយ៉ាង កាលឃើញនូវការសូន្យ រមែងឃើញនូវលក្ខណៈប៉ុន្មានយ៉ាង កាលឃើញនូវការកើតឡើង និងការសូន្យ រមែងឃើញនូវលក្ខណៈប៉ុន្មានយ៉ាង ។ បុគ្គលកាលឃើញនូវការកើតឡើងនៃខន្ធ ៥ រមែងឃើញនូវលក្ខណៈ ២៥ យ៉ាង ។បេ។ បុគ្គលកាលឃើញនូវការកើតឡើង និងការសូន្យនៃខន្ធ ៥ រមែងឃើញនូវលក្ខណៈ ៥០ នេះឯង បុគ្គលសិក្សាថា អាត្មាអញ ជាអ្នកពិចារណាឃើញថាមិនទៀងក្នុងរូប ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញជាអ្នកពិចារណាឃើញថាមិនទៀងក្នុងរូប ទើបដកដង្ហើមចូល សិក្សាថា អាត្មាអញ ជាអ្នកពិចារណាឃើញថាមិនទៀងក្នុងវេទនា ក្នុងសញ្ញា ក្នុងសង្ខារទាំងឡាយ ក្នុងវិញ្ញាណ ក្នុងចក្ខុ ។បេ។ ក្នុងជរាមរណៈ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញ ជាអ្នកពិចារណាឃើញថាមិនទៀងក្នុងជរាមរណៈ ទើបដកដង្ហើមចូល ធម៌ទាំងឡាយ ឈ្មោះថា ឧបដ្ឋាន សតិឈ្មោះថា អនុបស្សនាញាណ ធម៌ទាំងឡាយ ឈ្មោះថា ឧបដ្ឋាន មិនឈ្មោះថាសតិទេ ចំណែកខាងសតិ ទើបឈ្មោះថា ឧបដ្ឋានផង ឈ្មោះថា សតិផង ដោយអំណាចនៃដង្ហើមចេញ និងដង្ហើមចូលរបស់បុគ្គលអ្នកពិចារណាឃើញថាមិនទៀង បុគ្គលរមែងពិចារណាឃើញនូវធម៌ទាំងនោះ ដោយសតិនោះ ដោយញាណនោះ ហេតុនោះ លោកពោលថា ធម្មេសុធម្មានុបស្សនា-សតិប្បដ្ឋានភាវនា ។

សំណួរត្រង់ពាក្យថា ពិចារណាឃើញ តើពិចារណាឃើញនូវធម៌ទាំងនោះ ដូចម្តេច ។បេ។ បុគ្គលពិចារណាឃើញនូវធម៌ទាំងនោះ យ៉ាងនេះឯង ។

ពាក្យថា ភាវនា បានដល់ ភាវនា ៤ យ៉ាង ។បេ។ ឈ្មោះថា ភាវនា ដោយអត្ថថា សេព ។ ខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលរបស់បុគ្គល អ្នកពិចារណាឃើញថាមិនទៀង ឈ្មោះថា សីលវិសុទ្ធិ ដោយអត្ថថា សង្រួម ។បេ។ កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្ត មានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញ និងដង្ហើមចូលរបស់បុគ្គល អ្នកពិចារណាឃើញថាមិនទៀង ។បេ។ បុគ្គលកាលឃើញច្បាស់ ឈ្មោះថា ប្រមូលមកនូវឥន្ទ្រិយទាំងឡាយ ហេតុនោះ លោកពោលថា បុគ្គលចាក់ធ្លុះនូវអត្ថនៃការស្ងប់ ។

[ ១២៥ ] បុគ្គលសិក្សាថា អាត្មាអញ ជាអ្នកពិចារណាឃើញនូវការណាយ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញ ជាអ្នកពិចារណាឃើញនូវការណាយ ទើបដកដង្ហើមចូល តើដូចម្តេច ។ បុគ្គលឃើញទោសក្នុងរូបហើយ ជាអ្នកដុះធន្ទះក្នុងការណាយចាករូប មានចិត្តចុះស៊ប់ក្នុងសទ្ធា ទាំងចិត្តរបស់បុគ្គលនោះ ក៏តម្កល់នៅស៊ប់សួន បុគ្គលនោះ សិក្សាថា អាត្មាអញ ជាអ្នកពិចារណាឃើញនូវការណាយក្នុងរូប ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញ ជាអ្នកពិចារណាឃើញនូវការណាយក្នុងរូប ទើបដកដង្ហើមចូល បុគ្គលឃើញទោសក្នុងវេទនា ក្នុងសញ្ញា ក្នុងសង្ខារទាំងឡាយ ក្នុងវិញ្ញាណ ក្នុងចក្ខុ ។បេ។ ក្នុងជរាមរណៈហើយ ជាអ្នកដុះធន្ទះក្នុងការណាយចាកជរាមរណៈ មានចិត្តចុះស៊ប់ក្នុងសទ្ធា ទាំងចិត្តរបស់បុគ្គលនោះ ក៏តម្កល់នៅស៊ប់សួន បុគ្គលនោះ សិក្សាថា អាត្មាអញ ជាអ្នកពិចារណាឃើញនូវ

ការណាយក្នុងជរាមរណៈ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញ ជាអ្នកពិចារណាឃើញនូវការណាយក្នុងជរាមរណៈ ទើបដកដង្ហើមចូល ធម៌ទាំងឡាយ ឈ្មោះថា ឧបដ្ឋាន សតិ ឈ្មោះថា អនុបស្សនាញាណ ធម៌ទាំងឡាយ ឈ្មោះថា ឧបដ្ឋាន មិនឈ្មោះថាសតិទេ ចំណែកខាងសតិ ទើបឈ្មោះថា ឧបដ្ឋានផង ឈ្មោះថា សតិផង ដោយអំណាចនៃដង្ហើមចេញនិងដង្ហើមចូលរបស់បុគ្គល ជាអ្នកពិចារណាឃើញនូវការណាយ បុគ្គលពិចារណាឃើញនូវធម៌ទាំងនោះ ដោយសតិនោះ ដោយញាណនោះ ហេតុនោះ លោកពោលថា ធម្មេសុធម្មានុបស្សនាសតិប្បដ្ឋានភាវនា ។

សំណួរត្រង់ពាក្យថា ពិចារណាឃើញ តើពិចារណាឃើញនូវធម៌ទាំងនោះដូចម្តេច ។បេ។ បុគ្គលពិចារណាឃើញនូវធម៌ទាំងនោះ យ៉ាងនេះឯង ។

ពាក្យថា ភាវនា បានដល់ ភាវនា ៤ យ៉ាង ។បេ។ ឈ្មោះថា ភាវនាដោយអត្ថថា សេព ។ ខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលរបស់បុគ្គលអ្នកពិចារណាឃើញនូវការណាយ ឈ្មោះថា សីលវិសុទ្ធិ ដោយអត្ថថាសង្រួម ។បេ។ កាលបុគ្គលឃើញច្បាស់នូវភាពនៃចិត្ត មានអារម្មណ៍តែមួយដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញ និងដង្ហើមចូលរបស់បុគ្គលអ្នកពិចារណាឃើញនូវការណាយ ។បេ។ បុគ្គលកាលឃើញច្បាស់ ឈ្មោះថា ប្រមូលមកនូវឥន្ទ្រិយទាំងឡាយ ហេតុនោះ លោកពោលថា បុគ្គលចាក់ធ្លុះនូវអត្ថនៃការស្ងប់ ។

[ ១២៦ ] បុគ្គលសិក្សាថា អាត្មាអញ ជាអ្នកពិចារណាឃើញនូវការ

រលត់ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញ ជាអ្នកពិចារណាឃើញនូវការរលត់ ទើបដកដង្ហើមចូល តើដូចម្តេច ។ បុគ្គលឃើញទោសក្នុងរូបហើយ ជាអ្នកជុះឆន្ទៈក្នុងការរលត់នៃរូប មានចិត្តចុះស៊ប់ក្នុងសទ្ធា ទាំងចិត្តរបស់បុគ្គលនោះ ក៏តម្កល់នៅស៊ប់ស្ងួន បុគ្គលនោះ សិក្សាថា អាត្មាអញ ជាអ្នកពិចារណាឃើញនូវការរលត់ក្នុងរូប ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញ ជាអ្នកពិចារណាឃើញនូវការរលត់ក្នុងរូប ទើបដកដង្ហើមចូល បុគ្គលឃើញទោសក្នុងវេទនា ក្នុងសញ្ញា ក្នុងសង្ខារទាំងឡាយ ក្នុងវិញ្ញាណ ក្នុងចក្ខុ ។បេ។ ក្នុងជរាមរណៈ ហើយជាអ្នកជុះឆន្ទៈ ក្នុងការរលត់នៃជរាមរណៈ មានចិត្តចុះស៊ប់ក្នុងសទ្ធា ទាំងចិត្តរបស់បុគ្គលនោះ ក៏តម្កល់នៅស៊ប់ស្ងួន បុគ្គលនោះ សិក្សាថា អាត្មាអញ ជាអ្នកពិចារណាឃើញនូវការរលត់ក្នុងជរាមរណៈ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញ ជាអ្នកពិចារណាឃើញនូវការរលត់ ក្នុងជរាមរណៈ ទើបដកដង្ហើមចូល ។

[ ១២៧ ] ទោសក្នុងអវិជ្ជា ដោយអាការប៉ុន្មានយ៉ាង អវិជ្ជារលត់ ដោយអាការប៉ុន្មានយ៉ាង ។ ទោសក្នុងអវិជ្ជាដោយអាការ ៥ យ៉ាង អវិជ្ជារលត់ដោយអាការ ៨ យ៉ាង ។

ទោសក្នុងអវិជ្ជាដោយអាការ ៥ យ៉ាង តើអ្វីខ្លះ ។ ទោសក្នុងអវិជ្ជា ដោយអត្ថថា មិនទៀង ១ ទោសក្នុងអវិជ្ជា ដោយអត្ថថា ជាទុក្ខ ១ ទោសក្នុងអវិជ្ជា ដោយអត្ថថា ជាអនត្តា ១ ទោសក្នុងអវិជ្ជា ដោយអត្ថថា ក្តៅសព្វ ១ ទោសក្នុងអវិជ្ជា ដោយអត្ថថា ប្រែប្រួល ១ នេះទោសក្នុងអវិជ្ជា ដោយ

អាការ ៥ យ៉ាង ។

អវិជ្ជារលត់ដោយអាការ ៨ យ៉ាង តើអ្វីខ្លះ ។ អវិជ្ជារលត់ដោយការរលត់នៃធម៌ជាគ្រឿងប្រគល់ឲ្យនូវផល ១ អវិជ្ជារលត់ដោយការរលត់នៃហេតុជាទីប្រជុំកើត ១ អវិជ្ជារលត់ដោយការរលត់នៃជាតិ ១ អវិជ្ជារលត់ដោយការរលត់នៃអាហារ ១ អវិជ្ជារលត់ដោយការរលត់នៃហេតុ ១ អវិជ្ជារលត់ដោយការរលត់នៃបច្ច័យ ១ អវិជ្ជារលត់ដោយការកើតឡើងនៃញាណ ១ អវិជ្ជារលត់ដោយការប្រាកដនៃនិរោធធម៌ ១ នេះអវិជ្ជារលត់ដោយអាការ ៨ យ៉ាង បុគ្គលឃើញទោស ក្នុងអវិជ្ជាដោយអាការ ៥ យ៉ាងនេះហើយ ជាអ្នកជុះឆន្ទៈក្នុងការរលត់នៃអវិជ្ជាដោយអាការ ៨ យ៉ាងនេះ មានចិត្តចុះស៊ប់ក្នុងសទ្ធា ទាំងចិត្តរបស់បុគ្គលនោះ ក៏តម្កល់នៅស៊ប់សួន បុគ្គលនោះ សិក្សាថា អាត្មាអញ ជាអ្នកពិចារណាឃើញនូវការរលត់នៃអវិជ្ជា ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញ ជាអ្នកពិចារណាឃើញនូវការរលត់នៃអវិជ្ជា ទើបដកដង្ហើមចូល ។

[ ១២៨ ] ទោសក្នុងសង្ខារដោយអាការប៉ុន្មាន សង្ខាររលត់ដោយអាការប៉ុន្មាន ។បេ។ ទោសក្នុងវិញ្ញាណ ដោយអាការប៉ុន្មាន វិញ្ញាណរលត់ដោយអាការប៉ុន្មាន ទោសក្នុងនាមរូបដោយអាការប៉ុន្មាន នាមរូបរលត់ដោយអាការប៉ុន្មាន ទោសក្នុងសឡាយតនៈ ដោយអាការប៉ុន្មាន សឡាយតនៈរលត់ដោយអាការប៉ុន្មាន ទោសក្នុងផស្សៈដោយអាការប៉ុន្មានយ៉ាង ផស្សៈរលត់ដោយអាការប៉ុន្មានយ៉ាង ទោសក្នុងវេទនាដោយអាការប៉ុន្មានយ៉ាង វេទនារលត់ដោយអាការប៉ុន្មានយ៉ាង ទោសក្នុងតណ្ហា ដោយអាការប៉ុន្មានយ៉ាង តណ្ហា

រលត់ដោយអាការប៉ុន្មានយ៉ាង ទោសក្នុងឧបាទាន ដោយអាការប៉ុន្មានយ៉ាង ឧបាទានរលត់ដោយអាការប៉ុន្មានយ៉ាង ទោសក្នុងភពដោយអាការប៉ុន្មានយ៉ាង ភពរលត់ដោយអាការប៉ុន្មានយ៉ាង ទោសក្នុងជាតិដោយអាការប៉ុន្មានយ៉ាង ជាតិរលត់ដោយអាការប៉ុន្មានយ៉ាង ទោសក្នុងជរាមរណៈដោយអាការប៉ុន្មានយ៉ាង ជរាមរណៈរលត់ ដោយអាការប៉ុន្មានយ៉ាង ។ ទោសក្នុងជរាមរណៈដោយអាការ ៥ យ៉ាង ជរាមរណៈរលត់ដោយអាការ ៨ យ៉ាង ។

ទោសក្នុងជរាមរណៈ ដោយអាការ ៥ យ៉ាង តើអ្វីខ្លះ ។ ទោសក្នុងជរាមរណៈ ដោយអត្ថថា មិនទៀង ១ ដោយអត្ថថា ជាទុក្ខ ១ ដោយថាជាអនត្តា ១ ដោយអត្ថថា ក្តៅសព្វ ១ ទោសក្នុងជរាមរណៈ ដោយអត្ថថាប្រែប្រួល ១ នេះទោសក្នុងជរាមរណៈ ដោយអាការ ៥ យ៉ាង ។

ជរាមរណៈ រលត់ដោយអាការ ៨ យ៉ាង តើអ្វីខ្លះ ជរាមរណៈរលត់ដោយការរលត់នៃហេតុ ជាគ្រឿងប្រគល់ឲ្យនូវផល ១ ដោយការរលត់នៃហេតុជាទីប្រជុំកើត ១ ដោយការរលត់នៃជាតិ ១ ដោយការរលត់នៃភព ១ ដោយការរលត់នៃហេតុ ១ ដោយការរលត់នៃបច្ច័យ ១ ដោយការកើតឡើងនៃញាណ ១ ជរាមរណៈរលត់ ដោយការប្រាកដនៃនិរោធធម៌ ១ នេះជរាមរណៈ រលត់ដោយអាការ ៨ យ៉ាង ។ បុគ្គលឃើញទោស ក្នុងជរាមរណៈ ដោយអាការ ៥ យ៉ាង ហើយជាអ្នកជុះធ្នុះក្នុងការរលត់នៃជរាមរណៈ ដោយអាការ ៨ យ៉ាង ជាអ្នកមានចិត្តចុះស៊ប់ក្នុងសទ្ធា ទាំងចិត្តរបស់បុគ្គលនោះ ក៏តម្កល់នៅស៊ប់ស្ងួន បុគ្គលនោះ សិក្សាថា អាត្មាអញ

ជាអ្នកពិចារណា ឃើញនូវការរលត់ជរាមរណៈ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញ ជាអ្នកពិចារណាឃើញនូវការរលត់ជរាមរណៈ ទើបដកដង្ហើមចូល ធម៌ទាំងឡាយ ឈ្មោះថា ឧបដ្ឋាន សតិ ឈ្មោះថា អនុបស្សនាញាណ ធម៌ទាំងឡាយ ឈ្មោះថា ឧបដ្ឋាន មិនឈ្មោះថាសតិទេ ចំណែកខាងសតិទើបឈ្មោះថា ឧបដ្ឋានផង ឈ្មោះថា សតិផង ដោយអំណាចនៃដង្ហើមចេញ និងដង្ហើមចូលរបស់បុគ្គល អ្នកពិចារណាឃើញនូវការរលត់ បុគ្គលពិចារណាឃើញនូវធម៌ទាំងនោះ ដោយសតិនោះ ដោយញាណនោះ ហេតុនោះ លោកពោលថា ធម្មេសុធម្មានុបស្សនាសតិប្បដ្ឋានភាវនា ។

សំណួរត្រង់ពាក្យថា ពិចារណាឃើញ តើពិចារណាឃើញនូវធម៌ទាំងនោះដូចម្តេច ។បេ។ បុគ្គលពិចារណាឃើញនូវធម៌ទាំងនោះ យ៉ាងនេះឯង ។

ពាក្យថា ភាវនា បានដល់ ភាវនា ៤ យ៉ាង ។បេ។ ឈ្មោះថា ភាវនា ដោយអត្ថថា សេព ។ ខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលរបស់បុគ្គលអ្នកពិចារណាឃើញនូវការរលត់ ឈ្មោះថា សីលវិសុទ្ធិ ដោយអត្ថថា សង្រួម ។បេ។ កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្ត មានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញ និងដង្ហើមចូល របស់បុគ្គលអ្នកពិចារណាឃើញនូវការរលត់ ។បេ។ បុគ្គលកាលដឹង ឈ្មោះថា ប្រមូលមកនូវឥន្ទ្រិយទាំងឡាយ ហេតុនោះ លោកពោលថា បុគ្គលចាក់ធ្លុះនូវអត្ថនៃការស្ងប់ ។

[ ១២៩ ] បុគ្គលសិក្សាថា អាត្មាអញជាអ្នកពិចារណា ឃើញនូវការ

រលាស់ចេញ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញ ជាអ្នកពិចារណាឃើញនូវការរលាស់ចេញ ទើបដកដង្ហើមចូល តើដូចម្តេច ។ ការរលាស់ចេញមាន ២ យ៉ាង គឺការរលាស់ចេញ គឺការលះបង់ ( បរិច្ចាគប្បដិនិស្សគ្គ ) ១ ការរលាស់ចេញ គឺការស្ទុះទៅ ( បក្ខន្ទនប្បដិនិស្សគ្គៈ ) ១ ។ ធម៌ណាលះស្រឡះនូវរូប ធម៌នោះ ឈ្មោះថា ការរលាស់ចេញ គឺការលះបង់ ចិត្តស្ទុះទៅក្នុងព្រះនិព្វាន ជាទីរលត់នៃរូប ឈ្មោះថា ការរលាស់ចេញ គឺការស្ទុះទៅ ។ បុគ្គលសិក្សាថា អាត្មាអញជា អ្នកពិចារណាឃើញនូវការរលាស់រូបចេញ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញ ជាអ្នកពិចារណាឃើញនូវការរលាស់រូបចេញ ទើបដកដង្ហើមចូល ធម៌ណាលះស្រឡះនូវវេទនា នូវសញ្ញា នូវសង្ខារ នូវវិញ្ញាណ នូវចក្ខុ ។បេ។ នូវជរាមរណៈ ធម៌នោះ ឈ្មោះថា ការរលាស់ចេញ គឺការលះបង់ ចិត្តស្ទុះទៅក្នុងព្រះនិព្វាន ជាទីរលត់នៃជរាមរណៈ ឈ្មោះថា ការរលាស់ចេញ គឺការស្ទុះទៅ ។ បុគ្គលសិក្សាថា អាត្មាអញ ជាអ្នកពិចារណាឃើញនូវការរលាស់ជរាមរណៈ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញ ជាអ្នកពិចារណាឃើញនូវការរលាស់ជរាមរណៈ ទើបដកដង្ហើមចូលធម៌ ទាំងឡាយ ឈ្មោះថា ឧបដ្ឋាន សតិ ឈ្មោះថា អនុបស្សនាញាណ ធម៌ទាំងឡាយ ឈ្មោះថា ឧបដ្ឋាន មិនឈ្មោះថាសតិទេ ចំណែកខាងសតិ ទើបឈ្មោះថា ឧបដ្ឋានផង ឈ្មោះថា សតិផង ដោយអំណាចនៃដង្ហើមចេញ និងដង្ហើមចូលរបស់បុគ្គល អ្នកពិចារណាឃើញនូវការរលាស់ចេញ បុគ្គលពិចារណាឃើញនូវធម៌ទាំងនោះ ដោយសតិនោះ ដោយញាណ

នោះ ហេតុនោះ លោកពោលថា ធម្មេសុធម្មានុបស្សនាសតិប្បដ្ឋានភាវនា ។

សំណួរត្រង់ពាក្យថា ពិចារណាឃើញ តើពិចារណាឃើញនូវធម៌ទាំង នោះដូចម្តេច ។ បុគ្គលពិចារណាឃើញថាមិនទៀង មិនមែនថាទៀងទេ ។បេ។ រលាស់ចេញ មិនមែនកាន់យកទេ បុគ្គលកាលពិចារណាឃើញ ថាមិនទៀង រមែងលះបង់នូវនិច្ចសញ្ញា ( ការសម្គាល់ថាទៀង ) ។បេ។ បុគ្គលកាល រលាស់ចេញ ឈ្មោះថា លះបង់នូវសេចក្តីប្រកាន់ បុគ្គលពិចារណាឃើញនូវ ធម៌ទាំងនោះ យ៉ាងនេះឯង ។

ពាក្យថា ភាវនា បានដល់ ភាវនា ៤ យ៉ាង ឈ្មោះថា ភាវនា ដោយអត្ថ ថា មិនកន្លងនូវធម៌ទាំងឡាយ ដែលកើតក្នុងសមាធិនោះ ។បេ។ ឈ្មោះថា ភាវនា ដោយអត្ថថា សេព ។បេ។ ខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលរបស់ បុគ្គលអ្នកពិចារណាឃើញនូវការរលាស់ចេញ ឈ្មោះថា សីលវិសុទ្ធិ ដោយ អត្ថថា សង្រួម ឈ្មោះថា ចិត្តវិសុទ្ធិ ដោយអត្ថថា មិនរាយមាយ ឈ្មោះថា ទិដ្ឋិវិសុទ្ធិ ដោយអត្ថថា ឃើញ អត្ថថា សង្រួមក្នុងធម៌នោះឯណា នេះឈ្មោះ ថា អធិសីលសិក្ខា អត្ថថា មិនរាយមាយក្នុងធម៌នោះឯណា នេះឈ្មោះថា អធិចិត្តសិក្ខា អត្ថថា ឃើញក្នុងធម៌នោះឯណា នេះឈ្មោះថា អធិប្បញ្ញាសិក្ខា បុគ្គលកាលរំពឹងឃើញនូវសិក្ខាទាំង ៣ នេះឈ្មោះថា សិក្សា កាលដឹង ឈ្មោះថា សិក្សា ។បេ។ កាលធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ឈ្មោះថា សិក្សា កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្ត មានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញ និងដង្ហើមចូលរបស់បុគ្គល

អ្នកពិចារណាឃើញនូវការរលាស់ចេញ វេទនាដ៏ប្រាកដរមែងកើតឡើង វេទនាដ៏ប្រាកដរមែងតាំងឡើង វេទនាដ៏ប្រាកដរមែងដល់នូវសេចក្តីវិនាស ។បេ។ កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្ត មានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញ និងដង្ហើមចូលរបស់បុគ្គល អ្នកពិចារណាឃើញនូវការរលាស់ចេញ ។បេ។ បុគ្គលកាលដឹងច្បាស់ ឈ្មោះថា ប្រមូលមកនូវឥន្ទ្រិយទាំងឡាយ ឈ្មោះថា ដឹងច្បាស់នូវគោចរផង ចាក់ធ្លុះនូវអត្ថនៃការស្ងប់ផង បុគ្គលប្រមូលមកនូវពល ប្រមូលមកនូវពោជ្ឈង្គ ប្រមូលមកនូវមគ្គ ប្រមូលមកនូវធម៌ ឈ្មោះថា ដឹងច្បាស់នូវគោចរផង ចាក់ធ្លុះនូវអត្ថនៃការស្ងប់ផង ។

សំណួរត្រង់ពាក្យថា ប្រមូលមកនូវឥន្ទ្រិយទាំងឡាយ តើប្រមូលមកនូវឥន្ទ្រិយទាំងឡាយ ដូចម្តេច ។ បុគ្គលប្រមូលមកនូវសទ្ធិន្ទ្រិយ ដោយអត្ថថាជឿស៊ប់ ។បេ។ ហេតុនោះ លោកពោលថា ចាក់ធ្លុះនូវអត្ថនៃការស្ងប់ អនុបស្សនាញាណ ៨ ឧបដ្ឋានានុស្សតិ ៨ និងសុត្តន្តិកវត្ថុ ៤ ( រមែងមាន ) ក្នុងធម្មសុធម្មានុបស្សនា ទាំងនេះឈ្មោះថា សតោការីញាណ ៣២ ប្រការ ។

[ ១៣០ ] ញាណ ២៤ ដោយអំណាចនៃសមាធិ តើដូចម្តេច ។ ភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញវែង ឈ្មោះថា សមាធិ ភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចូលវែង ឈ្មោះថា សមាធិ ។បេ។ ភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញរបស់

បុគ្គល កាលញុំាងចិត្តឲ្យរួច ( ចាកកិលេស ) ឈ្មោះថា សមាធិ នេះញាណ ២៤ ដោយអំណាចនៃសមាធិ ។

ញាណ ៧២ ប្រការដោយអំណាចនៃវិបស្សនា តើដូចម្តេចខ្លះ ។ ឈ្មោះថា វិបស្សនា ដោយអត្ថថា ពិចារណាឃើញថាមិនទៀង ឈ្មោះថា វិបស្សនា ដោយអត្ថថា ពិចារណាឃើញថាជាទុក្ខ ឈ្មោះថា វិបស្សនា ដោយអត្ថថា ពិចារណាឃើញថាជាអនត្តា នូវខ្យល់ដង្ហើមចេញវែង ឈ្មោះថា វិបស្សនា ដោយអត្ថថា ពិចារណាឃើញថាមិនទៀង ឈ្មោះថា វិបស្សនា ដោយអត្ថថា ពិចារណាឃើញថាជាទុក្ខ ឈ្មោះថា វិបស្សនា ដោយអត្ថថា ពិចារណាឃើញថាជាអនត្តា នូវខ្យល់ដង្ហើមចូលវែង ។បេ។ ឈ្មោះថា វិបស្សនា ដោយអត្ថថា ពិចារណាឃើញថាមិនទៀង ឈ្មោះថា វិបស្សនា ដោយអត្ថថា ពិចារណាឃើញថាជាទុក្ខ ឈ្មោះថា វិបស្សនា ដោយអត្ថថា ពិចារណាឃើញថាជាអនត្តា នូវខ្យល់ដង្ហើមចេញរបស់បុគ្គល កាលញុំាងចិត្តឲ្យរួចនូវខ្យល់ដង្ហើមចូលរបស់បុគ្គល កាលញុំាងចិត្តឲ្យរួច នេះញាណ ៧២ ប្រការដោយអំណាចនៃវិបស្សនា ។

និព្វិទាញាណ ៨ យ៉ាង តើដូចម្តេចខ្លះ ។ ឈ្មោះថា និព្វិទាញាណ ព្រោះហេតុដឹង ឃើញតាមពិតនូវខ្យល់ដង្ហើមចេញរបស់បុគ្គល អ្នកពិចារណាឃើញថាមិនទៀង ១ ឈ្មោះថា និព្វិទាញាណ ព្រោះហេតុដឹង ឃើញតាមពិតនូវខ្យល់ដង្ហើមចូលរបស់បុគ្គល អ្នកពិចារណាឃើញថាមិនទៀង ១ ។បេ។ ឈ្មោះថា និព្វិទាញាណ ព្រោះហេតុដឹង ឃើញតាមពិតនូវខ្យល់ដង្ហើមចេញ

របស់បុគ្គល អ្នកពិចារណាឃើញនូវការរលាស់ចេញ ១ ឈ្មោះថា និព្វិទា-ញាណ ព្រោះហេតុដឹង ឃើញតាមពិតនូវខ្យល់ដង្ហើមចូលរបស់បុគ្គល អ្នកពិចារណាឃើញនូវការរលាស់ចេញ ១ នេះនិព្វិទាញាណ ៨ យ៉ាង ។

និព្វិទានុលោមញាណ ៨ យ៉ាង តើដូចម្តេចខ្លះ ។ បញ្ញាក្នុងការប្រាកដជាគួរភ័យចំពោះខ្យល់ដង្ហើមចេញរបស់បុគ្គល អ្នកពិចារណាឃើញថាមិនទៀង ឈ្មោះថា និព្វិទានុលោមញាណ ១ បញ្ញាក្នុងការប្រាកដជា គួរភ័យចំពោះខ្យល់ដង្ហើមចូលរបស់បុគ្គល អ្នកពិចារណាឃើញថាមិនទៀង ឈ្មោះថា និព្វិទានុលោមញាណ ១ ។បេ។ បញ្ញាក្នុងការប្រាកដជា គួរភ័យចំពោះខ្យល់ដង្ហើមចេញរបស់បុគ្គល អ្នកពិចារណាឃើញនូវការរលាស់ចេញ ឈ្មោះថា និព្វិទានុលោមញាណ ១ បញ្ញាក្នុងការប្រាកដជា គួរភ័យចំពោះខ្យល់ដង្ហើមចូលរបស់បុគ្គល អ្នកពិចារណាឃើញនូវការរលាស់ចេញ ឈ្មោះថា និព្វិទា-នុលោមញាណ ១ នេះនិព្វិទានុលោមញាណ ៨ យ៉ាង ។

និព្វិទាបដិប្បស្សទ្ធិញាណស្ងប់ ( ការដឹងក្នុងការនឿយណាយ និងការរម្ងាប់ ) ៨ យ៉ាង តើដូចម្តេចខ្លះ ។ បញ្ញា គឺការពិចារណា និងការរំពឹងនូវខ្យល់ដង្ហើមចេញរបស់បុគ្គល អ្នកពិចារណាឃើញថាមិនទៀង ឈ្មោះថា និព្វិទាបដិប្បស្សទ្ធិញាណ ១ បញ្ញា គឺការពិចារណា និងការរំពឹងនូវខ្យល់ដង្ហើមចូលរបស់បុគ្គល អ្នកពិចារណាឃើញថាមិនទៀង ឈ្មោះថា និព្វិទា-បដិប្បស្សទ្ធិញាណ ១ ។បេ។ នេះនិព្វិទាបដិប្បទ្ធិញាណ ៨ យ៉ាង ។

វិមុត្តិសុខញាណ ២១ តើដូចម្តេចខ្លះ ។ ញាណកើតឡើង ព្រោះភាពនៃ

សក្កាយទិដ្ឋិដែលលោកលះបង់ហើយ ផ្តាច់ផ្តិលហើយ ដោយសោតាបត្តិមគ្គ ឈ្មោះថា វិមុត្តិសុខញ្ញាណ ញាណកើតឡើង ព្រោះភាពនៃវិចិកិច្ឆា ដែលលោកលះបង់ហើយ ផ្តាច់ផ្តិលហើយដោយសោតាបត្តិមគ្គ ឈ្មោះថា វិមុត្តិសុខញ្ញាណ ញាណកើតឡើង ព្រោះភាពនៃសីលព្វតបរាមាសនៃទិដ្ឋានុស័យ នៃវិចិកិច្ឆានុស័យ ដែលលោកលះបង់ហើយ ផ្តាច់ផ្តិលហើយដោយសោតាបត្តិមគ្គ ឈ្មោះថា វិមុត្តិសុខញ្ញាណ ញាណកើតឡើង ព្រោះភាពនៃកាមរាគសញ្ញោជនៈ នៃបដិឃសញ្ញោជនៈ ជាកិលេសដ៏គ្រោតគ្រាតនៃកាមរាគានុស័យ នៃបដិឃានុស័យ ជាកិលេសដ៏គ្រោតគ្រាត ដែលលោកលះបង់ហើយ ផ្តាច់ផ្តិលហើយដោយសកទាមិមគ្គ ឈ្មោះថា វិមុត្តិសុខញ្ញាណ ញាណកើតឡើង ព្រោះភាពនៃកាមរាគសញ្ញោជនៈ នៃបដិឃសញ្ញោជនៈ ជាកិលេសដ៏ល្អិតនៃកាមរាគានុស័យ នៃបដិឃានុស័យ ជាកិលេសដ៏ល្អិតដែលលោកលះបង់ហើយ ផ្តាច់ផ្តិលហើយដោយអនាគាមិមគ្គ ឈ្មោះថា វិមុត្តិសុខញ្ញាណ ញាណកើតឡើង ព្រោះភាពនៃរូបរាគៈ នៃអរូបរាគៈ នៃមានះ នៃឧទ្ធច្ចៈ នៃអវិជ្ជា នៃមានានុស័យ នៃភវរាគានុស័យ នៃអវិជ្ជានុស័យ ដែលលោកលះបង់ហើយ ផ្តាច់ផ្តិលហើយដោយអរហត្តមគ្គ ឈ្មោះថា វិមុត្តិសុខញ្ញាណ នេះវិមុត្តិសុខញ្ញាណ ២១ កាលបុគ្គលចម្រើននូវអានាបានស្សតិសមាធិ មានវត្ថុ ១៦ ញាណ ២២០ នេះ រមែងកើតឡើង ។

**អានាបានកថា ចប់**

# អដ្ឋកថា

# អានាបានស្សតិកថា

## គណនវារៈ

[ ៦៩ ] ឥឡូវនេះ ដល់លំដាប់នឹងពណ៌នាអត្ថ ដែលមិនធ្លាប់ពណ៌នានៃអានាបានស្សតិកថា ដែលព្រះសារីបុត្តពោលក្នុងលំដាប់នៃទិដ្ឋិកថា ។

ពិតហើយ អានាបានស្សតិកថានេះ លោកពោលក្នុងលំដាប់ទិដ្ឋិកថា ព្រោះសមាធិភាវនា ដើម្បីត្រាស់ដឹងតាមសេចក្ដីពិតនៃបុគ្គល ដែលដឹងច្បាស់ឃើញទោសល្អហើយក្នុងទិដ្ឋិកថា បុគ្គលមានចិត្តបរិសុទ្ធល្អហើយ ដោយជម្រះមន្ទិល គឺមិច្ឆាទិដ្ឋិឲ្យបរិសុទ្ធ រមែងជាការធ្វើបានងាយក្នុងសមាធិភាវនាទាំងពួង សមាធិភាវនានេះឯងជាប្រធាន ព្រោះសព្វញ្ញូពោធិសត្វទាំងពួង ដែលមានចិត្តតាំងមាំ ហើយត្រាស់ដឹងតាមសេចក្ដីពិត ដោយសមាធិនេះឯងទៀបគល់ឈើដែលត្រាស់ដឹង ។

ក្នុងអានាបានស្សតិកថានេះ គប្បីជ្រាបការកំណត់បាលីមុន យ៉ាងនេះថា បទថា **សោឡសវត្ថុកំ អានាបានស្សតិសមាធឹ ភាវយតោ សមាធិកានិ**[១] **ទ្វេ ញាណសតានិ ឧប្បជ្ជន្តិ** ជាការលើកឡើងសម្ដែងចំនួនញាណ បទថា **អដ្ឋ បរិបន្ថេ ញាណានិ** ជាដើម ជាការចង្អុលបង្ហាញចំនួនញាណ បទខាងដើមថា **កតមានិ អដ្ឋ បរិបន្ថេ ញាណានិ** បទខាងចុងថា **ឥមានិ ឯក-វីសតិ វិមុត្តិសុខេ ញាណានិ** ជាការចង្អុលបង្ហាញសេចក្ដីពិស្ដារនៃញាណ

---

១- បិដកខ្មែរជា វិសាធិកានិ បិដកឆដ្ឋសង្គាយនាជា សមាធិកានិ ។

ទាំងពួងក្នុងខាងចុង បទថា **សោឡសវត្ថុកំ អានាបានស្សតិសមាធឹ ភាវយតោ** ជាដើម ជាពាក្យសរុប ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគណនវារ ក្នុងការសម្តែងការរាប់ក្នុងអានាបានស្សតិកថានោះ ដូច្នេះសិន ។ បទថា **សោឡសវត្ថុកំ** មានវិនិច្ឆ័យថា ឈ្មោះថា **សោឡសវត្ថុក** ព្រោះអត្ថថា មានវត្ថុ ១៦ ជាទីតាំង ជាអារម្មណ៍ ដោយអំណាចនៃចតុក្កៈ ៤ ពួក ទាំងនេះ គឺខ្យល់ដកដង្ហើមវែង ខ្យល់ដកដង្ហើមខ្លី កំណត់ដឹងច្បាស់នូវកាយទាំងពួង រម្ងាប់កាយសង្ខារ ឈ្មោះថា កាយានុបស្សនាចតុក្កៈ ១ កំណត់ដឹងច្បាស់នូវបីតិ កំណត់ដឹងច្បាស់នូវសេចក្តីសុខ កំណត់ដឹងច្បាស់នូវចិត្តសង្ខារ រម្ងាប់នូវចិត្តសង្ខារ ឈ្មោះថា វេទនានុបស្សនាចតុក្កៈ ១ កំណត់ដឹងច្បាស់ចិត្ត ញុំាងចិត្តឲ្យរីករាយខ្លាំង តម្កល់ចិត្ត ដោះចិត្ត ឈ្មោះថា ចិត្តានុបស្សនាចតុក្កៈ ១ ពិចារណានូវអនិច្ចលក្ខណៈ ពិចារណានូវការប្រាសចាករាគៈ ពិចារណានូវធម៌ជាទីរលត់ ពិចារណានូវធម៌ជាគ្រឿងរលាស់ចិត្តចេញចាកកិលេស ឈ្មោះថា ធម្មានុបស្សនាចតុក្កៈ ១ ។ អានាបានស្សតិសមាធិមានវត្ថុ ១៦ នោះ ។ ក្នុងបទនេះ លុបវិភត្តិដោយវិធីនៃសមាស ។

បទថា **អានំ** បានដល់ ខ្យល់ដកដង្ហើមចូលក្នុងខាងក្នុង ។ បទថា **អបានំ** បានដល់ ខ្យល់ដកដង្ហើមចេញខាងក្រៅ ។ តែអាចារ្យពួកខ្លះ ពោលផ្ទុយគ្នាអំពីនេះ ពិតហើយ ខ្យល់ដង្ហើមចេញ លោកពោលថា **អបាន** ព្រោះប្រាសចាកការដកដង្ហើមចូល តែក្នុងនិទ្ទេស លោកពោលថា **អាបាន** ព្រោះសម្លឹង

ដល់ **ឆា** អក្ខរៈ ជាទីឃៈ ។

សតិក្នុងខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញនោះ ឈ្មោះថា អានាបានស្សតិ ពាក្យនោះ ជាឈ្មោះរបស់សតិដែលកំណត់អស្សាសៈ បស្សាសៈ សមាធិដែលប្រកបដោយអានាបានស្សតិ ឬសមាធិក្នុងអានាបានស្សតិ ឈ្មោះថា អានាបានស្សតិសមាធិ ។

បទថា **ភាវយតោ** បានដល់ កាលព្រះយោគាវចរអប់រំនិព្វេធភាគិយធម៌ ( ធម៌ជាចំណែកនៃការត្រាស់ដឹង ) ។ បទថា **សមធិកានិ** មានវិគ្គហៈថា ឈ្មោះថា **សមធិកានិ** ព្រោះអត្ថថា ប្រព្រឹត្តទៅដោយភាពក្រៃលែង អធិប្បាយថា ច្រើនជាង ។ ក្នុងបទថា **សមធិកានិ** នេះ **ម** អក្ខរៈ ជាបទសន្ធិ ។ តែអាចារ្យពួកខ្លះពោលថា **សំអធិកានិ ។** កាលបើយ៉ាងនោះ ក៏បានសេចក្ដីថា ញាណ ២០០ នោះឯង ជាញាណក្រៃលែង ពាក្យរបស់អាចារ្យពួកនោះមិនត្រឹមត្រូវ ព្រោះញាណទាំងនេះ មាន ២០០ លើស ២០ ។

បទថា **បរិបន្ថេ ញាណានិ** បានដល់ ញាណដែលធ្វើធម៌ ដែលជាអន្តរាយឲ្យជាអារម្មណ៍ ហើយប្រព្រឹត្តទៅ ។ ឧបការញ្ញាណ និងឧបក្កិលេសញ្ញាណក៏មានន័យយ៉ាងនោះ ។ បទថា **វោទានេ ញាណានិ** មានវិគ្គហៈថា ឈ្មោះថា វោទាន ព្រោះជាហេតុឲ្យចិត្តបរិសុទ្ធ សេចក្ដីនោះ គឺអ្វី គឺញាណ ។ កាលគួរពោលថា **វោទានញាណានិ** លោកក៏ពោលថា **វោទានេ ញាណានិ** ដូចក្នុងពាក្យជាដើមថា **សុតមយេ ញាណំ ។** ឈ្មោះថា **សតោការី** ព្រោះមានសតិសម្បជញ្ញៈធ្វើ ។ ញាណក្នុងភាពជាអ្នកធ្វើសតិ

របស់ព្រះយោគាវចរនោះ ។

បទថា **និព្វិទាញាណានិ** បានដល់ ញាណដែលជានិព្វិទា ( នឿយណាយ ) ។ បទថា **និព្វិទានុលោមញាណានិ** បានដល់ ញាណអនុលោមដល់និព្វិទា ។ បាឋៈថា **និព្វិទានុលោមិញាណានិ** ដូច្នេះក៏មាន ។ សេចក្តីថា ឈ្មោះថា **និព្វិទានុលោមី** ព្រោះអត្ថថា ញាណទាំងនោះ មាននិព្វិទាអនុ-លោម ។ បទថា **និព្វិទាបដិប្បស្សទ្ធិញ្ញាណានិ** បានដល់ ញាណក្នុងសេចក្តីស្ងប់និព្វិទា ។

បទថា **វិមុត្តិសុខេ ញាណានិ** បានដល់ ញាណសម្បយុត្តដោយវិមុត្តិសុខ ។

[ ៧០ ] ដោយបទថា **កតមានិ អដ្ឋ** ជាដើម លោកសម្តែងរួមគ្នាដល់ញាណ ក្នុងធម៌ដែលជាអន្តរាយ និងក្នុងធម៌ដែលជាឧបការៈទាំងនោះ ព្រោះញាណក្នុងធម៌ដែលជាអន្តរាយ និងក្នុងធម៌ដែលជាឧបការៈ ជាធម៌គូគ្នាដោយផ្ទុយគ្នា និងជាសត្រូវដល់គ្នា ។ បទថា **កាមច្ឆន្ទនេក្ខម្មា** ជាដើម មានសេចក្តីដូចពោលមកហើយ ។ម្យ៉ាងទៀត បទថា **ឧបការំ** លោកធ្វើឲ្យជានបុំសកលិង្គ ។

បទថា **សព្វេបិ អកុសលា ធម្មា** បានដល់ អកុសលធម៌ពួកណានីមួយដែលសល់អំពីពោលហើយ ។ កុសលធម៌ដែលជាចំណែកនៃការត្រាស់ដឹងទាំងពួងក៏ដូចគ្នា ។ បទថា **បរិបន្ថោ** និងបទថា **ឧបការំ** លោកធ្វើឲ្យជាឯកវចនៈ ព្រោះសម្លឹងដល់ធម៌នោះៗ ឯង ។ ក្នុងសេចក្តីនេះ ព្រះសារីបុត្តត្ថេរ

កាលសម្តែងដល់ញាណ ក្នុងធម៌ដែលជាអន្តរាយ និងញាណក្នុងធម៌ ដែលជាឧបការៈហើយ ក៏ធ្វើយអារម្មណ៍នៃញាណទាំងនោះឯង ទើបឈ្មោះថា ធ្វើយញាណទាំងនោះដោយអារម្មណ៍ទាំងនោះឯង ព្រោះហេតុនោះ ទើបលោកសម្តែងសរុបញាណដែលមានធម៌ដែលជាអន្តរាយ និងដែលជាឧបការៈនោះ ជាអារម្មណ៍ ។ ក្នុងបទជាដើមថា ញាណក្នុងឧបក្កិលេសក៏មានន័យនេះដូចគ្នា ៕

## អដ្ឋកថា គណនវារៈ ចប់

# អដ្ឋកថា

## សោឡសញ្ញាណនិទ្ទេស

*បទថា* **សោឡសហិ អាការេហិ** *បានដល់ ដោយញាណ ១៦ ចំណែក ដូចបានពោលហើយដោយចំណែកទាំងពីរ ។ បទថា* **ឧទុចិតំ ចិត្តំ សមុទុចិតំ** *សេចក្ដីថា ចិត្តក្នុងឧបចារភូមិ សន្សំខ្ពស់ឡើង សន្សំខ្ពស់ឡើងដោយប្រពៃ ការកព្វូនខ្ពង់ខ្ពស់ឡើងៗ ធ្វើការកព្វូនខ្ពង់ខ្ពស់ឡើងៗ ដោយប្រពៃ ។ បាឋៈថា* **ឧទុជិតំ ចិត្តំ សមុទុជិតំ** *ក៏មាន ។ ចិត្តឈ្មោះព្រោះខ្ពស់ឡើង ឬឈ្មោះដោយញាណដែលធ្វើការខ្ពស់ឡើង ឈ្មោះថា* **ឧទុជិតំ** ។

*ចិត្តឈ្មោះដោយការខ្ពស់ឡើង ដោយស្មើ ឬដោយញាណដែលធ្វើនូវការខ្ពស់ឡើង ឈ្មោះថា* **សមុទុជិតំ** *បទថា* **សម** *ក្នុងបទថា* **សមុទុជិតំ** *នេះ ជាពាក្យបដិសេធការមិនស្មើ ។ ក្នុងបាឋៈនេះមានឧបសគ្គមួយពាក្យ ២ សព្ទ គឺ* **ឧ** *និង* **ទុ**។ *បាឋៈថា* **ឧ្យជិតំ ចិត្តំ សម្មា្យបជិតំ** *ក៏មាន ។ ក្នុងបាឋៈនេះ ក៏មានសេចក្ដីថា ឈ្មោះហើយដូចគ្នា ។ អាចារ្យពួកមួយពោលថា បទថា* **ឧ្យ អ្យ** *នេះ ត្រឹមតែជានិបាតប៉ុណ្ណោះ ។*

*ក្នុងអដ្ឋកថាវិណោបមសូត្រ ពោលថា* **តជ្ជិតំ** *និង* **សុតជ្ជិតំ** □*គំរាម ហើយគំរាមដោយល្អហើយ ) ។ សេចក្ដីនោះមិនសមគួរក្នុងទីនេះ ។ បទថា* **ឯកត្តេ សណ្ឋិដ្ឋតិ** *បានដល់ រមែងតាំងនៅក្នុងភាពជាធម៌តែមួយ ក្នុងឧបចារ-ភូមិ ដោយមិនមានភាពរាយមាយក្នុងអារម្មណ៍ផ្សេងៗ ។*

[ ៧២ ] *ក្នុងបទនេះថា* **និយ្យានាវរណដ្ឋេន នីវរណា** *លោកពោល*

ថា សូម្បីអរតិ សូម្បីអកុសលទាំងពួង ក៏ឈ្មោះថា នីវរណៈ ដោយអត្ថថា ជាគ្រឿងរារាំង ។ បទថា **និយ្យានាវរណដ្ឋេន** បានដល់ ដោយអត្ថថា ជាគ្រឿងបិទផ្លូវមកនៃធម៌ជាគ្រឿងនាំចេញ ។ បាឋៈថា **និយ្យានាវរណដ្ឋេន** ក៏មាន ។ សេចក្តីថា ដោយអត្ថថាជាគ្រឿងហាមធម៌ដែលជាធម្មជាតនាំចេញ ។

បទថា **នេក្ខម្មំ អរិយានំ និយ្យានំ** សេចក្តីថា នេក្ខម្មៈ ឈ្មោះថា ធម៌ជាគ្រឿងនាំចេញរបស់ព្រះអរិយៈទាំងឡាយដោយឧបចារៈ ព្រោះជាហេតុនៃអរិយមគ្គ ពោល គឺធម៌ជាគ្រឿងនាំចេញរបស់ព្រះអរិយៈទាំងឡាយ ដែលតាំងនៅក្នុងមគ្គ ។ ព្រះអរិយៈទាំងឡាយរមែងនាំចេញ គឺចូលដល់ក្នុងខណៈនៃមគ្គដោយនេក្ខម្មៈនោះដែលជាហេតុ ។ ចំណែកអាចារ្យពួកខ្លះពោលថា មគ្គឈ្មោះថា និយ្យានធម៌ ។ សេចក្តីនោះ មិនត្រឹមត្រូវ ព្រោះក្នុងទីនេះលោកបំណងយកឧបចារៈ និងព្រោះមិនមានអាលោកសញ្ញា និងកុសលធម៌ទាំងពួង ក្នុងខណៈនៃមគ្គ ។ បទថា **និវុតត្តា** បានដល់ ព្រោះត្រូវអកុសលធម៌បិទបាំង ។

បទថា **នប្បជានាតិ** លោកពោលដោយអំណាចនៃបុគ្គល ។ បទថា **វិសុទ្ធចិត្តស្ស** បានដល់ ក្នុងឧបចារភូមិនោះឯង ។ បទថា **ខណិកសមោធានា** មានវិគ្គហៈថា ឈ្មោះថា ខណិកៈ ព្រោះអត្ថថា មានខណៈ ព្រោះកើតឡើងគ្រប់ៗ ខណៈចិត្ត បានដល់ ឧបក្កិលេស ការតាំងមាំ ការប្រជុំ ការ

*ទាក់ទងគ្នានៃធម៌ដែលមានក្នុងខណៈ ឈ្មោះថា ការតាំងមាំប្រព្រឹត្តទៅមួយជួរខណៈ ព្រោះហេតុនោះ ទើបឈ្មោះថា ភាពដែលចិត្តតាំងមាំប្រព្រឹត្តទៅមួយជួរខណៈ មានពាក្យអធិប្បាយថា ឧបក្កិលេសទាំងឡាយ កាលកើត រមែងកើតឡើងដោយអំណាចទាក់ទងគ្នាមួយជួរខណៈ ដោយការបន្តមួយជួរខណៈ គឺមិនកើតឡើងដោយអំណាចខណៈចិត្តមួយដួង ។*

## អដ្ឋកថា សោឡសញ្ញាណនិទ្ទេស ចប់

# អដ្ឋកថា

## ឧបក្កិលេសញ្ញាណនិទ្ទេស

## បឋមច្ឆក្កៈ

[ ៧៣ ] គប្បីជ្រាបវិនិច្ឆ័យ ក្នុងបឋមច្ឆក្កៈដូចតទៅ បទថា **អស្សា-សាទិមជ្ឈបរិយោសានំ** បានដល់ ចុងច្រមុះ ឬនិមិត្តមាត់[(១)] ជាខាងដើមនៃ ខ្យល់ចូលក្នុងខាងក្នុង បេះដូងជាកណ្ដាល មានផ្ចិតជាខាងចុង ។ កាលព្រះ យោគាវចរញ៉ាំងសតិទៅតាមខាងដើម កណ្ដាល និងខាងចុងនៃខ្យល់ដកដង្ហើម ចូលនោះ ចិត្តដល់ភាពរាយមាយក្នុងខាងក្នុង ទៅតាមសភាពផ្សេងគ្នានៃទីតាំង ចិត្តដល់សភាពរាយមាយក្នុងខាងក្នុងនោះ ជាអន្តរាយដល់សមាធិ ព្រោះមិន តាំងនៅក្នុងអារម្មណ៍តែមួយ ។

បទថា **បស្សាសាទិមជ្ឈបរិយោសានំ** បានដល់ ផ្ចិតជាខាងដើមនៃខ្យល់ចេញទៅខាងក្រៅ បេះដូងជាកណ្ដាល ចុងច្រមុះ ឬនិមិត្តមាត់ ឬអាកាសខាងក្រៅជាខាងចុង ។ ក្នុងទីនេះ គប្បីជ្រាបការប្រកបដោយន័យដូចពោលហើយនោះឯង ។

បទថា **អស្សាសបដិកង្ខនា និកន្តិតណ្ហាចរិយា** សេចក្ដីថា ការកំណត់ថា កម្មដ្ឋាននេះទាក់ទងដោយខ្យល់ច្រមុះ ហើយពេញចិត្ត ពោល គឺប្រាថ្នានូវដង្ហើមចូលដែលគ្រោតគ្រាត គឺការប្រព្រឹត្តទៅនៃតណ្ហា ។ កាលមានការប្រ-ព្រឹត្តទៅនៃតណ្ហា ឈ្មោះថា ជាអន្តរាយដល់សមាធិ ព្រោះមិនតាំងនៅក្នុងភាព

---

១- ទីខាងក្រោមច្រមុះ ខាងលើបបូរមាត់ ដែលខ្យល់ដង្ហើមអាចប៉ះត្រូវបាន ។

ជាអារម្មណ៍តែមួយ ។

បទថា **បស្សាសបដិកង្ខនា និកន្តិ** បានដល់ ការពេញចិត្ត ពោល គឺការប្រាថ្នាក្នុងខ្យល់ដកដង្ហើមចេញ ដែលមានខ្យល់ដកដង្ហើមចូល ដែលមានមកអំពីមុនទៀត ។ បទដ៏សេសគប្បីប្រកបតាមន័យដូចពោលហើយនោះឯង ។

បទថា **អស្សាសេនាភិតុន្នស្ស** បានដល់ កាលខ្យល់ដកដង្ហើមចូលវែងពេកទៅ ឬខ្លីពេកទៅ ត្រូវខ្យល់ដកដង្ហើមចូលនោះចាក់ដោតបៀតបៀន ព្រោះមានសេចក្ដីលំបាកនៃកាយ និងចិត្តដែលមានខ្យល់ដកដង្ហើមចូលជាមូល ។

បទថា **បស្សាសបដិលាភេ មុច្ឆនា** បានដល់ សេចក្ដីត្រេកអរក្នុងការបានខ្យល់ដង្ហើមចេញនោះរបស់បុគ្គលដែលមានសេចក្ដីសម្គាល់ថា គួរពេញចិត្តក្នុងខ្យល់ដង្ហើមចេញ ប្រាថ្នាខ្យល់ដង្ហើមចេញ ព្រោះត្រូវខ្យល់ដង្ហើមចូលបៀតបៀន ។ ក្នុងសេចក្ដីលំបាកនៃកាយ និងចិត្តដែលមានខ្យល់ដង្ហើមចេញជាមូល ក៏មានន័យនេះដូចគ្នា ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាព័ន្ធ ដែលលោកពោលដើម្បីពណ៌នាសេចក្ដីដូចដែលបានពោលហើយនោះឯងដូចតទៅ

បទថា **អនុគច្ឆនា** បានដល់ តាមទៅ ។ បទថា **សតិ** បានដល់ សតិដែលជាហេតុឲ្យចិត្តរាយមាយទៅក្នុងខាងក្នុង និងខាងក្រៅ ឈ្មោះថា **វិក្ខេបោ** ព្រោះអត្ថថា ជាហេតុឲ្យចិត្តរាយមាយ ។ នោះគឺអ្វី គឺខ្យល់ដង្ហើមចូល ។ ការរាយមាយដែលមានក្នុងខាងក្នុង ឈ្មោះថា **អជ្ឈត្តវិក្ខេបោ** ការប្រាថ្នានូវភាពរាយមាយដែលមានក្នុងខាងក្នុងនោះ ឈ្មោះថា **អជ្ឈត្តវិក្ខេបាកង្ខនា**

មានពាក្យអធិប្បាយថា សេចក្ដីប្រាថ្នាខ្យល់ដង្ហើមចូលដែលរាយមាយក្នុងខាងក្នុង ដោយអំណាចអយោនិសោមនសិការ ។ គប្បីជ្រាបសេចក្ដីប្រាថ្នាខ្យល់ដង្ហើមចេញដែលរាយមាយខាងក្រៅដោយន័យនេះដូចគ្នា ។ បទថា **យេហិ** បានដល់ ដោយឧបក្កិលេសពួកណា ។ បទថា **វិកម្បមានស្ស** បានដល់ ដែលត្រូវធ្វើឲ្យរាយមាយ គឺឲ្យដល់នូវការរាយមាយ ។

បទថា **នោ ច ចិត្តំ វិមុច្ចតិ** បានដល់ ចិត្តមិនបង្អោនទៅក្នុងអារម្មណ៍ដែលជាអស្សាសបស្សាសៈ និងមិនទាន់រួចផុតចាកធម៌ជាសត្រូវទាំងឡាយ ។ គប្បីជ្រាបការភ្ជាប់សេចក្ដីថា ជាហេតុឲ្យចិត្តមិនរួចផុត និងឲ្យដល់នូវការជឿចំពោះអ្នកដទៃ ។ បទថា **វិមោក្ខំ អប្បជានន្តា** បានដល់ បុគ្គលនោះ ឬបុគ្គលដទៃមិនដឹងច្បាស់នូវវិមោក្ខ ដែលបង្អោនទៅក្នុងអារម្មណ៍ និងនូវវិមោក្ខដែលរួចផុតចាកធម៌ជាសត្រូវយ៉ាងនេះ ។ បទថា **បរបត្តិយា** បានដល់ មានមនុស្សដទៃជាបច្ច័យ ជឿមនុស្សដទៃ មិនមានញាណដែលប្រចក្សដល់ខ្លួន កាលគួរពោលថា **បរបច្ចយិកា** លោកពោលថា **បរបត្តិយា** សេចក្ដីក៏យ៉ាងនោះដូចគ្នា ។l៙៚

# ទុតិយចក្កៈ

[ ៧៤ ] គប្បីជ្រាបវិនិច្ឆ័យ ក្នុងទុតិយចក្កៈដូចតទៅ បទថា **និមិត្តំ** បានដល់ ត្រង់ទីដែលខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញពាល់ត្រូវ ព្រោះថា ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ប៉ះចុងច្រមុះរបស់បុគ្គល ដែលមានច្រមុះវែងប្រព្រឹត្តទៅ ប៉ះបបូរមាត់ខាងលើរបស់បុគ្គលដែលមានច្រមុះខ្លី ។ បើព្រះយោគាវចរនេះនឹកដល់និមិត្តនោះ ចិត្តរបស់ព្រះយោគាវចរ ដែលនឹកដល់និមិត្តនោះ រមែងញាប់ញ័រត្រង់ខ្យល់ដង្ហើមចូល អធិប្បាយថា មិនតាំងនៅបាន ។

កាលចិត្តរបស់ព្រះយោគាវចរនោះ មិនតាំងនៅ ការញាប់ញ័រនោះជាអន្តរាយដល់សមាធិ ព្រោះមិនមានសមាធិ ។ បើនឹកដល់ខ្យល់ដង្ហើមចូលតែម្យ៉ាង ចិត្តរបស់ព្រះយោគាវចរនោះ រមែងនាំមកនូវការរាយមាយ ដោយការចូលទៅក្នុងខាងក្នុង មិនតាំងនៅក្នុងនិមិត្ត ព្រោះហេតុនោះ ទើបចិត្តញាប់ញ័រក្នុងនិមិត្ត ។ គប្បីធ្វើការប្រកបសេចក្តីក្នុងបទដ៏សេស ដោយន័យនេះ ។ ក្នុងគាថាទាំងឡាយ បទថា **វិក្ខិប្បតេ** បានដល់ ធ្វើឲ្យរាយមាយ គឺឲ្យដល់នូវការរាយមាយ ។៚

## តតិយចតុក្កៈ

[ ៧៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងតតិយចតុក្កៈដូចតទៅ បទថា **អតីតានុធាវនំ ចិត្តំ** បានដល់ ចិត្តដែលទៅតាមខ្យល់ដង្ហើមចូល ឬខ្យល់ដង្ហើមចេញដែលហួសទីដែលខ្យល់ពាល់ត្រូវទៅ ។

បទថា **វិក្ខេបានុបតិតំ** បានដល់ ទៅតាមដោយការរាយមាយ ឬធ្លាក់ទៅ គឺទៅតាមការរាយមាយឯង ។ បទថា **អនាគតបដិកង្ខនំ ចិត្តំ** បានដល់ ចិត្តដែលប្រាថ្នា គឺ សង្ឃឹមខ្យល់ដង្ហើមចូល ឬខ្យល់ដង្ហើមចេញដែលមិនទាន់ដល់ទីដែលខ្យល់ពាល់ត្រូវ ។ បទថា **វិកម្បិតំ** បានដល់ ញាប់ញ័រដោយ សេចក្តីរាយមាយដែលមិនតាំងនៅក្នុងខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញនោះ ។ បទថា **លីនំ** បានដល់ ចិត្តរួញរាដោយការព្យាយាមដែលធូរថយពេកជាដើម ។ បទថា **កោសជ្ជានុបតិតំ** បានដល់ ទៅតាមសេចក្តីខ្ជិលច្រអូស ។ បទថា **អតិប្បគ្គហិតំ** បានដល់ ចិត្តដែលមានសេចក្តីឧស្សាហ៍ពេក ដោយប្រារព្ធការព្យាយាមហួសពេកជាដើម ។ បទថា **ឧទ្ធច្ចានុបតិតំ** បានដល់ ទៅតាមសេចក្តីរាយមាយ ។ បទថា **អភិនតំ** បានដល់ បង្អោនទៅក្រៃលែង គឺ ជាប់នៅក្នុងវត្ថុដែលគួរត្រេកអរទាំងឡាយ ។ បទថា **អបនតំ** បានដល់ ថយក្រោយក្នុងវត្ថុដែលមិនគួរត្រេកអរទាំងឡាយ គឺទៅប្រាស ឬបង្អោនទៅប្រាសចាកវត្ថុដែលមិនគួរត្រេកអរនោះ អធិប្បាយថា មិនទាន់ប្រាសចាកវត្ថុនោះ ។ បទថា **រាគានុបតិតំ** បានដល់ កាលព្រះយោគាវចរធ្វើទុកក្នុងចិត្តនូវនិមិត្តនៃខ្យល់ដង្ហើមចូលខ្យល់ដង្ហើមចេញ សេចក្តីត្រេកត្រអាលរមែងធ្លាក់ទៅក្នុងបីតិ និងសុខដែលកើតឡើងហើយ ឬក្នុងរឿង

ដែលត្រេកអរ ជជែក និងប្រឡែងក្នុងកាលមុន ។

បទថា **ព្យាបាទានុបតិតំ** បានដល់ កាលព្រះយោគាវចរ មានចិត្តមិនត្រេកអរក្នុងការធ្វើទុកក្នុងចិត្ត ការព្យាបាទរមែងធ្លាក់ទៅតាមអំណាចនៃទោមនស្សដែលកើតឡើងហើយ ឬក្នុងអាឃាតវត្ថុ ( វត្ថុនៃអាឃាត ) ដែលប្រព្រឹត្តមកក្នុងកាលមុន ។

ក្នុងគាថាទាំងឡាយ មានអធិប្បាយដូចតទៅ បទថា **ន សមាធិយតិ** បានដល់ ចិត្តមិនតាំងមាំ ។ បទថា **អធិចិត្តំ** បានដល់ សមាធិដ៏ក្រៃលែងដែលលោកសម្តែងដោយចិត្តជាប្រធាន ។

[ ៧៦ ] ដោយហេតុមានប្រមាណប៉ុណ្ណេះ ព្រះសារីបុត្តត្ថេរកាលសម្តែងឧបក្កិលេស ១៨ ដោយឆក្កៈ ៣ ហើយ ឥឡូវនេះ កាលនឹងសម្តែងដល់ទោសនៃឧបក្កិលេសទាំងនោះ ដោយឲ្យសម្រេចភាពជាអន្តរាយដល់សមាធិ ទើបពោលពាក្យដដែលទៀតថា **អស្សាសាទិមជ្ឈបរិយោសានំ** ជាដើម ។

ក្នុងបទទាំងនោះ បទថា **កាយោបិ ចិត្តម្បិ សារទ្ធា ច ហោន្តិ** សេចក្តីថា សូម្បីរូបកាយដោយអំណាចនៃរូប ដែលមានការរាយមាយ ជាសមុដ្ឋានសូម្បីចិត្តដោយអំណាចនៃការរាយមាយ ជាសន្តតិ ( ការបន្តគ្នា ) រមែងកម្រើកដោយការកម្រើកដ៏ច្រើន និងរមែងមានសេចក្តីក្រវល់ក្រវាយ ។ ដោយការស្រោលជាងនោះ ក៏រំភើបញាប់ញ័រ ដោយការស្រោលជាងនោះ ក៏ឃ្លេងឃ្លោងកម្រើក ។ រមែងមានការកម្រើកខ្លាំងខ្លះ ស្រាលខ្លះ ទន់ខ្លះ មានពាក្យអធិប្បាយថា បុគ្គលណាមួយ មិនអាចមិនឲ្យកម្រើកបាន ។

បទថា **ចិត្តំ វិកម្បិតត្តា** បានដល់ ព្រោះចិត្តញាប់ញ័រ ។ ក្នុងគាថាទាំងឡាយមានអធិប្បាយថា បទថា **បរិបុណ្ណា អភាវិតា** បានដល់ មិនចម្រើនដោយប្រការដែលឲ្យបរិបូណ៌ ។ បទថា **ឥញ្ជិតោ** បានដល់ រំភើបខ្លាំង ។ បទថា **ផន្ទិតោ** បានដល់ ញាប់ញ័រយ៉ាងទន់ ព្រោះភាពដែលនីវរណៈទាំងឡាយ ក្នុងបទមុនមិនមានរឿងដទៃជ្រែកចូលមក ទើបលោកសម្តែងដោយអច្ចន្តសមីបៈ ( ជិតបំផុត ) ដោយពាក្យថា **ឥមេហិ ច បន នីវរណេហិ** ជាដើម ។ តែក្នុងទីនេះ ព្រោះនីវរណៈទាំងឡាយក្នុងបទសរុប មានរឿងដទៃជ្រែកចូលមក ទើបលោកសម្តែងជាបរម្មុខា ( កំបាំងមុខ ) ដោយពាក្យថា **តេហិ ច បន នីវរណេហិ** ជាដើម ។\៚

**អដ្ឋកថា ឧបក្កិលេសញ្ញាណនិទ្ទេស ចប់**

# អដ្ឋកថា

## វោទានញាណនិទ្ទេស

[ ៧៧ ] បទថា **វោទានេ ញាណានិ** បានដល់ ញាណដែលបរិសុទ្ធ ។ បទថា **តំ វិវជ្ជយិត្វា** គប្បីជ្រាបសេចក្ដីថា វៀរចិត្តដែលស្ទុះទៅតាមអតីតា-រម្មណ៍ ធ្លាក់ទៅខាងចំណែកកាយមាយ ដូចពោលហើយក្នុងកាលមុន ។ បទថា **ឯកដ្ឋានេ សមាទហតិ** បានដល់ តាំងមាំស្មើ គឺឲ្យតាំងទុកចំពោះក្នុងទីដែលខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញ ពាល់ត្រូវ ។ បទថា **តត្ថេវ អធិមោចេតិ** បានដល់ កាលពោលថា **ឯកដ្ឋានេ** ( ក្នុងឋានៈមួយ ) ព្រះយោគាវចររមែងតាំងមាំដោយល្អ គឺធ្វើនូវការសម្រេចចិត្តដោយល្អក្នុងទីដែលខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញ ពាល់ត្រូវនោះឯង ។

បទថា **បគ្គណ្ហិត្វា** បានដល់ ផ្គងចិត្ត ដោយចម្រើនធម្មវិចយសម្ពោជ្ឈង្គ និងបីតិសម្ពោជ្ឈង្គ ។ បទថា **វិនិគ្គណ្ហិត្វា** បានដល់ សង្កត់ចិត្ត ដោយការចម្រើនបស្សទ្ធិសម្ពោជ្ឈង្គ សមាធិសម្ពោជ្ឈង្គ និងឧបេក្ខាសម្ពោជ្ឈង្គ ។ អាចារ្យពួកមួយពោលថា ផ្គងចិត្ត ដោយសតិន្ទ្រិយ និងវីរិយិន្ទ្រិយ សង្កត់ចិត្តដោយសតិន្ទ្រិយ និងសមាធិន្ទ្រិយក៏មាន ។

បទថា **សម្បជានោ ហុត្វា** បានដល់ ដឹងទាន់ដោយអសុភភាវនាជាដើម ។ លោកពោលថា **សម្បជានោ ហុត្វា** ដដែលទៀត ដោយមេត្តា-ភាវនាជាដើម ។ គប្បីជ្រាបការភ្ជាប់សេចក្ដីថា ព្រះយោគាវចររមែងលះរាគៈ និងព្យាបាទដែលចិត្តធ្លាក់ទៅតាម ។ ម្យ៉ាងទៀត អធិប្បាយថា កាលដឹងទាន់ថា ចិត្តនោះ បែបនេះ រមែងលះរាគៈ និងព្យាបាទដោយធម៌ដែលជា

សត្រូវចំពោះរាគៈ និងព្យាបាទនោះ ។ បទថា **បរិសុទ្ធំ** បានដល់ មិនមានឧបក្កិលេស ។ បទថា **បរិយោទាតំ** បានដល់ ត្រចះត្រចង់ ។ បទថា **ឯកត្តគតំ ហោតិ** បានដល់ កាលព្រះយោគាវចរដល់នូវភាពវិសេសនោះៗ ចិត្តនោះៗ ក៏រមែងដល់ភាវៈជាធម៌តែមួយ ។

[ ៧៨ ] បទថា **កតមេ តេ ឯកត្តា** ព្រះសារីបុត្តត្ថេររមែងសួររួមគ្នានូវភាវៈជាធម៌តែមួយដែលប្រកបបាន និងប្រកបមិនបាន ។ បទថា **ទានូបសគ្គុបដ្ឋានេកត្តំ** សេចក្តីថា ការចូលទៅលះបង់ គឺការលះបង់ទាន ពោលគឺទានវត្ថុ ឈ្មោះថា ទានូបសគ្គៈ បានដល់ ចេតនាបរិច្ចាគទានវត្ថុ ។ ការប្រាកដនៃទានូបសគ្គៈនោះ គឺការចូលទៅតាំងទុកដោយអំណាចធ្វើឲ្យជាអារម្មណ៍ ឈ្មោះថា ទានូបសគ្គុបដ្ឋាន ។ ភាពជាធម៌តែមួយ គឺទានូបសគ្គុបដ្ឋាននោះឯង ។ ម្យ៉ាងទៀត ភាពជាធម៌តែមួយ គឺការដល់អារម្មណ៍តែមួយដោយទានូបសគ្គុបដ្ឋាននោះ ឈ្មោះថា ទានូបសគ្គុបដ្ឋានេកត្តៈ ។ បាឋៈថា **ទានវោសគ្គុបដ្ឋានេកត្តំ** ល្អជាង ឯសេចក្តីក៏ដូចគ្នា ។

ដោយបទថា ទានវោសគ្គុបដ្ឋានេកត្តៈនេះ លោកពោលដល់ចាគានុស្សតិសមាធិដោយការលើកបទឡើង ។ ម្យ៉ាងទៀត ចាគានុស្សតិនោះសូម្បីលោកពោលហើយដោយការលើកពាក្យឡើង ក៏ជាឧបនិស្សយប្បច្ច័យដល់ភាពជាធម៌តែមួយ សូម្បី ៣ យ៉ាងក្រៅពីនេះ ព្រោះហេតុនោះ ទើបអាចារ្យពួកមួយពោលក្នុងទីនេះថា លោកចង្អុលបង្ហាញហើយ ។ ពិតហើយ សូម្បីនាងវិសាខាមហាឧបាសិកា ក៏នៅក្រាបទូល ( ក្នុងវិនយបិដក មហាវគ្គ ) ថា

នាងវិសាខាក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកភិក្ខុក្នុងសាសានានេះ នៅចាំវស្សាក្នុងទិសទាំងឡាយរួចហើយ នឹងមកកាន់ក្រុងសាវត្ថី ដើម្បីគាល់ព្រះអង្គ ភិក្ខុទាំងនោះនឹងចូលគាល់ព្រះអង្គហើយសួរថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុឈ្មោះនេះធ្វើមរណកាលហើយ ភិក្ខុនោះមានគតិដូចម្តេច មានបរលោកដូចម្តេច ព្រះដ៏មានព្រះភាគ មុខជានឹងព្យាករបញ្ហានោះក្នុងសោតា-បត្តិផលក្តី សកទាគាមិផលក្តី អនាគាមិផលក្តី អរហត្តផលក្តី ខ្ញុំព្រះអង្គនឹងចូលទៅរកភិក្ខុទាំងនោះហើយនឹងសួរថា បពិត្រលោកម្ចាស់ទាំងឡាយដ៏ចម្រើន លោកម្ចាស់នោះ ធ្លាប់និមន្តមកក្រុងសាវត្ថីដែរឬ ប្រសិនបើពួកភិក្ខុនិយាយប្រាប់ខ្ញុំព្រះអង្គថា ភិក្ខុនោះធ្លាប់មកក្រុងសាវត្ថីដែរ ខ្ញុំព្រះអង្គនឹងដល់នូវសេចក្តីចូលចិត្តក្នុងហេតុនេះថា ច្បាស់ជាលោកម្ចាស់នោះធ្លាប់បានបរិភោគវស្សិ-កសាដកក្តី អាគន្តុកភត្តក្តី គមិកភត្តក្តី គិលានភត្តក្តី គិលានុបដ្ឋាកភត្តក្តី គិលានភេសជ្ជៈក្តី ធុវយាគូក្តី ( មិនខាន ) កាលខ្ញុំព្រះអង្គនោះ រឭកទាននោះរឿយៗ ហើយ សេចក្តីត្រេកអរទន់នឹងកើតឡើង កាលបើសេចក្តីត្រេកអរទន់កើតឡើងហើយ ចិត្តប្រកបដោយបីតិនឹងកើតឡើង កាលបើចិត្តប្រកបដោយបីតិកើតឡើងហើយ កាយក៏នឹងស្ងប់រម្ងាប់ លុះខ្ញុំព្រះអង្គមានកាយស្ងប់រម្ងាប់ហើយ នឹងទទួលសេចក្តីសុខ កាលបើខ្ញុំព្រះអង្គបានទទួលសេចក្តីសុខហើយ ចិត្តក៏នឹងតម្កល់មាំ ឥន្ទ្រិយភាវនា ពលភាវនា ពោជ្ឈង្គភាវនានោះ នឹងមានដល់ខ្ញុំព្រះអង្គ ដូច្នេះ ។ ម្យ៉ាងវិញទៀត គប្បីជ្រាបថា ក្នុងភាពជាធម៌តែមួយ លោកពោលដល់ធម៌ទីមួយដោយឧបចារសមាធិ ធម៌ទីពីរដោយអប្បនា-

សមាធិ ធម៌ទីបីដោយវិបស្សនាសមាធិ ធម៌ទីបួនដោយមគ្គ និងផល ។ និមិត្តនៃសមថៈ ឈ្មោះថា សមថនិមិត្ត ។

លក្ខណៈ គឺការអស់ទៅ ការបែកធ្លាយទៅ ឈ្មោះថា **វយលក្ខណា** ។ បទថា **និរោធោ** បានដល់ ព្រះនិព្វាន ។ បទដ៏សេសក្នុងបទ ៣ នេះ គប្បីប្រកបតាមន័យដែលពោលហើយ ។ បទថា **ចាគាធិមុត្តានំ** បានដល់ របស់បុគ្គលអ្នកបង្អោនទៅក្នុងទាន ។ បទថា **អធិចិត្តំ** បានដល់ សមាធិដែលជាបាទនៃវិបស្សនា ។ បទថា **វិបស្សកានំ** បានដល់ របស់បុគ្គលដែលឃើញច្បាស់សង្ខារទាំងឡាយដោយអនុបស្សនា ៣ តាំងអំពីភង្គានុបស្សនា ។ បទថា **អរិយបុគ្គលានំ** បានដល់ ព្រះអរិយបុគ្គល ៨ ។ ភាពជាធម៌តែមួយ ៣ មានធម៌ទី ២ ជាដើម រមែងប្រកបដោយអានាបានស្សតិ និងដោយអំណាចកម្មដ្ឋានដ៏សេស ។ បទថា **ចតូហិ ឋានេហិ** បានដល់ ដោយហេតុ ៤ ។ បទថា **ឯកត្តគតំ ចិត្តំ បដិបទាវិសុទ្ធិបក្ខន្ទញ្ចេវ ហោតិ** ដោយអំណាចនៃសមាធិ វិបស្សនា មគ្គ និងផលជាពាក្យឧទ្ទេស ។ ពាក្យដែលជាពាក្យសួរដែលប្រាថ្នានឹងធ្វើពាក្យឧទ្ទេសទាំងនោះឲ្យពិស្តារដែលជាខាងដើមថា បឋមជ្ឈានមានអ្វីជាខាងដើមជាដើម ជាពាក្យនិទ្ទេស ។

ក្នុងបទទាំងនោះ បទថា **បដិបទាវិសុទ្ធិបក្ខន្ទំ** បានដល់ បដិបទានោះឯង ឈ្មោះថា វិសុទ្ធិ ព្រោះជម្រះមន្ទិល គឺនីវរណៈ ចិត្តស្ទុះទៅ គឺចូលទៅកាន់បដិបទាវិសុទ្ធិនោះ ។ បទថា **ឧបេក្ខានុព្រូហិតំ** បានដល់ លូតលាស់ចម្រើនដោយតត្រមជ្ឈត្តុបេក្ខា ។ បទថា **ញាណេន ច សម្បហំសិតំ** បាន

ដល់ រីករាយ ផូរផង់ បរិសុទ្ធដោយញាណដែលផូរផង់ ។

[ ៧៩ ] អាចារ្យពួកមួយពណ៌នាយ៉ាងនេះថា ឧបចារៈ មួយអន្ទើដោយអន្តរាយ ឈ្មោះថា **បដិបទាវិសុទ្ធិ** អប្បនា ឈ្មោះថា **ឧបេក្ខានុព្រូហនា** បច្ចវេក្ខណៈ ឈ្មោះថា **សម្បហំសនា** ។

ម្យ៉ាងទៀត ព្រោះលោកពោលបទថា **ឯកត្តគតំ ចិត្តំ បដិបទាវិសុទ្ធិ-បក្ខន្ទញ្ចេវ ហោតិ** ជាដើម គប្បីជ្រាបបដិបទាវិសុទ្ធិដោយអំណាចការមកនៃអប្បនា ខាងក្នុងនោះឯង ការចម្រើនឧបេក្ខាដោយអំណាចកិច្ចនៃតត្រមជ្ឈត្ត-បេក្ខា ការរីករាយព្រមដោយអំណាចការសម្រេចកិច្ចនៃញាណ ដែលផូរផង់ដោយឲ្យសម្រេចភាពដែលធម៌ទាំងឡាយ មិនកន្លងគ្នាជាដើម ។

[ ៨០ ] សេចក្ដីនេះ តើដូចម្ដេច ក្នុងវារៈណាអប្បនាកើតឡើង ក្នុងវារៈនោះ ចិត្តរមែងបរិសុទ្ធចាកពួកកិលេស គឺនីវរណៈដែលជាអន្តរាយដល់ឈាននោះ ជាចិត្តប្រាសចាកគ្រឿងរាំង ព្រោះចិត្តបរិសុទ្ធ ទើបប្រព្រឹត្តទៅកាន់សមថនិមិត្តដែលជាកណ្ដាល អប្បនាសមាធិនោះឯង ប្រព្រឹត្តទៅស្មើ ឈ្មោះថា សមថនិមិត្តជាកណ្ដាល ។

តែបុរិមចិត្ត ( ចិត្តដួងមុន ) ដែលជាប់គ្នាជាមួយអប្បនាសមាធិចិត្តនោះ ដែលចូលដល់ភាពជាយ៉ាងនោះ ដោយន័យនៃការប្រែប្រួលនៃសន្តតិមួយ ឈ្មោះថា រមែងប្រព្រឹត្តទៅកាន់សមថនិមិត្ត ដែលជាកណ្ដាល ។ ព្រោះប្រព្រឹត្តទៅយ៉ាងនេះ ទើបចិត្ត ឈ្មោះថា ស្ទុះទៅក្នុងសមថនិមិត្តនោះ ដោយចូលដល់ភាពជាយ៉ាងនោះ ។

គប្បីជ្រាបបដិបទាវិសុទ្ធិដែលសម្រេចអាការ មាននៅក្នុងបុរិមចិត្តយ៉ាងនេះមុន ដោយអំណាចនៃការមកក្នុងខណៈបឋមជ្ឈានកើតនោះឯង ។

[ ៨១ ] ព្រះយោគាវចរ កាលមិនធ្វើសេចក្តីខ្វល់ខ្វាយក្នុងការជម្រះចិត្ត ព្រោះចិត្តដែលបរិសុទ្ធហើយយ៉ាងនោះ មិនមានវត្ថុដែលគួរជម្រះទៀត ទើបឈ្មោះថា សម្លឹងផ្ទៀងផ្ទាត់ គឺត្រង់ដែលចិត្តបរិសុទ្ធ ។

ព្រះយោគាវចរ កាលមិនធ្វើសេចក្តីខ្វល់ខ្វាយក្នុងការសមាទានចិត្ត ដែលប្រព្រឹត្តទៅកាន់សមថៈទៀត ព្រោះចូលដល់ភាពជាសមថៈ ទើបឈ្មោះថា ចិត្តដើរឆ្ពោះទៅរកសមថៈ សម្លឹងផ្ទៀងផ្ទាត់ ។

ព្រះយោគាវចរ កាលមិនធ្វើសេចក្តីខ្វល់ខ្វាយក្នុងការប្រាកដ ក្នុងភាពជាធម៌តែមួយនៃចិត្ត ដែលលះនូវការជាប់ជំពាក់ដោយកិលេស ហើយប្រាកដដោយភាពជាធម៌តែមួយ ព្រោះជាចិត្តប្រព្រឹត្តទៅកាន់សមថៈហើយនោះឯង ទើបឈ្មោះថា ចិត្តតាំងឡើងក្នុងឯកត្តៈ សម្លឹងផ្ទៀងផ្ទាត់ ។

គប្បីជ្រាបការចម្រើនឡើងនូវឧបេក្ខា ដោយអំណាចកិច្ចនៃតត្រមជ្ឈត្តុបេក្ខា ដោយប្រការដូច្នេះ ។

[ ៨២-៨៦ ] ធម៌ជាគូ គឺសមាធិ និងបញ្ញា ពួកណាដែលកើតហើយក្នុងចិត្តនោះដែលចម្រើនឡើងដោយឧបេក្ខាយ៉ាងនេះ មិនកន្លងនូវគ្នានិងគ្នាប្រព្រឹត្តទៅហើយ ឥន្ទ្រិយមានសទ្ធិន្ទ្រិយជាដើម ពួកណាមានរសតែមួយដោយវិមុត្តិរស ព្រោះផុតចាកកិលេសផ្សេងៗ ប្រព្រឹត្តទៅ ព្រះយោគាវចរនោះ នាំសេចក្តីព្យាយាមណាដែលចូលដល់សភាវៈពីរយ៉ាងនោះ គឺដែលសមគួរដល់ភាពដែល

ធម៌ទាំងឡាយ មិនកន្លងគ្នានិងគ្នា និងភាពដែលឥន្ទ្រិយទាំងឡាយ មានរសតែមួយ ការសេពណាដែលប្រព្រឹត្តទៅហើយក្នុងខណៈនោះ នៃចិត្តនោះ អាការទាំងអស់នោះ ឈ្មោះថា សម្រេចហើយ ព្រោះចិត្តឃើញទោសក្នុងការសៅហ្មង និងឃើញអានិសង្សក្នុងការផូរផង់នោះៗ ដោយញាណ ទើបជាចិត្តរីករាយ និងជាចិត្តផូរផង់ដោយអាការនោះៗ ព្រោះហេតុណា ហេតុនោះទើបលោកពោលថា គប្បីជ្រាបការរីករាយដោយអំណាចនៃការសម្រេចកិច្ចនៃញាណ ដែលផូរផង់ហើយដោយឲ្យសម្រេចភាពដែលធម៌ទាំងឡាយមិនកន្លងគ្នានិងគ្នាជាដើម ។

ក្នុងបទនោះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ព្រោះញាណប្រាកដដោយអំណាចនៃឧបេក្ខា ដូចដែលព្រះសារីបុត្តត្ថេរពោលថា ចិត្តដែលបុគ្គលតម្កល់មាំហើយដូច្នោះ រមែងផ្គងឡើងដោយប្រពៃ បញ្ញិន្ទ្រិយជាធម្មជាតដ៏ក្រៃលែងដោយអំណាចនៃការផ្គងឡើង និងដោយអំណាចនៃបញ្ញា ចិត្តដែលបុគ្គលផ្គងឡើងហើយដូច្នោះ រមែងព្រងើយកន្តើយដោយប្រពៃ បញ្ញិន្ទ្រិយជាធម្មជាតដ៏ក្រៃលែង ដោយអំណាចនៃសេចក្ដីព្រងើយកន្តើយ និងដោយអំណាចនៃបញ្ញា ចិត្តរមែងរួចស្រឡះ ចាកកិលេសផ្សេងៗ ដោយអំណាចនៃសេចក្ដីព្រងើយកន្តើយ បញ្ញិន្ទ្រិយជាធម្មជាតដ៏ក្រៃលែង ដោយអំណាចនៃការរួចស្រឡះ និងដោយអំណាចនៃបញ្ញា ធម៌ទាំងឡាយនោះមានរសតែមួយ ព្រោះរួចស្រឡះ បញ្ញិន្ទ្រិយ ជាធម្មជាតដ៏ក្រៃលែង ដោយអត្ថថា មានរសតែមួយ ដោយអំណាចនៃការអប់រំ ដូច្នេះ ហេតុនោះ ទើបលោកពោលថា ការរីករាយដែលជាកិច្ចនៃញាណជាទីបំផុត ។

បទថា **ឯវំ តិវត្តគតំ** ជាពាក្យសរសើរចិត្តនោះ ។ ក្នុងបទទាំងនោះ បទថា **ឯវំ តិវត្តគតំ** បានដល់ ចិត្តដែលដល់នូវការប្រព្រឹត្តទៅ ៣ យ៉ាង ដោយអំណាចនៃការស្ទុះទៅកាន់បដិបទាវិសុទ្ធិ ការចម្រើនឡើងនូវឧបេក្ខា និងការរីករាយដោយញាណ ដោយវិធីតាមដែលពោលហើយយ៉ាងនេះ ។

បទថា **វិតក្កសម្បន្នំ** បានដល់ ដល់ គឺទៅកាន់ភាពជាចិត្តស្អាតដោយវិតក្ក ព្រោះប្រាសចាកការកម្រើកនៃកិលេស ។

បទថា **ចិត្តស្ស អធិដ្ឋានសម្បន្នំ** បានដល់ ចិត្តបរិបូណ៌ មិនខ្វះដោយការអធិដ្ឋាន ពោល គឺប្រព្រឹត្តទៅតាមលំដាប់នៃចិត្តក្នុងអារម្មណ៍នោះឯង ការប្រព្រឹត្តទៅនៃឈាន ឈ្មោះថា អធិដ្ឋាន ព្រោះការជំនាញនៃអធិដ្ឋានយ៉ាងណា សូម្បីក្នុងទីនេះ សភាពដែលចិត្តមានអារម្មណ៍តែមួយ ឈ្មោះថា អធិដ្ឋានចិត្ត រមែងសមគួរយ៉ាងនោះ ពិតហើយ ចិត្តរមែងតាំងនៅក្នុងអារម្មណ៍តែមួយប៉ុណ្ណោះ គឺចិត្តក្នុងអារម្មណ៍នេះ រមែងមិនរាយមាយ តែព្រោះពោលថា **សមាធិសម្បន្នំ** ដោយឡែក ទើបគួរកាន់យកតាមន័យដែលពោលហើយនោះឯង ។ម្យ៉ាងទៀត បទថា **ចិត្តស្ស អធិដ្ឋានសម្បន្នំ** លោកពោលដោយអំណាចពួក ៥ នៃអង្គឈាន ព្រោះសង្គ្រោះសមាធិនោះឯង ចូលក្នុងអង្គឈាន ។ បទថា **សមាធិសម្បន្នំ** លោកពោលដោយអំណាចពួក ៥ នៃឥន្ទ្រិយ ព្រោះសង្គ្រោះ សមាធិចូលក្នុងឥន្ទ្រិយ ។ តែក្នុងទុតិយជ្ឈានជាដើម លោកលះបទដែលមិន មាន ហើយពោលថា បរិបូរដោយបីតិជាដើម ដោយអំណាចនៃបទ ដែលមាន ។

[ ៨៧-៩០ ] ក្នុងមហាវិបស្សនា ១៨ មានអនិច្ចានុបស្សនាជាដើម វិតក្កជាដើម បរិបូណ៌ហើយ ព្រោះមហាវិបស្សនាទាំងនោះ ជាកាមាវចរ ។ ព្រោះក្នុងមហាវិបស្សនាទាំងនោះ មិនមានអប្បនា ទើបគួរប្រកបបដិបទា-វិសុទ្ធិជាដើម ដោយអំណាចនៃខណិកសមាធិ ។ ក្នុងមគ្គទាំង ៤ លោកពោលវិតក្កជាដើម ដោយអំណាចមាននៅនោះឯង ព្រោះវិតក្កជាដើម មានដោយអំណាចមគ្គដែលប្រកបដោយបឋមជ្ឈាន ។ ក្នុងមគ្គដែលប្រកបដោយទុតិ-យជ្ឈានជាដើម វិតក្កជាដើម រមែងបាត់ទៅដូចក្នុងឈានទាំងឡាយ ។ ដោយហេតុមានប្រមាណប៉ុណ្ណេះ ឈ្មោះថា លោកសម្តែងវោទានញ្ញាណ ១៣ ប្រការដោយពិស្តារ ។

សម្តែងដូចម្តេច លោកសម្តែងញាណទាំង ១៣ នេះ គឺញាណ ៦ ដែលប្រកបដោយការតាំងមាំ ក្នុងទីតែមួយដោយការបង្អោនទៅក្នុងការតាំងមាំនោះឯង ដោយការលះសេចក្តីខ្ជិលច្រអូស ដោយការលះសេចក្តីរាយមាយ ដោយការលះរាគៈ ដោយការលះព្យាបាទ ញាណ ៤ ប្រកបដោយភាពជាធម៌តែមួយ ៤ ញាណ ៣ ដែលប្រកបដោយបដិបទាវិសុទ្ធិ ការចម្រើនឡើងនៃឧបេក្ខា និងភាពរីករាយ ។

[ ៩១ ] សូម្បីយ៉ាងនេះ ព្រះសារីបុត្តត្ថេរ បំណងនឹងសម្តែងសេចក្តីសម្រេចនៃញាណទាំងនោះ ដោយអំណាចនៃការចម្រើនអានាបានស្សតិសមាធិ ទើបមិនសរុបញាណទាំងនោះ តែសម្តែងវិធីចម្រើនអានាបានស្សតិសមាធិមុន ពាក្យសួរដោយន័យថា និមិត្ត ១ អស្សាសៈ ១ បស្សាសៈ ១ ជាដើម

*ហើយសម្តែងសរុបញាណទាំងនោះក្នុងខាងចុង ។ និមិត្តក្នុងអានាបានស្សតិនោះ លោកពោលហើយ ។*

*បទថា* **អនារម្មណាមេកចិត្តស្ស** *បានដល់ មិនជាអារម្មណ៍នៃចិត្តដួងមួយ ។ ក្នុងបទនេះ* **ម** *អក្ខរៈ ជាបទសន្ធិ ។ បាឋៈថា* **អនារម្មណាមេក-ចិត្តស្ស** *ក៏មាន សេចក្តីថា មិនជាអារម្មណ៍នៃចិត្តដួងមួយ ។ បទថា* **តយោធម្មេ** *បានដល់ ធម៌ ៣ ប្រការ មាននិមិត្តជាដើម ។ បទថា* **ភាវនា** *បានដល់ អានាបានស្សតិសមាធិភាវនា ។*

*[ ៩២ ] បទថា* **កថំ** *ជាពាក្យសួរ ដែលប្រាថ្នានឹងពោលអត្ថរបស់បរិហារគាថាដែលពោលហើយ ក្នុងលំដាប់នៃចោទនាគាថា ដែលពោលជាគាថាទីមួយ ។ បទថា* **ន ចិមេ** *កាត់បទថា* **ន ច ឥមេ** *បាឋៈថា* **ន ច មេ** *ដូច្នេះក៏មាន ។ បាឋៈនោះ ជាបាឋៈកាត់បទ ។*

*គប្បីប្រកប* **កថំ** *សព្វ ដោយបទសូម្បីដ៏សេស ៥ យ៉ាងនេះថា* **កថំ ន ច អវិទិតា ហោន្តិ កថំ ន ច ចិត្តំ វិក្ខេបំ គច្ឆតិ** *ជាដើម ។ បទថា* **បធានញ្ច បញ្ញាយតិ** *បានដល់ ការព្យាយាមដែលផ្តើមចម្រើនអានាបានស្សតិសមាធិប្រាកដ ។ ការព្យាយាមលោកពោលថាជាបធាន ព្រោះអត្ថថាជាហេតុផ្តើមប្រារព្ធ ។ បទថា* **បយោគញ្ច សាធេតិ** *បានដល់ ព្រះយោគាវចរញ៉ាំងឈានដែលសង្កត់សង្កិននីវរណៈ ឲ្យសម្រេច ។ ឈាន លោកពោលថា* **បយោគ** *ព្រោះប្រកបដោយការសង្កត់សង្កិននីវរណៈ ។ បទថា* **វិសេសមធិគច្ឆតិ** *បានដល់ បានមគ្គដែលធ្វើការលះសំយោជនៈ ។ មគ្គ*

លោកពោលថា គុណវិសេស ព្រោះជាអានិសង្សនៃសមថៈ និងវិបស្សនា ។ ម្យ៉ាងទៀត ព្រោះគុណវិសេសជាប្រធាន ទើបមិនធ្វើការផ្គួបបទដោយ ច អក្ខរៈ ។

ឥឡូវនេះ ព្រះសារីបុត្តត្ថេរ កាលធ្វើអត្ថដែលសួរនោះ ឲ្យសម្រេចដោយឧបមា ទើបពោលពាក្យថា **សេយ្យថាបិ រុក្ខោ** ជាដើម ។

សេចក្ដីឧបមានោះ មានន័យដូចតទៅនេះ ប្រៀបដូចដើមឈើដែលមេជាងយកកាំបិតចាំងហើយ ក្នុងទីសមគួរដល់ការអារលើផែនដី ដែលរៀបស្មើ ដើម្បីកុំឲ្យរង្គើក្នុងពេលអារជាបន្ទះ ដើម្បីនឹងអារឲ្យជាបន្ទះយ៉ាងណា ។ បទថា **កកចេន** បានដល់ រណារដៃ ។ បទថា **អាគតេ** បានដល់ ធ្មេញរណារដែលអារដើមឈើ មកកាន់ចំណែកជិតខ្លួន ។ បទថា **គតេ** បានដល់ ធ្មេញរណារដែលអារដើមឈើ ទៅកាន់ចំណែកបុគ្គលដទៃ ។ **វា** សព្ទ ជាសមុច្ចយត្ថៈ ចុះក្នុងអត្ថ ( រួបរួម ) ។ បទថា **ន អវិទិតា ហោន្តិ** បានដល់ ធ្មេញរណារ សូម្បីទាំងអស់ជារបស់ប្រាកដហើយនោះឯង ព្រោះមិនមានការទៅ ឬការមករបស់ធ្មេញរណារទាំងនោះ ដែលមិនទាន់ដល់តំណែង ដែលធ្មេញរណារពាល់ត្រូវត្រង់ដើមឈើ ដែលបុរសសម្លឹងមើល ។ បទថា **បធានំ** បានដល់ សេចក្ដីព្យាយាមក្នុងការកាត់ដើមឈើ ។ បទថា **បយោគំ** បានដល់ កិរិយាដែលកាត់ដើមឈើ ។ បទថា **វិសេសមធិគច្ឆតិ** មិនមានដោយឧបមា ។

បទថា **ឧបនិពន្ធនា និមិត្តំ** បានដល់ ចុងច្រមុះក្ដី បបូរមាត់ក្ដី ជានិមិត្ត

គឺជាហេតុនៃសតិដែលចងទុក ។ សតិ ឈ្មោះថា **ឧបនិពន្ធនា** ព្រោះអត្ថថា ជាគ្រឿងចងចិត្តទុកក្នុងអារម្មណ៍ ។ បទថា **នាសិកគ្គេ វា** បានដល់ អ្នកមានច្រមុះវែង តម្កល់សតិត្រង់ចុងច្រមុះ ។ បទថា **មុខនិមិត្តេ វា** បានដល់ អ្នកមានច្រមុះខ្លី តម្កល់សតិទុកត្រង់បបូរមាត់ខាងលើ ។ បបូរមាត់លើ ហៅថា មុខនិមិត្ត ព្រោះនិមិត្តនៃសតិមានត្រង់មាត់ ។ បទថា **អាគតេ** បានដល់ ដែលចូលមកខាងក្នុងអំពីទីដែលប៉ះ ។ បទថា **គតេ** បានដល់ ដែលចេញទៅខាងក្រៅអំពីទីដែលប៉ះ ។ បទថា **ន អវិទិតា ហោន្តិ** បានដល់ ខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញ ទាំងអស់នោះ រមែងប្រាកដនោះឯង ។ ព្រោះមិនមានការចូល ការចេញនៃខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញដែលមិនទាន់ដល់ទីដែលប៉ះ ។

[ ៩៣ ] បទថា **កម្មនិយំ ហោតិ** បានដល់ ទាំងកាយទាំងចិត្ត រមែងគួរដល់ការងារសមគួរដល់ការនៃកម្ម សមគួរដល់ការនៃកម្មដោយសេចក្តីព្យាយាមណា សេចក្តីព្យាយាមនេះ ឈ្មោះថា បធាន ព្រោះហេតុនោះ ទើបលោកពោលដល់ហេតុដោយផល ។

បទថា **ឧបក្កិលេសា បហីយន្តិ** បានដល់ លះនីវរណៈបានដោយការសង្កត់សង្កិន ។ បទថា **វិតក្កា វូបសមន្តិ** បានដល់ វិតក្កដែលប្រព្រឹត្តទៅក្នុងអារម្មណ៍ផ្សេងៗ មិនតាំងមាំ រមែងដល់ការស្ងប់ ។ ឧបក្កិលេស ត្រូវរម្ងាប់បានដោយឈានណា វិតក្កទាំងឡាយ រមែងស្ងប់ដោយឈាននោះ ។ បទថា **អយំ បយោគោ** លោកធ្វើនិទ្ទេសជាបុំលិង្គ ព្រោះសម្ព័ន្ធដល់

បយោគ ។ បទថា **សញ្ញោជនា បហីយន្តិ** បានដល់ លះបង់សំយោជនៈដែល មគ្គនោះៗ គប្បីសម្លាប់ រមែងលះបានដោយសមុច្ឆេទប្បហាន ។ បទថា **អនុសយា ព្យន្តីហោន្តិ** មានវិគ្គហៈថា ទីបំផុតនៃការកើតឡើង ឬទីបំផុតនៃការសូន្យទៅនៃអនុស័យទាំងនោះ ទៅប្រាសហើយ ព្រោះអនុស័យដែលលះបានហើយ មិនមានការកើតឡើងទៀតជាធម្មតា ព្រោះហេតុនោះ ទើបឈ្មោះថាមានទីបំផុតអស់ទៅ អនុស័យដែលមានទីបំផុតមិនទាន់អស់ទៅក្នុងកាលមុន រមែងមានទីបំផុតអស់ទៅ ព្រោះហេតុនោះ ទើបឈ្មោះថា **ព្យន្តីហោន្តិ** អធិប្បាយថា វិនាសទៅ ។ ដើម្បីសម្តែងថាការលះសំយោជនៈ រមែងមានដោយការលះអនុស័យ មិនមែនដោយប្រការដទៃ ទើបលោកពោលដល់ការលះអនុស័យ អធិប្បាយថា លះសំយោជនៈបានដោយមគ្គណា អនុស័យរមែងមានទីបំផុតអស់ទៅដោយមគ្គនោះ នេះជាគុណវិសេស ។

លោកពោលដល់អរិយមគ្គក្នុងទីនេះ ព្រោះសូម្បីអរិយមគ្គ លោកក៏បានចង្អុលបង្ហាញហើយ ក្នុងចតុក្កៈដែលជាលំដាប់ទី ៤ ព្រោះចិត្តដួងមួយមិនមានអារម្មណ៍ ២ សូម្បីមិនពោលដល់ក៏យល់បាន ទើបមិនឆ្លើយសេចក្តីនោះ តែធ្វើការសរុបថា នេះធម៌ ៣ យ៉ាង ដែលមិនមែនជាអារម្មណ៍នៃឯកចិត្ត យ៉ាងនេះឯង ។

[ ៩៤ ] ឥឡូវនេះ ព្រះសារីបុត្តត្ថេរ កាលនឹងសរសើរព្រះយោគាវចរអ្នកសម្រេចភាវនានោះ ទើបពោលគាថាថា **អានាបានស្សតិ យស្ស** ហើយ ពោលនិទ្ទេសនៃគាថានោះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទទាំងនោះដូចតទៅនេះ ភិក្ខុណា ចម្រើនអានាបានស្សតិ បានបំពេញហើយ ចម្រើនហើយដោយប្រពៃ សន្សំហើយដោយលំដាប់ ឲ្យដូចព្រះពុទ្ធ ទ្រង់សម្តែងហើយមាន គឺប្រាកដ ភិក្ខុនោះ រមែងញុំាងលោកនេះឲ្យភ្លឺច្បាស់ ដូចអ្វី ដូចព្រះចន្ទដែលផុតស្រឡះចាកពពក ។ គប្បីជ្រាបការភ្ជាប់សេចក្តីនៃគាថាថា ព្រះយោគាវចរនោះ ញុំាងលោក មានខន្ធលោកជាដើមនេះឲ្យភ្លឺស្វាង ដូចព្រះចន្ទផុតហើយចាកពពកជាដើម ញុំាងឱកាសលោកនេះឲ្យភ្លឺស្វាង ដូច្នោះ ។ ក្នុងនិទ្ទេសនៃបទថា **អព្ភា មុត្តោវ ចន្ទិមា** គប្បីជ្រាបថា ក្នុងទីនេះ លោកធ្វើការលុប **អាទិ** សព្ទ ព្រោះសូម្បីពពកជាដើម លោកក៏ពោលផងដែរ ។

ក្នុងគាថានិទ្ទេស លោកពោលឲ្យវិសេសដោយបដិសេធសេចក្តីនោះថា **នោ បស្សាសោ នោ អស្សាសោ** ដូច្នេះ ។

បទថា **ឧបដ្ឋានំ សតិ** សេចក្តីថា ការចូលដល់ខ្យល់ដង្ហើមចូលនោះឯង ហើយតាំងនៅឈ្មោះថាសតិ ព្រោះការមិនវង្វេង ។ ខ្យល់ដង្ហើមចេញក៏ដូចគ្នា ដោយហេតុមានប្រមាណប៉ុណ្ណេះ ឈ្មោះថា លោកពោលសេចក្តីថា សតិក្នុងខ្យល់ដកដង្ហើមចូល និងដកដង្ហើមចេញ ឈ្មោះថា **អានាបានស្សតិ**។ ឥឡូវនេះ ព្រះសារីបុត្តត្ថេរ បំណងចង្អុលបង្ហាញដល់បុគ្គលដែលលោកពោលថា **យស្ស** ដោយអំណាចនៃសតិប៉ុណ្ណោះ គប្បីពោលថា សតិ ( ស្មារតី ) ជាទីតាំងមាំ រមែងតាំងមាំដល់ភិក្ខុដែលដកដង្ហើមចូល តាំងមាំដល់ភិក្ខុដែលដកដង្ហើមចេញ សេចក្តីថា បុគ្គលណាដកដង្ហើមចូល សតិរបស់បុគ្គលនោះ

រមែងចូលទៅកំណត់ខ្យល់ដង្ហើមចូល បុគ្គលណាដកដង្ហើមចេញ សតិរបស់បុគ្គលនោះ រមែងចូលទៅកំណត់ខ្យល់ដកដង្ហើមចេញ ។

បទថា **បរិបុណ្ណា** បានដល់ ឲ្យបរិបូរណ៌ដោយការសម្រេចអរហត្តមគ្គ ដែលបន្តមកដោយឈាន វិបស្សនា និងមគ្គ ។ ព្រះសារីបុត្តត្ថេរពោលពាក្យថា **បរិគ្គហដ្ឋេន** ជាដើម សំដៅដល់ធម៌ គឺឈាន វិបស្សនា និងមគ្គទាំងនោះឯង ។ ពិតហើយ ធម៌ទាំងនោះ ឈ្មោះថា **បរិគ្គហា** ព្រោះដែលព្រះយោគាវចរនេះកំណត់បាន ឈ្មោះថា **បរិបុណ្ណា** ដោយអត្ថថា កាន់យកជុំវិញនោះ ។

ឈ្មោះថា **បរិវារដ្ឋេន បរិបុណ្ណា** ព្រោះចិត្ត និងចេតសិកទាំងពួង ជាបរិវារនៃគ្នានិងគ្នា ។

ឈ្មោះថា **បរិបូរដ្ឋេន បរិបុណ្ណា** ដោយការបរិបូរណ៌នៃភាវនា ។

បទថា **ចតស្សោ ភាវនា** លោកពោលដោយអំណាចនៃបទដែលពោលហើយថា **សុភាវិតា** ភាវនា ៤ លោកធ្លាប់ពោលហើយនោះឯង ។ បទថា **យានីកតា** បានដល់ ធ្វើឲ្យដូចជាយាន ដែលទឹមហើយ ។ បទថា **វត្ថុកតា** បានដល់ ធ្វើឲ្យដូចជាវត្ថុ ដោយអត្ថថា ជាទីតាំង ។ បទថា **អនុដ្ឋិតា** បានដល់ ប្រាកដហើយ ។ បទថា **បរិចិតា** បានដល់ សន្សំ គឺចូលទៅសន្សំដោយជុំវិញ ។ បទថា **សុសមារទ្ធា** បានដល់ ប្រារព្ធដោយល្អ ធ្វើយ៉ាងល្អ ។

បទថា **យត្ថ យត្ថ អាកង្ខតិ** បានដល់ ប្រសិនបើភិក្ខុប្រាថ្នាក្នុងឈាន

ណាៗ ក្នុងវិបស្សនាណាៗ ។ បទថា **តត្ថ តត្ថ** បានដល់ ក្នុងឈាននោះៗ ក្នុងវិបស្សនានោះៗ ។ បទថា **វសិប្បត្តោ** បានដល់ ដល់នូវភាពជាអ្នកជំនាញ គឺភាពជាអ្នកមានវសីច្រើន ។ បទថា **ពលប្បត្តោ** បានដល់ ដល់កម្លាំងនៃសមថៈ និងវិបស្សនា ។ បទថា **វេសារជ្ជប្បត្តោ** បានដល់ ដល់នូវភាពជាអ្នកក្លៀវក្លា ដល់នូវភាពជាអ្នកឈ្លាស ។ បទថា **តេ ធម្មា** បានដល់ ធម៌ គឺសមថៈ និងវិបស្សនា ។ បទថា **អាវជ្ជនប្បដិពទ្ធា** បានដល់ ជាប់ទាក់ទងដោយការនឹកភាវរក សេចក្តីថា ត្រឹមតែភិក្ខុនោះនឹកគិតប៉ុណ្ណោះ ធម៌ទាំងឡាយរមែងដល់ការប្រកបព្រមដោយសន្តាន ឬដោយញាណ របស់ភិក្ខុនោះ ។ បទថា **អាកង្ខណប្បដិពទ្ធា** បានដល់ ទាក់ទងដោយការពេញចិត្ត សេចក្តីថា ត្រឹមតែភិក្ខុពេញចិត្តប៉ុណ្ណោះ ធម៌ទាំងឡាយរមែងដល់ការប្រកបព្រម ដោយន័យដូចពោលហើយ ។

ឯបទថា **មនសិការ** ក្នុងបទថា **មនសិការប្បដិពទ្ធា** នេះ ជាចិត្តុប្បាទក្នុងការនឹកភាវរក ។ លោកពោលដើម្បីពង្រីកសេចក្តីដោយអំណាចនៃវេវចនៈនៃការសង្ស័យ ។ បទថា **តេន វុច្ចតិ យានីកតា** មានពាក្យអធិប្បាយថា ធម៌ទាំងនោះ ឈ្មោះថា លោកធ្វើឲ្យដូចជាយានដែលទឹមហើយ ព្រោះធ្វើហើយយ៉ាងនោះ ។

បទថា **យស្មឹ យស្មឹ វត្ថុស្មឹ** បានដល់ ក្នុងវត្ថុនីមួយៗ បណ្តាវត្ថុ ១៦ ។ បទថា **ស្វាធិដ្ឋិតំ** បានដល់ តាំងទុកល្អហើយ ។ បទថា **សុប្បតិដ្ឋិតា** បានដល់ ចូលទៅតាំងទុកដោយល្អ ។ លោកសម្តែងធម៌ទាំង ២ យ៉ាងនោះ

ប្រកបដោយចិត្តនិងសតិ ដែលសម្បយុត្តដោយអំណាចអនុលោមនិងបដិលោម ព្រោះការធ្វើកិច្ចរៀងៗខ្លួន ។ បទថា **តេន វុច្ចតិ វត្ថុកតា** មានពាក្យអធិប្បាយថា ឈ្មោះថា មានទីតាំងដែលធ្វើហើយព្រោះភាពជាយ៉ាងនេះនោះឯង ។

បទថា **យេន យេន ចិត្តំ អភិនីហរតិ** បានដល់ ចិត្តនាំចេញចាកការប្រព្រឹត្តទៅក្នុងកាលមុនហើយ រមែងបង្អោនចូលទៅក្នុងការនានាវិសេសណាៗ ។ បទថា **តេន តេន សតិ អនុបរិវត្តតិ** បានដល់ សតិជាសការៈ ជួយស្រោចស្រង់ វិលត្រឡប់ចាកការប្រព្រឹត្តទៅក្នុងកាលមុន រមែងប្រព្រឹត្តទៅក្នុងការនានាវិសេសនោះៗ ។ ក្នុងបទថា **យេន តេន** នេះ គប្បីជ្រាបថាជាសត្តមីវិភត្តិ ដូចក្នុងប្រយោគជាដើមថា **យេន ភគវា តេនុបសង្កមិ** ព្រះមានព្រះភាគគង់នៅក្នុងទីណា ក៏ចូលទៅរកក្នុងទីនោះ ដូច្នេះ ។ បទថា **តេន វុច្ចតិ អនុដ្ឋិតា** មានពាក្យអធិប្បាយថា ទៅតាមការនានានោះៗ តាំងនៅព្រោះធ្វើយ៉ាងនោះឯង ព្រោះអានាបានស្សតិជាប្រធានរបស់សតិ គប្បីជ្រាបថា លោកធ្វើការប្រកបអត្ថដោយសតិក្នុងបទថា **វត្ថុកតា** និង **អនុដ្ឋិតា** ។

ព្រោះសតិដែលភិក្ខុឲ្យបរិបូរណ៍ហើយ រមែងឈ្មោះថា ភិក្ខុអប់រំហើយ ឲ្យចម្រើនហើយ បានអាសេវនៈហើយ ហេតុនោះ អត្ថទាំង ៣ ដែលលោកពោលក្នុងបទថា **បរិបុណ្ណា** ទើបលោកពោលក្នុងបទថា **បរិចិតា** ។ លោកពោលអត្ថទី ៤ ដែលវិសេសចេញទៅ ។

ក្នុងបទទាំងនោះ បទថា **សតិយា បរិគ្គណ្ហន្តោ** បានដល់ ព្រះយោគាវចរកំណត់កាន់យកវត្ថុដែលគួរកាន់យកដោយសតិ ដែលសម្បយុត្តហើយ

ឬជាបុព្វភាគ ។ បទថា **ឯិឆាតិ ចាបកេ អកុសលេ ធម្មេ** បានដល់ រមែង ឈ្នះ រមែងគ្របសង្កត់កិលេសដ៏លាមកដោយការផ្តាច់ផ្តិល ។ ធម្មទេសនា នេះ ជាបុគ្គលាធិដ្ឋាន ព្រោះកាលធម៌ទាំងឡាយឈ្នះ សូម្បីបុគ្គលអ្នកដល់ព្រម ដោយធម៌នោះ ក៏ឈ្មោះថា រមែងឈ្នះផង ។ ម្យ៉ាងទៀត ធម៌ទាំងនោះ មិន លះសតិប្រារព្ធដើម្បីទឹងឈ្នះក្នុងខណៈដែលខ្លួនប្រព្រឹត្តទៅ លោកពោលថា ឈ្នះហើយ ដូចដែលលោកពោលថា បុគ្គលប្រារព្ធដើម្បីបរិភោគ ក៏ជាការ បរិភោគហើយ ។ ម្យ៉ាងទៀត ក្នុងពាក្យនេះ គប្បីជ្រាបលក្ខណៈ ដោយគម្ពីរ សព្ទសាស្ត្រ ។

កាលបើយ៉ាងនោះ កាលគួរនឹងពោលថា **បរិឯិតា** លោកផ្លាស់ ជ អក្ខរៈ ជា ច អក្ខរៈ ពោលថា **បរិចិតា** ។ លោកធ្វើ ឌ អក្ខរៈ ជា ត អក្ខរៈ ដោយ លក្ខណៈនៃភាសាក្នុងអត្ថវិកប្បថា **សម្មា គតោ អស្សាតិ សុគតោ** ឈ្មោះ ថា **សុគត** ( ព្រោះមានព្រះវាចាប្រពៃ ) យ៉ាងណា សូម្បីក្នុងបទនេះ ក៏គប្បី ជ្រាបយ៉ាងនោះ ។ បទថា **បរិចិតា** ក្នុងអត្ថវិកប្បនេះ ជាកត្តុសាធនៈ ៣ បទមុន ជាកម្មសាធនៈ ។

បទថា **ចត្តារោ សុសមារទ្ធា** មានពាក្យអធិប្បាយថា ធម៌ ៤ យ៉ាង មានអត្ថ ដែលភិក្ខុប្រារព្ធល្អហើយ ។ គប្បីឃើញថា លុប **អត្ថ** សព្ទ ។ សូម្បីអត្ថនៃបទថា **សុសមារទ្ធា** គប្បីជ្រាបថា លោកពោលថា **សុសមារទ្ធា** ក្នុងទីនេះ ឬ **សុសមារទ្ធធម្មា** ( មានធម៌ដែលភិក្ខុប្រារព្ធល្អហើយ ) ។

គប្បីជ្រាបថា លោកពោលថា **ចត្តារោ** ដោយប្រភេទនៃអត្ថ ៤ យ៉ាង

មិនមែនដោយប្រភេទនៃធម៌ ។ ព្រោះធម៌ទាំងឡាយ ដែលព្រះយោគាវចរ ចម្រើនល្អហើយ ឈ្មោះថា ប្រារព្ធល្អហើយ មិនមែនធម៌ពួកដទៃ ហេតុនោះ ទើបលោកពោលអត្ថនៃការចម្រើន ៣ យ៉ាងសូម្បីក្នុងទីនេះ ។ សូម្បីអត្ថនៃ អាសេវនៈ ( ការសេព ) លោកក៏ពោលទុកក្នុងអត្ថនៃការចម្រើន ៣ យ៉ាង ដែលពោលហើយ ព្រោះហេតុនោះ ទើបលោកមិនពោលអត្ថនៃអាសេវនៈ នោះ ហើយពោលអត្ថនៃកិលេស ដែលជាសត្រូវដល់ធម៌នោះ ដែលត្រូវ ដកហើយ ព្រោះទីបំផុតនៃការប្រារព្ធ រមែងប្រាកដដោយការដកកិលេសដែល ជាសត្រូវ ដោយហេតុនោះ ឈ្មោះថា លោកពោលដល់អត្ថដែលដល់កំពូល នៃធម៌ដែលប្រារព្ធល្អហើយ ។

ក្នុងបទទាំងនោះ បទថា **តប្បច្ចនីកានំ** បានដល់ កិលេសជាសត្រូវ ដល់ឈាន វិបស្សនា និងមគ្គទាំងនោះ ។ បទថា **កិលេសានំ** បានដល់ នៃ កិលេសទាំងឡាយ មានកាមច្ឆន្ទៈជាដើម និងទិដ្ឋិទាំងឡាយ មានសក្កាយទិដ្ឋិ ជាដើម ដែលសម្បយុត្តដោយនិច្ចសញ្ញាជាដើម ។ បទថា **សុសមូហតត្តា** បានដល់ ព្រោះដកឡើង គឺឲ្យវិនាសទៅដោយល្អ ដោយអំណាចនៃវិក្ខម្ភ- នប្បហាន តទង្គប្បហាន និងសមុច្ឆេទប្បហាន ។ តែក្នុងគម្ពីរទាំងឡាយ ពួក អាចារ្យសរសេរថា **សុសមុគ្ឃាតត្តា** បទនោះ មិនល្អ ។

ព្រះសារីបុត្ត កាលសម្តែងអត្ថវិកប្បសូម្បីដទៃនៃបទនោះ ( សុសមា- រទ្ធា ) ទៀត ទើបពោលពាក្យថា **សុសមំ** ជាដើម ។ ក្នុងបទទាំងនោះ បទថា **តត្ថ ជាតា** បានដល់ កើតក្នុងការនានាវិសេសដែលដល់កំពូលនោះ ។

បទថា **អនវជ្ជា** បានដល់ ប្រាសចាកទោសនៃកិលេស ដោយការមិនចូលដល់ភាពដែលកិលេសទាំងឡាយជាអារម្មណ៍ ។ បទថា **កុសលា** បានដល់ កុសលដោយកំណើត ។ បទថា **ពោធិបក្ខិយា** បានដល់ ឈ្មោះថា **ពោធិ-បក្ខិយា** ព្រោះជាចំណែកនៃព្រះអរិយៈ ដែលបានឈ្មោះថា **ពោធិ** ព្រោះអត្ថថា ត្រាស់ដឹង ។ ពាក្យថា ព្រោះជាចំណែក បានដល់ ព្រោះតាំងនៅក្នុងភាពជាឧបការៈ ។ ពោធិបក្ខិយធម៌ទាំងនោះ មាន ៣៧ គឺសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពល ៥ ពោជ្ឈង្គ ៧ អរិយមគ្គមានអង្គ ៨ ។ បទថា **ឥទំ សមំ** បានដល់ ឈ្មោះថា **សម** ព្រោះអត្ថថា ធម្មជាតក្នុងខណៈមគ្គនេះ រមែងញុំាងកិលេសទាំងឡាយឲ្យស្ងប់ គឺឲ្យវិនាសទៅដោយការផ្តាច់ផ្តិល ។ បទថា **និរោធោ និព្វានំ** បានដល់ ឈ្មោះថា **និរោធ** ព្រោះជាការរម្ងត់ទុក្ខ ឈ្មោះថា **និព្វាន** ព្រោះមិនមានតណ្ហា ពោលគឺគ្រឿងជោតក្រង ។ បទថា **ឥទំ សុសមំ** បានដល់ និព្វាននេះ ឈ្មោះថា ស្មើល្អ ព្រោះអត្ថថា ស្មើដោយល្អ ព្រោះប្រាសចាកភាពមិនស្មើ គឺសង្ខតធម៌ទាំងពួង ។ បទថា **ញាតំ** បានដល់ ដឹងនូវការស្មើ ពោល គឺពោធិបក្ខិយធម៌ដោយញាណ ព្រោះមិនវង្វេង ដឹងនូវការស្មើល្អ ពោល គឺនិព្វានដោយញាណដោយភាពជាអារម្មណ៍ ដែលឃើញហើយទាំងពីរយ៉ាងនោះឯង ដូចឃើញដោយភ្នែក ។ បទថា **វិទិតំ** បានដល់ បានទាំងពីរយ៉ាងនោះ ដោយការកើតក្នុងសន្តាន និងដោយធ្វើជាអារម្មណ៍ ធ្វើឲ្យច្បាស់ហើយ និងពាល់ត្រូវហើយដោយបញ្ញាដូចដឹងហើយ ។ បទថា **អសច្ឆិកតំ អសម្មុដ្ឋា អសារទ្ធោ ឯកគ្គំ**

ជាពាក្យប្រកាសអត្ថនៃបទមុនៗ ។

ក្នុងបទទាំងនោះ បទថា **អារទ្ធំ** បានដល់ ប្រាថ្នាហើយ ។ បទថា **អសល្លីនំ** បានដល់ មិនរាថយ ។ បទថា **ឧបដ្ឋិតា** បានដល់ ចូលទៅតាំងទុកហើយ ។ បទថា **អសម្មុដ្ឋា** បានដល់ មិនបាត់ទៅ ។ បទថា **បស្សទ្ធោ** បានដល់ រលត់ហើយ ។ បទថា **អសារទ្ធោ** បានដល់ មិនក្រវល់ក្រវាយ ។ បទថា **សមាហិតំ** បានដល់ តម្កល់ស្មើ ។ បទថា **ឯកគ្គំ** បានដល់ មិនរាយមាយ ។

បទថា **ចត្តារោ សុសមារទ្ធា** មានអត្ថជាមូលរបស់ពាក្យថា **សុសមា-រទ្ធ** ទាំងមូល ។ ចំណែកបទថា **អត្ថិ សមំ** ជាដើម មានអត្ថជាមូលរបស់ពាក្យថា **សុសម** ។ បទថា **ញាតំ** ជាដើម មានអត្ថជាវិកប្បរបស់ពាក្យថា **អារទ្ធ** ។

តទៅនេះ ជាការប្រៀបធៀបអត្ថនៃបទក្នុងអធិការនេះថា កាលគួរនឹងពោលថា **សមា ច សុសមា ច សមសុសមា** លោកធ្វើជាឯកសេសសមាសមានពាក្យសរុបជាឯកទេសពោលថា **សុសមា** ដូចពោលថា **នាមញ្ច រូបញ្ច នាមរូបញ្ច នាមរូបំ** នាម រូប និងនាមរូប ឈ្មោះថា នាមរូប ។ បទថា **ឥធំ សមំ ឥធំ សុសមំ** លោកសម្ដែងការមិនដឹង ធ្វើជាពាក្យនបុំសកលិង្គ ។ម្យ៉ាងទៀត ព្រោះសូម្បី **ញាតំ** ( ដឹងហើយ ) លោកក៏ហៅថា **ទិដ្ឋំ** ( ឃើញហើយ ) ឃើញហើយ និងប្រារព្ធហើយដោយអត្ថក៏តែមួយដូចគ្នា ។ ចំណែកបទថា **វិទិត** □ជាបហើយ ) **សច្ឆិកត** ( ធ្វើឲ្យច្បាស់ហើយ ) **ផស្សិត**

( ពាល់ត្រូវហើយ □ជាវេវចនៈរបស់បទថា **ញាត** ( ដឹងហើយ ) ហេតុនោះ ទើបឈ្មោះថា លោកពោលអត្ថនៃ **អារទ្ធ** ( ប្រារព្ធហើយ ) ថា **ញាត** □ដឹងហើយ ) ។ បទថា **អារទ្ធំ ហោតិ វីរិយំ អសល្លីនំ** ជាអត្ថដោយត្រង់នៃបទថា **អារទ្ធ** ។ តែបទថា **ឧបដ្ឋិតា សតិ** ជាដើម លោកពោលដើម្បីសម្តែងធម៌ដែលជាឧបការៈដល់សេចក្តីព្យាយាម ដែលសម្បយុត្តហើយ មិនបានពោលដើម្បីសម្តែងអត្ថនៃពាក្យថា **អារទ្ធ** ។ ឈ្មោះថា **សុសមារទ្ធា** ព្រោះអត្ថថា ប្រារព្ធហើយដោយល្អ ដោយអត្ថមុន និងឈ្មោះថា **សុសមារទ្ធា** ព្រោះប្រារព្ធហើយស្មើ និងស្មើល្អ ដោយអត្ថនេះ កាលលោកធ្វើឲ្យសល់ជាបទមួយ ទើបពោលថា **សុសមារទ្ធា** ។ លោកកំណត់កាន់យកអត្ថនេះ ហើយពោលថា ហេតុនោះ ទើបលោកពោលថា ប្រារព្ធសេចក្តីស្ងប់ប្រពៃ ។

បទថា **អនុបុព្វំ** សេចក្តីថា ឈានទៅតាមលំដាប់ អធិប្បាយថា តាមក្រោយខ្យល់ដង្ហើមចូលចេញមុនៗ ។ បទថា **ឱយំ អស្សាសវសេន** បានដល់ ដោយអំណាចខ្យល់ដកដង្ហើមចូលដែលលោកពោលថា **ឱយំ** ។

បទថា **បុរិមា បុរិមា** បានដល់ សតិ សមាធិខាងដើមៗ ។ លោកពោលអត្ថនៃបទថា **បុព្វំ** ដោយបទនេះ ។ បទថា **បច្ឆិមា បច្ឆិមា** បានដល់សតិនោះឯង ។ លោកពោលអត្ថនៃបទថា **អនុ** ដោយបទនេះ ។ ដោយបទទាំងពីរនោះ បានសេចក្តីថា អប់រំអានាបានស្សតិមុន និងក្រោយផងដែរ ។ ព្រោះពាក្យដែលពោលឲ្យពិស្តារនូវវត្ថុ ១៦ ខាងមុខ ក្នុងទីនេះ ទើបលោកសង្ខេប ហើយសម្តែងបទចុងក្រោយថា **បដិនិស្សគ្គានុបស្សី** ដូច្នេះ ។

ព្រោះអានាបានស្សតិទាំងពួងនៃការនាំដែលដល់កំពូល រមែងឈ្មោះថា ព្រះយោគាវចរអប់រំតាមលំដាប់ហើយ ព្រោះប្រព្រឹត្តទៅតាមការគាប់ចិត្ត រឿយៗ ដោយហេតុនោះ ទើបលោកពោលថា **អញ្ញមញ្ញំ បរិចិតា ចេវ ហោន្តិ អនុបរិចិតា ច** ។

បទថា **យថត្ថា** បានដល់ អត្ថតាមសភាវៈ ។ បទថា **អត្តទមថត្ថោ** បានដល់ ការអស់ព្យសនៈរបស់ខ្លួន ក្នុងខណៈអរហត្តមគ្គ ។ បទថា **សម-ថត្ថោ** បានដល់ ភាពជាអ្នកត្រជាក់ត្រជុំ ។ បទថា **បរិនិព្វាបនត្ថោ** បានដល់ ដោយការរម្ងាត់កិលេស ។ បទថា **អភិញ្ញត្ថោ** បានដល់ ដោយអំណាច នៃធម៌ទាំងពួង ។ បទថា **បរិញ្ញត្ថោ** ជាដើម បានដល់ដោយអំណាច នៃកិច្ច គឺមគ្គញាណ ។ បទថា **សច្ចាភិសមយត្ថោ** បានដល់ ដោយអំណាច នៃការឃើញច្បាស់ចាក់ធ្លុះអរិយសច្ចៈ ៤ ព្រមគ្នា ។ បទថា **និរោធេ បតិដ្ឋាបកត្ថោ** បានដល់ ដោយអំណាចនៃការធ្វើឲ្យជាអារម្មណ៍ ។

សួរថាមិនមានបទថា **ពុទ្ធោ** លោកបំណងនឹងសម្ដែងព្រះពុទ្ធអង្គនោះក្នុង បទថា **ពុទ្ធេន** ទើបពោលថា **ពុទ្ធោ** ។

បទថា **សយម្ភូ** បានដល់ កើតឯងប្រាសចាកការប្រៀនប្រដៅ ។ បទថា **អនាចរិយកោ** ជាពាក្យពង្រីកអត្ថនៃបទថា **សយម្ភូ** ។ ព្រោះថា បុគ្គលណា ចាក់ធ្លុះអរិយសច្ច ប្រាសចាកអាចារ្យ បុគ្គលនោះ ឈ្មោះថា **សយម្ភូ** ។ សួរថា បទថា **បុព្វេ អននុស្សុតេសុ** ជាដើម ជាការប្រកាសអត្ថនៃភាពមិនមានអា-ចារ្យ ។ បទថា **អននុស្សុតេសុ** បានដល់ មិនធ្លាប់ស្ដាប់មកអំពីអាចារ្យ ។

*បទថា* **សាមំ** *បានដល់ ខ្លួនឯងនោះឯង ។ បទថា* **អភិសម្ពុជ្ឈិ** *បានដល់ ចាក់ធ្លុះដោយប្រពៃយ៉ាងក្រៃលែង ។ បទថា* **តត្ថ ច សព្វញ្ញុតំ បាបុណិ** *បានដល់ ទ្រង់សម្រេចភាពជាព្រះសព្វញ្ញូក្នុងសច្ចៈទាំងនោះ ។ លោកពោល យ៉ាងនោះ ព្រោះទ្រង់ចាក់ធ្លុះសច្ចៈទាំងឡាយ ដូចដែលព្រះសព្វញ្ញូទាំងឡាយ ចាក់ធ្លុះ ។ បាឋៈថា* **សព្វញ្ញុតំ បត្តោ** *ដូច្នេះក៏មាន ។ បទថា* **ពលេសុ ច វសីភាវំ** *បានដល់ ទ្រង់សម្រេចភាពជាធំក្នុងកម្លាំងរបស់ព្រះតថាគត ១០ ។ បុគ្គលណាមានសភាពយ៉ាងនោះ លោកពោលបុគ្គលនោះថាជា* **ពុទ្ធ**

*ក្នុងបទថា* **ពុទ្ធោ** *នោះ ព្រះពុទ្ធជាបុគ្គលវិសេស បានទទួលការបញ្ញត្តិ ព្រោះអាស្រ័យខន្ធសន្តានដែលអប់រំគ្រប់គ្រាន់ហើយ ដើម្បីការសម្រេចនូវការ រួចផុតដ៏កំពូល ដែលមិនមានអ្វីរាំងក្នុងញាណនោះបាន ក្នុងធម៌ទាំងឡាយ ជាគ្រឿងសម្គាល់ ឬបានទទួលការបញ្ញត្តិ ព្រោះអាស្រ័យការត្រាស់ដឹង ក្រៃលែងក្នុងសច្ចៈ ដែលជាបទដ្ឋាននៃភាពជាសព្វញ្ញូ ។ ដោយពាក្យមាន ប្រមាណប៉ុណ្ណេះ ឈ្មោះថា លោកធ្វើការចង្អុលបង្ហាញនូវបទថា* **ពុទ្ធោ** *ឲ្យប្រាកដជាក់ច្បាស់ដោយអត្ថ ។*

*ឥឡូវនេះ ព្រះសារីបុត្ត កាលនឹងបង្ហាញឲ្យជាក់ច្បាស់ដោយព្យញ្ជនៈ ទើបពោលពាក្យថា* **ពុទ្ធោតិ កេនដ្ឋេន ពុទ្ធោ** *ជាដើម ។ ក្នុងបទនោះ អ្នក ដឹង អ្នកយល់ក្នុងលោក ហៅថា អវគតៈ យ៉ាងណា ឈ្មោះថា* **ពុទ្ធោ** *ព្រោះត្រាស់ដឹងសច្ចធម៌ទាំងឡាយ ក៏យ៉ាងនោះ ។*

*ឈ្មោះថា* **ពុទ្ធោ** *ព្រោះជាហេតុឲ្យពួកសត្វត្រាស់ដឹង ដូចស្លឹកឈើស្ងួត*

ព្រោះខ្យល់ប៉ះត្រូវ ក៏ហៅថា ស្ងឹកឈើស្ងួត ។

បទថា **សព្វញ្ញុតាយ ពុទ្ធោ** មានពាក្យអធិប្បាយថា ឈ្មោះថា **ពុទ្ធោ** ព្រោះពុទ្ធិបញ្ញាដែលអាចត្រាស់ដឹងធម៌ទាំងពួង ។ បទថា **សព្វទស្សាវិតាយ ពុទ្ធោ** មានពាក្យអធិប្បាយថា ឈ្មោះថា **ពុទ្ធោ** ព្រោះទ្រង់ឃើញធម៌ទាំងពួង ដោយញាណចក្ខុ ។ មានពាក្យអធិប្បាយថា ឈ្មោះថា **ពុទ្ធោ** ព្រោះទ្រង់ ឃើញធម៌ទាំងពួងដោយញាណចក្ខុ ។ បទថា **អនញ្ញនេយ្យតាយ ពុទ្ធោ** មានពាក្យអធិប្បាយថា ឈ្មោះថា **ពុទ្ធោ** ព្រោះត្រាស់ដឹងដោយព្រះអង្គឯង មិនមានបុគ្គលដទៃដឹកនាំ ។ បទថា **វិសវិតាយ ពុទ្ធោ** មានពាក្យអធិប្បាយ ថា ឈ្មោះថា **ពុទ្ធោ** ព្រោះអត្ថថា រីកដូចផ្កាឈូក ព្រោះទ្រង់រីកដោយព្រះ គុណផ្សេងៗ ។ ពោលដោយបរិយាយ ៦ បទថា **ខីណាសវសង្ខាតេន ពុទ្ធោ** ជាដើម មានពាក្យអធិប្បាយថា ឈ្មោះថា **ពុទ្ធោ** ព្រោះទ្រង់ភ្ញាក់ល្អ ហើយ ព្រោះការអស់ទៅនៃការដេកលក់ គឺកិលេសទាំងពួង ដូចបុរសភ្ញាក់ ល្អហើយ ព្រោះការអស់ទៅនៃការដេកលក់ដោយការលះធម៌ដែលធ្វើចិត្ត ឲ្យ រួញរា ។ បទថា **សង្ខាតេន** មានពាក្យអធិប្បាយថា ដោយចំណែកនៃវាចា ព្រោះពាក្យថា **សង្ខា សង្ខាតំ** ដោយអត្ថតែមួយដូចគ្នា ។ ព្រោះមិនមាន គ្រឿងបូកលាប គឺតណ្ហា និងទិដ្ឋិ ទើបឈ្មោះថា **និរុបលេបសង្ខាតេន** ។

បទថា **ឯកន្តវីតរាគោ** លោកពោលឲ្យវិសេស ដោយបទថា **ឯកន្ត** ព្រោះទ្រង់លះកិលេសទាំងពួងមួយអន្លើដោយវាសនាបានហើយ ។

បទថា **ឯកន្តនិក្កិលេសោ** បានដល់ ទ្រង់អស់កិលេស ចាកកិលេសទាំង

ពួនដែលសល់ពីរាគៈ ទោសៈ និងមោហៈ ។ បទថា **ឯកាយនមគ្គំ គតោតិ ពុទ្ធោ** មានពាក្យអធិប្បាយថា ធាតុដែលមានអត្ថថាត្រាស់ដឹង ក៏រមែង មានអត្ថថា ទៅ ព្រោះធាតុដែលមានអត្ថថា ទៅ ក៏មានអត្ថថា ត្រាស់ដឹង ព្រោះហេតុនោះ ឈ្មោះថា **ពុទ្ធោ** ព្រោះយាងទៅកាន់ផ្លូវជាទីទៅនៃបុគ្គលម្នាក់ឯង ។

ម្យ៉ាងទៀត ក្នុងបទថា **ឯកាយនមគ្គោ** នេះ លោកពោលដោយឈ្មោះថាជាទីប្រព្រឹត្តទៅក្នុងឈ្មោះនៃផ្លូវជាច្រើន គឺ

ឈ្មោះថា មគ្គ បានដល់ តម្រាយ គន្លង ប្រទេសសម្រាប់ទៅដោយជើង ទីសម្រាប់ដើរ ទីសម្រាប់ដើរទៅដើរមក ទូកស្ពាន សម្រាប់ឆ្លង ផែ ពោងពាយ[១] ដូច្នេះ ។

ព្រោះហេតុនោះ ទើបមានសេចក្តីថា ជាផ្លូវមូលតែមួយ មិនជាផ្លូវ ២ ។ ម្យ៉ាងទៀត ឈ្មោះថា ឯកាយនមគ្គ ព្រោះជាផ្លូវដែលបុគ្គលតែម្នាក់គប្បីទៅ ។ ពាក្យថា បុគ្គលតែម្នាក់ បានដល់ ចិត្តដែលស្ងាត់ ព្រោះលះនូវការប្រឡុកប្រឡំដោយពួក ។ ពាក្យថា គប្បីទៅ បានដល់ គប្បីបដិបត្តិ ។ ម្យ៉ាងវិញទៀត ឈ្មោះថា **អយន** ព្រោះជាហេតុទៅ អធិប្បាយថា ទៅអំពីសង្សារកាន់និព្វាន ។ ការទៅរបស់បុគ្គលប្រសើរទាំងឡាយ ឈ្មោះថា **ឯកាយន** ។ បទថា **ឯកេ** បានដល់ បុគ្គលដែលប្រសើរបំផុត ។ ព្រះសម្មាសម្ពុទ្ធជាបុគ្គលប្រសើរជាងសត្វទាំងពួង ។ ព្រោះហេតុនោះ ទីបលោកពោលថា ផ្លូវដែលជាផ្លូវទៅរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទាំងឡាយ ឈ្មោះថា **ឯកាយនមគ្គ** ។

---

១- ខុទ្ទកនិកាយ ចូឡនិទ្ទេស បិដក ៦៨ ឃ្នាប ១៣៦ ។

ម្យ៉ាងទៀត ឈ្មោះថា **អយន** ព្រោះអត្ថថា ទៅ សេចក្ដីថា រមែងដំណើរទៅ គឺរមែងប្រព្រឹត្តទៅ ។ ឈ្មោះថា **ឯកាយនមគ្គ** ព្រោះអត្ថថា ជាផ្លូវទៅក្នុងផ្លូវតែមួយ មានពាក្យអធិប្បាយថា ផ្លូវប្រព្រឹត្តទៅក្នុងព្រះពុទ្ធសាសនា ផ្លូវតែមួយប៉ុណ្ណោះ មិនមែនក្នុងផ្លូវដទៃ ។

ម្យ៉ាងវិញទៀត ឈ្មោះថា **ឯកាយន** ព្រោះទៅកាន់វត្ថុតែមួយ មានអធិប្បាយថា ក្នុងខាងដើមសូម្បីប្រព្រឹត្តទៅដោយមុខផ្សេងៗ និងន័យផ្សេងៗ ក្នុងខាងក្រោយ ក៏ទៅនិព្វានតែម្យ៉ាងប៉ុណ្ណោះ ព្រោះហេតុនោះ ទើបមានពាក្យអធិប្បាយថា បទថា **ឯកាយនមគ្គ** បានដល់ ផ្លូវដើរទៅកាន់និព្វានតែមួយ ។

បទថា **ឯកោ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោតិ ពុទ្ធោ** បានដល់ ឈ្មោះថា **ពុទ្ធោ** ព្រោះមិនបានត្រាស់ដឹងអំពីអ្នកដទៃ មានពាក្យអធិប្បាយហើយមិនមែនឬថា ឈ្មោះថា **ពុទ្ធោ** ព្រោះត្រាស់ដឹងសម្មាសម្ពោធិញ្ញាណដ៏កំពូលដោយព្រះអង្គឯងប៉ុណ្ណោះ ។

បទថា **អពុទ្ធិវិហតត្តា ពុទ្ធិប្បដិលាភា ពុទ្ធោ** នេះ ជាពាក្យពោលដោយអមថា **ពុទ្ធិ ពុទ្ធំ ពោធោ ។** ក្នុងបទនោះ លោកពោលទុកដើម្បីឲ្យដឹងថា ឈ្មោះថា **ពុទ្ធោ** ព្រោះទ្រង់ប្រកបដោយពុទ្ធគុណ ដូចពោលថា សំពត់ពណ៌ខៀវ ពណ៌ក្រហម ព្រោះប្រកបដោយប្រភេទនៃពណ៌ខៀវ ពណ៌ក្រហម ។

តពីនោះទៅ បទថា **ពុទ្ធោតិ នេតំ នាមំ** ជាដើម លោកពោលដើម្បីឲ្យដឹងថា បញ្ញត្តិនេះ ប្រព្រឹត្តទៅតាមអត្ថ ។

ក្នុងបទទាំងនោះ សម្លាញ់ ឈ្មោះថា **មិត្តា** ។ បុគ្គលទទួលរាជការ ឈ្មោះថា **អមច្ចា** ។ ញាតិខាងបិតា ឈ្មោះថា **ញាតី** ។ ញាតិខាងមាតា ឈ្មោះថា **សាលោហិតា** ។ អ្នកបួស ឈ្មោះថា **សមណា** ។ អ្នកមានវាទៈថាចម្រើន ឬអ្នកស្ងប់បាប មានបាបបន្សាត់ហើយ ឈ្មោះថា **ព្រាហ្មណា** ។ សក្កទេវរាជជាដើម និងព្រហ្ម ឈ្មោះថា **ទេវតា** ។

បទថា **វិមោក្ខន្តិកំ** បានដល់ វិមោក្ខ គឺអរហត្តមគ្គ ទីបំផុតនៃវិមោក្ខ គឺអរហត្តផល ព្រះនាមមានក្នុងទីបំផុតនៃវិមោក្ខនោះ ឈ្មោះថា វិមោក្ខន្តិក-នាម ។ ពិតហើយ ភាពជាព្រះសព្វញ្ញូ រមែងសម្រេចដោយអរហត្តមគ្គ ជាការសម្រេចហើយក្នុងការកើតឡើងនៃអរហត្តផល ព្រោះហេតុនោះ ទើបភាពជាព្រះសព្វញ្ញូមានក្នុងទីបំផុតនៃវិមោក្ខ ។ នេមិត្តកនាមនេះ ក៏ឈ្មោះថា មានក្នុងទីបំផុតនៃវិមោក្ខ ដោយហេតុនោះ ទើបលោកពោលថា ព្រះនាមថា ព្រះពុទ្ធនេះ ជាវិមោក្ខន្តិកនាមរបស់ព្រះពុទ្ធទាំងឡាយ ទ្រង់មានព្រះភាគ ដូច្នេះ ។

បទថា **ពោធិយា មូលេ សហ សព្វញ្ញុតញ្ញាណស្ស បដិលាភា** បានដល់ ព្រមជាមួយការបានព្រះសព្វញ្ញុតញ្ញាណ ក្នុងខណៈតាមដែលបានពោលហើយ ត្រង់មណ្ឌលមហាពោធិ ។ បទថា **សច្ឆិកា បញ្ញត្តិ** បានដល់ ជាបញ្ញត្តិដែលកើតដោយការធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល ឬដោយការធ្វើឲ្យជាក់ច្បាស់នូវធម៌ទាំងពួង ។ បទថា **យទិទំ ពុទ្ធោ** បានដល់ បញ្ញត្តិថា **ពុទ្ធោ** នេះ ជាការប្រកាសភាពជាពុទ្ធៈដោយព្យញ្ជនៈ ។

ការប្រៀបធៀបគ្នាដោយអត្ថដូចដែលបានពោលហើយ ក្នុងបទភាជនីយ

នេះនៃបាទគាថាថា **យថា ពុទ្ធេន ទេសិតា** មានដូចតទៅ

អានាបានស្សតិតាមដែលព្រះពុទ្ធទ្រង់សម្តែងហើយ គឺដោយប្រការដែលព្រះពុទ្ធទ្រង់សម្តែងហើយ ។ អត្ថនៃ **យថា** សព្ទទាំង ១០ ដែលសង្គ្រោះដោយ **យថា** សព្ទតាមដែលព្រះពុទ្ធទ្រង់សម្តែងហើយ គឺដោយប្រការដែលព្រះពុទ្ធទ្រង់សម្តែងហើយ ព្រោះហេតុនោះ គប្បីជ្រាបថា លោកធ្វើឲ្យជាឯកសេសសមាស ដោយអំណាចនៃសរូបេកសេសសមាសនៃ **យថា** សព្ទដែលមានប្រការជាអត្ថ និងនៃ **យថា** សព្ទ ដែលមានសភាវៈជាអត្ថ ហើយពោលថា **យថា** ។

តែក្នុងបទភាជនីយ លោកធ្វើឲ្យជាឯកវចនៈថា **ទេសិតោ** ដោយការប្រកបសព្ទនីមួយៗ ក្នុងអត្ថនៃ **យថា** សព្ទនោះ ។

ព្រោះលោកពោលថា បទថា **សោតិ គហដ្ឋោ វា ហោតិ បព្វជិតោ វា** សូម្បីក្នុងបទដើមក៏ឈ្មោះថាលោកពោលបានថា គ្រហស្ថណាក្តី បព្វជិតណាក្តី ។ អត្ថនៃ **លោក** សព្ទ បានពោលហើយនោះឯង ។

បទថា **បភាសេតិ** សេចក្តីថា ធ្វើឲ្យប្រាកដដល់ញាណរបស់ខ្លួន ។ បទថា **អភិសម្ពុទ្ធត្ថា** បានដល់ ព្រោះចាក់ធ្លុះដោយសាវកបារមីញាណ ។ បទថា **ឱភាសេតិ** បានដល់ ធ្វើលោកដែលជាកាមាវចរ ឲ្យភ្លឺស្វាង ។ បទថា **ភាសេតិ** បានដល់ ធ្វើលោកដែលជារូបាវចរឲ្យភ្លឺ ។ បទថា **បភាសេតិ** ធ្វើលោកដែលជាអរូបាវចរឲ្យផ្លូវផង់ ។ បទថា **អរិយញ្ញាណំ** បានដល់អរហត្តមគ្គញ្ញាណ ។ បទថា **មហិកា មុត្តោ** បានដល់ ផុតចាកពពក ។ ពពកលោកហៅថា **មហិក** ។ បាឋៈថា **មហិយា មុត្តោ** ( ផុតចាកផែនដី )

ដូច្នេះក៏មាន ។ បទថា **ធូមរជា មុត្តោ** បានដល់ ផុតចាកផ្សែង និងធូលី ។ បទថា **រាហុគហណា វិប្បមុត្តោ** លោកពោលឲ្យប្លែកដោយឧបសគ្គ ២ យ៉ាង ព្រោះរាហុធ្វើឲ្យព្រះចន្ទសៅហ្មង ព្រោះជិតគ្នា ។ បទថា **ភាសតេ** បានដល់ ភ្លឺ ដោយអត្ថថា មានពន្លឺ ។ បទថា **តបតេ** បានដល់ រុងរឿង ដោយអត្ថថា មានតេជះ ។ បទថា **វិរោចតេ** បានដល់ ថ្កើងថ្កាន ដោយអត្ថថា មានការរុងរោចន៍ ។ បទថា **ឯវមេវ** កាត់បទជា **ឯវំ ឯវំ** ។ ម្យ៉ាងទៀត សូម្បីព្រះចន្ទកាលភ្លឺរុងរោចន៍ រមែងធ្វើឱកាសលោកនេះឲ្យភ្លឺស្វាង កិក្ខុកាលភ្លឺរុងរឿង ថ្កើងថ្កានដោយបញ្ញា រមែងធ្វើលោក មានខន្ធលោកនេះជាដើម ឲ្យភ្លឺស្វាងដោយបញ្ញាដូច្នោះ សូម្បីក្នុងបទទាំងពីរ លោកមិនពោលថា **ភាសតិ** តែពោលថា **ភាសតេ** ។

ព្រោះកាលពោលយ៉ាងនោះ ឈ្មោះថា ពោលហើយ សូម្បីអត្ថនៃហេតុផង ។ ប្រសិនបើសួរថា ព្រោះហេតុអ្វី ទើបមិនឧបមាដោយព្រះអាទិត្យដែលភ្លឺខ្លាំងក្រៃលែងជាង ត្រឡប់ទៅឧបមាដោយព្រះចន្ទ ។ ឆ្លើយថា គប្បីជ្រាបថា ដែលកាន់យកយ៉ាងនោះ ព្រោះការឧបមាដោយព្រះចន្ទដែលប្រកបដោយគុណសម្បត្តិត្រជាក់ ជាការសមគួរដល់កិក្ខុអ្នកស្ងប់ដោយការស្ងប់ការក្តៅក្រហាយ ព្រោះកិលេសទាំងពួង ។

ព្រះសារីបុត្តត្ថេរ កាលសរសើរព្រះយោគាវចរដែលចម្រើនអានាបានស្សតិឲ្យសម្រេចហើយ ទើបសម្តែងសរុបញាណទាំងនោះថា **ឥមានិ តេរស ញាណានិ** ដូច្នេះ ។l៚

**អដ្ឋកថា អានាបានញាណនិទ្ទេស ចប់**

# អដ្ឋកថា
# សគោការិញ្ញាណនិទ្ទេស
# អាណាបានស្សតិមាតិកា

[ ៩៥ ] គប្បីជ្រាបវិនិច្ឆ័យ ក្នុងសគោការិញ្ញាណនិទ្ទេស ដូចតទៅនេះ ក្នុងមាតិកា បទថា **ឥធ ភិក្ខុ** បានដល់ ភិក្ខុក្នុងសាសនានេះ ។ ពិតហើយ **ឥធ** សព្ទ ក្នុងបទនេះ សម្តែងដល់ពាក្យប្រៀនប្រដៅដែលជាទីអាស្រ័យរបស់បុគ្គលអ្នកញ៉ាំងអានាបានស្សតិសមាធិ ដោយប្រការទាំងពួងឲ្យកើតឡើង និងបដិសេធភាពជាយ៉ាងនោះរបស់សាសនាដទៃ ។ ដូចព្រះមានព្រះភាគត្រាស់ ( ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសក ) ថា ម្នាលភិក្ខុទាំងឡាយ សមណ ( ទី ១ ) ( គឺសោតាបន្ន ) មានតែក្នុងសាសនានេះ ។បេ។ វាទៈ ( គឺទិដ្ឋិ ៦២ ) របស់សាសនាដទៃ សូន្យចាកសមណទាំងឡាយ ដូច្នេះ ។ បទថា **អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា** នេះ សម្តែងដល់ការកំណត់កាន់យកសេនាសនៈ ដែលសមគួរដល់ការចម្រើនអានាបានស្សតិ-សមាធិរបស់ភិក្ខុនោះ ។ ចិត្តរបស់ភិក្ខុនោះផ្សាយទៅក្នុងអារម្មណ៍ទាំងឡាយមានរូបជាដើម រហូតអស់កាលយូរ មិនប្រាថ្នា ចម្រើននូវអារម្មណ៍ដែលជាអានាបានស្សតិសមាធិ រមែងស្ទុះទៅក្រៅផ្លូវនោះឯង ដូចរទេះទឹមដោយគោកៀច ព្រោះហេតុនោះ ប្រៀបដូចអ្នកចិញ្ចឹមគោ បំណងនឹងបង្ហឹកកូនគោកៀចដែលបៅទឹកដោះរបស់មេគោកៀច ហើយចម្រើនធំធាត់ ទើបនាំចេញចាកមេគោ បោះបង្គោលធំទុកម្ខាង យកខ្សែចងទុកត្រង់បង្គោលនោះ ពេលនោះ

កូនគោរបស់បុរសនោះ ដើរឆ្វេឆ្វាទៅជុំវិញ កាលមិនអាចគេចទៅបាន ទើបក្រាប ឬដេកជិតបង្គោលនោះឯង យ៉ាងណា សូម្បីភិក្ខុនេះក៏យ៉ាងនោះដូចគ្នា បំណងនឹងបង្ហឹកចិត្តដែលត្រូវកិលេសប្រទូស្ត ដែលចម្រើនមកដោយការផឹករសនៃរូបារម្មណ៍ជាដើម រហូតអស់កាលយូរ ទើបនាំចេញចាកអារម្មណ៍ មានរូបជាដើមហើយ ចូលទៅកាន់ព្រៃក្តី គល់ឈើក្តី ផ្ទះស្ងាត់ក្តី ចងដោយខ្សែគឺសតិ ត្រង់បង្គោល គឺខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញ ចិត្តរបស់ភិក្ខុនោះ សូម្បីរើបម្រះទៅខាងនេះខាងនោះ កាលមិនបានអារម្មណ៍ដែលស្និទ្ធស្នាលក្នុងកាលមុន ក៏មិនអាចកាត់ខ្សែ គឺសតិគេចទៅបាន ទើបចូលទៅស្ងប់និងស្ងប់ស្ងៀមជាមួយអារម្មណ៍នោះឯង ដោយអំណាចនៃឧបចារៈ និងអប្បនា ។ ដោយហេតុនោះ ទើបបោរាណាចារ្យទាំងឡាយពោលថា

> នរជនក្នុងលោកនេះ កាលបង្ហឹកកូនគោ គប្បីចងត្រង់បង្គោល
> នេះយ៉ាងណា ភិក្ខុគប្បីចងចិត្តរបស់ខ្លួនទុកក្នុងអារម្មណ៍ដោយ
> សតិឲ្យមាំមួន ក៏យ៉ាងនោះ ។

សេនាសនៈនោះសមគួរដល់ការនៅសម្រាប់ភិក្ខុនោះ ដោយប្រការដូច្នេះ ។ ម្យ៉ាងទៀត ព្រោះអានាបានស្សតិកម្មដ្ឋាននេះ ជាកំពូលក្នុងប្រភេទនៃកម្មដ្ឋាន ជាបទដ្ឋាននៃការសម្រេចគុណវិសេស និងធម៌ ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន របស់ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងសាវករបស់ព្រះពុទ្ធទាំងឡាយ ដែលព្រះយោគាវចរមិនលះបង់ស្រុកដែលអើងកងទៅដោយសំឡេងស្ត្រី សំឡេងបុរស សំឡេងដំរី សំឡេងសេះជាដើម មិនធ្វើបានងាយក្នុងការចម្រើន ព្រោះឈាន

មានសំឡេងជាបន្ទា ។ ចំណែកក្នុងព្រៃដែលមិនមែនជាស្រុក ព្រះយោគាវចរ កំណត់កាន់យកកម្មដ្ឋាននេះ ញុំាំងអានាបានស្សតិ ចតុត្ថជ្ឈានឲ្យកើត ធ្វើឈាននោះឲ្យជាបាទ ពិចារណាសង្ខារទាំងឡាយជាការធ្វើបានងាយ ដើម្បីសម្រេចអរហត្តដែលជាផលដ៏ប្រសើរ ហេតុនោះ ព្រះមានព្រះភាគ កាលទ្រង់សម្ដែងសេនាសនៈ ដែលសមគួរដល់ព្រះយោគាវចរនោះ ទើបត្រាស់ថា **អរញ្ញគតោ វា** ជាដើម ។ ព្រះថេរៈក៏ពោលយ៉ាងនោះ ។

ព្រះមានព្រះភាគ ដូចជាអាចារ្យអ្នកមានវិជ្ជាមើលទីដី ។ ពិតហើយ អាចារ្យអ្នកមានវិជ្ជាចេះមើលទីដីនោះ ឃើញទីដីដែលសាងនគរហើយ កំណត់ដោយល្អ ហើយចង្អុលបង្ហាញថា ចូរពួកលោកសាងនគរត្រង់ផ្ទៃដីនេះចុះ កាលនគរសម្រេចដោយល្អ រមែងបានសក្ការៈមកអំពីរាជត្រកូល យ៉ាងណា ព្រះមានព្រះភាគអង្គនោះ ក៏យ៉ាងនោះដូចគ្នា ទ្រង់កំណត់សេនាសនៈដែលសមគួរដល់ព្រះយោគាវចរ ហើយទ្រង់ណែនាំថា គួរប្រកបកម្មដ្ឋានក្នុងទីនេះ បន្ទាប់អំពីនោះ កាលព្រះយោគាវចរប្រកបកម្មដ្ឋានក្នុងទីនោះ សម្រេចអរហត្តដោយលំដាប់ ព្រះមានព្រះភាគទ្រង់រមែងបានទទួលសក្ការៈធំថា ព្រះមានព្រះភាគអង្គនោះ ព្រះអង្គជាព្រះសម្មាសម្ពុទ្ធហ្ន៎ ដូច្នេះ ។

ម្យ៉ាងទៀត ភិក្ខុនេះលោកពោលថា ដូចជាខ្លាដំបង ។ ស្ដេចខ្លាដំបងពួនអាស្រ័យគុម្ពោតស្មៅ គុម្ពោតព្រៃ ញកភ្នំ ក្នុងព្រៃ ចាប់ម្រឹគ មានក្របីព្រៃ ឈ្លូស ជ្រូកជាដើមយ៉ាងណា សេចក្ដីនេះគប្បីជ្រាបយ៉ាងនោះដូចគ្នា ភិក្ខុនេះ កាលប្រកបកម្មដ្ឋានរឿយៗ ក្នុងព្រៃជាដើម រមែងកាន់យកសោតាបត្តិមគ្គ

សកទាគាមិមគ្គ អនាគាមិមគ្គ និងអរហត្តមគ្គ និងអរិយផលទាំងឡាយ តាមលំដាប់ ។ ដោយហេតុនោះ ទើបបោរាណាចារ្យទាំងឡាយពោលថា

ខ្លាដំបងពួនចាប់ម្រឹគទាំងឡាយ យ៉ាងណា ព្រះពុទ្ធបុត្តនេះ ក៏

យ៉ាងនោះដូចគ្នា ប្រកបសេចក្តីព្យាយាម ចម្រើនវិបស្សនា

ចូលទៅកាន់ព្រៃហើយ រមែងកាន់យកផលដ៏ឧត្តម ។

ដោយហេតុនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងសេនាសនៈព្រៃ ដែលជាទីកន្លែងប្រកបសេចក្តីព្យាយាមបានយ៉ាងរហ័ស ទើបត្រាស់ថា **អរញ្ញគតោ វា** ជាដើម ។

ក្នុងបទទាំងនោះ បទថា **អរញ្ញគតោ** បានដល់ នៅព្រៃដែលជាហេតុនាំមកនូវសេចក្តីសុខ ដែលកើតអំពីការស្ងាត់ឯណានីមួយ មានលក្ខណៈដូចពោលហើយខាងមុខ ។ បទថា **រុក្ខមូលគតោ** បានដល់ នៅជិតដើមឈើ ។ បទថា **សុញ្ញាគារគតោ** បានដល់ នៅក្នុងឱកាសស្ងាត់សូន្យ ។

ម្យ៉ាងទៀត ក្នុងបទនេះ សូម្បីនៅក្នុងសេនាសនៈ ៧ យ៉ាងដ៏សេសវៀរព្រៃ និងគល់ឈើ ក៏គួរពោលបានថា **សុញ្ញាគារគតោ ។** ពិតហើយ សេនាសនៈមាន ៩ យ៉ាង ដូចដែលលោកពោល ( ក្នុងអភិធម្មវិភង្គ ) ថា ភិក្ខុនោះគប់រកទីសេនាសនៈដ៏ស្ងាត់ គឺព្រៃតូច គល់ឈើ ភ្នំ ជ្រោះភ្នំ គុហាភ្នំ ព្រៃស្មសាន ព្រៃញៀតស្បាត ទីវាល គំនរចំបើង ដូច្នេះ ។ ព្រះសារីបុត្តកាលណែនាំសេនាសនៈ ដែលសមគួរដល់ការចម្រើនអានាបានស្សតិកម្មដ្ឋាន ដែលសមគួរដល់រដូវទាំង ៣ និងសមគួរដល់ធាតុ និងចរិយាដល់ភិក្ខុនោះ

យ៉ាងនេះហើយ កាលទ្រង់ណែនាំដល់ឥរិយាបថដ៏ស្ងប់ ដែលជាចំណែកនៃការមិនរួញរា និងមិនរាយមាយ ទើបពោលថា **និសីទតិ** ។

កាលព្រះសារីបុត្ត សម្តែងភាពដែលការអង្គុយរបស់ភិក្ខុនោះមាំទាំ ភាពដែលខ្យល់ដង្ហើមចូល ដង្ហើមចេញប្រព្រឹត្តទៅប្រក្រតី និងឧបាយកំណត់កាន់យកអារម្មណ៍ ទើបពោលពាក្យជាដើមថា **បល្លង្កំ អាភុជិត្វា** ។

ក្នុងបទទាំងនោះ បទថា **បល្លង្កំ** បានដល់ អង្គុយពត់ជើងដោយជុំវិញ ( ពែនភ្នែន ) ។ បទថា **អាភុជិត្វា** បានដល់ ដាក់ជើងលើជើង ។ បទថា **ឧជុំ កាយំ បណិធាយ** បានដល់ តាំងកាយខាងលើឲ្យត្រង់ ឲ្យឆ្អឹងទ្រនុងខ្នង ១៨ ត្រួតលើគ្នា ព្រោះកាលអង្គុយយ៉ាងនេះ ស្បែក សាច់ សរសៃនឹងមិនកោងចុះ ។ វេទនាដែលកើតឡើងគ្រប់ៗ ខណៈ ព្រោះស្បែក សាច់ និងសរសៃកោងចុះ ជាហេតុមិនកើតឡើងដល់ភិក្ខុនោះ កាលវេទនាមិនកើត ចិត្តក៏មានអារម្មណ៍តែមួយ កម្មដ្ឋានមិនធ្លាក់ចុះ រមែងចូលដល់ភាពចម្រើន លូតលាស់ ។ បទថា **បរិមុខំ សតឹ ឧបដ្ឋបេត្វា** បានដល់ តម្រង់សតិចំពោះកម្មដ្ឋាន ។ បទថា **សោ សតោវ អស្សសតិ សតោ បស្សសតិ** បានដល់ភិក្ខុនោះ កាលអង្គុយយ៉ាងនេះ និងតម្កល់សតិទុកយ៉ាងនេះ កាលមិនលះសតិនោះ ឈ្មោះថា ជាអ្នកមានសតិដកដង្ហើមចូល មានសតិដកដង្ហើមចេញ ។ លោកអធិប្បាយថា ជាអ្នកធ្វើសតិ ( សតោការី ) ។

ឥឡូវនេះ ព្រះសារីបុត្ត កាលសម្តែងដល់ប្រការដែលភិក្ខុធ្វើសតិ ទើបពោលថា **ទីឃំ វា អស្សសន្តោ** ជាដើម ។

ក្នុងបទទាំងនោះ បទថា **ទីឃំ វា អស្សសន្តោ** បានដល់ ធ្វើខ្យល់ដក ដង្ហើមចូលឲ្យវែង ។ ដកដង្ហើមចូលខ្លី ក៏ដូច្នោះ ។ ម្យ៉ាងទៀត គប្បីជ្រាប ខ្យល់ដកដង្ហើមចូល និងខ្យល់ដកដង្ហើមចេញទាំងនោះវែង និងខ្លីដោយកាល ។

ពិតហើយ មនុស្សទាំងឡាយ គ្រាខ្លះ ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ វែងដោយកាល ដូចដំរី និងពស់ជាដើម គ្រាខ្លះ ខ្លី ដូចសុនខ និងទន្សាយ ជាដើម ។ ខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញ ដែលល្អិតដោយប្រការដទៃ មិនមានវែង និងខ្លី ។ ព្រោះហេតុនោះ ខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញ កាលចូល និងចេញ អស់ពេលយូរ គប្បីជ្រាបថា វែង កាលចូល និងចេញ អស់ពេលខ្លី គប្បីជ្រាប ថាខ្លី ។ ក្នុងរឿងនេះ ភិក្ខុនេះ កាលខ្យល់ដង្ហើម ចូល និងខ្យល់ដង្ហើមចេញវែង ដោយអាការ ៩ យ៉ាងដូចនឹងពោលខាងមុខ រមែងដឹងថា អាត្មាអញ ដកដង្ហើមចូល ដកដង្ហើមចេញវែង ។ ឯខ្យល់ ដង្ហើមខ្លី ក៏ដូចគ្នា ។ ម្យ៉ាងទៀត

វណ្ណៈ ៤ គឺវែង ខ្លី ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញបែបនោះ
រមែងប្រព្រឹត្តទៅលើចុងច្រមុះ របស់ភិក្ខុដែលដឹងយ៉ាងនោះ ។

គប្បីជ្រាបថា ការចម្រើនកាយានុបស្សនាសតិប្បដ្ឋាន រមែងសម្បូរដល់ ភិក្ខុនោះ ដោយអាការមួយនៃអាការ ៩ យ៉ាង ។

បទថា **សព្វកាយប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ សព្វកាយ-ប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ** សេចក្តីថា ភិក្ខុរមែងសិក្សាថា អញ នឹងធ្វើខាងដើម កណ្តាល និងទីបំផុតនៃគំនរខ្យល់ដង្ហើមចូលទាំងអស់ ឲ្យដឹង

ច្បាស់ ធ្វើឲ្យប្រាកដទើបដកដង្ហើមចូល រមែងសិក្សាថា អាត្មាអញនឹងធ្វើខាងដើម កណ្តាល និងទីបំផុតនៃគំនរខ្យល់ដង្ហើមចេញទាំងអស់ ឲ្យដឹងច្បាស់ ឲ្យប្រាកដ ទើបដកដង្ហើមចេញ ។ ភិក្ខុធ្វើឲ្យដឹងច្បាស់ ឲ្យប្រាកដយ៉ាងនេះ ដកដង្ហើមចូល និងដកដង្ហើមចេញ ដោយចិត្តសម្បយុត្តដោយញាណ ព្រោះហេតុនោះ ទើបលោកហៅថា សិក្សាថា អាត្មាអញនឹងដកដង្ហើមចូល អាត្មាអញនឹងដកដង្ហើមចេញ ។ ពិតហើយ ខាងដើមក្នុងគំនរខ្យល់ដង្ហើមចូល ឬក្នុងគំនរខ្យល់ដង្ហើមចេញដែលជារបស់ល្អិតរបស់ភិក្ខុមួយរូប រមែងប្រាកដ តែត្រង់កណ្តាល និងខាងចុង មិនប្រាកដ ។ ភិក្ខុនោះ រមែងកំណត់កាន់យកខាងដើមប៉ុណ្ណោះ រមែងលំបាកក្នុងកណ្តាល និងខាងចុង ។ ភិក្ខុមួយរូប កណ្តាលប្រាកដ ខាងដើម និងខាងចុងមិនប្រាកដ ។ ភិក្ខុរូបនោះ អាចកំណត់កាន់យកកណ្តាលប៉ុណ្ណោះ រមែងលំបាកក្នុងខាងដើម និងខាងចុង ។ ភិក្ខុមួយរូប ខាងចុងប្រាកដ ខាងដើម និងកណ្តាលមិនប្រាកដ ។ ភិក្ខុរូបនោះ អាចកំណត់កាន់យកខាងចុងប៉ុណ្ណោះ រមែងលំបាកក្នុងខាងដើម និងកណ្តាល ។ ភិក្ខុមួយរូប ប្រាកដទាំងអស់ ភិក្ខុរូបនោះ អាចកំណត់កាន់យកសូម្បីទាំងអស់បាន មិនលំបាកក្នុងទីណាមួយឡើយ ។ ព្រះសារីបុត្ត កាលសម្តែងថា ភិក្ខុគួរមានសភាពយ៉ាងនោះ ទើបពោលថា **សព្វកាយប្បដិសំវេទី** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **សិក្ខតិ** បានដល់ រមែងព្យាយាមយ៉ាងនេះ ។ ម្យ៉ាងទៀត គប្បីជ្រាបសេចក្តីក្នុងបទនេះយ៉ាងនេះថា ភិក្ខុរមែងសិក្សា រមែងសេព រមែងចម្រើន រមែងធ្វើឲ្យច្រើនក្នុងអារម្មណ៍នោះ ដោយសតិនោះ

ដោយមនសិការនោះ នូវសិក្ខាទាំង ៣ នេះ គឺក្នុងទីនេះ ការសង្រួមរបស់បុគ្គល ដែលមានសភាពបែបនោះ ឈ្មោះថា អធិសីលសិក្ខា សមាធិរបស់បុគ្គល ដែលមានសភាពបែបនោះ ឈ្មោះថា អធិចិត្តសិក្ខា បញ្ញារបស់បុគ្គលដែល មានសភាពបែបនោះ ឈ្មោះថា អធិប្បញ្ញាសិក្ខា ក្នុងបទនោះ ព្រោះគួរដក ដង្ហើមចូល និងគួរដកដង្ហើមចេញតែម្យ៉ាងដោយន័យមុន មិនគួរធ្វើអ្វីដទៃឡើយ ចាប់តាំងអំពីនោះ គួរធ្វើសេចក្តីព្យាយាម ក្នុងការធ្វើញាណឲ្យកើតឡើងជាដើម ព្រោះហេតុនោះ គប្បីជ្រាបថា ក្នុងបទទាំងនោះ ព្រះសារីបុត្តពោលដល់បាលី ដោយអំណាចនៃបច្ចុប្បន្នកាលថា **អស្សសាមីតិ បជានាតិ បស្សសាមីតិ បជានាតិ** ដឹងច្បាស់ដកដង្ហើមចូល ដឹងច្បាស់ដកដង្ហើមចេញ ដើម្បីសម្តែង អាការមានការធ្វើញាណឲ្យកើតឡើងជាដើម ដែលគប្បីធ្វើតាំងអំពីនេះទៅ ទើបលើកបាលីឡើងដោយអំណាចនៃអនាគតកាល ដោយន័យជាដើមថា **សព្វកាយប្បដិសំវេទី អស្សសិស្សាមិ** អាត្មាអញជាអ្នកកំណត់ដឹងច្បាស់នូវ កាយ គឺខ្យល់ចូលទាំងពួង នឹងដកដង្ហើមចូល ដូច្នេះ ។

បទថា **បស្សម្ភយំ កាយសង្ខារំ ។បេ។ សិក្ខតិ** បានដល់ រមែងសិក្សា ថា អាត្មាអញរម្ងាប់ ស្ងប់ រម្ងត់ និងចូលទៅស្ងប់កាយសង្ខារ ពោល គឺខ្យល់ ដង្ហើមចូល ដង្ហើមចេញ យ៉ាងគ្រោតគ្រាត ទើបដកដង្ហើមចូល ដកដង្ហើម ចេញ ។ ក្នុងបទនោះ គប្បីជ្រាបដល់សភាពគ្រោតគ្រាត ល្អិត និងស្ងប់ ដោយប្រការយ៉ាងនោះ ។

ក្នុងកាលភិក្ខុនេះ មិនបានកំណត់កាន់យកមុន កាយ និងចិត្តរមែងក្រវល់

ក្រវាយ និងជារបស់គ្រោតគ្រាត ។ កាលកាយ និងចិត្តគ្រោតគ្រាត មិនស្ងប់ស្ងាត់ខ្យល់ដកដង្ហើមចូល ខ្យល់ដកដង្ហើមចេញ ក៏គ្រោតគ្រាតផង ខ្យល់ដកដង្ហើមចូល ខ្យល់ដកដង្ហើមចេញ មានកម្លាំងជាង នៅប្រព្រឹត្តទៅ ច្រមុះមិនល្មមនឹងដកដង្ហើម ត្រូវឈរដកដង្ហើមចូលខ្លះ ដកដង្ហើមចេញខ្លះ តាមមាត់ ។ ម្យ៉ាងទៀត កាលណាកាយខ្លះ ចិត្តខ្លះដែលភិក្ខុនោះកំណត់កាន់យក កាលនោះខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញទាំងនោះល្អិត ស្ងប់រម្ងាប់ កាលកាយ និងចិត្តទាំងនោះស្ងប់រម្ងាប់ ខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញល្អិត នៅប្រព្រឹត្តទៅរមែងដល់នូវអាការគួរពិចារណាថា ខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញ មានឬមិនមានហ្ន៎ ។ ប្រៀបដូចកាលបុរសរត់ចុះអំពីភ្នំ ឬដាក់ទ្រនូលចុះអំពីក្បាលហើយឈរ ខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញ ក៏គ្រោតគ្រាត ច្រមុះក៏មិនល្មមដកដង្ហើម ត្រូវឈរដកដង្ហើមចូលខ្លះ ដកដង្ហើមចេញខ្លះ តាមមាត់ ។

ម្យ៉ាងទៀត កាលណាបុរសនោះ បន្ទោបង់នូវការហត់នឿយនោះ ងូតទឹកផឹកទឹក យកសំពត់សើមគ្របទ្រូងដេកក្រោមម្លប់ត្រជាក់ កាលនោះ ខ្យល់ដកដង្ហើមចូល ខ្យល់ដកដង្ហើមចេញ របស់បុរសនោះល្អិត រមែងដល់អាការដែលគួរពិចារណាថា ខ្យល់ដកដង្ហើមចូល ខ្យល់ដកដង្ហើមចេញ មាន ឬមិនមានហ្ន៎ យ៉ាងណា គប្បីឲ្យពិស្តារថា ក្នុងកាលដែលភិក្ខុនេះ មិនបានកំណត់យកយ៉ាងនោះ ក៏យ៉ាងនោះ ។

ពិតហើយ ក្នុងកាលដែលភិក្ខុនោះមិនបានកំណត់កាន់យកមុន ការចងចិត្ត ការរួបរួម និងការដាក់ចិត្តថា អាត្មាអញនឹងស្ងប់កាយសង្ខារគ្រោតគ្រាត

រមែងមិនមាន ។ តែក្នុងកាលដែលកំណត់កាន់យករមែងមាន ។ ដោយហេតុនោះ ក្នុងកាលដែលភិក្ខុនោះ កំណត់កាន់យកអំពីកាលដែលមិនបានកំណត់កាន់យក កាយសង្ខារជារបស់ល្អិត ។ ដោយហេតុនោះ ទើបបោរាណាចារ្យទាំងឡាយពោលថា

កាលកាយ និងចិត្តរសាប់រសល់ កាយសង្ខាររមែងប្រព្រឹត្ត
ទៅគ្រោតគ្រាត កាលកាយមិនរសាប់រសល់ កាយសង្ខារ
រមែងប្រព្រឹត្តទៅ យ៉ាងសុខុម ។

សូម្បីក្នុងការកំណត់កាន់យក កាយសង្ខារគ្រោតគ្រាត ក្នុងឧបចារៈនៃបឋមជ្ឈាន កាយសង្ខារសុខុម ។ សូម្បីក្នុងឧបចារៈនៃបឋមជ្ឈាននោះ កាយសង្ខារក៏នៅគ្រោតគ្រាត ក្នុងបឋមជ្ឈានទើបសុខុម ។ ក្នុងបឋមជ្ឈាន និងឧបចារៈនៃទុតិយជ្ឈាន កាយសង្ខារក៏នៅគ្រោតគ្រាត ក្នុងទុតិយជ្ឈានទើបសុខុម ។ ក្នុងទុតិយជ្ឈាន និងក្នុងឧបចារៈនៃតតិយជ្ឈានក៏នៅគ្រោតគ្រាត ក្នុងតតិយជ្ឈានទើបសុខុម ។ ក្នុងតតិយជ្ឈាន និងក្នុងឧបចារៈនៃចតុត្ថជ្ឈាន ក៏នៅគ្រោតគ្រាត ក្នុងចតុត្ថជ្ឈានទើបសុខុមក្រៃលែង រមែងដល់ការមិនប្រព្រឹត្តទៅទៀតឡើយ ។ នេះជាមតិរបស់លោកអ្នកពោលទីឃនិកាយ និងសំយុត្តនិកាយមុន ។

ចំណែកអាចារ្យ អ្នកពោលមជ្ឈិមនិកាយ រមែងប្រាថ្នាសេចក្ដីល្អិតជាងសូម្បីក្នុងឧបចារៈនៃឈានខ្ពស់ៗ អំពីឈានទាបៗ យ៉ាងនេះថា ក្នុងបឋមជ្ឈាននៅគ្រោតគ្រាត ក្នុងឧបចារៈនៃទុតិយជ្ឈាន ទើបសុខុម ។ តាមមតិរបស់

ការណការយ្យទាំងពួង កាយសង្ខារដែលប្រព្រឹត្តទៅហើយ ក្នុងកាលមិនបាន កំណត់កាន់យក រមែងស្ងប់រម្ងាប់ក្នុងកាលដែលកំណត់កាន់យក កាយសង្ខារ ដែលប្រព្រឹត្តទៅហើយក្នុងកាលកំណត់កាន់យក រមែងស្ងប់រម្ងាប់ក្នុងឧបចារៈ នៃបឋមជ្ឈាន ។បេ។ កាយសង្ខារដែលប្រព្រឹត្តទៅហើយ ក្នុងឧបចារៈនៃ ចតុត្ថជ្ឈាន រមែងស្ងប់រម្ងាប់ក្នុងចតុត្ថជ្ឈាន ។ នេះជាន័យក្នុងសមថៈមុន ។

ចំណែកក្នុងវិបស្សនា កាយសង្ខារដែលប្រព្រឹត្តទៅហើយ ក្នុងកាលមិន បានកំណត់កាន់យកនៅគ្រោតគ្រាត ក្នុងកាលកំណត់កាន់យកមហាភូតរូបទើប កាយសង្ខារសុខុម ។ សូម្បីកាយសង្ខារនោះ ក៏នៅគ្រោតគ្រាត ក្នុងកាល កំណត់កាន់យកឧបាទាយរូបទើបសុខុម ។ សូម្បីដូច្នេះក៏នៅគ្រោតគ្រាត ក្នុង កាលកំណត់កាន់យករូបទាំងអស់ទើបសុខុម ។ សូម្បីដូច្នោះក៏នៅគ្រោតគ្រាត ក្នុងកាលកំណត់កាន់យកអរូបទើបសុខុម ។ សូម្បីដូច្នោះ ក៏នៅគ្រោតគ្រាត ក្នុងកាលកំណត់កាន់យករូប និងអរូបទើបសុខុម ។ សូម្បីដូច្នោះ ក៏នៅគ្រោត គ្រាត ក្នុងកាលកំណត់កាន់យកបច្ច័យទើបសុខុម ។ សូម្បីដូច្នោះក៏នៅគ្រោត គ្រាត ក្នុងការឃើញនាមរូប ព្រមជាមួយបច្ច័យទើបសុខុម ។ សូម្បីដូច្នោះក៏ នៅគ្រោតគ្រាត ក្នុងវិបស្សនាដែលមានលក្ខណៈជាអារម្មណ៍ ទើបសុខុម ។ សូម្បីដូច្នោះ ក៏ឈ្មោះថា នៅគ្រោតគ្រាត ព្រោះជាវិបស្សនាទន់ខ្សោយ ក្នុង វិបស្សនាមានកម្លាំងទើបសុខុម ។ ក្នុងពាក្យទាំងនោះ គប្បីជ្រាបការស្ងប់រម្ងាប់ នៃកាយសង្ខារមុនៗ ដោយកាយសង្ខារក្រោយៗ ដោយន័យដូចពោលហើយ ក្នុងកាលមុននោះឯង ។

ក្នុងបទទាំងនេះ គប្បីជ្រាបសភាពដែលកាយសង្ខារគ្រោតគ្រាត និងសុខុម និងការស្ងប់ដោយអាការយ៉ាងនេះ ។ ការពណ៌នាបទតាមលំដាប់នៃបឋម-ចតុក្កៈ ដែលលោកពោលហើយ ដោយអំណាចនៃកាយានុបស្សនាក្នុងទីនេះ ដូច្នេះមុន ។

ព្រោះក្នុងទីនេះលោកពោលចតុក្កៈនេះប៉ុណ្ណោះ ដោយអំណាចនៃកម្មដ្ឋាននៃអាទិកម្មិក ។ ចំណែកចតុក្កៈ ៣ ក្រៅអំពីនេះ លោកពោលដោយអំណាចនៃវេទនានុបស្សនា ចិត្តានុបស្សនា និងធម្មានុបស្សនា សម្រាប់បុគ្គលដែលសម្រេចឈានហើយក្នុងអានាបានស្សតិសមាធិនេះ ហេតុនោះ កុលបុត្តអ្នកជាអាទិកម្មិក បំណងនឹងចម្រើនកម្មដ្ឋាននេះ ហើយសម្រេចព្រះអរហត្ត ព្រមដោយបដិសម្ភិទាដោយវិបស្សនាដែលមានចតុត្ថជ្ឈាន ក្នុងអានាបានស្សតិជាបទដ្ឋាន គប្បីធ្វើកិច្ចទាំងពួង មានញ៉ាំងសីលឲ្យបរិសុទ្ធជាដើម ដោយន័យដូចពោលហើយក្នុងវិសុទ្ធមគ្គ ហើយគប្បីរៀនយកកម្មដ្ឋានដែលមានសន្ធិ ( ការជាប់ត ) ៥ ក្នុងសម្នាក់របស់អាចារ្យដែលប្រកបដោយអង្គ ៧ ។

ក្នុងកម្មដ្ឋាននោះ សន្ធិមាន ៥ នេះ គឺឧគ្គហៈ ១ បរិបុច្ឆា ១ ឧបដ្ឋាន ១ អប្បនា ១ លក្ខណៈ ១ ។

ក្នុងសន្ធិទាំងនោះ ការរៀនកម្មដ្ឋាន ឈ្មោះថា ឧគ្គហៈ ។ ការសាកសួរកម្មដ្ឋាន ឈ្មោះថា បរិបុច្ឆា ។ ការប្រាកដនៃកម្មដ្ឋាន ឈ្មោះថា ឧបដ្ឋាន ។ ការចុះស៊ប់នៃកម្មដ្ឋាន ឈ្មោះថា អប្បនា ។ លក្ខណៈនៃកម្មដ្ឋាន ឈ្មោះថា លក្ខណៈ មានពាក្យអធិប្បាយថា ការចូលទៅពិចារណាសភាវៈនៃកម្មដ្ឋានថា

កម្មដ្ឋាននេះ មានលក្ខណៈយ៉ាងនេះ ។

កុលបុត្តកាលរៀនកម្មដ្ឋានដែលមានសន្ធិ ៥ នេះ រមែងមិនធ្វើខ្ទួនឲ្យលំបាក រមែងមិនបៀតបៀនសូម្បីអាចារ្យ ព្រោះហេតុនោះ ឲ្យអាចារ្យចង្អុលបង្ហាញបន្តិច ហើយប្រើវេលាទន្ទេញឲ្យច្រើន រៀនកម្មដ្ឋានមានសន្ធិ ៥ យ៉ាងនេះ វៀរលំនៅដែលប្រកបដោយទោស ១៨ យ៉ាងក្នុងសម្នាក់នៃអាចារ្យ ឬក្នុងទីដទៃ ហើយនៅក្នុងសេនាសនៈប្រកបដោយអង្គ ៥ កាត់បលិពោធបន្តិចបន្តួច បរិភោគស្រេចហើយបន្ទោបង់ការស្រវឹងក្នុងអាហារ អង្គុយឲ្យសប្បាយ រឭកដល់គុណព្រះរតនត្រ័យ ធ្វើចិត្តឲ្យរីករាយ មិនឲ្យសាបសូន្យសូម្បីតែបទមួយ ចាកការរៀនពីអាចារ្យគប្បីមនសិការអានាបានស្សតិកម្មដ្ឋាននេះក្នុងចិត្ត ។

វិធីមនសិការកម្មដ្ឋាន មានដូចតទៅនេះ

> គណនា ( ការរាប់ ) អនុពន្ធនា ( ការជាប់តាម ) ផុសនា ( ការប៉ះពាល់ ) ឋបនា ( ការតាំងទុក ) សល្លក្ខណា ( ការឃើញច្បាស់ ) វិវដ្ដនា ( ការចម្រើន ) បារិសុទ្ធិ ( សេចក្ដីបរិសុទ្ធ ) និងបដិបស្សនាធម៌ទាំងនោះ ។

ក្នុងបទទាំងនោះ បទថា **គណនា** គឺការរាប់នោះឯង ។ បទថា **អនុពន្ធនា** គឺការតាមរឭក ។ បទថា **ផុសនា** គឺទីការពាល់ត្រូវ ។ បទថា **ឋបនា** គឺអប្បនា ។ បទថា **សល្លក្ខណា** គឺវិបស្សនា ។ បទថា **វិវដ្ដនា** គឺមគ្គ ។ បទថា **បារិសុទ្ធិ** គឺផល ។ បទថា បដិបស្សនាធម៌ទាំងនោះ គឺបច្ចវេក្ខណញ្ញាណ ។

ក្នុងវិធីមនសិការកម្មដ្ឋាននោះ កុលបុត្តដែលផ្តើមបំពេញកម្មដ្ឋាននេះ គប្បីដាក់ចិត្តក្នុងកម្មដ្ឋាននេះ ដោយការរាប់មុន ។ កាលរាប់មិនគួរឲ្យតិចជាង ៥ មិនគួរច្រើនជាង ១០ មិនគួររាប់ឲ្យដាច់ក្នុងចន្លោះ ព្រោះកាលរាប់តិចជាង ៥ ចិត្តុប្បាទរមែងអន្ទះអន្ទែងក្នុងឱកាសចង្អៀត ដូចហ្វូងគោដែលដាក់ក្នុងក្រោលចង្អៀត កាលបើរាប់ច្រើនជាង ១០ ចិត្តុប្បាទរវល់តែក្នុងការរាប់ប៉ុណ្ណោះ កាលរាប់ឲ្យដាច់ក្នុងចន្លោះ ចិត្តរមែងញាប់ញ័រថា កម្មដ្ឋានរបស់អញសម្រេចហើយឬហ្ន៎ ព្រោះហេតុនោះ គួររាប់វៀរទោសទាំងនោះចេញ ។

ម្យ៉ាងទៀត ខាងដើម កាលរាប់ គួររាប់យឺតៗ ដូចការវាល់ស្រូវ ឯអ្នកវាល់ស្រូវកើបឲ្យពេញតៅ ហើយរាប់ថាមួយ ហើយចាក់ចុះ កាលពេញទៀត កាលឃើញសំរាមណានីមួយក៏រើសចោល ទើបរាប់ថា មួយ មួយ ។ សូម្បីក្នុងកាលរាប់ថា ពីរ ពីរ ជាដើម ក៏មានន័យនេះដូចគ្នា ។

ក្នុងខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញ ខ្យល់ណាប្រាកដ កុលបុត្តនេះកំណត់ខ្យល់នោះយ៉ាងនេះៗ ហើយកំណត់រាប់ខ្យល់ដែលប្រព្រឹត្តទៅតាំងអំពីរាប់ថា មួយ មួយ ទៅរហូតដល់ ដប់ ដប់ កាលកុលបុត្តនោះរាប់យ៉ាងនេះខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ទាំងចូល និងចេញ រមែងប្រាកដ ។

បន្ទាប់អំពីនោះ កុលបុត្តនោះលះការរាប់យឺតៗ ដូចការរាប់របស់អ្នកវាល់ស្រូវ ហើយគប្បីរាប់រហ័ស ដូចការរាប់របស់អ្នកចិញ្ចឹមគោ ។ ពិតហើយ អ្នកចិញ្ចឹមគោដែលឈ្លាស យកដុំក្រួសជាដើមដាក់ក្នុងថ្នក់ កាន់ខ្សែ និងរំពាត់ទៅកាន់ក្រោលអំពីព្រលឹមវាយគោត្រង់ខ្នងហើយ អង្គុយលើចុងសសរ ទ្វារ

ក្រោល ផ្ទាត់ជុំក្រុសរាប់គោដែលមកដល់ទ្វារមុនមួយថា មួយ ពីរ ។

ហ្វូងគោដែលនៅលំបាក ក្នុងទីចង្អៀតមករហូត ៣ យាម កាលចេញក៏ប្រជៀតគ្នានិងគ្នា ប្រញាប់ចេញជាពួកៗ ។ អ្នកចិញ្ចឹមគោនោះ ប្រញាប់រាប់ថា បី បួន ប្រាំ ដប់ កាលកុលបុត្តនោះរាប់ដោយន័យមុនយ៉ាងនេះ ខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញ ក៏នឹងប្រាកដជួងទៅមករឿយៗ យ៉ាងរហ័ស ។

បន្ទាប់អំពីនោះ កុលបុត្តនោះកាលដឹងថា ខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញជួងទៅមករឿយៗ មិនកំណត់ទាំងខាងក្នុងទាំងខាងក្រៅ កំណត់ចំពោះខ្យល់ដែលដល់ទ្វារប៉ុណ្ណោះ ហើយប្រញាប់រាប់ដោយរហ័សថា ១ ២ ៣ ៤ ៥ ១ ២ ៣ ៤ ៥ ៦ ១ ២ ៣ ៤ ៥ ៦ ៧ ១ ២ ៣ ៤ ៥ ៦ ៧ ៨ ១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩ ១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩ ១០ ។

ពិតហើយ ក្នុងកម្មដ្ឋានដែលទាក់ទងដោយការរាប់ ចិត្តរមែងមានអារម្មណ៍តែមួយ ដោយកម្លាំងនៃការរាប់ប៉ុណ្ណោះ ដូចចតទូកត្រង់ក្រសែទឹកហូរត្របាញ់ដោយការទប់ដោយថ្នោល ដូច្នោះ ។

កាលកុលបុត្តរាប់រហ័សយ៉ាងនេះ កម្មដ្ឋានរមែងប្រាកដ ដូចប្រព្រឹត្តទៅជាប់តគ្នា កាលដឹងថាកម្មដ្ឋានប្រព្រឹត្តទៅជាប់តគ្នាហើយ មិនកំណត់កាន់យកខ្យល់ខាងក្នុង និងខ្យល់ខាងក្រៅ គប្បីរាប់រហ័សដោយន័យមុននោះឯង ។ កាលបញ្ជូនចិត្តចូលទៅព្រមជាមួយខ្យល់ ដែលចូលខាងក្នុង ខាងក្នុងត្រូវប៉ះខ្ទប់ហើយរមែងដូចជាពេញដោយខ្លាញ់ខាប់ ។ កាលបញ្ជូនចិត្តចេញទៅព្រមជាមួយខ្យល់ដែលចេញខាងក្រៅ ចិត្តរមែងរាយមាយទៅក្នុងអារម្មណ៍ ដែល

ក្រៅស់ខាងក្រៅ ។ ម្យ៉ាងទៀត កាលតាំងសតិ ក្នុងទីដែលខ្យល់ពាល់ត្រូវ ហើយចម្រើនភាវនា ភាវនា រមែងបរិបូរណ៍ដោយហេតុនោះ ទើបលោក ពោលថា មិនកំណត់កាន់យកខ្យល់ខាងក្នុង និងខ្យល់ខាងក្រៅ គប្បីរាប់ ដោយរហ័ស ដោយន័យមុននោះឯង ។

ការរាប់ខ្យល់នេះ គួររាប់យូរប៉ុនណា រាប់រហូតដល់កាលវៀរចាកការរាប់ ហើយសតិតាំងមាំក្នុងអារម្មណ៍នៃខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញ ។ ការ រាប់ក៏ដើម្បីធ្វើនូវការកាត់វិតក្ក ដែលរាយមាយទៅខាងក្រៅចេញ ហើយធ្វើ សតិឲ្យតាំងមាំក្នុងអារម្មណ៍ គឺខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញនោះឯង ។

គួរធ្វើទុកក្នុងចិត្តដោយការរាប់យ៉ាងនេះ ហើយធ្វើទុកក្នុងចិត្តដោយការជាប់ តាម ។ ការឈប់រាប់ ហើយប្រើសតិតាមរឭកខ្យល់ដង្ហើមចូល ខ្យល់ដង្ហើម ចេញមិនឲ្យដាច់ខ្សែ ឈ្មោះថា អនុពន្ធនា ។ ការតាមរឭកនោះមិនមែនដោយ អំណាចនៃការតាមរឭកខាងដើម កណ្ដាល និងខាងចុង ។ ខាងដើម កណ្ដាល និងខាងចុង និងទោសក្នុងការតាមរឭកខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញ នោះ ខ្ញុំពោលហើយនោះឯង ព្រោះហេតុនោះ កាលមនសិការដោយការតាម រឭក មិនគួរដាក់ចិត្តដោយអំណាចនៃខាងដើម កណ្ដាល និងខាងចុង ដែល ពិតគួរដាក់ចិត្តដោយអំណាចនៃទីដែលខ្យល់ប៉ះ និងដោយអំណាចនៃអប្បនា ។ ការមនសិការញែកគ្នាដោយអំណាចនៃការប៉ះ និងអប្បនា រមែងមិនមាន ដូច ដោយអំណាចនៃការរាប់ និងការតាមរឭក ។ កាលរាប់ក្នុងទីដែលខ្យល់ប៉ះ ហើយ រមែងមនសិការដោយការរាប់ និងដោយការប៉ះ កាលឈប់រាប់ក្នុងទី

ដែលខ្យល់ប៉ះហើយនោះ ប្រើសតិតាមរឭកខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញទាំងនោះ និងតាំងចិត្តទុកដោយអំណាចអប្បនា ហៅថា រមែងដាក់ចិត្តដោយការតាមរឭកដោយការប៉ះ និងដោយអប្បនា ។ គប្បីជ្រាបសេចក្តីនោះ ដោយការឧបមាដោយមនុស្សពិការជើង និងមនុស្សយាមទ្វារ ដូចដែលលោកពោលក្នុងអដ្ឋកថាទាំងឡាយ និងដោយឧបមាដោយរណារ ដូចដែលលោកពោលហើយក្នុងបាលីនេះឯង ។ តទៅនេះ ជាឧបមាដោយមនុស្សពិការជើង ប្រៀបដូចមនុស្សពិការជើង យោលទោងដល់មាតា និងបុត្ត ដែលកំពុងលេងទោងអង្គុយនៅត្រង់គល់សសរទោងនោះឯង រមែងឃើញទីបំផុតទាំងពីរ និងកណ្តាលរបស់ក្តារទោងដែលយោលទៅមកតាមលំដាប់ មិនខ្វល់ខ្វាយដើម្បីនឹងមើលទីបំផុតទាំងពីរ និងកណ្តាលយ៉ាងណា ភិក្ខុក៏យ៉ាងនោះដូចគ្នា នៅត្រង់គល់សសរគឺនិមិត្តដែលចូលទៅចងដោយអំណាចសតិ ហើយយោលទោង គឺខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញ មានសតិក្នុងនិមិត្តនោះៗ ឯង អង្គុយប្រើសតិតាមរឭកខាងដើម កណ្តាល និងខាងចុងនៃខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញ ក្នុងទីដែលខ្យល់ចូល ខ្យល់ចេញ ពាល់ត្រូវដោយលំដាប់ តម្កល់ចិត្តក្នុងទីនោះៗ សម្លឹងមើល មិនខ្វល់ខ្វាយដើម្បីមើលខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញទាំងនោះ នេះជាឧបមាដោយមនុស្សពិការជើង ។

ចំណែកឧបមាដោយមនុស្សរក្សាទ្វារ មានដូច្នេះថា ប្រៀបដូចមនុស្សរក្សាទ្វារ រមែងមិនសាកសួរមនុស្សខាងក្នុង និងខាងក្រៅព្រះនគរថា លោកជានរណា មកអំពីណា និងទៅណា អ្វីក្នុងដៃរបស់លោក ព្រោះមនុស្ស

ទាំងនោះ មិនមែនជាមុខនាទីរបស់គេ តែគេសាកសួរចំពោះមនុស្ស ដែលមកដល់ទ្វារហើយប៉ុណ្ណោះ យ៉ាងណា ខ្យល់ចូលទៅខាងក្នុង និងខ្យល់ចេញទៅខាងក្រៅ មិនមែនជាកិច្ចរបស់ភិក្ខុនោះ ខ្យល់ដែលដល់ទ្វារហើយប៉ុណ្ណោះទើបជាកិច្ច នេះជាឧបមាដោយមនុស្សរក្សាទ្វារ ។

ចំណែកឧបមាដោយរណារ បានពោលហើយ ក្នុងអានាបានស្សតិកថានេះឯង ដោយន័យជាជាដើមថា **និមិត្តំ អស្សាសបស្សាសា** ( និមិត្តខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញ ) តែក្នុងទីនេះ គប្បីជ្រាបថា ការមិនដាក់ចិត្តដោយអំណាចនៃការមក និងការទៅរបស់ខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញនោះប៉ុណ្ណោះ ដែលលោកបំណងយក ។

សម្រាប់បុគ្គលខ្លះ កាលមនសិការកម្មដ្ឋាននេះ និមិត្តរមែងកើតឡើងដោយមិនយឺតយូរ និងការចុះស៊ប់ ពោល គឺអប្បនា ដែលប្រដាប់ដោយអង្គឈានដ៏សេសរមែងបរិបូរណ៍ សម្រាប់បុគ្គលខ្លះ ចាប់តាំងអំពីកាលមនសិការ ដោយអំណាចការរាប់នោះឯង គឺចាប់តាំងអំពីកាលមនសិការដោយការរាប់យ៉ាងនោះ កាលសេចក្តីក្រវល់ក្រវាយស្ងប់ ដោយអំណាចនៃការរម្ងត់ខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញយ៉ាងគ្រោតគ្រាតតាមលំដាប់ កាយក្តី ចិត្តក្តី ជារបស់ស្រាល រាងកាយដូចអណ្តែតទៅក្នុងអាកាស ដូចបុគ្គលមានកាយរសាប់រសល់ អង្គុយលើគ្រែ ឬតាំង គ្រែ និងតាំងរមែងស្រុតចុះ រមែងមានសំឡេងប្រិបប្រិបកម្រាលរមែងជ្រួញ ចំណែកបុគ្គលដែលមានកាយមិនរសាប់រសល់ អង្គុយគ្រែ និងតាំង រមែងមិនស្រុតចុះ មិនមានសំឡេងប្រិបប្រិប កម្រាលមិនជ្រួញ

គ្រៃ និងតាំងហាក់ដូចពេញដោយសំឡី ព្រោះហេតុអ្វី ព្រោះកាយដែលមិនរសាប់រសល់ ជាកាយស្រាល ។

កាលខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញយ៉ាងគ្រោតគ្រាតរបស់ភិក្ខុនោះរលត់ហើយ ចិត្តដែលមាននិមិត្ត គឺខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញល្អិតជាអារម្មណ៍ រមែងប្រព្រឹត្តទៅ ។ សូម្បីកាលចិត្តនោះរលត់ហើយ ចិត្តបន្ទាប់មកដែលល្អិតជាងចិត្តនោះដែលមាននិមិត្ត គឺខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញជាអារម្មណ៍ រមែងប្រព្រឹត្តទៅនោះឯង ។ គប្បីជ្រាបសេចក្តីនេះ ដោយឧបមាដោយថាសលោហៈដូចពោលខាងមុខ ។

កម្មដ្ឋានពួកដទៃ រមែងប្រាកដច្បាស់បន្តិចម្តងៗ យ៉ាងណា កម្មដ្ឋាននេះមិនប្រាកដយ៉ាងនោះឡើយ ។ ម្យ៉ាងទៀត កម្មដ្ឋាននេះសម្រាប់បុគ្គលដែលចម្រើនក្រៃលែងឡើងទៅ រមែងដល់នូវភាពល្អិត ដល់នូវការមិនប្រាកដ ។ កាលកម្មដ្ឋាននោះមិនប្រាកដយ៉ាងនេះ ភិក្ខុនោះមិនគួរក្រោកចាកអាសនៈទៅដោយគិតថា អញនឹងសួរអាចារ្យ ឬថា ឥឡូវនេះ កម្មដ្ឋានរបស់អញ វិនាសហើយ ព្រោះកាលភិក្ខុញុំាងឥរិយាបថឲ្យកម្រើកហើយទៅ កម្មដ្ឋានរមែងត្រូវផ្តើមជាថ្មីដោយពិត ព្រោះហេតុនោះ គួរអង្គុយដដែលនោះឯង ហើយធ្វើកម្មដ្ឋានដោយកំណត់ទីដែលខ្យល់ពាល់ត្រូវ ។

តទៅនេះជាឧបាយធ្វើកម្មដ្ឋានបន្ត ភិក្ខុនោះដឹងភាពដែលកម្មដ្ឋាន មិនប្រាកដគប្បីសិក្សាយ៉ាងនេះថា ឈ្មោះថា ខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញទាំងនេះមាននៅត្រង់ណា មិនមានត្រង់ណា មានដល់នរណា ឬមិនមានដល់នរណា ។

កាលភិក្ខុសិក្សាយ៉ាងនេះ ដឹងថា ខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញទាំងនេះ មិនមានខាងក្នុងផ្ទៃមាតា ( មិនមានដល់ទារក ) មិនមានដល់អ្នកជ្រមុជទឹក មិនមានដល់អសញ្ញីសត្វ មិនមានដល់អ្នកស្លាប់ មិនមានដល់អ្នកចូលចតុត្ថជ្ឈាន មិនមានដល់បុគ្គលដែលដល់ព្រមដោយរូបភព និងអរូបភព មិនមានដល់បុគ្គលអ្នកចូលនិរោធសមាបត្តិ ហើយគប្បីដាស់តឿនខ្លួន ដោយខ្លួនឯងយ៉ាងនេះថា នែបណ្ឌិត អ្នកមិនបាននៅក្នុងផ្ទៃមាតា មិនបានជ្រមុជទឹក មិនមែនជាអសញ្ញីសត្វ មិនមែនស្លាប់ មិនបានចូលចតុត្ថជ្ឈាន មិនបានដល់ព្រមដោយរូបភព អរូបភព មិនបានចូលនិរោធមិនមែនឬ ខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញរបស់អ្នកនៅមានពិតៗ តែអ្នកមិនអាចកំណត់កាន់យកបាន ព្រោះអ្នកមានបញ្ញាទន់ខ្សោយ ។

តមក ភិក្ខុនោះគួរតាំងចិត្តដោយអំណាចខ្យល់ដែលប៉ះតាមប្រក្រតី ហើយធ្វើមនសិការឲ្យប្រព្រឹត្តទៅ ។ ខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញទាំងនេះ ប៉ះក្ដោងច្រមុះរបស់អ្នកមានច្រមុះវែងប្រព្រឹត្តទៅ ប៉ះបបូរមាត់ខាងលើរបស់អ្នកមានច្រមុះខ្លី ព្រោះហេតុនោះ ភិក្ខុនោះគួរតាំងនិមិត្តថា ខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញប៉ះត្រង់នេះ ។ ពិតហើយ ព្រះមានព្រះភាគត្រាស់ ( ក្នុងមជ្ឈិមនិកាយ ឧបរិបណ្ណាសក ) អាស្រ័យអំណាចនៃប្រយោជន៍នេះឯងថា ម្នាលភិក្ខុទាំងឡាយ តថាគតមិនបានពោលនូវអានាបានស្សតិ របស់ភិក្ខុដែលវង្វេងស្មារតី មិនប្រកបដោយប្រាជ្ញាដឹងសព្វទេ ដូច្នេះ ។ ពិតហើយ កម្មដ្ឋានគ្រប់យ៉ាងរមែងសម្រេចដល់អ្នកមានសតិ អ្នកមានសម្បជញ្ញៈក៏ពិត តែកម្មដ្ឋានដទៃ

ក្រៅអំពីអានាបានស្សតិកម្មដ្ឋាននេះ រមែងប្រាកដដល់បុគ្គល ដែលធ្វើទុកក្នុងចិត្ត ចំណែកអានាបានស្សតិកម្មដ្ឋាននេះ ជាកម្មដ្ឋានធ្ងន់ ចម្រើនបានដោយក្រ ជាមនសិការភូមិរបស់ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងពុទ្ធបុត្ត ដែលជាមហាបុរសប៉ុណ្ណោះ មិនមែនជាកម្មដ្ឋានតូចទាប មិនមែនសត្វដែលថោកថយសេពបានឡើយ ។ កម្មដ្ឋាននេះដែលភិក្ខុមនសិការដោយប្រការណាៗ រមែងស្ងប់ និងល្អិតដោយប្រការនោះៗ ព្រោះហេតុនោះ ទើបក្នុងកម្មដ្ឋាននេះ ត្រូវប្រើសតិនិងបញ្ញាដែលមានកម្លាំង ។

ដូចជាក្នុងវេលាដេរសំពត់សាជកសាច់ម៉ដ្ឋ ត្រូវប្រើម្ជុលដែលតូច សូម្បីអំបោះដោតម្ជុលក៏ត្រូវតែតូចជាងនោះយ៉ាងណា ក្នុងវេលាចម្រើនកម្មដ្ឋាននេះដូចគ្នានឹងសំពត់សាជកសាច់ម៉ដ្ឋ យ៉ាងនោះដូចគ្នា សតិដែលប្រៀបដូចម្ជុល បញ្ញាដែលសម្បយុត្តដោយសតិនោះ ដែលប្រៀបដោយការដេរក៏ត្រូវមានកម្លាំង ។ ភិក្ខុដែលប្រកបដោយសតិបញ្ញាទាំងនោះ មិនគប្បីស្វែងរកខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញទាំងនោះ ក្រៅពីឱកាសដែលខ្យល់ពាល់ត្រូវតាមប្រក្រតី ។

ដូចជាអ្នកស្រែភ្ជួរស្រែ ហើយលែងគោឲ្យបែរមុខទៅកាន់ទីរកស៊ី អង្គុយសម្រាកត្រង់ម្លប់ ។ លំដាប់នោះ គោទាំងនោះ របស់បុរសនោះចូលព្រៃយ៉ាងរហ័ស ។ អ្នកស្រែដែលជាមនុស្សឈ្លាស បំណងនឹងចាប់គោទាំងនោះមកទឹមភ្ជួរ មិនដើរទៅតាមស្នាមជើងរបស់គោទាំងនោះ ដែលចូលទៅកាន់ព្រៃដែលពិតគាត់កាន់ខ្សែ និងជន្លួញ ទៅកាន់កំពង់ទឹកដែលគោទាំងនោះចុះ អង្គុយ

ខ្លះ ដេកខ្លះ កាលឃើញគោទាំងនោះដែលត្រាច់ទៅអស់ថ្ងៃហើយ ចុះកាន់កំពង់ដែលធ្លាប់ចុះ ងូត និងផឹកហើយ ឡើងមកឈរ ទើបយកខ្សែចង យកជន្លួញចាក់នាំមកទីមក្លួរធ្វើការងារតទៅ យ៉ាងណា ភិក្ខុនោះក៏យ៉ាងនោះដូចគ្នា មិនគប្បីស្វែងរកខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញទាំងនោះ ក្រៅអំពីឱកាសដែលខ្យល់ពាល់ត្រូវតាមប្រក្រតី គប្បីកាន់យកខ្សែ គឺសតិ និងជន្លួញ គឺបញ្ញា តាំងចិត្តទុកក្នុងឱកាសដែលខ្យល់ពាល់ត្រូវតាមប្រប្រកតី ហើយញ៉ាំងមនសិការឲ្យប្រព្រឹត្តទៅ ។ កាលភិក្ខុមនសិការយ៉ាងនេះមិនយូរឡើយ ខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញទាំងនោះ ក៏ប្រាកដដូចគោប្រាកដត្រង់កំពង់ដែលធ្លាប់ចុះ បន្ទាប់អំពីនោះ ភិក្ខុនោះគប្បីចងដោយខ្សែ គឺសតិ ប្រកបក្នុងទីនោះហើយ ចាក់ដោយជន្លួញ គឺបញ្ញា ប្រកបកម្មដ្ឋានរឿយៗ ។

កាលប្រកបយ៉ាងនេះមិនយូរឡើយ និមិត្តរមែងប្រាកដ និមិត្តនោះមិនដូចគ្នាដល់ព្រះយោគាវចរទាំងពួង ។ អាចារ្យពួកខ្លះពោលថា សម្រាប់ព្រះយោគាវចររូបខ្លះ និមិត្តប្រាកដដូចប៉ុយគរ ប៉ុយកប្បាស និងខ្សែខ្យល់ ដែលញ៉ាំងសុខសម្ផស្សឲ្យកើត ។

ចំណែកក្នុងអដ្ឋកថាទាំងឡាយមានវិនិច្ឆ័យ ដូចតទៅនេះថា ពិតហើយ និមិត្តនេះសម្រាប់ព្រះយោគាវចររូបខ្លះប្រាកដដូចរូបផ្កាយ ដូចដុំកែវមណី និងដូចដុំកែវមុក្តា សម្រាប់ព្រះយោគាវចររូបខ្លះ ប្រាកដដូចគ្រាប់កប្បាស និងដូចជង់ដែកចារដែលធ្វើអំពីឈើខ្លឹម មានសម្ផស្សគ្រោតគ្រាត សម្រាប់ព្រះយោគាវចររូបខ្លះ ប្រាកដដូចសន្ធារដ៏វែង ដូចកម្រងផ្កា និងដូចផ្សែង សម្រាប់ព្រះ

យោគាវចររូបខ្លះ ប្រាកដដូចសរសៃពីងពាងដ៏ធំ ដូចដុំពពក ដូចផ្កាឈូក ដូចកង់រថ ដូចមណ្ឌលព្រះចន្ទ និងដូចមណ្ឌលព្រះអាទិត្យ កាលភិក្ខុច្រើនរូបអង្គុយស្វាធ្យាយព្រះសូត្រ កាលភិក្ខុមួយរូបពោលថា ព្រះសូត្រនេះ ប្រាកដដល់លោកទាំងឡាយដូចម្តេច ភិក្ខុមួយរូបពោលថា ប្រាកដដល់ខ្ញុំ ដូចស្ទឹងធំហូរអំពីកំពូលភ្នំ មួយរូបទៀតពោលថា ប្រាកដដល់ខ្ញុំ ដូចជួរព្រៃមួយកន្ទែង ។ ភិក្ខុរូបដទៃពោលថា ប្រាកដដល់ខ្ញុំ ដូចដើមឈើមានម្លប់ត្រជាក់សម្បូរដោយមែក ពោរពេញដោយផ្លែ ។ សូត្រតែមួយប៉ុណ្ណោះ ប្រាកដដល់ភិក្ខុទាំងនោះដោយសេចក្តីផ្សេងគ្នា ព្រោះសញ្ញាផ្សេងគ្នា យ៉ាងណា កម្មដ្ឋានមួយប៉ុណ្ណោះរមែងប្រាកដដោយសេចក្តីផ្សេងគ្នា ព្រោះសញ្ញាផ្សេងគ្នា ។ ពិតហើយ កម្មដ្ឋាននោះកើតអំពីសញ្ញា មានសញ្ញាជាហេតុ មានសញ្ញាជាដែនកើត ព្រោះហេតុនោះ គប្បីជ្រាបថា និមិត្តនោះ រមែងប្រាកដដោយសេចក្តីផ្សេងគ្នា ព្រោះសញ្ញាផ្សេងគ្នា ។

ម្យ៉ាងទៀត កាលនិមិត្តប្រាកដហើយយ៉ាងនេះ ភិក្ខុនោះ គប្បីទៅរកអាចារ្យហើយប្រាប់ឲ្យជ្រាបថា លោកអាចារ្យ និមិត្តបែបនេះប្រាកដដល់ខ្ញុំ ។ ចំណែកអាចារ្យគួរពោលថា នែអាវុសោ នេះជានិមិត្ត នែសប្បុរស ចូរលោកធ្វើកម្មដ្ឋានក្នុងចិត្តឲ្យរឿយៗ ចុះ បន្ទាប់អំពីនោះ គប្បីតាំងចិត្តទុកក្នុងនិមិត្តប៉ុណ្ណោះ ។

ចាប់តាំងអំពីនេះទៅ ភាវនារមែងមានដោយការចុះស៊ប់ ដល់ភិក្ខុនោះដោយអាការយ៉ាងនេះ សមដូចបោរាណាចារ្យទាំងឡាយពោលថា

អ្នកមានបញ្ញា ញ៉ាំងចិត្តឲ្យចុះស៊ប់ក្នុងនិមិត្ត ចម្រើនអាការផ្សេងៗ រមែងចងចិត្តរបស់ខ្លួនក្នុងខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញ ដូច្នេះ ។

ចាប់តាំងអំពីការប្រាកដនៃនិមិត្តយ៉ាងនេះ ភិក្ខុនោះ ក៏ឈ្មោះថាគ្របសង្កត់នីវរណៈទាំងឡាយបានហើយ កិលេសទាំងឡាយស្ងប់ ចិត្តតាំងមាំ ដោយឧបចារសមាធិ ភិក្ខុនោះមិនគួរដាក់ចិត្តដល់និមិត្តនោះ ដោយភាពជាវសី មិនគួរពិចារណាដោយភាពជាលក្ខណៈដែលពិត ភិក្ខុគួរវៀរអសប្បាយ ៧ មានអាវាសជាដើម ហើយសេពសប្បាយទាំង ៧ នោះ គួររក្សាទុកឲ្យល្អដូចខត្តិយមហេសីរក្សាគភ៌របស់ព្រះបាទចក្រពត្តិ និងដូចអ្នកស្រែរក្សាស្រូវសាលីផើម និងស្រូវជំណើបដូច្នោះ កាលរក្សានិមិត្តនោះយ៉ាងនេះហើយ ធ្វើនិមិត្តឲ្យដល់នូវការចម្រើនលូតលាស់ ដោយអំណាចមនសិការរឿយៗ ហើយធ្វើភាពជាអ្នកឈ្លាសក្នុងអប្បនាកោសល្ល ១០ ឲ្យដល់ព្រម គប្បីប្រកបព្យាយាមដោយស្មើ ។

កាលភិក្ខុព្យាយាមយ៉ាងនេះ ចតុក្កជ្ឈាន និងបញ្ចកជ្ឈានរមែងកើតក្នុងនិមិត្តនោះតាមលំដាប់ ដូចដែលលោកពោលហើយក្នុងវិសុទ្ធិមគ្គ ។ ម្យ៉ាងទៀត ភិក្ខុអ្នកមានចតុក្កជ្ឈាន និងបញ្ចកជ្ឈាន ដែលកើតហើយក្នុងនិមិត្តនោះយ៉ាងនេះ បំណងនឹងចម្រើនកម្មដ្ឋានដោយអំណាចនៃវិបស្សនា និងមគ្គ ហើយសម្រេចផល រមែងធ្វើឈាននោះឲ្យស្ទាត់ដល់នូវភាពជាវសីដោយអាការ ៥ កំណត់នាមរូប ចម្រើនវិបស្សនា ។

កំណត់ដូចម្ដេច ភិក្ខុនោះចេញចាកសមាបត្តិហើយ រមែងឃើញថា ករជ-កាយ និងចិត្តជាហេតុកើតខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញ ។ ដូចស្នប់របស់ជាងមាសកំពុងសប់ ខ្យល់រមែងសញ្ចរ ព្រោះអាស្រ័យស្នប់ និងសេចក្ដីព្យា-យាមដ៏សមគួររបស់បុរស ( អ្នកសប់ ) យ៉ាងណា ខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញ រមែងសញ្ចរព្រោះអាស្រ័យកាយ និងចិត្តយ៉ាងនោះដូចគ្នា បន្ទាប់អំពីនោះ ភិក្ខុនោះ រមែងកំណត់ខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញ និងកាយថាជារូប កំណត់ចិត្ត និងធម៌ដែលសម្បយុត្តដោយចិត្តនោះ ថាជាអរូប ។

លុះភិក្ខុកំណត់នាមរូបយ៉ាងនេះហើយ ស្វែងរកបច្ច័យនៃនាមរូបនោះ កាលស្វែងរកឃើញបច្ច័យនោះហើយ ប្រារព្ធដល់ការប្រព្រឹត្តទៅនៃនាមរូបក្នុងកាលទាំង ៣ ហើយ ទើបឆ្លងសេចក្ដីសង្ស័យបាន ឆ្លងសេចក្ដីសង្ស័យបានហើយ ទើបលើកឡើងកាន់ត្រៃលក្ខណ៍ថា អនិច្ចំ ទុក្ខំ អនត្តា ដោយអំណាចនៃការពិចារណាជាកលាបៈ លះវិបស្សនូបក្កិលេស ១០ មានឱភាសជាដើម ដែលកើតឡើងក្នុងចំណែកខាងដើមនៃឧទយព្វយានុបស្សនា ហើយកំណត់ឧទយ-ព្វយានុបស្សនាញាណដែលផុតចាកឧបក្កិលេស ថាជាមគ្គ លះការកើតឡើងហើយដល់នូវភង្គានុបស្សនា ( ពិចារណាឃើញការរលត់ ) បន្ទាប់អំពីនោះក៏នឿយណាយ ប្រាសចាកតម្រេកក្នុងសង្ខារទាំងពួង ដែលប្រាកដដោយភាពជាភ័យដោយភង្គានុបស្សនា រួចផុត សម្រេចអរិយមគ្គ ៤ តាមលំដាប់តាំងនៅក្នុងអរហត្តផលហើយ ដល់នូវទីបំផុតនៃបច្ចវេក្ខណញ្ញាណ ១៩ ជាទក្ខិ-ណេយ្យបុគ្គលដ៏ប្រសើររបស់លោក ព្រមទាំងទេវលោក ។ ដោយហេតុមាន

ប្រមាណប៉ុណ្ណោះ ការចម្រើនអានាបានស្សតិសមាធិរបស់ព្រះយោគាវចរដែលបំពេញអានាបានកម្មដ្ឋាននោះ តាំងអំពីការរាប់ មានការពិចារណាជាទីបំផុត ជាការគ្រប់គ្រាន់បរិបូរណ៍ នេះជាការពណ៌នាបឋមចតុក្កៈដោយអាការទាំងពួង ដូច្នេះឯង ។

ម្យ៉ាងទៀត ក្នុងចតុក្កៈ ៣ ក្រៅនេះ ព្រោះមិនមានន័យរបស់កម្មដ្ឋានភាវនាដោយឡែក ហេតុនោះ គប្បីជ្រាបអត្ថនៃចតុក្កៈទាំងនោះ ដោយន័យរបស់ការពណ៌នាតាមបទដែលសមគួរនោះឯង ។

បទថា **បីតិបដិសំវេទី** បានដល់ រមែងសិក្សាថា អញនឹងធ្វើបីតិឲ្យជាក់ច្បាស់ ធ្វើឲ្យប្រាកដ ទើបដកដង្ហើមចូល ដកដង្ហើមចេញ ។ ក្នុងបទនោះ ជាការដឹងច្បាស់នូវបីតិដោយអាការ ២ គឺដោយអារម្មណ៍ និងដោយការមិនវង្វេង ។

ដឹងច្បាស់បីតិដោយអារម្មណ៍ តើដូចម្តេច ។ ភិក្ខុរមែងចូលឈាន ២ យ៉ាងដែលមានបីតិ ភិក្ខុនោះ ឈ្មោះថា ដឹងច្បាស់បីតិដោយអារម្មណ៍ដោយការបានឈានក្នុងខណៈនៃសមាបត្តិ ព្រោះដឹងច្បាស់អារម្មណ៍ហើយ ។

ដឹងច្បាស់នូវបីតិដោយការមិនវង្វេង តើដូចម្តេច ។ ភិក្ខុចូលឈាន ២ យ៉ាង ដែលមានបីតិ កាលចេញហើយ រមែងពិចារណាបីតិដែលសម្បយុត្តដោយឈានដោយការអស់ទៅ ដោយការវិនាសទៅ ភិក្ខុនោះ ឈ្មោះថា ដឹងច្បាស់នូវបីតិដោយការមិនវង្វេង ដោយការចាក់ធ្លុះលក្ខណៈក្នុងខណៈនៃវិបស្សនា ។ ដោយន័យនេះឯង គប្បីជ្រាបសូម្បីបទដ៏សេសដោយអត្ថ តែក្នុងបទដ៏សេសនេះ មានសេចក្តីត្រឹមតែផ្សេងគ្នាដូច្នេះ ការដឹងច្បាស់នូវសុខមាន

ដោយអំណាចឈាន ៣ ការដឹងច្បាស់នូវចិត្តសង្ខារ គប្បីជ្រាបដោយអំណាចឈានទាំង ៤ ។

បទថា **ចិត្តសង្ខារំ** បានដល់ វេទនាខន្ធ និងសញ្ញាខន្ធ ។ បទថា **បស្សម្ភយំ ចិត្តសង្ខារំ** សេចក្តីថា រម្ងាប់ គឺរម្ងត់ចិត្តសង្ខារគ្រោតគ្រាត ។ គប្បីជ្រាបចិត្តសង្ខារនោះដោយពិស្តារតាមន័យដូចពោលហើយក្នុងកាយសង្ខារ ។

ម្យ៉ាងទៀត ក្នុងទីនេះ គប្បីជ្រាបថា លោកពោលចតុក្កៈនេះដោយន័យរបស់វេទនានុបស្សនាយ៉ាងនេះថា ក្នុងបទថា **បីតិ** លោកពោលវេទនាដោយមាតិកានៃបីតិ ក្នុងបទថា **សុខ** លោកពោលវេទនាដោយសរូបនោះឯង ។ ក្នុងបទថា **ចិត្ត សង្ខារ** ទាំងពីរ លោកពោលវេទនាដែលសម្បយុត្តដោយសញ្ញា ដោយបាលីថា **សញ្ញា ច វេទនា ច ចេតសិកា ឯតេ ធម្មា ចិត្តបដិពទ្ធា ចិត្តសង្ខារា** សញ្ញា និងវេទនា ជាតួចេតសិក ធម៌ទាំងនុ៎ះ ជាប់ចំពោះដោយចិត្ត ឈ្មោះថា ចិត្តសង្ខារ ដូច្នេះ ។

ក្នុងចតុក្កៈទី ៣ ក៏គប្បីជ្រាបការដឹងច្បាស់នូវចិត្ត ដោយអំណាចនៃឈាន ៤ ។

បទថា **អភិប្បមោទយំ ចិត្តំ** បានដល់ ភិក្ខុរមែងសិក្សាថា អញនឹងធ្វើចិត្តឲ្យរីករាយ ឲ្យរីករាយព្រម ឲ្យត្រេកអរ ឲ្យត្រេកអរព្រម ដកដង្ហើមចូល ដកដង្ហើមចេញ ។ ក្នុងពាក្យនោះ ការរីករាយមានដោយអាការ ២ យ៉ាង គឺដោយអំណាចសមាធិ និងដោយអំណាចវិបស្សនា ។

ដោយអំណាចសមាធិ តើដូចម្តេច ភិក្ខុចូលឈាន ២ ដែលមានបីតិ

ភិក្ខុធ្វើចិត្តឲ្យរីករាយ ឲ្យរីករាយព្រម ដោយបីតិដែលសម្បយុត្តក្នុងខណៈនៃសមាបត្តិ ។

ដោយអំណាចវិបស្សនា តើដូចម្តេច ភិក្ខុចូលឈាន ២ ដែលមានបីតិ កាលចេញហើយ រមែងពិចារណាបីតិដែលសម្បយុត្តដោយឈានដោយការអស់ទៅ ដោយការសូន្យទៅ ។ ភិក្ខុធ្វើបីតិដែលសម្បយុត្តដោយឈាន ក្នុងខណៈនៃវិបស្សនាឲ្យជាអារម្មណ៍យ៉ាងនេះ រមែងធ្វើចិត្តឲ្យរីករាយ ឲ្យរីករាយព្រម ។ ភិក្ខុដែលបដិបត្តិយ៉ាងនេះ ហៅថា សិក្សាថាអាត្មាអញ កាលញុំាងចិត្តឲ្យរីករាយខ្លាំង ដកដង្ហើមចូល ដកដង្ហើមចេញ ដូច្នេះ ។

បទថា **សមាទហំ ចិត្តំ** បានដល់ តម្កល់ស្មើ គឺតម្កល់ស្មើនូវចិត្តក្នុងអារម្មណ៍ ដោយអំណាចនៃបឋមជ្ឈានជាដើម ។ ឬកាលភិក្ខុចូលឈានទាំងនោះហើយ កាលចេញហើយ ពិចារណាចិត្តដែលសម្បយុត្តដោយឈានដោយការអស់ទៅ ដោយការសូន្យទៅ ភាពដែលឯកគ្គតាចិត្ត មួយជួរខណៈរមែងកើតឡើងដោយការចាក់ធ្លុះលក្ខណៈ ក្នុងខណៈនៃវិបស្សនា ភិក្ខុកាលតម្កល់ស្មើ គឺតម្កល់ស្មើនូវចិត្តក្នុងអារម្មណ៍ ដោយអំណាចភាពដែលចិត្តជាឯកគ្គតាមួយជួរខណៈ ដែលកើតឡើងហើយយ៉ាងនេះ ហៅថា សិក្សាថាអាត្មាអញនឹងតម្កល់ចិត្ត ដកដង្ហើមចូល ដកដង្ហើមចេញ ដូច្នេះ ។

បទថា **វិមោចយំ ចិត្តំ** បានដល់ ដោះ គឺដោះចិត្តចាកនីវរណៈទាំងឡាយដោយបឋមជ្ឈាន ដោះ គឺដោះចិត្តចាកវិតក្ក វិចារ ដោយទុតិយជ្ឈាន ចាកបីតិដោយតតិយជ្ឈាន ចាកសុខ និងទុក្ខដោយចតុត្ថជ្ឈាន ឬចូលឈានទាំង

ឡាយនោះ កាលចេញហើយ រមែងពិចារណាចិត្តដែលសម្បយុត្តដោយឈាន ដោយការអស់ទៅ ដោយការសូន្យទៅ ភិក្ខុនោះក្នុងខណៈនៃវិបស្សនា ដោះ គឺដោះចិត្តចាកនិច្ចសញ្ញាដោយអនិច្ចានុបស្សនា ដោះ គឺដោះចិត្តចាកសុខសញ្ញា ដោយទុក្ខានុបស្សនា ចាកអត្តសញ្ញាដោយអនត្តានុបស្សនា ចាកនន្ទិ ( សេចក្តីត្រេកត្រអាល ) ដោយនិព្វិទានុបស្សនា ចាករាគៈ ដោយវិរាគានុបស្សនា ចាកសមុទយៈដោយនិរោធានុបស្សនា ចាកការអាទានៈ ( សេចក្តីប្រកាន់ ) ដោយបដិនិស្សគ្គានុបស្សនា រមែងដកដង្ហើមចូល ដកដង្ហើមចេញ ។

ដោយហេតុនោះ ទើបលោកថា **វិមោចយំ ចិត្តំ អស្សាសាមិ បស្សាសាមីតិ សិក្ខតិ** សិក្សាថា អាត្មាអញនឹងដោះចិត្តដកដង្ហើមចូល ដកដង្ហើមចេញ ដូច្នេះ ។ គប្បីជ្រាបថា ចតុក្កៈនេះ លោកពោលដោយអំណាចនៃចិត្តានុបស្សនា ដោយប្រការដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងចតុក្កៈទី ៤ ដូចតទៅ ក្នុងបទថា **អនិច្ចានុបស្សី** ជាដើម គប្បីជ្រាបអនិច្ចំ គប្បីជ្រាបអនិច្ចតា គប្បីជ្រាបអនិច្ចានុបស្សនា គប្បីជ្រាបអនិច្ចានុបស្សី ។

ក្នុងពាក្យទាំងនោះ ពាក្យថា **អនិច្ចំ** បានដល់ ខន្ធ ៥ ។ ព្រោះហេតុអ្វី ព្រោះបញ្ចក្ខន្ធ មានការកើត រលត់ និងជាយ៉ាងដទៃ ។

ពាក្យថា **អនិច្ចតា** បានដល់ ភាពដែលបញ្ចក្ខន្ធទាំងនោះឯងមានការកើតឡើង ការសូន្យទៅ និងភាពជាយ៉ាងដទៃ ឬមានហើយ ត្រឡប់ជាមិនមាន អធិប្បាយថា ភាពដែលខន្ធទាំងឡាយកើតឡើង ហើយមិនតាំងនៅ ដោយ

អាការយ៉ាងនោះ ហើយបែកធ្លាយទៅ ដោយបែកធ្លាយទៅគ្រប់ខណៈ ។

ពាក្យថា **អនិច្ចានុបស្សនា** បានដល់ ការពិចារណាឃើញថា មិនទៀងក្នុងរូបជាដើម ដោយអំណាចនៃការមិនទៀងនោះ ។

ពាក្យថា **អនិច្ចានុបស្សី** បានដល់ ជាអ្នកប្រកបដោយអនុបស្សនានោះ ព្រោះហេតុនោះ ភិក្ខុដែលមានសភាពយ៉ាងនោះ ដកដង្ហើមចូល ដកដង្ហើមចេញ គប្បីជ្រាបក្នុងទីនេះថា សិក្សាថា អាត្មាអញនឹងជាអ្នកពិចារណានូវអនិច្ចលក្ខណៈ ដកដង្ហើមចូល ដកដង្ហើមចេញ ដូច្នេះ ។

ក្នុងបទថា **វិរាគានុបស្សី** នេះ វិរាគៈមាន ២ យ៉ាង គឺខយវិរាគៈ ១ អច្ចន្តវិរាគៈ ១ ។ ក្នុងវិរាគៈ ២ នោះ ពាក្យថា ខយវិរាគៈ បានដល់ ការបែកធ្លាយគ្រប់ខណៈនៃសង្ខារទាំងឡាយ ។ ពាក្យថា អច្ចន្តវិរាគៈ បានដល់ និព្វាន ។

បទថា **វិរាគានុបស្សី** បានដល់ វិបស្សនា និងមគ្គ ប្រព្រឹត្តទៅហើយ ដោយអំណាចនៃការឃើញទាំងពីរយ៉ាងនោះ ។ ភិក្ខុប្រកបដោយអនុបស្សនាទាំងពីរនោះ ដកដង្ហើមចូល ដកដង្ហើមចេញ គប្បីជ្រាបថា សិក្សាថា អាត្មាអញនឹងជាអ្នកពិចារណានូវការប្រាសចាករាគៈ ដកដង្ហើមចូល ដកដង្ហើមចេញ ដូច្នេះ ។ សូម្បីក្នុងបទថា **និរោធានុបស្សី** ក៏មានន័យនេះដូចគ្នា ។

បទថា **បដិនិស្សគ្គានុបស្សី** នេះ បដិនិស្សគ្គមាន ២ យ៉ាង គឺបរិច្ចាគ-បដិនិស្សគ្គៈ ១ បក្ខន្ទនបដិនិស្សគ្គៈ ១ ។ ការពិចារណា គឺការលះបង់ ឈ្មោះថា **បដិនិស្សគ្គានុបស្សនា** ។ បទនេះជាឈ្មោះនៃវិបស្សនា និងមគ្គ ។

ពិតហើយ វិបស្សនា រមែងលះបង់កិលេសទាំងឡាយ មួយអន្លើដោយខន្ធា-
ភិសង្ខារ ដោយអំណាចនៃតទង្គប្បហាន និងព្រោះឃើញទោសក្នុងសង្ខតធម៌
ទើបស្ទុះទៅក្នុងនិព្វាន ដែលផ្ទុយគ្នានឹងសង្ខតធម៌នោះ ដោយបង្អោនទៅក្នុង
និព្វាននោះ ព្រោះហេតុនោះ ទើបហៅថា បរិច្ចាគបដិនិស្សគ្គៈ ( លះបង់
ដោយការបរិច្ចាគ ) និងបក្ខន្ទនបដិនិស្សគ្គៈ ( លះបង់ដោយការស្ទុះទៅ ) ។
មគ្គរមែងលះកិលេសទាំងឡាយ មួយអន្លើដោយខន្ធាភិសង្ខារ ដោយអំណាច
ការផ្ដាច់ផ្ដិល និងស្ទុះទៅក្នុងនិព្វាន ដោយការធ្វើឲ្យជាអារម្មណ៍ ព្រោះហេតុ
នោះ ទើបហៅថា បរិច្ចាគបដិនិស្សគ្គៈ និងបក្ខន្ទនបដិនិស្សគ្គៈ ។

សូម្បីទាំងពីរបទនោះ ក៏ហៅថា អនុបស្សនា ព្រោះតាមឃើញដោយ
ញាណមុនៗ គប្បីជ្រាបថា ភិក្ខុប្រកបដោយបដិនិស្សគ្គានុបស្សនាទាំងពីរ
យ៉ាងនោះ ដកដង្ហើមចូល ដកដង្ហើមចេញ គប្បីជ្រាបថា សិក្សាថា អាត្មា
អញ នឹងជាអ្នកពិចារណានូវធម៌ជាគ្រឿងរលាស់ចិត្ត ចេញចាកកិលេស
ដកដង្ហើមចូល ដកដង្ហើមចេញ ដូច្នេះ ។

ក្នុងបទទាំងនេះគប្បីជ្រាបថា **អនិច្ចានុបស្សី** លោកពោលដោយអំណាច
នៃវិបស្សនាយ៉ាងទន់ ។ បទថា **វិរាគានុបស្សី** លោកពោលដោយអំណាច
នៃវិបស្សនាដែលមានកម្លាំងច្រើនជាងនោះ ដែលអាចប្រាសចាកតម្រេក ក្នុង
សង្ខារទាំងឡាយបាន ។ បទថា **និរោធានុបស្សី** លោកពោលដោយអំណាច
វិបស្សនាដែលមានកម្លាំងច្រើនជាងនោះ ដែលអាចរម្ងត់កិលេស ។ បទថា
**បដិនិស្សគ្គានុបស្សី** លោកពោលដោយអំណាចនៃវិបស្សនាដែលមានកម្លាំង

ជិតចូលដល់មគ្គ ។ បដិនិស្សគ្គៈដែលជាទីបានមគ្គ មិនមានវិនាសឡើយ ។ លោកពោលចតុក្កៈនេះ ដោយអំណាចនៃវិបស្សនាសុទ្ធៗ ចំណែកចតុក្កៈ ៣ ខាងដើម លោកពោលដោយអំណាចនៃសមថៈ និងវិបស្សនា ដោយប្រការដូច្នេះ ៕

## អដ្ឋកថា អានាបានស្សតិមាតិកា ចប់

# អដ្ឋកថា

## ទីឃអស្សាសបស្សាសនិទ្ទេស

[ ៩៦ ] ឥឡូវនេះ ដើម្បីសម្តែងចែកមាតិកាតាមដែលតាំងទុកដោយលំដាប់ ទើបផ្តើមបទថា **ឥធាតិ ឥមិស្សា ទិដ្ឋិយា** ជាដើម ។

ក្នុងបទទាំងនោះ លោកពោលដល់ពាក្យប្រៀនប្រដៅ របស់ព្រះសព្វញ្ញុពុទ្ធ ប៉ុណ្ណោះដែលបានដល់ត្រៃសិក្ខាដោយបទ ១០ មានបទថា **ឥមិស្សា ទិដ្ឋិយា** ជាដើម ។

ពាក្យប្រៀនប្រដៅនោះ ហៅថា **ទិដ្ឋិ** ព្រោះព្រះពុទ្ធមានព្រះភាគទ្រង់ឃើញ ហើយហៅថា **ខន្តិ** ដោយអំណាចការអត់ធន់ របស់ព្រះមានព្រះភាគនោះឯង ហៅថា **រុចិ** ដោយអំណាចការគាប់ចិត្តរបស់ព្រះមានព្រះភាគនោះឯង ហៅថា **អាទាយ** ដោយអំណាចការកាន់យករបស់ព្រះមានព្រះភាគនោះឯង ហៅថា **ធម្ម** ដោយអត្ថថា ជាសភាវធម៌ ហៅថា **វិនយ** ដោយអត្ថថា គួរសិក្សា ហៅថា **ធម្មវិនយ** ដោយអត្ថទាំងពីរនោះ ហៅថា **ធាវចន** ដោយអំណាចធម៌ដែលត្រាស់ទូទៅហើយ ហៅថា **ព្រហ្មចរិយ** ដោយអត្ថថា ជាការប្រព្រឹត្ត ដ៏ប្រសើរ ហៅថា **សត្ថុសាសន** ដោយអំណាចឲ្យនូវពាក្យប្រៀនប្រដៅ ។

ព្រោះហេតុនោះ ក្នុងបទថា **ឥមិស្សា ទិដ្ឋិយា** ជាដើម គប្បីជ្រាបសេចក្តីថា ក្នុងការឃើញរបស់ព្រះពុទ្ធនេះ ក្នុងការអត់ធន់របស់ព្រះពុទ្ធនេះ ក្នុងសេចក្តីគាប់ចិត្តរបស់ព្រះពុទ្ធនេះ ក្នុងការកាន់យករបស់ព្រះពុទ្ធនេះ ក្នុងធម៌របស់ព្រះពុទ្ធនេះ ក្នុងវិន័យរបស់ព្រះពុទ្ធនេះ ក្នុងធម៌វិន័យរបស់ព្រះពុទ្ធនេះ

ក្នុងបាវចនៈ ( ពាក្យជាប្រធាន ) របស់ព្រះពុទ្ធនេះ ក្នុងព្រហ្មចរិយៈរបស់ព្រះពុទ្ធនេះ ក្នុងសត្ថុសាសនៈរបស់ព្រះពុទ្ធនេះ ។

ម្យ៉ាងវិញទៀត ក្នុងបទទាំងនេះ បាវចនៈទាំងអស់ បានដល់ ត្រៃសិក្ខា ឈ្មោះថា **ទិដ្ឋិ** ព្រោះព្រះមានព្រះភាគ ទ្រង់ឃើញហើយ ព្រោះជាបច្ច័យនៃសម្មាទិដ្ឋិ និងព្រោះមានសម្មាទិដ្ឋិជាសភាវៈដល់មុន ។ ឈ្មោះថា **ខន្តិ** ដោយអំណាចការអត់ធន់ របស់ព្រះមានព្រះភាគ ។ ឈ្មោះថា **រុចិ** ដោយអំណាចការគាប់ចិត្ត ។ ឈ្មោះថា **អាទាយ** ដោយអំណាចការកាន់យក ឈ្មោះថា **ធម្ម** ព្រោះអត្ថថា ទ្រទ្រង់ទុកនូវអ្នកបដិបត្តិតាមធម៌មិនឲ្យធ្លាក់ទៅក្នុងអបាយ ឈ្មោះថា **វិនយ** ព្រោះអត្ថថា កម្ចាត់ធម៌ចំណែកសៅហ្មងនៃបុគ្គលនោះឯង ។ ធម្មនោះផង វិន័យនោះផង ឈ្មោះថា **ធម្មវិនយ** ឬឈ្មោះថា ធម្មវិន័យ ព្រោះអត្ថថា ធម៌ជាគ្រឿងកម្ចាត់អកុសលធម៌ទាំងឡាយ ដោយកុសលធម៌ទាំងឡាយ ។

ដោយហេតុនោះឯង ទើបព្រះមានព្រះភាគត្រាស់ ( ក្នុងវិនយបិដក ចូឡវគ្គ ) ថា ម្នាលព្រះនាងគោតមី មួយវិញទៀត ព្រះនាងគប្បីដឹងនូវធម៌ណា ជាធម៌ទាំងនេះ ប្រព្រឹត្តទៅដើម្បីការប្រាសចាកតម្រេក មិនប្រព្រឹត្តទៅដើម្បីការប្រកបដោយតម្រេក ។បេ។ ម្នាលព្រះនាងគោតមី ព្រះនាងគប្បីចាំទុកដោយចំណែកមួយថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រដៅរបស់ព្រះសាស្តាហើយ ដូច្នេះ ។ ម្យ៉ាងទៀត ឈ្មោះថា ធម្មវិន័យ ព្រោះអត្ថថា ជាអាជ្ញាដោយធម៌ មិនមែនអាជ្ញាដោយអាជ្ញាជាដើមទេ សមដូចព្រះមានព្រះភាគ

ត្រាស់ ( ក្នុងវិនយបិដក ចូឡវគ្គ ) ថា

ជនពួកមួយតែងទូន្មាន ( ដំរី ) ដោយដំបងខ្លះ ដោយកង្វេរខ្លះ ដោយរំពាត់ខ្លះ ( ចំណែក ) ព្រះពុទ្ធដែលព្រះអង្គស្វែងរកនូវគុណធំ ឥតមានដំបង ឥតមានគ្រឿងសស្ត្រាអ្វីទេ តែអាចទូន្មានហត្ថិនាគបាន ដូច្នេះ ។

ម្យ៉ាងទៀត ព្រះមានព្រះភាគត្រាស់( ក្នុងវិនយបិដក មហាវគ្គ ) ថា ហេតុដូចម្ដេចក៏មានសេចក្ដីប្រណៃនទីងពួកអ្នកប្រាជ្ញ ដែលជាអ្នកណែនាំសត្វដោយធម៌ ( នោះឯង ) ដូច្នេះ ។ ម្យ៉ាងទៀត ការណែនាំដោយធម៌ ឈ្មោះថា ធម្មវិន័យ ។ វិន័យនោះ ដើម្បីធម៌មិនមានទោស មិនមែនដើម្បីអានិសង្សនៃភោគសម្បត្តិក្នុងភព ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ ( ក្នុងខុទ្ទកនិកាយ ឥតិវុត្តកៈ ) ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រព្រឹត្តព្រហ្មចរិយៈនេះ មិនមែនដើម្បីកុហកនូវជន ដូច្នេះ ។ គប្បីធ្វើសេចក្ដីនេះឲ្យពិស្ដារ ។ សូម្បីព្រះបុណ្ណត្ថេរក៏ពោល ( ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសក ) ថា ម្នាលអាវុសោ ព្រហ្មចរិយធម៌ដែលខ្ញុំប្រព្រឹត្តក្នុងសម្នាក់ព្រះមានព្រះភាគ ដើម្បីអនុបាទាបរិនិព្វានទេតើ ដូច្នេះ ។ ម្យ៉ាងវិញទៀត ឈ្មោះថា វិន័យ ព្រោះអត្ថថា នាំទៅឲ្យបរិសុទ្ធ ការនាំទៅដោយធម៌ ឈ្មោះថា ធម្មវិន័យ ។ វិន័យនោះរមែងនាំទៅចាកធម៌ គឺសង្សារ ឬចាកធម៌មានសេចក្ដីសោកជាដើម ទៅកាន់និព្វានដ៏បរិសុទ្ធ ឬការនាំទៅកាន់ធម៌មិនមែននាំទៅកាន់ពួកម្ចាស់លទ្ធិ ព្រោះហេតុនោះ ទើបឈ្មោះថា ធម្មវិន័យ ។ ពិតហើយ ព្រះមានព្រះភាគ កើត

ក្នុងធម៌ វិន័យនោះក៏ជារបស់ព្រះមានព្រះភាគអង្គនោះឯង ។ ម្យ៉ាងវិញទៀត ព្រោះធម៌ទាំងឡាយនោះឯង គួរដឹងក្រៃលែង គួរកំណត់ដឹង គួរលះ គួរបម្រើន និងគួរធ្វើឲ្យជាក់ច្បាស់ ហេតុនោះ វិន័យនោះ ជាការនាំទៅក្នុងធម៌ទាំងឡាយ មិនមែននាំទៅក្នុងសត្វ និងក្នុងជីវៈទាំងឡាយ ព្រោះហេតុនោះ ទើបឈ្មោះថា ធម្មវិន័យ ។

ពាក្យជាប្រធានជាងពាក្យរបស់អ្នកដទៃ ដោយពាក្យទាំងឡាយ ប្រកប ដោយអត្ថ និងប្រកបដោយព្យញ្ជនៈជាដើម ព្រោះហេតុនោះ ទើបឈ្មោះថា ពាក្យជាប្រធាន ពាក្យជាប្រធាននោះឯង ឈ្មោះថា បាវចនៈ ។ ឈ្មោះថា ព្រហ្មចរិយៈ ព្រោះជាការប្រព្រឹត្តដ៏ប្រសើរដោយចរិយាទាំងពួង ។ ឈ្មោះថា សត្ថុសាសនៈ ព្រោះជាពាក្យប្រៀនប្រដៅរបស់ព្រះមានព្រះភាគ ដែលជា សាស្តានៃទេវតា និងមនុស្សទាំងឡាយ ឬពាក្យប្រៀនប្រដៅដែលជារបស់ ព្រះសាស្តា ឈ្មោះថា សត្ថុសាសនៈ ។ ធម្មវិន័យនោះឯង ហៅថា សាស្តា ក្នុងបាលី ( មហាបរិនិព្វានសូត្រ ) ថា ម្នាលអានន្ទ ធម៌ណាក្តី វិន័យណាក្តី ដែលតថាគតសម្តែងហើយ បញ្ញត្តិហើយ ដល់អ្នកទាំងឡាយ លុះអំណឹះឥត អំពីតថាគតទៅ ធម៌ និងវិន័យនោះ ជាគ្រូរបស់អ្នកទាំងឡាយ ដូច្នេះ ។ គប្បី ជ្រាបសេចក្តីនៃបទទាំងឡាយនោះ ដោយប្រការដូច្នេះ ។ ម្យ៉ាងទៀត ព្រោះ ភិក្ខុអ្នកញុំាងអានាបានស្សតិសមាធិឲ្យកើត ដោយអាការទាំងពួង មាននៅក្នុង សាសនានេះប៉ុណ្ណោះ មិនមានក្នុងសាសនាដទៃ ហេតុនោះ គប្បីជ្រាបថា ក្នុង បទនោះៗ ទើបលោកកំណត់សេចក្តីពិតប្រាកដដូច្នេះថា **ឥមិស្សា** និង **ឥមស្មឹ** ។

នេះជាអត្ថនៃការបង្អួលបង្ហាញនៃមាតិកាថា ក្នុងធម្មវិន័យនេះ ។

ម្យ៉ាងទៀត លោកមិនពោលអត្ថនៃ **ភិក្ខុ** សព្ទ តែសម្ដែងដល់ភិក្ខុ ដែលបំណងយកក្នុងទីនេះនោះឯង ដោយពាក្យថា **បុថុជ្ជនកល្យាណកោ វា** ជាដើម ។ ក្នុងពាក្យនោះ ភិក្ខុ ឈ្មោះថា បុថុជ្ជន ព្រោះជាអ្នកកាត់កិលេសមិនទាន់បាន និងឈ្មោះថា កល្យាណ ព្រោះជាអ្នកប្រកបដោយបដិបទា មានសីលជាដើម ព្រោះហេតុនោះ ទើបឈ្មោះថា កល្យាណបុថុជ្ជន កល្យាណបុថុជ្ជននោះឯង ឈ្មោះថា **បុថុជ្ជនកល្យាណកោ** ។

ឈ្មោះថា **សេក្ខោ** ព្រោះអត្ថថា នៅសិក្សាអធិសីលជាដើម ។ ជាព្រះសោតាបន្ន ព្រះសកទាគាមី ឬព្រះអនាគាមី ។

ឈ្មោះថា **អកុប្បធម្មោ** ព្រោះអត្ថថា មានធម៌ គឺអរហត្តផលមិនកម្រើក គឺមិនអាចឲ្យញាប់ញ័របាន ។ ពិតហើយ សូម្បីបុគ្គលមានធម៌មិនកម្រើកនោះក៏នៅបម្រើនសមាធិនេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសដែលពោលអំពីព្រៃ ដូចតទៅនេះថា ដោយបរិយាយនៃវិន័យ ពាក្យថា ព្រៃ ដូចក្នុងប្រយោគជាដើមថា ទីដ៏សេស លើកលែងតែស្រុក និងឧបចារៈនៃស្រុកចេញ ឈ្មោះថា ព្រៃ ដូច្នេះ ។ ដោយបរិយាយនៃព្រះសូត្រ សំដៅដល់ភិក្ខុអ្នកនៅព្រៃ ដូចក្នុងប្រយោគជាដើមថា ទីសេនាសនៈយ៉ាងជិតបំផុតត្រឹម ៥០០ ធ្នូរផ្ទួអំពីស្រុក ហៅថា សេនាសនៈតាំងនៅក្នុងព្រៃ ដូច្នេះ ។ ព្រះវិន័យ និងព្រះសូត្រសូម្បីទាំងពីរ ជាបរិយាយទេសនា ( ទេសនាដោយអម ) ព្រះអភិធម្ម ជានិប្បរិយាយទេសនា

( ទេសនាដោយត្រង់ ) ព្រោះហេតុនោះ ដើម្បីសម្តែងព្រៃដោយបរិយាយនៃអភិធម្ម ទើបពោលថា ទីចេញទៅខាងក្រៅអំពីសសរគោលដូច្នេះ ។ អធិប្បាយថា ចេញទៅខាងក្រៅអំពីសសរគោល ។ បាឋៈថា **និក្ខមិត្វា ពហិ ឥន្ទខីលំ** ដូច្នេះក៏មាន មានពាក្យអធិប្បាយថា ហួសសសរគោលចេញទៅ ។ ម្យ៉ាងទៀត ក្នុងបទថា **ឥន្ទខីលោ** នេះ បានដល់ ធរណីទ្វារស្រុក ឬនគរ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងនិទ្ទេសនៃរុក្ខមូលដូចតទៅ លោកមិនបានពោលដល់គល់ឈើនោះ ព្រោះគល់ឈើប្រាកដអត្ថជាក់ច្បាស់ហើយ តែពោលពាក្យថា **យត្ថ** ជាដើម ។

បទថា **យត្ថ** បានដល់ ត្រង់គល់ឈើណា ។ ឈ្មោះថា **អាសន** ព្រោះអត្ថថា ជាទីអង្គុយសម្រាក ជាទីអង្គុយ ។ បទថា **បញ្ញត្តំ** បានដល់ តាំងទុកហើយ ។ បទថា **មញ្ចោ វា** ជាដើម ជាពាក្យពោលដល់ប្រភេទរបស់អាសនៈ ។ ពិតហើយ សូម្បីគ្រែលោកក៏ពោលសង្គ្រោះទុកក្នុងអាសនៈទាំងឡាយក្នុងទីនេះ ព្រោះជាទីសម្រាប់អង្គុយក៏បាន ។ ម្យ៉ាងទៀត គ្រែនោះទោះជាគ្រែឈ្មោះ **មសារក** គ្រែដែលគេជាប់ជើង ហើយបញ្ចូលមេគ្រែទៅក្នុងជំណាប់នោះ **ពុន្ទិកាពទ្ធ** គ្រែដែលគេបន្ទាំជើងគ្រែដោយមេគ្រែ ហើយធ្វើដោយសន្ទេបជាបល្ល័ង្ក **កុឡីរបាទក** គ្រែមានជើងដូចជើងក្តាម **អាហច្ចបាទក** គ្រែដែលគេបានបញ្ចុះពន្លួញទៅក្នុងមេឯណានីមួយក៏បាន ។

តាំង ក៏ជាប្រភេទតាំង **មសារក** ឯណានីមួយដូចគ្នា ។ បទថា **ភិសិ** បានដល់ ពូកឯណាមួយបណ្តាពូកញាត់រោមកែះ ១ ពូកញាត់សំពត់ ១ ពូក

ញាត់សម្បកឈើ ១ ពួកញាត់ស្មៅ ១ ពួកញាត់ស្លឹកឈើ ១ ។ បទថា **តដ្ដិកា** បានដល់ កន្ទេលត្បាញដោយស្លឹកត្នោតជាដើម ។ បទថា **ចម្ម-ខណ្ឌា** បានដល់ កំណាត់ស្បែកឯណានីមួយដែលសមគួរជាទីអង្គុយ ។ បទថា **តិណសន្ថរោ** បានដល់ កម្រាលដែលក្រងដោយស្មៅជាដើម ។ បទថា **តត្ថ** បានដល់ ត្រង់គល់ឈើនោះ ។ ដោយបទថា **ចង្កមតិ វា** ជាដើម លោកពោលដល់គល់ឈើដែលជាទីញុំាងឥរិយាបថ ៤ ឲ្យប្រព្រឹត្តទៅបាន ។ ដោយបទទាំងពួង មានបទថា **យត្ថ** ជាដើម លោកពោលដល់គល់ឈើដែលមានម្លប់ក្រាស់ និងជាទីស្ងាត់ចាកពួកមនុស្ស ។ បទថា **កេនចិ** បានដល់ ដោយពួកជនណាមួយ ។

លោកចែកពួកជននោះឲ្យពិស្ដារចេញទៅ ទើបពោលថា **គហដ្ឋេហិ វា បព្វជិតេហិ វា។** បទថា **អនាកិណ្ណំ** បានដល់ មិនកុះករ មិនឆ្អៀតចង្អល់ ។ ដោយជុំវិញនៃសេនាសនៈណាដែលក្រាស់ដោយភ្នំ ក្រាស់ដោយព្រៃ ក្រាស់ដោយស្ទឹង មួយគាវុតខ្លះ កន្លះយោជន៍ខ្លះ បុគ្គលណាមួយមិនអាចចូលទៅបានដោយមិនមែនវេលាដែលគួរ សេនាសនៈនេះ ទោះបីនៅជិត ក៏ឈ្មោះថា មិនកុះករ ចំណែកសេនាសនៈណានៅកន្លះយោជន៍ ឬមួយយោជន៍ សេនាសនៈនេះ ឈ្មោះថា មិនកុះករ ព្រោះនៅឆ្ងាយនោះឯង ។

បទថា **វិហារោ** បានដល់ លំនៅដ៏សេសផុតចាកអឌ្ឍយោគជាដើម ។ បទថា **អឌ្ឍយោគោ** បានដល់ រោងដែលមានដំបូលកោងដូចស្លាបគ្រុឌ ។ បទថា **បាសាទោ** បានដល់ ប្រាសាទវែងមានជហ្វាពីរ ។ បទថា **ហម្មិយំ**

បានដល់ ប្រាសាទមានផ្ទះកំពូលតាំងនៅខាងលើកណ្ដាលអាកាស ។

បទថា **គុហា** លោកពោលក្នុងអដ្ឋកថាខន្ធកៈយ៉ាងនេះ គឺល្អាងឥដ្ឋ ល្អាងថ្ម ល្អាងឈើ ល្អាងដី ។ ចំណែកក្នុងអដ្ឋកថាវិភង្គ លោកពោលដល់ សេនាសនៈ ដែលធ្វើឲ្យមានផ្លូវដើរបានជុំវិញ និងមានទីសម្រាកពេលយប់ និងពេលថ្ងៃទុកខាងក្នុងថា វិហារ ។

បទថា **គុហា** បានដល់ ល្អាងក្នុងដីដែលគួរបានពន្លឺភ្លើង អស់យប់ និង ថ្ងៃ ។ លោកពោលបទទាំងពីរនេះឲ្យពិសេសថា គឺល្អាងភ្នំ ឬល្អាងដី ។ ក្នុង មាតិកា បទថា **និសីទតិ** លោកធ្វើឲ្យជាវត្តមានាវិភត្តិ ដោយអំណាចនៃ លក្ខណៈទូទៅដល់កាលទាំងពួង តែក្នុងទីនេះ លោកធ្វើឲ្យជារូបសម្រេចថា **និសិន្នោ** ( អង្គុយ ) ដើម្បីសម្ដែងការចាប់ផ្ដើម និងទីបំផុតនៃការអង្គុយ ព្រោះមានការផ្ដើមការនៃរបស់ភិក្ខុដែលអង្គុយហើយ ។

ម្យ៉ាងទៀត ព្រោះកាលភិក្ខុអង្គុយតាំងកាយត្រង់ កាយរមែងត្រង់ ហេតុ នោះ លោកមិនអើពើក្នុងព្យញ្ជនៈ កាលនឹងសម្ដែងដល់សេចក្ដីបំណង តែម្យ៉ាង ទើបពោលពាក្យថា **ឧជុំកោ** ជាដើម ។

ក្នុងបទទាំងនោះ បទថា **ឋិតោ សុបណិហិតោ** សេចក្ដីថា ជាកាយ តាំងទុកត្រង់ ព្រោះតាំងចិត្តឲ្យត្រង់ហើយ មិនមែនតាំងទុកត្រង់ដោយទំនើង ខ្លួនឯង ។ បទថា **បរិគ្គហដ្ឋោ** បានដល់ មានអត្ថដែលកំណត់កាន់យក ហើយ ។ កំណត់កាន់យកអ្វី កាន់យកការនាំចេញ ។ នាំចេញនូវអ្វី អានា- បានស្សតិសមាធិនោះឯង នាំចេញរហូតដល់អរហត្តមគ្គ ដោយហេតុនោះ

ទើបលោកពោលថា **និយ្យានដ្ឋោ** មានអត្ថថា ធម៌ជាគ្រឿងចេញទៅ ។ លោកពោលសភាពនាំចេញចាកសង្សារដោយអំណាចនៃអត្ថ ដែលសំខាន់បំផុតនៃ**មុខ** សព្ទ ។

បទថា **ឧបដ្ឋានដ្ឋោ** បានដល់ មានសភាវធម៌ជាអត្ថ ។ ដោយបទទាំងអស់នេះ ឈ្មោះថា លោកអធិប្បាយអត្ថថា ធ្វើសតិដែលជាគ្រឿងនាំចេញដែលកំណត់កាន់យកហើយ ។ តែអាចារ្យពួកខ្លះពណ៌នាថា បទថា **បរិគ្គ-ហដ្ឋោ** បានដល់ មានការកំណត់កាន់យកជាអត្ថដោយសតិ បទថា **និយ្យា-នដ្ឋោ** បានដល់ មានទ្វារចូលចេញនៃខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញ មានពាក្យអធិប្បាយថា តម្កល់សតិដែលជាគ្រឿងនាំចេញនូវខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញ ដែលកំណត់កាន់យកហើយ ។

[ ៩៧ ] បទថា **ពត្តឹសាយ អាការេហិ** លោកពោលដោយអំណាចការកាន់យកដោយមិនមានចំណែកសល់នៃខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញ ដែលនឹងបានតាមលំដាប់ក្នុងការកំណត់នោះៗ ។ បទថា **ទីឃំ អស្សាស-វសេន** បានដល់ ដោយអំណាចខ្យល់ដង្ហើមចូលដែលពោលហើយថា **ទីឃំ** ក្នុងមាតិកា ។ ក្នុងបទដ៏សេស ក៏យ៉ាងនេះ ។ បទថា **ឯកគ្គតំ** បានដល់ ភាវៈដែលចិត្ត មានអារម្មណ៍តែមួយ ។ បទថា **អវិក្ខេបំ** បានដល់ ការមិនរាយមាយ ។ ភាពដែលចិត្តមានអារម្មណ៍តែមួយ លោកពោលថា អវិក្ខេបៈ ព្រោះចិត្តមិនរាយមាយទៅក្នុងអារម្មណ៍ផ្សេងៗ ។ បទថា **បជានតោ** អធិប្បាយថា ដឹង គឺដឹងច្បាស់ដោយការមិនវង្វេង ឬដឹងដោយធ្វើឲ្យជាអារម្មណ៍

ថា អញបានការមិនរាយមាយហើយ ។ បទថា **តាយ សតិយា** បានដល់ ដោយសតិដែលប្រាកដហើយ ។ បទថា **តេន ញាណេន** បានដល់ ដោយញាណដែលដឹងការមិនរាយមាយនោះ ។ ក្នុងបទថា **សតោការី ហោតិ** នេះ ព្រោះសតិដែលសម្បយុត្តដោយញាណនោះឯង បំណងយកថាសតិ ។ ដូចព្រះមានព្រះភាគ ត្រាស់ថា ភិក្ខុក្នុងសាសនានេះ ជាអ្នកមានស្មារតីប្រកបដោយស្មារតី និងបញ្ញាខ្ជាប់ខ្ជួនដ៏ប្រសើរ ហេតុនោះ សូម្បីញាណក៏ឈ្មោះថា កាន់យកហើយ ដោយបទថា **សតោ** ។

[ ៩៨-៩៩ ] បទថា **អទ្ធានសង្ខាតេ** បានដល់ ក្នុងកាលដែលរាប់ថាវែង ។ ពិតហើយ ផ្លូវវែង លោកក៏ហៅថា អទ្ធានៈ សូម្បីកាលនេះ លោកក៏ហៅថា អទ្ធានៈ ព្រោះវែងដូចផ្លូវវែង ។ សូម្បីលោកពោលខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញបែកគ្នាថា ដកដង្ហើមចូល និងដកដង្ហើមចេញ ហើយគង់ពោលរួមគ្នាទៀតថា ខ្យល់ដង្ហើមចូលខ្លះ ខ្យល់ដង្ហើមចេញខ្លះ ដើម្បីសម្តែងការប្រព្រឹត្តទៅជាប់តនៃភាវនា ។

បទថា **ឆន្ទោ ឧប្បជ្ជតិ** បានដល់ ឆន្ទៈរមែងកើត ដើម្បីការចម្រើននៃភាវនាក្រៃលែងៗ ឡើង ។ បទថា **សុខុមតរំ** បានដល់ លោកពោលព្រោះមានការស្ងប់ ។ បទថា **បាមុជ្ជំ ឧប្បជ្ជតិ** បានដល់ បីតិរមែងកើត ព្រោះការបរិបូរណ៍នៃភាវនា ។

បទថា **អស្សាសបស្សាសាបិ ចិត្តំ វិវត្តតិ** បានដល់ កាលបដិភាគ-និមិត្តកើតព្រោះអាស្រ័យខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញ ចិត្តរមែងលះ

បាកខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញ តាមប្រក្រតី ។ បទថា **ឧបេក្ខា សណ្ឋាតិ** បានដល់ ក្នុងបដិភាគនិមិត្តនោះ មជ្ឈត្តុបេក្ខា ឈ្មោះថា រមែង តាំងមាំ ព្រោះមិនមានការខ្វល់ខ្វាយក្នុងការតាំងមាំទៀត ព្រោះសម្រេច ឧបចារសមាធិ និងអប្បនាសមាធិ ។

បទថា **នវហាការេហិ** បានដល់ អាការ ៩ គឺអាការ ៣ ដែលលោក ពោលថា រមែងដកដង្ហើមចូលខ្លះ ដកដង្ហើមចេញខ្លះ តាំងអំពីផ្តើមការនាមុន ឆន្ទៈកើត អាការ ៣ តាំងអំពីឆន្ទៈកើតមុនអំពីបាមោជ្ជកើត អាការ ៣ តាំង អំពីបាមោជ្ជកើត ។ បទថា **កាយោ** បានដល់ ខ្យល់ដង្ហើមចូល ខ្យល់ ដង្ហើមចេញដែលល្អិត ឈ្មោះថា កាយ ព្រោះអត្ថថា ប្រជុំ ។ សូម្បីនិមិត្ត ដែលកើតព្រោះអាស្រ័យខ្យល់ដង្ហើមចូលប្រក្រតី ខ្យល់ដង្ហើមចេញប្រក្រតីក៏ រមែងបានឈ្មោះថា ខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញ ។

បទថា **ឧបដ្ឋានំ សតិ** បានដល់ សតិ ឈ្មោះថា ឧបដ្ឋាន ព្រោះចូល ដល់អារម្មណ៍នោះតាំងនៅ ។ បទថា **អនុបស្សនា ញាណំ** សេចក្តីថា ការ ពិចារណាកាយ ដែលជានិមិត្តដោយអំណាចសមថៈ ការពិចារណានាមកាយ និងរូបកាយដោយអំណាចវិបស្សនាជាញាណ ។

បទថា **កាយោ ឧបដ្ឋានំ** បានដល់ កាយ ឈ្មោះថា ឧបដ្ឋាន ព្រោះ អត្ថថា ជាទីដែលសតិចូលទៅតាំងនៅ ។ បទថា **នោ សតិ** សេចក្តីថា កាយ នោះមិនមែនសតិ ។ បទថា **តាយ សតិយា** បានដល់ ដោយសតិដែល ពោលហើយក្នុងឥឡូវនេះ ។ បទថា **តេន ញាណេន** បានដល់ ដោយ

ញាណដែលពោលក្នុងឥឡូវនេះដូចគ្នា ។ បទថា **តំ កាយំ អនុបស្សតិ** បានដល់ ពិចារណាទៅតាមកាយ ដែលពោលដោយអំណាចសមថៈ និង វិបស្សនា ដោយញាណសម្បយុត្តដោយឈាន ឬដោយវិបស្សនាញាណ ។

សូម្បីក្នុងមាតិកាមិនមានពាក្យថា **កាយ** ជាដើម ក៏គួរពោលក្នុងឥឡូវ នេះ ព្រោះចតុក្កៈនេះ លោកពោលដោយអំណាចកាយានុបស្សនា ទើបលោក ធ្វើការចន្លុលបង្ហាញបទនៃ **កាយ** សំដៅដល់ពាក្យថា **កាយេ កាយានុ-បស្សនាសតិប្បដ្ឋានភាវនា ។**

បទថា **កាយេ កាយានុបស្សនា** បានដល់ ពិចារណាឃើញកាយនោះៗ ក្នុងកាយច្រើនយ៉ាង ។ ម្យ៉ាងទៀត លោកអធិប្បាយថា ការពិចារណាឃើញ កាយក្នុងកាយ មិនមែនពិចារណាឃើញធម៌ដទៃ មិនមែនពិចារណាឃើញការ ទៀង ភាពជាសុខ ភាពជាអត្តា និងការស្អាតក្នុងកាយដែលមិនទៀង ជាទុក្ខ ជាអនត្តា និងមិនស្អាតដោយពិត ការពិចារណាឃើញកាយនោះឯង ដោយភាព មិនទៀង ជាទុក្ខ ជាអនត្តា និងមិនស្អាត ។ ម្យ៉ាងវិញទៀត លោកអធិប្បាយ ថា ការពិចារណាឃើញកាយនោះឯង ជាត្រឹមតែកាយ ព្រោះពិចារណាមិន ឃើញរបស់ណាមួយដែលគួរប្រកាន់ ក្នុងកាយថា អញ របស់អញ ស្រី ឬ ប្រុស ។

សូម្បីក្នុង ៣ បទ មានបទជាដើមថា **វេទនាសុ វេទនានុបស្សនា** ខាង មុខ ក៏ន័យនេះដូចគ្នា ។ ការប្រាកដ គឺសតិ ឈ្មោះថា សតិប្បដ្ឋាន សតិប្បដ្ឋានដែលសម្បយុត្តដោយកាយានុបស្សនា ឈ្មោះថា កាយានុ-

បស្សនាសតិប្បដ្ឋាន ការចម្រើនកាយានុបស្សនាសតិប្បដ្ឋាននោះ ឈ្មោះថា កាយានុបស្សនាសតិប្បដ្ឋានភាវនា ។

បទថា **តំ កាយំ** សូម្បីមិនបានសម្តែងនាមកាយរូបកាយ លោកក៏ពោលធ្វើដូចសម្តែងហើយ ព្រោះកាយនោះលោកសង្គ្រោះហើយដោយ **កាយ** សព្ទ ព្រោះអនិច្ចានុបស្សនាជាដើម រមែងបានក្នុងនាមកាយ និងរូបកាយនោះឯង មិនបានក្នុងកាយដែលជានិមិត្ត ។ អនុបស្សនា និងភាវនា មានអត្ថតាមដែលពោលហើយនោះឯង ។

[ ១០០-១០៣ ] បទថា **ឥធំ អស្សាសបស្សាសវសេន** ជាដើម លោកពោលដើម្បីសម្តែងដល់អានិសង្សនៃអានាបានស្សតិភាវនា ។ ភាពដែលសតិបរិបូរ និងញាណបរិបូរ ជាអានិសង្សរបស់អានាបានស្សតិភាវនានោះ ។

ក្នុងបទទាំងនោះ បទថា **ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ** លោកពោលសំដៅដល់ភាពដែលចិត្តមានអារម្មណ៍តែមួយ ក្នុងកាលឃើញច្បាស់នូវឈានដែលបានហើយ ។ បទថា **វិទិតា វេទនា** បានដល់ វេទនាដែលប្រាកដដោយឃើញការកើតឡើងដោយភាពជាសាមញ្ញ ( ត្រៃលក្ខណ៍ ) ។ បទថា **វិទិតា ឧបដ្ឋហន្តិ** បានដល់ ប្រាកដចូលទៅតាំងនៅដោយការអស់ទៅ ដោយការវិនាសទៅ ដោយការសូន្យទៅ ។

បទថា **វិទិតា អព្ភត្ថំ គច្ឆន្តិ** បានដល់ ប្រាកដដល់ការវិនាស ដោយឃើញការវិនាសដោយភាពជាសាមញ្ញ អធិប្បាយថា រមែងបែកធ្លាយទៅ ។ សូម្បីក្នុងសញ្ញា និងវិតក្ក ក៏មានន័យនេះដូចគ្នា ។

ម្យ៉ាងវិញទៀត កាលលោកពោលដល់វេទនា សញ្ញា និងវិតក្ក ៣ យ៉ាងនេះហើយ សូម្បីរូបធម៌ដ៏សេស ក៏ជាការពោលផងដែរ ។ បើមានពាក្យសួរថា ព្រោះហេតុអ្វី ទើបពោល ៣ យ៉ាងប៉ុណ្ណោះ ឆ្លើយថា ព្រោះកំណត់កាន់យកបានដោយក្រ ។ ក្នុងវេទនាទាំងឡាយ សុខ ទុក្ខប្រាកដ តែឧបេក្ខាជាធម្មជាតល្អិតកំណត់កាន់យកបានដោយក្រ មិនប្រាកដច្បាស់ ។ សូម្បីឧបេក្ខានោះ ក៏គង់ប្រាកដដល់ភិក្ខុនោះ សញ្ញាមិនកាន់យកតាមសេចក្ដីពិត ព្រោះកាន់យកត្រឹមតែអាការ ។ ម្យ៉ាងទៀត សញ្ញានោះសម្បយុត្តដោយវិបស្សនាញាណដែលកាន់យកសាមញ្ញលក្ខណៈ តាមសេចក្ដីពិត រមែងមិនប្រាកដច្បាស់យ៉ាងក្រៃលែង សូម្បីសញ្ញានោះ ក៏គង់ប្រាកដដល់ភិក្ខុនោះ វិតក្កញែកចេញដោយឡែកអំពីបញ្ញា កំណត់កាន់យកបានដោយក្រ ព្រោះជិតគ្នាជាមួយបញ្ញា ។ ពិតហើយ វិតក្កជិតគ្នាជាមួយបញ្ញា សមដូចព្រះនាងធម្មទិន្នាភិក្ខុនីពោល ( ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសក ) ថា ម្នាលអាវុសោវិសាខ សម្មាទិដ្ឋិ ១ សម្មាសង្កប្ប ១ ធម៌ទាំង ( ២ ) នេះ លោកសង្គ្រោះចូលក្នុងបញ្ញាខន្ធដូច្នេះ ។

សូម្បីវិតក្កនោះ ក៏គង់ប្រាកដដល់ភិក្ខុនោះ ព្រោះហេតុនោះ កាលពោលដល់វេទនា សញ្ញា និងវិតក្កដែលកំណត់កាន់យកបានដោយក្រយ៉ាងនេះហើយ រូបធម៌ដ៏សេស ក៏ជាការពោលហើយផងដែរ ។ ក្នុងនិទ្ទេសនៃបទទាំងនេះ លោកសួរថា វេទនាប្រាកដកើតឡើងដូចម្ដេចជាដើម ហើយមិនឆ្លើយពាក្យសួរនោះ កាលលោកឆ្លើយការកើតឡើងនៃវេទនាដែលប្រាកដហើយនោះឯង

វេទនាដែលប្រាកដ ក៏ឈ្មោះថា លោកឆ្លើយហើយ ព្រោះហេតុនោះ ទើបពោលពាក្យជាដើមថា ការកើតឡើងនៃវេទនាដ៏ប្រាកដ តើដូចម្ដេច ។ ក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។

បទថា **អវិជ្ជាសមុទយា អវិជ្ជានិរោធា** ជាដើម មានអត្ថដូចធ្លាប់ពោលហើយនោះឯង ។ សូម្បីសញ្ញា និងវិតក្ក ក៏គប្បីជ្រាបដោយន័យនេះឯង ។ ក្នុងវិតក្កវារៈលោកមិនបានពោលថា **ផស្សសមុទយា ផស្សនិរោធា** ហើយពោលក្នុងទីនៃផស្សៈថា **សញ្ញាសមុទយា សញ្ញានិរោធា** ។ ប្រសិនបើសួរថា ដែលពោលដូច្នោះ ព្រោះហេតុអ្វី ។ ឆ្លើយថា ព្រោះវិតក្ក មានសញ្ញាជាមូល ព្រោះលោកពោល ( ក្នុងទីឃនិកាយ បាដិកវគ្គ ) ថា សេចក្ដីត្រិះរិះផ្សេងៗ អាស្រ័យសញ្ញាផ្សេងៗ ហើយ ទើបកើតឡើង ដូច្នេះ ។

ម្យ៉ាងទៀត ក្នុងបទថា **អនិច្ចតោ មនសិការោតោ** ជាដើម គប្បីប្រកបធម៌នោះៗ ក្នុងវារៈនោះៗ ដោយន័យជាដើមថា កាលមនសិការវេទនាដោយការមិនទៀង ។ ក៏ព្រោះវេទនាដែលសម្បយុត្តដោយវិបស្សនា មិនជាឧបការៈដល់វិបស្សនា ព្រោះវេទនាមិនអាចក្នុងការធ្វើកិច្ចនៃវិបស្សនាបាន ហេតុនោះឯង ទើបវេទនាមិនមកក្នុងពោធិបក្ខិយធម៌ទាំងឡាយ ។ ម្យ៉ាងទៀត កិច្ចនៃសញ្ញាដែលសម្បយុត្តដោយវិបស្សនា មិនជាក់ច្បាស់ ព្រោះហេតុនោះ ទើបសញ្ញានោះ មិនជាឧបការៈដល់វិបស្សនាដោយសព្វគ្រប់ តែវៀរវិតក្កហើយ កិច្ចនៃវិបស្សនារមែងមិនមាន ព្រោះថា វិបស្សនាដែលមានវិតក្កជាសម្ភារៈ រមែងធ្វើកិច្ចរបស់ខ្លួនបាន ។ ដូចដែលលោកពោលថា បញ្ញារមែង

មិនអាចកាត់សម្រេចអារម្មណ៍បានថា មិនទៀង ជាទុក្ខ ជាអនត្តា តាមធម្មតារបស់ខ្លួន តែកាលវិតក្កចាប់អារម្មណ៍ ហើយប្រគល់ឲ្យ ទើបបញ្ញាអាចកាត់សម្រេចបាន សេចក្ដីនេះដូចម្ដេច ដូចនាយហិរញ្ញិក ដាក់កហាបណៈត្រង់ដៃ សូម្បីបំណងនឹងពិនិត្យមើលក្នុងទីគ្រប់អន្លើ ក៏មិនអាចប្រែត្រឡប់ដោយភ្នែកបាន តែកាលយកម្រាមដៃក្ដិះត្រឡប់ទៅមក ក៏អាចពិនិត្យមើលខាងនោះខាងនេះបាន យ៉ាងណា បញ្ញាក៏យ៉ាងនោះដូចគ្នា មិនអាចវិនិច្ឆ័យអារម្មណ៍ដោយអំណាចនៃការមិនទៀងជាដើមបានតាមធម្មតារបស់ខ្លួន តែអាចវិនិច្ឆ័យអារម្មណ៍ដែលវិតក្ក ដែលមានការលើកចិត្តឡើងកាន់អារម្មណ៍ជាលក្ខណៈ មានការប៉ះខ្ទប់ និងការទល់ទ្រត្រង់អារម្មណ៍ជាកិច្ច បញ្ជូនឲ្យបាន ដូចចាប់ប្រែត្រឡប់ទៅត្រឡប់មក ដូច្នោះ ព្រោះហេតុនោះ ដើម្បីសម្ដែងដោយអំណាចត្រឹមតែលក្ខណៈប៉ុណ្ណោះ ព្រោះវេទនា និងសញ្ញា មិនជាឧបការៈដល់វិបស្សនា ទើបលោកធ្វើការចង្អុលបង្ហាញដោយឯកវចនៈ ក្នុងបទនោះៗ ថា **វេទនាយ សញ្ញាយ** ដូច្នេះ ។ ដើម្បីសម្ដែងថា ប្រភេទនៃវិបស្សនា មានប្រមាណប៉ុនណា ប្រភេទនៃវិតក្ក ក៏មានប្រមាណប៉ុណ្ណោះដូចគ្នា កាលពោលថា លោកធ្វើការចង្អុលបង្ហាញដោយពហុវចនៈ ក្នុងបទនោះៗ ថា **វិតក្កានំ** ទើបត្រឹមត្រូវ ។

[ ១០៤-១០៧ ] បទថា **ទីឃំ អស្សាសបស្សាសវសេន** ជាដើម លោកពោលដដែលទៀត ក៏ដើម្បីសម្ដែងការដល់ព្រមនៃអានាបានស្សតិភាវនា និងផលនៃភាវនា ។ ក្នុងបទទាំងនោះ បទថា **សមោធានេតិ** សេចក្ដីថា

តាំងទុកនូវអារម្មណ៍ ឬញុំាងអារម្មណ៍ឲ្យតាំងទុក ។ បុគ្គល ឈ្មោះថា រមែង តាំងអារម្មណ៍ ដើម្បីសេចក្តីបរិបូរណ៍នៃការនោ សូម្បីមិនមានការតាំងមាំ និង ការវង្វល់ខ្វាយ ។ បទថា **គោចរំ** បានដល់ សង្ខារជាអារម្មណ៍ក្នុងខណៈនៃ វិបស្សនា និងនិព្វាន ជាអារម្មណ៍ក្នុងខណៈនៃមគ្គ និងខណៈនៃផល ។ បទ ថា **សមត្ថំ** បានដល់ ប្រយោជន៍ គឺការស្ងប់ ឬប្រយោជន៍នៃការស្ងប់ ព្រោះហេតុនោះ ទើបឈ្មោះថា **សមត្ថ** ។ នូវធម៌ដែលជា **សមត្ថ** នោះ ។ ក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។

បទថា **មគ្គំ សមោធានេតិ** បានដល់ និព្វាននោះឯងជាអារម្មណ៍ ក្នុង ខណៈមគ្គ និងផល ។ បទថា **អយំ បុគ្គលោ** បានដល់ ព្រះយោគាវចរនោះ ឯងដែលប្រកបរឿយៗ នូវអានាបានស្សតិភាវនា ។ ក្នុងបទថា **ឥមស្មឹ អារម្មណេ** បានដល់ ក្នុងអារម្មណ៍ដែលជាសង្ខតៈ ពោល គឺនាមកាយ និង រូបកាយដែលលោកសង្គ្រោះដោយបទថា **កាយេ** ក្នុងមគ្គ និងក្នុងនិព្វានដែល ជាអារម្មណ៍ តាមលំដាប់នោះឯង ។ លោកពោល **អារម្មណា** សព្ទ និង **គោចរ** សព្ទ មានអត្ថដូចគ្នាតែមួយ ដោយបទថា **យន្តស្ស** ជាដើម ។

បទថា **តស្ស** បានដល់ នៃបុគ្គលនោះ ។ បទថា **បជានាតីតិ បុគ្គលោ បជានា បញ្ញា** លោកអធិប្បាយថា បុគ្គលរមែងដឹងដោយបញ្ញា ។ បទថា **អារម្មណស្ស ឧបដ្ឋានំ** បានដល់ ការចូលទៅតាំងទុកនូវអារម្មណ៍ដែលជា សង្ខារក្នុងខណៈនៃវិបស្សនា និងការចូលទៅតាំងទុកនូវអារម្មណ៍ គឺនិព្វានក្នុង ខណៈនៃមគ្គផល ចាត់ជាសតិ ។ ក្នុងបទនេះ ឆដ្ឋីវិភត្តិ ចុះក្នុងអត្ថនៃឆដ្ឋីកម្ម

( ទុតិយាវិភត្តិ ) ដូចបទថា **រញ្ញោ ឧបដ្ឋានំ** ( ការបម្រើនូវព្រះរាជា ) ។ បទថា **អវិក្ខេបោ** បានដល់ សមាធិ ។ បទថា **អធិដ្ឋានំ** បានដល់ មានសង្ខារតាមដែលពោលហើយជាអារម្មណ៍ និងមាននិព្វានជាអារម្មណ៍ ។ ពិតហើយ ឈ្មោះថា អធិដ្ឋាន ព្រោះជាទីដែលចិត្តតាំងមាំ ។ បទថា **វោទានំ** បានដល់ ញាណ ។ ញាណនោះ ឈ្មោះថា វោទាន ព្រោះជាហេតុធ្វើចិត្តឲ្យផូរផង់ ។

សមាធិជាបក្សពួកនៃការរួញរា តែព្រោះដល់នូវការមិនរួញរាដែលជាការស្ងប់ ទើបឈ្មោះថា ស្ងប់ បញ្ញាជាបក្សពួកនៃការរាយមាយ តែព្រោះដល់នូវការមិនរាយមាយដែលជាការស្ងប់ ទើបឈ្មោះថា ស្ងប់ ។ ដោយហេតុនោះ ឈ្មោះថា លោកពោលដល់ភាពដែលសមថៈ និងវិបស្សនា ជាធម៌គូគ្នាក្នុងខណៈនៃវិបស្សនាមគ្គ និងផល ។ សតិ ឈ្មោះថា ស្ងប់ ព្រោះជាឧបការៈដល់សេចក្តីស្ងប់ទាំងពីរនោះ ព្រោះមានប្រយោជន៍ក្នុងទីទាំងពួង អារម្មណ៍ ឈ្មោះថា ស្ងប់ ព្រោះតាំងមាំដោយការស្ងប់ ។

បទថា **អនវជ្ជដ្ឋោ** បានដល់ សភាវៈនៃវិបស្សនាមិនមានទោស ។ បទថា **និក្កេសដ្ឋោ** បានដល់ សភាវៈនៃមគ្គមិនមានកិលេស ។ បាឋៈថា **និក្កិលេសដ្ឋោ** ដូច្នេះក៏មាន ។ បទថា **វោទានដ្ឋោ** បានដល់ សភាវៈនៃផលបរិសុទ្ធ ។ បទថា **បរមដ្ឋោ** បានដល់ សភាវៈនៃនិព្វានជាធម៌ខ្ពង់ខ្ពស់បំផុតជាងធម៌ទាំងពួង ។ បទថា **បដិវិជ្ឈតិ** បានដល់ ចាក់ធ្លុះសភាវៈនោះៗដោយការមិនវង្វេង ។ ក្នុងបទនេះ លោកពោលដល់ការចាក់ធ្លុះដោយប្រពៃ ដោយ

បទថា **អារម្មណស្ស ឧបដ្ឋានំ ។** ម្យ៉ាងទៀត ក្នុងបទនេះឯង ព្រោះលោក ពោលដល់ការចាក់ធ្លុះធម៌ដែលមានអត្ថនៃការផ្ទួនផង់ ទើបឈ្មោះថាពោលដល់ ធម៌ដែលមានអត្ថនៃការមិនមានទោស ធម៌ដែលមានអត្ថនៃការមិនសៅហ្មង និងធម៌ដែលមានអត្ថនៃគុណក្រៃលែង ដែលមានលក្ខណៈដូចគ្នាដោយអំណាច ការនាំមកដោយលក្ខណៈដូចលោកពោល ( ក្នុងនេត្តិបករណ៍ ) ថា

ធម៌ជាគ្រឿងនាំទៅ មានលក្ខណៈដូចដែលលោកពោលថា
កាលពោលដល់ធម៌មួយ ឈ្មោះថា ពោលដល់ធម៌មួយ
( ព្រោះ ) ធម៌ទាំងអស់ មានលក្ខណៈតែមួយ ។

ម្យ៉ាងទៀត ក្នុងបទនេះ អត្ថនៃការមិនមានទោស អត្ថនៃការមិនសៅហ្មង ឈ្មោះថា អត្ថនៃការស្ងប់ ព្រោះជាអត្ថរបស់ការស្ងប់ ពោល គឺការមិនរាយ មាយ អត្ថនៃការផ្ទួនផង់ ឈ្មោះថា អត្ថនៃការស្ងប់ ព្រោះអត្ថ គឺការស្ងប់សំដៅ ដល់ការផ្ទួនផង់នៃវិបស្សនា និងមគ្គ ឈ្មោះថា អត្ថនៃការស្ងប់ ព្រោះអត្ថនៃការ ស្ងប់ ពោល គឺការផ្ទួនផង់នៃមគ្គ សំដៅដល់ការផ្ទួនផង់នៃផល ចំណែកអត្ថនៃ គុណក្រៃលែង ឈ្មោះថា អត្ថនៃការស្ងប់ ព្រោះអត្ថ គឺការស្ងប់ ឬព្រោះអត្ថនៃ ការស្ងប់ទាំងអស់ ព្រោះប្រកបដោយនិព្វាន ការស្ងប់ និងអត្ថនៃការស្ងប់ មានប្រការដូចពោលហើយនោះ លោកធ្វើឲ្យជាឯកទេសសមាស និងស្យុ- បេកសេសមាសហើយ ទើបពោលថា **សមត្ថញ្ច បដិវិជ្ឈតិ** រមែងចាក់ធ្លុះ នូវអត្ថនៃការស្ងប់ ។

ធម៌ គឺឥន្ទ្រិយ ពល និងពោជ្ឈង្គ រមែងបានសូម្បីក្នុងខណៈនៃវិបស្សនា

មគ្គ និងផល ។ មគ្គ និងវិសុទ្ធិ ៣ រមែងបានក្នុងខណៈនៃមគ្គ និងផលនោះឯង ។ វិមោក្ខ វិជ្ជា និងខយញ្ញាណ ( ការដឹងក្នុងការអស់ទៅនៃអាសវៈ ) រមែងបានក្នុងខណៈនៃមគ្គនោះឯង ។ វិមុត្តិ និងអនុប្បាទញ្ញាណ ( ការដឹងក្នុងការមិនកើត ) រមែងបានក្នុងខណៈនៃផលនោះឯង ។ ធម៌ដ៏សេស រមែងបានក្នុងខណៈនៃវិបស្សនា ។

[ ១០៨ ] គប្បីជ្រាបវិនិច្ឆ័យ ក្នុងធម្មវារៈដូចតទៅ បទថា **ឥមេ ធម្មា ឥមស្មឹ អារម្មណេ សមោធានេតិ** គប្បីជ្រាបធម៌ដ៏សេស តាមការប្រកបបាន វៀរនិព្វាន ។ លោកពោលបទនេះ ដោយអំណាចជាយេភុយ្យន័យ ( ជាចំណែកច្រើន ) ។ម្យ៉ាងទៀត ក្នុងទីនេះ អត្ថដែលមិនទាន់បានពោល ខ្ញុំធ្លាប់ពោលហើយ ។ ក្នុងទីនេះ កាលលោកសំដែងធម៌ ជាគ្រឿងនាំចេញ ដោយអំណាចចតុក្កៈនីមួយៗ ក៏ឈ្មោះថា សំដែងដល់ធម៌ជាគ្រឿងនាំចេញ ដោយអំណាចចំណែកនីមួយៗ ព្រោះធម៌ជាគ្រឿងនាំចេញ ដែលចំណែកនីមួយៗ ដែលឈមចុះខាងក្នុងចតុក្កៈ ជាឧបនិស្សយប្បច្ច័យ ។ វៀរចំណែកនីមួយៗ រមែងមិនមានការនាំចេញ ។៙

## អដ្ឋកថា នីយអស្សាសបស្សាសនិទ្ទេស ចប់

# អដ្ឋកថា

## បឋមចតុក្កនិទ្ទេស

[ ១០៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវេស្សនិទ្ទេសដូចតទៅ បទថា **ឥត្តរសង្ខាតេ** បានដល់ ក្នុងកាលដែលរាប់បានបន្តិចបន្តួច ។ ក្នុងនិទ្ទេសនេះ បទដ៏សេស គប្បីជ្រាបដោយន័យដូចពោលហើយ ។

[ ១១១ ] គប្បីជ្រាបវិនិច្ឆ័យ ក្នុងសព្វកាយបដិសំវេទិនិទ្ទេសដូចតទៅ ព្រោះវេទនាក្នុងអរូបធម៌ទាំងឡាយគ្រោតគ្រាត ទើបលោកពោលដល់វេទនាដែលសោយឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍មុន ដើម្បីឲ្យកំណត់បានងាយ បន្ទាប់អំពីនោះ ពោលដល់សញ្ញាដែលកំណត់អាការនៃអារម្មណ៍របស់វេទនា យ៉ាងនេះថា បុគ្គលរមែងចាំបានដល់វេទនាដែលសោយ បន្ទាប់អំពីនោះ ពោលដល់ចេតនាដែលជាអភិសង្ខារដោយអំណាចនៃសញ្ញា បន្ទាប់អំពីនោះ ពោលដល់ផស្សៈ ព្រោះបាលី ( ក្នុងសំយុត្តនិកាយ សឡាយតនវគ្គ ) ថា **ផុដ្ឋោ វេទេតិ ផុដ្ឋោ សញ្ជានាតិ**[១] **ផុដ្ឋោ ចេតេតិ** បុគ្គលដែលអារម្មណ៍ពាល់ត្រូវហើយ រមែងដឹងច្បាស់ ដែលអារម្មណ៍ពាល់ត្រូវហើយ រមែងចាំបាន ដែលអារម្មណ៍ពាល់ត្រូវហើយ រមែងគិត ដូច្នេះ បន្ទាប់អំពីនោះ ពោលដល់មនសិការដែលមានលក្ខណៈទូទៅនៃធម៌ទាំងពួង ពោលដល់សង្ខារក្ខន្ធដោយចេតនាជាដើម កាលលោកពោលដល់ខន្ធ ៣ យ៉ាងនេះហើយ ឈ្មោះថា ពោលដល់វិញ្ញាណក្ខន្ធដែលជាទីអាស្រ័យរបស់ខន្ធទាំង ៣ នោះ ។ បទថា **នាមញ្ច** បានដល់ នាមមានប្រការដូចដែលពោលហើយ ។ បទថា **នាម–**

**កាយោ ច** នេះ លោកពោលដើម្បីកាត់នាមនោះចេញ ព្រោះនិព្វានក៏សង្គ្រោះចូលជាមួយនាម និងព្រោះលោកុត្តរធម៌ ប្រើជាវិបស្សនាមិនបាន ។ លោកនាំយកនិព្វានចេញ ដោយបទថា **កាយោ** ព្រោះនិព្វានផុតចាកគំនរ ។ បទថា **យេ ច វុច្ចន្តិ ចិត្តសង្ខារា** មានពាក្យអធិប្បាយថា ចិត្តសង្ខារ លោកពោលយ៉ាងនេះថា សញ្ញា និងវេទនាជាតួចេតសិក ធម៌ទាំងនុ៎ះជាប់ចំពោះដោយចិត្ត ដោយអំណាចនៃដង្ហើមចូលវែង ឈ្មោះថា ចិត្តសង្ខារ សង្គ្រោះចូលដោយនាមកាយ ក្នុងទីនេះ ។

បទថា **មហាភូតា** ឈ្មោះថា មហាភូតរូប ព្រោះការប្រាកដជាធំ ព្រោះស្មើនឹងរបស់ដែលធំ ព្រោះមានការរក្សាច្រើន ព្រោះមានវិការច្រើន និងព្រោះជារបស់ធំ ។ មហាភូតរូបទាំងនោះ មាន ៤ យ៉ាង គឺបឋវី អាបោ តេជោ និងវាយោ ។ បទថា **ចតុន្នញ្ច មហាភូតានំ ឧបាទាយរូបំ** ជាឆដ្ឋីវិភត្តិចុះក្នុងអត្ថនៃទុតិយាវិភត្តិ សេចក្តីថា រូបដែលអាស្រ័យមិនលះនូវមហាភូតរូប ៤ ប្រព្រឹត្តទៅ ។ ឧបាទាយរូបនោះ មាន ២៤ គឺភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ រូប សំឡេង ក្លិន រស ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ ជីវិតិន្ទ្រិយ ហទយវត្ថុ ឱជៈ កាយវិញ្ញត្តិ វចីវិញ្ញត្តិ អាកាសធាតុ រូបលហុតា រូបមុទុតា រូបកម្មញ្ញតា ឧបចយរូប សន្តតិរូប ជរតារូប អនិច្ចតារូប ។

បទថា **អស្សាសោ ច បស្សាសោ ច** គឺខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញតាមប្រក្រតីនោះឯង ។ សូម្បីបដិភាគនិមិត្តកើតឡើង ព្រោះអាស្រ័យខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញ ក៏បានឈ្មោះនោះៗ ឯង ដូចបឋវីកសិណ

ជាដើម ។ ម្យ៉ាងទៀត ព្រោះដូចគ្នានឹងរូប ទើបបានឈ្មោះថា រូប ដូចក្នុងប្រយោគជាដើមថា ឃើញនូវពួករូបខាងក្រៅ ដូច្នេះ ។

បទថា **និមិត្តញ្ច ឧបនិពន្ធនា** បានដល់ ទីដែលខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញប៉ះត្រូវ ដែលជានិមិត្តនៃការចូលទៅចងទុកដោយសតិ ។

បទថា **យេ ច វុច្ចន្តិ កាយសង្ខារា** មានពាក្យអធិប្បាយថា កាយ-សង្ខារដែលលោកពោលយ៉ាងនេះថា ពួកខ្យល់ដង្ហើមចូល ពួកខ្យល់ដង្ហើមចេញ ប្រព្រឹត្តទៅក្នុងកាយ ធម៌ទាំងនេះ ជាប់ដោយកាយ ឈ្មោះថា កាយសង្ខារ ក៏សង្គ្រោះចូលដោយរូបកាយ ក្នុងទីនេះ ។

[ ១១២ ] បទថា **តេ កាយា បដិវិទិតា ហោន្តិ** បានដល់ កាយ មានខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញ ជានិមិត្តក្នុងខណៈនៃឈាន រូបកាយនិងអរូបកាយដ៏សេស ក្នុងខណៈនៃវិបស្សនា រមែងប្រាកដដោយអារម្មណ៍ ក្នុងខណៈនៃមគ្គ រមែងប្រាកដដោយការមិនវង្វេង ។

លោកពោលបទជាដើមថា **ទីឃំ អស្សាសបស្សាសវសេន** សំដៅដល់វិបស្សនា និងមគ្គ ដែលកើតឡើងហើយដល់ព្រះយោគាវចរអ្នកបានឈាន ដោយអំណាចនៃខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញ ។

បទថា **អាវជ្ជតោ បជានតោ** ជាដើម មានអត្ថដូចបានពោលហើយក្នុងសីលកថា ។ លោកធ្វើកាយទាំងឡាយ មានប្រការដូចពោលហើយទាំងនោះក្នុងខាងក្នុងហើយ ពោលថា **សព្វកាយប្បដិសំវេទី** ។

[ ១១៣ ] ក្នុងបទថា **សព្វកាយបដិសំវេទី អស្សាសបស្សាសានំ**

**សំវរដ្ឋេន** គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះថា ការសង្រួមក្នុងឈាន វិបស្សនា និងមគ្គដែលកើតឡើងហើយអំពីខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញ ដូចលោកពោលថា កំណត់ដឹងនូវកាយទាំងពួង ឈ្មោះថា សីលវិសុទ្ធិ ដោយអត្ថថា សង្រួម ។ ការមិនរាយមាយនោះឯង ឈ្មោះថា ចិត្តវិសុទ្ធិ ដោយអត្ថថា មិនរាយមាយ ។ បញ្ញានោះឯង ឈ្មោះថា ទិដ្ឋិវិសុទ្ធិ ដោយអត្ថថា ឃើញ ។ សូម្បីមិនមានវិរតិក្នុងឈាន និងវិបស្សនា ត្រឹមតែការមិនមានបាប ក៏គប្បីជ្រាបថា ឈ្មោះថា សង្រួម ។

[ ១១៤ ] គប្បីជ្រាបវិនិច្ឆ័យ ក្នុងបស្សម្ភយន្តិទ្ទេសជាដើមដូចតទៅ បទថា **កាយិកា** បានដល់ មានក្នុងរូបកាយ ។ បទថា **កាយបដិពទ្ធា** បានដល់ ទាក់ទងដល់កាយ គឺអាស្រ័យកាយ ។ កាលមានកាយ ខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញក៏មាន កាលកាយមិនមាន ខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញក៏មិនមាន ព្រោះហេតុនោះ ទើបខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញ ឈ្មោះថា កាយសង្ខារ ព្រោះខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញទាំងនោះ តាក់តែងឡើងដោយកាយ ។

បទថា **បស្សម្ភេន្តោ** បានដល់ ឲ្យរលត់ ឲ្យស្ងប់ ។ ការរម្ងាប់កាយសង្ខារយ៉ាងគ្រោតគ្រាតសម្រេចដោយពាក្យថា រម្ងាប់នោះឯង ។ បទថា **និរោធេន្តោ** បានដល់ រម្ងត់ដោយមិនឲ្យកាយសង្ខារយ៉ាងគ្រោតគ្រាតកើតឡើង ។ បទថា **វូបសមេន្តោ** បានដល់ នាំកាយសង្ខារគ្រោតគ្រាតនោះឯង ទៅកាន់ការស្ងប់ដោយន័យនៃការប្រែប្រួលសន្តតិមួយខណៈ ។

ដោយអធិការថា **សិក្ខតិ** គប្បីភ្ជាប់សេចក្ដីថា រមែងសិក្សាថា អាត្មាអញនឹងដកដង្ហើមចូល ឬអធិប្បាយថា រមែងសិក្សាត្រៃសិក្ខា ។ ឥឡូវនេះ ដើម្បីសម្ដែងដល់ការរម្ងាប់កាយសង្ខារយ៉ាងគ្រោតគ្រាត ទើបលោកពោលពាក្យជាដើមថា **យថារូបេហិ** ។ ក្នុងបទទាំងនោះ បទថា **យថារូបេហិ** បានដល់ បែបណា ។ បទថា **អានមនា** បានដល់ បង្អោនទៅខាងក្រោយ ។ បទថា **វិនមនា** បានដល់ បង្អោនទៅទាំងពីរខាង ។ បទថា **សន្នមនា** បានដល់ បង្អោនទៅយ៉ាងល្អរបស់កាយសង្ខារ ដែលបង្អោនទៅដោយខាងៗ ទាំងពួង ។ បទថា **បណាមនា** បានដល់ បង្អោនទៅខាងមុខ ។ បទថា **ឥញ្ជនា** បានដល់ ការរញ្ជួយ ។ បទថា **ផន្ទនា** បានដល់ ការកម្រើកបន្តិចបន្តួច ។ បទថា **បកម្បនា** បានដល់ ញាប់ញ័រទៅមកច្រើន ។ គប្បីធ្វើការភ្ជាប់សេចក្ដីថា ការខិន ។បេ។ ការញាប់ញ័រណានៃកាយ ដោយកាយសង្ខារទាំងឡាយ មានសភាពយ៉ាងណា រម្ងាប់នូវកាយសង្ខារមានសភាពយ៉ាងនោះ និងការខិន ។បេ។ ការញាប់ញ័រណានៃកាយមានសភាពយ៉ាងណា រម្ងាប់នូវការខិនមានសភាពយ៉ាងនោះ ។ ព្រោះថា កាលកាយសង្ខាររម្ងាប់ហើយ ក៏ជាការរម្ងាប់ការខិនជាដើមរបស់កាយ ។ គប្បីជ្រាបដោយការភ្ជាប់សេចក្ដីថា កាយមិនមានការខិនទៅជាដើម ដោយកាយសង្ខារបែបណា រម្ងាប់កាយសង្ខារសូម្បីល្អិតសុខុមបែបនោះបាន និងថា កាយមិនមានការខិនទៅជាដើមណា រម្ងាប់កាយ-សង្ខារដែលល្អិតសុខុមនោះបាន ។ បទថា **សន្តំ សុខុមំ** នេះ ជានបុំសកលិង្គ ។ ក្នុងបទថា **ឥតិ កិរ** នេះ **ឥតិ** សព្ទប្រើក្នុងអត្ថថា **ឯវំ** ។ **កិរ** សព្ទ ប្រើក្នុង

អត្ថថា **យទិ**។ បើអ្នកចោទផ្តើមចោទយ៉ាងនេះថា ភិក្ខុរមែងសិក្សាថា អាត្មាអញ នឹងរម្ងាប់ខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញ ដែលល្អិត ដកដង្ហើមចូល ដកដង្ហើមចេញ ។

ម្យ៉ាងវិញទៀត បទថា **កិរ** លោកអធិប្បាយថា ព្រោះជាពាក្យនិយាយតៗ គ្នា ទើបគួរចុះក្នុងអត្ថថា មិនគួរជឿ មិនគួរអត់ធន់ ឯមនុស្សដទៃគេនិយាយមក ទើបយើងមិនជឿ មិនអត់ធន់ មិនប្រចក្សដល់យើងថា ភិក្ខុរមែងសិក្សាការរម្ងាប់កាយសង្ខារ សូម្បីល្អិតយ៉ាងនេះ ។

បទថា **ឯវំ សន្តេ** បានដល់ កាលមានការរម្ងាប់កាយសង្ខារ ដែលល្អិតយ៉ាងនេះ ។ បទថា **វាតូបលទ្ធិយា ច បភាវនា ន ហោតិ** បានដល់ការបានខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញ ។ បទថា **ឧបលទ្ធិ** បានដល់ការដឹងច្បាស់ ។ ការដឹងច្បាស់នូវការនា ដែលបានខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញ ដែលមានខ្យល់ដង្ហើមចូលខ្យល់ដង្ហើមចេញនោះជាអារម្មណ៍ រមែងមិនប្រាកដ គឺមិនកើតឡើង អធិប្បាយថា អារម្មណ៍នោះរមែងមិនចម្រើន ។

បទថា **អស្សាសបស្សាសានញ្ច បភាវនា ន ហោតិ** សេចក្តីថា ព្រោះរម្ងត់ខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញ ដែលល្អិតដោយការនា ខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញទាំងនោះ ក៏មិនកើត មិនប្រព្រឹត្តទៅ ។

បទថា **អានាបានស្សតិយា ច បភាវនា ន ហោតិ** បានដល់ សតិដែលសម្បយុត្តដោយការដឹងច្បាស់នូវការនា ដែលមានអានាបានស្សតិនោះជាអារម្មណ៍ រមែងមិនប្រព្រឹត្តទៅព្រោះមិនមានខ្យល់ដង្ហើមចូល ខ្យល់ដង្ហើម

ចេញ ព្រោះហេតុនោះឯង ការចម្រើនអានាបានស្សតិសមាធិ ដែលសម្បយុត្ត ដោយការដឹងច្បាស់នូវការនានោះ រមែងមិនមាន ។ បទថា **ច ឆំ** ក្នុងបទនេះ ថា **ន ច ឆំ តំ** ត្រឹមតែជានិបាត ដូចក្នុងបទថា **ភិក្ខុ ច ឆំ** ជាដើម ។ គប្បីភ្ជាប់សេចក្តីថា បណ្ឌិតទាំងឡាយនឹងចូលសមាបត្តិដូចដែលពោលហើយ នោះក៏មិនមែន សូម្បីនឹងចេញចាកសមាបត្តិនោះក៏មិនមែន ។

បទថា **ឥតិ កិរ** បានដល់ ដោយប្រការយ៉ាងនេះ ដោយជាពាក្យចៀស វាងរបស់អ្នកនិយាយតៗ គ្នា ។ គប្បីឃើញ **កិរ** សព្ទ ក្នុងបទនេះ ប្រើក្នុង អត្ថថា **ឯវ**។ បទថា **ឯវំ សន្តេ** បានដល់ កាលមានការរម្ងាប់យ៉ាងនេះឯង ។ បទថា **យថា កថំ វិយ** បានដល់ លោកសួរការប្រៀបធៀបថា សេចក្តីនោះ ដូចវិធីដែលពោលដូចម្តេច ។ ឥឡូវនេះ លោកសម្តែងការប្រៀបធៀបនោះ ថា **សេយ្យថាបិ** ។

បទថា **កំសេ** បានដល់ ភាជនៈធ្វើដោយសំរឹទ្ធ ។ បទថា **និមិត្តំ** បាន ដល់ អាការនៃសំឡេងទាំងនោះ ។ម្យ៉ាងទៀត បទថា **និមិត្តំ** ជាទុតិយា- វិភត្តិ ចុះក្នុងអត្ថនៃឆដ្ឋីវិភត្តិ សេចក្តីថា នៃនិមិត្ត និមិត្តនៃសំឡេង មិនមែន ដទៃអំពីសំឡេង ។ បទថា **សុគ្គហិតត្តា** បានដល់ ព្រោះកាន់យកដោយល្អ ។ បាឋៈថា **សុគហិតត្តា** ដូច្នេះក៏មាន អធិប្បាយថា កាន់យកហើយដោយ ល្អ ។ បទថា **សុមនសិកតត្តា** បានដល់ ព្រោះនឹកគិតដោយល្អ ។ បទថា **សូបធារិតត្តា** បានដល់ តាំងទុកក្នុងចិត្តដោយល្អ ។

បទថា **សុខុមសទ្ទនិមិត្តារម្មណតាបិ** បានដល់ ព្រោះសំឡេងវំពងក្នុង

កាលនោះរលត់ទៅ ចិត្តមិនមាននិមិត្តនៃសំឡេងដែលឧបការៈ ជាអារម្មណ៍ សូម្បីមាននិមិត្តនៃសំឡេងដែលល្អិតជាងជាអារម្មណ៍ ព្រោះធ្វើនិមិត្តនៃសំឡេងដែលល្អិតជាងឲ្យជាអារម្មណ៍ ក៏រមែងប្រព្រឹត្តទៅបាន ។ ម្យ៉ាងទៀត អធិប្បាយថា ព្រោះមាននិមិត្តនៃសំឡេងដែលល្អិតជាង ជាអារម្មណ៍ ។ គប្បីជ្រាបអត្ថសូម្បីក្នុងអប្បនាដោយន័យនេះ ។

ក្នុងបទថា **បស្សម្ភយំ** ជាដើម គប្បីជ្រាបការប្រកបសេចក្តីថា ខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញដែលលោកពោលថា រម្ងាប់កាយសង្ខារ គឺកាយ ឬថា ខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញ ក្នុងបទនេះថា រម្ងាប់កាយសង្ខារ គឺកាយ ។ កាលព្រះយោគាវចរមានការចងចិត្តថា កាលកាយសង្ខាររម្ងាប់ទៅដោយភាវនាវិសុទ្ធិ អាត្មាអញ នឹងរម្ងាប់កាយសង្ខារយ៉ាងគ្រោតគ្រាត កាយ-សង្ខារ រមែងរម្ងាប់បានល្អក្រៃលែង ដោយការយកចិត្តទុកដាក់នោះ ។ និមិត្តដែលល្អិតសូម្បីមិនប្រាកដ ក៏ប្រព្រឹត្តទៅបានងាយ ។

[ ១១៥ ] បទថា **អដ្ឋ អនុបស្សនាញាណានិ** បានដល់ អនុ-បស្សនាញាណ ៨ គឺអនុបស្សនា ៤ ដោយអំណាចខ្យល់ដង្ហើមចូល អនុ-បស្សនា ៤ ដោយអំណាចខ្យល់ដង្ហើមចេញ ក្នុងវត្ថុ ៤ ដែលលោកពោលថា វែង ខ្លី កំណត់ដឹងនូវកាយទាំងពួង និងរម្ងាប់នូវកាយសង្ខារ ។

បទថា **អដ្ឋ ច ឧបដ្ឋានានុស្សតិយោ** បានដល់ ឧបដ្ឋានានុស្សតិ ៨ គឺឧបដ្ឋានានុស្សតិ ៤ ដោយអំណាចខ្យល់ដង្ហើមចូល ឧបដ្ឋានានុស្សតិ ៤ ដោយអំណាចខ្យល់ដង្ហើមចេញក្នុងវត្ថុ ៤ ដែលពោលដោយន័យជាដើមថា

កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្ត មានអារម្មណ៍តែមួយ មិនរាយមាយ ដោយអំណាចនៃដង្ហើមចូលវែង សតិក៏តម្កល់មាំ ។

បទថា **ចត្តារិ សុត្តន្តិកវត្ថូនិ** បានដល់ សុត្តន្តិកវត្ថុ ៤ ដោយអំណាចនៃចតុក្កៈទី ១ ព្រោះព្រះមានព្រះភាគត្រាស់ហើយ ក្នុងអានាបានស្សតិសូត្រ ៕

## អដ្ឋកថា បឋមចតុក្កនិទ្ទេស ចប់

# អដ្ឋកថា
## ទុតិយចតុក្កនិទ្ទេស

[ ១១៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបីតិបដិសំវេទិនិទ្ទេសនៃចតុក្កទី ២ ដូចតទៅ ក្នុងបទថា **ឧប្បជ្ជតិ បីតិ ចាមោជ្ជំ** បទថា **បីតិ** ជាមូលបទ ។ បទថា **ចាមោជ្ជំ** ជាបទពន្យល់សេចក្តីនៃមូលបទនោះ អធិប្បាយថា ភាពជាអ្នកត្រេកអរ ។ ក្នុងបទថា **យា បីតិ ចាមោជ្ជំ** ជាដើម លោកពោលថា បីតិរមែងបានឈ្មោះ មានជាដើមយ៉ាងនេះថា បីតិ និងបាមោជ្ជ ។

ក្នុងបទទាំងនោះ បទថា **បីតិ** ជាបទសម្តែងសភាវៈ ។ ភាពជាអ្នកត្រេកអរឈ្មោះថា **ចាមោជ្ជំ** ។ អាការត្រេកអរ ឈ្មោះថា **អាមោទនា** ។ អាការត្រេកអរខ្លាំង ឈ្មោះថា **បមោទនា** ។ ម្យ៉ាងទៀត ការធ្វើភេសជ្ជៈ ប្រេង ឬទឹកក្តៅទឹកត្រជាក់ឲ្យរួមជាចំណែកតែមួយ លោកហៅថា **មោទនា** យ៉ាងណា សូម្បីការរួមធម៌ទាំងឡាយចូលគ្នាតែមួយ ក៏ហៅថា **មោទនា** យ៉ាងនោះ លោកពោលថា **អាមោទនា បមោទនា** ព្រោះបន្ថែមបទឧបសគ្គចូលទៅ ។ ឈ្មោះថា **ហាសោ** ព្រោះអត្ថថា ស្រស់ស្រាយ ។ ឈ្មោះថា **បហាសោ** ព្រោះអត្ថថា ស្រស់ស្រាយខ្លាំង ។ បទនេះ ជាឈ្មោះនៃអាការរបស់បុគ្គលដែលត្រេកអរខ្លាំង ។ ឈ្មោះថា **វិត្តិ** ព្រោះអត្ថថា ចិត្តផ្អែត ពាក្យនេះ ជាឈ្មោះរបស់ទ្រព្យ ។ ម្យ៉ាងទៀត បីតិនេះ ឈ្មោះថា ការអរសប្បាយ ព្រោះជាបច្ច័យនៃសោមនស្ស ព្រោះដូចគ្នានឹងការសប្បាយ ចិត្តដូចសោមនស្ស រមែងកើតដល់បុគ្គលមានទ្រព្យ ព្រោះអាស្រ័យទ្រព្យយ៉ាងណា សោមនស្ស រមែង

កើតដល់បុគ្គលមានបីតិ ព្រោះអាស្រ័យបីតិក៏យ៉ាងនោះ ព្រោះហេតុនោះ ទើបលោកពោលថា **វិត្តិ**។ ពិតហើយ ពាក្យនេះ ជាឈ្មោះរបស់បីតិ ដែលតម្កល់សភាវៈនៃការត្រេកអរ ។ ម្យ៉ាងទៀត បុគ្គលអ្នកមានបីតិ លោកហៅថា **ឧទគ្គ** ព្រោះជាអ្នកមានកាយ និងចិត្តអណ្ដែតឡើង ផ្សាយឡើង ចំណែកនៃឧទគ្គៈ ឈ្មោះថា **ឱទគ្យំ** ភាពនៃចិត្តអរសប្បាយ ។

ភាពជាអ្នកមានចិត្តជារបស់ខ្លួន ឈ្មោះថា **អត្តមនតា**។ ពិតហើយ ចិត្តរបស់អ្នកមិនត្រេកអរ មិនឈ្មោះថាមានចិត្តជារបស់ខ្លួន ព្រោះមានទុក្ខជាហេតុ ចិត្តរបស់បុគ្គលដែលត្រេកអរ ឈ្មោះថា មានចិត្តជារបស់ខ្លួន ព្រោះមានសុខជាហេតុ ការមានចិត្តជារបស់ខ្លួន ឈ្មោះថា **អត្តមនតា** គឺភាពមានចិត្តជារបស់ខ្លួន អធិប្បាយថា ការមានចិត្តជាម្ចាស់ ។ ម្យ៉ាងទៀត ព្រោះការពេញចិត្តរបស់ខ្លួនមិនមែនរបស់បុគ្គលណាដទៃ ភាវៈនៃចិត្តនោះឯងជាចេតសិកធម៌ ហេតុនោះ ទើបបីតិនោះ លោកពោលថា **អត្តមនតា ចិត្តស្ស** ។ បទដ៏សេសក្នុងទីនេះ និងខាងមុខ គប្បីប្រកប ហើយជ្រាបដោយន័យដែលធ្លាប់ពោលហើយ ។

[ ១១៧ ] គប្បីជ្រាបវិនិច្ឆ័យ ក្នុងសុខបដិសំវេទិនិទ្ទេសដូចតទៅ បទថា **ទ្វេ សុខានិ** លោកពោលដើម្បីសម្ដែងដល់ភូមិរបស់សមថៈ និងវិបស្សនា ។ ព្រោះកាយិកសុខ( សុខផ្លូវកាយ ) ជាភូមិរបស់វិបស្សនា ។ ចេតសិកសុខ ( សុខផ្លូវចិត្ត ) ជាភូមិរបស់សមថៈ និងវិបស្សនា ។

បទថា **កាយិកំ** មានវិគ្គហៈថា ឈ្មោះថា **កាយិក** ព្រោះប្រកបក្នុង

កាយ ដ្បិតវៀរបសាទកាយហើយមិនកើតឡើង ។ បទថា **ចេតសិកំ** មានវិគ្គហៈថា ឈ្មោះថា **ចេតសិក** ព្រោះប្រកបក្នុងចិត្ត ដោយមិនប្រាសទៅ ។ ក្នុងពីរបទនោះ បដិសេធចេតសិកសុខដោយបទថា **កាយិក** ។ បដិសេធកាយិកទុក្ខដោយបទថា **សុខ**។ ម្យ៉ាងទៀត បដិសេធកាយិកសុខ ដោយបទថា **ចេតសិក** ។ បដិសេធចេតសិកទុក្ខដោយបទថា **សុខ** ។

បទថា **សាតំ** បានដល់ ការផ្អែម ផ្អែមដោយល្អ ។ បទថា **សុខំ** បានដល់ សេចក្តីសុខនោះឯងមិនមែនទុក្ខ ។ បទថា **កាយសម្ផស្សជំ** បានដល់កើតក្នុងកាយសម្ផស្ស ។ បទថា **សាតំ សុខំ វេទយិតំ** បានដល់ សេចក្តីឆ្ងាញ់ពិសាដែលបានសោយ មិនមែនសេចក្តីមិនឆ្ងាញ់ពិសាដែលបានសោយ សេចក្តីសុខដែលបានសោយ មិនមែនសេចក្តីទុក្ខដែលបានសោយ ។ ៣ បទតទៅ លោកពោលជាឥត្ថីលិង្គ ។ សេចក្តីក្នុងបទនេះ មានដូច្នេះថា ការសោយដែលឆ្ងាញ់ពិសា មិនមែនការសោយដែលមិនឆ្ងាញ់ពិសា វេទនាដែលជាសុខ មិនមែនវេទនាដែលជាទុក្ខ ។

គប្បីប្រកបចេតសិកសុខនិទ្ទេស ដោយន័យផ្ទុយគ្នាតាមដែលពោលហើយ ។ បទថា **តេ សុខា** ជាលិង្គវិបល្លាស ។ មានពាក្យអធិប្បាយថា **តានិ សុខានិ** ។ បទដ៏សេសក្នុងចតុក្កៈនេះ គប្បីជ្រាបដោយន័យដូចពោលហើយក្នុងបឋមចតុក្កៈនោះឯង ។ គប្បីជ្រាបសុត្តន្តិកវត្ថុ ( រឿងដែលមានក្នុងព្រះសូត្រ ) ៤ ដោយអំណាចនៃទុតិយចតុក្កៈ ៕៚

**អដ្ឋកថា ទុតិយចតុក្កនិទ្ទេស ចប់**

## អដ្ឋកថា

## តតិយចតុក្កនិទ្ទេស

[ ១២០ ] គប្បីជ្រាបវិនិច្ឆ័យ ក្នុងតតិយចតុក្កនិទ្ទេសដូចតទៅ បទថា **ចិត្តំ** ជាមូលបទ ។ បទថា **វិញ្ញាណំ** ជាបទពង្រើកសេចក្តី ។ បទថា **យំ ចិត្តំ** ជាដើម គប្បីប្រកបដោយន័យដូចពោលហើយក្នុងបីតិ ។

បណ្តាបទទាំងនោះ ក្នុងបទថា **ចិត្តំ** ជាដើម គប្បីជ្រាបវិនិច្ឆ័យដូចតទៅ ឈ្មោះថា **ចិត្ត** ព្រោះចិត្តជាធម្មជាតវិចិត្រ ។ ឈ្មោះថា **មន** ព្រោះកំណត់ដឹងអារម្មណ៍ ។ បទថា **មានសំ** បានដល់ មនៈនោះឯង ។ ធម៌ដែលសម្បយុត្ត ហៅថា **មានស** ក្នុងបទនេះថា **អន្តលិក្ខចរោ បាសោ យ្វាយំ ចរតិ មានសោ** អន្ទាក់ គឺរាគៈណាដែលត្រាច់ទៅលើអាកាស តែងតែប្រព្រឹត្តទៅក្នុងចិត្ត ដូច្នេះជាដើម ។ ព្រះអរហត្ត លោកហៅថា **មានស** ក្នុងគាថានេះថា

**កថញ្ហិ ភគវា តុយ្ហំ សាវកោ សាសនេ រតោ**
**អប្បត្តមានសោ សេក្ខោ កាលំ កយិរា ជនេ សុតា ។**

បពិត្រព្រះមានព្រះភាគ អ្នកល្បីក្នុងប្រជុំជន សាវ័ករបស់ព្រះអង្គ
ជាសេក្ខបុគ្គល មានបំណងមិនទាន់សម្រេច នៅត្រេកអរក្នុង
សាសនា គប្បីធ្វើមរណកាលដូចម្តេចបាន ដូច្នេះ ។

ក្នុងទីនេះ មនោនោះឯង ឈ្មោះថា មានសៈ ក្នុងបទនេះ លោកបន្ថែមបទចូលមកដោយអំណាចព្យញ្ជនៈ ។

ចិត្ត ឈ្មោះថា ហទយៈ ។ ដើមទ្រូង ហៅថា ហទយៈ ដូចក្នុងប្រយោគជាដើមថា **ចិត្តំ វា តេ ខិបិស្សាមិ ហទយំ វា តេ ផាលិស្សាមិ** ខ្ញុំនឹងបន្សាត់ចិត្តលោក គឺធ្វើចិត្តឲ្យខូច ឬវះហឫទ័យ ( ដើមទ្រូង ) របស់លោកដូច្នេះ ។ ចិត្ត ហៅថា ហទយៈ ដូចក្នុងប្រយោគជាដើមថា **ហទយា ហទយំ មញ្ញេ អញ្ញាយ តច្ឆតិ** សមីតិមាណពនេះ ហាក់ជាដឹងចិត្តដោយចិត្ត ហើយទើបចាំង ( នូវឈើ ) ដូច្នេះ ។ បេះដូង ហៅថា ហទយៈ ដូចក្នុងប្រយោគជាដើមថា **វក្កំ ហទយំ** ទាច បេះដូង ដូច្នេះ ។ តែក្នុងទីនេះ ចិត្តនោះឯង ហៅថា ហទយៈ ព្រោះអត្ថថា នៅខាងក្នុង ។ ចិត្តនោះ ឈ្មោះថា **បណ្ឌរំ** ព្រោះអត្ថថា បរិសុទ្ធ ។ ចិត្តនោះ ពោលសំដៅដល់ភវង្គចិត្ត ដូចព្រះមានព្រះភាគត្រាស់ថា **បភស្សរមិទំ ភិក្ខវេ ចិត្តំ តញ្ច ខោ អាគន្តុកេហិ ឧបក្កិលេសេហិ ឧបក្កិលិដ្ឋំ** ម្នាលភិក្ខុទាំងឡាយ ភវង្គចិត្តនេះ មានរស្មីផ្សាយចេញ ប៉ុន្តែ ចិត្តនោះឯងត្រូវឧបក្កិលេសទាំងឡាយ ជាអាគន្តុកចូលមកធ្វើឲ្យសៅហ្មង ដូច្នេះ ។ ម្យ៉ាងទៀត សូម្បីអកុសលចិត្តក៏ហៅថា **បណ្ឌរ** ដូចគ្នាព្រោះអកុសល ចេញអំពីចិត្តនោះ ដូចស្ទឹងគង្គាហូរចេញអំពីស្ទឹងគង្គា និងដូចស្ទឹងគោធាវរី ហូរចេញអំពីស្ទឹងគោធាវរី ដូច្នោះ ។ ម្យ៉ាងទៀត ព្រោះចិត្តមានលក្ខណៈដឹងអារម្មណ៍ ទើបមិនមានការសៅហ្មង ព្រោះឧបក្កិលេសជាចិត្តបរិសុទ្ធ ដោយសភាវៈនោះឯង តែកាលប្រកបដោយឧបក្កិលេស ទើបចិត្តឈ្មោះថា សៅហ្មង ព្រោះហេតុនោះ ទើបគួរហៅថា **បណ្ឌរ** ។ ម្យ៉ាងទៀតការប្រារព□**មនោ** សព្ទ ក្នុងបទនេះថា **មនោ មនាយតនំ** ដើម្បីសម្តែងដល់

ភាពជាអាយតនៈរបស់ចិត្តនោះឯង ។ ដោយហេតុនោះ ទើបលោកសម្តែងបទនោះថា ចិត្តនេះ ឈ្មោះថា មនាយតនៈ ព្រោះជាលំនៅនៃចិត្ត ដូចទេវាយតនៈ ( លំនៅរបស់ទេវតា ) ក៏មិនមែន ដែលពិត អាយតនៈ គឺមនោ ឈ្មោះថា មនាយតនៈ ។ អត្ថរបស់អាយតនៈ ខ្ញុំធ្លាប់ពោលហើយ ។ ឈ្មោះថា **មនោ** ព្រោះអត្ថថា ដឹង សេចក្តីថា ដឹងច្បាស់ ។ ចំណែកព្រះអដ្ឋកថាចារ្យទាំងឡាយពោលថា ឈ្មោះថា **មនោ** ព្រោះដឹងច្បាស់នូវអារម្មណ៍ ដូចវាល់ដោយនាឡិ និងដូចថ្លឹងដោយជញ្ជីងធំ ។ មនោនោះឯង ឈ្មោះថា ឥន្ទ្រិយ ព្រោះធ្វើនូវភាពជាធំក្នុងលក្ខណៈនៃការដឹង ។ ឥន្ទ្រិយ គឺមនោ ឈ្មោះថា មនិន្ទ្រិយ ។ ឈ្មោះថា វិញ្ញាណ ព្រោះអត្ថថា ដឹងច្បាស់ ។ ខន្ធ គឺវិញ្ញាណ ឈ្មោះថា វិញ្ញាណក្ខន្ធ ។ ខន្ធ លោកពោលដោយ **រុឡ្ហិ** សព្ទ ( ពាក្យពោលផ្សេង តែមានន័យផ្សេង ) វិញ្ញាណមួយដួង ជាចំណែកមួយរបស់វិញ្ញាណក្ខន្ធ ដោយអត្ថថា ជាគំនរ ។

ព្រោះហេតុនោះ បុគ្គលកាលកាត់ចំណែកមួយរបស់ដើមឈើ ក៏ហៅថា កាត់ដើមឈើយ៉ាងណា វិញ្ញាណសូម្បីមួយដួងដែលជាចំណែកមួយ របស់វិញ្ញាណក្ខន្ធ ក៏ហៅថា វិញ្ញាណក្ខន្ធ ដោយ **រុឡ្ហិ** សព្ទ យ៉ាងនោះដូចគ្នា ។ ម្យ៉ាងវិញទៀត ព្រោះអត្ថនៃគំនរ មិនមែនជាអត្ថនៃខន្ធ អត្ថនៃចំណែក ទើបជាអត្ថនៃខន្ធនោះឯង ហេតុនោះ ទើបមានអធិប្បាយថា ចំណែកនៃវិញ្ញាណ ដោយអត្ថនៃចំណែក ដូច្នេះខ្លះ ។ បទថា **តជ្ជា មនោវិញ្ញាណធាតុ** បានដល់មនោវិញ្ញាណធាតុ ដែលសមគួរដល់សម្បយុត្តធម៌ មានផស្សៈជាដើមទាំង

នោះ ។ ពិតហើយ ក្នុងបទនេះ ចិត្តមួយដួងប៉ុណ្ណោះ លោកពោលដោយ ៣ ឈ្មោះ គឺឈ្មោះថា មនោ ព្រោះអត្ថថា កំណត់អារម្មណ៍ ឈ្មោះថា វិញ្ញាណ ព្រោះអត្ថថា ដឹងច្បាស់ ឈ្មោះថា ធាតុ ព្រោះអត្ថថា ជាសភាវៈ ឬព្រោះអត្ថថា មិនមែនសត្វ ។

[ ១២១ ] បទថា **អភិប្បមោទោ** បានដល់ សេចក្តីរីករាយខ្លាំង ។

[ ១២២ ] គប្បីជ្រាបវិនិច្ឆ័យ ក្នុងសមាធិនិទ្ទេសដូចតទៅ ឈ្មោះថា **ឋិតិ** ព្រោះតាំងនៅក្នុងអារម្មណ៍ដោយការមិនញាប់ញ័រ ។ ពីរបទតទៅ លោកបន្ថែមឧបសគ្គចូល ។ម្យ៉ាងទៀត ឈ្មោះថា **សណ្ឋិតិ** ព្រោះប្រមូលសម្បយុត្តធម៌ទាំងឡាយ តម្កល់ទុកក្នុងអារម្មណ៍ ។ ឈ្មោះថា **អវដ្ឋិតិ** ព្រោះ ចូលទៅតោងអារម្មណ៍ ។ ធម៌ ៤ យ៉ាងក្នុងចំណែកកុសល គឺសទ្ធា សតិ សមាធិ បញ្ញា រមែងតោងនូវអារម្មណ៍ ។ ដោយហេតុនោះ ទើបសទ្ធា ហៅថា **ឱកប្បនា** គឺការជឿមុតមាំ ។ សតិ ហៅថា **អបិលាបនតា** គឺការមិនបណ្តោយចិត្ត ។ សមាធិ ហៅថា **អវដ្ឋិតិ** គឺការតាំងមាំ ។ **បញ្ញា** ហៅថា **បរិយោគាហណា** គឺការឈមចុះ ។

ចំណែកធម៌ ៣ យ៉ាង ក្នុងអកុសល គឺតណ្ហា ទិដ្ឋិ អវិជ្ជា រមែងតោងនូវអារម្មណ៍ ដោយហេតុនោះ ទើបធម៌ទាំងនោះ ហៅថា **ឱឃ** ។ ឈ្មោះថា **អវិសាហារោ** ព្រោះជាបដិបក្ខចំពោះការឃ្លេងឃ្លោង ដែលប្រព្រឹត្តទៅហើយដោយអំណាចនៃឧទ្ធច្ចៈ និងវិចិកិច្ឆា អធិប្បាយថា ការមិនរាយមាយ ។ ចិត្តដែលប្រព្រឹត្តទៅដោយអំណាចនៃការរាយមាយ និងការសង្ស័យ ឈ្មោះថា

រាយមាយ សមាធិនេះមិនជាយ៉ាងនោះ ព្រោះហេតុនោះ ទើបឈ្មោះថា **អវិក្ខេបោ** ។ ចិត្ត ឈ្មោះថា ឃ្លេងឃ្លោង ដោយអំណាចនៃឧទ្ធច្ចៈ និង វិចិកិច្ឆានោះឯង រមែងរាយមាយទៅខាងនោះខាងនេះ តែសមាធិនេះ មានចិត្ត មិនឃ្លេងឃ្លោង ព្រោះហេតុនោះ ទើបឈ្មោះថា **អវិសាហដមានសតា** ។

បទថា **សមថោ** បានដល់ សេចក្ដីស្ងប់ ៣ យ៉ាង គឺចិត្តស្ងប់ ១ អធិ-ករណ៍ស្ងប់ ១ សង្ខារទាំងពួងស្ងប់ ១ ។ ក្នុងសេចក្ដីស្ងប់ ៣ យ៉ាងនោះ ចិត្តមានអារម្មណ៍តែមួយ ក្នុងសមាបត្តិ ៨ ឈ្មោះថា ចិត្តស្ងប់ ព្រោះការ ញាប់ញ័រនៃចិត្ត ការអន្ទះអន្ទែងនៃចិត្តរមែងស្ងប់ រមែងចូលទៅស្ងប់ ព្រោះ អាស្រ័យចិត្តស្ងប់នោះ ហេតុនោះ ទើបសមថៈនោះ ហៅថា ចិត្តស្ងប់ ។

ការស្ងប់ ៧ យ៉ាង មានសម្មុខាវិន័យជាដើម ឈ្មោះថា អធិករណ៍ស្ងប់ ព្រោះអធិករណ៍នោះៗ ស្ងប់ ចូលទៅស្ងប់ ព្រោះអាស្រ័យអធិករណសមថៈ នោះ ហេតុនោះ ទើបសមថៈនោះ ហៅថា អធិករណ៍ស្ងប់ ។

ព្រោះសង្ខារទាំងពួងស្ងប់ ចូលទៅស្ងប់ ព្រោះអាស្រ័យនិព្វាន ហេតុ នោះ ទើបនិព្វាននោះ ហៅថា សង្ខារទាំងពួងស្ងប់ ។ ក្នុងអត្ថនេះ លោក បំណងយកចិត្តស្ងប់ ។

ឈ្មោះថា **សមាធិន្ទ្រិយំ** ព្រោះធ្វើភាពជាធំក្នុងលក្ខណៈនៃការតាំងមាំ ។ ឈ្មោះថា **សមាធិពលំ** ព្រោះមិនញាប់ញ័រដោយឧទ្ធច្ចៈ ។ បទថា **សម្មា-សមាធិ** បានដល់ សមាធិតាមសេចក្ដីពិត សមាធិធ្វើឲ្យផុតទុក្ខ កុសល-សមាធិ ។

[ ១២៣ ] *លោកពោលដល់ការញុំាងចិត្តឲ្យរួចចាកកិលេសវត្ថុ* ១០ *ដោយពាក្យថា* **រាគតោ វិមោចយំ ចិត្តំ** *ជាដើម ។ ម្យ៉ាងទៀត ក្នុងអធិការនេះ លោករួម* **មិទ្ធ**□*សព្ទដោយ* **ថីន** *សព្ទ និងរួម* **កុក្កុច្ច** *សព្ទដោយ* **ឧទ្ធច្ច** *សព្ទ ព្រោះហេតុនោះ ដោយពាក្យពោលដល់ការរួចចាកកិលេសវត្ថុ រមែងឈ្មោះថា ពោលដល់ការរួចចាកនីវរណៈជាដើម ដោយបឋមជ្ឈានជាដើម និងដល់ការរួចចាកនិច្ចសញ្ញាជាដើម ដោយអនិច្ចានុបស្សនាជាដើម ព្រោះធម៌ទាំងនេះ ទៅជាមួយគ្នាក្នុងបាឋៈដទៃៗ ។*

*ម្យ៉ាងទៀត ក្នុងបេយ្យាលនេះថា* **កថំ តំ ចិត្តំ អនុបស្សតិ** *លោកពោលដល់ការលះនិច្ចសញ្ញាជាដើម ដោយអនិច្ចានុបស្សនា ។ គប្បីជ្រាបសុត្តន្តិកវត្ថុ ៤ ដោយអំណាចនៃតតិយចតុក្កៈ ដោយប្រការដូច្នេះ ។*

## **អដ្ឋកថា តតិយចតុក្កនិទ្ទេស ចប់**

# អដ្ឋកថា

## ចតុត្ថចតុក្កនិទ្ទេស

[ ១២៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងចតុត្ថចតុក្កនិទ្ទេសដូចតទៅនេះថា លោកតាំងពាក្យសួរដោយពាក្យជានបុំសកលិង្គថា **អនិច្ចន្តិ កឹ អនិច្ចំ** មិនទៀង តើអ្វីមិនទៀង ។ ព្រោះបានប្រារព្ធថាជាវត្ថុនោះតាមគោល ( នៃភាសា ) ថាក្នុងវត្ថុដែលមិនទាន់ប្រារព្ធឲ្យពោលជានបុំសកលិង្គ ។

បទថា **ឧប្បាទវយដ្ឋេន** បានដល់ ដោយអត្ថ ពោល គឺការកើតឡើង និងការវិនាស អធិប្បាយថា ដោយសភាវៈនៃការកើតឡើង និងការវិនាស ។ ក្នុងបទនេះ បញ្ចក្ខន្ធជាសភាវៈលក្ខណៈ ការកើតឡើង និងការវិនាសនៃបញ្ចក្ខន្ធ ជាវិការលក្ខណៈ ( លក្ខណៈផ្លាស់ប្តូរ ) ដោយបទនេះ លោកពោលថា ឈ្មោះថា មិនទៀង ព្រោះមានហើយ ត្រឡប់ជាមិនមាន ដោយហេតុនោះឯង ក្នុងអដ្ឋកថា សូម្បីលោកពោលថា ការមិនទៀងដោយអំណាចនៃសង្ខតលក្ខណៈ និងពោលថា ភាពដែលបញ្ចក្ខន្ធទាំងនោះមានការកើតឡើងវិនាសទៅ និងក្លាយទៅជាបការដទៃ ក៏នៅពោលថា មានហើយ ត្រឡប់ជាមិនមាន ។ ដោយបទនេះ ឈ្មោះថា លោកពោលថា អាការ គឺមានហើយត្រឡប់ជាមិនមាន ជាអនិច្ចលក្ខណៈ ។ លោកពោលធ្វើបេយ្យាលថា បុគ្គលកាលឃើញនូវការកើតឡើង និងការសូន្យនៃខន្ធ ៥ រមែងឃើញនូវលក្ខណៈ ៥០ នេះឯង ។ បទថា **ធម្មា** បានដល់ ធម៌តាមដែលលោកពោលហើយមានរូបក្ខន្ធជាដើម ។

[ ១២៥-១២៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវិភគានុបស្សីនិទ្ទេស ដូចតទៅ

នេះថា បទថា **រូបេ អាទីនវំ ទិស្វា** បានដល់ ឃើញទោសក្នុងរូបក្ខន្ធដោយសភាពមិនទៀងជាដើម ដូចដែលលោកពោលហើយ ខាងមុខចាប់តាំងអំពីកង្ខានុបស្សនាញាណ ។ បទថា **រូបវិរាគេ** បានដល់ ក្នុងនិព្វាន ព្រោះថារូបដល់និព្វានហើយរមែងប្រាសទៅ រមែងរលត់ដោយការដល់នូវការមិនកើតទៀតជាធម្មតា ព្រោះហេតុនោះ ទើបលោកពោលនិព្វានថា **រូបវិរាគោ** ។ បទថា **ឆន្ទជាតោ ហោតិ** បានដល់ មានឆន្ទៈក្នុងធម៌ដែលកើតឡើង ដោយអំណាចនៃការស្តាប់ ។ បទថា **សទ្ធាធិមុត្តោ** បានដល់ បង្អោនទៅ សម្រេចចិត្តទៅក្នុងនិព្វាននោះដោយសទ□ ។ បទថា **ចិត្តញ្ចស្ស ស្វាធិដ្ឋិតំ** គប្បីជ្រាបដោយភ្ជាប់សេចក្តីថា ចិត្តរបស់ព្រះយោគាវចរនោះតាំងមាំដោយល្អ ប្រតិស្ឋានដោយល្អ ដោយអំណាចនៃអារម្មណ៍ ក្នុងការបែកធ្លាយនៃរូប ពោល គឺការប្រាសចាកតម្រេក ដោយការអស់ទៅ ដោយអំណាចនៃការបានឮ បានស្តាប់និព្វានដែលប្រាសចាកតម្រេកក្នុងរូប ពោលគឺការប្រាសចាកតម្រេកទាំងអស់ ។

បទថា **រូបេ វិរាគានុបស្សី** លោកពោលការប្រាសចាកតម្រេកដោយការអស់ទៅនៃរូបដោយសត្តមីវិភត្តិតាមប្រក្រតីថា ក្នុងការណាយចាករូប ។ លោកពោលការប្រាសចាកតម្រេកទាំងអស់នៃរូប ដោយនិមិត្តសត្តមីវិភត្តិថា ក្នុងការណាយចាករូប ។ ភិក្ខុដែលមានប្រក្រតីពិចារណាឃើញការប្រាសចាកតម្រេកទាំងពីរយ៉ាងនោះដោយអារម្មណ៍ និងដោយអជ្ឈាស្រ័យ ហៅថា អាត្មាអញជាអ្នកពិចារណាឃើញនូវការណាយក្នុងរូប ។ ក្នុងវេទនាជាដើម ក៏មានន័យនេះ ។ សូម្បីក្នុងនិទ្ទេសនៃបទថា អាត្មាអញ ជាអ្នកពិចារណាឃើញនូវ

ការរលត់ក៏មានន័យនេះដូចគ្នា ។

[ ១២៧ ] ក្នុងទីនេះ បទថា **កតិហាការេហិ** ជាដើម មានសេចក្ដីពិសេសដូចតទៅនេះថា លោកសម្ដែងដល់ការរលត់ទោសនៃរូបជាដើមដោយការឃើញទោស ការរលត់ទោសនៃអង្គរបស់បដិច្ចសមុប្បាទ មានអវិជ្ជាជាដើម ព្រោះរូបជាដើមទាំងនោះ ក៏មិនកន្លងអង្គបដិច្ចសមុប្បាទទៅបាន ដោយពាក្យពិសេសនេះឯង ឈ្មោះថា លោកពោលដល់ភាពវិសេសនៃនិរោធានុបស្សនា ដោយពិចារណាឃើញការប្រាសចាកតម្រេក ។

ក្នុងបទទាំងនោះ បទថា **អនិច្ចដ្ឋេន** បានដល់ ដោយអត្ថថា អស់ទៅ ឬដោយអត្ថថា មានហើយ ត្រឡប់ជាមិនមាន ។ បទថា **ទុក្ខដ្ឋេន** បានដល់ ដោយអត្ថថា ជាភ័យ ឬដោយអត្ថថា បៀតបៀន ។ បទថា **អនត្តដ្ឋេន** បានដល់ ដោយអត្ថថា រកសារៈមិនបាន ឬដោយអត្ថថា មិនប្រព្រឹត្តទៅក្នុងអំណាច ។ បទថា **សន្តាបដ្ឋេន** បានដល់ ដោយអត្ថថា កិលេសជាហេតុឲ្យក្ដៅ ។ បទថា **វិបរិណាមដ្ឋេន** បានដល់ ដោយអត្ថថា ប្រែប្រួលដោយ ២ ចំណែក ដោយអំណាចនៃជរា និងភង្គៈ ។ បទថា **និទាននិរោធេន** បានដល់ ដោយមិនមានបច្ច័យដែលជាមូល ។ បទថា **និរុជ្ឈតិ** បានដល់ មិនមាន ។ បទថា **សមុទយនិរោធេន** បានដល់ ដោយការមិនមានបច្ច័យដែលជិត ។ ពិតហើយ បច្ច័យដែលជាមូល លោកពោលថា ដើមហេតុ ដូចភោជនដែលមិនជាទីសប្បាយ ជាដើមហេតុនៃអ្នកជំងឺ បច្ច័យដែលជិត លោកពោលថា សមុទយៈដូចខ្យល់ ទឹកប្រមាត់ និងស្លេស្ម ជាសមុទយៈនៃអ្នកជំងឺ ។ ពិតហើយ

ដើមហេតុ ឈ្មោះថា ដើមហេតុ ព្រោះជាហេតុឲ្យផលដោយការកាត់សម្រេច សមុទយៈ ឈ្មោះថា សមុទយៈ ព្រោះជាដែនកើតនៃផលដោយល្អ ។ បទថា **ជាតិនិរោធេន** បានដល់ ដោយមិនមានការកើតនៃបច្ច័យដែលជាមូល ។ បទថា **បភវនិរោធេន** បានដល់ ដោយមិនមានការកើតនៃអាសន្នប្បច្ច័យ ( បច្ច័យដែលជិត ) គួរពោលថា ជាតិនោះឯង ឈ្មោះថា ជាដែនកើត ព្រោះជាដែនឲ្យកើតនៃទុក្ខ ។ បទថា **ហេតុនិរោធេន** បានដល់ ដោយមិនមានជនកប្បច្ច័យ ( បច្ច័យដែលកើត ) ។ បទថា **បច្ចយនិរោធេន** បានដល់ ដោយមិនមានឧបត្ថម្ភកប្បច្ច័យ សូម្បីបច្ច័យដែលជាមូល ក៏ជាអាសន្នប្បច្ច័យ ជនកប្បច្ច័យ និងឧបត្ថម្ភកប្បច្ច័យនោះឯង ។ ដោយបច្ច័យទាំងនោះ លោកពោលដល់ការរលត់ដោយតទង្គប្បហាន ក្នុងខណៈវិបស្សនាទាំងក្លា ពោលដល់ការរលត់ដោយសមុច្ឆេទប្បហានក្នុងខណៈនៃមគ្គ ។ បទថា **ញាណុប្បាទេន** បានដល់ ដោយការកើតឡើងនៃវិបស្សនាញាណខ្លាំងក្លា ឬនៃមគ្គញ្ញាណ ។ បទថា **និរោធុបដ្ឋានេន** បានដល់ ដោយការប្រាកដនៃនិព្វាន ពោលគឺនិរោធ ដោយអំណាចនៃការបានស្តាប់ ដល់ការរលត់ដោយការអស់ទៅដោយប្រចក្សក្នុងខណៈនៃវិបស្សនា និងដោយការប្រាកដនៃនិព្វានដោយប្រចក្សក្នុងខណៈនៃមគ្គ ។ ដោយបទទាំងនេះ ឈ្មោះថា លោកធ្វើការកំណត់អារម្មណ៍ និងវត្ថុដែលមានអារម្មណ៍ និងឈ្មោះថា ពោលដល់ការរលត់មួយគ្រា និងរលត់ជាសមុច្ឆេទ ។

[ ១២៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃបទថា **បដិនិស្សគ្គានុបស្សី**

ដូចតទៅនេះ បទថា **រូបំ បរិច្ចជតិ** បានដល់ លះបង់រូបក្ខន្ធ ព្រោះមិនសម្ងំនដល់ដោយការឃើញទោស ។ បទថា **បរិច្ចាគបដិនិស្សគ្គោ** មានពាក្យអធិប្បាយថា ឈ្មោះថា **បដិនិស្សគ្គោ** ព្រោះអត្ថថា លះបង់ ។ ដោយបទនេះ ឈ្មោះថា លោកពោលដល់អត្ថនៃការបរិច្ចាគរបស់បទថា **បដិនិស្សគ្គ** ព្រោះហេតុនោះ ទើបមានអធិប្បាយថា ការលះកិលេសទាំងឡាយ ។ម្យ៉ាងទៀត ក្នុងបទនេះ វិបស្សនាដែលជាវុដ្ឋានគាមិនី ( ញាណជាគ្រឿងនាំចេញទៅ ) រមែងលះកិលេសទាំងឡាយបានមួងម្កាល មគ្គរមែងលះបានដោយសមុច្ឆេទ ។ បទថា **រូបនិរោធេ និព្វានេ ចិត្តំ បក្ខន្ទតិ** បានដល់ វិបស្សនាដែលជាវុដ្ឋានគាមិនីរមែងស្ទុះទៅ ព្រោះបង្អោនទៅក្នុងនិព្វាននោះ មគ្គរមែងស្ទុះទៅដោយការធ្វើឲ្យជាអារម្មណ៍ ។

បទថា **បក្ខន្ទនបដិនិស្សគ្គោ** មានពាក្យអធិប្បាយថា ការលះបង់ដោយអត្ថថា ស្ទុះទៅ ដោយបទនេះ ឈ្មោះថា លោកពោលដល់អត្ថនៃការស្ទុះទៅនៃបទថា **បដិនិស្សគ្គ** ព្រោះហេតុនោះ ទើបមានអធិប្បាយថា ការលះបង់ចិត្ត ក្នុងនិព្វាន ។ គប្បីជ្រាបសុត្តន្តិកវត្ថុ ៤ ដោយអំណាចនៃចតុក្កចតុក្កៈ ។ ក្នុងចតុក្កៈនេះ គប្បីជ្រាបបទដែលគួរពោលដល់ក្នុងជរា និងមរណៈដោយន័យដូចពោលហើយនោះឯង ។

ម្យ៉ាងវិញទៀត ក្នុងសតិប្បដ្ឋានទាំងឡាយ គប្បីជ្រាបថា លោកធ្វើនិទ្ទេសជាឯកវចនៈ ដោយពោលដល់កាយ និងចិត្តតែម្យ៉ាងថា **កាយេ កាយានុបស្សនា** គឺពិចារណាឃើញកាយក្នុងកាយ **ចិត្តេ ចិត្តានុបស្សនា** គឺពិចារណា

*ឃើញចិត្តក្នុងចិត្ត ធ្វើនិទ្ទេសជាពហុវចនៈដោយពោលផ្សេងៗ គ្នា ដល់វេទនានិងធម៌ថា* **វេទនាសុ វេទនានុបស្សនា** *គឺពិចារណាឃើញវេទនាក្នុងវេទនាទាំងឡាយ* **ធម្មេសុ ធម្មានុបស្សនា** *គឺពិចារណាឃើញធម៌ក្នុងធម៌ទាំងឡាយដោយប្រការដូច្នេះ ។ល។*

**ចតុត្ថចតុក្កនិទ្ទេស ចប់**

**អដ្ឋកថា សតោការិញ្ញាណនិទ្ទេស ចប់**

# អដ្ឋកថា
# ញាណកាសិចក្កនិទ្ទេស

[ ១៣០ ] ឥឡូវនេះ ក្នុងញាណដែលលោកសម្ដែងដោយគំនរ ៦ គប្បីជ្រាបនិទ្ទេសពោលដោយសមាធិញ្ញាណ ២៤ មុន សមាធិមាន ២៤ ក្នុងវត្ថុ ១២ គឺសមាធិនីមួយៗ ២ គឺសមាធិ ១ ដោយអំណាចខ្យល់ដង្ហើមចូល សមាធិ ១ ដោយអំណាចខ្យល់ដង្ហើមចេញ ក្នុងវត្ថុនីមួយៗ នៃវត្ថុ ១២ ដោយអំណាចចតុក្កៈ ៣ មានកាយានុបស្សនាជាដើម ។ ញាណដែលសម្បយុត្តដោយសមាធិទាំងនោះ ក្នុងខណៈនៃឈាន ឈ្មោះថា ញាណ ដោយអំណាចនៃសមាធិ ២៤ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងវិបស្សនាញាណនិទ្ទេស ៧២ ដូចតទៅ បទថា **ទីឃំ អស្សាសា** បានដល់ ព្រោះខ្យល់ដង្ហើមចូលដែលលោកពោលហើយថាវែង ។ លោកពោលដូចម្ដេច លោកពោលថា វិបស្សនា ព្រោះអត្ថថាពិចារណាឃើញដោយភាពជារបស់មិនទៀង ក្នុងខណៈវិបស្សនា ដោយចិត្តដែលបានឈាន ហើយតាំងមាំដោយល្អ ព្រោះខ្យល់ដង្ហើមចូលវែង ។ ក្នុងសេចក្ដីដែលក្រែលែងឡើងទៅ ក៏មានន័យនេះ ។

អនុបស្សនាមាន ៧២ ក្នុងវត្ថុ ១២ គឺអនុបស្សនានីមួយៗ ៦ បានដល់អនុបស្សនា ៣ ដោយអំណាចនៃខ្យល់ដង្ហើមចូល អនុបស្សនា ៣ ដោយអំណាចនៃខ្យល់ដង្ហើមចេញ ក្នុងវត្ថុនីមួយៗ នៃវត្ថុទាំង ១២ នោះ អនុបស្សនា ៧២ ទាំងនោះឯង ជាញាណដោយអំណាចនៃវិបស្សនា ៧២ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនិព្វិទាញាណនិទ្ទេសដូចតទៅ បទថា **អនិច្ចានុបស្សី អស្សសំ** បានដល់ ជាអ្នកពិចារណាឃើញថាមិនទៀង ដកដង្ហើមចូល អធិប្បាយថា ជាអ្នកពិចារណាឃើញថាមិនទៀង ញុំាងខ្យល់ដង្ហើមចូល ឲ្យប្រព្រឹត្តទៅ ។ ម្យ៉ាងទៀត បទថា **អស្សសំ** នេះ គប្បីឃើញថា ចុះក្នុងអត្ថនៃហេតុ ។ បទថា **យថាភូតំ បជានាតិ បស្សតីតិ និព្វិទាញាណំ** សេចក្តីថា រមែងដឹងតាមសេចក្តីពិតនៃសង្ខារទាំងឡាយដោយវិបស្សនាញាណដែលប្រព្រឹត្តទៅ តាំងអំពីពិចារណាជាកលាបៈរហូតដល់ពិចារណាឃើញការរលត់ រមែងឃើញដោយញាណចក្ខុនោះឯង ដូចឃើញដោយភ្នែក ព្រោះហេតុនោះ ទើបឈ្មោះថា និព្វិទាញាណ ។ មានពាក្យអធិប្បាយថា ឈ្មោះថា និព្វិទាញាណក្នុងសង្ខារទាំងឡាយ ។គប្បីជ្រាបថា វិបស្សនាញាណតាមដែលបានពោលហើយក្នុងនិទ្ទេសនេះ ជានិព្វិទាញាណ ព្រោះញាណទាំងឡាយ មានភយតូបដ្ឋានញ្ញាណ ( បញ្ញាឃើញសង្ខារប្រាកដជារបស់គួរខ្លាច ) ជាដើម និងមុញ្ចិតុកម្យតាញាណ ( បញ្ញាដែលប្រាថ្នានឹងរួចផុត ) ជាដើម លោកពោលចែកហើយខាងមុខ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងនិទ្ទេសនៃនិព្វិទានុលោមញ្ញាណដូចតទៅ បទថា **អនិច្ចានុបស្សី អស្សសំ** បានដល់ របស់បុគ្គលដែលពិចារណាឃើញដោយភាពជារបស់មិនទៀង ដកដង្ហើមចូល បទនេះ ជាបឋមាវិភត្តិ ចុះក្នុងអត្ថនៃឆដ្ឋីវិភត្តិ ។

ដោយបទថា **ភយតុបដ្ឋានេ បញ្ញា** ឈ្មោះថា លោកពោលដល់

កយតុបដ្ឋានញាណ អាទីនវានុបស្សនាញាណ និងនិព្វិទានុបស្សនាញាណ ព្រោះញាណទាំង ៣ មានលក្ខណៈដូចគ្នា ។ ញាណទាំង ៣ នេះ លោកពោលថា និព្វិទានុលោមញ្ញាណ ព្រោះអនុលោមដោយការអនុគ្រោះដល់និព្វិទាញាណ ដែលលោកពោលហើយដោយលំដាប់ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងនិទ្ទេសនៃនិព្វិទាបដិបស្សទ្ធិញ្ញាណដូចតទៅ បទថា **អនិច្ចានុបស្សី អស្សសំ** ដូចគ្នានឹងការពោលមកហើយនោះឯង ។ បទថា **បដិសង្ខា សន្តិដ្ឋនា បញ្ញា** នេះ លោកពោលដល់មុញ្ចិតុកម្យតាញាណ បដិសង្ខានុបស្សនាញាណ សង្ខារុបេក្ខាញាណ ព្រោះញាណទាំង ៣ មានលក្ខណៈដូចគ្នា ។ សូម្បីអនុលោមញ្ញាណ និងមគ្គញ្ញាណ លោកក៏សង្គ្រោះដោយបទថា **បដិសង្ខា សន្តិដ្ឋនា** នោះឯង ។ សូម្បីសង្ខារុបេក្ខាញាណ និងអនុលោមញ្ញាណ ក៏ឈ្មោះថា និព្វិទាបដិបស្សទ្ធិញ្ញាណ ដោយលះការខ្វល់ខ្វាយ ក្នុងការឲ្យកើតនិព្វិទា ព្រោះនិព្វិទាដល់ទីបំផុតហើយ ។

ចំណែកមគ្គញ្ញាណ ឈ្មោះថា និព្វិទាបដិបស្សទ្ធិញ្ញាណ ព្រោះកើតក្នុងទីបំផុតនៃនិព្វិទាបដិបស្សទ្ធិញ្ញាណ ព្រោះហេតុនោះ ទើបត្រឹមត្រូវយ៉ាងក្រៃលែង ។ ការមិនកាន់យកមុញ្ចិតុកម្យតាញាណដែលជាខាងដើម ដូចក្នុងនិព្វិទានុលោមញ្ញាណទាំងឡាយ ហើយកាន់យកញាណពីរក្នុងទីបំផុតថា **បដិសង្ខា សន្តិដ្ឋនា** ក៏ដើម្បីសង្គ្រោះចូលក្នុងមគ្គញ្ញាណ ព្រោះថា កាលលោកពោលថា មុញ្ចិតុកម្យតាញាណ រមែងសង្គ្រោះយកអនុលោមញ្ញាណ មិនបានសង្គ្រោះយកមគ្គញ្ញាណ ។ ព្រោះមគ្គញ្ញាណមិនឈ្មោះថា មុញ្ចិតុកម្យតាញាណ តែឈ្មោះ

ថា **សន្តិដ្ឋនា** ព្រោះព្រងើយក្នុងការសម្រេចកិច្ច ។

ម្យ៉ាងទៀត សូម្បីក្នុងអដ្ឋកថាលោកក៏ពោលថា បទថា **ផុសនា** គឺ **អប្បនា**។ មគ្គញាណនេះ ឈ្មោះថា **សន្តិដ្ឋនា** ព្រោះចុះស៊ប់ក្នុងនិព្វាន ព្រោះហេតុនោះ សូម្បីមគ្គញាណក៏សង្គ្រោះដោយបទថា **សន្តិដ្ឋនា**។ សូម្បីនិព្វិទា-នុលោមញាណ ដោយអត្ថ ក៏ជានិព្វិទាញាណនោះឯង ព្រោះហេតុនោះ ទើបលោកសង្គ្រោះនិព្វិទានុលោមញាណទាំងនោះ ដោយនិព្វិទាញាណ ហើយប្រើសព្ទ **និព្វិទា** ក្នុងបទថា **និព្វិទាបដិបស្សទ្ធិញ្ញាណ** ។ មិនមែនសព្ទថា **និព្វិ-ទានុលោម**។ ក្នុងនិទ្ទេសពោលដោយញាណ ៨ ទាំង ៣ នេះ ញាណ ៨ យ៉ាងក្នុងវត្ថុ ៤ គឺញាណនីមួយៗ ២ បានដល់ ញាណមួយដោយអំណាចនៃខ្យល់ដង្ហើមចូល ញាណមួយដោយអំណាចនៃខ្យល់ដង្ហើមចេញ ក្នុងវត្ថុនីមួយៗនៃវត្ថុ ៤ ដែលលោកពោលហើយ ដោយអំណាចនៃធម្មានុបស្សនាចតុក្កៈទី ៤ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងវិមុត្តិសុខញាណនិទ្ទេសដូចតទៅ ព្រះសារីបុត្តត្ថេរកាលសម្ដែងការលះដោយបទថា **បហីនត្តា** កាលនឹងសម្ដែងភាពដែលការលះនោះ ជាសមុច្ឆេទប្បហាន ទើបពោលថា **សមុច្ឆិន្នត្តា** ដូច្នេះ ។

បទថា **វិមុត្តិសុខេ ញាណំ** បានដល់ ញាណដែលសម្បយុត្តដោយវិមុត្តិសុខដែលជាផល និងបច្ចវេក្ខណញាណ ដែលមានវិមុត្តិសុខដែលជាផលជាអារម្មណ៍ ។ ដើម្បីសម្ដែងថា មានការលះវត្ថុទុច្ចរិត ដែលរួបរឹតដោយការលះកិលេសដែលជាវត្ថុដេកត្រាំក្នុងសន្ដាន ទើបលោកពោលដល់ការលះ

កិលេសដែលជាអនុស័យទៀត ។ លោកធ្វើការរាប់ញាណដោយការរាប់កិលេសដែលលះបានហើយ សំដៅដល់ ផលញ្ញាណ ២១ និងធ្វើការរាប់បច្ចវេក្ខណញ្ញាណដែលជាផល ដោយការរាប់ការពិចារណាដល់កិលេសដែលលះបានហើយ សំដៅដល់ បច្ចវេក្ខណញ្ញាណ ។ល។

**អដ្ឋកថា ញាណរាសិឆក្កនិទ្ទេស ចប់**

**អដ្ឋកថា អានាបានស្សតិកថា ចប់**

# ក្បាលទី ៥៧

# សុត្តន្តបិដក បាលីប្រែ ~ ៦៩

## សន្ទឹកចង្អុលប្រាប់មាតិកា

មាតិកា                                                    លេខទំព័រ

### មហាវគ្គ

មាតិកា                                                    ទំព័រ


| | |
|---|---|
| សុត្តន្តបិដក .......... .......... .......... .......... | ២ |
| អដ្ឋកថា មគ្គញ្ញាណនិទ្ទេស .......... .......... .......... .......... .. | ៦ |
| សុត្តន្តបិដក .......... .......... .......... .......... .. | ១៦ |
| អដ្ឋកថា ផលញ្ញាណនិទ្ទេស .......... .......... .......... .......... .... | ១៩ |
| សុត្តន្តបិដក .......... .......... .......... .......... .... | ២០ |
| អដ្ឋកថា វិមុត្តិញ្ញាណនិទ្ទេស .......... .......... .......... .......... .. | ២២ |
| សុត្តន្តបិដក .......... .......... .......... .......... . | ២៤ |
| អដ្ឋកថា បច្ចវេក្ខណញ្ញាណនិទ្ទេស .......... .......... .......... .......... . | ២៩ |
| សុត្តន្តបិដក .......... .......... .......... .......... | ៣៤ |
| អដ្ឋកថា វត្ថុនានត្តញ្ញាណនិទ្ទេស .......... .......... .......... .......... . | ៣៨ |
| សុត្តន្តបិដក .......... .......... .......... .......... | ៤០ |
| អដ្ឋកថា គោចរនានត្តញ្ញាណនិទ្ទេស .......... .......... .......... .......... | ៤៤ |
| សុត្តន្តបិដក .......... .......... .......... .......... . | ៤៦ |
| អដ្ឋកថា ចរិយានានត្តញ្ញាណនិទ្ទេស .......... .......... .......... .......... . | ៥៨ |
| សុត្តន្តបិដក .......... .......... .......... .......... . | ៦៧ |
| អដ្ឋកថា ភូមិនានត្តញ្ញាណនិទ្ទេស .......... .......... .......... .......... | ៦៩ |

អត្ថរបស់ ចក្ក សព្ទ .......... .......... .......... .......... ៧៦

សុត្តន្តបិដក .......... .......... .......... .......... ៨០

អដ្ឋកថា ធម្មនានត្តញ្ញាណនិទ្ទេស .......... .......... .......... .......... ៨៥

សុត្តន្តបិដក .......... .......... .......... .......... ៩២

អដ្ឋកថា ញាណបញ្ចកនិទ្ទេស .......... .......... .......... .......... ៩៣

សុត្តន្តបិដក .......... .......... .......... .......... ៩៥

អដ្ឋកថា បដិសម្ភិទាញ្ញាណនិទ្ទេស .......... .......... .......... ........... ១០២

សុត្តន្តបិដក .......... .......... .......... ......... ១០៥

អដ្ឋកថា ញាណត្តយនិទ្ទេស .......... .......... .......... ............ ១១២

សុត្តន្តបិដក .......... .......... .......... .......... ១១៥

អដ្ឋកថា អានន្តរិកសមាធិញ្ញាណនិទ្ទេស .......... .......... .......... ........... ១២០

សុត្តន្តបិដក .......... .......... .......... ........... ១២៦

អដ្ឋកថា អរណាវិហារញ្ញាណនិទ្ទេស .......... .......... .......... .......... ១២៨

សុត្តន្តបិដក .......... .......... .......... ......... ១៣១

អដ្ឋកថា និរោធសមាបត្តិញ្ញាណនិទ្ទេស .......... .......... .......... .......... ១៣៧

សុត្តន្តបិដក .......... .......... .......... ......... ១៥៣

អដ្ឋកថា បរិនិព្វានញ្ញាណនិទ្ទេស .......... .......... .......... ......... ១៥៤

សុត្តន្តបិដក .......... .......... .......... ........ ១៥៦

អដ្ឋកថា សមសីសដ្ឋញ្ញាណនិទ្ទេស .......... .......... .......... ........ ១៥៩

សុត្តន្តបិដក .......... .......... .......... ........ ១៦៣

អដ្ឋកថា សល្លេខដ្ឋញ្ញាណនិទ្ទេស .......... .......... .......... ....... ១៦៥

សុត្តន្តបិដក .......... .......... .......... ...... ១៧០

អដ្ឋកថា វិរិយារម្ភញ្ញាណនិទ្ទេស .......... .......... .......... ...... ១៧២

សុត្តន្តបិដក .......... .......... ....... ១៧៤

អដ្ឋកថា អត្ថសន្ទស្សនញ្ញាណនិទ្ទេស .......... .......... ........ ១៧៥

សុត្តន្តបិដក .......... .......... ....... ១៧៦

អដ្ឋកថា ទស្សនវិសុទ្ធិញ្ញាណនិទ្ទេស .......... .......... ....... ១៧៨

សុត្តន្តបិដក .......... .......... ...... ១៨២

អដ្ឋកថា ខន្តិញ្ញាណបរិយោគាហណញ្ញាណនិទ្ទេស .......... .......... ...... ១៨៤

សុត្តន្តបិដក .......... .......... ...... ១៨៥

អដ្ឋកថា បទេសវិហារញ្ញាណនិទ្ទេស .......... .......... ...... ១៨៧

សុត្តន្តបិដក .......... .......... ...... ១៩៤

អដ្ឋកថា វិវដ្ដញ្ញាណឆក្កនិទ្ទេស .......... .......... ...... ២០១

សុត្តន្តបិដក .......... .......... ...... ២០៨

អដ្ឋកថា ឥទ្ធិវិធញ្ញាណនិទ្ទេស .......... .......... ..... ២១០

សុត្តន្តបិដក .......... .......... .... ២២៦

អដ្ឋកថា សោតធាតុវិសុទ្ធិញ្ញាណនិទ្ទេស .......... .......... .... ២២៨

សុត្តន្តបិដក .......... .......... ...... ២៣២

អដ្ឋកថា ចេតោបរិយញ្ញាណនិទ្ទេស .......... .......... ...... ២៣៤

សុត្តន្តបិដក .......... .......... ... ២៣៨

អដ្ឋកថា បុព្វេនិវាសានុស្សតិញ្ញាណនិទ្ទេស .......... .......... ... ២៤០

សុត្តន្តបិដក .......... .......... .... ២៧៧

អដ្ឋកថា ទិព្វចក្ខុញ្ញាណនិទ្ទេស .......... .......... .... ២៧៩

បញ្ចញាណបកិណ្ណកៈ .......... .......... ..... ២៩០

សុត្តន្តបិដក .......... .......... .. ២៩១

អដ្ឋកថា អាសវក្ខយញ្ញាណនិទ្ទេស .......... .......... .... ២៩៦

សុត្តន្តបិដក .......... .......... .......... .... ៣០១

អដ្ឋកថា សច្ចញ្ញាណចតុក្កទ្វយនិទ្ទេស .......... .......... .......... .... ៣០៣

សុត្តន្តបិដក .......... .......... .......... ....... ៣០៩

អដ្ឋកថា សុទ្ធិកបដិសម្ភិទាញាណនិទ្ទេស .......... .......... .......... ..... ៣១២

សុត្តន្តបិដក .......... .......... .......... ..... ៣១៤

អដ្ឋកថា ឥន្ទ្រិយបរោបរិយត្តញ្ញាណនិទ្ទេស .......... .......... .......... ..... ៣១៩

សុត្តន្តបិដក .......... .......... .......... ..... ៣២៧

អដ្ឋកថា អាសយានុសយញ្ញាណនិទ្ទេស .......... .......... .......... . ៣៣១

សុត្តន្តបិដក .......... .......... .......... .... ៣៤៨

អដ្ឋកថា យមកប្បាដិហីរញ្ញាណនិទ្ទេស .......... .......... .......... .. ៣៥០

សុត្តន្តបិដក .......... .......... .......... ... ៣៥៦

អដ្ឋកថា មហាករុណាញាណនិទ្ទេស .......... .......... .......... .... ៣៦៣

សុត្តន្តបិដក .......... .......... ............ ៤០៩

អដ្ឋកថា សព្វញ្ញុតញ្ញាណនិទ្ទេស .......... .......... ............ ៤១៦

# បាលីប្រែ ~៧០

## មហាវគ្គ

សុត្តន្តបិដក ទិដ្ឋិកថា .......... .......... .......... ...... ៤២៩

## អដ្ឋកថា ទិដ្ឋិកថា

អដ្ឋកថា អស្សាទទិដ្ឋិនិទ្ទេស .......... .......... .......... ......... ៤៨៤

អដ្ឋកថា អត្តានុទិដ្ឋិនិទ្ទេស .......... .......... .......... .......... ៥០៤

អដ្ឋកថា មិច្ឆាទិដ្ឋិនិទ្ទេស .......... .......... .......... .......... ៥១៧

អដ្ឋកថា សក្កាយទិដ្ឋិនិទ្ទេស .......... .......... .......... .......... ៥១៩
អដ្ឋកថា សស្សតទិដ្ឋិនិទ្ទេស .......... .......... .......... .......... ៥២០
អដ្ឋកថា ឧច្ឆេទទិដ្ឋិនិទ្ទេស .......... .......... .......... ......... ៥២១
អដ្ឋកថា អន្តគ្គាហិកទិដ្ឋិនិទ្ទេស .......... .......... .......... .......... ៥២២
អដ្ឋកថា បុព្វន្តានុទិដ្ឋិនិទ្ទេស .......... .......... .......... ......... ៥២៦
អដ្ឋកថា អបរន្តានុទិដ្ឋិនិទ្ទេស .......... .......... .......... ......... ៥២៨
អដ្ឋកថា សញ្ញោជនិកាទិទិដ្ឋិនិទ្ទេស .......... .......... .......... ......... ៥៣០
អដ្ឋកថា មានវិនិពន្ធទិដ្ឋិនិទ្ទេស .......... .......... .......... ........ ៥៣១
អដ្ឋកថា អត្តវាទប្បដិសំយុត្តទិដ្ឋិនិទ្ទេស .......... .......... .......... ........ ៥៣២
អដ្ឋកថា លោកវាទប្បដិសំយុត្តទិដ្ឋិនិទ្ទេស .......... .......... .......... ........ ៥៣៣
អដ្ឋកថា ភវវិភវទិដ្ឋិនិទ្ទេស .......... .......... .......... .... ៥៣៥
សុត្តន្តបិដក មហាវគ្គ អានាបានកថា .......... .......... .......... ....... ៥៥២

## អដ្ឋកថា អានាបានស្សតិកថា

អដ្ឋកថា គណនវារ .......... .......... .......... ......... ៦២៨
អដ្ឋកថា សោឡសញាណនិទ្ទេស .......... .......... .......... ......... ៦៣៣
អដ្ឋកថា ឧបក្កិលេសញាណនិទ្ទេស .......... .......... .......... ......... ៦៣៦
អដ្ឋកថា វោទានញាណនិទ្ទេស .......... .......... .......... ......... ៦៤៣
អដ្ឋកថា សតោការិញាណនិទ្ទេស .......... .......... .......... ......... ៦៧៣
អដ្ឋកថា ញាណរាសិឆក្កនិទ្ទេស ............ .......... .......... ...... ៧៤៩